# សត្រូវបងប្អូនឯង

## ណាយ៉ាន់ ចាន់ដា

ប្រែសម្រួលដោយ ខេព ម៉េងឃាន
*មជ្ឈមណ្ឌលឯកសារកម្ពុជា*

ឯកសារបកប្រែទី៥ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**◆ ណាយ៉ាន់ ចាន់ដា : សត្រូវបងប្អូនឯង**

◆ ប្រែសម្រួលជាភាសាខ្មែរដោយ ទេព ម៉េងឃាន ◆ ពិនិត្យនិងកែសម្រួលដោយ ឆាំង យុ ◆ ក្រាហ្វិកនិងកុំព្យូទ័រការីដោយ គីម សុវណ្ណដានី ◆ រចនាក្រប និង តួសៀវភៅដោយ ឆាំង យុ និង គីម សុវណ្ណដានី ◆ បោះពុម្ពផ្សាយលើកទី១ នៅឆ្នាំ២០០៦ ◆ រក្សាសិទ្ធិ ◆

Translation Series No.5 ◆ Documentation Center of Cambodia

◆ Nayan Chanda: Brother Enemy, Cambodia and the Khmer Rouge Revolution
◆ Translated by Tep Meng Khean ◆ Edited by Youk Chhang ◆ Graphic by Kim Sovanndany ◆ Cover and Book design by Youk Chhang and Kim Sovanndany ◆ Printed in Cambodia, 2007 ◆ Copyright ◆

មជ្ឈមណ្ឌលឯកសារកម្ពុជា
*Searching for the truth.*
Documentation Center of Cambodia
P.O. Box 1110, Phnom Penh, Cambodia
Tel.: + 855 (23) 211-875
Fax.: + 855 (23) 210-358
Email: dccam@online.com.kh
Homepage: www.dccam.org

DISCLAMER

The views expressed in this paper are solely those of the author.
ទស្សនៈបញ្ចេញនៅក្នុងសៀវភៅនេះ គឺរបស់អ្នកនិពន្ធតែម្នាក់គត់ ។

ISBN-10: 99950-6-08-6

លសខអ-១០: ៩៩៩៥០-៦-០៨-៦

ISBN-13: 978-99950-60-08-4

លសខអ-១៣: ៩៧៨-៩៩៩៥០-៦០-០៨-៤

Printed in Cambodia

*ចំពោះឪពុករបស់ខ្ញុំ ដែលជាដើមហេតុនាំឲ្យខ្ញុំសរសេរសៀវភៅនេះ*

*និងចំពោះ ហ្សីតង់ហ្សាលី ដែលធ្វើឲ្យសៀវភៅនេះអាចចេញផ្សាយបាន ។*

# សេចក្តីថ្លែងអំណរគុណ

តាមយោបល់របស់លោក E.H.Carr ថា ន័យរួមគឺត្រូវពិនិត្យមើលប្រវត្តិសាស្ត្រទុកដូចជាចង្កោមមួយនៃព្រឹត្តិការណ៍ទាំងឡាយដែលត្រូវមើលបញ្ជាក់ឲ្យដឹងខុសត្រូវមែនឬមិនមែន ៈ “ព្រឹត្តិការណ៍ទាំងឡាយ ដែលបង្ហាញឲ្យប្រវត្តិវិទូដឹង-ឯកសារផ្សេងៗ សិលាចារឹក ។ល ។ គឺដូចជាត្រីនៅលើតុអ្នកលក់ត្រីអ៊ីចឹង ។ ប្រវត្តិវិទូជ្រើសរើសវាហើយនាំមកផ្ទះ រៀបចំធ្វើម្ហូប និងផ្សំគ្រឿងគ្រៅត្រីទាំងនោះទៅតាមលំនាំរបស់វា” ។ លោក Carr បានជំទាស់ប្រកបដោយវិចារណញ្ញាណចំពោះមូលកភាព (ភាពសមហេតុសមផល) នៃយោបល់នេះ ។ ដូច្នេះ តើអ្វីទៅជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយ? ។ តាមការពិត ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយពុំត្រូវចាត់ទុកថាវាមិនប្រែប្រួលនោះទេ ពីព្រោះប្រវត្តិវិទូបានវិនិច្ឆ័យពីរឿងនោះដូច្នេះ ។ ដូចជា“សង្គ្រាមឥណ្ឌូចិនលើកទីបី” បញ្ហាគឺមានលក្ខណៈខុសគ្នាតិចតួច ប៉ុន្តែ នៅមានលក្ខណៈជាសារវន្តដដែល ។ លក្ខណៈពិបាកសំខាន់បំផុតពុំមែនស្ថិតនៅត្រង់ចរិតដែលប្រែប្រួលទៅតាមទម្លាប់នៃជនម្នាក់ក្នុងការជ្រើសរើសព្រឹត្តិការណ៍មួយក្នុងចំណោមភាពសម្បូរហួសហេតុនៃព្រឹត្តិការណ៍ផ្សេងៗឡើយ តាមធម្មតាព័ត៌មានទាំងឡាយករម្រកបានណាស់ ។ បណ្តារដ្ឋាភិបាលរបស់ចិន វៀតណាម និងកម្ពុជា យល់ព្រមឲ្យផ្សព្វផ្សាយជាសាធារណៈតែឯកសារផ្សេងៗដែលស្រាល់ជ្រើសដោយដិតដល់ ហើយដែលអាចបម្រើបុព្វហេតុរបស់គេប៉ុណ្ណោះ ។ វាជាការឥតប្រយោជន៍ដែលសង្ឃឹមថា រដ្ឋាភិបាលទាំងនោះបើកបណ្ណសារដ្ឋានរបស់ខ្លួនឲ្យប្រវត្តិវិទូឯករាជ្យចូលស្រាវជ្រាវ ។

ខ្ញុំចាប់ផ្តើមសរសេរអ្វីដែលមានការទាក់ទងដំបូងអំពីសង្គ្រាមឥណ្ឌូចិនលើកទីបីនេះ ដែលមិនទាន់គ្រប់សព្វដោយសារតែឥទ្ធិពលនៃព្រឹត្តិការណ៍ផ្សេងៗ ជាមួយនឹងការដឹងព្វដោយពេញលេញពីព្រំដែនទាំងនោះ ។ ខ្ញុំប្រហែលជាអ្នកចូលទៅកៀកបំផុតនឹងព្រឹត្តិការណ៍សំខាន់ ដើម្បីប្រមើលមើលហេតុការណ៍ទាំងឡាយប្រកបដោយលក្ខណៈស្របតាមភាពពិតដែលត្រូវតែមានជាចាំបាច់ ប៉ុន្តែខ្ញុំមាន(សម្រាប់ប្រើប្រាស់) នូវអ្វីដែលអាចឲ្យប្រយោជន៍ដ៏ជាក់លាក់មួយលើបណ្តាប្រវត្តិវិទូជំនាន់ក្រោយ ។ ក្នុងអំឡុងពេលដប់ប្រាំឆ្នាំ ខ្ញុំគឺជាសាក្សីដែលបានឃើញនឹងភ្នែកនូវឈុតឆាកខ្លះៗនៃសោកនាដកម្ម ។ ម្យ៉ាងទៀត ខ្ញុំបានជួបសន្ទនាជាមួយ“តួឯក”សំខាន់ៗព្រមទាំងអ្នកសង្កេតការណ៍បរទេសយ៉ាងច្រើនអំពីជម្លោះនៅឥណ្ឌូចិនផង ។ សំណាងដ៏ធំរបស់ខ្ញុំគឺខ្ញុំមានលទ្ធភាពចូលដល់ប្រភពព័ត៌មានផ្សេងៗដោយគ្មានឧបសគ្គ ។ ដូច្នេះ ខ្ញុំអាចប្រមាណដឹងមុនអំពីការគន់គូរដែលទទួលសារភាព មិនកើត, ល្បិចកលសម្ងាត់ផ្សេងៗ ដែលនឹងក្លាយទៅជាដើមហេតុដំបូងនៃការផ្ទុះបញ្ឆេះឲ្យមានជម្លោះ ។ វាធ្វើឲ្យមានសង្ឃឹមឡើងវិញដែលសង្កេតឃើញថា ក្នុងការប្រយុទ្ធតស៊ូដ៏នននៀល ហើយហាក់ដូចជាគ្មានការសម្របសម្រួលដែលនាំឲ្យជាប់ដៃរវាងបណ្តា“មិត្ត”ពីយូរមកហើយ និងអ្នកទទួលខុសត្រូវខ្លះទាំងវៀតណាម ក៏ដូចចិនឬកម្ពុជាកាលបើមានឱកាសអាចធ្វើការសន្ទនាជាឯកជន ដើម្បីសម្តែងពីការមិនទុកចិត្តខ្លះៗស្តីពីមូលកភាព (ភាពសម

ហេតុផល) នៃជីវិតរបស់ប្រទេសគេរៀងៗខ្លួន ថែមទាំងចាប់ផ្តើមធ្វើការរិះគន់ខ្លួនឯងមួយផង ។ សៀវភៅនេះជំពាក់គុណយ៉ាងសម្បើមចំពោះអ្នកទទួលខុសត្រូវអនាមិកទាំងនោះ ដែលមិនរួញរានឹងរំលែកឲ្យខ្ញុំនូវព័ត៌មានផ្សេងៗ ដែលផ្តល់ប្រយោជន៍យ៉ាងខ្លាំងចំពោះរដ្ឋាភិបាលរបស់ខ្លួន ។ ខ្ញុំសូមសម្តែងនូវការដឹងព្រះគុណ ដោយឡែកចំពោះសម្តេចព្រះ នរោត្តម សីហនុ ដែលមានបន្ទូលរៀបរាប់ប្រាប់ខ្ញុំដ៏វែងអន្លាយស្តីពីជីវិតរបស់ព្រះអង្គដែលចម្លែកខុសគ្នាគ្រប់ចំណុចទាំងអស់ ។ ឥស្សរជនជាច្រើនរូប ដែលខ្ញុំបង្ហាញក្នុងសៀវភៅនេះ មិនសំចៃពេលវេលារបស់គាត់សម្រាប់ខ្ញុំទេ ហើយបានរួមវិភាគទានតិចតួចក្នុងការបង្ហាញផ្លូវដល់ការស្រាវជ្រាវរបស់ខ្ញុំដោយរបៀបផ្សេងៗ ។ នៅពេលនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណជាពន្លឹក ។

លោក សេត លីបស្គី និងលោក វីល្លីយ៉ាំ ស្ហាវក្រូស គឺជាអ្នកផ្តើមគំនិតឲ្យសរសេរសៀវភៅនេះមុនគេ ។ អ្នកទាំងពីរបានជំរុញឲ្យខ្ញុំចាប់ផ្តើមធ្វើការនិពន្ធសៀវភៅនេះឡើង ។ និពន្ធនាយករបស់ខ្ញុំ លោក ដីរេក ដេវីស បានលើកទឹកចិត្តខ្ញុំ ដោយយល់ព្រមផ្តល់ឲ្យខ្ញុំនូវការឈប់សម្រាកជាបណ្តោះអាសន្នមួយចំនួនប្រាំមួយខែ ដើម្បីបើកឱកាសឲ្យខ្ញុំបំពេញកិច្ចការស្រាវជ្រាវរបស់ខ្ញុំ ។ ខ្ញុំក៏ជំពាក់គុណចំពោះ Research School of Pacific Studies (នៃសាកលវិទ្យាល័យជាតិនៅអូស្ត្រាលី) ផងដែរ ហើយជាពិសេសចំពោះលោក ដេវីដ ម៉ារ ដែលយល់ព្រមផ្តល់ឲ្យខ្ញុំនូវអាហារូបករណ៍សម្រាប់ការស្រាវជ្រាវមួយ បើគ្មានអាហារូបករណ៍នេះទេ ចំណែកជាប្រវត្តិសាស្ត្រដ៏ជាក់លាក់នៃកិច្ចការនេះនឹងពុំអាចនាំទៅដល់ទីបញ្ចប់បានឡើយ ។

មិត្តភក្តិនិងសហសេវិកយ៉ាងច្រើន, អ្នកឯកទេសខាងបញ្ហាអាស៊ីភាគអាគ្នេយ៍និងអ្នកការទូតបានអានសង្កាត់អត្ថបទសរសេរដៃរបស់ខ្ញុំខ្លះៗ ហើយបានចារមកខ្ញុំវិញនូវសេចក្តីអធិប្បាយនិងមតិណែនាំដ៏មានតម្លៃផ្សេងៗ ។ វាទំនងថា គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងនោះនឹងយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានទាំងមូលរបស់សៀវភៅនេះឡើយ ហើយខ្ញុំនឹងមិនទើសទាល់ក្នុងការរៀបរាប់ឈ្មោះអ្នកទាំងនោះដោយពេញលេញដែរ ។

# ខ្ញុំសូមសម្ដែងកតញ្ញូតាចំពោះលោក

*Graham Aliband, Desaix Anderson, Alain et Michèle Archambault, Jan Austin, Dorothy Avery, Jacques Beaumont, Elizabeth Becker, Stanley Bedlington, Madhu Bhaduri, Chanthou Boua, Mohammed Bouabid, Lyall Breckon, Terry Breese, Richard Breeze, Fred Brown, Raymond Burghardt, James Burnet, Timothy Carney, David Chandler, Parris Chang, Helen Chauncey, Michael Chinoy, Kraisak Choonhavan, Evelyn Colbert, Shyamala Cowsik, Maryse Daviet, Patrice et Brigitte de Beer, Philippe Devillers, Neelam Dhamija, Nguyen Huu Dong, Michael Eiland, David Elliott, Donald Emmerson, Harold Evans, Philippe Franchini, John Girling, Banning Garrett, Jim Gerrand, Tushar et Rajeshwari Ghose, William Gleysteen, Donald Gregg, Wang Gungwu, Sandor Gyori, Harry Harding, Lilian Harris, Barbara Harvey, David Hawk, Bob Hawkins, Hollis Hebbel, Stephen Heder, Bill et Peggy Herod, Murray et Linda Hiebert, Richard Horne, Mario Iseppi, Raphael Iungerich, Stephen Johnson, Paul et Sophie Quinn-Judge, Jérôme Kanapa, Stanley Karnow, Kasem Kasemiri, Henry Kenny, Donald Keyser, Ben Kiernan, Allen Kitchens, Tommy Koh, Gabriel Kolko, Charles Lahiguera, Dennison Lane, James Lilley, Michael Lombardo, Michel Lummoux, Steve Lyne, John MacAuliff, Jamie Mackie, A. Madhavan, Kishore Mahbubani, Abdul Majid, Robert Manning, Glenn May, John McBeth, George McQuillen, Charles Meyer, Atsuo Miyake, John Mohanco, Don Oberdorfer, Jean-Christophe Oberg, Bill O'Malley, Roland-Pierre Paringaux, Arun Phanupong, Douglas Pike, Jonathan Pollack, Gareth Porter, Mark Pratt, Kailash Puri, Ken Quinn, Dragoslav Rancic, Sean Randolph, K. Ranganathan, David Reese, Philippe Richer, Robert Ross, Daniel Roussel, Malcolm Salmon, Kernial Sandhu, Renji Sathiah, Turid Sato, Jean Sauvageot, Tonia Shand, Robert Shaplen, Frank Sieverts, Amarjit et Bhagwant Singh, Pami Singh, Richard Solomon, Daniel Southerland, Simon et Elise Spivak, Michel Strulovici, Roger Sullivan, Robert Sutter, Frank Tatu, CarlyleThayer, Jerry Tinker, William Turley, Lorenzo et Adriana de Vignal, Sarasin Viraphol, Jusuf Wanandi, Steve Wasserman, William Wilmott, Joseph Winder, William Wise, Leonard Woodcock, Maria Zammit.*

ខ្ញុំខ្លោចផ្សាក្នុងចិត្តចំពោះមរណភាពដ៏គួរឲ្យឈឺចាប់របស់លោក ដេនហ្សិល កែរីស, ប្រាវើស កុមារ និង ស. ស៊ីវ៉ារ៉ាម៉ាគ្រីស្ណាន់ ដែលបានជួយជ្រោមជ្រែងខ្ញុំយ៉ាងខ្លាំង ប៉ុន្តែ គាត់លែងមានជីវិតដើម្បីបានឃើញផ្លែផ្កានៃការលើកទឹកចិត្តរបស់គាត់ទៀតហើយ ។

ខ្ញុំជំពាក់គុណយ៉ាងច្រើនចំពោះលោក លីន ណេសប៊ីត ដែលបានជួយទំនុកបម្រុងយ៉ាងសប្បុរស ដើម្បីឲ្យបានសម្រេចក្នុងការបោះពុម្ពផ្សាយសៀវភៅនេះ និងចំពោះអ្នកទទួលបោះពុម្ពផ្សាយរបស់ខ្ញុំ ម៉ារីអា ក៉ណា វ៉ារង់ ដែលបានណែនាំខ្ញុំដោយអំណត់ចប់ចុងចប់ដើមក្នុងដំណើរបញ្ចប់សៀវភៅសរសេរដោយដៃដ៏ពិបាក ។ ពិតណាស់ សៀវភៅនេះនឹងមិនត្រូវបានសរសេរឡើយ បើគ្មានលោក អាមីត និង លោក អតេស្ហ ដែលត្រូវបាត់បង់ឪពុករបស់ខ្លួនក្នុងរយៈពេលមួយយូរលង់មកហើយ ។

# ប្រវត្តិរបស់អ្នកនិពន្ធ

*លោក ណាយ៉ាន់ ចាន់ដា* (*Nayan Chanda*) *កើតក្នុងឆ្នាំ១៩៤៦ នៅប្រទេសឥណ្ឌា ។ បន្ទាប់ពីបានសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រនៅទីក្រុងកាល់គុត្តា* (*Calcutta*) *និងទីក្រុងប៉ារីសរួចមក នៅឆ្នាំ១៩៧៤ គាត់បានក្លាយទៅជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់ទស្សនាវដ្ដី “សេដ្ឋកិច្ចចុងបូព៌ា”* (*Far Eastern Economic Review*) *សម្រាប់ឥណ្ឌូចិន និងបានតាំងស្នាក់ការនៅទីក្រុងព្រៃនគរបច្ចុប្បន្នគឺក្រុងហូជីមិញ ។ អត្ថបទផ្សេងៗរបស់លោកត្រូវបានចុះផ្សាយក្នុងសារព័ត៌មានធំៗរបស់ពិភពលោកដូចជាកាសែតញូវយ៉កថែម* (*New York Times*), *កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍* (*Washington Post*), *កាសែតឡឺម៉ុង* (*Le Monde*) *និង ឡឺម៉ុង ឌីប្លូម៉ាទិក* (*Le Monde Diplomatique*) *ជាដើម ។*

*តាំងពីឆ្នាំ១៩៨៤ លោក ណាយ៉ាន់ ចាន់ដា បានដឹកនាំការិយាល័យចាត់ការរបស់ទស្សនាវដ្ដី “សេដ្ឋកិច្ចចុងបូព៌ា” ប្រចាំនៅក្រុងវ៉ាស៊ីនតោន ។*

# មាតិកា

**សេចក្ដីថ្លែងអំណរគុណ**

**ប្រវត្តិរបស់អ្នកនិពន្ធ**

**បណ្ដាបុគ្គលដែលមានតួនាទីសំខាន់ៗក្នុងសៀវភៅនេះ**

**សេចក្ដីផ្ដើម : ខាំងនងធ្លាក់ចុះ** ....... ១

*១. ភាពជាសត្រូវនឹងគ្នាដំបូង* ....... ៩

*- សម្ដេច ព្រះនរោត្ដម សីហនុ : ម៉ោងនៃជ័យជម្នះ* ....... ៤៣

*២. ដង្កូវនាង និង កណ្ដុរ* ....... ៥៣

*៣. មនុស្សដែលគេមិនស្គាល់ម្នាក់ឈ្មោះ ប៉ុល ពត* ....... ៨៣

*- សម្ដេច ព្រះនរោត្ដម សីហនុ : ចាកចេញពីឆាកនយោបាយ* ....... ១១៧

*៤. ការផ្លាស់ប្ដូរទិសដៅដោយប្រវត្តិសាស្ត្រ* ....... ១២៣

*៥. ជំនោរខ្យល់ពីទិសខាងលិច* ....... ១៥៥

*៦. ខ្យល់ខាងកើតមានប្រៀបជាង* ....... ១៩៣

*៧. ភាពស្ងប់ស្ងាត់មុនខ្យល់ព្យុះ* ....... ២១៧

*- សម្ដេច ព្រះនរោត្ដម សីហនុ : ក្នុងគុកខ្មែរក្រហម* ....... ២៥៧

*៨. ការអុជអាលឡើតតែមានរឿងធំ* ....... ២៦៣

*៩. Yankee ត្រឡប់មកវិញ* ....... ៣០៣

*- សម្ដេច ព្រះនរោត្ដម សីហនុ : រួចផុតពីគ្រោះថ្នាក់* ....... ៣៤០

*១០. ណូអែលក្រហម* ....... ៣៤៩

*១១. ឥណ្ឌូចិន : នៅពេលណាទើបមានសន្តិភាព* ....... ៤០៣

**អវសានកថា** ....... ៤៥៣

**កាលប្បវត្តិសំខាន់ៗ** ....... ៤៥៧

**ប្រភពឯកសារសំអាង** ....... ៤៦២

# បណ្តាបុគ្គលដែលមានតួនាទីសំខាន់ៗក្នុងសៀវភៅនេះ

| | |
|---|---|
| ប៊ីកញូ ប្រ៊ីហ្ស៊ីនស្គី | ទីប្រឹក្សាសន្តិសុខជាតិរបស់លោកប្រធានាធិបតី ហ្ស៊ីមី ខាធ័រ (ប្រធានាធិបតីសហរដ្ឋអាមេរិក ១៩៧៧-១៩៨១) |
| តេង ស៊ាវពីង | អនុប្រធានបក្សកុម្មុយនីស្តចិន |
| ហាន នានឡុង | អនុរដ្ឋមន្ត្រីការបរទេសចិន |
| ហេង សំរិន | ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា |
| វ៉ាង ទុង | និពន្ធនាយកកាសែតញិនហ្សិនរបស់បក្សកុម្មុយនីស្តវៀតណាម |
| រីឆាដ ហូលប្រ៊ុក | អនុរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីខាងកើត និង ប៉ាស៊ីហ្វិក |
| ហ្វា គួហ្វេង | ប្រធានបក្សកុម្មុយនីស្តចិន |
| ហួង ហួ | រដ្ឋមន្ត្រីការបរទេសចិន |
| អៀង សារី | ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ |
| ខៀវ សំផន | ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ |
| គ្រៀងសាក់ ឆូម៉ាណន្ទ | នាយករដ្ឋមន្ត្រីថៃ |
| លី ស៊ាននាន | ឧបនាយករដ្ឋមន្ត្រីចិន |
| ឡេ យន់ | អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម |
| ឡេ ឌឹកថូ | សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាម |
| ឡេ ថាញ់ងី | ប្រធានគណៈកម្មការផែនការរបស់វៀតណាម |
| ង្វៀន កូថាច់ | រដ្ឋមន្ត្រីការបរទេសវៀតណាម |
| ផាន់ ហៀន | អនុរដ្ឋមន្ត្រីការបរទេសវៀតណាម |
| ផាំ វ៉ាន់ដុង | នាយករដ្ឋមន្ត្រីវៀតណាម |
| ប៉ុល ពត | អគ្គលេខាបក្សកុម្មុយនីស្តកម្ពុជា |
| នរោត្តម សីហនុ | អតីតព្រះប្រមុខរដ្ឋកម្ពុជា |
| សោ ភឹម | លេខាបក្សភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ |
| សូផានុវង្ស | ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ |
| ស៊ីរុស វ៉ាន់ស៍ | រដ្ឋមន្ត្រីការបរទេសអាមេរិកាំង |
| វ៉ ង្វៀងយ៉ាប | រដ្ឋមន្ត្រីការពារប្រទេសវៀតណាម |
| ឡេអូណារដ៍ វូដខូក | ឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំប្រទេសចិន |

# សេចក្តីផ្តើម
# ទាំខននធ្លាក់ចុះ

*ប្រហែលនេះជាជោគវាសនានៃយប់ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៥ហើយ ដែលភាពអន្ធការបានគ្របដណ្តប់មកលើក្រុងព្រៃនគរទាំងមូល ។ នៅម៉ោង៦និង៣០នាទីយប់ អគ្គិសនីត្រូវដាច់ហើយបានពន្លិចអ្វីៗទៅក្នុងភាពងងឹតសូន្យសុងទាំងអស់ ហាក់ដូចជាជួយបិទបាំងភាពអាម៉ាស់ និងបរាជ័យរបស់ទីក្រុងនេះអ៊ីចឹង ។ ពីលើដំបូលរាបស្មើនៃសណ្ឋាគារ "ការ៉ាវ៉ែល" ក្រោមភ្លៀងរលឹមស្រិចៗត្រជាក់ស្រេង ខ្ញុំឈរគយគន់ទីក្រុងព្រៃនគរដែលនៅគង់វង្សនារាត្រីចុងក្រោយនេះ ។ ឧទ្ធម្ភាគចក្រធំៗរបស់អាមេរិកាំង ដែលបញ្ចេញសំឡេងលាន់ទ្រហឹងគួរឲ្យព្រឺខ្លាច បានហោះសំកាំងលើអាកាសមួយរយៈខ្លី មុននឹងបន្ទាបខ្លួនចុះលើដំបូលអគារនានារបស់ទីក្រុង ដើម្បីនាំយកអាមេរិកាំងចុងក្រោយនិងសហការីជាតិវៀតណាមមួយចំនួនឆ្ពោះទៅកាន់នាវាធំៗនៃកងនាវាចរទី៧របស់សហរដ្ឋអាមេរិក ដែលបោះយុថ្កានៅកណ្តាលសមុទ្រចិនភាគខាងត្បូង ។ ពីរបីនាទីក្រោយមកយន្តហោះទាំងនេះបានបោះពួយទៅក្នុងលំហមេឃកប់បាត់ក្នុងពពកឆ្ងាយទៅៗ ដោយបន្សល់សំឡេងពុទ្ធ័ររណ្តំពេញផ្ទៃអាកាសទៅក្នុងពេលយប់ដ៏ក្រៀមក្រំនេះ ។*

*នៅខាងក្រោម ទីក្រុងដែលលិចបាត់ក្នុងភាពងងឹតចាក់ភ្នែកមិនយល់ និងស្ងាត់សូន្យឈឹង ហើយដែលគេប្រសិទ្ធនាមថា "គ្រាប់គជ់បូព៌ាទិស" ប៉ុន្តែគេក៏ហៅ "ព្រៃនគរទីក្រុងស្រីពេស្យា"ដែរនោះ នៅកំពុងទន្ទឹងរង់ចាំអ្នកដែលវាយឈ្នះរបស់ខ្លួន ។ អគារខ្ពស់ៗបានលេចរូបរាងឡើងជាស្រមោលស្ទុងៗ នៅឯនាយជើងមេឃ ពន្លឺបានចាំងភ្លឺរន្ទាលដោយសារការផ្ទុះនៃគ្រាប់រ៉ុក្កែតនិងពន្លឺចិញ្ចាចនៃការឆេះឃ្លាំងផ្ទុកគ្រាប់រំសេវនៅចំណតអាកាសយានតាន់ សឺនញ៉ឹក ។ មហាវិថីឡេឡូយ និងវិថីទុយដូ មានពន្លឺជះបំភ្លឺមួយភ្លែតៗដែរដោយសារភ្លើងហ្វារនៃរថយន្តរបស់នាយទាហាននិងអ្នកមានៗវៀតណាម រួមជាមួយក្រុមគ្រួសារកំពុងបើកយ៉ាងលឿនដូចព្យុះសំដៅទៅកាន់កាណូតជាច្រើនគ្រឿងដែលកំពុងរង់ចាំ តាមមាត់ទន្លេនៃក្រុងព្រៃនគរ ។ ទិដ្ឋភាពទាំងនេះគឺជាការប្រែប្រួលចុងក្រោយបំផុតនៃភាពកោលាហលមួយ ដែលគ្របមកលើភាគខាងត្បូង ចាប់តាំងពីការដួលរលំទៅនៃទីក្រុងវ៉េនិងដាណាង កាលពីខែមីនាកន្លងមក ។*

*ការរត់គេចខ្លួនយ៉ាងស្ទន់ស្ទោចេញពីមុខផ្ទាំងរលកកុម្មុយនីស្ត បានមកទើរត្រឹមរបងចម្រឹងដែករបស់ស្ថានទូតអាមេរិកាំង ។ នៅទីនោះ នាពេលក្បាលព្រលប់ ខ្ញុំអាចមើលឃើញជនជាតិវៀតណាមរាប់រយនាក់ឡើង ប្រយិតប្រតោងរបងដែកដោយគ្រវីបង្ហាញក្រដាសស្នាមផ្សេងៗ (អត្តសញ្ញាណប័ណ្ណ លិខិតបញ្ជាក់ និងបាច់ប្រាក់ដុល្លារ) អង្វរសុំចូលក្នុងបរិវេណស្ថានទូតដើម្បីឡើងទៅខាងលើដិះឧទ្ធម្ភាគចក្រដែលសំចតនៅលើដំបូលរាបនៃអគារនោះ ។ ពេញរយៈពេលមួយថ្ងៃ អ្នកទាំងនេះបានវាយដំទាញកន្ត្រាក់ទ្វារចម្រឹងដែក ដែលបិទចាក់ដោយសោត្រដោក និង*

យាមការពារដោយក្រុមទាហានម៉ារីនអាមេរិកាំងមានអាវុធគ្រប់ដៃ ។ នៅពេលនេះការខូចទឹកចិត្តបានរាលដាលខ្លាំងឡើងៗ ។ អ្នកឯទៀតៗដែលមានរាប់រយនាក់នោះបានទៅប្រមូលផ្ដុំនៅក្នុងប្រឡោះជណ្ដើរនៃអគារផ្សេងៗដែលបម្រុងទុកសម្រាប់ការឲ្យចេញដំណើរបន្តទៅទៀត ប៉ុន្តែ ពេញមួយរាត្រីសេចក្ដីសង្ឃឹមបានរលត់បន្តិចម្ដងៗដូចជាភ្លើងទៀនដែលឆេះខ្សោយទៅៗរហូតរលត់ភ្លឹប ។

វាមានកាលៈទេសៈជាច្រើន ដែលប្រវត្តិសាស្ត្រប្រែទៅជាមានដំណើរកាន់តែលឿនយ៉ាងគំហុក ហើយនេះគឺជាកាលៈទេសៈមួយក្នុងចំណោមកាលៈទេសៈទាំងនោះ ។ ការដោះស្រាយបញ្ចប់បញ្ហាបានវិវត្តទៅមុខយ៉ាងលឿនទប់មិនឈ្នះ ។ នៅថ្ងៃទី១០ ខែមីនា កាលបើកងទ័ពវៀតណាមខាងជើង ដែលដឹកនាំបញ្ជាដោយឧត្តមសេនីយ៍ វ៉ាន់ ទៀងយុង វាយប្រហារទៅលើបានមេធួត ក្នុងតំបន់សម្បូរភ្នំភាគកណ្ដាលគឺរបបរបស់ ង្វៀន វ៉ាន់ធីវ ទាំងមូលដែលញ័រខ្លាចនៅតាមមូលដ្ឋាននានារបស់ខ្លួន ។ ក្នុងការវាយប្រហារជាថ្មីដ៏អង់អាចក្លាហានអស្ចារ្យរបស់កុម្មុយនីស្តនេះ កម្រមានអ្នកសម្គាល់ឃើញអ្វីដែលត្រូវតែឃើញ “ការចាប់ផ្ដើមនៃទីបញ្ចប់”ណាស់ បន្ទាប់ពីកងទ័ពវៀតណាមខាងជើងវាយដណ្ដើមបានខេត្តភួកឡុងនៅខែមករា ។ នៅចំពោះការបបួលច្បាំងគ្នាថ្មីនេះ ធីវបានផ្លាស់ប្ដូរវិធីសាស្ត្ររបស់គាត់ទាំងស្រុង ៖ លែងវាយប្រយុទ្ធដើម្បីដីមួយចំអាមៗទៀតហើយ ។ គាត់បានបញ្ជាឲ្យដកថយតាមក្បួនយុទ្ធសាស្ត្រពីប្លេគូ និង កន់ទុម នៅតំបន់ខ្ពង់រាប និងឲ្យកងឯកភាពដ៏ឆ្នើមមួយចាកចេញពីទីក្រុងវ៉េ ។ លទ្ធផលគឺការបាក់បែកទាំងផ្ទាំងដូចទឹកធ្លាយទំនប់ ។ កងទ័ពវៀតណាមខាងត្បូងបានបែកខ្ញែកគ្នារប៉ាត់រប៉ាយក្នុងសភាពច្របូកច្របល់ទាំងស្រុង ។ តែក្នុងចន្លោះបីសប្ដាហ៍ ទីក្រុងវ៉េ, ដាណាង, ញ៉ាត្រាង និងភាគខាងត្បូងទាំងមូលបានដួលរលំដូចវិមានសាងសង់ពីសន្លឹកបៀមួយដូច្នោះដែរ ។

នៅដើមខែមេសា ឆ្នាំ១៩៧៥ រង្វង់ហ៊ុមព័ទ្ធបានរួមតូចមកនៅជុំវិញទីក្រុងព្រៃនគរ ។ អាមេរិកាំងបានបង្កើនល្បឿនក្នុងការផ្គត់ផ្គង់គ្រឿងសាស្ត្រាវុធតាមផ្លូវអាកាសព្រមពេលគ្នានឹងការជម្លៀស បុគ្គលិក និងមិត្តភក្តិជាតិវៀតណាមរបស់ខ្លួនចេញទៅក្រៅដែរ ។ ការវាយប្រយុទ្ធដណ្ដើមក្រុងព្រៃនគរបានចាប់ផ្ដើមនៅថ្ងៃបន្ទាប់ពីការរត់ភៀសខ្លួនរបស់ប្រធានាធិបតី ង្វៀង វ៉ាន់ធីវ តាមយន្តហោះC.118មួយគ្រឿងនៃកងអាកាសចរណ៍អាមេរិកាំង ។ នៅពេលព្រឹកព្រហាមថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវដាស់ឲ្យភ្ញាក់ពីដំណេកទាំងភ័យញ័រដើមទ្រូង ដោយសារការផ្ទុះនៃគ្រាប់រ៉ុក្កែតទីមួយរបស់ក្រុមកុម្មុយនីស្តដែលបាញ់មកលើទីក្រុងព្រៃនគរ ធ្លាក់ចំសណ្ឋាគារម៉ាហ្សេស្ទិកក្បែរកន្លែងខ្ញុំស្នាក់នៅ ។ នៅថ្ងៃទី២៨ ខែមេសា អ្នកបើកយន្តហោះវៀតណាមម្នាក់ (តាមពិតជាភ្នាក់ងារកុម្មុយនីស្ត) ដែលកាលពីមុនធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញដោយសារបានទម្លាក់គ្រាប់បែកទៅលើវិមានប្រធានាធិបតីនោះ បានត្រឡប់មកវាយប្រហារលើមូលដ្ឋានជើងអាកាស តាន់ សឺនញ៉ឹក វិញ ។ ការឆ្លក់វាយបង្ហិនបង្ហោចនេះបូកបន្ថែមនឹងការផ្លោងគ្រាប់រ៉ុក្កែតនិងគ្រាប់កាំភ្លើងធំដែលពុកាន់តែជិតឡើងៗនោះ នៅទីបំផុត ត្រូវបានរំពឹងថាស្ពានអាកាសមួយ នឹងត្រូវរៀបចំឲ្យដំណើរការដោយអាមេរិកាំងមិនខាន ។

ប្រតិបត្តិការ Frequent Wind របស់កងម៉ារីនអាមេរិកនៅពេលរសៀលថ្ងៃទី២៩ ខែមេសា ដើម្បីជម្លៀសមនុស្សចេញតាមឧទ្ធម្ភាគចក្រអាមេរិកាំង និងវៀតណាមបានត្រូវកាត់ផ្តាច់នៅព្រឹកថ្ងៃទី៣០ ខែមេសា ។ ពីលើដំបូលសណ្ឋាគារការ៉ាវែល គេអាចមើលឃើញរថក្រោះវៀតណាមខាងជើងកំពុងរុលមកមុខរបៀបជាជួរដូចហ្វូងស្រមោចដើរតាមផ្លូវជាតិលេខ១ដែលភ្ជាប់ទីក្រុងបៀនហ៊ា មកទីក្រុងព្រៃនគរ ។ ខ្ញុំបានកន្ទេលស្រួលអង្គុយមើលដោយមិនបាំងភ្នែក នៅពេលដែលឧទ្ធម្ភាគចក្រដាច់ពីគេឯងមួយបានលេចធ្លោឡើងពីផ្ទៃមេឃពណ៌ប្រផេះ ហោះមកបន្ទាបខ្លួនចុះលើដំបូលរាបស្មើនៃស្ថានទូតអាមេរិកាំង ។ ប៉ុន្មាននាទីក្រោយមក យន្តហោះបានដឹកយកទាហានម៉ារីនចុងក្រោយដែលនៅយាមការពារស្ថានទូតចេញទៅបាត់ ។ ដោយបត់យ៉ាងគំហុក ដើម្បីចៀសពីបន្ទោលប៉មប៉ុស្តិ៍ប្រៃសណីយ៍ ឧទ្ធម្ភាគចក្របានយកកម្ពស់ត្រង់ឡើងទៅលើហោះពីលើទន្លេហូរកាត់ទីក្រុងព្រៃនគរ ហើយរលាយបាត់ពីក្រោយជើងមេឃខាងកើត ។ ពេលនោះគឺ ម៉ោង៧និង៣៩នាទីព្រឹក ។ ម្ភៃមួយឆ្នាំបន្ទាប់ពីការមកដល់ទីក្រុងព្រៃនគររបស់វរសេនីយ៍ទោសេ.អ៊ី.អា.ម្នាក់ ឈ្មោះ អេដវីដ ឡេនដាល ដែលមកត្រួតពិនិត្យមើលការហាត់ហ្វឹកហ្វឺនរបស់កងទ័ពមួយនៅសាធារណរដ្ឋវៀតណាមខាងត្បូង ដែលទទួលបន្ទុកជាពិសេសក្នុងការវាយប្រយុទ្ធប្រឆាំងនឹងកុម្មុយនីស្តនោះ វាំងននបានធ្លាក់ចុះ គ្របមកលើការផ្សងព្រេងរបស់អាមេរិកាំងនៅឥណ្ឌូចិនដែរ ។

បួនម៉ោងក្រោយមក នៅក្នុងការិយាល័យដ៏ស្ងាត់ជ្រងំមួយនៃទីភ្នាក់ងារព័ត៌មានរ៉យទ័រ ដែលនៅទល់មុខវិមានប្រធានាធិបតី ខ្ញុំនៅអង្គុយវាយលិខិតទូរលេខមួយទាំងជ្រួលច្របល់ក្នុងចិត្ត ដោយរៀបរាប់ពីការលេចធ្លោឡើងនៃទង់ជ័យរបស់កុម្មុយនីស្តនៅតាមជាយក្រុងជុំវិញទីក្រុងព្រៃនគរ ។ រំពេចនោះខ្ញុំបានឮសូរសំឡេងរោទិ៍ង៉ោង១នៃម៉ាស៊ីន និងច្រវាក់កង់រថក្រោះមួយគ្រឿងដែលមានដោតទង់ជ័យវៀតកុង ពណ៌ខៀវ ក្រហម និងទឹកមាស កំពុងបើករុលមកមុខឆ្ពោះទៅកាន់វិមានប្រធានាធិបតី ។ ខ្ញុំស្រវាចាប់យកម៉ាស៊ីនថតរូប ហើយស្ទុះរត់ចេញពីការិយាល័យឆ្លងកាត់តាមសួនច្បារ ដែលខណ្ឌចែកការិយាល័យរបស់ រ៉យទ័រ និងវិមានប្រធានាធិបតី នៅពេលដែលរថក្រោះបានបាញ់កាំភ្លើងមួយគ្រាប់កម្ទេចចម្រឹងទ្វារដែក ហើយបើកចូលទៅក្នុងសួនឧទ្យានរបស់វិមាន ។ ទាហានជាច្រើននាក់លោតចុះពីរថក្រោះ ហើយរត់តាមជណ្តើរឡើងទៅលើ ។ នៅទីបញ្ចប់ ពួកនោះបានបង្ហូតទង់ជ័យវៀតកុងឡើងទៅលើអាកាស ។ ទាហានទាំងនោះ បានមកដល់ចុងបំផុតនៃផ្លូវលំហូដីមិញហើយ ហើយសង្គ្រាមត្រូវបញ្ចប់ត្រឹមនេះ ។

ត្រូវធ្វើឲ្យភាន់ភាំងដោយភាពលឿនរហ័សនៃព្រឹត្តិការណ៍ផ្សេង១ ខ្ញុំស្ទើរតែមិនជឿថា សង្គ្រាមនៅប្រទេសវៀតណាមជាសង្គ្រាមមួយដែលខ្ញុំធ្លាប់គិតថា វានឹងរីកធំ បែរជាត្រូវចប់ភ្លាម១អីចឹងសោះ ។ កាលពីមួយឆ្នាំមុននៅពេលដែលខ្ញុំស្នាក់នៅទីក្រុងព្រៃនគរក្នុងឋានៈជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់ទស្សនាវដ្តី«សេដ្ឋកិច្ចចុងបូព៌ា» ប្រចាំឥណ្ឌូចិន ខ្ញុំដឹងប្រាកដថា កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលរៀបចំដោយ លោក ហង់រី គីស្ស៊ីងហ្គ័រ

និង ឡេ ឌឹកថូ សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាម តាមការពិតត្រូវគេបំភ្លេចចោលទៅហើយ ។ គេលែងអាចនិយាយពីការរំលោភបទឈប់បាញ់គ្នាទៀតហើយ ប៉ុន្តែប្រតិបត្តិការយោធាដែលមានកម្រិតព្រំដែននៅតែមាន ។ ផ្ទុយទៅវិញ គ្មាននរណាម្នាក់ រួមទាំងអ្នកយុទ្ធសាស្ត្រក្រុងហាណូយផង ពុំបានប្រមាណទុកជាមុនពីការបាក់ទ័ពរប៉ាត់រប៉ាយដូច្នេះឡើយ ។ ប៉ុន្តែ នៅពាក់កណ្តាលខែមេសា វាប្រែទៅជាជាក់ច្បាស់ណាស់ថា គេខិតទៅជិតរបត់នាំទៅរកលទ្ធផលចុងក្រោយមួយហើយ ។ តាមការឲ្យដំបូន្មានដែលតឿនបន្ទំនៃការិយាល័យនិពន្ធរបស់ខ្ញុំនៅទីក្រុងហុងកុង ខ្ញុំបានបញ្ចុះបញ្ចូលឲ្យភរិយារបស់ខ្ញុំចាកចេញពីទីក្រុងព្រៃនគរ ប៉ុន្តែខ្លួនខ្ញុំផ្ទាល់បដិសេធមិនចាកចេញទេក្នុងពេលដែលគាត់ឲ្យយោបល់ខ្ញុំពីរឿងនេះ ។ និពន្ធនាយករបស់ខ្ញុំបានសរសេរសំបុត្រមកខ្ញុំថា ៈ «អត្ថបទមួយមានតម្លៃមិនស្មើនឹងអាយុជីវិតរបស់លោកទេ សូមលោកចាកចេញប្រសើរជាងប្រថុយគ្រោះថ្នាក់» ។ ការឆ្លើយតបរបស់ខ្ញុំ ដែលបញ្ជូនទៅហុងកុងនៅថ្ងៃទី២៥ ខែមេសា ខ្ញុំបានប្រាប់ឲ្យដឹងថា ខ្ញុំគ្មានគម្រោងចាកចេញ«មុនទីបញ្ចប់នៃព្រឹត្តិការណ៍អាក្រក់»ឡើយ ។ ប្រាំថ្ងៃក្រោយមកអ្វីៗបានមកដល់ទីបញ្ចប់មែន ។

ខ្ញុំឃើញមិត្តភក្តិវៀតណាមរបស់ខ្ញុំយ៉ាងច្រើនចាកចេញទាំងទឹកមុខស្រងូតស្រងាត់ ។ ខ្ញុំឃើញគ្រួសារជាច្រើនព្រាត់ប្រាសគ្នា នៅពេលធ្វើដំណើរចាកចោលស្រុកទាំងហ្វូងទាំងហ្វូងយ៉ាងគួរឲ្យខ្លោចចិត្ត ។ ខ្ញុំឃើញភាពស្ពឹកស្ពន់របស់ជនភៀសខ្លួនរាប់ពាន់នាក់ ជាអ្នករស់នៅតាមតំបន់ឆ្នេរសមុទ្រភាគកណ្តាល ដែលរត់គេចចេញពីរលកកុម្មុយនីស្ត បានមកជាប់អន្ទាក់ជាថ្មីនៅទីក្រុងព្រៃនគរវិញ ។ ការបែកខណ្ឌដ៏យូរវវាងភាគខាងជើងនិងភាគខាងត្បូងបានបញ្ចប់យ៉ាងចម្លែក ។ គេឃើញអ្នកទីក្រុងព្រៃនគរប្រញាប់ប្រញាល់ទៅរោមជុំវិញរថក្រោះ T-54 របស់កងទ័ពវៀតណាមខាងជើង ហើយសាកល្បងផ្តើមធ្វើការសន្ទនាជាមួយអ្នកមកពីភាគខាងជើង ដែលមានវ័យក្មេងៗ មិនសូវនិយាយស្តី និងស្លៀកឯកសណ្ឋានពណ៌បៃតង ។ ម្នាក់ៗមានអាការៈព្រួយបារម្ភជាខ្លាំងចំពោះថ្ងៃអនាគត ប៉ុន្តែ ជាមួយការធ្វើឲ្យមានសន្តិភាពដូចដើមឡើងវិញ នៅទីបំផុត អ្វីៗទាំងអស់នឹងត្រឡប់ទៅរករបៀបរៀបរយវិញដោយខ្លួនឯង ។

ជំនឿទុកចិត្តខ្លាំងនេះ ពុំមាននៅប្រទេសកម្ពុជាជិតខាង ដែលសង្គ្រាមបានបញ្ចប់មុននេះ១៣ថ្ងៃទេ ។ ក្នុងឱកាសនៃដំណើរចុងក្រោយរបស់ខ្ញុំទៅក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៥ មុខដង្កាប់របស់កងទ័ពខ្មែរក្រហមបានរួមរឹតមកលើរដ្ឋធានីជាថ្មី ។ សំឡេងផ្ទុះនៃគ្រាប់រ៉ុក្កែតបានធ្វើឲ្យទីក្រុងមួយដែលណែនណាន់ទៅដោយជនភៀសខ្លួនពីសង្គ្រាមជិត២លាននាក់ភ័យរន្ធត់ញាប់ញ័រលែងធ្វើអ្វីកើត ។ ខ្មែរក្រហមបានរាំងខ្ទប់ផ្លូវជាតិសំខាន់ៗដែលបែកចេញពីទីក្រុងទាំងអស់ ហើយទន្លេមេគង្គបានក្លាយទៅជាផ្លូវទាក់ទងតែមួយគត់ជាមួយពិភពខាងក្រៅ ។ ការសាកល្បងទាំងអស់សង្ឃឹមរបស់អាមេរិកាំងដើម្បីបង្កើតស្ពានអាកាសមួយសម្រាប់ដឹកស្បៀង និងប្រេងឥន្ធនៈមកឲ្យរបប លន់ នល់ មិនបានសម្រេចដូចការគ្រោងគិតឡើយ ក្រោយពេលដែលអាកាសយានដ្ឋាន

*ពោធិចិនតុងទទួលរងគ្រាប់កាំភ្លើងធំរបស់បច្ចាមិត្តដែលធ្លាក់ស្រោចដូចទឹកភ្លៀង ។ ប្រធានាធិបតី លន់ នល់ ដែលស្រយុតស្រយង់ចិត្តបានចាកចេញពីប្រទេសនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ ហើយបុគ្គលិកនៃស្ថានទូតអាមេរិកាំងក៏បានចេញបន្តជាក្រោយ គឺថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្រុកចូលមកដល់រដ្ឋធានីអាវុធក្ជួង់ទៅមុខដោយបណ្ដេញប្រជាជនទាំងអស់ចេញពីទីក្រុង ។ ពីរសប្ដាហ៍ក្រោយមកជនបរទេសដែលរត់ទៅជ្រកកោននៅស្ថានទូតបារាំងបានឡើងជិះប្រជ្រៀតគ្នាលើរថយន្តកាំមីញ៉ុងជាច្រើនគ្រឿង ហើយចាកចេញឆ្ពោះទៅប្រទេសថៃ ។ មួយរំពេចនោះលែងមានប្រទេសកម្ពុជាទៀតហើយ ដូចចំណុចមួយដែលឃើញកាន់តែតូចទៅៗ នៅឯជើងមេឃទីបំផុតក៏រលាយបាត់សូន្យ ។*

*សង្គ្រាមឥណ្ឌូចិនលើកទីពីរស្ទើរតែមិនទាន់ចប់ស្រួលបួលផង សង្គ្រាមទីបីក៏ប្រុងនឹងកើតមានក្នុងពេលឆាប់ៗដែរ ម្ដងនេះគឺសង្គ្រាមរវាងបងប្អូននិងបងប្អូន រវាងសមមិត្តនិងសមមិត្ត ។ សត្រូវជាចក្រពត្តិទើបនឹងចេញផុតពីឆាក ចាប់ពីពេលនេះទៅ ការប្រកួតគ្នា ការមិនទុកចិត្តគ្នា ដែលមានរាប់សតវត្សរ៍មកហើយនោះ បានលេចឡើងជាថ្មី ។ ផលប្រយោជន៍ជាតិបានក្លាយទៅជាអាវុធមួយគ្រវីឡើងប្រឆាំងនឹងសមមិត្តថ្មីៗនេះម្ដងទៀត ។ ប៉ុន្តែ ជម្លោះដែលរុំព័ទ្ធដោយរឿងសម្ងាត់ ដែលផាត់ពណ៌លាបម្សៅដោយវោហារសាស្ត្រសាមគ្គីភាពបដិវត្តន៍ នៅពុំទាន់ចេញជាក់ស្ដែងនៅឡើយ ។ នៅពេលនោះ ខ្ញុំមិនស្មានថា ខ្ញុំនឹងប្រើពេលភាគច្រើនក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ ដើម្បីរកឲ្យបានព័ត៌មានមួយទាំងស្រុងស្ដីពីជម្លោះមួយដែលមូលហេតុដំបូងៗកម្រើកឡើង នៅចំពេលដែលសន្តិភាពហាក់ដូចជាសណ្ឋិតនៅឥណ្ឌូចិនទៅហើយទេ ។ ដូចនៅលើក្រដាសថ្ពិតរូបថតមួយដែរ ក្នុងដំណើរព្រាវៗរបស់ខ្ញុំក្នុងតំបន់ ការពិតដែលដំបូងមានភាពមិនច្បាស់លាស់ បានលេចឡើងសន្សឹមៗ–រណ្ដៅសាកសពរាប់មិនអស់នៅប្រទេសកម្ពុជារហូតដល់ភ្នំទាបៗនៅតាមព្រំដែនចិន–វៀតណាម ដែលសាកសពជាច្រើនត្រូវរយះរយាយ ដោយការប្រយុទ្ធគ្នា និងការសន្ទនាជាបន្តបន្ទាប់ របស់ខ្ញុំជាមួយសាក្សីច្រើនឥតគណនា ។ ដើម្បីសាកល្បងផ្គុំផ្គុំវាឡើងវិញ ខ្ញុំបានប្រមូលចម្លើយជាសាក្សីរបស់អ្នកទទួលខុសត្រូវប្រមាណមួយរយនាក់ ទាំងមន្ត្រីផ្លូវការ ឬមិនផ្លូវការ និងមហាអំណាចសំខាន់ៗដែលពាក់ព័ន្ធក្នុងសោកនាដកម្មនេះ ។ សៀវភៅនេះគឺជាលទ្ធផលនៃការស៊ើបរកការពិតមួយដែលចាប់ផ្ដើម១២ឆ្នាំមកហើយ ។*

*ការដួលរលំនៃទីក្រុងព្រៃនគរនិងក្រុងភ្នំពេញបានត្រូវបន្តដោយការប្រយុទ្ធស៊ីសាច់ហុតឈាមរវាង ក្រុមអ្នកឈ្នះដើម្បីដណ្ដើមការត្រួតត្រាប្រជុំកោះនានានៅឈូងសមុទ្រថៃទៀត ។ ប៉ុល ពត មេដឹកនាំខ្មែរក្រហមដែលបានដឹងមុនពីការប្រឈមមុខមួយជាមួយវៀតណាមជាសត្រូវសួពូជនោះបានដាក់ចេញជាបន្ទាន់ នូវកម្មវិធីធ្វើដំណើរទាំងបង្ខំមួយឆ្ពោះទៅកាន់លទ្ធិសង្គមនិយមដោយឆាប់រហ័សក្នុងទិសដៅធ្វើឲ្យប្រទេសកម្ពុជារឹតតែរឹងមាំឡើង ។ ការកម្ចាត់ដ៏ឃោរឃៅទៅលើអ្នកប្រឆាំងដែលសង្ស័យថាជាអ្នកមានសមានចិត្តជិតស្និទ្ធនឹងវៀតណាម បានឲ្យសញ្ញាជាមុនពីការវាយលុកដោយត្រង់ៗទៅលើភូមិនានារបស់វៀតណាមនៅតាមព្រំដែន ។ សម្រាប់ខ្មែរក្រហម*

យល់ថា ៖ នេះគឺជាកិច្ចការពារមួយត្រឹមត្រូវតាមច្បាប់ ជាសង្គ្រាមមួយសម្រាប់បង្ការជាមុនទល់នឹងសត្រូវប្រវត្តិសាស្ត្រមួយដែលប្រព្រឹត្តអ្វីៗសំដៅតែ«លេបត្របាក់»កម្ពុជាប៉ុណ្ណោះ ។ ប៉ុន្តែ សម្រាប់វៀតណាមក៏ដូចគ្នាដែរ ភាពជាសត្រូវរបស់កម្ពុជាដែលលើកទឹកចិត្តដោយប្រទេសចិន បានធ្វើឲ្យនឹកឃើញអនុស្សាវរីយ៍អាក្រក់ៗឡើងវិញ ។ ហេតុអ្វីបានជាវៀតណាម មើលពុំឃើញការប៉ុនប៉ងមួយនៃសត្រូវតាំងពីដើមរៀងមក គឺប្រទេសចិនដែលចង់យកប្រទេសរបស់ខ្លួនដាក់ជាចំណុះ? ក្នុងការប្រយុទ្ធតស៊ូជាច្រើនលើករបស់ខ្លួនប្រឆាំងនឹង«អាណាចក្រកណ្ដាល» (ប្រទេសចិន) ក្នុងថិរវេលាមួយពាន់ឆ្នាំកន្លងមកប្រទេសវៀតណាមហាក់ដូចជាត្រៀមខ្លួនការពារមុនរួចជាស្រេចចំពោះការគំរាមកំហែងណាមួយ ហើយចាំវាយបកទៅវិញជាដរាប ។ អ្វីៗបានដល់ទីបំផុតនៅចុងឆ្នាំ ១៩៧៧ ។ ជម្លោះបានត្រូវលាតត្រដាងឲ្យពិភពលោកដឹងព្រោះនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ។ វិទ្យុភ្នំពេញ បានផ្សព្វផ្សាយជាសាធារណៈថា ប្រទេសកម្ពុជាជាអ្នករងគ្រោះពី«ការឈ្លានពានរបស់វៀតណាម» ។ ក្នុងរយៈពេល ៥ ខែដែលមានជាបន្តបន្ទាប់ ការជ្រួលច្របល់បានរាលដាលទៅដល់ភាគខាងជើងទៀត ។ ការចាកចេញទាំងហ្វូងៗនៃអាណិកជនចិនពីប្រទេសវៀតណាម បានផ្ដល់ឲ្យក្រុងប៉េកាំងនូវឱកាសលើកឡើងនិងបរិហារពី«ការធ្វើទុក្ខបុកម្នេញ»ជនជាតិចិនដោយក្រុងហាណូយនិងពី«មហិច្ឆតាត្រួតត្រា»របស់វៀតណាមនៅតំបន់ចិន ។ ការពង្រឹងសម្ព័ន្ធភាពរឹតតែជិតស្និទ្ធឡើងរវាងសូវៀតនិងវៀតណាមបានធ្វើឲ្យរឿងរ៉ាវជាប្រវត្តិសាស្ត្រនៃការគំរាមកំហែងដ៏«ឃោរឃៅ» ដែលគ្មានលក្ខណៈប្រាកដប្រជាកម្រើកឡើងវិញលើវណ្ណសិរ្សពីរគឺនៅភាគខាងជើងនិងភាគខាងត្បូង ។ តាំងពីរដូវក្ដៅឆ្នាំ១៩៧៨ ប្រទេសចិនបានគ្រោងរៀបចំដាក់ទណ្ឌកម្មវៀតណាមរួចជាស្រេច ចំពោះការរមិលគុណរបស់ខ្លួនដែលធ្លាប់តែបានទទួលអត្ថប្រយោជន៍ពីការជួយឧបត្ថម្ភរបស់ចិនអស់រយៈពេលសាមសិបឆ្នាំមកហើយ ។ នៅឆ្នាំ១៩៧៩ បន្ទាប់ពីការផ្ដួលរំលំសម្ព័ន្ធមិត្តខ្មែរក្រហមរបស់ខ្លួនដោយការចូលលុកលុយរបស់វៀតណាម ប្រទេសចិនអាចរក្សាទុកនូវការដាក់ទណ្ឌកម្មមួយដែលខ្លួនបានសន្យារួចមកហើយជានិច្ច ។

ចាប់ពីពេលនេះទៅ ជម្លោះរបស់តំបន់ចិនបានប្រែក្លាយទៅជារឿងដែលមានជាប់ទាក់ទងនឹងការប្រកួតប្រជែងគ្នាមិនអាចស្រាយបានរវាងសូវៀត អាមេរិក និងការប្រែប្រួលដែលកើតឡើងដោយចៃដន្យ គឺសម្ព័ន្ធភាពរវាងចិន-អាមេរិក ដែលពេលនោះកំពុងមានការរីកលូតលាស់យ៉ាងខ្លាំង ។ ដុយពីកម្ពុជាប្រជាធិបតេយ្យក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដែលបិទព្រំដែនរបស់ខ្លួនយ៉ាងជិតស្អិត និងពឹងផ្អែកតែលើប្រទេសចិននោះ ចាប់ពីឆ្នាំ១៩៧៥ ទៅក្រុងហាណូយបានខំប្រឹងពង្រីកនយោបាយការបរទេសឯករាជ្យមួយ ដោយផ្អែកលើមូលដ្ឋាននៃការធ្វើឲ្យមានទំនាក់ទំនងស្មើភាពគ្នាជាមួយមហាអំណាចផុតលេខទាំងពីរ ។ ក្នុងអំឡុងរដូវក្ដៅឆ្នាំ១៩៧៧ ប្រទេសវៀតណាមហៀបនឹងបានសម្រេចធ្វើឲ្យមានទំនាក់ទំនងផ្នែកការទូតជាមួយសហរដ្ឋអាមេរិកទៅហើយ ប៉ុន្តែការចចេសរបស់ខ្លួនដោយតម្រូវឲ្យអាមេរិកផ្ដល់ជំនួយសម្រាប់ការស្ដារប្រទេសឡើងវិញ បានធ្វើឲ្យគម្រោងការនោះរលាយខ្យល់ ។ មួយឆ្នាំក្រោយមក នៅពេលដែលជម្លោះមិនទាន់ចេញមុខរបស់ខ្លួនជាមួយប្រទេសកម្ពុជា និង

ចិនហៀបនឹងក្លាយទៅជាសង្គ្រាមចេញមុខមួយ និងនៅពេលដែលការខិតចូលជិតគ្នាជាមួយក្រុងវ៉ាស៊ីនតោនក្លាយទៅជាភាពចាំបាច់ខានមិនបាននោះ ប្រទេសវៀតណាមត្រូវតែលះបង់លក្ខខណ្ឌជាអាទិភាពនេះសិន ។ ប៉ុន្តែក្នុងចន្លោះពេលនោះ លក្ខណៈពិសេសផ្នែកការទូតបានប្រែក្រឡាស់អស់ ។ ដោយមិនឲ្យវៀតណាមដឹងខ្លួន ក្រុងប៉េកាំងបានប្រកាន់យកការសម្រេចចិត្ត "ផ្តល់មេរៀនមួយ" ចំពោះប្រទេសជិតខាងនៅភាគខាងត្បូងព្រំដែនខ្លួនរួចជាស្រេច ។ មុននឹងលោតចូលទៅក្នុងការផ្សងព្រេងនេះ ប្រទេសចិនបានបង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួនរឹតតែខ្លាំងឡើងថែមទៀត ដើម្បីសម្របសម្រួលធ្វើឲ្យទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិកមានប្រក្រតីភាពសិន ហើយការសម្រេចចិត្តរបស់ចិននេះ ក៏ស្របគ្នាយ៉ាងខ្លាំងទៅនឹងគោលដៅផ្សេងៗរបស់អាមេរិកាំងដែរ ប្រធានាធិបតី ហ្ស៊ីមីខាធ័រ និងទីប្រឹក្សាសន្តិសុខជាតិរបស់គាត់មានបំណងបញ្ចូលប្រទេសចិនក្នុងសម្ព័ន្ធភាពមួយប្រឆាំងសូវៀតខ្លាំងណាស់ ។ ហេតុនេះហើយបានជាអាមេរិកាំងសម្រេចចិត្តបោះបង់ចោលគំនិតធ្វើឲ្យមានប្រក្រតីភាពក្នុងទំនាក់ទំនងអាមេរិក-វៀតណាមមួយអន្លើ ហើយបានជំរុញឲ្យមានការខិតចូលគ្នាជាមួយក្រុងប៉េកាំងជាសម្ងាត់វិញ ។ សាមសិបឆ្នាំក្រោយការធ្វើអន្តរាគមន៍របស់ខ្លួននៅឥណ្ឌូចិនប្រឆាំងនឹង"លទ្ធិវាតទីនិយមចិន" សហរដ្ឋអាមេរិកបានត្រឡប់មកស្ថិតក្នុងស្ថានភាពជា "អ្នកចេញដើមទុន" ក្នុងសង្គ្រាមមួយដែលដឹកនាំដោយក្រុងប៉េកាំងប្រឆាំងនឹងវៀតណាមដដែល ៖ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ មេដឹកនាំចិន តេង ស៊ាវពីង ដែលទើបនឹងត្រឡប់ពីដំណើរទស្សនកិច្ចដ៏មានជោគជ័យនៅសហរដ្ឋអាមេរិក បានផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវ "កិច្ចប្រតិបត្តិការដាក់ទណ្ឌកម្ម"របស់គាត់ឲ្យគេដឹងឮជាសាធារណៈ ។

ការចូលកាន់កាប់ប្រទេសកម្ពុជាដោយប្រទេសវៀតណាម និង "កិច្ចប្រតិបត្តិការដាក់ទណ្ឌកម្ម" របស់ចិនទៅលើវៀតណាមជាសញ្ញាបង្ហាញឲ្យឃើញនូវកម្រិតខ្ពស់បំផុតនៃជម្លោះមួយដែលទុំជោរយូរយារណាស់មកហើយ ប៉ុន្តែជម្លោះនេះពុំបាននាំមកនូវដំណោះស្រាយបែបណាមួយឡើយ ។ នៅដើមឆ្នាំ១៩៨៦ កងទ័ពវៀតណាមចំនួន១៨០.០០០នាក់ បាននៅវាយប្រយុទ្ធទល់នឹងសង្គ្រាមទ័ពព្រៃរបស់ខ្មែរក្រហមក្នុងប្រទេសកម្ពុជានៅឡើយ ។ ប្រទេសចិននៅតែបន្តបាញ់ផ្លោងគ្រាប់កាំភ្លើងធំតាមព្រំដែនវៀតណាមខាងជើង ហើយទាហានថ្មើរជើងចិនក៏តែងលបវាយឆ្មក់ជានិច្ចកាលដែរ ។ ដោយត្រូវបណ្តេញចេញពីទីក្រុងភ្នំពេញ ក្រុមខ្មែរក្រហមមិនសូវផ្តល់កម្លាំងចិត្តដល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលជារដ្ឋាភិបាលតែមួយគត់ដែលគេទទួលស្គាល់នៅកម្ពុជានោះឡើយ ។ ប៉ុន្តែទាល់តែពេលសង្គ្រាមឥណ្ឌូចិនលើកទីបីជាប់គាំងទើបបរិការណ៍ (ការណ៍ទាំងឡាយដែលកើតមុនឬក្រោយព្រឹត្តការណ៍មួយ) អន្តរជាតិចាប់ផ្តើមផ្លាស់ប្តូរទាំងស្រុង ។ ដោយទាញអត្ថប្រយោជន៍ពីសង្គ្រាមចិន-វៀតណាម ក្រុងមូស្គូបានទទួលការអនុញ្ញាតឲ្យតាំងមូលដ្ឋានទ័ពជាច្រើនកន្លែងក្នុងប្រទេសវៀតណាម ដែលក្រុងហាណូយធ្លាប់បានបដិសេធជាយូរមកហើយ ដូច្នេះសូវៀតអាចលាតសន្ធឹងឥទ្ធិពលរបស់ខ្លួននៅមហាសមុទ្រប៉ាស៊ីហ្វិកថែមទៀត ។ ក្រុងវ៉ាស៊ីនតោន ត្រូវតែបោះបង់ចោលសម្ព័ន្ធភាពប្រឆាំងសូវៀត ដែលគម្រោងការនេះ

ធ្លាប់ដឹកនាំដោយអាមេរិក ដើម្បីគាំទ្រប្រទេសចិនប្រឆាំងនឹងប្រទេសវៀតណាមមួយរយៈពេល ទុកណាជាក្រុងប៉េកាំងដែលព្រួយបារម្ភពីឯករាជ្យភាពរបស់ខ្លួនចាប់ផ្តើមធ្វើកិច្ចចរចាស្តីពីការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងមូស្គូក៏ដោយ ។ ផ្លូវដែលឆ្ពោះទៅរក "ចំណុចចាប់ផ្តើម" ត្រូវខ្ទប់ជាប់ ។ ប្រទេសវៀតណាមដែលពូកែខាងរបៀបធ្វើចម្បាំង ប៉ុន្តែ ដែលគេមិនសូវទៅមកហើយដោយសេដ្ឋកិច្ចរបស់ខ្លួនត្រូវហិនហោចថែមទៀតនោះ បានចាប់ផ្តើមស្វែងរកការខិតចូលជិតគ្នាជាមួយសហរដ្ឋអាមេរិកជាថ្មី ព្រោះខ្លួនបានធ្វើឲ្យរបូតផុតពីដៃចំនួនពីរដងរួចមកហើយ ។

ទាំងអស់នេះហើយ ជាជម្លោះលើកទីបីរបស់ឥណ្ឌូចិន និងជាល្បែងការទូតរបស់មហាអំណាចធំៗ ។ តាំងពីការហោះហើរនៃឧទ្ធម្ភាគចក្រចុងក្រោយពីដំបូលអគារស្ថានទូតអាមេរិកប្រចាំក្រុងព្រៃនគរ អ្វីដែលកើតមាននៅឥណ្ឌូចិនបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា តើចំណុចណាខ្លះជាការធ្វើអន្តរាគមន៍របស់សហរដ្ឋអាមេរិកដែលវាយប្រឆាំគោលដៅរបស់ខ្លួននោះ? ដោយមិនធ្វើខ្លួនជាក្រុមឈានមុខប្រឆាំងទល់នឹងការវាតទីរបស់លទ្ធិកុម្មុយនីស្តចិននៅអាស៊ីដូចដែលក្រុមអ្នកជំនាញការអាមេរិកាំងភ័យខ្លាចពីបញ្ហានេះ ប្រទេសវៀតណាមមិនបង្អែបង្អង់ប្រែក្លាយខ្លួនទៅជាគូប្រជែងនឹងប្រទេសចិនដែលចូលចិត្តបង្កជម្លោះនោះឡើយ ។ ខ្មែរក្រហមដែលគេចាត់ទុកតាំងពីយូរមកហើយថា ជាឧបករណ៍របស់ក្រុងហាណូយនោះ បានបង្ហាញខ្លួនឡើងជាសត្រូវស្លាប់រស់នឹងគ្នាទៅវិញ ។ ប្រវត្តិសាស្ត្រក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះមានលក្ខណៈមួយដែលគេប្រើប្រាស់ជាមេរៀនបាន ហើយដែលវាបង្ហាញឲ្យឃើញថាគឺក្រុមអ្នកតស៊ូឲ្យមានរបៀបរបបថ្មីជាប្រវត្តិសាស្ត្រនិងក្រុមអ្នកជាតិនិយមនេះហើយដែលជាអ្នកក្តាប់កូនសោសម្រាប់អនាគតភូមិភាគនេះ ។ ថ្វីបើអ៊ីៗបង្ហាញឲ្យឃើញតែសំបកក្រៅក៏ដោយ ក៏បណ្តាមនុស្សគ្មានឆន្ទៈដែលមិនគួរយកចិត្តទុកដាក់លែងមានគេដឹងឮសុសសាយនៅឥណ្ឌូចិនទៀតហើយ ។

# ជំពូកទី១
# ភាពជាសត្រូវនឹងគ្នាដំបូង

*នៅខែឧសភា ឆ្នាំ១៩៧៥ ភាពស្ងប់ស្ងាត់បានកើតមានជាថ្មីនៅឥណ្ឌូចិន បន្ទាប់ពីភាពពុះកញ្ជ្រោល ក្នុងរយៈពេលមួយខែ ។ សំឡេងញ័ររណ្តំនៃហ្វូងយន្តហោះដែលហោះឆ្វែលឆ្វាត់នៅលើអាកាសដើម្បីស្វែងរកអ្នករួចផុតពីសេចក្តីស្លាប់បានរលត់សូន្យឈឹង ។ ប្រតិបត្តិការជួយសង្គ្រោះអ្នកភៀសខ្លួនតាមទូករាប់រយគ្រឿងដែលបើករត់ចេញយ៉ាងអស់ល្បឿនពីប្រទេសវៀតណាមនោះ បានត្រូវនាំមុខធ្វើដោយកងនាវាចរទី៧របស់អាមេរិកាំង ។ ការរំដើបរំជួលមិនសមហេតុផលទាំងនេះបានរើបឡើងវិញ ។ យ៉ាងហោចក៏គេវាយតម្លៃពីរឿងនេះដែរ ។*

*ព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ ពន្លឺស្រស់បំព្រងនៃព្រះអាទិត្យនៅឯជើងមេឃបានចោលរស្មីចិញ្ចាចមកលើផ្ទៃសមុទ្រពណ៌ខៀវថ្លានៅជុំវិញកោះតាងក្នុងឈូងសមុទ្រថៃ នៅពេលដែលសំឡេងមួយដែលជាលក្ខណៈពិសេសនៃសង្គ្រាមបានលាន់ឮឡើងជាថ្មី ។ នៅទិសខាងលិច ឧទ្ធម្ភាគចក្រដប់មួយគ្រឿង បានលេចឡើងស្ទុងៗនៅឯនាយជើងមេឃ ។ ឧទ្ធម្ភាគចក្រប្រភេទ Jolly Green Giants និង Knife នៃកងអាកាសចរអាមេរិកាំងបានតម្រង់ក្បាលឆ្ពោះមករកកោះរបស់កម្ពុជា ។ កម្មវត្ថុរបស់គេគឺស្វែងរកកប៉ាល់ដឹកកុងតឺន័របំណាស់មួយគ្រឿងរបស់អាមេរិកឈ្មោះ ម៉ៃយ៉ាហ្គេ ដែលត្រូវរុញច្រានដោយទឹករលក ហើយទម្លាក់យុថ្កាឈប់នៅត្រង់សមុទ្រក្បែរកោះតាង ។ កាលពីថ្ងៃទី១២ ខែឧសភា នាវាតូចមួយរបស់កម្ពុជាដែលផ្ទុកទៅដោយយុទ្ធជនក្មេងៗក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបានវាយដណ្តើមយកនាវានេះដោយកម្លាំងនៅក្នុងលំហសមុទ្រត្រង់តំបន់កោះពូលូវៃ ដែលនៅឆ្ងាយមកភាគខាងត្បូងទៀត[១] ។ ដោយឆ្លើយតបនឹងការបញ្ជូនសញ្ញាប្រាប់ពីគ្រោះអាសន្នរបស់នាវាលោកប្រធានាធិបតី ហ្សេរ៉ាល់ ហ្វ័រដ៍ បានចេញបទបញ្ជាឲ្យកងឯកភាពឧទ្ធម្ភាគចក្រមួយនៃកងអាកាសចរសហរដ្ឋអាមេរិកដែលសំចតប្រចាំការនៅមូលដ្ឋាន អ៊ូតាប៉ាវ ប្រទេសថៃ និងម៉ារីននៃកងនាវាចរទី៧ប្រចាំសមុទ្រប៉ាស៊ីហ្វិកចេញជួយសង្គ្រោះនាវា ម៉ៃយ៉ាហ្គេ និងក្រុមនាវិកចំនួនសាមសិបប្រាំបួននាក់ ។ ក្នុងពន្លឺមិនទាន់ច្បាស់នៃពេលព្រឹកព្រហាមនៅពេលដែលទាហានម៉ារីនប្រើងប្រែងវាយលុកដណ្តើមយកកោះនេះ ពួកគេពុំបានដឹងថា ក្រុមនាវិកទាំងនោះត្រូវខ្មែរក្រហមផ្ទេរមកកាន់ដីគោកនៅឯកំពង់ផែកំពង់សោមរួចមកហើយទេ ។ ម្យ៉ាងទៀត អ្នកយុទ្ធសាស្ត្រអាមេរិកាំងក៏វាយតម្លៃខុសយ៉ាងខ្លាំងពីកិច្ចការពារដ៏មោះមុតរបស់កងទ័ពខ្មែរក្រហមដែលមានកំណើតជាកសិករមានអាវុធមិនគ្រប់គ្រាន់តែអាចទប់ទល់នឹងកងកុម្ម៉ង់ដូជួយសង្គ្រោះរបស់អាមេរិកយ៉ាង មានប្រសិទ្ធភាពបំផុត ។ កប៉ាល់ទីមួយប្រភេទ Knife បានបញ្ចុះទាហានម៉ារីនរបស់ខ្លួនឲ្យឡើងគោកសឹងតែមិនទាន់ចប់សព្វគ្រប់ផង ស្រាប់តែនៅជួរដើមឈើដែលគ្របដណ្តប់មកលើឆ្នេរខ្សាច់ ស្នូរផ្ទុះនៃកាំភ្លើងយន្ត និងកាំភ្លើងវែង បានលាន់ឮឡើងដូច*

លាដផុះ ។ តាមការអះអាងរបស់អ្នករួចផុតពីគ្រោះថ្នាក់ម្នាក់ជាអ្នកបើកខទ្ទម្ភាគចក្រ ដែលស្ថិតនៅក្រោមការប៉ះទង្គិចខាងផ្លូវចិត្តនៅឡើយ បាននិយាយថា នោះជា«កម្រងផ្កាសាប៊ាំងមួយសម្រាប់ណូអែល»[២] ។ មិនដល់មួយម៉ោងផង នាវាពីរគ្រឿងបានត្រូវខ្មែរក្រហមកម្ទេចនៅលើឆ្នេរខ្សាច់ ។ នៅលើកោះគ្មានអ្នកណាជួយសង្គ្រោះអ្នកណាឡើយ លើកលែងតែទាហានម៉ារីននោះផ្ទាល់ដែលមិនអាចធ្វើអ្វីកើតសោះ ក្រោមភ្លៀងគ្រាប់កាំភ្លើងរបស់កម្ពុជា ។ ក្នុងរយៈពេលដប់បួនម៉ោងបន្ទាប់ពីនោះ យន្តហោះជាច្រើនគ្រឿងរបស់អាមេរិកដែលសំចតនៅលើឆ្នេរសមុទ្រ និងនាវាចម្បាំងធំៗរបស់កងនាវាចរទី៧ បានបាញ់ស្រោចទៅលើតំបន់នោះឆេះហុយទ្រលោម ។ ត្រូវធ្វើឲ្យភ័ក្តភាំងស្មារតីដោយការបង្ហាញកម្លាំងនេះ ខ្មែរក្រហមបានព្រមដោះលែងក្រុមនាវិកកប៉ាល់យ៉ាងឆាប់រហ័ស ។ ប៉ុន្តែទាហានម៉ារីនដែលជាប់ អន្ទាក់នៅលើកោះតាងនោះពុំទាន់ដោះខ្លួនរួចនៅឡើយទេ ។ ប្រធានាធិបតីហ្សេរ៉ាល់ ហ្វ័រដ៍ បានលើករឿងនេះមកធ្វើជាសំអាងដើម្បីបញ្ជាក់ថា ការទម្លាក់គ្រាប់បែករបស់ខ្លួនដែលបណ្ដាលឲ្យឋបនភ័ណ្ឌទាំងឡាយរបស់កម្ពុជានៅតាមឆ្នេរសមុទ្រឆេះខ្ទេចខ្ទីអស់យ៉ាងច្រើននោះ ពិតជាត្រឹមត្រូវមែន ។ លទ្ធផលនៃការប្រយុទ្ធនៅថ្ងៃនោះគឺអាមេរិកាំងដប់ប្រាំនាក់ និងខ្មែរច្រើនរាប់មិនអស់បានត្រូវស្លាប់ រោងចក្រចម្រាញ់ប្រេងកាតតែមួយគត់ និងយន្តហោះចម្បាំងមួយកងតូចរបស់កម្ពុជាត្រូវបំផ្លាញខ្ទេចខ្ទី ។ សម្រាប់ ហ្វ័រដ៍ រឿងនាវាម៉ៃយ៉ាហ្គេ គឺជាឱកាសលើកកម្ពស់ផ្លូវចិត្ត ដែលកំពុងទ្រេតទ្រោតបន្តិច នៅអាមេរិកឲ្យងើបត្រង់ឡើងវិញ បន្ទាប់ពីការដកថយទាំងអាម៉ាស់ពីទីក្រុងភ្នំពេញនិងក្រុងព្រៃនគរ ។ នេះជា«កម្ទេចភ្លើងដែលបញ្ឆេះឲ្យមានជំនឿទុកចិត្តឡើងវិញ» ។ សហរដ្ឋអាមេរិកទើបនឹងឆ្លងកាត់រយៈពេលដ៏ខ្មៅងងឹត មួយនៃសម័យកាលរបស់ខ្លួន ។ ដូច្នេះ «ព្រឹត្តិការណ៍នេះអាចបើកឱកាសឲ្យខ្លួនត្រឡប់ទំព័រ និងកំណត់ទិសដៅថ្មីៗទៀត»[៣] ។ អំណើះតទៅសហរដ្ឋអាមេរិកនឹងចំណាយពេលវេលាទាំងអស់របស់ខ្លួនដើម្បីរុំមុខរបួសកន្លងមក ។ អាមេរិកាំងបានបោះបង់ឥណ្ឌូចិនឲ្យវិលទៅរកភាពមិនប្រាកដប្រជាជាថ្មីម្ដងទៀត ។

សាច់រឿងនាវាម៉ៃយ៉ាហ្គេបានរលាយបាត់ពីទំព័រទីមួយនៃកាសែតនានាយ៉ាងឆាប់រហ័ស ។ តាមពិត អ្នកសរសេរអត្ថបទអត្ថាធិប្បាយរបស់កាសែតបានធ្វើការកត់សម្គាល់ខ្លះៗថា នេះគ្រាន់តែព្រឹត្តិការណ៍បន្ទាប់បន្សំប៉ុណ្ណោះនៅក្នុងជម្លោះមួយដែលគេនិយាយថារឹតតែធ្ងន់ធ្ងរជាងមុនទៅទៀត គឺបដិបក្ខភាពដណ្ដើមទឹកដីគ្នារវាងប្រទេសជិតខាងពីរដែលបញ្ឈប់យូរមកហើយ ។ ការប្រយុទ្ធចុងក្រោយដើម្បីស្ដារកិត្តិយសរបស់សហរដ្ឋអាមេរិកនៅឥណ្ឌូចិន បានជួយឲ្យមានការបិទបាំងសញ្ញាឲ្យដឹងដំបូងៗនៃសង្គ្រាមថ្មីមួយ លើកនេះជាសង្គ្រាមសម្លាប់តែបងប្អូនឯងដែលកំពុងចាប់ផ្ដើមរវាងអតីតសមមិត្តទាំងឡាយ ដែលកាលពីពេលថ្មីៗនេះ បានពួតដៃគ្នាប្រយុទ្ធទល់នឹងសត្រូវរួមគឺអាមេរិកាំង ។ ដ្បិតអីការចាប់នាវាម៉ៃយ៉ាហ្គេ បានកើតមានឡើងក្នុងជំហាននៃការវាយប្រហាររបស់ខ្មែរក្រហមទៅលើកោះទាំងឡាយក្នុងឈូងសមុទ្រ ដែលកាន់កាប់ដោយវៀតណាមដែរ ។ ទាហានខ្មែរក្រហមក្មេងៗដែលពុះពោរទៅដោយកំហឹង បានវាយប្រហារនាវាម៉ៃយ៉ាហ្គេជាមួយនឹងកាំភ្លើងអាកា៤៧របស់

*ខ្លួនប៉ុណ្ណោះ ។ តាមពិតគឺខ្មែរក្រហមចង់បង្ហាញឲ្យឃើញពីអធិបតេយ្យភាពទាំងស្រុងរបស់ខ្លួនជាថ្មីលើព្រំដែនសមុទ្ររបស់កម្ពុជាប៉ុណ្ណោះ ។*

## កោះទាំងឡាយដែលគេស្រក់ទឹកមាត់ចង់បាន

*វាជាបែបផែនធម្មជាតិមួយទៅហើយ ។ ថែមទាំងចៀសមិនរួចផងថា នៅក្រោយពេលមានការវាយប្រយុទ្ធដ៏ជោគជ័យមួយប្រឆាំងនឹងការកាន់កាប់របស់បរទេស អ្នកឈ្នះតែងតែប្រឹងប្រែងសម្តែងឲ្យឃើញនូវការត្រួតត្រាលើទឹកដីទាំងឡាយ ដែលគេទាមទារទុកដូចជាចំណែកមួយរួមបញ្ចូលទៅក្នុងបេតិកភ័ណ្ឌជាតិរបស់គេ ។ ប៉ុន្តែ ក្នុងករណីប្រទេសកម្ពុជា និងវៀតណាម វាជាវិបាកនៃការលេចឡើងជាថ្មីនូវការប្រកួតប្រជែង និងអធិករណ៍តាំងពីយូរមកហើយ ដែលលាក់ខ្លួនពីក្រោយពាក្យ “សាមគ្គីភាពបដិវត្តន៍” ដែលគ្រាន់តែមានលក្ខណៈបញ្ឆោតប៉ុណ្ណោះ ។*

*កាលបើក្តីសង្ឃឹមនៃជ័យជម្នះរបស់វៀតណាមខាងជើងនៅភាគខាងត្បូងចាប់លេចរូបរាងច្បាស់ហើយ ការផ្តើមគំនិតមួយក្នុងចំណោមការផ្តើមគំនិតជាច្រើនរបស់ក្រុងហាណូយ គឺ “រំដោះ” ប្រជុំកោះស្ព្រាតលីក្នុងសមុទ្រចិនខាងត្បូងពីការគ្រប់គ្រងរបស់របប ធីវ (ប្រធានាធិបតីសាធារណរដ្ឋវៀតណាមខាងត្បូង) និងប្រកាសទាមទារកោះប៉ារ៉ាសែល ដែលកាន់កាប់ដោយចិនជាសាធារណៈទៀត ។ តែក្នុងរវាងប៉ុន្មានសប្តាហ៍ប៉ុណ្ណោះក្រោយការដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានដាក់ពង្រាយទ័ពភ្ជាម ដើម្បីការពារព្រំដែនគោក និងសមុទ្រ ។ កងទ័ពជាច្រើនបានត្រូវបញ្ជូនទៅកាន់ឈូងសមុទ្រថៃ ដើម្បីកាន់កាប់ជាកម្មសិទ្ធនូវកោះនានាដែលរបបចាស់ធ្លាប់បានគ្រប់គ្រង ឬទាមទារជារបស់ខ្លួន ។*

*គោលដៅជាច្រើនក្នុងការធ្វើប្រតិបត្តិការទាំងនេះពុំមែនត្រឹមតែទាមទារទឹកដីប៉ុណ្ណោះទេ ។ បំណងរបស់ខ្មែរក្រហមដែលរៀបចំរដ្ឋអំណាចរបស់ខ្លួនឲ្យមានស្ថិរភាពលើទឹកដីទាំងមូលនោះ គឺការលើកជ្រោងទង់ឯករាជ្យភាពឡើងវិញប្រឈមមុខទល់នឹងអ្នកឧបត្ថម្ភគាំពារខ្លួនក្នុងសម័យសង្គ្រាម ។ តាមទស្សនៈនយោបាយមួយ ពេលវេលាបានមកដល់ហើយសម្រាប់អ្នកបដិវត្តន៍វៀតណាមនិងកម្ពុជាក្នុងការជ្រើសរើសមាគ៌ាដើររៀងៗខ្លួន ទោះជាពួកគេនៅខ្វែងគំនិតគ្នាខ្លះក៏ដោយ ដោយមិនឱបក្រសោបការវិនិច្ឆ័យផ្សេងៗដែលនាំឲ្យរំខានដល់ឯកភាពនិងសហប្រតិបត្តិការរបស់ខ្លួនដែលធ្លាប់មានក្នុងរយៈពេលធ្វើសង្គ្រាមឡើយ ។ តាំងពីជម្លោះផ្សេងៗរលត់ទៅវៀតណាមលែងរួញរានឹងពោលអះអាងពីការទាមទារទឹកដីរបស់ខ្លួនចំពោះមុខប្រទេសចិនទៀតហើយ ហើយកម្ពុជាក៏ធ្វើដូចនេះចំពោះប្រទេសវៀតណាមដែរ ។ មួយផ្នែក បដិបក្ខភាពជាប្រវត្តិសាស្ត្រដ៏ចាស់គំរឹលរវាងប្រទេសចិននិងវៀតណាម ហើយមួយផ្នែកទៀតរវាងប្រទេសវៀតណាមនិងកម្ពុជាធ្លាប់ត្រូវបង្ខំឲ្យនៅស្ងៀមស្ងាត់ដោយការធ្វើអាណានិគមរបស់បារាំងនិងអន្តរាគមន៍របស់អាមេរិកាំងនៅក្នុងតំបន់នេះ ។ អំណើះតទៅ រឿងនេះអាចចូលមកបំពេញចន្លោះ*

នៅខាងមុខឆាកដែលពីដំបូងផ្ទើឡើងដោយស្ងាត់ៗ បន្ទាប់មកប្រកបដោយភាពខ្លាំងក្លាមួយកាន់តែរីកធំឡើងៗ ។ ថ្វីបើកំពុងអះអាងពីការទាមទារទឹកដីតែរៀងៗខ្លួនជាចំហក៏ដោយ ក៏ដំណាក់កាលនេះ គ្មានរបបបដិវត្តន៍ណាមួយក្នុងចំណោមរបបបដិវត្តន៍ទាំងពីរបណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងជម្លោះមួយដែលមានទំហំធំដែរ ។ ភាពចាំបាច់ដែលពួកគេយល់ឃើញដូចគ្នាក្នុងការរៀបចំរដ្ឋអំណាចរបស់ខ្លួនក្នុងប្រទេស និងការដោះស្រាយបញ្ហាយ៉ាងច្រើនឥតគណនាបន្ទាប់ពីសម័យសង្គ្រាមបានបង្ខំឲ្យមានការខិតចូលជិតគ្នាមួយយ៉ាងប្រយ័ត្នប្រយែង ។ ម្យ៉ាងទៀតមេដឹកនាំចិនយ៉ាងសំខាន់ពីររូប ម៉ៅ សេទុង និង ជូ អេនឡាយ បានស្លាប់បាត់ទៅហើយ ។ បន្ទាប់ភ្លាមនោះប្រទេសចិនដែលជាតួឯកសំខាន់មួយក្នុងចំណោមតួឯកសំខាន់ៗនៃជម្លោះថ្មីនេះពុំយល់ព្រមឲ្យមានការយកចិត្តទុកដាក់ទាំងអស់ចំពោះបញ្ហាផ្សេងៗដែលកើតមាននៅតាមព្រំដែនភាគខាងត្បូងរបស់ខ្លួនឡើយ ។ ដូច្នេះ ដោយសារតែការជាប់រវល់ដោះស្រាយរឿងផ្ទៃក្នុងរបស់តួឯកទាំងនោះ ជម្លោះនេះបានកំណត់នូវការផ្អាកមួយរយៈពេល ។ ប៉ុន្តែ ការបារម្ភភ័យខ្លាចដែលដក់ជាប់យ៉ាងជ្រៅក្នុងផ្នត់គំនិតដែលពួកគេមានទៅវិញទៅមក មហិច្ឆតានិងភាពសមហេតុផលនៃនយោបាយក្នុងនិងក្រៅប្រទេសដែលខុសគ្នាយ៉ាងខ្លាំងនោះ បានបង្ខំឲ្យប្រទេសកម្ពុជានិងចិនធ្លាក់ទៅក្នុងការប្រឈមមុខដាក់គ្នាមួយជាមួយប្រទេសវៀតណាមយ៉ាងឆាប់រហ័ស ។

ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ប្រាំថ្ងៃមុនការដើរចូលក្រុងភ្នំពេញប្រកបដោយជោគជ័យរបស់ខ្មែរក្រហម មេដឹកនាំម្នាក់ក្នុងបណ្ដាមេដឹកនាំនៃចលនាតស៊ូគឺ អៀង សារី កំពុងស្ថិតនៅខេត្តក្វាងទ្រី (Quang Tri) វៀតណាមខាងត្បូងឯណោះ ។ សារី មានដើមកំណើតចេញពីគ្រួសារខ្មែរក្រោមមួយ ហៅម្យ៉ាងទៀតថា ជនជាតិភាគតិចខ្មែរ នៅដែនដីសណ្ដទន្លេមេគង្គនៃប្រទេសវៀតណាម ។ គាត់បានក្លាយទៅជាជនម៉ាក្សស៊ីសនិយមម្នាក់ក្នុងរយៈពេលដែលគាត់សិក្សានៅក្រុងប៉ារីស នាទសវត្សរ៍៥០ ហើយរួមជាមួយនឹងនិស្សិតដទៃទៀត ដែលមានទាំង ប៉ុល ពត ផងនោះ គាត់បានបង្កើតក្រុមតស៊ូផ្នែកនយោបាយនិយមកុម្មុយនីស្តមួយនៅទីនោះ ។ ក្រោយមកគាត់បានក្លាយទៅជាមនុស្សទីពីររបស់ខ្មែរក្រហមថែមទៀតគឺ «បងទី២» ដ៏គួរឲ្យព្រឺខ្លាច ។ ក្នុងបទសម្ភាសន៍មួយនៅឆ្នាំ១៩៨០ សារី បានរៀបរាប់ប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា គាត់បានធ្វើដំណើរឆ្លងកាត់តំបន់ដែលទើបនឹងរំដោះបានថ្មីៗនៅវៀតណាមខាងត្បូង ដើម្បីទៅកាន់ទីក្រុងប៉េកាំងតាមតំបន់រំដោះរបស់កម្ពុជានៅពេលគាត់បានទទួលទូរលេខមួយរបស់ក្រុងហាណូយ ដែលប្រាប់ឲ្យគាត់ដឹងពីការដកថយរបស់អាមេរិកាំង ។ សម្រាប់ សារី ផ្លូវនៅសល់ដែលគាត់ត្រូវធ្វើដំណើរគឺ ផ្លូវលំហូជីមិញដ៏សែនពិបាកស្មុគស្មាញជាពិសេសក្នុងការឆ្លងកាត់ព្រៃកនានាដែលមានទឹកហូរខ្លួលខ្មាញ់ក្នុងខេត្តរតនគិរីរបស់កម្ពុជានោះ គឺគ្រាន់តែដើម្បីស្គាល់ប៉ុណ្ណោះ ។ ក្នុងអំឡុងពេលសង្គ្រាម គាត់ធ្លាប់បានរស់នៅប្រទេសវៀតណាមជាច្រើនឆ្នាំ ដោយពុះពារតស៊ូនឹងគ្រោះថ្នាក់ជាច្រើនលើកក្នុងការដើរឆ្លងកាត់ទៅមករវាងប្រទេសទាំងពីរ ។ ប៉ុន្តែដំណឹងស្ដីពីការដួលរលំនៃទីក្រុងភ្នំពេញដែលច្បាស់ជាកើតមានក្នុងពេលឆាប់ៗ បានផ្លាស់ប្ដូរអ្វីៗទាំងអស់ ។ តែក្នុងរយៈពេលដ៏ខ្លី ផ្លូវលំហូជីមិញដែលជាផ្លូវទាក់ទងដ៏សំខាន់

បំផុតជាមួយបដិវត្តន៍កម្ពុជា បានប្រែជាលែងមានប្រយោជន៍ទាំងស្រុង ។ ជំនួសការបន្តដំណើរឆ្លងកាត់ជួរភ្នំអាណ្ណាម តាមរថយន្តហ្ស៊ីបដែលធ្វើឲ្យនឿយលំបាកស្ទើរបាក់ចង្កេះនោះ សារី បានប្រែគំនិតធ្វើដំណើរតាមយន្តហោះទៅក្រុងហាណូយវិញ ហើយចេញពីទីនោះគាត់បន្តដំណើរឆ្ពោះទៅក្រុងប៉េកាំងទៀត ។ គាត់បានមកដល់ក្រុងភ្នំពេញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ តាមយន្តហោះ ប៊ូអ៊ីង៧០៧ របស់ចិនមួយគ្រឿង ដែលនេះជាយន្តហោះបរទេសដំបូងបំផុតដែលមកចុះចតនៅប្រទេសកម្ពុជាថ្មី ។ សម័យកាលនៃផ្លូវលំហូជីមិញបានគោចរមកបញ្ចប់ត្រឹមនេះ ។

អ្វីដែល សារី ពុំបាននិយាយប្រាប់ខ្ញុំនៅពេលធ្វើសម្ភាសន៍នោះ គឺថាក្នុងរយៈពេលនៃដំណើរឆ្លងកាត់ដ៏ខ្លីរបស់គាត់នៅទីក្រុងប៉េកាំង គាត់បានជួបពិភាក្សាជាមួយពួកមេដឹកនាំចិនអំពីការពង្រឹងកងទ័ពរបស់កម្ពុជា ឲ្យរឹតតែរឹងមាំឡើងទៀត ។ គាត់បានស្នើសុំឲ្យពួកចិនបញ្ឈប់ការផ្គត់ផ្គង់អាវុធនិងសម្ភារយោធា តាមមធ្យោបាយដូចសព្វដងទៀតទៅគឺកុំឲ្យធ្វើតាមរយៈវៀតណាម ។ ពីរបួនសប្ដាហ៍ក្រោយមក នាវាធំៗរបស់ចិនជាច្រើនគ្រឿងដែលផ្ទុកស្រូវ ប្រេងឥន្ធនៈ និងគ្រឿងឧបភោគបរិភោគ បានចូលមកចតនៅកំពង់ផែកំពង់សោម ។

ប៉ុន្តែមុនការមកដល់របស់នាវាចិនទាំងនេះ ដែលបញ្ចប់ជានិមិត្តរូបមួយនូវភាពឯកោរបស់ប្រទេសកម្ពុជាបដិវត្តន៍ ខ្មែរក្រហមបានតវ៉ាជំទាស់នឹងការត្រួតត្រារបស់វៀតណាមលើកោះទាំងឡាយក្នុងឈូងសមុទ្រថៃស្រេចទៅហើយ ។ ដោយយកមកប្រើឡើងវិញនូវការទាមទារពីមុនមួយរបស់កម្ពុជាទាក់ទងនឹងកោះភូកុក ខ្មែរហៅកោះត្រល់ ខ្មែរក្រហមបានវាយលុកតាមផ្លូវសមុទ្រចូលត្រួតត្រាលើកោះនោះយ៉ាងរហ័ស ។ កងទ័ពទាំងនោះបានឡើងទៅលើកោះនៅថ្ងៃ៤ ខែឧសភា ឆ្នាំ១៩៧៥ ។ ប្រាំមួយថ្ងៃក្រោយមក ខ្មែរក្រហមបានវាយយកកោះពូឡូប៉ង់ហ្សង់ វៀតណាមហៅ ថូ ជូ ខ្មែរហៅកោះក្រចកសេះថែមទៀត ។ ក្រោមការគំរាមកំហែងនៃអាវុធប្រជាជនវៀតណាម៥០០នាក់បានត្រូវបណ្ដេញចេញពីទីនោះ ។ ពីរសប្ដាហ៍ក្រោយការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកមួយសងទៅវិញដោយបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់បាន៣០០នាក់ជាឈ្លើយសឹក[៤] ។

អៀង សារី បានរៀបរាប់ប្រាប់អ្នកមានសមានចិត្តអាមេរិកាំងមួយក្រុមថា ការចាប់នាវា ម៉ៃយ៉ាហ្គេកាលពីថ្ងៃទី១២ ខែឧសភា គឺជាការសម្រេចដោយឯកចិត្តដែលធ្វើឡើងដោយអ្នកទទួលខុសត្រូវខាងយោធាម្នាក់នៅមូលដ្ឋាននោះ ដោយគ្មានសួរយោបល់ក្រុងភ្នំពេញឡើយ[៥] ។ វាអាចថា ពួកកម្មាភិបាលដែលចូលចិត្តឈឺឆ្អាលនឹងការងារបានប្រព្រឹត្តជ្រុលហួសពីបទបញ្ជាក្នុងភារកិច្ចការពារទឹកដីកម្ពុជា ដើម្បីវាយប្រហារទៅលើកោះទាំងឡាយរបស់វៀតណាមផងដែរ ។ ប៉ុន្តែ អ្វីដែលទំនងបំផុតគឺថា បទបញ្ជាតែងតែត្រូវផ្ដល់ពីថ្នាក់លើទៅក្រោមជានិច្ច ។ ដោយពិត ខ្មែរក្រហមប្រហែលជាជឿថា ការកាន់កាប់កោះទាំង នោះនឹងបានទៅជាឧទ្ទិករណ៍មួយសម្រាប់ជួយពង្រឹងដល់ការសម្រេចផ្សេងៗក្នុងករណីដែលកើតមានវិវាទកម្មទឹកដីរវាងប្រទេសទាំងពីរ ។

*តាំងពីដើមមក ជនជាតិខ្មែរមិនដែលយល់ព្រមបោះបង់កោះទាំងនោះ ជាគុណប្រយោជន៍ដល់កូសាំងស៊ីនរបស់បារាំង បន្ទាប់មកដល់សាធារណរដ្ឋវៀតណាមសោះឡើយ ។ នៅឆ្នាំ១៩៦០ សម្តេចព្រះ នរោត្តម សីហនុ ដែលពេលនោះជាព្រះប្រមុខរដ្ឋកម្ពុជាធ្លាប់បានសាកល្បងដោយឥតបានការ ដើម្បីទាមទារយកកោះត្រល់ពីវៀតណាមមកវិញតាមរយៈផ្លូវទូតដែរ ។ នៅពេលនោះ សម្តេចបានថ្លែងរបៀបជាការព្រមានថា "ការបាត់បង់កោះទាំងនោះនិងដែនសមុទ្រដែលព័ទ្ធជុំវិញ អាចបណ្តាលឲ្យកំពង់ផែកំពង់សោមត្រូវថប់ដង្ហើម…និងក្នុងរយៈពេលដ៏ខ្លីគឺទីបញ្ចប់នៃឯករាជ្យរបស់យើង"[៦] ។*

*ក្នុងភាពច្របូកច្របល់ដែលកើតមានបន្តបន្ទាប់ពីការដួលរលំនៃទីក្រុងព្រៃនគរ ខ្មែរក្រហមទំនងជាគិតឃើញថា ពេលវេលាបានមកដល់ហើយដើម្បីសម្រេចទាមទារទឹកដីទាំងឡាយរបស់ខ្លួនតាមរយៈការចូលកាន់កាប់ដោយកម្លាំងទ័ពតែម្តង ។ ប៉ុល ពត អតីតនិស្សិតដែលទៅទីក្រុងប៉ារីសធ្វើការសិក្សាខាងផ្នែកវិទ្យុអគ្គិសនី ហើយប្រលងមិនជាប់នោះគឺជាអ្នកម៉ាក្សស៊ីសនិយមដែលងប់នឹងទ្រឹស្តីកុម្មុយនីស្តហួសហេតុ បានក្លាយទៅជាអគ្គលេខាបក្សកុម្មុយនីស្តកម្ពុជានៅដើមទសវត្សរ៍៦០ ។ ពេលនេះគាត់អាចដាក់ឲ្យអនុវត្តនូវគំនិតដែលចង់ឲ្យមានការកែទម្រង់ដាច់ខាតខាងនយោបាយនិងការស្អប់ខ្ពើម (ដោយមិនដឹងរឿងអ្វី) ដែលកប់យ៉ាងជ្រៅក្នុងចិត្តរបស់គាត់ចំពោះប្រទេសវៀតណាមដែលជាសត្រូវគ្មានទីបំផុត ។ បន្ទាប់ពីការវាយដណ្តើមយកទីក្រុងភ្នំពេញបានភ្លាម ប៉ុល ពត បានចេញមតិណែនាំ(ឬសារាចរ)មួយមាន៨ចំណុច ក្នុងនោះមាន២ចំណុចដែលបញ្ញត្តិឲ្យធ្វើការបណ្តេញអាណិកជនវៀតណាមទាំងអស់ចេញពីកម្ពុជា និងការបញ្ជូនទ័ពទៅកាន់ព្រំដែន ជាពិសេសព្រំដែនវៀតណាម[៧] ។ ប៉ុន្តែភាពអមនុស្សធម៌នៃប្រតិកម្មរបស់វៀតណាម បាននាំឲ្យមានការពិនិត្យឡើងវិញនូវមូលកភាព (ភាពសមហេតុផល) នៃវិធានការមួយដែលត្រូវធ្វើឡើងដោយប្រញាប់ដូចគ្នា ។ ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៥ ង្វៀន វ៉ាន់លិញ សមាជិកការិយាល័យនយោបាយមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម បានធ្វើដំណើរមកក្រុងភ្នំពេញតាមរថយន្តដើម្បីជួប ប៉ុល ពត ពិភាក្សាគ្នាពីរឿងនេះ ។ ក្នុងភាពស្មោះត្រង់ពីក្នុងដួងចិត្ត ប៉ុល ពត បានការពារខ្លួនដោយព្រមទទួលស្គាល់កំហុសនេះ និងសម្តែងការសោកស្តាយរបស់គាត់ផងដែរ ។ នៅចំពោះមុខ លិញ គាត់បានទទួលស្គាល់ការពិតនៃការចូលលុកលុយរបស់កម្ពុជា ប៉ុន្តែ គាត់បានអះអាងថា "ការប្រឈមមុខដ៏ខ្លោចផ្សានិងដ៏បង្ហូរឈាមនេះ" គឺបណ្តាលមកពី"យុទ្ធជនកម្ពុជាមិនសូវស្គាល់ភូមិសាស្ត្រតំបន់នោះ" ។*

## "ចម្ងល់, សរុបទៅគឺចម្ងល់…"

*វៀតណាមមិនជឿសម្តីដំបូងៗនេះទេ ។ ពិតណាស់ ប៉ុល ពត គឺជាមនុស្សដែលត្រូវគេទទួលស្វាគមន៍រាក់ទាក់នៅទីក្រុងហាណូយ ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ វៀតណាមបានបើកការវាយលុកមួយទាំងជើងអាកាស ទាំងជើងទឹកទៅលើកោះពូឡូវៃរបស់កម្ពុជាជាថ្មី ។ នៅពេលដែល ប៉ុល ពត ដែលអមដំណើរដោយ*

អៀង សារី អគ្គលេខាបក្សរង នួន ជា និងមេដឹកនាំមួយចំនួនទៀតទៅដល់ក្រុងហាណូយ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៥ ដើម្បីធ្វើ«ទស្សនកិច្ចជាបងប្អូន»មួយនោះ អ្វីៗបានចប់ស្រេចទៅហើយ នៅកោះពូឡូវៃ ដែលទង់ជាតិវៀតណាមបានបក់រវិចនៅទីនោះជាស្រេច ។ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៥ ដោយនិយាយបន្តពីការមិនចេះទប់មាត់របស់ពួកភ្នាក់ងារសម្ងាត់អាមេរិកាំង កាសែតញូវយ៉ កថែមបានផ្សព្វផ្សាយជាសាធារណៈពីការដណ្តើមបានកោះនេះ ។ ភាពដំណាលគ្នានៃទស្សនកិច្ចរបស់ ប៉ុល ពត នៅហាណូយ ជាមួយនឹងរឿងនេះទាល់តែប្រហែលបីឆ្នាំក្រោយមកទើបបានគេដឹងពុ ។

អៀង សារី បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ) នៅពេលក្រោយមកទៀតថា ក្នុងឱកាសនៃការជួបពិភាក្សាជាច្រើនលើក គណៈប្រតិភូរបស់គាត់បានលើកឡើងពីបញ្ហាជម្លោះព្រំដែនជាមួយនឹងវៀតណាមដែរ ប៉ុន្តែឥតបានការ ។ តាមគាត់ឲ្យដឹងថា កម្ពុជាប្រាថ្នាឈានឲ្យដល់កិច្ចព្រមព្រៀងមួយដោយផ្អែកលើមូលដ្ឋាននៃសេចក្តីប្រកាសនៅឆ្នាំ១៩៦៧ របស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (គឺប្រទេសវៀតណាមខាងជើង) ដែលកាលណោះបានទទួលស្គាល់កម្ពុជាក្នុង«ព្រំដែនបច្ចុប្បន្ន» ដែលស្នើឡើងដោយ សម្តេចព្រះ នរោត្តម សីហនុ ។ ប៉ុន្តែវៀតណាមបានប្រឆាំងជំទាស់គ្រប់ការជជែកពិភាក្សាទាំងអស់ ។ សេចក្តីប្រកាសទាំងឡាយរបស់វៀតណាម ដែលមានក្រោយៗមកទៀតបានប្រើប្រាស់ការបកស្រាយមួយផ្សេងទៅវិញ ៈ បើកម្ពុជាពិតជាចង់សម្រេចកិច្ចព្រមព្រៀងមិត្តភាពមួយ ដោយផ្តោតជាពិសេស ទៅលើកិច្ចការជំនួញ ទំនាក់ទំនងផ្នែកកុងស៊ុល និងការកម្រិតព្រំដែននោះ វានឹងគ្មានការចរចាក្លាមៗស្តីពីរឿងព្រំដែនឡើយ ។ ការគិតធ្វើឲ្យបានសម្រេចកិច្ចព្រមព្រៀងមិត្តភាពមួយដែលលើកឡើងដោយពួកខ្មែរក្រហម ដើម្បីសាកល្បងបន្ទន់ចិត្តវៀតណាមនឹងធ្វើឲ្យវៀតណាមទទួលស្គាល់ភាពមិនអាចប៉ះពាល់បាននៃព្រំដែនប្រទេសទាំងពីរឬយ៉ាងណា? រឿងនេះមិនដែលត្រូវលើកយកមកជជែកគ្នាទាល់តែសោះ[៨] ។

ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៥ ឡេយន់ អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម ផាំហ៊ុង សមាជិកការិយាល័យនយោបាយ និង ស៊ន់ធុយ មនុស្សជើងចាស់ក្នុងកិច្ចចរចាសន្តិភាពក្រុងប៉ារីសបានឡើងយន្តហោះឆ្ពោះមកក្រុងភ្នំពេញដើម្បីធ្វើទស្សនកិច្ចខ្លីមួយ ។ ក្រោយពីបានបង្ហាញឲ្យកម្ពុជាឃើញពីកម្លាំងយោធារបស់ខ្លួនមួយគ្រួសរួចមក វៀតណាមអាចបង្ហាញឲ្យឃើញភ័ស្តុតាងនៃភាពទន់ភ្លន់របស់ខ្លួនម្តង ។ ឡេយន់ ដែលជាសមាជិកស្ថាបនិកបក្សកុម្មុយនីស្តឥណ្ឌូចិន ហើយមុននឹងកាន់មុខតំណែងជាអគ្គលេខាបក្សរបស់វៀតណាម គាត់ធ្លាប់បានរស់នៅក្នុងគុកដប់ឆ្នាំ និងធ្លាប់បានដឹកនាំចលនាបដិវត្តន៍នៅវៀតណាមខាងត្បូងអស់រយៈពេលជាច្រើនឆ្នាំទៀត ។ ខុសប្លែកពីសហការីគាត់ ផាំហ៊ុង គឺជាមនុស្សភាគខាងត្បូង ធាត់ដុះក្បាលពោះ ហើយធ្លាប់បានដឹកនាំធ្វើការប្រយុទ្ធនៅភាគខាងត្បូងនិងរក្សាការទាក់ទងជាមួយមេដឹកនាំខ្មែរក្រហមដែលនៅព្រំដែនម្ខាងទៀត ។ នេះគឺជាលើកទីមួយហើយដែល ឡេយន់ ធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ។ កាលដែលអ្នកទាំងពីរមកកាន់ក្រុងភ្នំពេញ

គឺពុំមែនមកធ្វើទេសចរណ៍ទេ ។

គណៈប្រតិភូវៀតណាមបានចាកចេញពីក្រុងភ្នំពេញ ដែលក្លាយទៅជាទីក្រុងខ្មោចមួយទៅហើយ តាំងពីមានការជម្លៀសប្រជាជនរបស់ខ្លួនទាំងអស់ចេញទាំងកំរោលកាលពីខែមេសា ។ តាមការស្នើសុំរបស់កម្ពុជា របាយការណ៍ផ្សេងៗស្ដីពីទស្សនកិច្ចនេះត្រូវបានកាត់បំព្រួញជាអតិបរមា[៩] ។ បើទុកជាការទទួលភ្ញៀវយ៉ាងសោះកក្រោះដែលត្រៀមបម្រុងសម្រាប់គាត់ក៏ដោយ ក៏ ឡេយន់ នៅតែបង្ហាញឲ្យឃើញថា គាត់ជាមនុស្សដែលងាយស្រុះស្រួលជានិច្ច ។ គាត់ទទួលស្គាល់ថា កោះពូឡូវៃ ពិតជាចំណែកមួយនៃទឹកដីរបស់កម្ពុជាប្រាកដមែន ហើយគាត់បានសន្យានឹងប្រគល់ឲ្យវិញក្នុងពេលឆាប់ៗ ។ សេចក្ដីថ្លែងការណ៍រួមមួយត្រូវបានភាគីទាំងពីរចុះហត្ថលេខា ក្នុងនោះភាគីនីមួយៗបានសន្យាធ្វើការដោះស្រាយអធិករណ៍របស់ខ្លួនតាមរយៈការចរចាគ្នា ប៉ុន្តែសេចក្ដីថ្លែងការណ៍នេះពុំដែលត្រូវប្រកាសផ្សាយឲ្យដឹងឮជាសាធារណៈទាល់តែសោះ ហើយក៏ពុំមានការលៀងសាយភោជន៍ និងការថ្លែងសុន្ទរកថាជាកិច្ចគួរសមដែរ ។ របាយការណ៍ខ្លីកំបុតមួយនៃទស្សនកិច្ចនេះត្រូវបានផ្សាយបន្តដំណាលគ្នា ដោយវិទ្យុហាណូយនិងវិទ្យុភ្នំពេញនៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៥ ៖ "ការផ្លាស់ប្ដូរយោបល់គ្នាដ៏ស្មោះស្ម័គ្របានប្រព្រឹត្តទៅរវាងវៀតណាម និងគណៈប្រតិភូកម្ពុជាមួយក្រុមក្នុងបរិយាកាសមួយប្រកបដោយភាតរភាពជាបងប្អូន ។ ការផ្លាស់ប្ដូរយោបល់ទាំងនោះបានផ្ដោតទៅលើបញ្ហាផ្សេងៗ ដែលជាផលប្រយោជន៍រួមរវាងប្រទេសទាំងពីរដោយស្មើភាពគ្នា"[១០] ។

បើសិនជាភាពស្មោះអស់ពីដួងចិត្តក្នុងការពិភាក្សាផ្សេងៗ មានបង្កប់ទៅដោយពាក្យភូតកុហកនោះ បរិយាកាសមុខជាឆេះឆួលជាថ្មី ប៉ុន្តែបែរជាចុះថយបន្តិចទៅវិញ នៅពេលដែលវៀតណាមសម្រេចប្រគល់កោះពូឡូវៃមកឲ្យកម្ពុជា ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៥ ង្វៀន វ៉ាន់លិញ បានជួប នួន ជា មេដឹកនាំជាន់ខ្ពស់ម្នាក់ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់របស់បក្សកម្ពុជា ដើម្បីផ្ដល់ព័ត៌មានពីការដកថយរបស់កងទ័ពវៀតណាមចេញពីកោះនោះ ។ នួន ជា បានថ្លែងអំណរគុណប្រទេសវៀតណាមចំពោះការសម្រេចចិត្តនេះ ហើយបានបញ្ជាក់ថា "កំហុសក្នុងការមិនស្គាល់ព្រំដែន"[១១] នោះហើយដែលជាមូលហេតុនាំឲ្យមានព្រឹត្តិការណ៍ឈ្លោះទាស់ទែងគ្នានេះ ។ តាមពិត មូលហេតុដើមនៃការពើបប្រយុទ្ធស៊ីសាច់ហុតឈាមដែលកើតមានជាបន្តបន្ទាប់ក្រោយជ័យជម្នះនោះ គឺមកពីការផ្ដោតចិត្តខ្លាំងពេកចំពោះបញ្ហាព្រំដែននិងគំនិតជាតិនិយមដ៏ពុះពោរនៃភាគីទាំងពីរនេះឯង ។

ប៉ុន្តែក្នុងចំណោមប្រទេសទាំងពីរ គ្មានប្រទេសណាមួយចាប់ផ្ដើមមុនគេក្នុងការប្រឈមមុខគ្នានេះឡើយ ។ ជាពិសេសខាងវៀតណាមបានរក្សាទុកជម្លោះនេះមិនឲ្យសាធារណៈមតិដឹងឮទេ ។ ដោយខំប្រឹងបំបាត់ឧបសគ្គផ្សេងៗ ដែលជួនកាលប្រើកម្លាំង ជួនកាលប្រើនយោបាយការទូតផងនោះ ក្រុងហាណូយបានសម្រេចចិត្តថែរក្សាសាមគ្គីភាពមួយដែលមានតែសំបកក្រៅ ជាមួយក្រុងភ្នំពេញជាបន្តទៅទៀត ។

នៅខែកក្កដា ឆ្នាំ១៩៧៥ បន្ទាប់ពីការស្នាក់នៅពីរខែកន្លះក្នុង“ក្រុងព្រៃនគររំដោះ” ខ្ញុំបានជិះយន្តហោះឆ្ពោះទៅក្រុងហាណូយទៀតមុននឹងចាកចេញពីប្រទេសវៀតណាម ។ ក្នុងឱកាសនៃការសម្ភាសន៍ជាមួយ វ៉ាង ទុង អគ្គនិពន្ធនាយកទិនានុប្បវត្តិ ញ៉ានហ្សិន របស់បក្សកុម្មុយនីស្តវៀតណាម ខ្ញុំបានស៊ើបសួរព័ត៌មានអំពីស្ថានភាពនៃទំនាក់ទំនងជាមួយប្រទេសកម្ពុជាដែរ ។ គាត់បានឆ្លើយយ៉ាងរហ័សប្រាប់ខ្ញុំថា “ធម្មតា” ។ បន្ទាប់ពីឈប់មួយស្របក់ គាត់បានបន្ថែមថា : “សរុបទៅគឺធម្មតា” ។ គាត់បានបដិសេធព័ត៌មានមួយស្តីពីការប្រឈមមុខដាក់គ្នារវាងប្រទេសកម្ពុជានិងវៀតណាមនៅក្នុងឈូងសមុទ្រថៃដែលមានចុះផ្សាយដោយសារព័ត៌មានលោកខាងលិច ។

ក្នុងពេលដែលខ្ញុំកំពុងសន្ទនាជាមួយ ទុង ក្នុងការិយាល័យមិនសូវភ្លឺរបស់គាត់ដែលលេចត្រដែតពីបឹងហ័នគៀម នៅក្រុងហាណូយ មានជនជាតិវៀតណាមរាប់ពាន់នាក់-ប្រុសស្រី និងកូនក្មេងបានត្រូវបណ្តេញចេញពីកម្ពុជាឆ្ពោះទៅដែនដីសណ្តទន្លេមេគង្គនៅវៀតណាមខាងត្បូង ។ នៅត្រង់ព្រំដែនអ្នកទាំងនោះត្រូវបានកងឯកភាពវៀតណាមរ៉ាប់រងបន្ទុក និងរៀបចំឲ្យរស់នៅក្នុងជំរំបណ្តោះអាសន្នជាច្រើនកន្លែងដែលកសាងឡើងដោយរដ្ឋាភិបាល ។ អ្នកភៀសខ្លួនកម្ពុជាដែលមានដើមកំណើតវៀតណាមនិងចិនជាច្រើនរយនាក់បានសម្រេចចូលទៅរស់នៅក្នុងវត្តមួយនៅច្រឹឡឹងដោយខ្លួនឯង ។ អ្នកឆ្លងឆ្លើយព័ត៌មាននៃទីភ្នាក់ងារព័ត៌មានបារាំងអាអេហ្វប៉េឈ្មោះ ឆាល អង់តង់ន ដឺ ណៃស៊ីយ៉ាត់ មិននឹកស្មានថាខ្លួនអាចទទួលបានព័ត៌មានសំខាន់ផ្តាច់មុខមួយដូច្នេះឡើយ នៅពេលដែលគាត់ឃើញពីចម្ងាយនូវអ្នកភៀសខ្លួនចេញពីកម្ពុជាបដិវត្តន៍ជាបងប្អូនមករស់នៅក្នុង “ព្រៃនគររំដោះ”នោះ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារការប្រុងប្រយ័ត្នរបស់ផ្នែកត្រួតពិនិត្យវៀតណាម ទូរលេខរបស់គាត់មិនដែលត្រូវគេបញ្ជូនទៅគោលដៅដែលត្រូវផ្ញើសោះឡើយ ។ ភាពគាប់ជួនដែលគួរឲ្យអស់សំណើចគឺនៅថ្ងៃដដែលនោះ ប៉ុល ពត បានទៅដល់ក្រុងហាណូយក្នុងសភាពអាថ៌កំបាំងបំផុត ។ តើអ្នកត្រួតពិនិត្យត្រូវគេប្រាប់ឲ្យដឹងពីទស្សនកិច្ចនេះឬទេ? វាពិបាកនឹងនិយាយណាស់ ។ ទុកជាយ៉ាងណាក៏ដោយ ក៏វៀតណាមមិនបណ្តោយឲ្យពួកអ្នកកាសែតរបស់សារព័ត៌មានគហបតីលាតត្រដាងពីរឿងគួរឲ្យខ្ពើមរអើមនៃអ្នកភៀសខ្លួនហើយធ្វើឲ្យស្មុគស្មាញដល់ទំនាក់ទំនងផ្សេងៗជាមួយកម្ពុជាដែរ ។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៧៨ ទើបការពិតចាប់ផ្តើមលេចឡើងដោយខ្លួនឯង ។ នៅខែមីនានៃឆ្នាំដដែលនេះ(១៩៧៨) ក្នុងឱកាសនៃដំណើរមួយទៅកាន់តំបន់នានាតាមព្រំដែន ខ្ញុំបានដឹងទាំងភ្ញាក់ផ្អើលថា ក្នុងអំឡុងប្រាំខែបន្ទាប់ពី“ការរំដោះ”ក្រុងភ្នំពេញជនជាតិវៀតណាមជាង១៥០.០០០នាក់ ដែលត្រូវដកហូតទ្រព្យសម្បត្តិអស់ពីខ្លួនបានហូរចូលមកក្នុងខេត្តដុងថាប អានយ៉ាង និង តាយនិញ យ៉ាងកុះករ ។ អ្នកដែលមានដើមកំណើតជាវៀតណាមត្រូវបានអនុញ្ញាតឲ្យស្ថិតនៅ ប៉ុន្តែអ្នកភៀសខ្លួនដែលមានដើមកំណើតជាចិននិងខ្មែរត្រូវបានរុញច្រានមកកម្ពុជាវិញ ។

វត្តមានអែបមកខាងក្រុងភ្នំពេញនូវមិត្តដ៏មានអំណាចមួយប្រហែលជាជួយពង្រឹងកន្ទល់ក្នុងការប្រុងប្រយ័ត្នថែមទៀត ដែលសម្តែងឲ្យឃើញដោយវៀតណាម ។ ម្យ៉ាងទៀតក្រុងប៉េកាំងគឺជាដំណាក់កាលទី២នៃ

ដំណើរសម្ងាត់របស់ ប៉ុល ពត បន្ទាប់ពីក្រុងហាណូយ ។ នៅថ្ងៃទី២១ ខែមិថុនា ប៉ុល ពត ត្រូវបានទទួលបដិសណ្ឋារកិច្ចរបៀបជាវីរបុរសដោយប្រធាន ម៉ៅ ដែលជាមគ្គុទ្ទេសក៍មនោគមវិជ្ជារបស់គាត់ ។ ម៉ៅ បានថ្លែងប្រាប់ "សាវ័ក" ដែលមានទឹកមុខស្រស់ប៉ប្រៃរបស់គាត់ថា "ជាមួយប្រជាពលករកម្ពុជា លោកបានសម្រេចជោគជ័យក្នុងការប្រយុទ្ធលើកដំបូងតែម្តង ចំណែកយើងបែរជាបរាជ័យ"[១២] ។ ក្នុងពេលដែល"មហាមគ្គុទ្ទេសក៍" នេះកំពុងនិយាយ ប្រជាជនកម្ពុជារាប់រយពាន់នាក់ដែលត្រូវបណ្តេញចេញទាំងកំរោលពីទីក្រុងនានា ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុង"ជំរំប្រមូលផ្តុំ"នានាដែលមាននៅពាសពេញផ្ទៃប្រទេស របៀបជំរំ ហ្គូឡាក់ នៅអតីតសហភាពសូវៀតដែរ (Goulag ជាអក្សរកាត់នៃពាក្យរុស្ស៊ី អក្សរពេញគឺ *Glavnoïe Oupravlenie Laguereï* = *direction générale des camps* = មន្ទីរចាត់ការទូទៅសម្រាប់គ្រប់គ្រងជំរំ គឺជាប្រព័ន្ធប្រមូលផ្តុំមនុស្សឬបង្ក្រាបមនុស្សរបស់អតីតសហភាពសូវៀតនិងបណ្តាប្រទេសដែលជារណបរបស់ខ្លួន-កំណត់របស់អ្នកបកប្រែ) ។

ម៉ៅ អបអរសរសើរទាំងស្រុងចំពោះយុទ្ធសាស្ត្របដិវត្តន៍របស់ ប៉ុល ពត និងបំណងដើរតាមផ្លូវមួយដាច់ដោយឡែកពីផ្លូវរបស់វៀតណាម ។ ការជួបសន្ទនាគ្នានេះ ពីរឆ្នាំក្រោយមកទៀតទើបត្រូវបានផ្សព្វផ្សាយឲ្យដឹងជាសាធារណៈនៅពេលដែល ប៉ុល ពត ទម្លាក់របាំងមុខចុះនិងទទួលស្គាល់តួនាទីរបស់គាត់ ជាអគ្គលេខាបក្សពេញលក្ខណៈ ។ ពិតណាស់ វៀតណាមគ្មានដឹងពីការស្ងើចសរសើរយ៉ាងខ្លាំងដែល ម៉ៅ ផ្តល់ទៅលើខ្មែរក្រហមសោះឡើយ ។ ជាឧទាហរណ៍ នៅឆ្នាំ១៩៧៥ ម៉ៅ បានទូន្មានមេដឹកនាំវៀតណាមមួយរូបថា "ត្រូវរៀនសូត្រតាមកម្ពុជាពីរបៀបដឹកនាំការបដិវត្តន៍មួយយ៉ាងប្រសើរ"[១៣] ។

មិត្តភាពរវាងប្រទេសចិនរបស់ ម៉ៅ និងកម្ពុជាប្រជាធិបតេយ្យផ្អែកលើភាពដូចគ្នាខាងមនោគមវិជ្ជា និងជាពិសេសលើភាពស្របគ្នានៃផលប្រយោជន៍ជាតិរៀងៗខ្លួន ។ ប៉ុល ពត និងបណ្តាមិត្តរបស់គាត់ដែលស្ងើចសរសើរដោយគ្មានព្រំដែនមួយចំពោះទ្រឹស្តីម៉ៅក្នុង "ការតស៊ូវណ្ណៈ" និង "ការធ្វើបដិវត្តគ្មានឈប់ឈរ"នោះ គឺមកពីការក្រែងរអែង និងការភ័យខ្លាចសហភាពសូវៀតដូចគ្នា ។ ក្នុងលំដាប់ដែលការប្រឆាំងជំទាស់ចំពោះការគ្របសង្កត់របស់វៀតណាមមកលើជ្រោយឥណ្ឌូចិនក្លាយទៅជាការបារម្ភដ៏ចម្បងរបស់ខ្លួននោះ ក្រុមមេដឹកនាំខ្មែរក្រហមបានសម្តែងខ្លួនជាសម្ព័ន្ធមិត្តដ៏សំខាន់របស់ប្រទេសចិនដោយឯងៗ ក្នុងយុទ្ធសាស្ត្រជាប្រពៃណីរបស់ខ្លួន សំដៅធ្វើយ៉ាងណាបញ្ចៀសការកកើតរដ្ឋដ៏ខ្លាំងពូកែមួយនៅព្រំដែនភាគខាងត្បូងរបស់ខ្លួន ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយដែលថា នៅខែសីហា ឆ្នាំ១៩៧៥ ពេលដែល ដូ អេនឡាយ មានជំងឺដេកជាប់នឹងគ្រែបានថ្លែងប្រាប់ ឡេថាញ់ងី អ្នកទទួលខុសត្រូវសំខាន់បំផុតនៃគណៈកម្មការផែនការរបស់វៀតណាមថា ប្រទេសចិនពុំអាចជួយប្រទេសវៀតណាមទេ ក្រុងប៉េកាំងបានត្រៀមបម្រុងនូវការស្វាគមន៍ដ៏អឹកធឹកមួយចំពោះប្រធានរដ្ឋ ខៀវ សំផន និងឧបនាយករដ្ឋមន្ត្រី អៀង សារី រួចជាស្រេច ។ ជំនួយមួយដែលមានទឹកប្រាក់មួយកោដិដុល្លារអាមេរិកសម្រាប់រយៈពេលប្រាំឆ្នាំ ត្រូវបានផ្តល់ឲ្យកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានម្ភៃលានដុល្លារត្រូវចិន

ប្រគល់ឲ្យភ្លាមៗតែម្តង ។

ជ័យជម្នះត្រូវធ្លាក់មកលើ ខៀវ សំផន និង អៀង សារី ហើយជំនួយផ្នែកហិរញ្ញវត្ថុនេះជាភ័ស្តុតាងមិនអាចប្រកែកបានក្នុងការគាំទ្រដោយគ្មានលក្ខខណ្ឌរបស់ប្រទេសចិនចំពោះប្រទេសកម្ពុជា ។ ដោយស្របគ្នាក្នុងឱកាសនៃការធ្វើដំណើររបស់ ប៉ុល ពត នៅប្រទេសចិន នាខែមិថុនា មានការចាប់ផ្តើមធ្វើការចរចាសម្ងាត់ជាច្រើនទាក់ទងទៅនឹងជំនួយយោធារបស់ចិន ។ នៅខែសីហានិងខែតុលា អ្នកជំនាញការជាច្រើនក្រុមនៃក្រសួងការពារប្រទេសចិនបានមកធ្វើការសិក្សាអង្កេតយ៉ាងស៊ីជម្រៅមួយស្តីពីសេចក្តីត្រូវការផ្សេងៗរបស់កម្ពុជាខាងវិស័យយោធានេះដល់កន្លែងតែម្តង ។ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៥ អ្នកជំនាញការទាំងនោះបានដាក់ជូនក្រុងភ្នំពេញពិនិត្យនូវសេចក្តីព្រាងដំបូងមួយនៃគម្រោងជំនួយយោធា ដើម្បីសុំការអនុម័តយល់ព្រម ។

ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ ស្ថានទូតចិននៅក្រុងហាណូយបានដាក់ពាក្យបណ្តឹងជាផ្លូវការដំបូងរបស់ខ្លួនទាក់ទងទៅនឹងការបង្ខំឲ្យអាណិកជនចិននៅវៀតណាមខាងត្បូង ចូលសញ្ជាតិវៀតណាម ។ នៅថ្ងៃដដែលនោះ មេដឹកនាំជាន់ខ្ពស់ម្នាក់របស់កងទ័ពចិនបានធ្វើដំណើរជាសម្ងាត់មកកាន់ក្រុងភ្នំពេញ ដើម្បីសម្រេចបង្ហើយកិច្ចព្រមព្រៀងជំនួយផ្នែកយោធា ។ វ៉ាង សាងវ៉ុង អគ្គសេនាធិការរងនៃកងទ័ពប្រជាជនចិនបានប្រាប់ សុន សេន រដ្ឋមន្ត្រីការពារប្រទេសកម្ពុជាប្រជាធិបតេយ្យឲ្យដឹងពីការសម្រេចចិត្តរបស់ចិនក្នុងការប្រគល់ឲ្យមុនគេនូវកាំភ្លើងធំនាវាល្បាតឆ្នេរសមុទ្រ និងប្រព័ន្ធផ្នែកការពារអាកាសផង ។ ទីប្រឹក្សាចិនចំនួនប្រាំរយនាក់នឹងត្រូវចាត់ឲ្យមកទទួលបន្ទុកបង្ហាត់បង្រៀនកងទ័ពខ្មែរក្រហមពីរបៀបប្រើប្រាស់សម្ភារទាំងនោះ ។ វ៉ាង បានរំឭកពីការប្រគល់សម្ភារសឹកដែលគ្រោងសម្រាប់ឆ្នាំ១៩៧៧ និង១៩៧៨ផងដែរ ។ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៦ វ៉ាង និង សុន សេន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ជំនួយយោធាដោយគ្មានសំណងចំពោះប្រទេសកម្ពុជា[១៤] ។

សហប្រតិបត្តិការផ្នែកយោធាបានរីកលូតលាស់ក្នុងសភាពស្ងាត់កំបាំងបំផុត ក្នុងរបៀបធ្វើយ៉ាងណាកុំឲ្យទាំងប្រទេសថៃ ទាំងវៀតណាមភ័យខ្លាច ។ ការធ្វើឲ្យសមហេតុផលដំបូងរបស់ពួកចិនហាក់ដូចជាយល់ព្រមធ្វើតាមបំណងត្រឹមត្រូវតាមច្បាប់របស់កម្ពុជាក្នុងការប្រែក្លាយទ័ពព្រៃរបស់ខ្លួនឲ្យទៅជាកងទ័ពរៀបរយមួយ ដែលអាចប្រឈមមុខនឹងការកៀបសង្កត់ថ្មីៗក្នុងកិច្ចការពារប្រទេស ។ គ្មានអ្វីដែលត្រូវសង្ស័យឡើយថា ប្រទេសចិនមានបំណងថ្លឹងឲ្យស្មើគ្នានូវវិសមតាយ៉ាងសម្បើមរវាងម៉ាស៊ីនសង្គ្រាមវៀតណាម – ដែលគួរឲ្យស្ញើមទាំងចំនួនទាហានក៏ដូចចំនួនយុទ្ធោបករណ៍ និងកងទ័ពខ្មែរមួយដែលមានអាវុធមិនគ្រប់គ្រាន់ ។ ពួកកុម្មុយនីស្តវៀតណាមបានទទួលមរតកជាគ្រឿងសព្វាវុធពីអតីតសាធារណរដ្ឋវៀតណាមខាងត្បូង ដែលមានតម្លៃប្រមាណ៥កោដិដុល្លារអាមេរិក ។ តាមគេយល់ ប្រទេសចិនរបស់ ម៉ៅ ពុំមានទាំងមធ្យោបាយ ទាំងឆន្ទៈ ដើម្បីជំរុញខ្មែរក្រហមឲ្យធ្វើការប្រឈមមុខមួយដោយអាវុធជាមួយវៀតណាមឡើយ ។ ប្រទេសចិនគ្រាន់តែផ្តល់“សាច់ដុំ” ឲ្យសម្ព័ន្ធមិត្តរបស់ខ្លួនសម្រាប់ទប់ទល់នឹងការគំរាមកំហែងដាយថាហេតុរបស់វៀតណាមប៉ុណ្ណោះ ។

*ទោះថាភាគល្អិតល្អន់នៃការចរចាផ្នែកយោធាត្រូវបានទុកជាសម្ងាត់ក៏ដោយ ក៏ជំហរជាគោលការណ៍របស់ចិន ដែលគាំទ្រប្រទេសកម្ពុជាទាំងស្រុង បានត្រូវលាតត្រដាងជាសាធារណៈ និងជាឧឡារិកដែរ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ក្រុងប៉េកាំងបានប្រារព្ធធ្វើពិធីបុណ្យខួបលើកទីមួយនៃ«ការរំដោះ»ទឹកដីរបស់ប្រជាជនកម្ពុជាយ៉ាងគគ្រឹកគគ្រេង ។ នៅក្នុងឱកាសនោះតាមរយៈសារលិខិតមួយដែលផ្ញើជូន ប៉ុល ពត, ម៉ៅ, ជូ អេនឡាយ, ជូតិ និង ហ្វា គួហ្វេង បានសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះការការពារយ៉ាងម៉ឺងម៉ាត់នូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីនិងឆន្ទៈរបស់គាត់ ដែលផ្តើមចលនា «ធ្វើឲ្យបដិវត្តន៍មានការប្រែប្រួលយ៉ាងស៊ីជម្រៅ»សម្រាប់ប្រទេសកម្ពុជា ។ ដើម្បីបន្ថែមទម្ងន់ឲ្យរឹតតែខ្លាំងក្លាឡើងទៀត ពួកមេដឹកនាំចិនបានសង្កត់បញ្ជាក់ពីឆន្ទៈរបស់ប្រជាជនខ្លួនថា «នឹងវាយប្រយុទ្ធស្មា ប្រកៀកស្មា ហើយបន្តដំណើរទៅមុខ» ជាមួយប្រជាជនកម្ពុជាជានិច្ច[១៥] ។*

*អាស្រ័យដូចនេះ នៅនិទាឃរដូវឆ្នាំ១៩៧៦ ប្រទេសកម្ពុជាបានក្លាយទៅជាកត្តាមួយនៃភាពតានតឹងដ៏ចម្បងរវាងចិននិងវៀតណាម ប៉ុន្តែការធ្លាក់ចុះជាលំដាប់លំដោយនូវទំនាក់ទំនងរវាងប្រទេសទាំងពីរបានចាប់ផ្តើមមានតាំងពីមុនមកម្ល៉េះ ។ ដោយពិត តាំងពីជ័យជម្នះរបស់ក្រុងហាណូយលើភាគខាងត្បូង ហេតុផលដែលបណ្តាលឲ្យមានការអាក់អន់ចិត្តនឹងគ្នាបានត្រូវគេទុកឲ្យកន្លងផុតទៅដោយរកច្រកដោះស្រាយមិនឃើញ ។ ការអាក់អន់ចិត្តទាំងនោះបាននាំបណ្តាលឲ្យមានការខ្វែងគំនិតគ្នាជាសំខាន់ខាងផ្នែកនយោបាយ និងមនោគមវិជ្ជារវាងបក្សទាំងពីរផងដែរ ។*

## ការសម្រុកស្រទៅកោះស្ព្រាតលី

*ប្រហែលបីសប្តាហ៍មុនពេលដែលទង់កុម្មុយនីស្តមិនទាន់បង្ហូតឡើងលើទីក្រុងព្រៃនគរ ដែលក្រោយមកត្រូវដាក់ឈ្មោះថ្មីថាក្រុងហូជីមិញនោះ កងទ័ពម៉ារីនវៀតណាមខាងជើងបានដណ្តើមកាន់កាប់ប្រជុំកោះស្ព្រាតលីជាកម្មសិទ្ធិដែលកាន់កាប់ដោយកងទ័ពវៀតណាមខាងត្បូងរហូតមកទល់នឹងពេលនេះ ។ ក្រុងហាណូយហាក់ដូចជាដឹងខ្លួនមុនថា សម័យតភ្ជាប់(អន្តរកាល) និងមិនច្បាស់លាស់មួយនឹងសណ្ឋិតមានបន្ទាប់ពីជ័យជម្នះ ហើយមានបំណងយកប្រៀបលើប្រទេសចិនក្នុងការធ្វើជាម្ចាស់កោះទាំងឡាយ ដែលកំពុងទាមទារដោយប្រទេសទាំងពីរ ។ នៅថ្ងៃទី៥ ខែឧសភា វិទ្យុហាណូយបានប្រកាសថា នៅថ្ងៃទី១១ ខែមេសា និងថ្ងៃជាបន្តបន្ទាប់មកទៀត «កងទ័ពរំដោះនិងកងម៉ារីន»បាន«រំដោះ»កោះចំនួនប្រាំមួយនៃប្រជុំកោះស្ព្រាតលីទាំងស្រុង ។ ពីរថ្ងៃក្រោយមក សារព័ត៌មានផ្លូវការឈ្មោះ Saigon Giai Phong (ព្រៃនគរត្រូវរំដោះ) បានបោះពុម្ពផ្សាយ ផែនទីពណ៌មួយរបស់ប្រទេសវៀតណាម ដែលមានប្រជុំកោះស្ព្រាតលីផង ប៉ុន្តែ ប្រជុំកោះប៉ារ៉ាសែល ដែលកាន់កាប់ដោយពួកចិនក៏មានគូរបញ្ចូលជាផ្នែកមួយនៃទឹកដីវៀតណាមដែរ ។*

ក្រុងប៉េកាំងបានរក្សាភាពស្ងៀមស្ងាត់មួយចំពោះឧបទ្ទវហេតុនេះ ។ ជាច្រើនឆ្នាំក្រោយមក ខ្ញុំគ្រាន់តែបានដឹងពីមាត់របស់លោក លីន តេក្វាន ជាអ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានស៊ីនហួនូវអ្វីដែលជាមនោសញ្ចេតនាដ៏ជ្រាលជ្រៅរបស់ពួកចិននៅពេលនោះថា «យើងបម្រុងខ្លួនចាកចេញពីក្រុងហាណូយដើម្បីទៅធ្វើទស្សនកិច្ចមួយនៅភាគខាងត្បូងដែលទើបរំដោះ ទុកណាជាយើងបានដឹងដំណឹងស្តីពីការដណ្តើមយកប្រជុំកោះណានសា (Nansha) – បារាំងហៅស្រ្តាតលីក៏ដោយ ។ ខ្ញុំអួលដើម – កនិយាយលែងចេញ» ។ ដោយបំពេញមុខងារក្នុងរយៈពេលជាច្រើនឆ្នាំនៅការិយាល័យនៃទីភ្នាក់ងារព័ត៌មានចិនថ្មីប្រចាំទីក្រុងហាណូយ លោក លីង តេក្វាន គឺជាសមាជិកម្នាក់នៃក្រុមអ្នកកាសែតកុម្មុយនីស្តលើកដំបូងកំពុងស្នាក់នៅក្នុងទីក្រុងនេះ ដែលបានទៅធ្វើទស្សនកិច្ចនៅភាគខាងត្បូងវៀតណាមនាខែឧសភា ឆ្នាំ១៩៧៥ ។ គាត់បានបន្ថែមថា ការធ្វើប្រតិបត្តិការរបស់វៀតណាមមានលក្ខណៈជាអំពើក្បត់មួយរឹតតែធ្ងន់ធ្ងរជាងការដែលប្រទេសវៀតណាមទទួលស្គាល់អធិបតេយ្យរបស់ចិនលើប្រជុំកោះស្រ្តាតលីពីមុនទៅទៀត ។ លីន បាននិយាយពន្ទើសបន្តិច ដោយមិនជឿទាស់ដោយជាក់លាក់ចំពោះការទាមទាររបស់ចិន ក្រុងហាណូយបានសម្តែងឲ្យដឹងដោយសញ្ញាផ្សេងៗ នូវលក្ខខណ្ឌទាំងឡាយរបស់ខ្លួនស្តីពីបញ្ហានេះ ។ នៅខែមិថុនា ឆ្នាំ១៩៧៤ វ៉ាង ទុង បានប្រកាសប្រាប់អ្នកកាសែតថៃម្នាក់ថា «អាស៊ីអាគ្នេយ៍ជាកម្មសិទ្ធិរបស់ប្រជាជននៅអាស៊ីអាគ្នេយ៍...។ ប្រទេសចិនពុំមែនជាប្រទេសមួយនៅអាស៊ីអាគ្នេយ៍ទេ ដោយហេតុនេះការទាមទាររបស់ចិនលើដែនសមុទ្រក៏ពុំត្រឹមត្រូវដែរ»[១៦] ។ នៅជំនាន់ដែលមានសេចក្តីប្រកាសនេះ វៀតណាមខាងជើងនៅមិនទាន់ប្រុងប្រៀបដណ្តើមភាគខាងត្បូងដោយឆាប់រហ័សដូច្នេះទេ ។ ប៉ុន្តែ កាលបើកងទ័ពរបស់ ធីវ ចាប់ផ្តើមបង្ហាញឲ្យឃើញនូវសញ្ញាចុះខ្សោយភ្លាម វាច្បាស់ណាស់ថា ក្រុងហាណូយមិននៅឈរស្ងៀមឱបដៃឡើយ ហើយក៏មិនបណ្តោយឲ្យប្រទេសចិនកាន់កាប់ប្រជុំកោះស្រ្តាតលី ដូចដែលចិនធ្លាប់បានកាន់កាប់ប្រជុំកោះប៉ារ៉ាសែលកាលពីឆ្នាំមុនដែរ ។

ប្រជុំកោះទាំងពីរនេះ ដែលស្ថិតនៅសមុទ្រចិនខាងត្បូងរួមមានកោះតូចៗប្រហែលមួយរយហាសិប ដែលសុទ្ធតែកោះមានតែដីហុយផ្សោង, ជួរថ្មប៉ប្រះទឹកនិងផ្នូកខ្សាច់ ។ អ្នកនេសាទចិន, វៀតណាម និង ហ្វីលីពីន បានប្រមូលជីកាកត្រី (សម្រាប់ធ្វើជាជី) និងសំបុកត្រចៀកកាំនៅទីនោះតាំងពីច្រើនសតវត្សរ៍មកហើយសម្រាប់ជាមុខម្ហូបសម្រាំងមួយដែលជាលក្ខណៈពិសេសនៃម្ហូបរបស់ចិន ។ តំបន់នេះចាប់មានផលប្រយោជន៍ថ្មីមួយនៅដើមទសវត្សរ៍៧០ នៅពេលដែលមានការចាប់ផ្តើមរុករករ៉ែប្រេងកាតនៅតំបន់អាស៊ីអាគ្នេយ៍ ។ ការកំណត់ថាប្រទេសណាមួយត្រូវមានអធិបតេយ្យលើកោះទាំងនេះ ពុំមែនជាបញ្ហាធម្មតាមួយឡើយ ។ ប្រទេសចិនដែលទាមទារប្រជុំកោះនេះទាំងមូល បានទ្រទ្រង់ជំហររបស់ខ្លួនដោយឯកសារផ្សេងៗខាងបុរាណវត្ថុវិទ្យានិងប្រវត្តិសាស្រ្ត (មានការលុកលុយពីរ – បីលើកមកហើយរបស់អាណិកជនចិន) ។ ប៉ុន្តែ ក្នុងរយៈពេលជាច្រើនសតវត្សរ៍មកហើយ ទាំងប្រទេសចិន ទាំងប្រទេសវៀតណាម ទាំងប្រទេសហ្វីលីពីន ក៏មិនដែលនឹកគិតកាន់កាប់កោះទាំងនេះ

យូរអង្វែងដែរ ។ រហូតមកដល់ដំណាច់ទសវត្សរ៍៥០ រដ្ឋាភិបាលវៀតណាមខាងត្បូង ក៏ចៀសវាងមិនតវ៉ាជំទាស់នឹងការទាមទាររបស់ចិនឡើយ ។ ចំណែកវៀតណាមខាងជើងដែលជាសម្ព័ន្ធមិត្តផ្នែកមនោគមវិជ្ជា និងដែលទទួលផលប្រយោជន៍ពីជំនួយរបស់ចិន ក៏យល់ឃើញដូចគ្នា ។ ការប៉ះទង្គិចគ្នាលើកដំបូងរវាងក្រុងព្រៃនគរ និងក្រុងប៉េកាំងស្ដីពីបញ្ហាកោះទាំងនោះ គឺមានមកតាំងពីឆ្នាំ១៩៥៩ម្ល៉េះ ហើយដោយការមិនចង់និយាយរបស់ខ្លួនរួមផ្សំផង ក្រុងហាណូយបានចៀសវាងដោយប្រយ័ត្នប្រយែងក្នុងការគាំទ្រប្រទេសចិន ។

## ប្រតិបត្តិការនៅប្រជុំកោះប៉ារ៉ាសែល

នៅឆ្នាំ១៩៧២ របបរបស់ប្រធានាធិបតី ធីវ បានចាប់ផ្ដើមចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រេងបរទេសនានា ដើម្បីជាប្រយោជន៍ដល់ការសោងសង់កន្លែងខួងប្រេងជាច្រើនកន្លែង ក្នុងគោលបំណងធ្វើអាជីវកម្មរ៉ែប្រេងដែលអាចមានជាយថាហេតុ ។ នេះជាសញ្ញាដែលធ្វើឲ្យពួកចិនព្រួយបារម្ភ ព្រោះបញ្ហាប្រជុំកោះបានលេចឡើងជាថ្មីនៅពេលនេះភ្លាម ។ នៅទីបំផុត ពួកចិនគ្រាន់តែបង្ហាញឲ្យឃើញវត្តមានរបស់ខ្លួននៅតាមជួរកោះអំហ្វីទ្រីតនៃប្រជុំកោះប៉ារ៉ាសែលប៉ុណ្ណោះ ខណៈដែលវៀតណាមខាងត្បូង បានរក្សាទុកកងទ័ពតូចៗនៅលើបណ្ដាកោះខ្លះនៃជួរកោះក្រេសស្ស៊ង់ ។ នៅខែមេសាឆ្នាំដដែល ដោយប្រឆាំងតវ៉ានឹងការលុកលុយរបស់បណ្ដានាវាអាមេរិកាំងមកក្នុងដែនទឹកនៃប្រជុំកោះប៉ារ៉ាសែល ក្រុងប៉េកាំងបានផ្ដួចផ្ដើមគំនិតមួយ ដែលហាក់ដូចជាមានគោលបំណងបង្កើនការគាំទ្ររបស់អាមេរិកាំងចំពោះការទាមទារដែនដីរបស់ខ្លួន គឺពីរខែបន្ទាប់ពីទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់ប្រធានាធិបតី និចសុន នៅប្រទេសចិន ។ ដោយវិនិច្ឆ័យរឿងនេះតាមការចងចាំរបស់គាត់ លោក ហង់រី គីស្ស៊ីងហ្គ័រ មិនមានបំណងជំទាស់ចំពោះភាពសមហេតុសមផលនៃការទាមទាររបស់ចិនឡើយ ទោះបីជាវៀតណាមខាងត្បូង មានអភិមានះចង់បានប្រជុំកោះប៉ារ៉ាសែល ហើយដែលពួកគេធ្លាប់បានកាន់កាប់មួយផ្នែកក៏ដោយ ។ លោក គីស្ស៊ីងហ្គ័រ បានប្រាប់ឲ្យពួកចិនដឹងថា «ដោយមិនទាន់និយាយដល់ដំហរផ្លូវការរបស់សហរដ្ឋអាមេរិកស្ដីពីបញ្ហាដែនសមុទ្រ អំណឹះតទៅ កងម៉ារីនអាមេរិកាំងនឹងត្រូវទទួលបញ្ជាមិនឲ្យទៅក្បែរប្រជុំកោះប៉ារ៉ាសែលទេ យ៉ាងហោចក្នុងចម្ងាយពីកោះ ២០គីឡូម៉ែត្រ»[១៧] ។

ក្រុងហាណូយហើយទំនងជាក្រុងព្រៃនគរដែរ មិនដឹងអ្វីទាំងអស់ពីការសន្យារបស់អាមេរិកាំង ។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៣ វៀតណាមខាងជើងបានឲ្យដំណឹងទៅរដ្ឋាភិបាលចិនអំពីគោលបំណងរបស់ខ្លួនដើម្បីផ្ដើមធ្វើការចរចាជាមួយក្រុមហ៊ុនប្រេងអ៊ីតាលីមួយ ដើម្បីរុករកប្រេងនៅឈូងសមុទ្រតុងកឹង ។ នៅថ្ងៃទី១១ ខែមករា ក្រុងប៉េកាំងបានទាមទារជាផ្លូវការនូវកោះទាំងអស់ដែលស្ថិតនៅសមុទ្រចិនខាងត្បូង ។ បួនថ្ងៃក្រោយមក កងទ័ពរបស់ចិនបានប្រមូលផ្ដុំគ្នាឡើងពេញលើកោះក្រេសស្ស៊ង់ ។ វៀតណាម ខាងត្បូងបានខំប្រឹងវាយរុញច្រានពួកចិនឲ្យចេញទៅវិញ ប៉ុន្តែ ពួកគេបានទទួលរងការតបតមួយដែលមានការរៀបចំយ៉ាងប្រយ័ត្នប្រយែង ។

នៅថ្ងៃទី១៩ ខែមករា ប្រតិបត្តិការរួមគ្នាមួយរវាងកងអាកាសចរ និងកងម៉ារីនរបស់ចិន បានបង្ខំឲ្យទ័ពជំនួយរបស់វៀតណាមខាងត្បូងជម្លៀសចេញពីកោះនានា ហើយដាក់កោះទាំងនោះឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់ចិន ។ គេនិយាយថា សហរដ្ឋអាមេរិកបានជំទាស់ដោយការបដិសេធយ៉ាងគួរសមមួយចំពោះសំណើសុំឲ្យជួយរបស់ប្រធានាធិបតី ធីវ ។ មន្ទីរបញ្ចកោណ (ប៉ង់តាហ្គោន) បានអះអាងថា ខ្លួនពុំបានទទួលសំណើណាមួយប្រភេទនេះទេ ហើយកងនាវាចរទី៧របស់អាមេរិកាំង បានស្ថិតនៅដោយឡែកពីការប្រទូសរ៉ាយនេះ ។ ទីប្រឹក្សាអាមេរិកាំងម្នាក់ដែលកំពុងបម្រើការនៅកងនាវាចររបស់វៀតណាមខាងត្បូង ហើយដែលត្រូវចាប់ខ្លួនដោយកងទ័ពចិន បានត្រូវបញ្ជូនទៅក្រុងហុងកុង ដោយគ្មានឧបសគ្គបន្ទាប់ពីឧបទ្ទវហេតុនេះ ។ មុនមានការវាយលុករបស់ចិន ក្រុងប៉េកាំងបានប្រាប់ឲ្យក្រុងហាណូយដឹងអំពីបំណងរបស់ខ្លួន ដើម្បីបើកការចរចាស្ដីពីបញ្ហាដែនសមុទ្រ ដោយសង្កត់បញ្ជាក់ពីការប្រឆាំងជំទាស់របស់ខ្លួន ចំពោះការចាប់ផ្ដើមរុករកប្រេងទាំងអស់ ។

ជាច្រើនឆ្នាំក្រោយមក ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំក្រុងប៉ារីស លោក ម៉ៃ វ៉ាន់បូ បាននិយាយរឿងអាថ៌កំបាំងប្រាប់ខ្ញុំថា ប្រតិបត្តិការនៅប្រជុំកោះប៉ារ៉ាសែល នាខែមករា ឆ្នាំ១៩៧៤ បានបង្កជា«អំពើឈ្លានពានដោយអាវុធលើកដំបូងរបស់ប្រទេសចិន ប្រឆាំងនឹងប្រទេសវៀតណាម» ។ ប៉ុន្តែ នៅជំនាន់នោះ ក្រុងហាណូយគ្រាន់តែបញ្ជាក់ថា ការដោះស្រាយជម្លោះទឹកដីដ៏ស្មុគស្មាញទាំងនេះរវាងបណ្ដាប្រទេសជិតខាងតម្រូវឲ្យមានជាចាំបាច់នូវការស្រាវជ្រាវពិនិត្យដ៏ស៊ីជម្រៅមួយ ។ ក្រុងហាណូយបានបន្ថែមថា «បណ្ដាប្រទេសដែលពាក់ព័ន្ធត្រូវតែដោះស្រាយភាពមិនត្រូវគ្នាតាមរយៈការចរចាក្នុងស្មារតីស្មើភាពមួយ ការគោរពគ្នាទៅវិញទៅមក និងភាពជាអ្នកជិតខាងល្អ»[១៨] ។

សេចក្ដីប្រកាសនៅឆ្នាំ១៩៧៤នេះ ដែលធ្វើឡើងបន្ទាប់ពីមានការច្បាំងដណ្ដើមប្រជុំកោះប៉ារ៉ាសែលដោយអាវុធ ពិតហើយគឺជាការរិះគន់លាក់ពុតមួយរបស់ប្រទេសចិន ។ ប៉ុន្តែ ដោយផ្អែកកងទ័ព និងសេដ្ឋកិច្ចត្រូវពឹងពាក់លើក្រុងប៉េកាំង ក្រុងហាណូយមិនអាចនិយាយពីរឿងនេះច្រើនឡើយ ។ មួយឆ្នាំក្រោយមក ជាមួយនឹងជ័យជម្នះទាំងស្រុងមួយនៅភាគខាងត្បូង របៀបនិយាយរបស់វៀតណាមមានលក្ខណៈខុសគ្នាស្រឡះ ។ ពួកកុម្មុយនីស្តវៀតណាមបានបញ្ជាក់យ៉ាងជាក់លាក់ពីការប្រឆាំងជំទាស់របស់ខ្លួន ចំពោះប្រទេសចិនដោយបានប្រកាសជាសាធារណៈពី«ការរំដោះ» កោះចំនួន៦នៃប្រជុំកោះស្ព្រាតលី (វៀតណាម ហៅត្រឿងសា) ។ តាំងពីពាក់កណ្ដាលទសវត្សរ៍៥០ ភាពមិនត្រូវគ្នាជាច្រើនបានលេចឡើង អំពីរឿងចម្រៀកដីខ្លះៗនៅតាមព្រំដែនគោករវាងចិននិងវៀតណាម ប៉ុន្តែ ទោះជាយ៉ាងណាក៏វាមិនប្រែពីល្អទៅអាក្រក់ដែរ ។ ក្រោយពីដំណើរទស្សនកិច្ចរបស់ និចសុន នៅប្រទេសចិននាឆ្នាំ១៩៧២ បន្ទាប់មក ជាមួយការបញ្ចប់ការទម្លាក់គ្រាប់បែកនៅភាគខាងជើង និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ក្រុងហាណូយបានចាប់ផ្ដើមពង្រឹងជំហររបស់ខ្លួនស្ដីពីបញ្ហាព្រំដែន ។ ដោយកន្លែងដទៃនៃពិភពលោកអត់ដឹង ឧបទ្ទវហេតុតូចតាចជាច្រើននៅតាមព្រំដែនបានផ្ទុះ

ឡើង ។ តាមការនិយាយឲ្យដឹងរបស់ចិនដែលមានមកជាក្រោយ គេវាយតម្លៃថា មានការប្រយុទ្ធគ្នាស្រាលៗជាងមួយរយបួយលើកនៅឆ្នាំ១៩៧៤ ។ បន្ទាប់ពីជ័យជម្នះរបស់ក្រុងហាណូយនៅភាគខាងត្បូង ចំនួននៃការប៉ះទង្គិចគ្នាបានកើនឡើងបួនដង[១៩] ។

## រវាងខ្លាឃ្មុំនិងនាគ

វាជាសំណើចចំអកនៃប្រវត្តិសាស្ត្រ ព្រោះបន្ថែមពីលើសហរដ្ឋអាមេរិក គឺប្រទេសចិនដែលចាញ់សង្គ្រាមនៅវៀតណាម ។ ជាមួយនឹងការដកថយរបស់អាមេរិកាំង នៅឆ្នាំ១៩៧៥ គំនិតដែលនៅដក់ជាប់ជានិច្ចរបស់អ្នកទទួលខុសត្រូវចិនខាងផ្នែកនយោបាយហាក់ដូចជាជិតលេចជារូបរាង ៖ ប្រទេសវៀតណាមមួយដែលខ្លាំងពូកែ និងរួមគ្នាឡើងវិញ កំពុងបង្កហេតុនឹងចិនតាមព្រំដែនភាគខាងត្បូងរបស់ខ្លួននិងកំពុងចូលដៃចូលជើងជាមួយសត្រូវស្លាប់រស់របស់ខ្លួននៅភាគខាងជើងគឺ(សូវៀត) ។

ពិភពលោកទាំងមូលបានរក្សាទុកក្នុងចិត្តនូវរូបភាពផ្សេងៗដែលគួរឲ្យចង់មើលនៃការដួលរលំរបស់មហាអំណាចអាមេរិកាំងនៅឥណ្ឌូចិន ៖ ឯកអគ្គរដ្ឋទូតអាមេរិកនៅកម្ពុជាលោក ហ្ស៊ូន ហ្គុនធ័រ ឌៀន កំពុងចាកចេញពីប្រទេសនេះដោយឱបទង់ជាតិរបស់ខ្លួនដែលដាក់ក្នុងថង់ប្លាស្ទិកមួយ ឧទ្ធម្ភាគចក្រជាច្រើនគ្រឿងកំពុងជម្លៀសមនុស្សចេញពីទីក្រុងព្រៃនគរ ហើយហោះទៅចុះចតលើនាវារបស់អាមេរិកាំងដែលរង់ចាំនៅឯមហាសមុទ្រប៉ាស៊ីហ្វិក ។ នៅពេលដែលការដួលរលំនេះកើតឡើងដោយមិនបានប្រុងប្រៀបទុកជាមុនប្រទេសចិនបានត្រូវធ្វើឲ្យខ្វល់ចិត្តមែនទែនដោយសារឥទ្ធិពល “សង្គមចក្រពត្តិនិយម” របស់សូវៀតនៅអាស៊ីដែលកាន់តែរីកធំឡើងៗ ។ តាំងពីទស្សនកិច្ចរបស់ និចសុន [ប្រធានាធិបតីអាមេរិកពីរអាណត្តិពីឆ្នាំ១៩៦៨-១៩៧២ ប៉ុន្តែអាណត្តិទី២កាន់អំណាចបានតែ២ឆ្នាំប៉ុណ្ណោះ ដោយសារមានរឿងអាស្រូវ “Watergate” ហើយបានសុំលាលែងពីតំណែងនៅឆ្នាំ១៩៧៤-កំណត់របស់អ្នកបកប្រែ] ក្រុងប៉េកាំងបានវាយតម្លៃដោយក្រសែភ្នែកជ្រោមជ្រែងនូវវត្តមានរបស់អាមេរិកក្នុងតំបន់នៃពិភពលោកនេះ ពិតហើយ លើកលែងតែនៅតែវ៉ាន់ៗ ។ ការដកថយទាំងរហ័សរបស់ពួកអាមេរិកាំងបានធ្វើឲ្យពួកចិននឹកភ័យបារម្ភដែរ ព្រោះថាអំណឹះតទៅ “កន្លែងទំនេរ” នេះ ច្បាស់ជាត្រូវក្រុងមូស្គូដែលជាអ្នកផ្គត់ផ្គង់សម្ភារយោធាដ៏សំខាន់បំផុតឲ្យប្រទេសវៀតណាមចូលកាន់កាប់ភ្លាម ។ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៥ ក្នុងពេលដែលប្រតិបត្តិការ “Frequent Wind” ប្រឹងប្រែងលុបបំបាត់ស្លាកស្នាមចុងក្រោយនៃវត្តមានអាមេរិកាំងនៅវៀតណាមនោះ ដំណឹងសំខាន់ផ្នែកនយោបាយបរទេសរបស់ទីភ្នាក់ងារសារព័ត៌មានចិនថ្មីបាននិយាយបញ្ចិតបញ្ចៀងទៅរកការធ្វើសមយុទ្ធនៃកងនាវាចរសហភាពសូវៀតដែលផ្តើមធ្វើក្នុងមហាសមុទ្រប៉ាស៊ីហ្វិកព្រមពេលជាមួយគ្នានោះដែរ ។ បន្ទាប់ពីបានរៀបរាប់បញ្ចូលនូវវត្តមាននៃកងនាវាចរសូវៀតនៅចំណុចផ្សេងៗនៃពិភពលោក ដោយលើកឡើងជាពិសេសពីព្រឹត្តិការណ៍នៃ “ការជ្រៀតចូលមួយដែលគ្មានអ្វីអាច

ទប់បានក្នុងច្រោយ ម៉ាឡាកា (*Malacca* ជាច្រោយនៅចន្លោះប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ី) រហូតមកដល់ភាគខាងត្បូងវៀតណាម»នោះ ទីភ្នាក់ងារនេះបានសម្តែងនូវសេចក្តីសង្ឃឹមថា សមយុទ្ធដែលកំពុងប្រព្រឹត្តទៅនេះ រឹតតែជួយពង្រីងឲ្យមានការប្រុងប្រយ័ត្នខ្លាំងឡើងថែមទៀត «ប្រឆាំងនឹងគ្រោះថ្នាក់ផ្សេងៗនៃការឈ្លានពាន និងការវាតទីរបស់សង្គមចក្រពត្តិ»[២០] ។

ប្រធាន ម៉ៅ, លោក ជូតិ និង ជូ អេនឡាយ ពិតជារវៀសរវៃបញ្ជូនសារទូរលេខអបអរសាទរសើរមួយទៅក្រុងហាណូយចំពោះ«ដំណឹងល្អ»ទាំងនេះ ប៉ុន្តែមេដឹកនាំចិនបានធ្វើការកត់សម្គាល់ផងដែរថា ជ័យជម្នះរបស់វៀតណាមជាភស្តុតាងបន្ថែមមួយនៃភាពមិនចេះចាញ់របស់សង្គ្រាមប្រជាជន នេះជាទស្សនៈមួយដែលលើកឡើងជារឿយៗដោយប្រទេសចិន ។ បទអត្ថាធិប្បាយមួយនៃទិនានុប្បវត្តិប្រជាជនចុះថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៥ បាននិយាយពន្ធើសជ្រុលហួសហេតុក្នុងការបន្ថោកតម្លៃអំពីតួនាទីរបស់សូវៀត ។ កាសែតបានសរសេរថា «ជ័យជម្នះដ៏ធំធេងរបស់វៀតណាមបានបង្ហាញឲ្យឃើញជាថ្មីម្តងទៀតថា អ្វីដែលកំណត់ជ័យជម្នះឬបរាជ័យគឺប្រជាជន និងការគាំទ្ររបស់ប្រជាជននេះឯង ពុំមែនដោយសារគ្រឿងសាស្ត្រាវុធនោះទេ» ។ និយាយម្យ៉ាងទៀតគឺពុំមែនរថក្រោះ កាំជ្រួចមីស៊ីលសូវៀតទេ ដែលផ្តល់ជ័យជម្នះឲ្យវៀតណាមនោះ ប៉ុន្តែគឺពិតជាការចូលរួមរបស់ប្រជាជន ។

ការប្រាប់ឲ្យប្រុងប្រយ័ត្នទាំងនេះ បង្ហាញឲ្យឃើញពីភាពចាំបាច់សម្រាប់ក្រុងប៉េកាំងដែលសង្ស័យ «ពួកសេរីនិយម»របស់វៀតណាមបច្ចុប្បន្ន ដែលសាកល្បងអនុញ្ញាតឲ្យមានការតាំងមូលដ្ឋានទ័ពរបស់សូវៀតជាថ្នូរនឹងជំនួយមួយដែលនឹងមកដល់ខាងមុខ ។ ប្រទេសចិនបានកត់សម្គាល់ប្រកបដោយការព្រួយបារម្ភនូវការទៅដល់នៃគណៈប្រតិភូយោធាសូវៀតមួយក្រុម ក្រោយការដួលរលំក្រុងព្រៃនគរមិនដល់មួយសប្តាហ៍ផង និងការផ្តើមចូលចតគ្មានដាច់ នូវនាវាជំនួញសូវៀតតាមបណ្តាកំពង់ផែនៅភាគខាងត្បូងវៀតណាមជាច្រើនកន្លែង ។ ដប់ប្រាំថ្ងៃក្រោយមក ក្រុងប៉េកាំងបានសម្តែងឲ្យដឹងជាសាធារណៈនូវការក្តៅក្រហាយរបស់ខ្លួនជាលើកដំបូងដោយនិយាយប្រាប់គណៈប្រតិភូជប៉ុនមួយក្រុមដែលធ្វើដំណើរឆ្លងកាត់ប្រទេសចិនថា ពួកសូវៀតបាន«ស្នើដោយតឿនបន្ទំ»ឲ្យរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតណាមខាងត្បូងអនុញ្ញាតឲ្យខ្លួនប្រើប្រាស់អតីតមូលដ្ឋាននានារបស់កងទ័ពអាមេរិកាំង»[២១] ។

នៅខែកក្កដា ឆ្នាំ១៩៧៥ ដោយបានជួប ង្វី ឌៀន អ្នកការទូតវៀតណាមទទួលបន្ទុកផ្នែកព័ត៌មាននៃក្រសួងការបរទេស (ក្រោយមកជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសកម្ពុជា) ខ្ញុំបានសួរគាត់ថា តើពិតឬទេ រឿងដែលពួកសូវៀតទាមទារប្រើប្រាស់អតីតមូលដ្ឋានកងទ័ពអាមេរិកាំងនោះ? ។ ប្រហែលដោយក្តៅក្រហាយផងគាត់បានឆ្លើយប្រាប់ខ្ញុំដោយពោលពាក្យធំៗថា «លោកឯងគិតថា ពួកសូវៀតអាចទាមទារមូលដ្ឋានទ័ពនានាដែលមានក្នុងប្រទេសយើងប្រាកដមែនឬ? មុនសួរអ្វីក៏ដោយចំពោះមិត្តភក្តិម្នាក់ ត្រូវយល់ឲ្យច្បាស់ពីអ្វីដែលខ្លួន

គិតនោះផង ។ ហេតុអ្វីពួកសូវៀតអាចទាមទារ (មូលដ្ឋានមួយ) ជាមួយនឹងក្ដិនអសោចិ៍គ្រប់បែបយ៉ាងជាចក្រពត្តិនិយមដែលចង់ភ្ជាប់នឹងពាក្យនេះផងនោះ?» ។ ប៉ុន្តែគាត់បានបន្ថែមថា នាវារបស់សូវៀតមានសិទ្ធិចូលចតកំពង់ផែកាំរ៉ាញ់បាន (អតីតមូលដ្ឋាននាវាចររបស់អាមេរិក) បើសិនជាត្រូវការក្នុងលក្ខខណ្ឌអនុគ្រោះដូចគ្នាចំពោះនាវាទាំងឡាយដែលមកពីបណ្ដាប្រទេសជាមិត្តដែរ ។ ប្រាំមួយឆ្នាំក្រោយមក អ្នកការទូតវៀតណាមដទៃៗទៀតបានទទួលស្គាល់ចំពោះមុខខ្ញុំថា នៅឆ្នាំ១៩៧៥ ក្រុងមូស្គូ ពិតជាមានបំណងធ្វើឲ្យបានសម្រេចការតាំងឋានបនភ័ណ្ឌយោធាប្រាកដមែន ប៉ុន្តែឥតបានការ ។ ម្យ៉ាងទៀត សូវៀតត្រូវរង់ចាំដល់ទៅបួនឆ្នាំឯណោះ ទើបបានឈ្នះក្នុងការជជែកគ្នាពីរឿងនេះ ពោលគឺពេលដែលជម្លោះរវាងចិននិងវៀតណាមកាន់តែរីកធំឡើងៗ ។

ទោះជាមានមូលដ្ឋានកងទ័ពរបស់សូវៀតឬគ្មានក៏ដោយ ក៏ការប្រែប្រួលភ្លាមៗនៃតុល្យភាពកម្លាំងក្នុងភូមិភាគអាស៊ីអាគ្នេយ៍ បានធ្វើឲ្យប្រទេសចិនព្រួយបារម្ភខ្លាំងដែរ ។ ជាមួយកងទ័ពដ៏ច្រើនសម្បើមនិងដែលដោកជាំក្នុងចម្បាំង ជាមួយនឹងបរិមាណគ្រឿងសព្វាវុធដ៏សន្ធឹកសន្ធាប់របស់អាមេរិកាំងដែលរឹបអូសបានពីភាគខាងត្បូង ពេលនេះ ក្រុងហាណូយបានក្លាយទៅជាមហាអំណាចថ្នាក់ទីមួយនៅតណ្ហចិនជាស្រេច ក្នុងការដណ្ដើមយក «ប្រទីប» កងឈានមុខបដិវត្តមកកាន់វិញម្ដង ។ ផ្ទុយទៅវិញដោយធ្វើការចំអកបញ្ឈឺចិត្តអំពីការព្រួយបារម្ភរបស់ចិនចំពោះលក្ខណៈប្រកបដោយគ្រោះថ្នាក់ដោយសារ «កន្លែងទំនេរ» ដែលទើបនឹងកើតមានថ្មីៗក្នុងតំបន់ វិចារណកថាមួយរបស់កាសែតញ៉ានហ្សិន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៥ សប្បាយចិត្តនឹងការវិនាសអន្តរាយខ្សែបន្ទាត់ការពាររបស់អាមេរិកាំងនេះណាស់ ។ វិចារណកថាបានធ្វើអធិប្បាយថា ជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនវៀតណាមបានជួយធ្វើឲ្យមានការផ្លាស់ប្ដូរទាំងស្រុង នូវតុល្យភាពនៃកម្លាំងទាំងអស់ក្នុងពិភពលោក... ។ អំណឹះតទៅលក្ខណៈសម្បត្តិគ្រប់បែបយ៉ាងបានត្រូវប្រមូលផ្ដុំដើម្បីឲ្យប្រជាជនភូមិភាគរបស់យើងរំដោះខ្លួនពីភាពចំណុះគេនៅចំពោះមុខចក្រពត្តិនានា[២២] ។ ប្រការនេះ ក្រុងប៉េកាំងពុំយល់ច្រឡំសោះឡើយ ។ ដោយសេចក្ដីប្រកាសបែបនោះបានធ្វើឲ្យក្រុងហាណូយទាមទារថាខ្លួនជាអ្នកមានតួនាទីដឹកនាំក្នុងដំណើរចាត់ចែងការបដិវត្តន៍នៅអាស៊ីអាគ្នេយ៍ ។

ខ្ញុំធ្លាប់មានទស្សនៈទូទៅមួយអំពីការទទួលអារម្មណ៍សប្បាយក្នុងចិត្ត ដែលស្ថិតមានមួយរយៈនៅទីក្រុងហាណូយ ក្នុងឱកាសនៃការដើរទស្សនាមួយដែលខ្ញុំបានធ្វើនៅរដូវក្ដៅឆ្នាំ១៩៧៥ ។ ក្នុងទីក្រុង ខ្ញុំគ្មានឃើញអ្វីក្រៅពីកងទ័ពប្រដាប់អាវុធដែលដើរដេរដាសគ្រប់ទីកន្លែង និងពោរពេញទៅដោយប័ណ្ណបិទផ្សាយជាសាធារណៈដែលអំពាវនាវឲ្យមានបដិវត្តន៍ទូទាំងពិភពលោកឡើយ ។ ក្រុងហាណូយបានផ្ដល់នូវការសប្បាយក្នុងភាពស្ងប់ស្ងាត់ ។ ពិភពមនុស្សមួយដែលផ្ទុយគ្នាទាំងចិត្តទាំងថ្លើម បានខណ្ឌចែករដ្ឋធានីភាគខាងជើងពីក្រុងព្រៃនគរ ដែលខ្ញុំលែងរវល់ ចំពេលកំពុងមានវិបត្តិពេលកំពុងជ្រួលច្របល់ដោយសូរកង រំពងនៃយានយន្តនិងភាពអនាធិបតេយ្យ ។ មានរបស់តិចតួចណាស់ដែលផ្លាស់ប្ដូរនៅទីក្រុងហាណូយ តាំងពីការចាកចេញរបស់ពួកបារាំងពី

*ឥណ្ឌូចិនកាលពីម្ភៃមួយឆ្នាំមុន ។ ទីក្រុងមានភាពចំណាស់ប្រកបដោយភាពសមរម្យ ជាមួយមហាវិថីនានាដែលមានម្លប់ត្រឈឹងត្រឈៃ និងបឹងទាំងឡាយរបស់ខ្លួនដែលមានលក្ខណៈ កេរ្សមក្សាន្ត, ភាពស្ងប់ស្ងាត់នៃវិថីនានាដែលទើបនឹងធ្វើឲ្យបាត់សណ្តាប់ធ្នាប់ដោយសូរសំឡេងរងំដាច់ៗពីគ្នា នៃហ្វូងទោចក្រយានយ៉ាងច្រើន តែទីក្រុងបានបង្ហាញឲ្យឃើញបរិយាកាសទុកចិត្តមួយឥតភ័យព្រួយ ។ នៅពេលដែលយើងសន្ទនាគ្នានៅក្នុងអគារក្រសួងការបរទេសដែលមានរចនាប័ទ្មអាណានិគម ង្វៀន បានសូត្រឲ្យខ្ញុំស្តាប់នូវកម្រងកំណាព្យសម័យសតវត្សរ៍ទី១៥មួយដែលសរសេរបន្ទាប់ពីការចាកចេញពីវៀតណាមនៃរាជវង្សមិញ ជាអ្នកលុកលុយចុងក្រោយថា ៖*

- *លែងមានត្រីឆ្លាមក្នុងសមុទ្រ*
- *ហើយក៏លែងមានសត្វសាហាវលើដីដែរ*
- *ផ្ទៃមេឃមានសភាពស្រឡះល្អ*
- *ពេលនេះជាពេលដែលត្រូវកសាងសន្តិភាព សម្រាប់រយៈពេលដប់ពាន់ឆ្នាំទៅមុខទៀត ។*

*វៀតណាមបានត្រូវធ្វើឲ្យវិងស៊ុងនឹងគេជដៃក្នុងសង្គ្រាមរបស់គេនៅឡើយ ។ ក្នុងពេលវេលាដ៏ខ្មៅងងឹតនៃសង្គ្រាម នៅពេលដែលយន្តហោះបេ-៥២របស់អាមេរិកាំងទម្លាក់គ្រាប់បែកមកលើភាគខាងជើង ហើយដែលយុវជនរាប់ពាន់នាក់ចេញដំណើរទៅវាយប្រយុទ្ធនៅភាគខាងត្បូងដោយមិនដែលវិលត្រឡប់មកវិញនោះ កម្រមានអ្នកណាដែលសង្ឃឹមរស់រានជីវិតបានយូរបន្តរ ដើម្បីមើលជ័យជម្នះដែលនិយាយទុកជាមុនដោយ ហូជីមិញ ណាស់ ។ បន្ទាប់ពីការស៊ូទ្រាំក្នុងសង្គ្រាមនិងទទួលបានជ័យជម្នះលើប្រទេសមហាអំណាចដ៏ខ្លាំងផុតលេខនៃភពផែនដី អ្វីៗទាំងអស់ហាក់ដូចជាអាចកើតមាន ។ អំណឹះតទៅប្រទេសវៀតណាមបានប្រុងប្រៀបជាស្រេចដើម្បីកាន់កាប់កន្លែងនាំមុខគេឡើងវិញ ហើយឈមមុខតតាំងនឹងបណ្តាសត្រូវក៏ដូចបណ្តាមិត្តរបស់ខ្លួន និងអាចនិយាយដោយសំឡេងផ្ទាល់របស់ខ្លួនថែមទៀត ។*

*ដោយខ្វល់ខ្វាយចិត្ត ប្រទេសចិនបានឆ្លៀតទាញប្រយោជន៍ក្នុងឱកាសបុណ្យខួបលើកទី៣០ របស់ប្រទេសវៀតណាមខាងជើង ដើម្បីឲ្យដំណឹងពួកមេដឹកនាំក្រុងហាណូយដោយផ្ទាល់អំពីការព្រួយបារម្ភរបស់ខ្លួន ។ ប្រទេសចិនបានចាត់ឲ្យឧត្តមសេនីយ៍ ចេន ស៊ីលាន សមាជិកការិយាល័យនយោបាយដឹកនាំគណៈប្រតិភូមួយទៅចូលរួមពិធីបុណ្យដែលរៀបចំនៅក្រុងហាណូយ ។ ចេន ជាមនុស្សមានមាឌក្រអាញម្នាក់ ។ ជាមេបញ្ជាការយោធភូមិភាគប៉េកាំង គាត់បានដឹកនាំបញ្ជាកងទ័ពចិនដោយផ្ទាល់ ក្នុងឱកាសមានការប៉ះទង្គិចគ្នាតាមព្រំដែនចិន-សូវៀតកាលពីឆ្នាំ១៩៦៩ ។ ដូច្នេះ គាត់ពិតជាមនុស្សមានអំណោយទានដើម្បីរំឭកក្រុងហាណូយឲ្យប្រុងប្រយ័ត្នប្រឆាំងនឹងគ្រោះថ្នាក់ដែលបង្ហាញឲ្យឃើញដោយក្រុងមូស្គូនៅអាស៊ី ។ នៅក្នុង “ឱកាសពិធីបុណ្យមួយដែលប្រព្រឹត្តទៅនៅក្នុងរោងចក្រដែកថែប ថៃ ង្វៀន (Thai Nguyen) ដែលស្ថាបនាដោយពួកចិន, ដែលត្រូវទម្លាក់គ្រាប់បែកក្នុងអំឡុងសង្គ្រាមហើយដែលកសាងឡើងវិញដោយជំនួយរបស់ក្រុងប៉េកាំង ចេន បាននិយាយ*

សរសើរពីការប្រយុទ្ធ “ប្រឆាំងអនុត្តរភាព” (ជាភាសាប្រើក្នុងមជ្ឈដ្ឋានដោយឡែកគឺប្រឆាំងសូវៀត) ក្នុងពិភពលោក ។ គាត់បានរំឭកពួកម្ចាស់ផ្ទះថា “ការវាយប្រយុទ្ធរបស់បណ្តាមហាអំណាចផុតលេខដើម្បីអនុត្តរភាព” និយាយម្យ៉ាងទៀត គឺការប៉ុនប៉ងរបស់សូវៀត ដើម្បីកាន់កាប់កន្លែង ទំនេរ បានប្រែក្លាយទៅជាសាហាវឡើងៗ ហើយដែលវាបង្កើននូវគ្រោះថ្នាក់ផ្សេងៗនៃសង្គ្រាមថែមទៀត ។ នៅពេលដែល ចេន ទៅដល់ក្រុងហាណូយនៅថ្ងៃទី៣១ ខែសីហា នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង បានមកទទួលដោយចាប់ឱបរឹតគាត់នៅជើងជណ្តើរយន្តហោះ ទៅតាមប្រពៃណីមួយដែលមានឫសគល់តាំងពីជំនាន់យុទ្ធសាមគ្គីភាពម៉្លេះ ។ ប៉ុន្តែ សេចក្តីគួរសមនិងការពោលអះអាងពីឯករាជ្យជាតិ ពុំមែនជាការធ្វើឲ្យស្រុះស្រួលនឹងគ្នាដោយខានមិនបាននោះទេ ៖ ក្នុងសេចក្តីរាយការណ៍ដែលបោះពុម្ពផ្សាយដោយសារព័ត៌មានក្រុងហាណូយ ការនិយាយយោងពីអនុត្តរភាពក្នុងសន្ទរកថារបស់ ចេន បានត្រូវដកចោលទាំងអស់ ។ ប្រវត្តិសាស្ត្រមិនភ្លេច “ឱកាសមួយដើម្បីយកប្រៀបលើក្រុងប៉េកាំងឡើយ” ចំណែកវិទ្យុមូស្គូបានចាប់ថ្នាក់ ចេន ដោយហៅសកម្មភាពរបស់គាត់ថា មានលក្ខណៈ “បង្កហេតុខាងនយោបាយ”បន្តិច ។ អ្នកធ្វើអត្ថាធិប្បាយ បានបន្តថា ៖ “ប្រជាជនវៀតណាមចេះធ្វើការបែងចែករវាងសត្រូវម្នាក់ និងមិត្តម្នាក់” និងចេះឲ្យតម្លៃចំពោះការគាំទ្រដ៏មានតម្លៃ និងមិនគិតប្រយោជន៍ផ្ទាល់ខ្លួនដែលសហភាពសូវៀតនាំមកផ្តល់ឲ្យគេ[២៣] ។

ការតបតគ្នាជាសាធារណៈរវាងក្រុងមូស្គូនិងប៉េកាំងស្តីពីបញ្ហាចង់ដឹងថា អ្នកណាមួយដែលក្រុងហាណូយនឹងជ្រើសរើសដើម្បីដាក់ខ្លួនក្រោមឱវាទគឺពិតជាមានប្រផ្នូលមិនល្អសម្រាប់ជោគជ័យនៃនយោបាយរបស់វៀតណាម ដែលសម្រេចដាក់ខ្លួនដាច់ដោយឡែកពីជម្លោះរវាងមហាអំណាចជាបងប្អូនទាំងពីរផងនិងសុំជំនួយផង ។ ថ្ងៃទី២២ ខែកញ្ញា នៅពេលដែល ឡេ យន់ និង ឡេ ថាញ់ងី ចាប់ផ្តើមធ្វើដំណើរទៅក្រុងប៉េកាំង ដើម្បីអរគុណពួកមេដឹកនាំចិន និងសុំឲ្យបន្តជំនួយថែមទៀត វាលេចឡើងយ៉ាងច្បាស់ថា ភាពប៉ិនប្រសប់ប្រើល្បិចកលរបស់វៀតណាមនឹងត្រូវពិសោធមើលយ៉ាងតឹងតែងមិនខាន ។ មួយថ្ងៃមុនការចេញដំណើររបស់អ្នកទាំងពីរ ដំណឹងមួយដែលចេញមកពីក្រុងប៉េកាំងបានឲ្យដឹងជាមុនពីប្រភេទសុន្ទរកថា ដែលពួកមេដឹកនាំចិនប្រាថ្នាចង់ស្តាប់ពីមាត់របស់ ឡេ យន់ ផ្ទាល់ ។ នៅក្រោយពេលជួបគ្នាតាមការណាត់មួយជាមួយប្រធាន ម៉ៅ និង តេង ស៊ាវពីង អតីតនាយករដ្ឋមន្ត្រីអង់គ្លេស អេដវឺដ ហីត បានប្រកាសក្នុងសន្និសីទកាសែតមួយថា បំណងប្រាថ្នារបស់ក្រុងមូស្គូដែលព្រមទទួលមូលដ្ឋានយោធាជាច្រើននៅប្រទេសវៀតណាមហាក់ដូចជាធ្វើឲ្យ ម៉ៅ ប្រែទៅជាមនុស្សអំពល់ក្នុងចិត្ត ។ ប៉ុន្តែគាត់យល់ថា ប្រទេសចិនមិនជឿ ពីឥទ្ធិពលយូរអង្វែងមួយរបស់ក្រុងមូស្គូលើប្រទេសវៀតណាមឡើយ យ៉ាងហោចក្នុងរយៈពេលវែងដែរ ព្រមទាំងការទទួលបានមូលដ្ឋាននាវាចរផង ។ តាមរយៈ ហីត គឺត្រង់នេះឯងជាសញ្ញាមួយដែលគេអាចយល់កាន់ តែច្បាស់ពីបំណងរបស់ក្រុងហាណូយ ។ ឥឡូវនេះវាដល់ពេលដែល ឡេ យន់ ត្រូវធ្វើឲ្យជំហររបស់ប្រទេសចិនរឹតតែរឹងមាំឡើងក្នុងសុទិដ្ឋិនិយមរអែងប្រយ័ត្ននេះហើយ ។

## ការផ្ដើមបំបាក់មុខមួយចំពោះប្រទេសចិន

ការទទួល ឡុង យន់ នៅក្រុងប៉េកាំងនាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ប្រហែលជាមិនសូវអធិកអធម ដូចការទទួល ខៀវ សំផន និង អៀង សារី កាលពីខែមុនឡើយ ។ នៅពេលចុះពីលើយន្តហោះ យន់ ត្រូវបានទទួលដោយ តេង ស៊ាវពីង និងឥស្សរជនល្បីល្បាញមួយក្រុមដែលសុទ្ធតែជាមេដឹកនាំជាន់ខ្ពស់ ។ យន់ បានដើរត្រង់ជាប្រពៃណីទៅរកជួរកងទ័ពរំដោះប្រជាជនដែលឈរជារបងកិត្តិយស, ទទួលបាច់ផ្កានិងរបាំស្វាគមន៍ដែលសម្ដែងដោយក្រុមយុវជនប៉េកាំង ។ តេង ដែលកាលណោះអាយុ៧១ឆ្នាំ (ស្លាប់នៅឆ្នាំ១៩៩៧ក្នុងជន្មាយុ៩៣ឆ្នាំ) កាលពីមុនធ្លាប់ត្រូវពួកឆ្មាំក្រហមប្រមាថកាតទាន [ឆ្មាំក្រហមជាចលនាយុវជនចិនដែល ម៉ៅ បង្កើតឡើងសម្រាប់ការពារបដិវត្តវប្បធម៌នៅប្រទេសចិនក្នុងអំឡុងឆ្នាំ១៩៦៦-១៩៦៩ -កំណត់របស់អ្នកបកប្រែ] ដោយចាត់ទុកថាជា“អ្នកដឹកមុខលទ្ធិចក្រពត្តិនិយម”នោះ បានទទួលរងទុក្ខទោសអស់រយៈបួនឆ្នាំនៅក្នុងបន្ទាយទាហានមួយ ក្នុងឋានៈជាអ្នកលាងសម្អាតសាលបរិភោគបាយរបស់នាយទាហាននៅទីនោះ ។ ត្រូវធ្វើឲ្យមាននីតិសម្បទាឡើងវិញដោយ ជូ អេនឡាយ នៅឆ្នាំ១៩៧៣ ការទទួលធ្វើបដិសណ្ឋារកិច្ច ឡុង យន់ ប្រហែលជាការលេចមុខចុងក្រោយរបស់គាត់ជាសាធារណៈហើយមើលទៅមុននឹងជោគជតារាសីរបស់គាត់ធ្លាក់ចុះជាថ្មីទៀត ។ លើទីលាន ទៀនអានម៉េន នៅក្រុងប៉េកាំង គេឃើញមានគោមពណ៌ក្រហមនិងពណ៌ទឹកមាសធំៗ ទង់ជាតិនិងទង់ជ័យលាស្អេកស្កះដែលបង្ហាញឲ្យឃើញពីមិត្តភាពរវាងប្រជាជនទាំងពីរ ។ ប៉ុន្តែ បរិយាកាសរីករាយប្រែទៅជាសោះកក្រោះភ្លាមមួយរំពេច ក្នុងពិធីជប់លៀងជូនភ្ញៀវ ។ តេង បានថ្លែងសុន្ទរកថាស្វាគមន៍មួយដែលមានទម្រង់ជា“ធម៌ទេសនា” ស្ដីពីគុណវិបត្តិផ្សេងៗនៃនយោបាយ“អនុត្តរភាពនិយម” ។ ក្នុងការវិនិច្ឆ័យពីមិត្តភាពរវាងវៀតណាម-សូវៀត តេង បានចៀសវាងមិននិយាយពីពួកសូវៀតចំៗឡើយ ដោយចូលចិត្តលើកឡើងជាទូទៅពីពួកមហាអំណាចផុតលេខជាង ។ តេង បានក្រើនរំឭកវៀតណាមថា “ឥឡូវនេះមានប្រទេសកាន់តែច្រើនឡើងដឹងខ្លួនថា ការវាយប្រយុទ្ធនឹងអនុត្តរភាពនិយមរបស់បណ្ដាប្រទេសមហាអំណាច គឺជាភារកិច្ចមួយសំខាន់ស្មើអាយុជីវិតរបស់ប្រជាជនគ្រប់ប្រទេសទាំងអស់” ។ នៅពេលរំឭកពីទំនាក់ទំនងផ្សេងៗរវាងប្រទេសចិននិងវៀតណាម តេង ពុំមានប្រើប្រាស់ឃ្លាប្រយោគសម្រាប់ប្រើជាផ្លូវការ (ដែលស្មើរដូចឃ្លាថា “សាមគ្គីស្អិតល្មួតដូចបបូរមាត់និងធ្មេញ”) ឡើយ ។ ចំពោះ ឡេយន់ គាត់ត្រូវបានធ្វើឲ្យដឹងខ្លួនឡើងវិញថា ការខបត្ថម្ភគាំពារនិងការអភិវឌ្ឍន៍ចំណងមិត្តភាព គឺជាផលប្រយោជន៍សំខាន់ស្មើអាយុជីវិតរវាងប្រទេសយើងទាំងពីរ[២៤] ។

យន់ ពុំមានមុខនៅពិធីជប់លៀងដំបូងរបស់គាត់ក្នុងមហាសាលនៃវិមានប្រជាជន ដែលគុបតែងលំអដោយដើងទៀនជាច្រើនទេ ។នេះជាលើកទីមួយហើយ ដែល ឡេយន់ មកកាន់ក្រុងប៉េកាំងពុំត្រឹមតែមកសុំជំនួយមួយមុខប៉ុណ្ណោះទេ ប៉ុន្តែដើម្បីបញ្ជាក់អះអាងពីជំហររបស់វៀតណាមដែលរួមគ្នាតែមួយ និងឯករាជ្យផង ។ គាត់បានថ្លែងសរសើរយ៉ាងច្រើនពីជោគជ័យរបស់ចិនក្នុងការកសាងលទ្ធិសង្គមនិយម ។ វៀតណាមបាន

សម្ដែងនូវ «មនោសញ្ចេតនាយ៉ាងកក់ក្ដៅបំផុតនិងការដឹងគុណយ៉ាងជ្រាលជ្រៅផុសចេញពីក្រអៅបេះដូងពិតៗ» ចំពោះជំនួយរបស់ចិន ។ ដោយគួរសម ប៉ុន្តែម៉ឺងម៉ាត់ យន់ បានគូសបញ្ជាក់ថា គាត់មិនយល់ស្របនឹង«ទស្សនៈពិភពលោក»របស់បណ្ដាមេដឹកនាំគាត់ទេ ។ ដោយកត់សម្គាល់ថា ជ័យជម្នះរបស់វៀតណាមពុំអាចកើតមានទេ បើសិនជាគ្មានសមានចិត្តនិងជំនួយដ៏សន្ធឹកសន្ធាប់ និងដ៏មានតម្លៃរបស់បណ្ដាប្រទេសសង្គមនិយមជាបងប្អូន និយាយដោយឡែក គឺប្លុកសូវៀតតែម្ដង ។ យន់ បានបន្តដោយពាក្យពេចន៍របៀបនេះថា «ចំពោះមូលហេតុនេះ ជ័យជម្នះរបស់យើងគឺជាជ័យជម្នះរួមរបស់បណ្ដាកម្លាំងសង្គមនិយមដែលស្រឡាញ់ឯករាជ្យជាតិប្រជាធិប-តេយ្យ និងសន្តិភាពក្នុងការតស៊ូរួមប្រឆាំងនឹងចក្រពត្តិនិយមដែលមានអាមេរិកាំងជាមេខ្លោង» ។ ពោលដោយខ្លី វៀតណាមនឹងមិនចូលរួមជាមួយប្រទេសចិនក្នុងយុទ្ធនាការប្រឆាំងសហភាពសូវៀតឡើយ ។ ប៉ុន្តែថ្វីដ្បិតតែមានការខ្វែងមតិគ្នាផ្នែកនយោបាយទាំងនេះក៏ដោយ ក៏ យន់ នៅតែទទូចសុំជំនួយរបស់ចិន ។ គាត់បានរំឭកប្រាប់ម្ចាស់ផ្ទះថា ប្រជាជនវៀតណាម«ត្រូវធ្វើឲ្យជឿជាក់យ៉ាងម៉ឺងម៉ាត់ថា ក្នុងសម័យកាលថ្មីនេះក៏ដូចក្នុងអតីតកាល ពួកគេនឹងនៅតែទទួលគុណប្រយោជន៍ពីការគាំទ្រដ៏កក់ក្ដៅនិងជំនួយ ដ៏ច្រើនសន្ធឹកសន្ធាប់»របស់ប្រទេសចិនជានិច្ច[២៥] ។ នៅក្រុងហាណូយ ទីភ្នាក់ងារព័ត៌មានវៀតណាមបានហាមមិនឲ្យផ្សាយក្នុងសេចក្ដីរាយការណ៍របស់គាត់ នូវការនិយាយយោងទាំងអស់ដែលលើកឡើងដោយ តេង ស្ដីពីអនុត្តរភាពនិយមរបស់មហាអំណាចផុតលេខនានាទេ ។

យន់ នៅតែធ្វើមិនដឹងមិនឮចំពោះទស្សីករណ៍ផ្សេងៗរបស់ប្រទេសចិនដែលជាផលនៃការពង្រឹងរបស់ក្រុងប៉េកាំងទៅលើបញ្ហាជំនួយខាងផ្នែកសេដ្ឋកិច្ច ។ ប្រាំសប្ដាហ៍មុន ឡេថាញ់ងី ដែលពួកចិនដាក់រហស្សនាមថា «ស្មូមយាចក» ដោយសារតែការធ្វើដំណើរជាញឹកញាប់របស់គាត់ទៅទីក្រុងប៉េកាំងនោះបានធ្វើដំណើរមករដ្ឋធានីចិនជាថ្មីម្ដងទៀត ដើម្បីស្នើសុំជំនួយពីប្រទេសចិន[២៦] ។ នៅខែមិថុនា ឆ្នាំ១៩៧៣ នៅពេលដែល ជូ អេនឡាយ ផ្ដល់យោបល់ឲ្យ យន់ បញ្ឈប់ការវាយប្រយុទ្ធនៅភាគខាងត្បូងរយៈពេលពីរឆ្នាំនោះជាថ្នូរមកវិញ ជូ បានសន្យាថានឹងបន្តជំនួយឲ្យវៀតណាមរយៈពេលប្រាំឆ្នាំទៀតលើមូលដ្ឋាននៃជំនួយឆ្នាំ១៩៧៣ ។ ប៉ុន្តែនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៥ មតិរបស់ជនម្នាក់មានលក្ខណៈខុសប្លែកទាំងស្រុង ។ ងី បានទៅសួរសុខទុក្ខ ជូ ដែលកំពុងត្រដរខ្យល់ជិតផុតដង្ហើមទៅហើយ ។ តាមសេចក្ដីរាយការណ៍មួយដែលចេញផ្សាយក្រោយមកដោយកាសែត *Peking Review* បានឲ្យដឹងថា ជូ បានថ្លែងប្រាប់ភ្ញៀវរបស់គាត់ថា «ក្នុងសម័យសង្គ្រាមនៅពេលដែលប្រទេសលោកត្រូវអត់ស្បៀង យើងបានដកយករបបពីកងទ័ពរបស់យើងផ្ទាល់ដើម្បីយកទៅជួយពួកលោក ។ យើងបានធ្វើការប្រឹងប្រែងមួយយ៉ាងសម្បើម ។ សរុបទៅ សព្វថ្ងៃនេះជំនួយរបស់យើងដែលផ្ដល់ឲ្យប្រទេសវៀតណាមនៅតែមានសារសំខាន់ជាងជំនួយដែលយើងបានសម្រេចផ្ដល់ដល់បណ្ដាប្រទេសក្រៅទៅទៀត ។ សូមទុកឲ្យយើងធូរស្រាលបន្តិចដើម្បីអនុញ្ញាតឲ្យយើងពង្រឹងកម្លាំងឡើងវិញ»[២៧] ។

យន់ ពិនិត្យឃើញថា ក្រុមមេដឹកនាំចិនបានសម្រេចចិត្តបន្តឲ្យមានបញ្ហាជាថ្មីដោយម៉ឺងម៉ាត់បំផុតអំពីជំនួយជាប្រាក់និងជំនួយស្បៀងអាហារសរុបដែលចិនបានសន្យាផ្តល់ឲ្យកាលពីពេលកន្លងមក ។ ក្រុមមេដឹកនាំចិននិយាយថា សង្គ្រាមបានផុតរលត់ទៅហើយ ពេលនេះប្រទេសវៀតណាមត្រូវតែចិញ្ចឹមប្រជាជនខ្លួនឯងដោយមធ្យោបាយផ្ទាល់របស់ខ្លួន ។ ងី ដែលទៅជួប ម៉ៅ នោះ បានប្រឹងប្រែងធ្វើឲ្យមានការយោគយល់មកលើរូបគាត់ដែរ ។ ងី និយាយថា «បើគ្មានប្រទេសចិនដែលយើងចាត់ទុកជាមូលដ្ឋានបង្អែកដ៏រឹងមាំមួយ គ្មានដំបូន្មាន គ្មានជំនួយ យើងពិតជាគ្មានសំណាងណាមួយទទួលបានជ័យជម្នះឡើយ ។ យើងនៅតែវាយតម្លៃជាប់ជានិច្ចថា មានតែប្រទេសចិនទេដែលអាចមកជួយឧបត្ថម្ភដោយផ្ទាល់និងគ្មានរួញរាក្នុងកាលៈទេសៈសំខាន់ៗ ដែលជោគវាសនារបស់យើងពើបប្រទះនឹងឧបសគ្គផ្សេងៗ គឺពុំមែនសហភាពសូវៀតទេ»[២៨] ។ ការលើកសរសើរហួសហេតុនេះបានត្រឹមតែទទួលផលប្រយោជន៍មានកម្រិតកំណត់មួយប៉ុណ្ណោះ ៈ គឺការឲ្យខ្ចីឥណទានមួយដោយគ្មានយកការប្រាក់ ដើម្បីទ្រទ្រង់ការនាំចូលប្រេងឥន្ធនៈ និងគ្រឿងឧបភោគបរិភោគ ។ ប៉ុន្តែ ងី បានបង្ហាញឲ្យឃើញថា ក្រុងប៉េកាំងពុំទាន់ «គូសសញ្ញាខ្វែងដើងក្អែកមួយ» ជាស្ថាពរមកលើប្រទេសវៀតណាមនៅឡើយទេ ។ សញ្ញាឯទៀតៗនឹងមានដំណើរទៅក្នុងទិសតែមួយគឺ សុឆន្ទៈដែលសម្តែងឲ្យឃើញស្តីពីបញ្ហាប្រជុំកោះប៉ារ៉ាសែល និងស្ព្រាតលី ។ ពួកចិនមិនទាន់បិទទ្វារប្រទេសទេ ។ ក្នុងការសន្ទនារបស់គាត់ នៅថ្ងៃទី២៤ ខែកញ្ញា ជាមួយឡេយន់, តេង បានដកចោលទស្សនៈ ផ្លូវការរបស់គាត់ដែលថា ប្រជុំកោះទាំងនោះជា«ចំណែកដ៏ពិសិដ្ឋនៃដែនដីចិន» និងដែលមិនអាចចរចាបាន ។ គាត់បានទទួលស្គាល់ការស្ថិតមានអធិករណ៍មួយដែលធ្វើឲ្យឃើញឡើងតាមការចរចាទ្វេភាគី[២៩] ។

ប៉ុន្តែអំណឹះតទៅ ភាសាមិនស៊ីខ្សែគ្នាផ្នែកនយោបាយរវាងភាគីទាំងពីរមានលក្ខណៈធ្ងន់ធ្ងរបំផុត ហើយការខកចិត្តរបស់ យន់ ក៏មានលក្ខណៈខ្លាំងណាស់ដែរ ។ នៅឆ្នាំ១៩៧៣ ក្នុងអំឡុងដំណើរផ្លូវការចុងក្រោយរបស់គាត់ទៅកាន់ប្រទេសចិន គាត់បានលុបចោលពិធីជប់លៀងលាគ្នាជាប្រពៃណីមួយដើម្បីជាកិត្តិយសដល់ម្ចាស់ផ្ទះ ។ នេះជាការសម្រេចចិត្តមួយ ដែលក្រោយមកមន្ត្រីចិនម្នាក់បានចាត់ទុកថា ៈ «ជាអាកប្បកិរិយាឈ្លើយខុសគេ ដែលចេញមកពីមេដឹកនាំបក្សជាបងប្អូនម្នាក់»[៣០] ។ ថ្ងៃទី២៥ ខែកញ្ញា យន់ បានជិះរថភ្លើងត្រឡប់មកក្រុងហាណូយវិញកាត់តាមទីក្រុងទៀងស៊ីន ។ ប្រទេសវៀតណាមក្រោយសម័យសង្គ្រាម ទើបនឹងដាក់ទោសក្រុងប៉េកាំងចំពោះការទទួលស្វាគមន៍ដោយគំរោះគំរើយជាសាធារណៈលើកដំបូងរបស់ខ្លួន ។

មួយខែក្រោយមក យន់ បានធ្វើដំណើរទៅក្រុងម៉ូស្គូ ។ គាត់បានទទួលពាក្យសន្យាពីសហភាពសូវៀត ក្នុងការផ្តល់ជំនួយរយៈពេលវែងមួយ ហើយបានយល់ព្រមចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយ ដើម្បីគាំទ្រជំហរផ្សេងៗរបស់សូវៀតខាងវិស័យនយោបាយបរទេស ។ ក្រោយមកមេដឹកនាំចិនម្នាក់បាននិយាយប្រាប់ខ្ញុំថា សេចក្តីថ្លែងការណ៍រួមសូវៀត-វៀតណាម នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៥ បញ្ជាក់ឲ្យឃើញពី«ការចុះ

ញ៉មរបស់វៀតណាមចំពោះមុខអនុត្តរភាពនិយម»[៣១] ។

ការរីកដុះដាលនៃស្ថានការណ៍ផ្ទៃក្នុងរបស់វៀតណាម អាចធ្វើឲ្យប្រទេសចិនផ្តល់នូវសារសំខាន់ថែមទៀតក្នុងការក្រែងរអែងរបស់ខ្លួនដែលមានលក្ខណៈទុទិដ្ឋិនិយមបំផុត ។ ថ្វីដ្បិតតែមានការគាំទ្ររបស់ខ្លួន ដោយវាចាចំពោះគោលដៅនៃការបង្រួបបង្រួមប្រទេសឡើងវិញ ដែលមានតម្លៃសម្រាប់ក្រុងហាណូយ ក៏ដោយ ក៏ក្រុងប៉េកាំងវិនិច្ឆ័យដោយគំនិតអាក្រក់យ៉ាងខ្លាំងពីទស្សនវិស័យនៃការរួបរួមគ្នាមួយខាងនយោបាយនិងរដ្ឋាភិបាលរបស់ប្រទេសទាំងពីរ ដែលអាចធ្វើឲ្យប្រែប្រួលតុល្យភាពកម្លាំងទាំងអស់នៅឥណ្ឌូចិន ។ ក្នុងសារសម្តែងការអបអរសាទរសើរដែលក្រុមមេដឹកនាំចិនផ្ញើទៅឲ្យប្រទេសវៀតណាម បន្ទាប់ពីជ័យជម្នះ ពួកចិនបានបង្ហាញឲ្យឃើញការព្រួយបារម្ភរបស់ខ្លួនដែលមិនឲ្យសម្គាល់បាន ។ ពួកគេបានសរសេរថា «យើងសូមជូនពរដោយស្មោះស្ម័គ្រ ដែលប្រជាជនវៀតណាមខាងត្បូងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ជានិច្ចក្នុងការប្រយុទ្ធដ៏ខ្លាប់ខ្ជួនរបស់ខ្លួន ដើម្បីដឹកនាំបដិវត្តន៍ជាតិនិងប្រជាធិបតេយ្យឲ្យបានសម្រេចផលល្អ»[៣២] ។ ដូច្នេះ ដោយធ្វើឲ្យមានរហូតទៅថា ជ័យជម្នះនេះ គឺជាស្នាដៃដ៏សំខាន់លើសលប់របស់ប្រជាជនវៀតណាមខាងត្បូង ហើយពុំមែនជាស្នាដៃរបស់កងទ័ពនិងគ្រឿងសាស្ត្រាវុធរបស់វៀតណាមខាងជើងទេនោះ ពួកចិនបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា មនោសញ្ចេតនារបស់គេនឹងលំអៀងទៅរកភាគខាងត្បូងជាងដែលខ្លួនចង់ឲ្យមានប្រព័ន្ធសង្គមកិច្ចមួយខុសប្លែកពីប្រព័ន្ធសង្គមកិច្ចសង្គមនិយមនៅភាគខាងជើង ។

ក្នុងបណ្តាខែដំបូងៗដែលមានបន្តពីជ័យជម្នះ ពួកមេដឹកនាំវៀតណាមបានសម្តែងឲ្យដឹងពីបំណងចង់រក្សាទុកប្រព័ន្ធសង្គមកិច្ចនិងសេដ្ឋកិច្ចមួយផ្សេងនៅភាគខាងត្បូងក្នុងរយៈពេលប្រាំឆ្នាំយ៉ាងហោច មុននឹងធ្វើការរំលាយបញ្ចូលគ្នាជាមួយភាគខាងជើងសង្គមនិយម[៣៣] ។ ក្នុងសុន្ទរកថាមួយដែលថ្លែងក្នុងក្របខ័ណ្ឌនៃពិធីបុណ្យអបអរជ័យជម្នះនៅថ្ងៃទី១៥ ខែឧសភា ឡេយន់ បានប្រកាសថា ភាគខាងត្បូងនឹងយកចិត្តទុកដាក់កសាង«របបប្រជាធិបតេយ្យជាតិ»មួយ ដែលក្នុងភាសាដោយឡែកនៃលទ្ធិម៉ាក្សស៊ីស មានន័យថា ជារដ្ឋបុរេសង្គមនិយមមួយ ។ ម្យ៉ាងទៀត រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូងបានដាក់បេក្ខភាពរបស់ខ្លួនដើម្បីសុំអាសនៈមួយនៅអង្គការសហប្រជាជាតិដោយរបៀបស្វយ័ត ។ បន្ទាប់ពីមានបទពិសោធន៍ក្នុងការគ្រប់គ្រងកិច្ចការផ្សេងៗរយៈពេលប្រាំមួយខែនៅភាគខាងត្បូង ពួកមេដឹកនាំបក្សកុម្មុយនីស្តវៀតណាមយល់ឃើញថាវាមានផលអាក្រក់ច្រើនជាងអត្ថប្រយោជន៍ដែលត្រូវពន្យឺតការបង្រួបបង្រួមប្រទេសឡើងវិញ ។ ដូច្នេះ បើសិនជាលុបបំបាត់រចនាសម្ព័ន្ធអ្នកមានមូលធននៅភាគខាងត្បូងលឿនរហ័សពេក វាមុខជានឹងបណ្តាលឲ្យមានការរំដើបរំជួលនិងការតស៊ូមិនខាន ។ ការរក្សារបៀបគ្រប់គ្រងមួយដែលផ្តល់សេរីភាពក្នុងការបង្កើតសហគ្រាសមុខជាបង្កឲ្យមានការជ្រួលច្របល់ដែរ ដោយសារការខ្វះក្របខ័ណ្ឌអ្នកធ្វើការដែលមានសមត្ថភាព ហើយរឹតតែធ្ងន់ធ្ងរជាងនេះ គឺវាធ្វើឲ្យអ្នកដែលមាននិន្នាការផ្តាច់ខ្លួននៅភាគខាងត្បូងរឹតតែរឹងមាំថែមទៀត ។ ពួកមេដឹកនាំ

វៀតណាម បានពិនិត្យមើលជាមួយការព្រួយបារម្ភនូវខ្សែរយៈទាក់ទងគ្នាដោយផ្ទាល់រវាងក្រុមប៉េកាំងនិងពួកកុម្មុយនីស្តនៅភាគខាងត្បូង តាមរយៈមធ្យោបាយដោយមិនចំពោះនៅទីក្រុងច្រឹឡឹង ជាទីក្រុងមួយដែលភាគច្រើនជាជនជាតិចិន រួមទាំងការទាក់ទងដ៏ជិតស្និទ្ធរបស់ក្រុងប៉េកាំងជាមួយប្រទេសកម្ពុជាជិតខាងផង ។ ដោយសារប្រទេសចិនបង្ហាញពីគោលបំណងរបស់ខ្លួនដោយខ្លួនឯង ដើម្បីឲ្យមានការរក្សាទុកភាគខាងត្បូងនៅស្វយ័ត គឺដូចជាបន្ថែមទឡ្ហីករណ៍មួយជាគុណប្រយោជន៍ដល់ការបង្រួបបង្រួមប្រទេសឡើងវិញយ៉ាងឆាប់រហ័ស ។ តើនេះ មិនមែនដើម្បីប្រឆាំងនឹងការប្រើកលល្បិចដាយថាហេតុរបស់ក្រុងប៉េកាំងទេឬ? ។

ដោយមានការភ្ញាក់ផ្អើលជាទូទៅ សេចក្តីប្រកាសមួយដែលផ្សព្វផ្សាយដំណាលគ្នាតាមរលកធាតុអាកាសវិទ្យុក្រុងហាណូយ និងវិទ្យុក្រុងហូជីមិញ នៅថ្ងៃទី៩ ខែវិច្ឆិកា បានប្រកាសឲ្យដឹងពី«ការប្រជុំពិគ្រោះមួយ»ជើង-ត្បូង នៅពេលឆាប់ៗខាងមុខនេះដើម្បីរៀបចំការបង្រួបបង្រួមរដ្ឋាភិបាលទាំងពីរឡើងវិញ ។ ពីរ-បីសប្តាហ៍ក្រោយមក នៅពេលដែលការប្រជុំផ្សព្វផ្សាយជាសាធារណៈពីការសម្រេចចិត្តរបស់ខ្លួន ក្រុងហាណូយបានជោរជន់ទៅដោយសារលិខិតអបអរសាទរសើរជាច្រើនដែលចេញមកពីប្រទេសសង្គមនិយមនានា លើកលែងតែប្រទេសចិនមួយ ។

ការក្តៅក្រហាយកាន់តែរីកធំឡើងៗរបស់ក្រុងប៉េកាំង ចំពោះប្រទេសវៀតណាមបានសម្តែងឲ្យដឹងនៅថ្ងៃទី២៨ ខែវិច្ឆិកា គឺបីថ្ងៃបន្ទាប់ពីការបញ្ចប់ «ការប្រជុំពិគ្រោះ» នៅទីក្រុងហូជីមិញ ។ ប្រទេសចិនបានទម្លាយភាពស្ងៀមស្ងាត់ភ្លាមៗ ដែលខ្លួនបានតាមសង្កេតមើលរហូតមកទល់នឹងពេលនេះពីបញ្ហាប្រជុំកោះស្ព្រាតលីដែល«រំដោះ»នៅខែមេសាដោយកម្លាំងទ័ពរបស់ក្រុងហាណូយ ។ ក្នុងអត្ថបទដ៏វែងមួយរបស់កាសែត ហ្គនមិញដេលី ដែលសរសេរដើម្បីទប់ការយកចិត្តទុកដាក់របស់ប្រទេសវៀតណាមនោះ បានរំឭកពីការកាន់កាប់ត្រួតត្រាតាំងពីយូរយារណាស់មកហើយរបស់ប្រទេសចិនលើប្រជុំកោះប៉ារ៉ាសែលនិងស្ព្រាតលី ។ អត្ថបទនេះបានអធិប្បាយបញ្ជ្រាសនឹងជំហររបស់ គេង ដែលសម្តែងឲ្យដឹងនៅខែកញ្ញា គឺថាបញ្ហានៃនាទីរបស់ខ្លួនចំពោះប្រទេសមួយ ឬ ប្រទេសមួយទៀត នៅពុំទាន់សម្រេចទេ ។ ផ្ទុយទៅវិញ កាសែត ហ្គនមិញ ដេលី បានធ្វើឲ្យកម្រើកជាថ្មីនូវនិក្ខេបបទស្តីពី«ចំណែកដ៏ពិសិដ្ឋនៃដែនដីរបស់ប្រទេសចិន» និងព្រមានថា ប្រជុំកោះទាំងនោះ ដែលជាកម្មសិទ្ធិរបស់ចិនត្រូវតែវិលមកក្នុងផ្នែកនៃមាតុប្រទេសជាស្ថាពរវិញ[៣៤] ។

ត្រូវធ្វើឲ្យចាប់អារម្មណ៍តិចតួចពីការគំរាមបិទមុខនេះ ក្រុងហាណូយបានបន្តកម្មវិធីរបស់ខ្លួនក្នុងការពង្រឹងការត្រួតត្រាលើភាគខាងត្បូងនិងលើជនជាតិចិនមួយលានប្រាំសែននាក់ដែលរស់នៅក្នុងប្រទេសខ្លួនថែមទៀត ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ក្នុងក្របខ័ណ្ឌនៃការបោះឆ្នោតជ្រើសរើសសមាជិកសម្រាប់អនាគត រដ្ឋសភាជាតិ ការធ្វើជំរឿនប្រជាជនបានចាប់ផ្តើមជំរុញឲ្យប្រជាពលរដ្ឋទាំងអស់ប្រកាសពីសញ្ជាតិរបស់ខ្លួន ។ មនុស្សទាំងអស់ដែលប្រកាសថាខ្លួនមានសញ្ជាតិបរទេស ត្រូវបានដកហូតជាស្វ័យប្រវត្តិនូវសិទ្ធិពលរដ្ឋ និងរបបស្បៀងអាហារ

របស់ខ្លួន ។ អាណិកជនចិនមួយភាគយ៉ាងធំនៅភាគខាងត្បូង ត្រូវតែបង្ខំចិត្តប្រកាន់យកសញ្ជាតិវៀតណាម ។

ក្នុងរឿងនេះ ពួកចិនបានសម្គាល់ឃើញការរំលោភមួយលើកិច្ចព្រមព្រៀងដោយមាត់ទទេកាលពីឆ្នាំ១៩៥៥ រវាងប្រទេសចិននិងប្រទេសវៀតណាមខាងជើង-ដែលតាមរយៈនេះថា ពួកអាណិកជនចិនមិនអាចក្លាយទៅជាពលរដ្ឋវៀតណាមបានទេ ក្រៅពី«ការស្ម័គ្រចិត្ត»របស់អ្នកទាំងនោះ ប៉ុន្តែ ក៏រំលោភលើខសន្យាដូចគ្នាដែលឲ្យសច្ចាប័នដោយរណសិរ្សរំដោះជាតិនៅវៀតណាមខាងត្បូងផងដែរ ។ ប្រទេសចិនបានតវ៉ាជាឯកជនប្រឆាំងនឹងអ្វីដែលខ្លួនហៅថា «ការចូលសញ្ជាតិដោយបង្ខំ» នៃបណ្តាអាណិកជនរបស់ខ្លួន ។ នៅខែកុម្ភៈ និងខែមេសា ឆ្នាំ១៩៧៦ ការប្រជុំសម្ងាត់ដែលរៀបចំឡើងចំនួនបីលើក ដើម្បីសាកល្បងដោះស្រាយការវិវាទនេះគ្មានបានទទួលលទ្ធផលណាមួយឡើយ ។ បីឆ្នាំក្រោយមក រឿងនេះបានត្រូវឯកអគ្គរដ្ឋទូតវៀតណាមប្រចាំក្រុងប៉េកាំង ង្វៀង ត្រុងវិញ បំភ្លឺប្រាប់ខ្ញុំថា វៀតណាមបានអះអាងថា ប្រយោគ«តាមការស្ម័គ្រចិត្ត» គឺពុំមានក្នុងកិច្ចព្រមព្រៀងឆ្នាំ១៩៥៥ទេ ។ ពីរឆ្នាំក្រោយមកការប្រព្រឹត្តមិនល្អរបស់ក្រុងហាណូយ ចំពោះអាណិកជនចិន បានបញ្ឆេះឲ្យរឹតតែមានជម្លោះនឹងគ្នា និងបង្កការប្រឈមមុខដាក់គ្នារវាងចិន និងវៀតណាមថែមទៀត ។

ប្រហែលក្នុងពេលជាមួយគ្នាដែលត្រូវចាប់ផ្តើមធ្វើការជំរឿនប្រជាជនរបស់ខ្លួន និងរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកសម្រាប់រដ្ឋសភាជាតិបង្រួបបង្រួមមួយ ប្រទេសវៀតណាមបានបង្កើនការប្រឹងប្រែងរឹតតែខ្លាំង ដើម្បីពង្រឹងជំហររបស់ខ្លួននៅឥណ្ឌូចិនឲ្យកាន់តែរឹងមាំឡើងទៀត ។ ជាបឋមគឺ ប្រឹងប្រែងរឹតចំណងសម្ពន្ធភាពរបស់ខ្លួនជាមួយប្រទេសឡាវ បន្ទាប់មក ប្រឹងប្រែងបន្ថយជម្លោះទឹកដីរបស់ខ្លួនជាមួយប្រទេសកម្ពុជា ។ ដោយហេតុនេះ ពួកមេដឹកនាំក្រុងហាណូយបានវាយតម្លៃថា ការបង្កើតឲ្យមាននៅក្នុងប្រទេសនូវរដ្ឋាភិបាលបង្រួបបង្រួមមួយនិងក្បាលម៉ាស៊ីនសម្រាប់ធ្វើផែនការមួយ ត្រូវតែធ្វើព្រមគ្នានឹងការរឹតចំណងទាក់ទងមួយជាមួយបណ្តាប្រទេសជិតខាងនៅឥណ្ឌូចិន ដែលជាអាទិភាពចាំបាច់ខានមិនបានក្នុងការកសាងប្រទេសមួយដែលបំផ្លិចបំផ្លាញដោយសារសង្គ្រាមឡើងវិញ និងការចាប់ប្រតិបត្តិប្រែផ្លាស់ទ្រង់ទ្រាយប្រទេសទៅជាសង្គមនិយមវិញ ។ ប៉ុន្តែ ការចំអកបញ្ញឺនយោបាយនេះ ទៅជាមានលទ្ធផលធ្វើឲ្យប្រទេសចិន និងកម្ពុជា រួបរួមគ្នាក្នុងជម្លោះតែរៀងៗខ្លួនរបស់ពួកគេជាមួយប្រទេសវៀតណាមទៅវិញ ។ មូលហេតុផ្សេងៗនៃអរិភាព គឺប្រហែលជាខុសគ្នា ប៉ុន្តែ ប្រទេសកម្ពុជានិងចិនមានគំនិតប្រឆាំងដូចគ្នាចំពោះការលេចឡើងនូវប្រទេសវៀតណាមមួយ ដែលខ្លាំងពូកែទាំងធនធានទាំងកម្លាំងទ័ព និងអំណាចត្រួតត្រាគេ ។

តើនេះជាការប្រព្រឹត្តដោយគិតទុកជាមុន ឬជាភាពគាប់ជួនធម្មតា ព្រោះពីរថ្ងៃក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងយោធាជាសម្ងាត់រវាងចិន-ខ្មែរនៅក្រុងភ្នំពេញ វៀតណាមបានបោះជំហានមុនគេនៅលើផ្លូវនៃការបង្កើតឲ្យមានសម្ពន្ធ័ភាពឥណ្ឌូចិនមួយ ។ រដ្ឋមន្ត្រីទី១នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវនិងជាអគ្គលេខាបក្សប្រជាជនបដិវត្តន៍ឡាវ កៃសន ភូមិវិហាន ដែលជាសម្ព័ន្ធមិត្តដ៏យូរលង់របស់

វៀតណាមបានធ្វើដំណើរទៅក្រុងហាណូយ ដើម្បីធ្វើទស្សនកិច្ចដាច់ឯកជនមួយ ។ សេចក្តីថ្លែងការណ៍រួមដែលគាត់បានចុះហត្ថលេខាជាមួយ ឡេយន់ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៦ បានគូសបញ្ជាក់ថា «ទំនាក់ទំនងពិសេស» ដែលកំពុងស្ថិតមានរវាងប្រទេសទាំងពីរនឹងជួយសម្រួលដល់ទស្សនវិស័យនៃសហប្រតិបត្តិការដ៏យូរអង្វែងមួយ ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក និងកិច្ចសហការក្នុងការប្រឆាំងទល់នឹង «ចក្រពត្តិនិយមនិងពួកប្រតិកិរិយាស៊ីឈ្នួល» ។ សេចក្តីថ្លែងការណ៍ក៏បានសង្កត់បញ្ជាក់ពីចេតនារបស់បក្សទាំងពីរដើម្បី «បង្កើនសាមគ្គីភាពរវាងឡាវ-កម្ពុជានិងវៀតណាមកាន់តែរីកចម្រើនឡើង» ផងដែរ ។ ប្រការទាំងនេះគឺជានិមិត្តរូបនៃចេតនារបស់វៀតណាមដើម្បីបញ្ជាក់ពីការការកំណត់ជាអាទិភាពនៃនយោបាយស្និទ្ធវៀតណាមរបស់ឡាវ ។ ប៉ុន្តែដូចដែលអ្នកសង្កេតការណ៍ម្នាក់កត់សម្គាល់ក្រោយមកទៀត ពី«ការប្រើប្រាស់ប្រយោគ«ទំនាក់ទំនងពិសេស» ដែលអាចត្រូវគេបកស្រាយថា ជាការព្រមានមួយចំពោះប្រទេសចិននិងបណ្តាប្រទេសជាមិត្តរបស់ ប៉ុល ពត ។ សារនេះមានន័យថា ក្រុងហាណូយនឹងមិនបណ្តោយឲ្យកម្ពុជាប្រជាធិបតេយ្យឈរក្នុងជួរជាមួយប្រទេសចិនប្រឆាំងនឹងវៀតណាមឡើយ»[៣៥] ។

ក្រុងប៉េកាំងមិនបានធ្វើប្រតិកម្មភ្លាមៗចំពោះការប្រកាសជាសាធារណៈពី «ទំនាក់ទំនងពិសេស» នេះទេ ។ ដោយរបៀបដូចគ្នា ជាច្រើនសប្តាហ៍ក្រោយមក នៅពេលដែលវៀតណាមប្រារព្ធបុណ្យខួបយ៉ាងគគ្រឹកគគ្រេងក្នុង«ការរំដោះ» ភាគខាងត្បូង ប្រទេសចិនបានបង្ហាញឲ្យឃើញទឹកចិត្តរបស់ខ្លួនចំពោះព្រឹត្តិការណ៍នេះ ដោយនៅស្ងៀមឈឹងតែម្តង ។ ក្នុងទិនានុប្បវត្តិប្រជាជន(របស់ចិន) ពុំមានចុះវិចារណកថា សម្តែងអំណរសាទរ ហើយសារលិខិតជូនពរក៏ពុំមានផ្ញើទៅឲ្យពួកមេដឹកនាំក្រុងហាណូយដែរ ។

ក្រុងភ្នំពេញក៏ចៀសវាងមិនធ្វើអត្ថាធិប្បាយជាសាធារណៈដូចគ្នា ។ ក៏ប៉ុន្តែការប្រឆាំងរបស់ខ្មែរក្រហមចំពោះ «ទំនាក់ទំនងពិសេស» នេះគឺមានប្រាកដណាស់ ។ ការបង្ហាញឲ្យដឹងមួយអាចឲ្យគេវាស់ជម្រៅរឿងនេះបាន ។ ការបង្ហាញនោះបានត្រូវលាតត្រដាងប្រាប់យើងដោយអតីតព្រះប្រមុខរដ្ឋកម្ពុជា ដែលពេលនោះជាមេដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា គឺសម្តេចព្រះ នរោត្តម សីហនុ ។ នៅក្នុងជំពូកមួយនៃសៀវភៅក្បាលទីបីស្តីពីកម្រងអនុស្សាវរីយ៍របស់ព្រះអង្គដែលមានចំណងជើងថា «ការខំមាត់សង្កត់ចិត្តនឹងការមើលងាយហួសហេតុ» សម្តេចបានទ្រង់លិខិតថា នៅពេលព្រះអង្គយាងទៅក្រុងហាណូយជាមួយ ខៀវ សំផន នៅខែកញ្ញា ឆ្នាំ១៩៧៥ ក្នុងឱកាសបុណ្យខួបកំណើតលើកទី៣០ របស់វៀតណាមខាងជើង មេដឹកនាំកម្ពុជាទាំងពីរបានចូលជួបរដ្ឋមន្ត្រីទី១ ផាំ វ៉ាន់ដុង ដែលជាអ្នកអញ្ជើញឲ្យចូលរួមបរិភោគ «អាហារពេលល្ងាចជាលក្ខណៈគ្រួសារមួយ» ជាមួយពួកមេដឹកនាំវៀតណាមខាងជើង បណ្តាសមាជិកនៃរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតកុងនិងពួកមេដឹកនាំឡាវដែលស្នាក់នៅក្រុងហាណូយមួយរយៈខ្លី ។ ដោយធ្វើឲ្យសម្តេចងឿងឆ្ងល់ និងស្រឡាំងកាំង សំផន បាន«បដិសេធយ៉ាងសោះកក្រោះនូវការអញ្ជើញនេះដោយបញ្ជាក់ថា កម្ពុជាចូលចិត្តបរិភោគអាហារពេលល្ងាចជាឧភតោភាគី

មួយជាង»។ ក្រោយមក សំផន បានពន្យល់ប្រាប់សម្តេចថា «យើងត្រូវតែចៀសវាងជានិច្ចកុំឲ្យធ្លាក់ចូលក្នុងអន្ទាក់នេះ។ វៀតណាមចង់ត្រួតត្រាប្រទេសកម្ពុជារបស់យើងដោយរួមបញ្ចូលនៅក្នុងសហព័ន្ធឥណ្ឌូចិនរបស់គេ»។ សំផន បានអះអាងថា គំនិតតែមួយគត់ក្នុងការបរិភោគបាយល្ងាចមួយបែបនោះគឺជាគំនិតប្រកបដោយគ្រោះថ្នាក់ខ្លាំងណាស់។

ស្រមោលសហព័ន្ធឥណ្ឌូចិនដែលបក្សកុម្មុយនីស្តឥណ្ឌូចិនចាប់ផ្តើមចាក់គ្រឹះក្នុងទសវត្សរ៍៣០ នៅតែធ្វើឲ្យខ្មែរគិតមមៃពីរឿងនោះរៀងរហូតមក។ ដោយនិយាយសម្រាប់បុណ្យខួបលើកទី១នៃ«ការរំដោះ»ប្រទេសកម្ពុជានៅថ្ងៃទី១៧ មេសា អៀង សារី បានដៅទៅរកអ្វីដែលគេហៅថា «ទំនាក់ទំនងពិសេស»នោះ ច្បាស់ណាស់នៅពេលដែលគាត់ប្រកាសថា «ប្រជាជនយើងនឹងមិនអនុញ្ញាតឲ្យបណ្តាប្រទេសក្រៅបំផ្លាញឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជាឡើយ»។ គាត់បានប្រើពាក្យបញ្ឆិតបញ្ឆៀងមួយអំពីវត្តមានកងទ័ពវៀតណាមនៅប្រទេសឡាវដែលអាចឲ្យគេយល់ធ្លុះបានថា «ការការពារប្រទេសមួយត្រូវតែជាស្នាដៃរបស់ប្រជាជនខ្លួនផ្ទាល់ ដូចគ្នានឹងការបដិវត្តន៍ដែរ វាត្រូវតែសម្រេចដោយប្រជាជនរបស់ខ្លួនផ្ទាល់ដោយមិនចំណុះអ្នកណាទាំងស្រុង»[៣៦]។

បើទុកជាមានការរិះគន់មិនចេញមុខទាំងនេះដែលបញ្ចេញនៅចំពោះមុខឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅក្រុងភ្នំពេញគឺលោក ផាំ វ៉ាន់បា ក៏ដោយ ក៏កម្ពុជាបានទទួលយល់ព្រមធ្វើកិច្ចប្រជុំកំពូលមួយតាមការឲ្យយោបល់របស់វៀតណាមនៅខែមិថុនាដែរ។ ដោយនៅតែមិនទាន់ទោរទន់ចំពោះបញ្ហាផ្សេងៗផ្នែកនយោបាយ កម្ពុជាប្រជាធិបតេយ្យបានខំប្រឹងប្រែងស្នើឲ្យមានកិច្ចប្រជុំចរចាមួយស្តីពីបញ្ហាព្រំដែនជានិច្ច។ តាមពិតសម្រាប់ក្រុងភ្នំពេញគឺប្រការនេះឯងដែលជាការសាកល្បងដាច់ខាត ដើម្បីឲ្យដឹងពីសុឆន្ទៈរបស់ក្រុងហាណូយ ហើយតាមដំណើរហេតុនេះ គឺជាអាទិភាពដែលមិនអាចចៀសវាងបាននៅក្នុងការប្រជុំកំពូល។

នៅថ្ងៃទី៤ ខែឧសភា អនុរដ្ឋមន្ត្រីការបរទេសវៀតណាម ផាន់ហៀន បានមកដល់ក្រុងភ្នំពេញ។ កម្មវិធីរបស់គាត់គឺកិច្ចចរចាពីរសប្តាហ៍ស្តីពីជម្លោះទឹកដី។ ការជួបពិភាក្សាបានពើបប្រទះនឹងភាពស្មុគស្មាញភ្លាមដោយសារចេតនារបស់វៀតណាមដែលសំអាងលើដែនទឹផ្សេងៗរបស់បារាំងមានកាលបរិច្ឆេទ តាំងពីមុនឆ្នាំ១៩៥៤ម៉្លេះ ដើម្បីកំណត់ព្រំដែនរវាងប្រទេសទាំងពីរ។ ចំណែកខាងកម្ពុជាវិញ ដោយយល់ព្រមយកដែនទីទាំងនេះធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សា បានទាមទារសិទ្ធិអំណាចកែប្រែគំនូសបន្ទាត់ព្រំដែនដែរ បើសិនជាត្រូវធ្វើ។ ដូចដែល អៀង សារី បានបកស្រាយរឿងនេះក្រោយមកថា «ដែនទីរបស់បារាំងមានលក្ខណៈអំណោយផលបំផុតចំពោះវៀតណាម នៅពេលដែលដែនទីនេះត្រូវបានរៀបចំឡើង ពីព្រោះកូសាំងស៊ីនជាអាណានិគមមួយរបស់បារាំង។ បើសិនជាយើងត្រូវបង្ខំទទួលយកដែនទីនេះ សម្រាប់កំណត់ព្រំដែនដីគោកនោះវៀតណាមប្រហែលជាទទួលស្គាល់ព្រំដែនសមុទ្រដែលកំណត់ដោយពួកបារាំងជាថ្នូរវិញមិនខាន»[៣៧]។

និយាយឲ្យមែនទែនទៅ វាពុំមានបញ្ហាស្តីពីព្រំដែនសមុទ្រដែលគូសដោយពួកបារាំងឡើយ ។ នៅឆ្នាំ១៩៣៩ ខ្សែបន្ទាត់ប្រេវីយេ គឺយកតាមឈ្មោះលោក ហ្ស៊ុលប្រេវីយេ ជាអគ្គទេសាភិបាលប្រចាំឥណ្ឌូចិន ដែលត្រូវបានគូសឡើងសម្រាប់កំណត់ព្រំដែនយុត្តាធិការផ្នែករដ្ឋបាល និងប៉ូលិស រវៀងខ្លួនរបស់កូសាំងស៊ីន និងកម្ពុជានៅលើកោះនានាក្នុងលំហសមុទ្រប៉ុណ្ណោះ ។ (យុត្តាធិការគឺសិទ្ធិត្រួតពិនិត្យក្នុងការវិនិច្ឆ័យ និងផ្តល់យុត្តិធម៌លើទឹកដីដែលរដ្ឋអំណាចកាន់កាប់) ។ នៅលើផែនទី ខ្សែបន្ទាត់នេះបានគូសចេញពីព្រំដែនឆ្នេរសមុទ្ររវាងតំបន់ទាំងពីរ ដែលត្រួតត្រាដោយពួកបារាំងកាត់ឈូងសមុទ្រសៀមជាមុំ១៨០ដឺក្រេ ប៉ុន្តែ ខ្សែបន្ទាត់នេះបានត្រូវបារាំងគូសវាងជុំវិញចម្ងាយប្រហែល១,៥ម៉ៃល៍ ពីកោះភូកុក (ខ្មែរហៅ កោះត្រល់) ដើម្បីដាក់ឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់អាជ្ញាធរកូសាំងស៊ីន ។ ការសម្រេចនេះ បង្ហាញឲ្យឃើញភ័ស្តុតាងយ៉ាងគ្រប់គ្រាន់នូវទស្សនះរបស់រដ្ឋាភិបាលអាណានិគម ប៉ុន្តែដូចដែលលោក ប្រេវីយេ ប្រកាសឲ្យដឹងដោយខ្លួនគាត់ផ្ទាល់ថា ៖ "ភាពស្ថិតនៅក្រោមអំណាចនៃកោះទាំងនោះ នៅតែត្រូវតម្កល់ទុកទាំងស្រុងមិនទាន់សម្រេចថាឲ្យទៅខាងណាៗទេ"[៣៨] ។

ប៉ុន្តែសុពលភាព (ភាពប្រើការបាន) របស់ខ្សែបន្ទាត់ប្រេវីយេ ក្នុងនាទីជាខ្សែកំណត់ព្រំដែននេះធ្លាប់ត្រូវបានភាគីទាំងពីរទទួលស្គាល់ម្តងរួចហើយ ក្នុងឱកាសនៃកិច្ចចរចាគ្នារវាងកម្ពុជានិងរណសិរ្សរំដោះជាតិ(វៀតកុង) កាលពីឆ្នាំ១៩៦៦ ។ ក្នុងកាលៈទេសៈមួយដែលរណសិរ្សរំដោះជាតិត្រូវការកិច្ចគាំទ្រពីសម្តេច ព្រះនរោត្តម សីហនុ ហើយប្រហែលជាដើម្បីកុំឲ្យសម្តេចអាក់អន់ព្រះទ័យ វៀតណាមបានទទួលស្គាល់យ៉ាងជាក់លាក់ថា ខ្សែបន្ទាត់នេះជាព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ ។ នៅក្រុងប៉ារីសនាខែមិថុនា ឆ្នាំ១៩៧៧ ផាន់ហៀន បានអនុញ្ញាតឲ្យខ្ញុំជួបធ្វើការសម្ភាសន៍មួយ ។ នៅពេលនោះ ការសន្ទនានៅខែឧសភា ឆ្នាំ១៩៧៦ និងតួនាទីដែលគាត់បានសម្តែងនៅតែស្ថិតក្នុងភាពសម្ងាត់ដដែល ។ ខ្ញុំបានសួរគាត់ថា តើក្រុងហាណូយទទួលស្គាល់ខ្សែបន្ទាត់ប្រេវីយេនេះទេ? ។ គាត់ឆ្លើយថា "បាទ! ព្រោះថានៅពេលនោះ យើងពុំដែលបានដឹងពីបញ្ហាព្រំដែនទឹកព្រំដែនបាតសមុទ្រឡើយ និយាយដោយខ្លីគឺកត្តាថ្មីៗទាំងនេះ" ។ នេះជារបៀបទទួលស្គាល់ដែលចេះខ្មាសអៀនមួយថា តាំងពីមានការចាប់ផ្តើមស្វង់រកអណ្តូងប្រេងកាតក្នុងតំបន់នេះក្នុងទសវត្សរ៍៧០ ក្រុងហាណូយចាំបាច់ត្រូវតែពិនិត្យជំហររបស់ខ្លួនស្តីពីព្រំដែនសមុទ្រឡើងវិញ ដែរ ។

## អំណោយដែលឱ្យប្រផ្នូលអាក្រក់

ក្នុងកំឡុងនៃការជួបសន្ទនាគ្នានៅក្រុងភ្នំពេញ ហៀន បានអះអាងបន្ថែមពីការយល់ព្រមរបស់វៀតណាមក្នុងការបែងចែកកោះនានាតាមគំនូសខ្សែបន្ទាត់ប្រេវីយេ គឺកោះទាំងឡាយដែលនៅខាងជើងត្រូវបានមកកម្ពុជា ហើយកោះទាំងឡាយដែលនៅខាងត្បូងត្រូវបានទៅវៀតណាម ។ ប៉ុន្តែគាត់បានចោទប្រកាន់ជាថ្មីស្តីពីការកំណត់ព្រំដែនសមុទ្រ ។ ចំពោះចំណុចនេះ គាត់ស្នើឲ្យមានការគូសខ្សែបន្ទាត់ព្រំដែនឡើងវិញ ។ មិនយូរប៉ុន្មានក្រោយ

មក នៅពេលដែលជម្លោះតាមសង្គ្រាមប៉ាកកាឡើងដល់កម្រិតខ្ពស់បំផុតនោះ ក្រុងភ្នំពេញបានឈានរហូតដល់ចោទប្រកាន់សំណើរបស់វៀតណាមថា នេះជាគោលបំណង «ភ្ជាប់ដែនទឹកមួយចំណែកយ៉ាងធំរបស់កម្ពុជាធ្វើជារបស់ខ្លួន» ។ សម្រាប់ខ្មែរយល់ថា នេះជាភស្តុតាងនៃបំណងវាតទីរបស់វៀតណាមមកលើកម្ពុជាយ៉ាងពិតប្រាកដ ។ កិច្ចចរចាបានត្រូវផ្អាកដោយគ្មានកំណត់ថ្ងៃជួបគ្នាទៀតឡើយ ហើយក៏មិនដែលត្រូវបន្តឡើងវិញទាល់តែសោះ ជាមួយនឹងការចរចាទាំងនេះ គំនិតឲ្យមានការជួបប្រជុំកំពូលរវាងប្រទេសទាំងពីរក៏រលាយសូន្យ ។ ប៉ុន្តែថ្វីបើជួបបរាជ័យនេះក៏ដោយ ក៏គ្មានប្រទេសណាមួយក្នុងចំណោមប្រទេសទាំងពីរត្រៀមបម្រុងនឹងផ្តាច់ «ស្ពានមេត្រី» នៅឡើយដែរ ។ ផាន់ហៀន បានវិលទៅក្រុងហាណូយវិញដោយពាំនាំសំបុត្រអញ្ជើញមួយរបស់អៀង សារី ឲ្យអ្នកកាសែតវៀតណាមទៅធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យផង ដែលរហូតមកទល់នឹងពេលនេះ ត្រូវកាត់ផ្តាច់ប្រទេសទាំងស្រុងពីពិភពខាងក្រៅ ។

នៅខែកក្កដា ឆ្នាំ១៧៧៦ ប្រតិភូអ្នកសារព័ត៌មាន និងទូរទស្សន៍របស់វៀតណាមមួយក្រុមដឹកនាំដោយត្រាន់ ថាញ់ស៊ិន់ អនុប្រធានទីភ្នាក់ងារព័ត៌មានវៀតណាមគឺជាក្រុមអ្នកសារព័ត៌មានបរទេសលើកដំបូងបំផុតដែលធ្វើដំណើរទៅកាន់កម្ពុជា ។ ស៊ិន់ ដែលមានអាយុ៥០ប្លាយឆ្នាំ ពាក់វ៉ែនតា រាងស្គមចម្អឹង និងឆាប់មួម៉ៅត្រូវបានជ្រើសរើសឲ្យធ្វើជាមេដឹកនាំគណៈប្រតិភូ ពីព្រោះគាត់ជាអតីតនិស្សិតនៅក្រុងប៉ារីស ហើយជាអ្នកធ្លាប់បានជួប ប៉ុល ពត, អៀង សារី និងអនាគតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យជាច្រើនរូបទៀតផង ។ នៅក្នុងឱកាសនេះ បុគ្គលដ៏អាថ៌កំបាំង ប៉ុល ពត ដែលអត្តសញ្ញាណពិតប្រាកដត្រូវបានគេយកទៅធ្វើជាកម្មវត្ថុរកកម្រៃជានិច្ចកាលនៅបរទេសនោះ ទីបំផុតបានចេញពី «ទីកំបាំង» ហើយ ។ ប៉ុល ពត បានអនុញ្ញាតឲ្យ ស៊ិន់ ធ្វើបទសម្ភាសន៍មួយ ហើយយល់ព្រមបណ្តោយខ្លួនឲ្យអ្នកទាំងនោះថតរូបគាត់តាមចិត្ត ។ បួនឆ្នាំក្រោយមក ដោយនៅនឹកឃើញពីការជួបគ្នានេះ ស៊ិន់ បាននិយាយថា នៅពេលនោះ ប៉ុល ពត មានបុកពាជាបុរសម្នាក់ដែលគួរឲ្យស្រឡាញ់ចូលចិត្តពិតៗ ។ ដោយមិនពេញចិត្តនឹងបង្ហាញខ្លួនជាម្ចាស់ផ្ទះគួរសមម្នាក់ ក្នុងការសម្ភាសលើកដំបូង គាត់បានសម្តែងនូវការដឹងគុណរបស់កម្ពុជាចំពោះប្រជាជនវៀតណាមជាមិត្តនិងជាបងប្អូនដែលធ្លាប់បានជួយឧបត្ថម្ភកាលពីពេលកន្លងមក ។ ក្នុងរឿងនេះ តាមដែលគាត់យល់គឺថាមិត្តភាព និងសាមគ្គីភាពរវាងប្រទេសទាំងពីរមានលក្ខណៈព្រមគ្នាជា «បញ្ហាយុទ្ធសាស្ត្រមួយផងនិងមនោសញ្ចេតនាដ៏ខ្ពង់ខ្ពស់មួយផង» ។

ក្នុងឱកាសនៃការសម្ភាសមួយនៅក្រុងហូជីមិញកាលពីឆ្នាំ១៩៨១ ស៊ិន់ បានធ្វើអត្ថាធិប្បាយថា គោលបំណងក្នុងការអញ្ជើញអ្នកសារព័ត៌មានវៀតណាមរបស់កម្ពុជាគឺដើម្បីជួសជុលរូបភាពរបស់ខ្លួនដែលខូចខាតដោយសារការទិតៀនរបស់ពួកបស្ចិមប្រទេសដំបូងគេ ដែលបានទៅធ្វើទស្សនកិច្ចនៅប្រទេសនេះ កាលពីខែមីនា ១៩៧៦ ។ ប៉ុល ពត គិតថាវៀតណាមនឹងត្រូវ(គាត់) ប្រើប្រាស់សម្រាប់គម្រោងការនេះ ហើយគាត់មិនដែលគិតខុសឡើយ ។ ប៉ុន្តែដោយត្រូវធ្វើឲ្យទាស់ភ្នែកទាស់ត្រចៀកខ្លាំង វ៉ាង ទុង ដែលជាមនុស្សភ្នែកមុតដូចខ្លាត្រី

ហើយដែលគ្មានអ្វីមួយអាចគេចផុតពីក្រសែភ្នែកគាត់នោះ បានវាយតម្លៃទាល់តែគ្មានចំណាប់អារម្មណ៍អវិជ្ជមានណាមួយលេចឡើងក្នុងដំណឹងស្ដីពីព័ត៌មានរបស់គាត់ឡើយ ។ ស៊ីន់ បានរំឭកថា “ក្រុមទូរទស្សន៍របស់យើងមានការលំបាកយ៉ាងខ្លាំង ក្នុងការស្វែងជួបប្រជាកសិករប្រកបដោយទឹកមុខញញឹមរួសរាយដែលជាប់រវល់កសាងប្រទេសជាតិឡើងវិញ ។ អ្នកទាំងនោះមានសភាពដូចជាមនុស្សម្ហូងក្នុងចិត្តនិងក្រៀមក្រំដែលបង្ហាញឲ្យឃើញទុក្ខលំបាកវេទនារបស់ខ្លួនខ្លាំងណាស់” ។ ទុង បានឈានរហូតដល់ហាមមិនឲ្យផ្សាយឃ្លាមួយនៃអត្ថបទមួយរបស់ស៊ីន់ ក្នុងកាសែតញិនហ្សិនទៀតផង ។ អ្នកកាសែតបានសរសេរថា “ទីក្រុងនានាសុទ្ធតែស្ងាត់ជ្រងំ ប្រជាជនទៅធ្វើស្រែចម្ការទាំងអស់” ។ តាមនិពន្ធនាយកកាសែតថា វាប្រសើរជាងដែលត្រូវយកចិត្តទុកដាក់ចំពោះការខូចខាតដោយសារសង្គ្រាមដែលបង្កឡើងដោយ លន់ នល់ និងសហរដ្ឋអាមេរិក ។ ការធ្វើទស្សនកិច្ចសម្បូរទៅដោយភាពជានិមិត្តរូបគួរឲ្យព្រឺខ្លាច ។ ទាល់តែជាច្រើនឆ្នាំក្រោយមកទៀតទើប វ៉ាង ទុង ប្រាប់ឲ្យដឹងពីកាយវិការប្រកបដោយគំនិតឈ្លានីសរបស់ ប៉ុល ពត មកលើរូបគាត់ ។ ជាជំនួសជំនូន មេដឹកនាំខ្មែរក្រហមបានផ្ញើសត្វស៊ីសាច់មួយក្បាលមកឲ្យគាត់ គឺកូនក្រពើមួយ[៣៩] ។ ប៉ុន្តែរឿងនេះវាអាចថា ប៉ុល ពត មានគំនិតមួយផ្សេងទៀតក្នុងខួរក្បាលរបស់គាត់ ៈ ក្នុងបណ្ដាឆ្នាំជាបន្តបន្ទាប់មកទៀត ការឃោសនាទាំងប៉ុន្មានរបស់ខ្មែរក្រហមគឺបានដាក់សម្មតិនាមឲ្យវៀតណាមជារឿយៗថា “ពួកក្រពើរមិលគុណ” ។

ក្នុងលំដាប់ដែលភាពតានតឹងនៃទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយប្រទេសចិននិងកម្ពុជាឡើងកាន់តែខ្ពស់នោះ ក្រុងហាណូយបានបង្កើតកិច្ចខិតខំប្រឹងប្រែងរឹតតែខ្លាំងឡើងថែមទៀត ដើម្បីភ្ជាប់ទំនាក់ទំនងជាមិត្តភាពជាមួយពិភពមិនមែនកុម្មុយនីស្តវិញ ។ ភ្លាមៗបន្ទាប់ពីបានទទួលជ័យជម្នះ នៅពេលដំបូង ពួកវៀតណាមបានបរិហារជាសាធារណៈដល់បណ្ដាប្រទេសប្រឆាំងកុម្មុយនីស្តនៃសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍ (ហៅកាត់អាស៊ាន) យ៉ាងខ្លាំងចំពោះការស៊ុមគ្រលុំរបស់គេជាមួយចក្រពត្តិអាមេរិកាំង ។ វៀតណាមបានទាមទារឲ្យធ្វើការរំលាយចោលមូលដ្ឋានអាមេរិកាំងទាំងអស់ ដែលមាននៅប្រទេសថៃ និងហ្វីលីពីន ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៥ ក្រុងហាណូយអាចថ្លឹងថ្លែងពីការសម្រេចចិត្តរបស់ពួកចិនដែលប៉ុនប៉ងប្រមូលបណ្ដាប្រទេសអាស៊ាន ឲ្យរួបរួមក្នុងយុទ្ធសាស្ត្រមួយប្រឆាំងសូវៀតនិងប្រឆាំងវៀតណាមផងដែរ ។ ជាពិសេសវៀតណាមក៏កត់សម្គាល់ឃើញនូវការខ្នះខ្នែងរបស់ក្រុងប៉េកាំង ក្នុងគោលបំណងជួយធ្វើឲ្យមានការខិតចូលជិតគ្នារវាងកម្ពុជា និងប្រទេសថៃថែមទៀត ។ ប្រទេសចិនបានកែសម្រួលទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយប្រទេសថៃឲ្យមានប្រក្រតីភាពឡើងវិញ គឺមិនដល់មួយខែផងបន្ទាប់ពីទីក្រុងព្រៃនគរ ដួលរលំក្នុងពេលដែលវៀតណាមផ្អាកទុករឿងនេះមួយអន្ទើសិន ។ នៅខែតុលា ឆ្នាំ១៩៧៦ ដោយសារការជួយជ្រោមជ្រែងរបស់ចិន អៀង សារី បានចាប់ផ្ដើមទាក់ទងមួយជំហានមុនដោយធ្វើដំណើរទៅកាន់ក្រុងបាងកកតាមយន្តហោះចិនមួយគ្រឿង ។

ទោះជាប្រទេសវៀតណាមចាត់ទុកខ្លួនឯងជា “កងឈានមុខនៃលទ្ធិសង្គមនិយមក្នុងភូមិភាគអាស៊ី-

អាគ្នេយ៍» និងចិញ្ចឹមមហិច្ឆតាប្រែក្លាយខ្លួនជា«អ្នកដឹកនាំ»បណ្តាចលនាបដិវត្តក្នុងតំបន់នេះក៏ដោយ ក៏ពួកមេដឹកនាំរបស់ខ្លួនសុទ្ធតែយល់ថា អ្វីដែលជាអាទិភាពគឺត្រូវខិតខំស្តារសេដ្ឋកិច្ចដែលបំផ្លិចបំផ្លាញដោយសារសង្គ្រាមឡើងវិញ ។ម្យ៉ាងទៀត ក្នុងប្រទេសនៅអាស៊ី-អាគ្នេយ៍ទាំងអស់ បណ្តាចលនាបដិវត្តដែលធ្វើការតស៊ូដោយអាវុធមិនដែលឆ្លងផុតពីដំណាក់កាលដែលទើបនឹងចាប់ផ្តើមឡើយ ។ ដូច្នេះក្រុងហាណូយពុំមានការជ្រើសរើសទេ គឺគេត្រូវតែសម្របសម្រួលជាមួយរបបគ្រប់គ្រងនៅនឹងកន្លែងជាមុន ។ ការធ្វើឲ្យមានទំនាក់ទំនងជាមួយបណ្តាប្រទេសជិតខាងមានភាពប្រក្រតីឡើងវិញ បានក្លាយទៅជាកាតព្វកិច្ចមួយសម្រាប់មូលហេតុផ្សេងៗខាងនយោបាយក៏ដូចសេដ្ឋកិច្ច ។ ដើម្បីឲ្យទទួលបានជំនួយ និងឥណទានពីបណ្តាប្រទេសលោកខាងលិច ប្រទេសវៀតណាមមិនត្រូវធ្វើខ្លួនឲ្យលេចឡើងជាអ្នកនាំអាទិឲ្យមានការវឹកវរឡើយ ទោះជាមានអ្វីកើតឡើងក៏ដោយ ។

## ក្រុងប៉េកាំងលែងឆ្លើយតប

ថ្ងៃទី៥ ខែកក្កដា គឺបីថ្ងៃបន្ទាប់ពីការប្រកាសជាផ្លូវការនូវការបង្រួបបង្រួមប្រទេសដែលរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ន និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមសម្រេចប្រសិទ្ធនាមថ្មីថា «សាធារណរដ្ឋសង្គមនិយមវៀតណាម»នោះ ក្រុងហាណូយបានថ្លែងប្រកាសជាសាធារណៈនូវកម្មវិធីមួយមាន៤ចំណុចក្នុងគោលដៅរៀបចំនិងពង្រីក«ទំនាក់ទំនងមិត្តភាពនិងសហប្រតិបត្តិការក្នុងវិស័យជាច្រើន»ជាមួយប្រទេសផ្សេងៗនៅអាស៊ី-អាគ្នេយ៍ ។ ដោយឈរលើមូលដ្ឋាននៃការគោរពឯករាជ្យជាតិទៅវិញទៅមក ទំនាក់ទំនងនេះបានហាមមិនឲ្យមានការផ្តល់ជាមូលដ្ឋានផ្សេងៗសម្រាប់ការឈ្លានពានទាំងអស់របស់ប្រទេសទីបីមួយ ប្រឆាំងនឹងប្រទេសហត្ថលេខីណាមួយឡើយ ទោះជាដោយចំពោះក្តីឬមិនចំពោះក្តី ។ ភាពទាក់ទងគ្នាជាអ្នកជិតខាងល្អ គឺត្រូវគិតដល់«ស្ថានភាពដោយឡែក»របស់ប្រទេសនីមួយៗ «ដើម្បីជាគុណប្រយោជន៍យ៉ាងធំធេងដល់ឯករាជ្យភាព សន្តិភាព និងអព្យាក្រឹតភាពពិតប្រាកដក្នុងតំបន់»[៤០] ។

មួយសប្តាហ៍ក្រោយមក ផាន់ ហៀន បានចេញដំណើរទៅធ្វើទស្សនកិច្ចនៅប្រទេសហ្វីលីពីន ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី និងភូមា ។ ក្នុងដំណើរទស្សនកិច្ចនេះគាត់បានប្រឹងប្រែងនិយាយដោះសាពីការបរិហារកេរ្តិ៍ផ្សេងៗដែលថា ក្នុងអតីតកាលប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុងហាណូយមិនដែលខ្វះខ្វាយពេលវេលាប្រឆាំងនឹងបណ្តាប្រទេសអាស៊ាននោះឡើយ ។ ការអះអាងរបស់គាត់មានលក្ខណៈប៉ិនប្រសប់មែន គាត់បានបកស្រាយថា «អ្នកកាសែតបានសរសេរអ្វីៗតាមដែលគេយល់ដឹង ប៉ុន្តែពុំមែនជាជំហររបស់រដ្ឋាភិបាលទេ» ។ មានតែប្រទេសសិង្ហបុរីមួយប៉ុណ្ណោះដែលចេះតែសង្ស័យចំពោះមុខនូវបំណងជាអ្នកជិតខាងល្អដែលសម្តែងឲ្យឃើញដោយក្រុងហាណូយ ។ ប្រទេសឯទៀតៗហាក់ដូចជាត្រូវធ្វើឲ្យចាប់អារម្មណ៍ចំពោះសំបកក្រៅនៃភាពស្មោះត្រង់អស់ពីដួងចិត្តនេះ បើទុកជារណ្តៅមនោគមវិជ្ជាខណ្ឌចែកក៏ដោយ ។ ហៀន បានស្វែងរកចំណងមិត្តភាពរបស់គាត់

ជាថ្មី ។ ដោយលះបង់តវិយាបថគំរាមកំហែងគេ នៅពេលនេះក្រុងហាណូយបានបញ្ចេញស្នាមញញឹមរបស់ខ្លួនឲ្យគេឃើញម្តង ។ បណ្តាប្រទេសនៃសមាគមអាស៊ានអាចត្រឹមតែធ្វើឲ្យធូរស្រាលក្នុងចិត្តប៉ុណ្ណោះ ។

ក្រោយទស្សនកិច្ចរបស់ ហៀន នៅទីក្រុងកូឡាលំពួរ មន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេសម៉ាឡេស៊ីបានប្រាប់រឿងអាថ៌កំបាំងឲ្យខ្ញុំដឹងថា «យើងចាប់អារម្មណ៍ថា វៀតណាមខំប្រឹងប្រែងធ្វើឲ្យប្រទេសរបស់ខ្លួនស្ថិតនៅចម្ងាយស្មើគ្នារវាងក្រុងប៉េកាំងនិងក្រុងមូស្គូ» ។ ហៀន បានអះអាងប្រាប់ម៉ាឡេស៊ីថា ប្រទេសរបស់គាត់ប្រឆាំងជំទាស់នឹងគោលបំណងចង់ត្រួតត្រាគេគ្រប់បែបយ៉ាងរបស់បណ្តាប្រទេសមហាអំណាចនិងមិនអនុញ្ញាតឲ្យប្រទេសណាមួយប្រើប្រាស់មូលដ្ឋាននាវាចរនៅឆកសមុទ្រកាំរ៉ាញ់ឡើយ ។ គូសន្ទនារបស់ខ្ញុំ (មន្ត្រីជាន់ខ្ពស់ម៉ាឡេស៊ី) កត់សម្គាល់ឃើញថា «ប្រាកដណាស់ គាត់ធ្វើជា និយាយដៀមដាមរុស្ស៊ី ហើយពាក្យសម្តីរបស់គាត់ដែលនិយាយទៅកាន់ប្រទេសមិនមែនកុម្មុយនីស្តមួយមានលក្ខណៈមិនសមស្របតាមស្ថានភាពឡើយ» ។ ពួកម៉ាឡេបានវិនិច្ឆ័យគួរឲ្យចាប់អារម្មណ៍ខ្លាំងថា អ្នកការទូតទាំងអស់ ទាំងពួកសូវៀត ទាំងពួកសម្ពន្ធមិត្រអឺរ៉ុបខាងកើតរបស់គេ សុទ្ធតែបង្ហាញឲ្យឃើញនូវការឆ្ងើងឆ្ងល់យ៉ាងខ្លាំងពីពាក្យសម្តីភ្លៀវភ្លាវៀតណាមរបស់គាត់ ។ ក្រៅពីការកំប្លែងលេងសើចមួយនៅពេលកំពុងហោះឆ្លងកាត់ពីលើ «កោះស្រ្តាតលីរបស់យើង» តាមផ្លូវហោះហើរពីក្រុងម៉ានីល មកទីក្រុងកូឡាលំពួរ ហៀន ពុំមាននិយាយពាក្យដៀមដាមណាមួយចំពោះការទាស់ទែងគ្នាជាមួយប្រទេសចិនទាល់តែសោះ ។

ចំពោះមុខ «ប្រតិបត្តិការដាក់ស្នេហ៍» របស់វៀតណាមនៅអាស៊ី-អាគ្នេយ៍ ប្រទេសចិនបានរក្សាភាពស្ងៀមស្ងាត់មិននិយាយអ្វីទាំងអស់ គឺជាភាពស្ងៀមស្ងាត់មួយដែលផ្ទុកទៅដោយការគំរាមកំហែងយ៉ាងធ្ងន់ ។ ទីភ្នាក់ងារសារព័ត៌មានចិនថ្មី ដែលមានទម្លាប់រាយការណ៍ពីព្រឹត្តិការណ៍សំខាន់ៗទាំងផ្នែកផ្ទៃក្នុងនិងផ្នែកការទូតទាក់ទងនឹងប្រទេសវៀតណាមនោះ គ្មានបានដឹងទាំងស្រុងពីដំណើរព័ទ្ធជុំវិញអាស៊ី-អាគ្នេយ៍របស់ ហៀន ឡើយ ។ ប៉ុន្តែជាច្រើនថ្ងៃក្រោយការវិលត្រឡប់របស់គាត់មកប្រទេសវិញ វិទ្យុប៉េកាំងបានធ្វើបទអត្ថាធិប្បាយមួយព្រមានឲ្យបណ្តាប្រទេសអាស៊ានប្រុងប្រយ័ត្នប្រឆាំងទល់នឹងការប៉ុនប៉ងរបស់សូវៀតក្នុងការជ្រៀតចូល និងការវាតទីក្នុងតំបន់នេះ ។ «ដរាបណាប្រជាជនអាស៊ី-អាគ្នេយ៍រួបរួមគ្នាយ៉ាងជិតស្និទ្ធ និងបន្តការប្រយុទ្ធតស៊ូដរាបនោះពួកគេនឹងធ្វើឲ្យសត្រូវរួមបាត់សេចក្តីក្លាហាន ហើយការធ្វើដូច្នេះអាចឲ្យប្រជាជនទាំងនោះការពារឯករាជ្យភាព និងអធិបតេយ្យភាពផ្ទាល់របស់ខ្លួនប្រកបដោយជោគជ័យ»[៤១] ។

កាលបរិច្ឆេទនៃការផ្សាយតាមវិទ្យុ គ្មានអ្វីគួរឲ្យសង្ស័យឡើយចំពោះប្រទេសដែលកំណត់ដោយក្រុងប៉េកាំងថាជាភ្នាក់ងារនៃការជ្រៀតចូលរបស់សូវៀត ។ បើទោះជាប្រទេសចិនចៀសវាងមិនបរិហារ ប្រទេសវៀតណាមដោយចេញឈ្មោះក៏ដោយ ក៏ជនជាតិវៀតណាមខ្វះមិនលាក់បាំងការរួមទស្សនៈរបស់ខ្លួនជាមួយសហភាព សូវៀតប្រឆាំងនឹងប្រទេសចិនដែរ ។ ជាឧទាហរណ៍ ក្នុងការធ្វើសម្ភាសន៍មួយដែលផ្តល់ដល់អ្នកកាសែត

ស៊ុយអែង អេរិចព្យែរ វ៉ាង ទុង បាននិយាយមិនញញើតមាត់ថា ៖ "តាមលក្ខណៈជាក់ស្តែង ផលប្រយោជន៍របស់សូវៀត ត្រូវគ្នាជាមួយនឹងផលប្រយោជន៍របស់វៀតណាមដែរ ដែលត្រូវកាត់បន្ថយឥទ្ធិពលរបស់ប្រទេសចិននៅក្នុង ផ្នែកនេះនៃពិភពលោក" ។ សម្តីសន្ទនានេះដែលដកស្រង់ជាសំអាងដោយពួកមេដឹកនាំចិននៅពេលក្រោយមកថាជាឧទាហរណ៍នៃ"ការប្រមាថដ៏ធ្ងន់ធ្ងរមកលើប្រជាជនចិនដោយពួកវៀតណាម"[៤៧] ។

ពេញថិរវេលានៃរដូវក្តៅឆ្នាំ១៩៧៦ ប្រទេសចិនត្រូវជាប់រវល់យ៉ាងខ្លាំងដោយសារការតស៊ូផ្ទៃក្នុងរបស់ខ្លួនដើម្បីប្រឆាំងទល់នឹងការវាយលុកផ្នែកការទូតរបស់វៀតណាមក្រៅពីពាក្យទ្រគោះដែលបិទបាំងការឃោសនារបស់ខ្លួន ។ តាំងពីដំណាច់ឆ្នាំ១៩៧៣ ការិយាល័យនយោបាយរបស់បក្សកុម្មុយនីស្តចិន មានការបែកបាក់មតិគ្នាយ៉ាងខ្លាំង ។ ការខ្វែងគំនិតនេះបានធ្វើឲ្យពួកយុទ្ធិកជនដើរតាមមាគ៌ាប្រតិបត្តិនិយមរបស់ ជូ អេនឡាយ ដែលខំប្រឹងរកផ្លូវទប់ទល់នឹងការគំរាមកំហែងរបស់សូវៀតដោយការបង្កើនសហប្រតិបត្តិការមួយជាមួយសហរដ្ឋអាមេរិកនោះ ត្រូវប្រឈមមុខនឹងពួករ៉ាឌីកាល់មួយក្រុមដឹកនាំដោយ ហ្សាងជុនជាវ និង វ៉ាងហុងវើន ដែលរួតរាងដូចគ្នាពីការប្រឆាំងដ៏អង់អាចចំពោះមហាអំណាចផុតលេខទាំងពីរ និងការគាំទ្រចំពោះការប្រយុទ្ធតស៊ូដោយអាវុធប្រឆាំងចក្រពត្តិនិយមទាំងអស់ដ៏អង់អាច[៤៣] ។ ពួករ៉ាឌីកាល់ក៏ជាយុទ្ធិកជនដែលមិនមានជាប់លក្ខខណ្ឌនឹងខ្មែរក្រហមដែរ ។ ពួកនេះបានធ្វើឲ្យអ៊ីៗជឿនលឿនទៅមុខសន្សឹមៗ ដោយហេតុថា កណ្តាប់ដៃដែករបស់ ម៉ៅ បានបន្ធូរការរឹតរួតរបស់គាត់ជាលំដាប់ ហើយការទប់ទល់របស់ ជូ ក៏ធ្លាក់ចុះដែរ ។ នៅឆ្នាំ១៩៧៤-៧៥ ការរិះគន់របស់ពួកនេះប្រឆាំងនឹងការខិតចូលជិតជាមួយសហរដ្ឋអាមេរិកមានសភាពយ៉ាងជូរចត់បំផុត ។ ម្យ៉ាងទៀត ពួកគេបានបរិហារពីភាពធូរស្រាលរវាងសូវៀតនិងអាមេរិកាំងទៀតផង ដែលតាមមតិពួកគេថានេះគឺជានយោបាយដែល ជូ ជួយឲ្យបានសម្រេច[៤៤] ។

មរណភាពរបស់ ជូ នៅខែមករា ១៩៧៦ ត្រូវបានបន្តបីខែក្រោយមក គឺនៅខែមេសាដោយការបណ្តេញចេញពីតំណែងនូវមនុស្សដៃស្តាំរបស់គាត់គឺ តេង ស៊ាវពីង ។ តុល្យភាពនៃបក្ខពួកផ្សេងៗក្នុងការិយាល័យនយោបាយបានប្រែប្រួលជាគុណប្រយោជន៍ដល់ពួករ៉ាឌីកាល់ម្តង ។ ហ្វា គួហ្វេង ដែលមានដើមកំណើតនៅ ខេត្តហ៊ូណាន ហើយដែលគេរួមបញ្ចូលក្នុងក្រុមរ៉ាឌីកាល់នោះ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទី១ពេញឋានៈ ។ ប៉ុន្តែ ជោគជ័យនេះពុំមានលក្ខណៈជាស្ថាពរទេ ។ នៅព្រហាមថ្ងៃទី៩ ខែកញ្ញា ម៉ៅ ដែលជាអាជ្ញាកណ្តាលធំបានចាក ចេញពីឆាកនយោបាយ ។ វាសនារបស់ប្រទេសចិននឹងត្រូវសំដែងជាថ្មី ក៏ដូចជាឥរិយាបថរបស់ខ្លួនដែលត្រូវប្រឈមនឹងពិភពលោកខាងក្រៅដែរ ។ ដូចប្រជាជនចិនរាប់លាននាក់ បណ្តាមេដឹកនាំនៃពិភពលោកទាំងមូល ហើយដោយឡែក ពួកមេដឹកនាំក្រុងមូស្គូ ក្រុងវ៉ាស៊ីនតោន ក្រុងហាណូយ និងក្រុងភ្នំពេញ បានបែរការសម្លឹងមើលរបស់ពួកគេឆ្ពោះទៅក្រុងប៉េកាំងវិញម្តង ។ ការនឹកសង្ឃឹមបានចាប់ផ្តើម ។

# សម្តេច ព្រះនរោត្តម សីហនុ : ម៉ោងនៃជ័យជម្នះ

*គឺនៅក្រុងប៉េកាំងដែលសម្តេចព្រះ នរោត្តម សីហនុ ទ្រង់ជ្រាបពីការដួលរលំរបស់ក្រុងភ្នំពេញក្នុងភូមិគ្រឹះដ៏ល្អឆើតឆាយរបស់ព្រះអង្គស្ថិតនៅតាមវិថីមួយឈ្មោះ «ប្រឆាំងចក្រពត្តិនិយម» ។ លិខិតជាទូរលេខមួយដែលផ្ញើថ្វាយដោយមន្ត្រីចិនម្នាក់ប្រាប់ឲ្យដឹងថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមដែលជាសម្ព័ន្ធមិត្តរបស់ព្រះអង្គតាំងពីប្រាំឆ្នាំមុនបានដើរចូលដល់ទីក្រុងភ្នំពេញហើយ ។*

*លោក លន់ នល់ ឧត្តមសេនីយ៍ខ្វិនជើង ជាមេនៃរដ្ឋប្រហារទម្លាក់សម្តេច សីហនុ កាលពីឆ្នាំ១៩៧០ បាននិរទេសខ្លួនទៅនៅសហរដ្ឋអាមេរិកបាត់ទៅហើយ ។ «ពួកក្បត់» ខ្លះដែលធ្លាប់សហការជាមួយ លន់ នល់ បានរត់ភៀសខ្លួនចេញពីប្រទេស ខ្លះចុះចាញ់នៅចំពោះមុខខ្មែរក្រហម ។ សង្គ្រាមត្រូវបានបញ្ចប់ ។ ការប្រថុយប្រថានដែលសម្តេចសម្រេចព្រះទ័យនៅខែមេសា ឆ្នាំ១៩៧០ ក្នុងការរួបរួមជាមួយពួកកុម្មុយនីស្ត ដែលជាសត្រូវគ្មានទីបំផុតរបស់ព្រះអង្គនោះ ត្រូវបានតបស្នងមកវិញ ។ សម្តេចក៏ទទួលបានកិត្តិយសរបស់ព្រះអង្គឡើងវិញដែរ ។ ក្រោយរដ្ឋប្រហារ បណ្តាឧត្តមសេនីយ៍ អ្នកនយោបាយប្រតិកិរិយាដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន និងដែលធ្លាប់ជឿថា អាចសំអុយព្រះកិត្តិនាមរបស់ព្រះអង្គនោះ បានបោះបង់គម្រោងការជាប្រវត្តិសាស្ត្រនេះទៅវិញ ។ ជាព្រះមហាក្សត្រដែលត្រូវនិរទេស ជាព្រះបិតាឯករាជ្យរបស់ប្រទេសកម្ពុជា ព្រះអង្គគ្មានព្រះទ័យបញ្ចប់អាជីពនយោបាយដ៏អភ័ព្វរបស់ព្រះអង្គឡើយ ។ ប៉ុន្តែព្រះអង្គមានលក្ខណៈប្រាកដនិយមណាស់ ដែលអាចវិនិច្ឆ័យជាមុនថា ជ័យជម្នះរបស់ខ្មែរក្រហមអាចមានន័យថា នេះជាទីបញ្ចប់នៃតួនាទីរបស់ព្រះអង្គ ជានិមិត្តរូបនៃឯកភាព និងភាពស្របច្បាប់របស់ចលនាតស៊ូផងដែរ ។ ត្រូវបានសាកសួរនៅឆ្នាំ១៩៧៣ ក្នុងពេលដែលព្រះអង្គលែងមានផលប្រយោជន៍ណាមួយសម្រាប់សម្ព័ន្ធមិត្តរបស់ព្រះអង្គហើយនោះ សម្តេចបានព្យាករណ៍ទុកជាមុនថា «ពួកគេនឹងខ្ជាក់ខ្ញុំចោលម្តងទៀតដូចជាគេខ្ជាក់គ្រាប់ផ្លែសឺរីចោលអ៊ីចឹង» ។ នៅក្រុងប៉េកាំងបាតុកម្មជាច្រើនបានត្រូវគេបំផុសឡើងដើម្បីអបអរសាទរជ័យជម្នះនេះ ។ បន្ទាប់មក រយៈពេលជាច្រើនសប្តាហ៍បានកន្លងផុតទៅដោយគ្មានអ្នកណាម្នាក់នឹកភ្នកយាងព្រះអង្គត្រឡប់ទៅប្រទេសកម្ពុជាដែលទើបរំដោះឡើយ ។ សម្តេច សីហនុ អាចសន្និដ្ឋានថា ពេលវេលាដែលគួរឲ្យខ្លាចបំផុតបានមកដល់ហើយ ។*

*សម្តេចបានមានបន្ទូលនឹងពួកតំណាងខ្មែរក្រហមនៅរដ្ឋធានីចិនថា «សូមអនុញ្ញាតឲ្យខ្ញុំវិលត្រឡប់ទៅក្រុងភ្នំពេញវិញ ។ បើសិនជាអស់លោកមិនត្រូវការ សីហនុ ក្នុងឋានៈជាព្រះប្រមុខរដ្ឋ គឺជាករណីយកិច្ចរបស់អស់លោក ។ ខ្ញុំមិនប្រាថ្នាចង់បានមុខតំណែងទៀតទេ ប៉ុន្តែខ្ញុំចង់រស់នៅប្រទេសកម្ពុជា ខ្ញុំលែងចង់ធ្វើជាអ្នកភៀសខ្លួនម្នាក់ទៀតហើយ» ។ ខ្មែរក្រហមបានឆ្លើយតបនឹងព្រះអង្គថា ព្រះករុណាថ្លៃវិសេស ព្រះអង្គនឹងត្រូវយាងវិលទៅវិញ ប៉ុន្តែពុំមែននៅពេលភ្លាមៗនេះទេ ។ ពួកគេបានបន្ថែមថា «សម្រាប់ពេលនេះ យើងមានបញ្ហា*

ជាច្រើនដែលត្រូវដោះស្រាយ  យើងមិនចង់ឲ្យព្រះអង្គចូលឡូកឡំក្នុងបញ្ហានេះឡើយ» ។ ជាការជាក់ច្បាស់ណាស់ថា ខ្មែរក្រហមមិនចូលចិត្តប្រថុយគ្រោះថ្នាក់ ដោយយាងសម្ដេចមកកម្ពុជាវិញឡើយ ។ សប្បុរសធម៌ និងប្រជាប្រិយភាពរបស់ព្រះអង្គបានធ្វើឲ្យខ្មែរក្រហមភ័យបារម្ភជាខ្លាំង ។ ក្នុងរយៈពេលដែលសម្ដេច សីហនុ នៅគង់ចាំ ខ្មែរក្រហមបានបន្តជម្លៀសប្រជាជនទាំងអស់ ចេញពីទីក្រុងទាំងតូចទាំងធំ ហើយពង្រាយប្រជាជនទីក្រុង "ដែលចម្លងមេរោគដោយពួកចក្រពត្តិ និងពួកប្រតិកិរិយា"ទៅគ្រប់ទិសទី ។ នេះគឺជាការចាប់ផ្ដើមនៃ "បដិវត្តន៍ដ៏ល្បីល្បាញ" មួយ ។

តាំងពីការចាប់ផ្ដើមចងសម្ព័ន្ធភាពរបស់ព្រះអង្គនៅឆ្នាំ១៩៧០ សម្ព័ន្ធមិត្តខ្មែរក្រហមរបស់ព្រះអង្គ បានចាត់ទុកសម្ដេចដែលធ្លាក់ពីតំណែងក្នុងតួនាទីសាមញ្ញធម្មតា ដែលគ្មានអំណាចពិតប្រាកដឡើយ ។ សំណើទាំងឡាយរបស់ព្រះអង្គម្ដងហើយម្ដងទៀត ដើម្បីយាងធ្វើទស្សនកិច្ចក្នុងតំបន់ដែលត្រួតត្រាដោយពួកទ័ពព្រៃ បានត្រូវបដិសេធជាញឹកញយ ព្រោះតែមូលហេតុសន្តិសុខ ។ សម្រាប់ "អតីតព្រះមហាក្សត្រ" ព្រះជន្ម៥៣ព្រះវស្សាអង្គនេះ អ្វីដែលធ្វើឲ្យធុញទ្រាន់ជាងគេ គឺវត្តមាននៅកៀកកិតជាប់ជាប្រចាំនៃមេខ្មែរក្រហមម្នាក់ដែលព្រះអង្គធ្លាប់ស្អប់ខ្ពើមគឺ "បងលេខ២" អៀង សារី ជាតំណាងចលនាតស៊ូប្រចាំការនៅក្រុងប៉េកាំង ដែលធ្វើឲ្យព្រះអង្គនឹកឃើញដល់ "ពួកទីប្រឹក្សា" បារាំងដែលតាមព្រះអង្គប្រកិតពីក្រោយគ្មានឈប់ឈរ ពេញរយៈពេលនៃបណ្ដាឆ្នាំដែលព្រះអង្គធ្លាប់ធ្វើជាព្រះមហាក្សត្រអាយ៉ងនៃប្រទេសមួយ ដែលត្រួតត្រាដោយប្រទេសបារាំងដែរ ។ ក្នុងឱកាសនៃព្រះរាជដំណើរទៅកាន់ក្រុងហាណូយ ក្នុងឆ្នាំ១៩៧៣ សម្ដេច សីហនុ ដែលទប់ព្រះទ័យលែងបាន បានបង្កឲ្យមានឧបទ្ទវហេតុការទូតមួយដោយចង្អុលប្រាប់លោក ហ្សង់ គ្រីសតូហ្វ អូប៊ែរ ឯកអគ្គរដ្ឋទូតស៊ុយអែដប្រចាំក្រុងហាណូយ ដែលអញ្ជើញមកសាកសួរសុខទុក្ខសម្ដេចនៅនិវេសនដ្ឋានរបស់ព្រះអង្គ នូវអ្នកដែលចាំឃ្លាំមើលដ៏តឹងតែងរបស់ព្រះអង្គនេះ ។ សម្ដេចបានត្អូញត្អែរដោយសំឡេងមុតស្រួចថា "មនុស្សដ៏គួរឲ្យស្អប់របៀប អៀង សារី នេះបានចំណាយពេលវេលាទាំងអស់របស់គាត់ដើម្បីតាមយកការណ៍ពីខ្ញុំ" ។ នៅពេលកំពុងចាកចេញពីបន្ទប់ សម្ដេចបានមានបន្ទូលទៀតថា "សូមលោកឯកអគ្គរាជទូតសម្លឹងមើលខាងក្រោមវាំងននេះ លោកនឹងឃើញចុងស្បែកជើងរបស់គាត់មិនខាន គឺគាត់នៅឈរពីខាងក្រោយនោះជានិច្ច ដើម្បីលួចស្ដាប់ខ្ញុំមានបន្ទូល" ។ ដោយត្រូវធ្វើឲ្យទីទើរក្នុងចិត្តលោក អូប៊ែរ ពុំហ៊ានពិនិត្យមើលឲ្យដឹងថា មែនឬពុំមែនឡើយ ។

នៅខែមីនា ឆ្នាំ១៩៧៣ ខ្មែរក្រហមបានត្រួតត្រាទឹកដីកម្ពុជាមួយភាគយ៉ាងធំ ។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស មានន័យថាជាការផ្អាកការទម្លាក់គ្រាប់បែកមួយរបស់អាមេរិកាំងនៅប្រទេសវៀតណាម ។ អំណើះតទៅ ផ្លូវលំហូជីមិញលែងជាផ្លូវមានគ្រោះថ្នាក់ទៀតហើយ ។ ហេតុនេះ សម្ដេច សីហនុ បានត្រូវខ្មែរក្រហមអនុញ្ញាតឲ្យធ្វើព្រះរាជដំណើរជាលើកដំបូងរបស់ព្រះអង្គមកកាន់តំបន់រំដោះនានានៅកម្ពុជា ។ នេះគឺជាការលួងលោមព្រះទ័យមួយចំពោះព្រះអង្គ ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ ព្រះអង្គទ្រង់

*ជ្រាបថា ព្រះអង្គលែងមានតំណែងមួយក្នុងកម្ពុជាថ្មីដែលត្រួតត្រាដោយខ្មែរក្រហមទៀតហើយ ។ សម្តេច និង ព្រះមហេសី ម៉ូនិក តែងត្រូវបានតាមដានដោយពួកកម្មាភិបាលខ្មែរក្រហម ដូចស្រមោលអន្ទោលតាមប្រាណ ក្នុងរយៈពេលនៃព្រះរាជដំណើររបស់ព្រះអង្គ ដោយមិនបណ្តោយឲ្យព្រះអង្គទាំងពីរជួបប្រាស្រ័យទាក់ទង ជាមួយប្រជាជនផ្ទាល់ឡើយ ។ ព្រះអង្គទតឃើញតែទឹកមុខគួរឲ្យខ្លាចនៃហ្វូងប្រជាជនដែលគេតម្រូវឲ្យមក សម្រាប់តែលើកកណ្តាប់ដៃជាសង្វាក់និងស្រែកជយឃោសប៉ុណ្ណោះ ។ សម្តេចពុំអាចធ្វើតាមទម្លាប់ពីមុនៗរបស់ ព្រះអង្គ ៖ គឺការព្រលែងព្រះកាយចូលទៅក្នុងហ្វូងមហាជនកាន់ពាល់អ្នកដែលមានស្មារតីភក្តី ដែលរោមជុំជិត ព្រះអង្គក្នុងសម្រែកថា ៖ «សម្តេចឪ ៗ!»ឡើយ ។*

*ជូ អេនឡាយ ដែលជាមិត្តនិងជាអ្នកគាំពារសម្តេចបានដឹងយ៉ាងច្បាស់ថា សម្តេចបានអត់ធ្មត់ទទួលរង អំពើមួយទាំងអាក់អន់ព្រះទ័យ ហើយបានជួយរំលែកការព្រួយបារម្ភរបស់ព្រះអង្គចំពោះពួកជ្រុលនិយមខ្មែរ ក្រហមដែរ ។ តាំងពីខែកុម្ភៈ ឆ្នាំ១៩៧៣ ជូ បាននិយាយប្រាប់ គីស្ស៊ីងហ្គ័រ (រដ្ឋមន្ត្រីការបរទេសអាមេរិក អាណត្តិប្រធានាធិបតី និចសុន) ជាសម្ងាត់ថា វាហាក់ដូចជា «មិនអាចទៅរួចដែលថាកម្ពុជាប្រែក្លាយទៅជា ក្រហមទាំងស្រុងនោះ» ។ គាត់បានសង្កត់បញ្ជាក់ថា ៖ បើសិនជាគេល្បងពិសោធពីរឿងនេះ គេគ្មានបានអ្វីក្រៅ តែពីធ្វើឲ្យបញ្ហាទាំងឡាយកាន់តែស្មុគស្មាញឡើយ»[១] ។ តាមមតិគាត់ថា គេត្រូវតែដាក់សម្តេចឲ្យកាន់អំណាចនៅ ក្រុងភ្នំពេញឡើងវិញ ។ ប៉ុន្តែការប៉ុនប៉ងទាំងប៉ុន្មានរបស់គាត់ ដើម្បីញ៉ាំងឲ្យសហរដ្ឋអាមេរិកភ្ជាប់ការជួបសន្ទនា ជាមួយសម្តេចសីហនុជាថ្មី និងឈានទៅរកដំណោះស្រាយសម្របសម្រួលមួយនោះបានត្រូវបរាជ័យ ។ ពីរឆ្នាំ ក្រោយមក នៅពេលដែលសហរដ្ឋអាមេរិកយល់ព្រមទាត់ចោល លន់ នល់ និងស្នើយាងសម្តេចត្រឡប់ចូលមាតុ ប្រទេសវិញ ចម្បាំងទ័ពព្រៃរបស់ខ្មែរក្រហមឈានជិតដល់ជ័យជម្នះស្រេចទៅហើយ ។ ប្រធានស្ថានបេសកកម្ម ទំនាក់ទំនងរបស់អាមេរិកនៅក្រុងប៉េកាំងគឺ លោក ហ្ស៊កក ប៊ូស (ក្រោយមកជាប្រធានាធិតីសហរដ្ឋអាមេរិកពីឆ្នាំ ១៩៨៩-១៩៩៣) តាមរយៈស្ថានទូតបារាំង ជាអន្តរការីបានស្នើសុំឲ្យសម្តេច ឡើងកាន់ចង្កូតដឹកនាំប្រទេស កម្ពុជាអព្យាក្រឹតមួយ ។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥ សហរដ្ឋអាមេរិកបានស្នើដោយដាក់លាក់ឲ្យសម្តេច យាងចូលក្រុងភ្នំពេញវិញតាមយន្តហោះចិនមួយគ្រឿងហើយឡើងកាន់អំណាចនៅទីនោះ ។ សន្តិសុខផ្ទាល់របស់ ព្រះអង្គក៏ត្រូវបានធានារ៉ាប់រង ។ ប៉ុន្តែពេលនោះខ្មែរក្រហមបានចូលមកដល់មាត់ទ្វារទីក្រុងទៅហើយ ហើយ ជូ អេនឡាយ ក៏លែងអាចយល់ស្របតាមដែរ ។ នៅព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ សម្តេច សីហនុ បាន បដិសេធមិនទទួល«តង្វាយ»របស់អាមេរិកាំងនេះទេ ។ ប៉ុន្មានម៉ោងបន្ទាប់មក ប្រតិបត្តិការ«សត្វឥន្ទ្រីដកថយ» (Eagle Pull) បានចាប់ផ្តើមក្នុងសភាពបន្ទាន់បំផុតដើម្បីជម្លៀសបុគ្គលិកអាមេរិកាំង និងសម្ពន្ធមិត្តខ្មែររបស់ខ្លួន តាមឧទ្ធម្ភាគចក្រ ។ លែងមានអ្វីដែលត្រូវធ្វើទាំងអស់ ។ ដោយរំពុកឡើងវិញពីព្រឹត្តិការណ៍នេះ សម្តេច សីហនុ បានធ្វើអត្ថាធិប្បាយ ដោយសុភាពថា «យឺតពេលណាស់ទៅហើយ» ។*

ខុសប្លែកពីឆ្នាំ១៩៥៣ ទុកណាជាព្រះអង្គសម្រេចជោគជ័យទាមទារបានឯករាជ្យពីបារាំងក៏ដោយ ក៏ពេលនេះ សម្ដេច សីហនុ លែងអាចធ្វើអ្វីមួយក្នុងការដឹកនាំសន្សំព្រឹត្តិការណ៍ផ្សេងៗ ហើយថែមទាំងមិនអាចកំណត់ព្រឹត្តិការណ៍ទាំងនោះទៀតផង ។ បទពិសោធន៍ទាំងឡាយដែលប្រមូលបានតាំងពីការឡើងសោយរាជ្យរបស់ព្រះអង្គកាលពី៣៤ឆ្នាំមុន (គិតត្រឹមឆ្នាំ១៩៧៥) ហាក់ដូចជាឥតបានការអ្វីទាំងអស់ ។ នៅឆ្នាំ១៩៤១ ពួកបារាំងបានសម្រេចជ្រើសរើសខ្សែ នរោត្តម គឺសម្ដេច នរោត្តម សីហនុ ដែលមានព្រះជន្ម១៩ព្រះវស្សាឲ្យឡើងគ្រងរាជ្យបល្ល័ង្ក ជាជាងយកគូប្រជែងរបស់ព្រះអង្គខាងខ្សែស៊ីសុវត្ថិ ពីព្រោះបារាំងឃើញថាព្រះអង្គជាយុវក្សត្រមួយអង្គស្រស់សង្ហាជាងគេ ។ លោកស្រី ដឹគូ នៅពេលក្រឡេកឃើញសម្ដេច សីហនុ បានខទានឡើងថា ៖ «គួរឲ្យស្រឡាញ់ណាស់ ក្មេងតូចប្រុសឡើងនេះ!» ។ លោកអគ្គទេសាភិបាលឥណ្ឌូចិន គឺឧត្ដមនាវីបារាំង ហ្សង់ដឹគូ បានសុំយាងព្រះអង្គឲ្យចូលរួមសោយអាហារថ្ងៃត្រង់នៅវិមានរបស់លោកនាទីក្រុងព្រៃនគរ ។

យុវក្សត្រដ៏ស្រស់សង្ហាអង្គនេះបានផ្ដើមប្រឡូកក្នុងឆាកនយោបាយដោយឆាប់រហ័ស ។ មុខតំណែងរបស់ព្រះអង្គបានផ្ដល់នូវការអនុគ្រោះឲ្យព្រះអង្គវិញយ៉ាងច្រើន ។ សម្ដេចបានចាត់ការយ៉ាងឆ្លាតដើម្បីដណ្ដើម «កន្លែង»គណបក្សនយោបាយកម្ពុជានានា ដែលជាអ្នកទាមទារដោយទទូចនូវការបញ្ចប់អាណាព្យាបាលរបស់បារាំង ហើយធ្វើឲ្យគេជឿថាបុព្វហេតុជាតិនិយមជាបុព្វហេតុផ្ទាល់របស់ព្រះអង្គ ។ ឯករាជ្យភាពដែលព្រះអង្គអះអាងនឹងប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល (1947-1954) និងរដ្ឋមន្ត្រីការបរទេសអាមេរិក ហ្សន ហ្វូស្ទ័រ ឌុល (1953-1959) គឺជាមធ្យោបាយសម្រេចជោគជ័យតែមួយគត់ប្រឆាំងទល់នឹងពួកកុម្មុយនីស្ត ពីព្រោះថា ពួកនេះ សុទ្ធតែជាមនុស្សដំបូងៗគេ ដែលកាន់ទង់ជ័យក្នុងការប្រយុទ្ធប្រឆាំងអាណានិគមនិយម ។ ព្រះអង្គចេះប្រើប្រាស់សារព័ត៌មានអន្តរជាតិ ហើយសម្រេចបានផលយ៉ាងសម្បើមអស្ចារ្យ ដូចជានៅពេលដែលព្រះអង្គនិរទេសខ្លួនដោយស្ម័គ្រព្រះទ័យ ដើម្បីធ្វើឲ្យពួកបារាំងធ្លាក់ទៅក្នុងស្ថានភាពលំបាក និងប្រមូលបានយុទ្ធិកជនយ៉ាងច្រើនដែលជឿជាក់លើបុព្វហេតុរបស់ព្រះអង្គជាដើម ។ ទីបំផុត នៅខែវិច្ឆិកា ឆ្នាំ១៩៥៣ ពួកបារាំងបានប្រគល់ឯករាជ្យមកឲ្យព្រះអង្គវិញ រួចហើយសម្ដេចបានបូជាថាមពលរបស់ព្រះអង្គដើម្បីវាយប្រយុទ្ធនឹងវៀតមិញដែលដឹកនាំដោយហូជីមិញថែមទៀត ។

ក្នុងរយៈពេល១៧ឆ្នាំដែលក្នុងចិរវេលានោះ សម្ដេចជាអ្នកគ្រប់គ្រងប្រទេសកម្ពុជា ព្រះអង្គបានដឹកនាំប្រទេសក្នុងសភាពពេញលេញទាំងស្រុង ។ ដើម្បីកាន់កាប់អំណាចទាំងស្រុងក្នុងឋានៈជាព្រះប្រមុខរដ្ឋជាជាងក្នុងឋានៈជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ នៅឆ្នាំ១៩៦០ សម្ដេច សីហនុ បានដាក់រាជ្យដោយលើកព្រះបិតាព្រះអង្គឲ្យឡើងគ្រងរាជ្យវិញ ។ គ្មានអ្វីមួយដែលមិនសំខាន់ចំពោះព្រះអង្គឡើយ ៖ ព្រះអង្គសរសេរបទវិចារណកថាជាច្រើនចុះផ្សាយក្នុងកាសែត ដឹកនាំធ្វើគម្រោងការក្នុងវិស័យនយោបាយទឹកនិងកសាងមណ្ឌលសុខភាពយ៉ាងច្រើននៅតាមជនបទទាំងឡាយ ។ គឺព្រះអង្គនេះហើយជាអ្នកជ្រើសរើស«សម្មតិនាម»(ឈ្មោះក្រៅ) ដាក់

ឲ្យគណបក្សនានាដែលប្រឆាំងជិទាស់នឹងអំណាចផ្ទាល់របស់ព្រះអង្គនោះ ៖ ខ្មែរខៀវសម្រាប់ហៅពួកប្រឆាំងស្តាំនិយម ឬសាធារណរដ្ឋនិយម ខ្មែរក្រហមសម្រាប់ហៅពួកមាននិន្នាការនិយមឆ្វេងជ្រុល ដោយចោទប្រកាន់អ្នកទាំងនោះថា សុទ្ធតែជាវណបបរទេស ។ ព្រះអង្គតាមអំពល់ខ្មែរក្រហមគ្មានឈប់ឈរ ដោយសាកល្បងយកពួកនោះបញ្ចូលមកក្នុងរដ្ឋាភិបាលរបស់ព្រះអង្គទៅតាមកាលៈទេសៈហុចឲ្យ ។ ហេតុនេះហើយបានជានៅដើមទសវត្សរ៍៦០ មេដឹកនាំរបស់ពួកនេះជាច្រើននាក់ដូចជា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលរបស់ព្រះអង្គ ។ ខាងក្នុងប្រទេស ព្រះអង្គបានសាកល្បង "ផ្តាច់ដើង" ពួកនិយមឆ្វេងជ្រុល ដោយផ្តើមបង្កើតចលនាមួយដែលមានលក្ខណៈពិសេសខុសប្លែកពីធម្មតាគឺ "សង្គមនិយមព្រះពុទ្ធសាសនា" ដែលក្នុងការប្រព្រឹត្តគឺជាភាពផ្តាច់មុខមួយរបស់រដ្ឋកាន់កាប់ដោយវរជនម្នាក់ ដែលច្រើនពុករលួយឬជាមនុស្សរស់នៅដោយសារគេ ។ នៅក្រៅប្រទេស ព្រះអង្គចេះសម្តែងតួជា "អ្នកស្វែងរកឲ្យមានតុល្យភាពកម្លាំង" ដើម្បីការពារឯករាជ្យភាពនិងបូរណភាពដែនដីរបស់ប្រទេសកម្ពុជា ។ ប៉ុន្តែសង្គ្រាមនៅវៀតណាមកំពុងរាលដាលយ៉ាងខ្លាំង ហើយបញ្ហាផ្សេងៗក្នុងប្រទេសក៏កំពុងកាន់តែដុនដាបខ្លាំងណាស់ដែរ នៅទីបំផុត សម្តេច សីហនុ ដែលជា "អ្នកស្វែងរកឲ្យមានតុល្យភាពកម្លាំង" បានបរាជ័យក្នុងរឿងនេះ ។ ដើម្បីបំពេញចិត្តវៀតណាមខាងជើងដែលព្រះអង្គចាត់ទុកជាអ្នកមានជ័យជម្នះពិតប្រាកដក្នុងជម្លោះនេះ ហើយដែលក្នុងនោះព្រះអង្គទតឃើញកម្លាំងថ្មីងើបឡើងនៅតណ្ហចិនទៀតនោះ ព្រះអង្គត្រូវតែពត់អព្យាក្រឹតភាពរបស់ទ្រង់ឲ្យផ្អៀងទៅរកគេ ដោយយល់ព្រមផ្តល់ទីជម្រកនៅតាមព្រំដែន និងអនុញ្ញាតឲ្យពួកនោះនាំអាវុធឆ្លងកាត់តាមច្រកកំពង់ផែ(កំពង់សោម) របស់កម្ពុជាថែមទៀត ។ អំពើពុករលួយ ការគ្រប់គ្រងសេដ្ឋកិច្ចជាតិមិនល្អ និងការបាត់បង់ជំនួយរបស់អាមេរិកាំងបានបណ្តាលឲ្យមានការរវាតចិត្តខាងនយោបាយ ។ ការកើនឡើងក្នុងប្រទេសនូវភាពប្រទូសរ៉ាយចំពោះវត្តមានរបស់វៀតណាម បានត្រឹមតែដុតកំហឹងឲ្យឆាបឆេះឡើងថែមទៀតប៉ុណ្ណោះ ។ ជាមួយនឹងការគាំទ្រជាសម្ងាត់របស់សហរដ្ឋអាមេរិក ឧត្តមសេនីយ៍ លន់ នល់ បានធ្វើឲ្យសម្តេចខ្វាតចេញពីអំណាចក្នុងពេលដែលព្រះអង្គយាងត្រឡប់ពីការសម្រាកព្យាបាលព្រះរោគនៅប្រទេសបារាំង ដោយកាត់តាមទីក្រុងមូស្គូមកវិញ ។ ត្រូវជំរុញដោយវៀតណាមនិងចិន ព្រះអង្គបានជួយជ្រោមជ្រែងឲ្យមានចលនាតស៊ូមួយ ហើយយកទីក្រុងប៉េកាំងជាលំនៅស្ថានបណ្តោះអាសន្នរបស់ព្រះអង្គ ។

នៅរដូវក្តៅឆ្នាំ១៩៧៥ សម្តេច សីហនុ បានដណ្តឹងសួរក្នុងព្រះទ័យថា តើលំនៅស្ថានបណ្តោះអាសន្ននេះមានលក្ខណៈសម្បត្តិល្មមនឹងក្លាយជាអចិន្ត្រៃយ៍មែនឬ...? ខុសប្លែកពីបណ្តាស្តេចដែលត្រូវគេទម្លាក់ពីតំណែង ព្រះអង្គពុំមានគណនីណាមួយនៅឯធនាគារបរទេសសម្រាប់ប្រើប្រាស់តាមសេចក្តីត្រូវការឡើយ ។ ដូច្នេះព្រះអង្គគ្មានការជ្រើសរើសណាផ្សេងទៀត ក្រៅតែពីយល់ព្រមទទួលការឲ្យស្នាក់នៅដោយសេចក្តីសប្បុរសពីបណ្តាមិត្តចិននិងកូរ៉េខាងជើងប៉ុណ្ណោះ ។ ម៉ៅ និង ជូ បានធានាអះអាងនឹងព្រះអង្គថា សម្តេចអាចគង់ប្រថាប់នៅ

ប្រទេសចិនក្នុងរយៈពេលយូរថែមទៀតតាមតែព្រះអង្គសព្វព្រះទ័យ ។ ប្រធានាធិបតី គីម អ៊ីលស៊ុង បានស្ថាបនាវិមានដ៏ស្កឹមស្កៃមួយបែរមុខទៅរកបឹងឆាងស៊ូអុន នៅទីក្រុងព្យុងយ៉ាងសម្រាប់ថ្វាយព្រះអង្គគង់ប្រថាប់ជាកិត្តិយស ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ សម្តេច សីហនុ បានគង់នៅក្នុងទីក្រុងនេះនៅពេលដែលឧបនាយករដ្ឋមន្ត្រី ខៀវ សំផន និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន អៀង ធីរិទ្ធ នៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារដ្ឋាភិបាលនិរទេសដែលបង្កើតឡើងដោយសម្តេចសហការជាមួយខ្មែរក្រហមបានទៅដល់ទីនោះដោយនាំសារលិខិតមួយសុំយាងសម្តេចត្រឡប់មកប្រទេសវិញ ដែលព្រះអង្គទន្ទឹងរង់ចាំតាំងពីយូរមកហើយ ។ ខ្លឹមសារនៃសារលិខិតរបស់ ខៀវ សំផន មានដូចតទៅ "ឥឡូវនេះយើងត្រៀមខ្លួនជាស្រេច ដើម្បីស្វាគមន៍សម្តេចដោយរាក់ទាក់បំផុត ។ អំណើះតទៅលក្ខណៈសម្បត្តិផ្សេងៗបានត្រូវបំពេញរួចរាល់អស់ហើយ ដែលធ្វើឲ្យយើងទាំងអស់គ្នាក្លាយទៅជាជនកុម្មុយនីស្ត១០០ភាគរយ ។ យើងអាចគ្រោងគិតធ្វើឲ្យលើសពួកចិនជាបងប្អូនទៅទៀត ។ មហាលោតផ្លោះតែមួយជំហានទៅមុខ យើងអាចឈានទៅដល់ដំណាក់កាលកុម្មុយនីស្តបានដោយរៀបចំសេដ្ឋកិច្ចតាមលទ្ធិសង្គមនិយមជាដំណាក់ៗ" ។ ប្រការនេះមានលក្ខណៈគួរឲ្យព្រួយបារម្ភបន្តិច ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏សម្តេចសប្បាយព្រះទ័យវិលមកមាតុប្រទេសវិញដែរ ។

សម្តេចអ្នកម្នាង ម៉ូនិក និង អៀង ធីរិទ្ធ បានជិះរថភ្លើងមកកាន់ក្រុងប៉េកាំងជាមួយគ្នាដែលនៅទីនោះយន្តហោះប៊ូអ៊ីង-៧០៧របស់ចិនមួយគ្រឿងចាំជូនដំណើរមកកាន់ក្រុងភ្នំពេញទៀត ។ មុននឹងចាកចេញពីរដ្ឋធានីចិន សម្តេចព្រមទាំងមហេសីដែលអមដំណើរដោយ ខៀវ សំផន បានទៅសួរសុខទុក្ខប្រធាន ម៉ៅ និងនាយករដ្ឋមន្ត្រីទី១ ជូ អេនឡាយ ដែរ ។ ក្នុងអាយុ៨២ឆ្នាំ(អាយុកាលពីឆ្នាំ១៩៧៥) ម៉ៅ បានទទួលរងការឈឺចាប់ដោយសារជំងឺ ប៉ារគីនសុន (គឺជំងឺធ្លាក់ទន់ខ្សោយផ្នែកប្រពន្ធ័សរសៃប្រសាទមានលក្ខណៈសម្គាល់ដោយការញ័រទទ្រើក និងភាពរឹងឆ្អឹតនៃសាច់ដុំ-កំណត់របស់អ្នកបកប្រែ) ។ ការនិយាយស្តីរបស់គាត់មានសភាពសឹងតែមិនអាចឲ្យគេស្តាប់យល់បាន ។ ប៉ុន្តែយ៉ាងហោចណាស់ សេចក្តីណែនាំមួយក្នុងចំណោមសេចក្តីណែនាំជាច្រើនរបស់គាត់ចំពោះ ខៀវ សំផន និង អៀង ធីរិទ្ធ គឺមានសភាពច្បាស់លាស់ណាស់ "ខ្ញុំសូមសមមិត្តមេត្តាកុំបញ្ជូនសម្តេច សីហនុ និងព្រះមហេសី ឲ្យទៅរស់នៅក្នុងសហករណ៍" ។ ពាក្យសម្តីរបស់គាត់ទាំងនេះបានជួយសង្គ្រោះសម្តេច សីហនុ ឲ្យរួចផុតពីគ្រោះថ្នាក់ដល់ជីវិត ។

ជូ ត្រូវយាយីដោយជំងឺមហារីក រស់នៅដូចដាក់គុកខ្លួនឯង ។ គាត់បានទទូចសុំ ខៀវ សំផន ដោយសំឡេងមួយដែលសឹងតែស្តាប់មិនឮថា "សូមសមមិត្តធ្វើដំណើរទៅកាន់លទ្ធិកុម្មុយនីស្តដោយសន្សឹមៗ ។ សមមិត្តពុំអាចឈានឡើងលទ្ធិកុម្មុយនីស្តដោយពុំមានដំណាក់កាលផ្សេងៗនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺត្រូវដើរមួយជំហានម្តងៗ ។ សូមសមមិត្តរៀបចំជំហានតូចៗឲ្យបានច្រើនដោយល្បឿនយឺតៗ ប៉ុន្តែប្រាកដប្រជា" ។ អ្វីដែលធ្វើឲ្យគេចាប់អារម្មណ៍ខ្លាំងថែមទៀតនោះ គឺដំបូន្មានរបស់គាត់ដែលឲ្យដឹងហេតុមុនថា "កុំធ្វើតាមគំរូអាក្រក់នៃនយោ

*បាយមហាលោតផ្លោះរបស់យើង» ។ នេះជាពាក្យនិយាយបញ្ចិតបញ្ចៀង ចំពោះគម្រោងការដ៏ហួសវិស័យមួយ គឺការប៉ុនប៉ងកសាងលទ្ធិកុម្មុយនីស្តឲ្យបានភ្លាមៗនៅប្រទេសចិន ដែលបណ្ដាលឲ្យសេដ្ឋកិច្ចចិនខ្សោះរឹងរៃនៅចុង សតវត្សរ៍៥០ ។ សំផន និង ធីរិទ្ធ សើចញឹមៗរបៀបសមគំនិតគ្នា ហើយសម្ដេច សីហនុ ដែលធ្លាប់ឮអ្នក ទាំងពីរអួតថាបានចាប់ផ្ដើមអនុវត្តលទ្ធិកុម្មុយនីស្តដែរនោះ អាចដឹងពីន័យនៃការញញឹមនេះហើយ ។*

*ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៥ ក្រុងប៉េកាំងបានរៀបចំធ្វើពិធីបុណ្យអបអរម្ដងទៀត ។ នៅលើទីលាន ទៀនអានម៉េន គេឃើញទង់ជាតិ គោមធំៗនិងបដាជាច្រើនដើម្បីថ្លែងអំណរសរសើរនូវអ្វីដែល គេង ស៊ាវពីង ហៅថា «ការជួបជុំគ្នាឡើងវិញប្រកបដោយកិត្តិយស»របស់ សម្ដេច សីហនុ ។ យន្តហោះចិនបានផ្ដើមបន្ទាបខ្លួន ចុះចតលើអាកាសយានដ្ឋានពោធិចិនតុង ។ នេះជាលើកដំបូងហើយដែលសម្ដេចទតឃើញរាជធានីរបស់ព្រះអង្គ ពីលើយន្តហោះតាំងតែពីព្រះអង្គចាកចេញនៅខែមករា ឆ្នាំ១៩៧០មក ។ បើប្រៀបធៀបនឹងមនុស្សរាប់ពាន់ ម៉ឺននាក់ដែលឈរលើកដៃជាសញ្ញាមិត្តភាព តាមផ្លូវពេលដែលព្រះអង្គយាងចេញដំណើរពីទីក្រុងប៉េកាំងនឹងហ្វូង មនុស្សដែលឈររាយប៉ាយចាំទទួលព្រះអង្គតាមផ្លូវពីពោធិចិនតុងមកក្រុងភ្នំពេញនោះ គឺអ្នកទាំងនេះសុទ្ធតែ មានទឹកមុខស្ងេកស្ងាំងគួរឲ្យឆ្ងល់ ។ ព្រះសង្ឃពីរ-បីអង្គត្រូវបានអនុញ្ញាតឲ្យសូត្រជយន្តោថ្វាយព្រះអង្គ បន្ទាប់មក ក្បួនរថយន្តមួយបានអមការពាររថយន្តព្រះអង្គធ្វើដំណើរឆ្លងកាត់ទីក្រុងមួយ ដែលមានសភាពស្ងាត់ជ្រងំ ។ នេះ ជាការផ្ដល់កិត្តិយសទៅតាមប្រពៃណីជាលើកចុងក្រោយ ដែលគេធ្វើឲ្យព្រះអង្គទតឃើញក្នុងប្រទេសកម្ពុជារបស់ ខ្មែរក្រហម ។*

*សម្ដេចបានត្រូវធ្វើឲ្យរំជួលព្រះទ័យរហូតស្រក់ទឹកព្រះនេត្រនៅពេលដែលទ្រង់ទតឃើញទីក្រុងខ្មោចនេះ ដែលកាលពីដើមជាទីក្រុងដ៏ស្រស់ត្រកាលបំផុតនៃឥណ្ឌូចិនរបស់បារាំង ។ មហាវិថីនានាដែលអមដោយដើមឈើ ធំៗ សួនច្បារទាំងឡាយនិងកំពូលស្រួចនៃព្រះបរមរាជវាំង វត្តអារាមសុទ្ធតែនៅល្អស្អាតទាំងអស់ ប៉ុន្តែហាក់ដូចជា ក្រៀមក្រំរបៀបកាន់ទុក្ខ ។ ខ្មែរក្រហមបានបកស្រាយជូនសម្ដេចថា ៖ «ការជម្លៀសប្រជាជនគឺជាការចាំបាច់ ពីព្រោះទីក្រុងលែងអាចចិញ្ចឹមប្រជាជនរបស់ខ្លួនបានទៀតហើយ ហើយបញ្ហាសន្តិសុខក៏មិនអាចដោះស្រាយ បានដែរ» ។ ពួកនេះមិនបានទូលព្រះអង្គថា គឺត្រង់នេះឯងជានយោបាយមហាលោតផ្លោះដំបូងបំផុតឆ្ពោះទៅ កាន់លទ្ធិកុម្មុយនីស្តឡើយ ។ ក្នុងការចាកចេញទាំងហ្វូងៗនៅខែមេសា ឆ្នាំ១៩៧៥ សម្ដេចក្រុមព្រះ មុនីរ៉េត ជា ព្រះបិតុលាសម្ដេច សីហនុ ព្រមទាំងព្រះមាតុច្ឆាមួយអង្គក្នុងចំណោមព្រះមាតុច្ឆាជាច្រើនរបស់ព្រះអង្គបានត្រូវ ខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅជនបទដូចប្រជាជនដទៃៗទៀតដែរ ។ ក្នុងពេលដែលព្រះអង្គសុំទៅសួរសុខទុក្ខអ្នក ទាំងនោះ គេបានជំទាស់ដោយការបដិសេធយ៉ាងគួរសមមួយថា ៖ «មានគេមើលថែទាំអ្នកទាំងនោះល្អហើយ ។ ព្រះអង្គនឹងត្រូវបានអនុញ្ញាតឲ្យទៅបាន នៅពេលណាដែលព្រះអង្គវិលត្រឡប់ពីទីក្រុងញូវយ៉កមកវិញ» ។ ព្រះអង្គលែងបានជួបអ្នកទាំងនោះម្ដងទៀតជារៀងរហូត ។ ក្នុងយុទ្ធសាស្ត្ររបស់ខ្មែរក្រហម ការស្នាក់អាស្រ័យ*

របស់សម្តេច សីហនុ ចំនួនបីសប្តាហ៍នៅទីក្រុងភ្នំពេញបានបំពេញគោលដៅដ៏ជាក់លាក់មួយ ។ នោះគឺជាការធ្វើឲ្យគេទទួលស្គាល់តាមផ្លូវការនូវការប្រឌិតការចូលរួមរបស់ព្រះអង្គជាមួយរដ្ឋអំណាចថ្មីមុនពេលព្រះអង្គយាងទៅទាមទារអាសនៈរបស់កម្ពុជានៅឯមហាសន្និបាតអង្គការសហប្រជាជាតិ ។ សម្តេច និងអ្នកហែហមព្រះអង្គបានត្រូវយាងឲ្យធ្វើដំណើរទេសចរណ៍តាមជនទន្លេមេគង្គដោយមានរៀបចំពិធីជប់លៀងដ៏អធិកអធមជាកិត្តិយសដល់ព្រះអង្គផង ហើយបានសុំយាងព្រះអង្គនិងរាជបរិពារចូលរួមរាត្រីសមោសរបដិវត្តជាច្រើន ប៉ុន្តែអ្នកទាំងនោះមិនដែលបានជួបអ្នកដែលធ្លាប់រស់នៅទីក្រុងណាម្នាក់ឡើយ ។ អ្វីៗបានរលាយបាត់ដូចជាផ្សែង ។

សម្តេច សីហនុ ទ្រង់ជ្រាបយ៉ាងឆាប់រហ័សនូវអ្វីដែលខ្មែរក្រហមធ្វើតាមដំបូន្មានរបស់ ជូ អេនឡាយ និងសារសំខាន់នៃការធ្វើដំណើរដោយសន្សឹមៗឆ្ពោះទៅកាន់លទ្ធិសង្គមនិយម ។ សុន សេន អគ្គសេនាធិការ កងទ័ព និង ខៀវ សំផន បានទូលប្រាប់ព្រះអង្គថា កម្ពុជានឹងបង្ហាញឲ្យពិភពលោកឃើញថា យើងរៀបចំឲ្យមានសណ្តាប់ធ្នាប់តែមួយខ្ទាច់ និងយ៉ាងដាច់ស្រឡះ យើងមានលទ្ធភាពអាចឈានទៅដល់លទ្ធិកុម្មុយនីស្ត ។ អ្នកទាំងពីរបានទូលឲ្យព្រះអង្គដឹងទៀតថា «ធ្វើដូច្នេះឈ្មោះរបស់កម្ពុជានឹងត្រូវបានចារឹកដោយអក្សរមាសក្នុងប្រវត្តិសាស្ត្រពិភពលោកក្នុងឋានៈជាប្រទេសដំបូងគេបំផុត ដែលសម្រេចបានជោគជ័យក្នុងការបង្កើតលទ្ធិកុម្មុយនីស្ត ដោយមិនចាំបាច់មានដំណាក់កាលផ្សេងៗដែលឥតប្រយោជន៍ឡើយ» ។

នៅដើមខែតុលា ពេលយាងត្រឡប់មកទីក្រុងប៉េកាំងវិញ សម្តេច សីហនុ បានផ្តល់ដល់បណ្តាសមាជិករាជវង្សានុវង្ស និងអ្នកជិតស្និទ្ធរបស់ព្រះអង្គនូវសេរីភាពក្នុងការសម្រេចចិត្ត ។ រូបព្រះអង្គផ្ទាល់ក្នុងឋានៈជាអ្នកស្នេហាជាតិ និងជាប្រមុខរដ្ឋ សម្តេចនឹងត្រឡប់ទៅកម្ពុជាវិញ បន្ទាប់ពីបានធ្វើជាតំណាងប្រទេសរបស់ព្រះអង្គនៅឯអង្គការសហប្រជាជាតិរួចហើយ ។ ប៉ុន្តែ សម្រាប់អ្នកឯទៀត ព្រះអង្គបានទុកសេរីភាពឲ្យជ្រើសរើសទីកន្លែងរស់នៅដោយខ្លួនឯងចុះ ។ សហការីរបស់ព្រះអង្គជាច្រើននាក់ដែលតូចចិត្តយ៉ាងខ្លាំង ដោយសារអ្វីដែលពួកគេទើបនឹងបានសម្គាល់ឃើញថ្មីៗ មិនហ៊ានវិលមកភ្នំពេញវិញទេ ហើយបានចាកចេញឆ្ពោះទៅកាន់ប្រទេសបារាំងតែម្តង ។

សម្តេច សីហនុ ផ្ទាល់បានយាងត្រឡប់មកប្រទេសវិញដោយយាងឆ្លងកាត់តាមទីក្រុងប៉ារីស ។ ជនជាតិខ្មែរមួយហ្វូងធំបានមករង់ចាំទទួលស្វាគមន៍ព្រះអង្គនៅអាកាសយានដ្ឋានស្ពាលដឺហ្គោល ។ បន្តិចក្រោយមកភាគច្រើនក្នុងចំណោមជនជាតិខ្មែរទាំងនោះបានមកជួបជុំគ្នានៅនិវេសនដ្ឋានរបស់ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងប៉ារីស ដើម្បីទទួលព័ត៌មានសំខាន់ៗពីព្រះអង្គស្តីពីសកម្មភាពរបស់ប្រទេសក្រោមរបបពួកខ្មែរក្រហម ។ អ្នកទាំងអស់នោះងឿងឆ្ងល់ពីភាពប្រយត្ន័ប្រយែងរបស់ព្រះអង្គយ៉ាងខ្លាំង ដែលតាមទម្លាប់គឺព្រះអង្គមានសភាពក្លៀវក្លាណាស់ ។ ជនជាតិខ្មែរម្នាក់បានសួរព្រះអង្គថា តើទាហានរបស់ លន់ នល់ ក្លាយទៅជាយ៉ាងណាអស់ទៅហើយ? ។ ព្រះអង្គបានឆ្លើយតបថា អង្គការ (គឺបក្សកុម្មុយនីស្តកម្ពុជាដ៏មានអំណាចបំផុត) បានផ្តល់ឲ្យគេ

ម្នាក់ៗនូវកន្ទេលមួយនិងមុងមួយ ហើយបញ្ជូនឲ្យទៅធ្វើស្រែទាំងអស់ ។ ព្រះអង្គបានបន្ថែមថា ៈ តាមព្រះអង្គយល់ ទាហានទាំងនោះបានត្រឹមតែអ្វីដែលពួកគេស័ក្តិសមនឹងបានប៉ុណ្ណោះ ។ អៀង សារី ដែលនៅអង្គុយក្បែរព្រះអង្គញញឹមជាប់ ហើយពួកមេដឹកនាំខ្មែរក្រហមដទៃទៀត[៧] បានងក់ក្បាលយល់ស្រប ។ គ្មានអតីតមិត្តភក្តិរបស់សម្តេចណាម្នាក់អាចឆ្លងកាត់ «ខ្សែសន្តិសុខ» ដែលលាតសន្ធឹង ដោយខ្មែរក្រហមនៅជុំវិញព្រះអង្គឡើយ ។ ពុំមានការជួបសន្ទនាគ្នាជាលក្ខណៈឯកជនទេ ។ ដូច្នេះសម្តេច សីហនុ មានអារម្មណ៍មិនល្អស្រេចទៅហើយ ចំពោះអ្វីដែលនៅរង់ចាំព្រះអង្គ ។ ប៉ុន្តែ មោទនភាព និងការដឹងពីករណីយកិច្ចរបស់ព្រះអង្គបានរីកឡើងយ៉ាងខ្លាំង ដើម្បីអាចនឹងឲ្យសម្តេចបោះបង់ចោលការងារនៅពេលក្រោយ ។ នៅខែធ្នូ ឆ្នាំ១៩៧៥ សម្តេច សីហនុ ដែលអមដោយមហេសី ម៉ូនិក ព្រះមាតាក្មេក ប៉ុម ព្រមទាំងព្រះរាជបុត្រ និងព្រះរាជនត្តា(ចៅ) ចំនួន២២អង្គបានវិលត្រឡប់មកកាន់ក្រុងភ្នំពេញវិញ ។

# ជំពូកទី២
# ជនក្បត់ជាតិ និងកណ្ដុរ

នៅពេលដែលអ្វីៗមានដំណើរការទៅយ៉ាងល្អ ក៏ក្រុងហាណូយមិនសូវមានលក្ខណៈរីករាយខ្លាំងដែរ ។ ក៏ប៉ុន្តែ នៅពេលដែលភាពត្រជាក់មុតដល់ឆ្អឹងមួយបង្ខំឲ្យប្រជាពលរដ្ឋរបស់ខ្លួន ដែលស្លៀកពាក់ស្ទើរមិនជិតខ្លួន ប្រាណឲ្យស្ថិតនៅតែក្នុងផ្ទះ ទីក្រុងហាក់ដូចជារឹតតែគោកយ៉ាក និងស្ងាត់ជ្រងំថែមទៀតជាមួយនឹងរុក្ខវិថីនានា ដែលអមទៅដោយដើមឈើនិងទិដ្ឋភាពចាស់ទ្រុឌទ្រោមរបស់ខ្លួន ។ អ្នកជិះកង់បានធាក់កង់យ៉ាងលំបាក ខ្នងឡើងកោង ក្បាលគ្របដណ្ដប់ក្នុងកន្សែងវែងសម្រាប់រុំកនិងចង្កាកុំឲ្យរងា ឬអាវយឺត រីបខ្លួនដៃវែងគ្របដណ្ដប់លើស្មាទាំងពីរ ។ ជាមួយអាវរោមសំឡី ស្រោមដៃនិងកង់ម៉ាករ៉ាឡេក (Raleigh) ភ្លឺរលោងរបស់ខ្ញុំ ដែលខ្ញុំខ្ចីពីអ្នកការទូតម្នាក់ ខ្ញុំហាក់ដូចជាមានអារម្មណ៍ចង់ដើរលំហែបន្តិចក្នុងហ្វូងមនុស្ស ដែលមិនសូវនិយាយស្ដី និងដែលកំពុងរងាញាក់ក្នុងពេលធ្វើចរាចរ ។ តាមរថយន្ត ភាពប្លែកពីគេនៃសម្លៀកបំពាក់របស់ខ្ញុំ មិនសូវធ្វើឲ្យអ្នកដំណើរកត់សម្គាល់ទេ ។ ខ្ញុំបានសម្រេចចិត្តលែងត្រូវការរថយន្តម៉ាកវ៉ុលវ៉ូ ពណ៌ប្រផេះ ដែលជួលពីមន្ទីរទេសចរណ៍ក្រុងហាណូយ ដែលខ្ញុំត្រូវការប្រើប្រាស់សម្រាប់ការធ្វើដំណើរជាផ្លូវការផ្សេងៗរបស់ខ្ញុំ ហើយខ្ញុំបានឲ្យមគ្គុទ្ទេសក៍របស់ខ្ញុំនៅក្រសួងការបរទេសត្រឡប់ទៅវិញ ដោយយកលេសថា ខ្ញុំពុំមានការណាត់ជួបគ្នាណាមួយនៅពេលរសៀលនេះទេ ។ ប៉ុន្តែនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧នេះ ខ្ញុំមានការជួបគ្នាតាមការណាត់ដោយលួចលាក់មួយ ដែលពិតជាមិនធ្វើឲ្យរដ្ឋមន្ត្រីការបរទេសវៀតណាមសប្បាយចិត្តទេ ។

ព្រះអាទិត្យបានចោលរស្មីយ៉ាងស្រទន់នៅពេលរសៀលនេះដែលមានខ្យល់បក់បោកជានិច្ច ។ ខ្ញុំបានចាកចេញពីសណ្ឋាគារថុងញ៉ិត ដោយលបលាក់មិនឲ្យគេដឹង ហើយតម្រង់ឆ្ពោះទៅស្ថានទូតកម្ពុជាប្រជាធិបតេយ្យក្នុងក្រុងហាណូយ ។ វៀតណាមនិងកម្ពុជាបានបន្តផ្លាស់ប្ដូរការជូនពរសព្ទសាធុការគ្នាទៅវិញទៅមកក្នុងថ្ងៃប្រារព្ធពិធីបុណ្យជាតិរៀងៗខ្លួន ប៉ុន្តែទំនាក់ទំនងរបស់ពួកគេបានធ្លាក់ចុះយ៉ាងជាក់ច្បាស់ ។ ការធ្វើដំណើររបស់ ប៉ុល ពត ទៅក្រុងប៉េកាំងនៅខែតុលា ការវាយប្រហារគ្រង់ៗដែលស្ទើរតែមិនបិទបាំងរបស់មេដឹកនាំកម្ពុជាប្រឆាំងនឹងវៀតណាម សុទ្ធតែជាការអះអាងបន្ថែមជាសាធារណៈលើកដំបូងក្នុងការទាស់ទែងគ្នារបស់ខ្លួន ។ ក្នុងអំឡុងពេលឈប់សំចតរយៈខ្លីមួយនៅក្រុងវៀងច័ន្ទ (រដ្ឋធានីប្រទេសឡាវ) ក្នុងដំណើរឆ្ពោះទៅកាន់ក្រុងហាណូយនោះ ខ្ញុំបានស្ដាប់ព្វជាលើកដំបូងនូវសម្ដីរបស់អ្នកការទូតវៀតណាមម្នាក់ដែលរៀបរាប់បញ្ជាក់ពីការឈ្លានពានយ៉ាងឃោរឃៅប្រឆាំងនឹងវៀតណាមដោយខ្មែរក្រហមកាលពីប៉ុន្មានខែថ្មីៗនេះ ។ ដូច្នេះខ្ញុំត្រូវប្រញាប់ស្ដាប់ការបកស្រាយរបស់ខ្មែរក្រហមម្ដង ។ អ្នកការទូតជនជាតិ ម៉ិចស៊ិកម្នាក់ដែលជិតស្និទ្ធនឹងខ្មែរក្រហមបានរៀបចំឲ្យខ្ញុំជួបជាមួយ អ៊ិន ស៊ីវុធ ជាទីប្រឹក្សានយោបាយប្រចាំស្ថានទូតកម្ពុជាប្រជាធិបតេយ្យ ។ ពីចម្ងាយគេមើលឃើញ

ទង់ជាតិពណ៌ក្រហមឈាមរបស់ស្ថានទូតបក់រវិចៗតាមជំនោរខ្យល់នៅលើភូមិគ្រឹះមួយដែលមានរចនាប័ទ្មបែបអាណានិគម ។ បង្អួចទាំងអស់នៃគ្រឹះស្ថាននេះសុទ្ធតែបិទជិតស្កុង ។ ខាងក្រៅនិងក្នុងបរិវេណនោះគេពុំឃើញមានសកម្មភាពណាមួយឡើយ លើកលែងតែប៉ូលិសវៀតណាមម្នាក់ដែលឈរយាមនៅមាត់ច្រកទ្វារចូល ស្លៀកពាក់ឯកសណ្ឋានពណ៌អាចម៍សេះ និងពាក់មួករបៀបមួកអាណានិគមប៉ុណ្ណោះ ។ គាត់ស្ទើរតែមិនយកចិត្តទុកដាក់នឹងខ្ញុំឡើយ ពេលដែលខ្ញុំចុះពីលើកង់ដើរទៅរកទ្វារដែកស្ថានទូត ។ ការងាររបស់គាត់ដូចគ្នានឹងការងាររបស់ឆ្មាំដែលយាមការពារនៅមុខស្ថានទូតបរទេសឯទៀតៗនៅក្រុងហាណូយដែរ គឺឃាត់ឃាំងមិនឲ្យប្រជាជនវៀតណាម ចូលទៅជិតទីនោះទេ ។ ថ្វីបើកង់ខ្ញុំមិនស័ក្តិសមនឹងការយកចិត្តទុកដាក់របស់គាត់ក៏ដោយ ក៏ខ្ញុំជាជន បរទេសម្នាក់យ៉ាងពិតប្រាកដ ។

ខ្ញុំចុចកណ្តឹងឈរចាំមួយសន្ទុះ បន្តិចក្រោយមក ទ្វារស្ថានទូតបានត្រូវបើកឡើងយ៉ាងប្រុងប្រយ័ត្ន ដោយបង្ហើបតែពីរឬបីសង់ទីម៉ែត្រប៉ុណ្ណោះ ។ តាមប្រឡោះបង្ហើប ភ្នែកមួយគូសម្លក់សម្លឹងខ្ញុំទំនងជាចង់សួរ រួចសំណួរមួយក្នុងសំឡេងថប់ៗបានបន្លឺថា ៖ «លោក ចាន់ដា មែនទេ?» ។ ទ្វារបើកចំហឡើងយ៉ាងរហ័សល្មមឲ្យខ្ញុំចូលទៅក្នុងរួចហើយបានបិទពីក្រោយខ្នងខ្ញុំវិញយ៉ាងរហ័ស ។ នៅពេលដែលភ្នែករបស់ខ្ញុំទម្លាប់បាននឹងពន្លឺដ៏ខ្លាំងនៅទ្វារចូល ខ្ញុំអាចមើលស្គាល់ អ៊ិន ស៊ីវ៉ុធ យ៉ាងច្បាស់ ។ នៅខាងក្នុងស្ថានទូតមានសភាពហាក់ដូចជាយប់ទៅហើយ ។ ចង្កៀងមួយដែលព្យួរនៅពិតានបានជះពន្លឺដារផ្លង់មួយក្នុងការិយាល័យធ្វើការដែលមានសភាពស្រទំដាប់ ។ បង្អួចទាំងអស់ត្រូវបិទយ៉ាងជិត ហើយវាំងននបង្អួចក៏ទាញបិទជិតដែរ ។ ស៊ីវ៉ុធ ជាមនុស្សមាឌតូច ស្គម អាយុប្រហែលជាង៤០ឆ្នាំ បានសើចញញឹមទាំងមួហ្មងក្នុងចិត្ត ។ គាត់បានពន្យល់ខ្ញុំជាភាសាបារាំងឥតស្ទាក់ស្ទើរថា ៖ «អ្វីៗដែលលោកឃើញនេះ គឺជាការចាំបាច់ដើម្បីបញ្ចៀសវៀតណាមកុំឲ្យយកការណ៍ពីយើងបាន» ។ ស៊ីវ៉ុធ និយាយពីខ្មែរក្រហមតិចតួចណាស់ ។ គាត់មិនដែលចូលព្រៃម៉ាគីតស៊ូម្តងណាសោះឡើយ ។ គាត់បានក្លាយទៅជាជនកុម្មុយនីស្តហើយចូលរួមជាមួយខ្មែរក្រហមតាំងពីសម័យ ដែលគាត់រៀនសូត្រនៅទីក្រុងប៉ារីសម៉្លេះ ។ ក្នុងរយៈពេលនៃការស្នាក់អាស្រ័យដ៏យូររបស់គាត់នៅក្រុងប៉ារីស គាត់បានដឹងរឿងរ៉ាវយ៉ាងច្រើនស្តីពីក្រុមសេ.អ៊ី.អា និងមធ្យោបាយផ្សេងៗដែលក្រុមនេះមានសម្រាប់ប្រើប្រាស់ផង ។ គាត់យល់ឃើញថា ពួកភ្នាក់ងារស៊ើបការណ៍អាចចាប់ការសន្ទនាគ្នាពីចម្ងាយបានដោយប្រើប្រពន្ធ័រលកសញ្ញាមួយដែលឆ្លុះត្រឡប់ទៅវិញតាមកញ្ចក់បង្អួច ។ តាមមតិគាត់ថា ៖ «ពួកបិសាច»វៀតណាមទាំងនេះពិតជាបង្កើតគ្រឿងតូចៗប្រភេទដូចគ្នានោះ ដើម្បីឈ្លបយកការណ៍ពីស្ថានទូតកម្ពុជា ដោយប្រើមធ្យោបាយអេឡិចត្រូនិចនេះ ។ ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅតរបៀប ម៉ៅ, អ៊ិន ស៊ីវ៉ុធ អង្គុយ ត្រង់ភ្លឹងលើកៅអីពូកធំមួយ ដោយនិយាយខ្សឹបៗប្រាប់ខ្ញុំពីរបៀបដែលវៀតណាម «ក្បត់» នឹងកម្ពុជាបែបណាខ្លះ ។ «នៅឆ្នាំ១៩៧៣ ពេលដែលវៀតណាមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសជាមួយសហរដ្ឋអាមេរិក វៀតណាមបានសាកល្បងបង្ខំឲ្យយើងចរចាជាមួយ លន់ នល់ ។ ទីប្រឹក្សា

នយោបាយរូបនេះបានរំពុកក្នុងស្នាមញញឹមរបៀបឈឺចាប់មួយថា ៖ តម្លៃដែលគេត្រូវបង់ឲ្យយើងចំពោះការធ្វើមិនដឹងមិនឮពីការឲ្យយោបល់នេះ គឺការសម្របសម្រួលមួយរវាងវៀតណាមនិងពួកអាមេរិកាំងនេះឯង ។ ហ្វូងយន្តហោះបេ-៥២ ដែលធ្លាប់ទម្លាក់គ្រាប់បែកនៅវៀតណាម បានត្រូវបញ្ជូនឲ្យមកទម្លាក់គ្រាប់បែកនៅកម្ពុជាទាំងអស់ក្នុងរយៈពេលប្រាំខែកន្លះ» ។

មុននឹងត្រូវតែងតាំងឲ្យមកកាន់ក្រុងហាណូយ ស៊ីវ៉ុធ ធ្លាប់បានធ្វើការនៅស្ថានទូតនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំក្រុងប៉េកាំងអស់ជាច្រើនឆ្នាំមកហើយ ។ ចាប់តាំងពីជ័យជម្នះរបស់ខ្មែរក្រហមគាត់ពុំដែលមានឱកាសត្រឡប់មកកម្ពុជាដើម្បីរស់នៅក្បែរកូននិងប្រពន្ធរបស់គាត់ឡើយ ។ គាត់បានសារភាពប្រាប់ខ្ញុំថា មួយឆ្នាំកន្លះមកហើយដែលគាត់ពុំដែលបានទទួលដំណឹងបន្តិចណាសោះពីគ្រួសាររបស់គាត់ ។ គាត់និយាយដូចទើសទាល់ក្នុងចិត្តប្រាប់ខ្ញុំទៀតថា ៖ គាត់បានដឹងពីព្រឹត្តិការណ៍នានានៅកម្ពុជាគឺ ដោយសារតែស្តាប់វិទ្យុភ្នំពេញប៉ុណ្ណោះ ។ ប៉ុន្តែ ភាពមិនដឹងពីហេតុការណ៍ផ្សេងៗរបស់គាត់បានទូទាត់មកវិញយ៉ាងទូលំទូលាយ ដោយសេចក្តីទុកចិត្តប្រហែលគ្មានព្រំដែនចំពោះគាត់ ដែលមាននៅក្នុងការតម្រង់ទិសបដិវត្តន៍ដែលប្រកាន់យកដោយប្រទេសជាតិគាត់ ។ ដោយបណ្តេញប្រជាជនឲ្យចេញអស់ពីទីក្រុងនានា និងបញ្ជូនមនុស្សទាំងអស់ឲ្យទៅធ្វើស្រែ អង្គការបានប្រកាន់យកស្ថានភាពនយោបាយលើកំណាត់ផ្លូវដ៏លំបាក ប៉ុន្តែស័ក្តិសិទ្ធិគឺនយោបាយ“ឯករាជ្យម្ចាស់ការ” ។ ជាមួយការញញឹមមួយរបៀបពេបជ្រាយ គាត់បានបន្ថែមថា ៖ “វៀតណាមលែងអាចយកយើងដាក់ឲ្យស្ថិតនៅក្រោមអំណាចគេទៀតហើយ” ។ ប្រទេសកម្ពុជាពុំមែនប្រទេសឡាវទេ ។ គាត់ជឿជាក់ថា សន្ធិសញ្ញាមិត្តភាពឡាវ-វៀតណាមដែលចុះហត្ថលេខានៅខែកក្កដា ឆ្នាំ១៩៧៦ បានរួមបន្តជាដំណាក់កាលដំបូងក្នុងការធ្វើអាណានិគមទៅលើប្រទេសឡាវ ។ តើលោកចង់ឃើញអ្វីដែលកើតឡើងកន្លងមកហើយទេ? ពេលនោះគាត់ចាប់យកក្រដាសកាសែតឡាវមួយសន្លឹកដែលស្ថិតនៅលើតុដាក់អាហារមួយ ។ “ភ័ស្តុតាង” គឺរូបគំនូរមួយដែលបង្ហាញឲ្យឃើញប្រជាកសិករឡាវកំពុងស្ទូងស្រូវ ។ ស៊ីវ៉ុធ បានអះអាងដោយចង្អុលមនុស្សម្នាក់នៅលើរូបថតដែលពាក់មួកដូន របៀបកសិករវៀតណាមថា “វៀតណាមបានកាន់កាប់ស្រែរបស់កសិករឡាវតាំងពីពេលនេះទៅហើយ” ។ តាមគាត់យល់ គោលបំណងផ្សេងៗរបស់វៀតណាមមកលើឥណ្ឌូចិននឹងទៅឯងៗ ។ ភ័ស្តុតាងគឺមួកដូនតែមួយគត់ដែលគាត់រកឃើញក្នុងជួរកសិករឡាវ ពុំបម្រើអ្វីក្រៅតែពីបញ្ឈប់ការមិនព្រមជឿអ្វីៗទាំងអស់របស់បរទេសប៉ុណ្ណោះ ។

ភ្លាមៗនោះ ការពោលអាងនិងភ័ស្តុតាងស្តីពី“ការលោភលន់” និង“ការវៀចក្បត់”ទាំងអស់របស់ពួកវៀតណាមបានប្រែទៅជាការថ្លែងជាសាធារណៈពីការជឿជាក់របស់ខ្លួនទៅវិញ ៖ ចរិតវៀតណាមមានលក្ខណៈ“អាក្រក់ជួជាតិ”ពីកំណើត ការប្រឈមមុខច្បាស់ជាចៀសមិនផុត បើសិនប្រជាជនខ្មែរចង់ប្រយុទ្ធ ដើម្បីភាពគង់វង្សរបស់ខ្លួន ។ ការពិពណ៌នាតែចំណុចសំខាន់ៗដែល ស៊ីវ៉ុធ និយាយប្រាប់ខ្ញុំនៅពេលរសៀលនេះ បានធ្វើឲ្យ

ខ្ញុំដែលអង្គុយក្នុងការិយាល័យងងឹតស្លុបរបស់គាត់ដឹងយ៉ាងច្បាស់ប្រាកដថា ហេតុការណ៍ផ្សេងៗ បានប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ ។ ក្រោមសំបកនៃសេចក្តីគួរសមដែលភ្ញីរលោងតែក្រៅ និងពីក្រោយការនិយាយរំពងពីលទ្ធិម៉ាក្សនិយម ដែលបង្កប់ទៅដោយគំនុំប្រវត្តិសាស្ត្រមិនងាយរបេះ និងគំនិតរើសអើងជាតិសាសន៍នោះ គឺអ្វីៗនៅតែមានលក្ខណៈជាព្រលឹងខ្មែរជានិច្ច ។

## «កុំធ្វើឱ្យកំពប់ទឹកតែចៅហ្វាយ»

ចំពោះដើមកំណើតនៃបដិបក្ខភាពរើសអើងជាតិសាសន៍រវាងប្រជាជនខ្មែរនិងវៀតណាម គេបានរកឃើញហេតុការណ៍ដែលបង្កឲ្យមានបាតុភូតនេះជិតមួយពាន់ឆ្នាំមកហើយ នៅក្នុងការទាក់ទងគ្នារវាងប្រជាជនទាំងពីរ ។ មួយភាគបីចុងក្រោយនៃប្រវត្តិសាស្ត្រនេះ ត្រូវបានកត់សម្គាល់ដោយការប្រយុទ្ធគ្នារវាងចក្រភពវៀតណាមមួយ ដែលកំពុងវាតទីកដីនិងប្រទេសកម្ពុជាមួយដែលកំពុងចុះដុនដាប ។

ដំណើរឆ្ពោះមកទិសខាងត្បូងគឺជាភាគសំខាន់បំផុតនៃប្រវត្តិសាស្ត្ររបស់វៀតណាម តាំងពីពេលដែលប្រទេសនេះរំដោះខ្លួនរួចផុតពីនឹមរបស់ចិននៅសតវត្សរ៍ទី១០ ។ អ្នកឯកទេសបារាំងម្នាក់បានកត់ត្រាថា «ប្រវត្តិសាស្ត្ររបស់វៀតណាមបានរាលដាលមកលើតណ្ឌចិនបីដូចជាកម្លាំងទឹកហូរមួយ ដោយនាំមកតាមផ្លូវឆ្លងកាត់របស់វានូវប្រជាជនផ្សេងៗ ដែលកំពុងរស់នៅក្នុងតំបន់វាលកសិកម្ម ឬដែលងាយធ្វើឲ្យក្លាយទៅជាវាលស្រែបាន»[១] ។ ក្នុងដែនដីសណ្តទន្លេក្រហមជាទីកំណើតនៃប្រជាជនវៀតណាម សម្ពាធ ផ្នែកប្រជាសាស្ត្រ (ការកើនឬស្រកចុះនៃចំនួនប្រជាជន) ការរុញច្រានពីអ្នកជិតខាងចិននិងអស្ថិរភាព ផ្នែកនយោបាយ បានបណ្តាលឲ្យប្រជាជនស្វះស្វែងរកដីថ្មីៗ ដែលជាចលនាមួយប្រព្រឹត្តទៅដោយឯងៗ[២] ។ វៀតណាមបានធ្វើដំណើរចុះមកទិសខាងត្បូង ដែលត្រូវជំរុញជាអាទិ៍ដោយកម្លាំងទ័ពក៏ដូចភូមិសាស្ត្រ ៖ លាតសន្ធឹងនៅភាគខាងជើងគឺមហាយក្សចិន នៅភាគខាងលិចគឺជួរភ្នំអាណ្ណាមដែលមិនសូវអំណោយផលក្នុងការរស់នៅ ហើយនៅភាគខាងកើតគឺសមុទ្រចិនខាងត្បូង ។

ក្នុងការរុលមកមុខរបស់ខ្លួនឆ្ពោះមកភាគខាងត្បូងដែលមានរាល់តែសតវត្សរ៍ វៀតណាមមិនត្រឹមតែច្បាំងដណ្តើមយកទឹកដីប៉ុណ្ណោះទេ ពួកគេថែមទាំងយកប្រជាជនដាក់ជាចំណុះខ្លួនទៀត ។ ប្រជាជាតិដំបូងបំផុតដែលដល់នូវក្តីវិនាស គឺជនជាតិចាមដែលមានរាជាណាចក្រឈ្មោះ «ចម្ប៉ា» ជាអតីតគូប្រជែងមួយរបស់វៀត-ណាម ។ ដោយសារការធ្វើចម្បាំងផ្ទួនៗ ការភ្ជាប់ទឹកដីដោយវៀតណាម និងដំណើរផ្លាស់ប្តូរស្រុកទេសបន្តិចម្តងៗនិងដោយទៀងទាត់របស់ប្រជាជន នៅទីបំផុតប្រទេសនេះក៏ត្រូវរលុបបាត់ឈ្មោះពីផែនទីសកលលោកនៅចុងសតវត្សរ៍ទី១៧ ។ ភាគច្រើននៃជនជាតិចាមបានត្រូវសម្លាប់រង្គាល និងត្រូវបណ្តេញចេញពីទឹកដីរបស់ខ្លួន ឬត្រូវរំលាយបញ្ចូលជាតិសាសន៍ជាមួយជនជាតិវៀតណាមដែលគេបានវាយតម្លៃថា ក្នុងចំនួនប្រជាជនចាម

៣០.០០០គ្រួសារ (មានមនុស្សប្រហែលពី២៤០ទៅ៣០០.០០០នាក់) កាលពីសតវត្សរ៍ទី១១នោះ សព្វថ្ងៃនេះជនជាតិចាមមាននៅក្នុងប្រទេសវៀតណាមនៅសល់តែជាង ៦៥.០០០នាក់ប៉ុណ្ណោះ[៣] ។ ក្នុងចំណោមនោះ ជនជាតិចាមជាច្រើនពាន់នាក់ទៀតបានរត់ភៀសខ្លួនមកកម្ពុជា ដែលនៅទីបំផុត ក៏ត្រូវរបប ប៉ុល ពត សម្លាប់ស្ទើរតែអស់រលីងក្នុងឋានៈខ្លួនជាអ្នកកាន់សាសនាអ៊ីស្លាម ។

ទោះជានៅមុនចក្រភពវៀតណាមមិនទាន់លេបត្របាក់នគរចម្ប៉ាបានទាំងស្រុងក៏ដោយ ក៏និគមជនវៀតណាម បានចាប់ផ្ដើមបង្កើតភូមិករជាច្រើននៅលើទឹកដីដែលសម្បូរព្រៃឈើរបស់កម្ពុជាស្រេចទៅហើយ ក្នុងតំបន់មួយដែលបច្ចុប្បន្នគឺទីក្រុងបៀនវ៉ា និងបារាជ ។ កាលពីដើម ខ្មែរមានចក្រភពដ៏ធំល្បីងល្បើយមួយលាតសន្ធឹងពីជ្រោយម៉ាឡេស៊ីរហូតដល់ភាគកណ្ដាលប្រទេសឡាវ ប៉ុន្តែ ប្រជាជនខ្មែរដែលខ្សោះរីងរៃក្រោមការគ្រប់គ្រងមិនល្អរបស់របបរាជាធិបតេយ្យមួយដែលធ្លាក់ចុះដុនដាបតាំងពីយូរលង់ណាស់មកហើយនោះ បានស្ថិតនៅក្នុងស្ថានភាពប្រឈមមុខនឹងប្រទេសវៀតណាមមួយដែលប្រែផ្លាស់ទឹកចិត្តជាថ្មី និងសម្ដែងឲ្យឃើញចេតនាមិនល្អក្នុងការវាតទឹកដីទៀត ។ ការប្រយុទ្ធគ្នាផ្ទួនៗរវាងក្រុមបក្សផ្សេងៗក្នុងរាជវង្សខ្មែរនិងការប៉ុនប៉ងយកប្រទេសកម្ពុជាដាក់ជាចំណុះដោយប្រទេសសៀម (គឺប្រទេសថៃសព្វថ្ងៃជាប្រទេសជិតខាងនៅភាគខាងលិចដែលកាន់តែខ្លាំងជាងកម្ពុជា) បានផ្ដល់ឲ្យវៀតណាមនូវលេសផ្សេងៗ ដែលមានឡើងឯងៗសម្រាប់ការធ្វើអន្តរាគមន៍របស់គេ ។ អន្តរាគមន៍ទាំងនោះ ទោះជាមានគោលដៅសម្រាប់ជួយជ្រោមជ្រែងព្រះរាជាមួយអង្គដែលកំពុងសោយរាជ្យ ឬរៀបចំលើកក្សត្រមួយអង្គដែលមានសិទ្ធិសោយរាជ្យឲ្យឡើងគ្រងរាជ្យបល្ល័ង្កខ្មែរក៏ដោយ ក៏ត្រូវទូទាត់ទៅវិញដោយការប្រគល់ទឹកដីកម្ពុជាមួយចំណែកតូចទៅឲ្យវៀតណាមមិនដែលខានឡើយ ។ នៅសតវត្សរ៍ទី១៨ឧត្ដមសេនីយ៍វៀតណាមម្នាក់បានប្រៀបធៀបល្បិចកលលេបទឹកដីខ្មែរជាលំដាប់លំដោយនេះទៅនឹង«ការស៊ីយឺតៗនៃសត្វដង្កូវនាង»[៤] ក្រោមលេសថាជួយគាំទ្រព្រះរាជារបស់ខ្លួន ។ វៀតណាមគឺជាអ្នកល្មោភស៊ីសត្វដង្កូវនាងដូចគ្នា ។ ចន្លោះគ្នាតែមួយសតវត្សរ៍គឺនៅចន្លោះឆ្នាំ១៦៥០ និង១៧៥០ អាងទន្លេ វ៉ាមកូ និងដីសណ្ដទន្លេមេគង្គទាំងមូលរួមទាំងភូមិអ្នកនេសាទនៅព្រៃនគរ (ដែលក្រោយមកវៀតណាមហៅសៃហ្គន) ផងបានត្រូវភ្ជាប់បញ្ចូលជាទឹកដីរបស់វៀតណាមទាំងស្រុង ។

កាលបើធ្វើជាម្ចាស់ទឹកដីដ៏មានជីជាតិនៅភាគខាងត្បូងរួចហើយ ព្រះចៅអធិរាជវៀតណាមដែលពេលនោះមានរាជធានីនៅទីក្រុងវ៉េ បានគិតគូរជាបឋមពីរឿងការពារដែនដីនេះប្រឆាំងទល់នឹងពួកថៃសិន ។ ប្រទេសកម្ពុជាអាចជា«ទ្វារបើកចំហ»សម្រាប់ការចូលលុកលុយក្រុងព្រៃនគរពីសំណាក់កងទ័ពថៃ ៖ នេះជាមូលហេតុត្រឹមត្រូវមួយដែលធ្វើឲ្យប្រទេសកម្ពុជាទៅជារដ្ឋអាណាព្យាបាលមួយ ។ អធិរាជ មិញ ម៉ាង បានអះអាងនៅឆ្នាំ១៨៣១ ថា «ចាន់ឡាប់ (Chan Lap គឺប្រទេសកម្ពុជា) ជារដ្ឋទ្រនាប់របស់យើង ។ យើងមិនអាចបណ្ដោយឲ្យប្រទេសនេះស្រុតដួលឡើយ»[៥] ។

បន្ទាប់ពីបរាជ័យក្នុងការប៉ុនប៉ងភ្ជាប់ប្រទេសកម្ពុជាជារណបដោយពួកថៃនៅឆ្នាំ១៨៣៣-៣៤ វៀតណាមបានផ្តើមវាយលុកយ៉ាងគឃ្លើនក្នុងប្រតិបត្តិការមួយដែលអាចនាំទៅដល់ការរលត់រលាយប្រទេសកម្ពុជាតែម្តង បើសិនជាវៀតណាមសម្រេចជោគជ័យមែន ។ វៀតណាមបានសាងសង់បន្ទាយ ជាច្រើនកន្លែងក្នុងទូទាំងប្រទេសនិងបានរៀបចំយោធភូមិមួយ(កងទ័ពប្រចាំបន្ទាយក្នុងក្រុង) នៅភ្នំពេញផង ។ ប្រទេសកម្ពុជាឯករាជ្យបានប្រែទៅជា «រដ្ឋភាគខាងលិចដែលគេធ្វើឲ្យមានសន្តិភាពឡើងវិញ» ស្ថិតនៅក្រោមចំណុះវៀតណាម ។ មិញ ម៉ាង បានចាប់ផ្តើមអនុវត្តយុទ្ធនាការដ៏ខ្លាំងក្លាមួយដើម្បីធ្វើឲ្យជនជាតិខ្មែរ ជា «មនុស្សព្រៃគ្មានអារ្យធម៌» មានទម្លាប់រស់នៅសមរម្យក្នុងសង្គមវិញ ។ ព្រះអង្គបានបញ្ជូនសាស្ត្រាចារ្យវៀតណាមជាច្រើននាក់មកកាន់កម្ពុជាដើម្បីបង្រៀនទស្សនវិជ្ជាខុងជឺ ចំពោះមន្ត្រីជាន់ខ្ពស់ខ្មែរទាំងឡាយ ។ ព្រះអង្គក៏បានសាកល្បងកំហិតឲ្យប្រជាជនខ្មែរកាត់សក់ និងស្លៀកពាក់ជារបៀបវៀតណាម ហើយបញ្ចូលប្រពន្ធ័ពន្ធដារមួយដោយអនុលោមតាមប្រទេសវៀតណាម ព្រមទាំងបង្ខំឲ្យប្រជាកសិករដាំដំណាំផ្សេងៗដូចគ្នានឹងកសិករវៀតណាមដែរ ។ អ្នកដែលទទឹងរឹងរូសត្រូវបានផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរបំផុត ។

ការងើបបះបោរជាច្រើនបានផ្ទុះឡើងប្រឆាំងនឹងការបង្គាប់បញ្ជារបស់វៀតណាម ។ នៅឆ្នាំ១៨២០ ព្រះសង្ឃមួយអង្គព្រះនាម កៃ បានដឹកនាំការបះបោរជាលើកដំបូងមួយក្នុងចំណោមការបះបោរដំបូងៗ ប្រឆាំងនឹង «វិន័យដែកថែប» ដែលដាក់បង្ខំដោយកងទ័ពត្រួតត្រានិងប្រពន្ធ័ការងារគ្មានកម្រៃដែលគេបញ្ញត្តិឲ្យបំពេញ ។ អ្នកបះបោរបានសម្លាប់វៀតណាមដែលតាំងនៅភាគខាងកើតប្រទេសកម្ពុជាយ៉ាងរង្គាលរហូតដល់ចៅហ្វាយខេត្តវៀតណាមនៅតាមបណ្តាខេត្តភាគខាងត្បូងត្រូវតែបញ្ជូនកងទ័ពជំនួយមកជួយ ដើម្បីយកឈ្នះលើការជ្រួលជ្រើមបះបោរនេះ[៦] ។ ប៉ុន្តែគឺនៅឆ្នាំ១៨៤០ ដែលផ្ទុះឡើងនូវការបះបោរធ្ងន់ធ្ងរជាងគេបំផុត ៖ ក្រោយពីការចាប់ខ្លួនបណ្តាមន្ត្រីជាន់ខ្ពស់ខ្មែរនិងព្រះរាជាដែលគ្រងរាជ្យទៅឃុំឃាំងនៅវៀតណាម ប្រជាជនខ្មែរក៏ចាប់នឹកភ្នកបារម្ភចំពោះអត្ថិភាពនៃប្រទេសកម្ពុជាឯករាជ្យផងដែរ ។ មន្ត្រីជាន់ខ្ពស់ខ្មែរម្នាក់ឈ្មោះ ព្រហ្ម បានអះអាងនៅពេលនោះថា «យើងសប្បាយនឹងសម្លាប់វៀតណាមណាស់ យើងលែងខ្លាចពួកគេទៀតហើយ បើទុកជាពួកគេខ្លាំងពូកែក៏ដោយ» ។ គាត់បានលើកទឹកចិត្តឲ្យពួកយុទ្ធិកជនរបស់គាត់សម្លាប់ជនជាតិវៀតណាមទាំងអស់ដែលពួកគេជួបប្រទះតាមផ្លូវ «ពីភាគខាងជើងរហូតដល់ភាគខាងត្បូង» ប្រទេស ។ ក្នុងលិខិតមួយដែលផ្ញើជូនអ្នករដ្ឋការថៃ គាត់បានស្នើ «បន្តសម្លាប់រង្គាលជនជាតិវៀតណាមទៀត»[៧] នេះជាសេចក្តីប្រកាសដែលគេសន្និដ្ឋានថាជារបស់ ប៉ុល ពត អនាគតមេដឹកនាំប្រទេសកម្ពុជា ។

អនុស្សាវរីយ៍នៃការងើបបះបោរទាំងឡាយរបស់ខ្មែរនៅដើមសតវត្សរ៍ទី១៩ និងរឿងនិទានផ្សេងៗស្តីពីភាពសាហាវព្រៃផ្សៃនៃការកៀបសង្កត់របស់វៀតណាមសុទ្ធតែត្រូវចម្លងដាក់ក្នុងកាលប្បវត្តិ និងប្រពៃណីនិងទំនៀមទម្លាប់អ្នកស្រុករបស់កម្ពុជា ។ ដើម្បីបន្លាចក្មេងដែលមិនស្តាប់បង្គាប់ម្នាក់ មាតាខ្មែរទាំងឡាយច្រើនមាន

*ទម្លាប់គំរាមថា ៖ «បើឯងដើរទៅលេងឆ្ងាយៗក្នុងព្រៃ យួន (ជាពាក្យបន្ទុះបន្ទាប់របស់ខ្មែរ មានន័យប្រាកដថា មនុស្សគ្មានអារ្យធម៌) នឹងចាប់យកឯងទៅមិនខាន» ។ ព្រែកជីកវិញតេ* (Vinh Te) *ជាផ្លូវទឹកមួយប្រវែង៤០ គីឡូម៉ែត្រ ភ្ជាប់ពីឈូងសមុទ្រសៀមមកព្រែកវិញតេ ត្រូវបានជីកនៅឆ្នាំ១៨២០ ដោយសារវៀតណាមបង្ខិតបង្ខំឲ្យប្រជាជនខ្មែរបំពេញកិច្ចការនេះដោយខានមិនបាន ហើយនេះគឺជា «មុខរបួសចំហ»មួយដែលដក់ជាប់ក្នុងចិត្តគំនិតរបស់ប្រជាជនខ្មែរជានិច្ច ។ មុននិងក្រោយសម័យ ប៉ុល ពត ខ្ញុំមិនដឹងថាប៉ុន្មានដងទេដែលខ្ញុំ(អ្នកនិពន្ធ) បានស្ដាប់រឿងនិទានស្ដីពីការដាក់ទោសរបស់វៀតណាមមកលើប្រជាជនខ្មែរបីនាក់ដែលធ្វើការមិនសូវស្វាហាប់នៅការដ្ឋានជីកព្រែកនោះ ។ តាមគេអះអាងថា ជនអភ័ព្វទាំងបីត្រូវវៀតណាមជីករណ្ដៅកប់ត្រឹម-ក បន្ទាប់មកយកខ្ទះមួយដែលពេញប្រៀបទៅដោយទឹកពុះមកដាក់ពីលើក្បាលអ្នកទាំងបី នៅពេលដែលអ្នករងគ្រោះរមួលប្រកាច់ដោយការឈឺចាប់និងធ្វើឲ្យក្រឡុកទឹកចេញពីខ្ទះ វៀតណាមបានគំរាមថា «កុំធ្វើឲ្យកំពប់តែរបស់ចៅហ្វាយ» ។ ក្រោយមកប្រវត្តិរឿងនេះបានទៅជាលេសដែលទ្រទ្រង់ដល់ការឃោសនារបស់ខ្មែរក្រហមសំដៅអុជអាលឲ្យមាន«កំហឹងបដិវត្តន៍»ប្រឆាំងនឹងសត្រូវវៀតណាម*[៨] ។

*មនោសញ្ចេតនាអរិភាព និងបុរេនិច្ឆ័យរើសអើងជាតិសាសន៍ដែលខ្មែរក្រហមពង្រីកប្រឆាំងនឹងវៀតណាមនោះ គឺជាអំពើដូចគ្នាណាស់ ។ ត្រូវដោយ៉ាងជ្រៅដោយការត្រួតត្រារបស់ចិនចំនួនមួយពាន់ឆ្នាំ ប្រទេសវៀតណាមមើលឃើញខ្លួនឯងថាជា «អាណាចក្រកណ្ដាលតូច»មួយដែលព័ទ្ធជុំវិញដោយពួកអានារ្យជន ឬមនុស្សព្រៃ ។ បើទុកជាពាក្យនេះពុំមានប្រើជាផ្លូវការក៏ដោយ ក៏ជនជាតិវៀតណាមសាមញ្ញ នៅតែប្រើប្រាស់ពាក្យចិនថា ៖ កាវមៀន* (Cao Mien) *មានន័យថា មនុស្សព្រៃនៃតំបន់ភ្នំជានិច្ចដើម្បីសម្គាល់ប្រជាជនកម្ពុជា ។ សព្វថ្ងៃប្រហែលមានជនជាតិវៀតណាមតិចតួចប៉ុណ្ណោះដែលដឹងពីដើមកំណើតនៃពាក្យរបស់ចិននេះ ដោយសន្និដ្ឋានថានេះជាការហៅតាមបែបវៀតណាមនូវពាក្យថា «ខ្មែរ» ។ បណ្ដាព្រះចៅអធិរាជនៃសន្តតិវង្ស ង្វៀន ដែលសោយរាជ្យលើប្រទេសវៀតណាមរួបរួមនិងរឹងមាំមួយ តែងចាត់ទុកខ្លួនឯងជាអ្នកទទួលភារកិច្ចបំពេញបេសកកម្មដ៏ខុត្តមមួយគឺនាំយកពន្លឺអារ្យធម៌ទៅកាន់រាជាណាចក្រដែលនិយមសាសនាហិណ្ឌូនិងធ្វើឲ្យប្រទេសកម្ពុជាចុះខ្សោយ ។ ក្នុងកាយវិការមើលងាយចំពោះអសមត្ថភាពរបស់ជនជាតិខ្មែរក្នុងការគ្រាប់តាមឲ្យដូចវប្បធម៌ចិន-វៀតណាមនោះ ព្រះចៅអធិរាជមួយអង្គបានចាត់ទុកខ្មែរថា ៖ «សត្វស្វាជាប់ក្នុងលប» ឬ«បក្សីនៅក្នុងទ្រុង» ។ នៅឆ្នាំ១៨៤០ នៅពេលដែលប្រជាជនកម្ពុជាងើបបះបោរប្រឆាំងនឹងបេសកកម្មផ្ដល់អារ្យធម៌របស់ប្រទេសវៀតណាម ព្រះចៅអធិរាជ មិញ ម៉ាង បានខឹងប្រឡោតថា «យើងធ្លាប់បានជួយសង្គ្រោះពួកគេក្នុងពេលមានអាសន្ន យើងធ្លាប់បានជួយស្រង់ពួកគេចេញពីជីវិតថោកទាប (ដូចភក់ជ្រាំ) មើលចុះ! ពេលនេះពួកគេបែរជាងើបបះបោរប្រឆាំង! ។ អំពើឃោរឃៅ បានធ្វើឲ្យសក់ខ្ញុំឡើងបះសក់ប្រួង ។ គេត្រូវការកាំបិតរាប់រយសម្រាប់បិញ្ច្រាំពួកនេះជាកំណាត់ៗ និងកាត់អវៈយវៈចេញពីខ្លួន» ។ ក្នុងរឿងនិទានមួយទៀតស្ដីពីការងើបបះបោរ*

នៅឆ្នាំ១៨៤០ គឺវៀតណាមបានបណ្ដោយឲ្យផ្លាយចេញការក្ដៅក្រហាយរបស់ខ្លួននៅមុខកលល្បិចនៃ“ប្រតិបត្តិការវាយឆ្មក់យ៉ាងក្លាហាន និងលឿនរហ័ស”ដែលកងទ័ពព្រៃខ្មែរក្រហមចូលចិត្តប្រើ ហើយកំពុងរត់គេច“ដូចសត្វកណ្ដុរប្រែង និងកណ្ដុរស្អែះ”ពីមុខកងទ័ពរៀបរយរបស់វៀតណាម[៩] ។

សម្រាប់ប្រជាជនខ្មែរមួយចំនួនធំយល់ថា ទោះជាប្រជាជនវៀតណាមនៅតែជាពូជសាសន៍មួយ មិនទៀងត្រង់ជា“អ្នកលេបត្របាក់ទឹកដីខ្មែរ”ក៏ដោយ ក៏បច្ចុប្បន្នវៀតណាមហាក់ដូចជាមិនសម្ដែងនូវគំនុំព្យាបាទចំពោះខ្មែរដែរ ។ ពិតណាស់ថា គឺប្រជាជនខ្មែរដែលរងការឈឺចាប់ធ្ងន់ធ្ងរជាងគេក្នុងឋានៈជាប្រជាជាតិមួយដែលមានប្រវត្តិទំនាក់ទំនងដ៏យូរលង់រវាងប្រជាជនទាំងពីរ ។ វៀតណាមដែលរស់នៅកម្ពុជាក៏ស្គាល់នូវកាលៈទេសៈលំបាកវេទនាដូចគ្នាដែរ ប៉ុន្តែបញ្ហានេះទំនងជាមិនប៉ះពាល់ដល់មនោសញ្ចេតនា របស់ប្រជាជនវៀតណាមជាទូទៅទេ។ ផ្ទុយទៅវិញ ក្នុងការសំណេះសំណាលរបស់មនុស្សធ្វើការរដ្ឋ ឬមនុស្សសាមញ្ញ មនោសញ្ចេតនាប្រសើរលើសគេរបស់វៀតណាម ជាពិសេសទាក់ទងទៅនឹងការអប់រំនយោបាយ ការរៀបចំអង្គការនិងសមត្ថភាពបញ្ជាទ័ពរបស់វៀតណាមបានផុសចេញមកភ្លាមៗ ។ នៅពេលដែលពួកគេមានអារម្មណ៍សប្បុរសវៀតណាមបានចាត់ទុកដោយរីករាយថា ខ្មែរជាក្មេងធំដែលពិបាកប្រដៅ ។ ប៉ុន្តែ ជាញឹកញយវៀតណាមពិបាកនឹងលាក់បាំងការខ្វះអំណត់របស់ខ្លួនចំពោះខ្មែរ ដែលមិនចេះនៅស្ងៀមនិងដែលលម្អៀងទៅរកការបះបោរណាស់ដែលនេះហើយគឺជាប្រភពនៃបញ្ហាផ្សេងៗដែលកើតមានមិនចេះចប់ ។

សតិចងចាំរបស់ប្រជាជននិង“ការខឹងស្អប់គ្នាជាប្រពៃណី” ដែលក្លាយទៅជាទម្លាប់ទៅហើយនោះ សុទ្ធតែជាសញ្ញាណដែលមិនអាចសម្គាល់ឃើញនិងអរូបី ដែលគេពិបាកនឹងធ្វើឲ្យទៅជាឧបករណ៍វិទ្យាសាស្ត្រក្នុងការវិភាគមួយខាងសង្គមសាស្ត្រឬប្រវត្តិសាស្ត្រណាស់ ។ ប៉ុន្តែ គំនិតមិនសមហេតុផលទាំងអស់មានលក្ខណៈច្បាស់លាស់ណាស់សម្រាប់អ្នកណាម្នាក់ ដែលបានស្នាក់អាស្រ័យមួយរយៈនៅប្រទេសកម្ពុជា ។ ក្នុងអំឡុងរជ្ជកាលរបស់ព្រះអង្គ សម្ដេច សីហនុ បានថែរក្សាសតិចងចាំរបស់ប្រជាជននេះឲ្យនៅស្ថិតស្ថេរយូរអង្វែងដោយទ្រង់ច្រើនមានបន្ទូលឡើងវិញអំពីប្រវត្តិសាស្ត្រនៃការរំលោភរបស់វៀតណាមមកលើទឹកដីកម្ពុជាជារឿយៗ ។ មួយផ្នែកពីព្រោះប្រជាជនខ្មែរបានត្រូវញុាំងឲ្យជឿពីចរិតជា “អ្នកវាតទឹកដី ”ពីកំណើតរបស់វៀតណាមមួយផ្នែកទៀតអ្នកប្រើនយោបាយស្របតាមកាលៈទេសៈ គឺពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានតាំងចិត្តបកស្រាយជម្លោះរបស់ខ្លួនជាមួយប្រទេសវៀតណាម ដោយទឡ្ហីករណ៍ផ្សេងៗខាងជាតិសាសន៍ គឺពុំមែនខាងវប្បធម៌និងសង្គមទេ ។ “សៀវភៅខ្មៅ”ដែលបោះពុម្ពផ្សាយដោយរបប ប៉ុល ពត នៅខែកញ្ញា ឆ្នាំ១៩៧៨ គឺច្រើនខែក្រោយដែល អ៊ិន ស៊ីវុធ និយាយដោយឥតគិតប្រាប់ខ្ញុំតាមការរៀបរាប់ដ៏វែងអន្លាយគួរឲ្យធុញនូវការតិះដៀលដ៏ជូរចត់របស់គាត់ ដែលមានបញ្ចូលភាពខុសគ្នាបន្តិចបន្តួចនៃរឿងរ៉ាវតែមួយ ៖ “អំពើឈ្លានពាន និងការក្ដាប់ទឹកដីដែលប្រព្រឹត្តឡើងដោយវៀតណាមក្នុងអតីតកាល ក៏ដូចបច្ចុប្បន្នកាលបានបង្ហាញឲ្យឃើញយ៉ាង

ច្បាស់និងជានិច្ចកាលនូវមុខមាត់ពិតប្រាកដរបស់ជនជាតិវៀតណាម និងប្រទេសវៀតណាមថា ៖ ជាអ្នកឈ្លានពាន អ្នកវាតទី ដែលស្រេកឃ្លានចង់បានទឹកដីបណ្ដាប្រទេសដទៃយ៉ាងខ្លាំង» ។ គេបានអានសៀវភៅនេះដោយសង្ខេបថា ទោះជានៅក្រោមរបបសក្តិភូមិ របបអាណានិគម ឬក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តក៏ដោយ ក៏វៀតណាមនៅតែដូចពីមុនដដែល ។ ក្រោយមកក្រុម ប៉ុល ពត បានឈានរហូតដល់ប្រកាសថា បក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០ «ដើម្បីតទល់នឹងវៀតណាម»ជាទស្សនវិស័យដែលនឹងធ្វើឲ្យបណ្ដាស្ថាបនិកបង្កើតលទ្ធិកុម្មុយនីស្តស្រឡាំងកាំង[១០] ។

ការតាំងឲ្យមានអាណាព្យាបាលភាពមួយរបស់បារាំងនៅឆ្នាំ១៨៦៣ បានបញ្ចៀសមិនឲ្យមានការបែងចែកទឹកដីកម្ពុជាជាថ្មីរវាងប្រទេសវៀតណាមនិងថៃ ។ ក៏ប៉ុន្តែ ហេតុការណ៍ដែលដែនដីកូសាំងស៊ីនដិតខាង -ភាគខាងត្បូងវៀតណាមបច្ចុប្បន្ន- ក្លាយទៅជាអាណានិគមមួយរបស់បារាំងទាំងស្រុងនោះ បានបំផ្លាញផលប្រយោជន៍របស់ប្រទេសកម្ពុជាផងដែរ នៅពេលដែលមានការកំណត់ព្រំដែនរវាងប្រទេសទាំងពីរដោយពួកបារាំង ។ ការគូសបន្ទាត់ព្រំដែនបានត្រូវរៀបចំឡើងដោយពួកអាជ្ញាធរអាណានិគមរបស់កូសាំងស៊ីន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យផ្នែកភូមិសាស្ត្រ និងភាពងាយស្រួលក្នុងការគ្រប់គ្រងផ្នែករដ្ឋបាលជាជាងផ្អែកលើប្រវត្តិសាស្ត្រ ភាសា ឬពូជសាសន៍ ។ តាំងពីការគូសបន្ទាត់ព្រំដែនជាបន្តបន្ទាប់ដែលយកចិត្តទុកដាក់ដោយពួកបារាំង តំបន់ប៉ាក់សេ (សព្វថ្ងៃស្ថិតនៅភាគខាងត្បូងប្រទេសឡាវ) ខេត្តដាឡាក់ និងតំបន់នានាមានសុងបេ, តាយនិញ, ហ្វូដូហា និងហាទៀង (សព្វថ្ងៃជារបស់វៀតណាម) បានត្រូវប្របិចប្របោចបន្តិចម្ដងៗយកពីប្រទេសកម្ពុជាអស់ ។ ក្នុងនិក្ខេបបទថ្នាក់បណ្ឌិតមួយដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៦ សារិន ឆាក រដ្ឋមន្ត្រីការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាឆ្នាំ១៩៧០ បានលាតត្រដាងយ៉ាងវែងពីការកាត់ទឹកដីទាំងនេះ ហើយបានទទូចឲ្យវៀតណាមបើកធ្វើការចរចាគ្នាក្នុងគោលដៅគូសបន្ទាត់ព្រំដែនមួយដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ជាងមុន[១១] ។

មេដឹកនាំទាំងអស់របស់ប្រទេសកម្ពុជាតាំងពីស្ដេច អង្គឌួង (ឆ្នាំ១៨៤៨-១៨៦០) រហូតមកដល់ ប៉ុល ពត មិនដែលឈប់តវ៉ាប្រឆាំងនឹងការកាត់ទឹកដីទាំងនេះឡើយ ។ ក្នុងលិខិតដ៏គួរឲ្យរំភើបចិត្តមួយនៅឆ្នាំ១៨៥៦ ព្រះមហាក្សត្រអង្គឌួងបានជំរុញព្រះចៅអធិរាជ ណាប៉ូឡេអុងទី៣ កុំឲ្យទទួលយកដីខ្មែរដែលពួកវៀតណាមបានភ្ជាប់ធ្វើជាទឹកដីរបស់ខ្លួនកាលពីពេលថ្មីៗនេះ ដោយព្រះអង្គបានបញ្ចេញព្រះរាជយោបល់ថា «ដោយចៃដន្យបើសិន ជាវៀតណាមប្រគល់ទឹកដីថ្វាយព្រះចៅអធិរាជវិញ» ។ ក្នុងឆ្នាំ១៩៤៩ នៅពេលកូសាំងស៊ីនជាអាណានិគមបារាំង ត្រូវបញ្ចូលទៅក្នុងរដ្ឋបង្រួបបង្រួម(ប៉ុន្តែពុំទាន់មានអធិបតេយ្យទេ)វៀតណាមនោះ ក្រុងភ្នំពេញបាន ចេញផ្សាយនូវការប្រឆាំងតវ៉ាជាផ្លូវការមួយ ។ ទោះជាបន្ទាប់ពីឥណ្ឌូចិនទទួលបានឯករាជ្យនៅឆ្នាំ១៩៥៤ ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែបន្តទាមទារឲ្យវៀតណាមខាងត្បូងប្រគល់មកឲ្យវិញនូវទឹកដីកម្ពុជាក្រោមដែនដីសណ្ដទន្លេមេគង្គ(ពីដើមជាកម្ពុជាភាគខាងក្រោម) និងកោះមួយចំនួនតាមឆ្នេរសមុទ្រជាពិសេស

កោះត្រល់ដែរ ។ ដោយព្រួយបារម្ភពីស្ថានភាពរបស់ជនជាតិខ្មែរ ក្រោមនៅប្រទេសវៀតណាមជាប់ជានិច្ចនោះ សម្តេច សីហនុ បានធ្វើការប្រឆាំងតវ៉ាពីរឿងនេះតាមផ្លូវការជាច្រើនលើក[១២] ។

ការហូរចូលនៃជនជាតិវៀតណាមមកក្នុងប្រទេសកម្ពុជាចេះតែមានជាបន្តក្រោមការគ្រប់គ្រងរបស់អឺរ៉ុប ដែលមានការបន្ទូរបន្ថយច្រើន ។ ពួកបារាំងដែលមើលឃើញថា វៀតណាមជាអ្នកខស្សព្វាហ៍ និងស៊ិតស្វាញក្នុងការងារជាងខ្មែរបានយកពួកនោះមកប្រើប្រាស់ ដើម្បីជួយធ្វើឲ្យកម្ពុជារីកលូតលាស់ ។ នៅឆ្នាំ១៩២១ ជនជាតិវៀតណាមមានជិត៧ភាគរយនៃចំនួនប្រជាជនកម្ពុជាទាំងអស់ ។ មនុស្សទុក៏តជាច្រើនដែលមកពីវៀតណាមខាងជើង បានចាកចោលមាតុប្រទេសមកធ្វើការក្រោមកិច្ចសន្យាតាមចម្ការកៅស៊ូនានារបស់បារាំងនៅកម្ពុជា ជាការងារដែលមានខ្មែរតិចតួចប៉ុណ្ណោះពេញចិត្តធ្វើ ។ ម្យ៉ាងទៀតកសិករ និងអ្នកនេសាទជាច្រើនបានចាកចេញពីដែនដីកូសាំងស៊ីន ដើម្បីមកប្រដែងយកពីខ្មែរនូវដីកសិកម្ម និងតំបន់នេសាទរបស់ពួកគេថែមទៀត ។ អ្នកកាន់សាសនាកាតូលិកវៀតណាម ដែលជួយជំរុញដោយពួកសាសនទូតបារាំងពុំមែនជាពួកចុងក្រោយ ដែលមកដណ្តើមយកដីធ្លីរបស់កម្ពុជាទេ ដែលការណ៍នេះបានធ្វើឲ្យគំនុំកើនឡើងកាន់តែធំ[១៣] ។

អស្មិមានះ (សេចក្តីប្រកាន់ចិត្តរឹងត្អឹងថាអញថាគេ) របស់ខ្មែរបានរងការប៉ះពាល់យ៉ាងខ្លាំង ជាពិសេសចំពោះការដែលរដ្ឋបាលបារាំងជ្រើសរើសអ្នកធ្វើការ ភាគច្រើនតែក្នុងចំណោមវៀតណាមប៉ុណ្ណោះ ។ អ្នកបះបោរប្រឆាំងបារាំងនៅឆ្នាំ១៨៨៥-៨៦ បានបន្ទោសប្រទេសបារាំងដែលប្រើប្រាស់ពួកវៀតណាមក្នុងការបំផ្លិចបំផ្លាញសង្គមជាតិ និងវប្បធម៌របស់កម្ពុជា ។ ក៏ប៉ុន្តែសហគមន៍ទាំងពីរនេះពុំមែនរស់នៅជាខ្មាំងសត្រូវនឹងគ្នាជាប់ជាប្រចាំនោះទេ ។ ក្នុងឱកាសនៃការបះបោរប្រឆាំងអាណានិគមមានពួកវៀតណាមយ៉ាងច្រើនបានវាយប្រយុទ្ធរួមជាមួយខ្មែរដែរ ។ បើទោះជាមានភាពតានតឹងនិងការមិនចូលចិត្តគ្នាទៅវិញទៅមកក៏ដោយ ក៏ប្រជាជនកម្ពុជានិងវៀតណាមបានស្គាល់នូវភាពក្សេមក្សាន្តជាអ្នកជិតខាងល្អក្នុងរយៈពេលយ៉ាងយូរមួយ ប៉ុន្តែគ្រាន់តែមានវិបត្តិមួយឬព្រឹត្តិការណ៍ខាងក្រៅមួយប៉ុណ្ណោះ គឺតែងតែមានលេចចេញគំនុំចាស់ភ្លាម ។

នៅប្រទេសកម្ពុជា មេរោគប្រកាន់ជាតិសាសន៍បានធ្វើឲ្យវិនាសដល់ចលនាកុម្មុយនីស្តផ្ទាល់របស់ខ្លួន ដែលតាមការអួតរបស់គេថាជាចលនាអន្តរជាតិនិយម ។ លក្ខណៈសម្បត្តិផ្សេងៗក្នុងការបង្កើតនិងការអភិវឌ្ឍន៍របស់ខ្លួន ដែលមានក្រោយមកទៀតបានជួយបំប៉នឲ្យប្រជាជនខ្មែរមានគំនិតជាតិនិយមចង្អៀតចង្អល់ (Chauvinisme) និងមនោសញ្ចេតនាប្រឆាំងវៀតណាមដក់ជាប់ក្នុងចិត្តជានិច្ច ។

ពួកអន្តោប្រវេសន៍វៀតណាម បានរួមបង្កជាស្នូលដ៏រឹងមាំនៃក្រុមតស៊ូខាងនយោបាយជាច្រើនរបស់បក្សកុម្មុយនីស្តឥណ្ឌូចិននៅប្រទេសឡាវក៏ដូចនៅកម្ពុជា ។ នៅឆ្នាំ១៩៥០ ចលនាខ្មែរឥស្សរៈ(ខ្មែរសេរី) គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តឥណ្ឌូចិននៅឡើយ ។ ហូ ជីមិញ ដឹងច្បាស់ណាស់ពីគំនុំប្រឆាំងវៀតណាមដែលដក់ជាប់ក្នុងចិត្តរបស់ពួកឡាវនិងកម្ពុជា ។ ហេតុនេះហើយបានជានៅឆ្នាំ១៩៥១ គាត់បាន

សម្រេចចិត្តបំបែកបក្សកុម្មុយនីស្តឥណ្ឌូចិនទៅជាបីបក្សដាច់ដោយឡែកពីគ្នា ។ ការបង្ហាញឲ្យឃើញភ័ស្តុតាងក្នុងការបំបែកនេះ គឺមាននៅក្នុងឯកសារផ្ទៃក្នុងមួយរបស់បក្សពលករវៀតណាម ដែលជាអ្នកទទួលតំណែងបន្តពីបក្សកុម្មុយនីស្តឥណ្ឌូចិន ៖ “សមាសភាពខ្លះនៃអ្នកជាតិនិយមឡាវនិងកម្ពុជាអាចនៅមន្ទិលសង្ស័យថា ប្រទេសវៀតណាមមានបំណងដាក់បង្ខំឲ្យអនុវត្តច្បាប់របស់ខ្លួននៅប្រទេសឡាវនិងកម្ពុជា ។ បនចក្រពត្តិនិងពួកអាយ៉ងរបស់វាអាចឆ្លៀតឱកាសនៅពេលនោះទាញយកប្រយោជន៍ពីរឿងនេះ ដើម្បីបើកយុទ្ធនាការប្រឆាំងមួយសំដៅបំបែកបំបាក់ប្រទេសវៀតណាម កម្ពុជា និងឡាវ ដោយសាបព្រោះការសង្ស័យនៅក្នុងចំណោមប្រជាជនកម្ពុជា និងប្រជាជនឡាវ»[១៤] ។

ការបែកបាក់របស់បក្សកុម្មុយនីស្តឥណ្ឌូចិនទៅជាបីបក្សសម្រាប់ប្រទេសនីមួយៗ បានធ្វើឲ្យអ្នកជាតិនិយម ក្នុងប្រទេសទាំងនោះធូរស្រាលក្នុងចិត្ត ហើយបានប្រឆាំងតទល់នឹងការប៉ុនប៉ង “បំបែកបំបាក់ដើម្បីត្រួតត្រា»របស់បារាំងវិញ ។ ប៉ុន្តែការចាត់ចែងដឹកនាំចលនាកុម្មុយនីស្តរបស់ឥណ្ឌូចិននៅតែស្ថិតក្នុងកណ្ដាប់ដៃវៀតណាមជានិច្ច ។ នៅខែមិថុនា ឆ្នាំ១៩៥២ ប្រជាជនវៀតណាមនិងចិនដែលស្នាក់នៅប្រទេសកម្ពុជាបានទទួលលិខិតសម្ងាត់មួយចេញមកពីបក្សកុម្មុយនីស្តវៀតណាម ដោយដាក់កំហិតឲ្យពួកគេចូលជាសមាជិកបក្សពលករវៀតណាមជាជាងចូលបក្សប្រជាជនបដិវត្តន៍ខ្មែរដែលពុំមែនជា “បក្សឈានមុខរបស់វណ្ណៈកម្មករ ប៉ុន្តែគឺជាបក្សឈានមុខរបស់ប្រជាជាតិមួយដែលប្រមូលផ្ដុំគ្រប់សមាសភាពអ្នកស្នេហាជាតិ និងសមាសភាពចម្រើននិយម ដោយមិនរើសមុខរបស់ប្រជាជនខ្មែរ»[១៥] ។ ទោះជាយ៉ាងណាក៏ដោយគណៈកម្មាធិការប្រតិបត្តិបណ្ដោះអាសន្ននៃបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលបង្កើតឡើងនៅខែកញ្ញា ឆ្នាំ១៩៥១ នោះ គឺមានសមាសភាពវៀតណាមច្រើនជាងខ្មែរ ៖ ១.៨០០នាក់ជាវៀតណាមកើតនៅប្រទេសកម្ពុជាទល់នឹងខ្មែរ១៥០នាក់ ។

## រួមជាមួយ សីហនុ ប្រឆាំងនឹងចក្រពត្តិនិយម

នៅខែមករា ឆ្នាំ១៩៥៣ សាឡុត ស បានត្រឡប់មកក្រុងភ្នំពេញវិញបន្ទាប់ពីរស់នៅទីក្រុងប៉ារីសអស់រយៈពេលបីឆ្នាំ ។ អ្នកបដិវត្តន៍អាយុ២៥ឆ្នាំនេះ ក្រោយមកបានក្លាយទៅជាមនុស្សល្បីល្បាញបំផុត ក្រោមរហស្សនាមថា “ប៉ុល ពត” ។ លិខិតសុំចូលបក្សរបស់គាត់ចំពោះបក្សប្រជាជនបដិវត្តខ្មែរដ៏ថ្មីសន្លាង ត្រូវបានពិនិត្យពិច័យយ៉ាងហ្មត់ចត់ដោយកម្មាភិបាលបក្សរបស់វៀតណាមម្នាក់ឈ្មោះ ផាំ វ៉ាន់បា ជាបក្ខជនដើងចាស់របស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលត្រូវតែងតាំងឲ្យធ្វើការនៅក្រុងភ្នំពេញជាកន្លែងដែលគាត់បំពេញសកម្មភាពយ៉ាងច្រើនរួមទាំងសកម្មភាពជាអ្នកកាសែតផង ។ ជាអ្នកបាត់ខ្លួននៅក្នុងសតវត្សរ៍៥០ គាត់បានលេចមុខឡើងវិញក្នុងឋានៈជាអ្នកការទូតម្នាក់របស់វៀតកុង ។ បន្ទាប់ពីបានបម្រើក្នុងឋានៈជាប្រធានស្ថានបេសកកម្មនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នប្រចាំទីក្រុងប៉ារីសរហូតដល់ឆ្នាំ១៩៧៥ បា បានក្លាយទៅជាឯកអគ្គរដ្ឋទូត

ដំបូងរបស់វៀតណាមប្រចាំកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ។

ប្រាំពីរឆ្នាំក្រោយពីការជួបគ្នាលើកដំបូងរបស់ខ្ញុំជាមួយគាត់ ក្នុងការិយាល័យនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ននៅទីក្រុងប៉ារីស ខ្ញុំបានជួបគាត់ជាថ្មីម្ដងទៀតនៅទីក្រុងហូជីមិញកាលពីខែមករា ឆ្នាំ១៩៨១ ។ នៅពេលនោះ ដោយត្រេកអរចំពោះការមកដល់ដោយមិនដឹងខ្លួនរបស់ខ្ញុំ បា បានរៀបរាប់នូវអ្វីដែលគាត់ពុំអាចនិយាយប្រាប់ខ្ញុំ មុនពេលពុំទាន់មានការកាត់ផ្ដាច់ចំណងមិត្តភាពជាមួយខ្មែរក្រហមថា “កាលណោះ ខ្ញុំជាលេខាការិយាល័យចាត់ចែង (លួចលាក់) របស់បក្សកុម្មុយនីស្តឥណ្ឌូចិននៅក្រុងភ្នំពេញ ។ ប៉ុល ពត បានចាប់ទាក់ទងជាមួយខ្ញុំដើម្បីទទូចសុំចូលជាសមាជិកបក្ស ។ គាត់មានប័ណ្ណសមាជិកបក្សកុម្មុយនីស្តបារាំង ក្នុងអំឡុងពេលនៃការសិក្សារបស់គាត់នៅសាលាវិទ្យុអគ្គិសនីនាទីក្រុងប៉ារីស ក្នុងឋានៈជាសមាជិកសាខាកម្ពុជានៃបក្សកុម្មុយនីស្តបារាំង ។ ខ្ញុំបានស្នើទៅទីស្នាក់ការបក្សនៅ បាក់បូ វៀតណាមខាងជើង ដើម្បីឲ្យចាត់ចែងធ្វើការផ្ទៀងផ្ទាត់រឿងនេះជាមួយបក្សកុម្មុយនីស្តបារាំងថែមទៀត ។ មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានទទួលពីក្រុងបាងកកនូវសារទូរលេខ(ប្រើសញ្ញាជាអក្សរ)មួយរបស់ ហ័ង វ៉ាន់ហន ដែលដឹកនាំសាខា ជនជាតិវៀតណាមនៅបរទេសរបស់បក្ស ដោយគាត់បញ្ជាក់ថា ប៉ុល ពត ពិតជាសមាជិកបក្សកុម្មុយនីស្តបារាំងមែន ។ ដូច្នេះខ្ញុំក៏យល់ព្រមទទួលការសុំចូលបក្សរបស់គាត់” ។

ការគ្រប់គ្រងដោយផ្ទាល់លើបក្សប្រជាជនបដិវត្តន៍ខ្មែរពីសំណាក់វៀតណាមបានត្រូវបញ្ចប់ មួយឆ្នាំបន្ទាប់ពីការផុតរលត់នៃសង្គ្រាមឥណ្ឌូចិនលើកទី១ ។ ក្រោមការកៀបសង្កត់របស់គណៈប្រតិភូចិន និងសូវៀតនៅសម័យប្រជុំសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ ពួកកុម្មុយនីស្តវៀតណាមបានត្រូវបង្ខិតបង្ខំឲ្យព្រមទទួលយកនូវការបែងចែកប្រទេសវៀតណាមជាបណ្ដោះអាសន្ន និងការបោះបង់ទៅឲ្យរាជរដ្ឋាភិបាលកម្ពុជាវិញនូវតំបន់នានាដែលរំដោះដោយខ្មែរឥស្សរៈ ។ ចលនាតស៊ូរបស់ឡាវត្រូវបានទទួលស្គាល់នៅហ្សឺណែវ និងអនុញ្ញាតឲ្យកម្លាំងតស៊ូប្រមូលផ្ដុំឡើងវិញ ក្នុងខេត្តចំនួនពីរដែលមានព្រំដែនជាប់ប្រទេសចិន និងវៀតណាម ។ ផ្ទុយទៅវិញ ខ្មែរឥស្សរៈត្រូវរំលាយចលនារបស់ខ្លួនឯងចោល ។ សម្ដេចព្រះ ឧបយុវរាជ នរោត្ដម សីហនុ ដែលដឹកនាំចលនាទាមទារឯករាជ្យដោយផ្ទាល់ព្រះអង្គដើម្បីប្រឆាំងឥស្សរៈ ដែលគាំទ្រដោយវៀតមិញនោះ បានចាកចេញពីសន្និសីទហ្សឺណែវ ជាអ្នកឈ្នះពិតប្រាកដ ។ អនុលោមទៅតាមកិច្ចព្រមព្រៀង កងទ័ពវៀតមិញ និងអ្នកតស៊ូខ្មែរដែលវាយប្រយុទ្ធដោយលួចលាក់ក្នុងជួរកងទ័ពរបស់វៀតណាមប្រហែល២.០០០នាក់ បានត្រូវបញ្ជូនទៅវៀតណាមខាងជើងវិញដោយរង់ចាំកាលៈទេសៈអនុគ្រោះមកដល់ ។ បា បានបំភ្លឺថា “យើងមិនដែលជឿសោះថា ពួកបារាំងនឹងអនុវត្តកិច្ចព្រមព្រៀងក្រុងហ្សឺណែវរហូតដល់ចុងបំផុតទេ ដូច្នេះល្មមតែធ្វើឲ្យយើងរៀបចំប្រុងប្រៀបរួចមុនជាស្រេច” ។ រឿងដែលគួរឲ្យភ្ញាក់ផ្អើលគឺ ៖ នៅចន្លោះឆ្នាំ១៩៧២និង១៩៧៥ក្រុម ប៉ុល ពត បានកម្ចាត់ភាគច្រើននៃជនកម្ពុជា ដែលបណ្ដុះបណ្ដាលដោយក្រុងហាណូយស្ទើរតែទាំងអស់ ។ ក៏ប៉ុន្តែនៅមាន

សល់អ្នកដែលរួចពីគ្រោះថ្នាក់ដល់ជីវិតល្មមគ្រប់គ្រាន់សម្រាប់បង្កើតរដ្ឋាភិបាលស្និទ្ធវៀតណាមមួយនៅប្រទេសកម្ពុជានៅពេលក្រោយមកទៀតដែរ ។

ទោះបើអ្នកដើងចាស់មួយចំនួននៃគណៈដឹកនាំចលនាឥស្សរៈសុខចិត្តទទួលទុក្ខវេទនានេះការខាំមាត់សង្កត់ចិត្ត ដើម្បីយុទ្ធិកជនក្មេងៗដែលបណ្ដុះបណ្ដាលនៅបរទេសក៏ដោយ ក៏វាបានបន្សល់នូវរសជាតិជូរចត់មួយដែរ ។ ពេលត្រឡប់មកពីក្រុងប៉ារីសវិញ ពួកកុម្មុយនីស្ដដែលជាអ្នកស្នេហាជាតិជ្រុលហួសហេតុ ដូចជា ប៉ុល ពត, អៀង សារី និង សុន សេន ជាដើម បានចោទប្រកាន់វៀតណាមថា បានចំណាយការពិសោធន៍ របស់ចលនាតស៊ូខ្មែរដែលប្រមូលបានទាំងអស់នៅក្នុងការប្រយុទ្ធប្រឆាំងអាណានិគមរបស់ខ្លួន ។ ប៉ុន្តែ ជាមួយការដកថយទៅប្រទេសវៀតណាមនូវអ្នកប្រយុទ្ធតស៊ូភាគច្រើន និងបណ្ដាមេដឹកនាំជាប្រវត្តិសាស្ត្រដែលចងសម្ព័ន្ធភាពនឹងវៀតមិញ ប៉ុល ពត មានសេរីភាពយ៉ាងពេញលេញដើម្បីដាក់ឲ្យអនុវត្តនូវមាគ៌ានយោបាយផ្ទាល់របស់គាត់ ជាមួយនឹងការបោះបង់ចោលបក្ខពួក ឬការបាត់ខ្លួនរបស់អ្នកដែលស្ថិតនៅប្រទេសកម្ពុជាផង ។

មេដឹកនាំកុម្មុយនីស្ដនៃចលនាឥស្សរៈ សឺង ង៉ុកមិញ បានសម្រេចចិត្តស្ថិតនៅទីក្រុងហាណូយបន្ទាប់ពីសន្និសីទក្រុងហ្សឺណែវ ដូច្នេះការគ្រប់គ្រងដឹកនាំបក្សរបស់កម្ពុជាត្រូវធ្លាក់ទៅលើ ស៊ីវ ហេង ដែលបង្ហាញខ្លួនឡើងជាភ្នាក់ងារឲ្យការណ៍សម្ងាត់ម្នាក់ ។ សហប្រតិបត្តិការជាច្រើនឆ្នាំរបស់គាត់ជាមួយប៉ូលិសរបស់ សម្ដេច សីហនុ បានធ្វើឲ្យអន្តរាយដល់បណ្ដាញតស៊ូភាគច្រើនរបស់បក្ស ។ ហេង បានចុះចូលនឹងរដ្ឋាភិបាលរបស់សម្ដេចនៅឆ្នាំ១៩៥៩ ។ ក្នុងឱកាសមហាសន្និបាតបក្សលួចលាក់មួយដែលប្រារព្ធឡើងនៅការដ្ឋានស្ថានីយផ្លូវរថភ្លើងនៅក្រុងភ្នំពេញពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ព្រះសង្ឃមួយអង្គព្រះនាម ទូ សាមុត ដែលផ្លាស់គំនិតមកជឿលទ្ធិកុម្មុយនីស្ដ បានត្រូវជ្រើសតាំងជាអគ្គលេខាបក្ស(គាត់ជាមនុស្សមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយវៀតណាម)[១៦] ។

ប៉ុល ពត ដែលពេលនោះជាសាស្ត្រាចារ្យបង្រៀននៅភ្នំពេញបានក្លាយទៅជាអគ្គលេខាបក្សរងនៅឆ្នាំ១៩៦១ ។ បន្ទាប់ពីការបាត់ខ្លួន ទូ សាមុត យ៉ាងអាថ៌កំបាំងនៅខែកក្កដា ឆ្នាំ១៩៦២ ប៉ុល ពត ត្រូវបានដំឡើងឋានៈជាអគ្គលេខាបក្ស ។ ក្រោយមកមិនយូរប៉ុន្មាន ប៉ុល ពត, អៀង សារី (ប្អូនថ្លៃរបស់គាត់) , សុន សេន និងមនុស្សមួយចំនួនទៀតបានរត់ចូលព្រៃ ដើម្បីរៀបចំចាត់តាំងបក្សដោយលួចលាក់ឡើងវិញ ។ គេមិនដែលឮអ្នកណានិយាយពីពួកនេះទៀតទេរហូតមកដល់ឆ្នាំ១៩៧០ ។

នៅចន្លោះពេលនោះ ភាពឃ្លាតពីគ្នាមានសភាពកាន់តែឆ្ងាយទៅៗរវាងបន្ទាត់នយោបាយរ៉ាឌីកាល់និងជាតិនិយមចង្អៀតចង្អល់របស់ក្រុម ប៉ុល ពត និងបន្ទាត់នយោបាយនិយមកណ្ដាលដែលមិនពិតប្រាកដរបស់អ្នកដែលអួតពីការធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលប្រឆាំងអាមេរិកាំងរបស់ សម្ដេច សីហនុ និងជាមួយវៀតណាម ។ ក្នុងឱកាសនៃដំណើរមួយទៅក្រុងហាណូយនៅខែមីនា ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួម

ក្នុងការបរិភោគអាហារពេលល្ងាចមួយដោយមន្ត្រីជាន់ខ្ពស់ម្នាក់ព្រមទាំងមានការប្រកាសជូនព័ត៌មានផ្សេងៗខុសប្លែកពីសព្វដងផង ។ អនុរដ្ឋមន្ត្រីការបរទេសវៀតណាម វ៉ី ដុងយ៉ាង បានថ្លែងនៅពេលល្ងាចនោះពីការវិវាទមួយដែលមានចំណាស់ជាងម្ភៃឆ្នាំមកហើយ ពីការមិនចុះសម្រុងគ្នាយ៉ាងជ្រាលជ្រៅមួយរវាងបក្សវៀតណាមនិងក្រុមបក្ស ប៉ុល ពត នៃបក្សរបស់កម្ពុជា ។ យ៉ាង បាននិយាយប្រាប់ខ្ញុំថា តាំងពីការចាប់ផ្ដើមដំបូងៗ វៀតណាមបានយល់ស្របតាម“មាគ៌ាដឹកនាំដ៏ត្រឹមត្រូវ”ក្នុងផ្ទៃបក្សរបស់កម្ពុជាប្រឆាំងនឹងបន ប៉ុល ពត ដោយចំអកឡកឡឺយទៅលើ“អ្នកមកពីទីក្រុងប៉ារីសទាំងនោះថា ពិបាកនឹងនិយាយអំពីការចូលរួមដ៏សកម្ម ក្នុងការតស៊ូប្រឆាំងនឹងពួកបារាំងណាស់” ។ វិធីសាស្ត្រដែលពួកគេប្រើប្រាស់ ដើម្បីដឹកនាំការបដិវត្តន៍របស់គេបានបង្ហាញឲ្យឃើញពី“គំនិតក្មេងខ្ចីនៃលទ្ធិកុម្មុយនីស្ត”មួយ សម្ដេច សីហនុ ធ្លាប់បានជ្រោងទង់ប្រឆាំងនឹងចក្រពត្តិអាមេរិកយ៉ាងខ្លាំងក្លា ហើយប្រការនេះបានផ្ដល់មកឲ្យព្រះអង្គវិញនូវកិត្យានុភាពយ៉ាងសម្បើមមួយក្នុងចំណោមប្រជារាស្ត្ររបស់ព្រះអង្គ ។ ពួកកុម្មុយនីស្ត ដែលចេះប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវឥទ្ធិពលរបស់សម្ដេចប្រឆាំងនឹងចក្រពត្តិអាមេរិកនោះក៏ចំណេញប្រជាប្រិយភាពយ៉ាងច្រើនដែរ ។ បើពួកកុម្មុយនីស្តខ្មែរមានកិត្យានុភាពគឺកិត្យានុភាពរបស់សម្ដេច សីហនុ តមកទៀតគឺឥទ្ធិពលនៃមាគ៌ានយោបាយ(ក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជា) ទេ ដែលអំណោយផលដល់ការរួមកម្លាំងយ៉ាងកុះកររបស់ប្រជាជនប្រឆាំងនឹងខ្មាំងសត្រូវនោះ ។ ប៉ុន្តែទោះជាបានសម្រេចជោគជ័យក៏ដោយក៏ពុំមែនដោយសារកិត្យានុភាពរបស់ ប៉ុល ពត ដែរ ។ ការរួបរួមគ្នារវាងកម្លាំងផ្សេងៗក្នុងការតស៊ូប្រឆាំងខ្មាំងសត្រូវ និងការជួយជំរុញឲ្យមានសាមគ្គីភាពរវាងប្រជាជនឥណ្ឌូចិនទាំងបី គឺជា“មាគ៌ាមិនប្រែប្រួលនៃការបដិវត្តន៍ផ្ទាល់របស់យើងចាប់ពីចាប់កំណើតរហូតមកដល់សព្វថ្ងៃ” ។ ក៏ប៉ុន្តែ ប៉ុល ពត បានប្រទាញការបដិវត្តន៍របស់កម្ពុជា ឲ្យធ្លាក់ទៅក្នុងផ្លូវឆ្វេងជ្រុលដោយប្រើឧបាយកលថា បក្សបានឆ្លងកាត់“ដំណាក់កាលដ៏លំបាកបំផុតមួយ” នៅរវាងឆ្នាំ១៩៦៧និងឆ្នាំ១៩៦៩ ។ យ៉ាង បាននិយាយរបៀបសម្រាលពាក្យមួយមិនឲ្យមុតពេក (ឧទាហរណ៍ដើម្បីថា “អាក្រក់”សម្រាលថា“មិនសូវល្អ”វិញ) ដើម្បីរំឭកពីការបង្ក្រាបប្រឆាំងជនកុម្មុយនីស្ត ដែលដឹកនាំដោយសម្ដេច សីហនុ ។

យ៉ាង បានសង្កត់បញ្ជាក់ពីប្រជាប្រិយភាពដែលសម្ដេចទទួលបានក្នុងឋានៈព្រះអង្គជាព្រះបិតាឯករាជ្យជាតិ ប៉ុន្តែគាត់ក៏រំឭកឡើងវិញដែរថា មុនឆ្នាំ១៩៥៤ វៀតមិញនិងខ្មែរឥស្សរៈបានចាត់ទុកព្រះអង្គរៀងរាល់ថ្ងៃថា ជាខ្ញុំកញ្ជះបារាំង ។ ដោយបញ្ជាក់អំពីនយោបាយការបរទេសប្រឆាំងអាមេរិករបស់សម្ដេច សីហនុ ក្នុងទសវត្សរ៍៦០នោះ យ៉ាង បានភ្លេចនិយាយពីការទទួលខុសត្រូវរបស់គាត់ក្នុងការកម្ចាត់ពួកឆ្វេងនិយមរបស់កម្ពុជាទៅវិញ ។ តាមពិត ក្នុងអំឡុងនៃបណ្ដាឆ្នាំទាំងនោះវៀតណាមបានណែនាំម្ដងទៀត ឲ្យខ្មែរផ្អាកសកម្មភាពក្នុងការតស៊ូវណ្ណៈនៅកម្ពុជា គឺកុំឲ្យ“យកដំបងទៅវាស់កង់”របស់សម្ដេច សីហនុ និងកុំធ្វើឲ្យទំនាក់ទំនងរបស់ខ្លួនជាមួយក្រុងហាណូយក្លាយទៅជាជម្លោះ ។

ដ្បិតអីវៀតណាមបានលើកតម្កើងការថែរក្សាចំណងទាក់ទងយ៉ាងសុខដុមជាមួយ សម្តេច សីហនុ នៅពីលើអ្វីៗទាំងអស់ ។ ជាមួយការកើនឡើងនៃសង្គ្រាមនៅវៀតណាម ចាប់តាំងពីឆ្នាំ១៩៦៥ វៀតកុង និងកងទ័ពវៀតណាមខាងជើងអាចបាត់បង់ទីជម្រក និងការផ្គត់ផ្គង់កងទ័ពដែលពួកគេរៀបចំបម្រុងនៅប្រទេសកម្ពុជានៅពេលណាមួយមិនខាន ។ ក្រោមលេសនៃអព្យាក្រឹតភាព សម្តេច សីហនុ បានយល់ព្រមបំពេញសេចក្តីត្រូវការរបស់ពួកនោះដោយស្ងាត់កំបាំង ។ សម្តេច សីហនុ បានប្រើកណ្តាប់ដៃដែកមួយប្រឆាំងនឹងខ្មែរក្រហម ប៉ុន្តែសប្បាយព្រះទ័យដោយមានសមានចិត្តចំពោះពួកកុម្មុយនីស្តវៀតណាម ។ ព្រះអង្គបានចោទពួកកុម្មុយនីស្តខ្មែរក្នុងប្រទេសថា ជាភ្នាក់ងាររបស់ក្រុងហាណូយនិងប៉េកាំង ប៉ុន្តែមានព្រះរាជតម្រិះថា ជាសំខាន់គឺសង្គ្រាមនៅវៀតណាមជាការប្រយុទ្ធតស៊ូរបស់ប្រជាជនមួយ ប្រឆាំងនឹងការធ្វើអន្តរាគមន៍មួយរបស់បរទេសដែលមិនអាចដោះសាបាន ។ សម្តេចបានទទួលស្គាល់ក្រោយមកក្នុងកម្រងអនុស្សាវរីយ៍របស់ព្រះអង្គថា បានធ្វើមិនដឹងមិនឮចំពោះការតាំងជំរំទ័ព មន្ទីរពេទ្យនិងកន្លែងផ្គត់ផ្គង់ស្បៀងរបស់វៀតណាមនៅលើទឹកដីកម្ពុជាមែន ។ ព្រះអង្គក៏បានអនុញ្ញាតឲ្យនាវាចិន សូវៀត ឆេកូស្លូវ៉ាគី (បច្ចុប្បន្នបែកជា២ប្រទេសហើយ គឺសាធារណរដ្ឋឆេក និងសាធារណរដ្ឋស្លូវ៉ាគី) និងបណ្តាប្រទេសសង្គមនិយមដទៃទៀតចូលចតនៅកំពង់ផែក្រុងព្រះសីហនុ ដើម្បីរើដាក់សម្ភារសម្រាប់ផ្តល់ឲ្យវៀតកុង បន្ទាប់មកទើបដឹកជញ្ជូនឆ្ពោះទៅកាន់ព្រំដែនវៀតណាមដោយស្ងាត់កំបាំង ហើយត្រូវកងទ័ពរបស់កម្ពុជាដកយកមួយចំណែកធំសម្រាប់ការឆ្លងកាត់នេះ[១៧] ។

ការយកចិត្តយកថ្លើមរបស់ សម្តេច សីហនុ ក្នុងការជួយពួកកុម្មុយនីស្តវៀតណាម គឺផ្អែកលើការគន់គូរដ៏វៃឆ្លាតមួយ ៖ គ្រប់ចំណុចទាំងអស់គឺជារឿងដែលឲ្យប្រយោជន៍ជាង ក្នុងការថែរក្សាទំនាក់ទំនងល្អជាមួយអ្នកទំនងជាឈ្នះពិតប្រាកដ ។ ក្រោយមក សម្តេចបានមានបន្ទូលទម្លាយអាថ៌កំបាំងថា ៖ «មូលហេតុដែលខ្ញុំធ្វើសហប្រតិបត្តិការនេះ គឺខ្ញុំចង់ធ្វើឲ្យវៀតណាមនៅជំពាក់គុណកម្ពុជា ហើយលែងហ៊ានលើកដៃវាយមកលើយើងប្រទេសយើង និងប្រជាជនយើងតទៅទៀត ដែលជាអ្នកធ្វើគុណទៅលើពួកគេ»[១៨] ។

ព្រះអង្គក៏ប្រហែលជាព្រឺខ្លាចផងដែរថា វៀតណាមខាងជើងច្បាស់ជាប្រឆាំងនឹងព្រះអង្គ ប្រសិនបើព្រះអង្គមិនជួយពួកគេក្នុងការប្រយុទ្ធនេះ ។ ហើយរឿងនោះ ព្រះអង្គបានត្រូវញុាំងឲ្យជឿថា ប្រទេសចិន និងវៀតណាមនឹងទៅជាកម្លាំងដែលខ្លាំងជាងគេនៅអាស៊ី ក្រោយការចាកចេញរបស់ពួកអាមេរិកាំង ។ នៅខែសីហា ឆ្នាំ១៩៦៣ សម្តេចបានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាមខាងត្បូង ហើយមិនយូរប៉ុន្មានក្រោយមកក្នុងឆ្នាំដដែល ព្រះអង្គបានប្រានចោលជំនួយសេដ្ឋកិច្ចនិងយោធារបស់អាមេរិកាំងថែមទៀត ។ នៅខែឧសភា ឆ្នាំ១៩៦៥ កម្ពុជាបានផ្តាច់ចំណងការទូតជាមួយក្រុងវ៉ាស៊ីនតោន ហើយសម្តេចបានទទួលនូវការអបអរសរសើរជាច្រើនពីក្រុងប៉េកាំងនិងហាណូយ ។ នៅខែមិថុនា ឆ្នាំដដែលនោះ ព្រះអង្គបានសម្តែងនូវការគាំទ្រចំពោះរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងតាមរយៈជំនួយឧបត្ថម្ភមួយផ្នែកថ្នាំពេទ្យ ។ សម្តេចបានបញ្ជាក់ប្រាប់

អ្នកកាសែតម្នាក់ដែលធ្វើសម្ភាសព្រះអង្គនៅខែវិច្ឆិកា ឆ្នាំ១៩៦៥ ថា «ពិតហើយ ពួកអាមេរិកាំងអាចសម្លាប់ប្រជាជនវៀតណាមពី១០ទៅ២០លាននាក់ ។ យូរបន្តិចទៅពួកគេនឹងតម្រូវឲ្យបោះបង់ប្រទេសនេះទៅឲ្យអ្នកដែលនៅរស់រានមានជីវិតវិញ...។ សហរដ្ឋអាមេរិកបានប្រឈមមុខនឹងការផ្សងព្រេងមួយដែលចៀសមិនផុតពីបរាជ័យឡើយ»[១៩] ។

វៀតណាមបានសម្តែងនូវការដឹងគុណសម្តេច សីហនុ ចំពោះការជួយគាំទ្ររបស់ព្រះអង្គ ។ ពុំមែនជារឿងគួរឲ្យភ្ញាក់ផ្អើលឡើយ ដែលថានៅរដូវក្តៅឆ្នាំ១៩៦៥ ពេលដែល ប៉ុល ពត ធ្វើដំណើរទៅប្រទេសចិន និងធ្វើទស្សនកិច្ចសម្ងាត់មួយនៅក្រុងហាណូយ វៀតណាមបានណែនាំគាត់ឲ្យគាំទ្រនយោបាយបរទេស ប្រឆាំងចក្រពត្តិរបស់សម្តេចដែរ ។ ដោយផ្តើមធ្វើការតស៊ូដោយអាវុធប្រឆាំងនឹងរដ្ឋាភិបាលរបស់សម្តេច សីហនុ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើឲ្យអន្តរាយយ៉ាងខ្លាំងដល់យុទ្ធសាស្ត្ររបស់វៀតណាម ។ ក្រុងហាណូយគិតថា ការតស៊ូវណ្ណៈនៅកម្ពុជានៅមិនទាន់ដល់ដំណាក់កាលធ្វើការបះបោរប្រឆាំងដោយអាវុធទេ ។ ម្យ៉ាងវិញទៀត ក្រុងហាណូយជឿថា ជ័យជម្នះនៅភាគខាងត្បូងនឹងបង្កឲ្យមានលក្ខណៈសម្បត្តិផ្សេងៗក្នុងការវាយប្រយុទ្ធដ៏ជាញជ័យក្នុងទីបំផុតប្រឆាំងនឹងរបបសម្តេច សីហនុ ។

## ការចាប់ផ្តើមដំបូងៗក្នុងការតស៊ូដោយអាវុធ

ក្រុម ប៉ុល ពត មិនទទួលព្រមតាមគំនិតណែនាំរបស់វៀតណាមទេ ។ រយៈពេលប្រាំខែដែលមេដឹកនាំកម្ពុជាស្នាក់នៅប្រទេសចិនកាលពីចុងឆ្នាំ១៩៦៥ និងដើមឆ្នាំ១៩៦៦ ប្រហែលពុំមែនជារឿង«ចម្លែក» សម្រាប់គាត់ទេ នៅពេលចាប់ផ្តើមការបដិវត្តវប្បធម៌ (ការភ័ន្តប្រែដល់ទីជម្រៅនូវតម្លៃជាមូលដ្ឋាននៃសង្គមមួយ) និងការរំដើបរំជួលប្រឆាំងចក្រពត្តិនិយម និងលទ្ធិសេរីនិយមដែលវាបំផុសឲ្យមានឡើង ។ ហេតុនេះហើយបានជា ប៉ុល ពតសម្រេចចិត្តធ្វើការប្រឈមមុខដោយអាវុធជាជាងធ្វើសហប្រតិបត្តិការជាមួយរបបសក្តិភូមិនោះ ។ [សូមមិត្តអ្នកអានស្វែងយល់ពីបដិវត្តន៍វប្បធម៌របស់ប្រទេសចិនជំនាន់ប្រធាន ម៉ៅ ដូចតទៅ ៖ បដិវត្តវប្បធម៌នៃវណ្ណៈពលករនៅប្រទេសចិនមានរយៈពេល១០ឆ្នាំគឺចាប់ពីឆ្នាំ១៩៦៦-៧៦ ដែលនៅពេលនោះអ្នកកាន់អំណាចក្នុងរដ្ឋាភិបាលនិងនយោបាយបានត្រូវបណ្តេញចេញពីតំណែងដូចជា តេង ស៊ាវពីង និង លីវ ចាវជីជាដើម ក្នុងពេលដែលពួកយុវជនតាមសាលារៀន និងមហាវិទ្យាល័យ(បិទទ្វារពីឆ្នាំ១៩៦៦-៧២) រៀបចំបង្កើតជាក្រុម«ឆ្មាំក្រហម»ជាច្រើនក្រុម ដើម្បីទាមទារឲ្យធ្វើតាមគំនិត ម៉ៅ សេទុង ។ បដិវត្តន៍វប្បធម៌នេះកត់សម្គាល់ដោយការផ្លាស់ប្តូរប្រជាជនទាំងហ្វូងៗពីជនបទទៅទីក្រុងផ្សេងៗ និងពីក្រុងនានាមកជនបទស្រែចម្ការវិញ ដោយការប្រយុទ្ធគ្នាយ៉ាងខ្លោចផ្សាតាមបណ្តាខេត្តជាច្រើន ដោយការចាប់ដាក់គុក ការសម្លាប់ពួកសិល្បករនិងបញ្ញវន្ត ការកម្ទេចបំផ្លាញសិល្បៈ ប្រពៃណី វិមានប្រវត្តិសាស្ត្រ និងសៀវភៅ ។ បដិវត្តវប្បធម៌

បានបញ្ចប់ទៅជាមួយមរណភាពរបស់ ម៉ៅ និងការចាប់ខ្លួនពួក“បន៤នាក់”នៅឆ្នាំ១៩៧៦ [បន៤នាក់ជាក្រុមមួយដែលដឹកនាំគ្រប់គ្រងប្រទេសចិន បន្ទាប់ពី ម៉ៅ ទទួលមរណភាពរួម មាន ចាងឈិញ (ប្រពន្ធម៉ៅ), វ៉ាង ហុងវ៉ិន, យ៉ាវ វ៉ិនយន់ និង ហ្សាង ជុនជីវ ។ ពួកនេះត្រូវចោទប្រកាន់ពីបទរួមគំនិតក្បត់រំលំរដ្ឋអំណាច ហើយត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៦)–កំណត់របស់អ្នកបកប្រែ] ។ ទោះបីជាប្រទេសចិនពុំបានជំរុញឲ្យមានការតស៊ូទល់នឹង សីហនុ ជាចំហក៏ដោយ ក៏អាចថា ប្រទេសចិនដែលកាន់តែព្រួយបារម្ភខ្លាំងឡើងៗ ដោយសារការធ្វើសហប្រតិបត្តិការរវាងវៀតណាម–សូវៀតនោះ បែរមកកាន់ជើង ប៉ុល ពត ក្នុងជម្លោះដែលធ្វើឲ្យខ្មែរប្រឈមមុខនឹងវៀតណាមវិញ[៧០] ។

“សៀវភៅខ្មៅ”របស់ ប៉ុល ពត តែងតែអះអាងក្រោយមកថា នៅឆ្នាំ១៩៦៦ “គោលដៅផ្សេងៗនៃការបដិវត្តន៍របស់កម្ពុជានិងវៀតណាម សុទ្ធតែទាក់ទងទៅនឹងជម្លោះ ឬការប្រកួតប្រជែងគ្នាយ៉ាងច្បាស់ក្រឡែត ។ វៀតណាមចង់ដាក់ការបដិវត្តន៍របស់កម្ពុជាឲ្យស្ថិតនៅក្រោមចំណុះរបស់ខ្លួនទាំងស្រុង” ។ ប្រការនេះពុំមែនមានន័យថា ពួកគេព្យាយាមត្រួតត្រាការបដិវត្តន៍ទេ ប៉ុន្តែជាជាងថាបដិវត្តន៍កម្ពុជាពុំទាន់មានអាទិភាពដាច់ខាតនៅឡើយ ។ ដើម្បីកុំឲ្យខ្មែរក្រហមមួម៉ៅ និងប្រហែលដើម្បីបន្ថយកំហឹងដែរនោះ នៅទីបំផុត ក្រុងហាណូយបានយល់ព្រមជួយខាងផ្នែកហ្វឹកហ្វឺនកងទ័ព និងជំនួយផ្នែកយោធាទៀត ។ នៅឆ្នាំ១៩៧៣ អ្នករត់ចោលជួរជាបក្ខជនកុម្មុយនីស្តថ្នាក់ខ្ពស់ម្នាក់ដែលសាកសួរដោយពួកអាមេរិកាំងបានថ្លែងថា នៅឆ្នាំ១៩៦៦វៀតណាមបានបង្កើតកងឯកភាពមួយដោយដាក់ឈ្មោះថា P-36ដើម្បីជួយគាំទ្របក្សកុម្មុយនីស្តរបស់កម្ពុជា ។ នៅមុនការផ្តួលរំលំសម្តេច សីហនុ ក្នុងឆ្នាំ១៩៧០ ក្រុមP-36បានចាប់ផ្តើមហ្វឹកហាត់ខ្មែរ និងវៀតណាមដែលកើតនៅប្រទេសកម្ពុជាតាំងពីពេលនោះម្ល៉េះ[៧១] ។

គេពុំបានបង្ហាញភ័ស្តុតាងឲ្យឃើញថា កងឯកភាព P-36 ដ៏អាថ៌កំបាំងនេះជាមេញុះញង់ឲ្យមានការបះបោរប្រឆាំងរបស់ប្រជាជនកម្ពុជាឡើយ ។ អ្វីដែលប្លែកនោះគឺកងឯកភាពនេះត្រូវបានបង្កើតឡើងនៅមុនការចាប់ផ្តើមធ្វើសកម្មភាពរបស់វា ។ នៅខែមីនា–មេសា ឆ្នាំ១៩៦៧ បន្ទាប់ពីការងើបបះបោរដោយឯងៗរបស់ប្រជាកសិករនៅសំឡូត (ខេត្តបាត់ដំបង) ប្រឆាំងនឹងការរឹបអូសដីធ្លីរបស់ពួកគេ ដោយពួកអគ្គការយុវជនមួយដែលមានការគាំទ្រពីថ្នាក់លើ ទើប ប៉ុល ពត សម្រេចបង្កើតកងទ័ពបដិវត្តន៍មួយ ហើយផ្តើមប្រឡូកក្នុងការតស៊ូដោយអាវុធប្រឆាំងនឹងរបបសម្តេច សីហនុ តែម្តង ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ សង្គ្រាមឆ្នក់របស់ខ្មែរក្រហមបានធ្វើឲ្យគេស្គាល់ខ្លួនក្នុងយុទ្ធនាការមួយ ៖ ការលួចស្ទាក់វាយប្រហារ ការចាប់ពង្រត់មនុស្ស និងការសម្លាប់ទាហាននិងបុគ្គលិករាជការដែលគេចាប់បាន ។ បក្សកុម្មុយនីស្តវៀតណាម បានត្រូវធ្វើឲ្យខូលចិត្តយ៉ាងខ្លាំងក្នុងរឿងនេះ ពុំនោះទេក៏ត្រូវធ្វើឲ្យអាក់អន់ចិត្តខ្លះដែរ ។ ដោយមិនដឹងពីការមិនចុះសម្រុងគ្នារបៀបជាល្បិចកលរបស់ភាគីទាំងពីរ សម្តេច សីហនុ បានចោទប្រកាន់ក្រុងហាណូយនិងក្រុងប៉េកាំងទៅវិញ ។ អ្នកឯកទេស

ដ៏ឆ្នើមម្នាក់ អំពីចលនាកុម្មុយនីស្តកម្ពុជាបានកត់សម្គាល់ថា ៖ "កាលណាបក្សកុម្មុយនីស្តកម្ពុជាទទួលជ័យជម្នះកាន់តែច្រើន កាលនោះផ្លូវផ្គត់ផ្គង់ស្បៀង សម្ភារយោធា និងទីជម្រកទាំងឡាយរបស់វៀតណាមនៅកម្ពុជា ក៏កាន់តែងាយវិនាសអន្តរាយដែរ ។ ទោះជាវៀតណាមធ្លាប់មាន ឬគ្មានគំនិតប៉ុនប៉ងបំផ្លាញការតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏ច្បាស់ណាស់ថា ភាពតានតឹង និងការសង្ស័យគ្នារវាងបក្សទាំងពីរកាន់តែកើនឡើងទៅទៀត"[២២] ។

ក្នុងការតបវិញភ្លាមៗចំពោះការងើបបះបោររបស់ប្រជាកសិករ សម្តេចបានពង្រីងការបង្ក្រាបប្រឆាំងនឹងពួកឆ្វេងនិយម ដោយបង្កើនការប្រមូលផ្តុំការយកព្រះទ័យទុកដាក់ទៅលើសកម្មភាពផ្សេងៗក្នុងជីវភាពនយោបាយរបស់ប្រទេស ។ ខៀវ សំផន និង ហ៊ូ យន់ ជាអ្នកសេដ្ឋសាស្ត្រដែលបណ្តុះបណ្តាលនៅសាលាស័រប៊ោន (Sorbonne) នាទីក្រុងប៉ារីស ព្រមទាំងបញ្ញវន្តកុម្មុយនីស្តដទៃទៀតរួមទាំង ហ៊ូ នឹម ផង ដែលរហូតមកដល់ពេលនោះបានសម្របខ្លួនទៅតាមប្រព័ន្ធដឹកនាំរបស់សម្តេច សីហនុ បានគេចខ្លួនរត់ចូលព្រៃ ។ ម្យ៉ាងទៀត បណ្តាគណបក្សនិយមស្តាំ និងបណ្តាឧត្តមសេនីយ៍ដែលមិនយល់ស្របនឹងនយោបាយប្រឆាំងអាមេរិកាំងរបស់សម្តេច ជាពិសេសការបដិសេធមិនទទួលយកជំនួយសហរដ្ឋអាមេរិករបស់ព្រះអង្គ នៅឆ្នាំ១៩៦៣ បានចាត់ទុកព្រះអង្គជាអ្នកទទួលខុសត្រូវចំពោះការតាំងទីជម្រករបស់វៀតកុងនៅលើទឹកដីកម្ពុជា និងឥទ្ធិពលរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកាន់តែរីកធំឡើងៗផង ។ នៅឆ្នាំ១៩៦៨ សម្តេច ចាប់ផ្តើមសង្ស័យពីការគាំទ្ររបស់ប្រទេសចិន ។ ព្រះអង្គបានត្រូវធ្វើឲ្យរំជួលព្រះទ័យយ៉ាងខ្លាំង ដោយការហៀរកំពប់នៃបដិវត្តន៍វប្បធម៌នៅប្រទេសចិនដែលលទ្ធផលរបស់វានឹងសាយភាយមកដល់កម្ពុជាមិនខានកាលបើឱកាសហុចឲ្យ ។ ដោយពិនិត្យឃើញពួកចិនលោសចោលប្រធានាធិបតី លីវ ចាវជី ជាទីគោរពយ៉ាងជ្រាលជ្រៅរបស់ព្រះអង្គ ដោយសារមូលហេតុមនោគមវិជ្ជានោះ សម្តេច សីហនុ ក៏បានដណ្តឹងសួរក្នុងព្រះទ័យ ពីជោគវាសនាផ្ទាល់របស់ព្រះអង្គដែរ[២៣] ។ ម្យ៉ាងទៀត សម្តេចបានចាប់ផ្តើមខ្វាយខ្វល់ពីការប្រើប្រាស់ទឹកដីកម្ពុជា ដោយវៀតកុងដែលមានសភាពកាន់តែរាលដាលធំឡើងៗថែមទៀត ។ ការកើនឡើងនូវចំនួន កងទ័ពអាមេរិកាំងយ៉ាងច្រើននៅវៀតណាម ក្រោមអាណត្តិប្រធានាធិបតី លីនដុន ប៉ែន ហ្សុនសុន [បានឡើងកាន់តំណែងជាប្រធានាធិបតីបន្ទាប់ពីការលួចធ្វើឃាតប្រធានាធិបតី កេណ្ណឌី នៅឆ្នាំ១៩៦៣ ហើយត្រូវបានជ្រើសតាំងជាថ្មីសម្រាប់អាណត្តិទីពីរទៀតពីឆ្នាំ១៩៦៤-១៩៦៨] បាននាំឲ្យសម្តេច មានព្រះរាជតម្រិះសាជាថ្មី ៖ តើជ័យជម្នះរបស់កុម្មុយនីស្តពិតជាទប់មិនបានមែនឬ? នៅឆ្នាំ១៩៦៩ សម្តេច សីហនុ បានសម្រេចព្រះទ័យរៀបចំទំនាក់ទំនងផ្នែកការទូតជាមួយក្រុងវ៉ាស៊ីនតោនឡើងវិញ ។ ក្នុងពេលជាមួយគ្នានោះ ព្រះអង្គបានធ្វើឲ្យពួកអាមេរិកាំងដឹងជាសម្ងាត់ថា ព្រះអង្គ "នឹងបិទព្រះនេត្រ" បើសិនជាពួកអាមេរិកាំងទម្លាក់គ្រាប់បែកលើជម្រកនានារបស់វៀតកុង ក្នុងតំបន់នានារបស់កម្ពុជាដែលមិនសូវមានមនុស្សរស់នៅ[២៤] ។

ការគួរសមថ្មីនេះរបស់សម្ដេចចំពោះមហាអំណាចអាមេរិកាំង គ្មានអ្វីក្រៅតែពីជួយពង្រឹងឲ្យឧត្ដមសេនីយ៍ លន់ នល់ និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលជាមេដឹកនាំក្រុមប្រឆាំងមិនមែនកុម្មុយនីស្ដរឹតតែរឹងមាំឡើងៗក្នុងការប្រឆាំងរបស់អ្នកទាំងពីរចំពោះរបបរបស់សម្ដេចប៉ុណ្ណោះ ។ ព្រឹត្តិការណ៍ផ្សេងៗកាន់តែស្មុគស្មាញឡើងៗ ដោយសារវិស័យសេដ្ឋកិច្ចបានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ។ នៅនិទាឃរដូវឆ្នាំ១៩៧០ ការកើនឡើងនូវការរំដើបរំជួលបានផ្ដល់ឱកាសឲ្យពួកស្ដាំនិយមបញ្ចប់បញ្ហានេះជាមួយសម្ដេច និងភក្ដីភាពដែលត្រង់គ្មានល្បិចកលរបស់ព្រះអង្គ ក្នុងការសន្យាជាមួយវៀតកុងនិងវៀតណាមខាងជើង ។ ការខ្វាយខ្វល់ព្រះទ័យទាំងនេះបានកើតមានព្រមគ្នានឹងផែនការរបស់អាមេរិកាំង ដែលកំពុងបោសសម្អាតទីជម្រកនានារបស់វៀតកុងនៅកម្ពុជា ដើម្បីដណ្ដើមយកឈ្នះពួកនេះនៅវៀតណាមខាងត្បូង ។ គ្មានអ្នកណាម្នាក់អាចផ្ដល់ភ័ស្ដុតាងដែលមិនអាចប្រកែកបានស្ដីពីការចូលពាក់ព័ន្ធដោយផ្ទាល់របស់អាមេរិក ក្នុងការរួមគំនិតក្បត់ប្រឆាំងនឹងសម្ដេច សីហនុ ឡើយ ។ ប៉ុន្តែក្រុងវ៉ាស៊ីនតោន បានដឹងពីរឿងនេះហើយពុំមានធ្វើសកម្មភាពអ្វីទាំងអស់ដើម្បីឃាត់ឃាំងផងទេ ។ សហរដ្ឋអាមេរិកចូលចិត្តជួយសម្ដេច សីហនុ មួយដៃមួយជើងជាសម្ងាត់ក្នុងការប្រយុទ្ធប្រឆាំងនឹងពួកកុម្មុយនីស្ដវៀតណាមដែរ ។ ក៏ប៉ុន្តែ អនុស្សាវរីយ៍នៃភាពជាសត្រូវកន្លងមករបស់ព្រះអង្គមានលក្ខណៈធ្ងន់ធ្ងរពេក ព្រោះតែបើកដៃឲ្យគេធ្វើអន្តរាគមន៍ជាគុណប្រយោជន៍ដល់ព្រះអង្គ ។ បក្សពួកប្រឆាំងដែលប្រឆាំងវៀតណាមយ៉ាងខ្លាំងក្លាបានកញ្ជ្រោលឡើងទល់នឹងសម្ដេច ដូចដែលអតីតជំនាញការម្នាក់របស់សេ.អ៊ី.អា. ឈ្មោះ ហ្វ្រង់ស្នីប បានកត់សម្គាល់ពីរឿងនេះថា «យើងមិនអាចធ្វើអ្វីក្រៅតែពីសម្ដែងការសប្បាយចិត្ត ហើយចាំតែឆ្លៀតទាញយកប្រយោជន៍ពីស្ថានការណ៍នេះប៉ុណ្ណោះ»[៧៥] ។

បន្ទាប់ពីមានបាតុកម្មប្រឆាំងវៀតណាមនៅក្រុងភ្នំពេញ និងការលុកលុយបំផ្លិចបំផ្លាញស្ថានទូតវៀតណាមខាងជើងដោយហ្វូងនិស្សិតមួយក្រុម នៅថ្ងៃ១៨ មីនា ១៩៧០ រដ្ឋសភាជាតិនិងពួកស្ដាំនិយមភាគច្រើនក្នុងសភាបានបោះឆ្នោតទម្លាក់សម្ដេច សីហនុ ពីតំណែង ដោយប្រគល់សេចក្ដីទុកចិត្តទៅឲ្យឧត្ដមសេនីយ៍ លន់ នល់ ដែលពេលនោះជារដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីការពារប្រទេសកាន់តំណែងជំនួសវិញ ។ សម្ដេច សីហនុ ដែលពេលនោះ ស្ថិតនៅទីក្រុងមូស្គូបានឡើងយន្តហោះឆ្ពោះមកក្រុងប៉េកាំងជាទីដែលព្រះអង្គនឹងរៀបចំជាកន្លែងនិរទេសខ្លួននៅទីនេះតែម្ដង ។

រដ្ឋប្រហារប្រឆាំងនឹងសម្ដេច សីហនុ បានធ្វើឲ្យពួកឆ្វេងនិយមរបស់កម្ពុជាស្ថិតក្នុងគ្រោះថ្នាក់ ហើយក៏ធ្វើឲ្យប៉ះពាល់ដល់ជម្រកទាំងឡាយនិងផ្លូវផ្គត់ផ្គង់សម្ភារសម្រាប់វៀតកុងផងដែរ ។ ដោយហេតុនេះ ខ្មែរក្រហម និងវៀតណាមបានត្រូវបង្ខំចិត្តធ្វើសម្ព័ន្ធភាពនឹងគ្នាប្រឆាំងទល់នឹងសត្រូវរួមរបស់ខ្លួនគឺរដ្ឋាភិបាលរបស់ លន់ នល់ ដែលទ្រទ្រង់ដោយសហរដ្ឋអាមេរិក ។ សម្ដេចដែលត្រូវគេទម្លាក់ពីតំណែងបានធ្វើជាអ្នកទទួលខុសត្រូវសំខាន់នៃសម្ព័ន្ធភាពថ្មីនេះ ។ ខ្មែរក្រហមត្រូវការព្រះនាមព្រះអង្គដើម្បីសម្រេចឲ្យបានភាពស្របច្បាប់ជាអន្តរជាតិមួយ

និងដើម្បីប្រមូលការគាំទ្រពីប្រជាកសិករដែលមានចំនួនយ៉ាងច្រើនលើសលប់ ។ ចំណែកពួកវៀតណាមវិញបានវិនិច្ឆ័យពីតួអង្គសម្តេចថា មិនត្រឹមតែជាចន្ទល់មួយរបស់ចលនាតស៊ូប្រឆាំងសហរដ្ឋអាមេរិក និង លន់ នល់ ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយមួយរារាំងឧត្តមានុភាព (ភាពមានអំណាចលើសលប់គេឯង) នៃចលនារបស់ ប៉ុល ពត នៅក្នុងផ្ទៃក្នុងសម្ព័ន្ធភាពដែរ ។

ឥរិយាបថរបស់ប្រទេសចិនមានលក្ខណៈស្រពេចស្រពិលបំផុត ។ ជាមួយការគាំពាររបស់ពួកជំនាញការបរទេសខ្លះ សម្តេច សីហនុ បានបដិសេធដោយម៉ឺងម៉ាត់នូវបញ្ហាដែលលើកឡើងដោយក្រុងហាណូយ ព្រោះថាពួកចិនអាចរួញរាក្នុងការគាំទ្រព្រះអង្គ ។ សម្តេចបានអះអាងថា “តាំងពីមានការជួបគ្នាលើកដំបូង នៅនិវេសនដ្ឋានរបស់ខ្ញុំនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៥ ជូ អេនឡាយ បានព្រមព្រៀងជាមួយខ្ញុំដើម្បីបញ្ជាក់ថា គ្មានបញ្ហាត្រូវទទួលស្គាល់ “ហេតុការណ៍សម្រេចធ្វើជ្រុលហើយ”ដែលដាក់បន្ទំដោយអ្នកធ្វើរដ្ឋប្រហារឡើយ ហើយថាត្រូវបដិសេធដាច់ខាតនូវភាពពេញច្បាប់ទាំងអស់នៃរបបថ្មីរបស់ខ្មែរផង” ។ ក៏ប៉ុន្តែ ជូ ពុំបានសាកល្បងបញ្ចុះបញ្ចូលសម្តេចឲ្យរួបរួមជាមួយខ្មែរក្រហមទេ ។ សម្តេចបានមានព្រះបន្ទូលថា ព្រះអង្គជាអ្នកពាំនាំសាររបស់ប្រធាន ម៉ៅ នេះ ដែលមានខ្លឹមសារដូចខាងក្រោម ៖

“ក្រុងប៉េកាំងនឹងគោរពដោយឥតងាករេ នូវសេចក្តីសម្រេចចិត្តទាំងអស់ដែលសម្តេចបានប្រកាន់យកបើព្រះអង្គសព្វព្រះទ័យបញ្ចប់អាជីពនយោបាយ ក្រោយពីមានរដ្ឋប្រហារក្នុងពេលថ្មីៗ ប្រទេសចិននឹងគោរពទៅតាមការសម្រេចព្រះទ័យនេះ ។ ប៉ុន្តែបើព្រះអង្គមិនទទួលស្គាល់ហេតុការណ៍ដែលកើតឡើងរួចមក ហើយទេហើយសព្វព្រះទ័យធ្វើជាមេដឹកនាំចលនាជាតិមួយក្នុងការតស៊ូប្រឆាំងនឹងអាមេរិកាំង ដើម្បីរំដោះប្រទេសកម្ពុជានោះ ប្រទេសចិននឹងផ្តល់នូវការគាំទ្ររបស់ខ្លួនយ៉ាងពេញទំហឹង ហើយយល់ព្រមផ្តល់ជំនួយគ្រប់បែបយ៉ាងថ្វាយព្រះអង្គតាមដែលអាចធ្វើទៅបាន”[២៦] ។

របៀបបកស្រាយរបស់សម្តេច សីហនុ អាចប្រាប់ឲ្យដឹងដោយផ្អែកថា ក្រុងប៉េកាំង អាចនៅមានពេលវេលាមួយក្នុងការរក្សាចំណងទាក់ទងផ្សេងៗជាមួយរបប លន់ នល់ សិន ។ ដោយជាក់ស្តែង ប្រទេសចិនគ្មានបំណងកាត់ផ្តាច់ទំនាក់ទំនងរបស់ខ្លួនជាមួយក្រុងភ្នំពេញ ដោយមិនទាន់ធ្វើឲ្យប្រាកដប្រជាពីលទ្ធភាពមួយក្នុងការប្រឆាំងដោយអាវុធទេនោះ ។ ក្នុងពេលដែលមានការធ្វើរដ្ឋប្រហារ ក្រុងប៉េកាំងបានចាប់ផ្តើមលៃលកកែលំអទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយក្រុងវ៉ាស៊ីនតោនឲ្យបានប្រសើរជាងមុនដែរ ដោយដកស្រង់ពីមេរៀនផ្សេងៗនៃការប្រឈមមុខខាងកងទ័ពជាលើកដំបូងរបស់ខ្លួនជាមួយសហភាពសូវៀត ។ សង្គ្រាមមួយប្រឆាំងទល់នឹង លន់ នល់ អាចធ្វើឲ្យអ្វីៗគ្រប់បែបយ៉ាងវិនាសអន្តរាយ ។

ការឃោសនារបស់វៀតណាមបានអះអាងក្រោយមកថា ប្រទេសចិនដែលចូលដៃចូលជើងជាមួយ លន់ នល់ គឺដើម្បីរារាំងជ័យជម្នះរបស់វៀតកុងនៅភាគខាងត្បូងវៀតណាម ។ អ្នកនាំពាក្យផ្លូវការរបស់បក្សកុម្មុយនីស្ត

វៀតណាម វ៉ាង ទុង បាននិយាយរឿងអាថ៌កំបាំងប្រាប់ខ្ញុំថា នៅខែមីនា ឆ្នាំ១៩៧០ ពួកចិនបានបង្ហាញនូវការរារែកចិត្តខ្លះៗចំពោះសម្ដេច សីហនុ ពីព្រោះពួកចិនមិនពេញចិត្តនឹងព្រះអង្គដែលទិតៀនប្រធាន ម៉ៅ ក្នុងសម័យចិនធ្វើបដិវត្តវប្បធម៌ ។ ទុង បានបន្ថែមប្រាប់ខ្ញុំទៀតថា "ចំណែកពួកមិត្តកុម្មុយនីស្តកម្ពុជារបស់យើងក៏មិនចូលចិត្ត សម្ដេច សីហនុ ដែរ ពីព្រោះព្រះអង្គជាអ្នកកម្ទេចបក្សរបស់គេនៅចន្លោះ ឆ្នាំ១៩៥៥-១៩៦៥...[២៧] ។ ក្នុងឱកាសនៃការគង់ប្រថាប់របស់សម្ដេច សីហនុ នៅក្រុងប៉េកាំងក្នុងខែមីនា ឆ្នាំ១៩៧០ ទាំង ជូ អេនឡាយ ទាំង ប៉ុល ពត ពុំបានផ្ដួចផ្ដើមគំនិតដើម្បីគាំទ្រសម្ដេចឲ្យចូលរួមក្នុងចលនាតស៊ូឡើយ ។ គឺយើងទេ (វៀតណាម) ដែលជាអ្នកនឹកឃើញធ្វើការផ្ដួចផ្ដើមគំនិតនេះ ។ ផាំ វ៉ាន់ដុង ដែលដឹកនាំគណៈប្រតិភូសម្ងាត់មួយទៅក្រុងប៉េកាំងបីថ្ងៃក្រោយរដ្ឋប្រហារបានត្រូវចាត់ឲ្យទទួលភារកិច្ចបញ្ចុះបញ្ចូល ជូ អេនឡាយ ។ ចំណែក ផាំ ហ៊ុង សមាជិកការិយាល័យ នយោបាយដែលអមដំណើរ ដុង ហើយដែលធ្លាប់បម្រើជាអន្តរការីទាក់ទងជាមួយខ្មែរក្រហមមុនឆ្នាំ ១៩៧០ នោះគឺមានករណីយកិច្ចប្រឹងប្រែងបញ្ចុះបញ្ចូល ប៉ុល ពត" ។

សម្ដេច សីហនុ បានអះអាងពីការទទួលបានកិច្ចគាំទ្រមួយយ៉ាងកក់ក្ដៅពី ផាំ វ៉ាន់ដុង ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីការជួបសន្ទនាតែពីរនាក់តគ្នាអស់រយៈពេលយ៉ាងយូរមក សម្ដេចបានប្រកាសសេចក្ដីអំពាវនាវមួយសុំឲ្យប្រជាពលរដ្ឋចូលរួមធ្វើការតស៊ូដោយអាវុធ ។ ក្នុងលិខិតមួយសរសេរដោយដៃផ្ញើថ្វាយសម្ដេចនៅពេលដែលគាត់ចេញពីក្រុងប៉េកាំងនៅថ្ងៃទី២៨ ខែមីនានោះ ដុង បានសម្ដែងក្នុងនាមប្រជាជនវៀតណាមនូវ"មនោសញ្ចេតនាមិត្តភាព ការស្ងើចសរសើរនិងការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតចំពោះសម្ដេចចំពោះនយោបាយ និងការប្រយុទ្ធរបស់ព្រះអង្គក្នុងឋានៈជាមេដឹកនាំប្រជាជនខ្មែរដ៏អង់អាចក្លាហាន"[២៨] ។ ការទាក់ទងគ្នាដ៏កក់ក្ដៅ និងប្រកបដោយមិត្តភាពបានបង្រួបបង្រួមសម្ដេច សីហនុ និងពួកមេដឹកនាំក្រុងហាណូយក្នុងរយៈពេលប្រាំឆ្នាំដែរ ។

ប៉ុន្មានថ្ងៃក្រោយពីការសន្យាគាំទ្រនេះ កងទ័ពវៀតកុងជាច្រើនកងឯកភាពបានត្រូវចាត់ឲ្យធ្វើដំណើរខ្វាត់ខ្វែងតាមភូមិជាច្រើននៅភាគខាងកើតកម្ពុជាដើម្បីចែកផ្សាយខិត្តប័ណ្ណ ដែលចម្លងតាមសេចក្ដីអំពាវនាវរបស់សម្ដេច សីហនុ នៅតាមភូមិទាំងនោះ និងឲ្យប្រជាកសិករស្ដាប់សាររបស់ព្រះអង្គ ដែលថតចម្លងមកចាក់ផ្សាយបន្តទៀតផង ។ ប្រជាប្រិយភាពរបស់សម្ដេចក្នុងចំណោមប្រជាកសិករខ្មែរបានទាក់ទាញឲ្យអ្នកទាំងនោះចូលធ្វើកងទ័ពរាប់រយនាក់ ដោយវៀតណាមជាអ្នកបណ្ដុះបណ្ដាលហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ និងបំពាក់អាវុធឲ្យ ដើម្បីបង្កើតកងទ័ពសីហនុនិយមមួយដែលប្រសិទ្ធនាមថាខ្មែររំដោះ ។ ម្យ៉ាងទៀត ពួកគ្រូបង្ហាត់ជាទាហានវៀតណាមខាងជើងបានបង្កើតសាលាយោធាមួយនៅក្នុងខេត្តក្រចេះ(ភាគឦសាន) ដើម្បីហ្វឹកហ្វឺនកងទ័ពខ្មែរដែលទើបចូលថ្មីៗ ដោយអាងលើអ្វីដែលសម្ដេច សីហនុ ឲ្យឈ្មោះថា "ខែលរបស់វៀតណាមខាងជើងដែលប្រកបដោយប្រសិទ្ធភាពមួយ និងវីរភាពមួយមិនអាចប្រកែកបាន"នោះ ចំនួនកងទ័ពរបស់ចលនា

*តស៊ូខ្មែរបានរីកធំធាត់ពី៤០០០នាក់ នៅខែមីនា ឆ្នាំ១៩៧០ ឡើងដល់ជិត៣០.០០០នាក់នៅឆ្នាំ១៩៧៥ ។ លន់ នល់ បានចាប់ផ្តើមធ្វើប្រតិបត្តិការសឹកផ្សេងៗ ដើម្បីរំដោះទីក្រុងនានាដែលឡោមព័ទ្ធដោយខ្មែរក្រហមឲ្យបានធូរស្រាលខ្លះ ប៉ុន្តែត្រូវពើបប្រទះនឹងកងកាំភ្លើងធំ កងរថក្រោះ និងកងទ័ពថ្មើរជើងរបស់វៀតណាមយ៉ាងច្រើន ។ នៅដំណាច់ឆ្នាំ១៩៧២ ខ្មែរក្រហមនិងកងឯកភាពរបស់ខ្មែររំដោះជាច្រើន បានចាប់ផ្តើមធ្វើប្រតិបត្តិការដោយឯករាជ្យរៀងៗខ្លួន ។ នៅពេលជាមួយគ្នានោះ កងទ័ពរៀបរយរបស់ក្រុងហាណូយបានវាយកម្ទេចកងទ័ព លន់ នល់ មិនឲ្យសម្រេចជោគជ័យរួចស្រេចទៅហើយ ។ ទឹកដីរបស់កម្ពុជាមួយភាគធំបានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកខ្មាំងបច្ចាមិត្ត... ក្នុងកណ្តាប់ដៃពួកខ្ទមបះបោរ ។*

## អាថ៌កំបាំងនៃសម្ព័ន្ធភាពមួយ

*ជោគជ័យរបស់ចលនាតស៊ូ ក៏ឲ្យប្រផ្នូលពីទីបញ្ចប់នៃសម្ព័ន្ធភាពរវាងបក្សកុម្មុយនីស្តកម្ពុជានិងក្រុងហាណូយដែរ ។ ការកែលម្អគួរឲ្យកត់សម្គាល់នូវទំនាក់ទំនងរបស់ពួកគេឲ្យកាន់តែប្រសើរឡើងក្រោយខែមីនា ឆ្នាំ១៩៧០ ពុំបានធ្វើឲ្យការសង្ស័យរបស់ ប៉ុល ពត រលាយបាត់ឡើយ ។ ក្នុងកម្រងអនុស្សាវរីយ៍របស់ព្រះអង្គដែលមានពីឆ្នាំ១៩៧០-៧១ សម្តេចបានរៀបរាប់ពីព្រឹត្តិការណ៍ខ្លីៗ ប្លែកៗគួរឲ្យជក់ចិត្តដូចតទៅ ៖ រដ្ឋមន្ត្រីជាច្រើនរូបនៃរដ្ឋាភិបាលរបស់ចលនាតស៊ូខ្មែរដែលទៅធ្វើទស្សនកិច្ចនៅក្រុងហាណូយ បានពិភាក្សាគ្នាជាឯកជនអំពី“ការលាក់ពុតរបស់យួន” ដោយរំឭកផងដែរពីភាពចាំបាច់សម្រាប់ពួកមន្ត្រីខ្មែរនៃរណសិរ្សរួបរួមជាតិកម្ពុជាកុំឲ្យទុកចិត្តមហិច្ឆតាត្រួតត្រាគេរបស់វៀតណាម បន្ទាប់ពីជ័យជម្នះរួមលើពួកឈ្លានពាន យ៉ាន់ឃី* (Yankee) *និងជនក្បត់ លន់ នល់” ។ [(យ៉ាន់ ឃី ឈ្មោះដែលពួកអង់គ្លេសហៅរបៀបចំអកចំពោះនិគមជនបះបោរនៅនូវ៉ែលអង់គ្លីទែរ ដែលបង្កើតឡើងនៅសតវត្សរ៍ទី១៧ ស្ថិតតាមឆ្នេរសមុទ្រអាត្លង់ទិច គឺរដ្ឋម៉ែន, ញូវហេមស្ស៊ៀរ, វើម៉ុងត៍, ម៉ាសស្សាឈូស្សែត, រ៉ូដអៃឡិន និង ខុនណែតធីខឹត តមកទៀតគឺជាឈ្មោះដែលពួកភាគខាងត្បូងហៅពួកភាគខាងជើង ហើយទីបំផុតហៅប្រជាពលរដ្ឋអង់គ្លូ-សាក់សុង*(Anglo-saxons) *ទូទាំងសហរដ្ឋអាមេរិកតែម្តង-កំណត់របស់អ្នកបកប្រែ] ។ ប៉ុន្តែ“ជញ្ជាំងមានត្រចៀក”ដូចដែលសម្តេច សីហនុ ទ្រង់លិខិតដោយការពេបជ្រាយមួយថា ៖ ដោយមានគេរាយការណ៍ប្រាប់ឧត្តមសេនីយ៍ វ៉ង្វៀង យ៉ាប ពាក្យសម្តីនេះបានធ្វើឲ្យគាត់អាក់អន់ចិត្តជាខ្លាំង ។ នៅពេលដែលគាត់ជួបសម្តេច សីហនុ នៅថ្ងៃបន្ទាប់ គាត់បានប្រកាសថា “សម្តីប្រឆាំងវៀតណាម”ទាំងនេះរបស់បណ្តាមន្ត្រីនៃរណសិរ្សរួបរួមជាតិកម្ពុជាដែលពោលពាក្យជេរក្រុងហាណូយ “បានធ្វើឲ្យយើងឈឺចាប់ក្រៃលែង ក្នុងពេលដែលកងទ័ពរបស់យើងសុខចិត្តឃ្លាតឆ្ងាយពីមាតុភូមិជាទីស្រឡាញ់ និងពីក្រុមគ្រួសារជាទីស្នេហាបំផុតរបស់ខ្លួន ដើម្បីវាយប្រយុទ្ធនិងស្លាប់រៀងរាល់ថ្ងៃនៅលើទឹកដីដ៏ពិសិដ្ឋរបស់បងប្អូនខ្មែរ ដោយច្បាំងតតាំងនឹងសត្រូវរួមរបស់យើង ដើម្បីធ្វើការសង្គ្រោះជាតិ និងការរំដោះប្រទេសរបស់*

ព្រះអង្គគឺកម្ពុជា» ។

ការបែកធ្លាយសម្ព័ន្ធរបស់ យ៉ាប មានលក្ខណៈថ្មីថ្មែងមុនរួចជាស្រេច ។ ការបែកធ្លាយនេះគឺជាការឆ្លើយតបទៅសម្ព័ន្ធមិនសមរម្យខ្លះ ។ ការបែកធ្លាយនេះក៏បង្ហាញឲ្យឃើញការខកចិត្តដែលបណ្តាលមកពីការធ្វើសហប្រតិបត្តិការរបស់គេជាមួយខ្មែរក្រហមដែរ ។ ក្នុងឱកាសនៃកិច្ចចរចាគ្នាជាមួយ ឡេ យន់ នៅក្រុងហាណូយនាខែមេសា ឆ្នាំ១៩៧០ ប៉ុល ពត បានប្រឆាំងជំទាស់នឹងការបង្កើតបញ្ជាការឯកភាពមួយដែលស្នើឡើងដោយវៀតណាម ។ នៅឆ្នាំ១៩៧០-៧១ រណសិរ្សខ្មែរដែលទើបនឹងកកើតបានត្រូវខ្មែរក្រហមយកទៅដាក់ជំនួសវៀតណាមដើម្បីគ្រប់គ្រងភូមិរំដោះនានា ។ នៅឆ្នាំ១៩៧១ ទំនាក់ទំនងរវាងពួកខ្មែរក្រហមនិងកងទ័ពវៀតណាមនៅកម្ពុជាបានធ្លាក់ចុះជាបណ្តើរៗ ។ នៅឆ្នាំ១៩៧៨ ខ្មែរបានឈានរហូតដល់ចោទប្រកាន់វៀតណាមថែមទៀតថា បានប៉ុនប៉ងដាក់ថ្នាំបំពុលសម្លាប់ ប៉ុល ពត នៅឆ្នាំ១៩៧០ ក្នុងឱកាសនៃកិច្ចប្រជុំមួយ ។ ខ្មែរមិនដែលបង្ហាញឲ្យឃើញភ័ស្តុតាងណាមួយស្តីពីរឿងនេះសោះ ប៉ុន្តែការចោទប្រកាន់នេះ គឺជាសញ្ញាដំបូងនៃបរិយាកាសមន្ទិលសង្ស័យគ្នា ដែលកំពុងលើកយកមកជាសំអាងរវាងភាគីទាំងពីរ ។ គេបានអានក្នុងរបាយការណ៍មួយរបស់ក្រុមសេ.អ៊ី.អា. ចុះកាលបរិច្ឆេទខែកញ្ញា ឆ្នាំ១៩៧០ថា ពួកកងទ័ពខ្មែរក្រហមបានបាញ់ស្រោចពីក្រោយទៅលើពួកកុម្មុយនីស្តវៀតណាម ដែលជាប់ដៃប្រយុទ្ធជាមួយកងឯកភាពមួយរបស់ លន់ នល់ នៅក្នុងខេត្តកំពង់ធំ[២៩] ។

ស្ត្រីវៀតណាមម្នាក់ឈ្មោះ ង្វៀង ធីគូ បានរ៉ាយរ៉ាប់ប្រវត្តិរបស់នាងប្រាប់ខ្ញុំនៅឆ្នាំ១៩៧៨ថា នាងបានរួចផុតគ្រោះថ្នាក់ពីការឆ្មក់វាយប្រហារមួយរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧២ នៅក្នុងខេត្តតាយនិញ ។ នាងយល់ច្បាស់ដូចប្រជាជនវៀតណាមរាប់ពាន់នាក់ដែលរស់នៅកម្ពុជាដែរថា ជាការប្រសើរត្រូវតែរត់ភៀសខ្លួនចេញពីតំបន់ដែលខ្មែរក្រហមត្រួតត្រា ។ កាលពីដើមគ្រួសារនាងបានចាកចេញពីវៀតណាមខាងជើងដើម្បីមកធ្វើការក្នុងចម្ការកៅស៊ូបារាំងមួយនៅជប់(ខេត្តកំពង់ចាម) ។ ប្តីនិងប្អូនប្រុសពីរនាក់របស់នាងបានចូលធ្វើទ័ពជាមួយវៀតកុងនៅចុងទសវត្សរ៍៦០ ។ កងទ័ពទាំងនោះបានធ្វើការទាក់ទងជាមួយពួកខ្មែរក្រហមក្រោយពីមានការផ្តួលរំលំសម្តេច សីហនុ ។ នៅចុងឆ្នាំ១៩៧១ ខ្មែរក្រហមបានចាប់ផ្តើមធ្វើទុក្ខបុកម្នេញសហគមន៍វៀតណាម នៅចម្ការកៅស៊ូ ហើយឈប់លក់ស្រូវអង្ករឲ្យពួកនេះថែមទៀត ។ នាងបាននិយាយប្រាប់ខ្ញុំថា «កងទ័ពរំដោះជាតិរបស់វៀតណាមបានសាកល្បងការពារពួកយើងដែរ ប៉ុន្តែវាមានសភាពកាន់តែលំបាកខ្លាំងឡើងៗ ។ នៅឆ្នាំ១៩៧២ ប្អូនប្រុសរបស់ខ្ញុំដែលធ្វើទ័ពបានជួយក្រុមគ្រួសាររបស់យើងឲ្យភៀសខ្លួនចេញពីប្រទេសកម្ពុជា» ។

វិបត្តិដែលនៅក្តៅគំរវាងវៀតណាម និងខ្មែរក្រហមបានផ្ទុះឡើងនៅចុងឆ្នាំ១៩៧២ ក្នុងរយៈពេលនៃកិច្ចចរចាសន្តិភាពដំណាក់កាលចុងក្រោយរវាងអាមេរិក-វៀតណាម និងការសាកល្បងជាច្រើនបានត្រូវរៀបចំឡើងដើម្បីបញ្ចុះបញ្ចូលឲ្យខ្មែរក្រហមធ្វើកិច្ចពិភាក្សាជាមួយ លន់ នល់ ។ ហង់រី គីស្ស៊ីងហ្គ័រ (Henry Kissinger) អ្នកចរចារបស់អាមេរិកបានបញ្ជូនសំណើនេះទៅឲ្យពួកមេដឹកនាំខ្មែរក្រហមក្នុងឱកាសនៃការប្រជុំគ្នាជាហូរហែមួយ

ដែលធ្វើដោយលួចលាក់នៅចុងឆ្នាំ១៩៧២ ហើយជាលើកចុងក្រោយគឺនៅចន្លោះ ថ្ងៃទី២៤ និងទី២៦ ខែមករា ក្នុងឱកាសនៃការជួបគ្នាមួយរវាង ផាំ ហ៊ុង សមាជិកការិយាល័យនយោបាយវៀតណាមជាមួយ ប៉ុល ពត ។ ប៉ុល ពត បានជំទាស់នឹងគាត់ ដោយការបដិសេធរបៀបមើលងាយមួយ ព្រោះគាត់មើលឃើញច្បាស់ថា របបឯកោ នឹងសួយក្សេរដែលឈ្មោះរបស់ លន់ នល់ មានជីវិតមកដល់ម៉ោងចុងក្រោយរបស់ខ្លួនហើយ ហើយថាស្ថានការណ៍ ផ្នែកយោធាក៏មានភាពអនុគ្រោះសម្រាប់គាត់ដែរ ។ វៀតណាមបានព្រើនរំពុកខ្មែរក្រហមថា ការបដិសេធមិន ព្រមចរចានេះនឹងនាំឲ្យមានការសងសឹកយ៉ាងធ្ងន់ធ្ងរពីសំណាក់ពួកអាមេរិកាំងមិនខាន ដែលរឿងនេះ ប៉ុល ពត យល់ថាជាការសាកល្បងគំរាមកំហែងមួយ ។ ក្រោយមកសៀវភៅខ្មៅបានអះអាងថា ដោយអស់មធ្យោបាយ ប្រើកម្លាំងវៀតណាមត្រូវការបន្ទាយពេលវេលា ហើយជាពិសេសមិនចង់ឲ្យចលនាតស៊ូរបស់កម្ពុជា ឈ្នះដោយ គ្មានការជួយរបស់ខ្លួនឡើយ ពីព្រោះនៅពេលនោះខ្លួនត្រូវការលះបង់មិនធ្វើឲ្យប្រទេសកម្ពុជាទៅជារណបមួយ របស់វៀតណាមទេ[៣០] ។

ទោះជាយ៉ាងណាក៏ដោយ វៀតណាមពិតជាយល់ឃើញត្រឹមត្រូវមែនចំពោះអ្វីដែលជាការសងសឹក ។ ដោយក្លាយទៅជាគ្មានប្រយោជន៍ក្នុងភាគសេសសល់នៃឥណ្ឌូចិន ហ្វូងយន្តហោះចម្បាំងរបស់អាមេរិកាំងបាន ទម្លាក់គ្រាប់បែកចំនួន២៥៧.៤៦៥តោន មកលើប្រទេសកម្ពុជានៅចន្លោះខែកុម្ភៈ និងខែសីហា ឆ្នាំ១៩៧៣ គឺ ត្រូវជាពាក់កណ្ដាលច្រើនជាងគ្រាប់បែកដែលទម្លាក់លើប្រទេសជប៉ុនក្នុងសម័យសង្គ្រាមលោកលើកទី២ទៅទៀត ដោយបង្កឲ្យមានអ្នករងគ្រោះជាប្រជាជនស៊ីវិលយ៉ាងច្រើនឥតគណនា ។ បួនឆ្នាំក្រោយមក ក្នុងស្ថានទូតរបៀប បន្ទាយទាហានរបស់កម្ពុជាប្រជាធិបតេយ្យនៅក្រុងហាណូយ អ៊ិន ស៊ីរ៉ុង បានរំពុកនៅចំពោះមុខខ្ញុំជាមួយការ តូចចិត្តពី«អំពើក្បត់របស់វៀតណាម»ដែលប្រព្រឹត្តល្មើសដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព មួយដាច់ដោយឡែកជាមួយសត្រូវ ហើយដូចជាបណ្ដោយឲ្យពួកអាមេរិកាំងមានសេរីភាពប្រមូលផ្ដុំកំហឹងខ្លាំង របស់គេប្រឆាំងនឹងប្រទេសកម្ពុជាតែម្ដង ។ ឧទាហរណ៍ ដែលមានគោលបំណងជាក់លាក់របស់ក្រុម ប៉ុល ពត គឺ ទម្លាក់ការទទួលខុសត្រូវពីគ្រោះអាក្រក់ទាំងអស់របស់ខ្លួនទៅលើវៀតណាម តាមរយៈការរើសអើសជាតិ សាសន៍និងភាពជាសត្រូវស្ទួពូជ ។ ដោយជាក់ស្ដែង ការតស៊ូរបស់កម្ពុជាដែលធ្វើឲ្យពួកមេដឹកនាំក្រុងហាណូយ ពេញចិត្តតែក្នុងករណីដែលការតស៊ូនោះអាចជំរុញបុព្វហេតុផ្ទាល់របស់គេឲ្យជឿនទៅមុខប៉ុណ្ណោះ ហើយចំណែក ខ្មែរក្រហមវិញក៏មិនសូវបង្ហាញឲ្យឃើញការវៀសវៃជួយវៀតណាមឲ្យបង្រួបបង្រួមប្រទេសរបស់គេឡើង វិញដែរ ។

ដោយផ្ទុយនឹងមតិរួម បើពួកអាមេរិកាំងមានសេរីភាពនឹងធ្វើអ្វីៗនៅប្រទេសកម្ពុជា ពិតហើយពួកគេ ត្រូវតែមានកិច្ចព្រមព្រៀងដែលចុះហត្ថលេខាជាមួយវៀតណាម ប៉ុន្តែ តាមលោក ហង់រី គីស្ស៊ីងហ្គ័រ ថា ក៏ត្រូវ មានការគាំទ្រជាសម្ងាត់ពី ដូ អេនឡាយ ដែល«ត្រូវការយ៉ាងហោចនូវអន្តរាគមន៍យោធារបស់យើងនៅ

ប្រទេសកម្ពុជាដែរ ដើម្បីធ្វើឲ្យគោលបំណងរបស់គាត់មានប្រៀបជាង» ។ តាម គីស្ស៊ីងហ្គ័រ ដដែលថា ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងគ្រាន់តែជាចំណែកមួយនៃការតថ្លៃដ៏ធំមួយប៉ុណ្ណោះ ដែលស្របទៅតាមនោះប្រទេសចិនមានសេចក្ដីសង្ឃឹមជំរុញឲ្យពួកសម្ពន្ធមិត្ររបស់ខ្លួនយល់ព្រមធ្វើការដោះស្រាយ ដោយការចរចាមួយ ដែលក្នុងនោះសម្ដេច សីហនុ នឹងសម្ដែងតួនាទីសំខាន់ជាងគេ[៣១] ។ មុនការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីស ពួកមេដឹកនាំខ្មែរក្រហមប្រហែលមិនដឹងថា ដូ បាននិយាយនឹង គីស្ស៊ីងហ្គ័រ ថា ដំណោះស្រាយនឹងកាន់តែងាយស្រួលនៅប្រទេសកម្ពុជាក៏ដូចនៅវៀតណាម «ពីព្រោះទោះជាមានអ្វីកើតឡើងក៏ដោយ ក៏វាច្បាស់ណាស់ថា សមាសភាពវណ្ណៈគហបតីជាតិនៅកម្ពុជា [នឹងមានចំណែកមួយ] ក្នុងរដ្ឋាភិបាលហើយថា សម្ដេច សីហនុ នឹងក្លាយជាប្រមុខរដ្ឋដោយចៀសមិនផុត»[៣២] ។

ប្រាំពីរខែក្រោយមក បើទុកជាខ្មែរក្រហមបានបដិសេធមិនចរចាជាមួយ លន់ នល់ ហើយបើទុកជាមានការវាយបុកទម្លុះយ៉ាងលឿនរហ័សរបស់កងទ័ពខ្មែរក្រហមក៏ដោយ ក៏ ដូ អេនឡាយ នៅតែជាមនុស្សម្នាក់ចង់ឲ្យមានការរកដំណោះស្រាយដោយការចរចាជានិច្ច ។ វៀតណាមពុំបានសម្រេចជោគជ័យក្នុងការនាំខ្មែរក្រហមមកកាន់តុចរចាឡើយ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៣ វៀតណាមបានស្នើយោបល់ឲ្យលោក គីស្ស៊ីងហ្គ័រ ជួបសម្ដេច សីហនុ ។ ប្រាំបីឆ្នាំក្រោយមក នៅពេលដែលរដ្ឋមន្ត្រីការបរទេសអាមេរិកាំងរំឭកពីរឿងនេះ គាត់បានវិនិច្ឆ័យថា ការស្នើយោបល់របស់វៀតណាមជា«សំណើមានលក្ខណៈគឃ្លើន» បើប្រៀបធៀបទៅនឹងការខ្វាយខ្វល់ខ្លាំងមែនទែនរបស់ ដូ ដើម្បីនាំយកសម្ដេចមកកាន់អំណាចវិញ[៣៣] ។ ក៏ប៉ុន្តែអ្វីៗបានធ្វើឲ្យគេគិតថា វៀតណាមមានគោលបំណងលេងសន្លឹកបៀ សីហនុ យ៉ាងប្រាកដ ។ ទោះជាយ៉ាងណាក៏ដោយ ក៏វៀតណាមមានលទ្ធភាពធ្វើអ្វីៗច្រើនជាង ដូ នៅពេលជជែកជាមួយពួកខ្មែរក្រហមដែលមាននិន្នាការម៉ៅនិយម ។

ប៉ុន្តែ អ្នកសង្កេតការណ៍ខ្លះនឹកឆ្ងល់តែម្នាក់ឯងថា ក្នុងរឿងនេះ ដូ ចង់ឲ្យមានការវិលត្រឡប់របស់សម្ដេចមកកាន់អំណាចមែនឬ? ឬគាត់គ្រាន់តែចង់ប្រើប្រាស់ប្រជាប្រិយភាពនិងកិត្យានុភាពជាអន្តរជាតិរបស់ព្រះអង្គដើម្បីធានាឲ្យមានជ័យជម្នះដល់ខ្មែរក្រហមដែលជាសម្ព័ន្ធមិត្តខាងមនោគមវិជ្ជារបស់ប្រទេសចិនទេដឹង? ប៉ុន្តែនាយករដ្ឋមន្ត្រី ដូ អេនឡាយ ដែលឈឺយ៉ាងធ្ងន់ ហើយថែមទាំងត្រូវពើបប្រទះនឹងការប្រឆាំងជិតាស់ដាច់ខាតមួយដែលដឹកនាំដោយ ចាង ឈិញ ប្រពន្ធ ម៉ៅ នៅឆ្នាំ១៩៧៣ ផងនោះ លែងអាចធ្វើឲ្យផលប្រយោជន៍ផ្សេងៗរបស់សម្ដេច សីហនុ មានប្រៀបលើផលប្រយោជន៍របស់ខ្មែរក្រហមទៀតហើយ ។ នៅចុងឆ្នាំ១៩៧៤ នៅពេលដែលពួកបារាំងចាប់ផ្ដើមប្រើមធ្យោបាយផ្សេងៗ ខាងការទូតជាសម្ងាត់ដោយសហការជាមួយក្រុងវ៉ាស៊ីនតោនក្នុងគោលដៅនាំយកសម្ដេចឲ្យធ្វើជាមេដឹកនាំរដ្ឋាភិបាលចម្រុះទូលំទូលាយមួយនោះ ឥរិយាបថរបស់ពួកចិនបែរទៅជាមានលក្ខណៈមិនច្បាស់លាស់យ៉ាងខ្លាំង[៣៤] ។

សម្ដេចបានសម្ដែងនូវការដឹងគុណចំពោះ ដូ អំពីមិត្តភាពនិងការគាំទ្រដែលគាត់ធានាការពារព្រះអង្គ

ប្រឆាំងនឹងខ្មែរក្រហមដែលជាពួកនិយមជ្រុលហួសហេតុ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ព្រះអង្គបានឆ្លងកាត់ការសង្ស័យក្នុងឱកាសខ្លះដែរ ។ សម្តេចបានមានបន្ទូលប្រាប់ខ្ញុំជាសម្ងាត់ទាំងឈឺចាប់ថា “តាំងពីដំបូងៗម្ល៉េះ ខ្ញុំជឿជាក់ដូចពួកចិនដែរថា ខ្មែរក្រហមនឹងរលាស់ខ្ញុំចោល” ។ នៅខែមេសា ឆ្នាំ១៩៨០ ក្នុងអំឡុងនៃការជួបសន្ទនាយ៉ាងយូរក្នុងនិវេសនដ្ឋានដ៏ល្អឆើតឆាយរបស់ព្រះអង្គនៅក្រុងប៉េកាំង សម្តេចបានរំឭកពីបណ្តាឆ្នាំជាបន្តបន្ទាប់ក្រោយពីការផ្តួលរំលំព្រះអង្គ ។ គឺនៅឆ្នាំ១៩៧១ ដែលសម្តេចបានស្នើ ជូ ជាលើកដំបូងបំផុត ឲ្យជួយបញ្ចុះបញ្ចូលខ្មែរក្រហមអនុញ្ញាតឲ្យព្រះអង្គយាងទៅកាន់តំបន់រំដោះនៅកម្ពុជាដោយអះអាងថា លក្ខណៈដែលគួរឲ្យជឿបានក្នុងឋានៈព្រះអង្គជាមេដឹកនាំរដ្ឋាភិបាលចលនាតស៊ូអាចនឹងខ្វះចន្លោះបើព្រះអង្គគង់និរទេសដូច្នេះ ប៉ុន្តែគ្មានអ្នកណាមួយរវល់អើពើឡើយ ។ “អ្វីដែលធ្វើឲ្យខ្ញុំអាក់អន់ព្រះទ័យបន្តិចបន្តួចគឺថា ប្រទេសចិនមិនគាំទ្រខ្ញុំបន្តិចសោះ” ។ ជូ បាននិយាយដោះសាដោយលើកពីមូលហេតុខាងសន្តិសុខដើម្បីហាមឃាត់ព្រះរាជដំណើររបស់ព្រះអង្គ ។ ផ្លូវលំហូជីមិញជាផ្លូវត្រូវធ្វើដំណើរមកកាន់កម្ពុជារំដោះនោះគឺស្ថិតនៅក្រោមការទម្លាក់គ្រាប់បែកជាប្រចាំ ។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស សម្តេច សីហនុ បានស្នើសុំការអនុញ្ញាតមកធ្វើទស្សនកិច្ចមាតុភូមិ ចំពោះ អៀង សារី ដែលស្ថិតនៅទីក្រុងប៉េកាំងក្នុងចន្លោះខែសីហា ឆ្នាំ១៩៧១ និងខែមេសា ឆ្នាំ១៩៧៥ ជាទីដែលគាត់ទទួលរ៉ាប់រងទំនាក់ទំនងរវាងខ្មែរក្រហមនិងបក្សកុម្មុយនីស្តចិន ហើយព្រមពេលជាមួយនោះ គាត់ក៏ជា“អ្នកចាំយាម”ស្តេចដែលកែមិនឡើងនេះដែរ ។ នេះជាការបដិសេធដាច់ខាតមួយ ។ សម្តេចបានសាកល្បងផ្សងសំណាងរបស់ព្រះអង្គជាថ្មីម្តងទៀតនៅទីក្រុងហាណូយ ។ ចាប់តាំងពីព្រះអង្គសម្រេចព្រះទ័យគង់នៅទីក្រុងប៉េកាំង សម្តេចតែងតែយាងទៅទីនោះរៀងរាល់បុណ្យចូលឆ្នាំចិន-យួន ដើម្បីជាតឹងតាងនៃសាមគ្គីភាពរបស់ព្រះអង្គចំពោះប្រជាជនវៀតណាម ។ ក្នុងឱកាសនៃទស្សនកិច្ចចូលរួមពិធីបុណ្យចូលឆ្នាំនៅខែកុម្ភៈ ឆ្នាំ១៩៧៣ ព្រះអង្គបានទទូចសុំឲ្យ ផាំ វ៉ាន់ដុង ជួយធ្វើអន្តរាគមន៍ជាមួយខ្មែរក្រហមជាគុណប្រយោជន៍ដល់ព្រះអង្គថា “លោកមានមធ្យោបាយកៀបសង្កត់មួយទៅលើពួកនោះ ពួកគេពុំអាចបន្តការវាយប្រយុទ្ធបានទេ បើសិនជាលោកមិនដឹកជញ្ជូនសម្ភារសឹកដែលប្រទេសចិនបានផ្តល់ឲ្យតាមរយៈប្រទេសលោកនោះ ។ សូមលោកនិយាយប្រាប់ថា សីហនុ មានករណីយកិច្ចវិលត្រឡប់ទៅកម្ពុជាវិញ បើសិនជាពួកគេចង់ឲ្យខ្ញុំធ្វើជាតំណាងប្រទេសរបស់គេប្រកបដោយកិត្តិយស និងភាពថ្លៃថ្នូរក្នុងសម័យប្រជុំនៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងអាល់ហ្សេ (ប្រទេសអាល់ហ្សេរី)” ។ បន្ទាប់មក ដុង បានជួបពិភាក្សាគ្នាយ៉ាងយូរជាមួយ អៀង សារី ពីភាពចាំបាច់ក្នុងការអនុញ្ញាតឲ្យសម្តេចយាងទៅធ្វើទស្សនកិច្ចនៅតំបន់រំដោះ ។ សារីនៅតែមិនទោរទន់ ។ ទីបំផុត ដុង បាននិយាយនឹងពួកចិនវិញម្តង ហើយទទួលបានជោគជ័យយ៉ាងប្រសើរ ។ “នៅពេលខ្ញុំ(សម្តេច)វិលត្រឡប់ទៅប្រទេសចិនវិញ អៀង សារី បានមកទូលខ្ញុំថា ខ្ញុំបានទទួលការអនុញ្ញាតពី“អ្នកនៅក្នុងប្រទេស”ឲ្យយាងទៅធ្វើទស្សនកិច្ចនៅកម្ពុជាហើយ ។ រឿងនេះ គឺដោយសារតែអន្តរាគមន៍របស់ ផាំ

វ៉ាន់ដុង ប៉ុណ្ណោះ»[៣៥] ។

បើសិនការវិលត្រឡប់ជាប្រវត្តិសាស្ត្ររបស់សម្តេច សីហនុ ទៅប្រទេសកម្ពុជាបីឆ្នាំក្រោយពីការផ្តួលរំលំព្រះអង្គគឺជាលទ្ធផលនៃការបង្ខិតបង្ខំរបស់ក្រុងហាណូយមែននោះ ដំណើរនេះបានធ្វើឲ្យព្រះអង្គថ្លឹងថ្លែងអំពីការខ្វែងគំនិតគ្នាដែលកាន់តែជ្រៅទៅៗ ដោយធ្វើឲ្យខ្មែរក្រហមប្រឈមមុខនឹងវៀតណាមដែលតាំងខ្លួនជាសមមិត្តរបស់ពួកគេយ៉ាងពិតប្រាកដ ។ នៅខែមីនា ឆ្នាំ១៩៧៣ សម្តេចបានឡើងយន្តហោះឆ្ពោះទៅក្រុងហាណូយបន្ទាប់មក តាមយន្តហោះអង់តូណូវ-២៦ មួយគ្រឿងរបស់កងទ័ពអាកាសវៀតណាមឆ្ពោះមកកាន់តំបន់ ដុងហ័រនៅភាគខាងត្បូងបំផុតរបស់ប្រទេសវៀតណាមខាងជើង ។ អមដំណើរដោយមហេសីព្រះអង្គ, ឡៀន ធឿងឯកអគ្គរដ្ឋទូតវៀតណាមដែលមានអំណាចលើសគេនៅកម្ពុជា និង អៀង សារី ផ្ទាល់ សម្តេច សីហនុ បានយាងធ្វើដំណើរចុះតាមផ្លូវលំហូជីមិញដោយរថយន្តកុម្ម៉ង់កា (Command Car) ។ រយៈពេលពេញមួយខែដែលព្រះអង្គយាងពីកន្លែងមួយទៅកន្លែងមួយនៅក្នុងភាគខាងជើង និងត្បូងសានប្រទេស ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យចោទប្រកាន់វៀតណាមថា មានបំណង«បំផ្លាញរដ្ឋអំណាចខ្មែរក្រហមតាំងពីមិនទាន់កើតម្ល៉េះ» ។ សុន សេន បានបន្ទោសកងទ័ពវៀតណាមថា បានចូលឆក់ប្លន់អ្នកស្រុកកម្ពុជា រំលោភប្រពន្ធរបស់ពួកគេ តាំងមូលដ្ឋានទ័ពក្នុងប្រទេសដោយគ្មានការអនុញ្ញាត ជ្រើសរើសប្រជាជនខ្មែរឲ្យធ្វើជាទ័ពជំនួយសម្រាប់កងទ័ពវៀតណាម និងកេងបន្លំសម្ភារយោធារបស់ចិនដែលផ្តល់មកឲ្យកម្ពុជា ។ ចំណែក ខៀវ សំផន បានទូលថ្វាយ ព្រះអង្គថា វៀតណាមបានប្រុងប្រៀបខ្លួនបង្កើតរដ្ឋាភិបាលក្លែងក្លាយមួយរបស់កម្ពុជានៅផ្ទាល់នឹងកន្លែង ដែលតាមពិតស្ថិតនៅក្រោមអំណាចប្រទេសវៀតណាមទាំងស្រុង ។

នៅពេលដែលសម្តេច សីហនុ រកឃើញអាថ៌កំបាំងរបស់ដែលហៅថា «ការរួមគំនិត»រវាងពួកវៀតណាមនិងកម្ពុជា ប៉ុល ពត និងបណ្តាមិត្តរបស់គាត់ដែលដើរតាមលំអានរបស់សម្តេចតាំងពីព្រះរាជអំណាចក្រមានតែស្រមោល បានកត់សម្គាល់ថា ប្រជាប្រិយភាពរបស់មហាក្សត្រដែលធ្លាក់ពីតំណែងនៅស្អាតបរិសុទ្ធគ្មានស្រកស្រុតឡើយ ។ ថ្វីបើមានកងទ័ពរាយការពារជុំវិញព្រះអង្គក្នុងពេលដែលព្រះអង្គជួបប្រាស្រ័យទាក់ទងដ៏កម្រមានជាមួយប្រជារាស្ត្រក៏ដោយ ក៏ភក្តីភាព និងការរំភើបចិត្តដែលអ្នកទាំងនោះបង្ហាញឲ្យឃើញ គឺពិតជាមិនអាចបដិសេធបាន ។ សម្តេច សីហនុ ស្ទើរតែមិនទាន់បញ្ចប់ទស្សនកិច្ចស្រួលបួលផង ក្រុមប៉ុលពតបានផ្តើមយុទ្ធនាការនិយាយបង្កាច់សំអុយមួយប្រឆាំងនឹងព្រះអង្គភ្លាម ហើយបង្កើនកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើងថែមទៀតដើម្បីកម្ចាត់ឥទ្ធិពលរបស់វៀតណាម ។ ពួកកម្មាភិបាលខ្មែរក្រហមដែលធ្លាប់ចូលរួមធ្វើសកម្មភាពនយោបាយក្នុងចំណោមមហាជន ក្នុងឋានៈជាអ្នកនាំពាក្យសីហនុនិយមតាំងពីយូរមកហើយ បានចាប់ផ្តើមលែងលាក់លៀមទឹកចិត្តពិតប្រាកដរបស់ខ្លួន ហើយនិយាយបរិហារសម្តេចក្នុងការប្រជុំជាសាធារណៈផ្សេងៗ ។ នៅឆ្នាំ១៩៧៣ ស្ត្រីអ្នកភៀសខ្លួនម្នាក់បានរៀបរាប់ថា «កាលមុនខ្មែរក្រហម មានបំណងចង់ឲ្យយើងនិយាយដដែលៗថា «យើង

ត្រូវការសម្ដេច សីហនុ» ប៉ុន្តែបច្ចុប្បន្នលែងមានទៀតហើយ ។ «កាលមុនអ្នកអាចនិយាយអ្វីៗពីសម្ដេច សីហនុ តាមតែចិត្តអ្នកចង់ ប៉ុន្តែនៅពេលនេះ គេថែមទាំងហាមមិនឲ្យតាំងព្រះឆាយាលក្ខណ៍របស់ព្រះអង្គថែមទៀត» ។ នាងបានប្រាប់ឲ្យដឹងទៀតថា គ្មានអ្នកណាម្នាក់ហ៊ានសាកសួរពីបញ្ហាអ្វីឡើយ ពីព្រោះប្រការនេះមានន័យថា សេចក្ដីស្លាប់[៣៦] ។ ពួកគេបានប្រុងប្រៀបរួចជាស្រេចនូវថ្ងៃដែលបក្សទទួលបន្ទុកកាន់កាប់ប្រទេសក្នុងដៃ គឺពុំមែនសម្ដេច សីហនុ ទេ ។ នៅដើមរដូវក្ដៅឆ្នាំ១៩៧៣ កម្មសិទ្ធិដីធ្លីឯកជន និងការប្រើប្រាស់ក្រដាសប្រាក់ត្រូវបានលុបបំបាត់ចោលដើម្បីពង្រឹងការគ្រប់គ្រងដែនដីនិងសេដ្ឋកិច្ចរបស់បក្ស ។ សហករណ៍ផលិតកម្មជាច្រើនត្រូវបានបង្កើតឡើង ។ ចំណែកពួកអ្នកជំនួញ និងអ្នកនេសាទសញ្ជាតិវៀតណាមត្រូវគេបណ្ដេញចេញពីប្រទេស ។ វៀតណាមដែលសម្រេចចិត្តស្ថិតនៅក្នុងប្រទេសត្រូវបានប្រមូលផ្ដុំឲ្យរស់នៅក្នុងសហករណ៍នានាដែលតាមបន្ទូលអះអាងរបស់សម្ដេច សីហនុ ថា ៖ «សហករណ៍ទាំងនោះ បានប្រែក្លាយទៅជាជំរំប្រមូលផ្ដុំយ៉ាងឆាប់រហ័ស» ។

នៅចុងឆ្នាំ១៩៧៣ រឿងដំណាលផ្សេងៗស្ដីពីការប្រឈមមុខដោយអាវុធរវាងខ្មែររំដោះ និងពួកខ្មែរក្រហមបានផ្ដើមលេចឮសុសសាយ ។ ដូច្នេះ វាទំនងថា ការបាញ់កាំភ្លើងតគ្នាបានកើតមាននៅខេត្តកណ្ដាលក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៣ បន្ទាប់ពីការបដិសេធរបស់ខ្មែររំដោះដែលមិនប្រតិបត្តិតាមការបង្គាប់បញ្ជាដាច់ខាតរបស់ខ្មែរក្រហមដែលឲ្យបញ្ឈប់សហប្រតិបត្តិការទាំងអស់ជាមួយវៀតកុង និងវៀតណាមខាងជើង ។ លោក ខេន ឃ៊ីន មន្ត្រីបំពេញមុខងារនៅស្ថានកុងស៊ុលអាមេរិកាំងប្រចាំទីក្រុងកងថី បានវាយទូរលេខទៅក្រុងវ៉ាស៊ីនតោន នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៤ថា «ខ្មែររំដោះដែលគាំទ្រដោយទ័ពវៀតកុង-វៀតណាមខាងជើងមួយកងឯកភាពបានសម្លាប់ខ្មែរក្រហម៤២នាក់ និងបង្ខំឲ្យអ្នកឯទៀតរត់ដកថយអស់ ។ តាំងពីពេលនោះមកខ្មែរក្រហម និងខ្មែររំដោះបានចាប់ផ្ដើមលួចវាយឆ្មក់ក្នុងទឹកដីរៀងខ្លួនរបស់ពួកគេទៅវិញទៅមក»[៣៧] ។

នៅឆ្នាំ១៩៧៤ ដោយធ្វើឲ្យមានស្ថិរភាពក្នុងការដាក់ឲ្យអនុវត្តវិធានការផ្នែកសេដ្ឋកិច្ចដាច់ខាត សមូហភាវូបនីយកម្មផ្នែកកសិកម្ម និងការលុបបំបាត់ផ្នែកពាណិជ្ជកម្ម-ខ្មែរក្រហមបានចាប់ផ្ដើមធ្វើការកម្ចាត់បក្ខពួកប្រឆាំងជាលើកដំបូងរបស់ខ្លួន ទោះជាមិនមែន ឬគ្រាន់តែសង្ស័យក៏ដោយ ។ នៅខែសីហា ឆ្នាំដដែល នៅភាគខាងកើតកម្ពុជា កម្មាភិបាលចំនួនចិតសិបមួយនាក់ដែលបណ្ដុះបណ្ដាលដោយក្រុងហាណូយ បានត្រូវហៅមកប្រជុំធ្វើ«ការរៀនសូត្រ»មួយ ដែលក្នុងឱកាសនោះគេបានស្ដីបន្ទោសពួកនោះយ៉ាងខ្លាំង ព្រោះតែគេចខ្លួនទៅរស់នៅប្រទេសវៀតណាម ។ ក្នុងចំណោមនោះ មានដប់នាក់ត្រូវបាត់ខ្លួន ។ អ្នកដទៃទៀតត្រូវបញ្ជូនឲ្យទៅធ្វើស្រែក្រោមការតាមឃ្លាំមើលជាប់ ។ ប្រហែលមានតែម្នាក់គត់ដែលរួចផុតគ្រោះថ្នាក់ដល់ជីវិតគឺ ហែម សាមិន ដោយបានសម្រេចចិត្តរត់ភៀសខ្លួនទៅដល់ប្រទេសវៀតណាមវិញ ។ នៅភូមិភាគនិរតីក្នុងចំណោមកម្មាភិបាលមួយរយនាក់ ដែលទើបត្រឡប់មកពីវៀតណាម គឺមានកម្មាភិបាលចំនួនកៅសិបនាក់ទៅហើយ ដែលត្រូវសម្លាប់នៅខែកញ្ញា ឆ្នាំ១៩៧៤[៣៨] ។ ក្នុងចំណោមអ្នកដែលរត់រួចពីសេចក្ដីស្លាប់មាននៅតែម្នាក់ដែរគឺ យស់ ប៉ោ ។

ក្រោយមក សាមិន និង ប៉ោ បានក្លាយជាមេដឹកនាំរណសិរ្ស ដែលគាំទ្រដោយក្រុងហាណូយនិងដឹកនាំចលនានេះប្រឆាំង ប៉ុល ពត វិញ ។

កិច្ចព្រមព្រៀងក្រុងប៉ារីស នៅឆ្នាំ១៩៧៣ ក៏កំណត់ផងដែរនូវការចាប់ផ្ដើមធ្វើការវាយប្រហាររបស់ខ្មែរក្រហមប្រឆាំងនឹងកន្លែងស្តុកអាវុធ មន្ទីរពេទ្យ និងជំរំបោះទ័ពនានារបស់វៀតណាមនៅលើទឹកដីកម្ពុជា ដែលក្រុម ប៉ុល ពត ប្រើងប្រែងបង្ហាញឲ្យឃើញភ័ស្តុតាងដោយចោទប្រកាន់ពីការមិនយល់និងភាពគ្មានវិន័យរបស់អ្នកប្រតិបត្តិជាកូនទាហានសាមញ្ញគ្មានឋានន្តរស័ក្តិ ។ អ្នកឆ្លើយឆ្លងព័ត៌មានពីរនាក់នៃទីភ្នាក់ងារព័ត៌មានវៀតណាមបានត្រូវសម្លាប់“ដោយការភ័ន្តច្រឡំ” នៅពេលដែលពួកគេទៅលេងខេត្តកំពង់ចាមក្នុងខែតុលា ។ នៅខែកុម្ភៈឆ្នាំ១៩៧៥ ក្រុមសិល្បៈមួយទាំងមូលនៃរណសិរ្សរំដោះជាតិដែលមកពី មី ថ (*My Tho*) បានត្រូវសម្លាប់រង្គាលក្នុងការពួនស្ទាក់មួយពេលកំពុងឆ្លងកាត់ទឹកដីកម្ពុជា នៅពេលដែលក្រុមនេះ ធ្វើដំណើរទៅកាន់តំបន់រំដោះទាំងឡាយរបស់ខេត្តតាយនិញវិញ ។ ដោយឆ្លើយតបទៅនឹងការស្នើឲ្យមានការពន្យល់បញ្ហានេះពីសំណាក់ពួកមេដឹកនាំវៀតកុង កម្ពុជាបានអះអាងថា ឧបទ្ទវហេតុគួរឲ្យសោកស្ដាយនេះ គឺជាអំពើរបស់ក្រុមជនដែលគេមិនអាចត្រួតត្រាបាន ។ តាម ត្រាន់ ថាញ់ស៊ិន់ អនុប្រធានទីភ្នាក់ងារព័ត៌មានវៀតណាមថា នៅឆ្នាំ១៩៧៣ យ៉ាងហោចគ្មានអ្នកទទួលខុសត្រូវណាម្នាក់ដែលមានឋានៈស្មើគាត់ជឿថា ការសម្លាប់រង្គាលប្រជាជនវៀតណាមទាំងនេះជាការទទួលខុសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ ។ គាត់និយាយថា “យើងចាត់ទុករឿងទាំងនេះជាការខូចខាតមួយដែលមិនអាចចៀសផុតនៅពេលមានសង្គ្រាម” ។ ក៏ប៉ុន្តែវាពិបាកទទួលស្របដែរថា ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមពុំបានទទួលព័ត៌មានពិតប្រាកដពីរឿងនេះទេ ។ ប៉ុន្តែ ក្រុងហាណូយធ្វើហាក់ដូចជាព្រមទទួលនូវការពន្យល់របស់ខ្មែរក្រហមនេះ ព្រោះមិនចង់ធ្វើឲ្យមានជម្លោះជាមួយ ប៉ុល ពត ក្នុងពេលដែលទីជម្រកទាំងឡាយក្នុងទឹកដីកម្ពុជានៅតែចាំបាច់សម្រាប់ខ្លួននៅឡើយ ។ ម្យ៉ាងទៀត វៀតណាមជឿថា ទីបំផុត “មាគ៌ាដ៏ត្រឹមត្រូវ”មួយមុខជាផុសឡើងនៅកម្ពុជាប្រឆាំងនឹងលទ្ធិជាតិនិយមចង្អៀតចង្អល់របស់ ប៉ុល ពត មិនខាន ។ ភារកិច្ចសំខាន់របស់ក្រុងហាណូយ គឺរំដោះភាគខាងត្បូងដោយមិនជំរុញឲ្យការវិវាទដែលខ្លួនកំពុងប្រឈមមុខនឹងសម្ព័ន្ធមិត្តមានចិត្តមិនទៀងឡើងដល់កម្រិតខ្ពស់មួយឡើយ ។ ដូច្នេះបើទុកជាមានភាពតានតឹងដែលកាន់តែរីកធំឡើងៗរវាងប្រទេសទាំងពីរក៏ដោយ ក៏វៀតណាមនៅតែបន្ត“គោរពការព្រមព្រៀងគ្នា”តទៅទៀតដែរ ។ ដោយឆ្លើយតបទៅនឹងសំណើមួយរបស់ខ្មែរក្រហម វៀតណាមបានសម្រេចបញ្ជូនកងឯកភាព វិស្វកម្ម និងកងកាំភ្លើងធំជាច្រើនទៅកាន់កម្ពុជាដើម្បីជួយប្រឫបាច់-ក ក្រុងភ្នំពេញឲ្យស្លាប់នៅទីកផ្ដាច់ព្រ័ត្រ ។

ប៉ុល ពត ផ្ទាល់ក៏ប្រឹងប្រែងថែទាំ“លក្ខណៈមានតែសំបកក្រៅ” ឲ្យនៅដដែលដែរ ។ នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៤ ក្នុងលិខិតថ្លែងអំណរគុណមួយចំពោះបក្សកុម្មុយនីស្តវៀតណាម គាត់បានសង្កត់បញ្ជាក់ថា “ជ័យ

ជម្នះទាំងឡាយដែលកងទ័ពវៀតណាមដណ្តើមបានគឺជាស្នាដៃនៃសាមគ្គីភាព និងការជួយឧបត្ថម្ភគ្នាទៅវិញទៅមករវាងបក្ស និងប្រជាជននៃប្រទេសយើងទាំងពីរ» ។ សម្តីទាំងអស់នេះត្រូវបានអះអាងបន្ទាប់ពីការបណ្តេញជនជាតិវៀតណាមរាប់ពាន់នាក់ចេញពីកម្ពុជា បន្ទាប់ពីការសម្លាប់ពួកកម្មាភិបាលដែលបណ្តុះបណ្តាលនៅក្រុងហាណូយ និងបន្ទាប់ពីការវាយប្រហារមូលដ្ឋានទ័ពនានារបស់វៀតណាម ក្នុងទឹកដីកម្ពុជារួចមក ។ ក្នុងផ្នែកនៃការឆ្លើយឆ្លងគ្នាតាមសំបុត្រដែលសរសេរដោយប្រើសញ្ញាសម្ងាត់នេះ គេអាចទាញហេតុជាសំអាងជាពិសេសការសន្យាយ៉ាងឱឡារិករបស់ ប៉ុល ពត ចំពោះ ឡេ ឌឹកថូ នូវឃ្លាថា «ដោយការគោរពយ៉ាងស្មោះស្ម័គ្រនិងអស់ពីដួងចិត្ត»ដែលគាត់នៅតែគោរពដោយខ្ជាប់ខ្ជួនចំពោះមាគ៌ា «សាមគ្គីភាពដ៏ជិតស្និទ្ធ និងមិត្តភាពជាបងប្អូន និងបដិវត្តរវាងប្រទេសកម្ពុជានិងវៀតណាម»ជានិច្ច[៣៩] ។ ទាំងស្ថិរភាពផ្នែកកម្លាំងក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជា ទាំងស្ថានការណ៍ជាតិនិងអន្តរជាតិនៅពុំទាន់ធ្វើឲ្យមានការប្រឈមមុខមួយដោយផ្ទាល់ជាមួយវៀតណាមនៅឡើយទេ ។ គេគោងតែរង់ចាំបីឆ្នាំថែមទៀត ។

# ជំពូកទី៣
# មនុស្សម្នាក់ឈ្មោះ ប៉ុល ពត ដែលគេមិនដែលស្គាល់សោះ

ព្រឹត្តិការណ៍មួយដែលហាក់ដូចជារន្ទះបាញ់កណ្ដាលថ្ងៃចែសបានមកដល់ អៀង សារី ឧបនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ៩៧៦ ។ ក្នុងដំណើរត្រឡប់ពីក្រុងញូវយ៉កមកវិញ បន្ទាប់ពីការហោះហើរមួយដែលធ្វើឲ្យអស់កម្លាំង អៀង សារី ដែលទើបមកដល់និវេសនដ្ឋានរបស់គាត់នៅទីក្រុងបែលហ្គ្រាដ (Belgrade) ស្ទើរតែមិនទាន់ស្រួលបួលផង ស្រាប់តែលោក ឌុយសាន ហ្កាសប៉ារី ប្រធាននាយកដ្ឋានអាស៊ីនៃទីស្ដីការក្រសួងការបរទេសយូហ្គោស្លាវី ដែលជាអ្នកទាក់ទងសំខាន់បំផុតរបស់គាត់នៅទីក្រុងបែលហ្គ្រាដ បានដើរចូលមកក្នុងបន្ទប់ទទួលភ្ញៀវដោយបញ្ចេញទឹកមុខគួរឲ្យខ្លាច ។ ហ្កាសប៉ារី បានប្រាប់ដំណឹងថា "ឯកឧត្ដម! ខ្ញុំបានទទួលការណែនាំឲ្យផ្ដល់ព័ត៌មានប្រាប់លោកអំពីការវិវត្តនៃស្ថានការណ៍ចុងក្រោយនេះនៅប្រទេសចិន ។ រដ្ឋមន្ត្រីការបរទេសចិនទើបនឹងអះអាងពីការចាប់ខ្លួនលោកស្រីចាង ឈិញ, ហ្សាងជុនជីវ, យ៉ាវវ៉ិនយន់ និង វ៉ាងហុងវេន ពីបទធ្វើសកម្មភាពប្រឆាំងបក្សនិងរដ្ឋ" ។ ក្រោយមក ហ្កាសប៉ារី បានរៀបរាប់ថា ពេលនោះឈាមបានច្រាលក្រហមពេញផ្ទៃមុខដែលស្រឡាំងកាំងរបស់ សារី មួយរំពេច ៖ "ទេ! វាពុំអាចទៅជាដូច្នេះទេ អ្នកទាំងនោះសុទ្ធតែជាសមាសភាពដ៏ល្អ ។ សារី ពោលរអ៊ូតិចៗដោយសំឡេងមួយដែលគេស្ដាប់សឹងតែមិនឮ"[១] ។

តាំងពីសរទរដូវឆ្នាំ១៩៧១ ជាកាលបរិច្ឆេទដែលគាត់ស្ថិតនៅក្រុងប៉េកាំងក្នុងឋានៈជាតំណាងបក្សកុម្មុយនីស្តកម្ពុជាអមបក្សកុម្មុយនីស្តចិន សារី បានចងមិត្តភាពជាមួយពួកវ៉ាឌីកាល់ជាច្រើននាក់ ។ ពួកយុវជន និងអ្នកដែលរីករាយខ្លាំងបានក្លាយទៅជាមនុស្សសំខាន់នៅសម័យបដិវត្តន៍វប្បធម៌ដ៏ច្របូកច្របល់ក្នុងពេលដែល ម៉ៅ ជំរុញឲ្យពួកឆ្មាំក្រហម"បំបាក់មុខពួកវរជន"របស់បក្សកុម្មុយនីស្តចិន និងបោសសម្អាតគុណវិបត្តិផ្សេងៗនៃលទ្ធិសេរីនិយម ។ ជាពិសេស យ៉ាវ វ៉ិនយន់ ដែលជាមិត្តដ៏ជិតស្និទ្ធបំផុតរបស់ សារី ។ យ៉ាវ ជាអ្នកនិពន្ធខាងអក្សរសាស្ត្រនៃក្រុងស៊ាងហៃដែលគេមិនសូវស្គាល់ បានក្លាយទៅជាសមាជិកការិយាល័យនយោបាយ នៅឆ្នាំ១៩៦៤ ។ គាត់មានគំនិតមិនចូលចិត្ត (ស្អប់ដោយមិនដឹងរឿងអ្វី) ចំពោះ សម្ដេច សីហនុ ដូចមេដឹកនាំខ្មែរក្រហមដែរ ដោយពួកនេះចាត់ទុកសម្ដេចជាមនុស្ស"ប្រតិកិរិយាតាំងពីជើងរហូតដល់ក្បាល"[២] ។ ចំពោះ សារី មិត្តភាពនេះមានសារសំខាន់មែនទែន ពីព្រោះដោយពិត យ៉ាវ មានមុខនាទី ដឹកនាំគណៈកម្មាធិការកិច្ចការបរទេសនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន ។ ពួកមេដឹកនាំខ្មែរក្រហមដឹងថា ទិសដៅឆ្វេងជ្រុលរបស់ខ្លួនត្រូវបានធានាអះអាងដោយការគាំទ្ររបស់ចិន លុះត្រាណា យ៉ាវ និងបក្សពួកដែលមានគំនិតដូចគ្នា នឹងនៅតែស្ថិតក្នុងមុខតំណែង ។

អាស្រ័យហេតុនេះ ទើបក្រោយពីនោះបន្តិច សារី គោងតែស៊ើបឲ្យដឹងពីរឿងចាប់ខ្លួនបណ្ដាមិត្តភក្តិដ៏ជិតស្និទ្ធ និងយុទ្ធិកជនរបស់គាត់ដែលកើតឡើងពីរថ្ងៃក្រោយការចេញដំណើររបស់គាត់ពីក្រុងប៉េកាំងទៅក្រុង

ញូវយ៉ក ជាទីដែលគាត់ត្រូវថ្លែងការណ៍ក្នុងឱកាសមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិ ។ ក្នុងរាត្រីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ គឺបីសប្តាហ៍ក្រោយមរណភាពរបស់ប្រធាន ម៉ៅ កងឯកភាពយោធាពិសេសលេខ២៣៤១ ដែលដឹកនាំដោយអតីតអង្គរក្សរបស់ ម៉ៅ គឺ វ៉ាំងដុងស៊ីង បានធ្វើការសម្រុកចូលរហ័សដូចផ្លេកបន្ទោរដើម្បីចាប់ខ្លួនប្រពន្ធមេម៉ាយរបស់ ម៉ៅ និង អ្នកជិតស្និទ្ធទាំងបីរបស់គាត់ ។ ឈ្មោះរបស់អ្នកទាំងនេះបានត្រូវដាក់បញ្ចូលដោយបង្រួមតែមួយក្នុងសន្ទានុក្រមនយោបាយរបស់ចិនក្រោមការហៅថា “បន៤នាក់” ។ នាយករដ្ឋមន្ត្រីស្តីទី ហ្វា គួហ្វេង និងរដ្ឋមន្ត្រីការពារប្រទេសសេនាប្រមុខ យេ ជានយីងដែលសុទ្ធតែជាជើងចាស់នៃបដិវត្តន៍ បានរៀបចំប្រតិបត្តិការមួយជាមួយ វ៉ាំង និងត្រួតពិនិត្យដោយខ្លួនគាត់ផ្ទាល់ យ៉ាងហោចការចាត់ការរបស់គាត់ទៅលើការផ្តាច់ចរន្តអគ្គិសនីសម្រាប់ស្ថានីយ៍ទូរទស្សន៍ដែរ ។

ប៉ុន្តែទាំងក្នុងឱកាសនៃការឈប់សំចតបីថ្ងៃនៅទីក្រុងប៉េកាំង ទាំងក្នុងការជួបពិភាក្សានៅអង្គការសហប្រជាជាតិជាមួយសមភាគីរបស់គាត់គឺ ជាវ ហួនហ្វា សារី ពុំមានការសង្ស័យបន្តិចសោះឡើយ នូវការឃុបឃិតក្បត់នៅប៉េកាំង ។ ពីរថ្ងៃមុនគាត់ចាកចេញពីក្រុងញូវយ៉កទៅកាន់ទីក្រុងបែលហ្ក្រាដ គាត់ត្រូវបានអញ្ជើញជាភ្ញៀវកិត្តិយសចូលរួមពិធីជប់លៀងមួយដែលរៀបចំឡើងដោយ ជាវ ប៉ុន្តែថ្វីដ្បិតតែ ជាវ មានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយពួករ៉ាឌីកាល់ក៏ដោយ ក៏គាត់គ្មានប្រើពាក្យបញ្ឆិតបញ្ឆៀងពីរឿងនោះដែរ ។ ភ្លាមនោះដីនៅក្រោមជើង សារី ហាក់ដូចជាស្រុតចុះ ។

នៅក្នុងឱកាសនៃការស្នាក់អាស្រ័យចុងក្រោយរបស់គាត់នៅប្រទេសចិន សារី ពិតជាដឹងតាមរយៈចាងឈីង ថា ពួករ៉ាឌីកាល់លែងមានភ័ព្វសំណាងទៀតហើយ ថ្វីបើពួកគេជាមនុស្សជិតស្និទ្ធបំផុតនឹង ម៉ៅ ដែលពេលនោះជិតស្លាប់ទៅហើយក៏ដោយ ។ បន្ទាប់ពីមរណភាពរបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៅខែមករា ឆ្នាំ១៩៧៦ ពួកគេបានប្រឹងប្រែងស្វែងរកការគាំទ្រពី ម៉ៅ ដើម្បីកម្ចាត់ការឡើងស្នងតំណែងរបស់មនុស្សដែល ជូ គាំពារគឺអ្នកប្រតិបត្តិនិយម តេង ស៊ាវពីង ។ ប៉ុន្តែ ប្រាកដណាស់ លោកប្រធាន ម៉ៅ មិនចង់ឲ្យចាងឈិញ និងក្រុមរបស់នាងឡើងមកជំនួសឡើយ ។ គឺហេតុនេះហើយបានជាគាត់ជ្រើសរើសមន្ត្រីបក្សម្នាក់ឈ្មោះ ហ្វា គួហ្វេង ដែលគេស្គាល់ច្បាស់ពីសមានចិត្តឆ្វេងនិយមរបស់គាត់ឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីជាជាងយកហ្សាង ជុនជាវ ដែលជាអ្នកទ្រឹស្តីឆ្នើមជាងគេរបស់ពួករ៉ាឌីកាល់ ។ រហូតមកដល់ពេលនេះ ហ្វា មានមុខតំណែងជារដ្ឋមន្ត្រីសន្តិសុខសាធារណៈ[៣] ។ បន្ទាប់ពីមរណភាពរបស់ ម៉ៅ គាត់បានឡើងឋានៈពីរក្រឹតទៀត ហើយបានក្លាយទៅជាប្រធានបក្ស ។ ខ្មែរក្រហម និង ប៉ុល ពត ជាពិសេស អៀង សារី បានតាមពិនិត្យមើលដំណើរមានគគ្រាហូរហែនៃព្រឹត្តិការណ៍ទាំងឡាយនៅប្រទេសចិនទាំងចិត្តព្រួយបារម្ភដោយខ្លាចក្រែងពួកនេះមានទំនោរទៅរកពួកស្តាំនិយម ។ មុននឹងចាកចេញពីភ្នំពេញទៅកាន់ក្រុងញូវយ៉កនៅថ្ងៃទី៣០ ខែកញ្ញា សារី បានជួយព្រាងធ្វើលិខិតអបអរសាទរមួយផ្ញើជូននាយករដ្ឋមន្ត្រីស្តីទី ហ្វា គួហ្វេង ក្នុងឱកាសបុណ្យជាតិរបស់ចិនដែរ ។ អ្វីដែល

*មានលក្ខណៈសំខាន់បំផុតគឺ សារលិខិតនេះបានថ្លែងសរសើរបដិវត្តវប្បធម៌និងរបៀបដែលបក្សកុម្មុយនីស្តចិនសម្រេចបានជោគជ័យក្នុងការកម្ទេច «សេនាធិការប្រឆាំងសង្គមនិយម និងប្រឆាំងបដិវត្តរបស់ លីវ ចាវជី និង តេង ស៊ាវពីង» ។ តាមការអះអាងរបៀបមិនច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជានឹងស្វាគមន៍ ហួរ ដោយពេញចិត្តក្នុងករណីដែលគាត់ដើរតាមបន្ទាត់នយោបាយរបស់ក្រុមបដិវត្តឆ្វេងនិយម ។*

*ក៏ប៉ុន្តែវាច្បាស់ណាស់ថា រដ្ឋប្រហារនៅក្រុងប៉េកាំងដែលធ្វើបានសម្រេចដោយគ្មានបង្ហូរឈាមបានបណ្តាលឲ្យមានការគិតស្មានទុកជាមុននូវការប្តូរទិសមួយទៅរកស្តាំនិយមវិញ ហើយប្រហែលជាមានការវិលត្រឡប់មកវិញរបស់ តេង ផងដែរ ដែលធ្លាប់រងគ្រោះពីការបោសសម្អាតចំនួនពីរដងរួចមកហើយ ។ ឥរិយាបថចម្លែកខុសពីធម្មតារបស់ សារី ក្នុងអំឡុងជាច្រើនសប្តាហ៍បន្តបន្ទាប់មកទៀត បានបង្ហាញឲ្យឃើញច្បាស់ជាពិសេសនូវការព្រួយបារម្ភរបស់គាត់ចំពោះមុខការរីករាលដាលនៃស្ថានការណ៍នៅប្រទេសចិន ។ តាមទីភ្នាក់ងារព័ត៌មានរបស់ រូម៉ានី និងចិនបានឲ្យដឹងថា ក្រោយពីការឈប់សំចតយ៉ាងខ្លីនៅប្រទេសរូម៉ានី និងយូហ្គោស្លាវី មេដឹកនាំខ្មែរក្រហមបានចាកចេញពីទីក្រុងប៊ុយការ៉េស (រដ្ឋធានីប្រទេសរូម៉ានី) នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៦ ។ តមកទៀត ស្រាប់តែបាត់មុខលែងឃើញ ទាល់តែ២៥ថ្ងៃក្រោយមកទៀត ទើបលេចមុខគាត់ជាថ្មីនៅក្រុងភ្នំពេញ ។ តាមធម្មតា គាត់ត្រូវជិះយន្តហោះមួយគ្រឿងរបស់ក្រុមហ៊ុន Tarom របស់រូម៉ានី ឆ្ពោះមកក្រុងប៉េកាំង សិនជាកន្លែងដែលគាត់ត្រូវរង់ចាំជើងយន្តហោះរបស់ចិន ដែលរ៉ាប់រងការហោះហើរមកក្រុងភ្នំពេញ២ជើងក្នុងមួយខែ ។ គ្រប់ការឈប់សំចតនៅប្រទេសចិន សារី តែងតែត្រូវបានទទួលនៅអាកាសយានដ្ឋានដោយអនុរដ្ឋមន្ត្រីការបរទេសម្នាក់តាមទម្លាប់ដូចសព្វដងជានិច្ច ។ ប្រសិនបើការឆ្លងកាត់មានរយៈពេលលើសពីមួយថ្ងៃ មានសមាជិកការិយាល័យនយោបាយម្នាក់ជាអ្នករៀបចំពិធីជប់លៀងជាកិត្តិយសជូនគាត់ ។ ការសម្តែងនូវភាពរាក់ទាក់ទាំងនេះ សុទ្ធតែត្រូវបានប្រកាសផ្សាយជាសាធារណៈ ដោយទីភ្នាក់ងារព័ត៌មានចិនថ្មី ។ តែថាលើកនេះ ទាំងសារព័ត៌មានចិន ទាំងសារព័ត៌មានកម្ពុជា ពុំមានលើកយកមកនិយាយពីទីកន្លែងដែល សារី ស្ថិតនៅឡើយតាំងពីការចេញដំណើររបស់គាត់ពីទីក្រុងប៊ុយការ៉េស មក ។ នៅទីបំផុតវិទ្យុក្រុងភ្នំពេញបានប្រកាសផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៦ថា គាត់ទើបនឹងបានទទួលសារតាំងពីឯកអគ្គរដ្ឋទូតបរទេសបីនាក់ ។ សេចក្តីបញ្ជាក់ដែលធ្វើឡើងជាផ្លូវការក្នុងការតែងតាំងរដ្ឋមន្ត្រីការពារប្រទេស សុន សេន ឲ្យធ្វើជារដ្ឋមន្ត្រីការបរទេសស្តីទីរហូតដល់ថ្ងៃទី៨ ខែវិច្ឆិកា នោះ សបញ្ជាក់ឲ្យឃើញថា សារី ពុំបានចូលកាន់តំណែងរបស់គាត់វិញទេមុនកាលបរិច្ឆេទនេះ[៤] ។*

*តើគាត់នៅឯណា? ជាសំណួរដែលខ្ញុំសួរភរិយា អៀង សារី គឺ អៀង ធីរិទ្ធ ជាច្រើនឆ្នាំក្រោយមកទៀត ។ យុវជនទាំងពីរនាក់នេះបានជួបគ្នានៅពេលដែលពួកគេសិក្សានៅទីក្រុងប៉ារីស ។ ក្នុងពេលជាមួយគ្នានោះ ប៉ុល ពត បានចាប់ចិត្តស្រឡាញ់បងស្រីរបស់ ធីរិទ្ធ គឺ ខៀវ ប៉ុណ្ណារី ដែលជានិស្សិតនៅប៉ារីសដែរ ។ មិនយូរ*

ប៉ុន្មាន បងប្អូនស្រីទាំងពីរព្រមទាំងស្វាមីរបស់ពួកគេបានក្លាយទៅជាគូស្វាមីភរិយាដ៏មានអំណាចបំផុត របស់ប្រទេសដូចដែល សម្តេច សីហនុ បានមានបន្ទូលថា “បន៤នាក់នៃកម្ពុជា”ដែរ ។ ចម្លើយដ៏សោះកក្រោះរបស់ ធីរិទ្ធ ចំពោះសំណួររបស់ខ្ញុំ មានសភាពហាក់ដូចជានាងគ្មានដឹងអ្វីបន្តិចសោះ ។ នាងនិយាយថា “លោកឃើញហើយថា ពួកយើងម្នាក់ៗរស់នៅដោយឡែកពីគ្នា” ។ ព័ត៌មានទាំងអស់ដែលយើងមានបញ្ជាក់ឲ្យឃើញថា សារី បានស្នាក់នៅប្រទេសចិនយ៉ាងហោចណាស់ក៏បីសប្តាហ៍ដែរ ។ ការនៅស្ងៀមស្ងាត់របស់សារព័ត៌មានចិន អាចត្រឹមតែបកស្រាយថា នេះជាការស្នាក់អាស្រ័យតាំងពីដើមមករបស់គាត់ ។ ពេញរយៈពេលនោះ មេដឹកនាំខ្មែរក្រហមរូបនេះទំនងជាផ្ចិតផ្ចង់វាយតម្លៃស្ថានការណ៍ បន្ទាប់ពីមានការភាន់ប្រែផ្នែកនយោបាយដែលទើបនឹងធ្វើឲ្យរង្គោះរង្គើប្រទេសចិន និងចាំទទួលពីពួកមេដឹកនាំថ្មីរបស់ចិននូវការធានាអះអាងថា មរណភាពរបស់ ម៉ៅ និងការបោសសម្អាតពួកវ៉ាឌីកាល់ នឹងមិនធ្វើឲ្យការគាំទ្ររបស់ក្រុងប៉េកាំងចំពោះកម្ពុជាចោទជាបញ្ហាឡើងវិញឡើយ ។

ការព្រួយបារម្ភរបស់ សារី ដែលសំអាងលើហេតុផលមនោគមវិជ្ជាគឺពិតជាត្រឹមត្រូវតាមហេតុផល ។ ក្នុងអំឡុងរយៈពេល-ប្រហែលដប់ឆ្នាំ-ដែលកត់សម្គាល់ដោយបដិវត្តន៍វប្បធម៌ ការតស៊ូដោយអាវុធនៅកម្ពុជា និងការផុសចេញខ្មែរក្រហមនោះ គឺផ្នែកមនោគមវិជ្ជាមានភាពប្រសើរលើសគេទាំងអស់ ។ តើប្រទេសកម្ពុជាអាចសង្ឃឹមលើការគាំទ្ររបស់ប្រទេសចិនមួយ ដែលអំណឹះតទៅកំពុងលម្អៀងទៅស្តាំតាំងពីមានការទាត់ចោលដៃគូផ្នែកមនោគមវិជ្ជារបស់ សារី ដែរទេ? ។ ពួកមេដឹកនាំខ្មែរក្រហមត្រូវតែបង្ហាញឲ្យឃើញដោយឆាប់រហ័សថា ចំពោះរឿងនេះ : ផលប្រយោជន៍ជាតិបានទទួលរងផលអាក្រក់បន្តិចបន្តួចពីផ្នែកមនោគមវិជ្ជា ហើយថាបំណងប្រឆាំងរបស់ចិនចំពោះចេតនាផ្សេងៗរបស់វៀតណាមនិងការរៀបចំទប់ទល់នឹងពួកសូវៀតមានទម្ងន់មួយយ៉ាងសម្បើមជាងខដាក់លក្ខខណ្ឌផ្សេងៗរបស់មេដឹកនាំចិនថ្មីមកលើកម្ពុជារបស់ ប៉ុល ពត ទៅទៀត ។ មុនមួយឆ្នាំ មិត្តភាពចិន-កម្ពុជានឹងត្រូវបញ្ជាក់អះអាងជាថ្មី ហើយនៅទីបំផុត ប៉ុល ពត ដែលចេញពីភាពអនាមិកនឹងរៀបចំដំហានដំបូងលើឆាកអន្តរជាតិរបស់គាត់នៅទីក្រុងប៉េកាំង ។

## ការព្រួយបារម្ភនៅក្រុងភ្នំពេញ

ក្នុងដំណើរត្រឡប់មកវិញរបស់គាត់ បណ្តាសហការីរបស់ សារី ដែលដក់ជាប់ដោយក្តីកង្វល់បានប្រញាប់ប្រញាល់ផ្ញើសារលិខិតអបអរសាទរមួយចំពោះ ហួ ក្នុងឱកាសនៃការតែងតាំងរូបគាត់ជាប្រធានបក្សកុម្មុយនីស្តចិន ។ ភាគច្រើននៃបណ្តាបក្សជាបងប្អូននៅទូទាំងពិភពលោកចូលចិត្តចៀសវាងមិនបង្ហាញឲ្យឃើញសេចក្តីលម្អៀងរបស់ខ្លួនក្នុងជម្លោះផ្ទៃក្នុងរបស់ចិនទេ ។ ពួកគេបានថ្លែងសរសើរ ហួ ដោយមិនលើកនិយាយពីពួករ៉ាឌីកាល់ដែលត្រូវដកហូតអំណាចឡើយ ។ ប៉ុន្តែ សម្រាប់បក្សកុម្មុយនីស្តកម្ពុជាវិញ អ្វីដែលកម្ពុជាត្រូវការការគាំទ្ររបស់ចិន គឺពិតជាមានសារសំខាន់ស្មើអាយុជីវិតក្នុងរយៈពេលដែលអ្នកទាំងនេះ បណ្តោយឲ្យការសង្ស័យ

តិចតួចគ្របដណ្តប់លើភក្តីភាពរបស់គេចំពោះពួកមេដឹកនាំក្រុងប៉េកាំង ។ អាស្រ័យហេតុនេះ សារលិខិតរបស់មេដឹកនាំកម្ពុជាពុំរួញរានឹងលើកសរសើរយ៉ាងកក់ក្តៅចំពោះប្រធានបក្សចិន ដែលបានសម្រេចជោគជ័យក្នុងការ«កម្ទេចក្រុមប្រឆាំងបក្ស និងប្រឆាំងបដិវត្តន៍នៃបន៤នាក់»ឡើយ ។ នេះជាការប្តូរគំនិតភ្លាមៗដ៏គួរឲ្យចម្លែកដោយហេតុថា មុននេះមិនដល់មួយខែផង សារលិខិតដំបូងមួយរបស់ក្រុងភ្នំពេញ បានអះអាងនូវការគាំទ្ររបស់ខ្លួនចំពោះ«ពួកមនុស្សទាំងនោះ» ដែលចិនសន្មតថាជាអ្នកប្រឆាំងបដិវត្តន៍... ។

ដោយប្រឹងប្រែងធ្វើឲ្យក្រុងប៉េកាំងកក់ក្តៅក្នុងចិត្តអំពីការផ្តាច់សម្ពន្ធភាពជាស្ថាពររបស់ពួកមេដឹកនាំកម្ពុជាជាមួយ«បន៤នាក់»រួចហើយ ប៉ុល ពត យល់ឃើញយ៉ាងច្បាស់ចំពោះដំណឹងចុងក្រោយផ្សេងៗ ដែលមានប្រភពមកពីប្រទេសចិនថា ប្រកបដោយគ្រោះថ្នាក់ខ្លាំងណាស់ នៅពេលដែលធ្វើការផ្សព្វផ្សាយក្នុងប្រទេសទោះជាគួរដល់កាលក៏ដោយ ។ គ្មានបញ្ហាព្រមានឲ្យដឹងពីគំនិតមិនសមហេតុផលទាំងឡាយចំពោះអ្នកនៅក្នុងបក្សដែលវាយតម្លៃថា ប៉ុល ពត និង អៀង សារី ធ្វើអ្វីៗជ្រុលហួសក្នុងប្រព័ន្ធនយោបាយមូលវិវដ្តនិយម (Radicalisme) ឡើយ ។ សារលិខិតដែលផ្ញើជូន ហ្វា គួហ្វេង ពុំត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ភ្នំពេញដែលជាប្រភពផ្តល់ព័ត៌មានតែមួយគត់សម្រាប់ប្រជាជនកម្ពុជាដែលរស់នៅរាយប៉ាយតាមជំរំប្រមូលផ្តុំធ្វើការងារនានានិងនៅដាច់ឆ្ងាយគ្នាពីមួយទៅមួយផងទេ ។ តិចជាងមួយសប្តាហ៍មុនការមកដល់របស់គណៈប្រតិភូកាសែតចិនមួយក្រុម ទើបវិទ្យុភ្នំពេញបានផ្សាយនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៦ ឲ្យអ្នកស្តាប់របស់ខ្លួនដឹងពីការតែងតាំង ហ្វា ក្នុងមុខតំណែងនិងការចាប់ខ្លួន«បន៤នាក់» ។ ដំណឹងត្រូវបានផ្សាយ ដោយគ្មានធ្វើការបញ្ជាក់អំពីអត្តសញ្ញាណនៃបណ្តាសមាជិករបស់«បន»នេះបន្តិចសោះឡើយ ទាំងមិននិយាយឲ្យដឹងពីប្រភេទនៃបទឧក្រិដ្ឋរបស់អ្នកទាំងនោះផង ។

ដោយគាប់ជួន គណៈប្រតិភូសេដ្ឋកិច្ចនិងពាណិជ្ជកម្មមួយរបស់កម្ពុជាបានស្នាក់អាស្រ័យនៅប្រទេសចិនដែរ ក្នុងពេលដែលមានការរុះរើថ្នាក់ដឹកនាំរបស់ចិនដ៏គួរឲ្យចង់ដឹងនេះ ។ គណៈប្រតិភូកម្ពុជាបានទទួលពីម្ចាស់ផ្ទះនូវការអះអាងថា «ក្រុងប៉េកាំងនឹងនៅតែជាមិត្តដ៏ទុកចិត្តម្នាក់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាប្រជាធិបតេយ្យជានិច្ចកាល»[៥] ។ ក៏ប៉ុន្តែ លទ្ធផលអវិជ្ជមានដែលគេមិនអាចប្រមាណដឹងមុនក្នុងការ«បត់ទៅស្តាំ» ដែលចាប់ផ្តើមដោយប្រទេសចិនមកលើកម្រិតនៃជំនួយរបស់ខ្លួនមកឲ្យកម្ពុជា ហើយលើសពីនេះទៀត មកលើផ្លូវចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជា បានធ្វើឲ្យ ប៉ុល ពត ព្រួយបារម្ភយ៉ាងជាក់ច្បាស់ ។ អំណឹះតទៅនៅគ្រប់កាលៈទេសៈកម្ពុជាតែងតែក្រើនរំឭកឲ្យប្រទេសចិនដឹងថា សមិទ្ធផលរបស់បដិវត្តន៍វប្បធម៌និយាយម្យ៉ាងទៀតគឺវិធានការឆ្វេងជ្រុលហួសហេតុទាំងប៉ុន្មាន ដែលចិនប្រកាន់យកនៅចន្លោះឆ្នាំ១៩៦៦ និង១៩៧១ ត្រូវតែការពារឲ្យបាននិងពង្រីកថែមទៀត ហើយថា ការតស៊ូវណ្ណៈបានបង្កបង្កើតជា«កងប្រវាក់មួយ ដែលនាំទៅរកលទ្ធផលចុងក្រោយ»ក្នុងការកសាងប្រទេសផងដែរ ។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៦ ក្នុងឱកាសជប់លៀងមួយជាកិត្តិយសដល់គណៈប្រតិភូនៃទីភ្នាក់ងារព័ត៌មានចិនថ្មីនៅក្រុងភ្នំពេញ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មានបានថ្លែងសរសើរ

*ចំពោះការបំផ្លាញឲ្យសាបសូន្យនូវ“បន៤នាក់” ប៉ុន្តែគាត់បាននិយាយទុកជាមុនថា ប្រជាជនចិន“នឹងមិនបណ្តោយឲ្យលទ្ធិសេរីនិយម ឬវណ្ណៈមូលធននិយមងើបក្បាលឡើងវិញបានឡើយ” ។ នេះជាប្រយោគសម្តែងឲ្យឃើញថែមទៀតនូវការព្រួយបារម្ភមួយជាងការជឿជាក់ពិតប្រាកដមួយ ។*

## ការរារែករបស់ចិន

*តាមការពិត តើគណៈដឹកនាំចិនយល់ឃើញពីខ្មែរក្រហមយ៉ាងដូចម្តេចខ្លះ? ។ បើវិនិច្ឆ័យរឿងនេះ តាមរយៈសេចក្តីថ្លែងការណ៍ផ្សេងៗរបស់គណៈប្រតិភូចិនដែលមកធ្វើទស្សនកិច្ចជាផ្លូវការនៅក្រុងភ្នំពេញ ក្នុងខែធ្នូ គឺការគាំទ្ររបស់ចិនមានលក្ខណៈពេញលេញលើកលែងតែការស្ញើចសរសើរដោយធ្វើមិនដឹងយ៉ាងគួរសមនូវការនិយាយបញ្ចិតបញ្ចៀងរបស់កម្ពុជាចំពោះការបន្តជាចាំបាច់នូវការតស៊ូវណ្ណៈនៅប្រទេសចិន ។ ម្យ៉ាងទៀត គណៈប្រតិភូចិនក៏ពុំបានអះអាងនូវការគាំទ្ររបស់ខ្លួនចំពោះ “ការតស៊ូរបស់កម្ពុជា ដើម្បីការពារឯករាជ្យ និងបូរណភាពទឹកដីរបស់ខ្លួន”ដែរ បើនិយាយតាមរបៀបមិនសូវអៀនខ្មាសគឺចិនមិនគាំទ្រ “ការតស៊ូរបស់កម្ពុជាប្រឆាំងនឹងវៀតណាម”ឡើយ ។ ការរារែកចិត្តនេះ ដែលជំរុញឲ្យមានការជជែកខុសត្រូវមួយខាងមនោគមវិជ្ជា និងផ្តល់នូវការគាំទ្រមួយ ទោះជាលួចលាក់ក៏ដោយ ក៏មួយចំណែកប្រហែលអាចឲ្យគេកាត់យល់ថានេះជាការទូន្មានមួយកុំឲ្យជ្រៀតជ្រែកនយោបាយផ្ទៃក្នុងរបស់ចិនដែរ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលត្រឡប់មកពីប្រទេសកម្ពុជាវិញ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសេដ្ឋកិច្ចជាមួយបរទេសរបស់ចិនឈ្មោះ ហ្វាងយី បាននិយាយប្រាប់ឯកអគ្គរដ្ឋទូតរូម៉ានីប្រចាំក្រុងប៉េកាំងនូវការមិនអបអររបស់គាត់ជាសម្ងាត់ថា “ពួកគេ(ខ្មែរក្រហម) បានប្រព្រឹត្តជ្រុលហួសហេតុក្នុងការស្វែងរកការខបត្ថម្ភខ្លួនដោយខ្លួនឯង(ឯករាជ្យម្ចាស់ការ)” ។ នៅជំនាន់ជាមួយគ្នានោះ ដោយនិយាយទៅកាន់បណ្តាអ្នកការទូតបស្ចិមប្រទេស ឯកអគ្គរដ្ឋទូតចិនប្រចាំហាណូយពុំបានលាក់លៀមនូវការភ្ញាក់ផ្អើលរបស់គាត់ចំពោះការប្រឹងប្រែងយ៉ាងខ្លាំងរបស់ខ្មែរក្រហមពីមុន ដើម្បីស្វែងរករបៀបរបបសេដ្ឋកិច្ចមួយ ដែលចង់រស់នៅដោយភោគផលរបស់ខ្លួនឯងឡើយ ។ គាត់បានប្រាប់ឯកអគ្គរដ្ឋទូតអ៊ីរ៉ុបម្នាក់ឲ្យដឹងថា កម្ពុជាបានច្រានចោលជំនួយស្បៀងអាហារ -តម្លៃស្មើនឹង២០លានដុល្លារអាមេរិក- ដែលផ្តល់ឲ្យដោយប្រទេសចិននៅឆ្នាំ១៩៧៦ថែមទៀត[៦] ។*

*ការទិតៀនក្រៅផ្លូវការទាំងនេះរបស់ពួកមេដឹកនាំចិន នានិទាឃរដូវឆ្នាំ១៩៧៧ ដែលថ្លែងដើម្បីបម្រើគោលបំណងអន្តទូតនិងសារព័ត៌មាននោះ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់នូវការប្រែប្រួលដ៏ជ្រាលជ្រៅដែលកើតមានដោយចៃដន្យនៅប្រទេសចិន តាំងពីមានការបណ្តេញពួកវ៉ាឌីកាល់ចេញពីតំណែងមក ។ នៅឆ្នាំ១៩៧៤ ក្នុងពេលដែលរាសីរបស់ពួកឆ្វេងនិយមជ្រុលហួសហេតុរបស់ចិនស្ថិតនៅកំពូលនៅឡើយនោះ មានឯកសារផ្ទៃក្នុងមួយរបស់បក្សបានវាយតម្លៃពួកកុម្មុយនីស្តកម្ពុជាថា ជាអ្នកគាំទ្រគំនិត ម៉ៅ សេទុង ដ៏រឹងមាំបំផុតនៅបរទេស ។*

*ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៥ ការសម្លាប់រង្គាលនិងអំពើសាហាវឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហមបានក្លាយទៅជារឿងដែលគេដឹងឮគ្រប់គ្នាទូទាំងសកលលោក ដោយសារចម្លើយជាសាក្សីរបស់អ្នកភៀសខ្លួនកម្ពុជា ។ នៅបស្ចិមប្រទេស តាមការវាយតម្លៃផ្សេងៗដែលចេញពីប្រភពរដ្ឋាភិបាល បានអះអាងពីតួលេខអ្នកស្លាប់នៅជំនាន់នោះថា មានចំនួនជាងមួយលាននាក់តាំងពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម ។ ប្រហែលនៅចុងឆ្នាំ១៩៧៦ វាមានការលំបាកបន្តិចសម្រាប់ពួកមេដឹកនាំចិនក្នុងការបង្ហាញមុខមាត់ខ្មែរក្រហមជាអ្នកគាំពារផ្នែកមនោគមវិជ្ជារបស់ខ្លួនឲ្យចេញមុខនៅបរទេសណាស់ ក្នុងពេលដែលសារព័ត៌មានរបស់ចិនបានបរិហារជារៀងរាល់ថ្ងៃ នូវការរំលោភបំពានច្រើនរាប់មិនអស់ ដែលប្រព្រឹត្តដោយ"បនបួននាក់"ក្នុងការដឹកនាំបង្ក្រាបយ៉ាងសាហាវរបស់ខ្លួនប្រឆាំងនឹងប្រជាជនចិននោះ ។ នៅដើមឆ្នាំ១៩៧៧ និពន្ធនាយកកាសែតកុម្មុយនីស្តចិនមួយនៅហុងកុងបាននិយាយប្រាប់ខ្ញុំថា : "យើងពុំអាចទិតៀនខ្មែរក្រហមជាចំហបានទេ ពីព្រោះនេះ ពុំមែនជានយោបាយរបស់ចិនដែលត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់បណ្តាប្រទេសដទៃ ។ ប៉ុន្តែយើងមានការចាប់អារម្មណ៍ថា ពួកគេបានប្រព្រឹត្តជ្រុលហួសហេតុបន្តិច ក្នុងរបៀបអនុវត្តសមភាពនិយមនិងនយោបាយឯករាជ្យម្ចាស់ការ" ។ គូសន្ទនារបស់ខ្ញុំបានទម្លាក់កំហុស ជាពិសេស ចំពោះការសម្រេចចិត្តរបស់ខ្មែរក្រហមដែលលុបបំបាត់ប្រាក់កាស ជំនួញតូចតាច និងកម្មសិទ្ធិឯកជន ។ គាត់មិនឲ្យតម្លៃថែមទៀតចំពោះការបដិសេធរបស់ខ្មែរក្រហម ដែលមិនទទួលស្គាល់អត្តិភាពនៃបក្សកុម្មុយនីស្តកម្ពុជា និងមិនដើរតាមគំរូដើមនៃមាក៏ា ម៉ាក្សលេនីន ក្នុងការធ្វើបដិវត្តសង្គមនិយមតាមដំណាក់កាលនីមួយៗ ។ ឥស្សរជនផ្លូវការម្នាក់ទៀតរបស់ចិន បានសារភាពប្រាប់ខ្ញុំជាឯកជនពីការទើសទាល់របស់ចិន ដែលត្រូវបង្ខំឲ្យខ្លួនធ្វើគធ្វើថ្លង់ចំពោះការអង្វររកររបស់ពួកអាណិកជនចិនដែលរត់គេចខ្លួនពីប្រទេសកម្ពុជា ដោយស្នើសុំឲ្យជួយធ្វើអន្តរាគមន៍ដើម្បីបញ្ឈប់ការសម្លាប់រង្គាលទាំងនោះផង ។ គាត់បានបកស្រាយថា ប៉ុន្តែប្រទេសចិនពុំអាចជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជាបានឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរហូរហែនៃព្រឹត្តិការណ៍ផ្សេងៗក្នុងការគាំទ្ររបស់ចិនចំពោះខ្មែរក្រហមទំនងជាបង្ហាញឲ្យឃើញថា "នយោបាយជាក់ស្តែងនិយម" (La real-politik) មានហេតុផលរបស់វាដែលមិនទទួលស្គាល់ទាំងការមិនយល់ស្របខាងផ្លូវចិត្តទាំងការមិនត្រូវគ្នាខាងមនោគមវិជ្ជា ។*

## នៅពេលដែល ប៉ុល ពត រៀបចំប្រវត្តិសាស្ត្រជាថ្មីឡើងវិញ

*តាមភាពដូចគ្នាដ៏ចម្លែកមួយ នៅក្រោយថ្ងៃនៃមរណភាពរបស់ ម៉ៅ និងការចាប់ខ្លួន"បន៤នាក់"ការតស៊ូប្រឆាំងនឹងពួកវៀតឌីកាល់បានកើនឡើងយ៉ាងខ្លាំងក្នុងផ្ទៃបក្សកុម្មុយនីស្តចិន និន្នាការលម្អៀងមកកម្ពុជា គឺខុសប្លែកពីមុនយ៉ាងជាក់ច្បាស់ ។ នៅចុងខែសីហា ឆ្នាំ១៩៧៦ គណៈលេខាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលប្រមូលផ្តុំនៅជុំវិញ ប៉ុល ពត បានជួបប្រជុំគ្នាអស់រយៈពេលបីថ្ងៃ ។ នៅក្នុងកម្មវិធីប្រជុំគឺសមូហភាវូបនីយកម្មខាង*

កសិកម្ម និងឧស្សាហកម្មទាំងស្រុង និងការបង្កើតផ្ទះបាយរួមក្នុងទូទាំងប្រទេស ។ សម្រាប់ ប៉ុល ពត យល់ថា ត្រូវតែបង្កើនល្បឿនក្នុងការកសាងលទ្ធិកុម្មុយនីស្តនិយម ដើម្បីតតាំងនឹងវៀតណាមប្រកបដោយជោគជ័យដ៏ប្រសើរ ។ ទស្សនាវដ្ដីសម្ងាត់បំផុតរបស់បក្សឈ្មោះ «ទង់បដិវត្ត» បានបកស្រាយដោយគ្មានលាក់លៀមនៅខែមិថុនា ឆ្នាំ១៩៧៦ថា «យើងចង់កសាងលទ្ធិសង្គមនិយមឲ្យបានឆាប់រហ័សបំផុត យើងចង់ធ្វើឲ្យប្រទេសរបស់យើងផ្លាស់ប្ដូរសភាពទ្រង់ទ្រាយ និងចង់ឲ្យប្រជាជនយើងការពារបាននូវភាពរុងរឿងរបស់ខ្លួនដោយឆាប់រហ័សបំផុត ។ ជាបឋម ប្រការទាំងនេះគឺសម្រាប់រារាំងសត្រូវមិនឲ្យបំផ្លិចបំផ្លាញយើងបាន»[៧] ។ ផ្លូវឆ្ពោះទៅរក«ភាពថ្កុំថ្កើងរុងរឿង» គឺក្រាលទៅដោយឈាមនិងទឹកភ្នែករបស់ប្រជាជនប្រុសស្រីរាប់រយពាន់នាក់ ដែលត្រូវបង្ខំឲ្យធ្វើស្រែដូចសត្វធាតុជាមួយនឹងម្ហូបអាហារដ៏អត្តខាត់ និងសេចក្ដីស្លាប់ចំពោះអ្នកណាដែលហ៊ានត្អូញត្អែរ ។ របបនេះមានលក្ខណៈតឹងរ៉ឹង ដោយឡែកចំពោះ«ប្រជាជនថ្មី»ជាអតីតអ្នកទីក្រុងដែលត្រូវវិនិច្ឆ័យថាពុករលួយស្មោកគ្រោកដោយមនោគមវិជ្ជាវណ្ណៈគហបតី ។ ការលុបលាងកំហុសរបស់បុគ្គលម្នាក់ៗ គឺទណ្ឌកម្មធ្វើការហត្ថកម្មមួយដែលលំបាកនឿយហត់យ៉ាងខ្លាំង ។ ចំណែកអ្នកទន់ខ្សោយដែលធ្វើការបានផលទាបជាងការកំណត់គឺពួកគេលែងមានផលប្រយោជន៍ណាមួយសម្រាប់កម្ពុជាបដិវត្តទៀតហើយ ដូចប្រយោគប្រជាប្រិយមួយលើកឡើងថា «ទុកក៏មិនចំណេញដកចេញក៏មិនខាត» ។ សម្រាប់អ្នកទាំងឡាយដែលពួកគេឲ្យរស់ ឬឲ្យស្លាប់ គឺពួកកម្មាភិបាលខ្មែរក្រហមប្រើតែប្រយោគនេះប៉ុណ្ណោះដែលធ្វើឲ្យម្នាក់ៗព្រឺរោមខ្លួន ។

ម្យ៉ាងទៀត តាមការគន់គូររបស់ ប៉ុល ពត ថា កាលណាបដិវត្តន៍កាន់តែដាច់ខាត គាត់កាន់តែមានសភាពងាយស្រួលក្នុងការកម្ចាត់បក្សពួកប្រឆាំងនឹងមាគ៌ាដឹកនាំរបស់គាត់ក្នុងផ្ទៃបក្សដែរ ។ ឯកសារផ្ទៃក្នុងមួយបានបញ្ជាក់ដូច្នេះថា «ពួកមេរោគដែលរុករានបក្សជាសម្ងាត់នឹងត្រូវផ្ទុញផ្ទាល់ឲ្យបង្ហាញខ្លួនឡើង តាមរយៈការលាតត្រដាងពីលក្ខណៈពិតរបស់បដិវត្តសង្គមនិយម»[៨] ។ បើអ្នកណាប្រឆាំងជំទាស់ ឬគ្រាន់តែសាកសួរពីបញ្ហានេះនឹងត្រូវគេចោទប្រកាន់ថាជាពួកចក្រពត្តិ ឬភ្នាក់ងាររបស់វៀតណាមដែលចង់បំផ្លាញ នយោបាយមហាលោតផ្លោះរបស់កម្ពុជា ។ ប្រហែលនៅពាក់កណ្ដាលរដូវក្ដៅឆ្នាំ១៩៧៦ ការប៉ុនប៉ងធ្វើឃាតជាច្រើនលើកទៅលើរូប ប៉ុល ពត បានផ្ដល់ជាលេសបន្ថែមមួយទៀតដល់ការស្វែងរកបក្សពួកប្រឆាំង ដែលមិនទាន់ចេញមុខជាក់ស្ដែង ។

យ៉ាងហោចណាស់ ការបៀតបៀនមួយក្នុងចំណោមការបៀតបៀនប្រឆាំងនឹង ប៉ុល ពត ដែលចុះផ្សាយក្នុងសៀវភៅខ្មៅរបស់កម្ពុជាប្រជាធិបតេយ្យ គឺទទួលបានការអះអាងបន្ថែមពីមាត់របស់កងទ័ពខ្មែរក្រហមរត់ចោលជួរម្នាក់ដែលភៀសខ្លួនទៅកាន់ប្រទេសថៃ ហើយដែលបាននិយាយអាថ៌កំបាំងប្រាប់ពួកមន្ត្រីផ្លូវការរបស់អាមេរិកនៅទីនោះថា នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ការរួមគំនិតក្បត់មួយក្នុងគោលបំណងបំពុល ប៉ុល ពត បានទទួលបរាជ័យ ពីព្រោះអង្គរក្សម្នាក់ក្នុងចំណោមអង្គរក្សជាច្រើនរបស់គាត់បានភ្លក្សដោយមិនប្រយ័ត្ននូវម្ហូប

អាហារមានដាក់ថ្នាំពុលដែលគេទុកបម្រុងសម្រាប់ ប៉ុល ពត ហើយត្រូវស្លាប់ភ្លាមមួយរំពេច។ តាមសម្ដីរបស់កងទ័ពខ្មែរក្រហមរត់ចោលជួរដដែលរូបនេះថា វីរភាពរបស់អ្នករួមគំនិតក្បត់-មេបញ្ជាការខ្មែរក្រហមម្នាក់ឈ្មោះ ចាន់ ចក្រី និងអ្នកសមគំនិតរបស់គាត់-បានត្រូវណែនាំឲ្យធ្វើកិច្ចការនេះ ដោយសារការមើលឃើញទស្សនីយភាពនៃ“ទុក្ខវេទនា” ដែលគេដាក់មកលើប្រជាជនកម្ពុជានេះឯង[៩] ។ វាក៏អាចថា អ្នករួមគំនិតក្បត់សុទ្ធតែជាអ្នកជិតទាស់នឹងនយោបាយប្រឆាំងវៀតណាមរបស់ ប៉ុល ពត ផងដែរ ប៉ុន្តែពុំមានភ័ស្តុតាងណាមួយជាបន្ថែកដល់ការពោលអះអាងផ្សេងៗ ដែលមានបញ្ចូលទាំងវៀតណាមដូចក្នុងសៀវភៅខ្មៅលើកឡើងទាល់តែសោះ ។

នៅខែកញ្ញា ឆ្នាំ១៩៧៦ រលកនៃការបោសសម្អាតតាមរបៀបជាក្បួនលើកដំបូងសំដៅទៅលើបណ្ដាសមាជិកបក្សគឺមានទាក់ទងដោយផ្ទាល់នឹងបញ្ហានៃទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងវៀតណាម យ៉ាងប្រាកដ ។ កាលបរិច្ឆេទដែលគេទទួលស្គាល់ជាទូទៅ នូវថ្ងៃបង្កើតបក្សកុម្មុយនីស្តកម្ពុជារហូតមកដល់ពេលនេះគឺថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ ជាប្រការអាចបង្កើតខ្សែរយៈទាក់ទងដោយផ្ទាល់របស់បក្សកុម្មុយនីស្តកម្ពុជាជាមួយបក្សកុម្មុយនីស្តឥណ្ឌូចិនដែលបង្កើតឡើងនៅឆ្នាំ១៩៣០ដោយ ហូ ជីមិញ ។ ក្នុងអំឡុងពេញថិរវេលានៃការប្រយុទ្ធប្រឆាំងនឹងពួកបារាំង (ឆ្នាំ១៩៤៦-១៩៥៤) វៀតណាម ឡាវ និងខ្មែរ បានរួមសហការគ្នាយ៉ាងជិតស្និទ្ធ ហើយក្នុងទីបំផុតជនជាតិកម្ពុជាជាច្រើនក៏វាយតម្លៃពីកិច្ចសហប្រតិបត្តិការនេះដែរ ។

យុទ្ធិកជនកុម្មុយនីស្តដើងចាស់ម្នាក់របស់កម្ពុជាឈ្មោះ កែវ មាស មានមុខក្នុងចំណោមមេដឹកនាំជាច្រើនដែលយកចិត្តទុកដាក់សង្កត់បញ្ជាក់ថែមទៀតពីដើមកំណើតបក្សដែលចេញពីវៀតណាម តាមរយៈការប្រារព្ធបុណ្យខួបកំណើតលើកទី២៥របស់ខ្លួនយ៉ាងមហោឡារិក ។ ម្យ៉ាងទៀត តាមគាត់យល់នយោបាយផ្ទៃក្នុងរបស់វៀតណាមគឺមានលំនាំស្របគ្នានឹងលទ្ធិម៉ាក់ស៊ិស ប្រកាន់តាមទ្រឹស្ដី (Marxisme Orthodoxe) ជាងមាគ៌ាឆ្កេងជ្រុលរបស់កម្ពុជា ។ មាស ប្រហែលជាដឹងខ្លួនថា គាត់ត្រូវតែប្រញាប់ចូលធ្វើសកម្មភាពជាបន្ទាន់ ។ ដោយពិត នៅខែសីហា បន្ទាប់ពីលិខិតសម្ដែងមរណទុក្ខរបស់ ប៉ុល ពត ចំពោះសពប្រធាន ម៉ៅ ដែលប្រកាសពីការស្ថិតនៅក្នុងឱវាទលទ្ធិម៉ៅនិយមនោះ គាត់បានឲ្យដំណឹងមុនពីគម្រោងការថ្មីៗជាច្រើន ។ ដេវីដ ឆេនដ៍ល័រ ប្រវត្តិវិទូដែលសរសេរពីប្រវត្តិប្រទេសកម្ពុជាបានសន្និដ្ឋានថា ភាពធូរស្រាលជាមួយវៀតណាមដែលគេអាចមើលឃើញច្បាស់នៅដើមរដូវក្ដៅឆ្នាំ១៩៧៦ ព្រមទាំងភាពមិនប្រាកដប្រជាផ្នែកនយោបាយនៅប្រទេសចិនក្រោយមរណភាពរបស់ ម៉ៅ ផង អាចជំរុញឲ្យ កែវ មាស កៀបសង្កត់ដើម្បីឲ្យគេប្រារព្ធបុណ្យខួបកំណើតលើកទី២៥របស់បក្សនៅចុងខែកញ្ញា ឆ្នាំ១៩៧៦[១០] ។

ដោយផ្ទុយមកវិញ ប៉ុល ពត បានសម្រេចចិត្តលុបបំបាត់គំនិតដែលថា បក្សកុម្មុយនីស្តកម្ពុជានៅតែមានប្រភពដើមផ្សេងៗចេញពីវៀតណាម ។ គាត់បានសម្រេចដោយអំណាចថា ការបង្កើតបក្សពុំមែនមានកាល

បរិច្ឆេទ នៅឆ្នាំ១៩៥១ទេ ប៉ុន្តែគឺមានចាប់ពីមហាសន្និបាតបក្សនៅឆ្នាំ១៩៦០ ដែលបានជ្រើសតាំងគាត់ជាអគ្គលេខាវង ។ ដូច្នេះប្រវត្តិសាស្ត្រដែលកែប្រែឡើងវិញ អាចបកស្រាយបានថា បក្សបានចាប់ផ្តើមសកម្មភាព "ដ៏ត្រចះត្រចង់"របស់ខ្លួនក្រោមការដឹកនាំរបស់ ប៉ុល ពត ដោយបំបាត់ចោលរយៈពេល៩ឆ្នាំនៃការរួបរួមគ្នាដ៏ជិតស្និទ្ធជាមួយវៀតណាម ព្រោះគេមិនចង់និយាយពីភាពស្ថិតនៅក្រោមបង្គាប់បក្សកុម្មុយនីស្តវៀតណាម ដែលក្នុងរយៈពេលនោះមេដឹកនាំខ្មែរក្រហមបច្ចុប្បន្នពុំដែលសម្តែងតួនាទីសំខាន់ណាមួយឡើយ ។ ទស្សនាវដ្តីទង់បដិវត្តលេខពិសេសមួយប្រចាំខែកញ្ញា-តុលា បានលើកបង្ហាញឲ្យឃើញភ័ស្តុតាងទាំងស្រុងស្តីពីការកែប្រែកាលបរិច្ឆេទនៃថ្ងៃកំណើតបក្សនេះ ។ អត្ថបទមួយដែលប្រហែលជាសរសេរដោយរូប ប៉ុល ពត ផ្ទាល់បានបញ្ជាក់បំភ្លឺពីរឿងនេះថា "យើងត្រូវតែកែសម្រួលប្រវត្តិសាស្ត្របក្ស ដើម្បីឲ្យសមស្របទៅនឹងនយោបាយឯករាជ្យនិងអធិបតេយ្យរបស់យើង"[១១] ។

ដប់ថ្ងៃមុនកាលបរិច្ឆេទដែលបានគ្រោងទុកសម្រាប់ការប្រារព្ធខួបកំណើតបក្ស ប៉ុល ពត បានចេញបញ្ជាឲ្យផ្អាកការរៀបចំបម្រុងផ្សេងៗនិងឲ្យចាប់ខ្លួន កែវ មាស ព្រមទាំងមេដឹកនាំជាន់ខ្ពស់ម្នាក់ទៀតគឺ ណៃ សារ៉ាន់ (ធ្លាប់បង្រៀននៅវិទ្យាល័យឯកជនមួយឈ្មោះចម្រើនវិជ្ជា) ។ អ្នកទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលសួរចម្លើយរបស់ផ្នែកសន្តិសុខជាតិនៅក្រុងភ្នំពេញ ដែលទីនោះជាអតីតអនុវិទ្យាល័យទួលស្វែងដោយអគារសិក្សាទាំងអស់ត្រូវបានប្រែក្លាយឲ្យទៅជាគុក និងកន្លែងសួរចម្លើយក្រោមឈ្មោះសម្ងាត់ថា ស-២១(S-21)វិញ ។ បន្ទាប់ពីការធ្វើទារុណកម្មអស់រយៈពេលមួយខែនិង"ការឆ្លើយសារភាព"ជាបន្តបន្ទាប់មិនចេះចប់ អ្នកទាំងពីរបានត្រូវយកទៅសម្លាប់ចោលដោយគ្មានអាណិតអាសូរ ។ ក្នុងអំឡុងពីរឆ្នាំជាបន្តបន្ទាប់មកទៀត កម្មាភិបាលសំខាន់ៗរបស់បក្សប្រហែលជា២០.០០០នាក់ រួមទាំងក្រុមគ្រួសាររបស់ពួកគេបានទទួលរងនូវជោគវាសនាដូចគ្នា បន្ទាប់ពីការជាប់ឃុំមួយរយៈក្នុងមណ្ឌលដ៏ល្បីល្បាញនេះ[១២] ។

ឆេនដ៍ល័រ បានកត់សម្គាល់ថា "ដោយមិនព្រមទទួលស្គាល់ការពិតទាំងអស់ស្តីពីចំណងទាក់ទងជាប្រវត្តិសាស្ត្រជាមួយវៀតណាម "ប៉ុល ពត ដែលទំនងជាគ្រោងការតាំងពីពេលដ៏ជាក់លាក់មួយអាចប្រកាន់យកស្ថានភាពខាងផ្លូវនយោបាយក្នុងជម្លោះដ៏មានទំហំធំធេងមួយជាមួយវៀតណាមជាស្រេចនិងក្នុងកម្មវិធីសមូហភាវូបនីយកម្មដាច់ខាតមួយនៅក្នុងប្រទេសដែលលែងយកតាមគំរូ ឬពាក្យណែនាំរបស់វៀតណាមទៀតហើយ"[១៣] ។

អត្ថបទរបស់ទស្សនាវដ្តីទង់បដិវត្តពុំមានបន្ទល់ការសង្ស័យណាមួយស្តីពីអត្ថិភាពនៃចំណងទាក់ទងជាបុព្វហេតុមួយរវាងការធ្វើវិសុទ្ធកម្មនិងការប្រឆាំងជិទាស់ចំពោះនយោបាយឆ្វេងជ្រុលហួសហេតុរបស់ ប៉ុល ពត ឡើយ ។ គាត់បានកត់សម្គាល់ថា មនុស្សខ្លះក្នុងផ្ទៃបក្សផ្ទាល់បានចាត់ទុកការជម្លៀសប្រជាជនពីទីក្រុងនានា ការលុបបំបាត់ក្រដាសប្រាក់និងកម្មសិទ្ធិឯកជនថាជា "នយោបាយឆ្វេងជ្រុល" មុននឹងអះអាងបន្ថែមថា "យើងមានហេតុផលរបស់យើង ហើយការផ្លាស់ប្តូរក្នុងសមូហភាពបានបង្ហាញឲ្យឃើញថា យើងវិនិច្ឆ័យត្រឹមត្រូវមែន ។

ឆ្អែតឬមិនឆ្អែតតើមានអ្វីជាសំខាន់ទៅ? ៈ យើងត្រូវតែស្ថិតនៅដោយស្រុះចិត្តស្រុះគំនិតគ្នាជាមួយការផ្លាស់ប្ដូរក្នុងសមូហភាព» ។ អ្នកនិពន្ធអត្ថបទបានចោទប្រកាន់សមាជិកបក្សខ្លះថា «ធ្វើខ្លួនប្រឆាំងនឹងការផ្លាស់ប្ដូរក្នុងសមូហភាពនិងក្បត់ការបដិវត្តន៍»[១៤] ។

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ វិទ្យុក្រុងភ្នំពេញបានប្រកាសជាសាធារណៈថា មួយសប្ដាហ៍មុន (ថ្ងៃដែលមានការចាប់ខ្លួន កែវ មាស) គណៈកម្មាធិការកណ្ដាលនៃសភាតំណាងប្រជាជនបានអនុញ្ញាតច្បាប់ឲ្យ ប៉ុល ពត «ឈប់សម្រាកជាបណ្ដោះអាសន្នមួយ ដោយមូលហេតុសុខភាព បន្ទាប់ពីគាត់មានជំងឺតាំងពីប៉ុន្មានខែមកហើយ» ។ នួន ជា បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រីស្ដីទី ។ អ្នកសង្កេតការណ៍ជាច្រើន បានសន្និដ្ឋានពីរឿងនេះថា ប៉ុល ពត បានទទួលរងគ្រោះពីការបោសសម្អាតមួយ ។ តាមការពិត «ការឈប់សម្រាកដោយមូលហេតុជំងឺ» គ្រាន់តែជាលេសមួយប៉ុណ្ណោះ ហើយគោលដៅរបស់មេដឹកនាំខ្មែរក្រហមគឺ ធ្វើឲ្យគាត់មានសេរីភាពពេញទីក្នុងការព្យាបាល«ជំងឺដ៏រ៉ាំរ៉ៃ»របស់បក្សដែលជាសមាសភាពបក្សពួក ប្រឆាំង ។ ក៏ប៉ុន្តែ ខេន ឃីរ៉ុន ជឿថា ប៉ុល ពត អាចត្រូវបង្ខំចិត្ត«នៅតែក្នុងបន្ទប់»បន្ទាប់ពីមានការប៉ុនប៉ងធ្វើឃាតមួយដែលកើតឡើងកាលពីដើមរដូវក្ដៅឆ្នាំ១៩៧៦ ។

ការស្រាវជ្រាវទាំងឡាយរបស់ ឃីរ៉ុន បាននាំទៅដល់ការសន្និដ្ឋានថា ប៉ុល ពត អាចគេចខ្លួនទៅរស់នៅក្នុងជម្រកសម្ងាត់មួយ និងមានកិច្ចការពារយ៉ាងមាំទាំបំផុតពីការវាយប្រហារដោយថាហេតុថ្មីៗទៀត ។ ពីទីលាក់ខ្លួនទៅ គាត់អាចដឹកនាំធ្វើការកម្ចាត់ចោលទាំងអស់នូវពួកមេគំនិតនៃការរួមគំនិតក្បត់សំដៅសម្លាប់គាត់ទៀតផង ។ ចម្លើយជាសាក្សីរបស់អ្នកភៀសខ្លួន និងអ្នកនៅរស់រានមានជីវិតពីការបោសសម្អាតទាំងឡាយដែលរត់ទៅដល់ប្រទេសថៃយ៉ាងច្រើនពេញរយៈពេលនៃឆ្នាំ១៩៧៧នោះ បានបង្ហាញឲ្យឃើញពីការសម្លាប់រង្គាលនូវ«ពួកអតីត»កម្មាភិបាលខ្មែរក្រហមក្នុងទំហំមួយយ៉ាងធំ- ប្រហែលមានអ្នកដែលមានសមានចិត្តនឹងវៀតណាមដែរ ទោះជាយ៉ាងណាអ្នកទាំងនេះចូលចិត្តធ្វើនយោបាយផ្ទៃក្នុងមួយដែលមិនប្រកាន់តឹង ហើយដែលប្រឆាំងនឹង ប៉ុល ពត រួមទាំង«ពួកប្រតិកិរិយា»ទាំងអស់ដែលគ្រាន់តែសន្មតផង ។ នៅជំនាន់នោះដែរ ក្រុមស៊ើបការណ៍សម្ងាត់របស់អាមេរិកាំងនៅប្រទេសថៃបានទទួលនូវព័ត៌មានដ៏ជាក់លាក់ជាច្រើន ដែលលាតត្រដាងថា ប៉ុល ពត បានដឹកនាំធ្វើការកម្ចាត់«អ្នកដែលគាត់ចាត់ទុកជាសត្រូវ»នៅភាគពាយ័ព្យប្រទេសដោយផ្ទាល់ខ្លួនតែម្ដង[១៥] ។

នៅក្នុងអំឡុងប្រាំមួយខែ ចុងក្រោយនៃឆ្នាំ១៩៧៦ ប្រហែលគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយនៅពេលដែលការបោសសម្អាតផ្សេងៗកំពុងប្រព្រឹត្តទៅយ៉ាងពេញទំហឹងទៅហើយនោះ ក៏កម្ពុជាខំប្រឹងថែរក្សាភាពមានតែសំបកក្រៅមួយ ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសវៀតណាមដែរ ។ ក្នុងពេលដែលរបប ប៉ុល ពត ខំប្រឹង «បោសសម្អាត» ជួរកម្មាភិបាលខ្លួនផ្ទាល់និងដាក់ឲ្យអនុវត្តនូវកម្មវិធីឆ្អែតជ្រុលរបស់ខ្លួន របបនេះចូលចិត្តមិនធ្វើឲ្យប៉ះពាល់ដល់សមានចិត្តដ៏ល្អរបស់វៀតណាម ដែលមានមកលើខ្លួនជាង ។ នៅខែសីហា ឆ្នាំ៩៧៦ គណៈប្រតិភូ

សមាគមនារីរបស់កម្ពុជាមួយក្រុមបានធ្វើដំណើរទៅកាន់ក្រុងហាណូយ ។ ទន្ទឹមនឹងនោះ ប៉ុល ពត មិនរួញរានឹងធ្វើបដិសណ្ឋារកិច្ចឯកអគ្គរដ្ឋទូត ផាំ វ៉ាន់ដុង ដើម្បីថ្លែងអបអរសាទរសើរគាត់ក្នុងឱកាសបុណ្យខួបលើកទីសាមសិបមួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមឡើយ ។ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៦ គឺជាថ្ងៃបើកសម្ពោធការទាក់ទងគ្នាតាមផ្លូវអាកាសរវាងទីក្រុងហូជីមិញនិងភ្នំពេញ ដែលរ៉ាប់រងដោយក្រុមហ៊ុនអ៊ែរវៀតណាម (Air Vietnam) ។ ពិធីសម្ពោធមួយបានប្រារព្ធធ្វើក្នុងឱកាសនោះ នៅចំណតអាកាសយានដ្ឋានពោធិចិនតុង ។ មុននេះមួយថ្ងៃ វៀតណាមប្រហែលជាពុំដឹងថា មិត្តខ្មែរម្នាក់ក្នុងចំណោមមិត្តខ្មែរដ៏កម្ររបស់ខ្លួនគឺ កែវ មាស បានត្រូវខ្មែរក្រហមចាប់ដាក់គុកនៅទួលស្លែងផងទេ ។

ក្នុងសុន្ទរកថារបស់គាត់ដែលថ្លែងនៅអង្គការសហប្រជាជាតិនៅខែតុលា ឆ្នាំ១៩៧៦ អៀង សារី ពុំលាក់លៀមនូវការកត់សម្គាល់ដ៏ជូរចត់ជាច្រើនចំពោះប្រទេសវៀតណាម ដោយមិនបញ្ចេញឈ្មោះឡើយ ដែលអាចរាំងរាមិនឲ្យប្រទេសនេះស្នើសុំចូលជាសមាជិកអង្គការអន្តរជាតិបាន ។ គេដឹងថា ការចូលជាសមាជិកអង្គការសហប្រជាជាតិរបស់វៀតណាមបានត្រូវរាំងខ្ទប់ដោយការបោះឆ្នោតវ៉េតូ (Veto) របស់អាមេរិកាំង [វ៉េតូ ជាពាក្យឡាតាំងមានន័យថា ខ្ញុំជំទាស់ ។ ជាសិទ្ធិ ឬអំណាចពិសេសដែលផ្តល់ឲ្យសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រាំប្រទេសគឺ អាមេរិក បារាំង អង់គ្លេស រុស្ស៊ី និងចិន ដែលអនុញ្ញាតឲ្យសមាជិកនីមួយៗជំទាស់គ្រប់បញ្ហាទាំងអស់ ។ ក្នុងចំណោមសមាជិកទាំងប្រាំ បើមានសមាជិកណាមួយជំទាស់ គឺបញ្ហាមួយនោះត្រូវគេចាត់ទុកជាមោឃៈ–កំណត់របស់អ្នកបកប្រែ] ។ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ដោយសារី អវត្តមាន រដ្ឋមន្ត្រីទី១ស្តីទី សុន សេន បានទទួលជួបឯកអគ្គរដ្ឋទូត ដុង ក្នុងរយៈពេលជាងពីរម៉ោង ។ ខ្លឹមសារនៃការជួបសន្ទនាគ្នានៅតែស្ថិតក្នុងភាពសម្ងាត់ ប៉ុន្តែបរិយាកាសនៃការជួបគ្នាត្រូវបានវាយតម្លៃដោយវិទ្យុភ្នំពេញថា "មានសភាពរាក់ទាក់និងស្និទ្ធស្នាល"[១៦] ។

បក្សកុម្មុយនីស្តកម្ពុជា មានសេចក្តីក្លាហានក្នុងការបញ្ជូនគណៈប្រតិភូអ្នកសារព័ត៌មានមួយក្រុមមានគ្នា៧នាក់ ទៅចូលរួមមហាសន្និបាតបក្សលើកទី៤របស់បក្សកុម្មុយនីស្តវៀតណាមដែលបើកធ្វើនៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៦ ។ ប្រតិភូបានពាំនាំនូវសារលិខិតអបអរសាទរមួយរបស់អង្គការបដិវត្តន៍ (ឈ្មោះដែលប្រើប្រាស់ដោយអង្គការបដិវត្តកម្ពុជា រហូតដល់ការចេញមុខជាបក្សកុម្មុយនីស្តកម្ពុជាតែម្តង) ហើយការផ្ញើលិខិតនេះ គឺក្នុងបំណងថែរក្សារូបភាពក្រៅនៃទំនាក់ទំនងជាប្រក្រតីរវាងបក្សទាំងពីរ ។ ចំពោះ"ការអបអរសាទរដ៏កក់ក្តៅបំផុត" ដែលក្រុងភ្នំពេញផ្ញើជូនបក្សកុម្មុយនីស្តវៀតណាមមានបន្ថែមនូវការរំឮកពីអត្ថិភាពនៃ"សាមគ្គីភាពបដិវត្តមួយ និងមិត្តភាពជាបងប្អូនស្ថិតស្ថេរយូរអង្វែងមួយដែលបក្សទាំងពីរធ្លាប់លត់ដំក្នុងភ្លើងនៃការតស៊ូបដិវត្តន៍"[១៧] ផង ។ អត្ថបទនៃសារលិខិតនេះ បានត្រូវបោះពុម្ពផ្សាយដោយក្រុងហាណូយ ប៉ុន្តែ វិទ្យុភ្នំពេញបានសម្រេចមិនផ្សាយសារលិខិតនេះឡើយ ។ នៅពេលដែលអ្នកមានសមានចិត្តនឹងវៀតណាម ត្រូវបានតាមដានប្រកិតៗដោយ

*ពួកភ្នាក់ងារសន្តិសុខ ប៉ុល ពត វាមុខជានឹងធ្វើឲ្យកើតមានការច្របូកច្របល់ក្នុងជួររបស់ខ្លួនមិនខាន ។*

## «មគ្គុទេសក៍របស់គណៈ៨៧០»

*វៀតណាមចាប់ផ្តើមមន្ទិលសង្ស័យនូវរឿងរ៉ាវខ្លះដែលកើតមានក្នុងផ្ទៃបក្សកុម្មុយនីស្តរបស់កម្ពុជាដោយមិនដឹងជារឿងអ្វីពិតប្រាកដឡើយ ។ រដ្ឋមន្ត្រីទី១ ផាំ វ៉ាន់ដុង ដែលបានជួបសន្ទនាដាច់ឯកជនជាមួយភ្ញៀវជាតិថៃម្នាក់នៅចុងឆ្នាំ១៩៧៦ បានជម្រាបឲ្យដឹងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះជោគវាសនា ដែលត្រៀមបម្រុងសម្រាប់«បណ្តាមិត្តភក្តិកម្ពុជា»ខ្លះរបស់គាត់ ។ អតីតអ្នកការទូតកម្ពុជាមួយចំនួនតូច ដែលជាសមាជិករដ្ឋាភិបាលតស៊ូដឹកនាំដោយ សម្តេច សីហនុ បានផ្ញើសំបុត្រជាច្រើនមកឲ្យមិត្តភក្តិទាំងឡាយនៅក្រុងហាណូយមុននឹងឡើងយន្តហោះធ្វើដំណើរពីក្រុងប៉េកាំងមកកាន់ក្រុងភ្នំពេញ ។ តាំងពីនោះមក គ្មានអ្នកណាម្នាក់បានទទួលដំណឹងពីអ្នកទាំងនោះសោះ[១៨] ។*

*តើក្រុងហាណូយវាយតម្លៃទំហំនៃការបោសសម្អាតនៅកម្ពុជាដោយច្បាស់លាស់ដែរទេ? ពិបាកនឹងនិយាយណាស់ ។ ប៉ុន្តែវាប្រាកដណាស់ថា វៀតណាមពិតជាត្រូវផ្តល់ព័ត៌មានឲ្យដឹងពីជម្លោះផ្សេងៗ ដែលធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាបែកបាក់គ្នា ។ នៅដើមខែមីនា ឆ្នាំ១៩៧៧ អ្នកការទូតវៀតណាមម្នាក់ប្រចាំនៅក្រុងវៀងច័ន្ទ(រដ្ឋធានីប្រទេសឡាវ) បានរំឭកប្រាប់នៅមុខខ្ញុំពី«ការប្រឈមមុខយ៉ាងធ្ងន់ធ្ងរ»រវាងក្រុមមនុស្សដែលគាត់ហៅថា «ពួកស្និទ្ធ ម៉ៅ-ប៉ុល ពត ចំនួន១០០ភាគរយ»និងអ្នកប្រកាន់«មាគ៌ាត្រឹមត្រូវ» ។ មាគ៌ាត្រឹមត្រូវផ្អែកលើការទាមទារឲ្យមានមិត្តភាពជាមួយវៀតណាម ។ គាត់មើលឃើញថា «នៅទីបញ្ចប់មាគ៌ាត្រឹមត្រូវនឹងលេចចេញប្រកបដោយជ័យជម្នះ» ពីការវិវាទនោះ ។ គឺក្រុមប្រកាន់មាគ៌ាត្រឹមត្រូវនេះហើយដែល ដុង គិតដល់នៅពេលដែលគាត់ទម្លាយប្រាប់ភ្ញៀវជាតិថៃពីសេចក្តីសង្ឃឹមរបស់គាត់ដែលឃើញលេចឡើងនូវ«អ្នកបដិវត្តពិតៗ»នៅកម្ពុជា ។ ត្រូវលើកទឹកចិត្តដោយសេចក្តីសង្ឃឹមនេះ ក្រុងហាណូយបានបញ្ចេញប្ញុកក្លែងជាអ្នកជិតខាងល្អដោយខំប្រឹងប្រឆាំងនឹង ប៉ុល ពត យ៉ាងខ្លាំង ។ ប្រហែលជានឹកបារម្ភចំពោះការរីករាលដាលនៃនយោបាយផ្ទៃក្នុងរបស់កម្ពុជានោះហើយ បានជាវៀតណាមខំប្រឹងយ៉ាងអស់ពីចិត្តពីថ្លើម ដើម្បីធ្វើឲ្យស្របនឹងចំណង់ចំណូលចិត្តរបស់មេដឹកនាំខ្មែរក្រហម ។ ជាពិសេសវៀតណាមសម្រេចចិត្តមិនបង្កើតលេសបន្ថែមផ្សេងៗចំពោះការធ្លាក់ចុះនៃទំនាក់ទំនងជាខភគោភាគីនិងភាពឯកោនៃបណ្តាមិត្តក្រុងហាណូយ (ខ្មែរមកពីវៀតណាមខាងជើង)ក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជាឡើយ ។ ដើម្បីជាសក្ខីកម្មនៃសាមគ្គីភាព គណៈប្រតិភូស្ត្រីវៀតណាមមួយក្រុមបានត្រូវបញ្ជូនមកក្រុងភ្នំពេញនៅដើមខែកុម្ភៈ ឆ្នាំ១៩៧៧ ។ ថ្ងៃទី១៥ ខែដដែលអនុរដ្ឋមន្ត្រីការបរទេស ហ័ង វ៉ាន់ឡូ ក៏ធ្វើដំណើរមកកាន់រដ្ឋធានីខ្មែរដើម្បីធ្វើទស្សនកិច្ចពីរថ្ងៃដែរ តែពុំមានការប្រកាសផ្សាយជាសាធារណៈទេ ។ គាត់មានបេសកកម្មយ៉ាងសំខាន់បំផុត គឺបញ្ចុះបញ្ចូលកម្ពុជាឲ្យចូលរួមសន្និសីទកំពូលឥណ្ឌូចិនមួយនៅពេល*

ខាងមុខ ។ ដើម្បីធ្វើឲ្យបរិយាកាសមានសង្ឃឹមឡើងវិញ ឡូ បានស្នើឲ្យមានសហប្រតិបត្តិការជាថ្មីដោយគ្មានលក្ខខណ្ឌក្នុងការបញ្ជូនទៅប្រទេសជាតិវិញនូវប្រជាជនកម្ពុជាទាំងអស់ដែលបានភៀសខ្លួនទៅប្រទេសវៀតណាមកាលពីប៉ុន្មានខែចុងក្រោយថ្មីៗនេះ[១៩] ។ ក្នុងករណីជាច្រើន ប្រតិបត្តិការនេះបែរជាមានលទ្ធផល ដោយការគិតគូររកស៊ីខាងផ្លូវជំនួញយ៉ាងគួរឲ្យអាម៉ាស់ទៅវិញ ។ អាស្រ័យហេតុនេះ នៅដើមឆ្នាំ១៩៧៧ ពួកអាជ្ញាធរតាមបណ្តាខេត្តរបស់វៀតណាម បានអនុញ្ញាតឲ្យខ្មែរក្រហមធ្វើការដោះដូរអ្នកភៀសខ្លួនសែសិបប្រាំបួននាក់ពីជំរុំម៉ុកវ៉ា ដោយប្តូរនឹងសត្វគោជាច្រើនក្បាល លើមូលដ្ឋានគោមួយក្បាលដូរមនុស្សម្នាក់[២០] ។

កម្ពុជាបានប្រានចោលគំនិតស្តីពីសន្និសីទកំពូលទាំងអស់ ។ សំណើនេះលេចឡើងហាក់ដូចជាការសម្តែងបន្ថែមមួយនៃចេតនារបស់វៀតណាម ដែលនៅតែចង់ដាក់ឥណ្ឌូចិនឲ្យស្ថិតនៅក្រោមអាណាព្យាបាលរបស់ខ្លួន ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ក្រុងភ្នំពេញបានបញ្ចេញប្រតិកម្មដោយប្រយ័ត្នប្រយែងនៅពេលដែលក្រុងហាណូយលើកយកមកនិយាយពី“ទំនាក់ទំនងពិសេស” ដែលកំពុងចងភ្ជាប់ប្រទេសវៀតណាម និងឡាវ ។ នៅខែធ្នូ ឆ្នាំ ១៩៧៦ ការប្រយ័ត្នប្រយែងនេះបានប្រែក្លាយទៅជាការព្រួយបារម្ភវិញនៅពេលដែលវាបង្ហាញថា គោលដៅយូរអង្វែងរបស់វៀតណាមគឺបង្កើតឲ្យមានចំណងទាក់ទងដ៏ជិតស្និទ្ធនិងជាអចិន្ត្រៃយ៍ជាមួយប្រទេសកម្ពុជា ។ សេចក្តីសម្រេចចិត្តចុងក្រោយរបស់បក្សកុម្មុយនីស្តវៀតណាមបានសង្កត់បញ្ជាក់ថា ប្រទេសវៀតណាមប្រាថ្នា “ការពារនិងពង្រីកទំនាក់ទំនងពិសេសរបស់ខ្លួនជាមួយប្រជាជនឡាវ និងកម្ពុជាជាបងប្អូន ពង្រឹងយុទ្ធសាមគ្គីភាព ការជឿទុកចិត្តទៅវិញទៅមក សហប្រតិបត្តិការយូរអង្វែងនិងការជួយឧបត្ថម្ភគ្នាទៅវិញទៅមកលើគ្រប់វិស័យ... ដើម្បីនឹងធ្វើឲ្យប្រជាជនទាំងបីដែលកាលពីដើមធ្លាប់រួបរួមគ្នាក្នុងការតស៊ូរំដោះជាតិ មានលទ្ធភាពចាប់ពីពេលនេះទៅក្នុងការស្ថាបនានិងការការពារប្រទេសរៀងៗខ្លួនជានិច្ចនិរន្តរ៍ ជាគុណប្រយោជន៍ដល់ឯករាជ្យភាព និងភាពចុំចេ្រីនរុងរឿងរបស់ប្រទេសនីមួយៗថែមទៀត”[២១] ។

ដប់ខែក្រោយមកការបោសសម្អាតជាបន្តបន្ទាប់ដែលចាប់ផ្តើមធ្វើនៅខែកញ្ញា ១៩៧៦ បានបណ្តាលឲ្យមានការកម្ទេចកម្មាភិបាលបដិវត្តន៍ជាច្រើនរយនាក់ ហើយជាពិសេសបានពង្រឹងការត្រួតត្រារបស់ ប៉ុល ពត លើក្បាលម៉ាស៊ីនដឹកនាំបក្សថែមទៀត ។ ប្រហែលនៅចុងខែមីនា ឆ្នាំ១៩៧៧ ចាប់ផ្តើមលេចឡើងនូវរបៀបបកស្រាយរបស់កម្ពុជាអំពី“ការសម្រេចចិត្តផ្តាច់ព្រ័ត្រ” ដើម្បីតតាំងនឹងការគំរាមកំហែងរបស់វៀតណាម ។ តាមប្រហែល ប៉ុល ពត បានសម្រេចបញ្ចប់បញ្ហានេះជាមួយនឹងការប្រឌិតឡើងនូវទំនាក់ទំនងជាអ្នកជិតខាងល្អជាមួយវៀតណាម ។ មួយផ្នែកគឺដល់ពេលវេលាដែលត្រូវចាត់ការដើម្បីកម្ចាត់អាណិកជនវៀតណាមនៅកម្ពុជាទាំងស្រុង ហើយមួយផ្នែកទៀតគឺធ្វើការវាយលុកប្រឆាំងនឹងប្រទេសវៀតណាមតែម្តង ។

រស់ សារឿន យន្តការីម្នាក់ដែលនៅរស់រានជីវិតពីបណ្តាឆ្នាំដ៏ខ្មៅងងឹតនៃរបប ប៉ុល ពត នៅនឹកឃើញយ៉ាងច្បាស់ពីថ្ងៃមួយនោះនាដើមខែមេសា ឆ្នាំ១៩៧៧ នៅឧដុង្គខេត្តកំពង់ស្ពឺ ។ ពេលនោះគាត់នៅឈរក្នុងមន្ទីរ

របស់ប្រធានស្រុកខ្មែរក្រហមដោយរង់ចាំការមកដល់របស់គាត់ដើម្បីដាក់ជូនបញ្ជីរថយន្តដែលខូចឲ្យគាត់ពិនិត្យ ។ សារឿន បានឃើញនៅលើតុធ្វើការនូវលិខិតមួយមានចុះកាលបរិច្ឆេទថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ដែលមានសរសេរថា ៖ «មតិណែនាំរបស់គណៈ៨៧០» ។ នៅជំនាន់នោះ សារឿន គ្មានដឹងថា លេខ«៨៧០»ជាលេខសម្ងាត់របស់គណៈមជ្ឈិមបក្សដ៏មានអំណាចបំផុតគឺអង្គការដ៏អាថ៌កំបាំងនោះទេ ។ ប៉ុន្តែ សេចក្តីក្នុងសំបុត្រនោះមានលក្ខណៈគួរឲ្យភ័យរន្ធត់បំផុត ៖ ជនជាតិវៀតណាមទាំងអស់ក្នុងតំបន់ព្រមទាំងជនជាតិខ្មែរ ដែលនិយាយភាសាវៀតណាម ឬដែលមានមិត្តភក្តិជាវៀតណាមត្រូវតែចាប់បញ្ជូនខ្លួនទៅឲ្យផ្នែកសន្តិសុខរបស់រដ្ឋ ។ សារឿន នៅតែឈរស្ទើរតែរឹងខ្លួនក្នុងទីនោះ ។ ជាកូនកំព្រា គាត់ត្រូវបានចិញ្ចឹមបីបាច់ដោយម្ចាស់យានដ្ឋានជាតិវៀតណាមម្នាក់នៅក្រុងភ្នំពេញ ។ ម្យ៉ាងទៀត គាត់ចេះនិយាយភាសាវៀតណាមនិងបានរៀបការជាមួយស្ត្រីវៀតណាមម្នាក់ផង ។ សំណាងល្អ ក្នុងសហករណ៍ដែលអ្នកទាំងពីររស់នៅគ្មានអ្នកណាម្នាក់បានដឹងពីសាវតាររបស់គាត់ឡើយ ។ សារឿន ជួសជុលឡានហ្ស៊ីប (Jeep) របស់គណៈស្រុក រួចក៏ប្រញាប់ប្រញាល់ត្រឡប់មកផ្ទះវិញភ្លាមដើម្បីប្រាប់ដំណឹងឲ្យប្រពន្ធគាត់ដឹង ។ ប៉ុន្តែនាងបានដឹងរឿងនេះរួចទៅហើយ ។ ស្ត្រីវៀតណាមម្នាក់ក្នុងភូមិទើបតែត្រូវសម្លាប់ដោយខ្មែរក្រហមវាយនឹងដំបង ហើយយកទៅកប់នៅខាងក្រៅភូមិយ៉ាងត្រឹមត្រូវ ។ ថ្ងៃមុនប្តីរបស់ស្ត្រីនោះបានត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅកាប់ឈើនៅក្នុងព្រៃ ។ ជាច្រើនថ្ងៃក្រោយមក ពេលគាត់ត្រឡប់មកវិញឃើញផ្ទះនៅទទេស្អាត ។ អ្នកជិតខាងដែលត្រូវធ្វើឲ្យបាក់ស្បាតបានបិទមាត់នៅស្ងៀម ហើយខំគេចពីគាត់ថែមទៀត ។ ដោយស្វែងរកប្រពន្ធនៅទីជិតខាងជុំវិញភូមិ គាត់បានរកឃើញអំពើសាហាវព្រៃផ្សៃនេះ គឺគាត់ឃើញដៃម្ខាងលេចចេញពីផ្នូរមួយដែលគេទើបនឹងកាយលុបថ្មីៗ ។ គាត់ស្គាល់ភិនភាគដៃនេះ ដោយគ្មានលំបាក ។ នៅសល់តែសំណួរមួយដែលគ្មានចម្លើយថា ៖ ហេតុអ្វី?[២២] ។ ចាប់តាំងពីខែមីនា ក្នុងគោលដៅត្រៀមទប់ទល់នឹងការប៉ះទង្គិចដោយអាវុធជាមួយវៀតណាម កងឯកភាពទ័ពជាច្រើនរបស់ភូមិភាគបូព៌ា បានត្រូវឲ្យឈប់បំពេញភារកិច្ចបង្កបង្កើនផល ដើម្បីរៀបចំខ្លួនទៅសមរភូមិវិញ ។ ក្នុងរាត្រីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ផ្តើមវាយឆ្លក់ជាបន្តបន្ទាប់ទៅលើភូមិ និងឃុំនានារបស់ខេត្តអានយ៉ាងក្នុងដែនដីសណ្តទន្លេមេគង្គដោយបាញ់សម្លាប់អ្នកភូមិ និងដុតផ្ទះសម្បែងអស់យ៉ាងច្រើន ។ ការវាយប្រហារទៅលើឃុំទិញបៀនតែមួយ បានធ្វើឲ្យប្រជាជនស៊ីវិលរងគ្រោះប្រហែល១០០នាក់ ។ មួយឆ្នាំក្រោយមក គេបានអនុញ្ញាតឲ្យខ្ញុំ(អ្នកនិពន្ធ) ធ្វើដំណើរទៅកាន់ទិញបៀន ដែលពីពេលនេះទៅបានប្រែក្លាយជាទីក្រុងខ្មោចទៅហើយ ជាកន្លែងដែលខ្ញុំអាចស្តាប់នូវរឿងនិទានផ្សេងៗរបស់អ្នកដែលរួចផុតពីគ្រោះភ័យនៃរាត្រីថ្ងៃទី៣០ ខែមេសា ដែលបណ្តាលឲ្យមានវិនាសកម្មយ៉ាងខ្លោចផ្សានោះ ។ តាមការពិត កម្ពុជាបានចាប់ផ្តើមធ្វើការវាយឆ្លក់ដំបូងៗរបស់ខ្លួនតាំងពីខែមករា ឆ្នាំ១៩៧៧ម្ល៉េះ ។ ប៉ុន្តែការវាយឆ្លក់របស់ខ្មែរក្រហមនៅថ្ងៃទី៣០ ខែមេសា ដ៏វិនាសហិនហោចនេះ គឺពួកគេចង់ជ្រើសរើសយកថ្ងៃខែជានិមិត្តរូបមួយ ។ ថ្ងៃនោះគឺជាថ្ងៃនៃការប្រារព្ធពិធីបុណ្យខួបឆ្នាំ

*ទីពីរនៃ«ការរំដោះវៀតណាមខាងត្បូង» (៣០ មេសា ១៩៧៥) និងមួយថ្ងៃមុន ថ្ងៃបុណ្យទី១ ឧសភា ដែលជាទិវាអន្តរជាតិនៃសាមគ្គីភាពរវាងពលករទូទាំងពិភពលោក ។*

## ហាណូយសង្ឃឹមលើជោគជ័យរបស់ តេង

*នៅពេលដែលម៉ាស៊ីនទូរអង្គុលីលេខ* (Téléscripteur) *គឺម៉ាស៊ីនអង្គុលីលេខសម្រាប់កត់អក្សរដែលគេបញ្ជូនមកពីចម្ងាយ នៃទីស្តីការក្រសួងការបរទេសលាន់ស្នូរឡើង ដើម្បីផ្សាយឲ្យដឹងជាសាធារណៈពីមរណភាពរបស់ ម៉ៅ ក្រុងហាណូយបានចែករំលែកស្នើគ្នារវាងការរង់ចាំ និងការសប្បាយរីករាយ ។ តាំងពីច្រើនខែមកហើយៗ ដោយពិតតាំងពីមរណភាពរបស់ ជូ អេនឡាយ នៅខែមករា ឆ្នាំ១៩៧៦ ព័ត៌មានផ្សេងៗដែលលេចចេញមកពីក្រុងប៉េកាំងបានឲ្យដឹងពីការកើនឡើងនូវការតស៊ូដើម្បីអំណាច និងការចម្រើនទៅមុខនៃពួកវ៉ាឌីកាល់ដែលប្រឈមមុខដាក់គ្នា ប្រសិនជាមានការតទល់គ្នាមែនទែន ។ មរណភាពរបស់ ម៉ៅ ជាស្នូរជួងមរណៈសម្រាប់ពួកឆ្វេងនិយមមែនឬ? ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុងហាណូយមានសង្ឃឹមពីរឿងនេះដែរ ។ ដើម្បីកុំឲ្យឱកាសមួយកន្លងទៅដោយខ្វះភាពស្មោះស្ម័គ្រក្នុងទំនាក់ទំនងដែលមានសភាពតានតឹងបំផុត រវាងប្រទេសទាំងពីរ វៀតណាមបានបញ្ជូនកម្រងផ្ការួមមរណទុក្ខយ៉ាងច្រើន ទៅកាន់ក្រុងប៉េកាំងតាមយន្តហោះពិសេសមួយគ្រឿង ។ ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមទាំងមូល ប្តូរសឹងតែទាំងអស់បានណាត់ជួបគ្នាក្នុងអគារមួយ ដែលមានរចនាប័ទ្មរបៀបជាព្រះវិហារ ដែលបម្រើជាស្ថានទូតរបស់ចិនប្រចាំក្រុងហាណូយ ដើម្បីចុះហត្ថលេខាក្នុងសៀវភៅចូលរួមសមានទុក្ខ ។*

*នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ ពួកមេដឹកនាំវៀតណាមស្ទើរតែមិនអាចទប់ការសប្បាយរីករាយយ៉ាងខ្លាំងរបស់ខ្លួនបានឡើយ នៅពេលដែលពួកគេបានដឹងពីការចាប់ខ្លួន «បន៤នាក់» ។ អ្នកដឹកនាំវៀតណាមម្នាក់ដែលពោរពេញទៅដោយទឹកចិត្តក្លៀវក្លាបានប្រកាសប្រាប់អ្នកឆ្លងឆ្លើយព័ត៌មានកាសែតលុយម៉ានីតេ* (l'Humanité) *ថា «លោកប្រហែលជាទៅក្រុងប៉េកាំងនៅឆ្នាំខាងមុខ ដើម្បីបំបិទបំបាំងព្រឹត្តិការណ៍នោះ»*[២៣] *។ ការទាយទុកជាមុននេះ មានលក្ខណៈមិនសូវអស្ចារ្យប៉ុន្មានទេ នៅសម័យមួយដែលបណ្តាសមាជិកបក្សកុម្មុយនីស្តបារាំងស្និទ្ធស្នូវៀត សុទ្ធតែជាមនុស្សដែលគេមិនចង់ឃើញមុខនៅប្រទេសចិន ។ អ៊ីចឹងហើយបានជាវៀតណាមមានសេចក្តីសង្ឃឹមថា បន្ទាប់ពីការកម្ចាត់ «បន៤នាក់» ប្រទេសចិនច្បាស់ជារកឃើញមាគ៌ាត្រឹមត្រូវឡើងវិញ ហើយប្រកាន់ឥរិយាបថមួយដែលមិនសូវចង្អៀតចង្អល់ (ស្រឡាញ់ជាតិខ្លួនឯងជ្រុលហួសហេតុ) និងទោរទន់ទៅរកលទ្ធិប្រតិបត្តិនិយមចំពោះប្រទេសរបស់ខ្លួនច្រើនជាងមុន ។ បើសិនកើតមានដោយចៃដន្យថា មាគ៌ានិយមផ្លូវកណ្តាលរបស់សព ជូ អេនឡាយ និង តេង ស៊ាវពីង ដែលពេលនេះរាសីកំពុងធ្លាក់ចុះ ចាប់ផ្តើមមានប្រៀបឡើងវិញនៅប្រទេសចិននោះនយោបាយឯករាជ្យរបស់ក្រុងហាណូយ ប្រហែលអាចសង្ឃឹមនិយាយស្តាប់គ្នា*

បានប្រសើរជាងមុនមិនខាន ។

ជាឧទាហរណ៍ឯកអគ្គរដ្ឋទូតរបស់វៀតណាមប្រចាំនៅប្រទេសចិន ង្វៀន ទ្រុងវិញ ក៏មានសេចក្តីសង្ឃឹមដែរ ។ គាត់បានព្រលយពាក្យឲ្យសហសេវិករបស់គាត់ខ្លះដឹងថា បើសិនជា តេង បានកាន់អំណាចឡើងវិញ ជម្លោះចិន-វៀតណាមស្តីពីកោះទាំងឡាយក្នុងសមុទ្រចិនភាគខាងត្បូង អាចនឹងរកឃើញដំណោះស្រាយមួយ ។ វិញ បានកត់សម្គាល់ពី តេង ថា ក្នុងឱកាសនៃការជួបជាមួយ ឡេ យន់ អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម នៅខែកញ្ញា ឆ្នាំ១៩៧៥ តេង បានទទួលស្គាល់ពីអត្ថិភាពនៃជម្លោះមួយ ហើយបានឲ្យដឹងពីបំណងរបស់គាត់ដែលនឹងផ្តល់នូវដំណោះស្រាយមួយនៅពេលក្រោយ ។ ប៉ុន្តែតាំងពីដើមដំបូងនៃ យុទ្ធនាការប្រឆាំងនឹង តេង នៅចុងឆ្នាំ១៩៧៥ ក្រុងប៉េកាំងបានបន្តឹងជំហររបស់ខ្លួនហើយប្រកាសថា កោះទាំងឡាយជា“ទឹកដីដ៏ពិសិដ្ឋរបស់មាតុភូមិជាទីស្រឡាញ់”របស់យើង ដោយហេតុនេះ គឺពុំអាចចរចាបានឡើយ ។ វៀតណាមធ្លាប់សង្ឃឹមថា ការជ្រើសតាំង តេង ឲ្យកាន់អំណាចឡើងវិញ អាចនឹងធ្វើឲ្យមានការខិតចូលជិតគ្នាភ្លាមៗមួយ ជាងទោរទន់ទៅរកហេតុការណ៍ជាក់ស្តែងស្តីពីបញ្ហានេះ[៧៤] ។

កាលបើដំណឹងស្តីពីការផ្លាស់ប្តូរផ្សេងៗដែលកើតមាននៅក្រុងប៉េកាំងរលាយបាត់ទៅ វៀតណាមក៏កំពុងរៀបចំផែនការប្រាំឆ្នាំទីពីររបស់ខ្លួនដែរ ។ តាំងពីមួយឆ្នាំមកហើយ ពួកមេដឹកនាំវៀតណាមបានធ្វើដំណើរទៅប្រទេសសង្គមនិយមនានាដើម្បីស្វែងរកមូលនិធិដែលចាំបាច់សម្រាប់ការកសាងប្រទេសឡើងវិញ ។ មហាប្រទេសសង្គមនិយមតែមួយគត់ដែលបដិសេធមិនចូលរួមជួយក្នុងរយៈពេលវែងគឺប្រទេសចិន ។ ការកម្ចាត់ចោលពួកវ៉ាឌីកាល់អាចមានន័យថា ជាការផ្លាស់ប្តូរឥរិយាបថមួយ ។ នៅថ្ងៃទី១៥ ខែតុលា គឺបីថ្ងៃបន្ទាប់ពីការប្រកាសផ្សាយឲ្យដឹងព្រឹត្តិការណ៍នោះ ក្រុងហាណូយដែលចង់បញ្ជាក់ឲ្យរឹតតែច្បាស់បានស្នើសុំជំនួយសេដ្ឋកិច្ចទៅទីក្រុងប៉េកាំងតាមរយៈសំបុត្រមួយ ។ ប៉ុន្តែ នៅពេលដែលក្រុងហាណូយប្រារព្ធបើកមហាសន្និបាតបក្សនៅខែធ្នូក្នុងសាលបាឌិញ ប្រកបទៅដោយការសប្បាយរីករាយបំផុតនោះ ការឆ្លើយតបបានទៅជារឿងដែលមេដឹកនាំវៀតណាមទន្ទឹងរង់ចាំជានិច្ច ។ គ្មានមុខប្រតិភូចិនណាម្នាក់ក្នុងចំណោមអ្នកតំណាងបក្សកុម្មុយនីស្តជាបងប្អូនចំនួនម្ភៃប្រាំបួន ដែលបានមកចូលរួមតាមការអញ្ជើញរបស់វៀតណាមឡើយ ។ នេះជាប្រភពនៃការរួញរាចិត្តមួយក្នុងសេចក្តីរាយការណ៍ខាងនយោបាយរបស់វៀតណាម ។ បន្ទាត់នយោបាយរបស់បក្សកុម្មុយនីស្តវៀតណាមលើឆាកអន្តរជាតិគឺតម្រង់ជាពិសេសទៅរកបុកប្រទេសមិនចូលបក្សសម្ព័ន្ធនិងតតិយលោក ។ បន្ទាត់នយោបាយនេះបានទុកមួយអន្លើនូវបញ្ហាជាសារវន្តដែលបានធ្វើឲ្យក្រុងប៉េកាំងនិងមូស្គូបែកបាក់គ្នា ។ វៀតណាមបានញែកឲ្យក្រុងប៉េកាំងឃើញនូវភាពខុសគ្នាក្នុងបញ្ហានេះ ដោយកំណត់ចក្រពត្តិនិយមអាមេរិកថា ជាអ្នកគំរាមកំហែងធំបំផុតប្រឆាំងនឹងសន្តិភាពពិភពលោក ប៉ុន្តែនៅយកចិត្តទុកដាក់សរសើរព្រមគ្នាចំពោះសហភាពសូវៀត និងប្រទេសចិនដែលបានសម្រេចជោគជ័យក្នុងការកសាងលទ្ធិសង្គមនិយមដែរ ។ វៀតណាមពុំបានបញ្ជាក់ពីប្រការ

នេះឲ្យច្បាស់ប្រាកដឡើយ ហើយក៏មិនជឿគំរូជាសកលមួយស្តីពីការបដិវត្តន៍ដែរ ៖ ប្រទេសនីមួយៗត្រូវតែធ្វើឲ្យយុទ្ធសាស្ត្រមួយ និងយុទ្ធវិធីមួយរីកចម្រើនសមស្របទៅតាមស្ថានភាពប្រទេសផ្ទាល់របស់ខ្លួន ។

តើប្រទេសចិនបញ្ចេញប្រតិកម្មបែបណាចំពោះការមិនចូលបក្សសម្ព័ន្ធរបស់វៀតណាម? ។ រយៈពេលរង់ចាំត្រូវបញ្ចប់ក្នុងបណ្តាថ្ងៃចុងក្រោយនៃខែកុម្ភៈ នៅពេលដែលចម្លើយពីប៉េកាំងឆ្លើយតបនឹងសំបុត្រមួយកាលពីខែតុលាមុនបានមកដល់វៀតណាម ។ តាមពិតនេះជាការល្បងពិសោធន៍ប្រតិកម្មរបស់ចិន ក្រោយ ម៉ៅទទួលមរណភាព ពុំមែនចង់សុំជំនួយផ្នែកសេដ្ឋកិច្ចមួយនោះទេ ។ នេះគឺជាការបដិសេធតាមរបៀបគួរសមមួយ ។ គេបានបកស្រាយប្រាប់អនុរដ្ឋមន្ត្រីវៀតណាមម្នាក់ដែលធ្វើដំណើរឆ្លងកាត់ក្រុងប៉េកាំងថា ប្រទេសចិនពុំអាចឆ្លើយតបតាមសំណើរបស់វៀតណាមបានទេ ពីព្រោះសេដ្ឋកិច្ចរបស់ខ្លួនផ្ទាល់ទើបនឹងងើបពីការខូចខាតដែលបង្កឡើងដោយពួក“បន៤នាក់”និងការរញ្ជួយដីយ៉ាងធ្ងន់ធ្ងរមួយ[២៥] ។

នេះពុំមែនជាលេសសាមញ្ញមួយទេ ទោះបីជាពុំមែនក៏ដោយ ក៏វាជាការបង្ហាញភស្តុតាងគួរឲ្យពេញចិត្តក្នុងការបដិសេធរបស់ចិនដែរ ។ បន្ទាប់ពីរយៈពេលដែលកើតមានការរំដើបរំជួលនិងសង្គ្រាមស៊ីវិលស្ទើរតែដប់ឆ្នាំនិងបន្តដោយការរញ្ជួយដី នៅខេត្តហេប៉ី (Hebei) ដែលជាមហន្តរាយដ៏ធំ នៅខែកក្កដា ឆ្នាំ១៩៧៦ ដោយធ្វើឲ្យមានអ្នករងគ្រោះ៧០ម៉ឺននាក់ និងបន្សល់ទុកអ្នកគ្មានជម្រកជាងមួយលាននាក់នោះ សេដ្ឋកិច្ចរបស់ចិនបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។ ប៉ុន្តែប្រការទាំងនេះពុំបានរារាំងមិនឲ្យក្រុងប៉េកាំងបញ្ជូន ហ្វាងយី ជាប្រញាប់មកកាន់ក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ១៩៧៦ឡើយ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយសេដ្ឋកិច្ចមួយសម្រាប់កម្ពុជាដោយគ្រោងធ្វើការប្រគល់“គ្រឿងសម្ភារបរិក្ខារផ្សេងៗ”ជាមុន ។ ហេតុផលពិតប្រាកដនៃការបដិសេធរបស់ចិន គឺប្រហែលជាចង់ស្វែងរកក្នុងអស្ថិរភាពនយោបាយនូវអ្វីដែលមានអត្ថប្រយោជន៍ពេលនោះនៅក្រុងប៉េកាំងហើយមើលទៅ ។ រយៈពេលបួនខែ ដើម្បីឆ្លើយតបនឹងសំបុត្ររបស់ប្រទេសវៀតណាមដែលចាំបាច់ខានមិនបាន គឺជាសញ្ញាបង្ហាញឲ្យឃើញថា ការជជែកវែកញែករកខុសត្រូវមួយបានប្រព្រឹត្តទៅស្តីពីគោលការណ៍ដែលត្រូវប្រកាន់យក ។ គេប្រហែលជាមិនដែលដឹងពីខ្លឹមសារនៃការជជែកពិភាក្សានោះសោះឡើយ ។ សេចក្តីសង្ឃឹមដែលវៀតណាមផ្អែកទៅលើរូបបុគ្គល តេង និងមាក៌និយមកណ្តាលថ្មីរបស់គាត់នោះឃើញថា មិនដឹងជាសំអាងទៅលើអ្វីដែរ ។ គេត្រូវតែរង់ចាំរហូតដល់ចុងឆ្នាំ១៩៧៨ ដើម្បីបានដឹងនូវអ្វីដែលកើតមានពិតប្រាកដក្នុងរឿងនេះ ។ ភាពមិនទៀងទាត់នៃស្ថានការណ៍អន្តរជាតិនៅពេលនោះបានធ្វើឲ្យ តេង ដែលតាំងខ្លួនឡើងនៅក្នុងចន្លោះពេលនោះជាមនុស្សខ្លាំងរបស់ប្រទេសចិនគឺជាសត្រូវដាច់ខាតបំផុតរបស់វៀតណាម ។ ប៉ុន្តែ នៅនិទាឃរដូវឆ្នាំ១៩៧៧ ទាំងពួកម៉ៅនិយមដែលប្រមូលផ្តុំជាថ្មីជុំវិញ ហ្វា គួហ្វេង ទាំងពួកប្រតិបត្តិនិយមដែលដឹកនាំដោយ តេង នៅមិនទាន់ទុកចិត្តខ្លួនឯងប៉ុន្មានទេ ដើម្បីផ្តើមគំនិតមុនគេខាងវិស័យនយោបាយបរទេស ជាពិសេសទៅទៀត វាផ្ទុយនឹងនយោបាយដែលបានអនុវត្តតាំងពីឆ្នាំ១៩៧៥

មក ។ សរុបសេចក្ដីទៅការសើរើពិនិត្យឡើងវិញមួយ អំពីទំនាក់ទំនងផ្សេងៗរវាងចិន-វៀតណាមនឹងមិនអាចមានទៅឯងៗឡើយដោយហេតុថា ភាពជូរចត់ដែលបន្សល់ទុកដោយជម្លោះទឹកដី ការប្រើអាកប្បកិរិយាមិនល្អដែលត្រៀមបម្រុងដោយក្រុងហាណូយចំពោះអាណិកជនចិននៅក្នុងប្រទេសវៀតណាម និងគំនិតផ្ដួចផ្ដើមទាំងឡាយរបស់ខ្លួនដើម្បីពង្រីកភាពខ្ពង់ខ្ពស់ជាងគេបំផុតរបស់វៀតណាមនៅឥណ្ឌូចិន ។ វាចាំបាច់ណាស់សម្រាប់មេដឹកនាំចិនដែលត្រូវតែធ្វើឲ្យមានភាពរយាលបន្តិច ភាពល្អិតល្អន់និងពោរពេញដោយភាពក្លាហានខាងនយោបាយ ដើម្បីជំរុញប្រទេសវៀតណាមដោយសកម្ម ក្នុងការស្វែងរកឯករាជ្យនយោបាយនិងធ្វើឲ្យការព្រួយបារម្ភអំពីរឿងសន្តិសុខរបស់ខ្លួនធូរស្រាល ។ ត្រង់កន្លែងដែលត្រូវបកស្រាយពីការប្រឹងប្រែងដែលសម្ដែងឲ្យឃើញដោយក្រុងហាណូយក្នុងគោលបំណងកែលម្អទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយបស្ចិមប្រទេសប្រៀបដូចកម្លាំងទប់ដ៏មានប្រយោជន៍មួយទល់នឹងឥទ្ធិពលក្រុងមូស្គូនោះ ពួកមេដឹកនាំចិនដែលនៅតែមិនទុកចិត្តបានត្រូវធ្វើឲ្យអាក់អន់ចិត្តនឹងរឿងទាំងនេះយ៉ាងខ្លាំង ។ ក្នុងទីបំផុត ទម្ងន់នៃប្រវត្តិសាស្ត្រមួយដែលផ្ទុកទៅដោយវិបរិយាកាស (ដំណើរប្រែត្រឡប់) និងសេចក្ដីភ័យខ្លាចចំពោះការរួមគំនិតគ្នាជាសម្ងាត់រវាងសូវៀត-វៀតណាម បានធ្វើឲ្យការសម្រេចចិត្តលេចឡើង : ប្រើព្រនង់ ប្រសើរជាងមើមការ៉ុត ។ ដោយជ្រើសរើសរវាងលទ្ធភាពផ្សេងៗ ដើម្បីឲ្យមានការខិតជិតគ្នាជាប្រពៃណីមួយ និងតាមវិធីនយោបាយដែលផ្ដល់គ្រោះថ្នាក់តិចជាងប្រទេសចិនបានចំណាយឥទ្ធិពលដែលខ្លួនអាចនៅមាននៅឡើយទៅលើវៀតណាមទាំងអស់ ។

នៅពេលដែលចម្លើយរបស់ប្រទេសចិនបំផ្លាញឲ្យសាបសូន្យនូវសេចក្ដីសង្ឃឹមទាំងអស់នៃការខិតជិតគ្នាទស្សនវិស័យនៃទិសដឹកនាំថ្មីមួយរបស់ចិនដោយចៀសវាងភាពស្និទ្ធស្នាលហួសប្រមាណជាមួយខ្មែរក្រហម ដែលក្រុងហាណូយចង់បានយ៉ាងខ្លាំងក្លានោះ ហាក់ដូចជារឹតតែឃ្លាតឆ្ងាយទៅៗ ។ ក្រុងប៉េកាំងបានយកចិត្តទុកដាក់ជាថ្មីចំពោះតំបន់នេះ ទុកណាជារដ្ឋធានីចិនដែលរំដើបរំជួលពេញទំហឹងកាលពីប្រាំខែមុន បានសម្ដែងឲ្យឃើញនូវភាពមិនអើពើមួយចំពោះរឿងរ៉ាវផ្សេងៗនៅអាស៊ីអាគ្នេយ៍ដែលប្រែប្រួលខុសពីមុន ។ ប្រទេសចិនមានបំណងបង្ហាញឲ្យឃើញដោយរបៀបមិនអាចបដិសេធបាននូវការកាត់ផ្ដាច់របស់ខ្លួនជាមួយការអនុវត្តគោលការណ៍ឆ្វេងជ្រុលកាលពីជំនាន់មុនៗ ។ ក្នុងគោលដៅនេះលោកជិទាវ តេង យិនជាវ ប្រពន្ធមេម៉ាយរបស់សព ជូ អេនឡាយ បានត្រូវបញ្ជូនទៅកាន់ប្រទេសភូមាសម្រាប់បេសកកម្មការទូតជាន់ខ្ពស់ជាលើកដំបូង នៅក្នុងប្រទេសនេះតាំងពីច្រើនឆ្នាំមកហើយ ។ បន្ទាប់មក លោកជិទាវបានទៅធ្វើទស្សនកិច្ចនៅប្រទេសប៉ាគីស្ថាន និងស្រីលង្កាទៀត ។ ទន្ទឹមនឹងនោះ ដោយទម្លាយឥរិយាបថនៅស្ងាត់ស្ងៀមក្នុងប៉ុន្មានខែចុងក្រោយរបស់គាត់ អៀង សារី បានធ្វើដំណើរទៅកាន់ក្រុងប៉េកាំងជាថ្មីដែលត្រូវបានមន្ត្រីជាន់ខ្ពស់ចិនទទួលបដិសណ្ឋារកិច្ចយ៉ាងអធិកអធមបំផុត ។ ក្រុងហាណូយបានកត់សម្គាល់ដោយការព្រួយបារម្ភចំពោះវត្តមានរបស់ឧត្ដមសេនីយ៍ វ៉ាង សាងរ៉ុង អគ្គសេនាធិការរងកងទ័ពចិន ក្នុងពិធីជប់លៀងមួយដែលផ្ដល់កិត្តិយសសម្រាប់ សារី ដោយឧបនាយករដ្ឋមន្ត្រី លី

ស៊ាននាន នៅថ្ងៃទី៣១ ខែមីនា នៅក្រុងប៉េកាំងផងដែរ ។ វត្តមានរបស់ វ៉ាង មានន័យដោយគ្មានឲ្យសង្ស័យថា សហប្រតិបត្តិការផ្នែកយោធាជាមួយកម្ពុជាពិតជាមានក្នុងរបៀបវារៈនៃការជួបជុំគ្នានោះហើយ ។

ប្រទេសចិនបានចាប់ផ្ដើមនាំយកប្រទេសកម្ពុជាឲ្យចេញផុតពីភាពឯកោនិយម (នយោបាយបរទេសនៃរដ្ឋមួយដែលនិយមមិនទាក់ទងនឹងកិច្ចការអន្តរជាតិឬប្រទេសក្រៅ) ដែលធ្វើឲ្យកម្ពុជាគ្រោកអរជាខ្លាំង និងប្រឆាំងទល់នឹង"ការវាយសម្រុកប្រលោមស្នេហ៍របស់វៀតណាម" ជាមួយបណ្ដាប្រទេសមិនមែនកុម្មុយនីស្តក្នុងតំបន់ផង ។ បណ្ដាញផ្សព្វផ្សាយព័ត៌មានរបស់ក្រុងប៉េកាំង ដែលបានឃ្លាំមើលដោយស្ងៀមស្ងាត់មួយចំពោះដំណើរដ៏គួរឲ្យកត់សម្គាល់បំផុត -ជាដំណើរលើកដំបូងតាំងពីសង្គ្រាមចប់- របស់អនុរដ្ឋមន្ត្រីការបរទេសវៀតណាម ផាន់ហៀន ក្នុងបណ្ដាប្រទេសអាស៊ាន នៅខែកក្កដា ឆ្នាំ១៩៧៦នោះ បានលាក់បាំងរឿងនេះ ដោយការស្ងើចសរសើរពីដំណើរទស្សនកិច្ចរបស់ សារី វិញ ។ មេដឹកនាំខ្មែរក្រហមបានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី សិង្ហបុរី និងភូមាដោយធ្វើជាអ្នកពាំនាំសារមួយដែលធានាអះអាងថា "ឥណ្ឌូចិនក្រហម" ដែលរួបរួមក្រោមការត្រួតត្រារបស់ក្រុងហាណូយពុំមានអត្ថិភាពទេ ។ សារី បានថ្លែងប្រាប់ឧបនាយករដ្ឋមន្ត្រីសិង្ហបុរី ស៊ីនណាថាំបី រ៉ាហ្សារ៉ាតណាំ ថា "ប្រជាជនកម្ពុជាពុំមានជំនឿចំពោះសហព័ន្ធឥណ្ឌូចិនមួយទេ ដោយគាត់បានប្រាប់ឲ្យដឹងទាំងអស់ពីជម្លោះទឹកដីដែលកំពុងធ្វើឲ្យកម្ពុជាប្រឈមមុខនឹងវៀតណាមទៀតផង ។ ដោយប្រហែលជាធ្វើផ្ទុយនឹងទស្សនៈឯកោនិយមជាប្រពៃណីរបស់កម្ពុជា សារី បានគូសបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យប្រាថ្នាបង្កើតទំនាក់ទំនងជាអ្នកជិតខាងល្អជាមួយសិង្ហបុរី និងជួយធ្វើឲ្យការផ្លាស់ប្តូរខាងវិស័យពាណិជ្ជកម្មកាន់តែរីកលូតលាស់ទៅអនាគតថែមទៀត[២៦] ។

មេដឹកនាំខ្មែរក្រហមបានបន្តដំណើរទស្សនកិច្ចរបស់ខ្លួនក្នុងតំបន់តទៅទៀត ។ ចំណែកប្រទេសចិន បន្ទាប់ពីមិនមាត់មិនកជាច្រើនខែស្ដីពីបញ្ហានេះ បានធ្វើការទាមទាររបស់ខ្លួនជាសាធារណៈម្ដងទៀតទៅលើកោះទាំងឡាយដែលស្ថិតនៅសមុទ្រចិនភាគខាងត្បូង ។ អត្ថបទដែលចេញផ្សាយក្នុងកាសែតមួយរបស់ចិន ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បានក្រើនរំឭកវៀតណាមនូវការសម្រេចចិត្តរបស់ប្រទេសចិនក្នុងការចូលកាន់កាប់ប្រជុំកោះស្ព្រាតលី ដែលមិនទាន់មាននរណាប៉ះពាល់ជាថ្មី[២៧] ។ សេចក្ដីថ្លែងការណ៍ជាច្រើន ដែលត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងឱកាសបុណ្យខួបលើកទីពីរនៃជ័យជម្នះរបស់ខ្មែរក្រហម បានបន្សល់ទុកនូវការសង្ស័យខ្លះៗអំពីចេតនារបស់កម្ពុជាដែលធ្វើឲ្យភាពតានតឹងជាមួយវៀតណាមកើនរឹតតែខ្លាំង និងអំពីការសន្យារបស់ប្រទេសចិនអែបមកខាង ប៉ុល ពតផង ។ ក្នុងឱកាសនៃពិធីជប់លៀងមួយដែលរៀបចំឡើងនៅភ្នំពេញ សារី បានឆ្លើយសារភាពដែលស្ទើរតែគ្មានលាក់លៀមពីការបោសសម្អាតជាច្រើនប្រឆាំងជនជាតិវៀតណាម ដែលផ្ដើមធ្វើក្នុងទូទាំងប្រទេស ។ នៅក្រុងប៉េកាំង រដ្ឋមន្ត្រីការបរទេសចិន ហួង ហួ បាននាំយកទៅនិយាយបន្តទៀតដោយថ្លែងសរសើរកម្ពុជាប្រជាធិបតេយ្យ ដែលបេះធ្វើឲ្យ"អំពើវិច្ឆេទកម្មដែលបង្កឡើងដោយពួកសត្រូវរបស់ខ្លួន ទោះជា

*នៅខាងក្នុង ឬមកពីខាងក្រៅត្រូវបរាជ័យទាំងអស់» ។ លោករដ្ឋមន្ត្រីបានឲ្យប្រទេសកម្ពុជាដឹងថា អំពីវិស័យនយោបាយការបរទេស មាគ៌ារបស់ ម៉ៅ ពុំមានចោទជាបញ្ហាឡើងវិញទេ ។ ដូច្នេះប្រទេសចិនមិនបោះបង់សម្ព័ន្ធភាពរបស់ខ្លួនជាមួយបណ្តាប្រទេសតូចតាចប្រឆាំងទល់នឹងការប្រើឧបាយកលសម្ងាត់ដែលនាំឲ្យមានភាពវឹកវរ ការជ្រៀតជ្រែក ឬការប្រើមធ្យោបាយបំភិតបំភ័យពីសំណាក់ពួកមហាអំណាចឡើយ ។ ហ្វួង និយាយថា «យើងជឿជាក់យ៉ាងប្រាកដថា ប្រជាជនចិននិងកម្ពុជាតទៅអនាគត នឹងរួបរួមគ្នាកាន់តែជិតស្និទ្ធថែមទៀត យើងនឹងវាយប្រយុទ្ធប្រកៀកស្មាគ្នា និងធ្វើដំណើរទៅមុខទាំងអស់គ្នាតាមផ្លូវនៃការប្រយុទ្ធតស៊ូរួមរបស់យើង»[២៨] ។*

*ការលើកទឹកចិត្តទាំងនេះ ហាក់ដូចជាការឲ្យតម្រុយដូច្នេះដែរ ។ ស្ទើរតែមិនដល់ពីរសប្តាហ៍ក្រោយមកផង ខ្មែរក្រហមបានចាប់ផ្តើមការវាយប្រហារក្នុងលក្ខណៈជាទ្រង់ទ្រាយធំជាលើកដំបូងរបស់ខ្លួនប្រឆាំងនឹងវៀតណាម ។ ការវាយប្រហារនេះត្រូវបានតបតមកវិញដោយការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសយ៉ាងច្រើន ។ យន្តហោះប្រដេញទម្លាក់គ្រាប់បែកធុន “Dragonfly A-37” ដែលបោះបង់ចោលដោយសហរដ្ឋអាមេរិកបានចាប់ផ្តើមសកម្មភាពឡើងវិញនៅក្នុងឱកាសនេះ ។ ប៉ុន្តែក្នុងចំណោមប្រទេសទាំងពីរ គ្មានប្រទេសណាមួយធ្វើសេចក្តីរាយការណ៍ស្តីពីឧបទ្ទវហេតុនៅតាមព្រំដែនរបស់ខ្លួនឡើយ ។ ការព្រមានជាលើកដំបូងរបស់វៀតណាមចំពោះកម្ពុជា ក្រោមទម្រង់ជាកំណត់ការទូតសម្ងាត់មួយចុះកាលបរិច្ឆេទថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៦៧ ត្រូវបានធ្វើមួយថ្ងៃមុនដំណើរទៅដល់ក្រុងប៉េកាំងរបស់ ផាំ វ៉ាន់ដុង ។ រដ្ឋមន្ត្រីការបរទេសរបស់វៀតណាមបានបញ្ជូនលិខិតមួយទៅឲ្យ សុក យាង ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំក្រុងហាណូយ ដែលក្នុងនោះគាត់បានផ្តល់យោបល់ឲ្យមានការបើកកិច្ចចរចាកម្រិតខ្ពស់មួយ ដើម្បីដោះស្រាយបញ្ហាព្រំដែន និងបញ្ចប់«ឧបទ្ទវហេតុប្រឡាក់ទៅដោយឈាម» ដែលកើតមានកន្លងមក ។ នេះជាការនិយាយយោងយ៉ាងច្បាស់ក្រឡែតពីការវាយប្រហាររបស់ខ្មែរក្រហមទៅលើទីប្រជុំជន ទិញបៀន និងខេត្តអានយ៉ាង ។ វៀតណាមបានចោទប្រកាន់ពួកមេដឹកនាំក្រុងភ្នំពេញដោយចំៗជាលើកដំបូងបំផុតថា «ការដាក់ឲ្យចូលប្រយុទ្ធនូវចំនួនទាហានដ៏សន្ធឹកសន្ធាប់ក្នុងប្រតិបត្តិការជាច្រើនលើកដំណាលគ្នា ទៅលើតំបន់ដ៏ធំល្វឹងល្វើយមួយពុំអាចកើតមានពីគំនិតផ្តួចផ្តើមរបស់អ្នកកាន់អំណាចកម្ពុជានៅតាមមូលដ្ឋានទាំងនោះទេ ។ បទឧក្រិដ្ឋដ៏សម្បើមទាំងនេះ ពិតជាប្រព្រឹត្តឡើងដោយមនុស្សមួយផ្នែកតូច គឺមនុស្សមួយក្រុម ដែលមានចេតនាមិនល្អ ក្នុងគោលបំណងចោទឲ្យមានភាពកករល្អក់ឡើងវិញដល់សាមគ្គីភាពជាប្រពៃណី និងមិត្តភាពជាបងប្អូន ដែលបាននិងកំពុងបង្រួបបង្រួមបក្ស និងប្រជាជនទាំងពីររបស់យើង»[២៩] ។*

*នៅថ្ងៃបន្ទាប់ ទិនានុប្បវត្តិរបស់កងទ័ពវៀតណាម គន់ដូយ ញ៉ានហ្សិន បានប្រើពាក្យបញ្ចិតបញ្ចៀងជាលើកដំបូងអំពីអត្ថិភាពនៃបញ្ហាព្រំដែនមួយដោយអំពាវនាវឲ្យកងទ័ពប្រុងប្រយ័ត្នជាប់ជានិច្ច ដើម្បីរុញច្រានទៅវិញនូវការវាយប្រហារណាមួយមិនឲ្យដឹងខ្លួនមុនពីសំណាក់សត្រូវ ។ តើសត្រូវជាអ្នកណា ហើយព្រំដែននៅត្រង់ណា? ប្រជាជនត្រូវតែរង់ចាំដល់ឆ្នាំ១៩៧៨ ទើបត្រូវប្រាប់ឲ្យដឹងពីរឿងនេះ ។*

ដោយឆ្លើយតបទៅនឹងសំណើរបស់វៀតណាម នៅថ្ងៃទី១៨ ខែមិថុនា រដ្ឋាភិបាលរបស់កម្ពុជាបានប្រាប់ឲ្យដឹងថា ការប្រជុំដើម្បីចរចាគ្នាទំនងដូចជាពុំអាចធ្វើបានឡើយ មុនការធ្វើឲ្យស្ថានការណ៍មានប្រក្រតីភាពសិនដែលនឹងត្រូវសម្រេចប្រកាន់យកនៅ«ពេលវេលាដ៏ជាក់លាក់»ណាមួយ[៣០] ។ មួយសប្តាហ៍ក្រោយមក រដ្ឋាភិបាលកម្ពុជាបានប្រើសម្តីបញ្ចិតបញ្ចៀងជាសាធារណៈ និងច្បាស់លាស់ជាលើកដំបូងបំផុតចំពោះការទាស់ទែងគ្នាជាមួយវៀតណាម ដោយថ្លែងសរសើរបណ្តាកម្មាភិបាលនិងយុទ្ធជននៅខេត្តកំពត ដែលមានព្រំដែនជាប់ប្រទេសវៀតណាមចំពោះ «ពលិកម្មរបស់ពួកគេក្នុងកិច្ចការពារព្រំដែនកោះទាំងឡាយ និងដែនទឹករបស់កម្ពុជាដែលមិនអាចប៉ះពាល់បាន»[៣១] ។

## ក្រុងប៉េកាំងបញ្ចេញអាកប្បកិរិយាជាសត្រូវ

ចំពេលដែលមានការធ្លាក់ចុះយ៉ាងច្បាស់ក្នុងទំនាក់ទំនងផ្សេងៗជាមួយប្រទេសកម្ពុជា រដ្ឋមន្ត្រីការពារប្រទេសវៀតណាម ឧត្តមសេនីយ៍ វ៉ៃ ង្វៀងយ៉ាប កំពុងស្ថិតនៅក្នុងដំណើរទៅកាន់សហភាពសូវៀត និងអឺរ៉ុបខាងកើត ។ ប៉ុន្តែ ដូចសព្វដង ពួកមេដឹកនាំវៀតណាមដែលប្រុងប្រយ័ត្ននិងដែលហ្វឹងហ្វឺនពីការធ្វើសកម្មភាពដោយឯករាជ្យរបស់ខ្លួននោះបានចៀសវាងមិនសម្តែងឲ្យឃើញថា ខ្លួនជាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធបំផុតរបស់ពួកសូវៀតនៅមុខក្រសែភ្នែកក្រុងប៉េកាំងឡើយ ។ បើទុកជាការលម្អៀងផ្នែកនយោបាយ និងសេចក្តីត្រូវការផ្នែកសេដ្ឋកិច្ចរបស់ខ្លួនប្រទាញទៅរកការខិតចូលជិតគ្នានិងក្រុងមូស្គូក៏ដោយ ក៏ពួកគេដឹងច្បាស់ណាស់ពីអំណាចរបស់ប្រទេសចិននៅពេលដែលហ៊ានធ្វើឲ្យប្រទេសនេះទាស់ចិត្ត ។ នៅខែមិថុនា មិនយូរប៉ុន្មាន បន្ទាប់ពីការវិលត្រឡប់របស់គាត់ពីទ្រឹកងមូស្គូ ឧត្តមសេនីយ៍ យ៉ាប បានចេញដំណើរទៅធ្វើ«ទស្សនកិច្ចជាផ្លូវការ និងជាមិត្តភាព»នៅប្រទេសចិនទៀតក្នុងឋានៈជាមេដឹកនាំគណៈប្រតិភូយោធាដ៏សម្បើមមួយ ។ ភាពធំដុំនៃគណៈប្រតិភូនេះ ត្រូវបានគិតគូរយ៉ាងឈ្លាសវៃបំផុតដោយរក្សាទុកសមាសភាពដដែល ដូចគ្នានឹងចំនួនសមាជិកគណៈប្រតិភូដែលគាត់ធ្លាប់ដឹកនាំទៅសហភាពសូវៀតកាលពីមុនដែរ ។ ដំណើរទស្សនកិច្ចនេះបានប្រព្រឹត្តទៅពុំបានទទួលផលល្អប្រសើរឡើយ ។ សមភាគីរបស់ យ៉ាប គឺសេនាប្រមុខ យេ ជានយីង ពុំបានទៅទទួលស្វាគមន៍គាត់នៅអាកាសយានដ្ឋាន ហើយក៏ពុំមានការជប់លៀងជាកិត្តិយសដែរ ។ ក្នុងកិច្ចសន្ទនាសំខាន់ៗជាច្រើន គូសន្ទនារបស់ យ៉ាប សុទ្ធតែជាឥស្សរជនថ្នាក់បន្ទាប់ ។ វៀតណាមបានត្រូវធ្វើឲ្យអាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង ។ គេបាននិយាយថា យ៉ាប បានធ្វើឲ្យ«ម្ចាស់ផ្ទះ»(ចិន)ភ័ន្តភាំងស្រឡាំងកាំង ដោយគាត់ប្រាប់រឿងស្ងាត់កំបាំងឲ្យដឹងថា «ទីប្រឹក្សាចិនជាច្រើននាក់របស់ខ្មែរក្រហមត្រូវបានចាប់ជាឈ្លើយសឹកនៅខែឧសភា ក្នុងឱកាសនៃការវាយប្រហារមួយប្រឆាំងនឹងវៀតណាម»[៣២] ។

បដិសណ្ឋារកិច្ចដែលគេត្រៀមបម្រុងសម្រាប់ យ៉ាប បានធ្វើឲ្យគាត់នឹកខឹងមិនតិចទេ ។ ដើម្បីបង្ហាញនូវ

ការមិនសប្បាយចិត្តរបស់ខ្លួន វៀតណាមបានចុះផ្សាយនៅទំព័រទីមួយនៃកាសែតកងទ័ពនូវអត្ថបទមួយ ដែលទុកសម្រាប់សារមន្ទីរហាណូយ និងសម្រាប់សមុច្ច័យ (ការប្រមូលទុកវត្ថុទាំងឡាយដែលស្រដៀងគ្នាឬដូចគ្នា) ជាប់នឹងរបាយការណ៍ស្តីពីដំណើររបស់ យ៉ាប នៅប្រទេសចិនដែលបង្ហាញឲ្យឃើញពីការតស៊ូ ដើម្បីឯករាជ្យរយៈពេលមួយពាន់ឆ្នាំរបស់វៀតណាមប្រឆាំងនឹងប្រទេសចិន ។

នៅថ្ងៃបន្ទាប់ពីការចេញដំណើររបស់ យ៉ាប នៅថ្ងៃទី៨ ខែមិថុនា រដ្ឋមន្ត្រីទី១ ផាំ វ៉ាន់ដុង បានត្រឡប់ពីក្រុងមូស្គូមកដល់ប្រទេសវិញ ដោយឈប់សំចតមួយរយៈខ្លីនៅក្រុងប៉េកាំង ។ កាលមុន ក្នុងឱកាសនៃការឈប់សំចតមួយរយៈខ្លីក្នុងរដ្ឋធានីចិននៅខែមេសា តាមផ្លូវឆ្ពោះទៅក្រុងប៉ារីសនោះ ដុង បានឲ្យយោបល់ស្តីពីការជួបប្រជុំគ្នាមួយដើម្បីពិភាក្សាដោះស្រាយបញ្ហាផ្សេងៗ ។ ការជួបប្រជុំគ្នានេះ ត្រូវបានគាត់រៀបចំជាមុនថាធ្វើនៅថ្ងៃទី៨ ខែមិថុនា ។ ដោយហេតុនេះ គាត់បានត្រៀមខ្លួនសម្រាប់ការសន្ទនាដោយស្មោះត្រង់មួយជាមួយ ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ដែលដឹងច្បាស់ប្រាកដពីសំណុំឯកសារទាក់ទងនឹងជំនួយមកឲ្យប្រទេសវៀតណាម ក្នុងឋានៈគាត់ជាអតីតដៃស្តាំរបស់ ជូ អេនឡាយ ទទួលបន្ទុកវិស័យសេដ្ឋកិច្ច ។ ប៉ុន្តែលើកនេះ ពុំមែនសន្ទនាពីបញ្ហាពាក្យសុំជំនួយរបស់វៀតណាមទេ ។ លី បាន ប្រគល់ឲ្យ ដុង នូវអនុស្សារណៈមួយដែលជាបណ្តឹងសារទុក្ខពិតប្រាកដប្រឆាំងនឹងប្រទេសវៀតណាមតែម្តង ។ លី បានចោទប្រកាន់វៀតណាមថា បានដឹកនាំនយោបាយប្រឆាំងចិនទាំងខាងពាក្យសម្តីក៏ដូចសកម្មភាព ។ នៅឆ្នាំ១៩៧៥ ប្រទេសចិនធ្លាប់បានធ្វើសំណើឲ្យមានការបើកកិច្ចចរចាគ្នាអំពីបញ្ហាព្រំដែនដែរ ។ លី បានស្តីបន្ទោស ដុង ថា "ប៉ុន្តែ ដោយលោកប្រើងប្រែងពន្យារពេលក្នុងការចរចានានា លោកពុំដែលបញ្ឈប់ការលុកលុយដោយខុសច្បាប់ មកក្នុងទឹកដីរបស់ចិនឡើយ ដោយលើកមូលហេតុថា ចំណែកដីត្រង់នេះឬត្រង់នោះត្រូវបានមកវៀតណាម ។ វៀតណាមក៏បង្កឲ្យមានការប្រយុទ្ធរប៉េះរប៉ោះនិងបង្កើនអំពើព្រៃផ្សៃគ្រប់បែបយ៉ាងទៀតផង"[៣៣] ។

គាត់បានចោទប្រកាន់ថា ចំនួនឧបទ្ទវហេតុតាមព្រំដែនបានកើនឡើងពី១០០ លើកនៅក្នុងឆ្នាំ១៩៧៤ ដល់៩០០លើកនៅឆ្នាំ១៩៧៦ ។ ប្រទេសវៀតណាមដែលកាលពីដើមនិងក្នុងអំឡុងពេលរាប់ឆ្នាំមកហើយ ធ្លាប់បានទទួលស្គាល់អធិបតេយ្យរបស់ចិនលើប្រជុំកោះប៉ារ៉ាសែល និងស្ព្រាតលី នោះ បានចូលលុកលុយប្រជុំកោះទាំងនេះ នៅឆ្នាំ១៩៧៥ ដោយបង្កើតឲ្យមានភាពតានតឹងមួយធំជាងគេបំផុត ។ លី ក៏បន្ទោសក្រុងហាណូយផងដែរ ចំពោះការមិនគោរពពាក្យសន្យារបស់ខ្លួន ដោយប្រើការបង្ខិតបង្ខំប្រឆាំងនឹងជនជាតិចិន ដែលកំពុងស្នាក់នៅវៀតណាមថែមទៀត ។ ក្រុងហាណូយមិនដែលបញ្ចេញឲ្យដឹងនូវអ្វីដែលជាប្រតិកម្មរបស់ ដុង សោះឡើយ ប៉ុន្តែតាមពួកចិនថា គាត់បានសាកល្បងនិយាយដោះសាពីការប្តូរគំនិតភ្លាមៗរបស់វៀតណាម ដោយសារការបង្ខំដែលតម្រូវដោយសង្គ្រាម ៖ ដោយជាប់ដៃប្រយុទ្ធនឹងពួកអាមេរិកាំងខ្លាំងពេក និងដោយពឹងផ្អែកខ្លាំងលើជំនួយរបស់ចិន ប្រទេសវៀតណាមពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីគិតគូរពីបញ្ហាកោះទាំងនោះទេ ។

ការជួបគ្នាដែលពោរពេញដោយភាពល្អឹងជូរចត់រវាងសមមិត្តកាលពីពេលកន្លងមកថ្មីៗក្នុងមហាសាលប្រជាជននៅក្រុងប៉េកាំង បានកំណត់នូវរបត់ជាស្ថាពរមួយ ។ សម័យកាលនៃសេចក្តីគួរសមខ្លាំង ការនិយាយបញ្ចិតបញ្ចៀង និងការរិះគន់ផ្សេងៗដែលខ្វះភាពច្បាស់លាស់គឺលែងមានតទៅទៀតហើយ ។ ចាប់ពីពេលនេះទៅ គេព្រលះគ្នាដោយប្រើពាក្យសម្តីធ្ងន់ៗដាក់គ្នាចំមុខតែម្តង គេគំរាមកំហែងគ្នាជាចំហឥតលាក់លៀម ។ ការទាស់ទែងគ្នានៅមិនទាន់លេចចេញជាសាធារណៈមែន ប៉ុន្តែគេញេញញ្ញេញដាក់គ្នារួចស្រេចទៅហើយ ។

## ប៉ុល ពត បង្កើតរឿងធ្វើឱ្យខូចចិត្ត

ការឈ្លានពានដ៏បង្ហូរឈាមរបស់ខ្មែរក្រហមប្រឆាំងនឹងភូមិនានារបស់វៀតណាម ហើយមួយខែក្រោយមកគឺនៅខែមិថុនា ដំណើរទៅកាន់ប្រទេសចិនដែលធ្វើឡើងក្រោកបន្តិចបន្តួចរបស់ឧត្តមសេនីយ៍ យ៉ាប និងការជួបគ្នាដ៏រំជើបរំជួលរវាង ផាំ វ៉ាន់ដុង និង លី ស៊ាននាន បានធ្វើឲ្យក្រុងហាណូយជឿប្រាកដក្នុងការបាម្ភរបស់ខ្លួនដែលត្រូវពង្រឹងសន្តិសុខផ្ទាល់ឲ្យរឹតតែខ្លាំងឡើងទៀត ។ វៀតណាមធ្លាប់មានជំនឿស៊ប់ដក់ ជាប់នៅក្នុងចិត្តថា សន្តិសុខប្រទេសរបស់ខ្លួនគឺទាក់ទងយ៉ាងជិតស្និទ្ធនឹងសន្តិសុខរបស់ប្រទេសឡាវ និងកម្ពុជា ។ ព្រឹត្តិការណ៍ផ្សេងៗក្នុងរយៈពេលពីរខែដែលកន្លងផុតទៅ បាននាំមកនូវភ័ស្តុតាងយ៉ាងច្រើនសម្រាប់បន្ថែមឲ្យការព្រួយបារម្ភរបស់ខ្លួនរឹតតែច្បាស់ឡើង ។ តាមមតិអ្នកយុទ្ធសាស្ត្រវៀតណាមថា បើសិនជាដោយគាប់ជួនមានមហាអំណាចជាសត្រូវមួយបង្កើតចំណងទាក់ទងដ៏ជិតស្និទ្ធជាមួយប្រទេសណាមួយក្នុងចំណោមប្រទេសទាំងពីរនោះ សន្តិសុខរបស់វៀតណាមនឹងពើបប្រទះនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមិនខាន ។ មិនយូរប៉ុន្មានក្រោយការវិលត្រឡប់របស់គាត់មកពីប្រទេសចិនវិញ ដុង បានចាប់ផ្តើមដំណើរជាថ្មី ។ លើកនេះ គោលដៅរបស់គាត់គឺប្រទេសឡាវ ជាកន្លែងដែលគាត់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាពមួយ ។ នេះជាខ្សែបន្ទាត់ការពារទីមួយប្រឆាំងនឹងការធ្វើអន្តរាគមន៍ដោយថាហេតុរបស់ចិននៅឥណ្ឌូចិន ។

នៅក្រុងវៀងច័ន្ទនាព្រឹកថ្ងៃទី១៥ ខែកក្កដានេះ ឥស្សរជនជាន់ខ្ពស់មួយចំនួនក្នុងគណៈប្រតិភូរបស់វៀតណាមបានផ្តល់នូវសហប្រតិបត្តិការដ៏ទូលំទូលាយដែលគ្រោងគិតដោយប្រទេសទាំងពីរ ។ ក្រៅពីអគ្គលេខាបក្ស ឡេយ៉ន់ (Le Duan) និងរដ្ឋមន្ត្រីទីមួយ ផាំ វ៉ាន់ដុង មានសមាជិកការិយាល័យនយោបាយពីររូប សមាជិកគណៈកម្មាធិការមជ្ឈិមបក្សពីររូប និងមន្ត្រីជួរការជាច្រើនរូបទៀតក៏បានធ្វើដំណើរទៅប្រទេសផ្សេងៗដែរ ។ នេះគឺជាលើកដំបូងហើយដែលប្រទេសឡាវបានទទួលស្វាគមន៍ -ហើយដែលប្រទេសវៀតណាមបញ្ជូនទៅ- នូវគណៈប្រតិភូជាន់ខ្ពស់មួយបែបនេះ ។ គណៈរដ្ឋមន្ត្រីឡាវស្ទើរតែទាំងអស់បានទៅទទួលស្វាគមន៍វៀតណាមដល់ចំណតអាកាសយានដ្ឋាន ។ ក្នុងចំណោមនោះក៏មាន“ព្រះអង្គម្ចាស់ក្រហម”ដែលមានពុកមាត់(ប្រធានាធិបតី សូផានុវង្ស) នាយករដ្ឋមន្ត្រី កៃសន ភូមិវិហាន រហូតដល់រដ្ឋលេខាធិការ ដែលមានឋានៈតូចទាបជាងគេទៀតផង ។ នៅថ្ងៃបន្ទាប់

ការប្រជុំហ្វូងមហាជនយ៉ាងធំមួយបានត្រូវរៀបចំឡើងនៅជិតវត្តថាតលួង ជាវត្តព្រះពុទ្ធសាសនាមួយ សម្រាប់ធ្វើការស្វាគមន៍ចំពោះភ្ញៀវជាសាធារណៈ ។ ប៉ុន្តែក្នុងហ្វូងមហាជនដែលប្រមូលផ្តុំដោយបក្សនៅទីនោះ តើអ្នកណាមួយដែលយល់ពិតប្រាកដពីអត្ថន័យនៃពាក្យសម្តីដែលថ្លែងដោយនាយករដ្ឋមន្ត្រី? ។ កៃសន ភូមិវិហាន បានរំឭកពីការធ្វើឲ្យបរាជ័យនូវ«គ្រប់ផែនការក្បត់និងប្រកបដោយល្បិចកល ព្រមទាំងអំពើវិច្ឆេទកម្មផ្សេងៗ ដែលអុជអាលដោយពួកចក្រពត្តិ និងពួកបរិវាររបស់វានិងពួកប្រតិកិរិយា ហើយបានសង្កត់បញ្ជាក់ពីភាពចាំបាច់ខានមិនបានដើម្បីធ្វើអ្វីៗគ្រប់យ៉ាងសំដៅពង្រឹងឯកភាពដ៏ជ្រាលជ្រៅជាមួយវៀតណាមសង្គមនិយមឲ្យរឹតតែរឹងមាំឡើងទៀត»[៣៤] ។

នាយករដ្ឋមន្ត្រី កៃសន បាននិយាយដៀមដាមដោយមិនចំពោះដល់ «ផែនការប្រកបដោយពិសពុល» របស់ប្រទេសចិន និងខ្មែរក្រហមដែលមានគោលដៅបំផ្លាញទំនាក់ទំនងពិសេសរបស់វៀតណាមជាមួយបណ្តាប្រទេសជិតខាងនៅឥណ្ឌូចិន ។ ការតបវិញភ្លាមៗរួមគ្នាចំពោះ «ផែនការទាំងនោះ» ត្រូវបានបង្ហាញឲ្យដឹងនៅព្រឹកថ្ងៃទី១៨ ខែកក្កដា ។ មុននឹងចាកចេញទៅក្រុងហាណូយវិញ វៀតណាមបានចុះហត្ថលេខាជាមួយប្រទេសឡាវលើសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការមួយ ។ ប្រទេសទាំងពីរត្រូវតែ «រួបរួមគ្នាជានិច្ចក្នុងការកសាងនិងការការពារប្រជាជាតិរបស់ខ្លួន» ។

មាត្រា១នៃសន្ធិសញ្ញានេះ ដែលសម្រេចសម្រាប់ពេល២៥ឆ្នាំ បានបង្គាប់ដោយដាច់ខាតឲ្យភាគីទាំងពីរត្រូវ «ធ្វើឲ្យប្រជាជននិងបក្សរៀងៗខ្លួនយល់ពីតម្លៃដែលព្រមព្រៀងគ្នាដោយយកចិត្តទុកដាក់ចំពោះទំនាក់ទំនងប្រកបដោយឯកសិទ្ធិរវាងប្រទេសវៀតណាមនិងប្រទេសឡាវ ដោយការគាំពារនិងការជួយជំរុញទំនាក់ទំនងនេះដើម្បីថែរក្សាកុំឲ្យមានមន្ទិលនិងគ្មានឧបសគ្គមករារាំងជារៀងរហូត» ។ ខសំខាន់នេះ មានគោលបំណងជម្នះឲ្យបាននូវការមិនចូលចិត្ត (ដោយមិនដឹងរឿងអ្វី) របស់ប្រជាជនឡាវចំពោះវៀតណាម និងបង្ការការលេចឡើងនូវគំនិតចង្អៀតចង្អល់និយមមួយ (ការកាន់ជើងជាតិមាតុភូមិជ្រុលហួសហេតុ) និងគំនិតមិនទុកចិត្តគេឯងមួយដូចដែលវាត្រូវធ្វើឲ្យពុះកញ្ជ្រោលខ្លាំងនៅប្រទេសកម្ពុជារួចមកហើយ ។ ថ្វីត្បិតតែបញ្ហាការពារប្រទេសនៅតែជាការទទួលខុសត្រូវរបស់រដ្ឋនីមួយៗក៏ដោយ ក៏មាត្រា២ ចែងថា ប្រទេសទាំងពីរ«គាំទ្រនិងជួយគ្នាទៅវិញទៅមកដោយឥតលក្ខខណ្ឌ» និង «សហការដ៏ជិតស្និទ្ធ ដើម្បីបង្កើនសមត្ថភាពការពារ និងគាំពាររក្សាឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីរបស់ខ្លួន និងកម្ទេចរាល់ផែនការនិងសកម្មភាពបំផ្លិចបំផ្លាញដែលអនុវត្តដោយពួកចក្រពត្តិនិងកម្លាំងប្រតិកិរិយាទាំងអស់នៅប្រទេសក្រៅ»[៣៥] ។

សន្ធិសញ្ញាមិត្តភាព និងកិច្ចព្រមព្រៀងបន្ទាប់បន្សំជាច្រើនដែលចុះហត្ថលេខាជាបន្តបន្ទាប់មកទៀត បានបង្កើតជាមូលដ្ឋានពេញលក្ខណៈច្បាប់ក្នុងការសហការផ្នែកនយោបាយដ៏ជិតស្និទ្ធមួយនិងអនុញ្ញាតឲ្យមានការពឹងផ្អែករបស់ប្រទេសឡាវចំពោះប្រទេសវៀតណាមអំពីវិស័យសន្តិសុខផង ។ អ្វីៗទាំងអស់បានមានអត្ថិភាព

ទៅតាមព្រឹត្តិន័យ (តាមដំណើរការដែលមានរួចមកហើយ) តាំងពីការបង្កើតសាធារណរដ្ឋឡាវម៉្លេះ ។ សន្ធិសញ្ញានេះបានរំពុកប្រទេសចិន និងកម្ពុជាឲ្យដឹងជាមុនថា ក្រុងហាណូយសម្រេចចិត្តរក្សាឧត្តមភាពរបស់ខ្លួននៅឥណ្ឌូចិនហើយ ថ្វីបើមានការប្រឆាំងជំទាស់នឹងខ្លួនក៏ដោយ ។ តាមពិត ក្រោយការវាយប្រហារជាច្រើនលើករបស់កម្ពុជា ការស្វែងរកទំនាក់ទំនងដែលមានឯកសិទ្ធិជាមួយប្រទេសឡាវ និងកម្ពុជា បានក្លាយទៅជាបញ្ហាអាទិភាពមួយ ហើយក៏ពុំមែនជាទស្សនវិស័យប្រយោលមួយដែរ ។

សម្រាប់ ប៉ុល ពត សន្ធិសញ្ញាវៀតណាម-ឡាវ បានធ្វើឲ្យអ្វីៗដែលអាក្រក់បំផុតទៅជាច្បាស់លាស់ឡើង ។ ប្រទេសវៀតណាមបានសម្រេចចិត្តបន្ទាប់ពីរារែកយ៉ាងយូរនិងបានចាប់ផ្តើមអនុវត្តគំនិតស្រមើស្រមៃពីសហព័ន្ធដ៏ចាស់គំរិលរបស់ខ្លួន ។ គេគ្មានសង្ស័យឡើយថា មហិច្ឆតារបស់វៀតណាមគឺ "ដណ្តើមយកប្រទេសកម្ពុជាទាំងមូលដោយកម្លាំង និងបញ្ចូលទៅក្នុងសហព័ន្ធមួយរបស់ឥណ្ឌូចិន ហើយក្នុងគោលដៅនេះ ក៏ដើម្បីជួយសម្រួលការធ្វើអន្តោប្រវេសន៍របស់ជនជាតិវៀតណាមរាប់រយពាន់នាក់ថែមទាំងរាប់លាននាក់ជារៀងរាល់ឆ្នាំមកកាន់កម្ពុជាផង" ។ ប៉ុល ពត បាននិយាយប្រាប់អ្នកសារព័ត៌មានយូហ្គោស្លាវីនៅខែមីនា ឆ្នាំ១៩៧៨ ជាសម្ងាត់ថា បើសិនជាក្រុងហាណូយសម្រេចគោលបំណងរបស់ខ្លួនមែននោះ "ប្រជាជនកម្ពុជានឹងក្លាយទៅជាជនជាតិភាគតិចធម្មតាមួយមិនខាន"[៣៦] ។ សន្ធិសញ្ញានេះជាសញ្ញាប្រាប់ឲ្យដឹងថា ប្រទេសវៀតណាមបានសម្រេចចិត្តភ្ជាប់ប្រទេសកម្ពុជាជារណបរបស់ខ្លួនរួចជាស្រេច[៣៧] ។

សាធារណជនគ្មានដឹងទាល់តែសោះពីការក្រែវអែងខុសទំនង ដែលសន្ធិសញ្ញានេះញ៉ាំងឲ្យ ប៉ុល ពត ចង់យកគំនិតតាម ។ ក្នុងបទយកការណ៍ខ្លីមួយសម្រាប់ទស្សនកិច្ចរបស់វៀតណាមនៅប្រទេសឡាវ វិទ្យុក្រុងភ្នំពេញគ្រាន់តែនិយាយបញ្ចិតបញ្ចៀងមិនច្បាស់លាស់ ចំពោះការមើលងាយឥតញញើតញញើម ដែលញ៉ាំងឲ្យប្រទេសវៀតណាម ផុសគំនិតគោរពអធិបតេយ្យភាពប្រទេសជិតខាងខ្លួន ដោយកំណត់ការព្រមព្រៀងត្រឹមតែថ្នាក់កុងស៊ុលប៉ុណ្ណោះ អាស្រ័យដោយអំណាចនៃមន្ត្រីជួរការរបស់ឡាវ និងវៀតណាម ដែល"នឹងត្រូវអនុញ្ញាតឲ្យឆ្លងកាត់ព្រំដែនដោយមិនចាំបាច់មានទិដ្ឋាការ"[៣៨] ។

## ការស្រើបស្រាលចិត្តរបស់អ្នកឈ្នះ

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧ ជាថ្ងៃដែលពួកមេដឹកនាំវៀតណាមចុះហត្ថលេខានៅខាងក្រោមសន្ធិសញ្ញាស្របទៅតាមទស្សនកិច្ចរបស់ខ្លួននៅក្រុងវៀងច័ន្ទនោះ ពួកកម្មាភិបាលជាន់ខ្ពស់នៃក្បាលម៉ាស៊ីនដឹកនាំបក្សសម្រាប់ភាគបូព៌ាកម្ពុជាបានជួបប្រជុំគ្នាជាសម្ងាត់ ដើម្បីកំណត់យុទ្ធសាស្ត្ររបស់ខ្លួនប្រឆាំងនឹងវៀតណាម ។ នេះជាការគាប់ជួនមួយគួរឲ្យឆ្ងល់ ។ សេចក្តីសម្រេចចិត្តដែលប្រកាន់យកក្នុងឱកាសនៃការប្រជុំនោះ មិនត្រូវបានផ្សព្វផ្សាយឲ្យដឹងជាសាធារណៈឡើយទាល់តែជាច្រើនខែក្រោយមកទៀត ទើបសំណៅដើមនៃកំណត់ហេតុ

ប្រជុំបានធ្លាក់ក្នុងកណ្តាប់ដៃវៀតណាម ក្នុងអំឡុងនៃប្រតិបត្តិការបោសសម្អាតមួយនៅប្រទេសកម្ពុជា ។ ពួកកម្មាភិបាលខ្មែរក្រហមប្រហែលជាដឹងថា ប្រទេសវៀតណាមនៅតែចិញ្ចឹម"មហិច្ឆតាខ្មៅងងឹតក្នុងការវាយដណ្តើមយកទឹកដីរបស់យើង និងកម្ទេចពូជសាសន៍ខ្មែរឲ្យសាបសូន្យជានិច្ច" ។ ដោយហេតុនេះ ទំនាស់រវាងរដ្ឋ "ពុំអាចដោះស្រាយតាមផ្លូវនយោបាយបានឡើយ" ។ ដោយនិយាយដៀមដាមត្រង់ៗចំពោះកម្មាភិបាលទាំងឡាយដែលរងគ្រោះពីការបោសសម្អាតជាច្រើន ព្រោះតែបដិសេធមិនដើរតាមមាគ៌ាប្រឆាំងវៀតណាមរបស់ខ្លួននោះ ការដោះស្រាយបញ្ហាបានចោទជាសំណួរថា "តើយើងជឿថា អាចដោះស្រាយ [ទំនាស់ជាមួយវៀតណាម] ដោយអនុវត្តតាមមាគ៌ារបស់បក្សយើង ឬយកតម្រាប់តាមភាពកំសាករបស់ក្រុមក្បត់ដែលលុតជង្គង់នៅមុខពួកយួន ហើយដាក់ខ្លួនជាខ្ញុំកញ្ជះវា? យើងត្រូវតែលត់ដំខ្លួនឲ្យរឹងប៉ឹងនិងមិនត្រូវប្រែក្លាយខ្លួនទៅជាខ្ញុំកញ្ជះយួនដាច់ខាត" ។

អត្ថបទនៃកំណត់ហេតុប្រជុំ បានជំរុញឲ្យយុទ្ធជនទាំងអស់ត្រៀមខ្លួនកម្ទេចវៀតណាមជានិច្ច ក្នុងករណីដែលមានការឈ្លានពានចូលកម្ពុជា ។ "បើសិនជាវៀតណាមប្រថុយផ្សងព្រេងចូលមកក្នុងទឹកដីរបស់យើង យើងមិនត្រឹមតែត្រូវបញ្ឈប់និងសម្លាប់ពួកវាប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវតែចាត់ការឲ្យបានមុន ហើយឆ្លងកាត់ព្រំដែន ដើម្បីកម្ទេចពួកវានៅក្នុងទឹកដីផ្ទាល់របស់វាក្នុងគោលដៅធ្វើឲ្យភាពក្លាហានរបស់វាចុះខ្សោយនិងបង្កើនការភ័យខ្លាចដែលវាមានដូចតែយើងដែរ ។ មិនយូរប៉ុន្មានក្រោយការវាយប្រហារ ពួកវានឹងលែងហ៊ានចូលលុកលុយប្រទេសយើង ហើយដល់ពេលដែលវាត្រូវការពារទប់ទល់វិញម្តង"[៣៩] ។

សេចក្តីសម្រេចចិត្តពុំបានផ្តល់នូវភាពជាក់លាក់ណាមួយចំពោះអ្វីដែលនឹងក្លាយទៅជាគោលដៅរបស់ខ្មែរក្រហម ដែលវៀតណាមធ្លាប់វាយបំបាក់ឲ្យនៅត្រឹមតែការការពារទប់ទល់ម្តងមកហើយទេ ។ ប៉ុន្តែចាប់ពីដើមឆ្នាំ១៩៧៧ សមាជិកខ្លះក្នុងចំណោមអ្នកនៅជុំវិញ ប៉ុល ពត ដែលរក្សាគំនិតហួសហេតុរួចមកហើយក្នុងការច្បាំងដណ្តើមយកកម្ពុជាក្រោម (ប្រទេសកម្ពុជាភាគខាងក្រោមសព្វថ្ងៃគឺដែនដីសណ្តទន្លេមេគង្គ) និងព្រៃនគរ[៤០] មកកាន់កាប់វិញ បានលើកកម្លាំងចិត្តកងទ័ពរបស់ខ្លួនឲ្យធ្វើការតស៊ូប្រឆាំងនឹងវៀតណាម ។

តើ ប៉ុល ពត គិតថា យុទ្ធជនក្មេងៗរបស់ខ្លួនដែលប្រដាប់ដោយសម្ភារសឹកមិនគ្រប់គ្រាន់អាចមានសមត្ថភាពយកជ័យជម្នះលើប្រទេសវៀតណាមប្រាកដមែនឬ? គាត់មានជំនឿដូច ម៉ៅ ដែរ អំពីឧត្តមភាពរបស់មនុស្សជាងទៅលើរថក្រោះ-រថពាសដែកនិងអាវុធ ។ ប្រការនេះត្រូវបានបន្ថែមដោយលទ្ធិជាតិនិយមចង្អៀតចង្អល់ដ៏ក្រអឺតក្រអោងរបស់ខ្មែរក្រហម ដែលផ្ទុកទៅដោយជំនឿមិនងាយរង្គោះរង្គើមួយចំពោះប្រជាជាតិ វីរភាពដ៏មោះមុតនិងសមត្ថភាពផ្សេងៗរបស់ខ្លួនផង ។ ប៉ុល ពត បានថ្លែងប្រកាសនៅខែកញ្ញា ឆ្នាំ១៩៧៧ថា "បើប្រជាជនយើងមានសមត្ថភាពស្ថាបនាប្រាសាទអង្គរវត្តបាន គាត់ក៏អាចធ្វើអ្វីៗគ្រប់យ៉ាងបានដែរ" ។ គាត់បានសម្រេចជោគជ័យក្នុងការញុំាងឲ្យគេជឿថា ខ្មែរក្រហមបានវាយឈ្នះសហរដ្ឋអាមេរិកទាំង

ស្រុក ហើយធ្លាប់ជួយវៀតណាមឲ្យដណ្តើមបានជ័យជម្នះផ្ទាល់របស់ខ្លួនថែមទៀត ។ អ្វីៗអាចធ្វើបានទាំងអស់ បន្ទាប់ពីជ័យជម្នះមួយដែលធ្វើឲ្យស្ទើបរំភើបដូច្នេះ ។ តាមទស្សនៈ ប៉ុល ពត ថា ពួកកងទ័ពរបស់ប្រទេសវៀតណាម វាគទី នឹងមិនមានសមត្ថភាពដូចកងទ័ពរបស់កម្ពុជា ដែលសុខចិត្តបូជាខ្លួនចំពោះបុព្វហេតុដ៏ត្រឹមត្រូវមួយរបស់ជាតិសោះឡើយ ។ កម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យស្ថិតនៅត្រង់ភាពបរិសុទ្ធខាងមនោគមវិជ្ជារបស់កងទ័ព និងអង្គការមូលដ្ឋានទាំងឡាយរបស់ខ្លួន ។ ក្នុងសម័យប្រជុំមួយរបស់បក្ស គាត់បានបញ្ជាក់ដូច្នេះថា "បើសិនជាយើងរៀបចំតម្រឹមតម្រង់កងទ័ពឲ្យបានល្អត្រឹមត្រូវ ខ្ញុំជឿថា យើងអាចយកជ័យជម្នះលើអាណ្ណាម(ប្រទេសវៀតណាម) បាន ពីព្រោះសង្គមយើងជាសង្គមសមូហនិយមមួយ នៅពេលដែលសង្គមរបស់វៀតណាមធ្វើមិនបានសម្រេចដូចយើង ហើយច្បាស់ជាអន្តរាយដោយការច្របូកច្របល់ និងការគ្មានសណ្តាប់ធ្នាប់ដែលបង្កឡើងដោយសាររបបកម្មសិទ្ធិឯកជន"[៤១] ។

ប្រហែលដោយសារ"ជោគជ័យ"ដែលបានមកដោយយុទ្ធជនរបស់ខ្លួនតាំងពីខែមេសា ឆ្នាំ១៩៧៧ គឺការកម្ទេចបំផ្លាញភូមិជាច្រើនរបស់វៀតណាម និងការសម្លាប់រង្គាលប្រជាជនស៊ីវិល ក្នុងឱកាសនៃការវាយឆ្មក់ជាច្រើនលើកដោយមិនឲ្យដឹងខ្លួនមុន ព្រមទាំងការគ្មានប្រតិកម្មរបស់វៀតណាមនោះហើយដែលជំរុញឲ្យ ប៉ុល ពត មានជំនឿទុកចិត្តមួយបែបនេះ ។ ក្រុងហាណូយត្រូវប្រឈមមុខនឹងការខ្វះខាតស្បៀងអាហារដ៏ធ្ងន់ធ្ងរមួយ វិបត្តិសង្គមដ៏ជ្រាលជ្រៅមួយនៅភាគខាងត្បូង និងការតស៊ូដោយអាវុធនៃក្រុមផ្សេងៗ ដែលក្នុងនោះយ៉ាងហោចមានចលនាមួយគឺ "រណសិរ្សរួបរួមដើម្បីការតស៊ូរបស់ពូជសាសន៍ដែលគេជិះជាន់" យើងធ្លាប់ឮគេហៅពួកនេះថាពួកហ្វុលរ៉ូៗ [តាមអក្សរកាត់ជាភាសាបារាំងថា F.U.L.R.O. (Front Uni pour la Lutte des Races Opprimées)] ដែលទទួលគុណប្រយោជន៍ពីការជួយគាំទ្ររបស់ខ្មែរក្រហមដែរ ហើយការលំបាកទាំងនេះ ប្រហែលជាធ្វើឲ្យប្រទេសកម្ពុជាមានចិត្តមោះមុតគ្មានកោតញញើតដូច្នេះ ។

គេអះអាងថារបប ប៉ុល ពត បានឈានដល់ធ្វើសេចក្តីសម្រេចថា ដំណោះស្រាយដោយការចរចាមួយស្តីពីជម្លោះទឹកដីជាមួយប្រទេសវៀតណាម គឺពុំអាចធ្វើបានឡើយ ។ ដើម្បីធានាឯករាជ្យភាព និងបូរណភាពទឹកដីរបស់ប្រទេស ប៉ុល ពត មិនព្រមរិះរកមធ្យោបាយណាផ្សេងក្រៅតែពីការបង្ហាញកម្លាំងទ័ពនៅតាមបណ្តោយព្រំដែននិងការពោលអះអាងជាសាធារណៈនូវការទាមទាររបស់ខ្លួនអំពីព្រំដែនសមុទ្រឡើយ ។ ក្នុងឱកាសនៃកិច្ចចរចាបញ្ហាព្រំដែននៅខែឧសភា ឆ្នាំ១៩៧៦ អ្នកចរចាវៀតណាម ផាន់ ហៀន មិនព្រមទទួលស្គាល់ខ្សែបន្ទាត់ប្រេវីយេសម្រាប់ធ្វើជាគោលវិនិច្ឆ័យដើម្បីកំណត់ព្រំដែនសមុទ្រទេ ។ ដោយលើកទៅថ្ងៃក្រោយ កិច្ចចរចាស្តីពីរឿងនេះមិនដែលបានបើកធ្វើឡើងវិញទាល់តែសោះ ។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ក្រុងហាណូយ បាននិយាយឲ្យដឹងថា តំបន់សេដ្ឋកិច្ចរបស់ខ្លួនលាតសន្ធឹងពីឆ្នេរទៅលំហសមុទ្រហូតដល់២០០ម៉ៃល៍ (ប្រហែល ៣២០គីឡូម៉ែត្រ)[៤២] ។

*បើទុកជាវៀតណាមប្រកាសត្រៀមខ្លួន "ស្វែងរកដំណោះស្រាយតាមកិច្ចចរចាជាមួយប្រទេសពាក់ព័ន្ធទាំងអស់ស្តីពីបញ្ហាផ្សេងៗទាក់ទងទៅនឹងតំបន់សមុទ្រនិងតំបន់ខ្ពង់រាបបាតសមុទ្រ ដោយឈរលើមូលដ្ឋាននៃការគោរពឯករាជ្យភាព និងអធិបតេយ្យភាពទៅវិញទៅមក និងទៅតាមច្បាប់អន្តរជាតិ"ក៏ដោយ ក៏ប្រទេសកម្ពុជាមិនជឿពីរឿងនេះដែរ ។ ទស្សនាវដ្តី"កម្ពុជាប្រជាធិបតេយ្យឈានទៅមុខ"ប្រចាំខែសីហា ឆ្នាំ១៩៧៧ ដែលជាទស្សនាវដ្តីដ៏ប្រណីតសម្រាប់ការឃោសនានៅបរទេសនោះ បានបោះពុម្ពផែនទីប្រទេសកម្ពុជាមួយ ។ ចំណុចតែមួយដែលគួរកត់សម្គាល់ជាងគេគឺ ខ្សែបន្ទាត់ចុចៗមួយ (ខ្សែបន្ទាត់ប្រេវីយេ) នៅលើផែនទីដែលគេគូសកាត់ឈូងសមុទ្រថៃ គឺសម្រាប់សម្គាល់ថានេះជាព្រំដែនសមុទ្ររបស់កម្ពុជា ។ នេះគឺជាចម្លើយរបស់ក្រុងភ្នំពេញចំពោះការចង់បានដែនសមុទ្ររបស់វៀតណាម ។*

*នៅថ្ងៃទី៣០ ខែកក្កដា អ្នកធ្វើអត្ថាធិប្បាយម្នាក់នៃវិទ្យុក្រុងភ្នំពេញបានរំឭកថា កាលពីពេលកន្លងមក ពួក "បនក្បត់កាន់អំណាច" នៅកម្ពុជាពុំចេះប្រឆាំងតបតចំពោះការរំលោភបំពានជាច្រើនលើកមកលើដែនសមុទ្ររបស់ខ្លួនឡើយដោយសង្កត់បញ្ជាក់ថា វាពុំដូចគ្នាទេក្នុង"ដំណាក់កាលបដិវត្តន៍បច្ចុប្បន្ន ដែលចេះការពារនិងកសាងប្រទេស" ។ ដោយរៀបរាប់ឈ្មោះកោះទាំងឡាយដែលត្រួតត្រាដោយកងទ័ពបដិវត្តន៍កម្ពុជា បទអត្ថាធិប្បាយបានព្រមានឲ្យដឹងពីការប្តេជ្ញាចិត្ត ប្រឆាំង"គ្រប់ការឈ្លានពានទាំងអស់មកលើបណ្តាកោះ និងគ្រប់ការជ្រៀតចូលដែនទឹករបស់ខ្លួន ដែលចេញមកពីសត្រូវមួយចំនួនទាំងឆ្ងាយទាំងជិតទោះជាសត្រូវណាក៏ដោយ[៤៣] ។ ពេលវេលាដល់ហើយ ដើម្បីផ្តល់ការព្រមានដ៏ខ្វះខ្វារមួយចំពោះក្រុងហាណូយ" ។*

## ការអះអាងបន្ថែមនៅក្រុងប៉េកាំង

*នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧ គំនិតសុទិដ្ឋិនិយមដ៏ជាក់លាក់មួយបានស្ថិតមាននៅមួយរយៈនៅក្រុងប៉េកាំង ។ នេះជាលើកដំបូងបំផុតតាំងពីយូរមកហើយ ដែលទីក្រុងនេះជាកន្លែងមានប្រារព្ធពិធីធំៗដូច្នេះ ។ ឆ្នាំ១៩៧៦ បានផ្តើមឡើងដោយមរណភាពរបស់ ជូ អេនឡាយ ។ បន្ទាប់មកមានព្រឹត្តិការណ៍ជាបន្តបន្ទាប់គ្នា គឺចលាចលផ្នែកនយោបាយ ការរញ្ជួយដីដែលបណ្តាលឲ្យមនុស្សស្លាប់យ៉ាងច្រើន មរណភាពរបស់ ម៉ៅ សេទុង និងការផ្លាស់ប្តូរឥស្សរជននយោបាយជាថ្មីដ៏គួរឲ្យភ្ញាក់ផ្អើលមួយ ។ ប្រទេសចិនដែលត្រូវធ្វើឲ្យគាំងចលនាពាក់កណ្តាលបានដកដង្ហើមធំបន្ទូរភាពតានតឹងក្នុងចិត្ត ដោយការដួលរលំរបស់ពួកវ៉ាឌីកាល់ ប៉ុន្តែតាមការពិត ចិនមានហេតុផលផ្សេងៗទៀតក្នុងការសម្តែងទឹកចិត្តរីករាយតិចតួចដែរ ។ នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ មានប្រារព្ធពិធីបុណ្យខួបលើកទី២៨ នៃកំណើតសាធារណរដ្ឋប្រជាមានិតចិនយ៉ាងអធិកអធម ។ នេះសុទ្ធតែជាបណ្តាពិធីបុណ្យធំៗជាផ្លូវការលើកដំបូងក្នុងប្រទេសចិនក្រោយសម័យ ម៉ៅ ហើយនេះក៏ជាឱកាសដែលគេមិនបានរង់ចាំមុននូវការលេចមុខជាអន្តរជាតិលើកដំបូងរបស់មេដឹកនាំកម្ពុជាម្នាក់ ដែលគេមិនធ្លាប់ដែលឃើញមុខសោះរហូតមកទល់នឹង*

*ពេលនេះ ហើយក៏ជាការអះអាងបន្ថែមពីសម្ព័ន្ធភាពចិន-កម្ពុជា ជាសាធារណៈផងដែរ ។ មិនត្រឹមតែដើម្បីរំឭកបុណ្យជាតិរបស់ចិនប៉ុណ្ណោះទេ ព្រោះនៅលើវេទិកា គេឃើញមានទង់ជាតិពណ៌ក្រហមល្មើងរបស់កម្ពុជាប្រជាធិបតេយ្យបក់រវិចៗកណ្តាលទង់ជាតិចិនជាច្រើន ។ ចង្កៀងគោមជាច្រើននៅតាមរុក្ខវិថីឆាងអាន ដែលនៅបណ្តោយវិមាន La Porte de la Paix Céleste ព្រមទាំងអំពូលភ្លើងធំៗពណ៌សមានរាងផ្កាឈូកក៏មានដោតទង់ជាតិរបស់សម្ពន្ធមិត្រអាស៊ីទាំងពីរដែរ ។ កូនសិស្សរាប់រយនាក់ដែលជាអ្នកកាន់ប៉ង់កាត មានលាបពណ៌ចម្រុះនៅឈរផ្ដុំគ្នាទាំងសងខាងទ្វារចូល ។ តាមការឲ្យសញ្ញា ពួកកូនសិស្សទាំងនេះបានលើកគ្រវីប៉ង់កាតផុតពីក្បាល ដែលមានសរសេរអក្សរចិន និងខ្មែរថា "ស្វាគមន៍" ។ ពលរដ្ឋក្រុងប៉េកាំងចំនួនដប់ម៉ឺននាក់ បានត្រូវគេកេណ្ឌប្រមូលដើម្បីឲ្យទៅស្រែកជយឃោសអបអរសាទរបណ្ដាភ្ញៀវពិសេសរបស់ខ្លួន ពលរដ្ឋទាំងនោះបានឈរជារបងយ៉ាងវែងមិនចេះផុតមួយ នៅខាងមុខអាកាសយានដ្ឋាននិងតាមបណ្តោយរុក្ខវិថីឆាងអាន ។ ប៉ុន្តែ ទោះជាភាគច្រើននៃហ្វូងមនុស្សរាយរងដែលប្រមូលផ្ដុំគ្នានៅទីនោះ ពុំគិតពីអត្តសញ្ញាណពួកភ្ញៀវដែលខ្លួនត្រូវផ្ដល់កិត្តិយសបន្តិចសោះក៏ដោយ ក៏ការរៀបចំទាំងនេះល្មមគ្រប់គ្រាន់បញ្ជាក់ឲ្យឃើញថា ភ្ញៀវទាំងនោះសុទ្ធតែជាមហាមិត្តរបស់ប្រទេសចិនហើយ ។*

*ព្រឹកនោះ នៅពេលដែលជនជាតិខ្មែរម្នាក់ប្រកបដោយទឹកមុខញញឹមពព្រាយ កាត់សក់ជ្រុង និងស្លៀកពាក់ខោអាវពណ៌ត្នោតចាស់របៀប ម៉ៅ លេចមុខចេញពីយន្តហោះប៊ូអ៊ីង-៧០៧ មួយគ្រឿងរបស់ចិន អាថ៌កំបាំងមួយជ្រុងដែលរុំព័ទ្ធជុំវិញពួកមេដឹកនាំខ្មែរក្រហម ត្រូវបានបើកចេញមួយផ្នែក ។ ព្រោះថា មនុស្សម្នាក់នេះដែលជាមេដឹកនាំកំពូលរបស់បដិវត្តន៍កម្ពុជា ហើយដែលគ្មានអ្នកណាមួយធ្លាប់បានឃើញមុខជាសាធារណៈសោះនោះមានឈ្មោះថា ប៉ុល ពត ។ នៅនិទាឃរដូវឆ្នាំ១៩៧៦ ពេលដែលវិទ្យុភ្នំពេញបានប្រកាសផ្សាយជាសាធារណៈថា នាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យមានឈ្មោះថា ប៉ុល ពត នោះ ការសិក្សាស្រាវជ្រាវអំពីអត្តសញ្ញាណពិតប្រាកដរបស់មនុស្សដែលគេមិនស្គាល់ទាំងស្រុងនេះ បានប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស ។ ប្អូនខែបន្ទាប់ពីការតែងតាំងរូបគាត់ អាថ៌កំបាំងប្រែទៅជាកាន់តែងងឹតឡើងៗថែមទៀត នៅពេលដែលគេដឹងថា គាត់បានដកខ្លួនថយជាបណ្តោះអាសន្នដោយសារមូលហេតុសុខភាព ។ គេលែងឮអ្នកណាម្នាក់និយាយពីគាត់ទៀតហើយ រហូតទាល់តែគាត់ដើរជាន់លើកម្រាលព្រំក្រហមនៅអាកាសយានដ្ឋានក្រុងប៉េកាំង ។ នៅទីបំផុត មនុស្សដែលគ្មានអ្នកណាស្គាល់បានលេចមុខទាំងសាច់ទាំងឈាមតែម្ដង ក្រោមការយកចិត្តទុកដាក់ពីមតិសាធារណៈអន្តរជាតិយ៉ាងច្រើន ។ ដោយបញ្ចេញស្នាមញញឹមយ៉ាងស្រស់មួយពេលចុះពីលើយន្តហោះ ប៉ុល ពត បានចាប់រលាក់ដៃគ្នាទៅវិញទៅមកជាមួយនាយករដ្ឋមន្ត្រី និងប្រធានបក្សរបស់ចិន ហ្វា គួហ្វេង យ៉ាងកក់ក្ដៅបំផុត ។ មេដឹកនាំជាន់ខ្ពស់ប្រាំបីនាក់ប្រហែលមួយភាគបីនៃសមាជិកការិយាល័យនយោបាយដ៏មានឥទ្ធិពលខ្លាំងបំផុតក្នុងចំណោមនោះមាន តេង ស៊ាវពីង ដែលបានផ្ដល់សិទ្ធិអំណាចឡើងវិញកាលពីពេលថ្មីៗបានទៅជួបជុំគ្នានៅ*

អាកាសយានដ្ឋាន ដើម្បីសម្តែងឲ្យឃើញនូវមិត្តភាពដ៏ជ្រាលជ្រៅដែលកំពុងបង្រួបបង្រួមប្រទេសចិននិងកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែល ប៉ុល ពត និង ហ្វា ឈរក្បែរគ្នាលើរថយន្តបើកដំបូលមួយគ្រឿង ធ្វើដំណើរតាមរុក្ខវិថីឆាងអាន ហ្វូងប្រជាជនបានវាយគងឃ្មោះលាន់រំពង គ្រវីទង់ជាតិក្រដាសនៃកម្ពុជាប្រជាធិបតេយ្យ និងព្រលែងប៉ឺតប៉ោងរាប់រយឲ្យហោះទៅក្នុងអាកាស ។ ការទះដៃអបអរសាទរបានលាន់ឮទ្រហឹងអឺងកងអមតាមដំណើរឆ្លងកាត់នៃក្បួនដង្ហែជាកិត្តិយស ។

ក្នុងឱកាសនៃសន្និសីទកាសែតមួយនៅក្រុងប៉េកាំង ជាមួយបណ្តាញអ្នកសារព័ត៌មានចិន ប៉ុល ពត បានធ្វើសេចក្តីសង្ខេបខ្លីមួយស្តីពីជីវិតបដិវត្តន៍របស់គាត់ ប៉ុន្តែ គ្មានពេលណាមួយដែលគាត់និយាយថា គាត់ជាអ្នកណាឡើយ ។ ដោយប្រៀបធៀបរូបថតជាច្រើន និងសេចក្តីរៀបរាប់ខ្លះៗពីជីវប្រវត្តិរបស់គាត់ អ្នកឯកទេសជាច្រើនបានសម្រេចធ្វើការសន្និដ្ឋានថា ប៉ុល ពត និងមេដឹកនាំកុម្មុយនីស្តឈ្មោះ សាឡុត ស ដែលបាត់មុខពីភ្នំពេញ នៅឆ្នាំ១៩៦៣ គឺជាមនុស្សតែមួយ ។ ក្រៅពីមិត្តចិន កូរ៉េខាងជើងនិងអ្នកឯកទេសបរទេសមួយក្តាប់តូច គ្មានអ្នកណាម្នាក់ដឹងថា ប៉ុល ពត នៅរង់ចាំបញ្ចប់ការបោសសម្អាតប្រឡាក់ទៅដោយឈាមដែលបានដឹកនាំធ្វើពេញថិរវេលាមួយឆ្នាំប្រឆាំងនឹងសត្រូវរបស់គាត់ដែលពិតប្រាកដ ឬដែលគ្រាន់តែសង្ស័យក្នុងផ្ទៃបក្សឲ្យចប់សិន ទើបគាត់ចេញពីទីងងឹតទេ ។ ពេលនេះគាត់ដឹងថា មានសន្តិសុខគ្រប់គ្រាន់ហើយ ដើម្បីបង្ហាញឲ្យពិភពលោកដឹងឮពីអត្តិភាពនៃបក្សកុម្មុយនីស្តកម្ពុជាដែលលាក់មុខតាំងពីយូរយារណាស់មកហើយ ក្រោមរបាំងអនាមិកថា "អង្គការ" និងដើម្បីផ្តើមធ្វើដំណើរទៅបរទេសជាលើកដំបូងរបស់គាត់ក្នុងឋានៈជាអគ្គលេខាបក្សនិងជានាយករដ្ឋមន្ត្រីផង ។

ក្នុងពិធីបុណ្យដ៏អឹកអធឹកផ្សេងៗដែលផ្តល់ជូនក្នុងឱកាសបុណ្យជាតិរបស់ចិន នៅវេលាល្ងាចថ្ងៃទី១ ខែតុលា ប៉ុល ពត ជាភ្ញៀវកិត្តិយស បានធ្វើបុកពាជាអ្នកធំដោយឈរនៅក្បែរប្រធានបក្ស ហ្វា គួហ្វេង លើវេទិកាកិត្តិយស ហើយបានថ្លែងសរសើរពីការជ្រួចដែលគេបាញ់ទៀតផង ។ ក្នុងចំណោមភ្ញៀវបរទេសដទៃៗទៀតដែលមានវត្តមាននៅល្ងាចនោះ គេសង្កេតឃើញមាន ហ្វូង វ៉ាន់ហ៊ាន់ ដែរ ។ ថ្វីដ្បិតតែគាត់ត្រូវបណ្តេញចេញពីគណៈកម្មាធិការមជ្ឈិមបក្សក៏ដោយ ក៏គាត់នៅតែជាអនុប្រធានសភាជាតិវៀតណាមដដែល ។ មិនដឹងថាតើគាត់ (ហ៊ាន់) មានឱកាសបានជួបពិភាក្សាដោយគ្មានសាក្សីជាមួយ ប៉ុល ពត ដើម្បីស្វែងយល់មុនបង្អស់អំពីការទិតៀនដ៏ជូរចត់របស់កម្ពុជាដែរឬក៏អត់ទេ ដុយទៅវិញ ដើម្បីជម្រាប ប៉ុល ពត អំពីរបៀបវិនិច្ឆ័យរបស់ពួកមេដឹកនាំវៀតណាមផង ប៉ុន្តែគំនិតនេះមានលក្ខណៈទាក់ទាញចិត្តយ៉ាងខ្លាំង ដោយហេតុថា ពីរឆ្នាំក្រោយមក ហ៊ាន់ បានធ្វើឲ្យពិភពលោកភ្ញាក់ផ្អើលស្រឡាំងកាំង ព្រោះគាត់បានក្លាយទៅជាមេដឹកនាំជាន់ខ្ពស់វៀតណាមដំបូងបំផុត ដែលចុះចូលនឹងប្រទេសចិន ហើយបានថ្កោលទោសនយោបាយរបស់ក្រុងហាណូយចំពោះប្រទេសកម្ពុជាថែមទៀត ។

ក្នុងសុន្ទរកថាផ្សេងៗគ្នា ដែលគាត់ថ្លែងនៅក្រុងប៉េកាំង ក្នុងឱកាសពិធីជប់លៀងឬសន្និសីទកាសែត ប៉ុល ពត តែងនិយាយបញ្ឆិតបញ្ឆៀងទៅរកការច្បាំងដណ្តើមយកទឹកដីកម្ពុជាខ្លះកាលពីអតីតដោយពួកថៃនិងវៀត

ណាមដែលជាអ្នកជិតខាង ។ ប្រាកដណាស់ថា ឈ្មោះវៀតណាមតែងផុសឡើងក្នុងគំនិតគាត់ជានិច្ចនៅពេលដែលគាត់ប្រកាសថា «យើងនឹងមិនអត់ឱនឲ្យការឈ្លានពាន ការបង្កហេតុ ការជ្រៀតជ្រែក ការធ្វើវិទ្ធង្សនា ឬសកម្មភាពឈ្លបយកការណ៍ណាមួយប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនយើងឡើយ ទោះជាចេញពីប្រភពណាក៏ដោយ» ។ គាត់បានបន្ថែមទៀតថា «របបបដិវត្តន៍កម្ពុជាមានករណីយកិច្ចការពារព្រំដែនរបស់ខ្លួន ហើយធ្វើយ៉ាងណាឲ្យទាល់តែព្រំដែនទាំងនេះមិនត្រូវបានសើរើឡើងវិញជាដាច់ខាត»[៤៤] ។

ក្នុងពេលធ្វើការផ្លាស់ប្តូរយោបល់គ្នាជាសម្ងាត់ជាមួយបណ្តាមេដឹកនាំចិន ប៉ុល ពត បានរំឭកប្រាប់អំពីសកម្មភាពវាយលុកប្រឆាំងប្រទេសវៀតណាមជាយថាហេតុថែមទៀត គឺមិនត្រឹមតែការពារខ្លួនប៉ុណ្ណោះទេ ។ គាត់បាននិយាយប្រាប់ ហ៊ា និងមេដឹកនាំចិនដទៃទៀតជាសម្ងាត់ថា តាមគាត់យល់ ទឹកចិត្តរបស់កងទ័ពវៀតណាមនៅមានកម្រិតទាបណាស់ ហើយទាហានរបស់វៀតណាមមានសភាពហាក់ដូចជាពុំអាចទ្រាំទ្រនឹងការខ្វះខាតឡើយ ។ គាត់បាននិយាយថា «ក្នុងស្ថានភាពទាំងនេះ គ្រាន់តែចលនាបដិវត្តន៍នៅអាស៊ីអាគ្នេយ៍ បង្កើនការវាយប្រហាររបស់ខ្លួនតែបន្តិច ស្ថានការណ៍មុខជាវិវត្តផ្តល់ភាពអនុគ្រោះមិនខាន ហើយនៅពេលនោះ យើងនឹងអាចដោះស្រាយបញ្ហាផ្សេងៗរបស់យើងបាន» ។ គាត់បានបំភ្លឺប្រាប់ពួកចិនថា «បក្សរបស់កម្ពុជាបានផ្លាស់ប្តូរទស្សនៈគ្នាយ៉ាងច្រើនអំពីបញ្ហានេះជាមួយបណ្តាបក្សរបស់ថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ភូមា ហើយបក្សទាំងនោះសុទ្ធតែសម្តែងមតិយល់ស្របជាមួយគាត់ដែរ ។ ប៉ុល ពត សន្និដ្ឋានថា «ទោះជានៅមានបញ្ហាជាច្រើនដែលត្រូវជម្នះពុះពារឲ្យបានមុននឹងឈានទៅដល់គោលដៅរបស់យើងក៏ដោយ ក៏យើងអាចសំអាងលើការគាំទ្ររបស់មិត្តចិននៅភាគខាងជើង ហើយនៅអាស៊ី-អាគ្នេយ៍ យើងអាចធ្វើឲ្យមានមតិឯកភាពតែមួយសម្រាប់ជាផលប្រយោជន៍របស់យើង ។ ការប្រែប្រួលជាយុទ្ធសាស្ត្រនេះគឺជាការលើកកម្លាំងចិត្តដ៏ធំធេងចំពោះយើង»[៤៥] ។

ឯកសារសម្ងាត់ផ្សេងៗដែលលាក់បាំងមិនឲ្យដឹងនៅក្រុងប៉េកាំងបានបង្ហាញឲ្យឃើញក្រោយមកទៀតថា ប៉ុល ពត មិនដែលឲ្យតម្លៃហួសហេតុពីទំហំនៃការគាំទ្ររបស់ចិនសោះឡើយ ។ ដោយពិត ក្នុងរបាយការណ៍សម្ងាត់មួយស្តីពីស្ថានការណ៍អន្តរជាតិដែល ហួង ហួ ថ្លែងនៅមុខគណៈកម្មាធិការមួយរបស់បក្សនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ បានដៅបញ្ជាក់ថា ការកម្ចាត់ពួកភ្នាក់ងារជ្រៀតចូលនៃលទ្ធិសេរីនិយមសូវៀតដែលផ្តើមធ្វើដោយ ប៉ុល ពត គឺជាវិធានការត្រឹមត្រូវមួយ ពីព្រោះវា«បានធ្វើឲ្យកងទ័ពរបស់គាត់ស្អាតបរិសុទ្ធប្រាសចាកភាពពុករលួយ និងជួយពង្រឹងសមត្ថភាពប្រយុទ្ធរបស់កងទ័ពថែមទៀត» ។ ហួ បានសង្កត់បញ្ជាក់ថា ការបោសសម្អាតទាំងនេះរួមនឹងការបដិសេធរបស់កម្ពុជាមិនទទួលយកអាណាព្យាបាលរបស់វៀតណាម និងជម្លោះផ្នែកមនោគមវិជ្ជារវាងប្រទេសទាំងពីរបាននាំទៅដល់ការបង្កឲ្យមានភាពជាសត្រូវនឹងគ្នាពិតប្រាកដ ។ បើទុកជា ហួង ហួ និយាយរៀបរាប់បញ្ចូលពីការជ្រៀតជ្រែកមួយរបស់សូវៀតក៏ដោយ ក៏គាត់នឹកគិតថែមទៀតពីប្រទេសវៀតណាមដោយរំពឹកពីយថាភាពនៃសង្គ្រាមមួយរវាងប្រទេសកម្ពុជានិងពួកសេរីនិយម ។ គាត់បានពោលអះអាងថា «ដូន

កាលសង្គ្រាមត្រឹមត្រូវមួយអាចបើកឱកាសឲ្យមានការពង្រឹងឧត្តមភាពម្ខាងៗ ហើយសង្គ្រាមផ្តាច់ព្រ័ត្រមួយ គឺជាមធ្យោបាយអាចដោះស្រាយបញ្ហាទាំងអស់» ។ តម្លៃដែលត្រូវបង់គឺធ្ងន់ធ្ងរជាទីបំផុត ប៉ុន្តែលទ្ធផលដែលបានមកក៏ស្មើនឹងការប្រឹងប្រែងនោះដែរ ។ តាមមតិគាត់ថា ប្រទេសចិនពុំអាចស្ថិតនៅស្ងៀមដោយមិនបញ្ចេញប្រតិកម្មនិងអត់ឱនចំពោះការចោទឲ្យមានបញ្ហាឡើងវិញដោយពួកសេរីនិយមសូវៀតអំពីអធិបតេយ្យភាពរបស់កម្ពុជាឡើយ ៖ «យើងគាំទ្រយ៉ាងម៉ឺងម៉ាត់នូវការសម្រេចរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាក្នុងការតស៊ូទល់នឹងលទ្ធិសង្គមចក្រពត្តិនិយម (Social-impérialisme) ហើយយើងនឹងផ្តល់ជំនួយគ្រប់បែបយ៉ាងតាមដែលយើងមានលទ្ធភាពផ្តល់ឲ្យ»[៤៦] ។

វាពិបាកបំភ្លឺឲ្យច្បាស់ថាតើការសន្យាដែលធ្វើឲ្យភ្ញាក់ផ្អើលនេះ ជាគុណប្រយោជន៍ដល់«សង្គ្រាមត្រឹមត្រូវ» មួយ ឆ្លុះបញ្ចាំងឲ្យឃើញពីជំហរជាឯកច្ឆ័ន្ទរបស់ក្រុមមេដឹកនាំចិនឬមួយថា តើនេះជាលក្ខណៈសញ្ញានៃអត្ថប្រយោជន៍ដែលប្រកាន់យកដោយពួកម៉ៅនិយមក្នុងការតស៊ូដែលបន្តធ្វើឲ្យពួកនេះប្រឆាំងនឹងពួកប្រតិបត្តិនិយមណាស់ ។ គ្មានឯកសារណាមួយរបស់ចិន ដែលមានមកនៅពេលក្រោយទៀតរំលឹកដោយច្បាស់លាស់ពីសេចក្តីប្រកាសនេះឡើយ ហើយប៉ុន្មានខែក្រោយមក មេដឹកនាំចិននិយមកណ្តាលម្នាក់បានប្រឹងប្រែងរម្ងាប់នយោបាយផ្សងព្រេងប្រឆាំងវៀតណាមរបស់ខ្មែរក្រហមដែរ ។ ដូច្នេះ អ្វីៗទាំងអស់បានធ្វើឲ្យគេគិតថា នៅនិទាឃរដូវឆ្នាំ ១៩៧៧ ការគាំទ្រចំពោះ ប៉ុល ពត គឺជាទង្វើរបស់បក្សពួកឆ្វេងនិយមយ៉ាងពិតប្រាកដ ។

ប៉ុន្តែនៅបរទេសគ្មានមនុស្សណាម្នាក់ដឹងពីឥទ្ធិពលនៃការប្រើល្បិច និងឧបាយកលដោយចំពោះនៃនយោបាយនៅក្នុងប្រទេសចិន ស្តីពីបញ្ហានៃការគាំទ្រចំពោះប្រទេសកម្ពុជាទាល់តែសោះ ។ សម្រាប់ពិភពខាងក្រៅខ្លឹមសារនេះគឺមានន័យច្បាស់លាស់បំផុត ការលាតត្រដាងរបស់កាសែតបស្ចិមប្រទេស ការសម្លាប់រង្គាល ដែលប្រព្រឹត្តឡើងនៅកម្ពុជាគ្មានអ្វីទាក់ទាញបន្តិចសោះ ដោយប្រទេសចិននៅតែស្មោះត្រង់ចំពោះបណ្តាសម្ព័ន្ធមិត្តរបស់ខ្លួនដដែល ។ ហួ បានប្រកាសក្នុងពិធីជប់លៀងមួយថា «វីរប្រជាជនកម្ពុជាមិនត្រឹមតែសម្រេចជោគជ័យក្នុងការកម្ទេចសង្គមចាស់ប៉ុណ្ណោះទេ តែក៏បង្ហាញឲ្យឃើញថា ខ្លួនក៏ចេះកសាងសង្គមថ្មីមួយផងដែរ» ។ រឹតតែច្បាស់លាស់ជាងនេះ ទុកណាជាភាសាដែលគាត់ប្រើក្នុងមជ្ឈដ្ឋានដោយឡែកដែលពន្យល់មិនកើតក៏ដោយ ក៏គាត់បានថ្លែងសរសើរចំពោះការបោសសម្អាតផ្សេងៗ និងការឈ្លានពានប្រឆាំងវៀតណាមជាច្រើនលើក ដែលផ្តើមធ្វើដោយ ប៉ុល ពត ដែរ ។គាត់បានសម្តែងសេចក្តីអបអរសាទរចំពោះជោគជ័យដែលទទួលបានក្នុងកិច្ចការពារបូរណភាពដែនដីរបស់កម្ពុជា និយាយដោយឡែក គឺក្នុងសង្គ្រាមព្រំដែនជាមួយវៀតណាម និងការកម្ទេចឲ្យសាបសូន្យនូវ «ឧបាយកលបំផ្លិចបំផ្លាញ និងបង្កហេតុរបស់សត្រូវផ្ទៃក្នុងនិងខាងក្រៅ» ។ ហួ និយាយប្រាប់ ប៉ុល ពត ដែលសើចញញឹមពព្រាយថា ៖ «បងប្អូនរួមអាវុធ ចិនមានសេចក្តីរីករាយយ៉ាងលើសលប់ចំពោះមុខជ័យជម្នះដ៏ត្រចះត្រចង់របស់អស់លោក»[៤៧] ។

*ដំណើរពោរពេញដោយជោគជ័យរបស់ ប៉ុល ពត នៅប្រទេសចិន គ្មានអ្វីក្រៅពីកម្ចាត់ភាពសង្ស័យ និងភាពអាចប្រែប្រួលដែលធ្វើឲ្យខូចដល់ទំនាក់ទំនងចិនកម្ពុជាតាំងពីសរទរដូវឆ្នាំ១៩៧៦ឡើយ ។ វាក៏បានជួយពង្រឹងជំហរផ្ទាល់របស់គាត់ក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជាឲ្យរឹតតែរឹងមាំឡើងដែរ ។ វាជាភស្តុតាងថា ជាបឋមមិត្តភាពរបស់ក្រុងប៉េកាំងគឺសំអាងលើលក្ខខណ្ឌខាងប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ-យុទ្ធសាស្ត្រ (Géostratégique) ហើយអ្វីដែលសំខាន់គឺថាប្រទេសកម្ពុជាអាចប្រឆាំងតទល់នឹងប្រទេសវៀតណាមដែលជាគូប្រជែងដ៏ចម្បងបំផុតរបស់ប្រទេសចិននៅក្នុងតំបន់ផង ។*

# សម្តេច ព្រះនរោត្តម សីហនុ : ចាកចេញពីឆាកនយោបាយ

ការចាកចេញពីអាកាសធាតុត្រជាក់ និងអ័ព្ទក្រាស់បែកផ្សែងនៃទីក្រុងប៉េកាំង គឺជាភាពធូរស្បើយព្រះទ័យមួយសម្រាប់ សម្តេច សីហនុ ។ ថ្ងៃនីមួយៗនៅក្រុងភ្នំពេញក្នុងខែធ្នូ មានសភាពស្រទន់ និងពោរពេញទៅដោយពន្លឺព្រះអាទិត្យ ។ វាលំបាកខ្លះៗជាមួយភាពសើមបន្តិចៗដែលធ្វើឲ្យខ្វាយខ្វល់នៅរដូវភ្លៀងធ្លាក់ ។ ហើយកាលបើគ្មានពន្លឺថ្ងៃចែងចាំងដែលលែងធ្វើឲ្យទន្លេមេគង្គឆ្លុះរស្មីផ្លេកៗនោះ វាអាចនឹងមានខ្យល់ដំនោរត្រជាក់បក់មកបបោសអង្អែលខ្លួនប្រាណអ្នកម្តងម្កាលដែរ ។ វាដល់ពេលល្មមដែលព្រះអង្គយាងត្រឡប់មកវិញបន្ទាប់ពីការនិរទេសព្រះកាយប្រាំឆ្នាំ ។ ប៉ុន្តែសម្រាប់ព្រះអង្គ ថ្ងៃទាំងឡាយហាក់ដូចជាសោះកក្រោះដូចក្នុងរយៈពេលនៃការគង់នៅដោយបង្ខំចិត្តនៅទីក្រុងប៉េកាំងដែរ ។ សម្តេចធ្លាប់មានព្រះរាជបំណងប្រែព្រះកាយទៅជាឯកអគ្គរាជទូតគោចរនៃកម្ពុជាថ្មី ដោយយាងត្រាច់ចរទៅគ្រប់ទិសទីក្នុងពិភពលោក ដើម្បីស្វែងរកសមានចិត្តការគាំទ្រនិងជំនួយសម្រាប់ការកសាងប្រទេសរបស់ព្រះអង្គ ដែលត្រូវបំផ្លិចបំផ្លាញដោយសង្គ្រាមឡើងវិញ ។ ប៉ុន្តែខ្មែរក្រហមបានជំទាស់នឹងរឿងនេះ ។ ពួកគេបានបដិសេធមិនផ្តល់ជំនឿទុកចិត្តចំពោះក្សត្រ(សក្តិភូមិ)មួយអង្គដើម្បីបង្ហាញជាថ្មីនូវនិន្នាការបដិវត្តន៍របស់ទ្រង់នៅបរទេសជាមួយនឹងការខ្វះខ្វែង បើមិនដូច្នោះទេជាមួយនឹងការស្រឡាញ់ពេញចិត្ត ។ តាមពិត សម្រាប់ពេលនេះខ្មែរក្រហមពុំត្រូវការឲ្យមានការផ្សព្វផ្សាយឲ្យគេដឹងពុជាសាធារណៈទេ ។ ដោយចាប់ផ្តើមកែប្រែសង្គមយ៉ាងស៊ីជម្រៅជាថ្មី ពួកគេគ្មានប្រាថ្នាអ្វីក្រៅតែពីដាក់«ការពិសោធន៍»របស់ខ្លួនឲ្យស្ថិតនៅដាច់ឆ្ងាយពីគេឯងប៉ុណ្ណោះ ។ តាមរយៈវត្តមានរបស់ព្រះអង្គជាមេដឹកនាំប្រទេស គឺវាគ្រប់គ្រាន់ហើយដែលសម្តេច សីហនុ ផ្តល់ឲ្យពិភពលោកឃើញនូវរូបភាពកម្ពុជា គួរឲ្យទុកចិត្តមួយក្នុងពេលដែលការពិសោធន៍របស់ខ្មែរក្រហម បានបន្តធ្វើឲ្យប្រទេសកម្ពុជារងទុក្ខវេទនាតទៅទៀត ។

នៅឆ្នាំ១៩៧៥ មុនការដួលរលំនៃក្រុងភ្នំពេញ សម្តេចបានមានបន្ទូលប្រាប់ប្រធាន ម៉ៅ ជាសម្ងាត់ថាបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម ព្រះអង្គប្រាថ្នាដកព្រះកាយចេញពីឆាកនយោបាយហើយ ។ ការធ្វើសហប្រតិបត្តិការជាមួយពួកគេ គឺវាហួសពីសមត្ថភាពរបស់ព្រះអង្គទៅហើយ ។ ម៉ៅ បានជំទាស់ពីបញ្ហានេះយ៉ាងម៉ឺងម៉ាត់ ។ គាត់បានពិតទូលសម្តេចថា «ព្រះអង្គត្រូវតែជួយខ្មែរក្រហម ។ អធិករណ៍របស់ព្រះអង្គ ជាមួយពួកគេមានមិនលើសពី២០ភាគរយទេ ហើយទស្សនៈដែលដៅទៅរកគោលបំណងតែមួយគឺមានដល់ទៅ៨០ភាគរយឯណោះ សូមសម្តេចបំភ្លេច២០ភាគរយនោះចោលទៅ» ។ សម្តេចមានបន្ទូលតបក្លាមថា «លោកប្រធាន! រឿងនេះមិនអាចធ្វើទៅរួចទេ» ។ ប៉ុន្តែ សម្តេចពុំអាចជជែកសំណេះសំណាលជាមួយ ម៉ៅ បានយូរទេ ព្រោះគាត់កំពុងឈឺចាប់ក្នុងកាយ ។ នៅទីបំផុត សម្តេច សីហនុ បានវិលត្រឡប់មកកម្ពុជាវិញ ដែលមិនយូរប៉ុន្មានព្រះអង្គដឹងព្រះកាយថា អធិករណ៍ចំនួន២០ភាគរយនោះបានប្រែទៅជា១០០ភាគរយពេញតែម្តង ។

ឧបទ្ទវហេតុមួយបានកើតឡើងដោយចៃដន្យក្នុងពេលទទួលបដិសណ្ឋារកិច្ចដែលរៀបចំឡើងក្នុងនិវេសនដ្ឋានរបស់ព្រះអង្គក្នុងឱកាសបុណ្យជាតិប្រទេសគុយបា នោះគឺជាភ័ស្តុតាងលើកដំបូងដែលព្រះអង្គទ្រង់ជ្រាបពីសារជាតិពិតប្រាកដរបស់ខ្មែរក្រហម គឺជាក្រុមបនមួយដែលស្អប់ខ្ពើមជនបរទេសបំផុត ។ ដូចតាមទម្លាប់ សម្តេច សីហនុ ត្រូវអានសន្ទកថាប្រសិទ្ធពរជាភាសាខ្មែរបន្ទាប់មកត្រូវឈប់មួយភ្លែតដើម្បីរង់ចាំការបកប្រែ ប៉ុន្តែស្ងាត់សូន្យ ។ គ្មានមេដឹកនាំខ្មែរក្រហមណាម្នាក់ក្នុងចំណោមនោះហើបមាត់ឡើយ ទោះជាចេះភាសាបារាំងថ្នឹកក៏ដោយ ។ គេអាចមើលឃើញ ខៀវ សំផន ជាម្ចាស់សញ្ញាប័ត្រថ្នាក់បណ្ឌិត ដែលចេញដោយសាលាស័របោន យកកែងដៃបុកអ្នកអង្គុយជិតគាត់ម្នាក់គឺ សួង ស៊ីគឿន ជាបញ្ញវន្តម្នាក់ទៀត ដែលចេះនិយាយភាសាបារាំង និងជាអតីតនាយកទីភ្នាក់ងារព័ត៌មានខ្មែរ ។ ការរង់ចាំចេះតែពន្យារទៅ នៅទីបំផុត សម្តេច សីហនុ ក៏បកប្រែសន្ទកថារបស់ព្រះអង្គទៅជាភាសាបារាំងដោយផ្ទាល់ ។ ក្នុងប្រទេសកម្ពុជារបស់ ប៉ុល ពត ការចេះដឹងភាសាបរទេសមួយមានន័យថា ជាការសម្តែងឲ្យឃើញភាពវណ្ណៈបមួយដែលគេមិនគួរសម្តែងឲ្យដឹងឡើយ ។

ក្នុងឱកាសដ៏កម្រជាច្រើនដែលព្រះអង្គជួបពិភាក្សាជាមួយ ខៀវ សំផន រដ្ឋមន្ត្រីការបរទេស អៀង សារី ឬជាមួយរដ្ឋមន្ត្រីឃោសនាការ ហ៊ូ នឹម គឺការផ្តល់មតិណែនាំទាំងប៉ុន្មានរបស់ព្រះអង្គតែងត្រូវច្រានចោលដោយការគួរសមជានិច្ច បើទុកជារឿងដែលមិនសូវសំខាន់ក៏ដោយ ដូចជា «ហេតុអ្វីបានជាមិនឲ្យសហករណ៍នានាបានឈប់សម្រាកនៅថ្ងៃអាទិត្យ? ជាដើម ។ គេឆ្លើយថា យើងមិនអាចបញ្ឈប់ការខំប្រឹងប្រែងរបស់ប្រជាជន ដែលមានទឹកចិត្តបំពេញភារកិច្ចតាមទិសដៅបង្កបង្កើនផលរបស់គាត់បានឡើយ» ។ ត្រូវធ្វើឲ្យខូចព្រះទ័យ សម្តេចបានសម្រេចបង្កើនការចំអកបញ្ឈឺចិត្ត និងការកត់សម្គាល់ដ៏ជូរចត់ថែមទៀត នេះជាមធ្យោបាយតែមួយគត់ដែលព្រះអង្គនៅសេសសល់ ។

ពីរ-បីសប្តាហ៍ក្រោយដំណើរយាងនិវត្តន៍មកក្រុងភ្នំពេញវិញ សម្តេច សីហនុ បានអញ្ជើញឯកអគ្គរដ្ឋទូតវៀតណាម ផាំ វ៉ាន់បា ដែលទើបមកពីភាគខាងត្បូងថ្មីៗ ចូលរួមពិសារអាហារថ្ងៃត្រង់ជាមួយព្រះអង្គ ។ ការអញ្ជើញដោយខ្លួនព្រះអង្គផ្ទាល់នេះមានលក្ខណៈគួរឲ្យរីករាយណាស់ ។ ក្នុងពេលដែល បា ដើរតួជាភ្នាក់ងារសម្ងាត់របស់កុម្មុយនីស្តដើម្បីផលប្រយោជន៍វៀតណាមនៅក្រុងភ្នំពេញកាលពីមុននោះ ឯកអគ្គរដ្ឋទូតរូបនេះ ធ្លាប់ត្រូវប៉ូលិសរបស់ សម្តេច សីហនុ តាមដានស្អិតណាស់ដែរ ។ ប៉ុន្មានឆ្នាំក្រោយមក គាត់បានត្រូវរដ្ឋាភិបាលយកមកប្រើវិញដោយឲ្យធ្វើជាតំណាងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ន វៀតណាមខាងត្បូង ប្រចាំទីក្រុងប៉ារីស ។ ហ៊ូ នឹម ក៏បានចូលរួមក្នុងការពិសារអាហារថ្ងៃត្រង់នោះដែរ ក្នុងឋានៈជារដ្ឋមន្ត្រីឃោសនាការនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ បា បានទូលសម្តេចពីការលំបាកទាំងឡាយ ដែលវៀតណាមខាងត្បូងទើបនឹងរំដោះថ្មីៗត្រូវប្រឈមមុខដោះស្រាយ ។ សម្តេចបានកាត់សម្តី បា ថា «ប៉ុន្តែកម្ពុជាក៏មានការលំបាកដូចគ្នា» ។ បន្ទូលនេះបានធ្វើឲ្យ ហ៊ូ នឹម មិនសូវសប្បាយចិត្តឡើយ ។ បា បានបំភ្លឺប្រាប់ខ្ញុំ(អ្នកនិពន្ធ) ក្រោយមកទៀតថា គាត់ខំប្រឹង

និយាយបង្វែងការបន្តហេតុតាមបន្ទូលរបស់សម្ដេចដែរ ។ គាត់បាននិយាយថា “ប្រទេសយើងទាំងពីរសុទ្ធតែទទួលរងគ្រោះពីការឈ្លានពានដោយចក្រពត្តិអាមេរិកដូចគ្នា ។ ពេលនេះជាពេលដែលត្រូវព្យាបាលឲ្យសះជាហើយ” ។ ដោយមិនទុកឲ្យខូចទឹកចិត្តសម្ដេចបានមានបន្ទូលសងមកវិញថា “គឺពិតជាអ៊ីចឹងមែន ប៉ុន្តែពួកមេដឹកនាំនៅទីនេះ(កម្ពុជាប្រជាធិបតេយ្យ) បានប្រើឱសថស័ក្តិសិទ្ធិមួយប៉ុន្តែពិបាកលេបណាស់” ។ ភាពស្ងៀមស្ងាត់ដ៏គុញគុះមួយបានសណ្ឋិតមានឡើង ។ បា គ្រឡេកមើល ហ៊ូ នឹម ដោយកន្ទុយភ្នែកមួយឆ្វាច់ ឃើញគាត់ឈ្ងោកសម្លឹងមើលក្រោម[១] ។ មួយឆ្នាំក្រោយមក មេដឹកនាំខ្មែរក្រហមរូបនេះ ត្រូវបានយកទៅប្រហារជីវិតក្រោមការចោទប្រកាន់ពីបទធ្វើចារកិច្ចជាគុណប្រយោជន៍សម្រាប់សេ.អ៊ី.អា. ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ក្រុមអ្នកការទូតដំបូងមួយមានគ្នាចំនួនប្រាំពីររូប មកពីប្រទេសអឺរ៉ុប អាហ្វ្រិក និងបណ្ដាប្រទេសអារ៉ាប់ ហើយដែលកំពុងស្នាក់នៅក្រុងប៉េកាំង ត្រូវបានអញ្ជើញឲ្យមកកាន់ក្រុងភ្នំពេញ ដើម្បីជូនលិខិតសារតាំងរបស់ខ្លួន ។ ពិធីលៀងសាយភោជន៍ពេលល្ងាចដែលផ្ដល់ជាកិត្តិយសចំពោះអ្នកទាំងនោះបានផ្ដល់ឲ្យ សម្ដេច សីហនុ មានឱកាសថ្មីមួយដើម្បីសម្ដែងឲ្យដឹងពីស្ថានភាពនៃទឹកព្រះទ័យរបស់ព្រះអង្គនិងប្រើការកំប្លែងស្លូតដើម្បីបញ្ឈឺចិត្តយ៉ាងកំរាល ។ ឯកអគ្គរដ្ឋទូតម្នាក់ក្នុងចំណោមនោះបានសាកសួរដោយមិនប្រាកដខ្លួនឯងថា ដោយមធ្យោបាយបែបណាទៅដែលអាចស្ដារប្រទេសកម្ពុជាឡើងវិញ បានបើគេបញ្ជូនពួកបញ្ញវន្តទាំងអស់ទៅជនបទហើយនោះ? សម្ដេចបានមានបន្ទូលតបរបៀបកាចថា “នៅទីនេះ យើងមិនខ្វះបញ្ញវន្តទេ ដូចជា ខៀវ សំផន អ្នកមានសញ្ញាប័ត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ច ដួន ជឿន បណ្ឌិតផ្នែកវេជ្ជសាស្ត្រ អៀង សារី បញ្ញវន្តម្នាក់ដែលធ្លាប់បំពេញការសិក្សារបស់ខ្លួននៅក្រុងប៉ារីស...” ។ ព្រះអង្គបានបង្ហូរព្រះបន្ទូលពន្យល់វែកញែកហូរហែទៅតាមដំណើរនៃព្រឹត្តិការណ៍ទាំងឡាយរបៀបត្រាប់តាមការចំអកមួយ ។ ភ្ញៀវទាំងអស់ដែលត្រូវធ្វើឲ្យទើសទាល់ក្នុងចិត្តបានរក្សាការស្ងៀមស្ងាត់គ្មានព្រមាត់ក ។ ពួកគេបានឃើញពីចម្ងាយរួចទៅហើយនូវទីក្រុងខ្មោចមួយ សេដ្ឋកិច្ចគ្មានរូបិយវត្ថុដាក់ឲ្យប្រើប្រាស់ ធនាគារកណ្ដាលរលំបាក់បែក និងក្រដាសប្រាក់ប៉ើងរសាត់តាមខ្យល់ ធ្លាក់រាយតាមផ្លូវថ្នល់នានា ។ ប្រការទាំងនេះ ពុំអាចរួចផុតពីការមើលឃើញរបស់ពួកគេបានឡើយ ។

ឱកាសដ៏កម្រផ្សេងៗដែល សម្ដេច សីហនុ មានសិទ្ធិដើម្បីបានជួបជាមួយពួកបរទេសដូចជាក្នុងពិធីជប់លៀងនានា បានត្រូវគេលុបចោលយ៉ាងឆាប់រហ័ស ។ តាមពិត ស្ថានភាពរបស់ព្រះអង្គបានចាប់ផ្ដើមមានសភាពរឹតតែអាក្រក់ឡើងៗក្រោយដំណើរយាងត្រឡប់របស់ព្រះអង្គបានប្រហែលមួយសប្ដាហ៍ប៉ុណ្ណោះ ។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ព្រះអង្គបានឡាយព្រះហស្តលេខាលើរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជាប្រជាធិបតេយ្យដែលត្រូវជំនួសរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាវិញ ។ ចាប់ពីនោះមក កម្ពុជាបានប្រែក្លាយយ៉ាងប្រត្យក្សថា “រដ្ឋប្រជាជន” ថ្មីលែងមានអ្វីជាសារសំខាន់សម្រាប់ព្រះអង្គទៀតហើយ ។ នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ មិត្តនិងជាអ្នកធ្លាប់គាំពារព្រះអង្គគឺ ជូ អេនឡាយ បានទទួលមរណភាព ។ មួយសប្ដាហ៍ក្រោយមក

យុទ្ធនាការឃោសនាមួយតាមសារព័ត៌មាននៅប្រទេសចិន បានផ្ដើមប្រឆាំងនឹងអ្នកស្នងតំណែងគាត់ដែលបានជ្រើសរើសទុកជាមុនគឺ គេង ស៊ាវពីង ។ ចលនានេះបានដៅឲ្យឃើញនូវការវិលត្រឡប់ដ៏ធំរបស់ពួករ៉ាឌីកាល់ដែលជាបងប្អូនខាងគំនិតនិយមជ្រុលដូចខ្មែរក្រហមដែរ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលសោះឡើយ ចំពោះសំណើដែលសម្ដេច សីហនុ សុំយាងទៅកាន់ក្រុងប៉េកាំង ដើម្បីសម្ដែងការវកិច្ចចុងក្រោយចំពោះ ជូ ហើយដែលត្រូវគេបដិសេធនោះ ។ ខ្មែរក្រហមកំពុងប្រុងប្រៀបតែងតាំងឲ្យមានរដ្ឋាភិបាលថ្មីមួយ សម្ដេចទ្រង់ព្រះតម្រិះថា គេប្រាថ្នាចង់ឲ្យព្រះអង្គស្ថិតនៅទីនេះដែរ ។ ខ្មែរក្រហមពុំមែនរង់ចាំឲ្យគេអង្វរ ដើម្បីព្រមទទួលនូវការសុំលាលែងពីតំណែងរបស់ព្រះអង្គឡើយ ។

ប៉ុន្តែ ការអនុញ្ញាតឲ្យព្រះអង្គចូលរ៉ឺត្រែតដោយគ្មានអន្តរាគមន៍ណាមួយដូច្នេះ អាចបង្កើតឲ្យមានសំណួរយ៉ាងច្រើននៅបរទេស ។ សម្រាប់ជាលើកដំបូងហើយតាំងពីការយាងត្រឡប់មកវិញរបស់សម្ដេច ដែលព្រះអង្គត្រូវបានអនុញ្ញាតឲ្យមានបន្ទូលតាមវិទ្យុជាតិនោះ ។ ក្រោយពេលដែលសេចក្ដីព្រាងសុន្ទរកថារបស់ព្រះអង្គទទួលបានការយល់ព្រមពី«អង្គការ»ហើយ មន្ត្រីម្នាក់បានមកថតព្រះសូរសៀងដាក់ខ្សែអាត់នៅព្រះរាជដំណាក់ព្រះអង្គផ្ទាល់ ។ សម្ដេច សីហនុ បានទតសារជម្រាបលាប្រជាជាតិរបស់ព្រះអង្គដែលផ្សាយនៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ដោយព្រះសូរសៀងអួលអាក់របៀបរំជើបរំជួលក្នុងព្រះទ័យថា ៖

«បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ និងបនរបស់វានាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅក្រុងភ្នំពេញ ខ្ញុំបានធ្វើសម្បថចំពោះខ្លួនខ្ញុំផ្ទាល់ និងចំពោះប្រជាជនកម្ពុជាថា ខ្ញុំនឹងដកខ្លួនទាំងស្រុងនិងជារៀងរហូតពីឆាកនយោបាយ ដោយហេតុថា ខ្ញុំបានរួមដំណើរជាមួយជនរួមជាតិខ្ញុំរហូតទទួលបានជ័យជម្នះជាស្ថាពរលើចក្រពត្តិអាមេរិកាំងនិងបនក្បត់ហើយ ហើយពេលនេះជាពេលចាប់ផ្ដើមសករាជថ្មីរបស់បដិវត្ត តួនាទីរបស់ខ្ញុំនឹងត្រូវដល់ពេលបញ្ចប់ហើយដែរ... ។ ក្នុងរយៈពេលសេសសល់នៃជីវិតរបស់ខ្ញុំ ខ្ញុំនៅតែដឹងគុណចំពោះប្រជាជនកម្ពុជាវីរបុរសនិងវីរនារីនៃប្រទេសកម្ពុជា និងចំពោះអង្គការបដិវត្តន៍កម្ពុជាដែលបានលុបលាងកេរ្ដិ៍ឈ្មោះ ខ្ញុំពីរឿងសៅហ្មងទាំងអស់នៅចំពោះមុខពិភពលោកនិងប្រវត្តិសាស្ត្រ ។ ដោយសារមនោសញ្ចេតនានេះ ដោយជំនឿជឿជាក់ដែលប្រជាជន និងអង្គការបដិវត្តន៍របស់យើងចាត់ទុកខ្ញុំក្នុងឋានៈជាសមាជិករបស់ខ្លួនម្នាក់ដូចគេដែរនោះ ទើបថ្ងៃនេះខ្ញុំបានស្នើសុំនូវការអនុញ្ញាតដកខ្លួនថយលែងរវីរវល់នឹងកិច្ចការសាធារណៈទៀត» ។

ពីរថ្ងៃក្រោយមក វិទ្យុភ្នំពេញបានប្រកាសផ្សាយជាសាធារណៈថា រដ្ឋាភិបាលបានទទួលយល់ព្រមនូវការសុំលាលែងពីតំណែងរបស់ សម្ដេច សីហនុ ដោយសោកស្ដាយបំផុតហើយបានផ្ដល់ឋានៈព្រះអង្គជា«មហាបុរសស្នេហាជាតិ»ទៀតផង ។ រដ្ឋាភិបាលបានស្នើកសាងវិមានមួយដើម្បីជាកិត្តិយសថ្វាយព្រះអង្គ និងបានបរិច្ចាគប្រាក់សោធនចំនួន៨.០០០ដុល្លារក្នុងមួយឆ្នាំសម្រាប់ព្រះអង្គផងដែរ ។ ក្រោយមកមិនដែលមាននរណាម្នាក់និយាយពីបញ្ហាកសាងវិមាននេះសោះឡើយ ។ ជាច្រើនឆ្នាំក្រោយមកទៀតខ្ញុំ(អ្នកនិពន្ធ) បានទូលសួរសម្ដេច

សីហនុ ថា តើព្រះអង្គបានធ្វើអ្វីខ្លះជាមួយប្រាក់ទាំងនេះក្នុងប្រទេសមួយដែលគ្មានរូបិយវត្ថុនោះ? ។ សម្តេចបានឆ្លើយតបដោយបញ្ចេញព្រះបស្សាវៈបន្ទូរព្រះឱរាថា «ទេ!ខ្ញុំមិនដែលឃើញពណ៌ក្រដាសប្រាក់មួយដុល្លារផង កុំថាឡើយស្រមោលប្រាក់ដុល្លារទីមួយនោះ» ។ តាមពិតព្រះអង្គបានទ្រង់ លិខិតទៅ«អង្គការ» ដោយបដិសេធមិនទទួលប្រាក់សោធននេះទេ ។ វិទ្យុភ្នំពេញបានផ្សាយឲ្យដឹងថា សម្តេច សីហនុ «ចង់ឆ្លៀតឱកាសពីការចូលរុំត្រែតរបស់ព្រះអង្គដើម្បីចំណាយពេលវេលាសម្រាប់គ្រួសារព្រះអង្គ ក្រោយពីបានបំពេញសកម្មភាពខាងនយោបាយអស់រយៈពេលសាមសិបប្រាំឆ្នាំមក» ។ វិភាគទានមួយក្នុងចំណោមវិភាគទានដំបូងៗរបស់ខ្មែរក្រហមចំពោះជីវភាពរស់នៅនៃក្រុមគ្រួសារសម្តេច គឺការដណ្តើមយកបុត្រីពីរអង្គក្នុងចំណោមបុត្រីជាច្រើនរបស់ព្រះអង្គ ស្វាមីរបស់អ្នកទាំងពីរ និងព្រះរាជនត្តាដប់អង្គក្នុងចំណោមព្រះរាជនត្តាទាំងអស់របស់ព្រះអង្គដើម្បីបង្ខំអ្នកទាំងនោះឲ្យទៅធ្វើស្រែ ។ ស្វាមីរបស់បុត្រីព្រះអង្គព្រះនាមបទុមបុប្ផា ដែលព្រះអង្គស្រឡាញ់ចូលចិត្តជាងគេ គឺជាអាកាសយានិកនៃកងអាកាសចរកម្ពុជា ។ បុត្រប្រសានេះហើយដែលបានបើកយន្តហោះប្រដេញតេ-២៨ទៅទម្លាក់គ្រាប់បែកលើវិមានប្រធានាធិបតី លន់ នល់ នៅក្នុងខែមីនា ឆ្នាំ១៩៧២ មុននឹងរត់ភៀសខ្លួនទៅកាន់តំបន់ដែលគ្រួតត្រាដោយខ្មែរក្រហម ។ សម្តេចមិនដែលបានឃើញអ្នកទាំងនោះជាថ្មីម្តងទៀតសោះឡើយ ។ ដោយប្រគល់នូវពាក្យសុំលាលែងពីតំណែងរបស់ព្រះអង្គ សម្តេចគ្មានដឹងថានេះជាការចាប់ផ្តើមរងទទួលទោសទណ្ឌមួយ គឺត្រូវកំណត់ឲ្យគង់នៅតែក្នុងប្រាសាទខេមរិន្ទប៉ុណ្ណោះ ហើយរឿងនេះខ្មែរក្រហមមិនដែលប្រកាសឲ្យដឹងព្ទទាល់តែសោះ ។

# ជំពូកទី៤
# ការផ្លាស់ប្តូរទិសដៅដោយប្រវត្តិសាស្ត្រ

បណ្តាសមាជិកនៃគណៈប្រតិភូរបស់ ប៉ុល ពត បានធ្វើដំណើរទៅកាន់ក្រុងប៉េកាំងតាមយន្តហោះប្រតិកម្មមួយគ្រឿង និងបានប្រើប្រាស់រថយន្តម៉ាក ហុងគី (ទង់ក្រហម) ជាជាងប្រើរទេះដែលទឹមដោយសេះ សម្រាប់ការធ្វើដំណើរចុះឡើងរបស់ពួកគេក្នុងរដ្ឋធានីចិន ។ អ្នកទាំងនោះបានសម្រេចចិត្តទៅគោរពវិញ្ញាណក្ខន្ធបណ្តាព្រះចៅអធិរាជចិននៅក្នុងវិមានតម្កល់សពប្រធាន ម៉ៅ ជាជាងទៅធ្វើមើលវិមានព្រះចៅអធិរាជ ។ ប៉ុន្តែទស្សនកិច្ចរបស់ ប៉ុល ពត បានត្រឹមតែសង្កត់បញ្ជាក់ពីប្រវត្តិចាស់មួយឡើងវិញប៉ុណ្ណោះ ។ មន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេសចិន បានធ្វើដំណើរមកកាន់ក្រុងភ្នំពេញ ដើម្បីអមដំណើរពួកភ្ញៀវកម្ពុជាជាកិច្ចគួរសមតាមយន្តហោះចិនមួយគ្រឿងរហូតដល់រដ្ឋធានីប៉េកាំង របៀបដូចគ្នានឹងពួកមន្ត្រីនៃព្រះរាជវាំងចិនជូនដំណើរពួកស្តេចត្រាញ់ចំណុះដែលនាំសួយសារអាករមកថ្វាយព្រះចៅអធិរាជកាលពីសម័យដើមយ៉ាងអធិកអធមតាំងពីព្រំដែនរហូតដល់រាជធានីដែរ ។ ប៉ុន្តែ ភាពដូចគ្នាគឺផ្អែកលើការវិនិច្ឆ័យផ្នែកនយោបាយ និងយុទ្ធសាស្ត្រ ដែលមាននាទីពិសេសក្នុងទំនាក់ទំនងរបស់ប្រទេសចិនជាមួយបណ្តាប្រទេសជិតខាងខ្លួននៅអាស៊ីអាគ្នេយ៍ ។

ចាប់តាំងពីសតវត្សរ៍ទី៣ និងរហូតដល់ចុងសតវត្សរ៍ទី១៥ បណ្តាព្រះមហាក្សត្រនៃព្រះរាជាណាចក្រនានា (ហ៊្វូណន, ចេនឡា, ចម្ប៉ា និង កម្ពុជា) ដែលលេចឡើងនៅលើដែនដីនៃប្រទេសកម្ពុជា និងវៀតណាមខាងត្បូងសព្វថ្ងៃ បានទទួលស្គាល់សិទ្ធិអធិរាជរបស់ចិនលើប្រទេសចំណុះ យ៉ាងហោចបែបជានិមិត្តរូបដែរ ដោយបង់សួយសារអាករតិចឬច្រើនយ៉ាងទៀងទាត់ទៅឲ្យព្រះចៅអធិរាជចិន ។ តាមការពិត បេសកកម្មទាំងឡាយដែលរៀបចំឲ្យមានដំណើរ ដើម្បីនាំសួយសារអាករទៅដល់គោលដៅគឺសុទ្ធតែជាប្រតិបត្តិការខាងពាណិជ្ជកម្មក្លែងបន្លំទាំងអស់ ។ ប្រតិបត្តិការខាងពាណិជ្ជកម្មនេះ ក៏អាចរ៉ាប់រងដល់ការការពារប្រទេសចិនដែរ ។ បណ្តាព្រះរាជាណាចក្រនៅអាស៊ីអាគ្នេយ៍ពិតជាវាយតម្លៃថា ការព្រមានមួយពីព្រះចៅអធិរាជដ៏មានអំណាចល្មមគ្រប់គ្រាន់ធ្វើឲ្យរសាយចិត្តនូវការឈ្លានពានដោយថាហេតុពីសំណាក់បណ្តាប្រទេសជិតខាងរបស់ខ្លួន[១] ។

របៀបគ្រប់គ្រងមានដំណើរទៅយ៉ាងល្អ ដរាបណាចក្រភពចិនមានលក្ខណៈខ្លាំងបង្គួរ ដើម្បីដាក់ការគំរាមរបស់ខ្លួនដោយកម្លាំងយោធាឲ្យប្រតិបត្តិតាម និងដរាបណាគ្មានកិច្ចការបន្ទាន់ដែលត្រូវដោះស្រាយ ។ នៅឆ្នាំ១៤០៧ ព្រះចៅអធិរាជ មិញ យ៉ុងលី បានបញ្ជូនកងទ័ពមួយមានកម្លាំង២០០.០០០នាក់ទៅដាក់ទណ្ឌកម្មប្រទេសវៀតណាមចំពោះបទឧក្រិដ្ឋដ៏សម្បើមរបស់ប្រទេសនេះ ជាពិសេស ការឈ្លានពានប្រឆាំងនឹងនគរចម្ប៉ា ។ វៀតណាមដែលចាញ់ការប្រយុទ្ធបានត្រូវបង្ខំឲ្យប្រគល់ដែនដីដែលពួកគេទើបនឹងភ្ជាប់ជារណបទៅឲ្យចិនវិញ[២] ។ ប៉ុន្តែ នៅឆ្នាំ ១៤១៤ ព្រះមហាក្សត្ររបស់កម្ពុជាមិនសូវមានសំណាងប៉ុន្មានទេ ។ ព្រះអង្គបានចាត់បញ្ជូនមន្ត្រីម្នាក់ទៅក្រុង

ប៉េកាំងយ៉ាងរហ័ស ដើម្បីសុំការគាំទ្ររបស់ចិនប្រឆាំងនឹងនគរចម្ប៉ា ដែលឲ្យទ័ពចូលលុកលុយប្រទេសរបស់ព្រះអង្គដោយប្តូរនឹងការបង់សួយសារអាករមួយ ។ ប៉ុន្តែ ព្រះចៅអធិរាជ យ៉ុងលី ដែលជាប់រវល់វាយប្រយុទ្ធនឹងពួកម៉ុងហ្គោលយ៉ាងខ្លាំងនៅភាគខាងជើងនោះ គ្រាន់តែឲ្យបេសកជនរបស់ខ្មែរត្រឡប់មកវិញប្រកបដោយកិត្តិយសស្មើនឹងឋានៈព្រះអង្គ និងអះអាងថា នគរចម្ប៉ាក៏ចំណុះប្រទេសចិនដែរ ។ បេសកជន ដែលព្រះអង្គបញ្ជូនទៅនគរចម្ប៉ាបានបញ្ជាយ៉ាងដាច់ខាតឲ្យព្រះរាជា(នគរចម្ប៉ា) "ដកកងទ័ពព្រះអង្គចេញពីកម្ពុជា និងទុកឲ្យប្រទេសនេះស្ថិតក្នុងសន្តិភាព" ។ ប៉ុន្តែ លិខិតផ្លូវការ(របស់ព្រះចៅអធិរាជចិន)ពុំមានការដាក់ទណ្ឌកម្ម ព្រមទាំងការគំរាមណាមួយឡើយ ។ ដូច្នេះ លិខិតនេះនៅតែគ្មានបានផល ព្រោះក្រុមមនុស្សប្រដាប់អាវុធ ដែលមកពីនគរចម្ប៉ានៅតែបន្តលួចប្លន់ប្រទេសកម្ពុជាដដែល ។ ក្នុងសម័យកាលតមកទៀត នៅពេលដែលព្រះរាជាណាចក្រខ្មែរចុះខ្សោយ និងក្លាយទៅជាចំណីនៃការស្រេកទឹកមាត់ចង់បានរបស់វៀតណាម និងសៀម ជាប្រទេសជិតខាងខ្លួនប្រទេសចិនបានបោះបង់កម្ពុជាទៅតាមព្រេងសំណាងរបស់ខ្លួនតែម្តង ។ តាមការយល់ឃើញរបស់ខ្មែរថា ទោះជាមានអ្វីកើតឡើងក៏ដោយ ក៏គំនិតជាប្រពៃណីនៃតួនាទីជាអាវុធហត្ថដែលប្រទេសចិន ត្រូវតែសម្តែងនៅក្នុងតំបន់ច្បាស់ជាបន្តអនុលោមទៅតាមគំនិតជាយុទ្ធសាស្ត្ររបស់គេដដែល ។ ព្រះមហាក្សត្រដំបូងនៃប្រទេសកម្ពុជាសម័យថ្មីគឺ សម្តេចព្រះ នរោត្តម សីហនុ បានប្រឹងស្វែងរកឡើងវិញយ៉ាងមោះមុតក្នុងការចងមិត្តភាពជាមួយប្រទេសចិនកុម្មុយនីស្ត ក្នុងសេចក្តីសង្ឃឹមបន្ទាចបណ្តាសត្រូវ (ដែលមិនទាន់ចេញជាក់ស្តែង)របស់ប្រទេសព្រះអង្គ ។ នៅឆ្នាំ១៩៦៦ ព្រះអង្គឈានរហូតប្រកាសថា មិត្តភាពនេះគឺ "មានន័យ ឯករាជ្យភាព សន្តិភាព និងបូរណភាពដែនដី" សម្រាប់ភាពគង់វង្សនៃប្រទេសកម្ពុជាថែមទៀត ។ ព្រះអង្គ បានប្រកាសដោយបញ្ចិតបញ្ចៀងទៅរកប្រទេសវៀតណាម និងប្រទេសថៃក្នុងន័យដាក់លាក់ថា : "បើសិនជាយើងឆាកចេញពីប្រទេសចិន យើងនឹងត្រូវខាំហែកស៊ី ដោយហ្វូងឆ្មាតដែលជាអ្នកជញ្ជែងទឹកដីខ្មែរជានិច្ចនិរន្តរ៍មិនខានឡើយ"[៣] ។

តាំងពីដើមរហូតដល់ចុងប្រវត្តិសាស្ត្ររបស់ខ្លួនមុនសម័យទំនើប ប្រទេសចិនគ្រាន់តែជាអ្នកគាំពារ ដ៏សប្បុរសមួយនិងជាដៃគូពាណិជ្ជកម្មមួយសម្រាប់ប្រទេសកម្ពុជាប៉ុណ្ណោះ ។ ចំណែកបែបផែននៃទំនាក់ទំនងផ្សេងៗដែលប្រទេសវៀតណាមរក្សាជាមួយប្រទេសជិតខាងខ្លួននៅភាគខាងជើង គឺមានលក្ខណៈខុសគ្នាស្រឡះ ។ នៅពេលដែលរាជរដ្ឋាភិបាលចិនផ្តល់នូវការការពារចំពោះប្រទេសចំណុះផ្សេងទៀតរបស់ខ្លួន ចិនបានប្រឹងប្រែងដោយគ្មានឈប់ឈរដើម្បីដាក់ប្រទេសវៀតណាមឲ្យស្ថិតនៅក្រោមអំណាចខ្លួនដែរ ។ ចំណែកប្រទេសវៀតណាម បានប្រឹងប្រែងបង្ហាញឲ្យឃើញនូវការចង់ឈ្នះដ៏ថ្លៃថ្នូររបស់ខ្លួនដូចគ្នា ដោយលើកខ្លួនឯង ជាអាណាចក្រកណ្តាលតូចមួយ (mini-Empire du Milieu) តាមមធ្យោបាយរបស់ខ្លួនដោយមិនចំណុះការកៀបសង្កត់របស់ពួកចិនឡើយ ។ ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសកម្ពុជានិងប្រទេសឡាវ ប្រទេសវៀតណាមកុម្មុយនីស្តបានដាក់ជំនួសទំនាក់ទំនងរបៀបនៅក្នុងឱវាទ (ខាងនយោបាយ) នៃសន្តតិវង្ស ង្វៀន ទៅជាប្រព័ន្ធសម្ពន្ធភាពមួយ

សំដៅរៀបចំសន្តិសុខ និងការត្រួតត្រារបស់ខ្លួនខាងផ្នែកសេដ្ឋកិច្ច ។ ដូចនៅសម័យដើមដែរ ចេតនារបស់វៀតណាម ដើម្បីតាំងឧត្តមភាពរបស់ខ្លួននៅព្រំដែនភាគខាងត្បូងប្រទេសចិនបានបណ្តាលឲ្យមានការប្រឆាំងដែលមិនអាចសម្រុះសម្រួលបានពីសំណាក់ពួកមេដឹកនាំរបស់ខ្លួនដែលសុទ្ធតែក្លាយទៅជាជនកុម្មុយនីស្ត ។

## ស្រមោលខ្មៅដែលនាំឱ្យឈឺចាប់

អ្នកប្រវត្តិវិទូមិនទាន់ត្រូវរ៉ូវគ្នាស្តីពីដើមកំណើតប្រទេសវៀតណាមទេ ។ តាមការបកស្រាយមួយថា ប្រជាជនវៀតណាមមានទីកំណើតជាប្រវត្តិសាស្ត្ររបស់ខ្លួននៅក្នុងតំបន់មួយនៃខេត្តហាងដុងរបស់ចិន ហើយតាមការបកស្រាយមួយទៀតថា នៅក្នុងអាងទន្លេក្រហម ។ ព្រះរាជាណាចក្រដំបូងរបស់វៀតណាម ដែលសៀវភៅវស្សិកប្រវត្តិ (សៀវភៅដែលមានចុះព្រឹត្តិការណ៍គ្រប់ឆ្នាំ) របស់ចិននិយាយគឺមានឈ្មោះថា ណាមវៀត (ភាសាចិន ហៅ Nan Yueh) ដែលត្រូវបង្កើតឡើងដោយស្តេចត្រាញ់សង្គ្រាមលះបង់សាសនាម្នាក់ឈ្មោះ ទ្រឿ ដា នៅឆ្នាំ ២០៨មុនគ្រិស្តសករាជ ។ ទ្រឿ ដា បានរៀបការជាមួយស្ត្រីវៀតណាមម្នាក់ ដោយប្រកាន់យកទំនៀមទម្លាប់វៀតណាម ហើយសម្លាប់វណ្ណៈជនជាតិចិនទាំងអស់ដែលនៅមានស្មារតីភក្តីចំពោះព្រះចៅអធិរាជរបស់គេ ។ បន្ទាប់ពីមានស្វ័យភាពមួយសតវត្សរ៍ ប្រទេសវៀតណាមបានត្រូវលេបត្របាក់ដោយសន្តតិវង្សថ្មីគឺ សន្តតិវង្សហាន ដែលធ្វើឲ្យតំបន់នោះទៅជាខេត្តពីររបស់ចិនគឺ ខេត្តប៉ាំនយូ (តំបន់កង់តុង) និងខេត្តយ៉ាវជី-ជីសណ្តទន្លេក្រហម ។ ក្នុងរយៈពេលមួយពាន់ឆ្នាំនៃការកាន់កាប់របស់ចិន វៀតណាមបានត្រូវធ្វើឲ្យជ្រួតជ្រាបនូវទម្រង់ផ្សេងៗនៃការរៀបចំសង្គម និងនយោបាយរបស់នាយចៅហ្វាយពួកគេផងដែរ ។ ពួកគេបានទទួលយកបច្ចេកទេសកសិកម្មទំនើបសម្រាប់ជំនាន់នេះ និងធ្វើឲ្យលូតលាស់នូវប្រព័ន្ធអក្សរមួយ ដែលក្លាយមកពីអក្សរចិន ។ នៅសម័យកាលនេះ គេឃើញមានការចាប់កំណើតនូវក្រុមអ្នកចេះដឹងជ្រៅជ្រះចិន-វៀតណាមមួយ ដែលជ្រួតជ្រាបទៅដោយវប្បធម៌ចិននិងទស្សនៈពិភពលោកបែបខុងជឺនិយម ។ ការគោរពរបស់វៀតណាមចំពោះវប្បធម៌ចិនគឺមានលក្ខណៈជ្រាលជ្រៅជាងប្រពៃណីរបស់អាណ្ណាម [អាណ្ណាម មានន័យថា "ភាគខាងត្បូងដែលធ្វើឲ្យមានសន្តិភាព" ឬ"ភាពសុខសាន្ត" ។ ពួកចិនបានដាក់ឈ្មោះប្រទេសវៀតណាមដូច្នេះសម្រាប់ជាលើកដំបូងនៅឆ្នាំ ៦៧៩] ។ ព្រះមហាក្សត្រវៀតណាមមួយព្រះអង្គនៅសតវត្សរ៍ ទី១៥ បានអះអាងតាមរយៈអត្ថបទនេះថា ៈ

- ពីរបៀបទាំងឡាយដែលធ្វើឲ្យមានអារ្យធម៌របស់ខ្លួន ភាគខាងត្បូងដែលមានសន្តិភាព (អាណ្ណាម) បានបញ្ចេញបុកក្រអឺត ។
- ព្រះមហាក្សត្រ និងអាណាប្រជានុរាស្ត្ររបស់ខ្លួន គ្មានគោរពច្បាប់ណាក្រៅពីច្បាប់របស់សន្តតិវង្សហាន ឡើយ ។
- មួក និង អាវផាយ យើងគោរពធ្វើតាមច្បាប់របស់សន្តតិវង្ស ថាង[៤] ។

ចំពេលដែលកម្លាំងជាតិនិយមកំពុងមានសន្ទុះខ្លាំងក្លាក្នុងប្រទេសនៅដើមសតវត្សរ៍នេះ អ្នកចេះដឹងវៀតណាមបានយកមកអួតជានិច្ចពីការចេះសិល្បៈខាងការសរសេរល្អ និងអក្សរបុរាណចិន ។ ភាគច្រើនសុទ្ធតែជាអ្នកដឹកនាំកុម្មុយនីស្តនៅវៀតណាម ដោយចាប់ផ្តើមពី ហូ ជីមិញ ទៅដែលជ្រួតជ្រាបទៅដោយវប្បធម៌របស់ចិន ។

ដោយផ្ទុយនឹងមតិធម្មតា ការធ្វើឲ្យជ្រួតជ្រាបនូវវប្បធម៌របស់ចិននេះបានផ្តល់ឲ្យវៀតណាមនូវឧបករណ៍នយោបាយ និងរបៀបរៀបចំផ្នែកសេដ្ឋកិច្ចដែលពួកគេត្រូវការ ដើម្បីបង្កហេតុនឹងអាណាចក្រនៃអាទិទេព Empire Céleste (នេះជាឈ្មោះពីដើមរបស់ប្រទេសចិន ព្រោះព្រះចៅអធិរាជប្រទេសនេះ ត្រូវគេឲ្យឈ្មោះថា កូនរបស់អាទិទេព) ។ ដូចដែលប្រវត្តិវិទូម្នាក់បានកត់ត្រាពីរឿងនេះថា "ប្រទេសចិនបានបង្កើត ប្រជាជាតិថ្មីមួយដោយអចេតនា ដែលចេះប្រកាន់យករបៀបគ្រប់គ្រងរបស់ចិន ដើម្បីរៀបចំឯករាជ្យភាពផ្ទាល់របស់ខ្លួន"[៥] ។ ដោយត្រូវធ្វើឲ្យវង់ទុក្ខក្នុងរយៈពេល៩០០ឆ្នាំក្រោមការគ្រប់គ្រងរបស់ចិន ប្រជាជាតិនេះ បានទម្លាប់ខ្លួនទ្រាំទ្រការលំបាកក្នុងរយៈពេលមួយពាន់ឆ្នាំថ្មីទៀត ក្នុងការតស៊ូទល់នឹងប្រទេសចិន ។

ដោយឆ្លៀតឱកាសនៃសម័យកាលជ្រួលច្របល់មួយនៅប្រទេសចិន មេដឹកនាំរបស់វៀតណាមម្នាក់ឈ្មោះ ង៉ូ ក្វៀន បានបណ្តេញកងទ័ពប្រចាំបន្ទាយទីក្រុង និងអ្នកធ្វើការក្នុងការិយាល័យរបស់ចិនទាំងអស់ចេញពីទីក្រុង ហើយបង្កើតសន្តតិវង្សឯករាជ្យមួយ ។ ការបាត់បង់នេះ ពុំមែនទទួលយកដោយគ្មានពិចារណាដោយព្រះចៅអធិរាជ សុង ហើយពុំមែនដោយពួកម៉ុងហ្គោលគឺព្រះចៅអធិរាជ មិញ និង ជីង ជាអ្នកទទួលតំណែងបន្តមកទៀតឡើយ ។ នៅពេលដែលសណ្តាប់ធ្នាប់ត្រូវរៀបចំឡើងវិញនៅភាគខាងត្បូងប្រទេសចិន ព្រះចៅអធិរាជ សុង បានបញ្ជូនកងទ័ពមួយទៅវាយដណ្តើមយកខេត្តយ៉ាវជីមកវិញ គឺ៤០ឆ្នាំបន្ទាប់ពីការធ្វើអបគមន៍របស់វៀតណាម ។ សារលិខិតមួយដែលបញ្ជូនដោយ តៃហ្សុង គឺព្រះចៅអធិរាជ សុង ទៅឲ្យព្រះមហាក្សត្រនៅប្រទេសវៀតណាម មុនការបញ្ជូនទ័ពទៅប្រទេសនេះ បានឆ្លុះបញ្ចាំងឲ្យឃើញគំនិតរបស់ចិនយ៉ាងច្បាស់ ៈ

"ទំនាក់ទំនងរបស់ប្រទេសចិនជាមួយពួកមនុស្សព្រៃគ្មានអារ្យធម៌នៅភាគខាងត្បូង គឺដូចគ្នានឹងរចនាសម្ព័ន្ធនៃខ្លួនប្រាណមនុស្សដែរ ៈ បេះដូងជាអ្នកបញ្ជាការកន្ត្រាក់របស់ដៃនិងជើងទាំងពីរ ។ ដូច្នេះបេះដូងជាចៅហ្វាយនិងជាម្ចាស់ ។ បើសិនមានអ្វីកើតឡើងដោយគាប់ជួនក្នុងដៃម្ខាងឬជើងម្ខាង សរសៃឈាមត្រូវធ្វើឲ្យស្ទះ ឬថាសរសៃប្រសាទធ្វើឲ្យអ្នកឈឺចាប់ខ្លាំង វិជ្ជាពេទ្យមួយអាចកែបំបាត់រោគនេះបាន ។ ក្នុងករណីផ្ទុយពីនេះ គេអនុវត្តការព្យាបាលដោយការចាក់ម្ជុល (បច្ចុប្បន្នហៅម្ជុលវិទ្យាសាស្ត្រ) រហូតដល់សុខភាពមានដូចដើមឡើងវិញ" ។ បន្ទាប់ពីព្យាបាល "ជើងនិងដៃ" រួចហើយ និយាយដោយឡែកគឺជនជាតិភាគតិចនៅភាគខាងត្បូងប្រទេសចិន ព្រះចៅអធិរាជបានប្រមូលផ្តុំការយកព្រះទ័យទុកដាក់ទៅលើប្រទេសវៀតណាម ដែលព្រះអង្គប្រៀបប្រដូចនឹងម្រាមជើងមួយ ។ "មនុស្សមានគតិបណ្ឌិតអាចមិនដឹងពីម្រាមជើងដែលនាំឲ្យឈឺចាប់តិចតួចមែនឬ? ។ បើសិន

*ជាព្រះអង្គត្រូវដឹកនាំប្រទេស ព្រះអង្គនឹងបណ្តោយឲ្យមានសេរីភាពគ្រប់បែបយ៉ាងទៅតាមអំពើមិនដឹងខុសត្រូវរបស់អ្នកដែលនឹងមិននាំឲ្យខូចដល់ភាពបរិសុទ្ធរបស់យើង» ។*

*សារលិខិតបានសូមឲ្យវៀតណាមដាក់ខ្លួនស្តាប់បង្គាប់រាជរដ្ឋាភិបាល សុង ដើម្បីសុខភាពល្អដល់ខ្លួនប្រាណរបស់ប្រទេសចិន ។ ក្នុងករណីដែលមិនព្រម ៖ «យើងនឹងបញ្ជាឲ្យកាត់សាកសពរបស់អ្នកជាដុំៗ អាវុធ្ធីង របស់អ្នកនិងធ្វើឲ្យដីរបស់អ្នកទៅជាគ្រាប់ល្អិតៗដូចជាគ្រាប់ធញ្ញជាតិ... ។ គ្រាប់គជ់នៃសមុទ្ររបស់អ្នក យើងនឹងបោះចោលទៅក្នុងទន្លេ មាសនៃភ្នំទាំងឡាយរបស់អ្នក យើងនឹងគ្រវែងចោលទៅក្នុងធូលីដី ។ យើងមិនស្រក់ទឹកមាត់ចង់បានរតនសម្បត្តិរបស់អ្នកទេ ។ អ្នកទាំងអស់គ្នាហោះហើរនិងលោតផ្លោះយ៉ាងលឿនដូចសត្វសាហាវ នៅពេលដែលរទេះរបស់យើងទាញដោយសត្វសេះ ។ អ្នកទាំងអស់គ្នាផឹកតាមប្រមុះ យើងមានអង្ករនិងស្រា ។ ចូលរួមគ្នាផ្លាស់ប្តូរបែបបទរបស់អ្នកទៅ! ។ អ្នកទាំងអស់គ្នាកាត់សក់ខ្លី យើងពាក់មួក ។ សម្តីអ្នកប្រៀបដូចសំឡេងយំរបស់បក្សី យើងមានសៀវភៅនិងការប្រឡង ។ សូមទុកឲ្យយើងបង្ហាត់បង្រៀនអ្នកពីច្បាប់ពិតៗ! ។ តើអ្នកចង់គេចផុតពីការរស់នៅជារបៀបមនុស្សព្រៃនៅចុងកាត់មាត់ញក ហើយសម្លឹងទៅរកមណ្ឌលនៃអារ្យធម៌ទេ? តើអ្នកចង់បោះបង់ចោលសម្លៀកបំពាក់ធ្វើពីស្លឹកឈើនិងស្មៅរបស់អ្នក ហើយស្លៀកពាក់អាវផាយដែលមានផ្កាដេរជាសប៉ាក់រូបភ្នំនិងរូបនាគដែរទេ? តើអ្នកយល់ហើយឬនៅ? កុំបិទទ្វារដោយកំហឹង អ្នកនឹងធ្វើឲ្យមានកំហុសមួយដែលនាំឲ្យវិនាស ។ យើងនឹងប្រមូលផ្តុំរថក្រោះ សេះ និងកងទ័ពប្រឆាំងនឹងអ្នក...»[៦] ។*

*ព្រះមហាក្សត្រវៀតណាម ឡេ ហ័ន មិនព្រឺព្រួចនឹងការគំរាមកំហែងនេះឡើយ ។ នៅឆ្នាំ៩៨១ កងទ័ពរាជវង្ស សុង បានទទួលរងបរាជ័យដ៏សែនអាម៉ាស់មួយនៅប្រទេសវៀតណាម ។ ក្នុងរយៈមួយពាន់ឆ្នាំដែលមានជាបន្តបន្ទាប់មកទៀត វៀតណាមបានវាយរុញច្រានការលុកលុយជាងម្ភៃបួយលើកដែលចេញមកពីភាគខាងជើង ។*

*អ្នកឯកទេសស្តីពីទំនាក់ទំនងជាប្រពៃណីរបស់ប្រទេសចិនជាមួយបណ្តាប្រទេសជិតខាងខ្លួន បានមូលមាត់គ្នាទទួលស្គាល់ជាទូទៅថា មនោសញ្ចេតនាដែលពួកចិនធ្លាប់មានអំពីភាពខ្ពង់ខ្ពស់លើសគេរបស់ខ្លួន តាំងពីសម័យគ្រប់គ្រងរបៀបនាំសួយសារអាករមកថ្វាយ គឺមានលក្ខណៈវប្បធម៌ច្រើនជាងនយោបាយ ។ លក្ខន្តិកៈដែលត្រូវបង់សួយសារអាករ ពុំមែនផ្តល់ឲ្យប្រទេសមួយទេ ប៉ុន្តែ ចំពោះព្រះមហាក្សត្រមួយអង្គ ឲ្យតែមហាក្សត្រនោះទទួលស្គាល់ភាពប្រសើរខ្ពង់ខ្ពស់លើសគេរបស់ប្រទេសចិន និងអង្វរសុំការទទួលឲ្យខ្លួនចូលក្នុង «អាណាចក្រកណ្តាល»(ប្រទេសចិន) ដើម្បីនឹងធ្វើឲ្យ«ខ្លួនប្រែប្រួលរីកចម្រើន» ។ ដោយពិចារណាតាមរបៀបអរូបី វាមានសារសំខាន់តិចតួចណាស់ចំពោះព្រះចៅអធិរាជចិន ដែលមនុស្សព្រៃគ្មានអារ្យធម៌ម្នាក់ទទួលស្គាល់ភាពខ្ពង់ខ្ពស់ជាងគេបំផុតរបស់ខ្លួននោះ ។ ប៉ុន្តែ ក្នុងព្រឹត្តិការណ៍ផ្សេងៗ ប្រទេសចិនបានខំប្រឹងជារឿយៗ ដើម្បីយកឈ្នះនិងត្រួតត្រាដោយផ្ទាល់នូវពួកមនុស្សព្រៃគ្មានអារ្យធម៌ដែលកំពុងរស់នៅបរិវេណខាងក្រៅនៃអាណា*

ចក្ររបស់ខ្លួន ។ ក្នុងករណីប្រទេសវៀតណាម ឧបសគ្គនៃស្ថានភាពដី និងការតស៊ូដ៏រឹងរូសរបស់អ្នកស្រុក បានធ្វើឲ្យការដោះស្រាយបញ្ហានេះមានការពិបាកខ្លាំងនិងមិនអាចធ្វើកើត ។ ការទាក់ទងតាមបែបដែនទាំសួយសារអាករទៅថ្វាយ គឺជាបែបផែនតែមួយគត់ ដែលមានគោលបំណង ។ ម្យ៉ាងទៀត របៀបគ្រប់គ្រងដែលរដ្ឋមួយត្រូវនាំសួយសារអាករទៅជូនរដ្ឋ មួយទៀតទុកជាការចំណុះ ដោយផ្អែកលើបណ្តាគោលការណ៍ខុងជឺនិយម បានទុកឲ្យប្រទេសចិនមានសេរីភាពមួយល្មមគ្រប់គ្រាន់ ដើម្បីធ្វើអន្តរាគមន៍នៅពេលដែលអ្វីៗអាចឲ្យធ្វើបាន ។

ទោះបីជាបណ្តាព្រះមហាក្សត្ររបស់វៀតណាម មិនដែលឈប់ទទួលស្គាល់អធិបតេយ្យរបស់ចិនក៏ដោយ ក៏ព្រះចៅអធិរាជដែលឡើងគ្រងរាជ្យបន្តបន្ទាប់គ្នា ហើយរៀងរាល់លើកដែលព្រះអង្គយល់ថា កម្លាំងទ័ពរបស់ព្រះអង្គខ្លាំងបង្គួរហើយ ព្រះអង្គតែងតែធ្វើអន្តរាគមន៍ក្នុងប្រទេសជិតខាងរបស់ខ្លួនជានិច្ច ដើម្បីធ្វើឲ្យមានស្ថិរភាពនិងរៀបចំរបៀបរបបសង្គមតាមលទ្ធិខុងជឺនិយម ។ ឧទាហរណ៍ មុនចាប់ផ្តើមធ្វើការលុកលុយនៅឆ្នាំ ១៨០៧ ដែលតាំងឲ្យមានឡើងវិញនូវការត្រួតត្រារបស់ចិនពីរទសវត្សរ៍លើប្រទេសវៀតណាម ព្រះចៅអធិរាជយ៉ុងលី បានយកព្រះទ័យទុកដាក់រៀបរាប់នូវ«បទឧក្រិដ្ឋ»ធំៗចំនួនម្ភៃដែលព្រះអង្គទម្លាក់ទោសទៅលើព្រះមហាក្សត្រវៀតណាម ។ បទឧក្រិដ្ឋសំខាន់បំផុតចំនួនប្រាំបីសុទ្ធតែជាការបំពានខាងសីលធម៌និងមនោគមវិជ្ជា : ការដណ្តើមអំណាចដោយប្រើឧបាយកល (បន្តដោយការធ្វើឃាតព្រះមហាក្សត្រពេញច្បាប់) ការធ្វើបាបទៅលើប្រជាជន ការជេរប្រមាថចំពោះព្រះចៅអធិរាជមិញ ។ បន្ទាប់មកទៀតគឺ«បទឧក្រិដ្ឋ»ចំនួនប្រាំដែលទាក់ទងទៅនឹងសន្តិសុខប្រទេសចិន ។ ព្រះចៅអធិរាជបានចោទប្រកាន់ប្រទេសវៀតណាមជាពិសេសថា បានញុះញង់ឲ្យមានការរីករាលក្នុងចំណោមពួកកុលសម្ព័ន្ធនៅតាមព្រំដែន និងជំរុញឲ្យមានការបះបោរប្រឆាំងនឹងព្រះចៅអធិរាជ ។ អំពើឈ្លានពានផ្សេងៗរបស់ប្រទេសវៀតណាមប្រឆាំងនឹងនគរចម្ប៉ាបានបង្កឲ្យមានការចោទប្រកាន់ចម្បងៗចំនួនប្រាំជាបន្តបន្ទាប់ ។ នៅទីបំផុត ក្នុងករណីពីរចុងក្រោយប្រទេសវៀតណាមមិនបានគោរពចំពោះរូបព្រះចៅអធិរាជឡើយ ។ ប្រវត្តិវិទូ វ៉ាង ហ៊ុងវូ បានគូសបញ្ជាក់ដោយយុត្តិធម៌ថា បញ្ជីកំហុសនេះ «បង្ហាញឲ្យឃើញពីការចង់បានរបស់ប្រទេសចិន អំពីសិទ្ធិអធិរាជលើប្រទេសចំណុះ ដោយដកហូតពីបណ្តារដ្ឋចំណុះនូវសេរីភាព និងឯករាជ្យភាពក្នុងការធ្វើសកម្មភាពរបស់គេ» ហើយជាពិសេសរដ្ឋមួយដែលនៅតែជាភាគីរួមបញ្ចូល(ដែលបំពេញឲ្យមូលឲ្យសព្វគ្រប់ ដូចជាដៃជើងដែលបគ្រប់រាងកាយដែរ) នៃចក្រភពចិនតាំងពីយូរមកហើយ[៧] ។ ដោយពិត ប្រទេសវៀតណាម ពុំមែនជាព្រះរាជាណាចក្រនៅក្រោមចំណុះដូចព្រះរាជាណាចក្រដទៃៗទេ ។ ជាអតីតខេត្តរបស់ព្រះចៅអធិរាជ កាលពីដើមវៀតណាមធ្លាប់បានក្រេបជញ្ជក់គុណប្រយោជន៍ផ្សេងៗពីអារ្យធម៌របស់ចិនជាច្រើន ។ ដើម្បីបង្ហាញភ័ស្តុតាងពីទណ្ឌកម្មដែលព្រះអង្គដាក់លើប្រទេសវៀតណាមនៅឆ្នាំ១៨០៧ ព្រះចៅអធិរាជ យ៉ុងលី បានធ្វើអត្ថាធិប្បាយថា ប្រទេសនេះជាប្រទេសមាន«សម្ព័ន្ធញាតិយ៉ាងជិតស្និទ្ធ»នឹងប្រទេសចិន ។ នេះគឺជាពាក្យសំខាន់មួយ ។ ដោយចង្អុលភ័ស្តុតាងពីចំណងសាច់ញាតិរវាងប្រទេស

*ទាំងពីរ ប្រទេសចិនបានផ្តល់ដល់ប្រទេសវៀតណាមនូវពន្លឺអារ្យធម៌របស់ខ្លួនយ៉ាងច្រើន ។ "បទខគ្រិដ្ឋ"ទាំងឡាយរបស់បណ្ឌាក្សត្រវៀតណាមគ្រាន់តែធ្វើឲ្យក្សត្រទាំងនេះអាក់អន់ព្រះទ័យយ៉ាងខ្លាំងប៉ុណ្ណោះ ។*

## "ប្រយុទ្ធដើម្បីរក្សាសក់វែង..."

*ក្នុងរយៈពេលពីរទសវត្សរ៍ដែលមានបន្ទាប់ពីការលុកលុយនៅឆ្នាំ១៤០៧ ការគ្រប់គ្រងរបស់វៀតណាមនៅតែស្ថិតនៅក្នុងដៃពួកមន្ត្រីជាន់ខ្ពស់ដែលមកពីប្រទេសចិនដដែល ។ សក្ខីភាពដែលបង្ហាញឲ្យឃើញពីវប្បធម៌របស់វៀតណាមបានត្រូវបំផ្លិចបំផ្លាញ ខ្លះត្រូវនាំទៅប្រទេសចិន ហើយភាគច្រើនត្រូវបាត់បង់-នេះជាការវិនាសដ៏គួរឲ្យឈឺចាប់សម្រាប់អ្នកអក្សរសាស្ត្រវៀតណាមរាប់សតវត្សរ៍ខាងមុខទៀត ។ ច្បាប់សារពើពន្ធរបស់រាជវង្សមិញ បានត្រូវបញ្ចូលមកក្នុងប្រទេស ហើយគេបានកសាងសាលារៀនជាច្រើនដើម្បីបង្ហាត់បង្រៀនអក្សរសាស្ត្របុរាណរបស់ចិន ។ ទំនៀមទម្លាប់ ប្រពៃណី ការកាត់ ឬការតុបតែងសក់ និងទំនៀមរបស់ចិនបានត្រូវចាប់បង្ខំឲ្យវៀតណាមទទួលយក ។ ច្បាប់ថ្មីមួយបានហាមការប្រតិបត្តិទម្លាប់ជាប្រពៃណីខ្លះៗរបស់វៀតណាមដូចជាទម្លាប់សាក់ខ្លួន លាបធ្មេញ(ឲ្យខ្មៅ) ឬទំពាស្លាម្លូ ។ ដូចយ៉ាងក្នុងរយៈពេលដំបូងនៃការកាន់កាប់ ពួកចិនបានប្រើប្រជាជនវៀតណាមឲ្យធ្វើការទាំងបង្ខំដើម្បីធ្វើអាជីវកម្ម រ៉ែមាស ប្រាក់ ស្ពាន់ និង ដែក ប៉ុន្តែក៏ប្រើក្នុងការបរបាញ់ដំរី ដើម្បីយកភ្លុកបរបាញ់រមាសដើម្បីយកកុយ និងការមុជរកគ្រាប់គជ់ទៀតផង[៨] ។*

*យុទ្ធនាការចម្បាំងទ័ពព្រៃដ៏យូរមួយដែលដឹកនាំដោយមេទ័ពរបស់វៀតណាមម្នាក់ឈ្មោះ ឡេ ឡយ បានបញ្ចប់ការត្រួតត្រារបស់ចិននៅឆ្នាំ១៤២៧ ។ រហូតមកដល់ការធ្វើសញ្ជ័យរបស់បារាំងរយៈពេល៤សតវត្សរ៍កន្លះក្រោយមកទៀត ប្រទេសវៀតណាមចេះការពារខ្លួនពីការលូកដៃចូលទាំងអស់របស់បរទេស ។ មានតែការគំរាមកំហែងដ៏ធ្ងន់ធ្ងរមួយប៉ុណ្ណោះ គឺនៅឆ្នាំ១៧៨៨ សន្តតិវង្ស ជិញ បានបញ្ជូនអគ្គកងទ័ពមួយ ដើម្បីសាកល្បងបង្ខំឲ្យវៀតណាមទទួលអាណាព្យាបាលរបស់ខ្លួនជាថ្មីម្តងទៀត ។ អ្នកយុទ្ធសាស្ត្រវៀតណាមដ៏ចំណានម្នាក់ឈ្មោះ ង្វៀន ហ៊ុយ បានធ្វើឲ្យប្រតិបត្តិការសឹកនេះបរាជ័យ ។ គាត់ចេះទាញយកប្រយោជន៍ដ៏ប្រសើរពីមនោសញ្ចេតនាជាតិនិយមដ៏ខ្លាំងក្លារបស់ប្រជាជនដែលរីកដុះដាលដោយសារការមិនចូលចិត្តចំណុះគេជាច្រើនសតវត្សរ៍ ដូចដែលបទបន្ទរនៃចម្រៀង"ដំណើរកងទ័ព"របស់ ង្វៀង ហ៊ុយ បង្ហាញជាភស្តុតាងស្រាប់ ៖*

- *ប្រយុទ្ធដើម្បីរក្សាសក់វែង*
- *ប្រយុទ្ធដើម្បីរក្សាធ្មេញខ្មៅ*
- *ប្រយុទ្ធដើម្បីបំផ្លាញរទេះ (កង់៤) ទាំងអស់របស់សត្រូវ*
- *ប្រយុទ្ធដើម្បីកម្ចាត់គ្រឿងការពារទាំងអស់របស់វានៅគ្រប់កន្លែង*
- *ប្រយុទ្ធដើម្បីឲ្យវាដឹងថា ប្រទេសភាគខាងត្បូងដ៏ខ្លាំងពូកែគឺជាចៅហ្វាយផ្ទាល់របស់វា[៩] ។*

ប្រយោគជាគោលគំនិតជាតិនិយមរបស់វៀតណាម ការប្រយុទ្ធប្រឆាំងនឹងការត្រួតត្រារបស់ចិនបានត្រូវលើកតម្កើងស្មើរតែស្មើនឹងសាសនាដែរ ។ ក្នុងអំឡុងនៃការធ្វើសង្គ្រាមពេញទំហឹងទល់នឹងសហរដ្ឋអាមេរិក ទុកណាជាការគាំទ្ររបស់ចិនមានសារសំខាន់យ៉ាងខ្លាំងមួយសម្រាប់ការគង់វង្សរបស់ប្រជាជនវៀតណាមក៏ដោយក៏ជំនឿនេះត្រូវបានប្រតិបត្តិដោយសម្ងាត់ជានិច្ច ។ ក្នុងអំឡុងនៃការស្នាក់អាស្រ័យមួយនៅវៀតណាមខាងជើងនាខែតុលា ឆ្នាំ១៩៧២ អ្នកស្រាវជ្រាវអាមេរិកាំង ហ្សេក កាហ៊ីន បាននឹកបារម្ភពីកម្រិតនៃសេរីភាពខាងសាសនា ។ ក្នុងព្រះវិហារគ្រិស្តសាសនានៅក្រុងហាណូយ គាត់បានទៅមើលក្នុងពិធីសូត្រធម៌ថ្ងៃអាទិត្យមួយដែលមានសាសនិកយ៉ាងច្រើនចូលរួម ។ បន្ទាប់ពីចប់ពិធីសូត្រធម៌ មគ្គុទ្ទេសក៍វៀតណាមរបស់គាត់បានសួរគាត់ថា : «តើលោកចង់ស្គាល់សាសនារបស់យើងទេ?» ។ កាហ៊ីន បានយល់ព្រមតាមការអញ្ជើញភ្លាម ។ គេបាននាំគាត់ឆ្លងកាត់ស្ពានមួយ ដែលនាំទៅកាន់កោះមួយនៃបឹងហ័នគៀម នៅទីក្រុងហាណូយ ។ ក្នុងព្រះវិហារមួយលើកោះនោះ មានអាសនៈបីសម្រាប់ដាក់គ្រឿងសក្ការៈ ។ អាសនៈទីមួយសម្រាប់ឧទ្ទិសចំពោះព្រះពុទ្ធ អាសនៈទីពីរចំពោះព្រះអាទិទេពដីនិងទឹក ហើយអាសនៈទីបីដែលនៅចំកណ្ដាលគឺសម្រាប់ឧទ្ទិសចំពោះ ត្រាន់ ហ៊ុងដាវ ជាឧត្ដមសេនីយ៍ដែលវាយឈ្នះកងទ័ពចិន-ម៉ុងហ្គោលនៅសតវត្សរ៍ទី១៣ ។ ដោយស្ទុះស្វែងចង់ដឹងលើសពីនេះទៀត កាហ៊ីន បានរកឃើញថា នៅក្រុងហាណូយមានបូជនីយដ្ឋានប្រាំមួយកន្លែងផ្សេងទៀត ដែលវៀតណាមសាងសង់ឡើងជាកិត្តិយសដល់បណ្ដាវីរបុរស និងវីរនារីក្នុងការតស៊ូប្រឆាំងនឹងអ្នកលុកលុយចិនដូចជា ឡេឡយ ឬបងប្អូនត្រកូលទ្រុង ជាដើម[10] ។

ដំណាលគ្នានឹងការប្រយុទ្ធនៅក្រោមការឧបត្ថម្ភរបស់ចិនដើម្បីឯករាជ្យភាពរបស់ខ្លួន ប្រទេសវៀតណាមបានបំពាក់ឲ្យខ្លួនឯងនូវបែបបទនយោបាយដើមមួយដែលលាយបញ្ចូលទៅដោយភាពម៉ឺងម៉ាត់ និងភាពទន់ភ្លន់ ។ ភាពម៉ឺងម៉ាត់ក្នុងការការពារអត្តសញ្ញាណនិងឯករាជ្យភាពរបស់ខ្លួន ។ ភាពទន់ភ្លន់ក្នុងការស្វែងរកដោយខ្ជាប់ខ្ជួននូវការសម្រុះសម្រួលដោយអត់ឱនឲ្យគ្នាទៅវិញទៅមកមួយ (Modus Vivendi) ជាមួយប្រទេសចិន ។ ដោយពិតការខិតចូលជិតគ្នាដែលមានតែមួយនេះ បានឆ្លុះបញ្ចាំងឲ្យឃើញមនោសញ្ចេតនារបស់វៀតណាមចំពោះប្រទេសចិនដែលមានលក្ខណៈផ្ទុយពីគ្នា គឺការស្រឡាញ់ចូលចិត្ត និងការស្អប់ខ្ពើម មនោសញ្ចេតនានឹកថា តូចទាបជាងគេ និងអភិមានះ សេចក្ដីក្លាហានប្រកបដោយវីរភាព និងប្រតិបត្តិនិយម (Pragmatisme) ។ បំណងរបស់វៀតណាមក្នុងការធ្វើជាម្ចាស់នៅប្រទេសរបស់ខ្លួន តែងតែត្រូវបង្កប់ដោយសតិសម្បជញ្ញៈច្បាស់លាស់មួយដែលពួកគេសម្ដែងឲ្យឃើញចំពោះអានុភាពរបស់ប្រទេសចិន និងដោយសារការស្ញើចសរសើរពិតប្រាកដមួយចំពោះអ្វីៗទាំងអស់ដែលមកពីប្រទេសចិន ។ តាំងពីដំបូងៗនៃឯករាជ្យភាព បណ្ដាព្រះមហាក្សត្រវៀតណាម បានយល់ដឹងយ៉ាងរហ័សថា មធ្យោបាយដែលឲ្យសម្រេចលទ្ធផលច្រើនប្រការដែលពួកគេមាន-វីរភាពនៃប្រជាជនអត្ថប្រយោជន៍នៃស្ថានភាពដី និងវិទ្យាសាស្ត្រផ្នែកយុទ្ធសាស្ត្ររបស់គេ-ល្មមគ្រប់គ្រាន់នឹងធ្វើឲ្យបរាជ័យនូវការ

ប៉ុនប៉ងរាតត្បាតទាំងអស់ ប៉ុន្តែថា ប្រទេសចិនមានប្រជាជនច្រើនណាស់ ហើយប្រភពធនធានក៏មានសន្ធឹកសន្ធាប់ ដែលពួកគេអាចសង្ឃឹមយកឈ្នះចិនបានក្នុងការប្រយុទ្ធរយៈពេលយ៉ាងយូរមួយ ។ សិទ្ធិអធិរាជរបស់ចិនលើប្រទេសចំណុះមានគុណវិបត្តិតិចតួចបំផុត ៖ ជាគោលការណ៍សិទ្ធិនេះបានបដិសេធនូវការជ្រៀតជ្រែកផ្ទាល់មួយ ។ ប្រវត្តិវិទូរបស់វៀតណាមបានសង្កត់បញ្ជាក់ពីរឿងនេះថា ៖ «វាជាផលប្រយោជន៍សម្រាប់បណ្ដាព្រះមហាក្សត្រវៀតណាម ដែលត្រូវលះបង់អធិបតេយ្យរបស់ខ្លួនមួយផ្នែកជាថ្នូរនឹងការគាំពាររបស់ចិនក្នុងករណីដែលមានការបះបោរ និងធ្វើឲ្យប្រាកដថា ប្រទេសជាតិនឹងមិនទទួលរងគ្រោះថ្នាក់ណាមួយដែលខ្លួនជាចំណុះ ឬគ្រប់គ្រងដោយផ្ទាល់ដោយប្រទេសចិនឡើយ»[១១] ។ បន្ទាប់ពីទទួលជ័យជម្នះលើកងទ័ពលុកលុយចិនម្ដងៗ ព្រះមហាក្សត្ររបស់វៀតណាមតែងចាត់បញ្ជូនជាប្រញាប់នូវមន្ត្រីទូតម្នាក់ដើម្បីសុំការអត់ឱនទោសពីព្រះចៅអធិរាជចិន និងបង់សួយសារអាករឲ្យព្រះអង្គជានិច្ច ។ ការអត់ឱនទោសនេះ តែងតែយល់ព្រមផ្ដល់ឲ្យជាដរាប ។

## សិល្បៈនៃការរៀបចំប្រួចប្រៀបជាស្រេច

បន្ទាប់ពីជ័យជម្នះលើកងទ័ពរាជវង្ស មិញ នៅឆ្នាំ១៤២៧ មួយផ្នែកនៃប្រជាជននិងកងទ័ព មានបំណងបដិសេធសន្តិភាពដែលគេផ្ដល់ឲ្យ ហើយចង់សងសឹកដោយការសម្លាប់រង្គាលអ្នកជាប់គុកចិនវិញ ។ ប៉ុន្តែសហការីដ៏ជិតស្និទ្ធបំផុតរបស់មេទ័ពវៀតណាម ឡេ ឡយ គឺអ្នកយុទ្ធសាស្ត្រនិងកវី ង្វៀន ត្រាយ បានប្រឆាំងនឹងបញ្ហានេះ ។ គាត់បានជជែកតវ៉ាថា ៖ «ក្នុងកាលៈទេសៈបច្ចុប្បន្នគ្មានអ្វីងាយស្រួលជាងវាយប្រហារខ្មាំងសត្រូវ និងបង្ហូរទ់សម្រេករបស់យើងជាមួយឈាមរបស់វាឡើយ ។ ប៉ុន្តែ បន្ទាប់មកទៀត...? ខ្ញុំខ្លាចក្រែងថា ការធ្វើដូច្នេះនឹងបណ្ដាលឲ្យមានគំនុំយ៉ាងស៊ិតស្មាញពីរាជវង្ស មិញ ។ ពួកគេនឹងស្វះស្វែងសងសឹកវិញ ព្រោះថាកិត្តិស័ព្ទនៃមហាអាណាចក្រមួយបានត្រូវធ្វើឲ្យប៉ះពាល់ ។ ពួកគេនឹងបញ្ជូនទ័ពថ្មីមួយទៀត ។ ដូច្នេះ តើពេលណាដែលសេចក្ដីឈឺចាប់ដោយសារសង្គ្រាមនឹងត្រូវបញ្ឈប់? ។ ដើម្បីសារប្រយោជន៍របស់ប្រជាជាតិយើងទាំងពីរ វាជាការប្រសើរដែលត្រូវឆ្លៀតឱកាសដែលសត្រូវលុតជង្គង់ ដើម្បីបង្កើតសន្តិភាពជាមួយវា»[១២] ។ ឡេ ឡយ បានធ្វើតាមការឲ្យយោបល់របស់ ត្រាយ ។ ជាងនេះទៅទៀត ឡេ ឡយ បានប្រគល់ទៅឲ្យកងទ័ពចិន ដែលចាញ់នូវទូកចំនួន៥០០គ្រឿង សេះជាច្រើនពាន់ក្បាល និងស្បៀងអាហារមួយចំនួនធំ ដើម្បីអាចឲ្យកងទ័ពនោះត្រឡប់ទៅប្រទេសវិញ ។

ដោយដឹងយ៉ាងច្បាស់អំពីការឆ្គួតនឹងបុណ្យសក្តិរបស់ព្រះចៅអធិរាជចិន និងកិត្យានុភាពដែលឲ្យព្រះអង្គមានកិត្តិយសតែសំបកក្រៅ វៀតណាមមានការប៉ិនប្រសប់ជាខ្លាំងក្នុងសិល្បៈទទួលបានពីព្រះអង្គដោយការបញ្ចើចបញ្ចើ និងការស្ដាប់ឱវាទរបៀបលាក់លៀមនូវអ្វីដែលពួកគេមិនអាចទទួលបានដោយកម្លាំងទ័ព ។ នៅដើមសតវត្សរ៍ទី១៨ វៀតណាមបានមានបំណងដាច់ខាតក្នុងការទាមទារតំបន់ព្រំដែនមួយចម្ងាយ៤០លី-

រន្ទាស់ចិនបុរាណប្រវែងប្រហែល២០គីឡូម៉ែត្រ-ខាងក្នុងដែនដីរបស់ចិន ។ ព្រះចៅអធិរាជចិនទ្រង់ពិរោធយ៉ាងខ្លាំង ។ នៅពេលនោះ ព្រះមហាក្សត្រវៀតណាមបានរៀសរវៃ សម្តែងនូវការសោកស្តាយរបស់ព្រះអង្គដោយពាក្យសម្តីចុះញ៉ំមពេញលេញមួយ ។ ដោយត្រូវធ្វើឲ្យធូរស្រាល ព្រះចៅអធិរាជបានធ្វើសម្បទានដោយឥតយកកម្រៃនិងរហូតតទៅនូវដែនដីដែលតវ៉ាដោយប្រទេសវៀតណាម[១៣] ។ នៅឆ្នាំ១៧៨៨ វីរបុរសវៀតណាម ង្វៀន ហ៊ុយ បានវាយរុញច្រានការលុកលុយមួយរបស់រាជវង្ស ជិញ ។ បន្ទាប់ពីការវាយរុញច្រាន គាត់បានបញ្ជូនទៅឲ្យព្រះចៅអធិរាជចិននូវលិខិតសុំដាក់ខ្លួនក្រោមបង្គាប់និងការសុំទោសមួយ ។ គាត់បានពន្យល់ដោយរាបសាថា ការវាយប្រហាររបស់កងទ័ពគាត់គឺជាខបន្ទុវហេតុមួយ ។ ប៉ុន្តែ អំពើដែលធ្វើឲ្យប៉ះពាល់ដល់អង្គអធិរាជត្រូវតែព្យាបាល ។ ដូច្នេះ ដើម្បីលុបលាងកំហុស ង្វៀន ហ៊ុយ បានសន្យាធ្វើដំណើរដោយផ្ទាល់ទៅកាន់ក្រុងប៉េកាំង ក្នុងឱកាសបុណ្យខួបប៉ែតសិបព្រះវស្សារបស់ព្រះចៅអធិរាជ ។ តាមការពិត គាត់បានបញ្ជូនក្មួយប្រុសម្នាក់ដែលមានរូបរាងនិងលក្ខណៈដូចគ្នាបេះបិទឲ្យទៅជំនួសគាត់ ។ តើព្រះចៅអធិរាជរកឃើញការបោកបន្លំនេះទេ? គេមិនដឹង ។ ទោះជាយ៉ាងណាក៏ដោយ ង្វៀន ហ៊ុយ ក្លែងក្លាយបានទទួលការធ្វើពិធីបដិសណ្ឋារកិច្ចដ៏ឱឡារិកមួយស័ក្តិសមជាភ្ញៀវព្រះចៅអធិរាជមួយអង្គដែលកំពុងមានវិប្បដិសារី[១៤] ។

ចាប់ពីសតវត្សរ៍ទី១០ នយោបាយរបស់វៀតណាមចំពោះបណ្តាប្រទេសជិតខាងខ្លួន-ចម្ប៉ា កម្ពុជា ថៃ និងដែនដីតូចៗដែលមានក្សត្រគ្រងរាជ្យនៅប្រទេសឡាវ-បានប្រែផ្លាស់ទៅជាលែងចំណុះប្រទេសចិន ។ ប៉ុន្តែ ក្នុងករណីជាច្រើន វៀតណាមបានប្រុងប្រៀបជាស្រេចដើម្បីទូលព្រះចៅអធិរាជឲ្យដឹងពីមូលហេតុ ឬលេសផ្សេងៗ និងសកម្មភាពនានាដែលផ្តើមធ្វើប្រឆាំងនឹងរដ្ឋចំណុះខ្លះក្នុងចំណោមរដ្ឋចំណុះជាច្រើនទៀត របស់ព្រះអង្គ ។ នៅឆ្នាំ១០៨៤ ព្រះមហាក្សត្រវៀតណាម លី ថៃតុង ដែលខំប្រឹងបង្ហាញភ័ស្តុតាងពីការចូលលុកលុយរបស់ព្រះអង្គក្នុងនគរចម្ប៉ា បានអញ្ជើញអ្នកនិពន្ធសៀវភៅលទ្ធិខុងជឺឲ្យមកជួយខ្លួន ដើម្បីបង្ហាញថាប្រទេសនេះខ្វះការគោរពចំពោះព្រះអង្គ ។ គំរូនៃសេចក្តីឆ្លើយដោះសាដូចគ្នានេះ អាចរកឃើញការអនុគ្រោះពីព្រះរាជវាំងចិនដងដែរ ។ នៅឆ្នាំ១៨៤៦ វៀតណាមបានប្តឹងរាជរដ្ឋាភិបាលរាជវង្ស មិញ អំពីការប្លន់បំផ្លាញដែលប្រព្រឹត្តដោយពួកចាមនៅតាមព្រំដែនថែមទៀត ។ ដោយហេតុនេះ ព្រះចៅអធិរាជចិនបានទូន្មានព្រះមហាក្សត្រចាមយ៉ាងម៉ឺងម៉ាត់ឲ្យឈប់រំលោភព្រំដែនរបស់វៀតណាម ។ ម្ភៃបីឆ្នាំក្រោយមកនៅពេលដែលព្រះអង្គត្រៀមព្រះកាយធ្វើការវាយប្រហារយ៉ាងធ្ងន់ធ្ងរបំផុត ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនទៅលើនគរចម្ប៉ា ព្រះចៅអធិរាជវៀតណាម ថាញ់ តុង បានចាត់បញ្ជូនបេសកជនម្នាក់ទៅជួបរាជរដ្ឋាភិបាលរាជវង្ស មិញ ដើម្បីរាយការណ៍ពីមូលហេតុផ្សេងៗនៃគម្រោងការលុកលុយរបស់ខ្លួន ក្នុងគោលបំណងកុំឲ្យពួកចិនមានកំហឹង[១៥] ។

ព្រះមហាក្សត្រទាំងឡាយរបស់វៀតណាមបានប្រឹងប្រែងបង្កើតតាមគំរូរបស់ចិននូវប្រព័ន្ធត្រូវបង់សួយសារអាករផ្ទាល់របស់ខ្លួន ។ ពួកក្សត្រទាំងនេះបានតែងតាំងខ្លួនតែខ្លួនឯងក្រោមពាក្យ *Vuong* (ព្រះមហាក្សត្រ)

នៅចំពោះមុខពួកចិន ប៉ុន្តែ ក្រោមពាក្យថា Hoang (ព្រះចៅអធិរាជ) នៅពេលដែលពួកគេមានការទាក់ទងជាមួយអាណាប្រជារាស្ត្រផ្ទាល់របស់គេឬជាមួយព្រះមហាក្សត្រផ្សេងៗ ទៀតនៅអាស៊ី-អាគ្នេយ៍ ។ ក្នុងគោលបំណងធ្វើត្រាប់តាម(ដោយគ្មានពិចារណា) ប្រទេសចិន ពួកក្សត្រទាំងនេះឈានរហូតដល់ហៅប្រទេសរបស់ខ្លួនថា "អាណាចក្រកណ្តាល" ទៀតផង ។ ភាពដូចគ្នានៃវិមានអធិរាជដែលពួកគេស្ថាបនានៅលើទីក្រុងវ៉េ គឺមានលក្ខណៈដូចគ្នា បេះបិទនឹងបុរីហាមឃាត់ (Cité interdite) នៅទីក្រុងប៉េកាំង តាំងពីប្រឡាយទឹករហូតដល់ទ្វារ ។ នៅដើមសតវត្សរ៍ទី១១ ព្រះរាជវាំងក្រុងវ៉េ បានថ្វាយព្រះមហាក្សត្រប្រទេសកម្ពុជា ដែលខ្លួនធ្វើឫកជាចាត់ទុកដូចប្រទេសចំណុះមួយនូវត្រាពណ៌មាសវិចិត្រទៅដោយរូបសត្វអូដ្ឋលេចក្រឡោតមួយ ដែលជាគំរូដើមពិតប្រាកដនៃត្រាដែលខ្លួនធ្លាប់បានទទួលពីទីក្រុងប៉េកាំងជាសក្ខីភាពនៃការទទួលស្គាល់ ។ "ភាពចម្លែក"នៃសត្វដែលឆ្លាក់នៅលើត្រាបានបង្កឲ្យមានការចង់ដឹងខ្លះៗ នៅទីក្រុងភ្នំពេញ ដែលនៅទីបំផុតគេបានកំណត់សត្វនេះក្រោមការហៅថា គោចិន[១៦] ។

លោក អាឡិចហ្សង់ឌ័រ វូដសែដ៍ បានកត់ត្រាថា ស្មារតីភក្តីរបស់ព្រះចៅអធិរាជវៀតណាមនិងរបៀបចាត់ការរដ្ឋរបស់ព្រះអង្គចំពោះប្រព័ន្ធនៃការចាត់ចែងនយោបាយចិន បានជំរុញឲ្យពួកចិនជឿថា "ពួកគេរួមបន្កជាប៉ូលស្រូបទាញផ្នែកវប្បធម៌នៃសង្គមខ្លួនឯងមួយដែលព័ទ្ធជុំវិញ ដោយ"ពួកអនារ្យជនដែលបានតែខាងបង្កឲ្យមានភាពវឹកវរ"[១៧] ។ បំណងផ្នែកវប្បធម៌របស់រាជរដ្ឋាភិបាលវៀតណាមមិនអាចប្រៀបបាននឹងវប្បធម៌របស់ប្រទេសចិន ប៉ុន្តែ ទីទៃពីវប្បធម៌របស់ចិនគឺប្រទេសវៀតណាមព័ទ្ធជុំវិញទៅដោយប្រទេសដែលមានវប្បធម៌សម្បូណ៌បែបទៀត ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកវៀតណាមខ្លួនឯងមិនដែលមានសេចក្តីទុកចិត្តមួយដែលអាចប្រៀបធៀបបាននឹងវប្បធម៌របស់ពួកចិនឡើយ ។ នេះហើយជាប្រភពនៃអស្ថិរភាពនិងជម្លោះ ដែលបង្ហាញឲ្យឃើញពីការសាកល្បងដែលនាំឲ្យវិនាសអន្តរាយរបស់ព្រះចៅអធិរាជ មិញ ម៉ាង ក្នុងការធ្វើឲ្យប្រទេសកម្ពុជាមានលក្ខណៈជាវៀតណាមប្រហែលនៅឆ្នាំ១៨៣០ ។

ដើម្បីបង្ហាញភស្តុតាងពីការពង្រីកអាណាព្យាបាលភាពរបស់ខ្លួននៅប្រទេសកម្ពុជា និងបណ្តារដ្ឋតូចៗ (ដែលមានក្សត្រគ្រងរាជ្យ) នៅប្រទេសឡាវ វៀតណាមបានទាញយកប្រយោជន៍ពីតម្រូវការផ្នែកសន្តិសុខថែមទៀត ក្រៅពីអំនួតក្អេងក្អាងផ្នែកវប្បធម៌របស់គេ ។ ង្វៀន ទ្រី ភុង ជាមន្ត្រីនៅព្រះរាជវាំងក្រុងវ៉េ បានបញ្ចេញយោបល់នៅឆ្នាំ១៨៣៥ថា ៖ "ស្ថានភាពភូមិសាស្ត្ររបស់ប្រទេសវៀតណាមជាស្ថានភាពដែលមានគ្រោះថ្នាក់ខ្លាំងណាស់ ។ ប្រទេសវៀតណាមមានលក្ខណៈទល់ខ្នងនឹងប្រទេសដ៏ធំល្វឹងល្វើយមួយគឺប្រទេសចិន ហើយដែលគំនិតចូលចិត្តចម្បាំងរបស់គេបានជំរុញឲ្យពង្រីកទឹកដីជាប់ជាប្រចាំមកកាន់ប្រទេសជិតខាងខ្លួនដែលចិនចាត់ទុកជាប្រទេសគ្មានអារ្យធម៌ ។ នៅភាគខាងលិច និងខាងត្បូងមានជាតិសាសន៍ជាច្រើនចូលចិត្តវាតទឹកដីដែរ ដែលការលុកលុយផ្សេងៗមកលើទឹកដីយើងលែងមានសារសំខាន់ទៀតហើយ... ។ ដើម្បីធានានូវសន្តិសុខនិងវិបុលភាព

ពួកគេ[វៀតណាម]ត្រូវតែប្រឆាំងដោយគ្មានឈប់ផ្អាកចំពោះការឈ្លានពានទាំងអស់របស់ប្រជាជននិងកុលសម្ពន្ធទាំងនោះ ។ ប្រទេសកម្ពុជាមានលក្ខណៈទន់ខ្សោយ ការបះបោរនៅក្នុងប្រទេសមានលក្ខណៈត្រាំត្រែង ដែលធ្វើឲ្យប្រជាជនភ័យជ្រួលច្របល់ ដូចជាការលុកលុយនៃកងទ័ពសៀមជាដើម ។ ជាច្រើនលើកច្រើនសាកម្ពុជាបានទទូចសុំជំនួយរបស់យើង ដើម្បីធ្វើឲ្យមានសន្តិសុខនិងរៀបចំឲ្យមានរបៀបរៀបរយក្នុងប្រទេសរបស់គេឡើងវិញ»[១៨] ។ ហេតុនេះ ព្រះរាជវាំង វេ បានរៀបចំការត្រួតត្រារបស់ខ្លួនលើប្រទេសកម្ពុជាក្រោមលេសថាការពារប្រទេសនេះទល់នឹងការធ្វើអន្តរាគមន៍របស់សៀម ។ នៅឆ្នាំ១៨២៧ វៀតណាមត្រូវតែជួយព្រះអង្គម្ចាស់ឡាវមួយអង្គ ដែលនៅក្រោមចំណុះខ្លួន ដើម្បីរុញច្រានការគំរាមកំហែងរបស់សៀមដូចគ្នា ។ ប្រទេសវៀតណាមបានឆ្លៀតឱកាសនេះ កាន់កាប់ដែនដីដ៏ធំល្វឹងល្វើយនៅភាគខាងជើងនិងភាគកណ្តាលប្រទេសឡាវជាពិសេស សាមនឿ ជាតំបន់មួយ ដែល១២៥ឆ្នាំក្រោយមកបានក្លាយទៅជាមូលដ្ឋានដ៏រឹងមាំរបស់ចលនាតស៊ូប៉ាថេតឡាវ ដោយមានការគាំទ្ររបស់វៀតណាមផង ។ នៅចុងសតវត្សរ៍ទី១៩ ដោយដណ្តើមយកប្រទេសឡាវកម្ពុជា និងវៀតណាម ប្រទេសបារាំងបានត្រឹមតែបញ្ចប់អធិបតេយ្យមួយពាន់ឆ្នាំរបស់ចិនមកលើប្រទេសនេះប៉ុណ្ណោះ ។ ប្រទេសបារាំងបានបង្កើតឲ្យមាននយោបាយនិងយុទ្ធសាស្ត្រតែមួយ (ឥណ្ឌូចិនរបស់បារាំង) ដែលបណ្តាព្រះចៅអធិរាជ ត្រកូល ង្វៀន ហាក់ដូចជាកំពុងធ្វើឲ្យសម្រេចពិតប្រាកដសម្រាប់ផលប្រយោជន៍ផ្ទាល់របស់ព្រះអង្គហើយ ។

## រួបរួមគ្នាប៉ុន្តែមិនស្មើគ្នា

មួយភាគបួននៃសតវត្សរ៍ក្រោយពីការបែកបាក់ឥណ្ឌូចិនរបស់បារាំង និងការកកើតរដ្ឋឡាវ កម្ពុជា និងវៀតណាមដែលឯករាជ្យ គំនិតចង់ឲ្យមាន«ប្លុកឥណ្ឌូចិន»មួយដែលគ្រប់គ្រងដោយក្រុងហាណូយបានលេចឡើងម្តងទៀត ។ តើវៀតណាមមានបំណងទទួលមរតកខ្សែបន្ទាត់ព្រំដែនរបស់អាណានិគមដើម្បី«បំពេញគោលដៅខាងវប្បធម៌និងនយោបាយរបស់បុព្វបុរសនៃប្រទេសវៀតណាម»មែនឬ?»[១៩] ។ សញ្ញាណនៃ«សហព័ន្ធឥណ្ឌូចិន» ដែលអំពាវនាវដោយពួកកុម្មុយនីស្តវៀតណាមក្នុងអំឡុងទសវត្សរ៍៣០ ពុំមែនជារបៀបបកស្រាយតាមរបៀបថ្មីនៃចក្រភពសន្តតិវង្ស ង្វៀន ទេឬ? ។ បើពិនិត្យឲ្យដិតដល់ទៅការវិវត្តនៃនយោបាយរបស់វៀតណាមនៅឥណ្ឌូចិនក្នុងរយៈពេលហាសិបឆ្នាំចុងក្រោយនេះ បានដៅឲ្យឃើញពីការបន្តយុទ្ធសាស្ត្ររបស់គេ ហើយបទពិសោធន៍ថ្មីៗក៏ត្រូវបានពង្រឹងឡើងថែមទៀត ។ ក៏ប៉ុន្តែ ការវាយតម្លៃដ៏ឈ្លាសវៃបំផុតរបស់គេអំពីកម្លាំងជាតិនិយមផ្សេងៗនិងស្ថិរភាពភូមិសាស្ត្រនយោបាយក្នុងតំបន់ បានឃាំងមិនឲ្យក្រុងហាណូយរៀបចំនយោបាយបច្ចុប្បន្នមួយស្របគ្នានឹងនយោបាយវៀតណាមសម័យព្រះចៅអធិរាជបានឡើយ ។

រឿងប្រវត្តិសាស្ត្រនិយាយតៗគ្នាមួយអះអាងថា ហូជីមិញ ធ្លាប់រក្សាបំណងយ៉ាងខ្ជាប់ខ្ជួនអំពី«សហពន្ធ័

ឥណ្ឌូចិន»មួយក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយបំណងនេះគឺជាប្រភពដើមនៃការបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិននោះឯង ។ តាមពិត គំនិតនៃឧត្តមានុភាព(ភាពសំខាន់ដ៏លើសលប់)របស់វៀតណាម នៅឥណ្ឌូចិននេះបានត្រូវដាក់បង្ហំទៅតាមឆន្ទៈរបស់អង្គការកុម្មិនទែនទៅវិញទេ ។ [កុម្មិនទែន ជាអង្គការកុម្មុយនីស្តអន្តរជាតិទីបីបង្កើតដោយលេនីននៅខែមីនា ឆ្នាំ១៩១៩ ត្រូវបានរំលាយចោលនៅឆ្នាំ១៩៤៣ ។ ពាក្យនេះជាអក្សរកាត់នៃភាសារុស្ស៊ី ពាក្យពេញលេញគឺ (Kommounistitcheski Internatsional) – កំណត់របស់អ្នកបកប្រែ] ។ ការស្រាវជ្រាវក្នុងពេលថ្មីៗនេះបង្ហាញឲ្យឃើញថា ក្នុងអំឡុងទសវត្សរ៍៣០ ពួកកុម្មុយនីស្តវៀតណាមបានយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីជួយធ្វើឲ្យការបដិវត្តន៍នៅឡាវនិងកម្ពុជារីកលូតលាស់ផងដែរ ។ នៅខែកុម្ភៈ ឆ្នាំ១៩៣០ ជនកុម្មុយនីស្តជាច្រើនក្រុមបានប្រមូលផ្តុំគ្នានៅក្រុងហុងកុង ដើម្បីបង្កើតបក្សមួយថ្មីដែលពួកគេឲ្យឈ្មោះថា បក្សកុម្មុយនីស្តវៀតណាម ។ ការសម្រេចចិត្តនោះនាំឲ្យមានការស្តីបន្ទោសយ៉ាងខ្លាំងពីសំណាក់អង្គការកុម្មិនទែនដោយទិតៀនពីគំនិតជាតិនិយមចង្អៀតចង្អល់និងការមិនដឹងពីលទ្ធិអន្តរជាតិនិយមវណ្ណៈអធនរបស់គេ ។ តាមបញ្ជារបស់អង្គការកុម្មិនទែន ឈ្មោះបក្សបានត្រូវផ្លាស់ទៅជាបក្សកុម្មុយនីស្តឥណ្ឌូចិនវិញ ។ អង្គការកុម្មុយនីស្តអន្តរជាតិបានអះអាងថា ការកាន់កាប់ត្រួតត្រារបស់អាណានិគមបារាំងគឺជាសត្រូវតែមួយគត់របស់ប្រជាជនឥណ្ឌូចិន ដូច្នេះដើម្បីវាយប្រយុទ្ធនឹងការកាន់កាប់នោះ ត្រូវព្រមព្រៀងគ្នាបង្កើតជាអង្គការឯកភាពមួយ ។ ទស្សនាវដ្តីមួយរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនចុះកាលបរិច្ឆេទឆ្នាំ១៩៣២ បានធ្វើអត្ថាធិប្បាយថា "ថ្វីដ្បិតប្រទេសទាំងបី (ឡាវ កម្ពុជា និង វៀតណាម) ជាពូជសាសន៍បីខុសគ្នាជាមួយភាសា ប្រពៃណី និងអាកប្បកិរិយាបុកពាខុសគ្នាក៏ដោយ ក៏ពួកគេបានបង្កើតជាប្រទេសតែមួយនិងដូចគ្នា... ។ គេពុំអាចធ្វើបដិវត្តដោយរបៀបដាច់ដោយឡែកនៅវៀតណាម កម្ពុជា និងនៅឡាវបានទេ ។ ដើម្បីប្រឈមមុខតតាំងនឹងសត្រូវប្រឆាំងបដិវត្តន៍ ដែលកម្លាំងទាំងអស់ប្រមូលផ្តុំក្រោមបញ្ជាការឯកភាពក្នុងទូទាំងឥណ្ឌូចិននោះ បក្សកុម្មុយនីស្តត្រូវតែប្រមូលផ្តុំកម្លាំងវណ្ណៈអធននៅឥណ្ឌូចិនបង្កើតជារណសិរ្សរួបរួមមួយ ក្រោមការដឹកនាំរបស់វណ្ណៈអធនឥណ្ឌូចិន (ដែលតំណាងដោយបក្សកុម្មុយនីស្តឥណ្ឌូចិន)»[៧០] ។

បើទោះជាមានការណែនាំទាំងនេះក៏ដោយ ក៏ការខិតខំប្រឹងប្រែងទាំងឡាយរបស់វៀតណាមដើម្បីប្រមូល "វណ្ណៈអធននៅឥណ្ឌូចិន" ឬជ្រើសរើសអ្នកសុំចូលបក្សជាជនជាតិឡាវ ឬជនជាតិខ្មែរមិនសូវបានលទ្ធផលឡើយព្រោះតាមប្រទេសទាំងនោះស្ទើរតែគ្មានមនុស្សដែលគេត្រូវការផង ។ សក្តានុពល(កម្លាំងដែលអាចប្រើបាន) បដិវត្តដែលលាក់ខ្លួនតាមភូមិតូចៗនៅប្រទេសឡាវ និងកម្ពុជាពុំទាន់លេចចេញច្បាស់លាស់នៅឡើយ ។ ម្យ៉ាងទៀតវៀតណាមក៏មានទស្សនៈសំគិះមួយចំពោះប្រទេសទាំងពីរដែរ ។ សរុបទៅបក្សកុម្មុយនីស្តឥណ្ឌូចិន គឺជាបក្សមួយរបស់វៀតណាម ។ នៅប្រទេសឡាវនិងនៅប្រទេសកម្ពុជាផ្ទាល់ ក្រុមតស៊ូផ្នែកនយោបាយនៃបក្សកុម្មុយនីស្តឥណ្ឌូចិន មានសមាសភាពភាគច្រើនសុទ្ធតែជាជនអន្តោប្រវេសន៍វៀតណាម ។ គោលការណ៍អន្តរជាតិនិយមនៃ

អង្គការកុម្មុយនិស្តអន្តរជាតិ និងជំនឿរបស់ខ្លួនអំពីរដ្ឋសហព័ន្ធមួយតាមបែបដែនសូវៀតនោះ យ៉ាងហោចណាស់បានបណ្ដាលឲ្យបក្សកុម្មុយនីស្តឥណ្ឌូចិនអនុម័តការសម្រេចចិត្តមួយនៅក្នុងឱកាសនៃសមាជលើកដំបូងរបស់ខ្លួន នាខែមីនា ១៩៣៥ ដោយរំពឹងពីយថាភាពនៃការបង្កើតសហព័ន្ធមួយ ។ អត្ថបទនេះបានដៅបញ្ជាក់ថា "នៅពេលដែលពួកចក្រពត្តិបារាំងត្រូវបានបណ្ដេញចេញពីឥណ្ឌូចិន ប្រជាជាតិនីមួយៗនឹងបានទទួលសិទ្ធិស្វ័យសម្រេច (ការសម្រេចកិច្ចការអ្វីៗដោយខ្លួនឯង) ។ សិទ្ធិស្វ័យសម្រេចនេះអាចចូលរួមក្នុងសហព័ន្ធក៏បាន ឬបង្កើតរដ្ឋមួយដាច់ដោយឡែកក៏បាន ។ ប្រជាជាតិនីមួយៗនឹងមានសេរីភាពចូលរួម ឬដកខ្លួនពីសហព័ន្ធ ។ សិទ្ធិនេះអាចរួបរួមនិងប្រព័ន្ធណាមួយក៏បានតាមការជ្រើសរើសរបស់ខ្លួន" ។[២១] នៅដើមទសវត្សរ៍៤០ ពួកវៀតណាមបានយល់ដឹងពីឧត្ដមគតិជាតិនៃប្រជាជនឡាវ និងកម្ពុជាថែមទៀត ជាពិសេសការយកចិត្តទុកដាក់របស់ប្រជាជនទៅលើចលនាខ្មែរឥស្សរៈដែលកាន់តែរីកធំឡើងៗ ។ នៅឆ្នាំ១៩៤១ សេចក្ដីសម្រេចចិត្តមួយរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការ"ប្រើប្រាស់នយោបាយសមស្របមួយស្ដីពីសិទ្ធិស្វ័យសម្រេចជាតិ" ក្រោយពីការចាកចេញរបស់ពួកបារាំង ។ អត្ថបទបានបន្តថា "នេះជាសិទ្ធិរបស់ប្រជាជននៅឥណ្ឌូចិន ក្នុងការសម្រេចចិត្តរបស់ខ្លួន បើសិនជាពួកគេប្រាថ្នារួមគ្នាបង្កើតទៅជាសហភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យ ឬផ្ទុយទៅវិញចង់ស្ថិតនៅជារដ្ឋដាច់ដោយឡែកក៏បាន"[២២] ។ ដប់ឆ្នាំក្រោយមក សញ្ញាណនៃសហព័ន្ធខាងនយោបាយដែលមិនប្រាកដប្រជានេះបានត្រូវគេបោះបង់ចោល ។ បក្សកុម្មុយនីស្តឥណ្ឌូចិន ត្រូវបែងចែកទៅជាបីបក្សតាមជាតិនីមួយៗ ធ្វើយ៉ាងណាកុំឲ្យពួកបារាំង មានឱកាសបញ្ឆេះមនោសញ្ចេតនាប្រឆាំងវៀតណាមពីសំណាក់ប្រជាជនឡាវ និងខ្មែរបាន ។ ទោះជាគំនិតអំពីសហព័ន្ធមិនបានសម្រេចក៏ដោយ ក៏គំនិតមួយទៀតបានផ្ដើមចាក់ឫសដែរ ដែលតាមរយៈនោះ ការចាត់ចែងដឹកនាំផ្នែកមនោគមវិជ្ជា និងការប្រយុទ្ធដើម្បីឯករាជ្យភាពនៅឥណ្ឌូចិនត្រូវធ្លាក់ទៅលើវៀតណាមដដែល ។ ការប្រយុទ្ធប្រឆាំងនឹងពួកបារាំងបានបំពេញគំនិតនេះថែមទៀត ។

ក្នុងពេលជាមួយគ្នា ដែលវៀតណាមចាប់ផ្ដើមចៀសវាងការធ្វើឲ្យមានគ្រោះថ្នាក់ ដោយប្រៀបធៀបនឹងគំនិតសហព័ន្ធដែលណែនាំដោយអង្គការកុម្មុយនិស្តអន្តរជាតិ ដោយពិត ការដឹកនាំធ្វើប្រតិបត្តិការយោធា បានប្រទាញពួកគេទៅរកទិសផ្ទុយគ្នាយ៉ាងជាក់ច្បាស់ ។ ឥណ្ឌូចិនបានលេចឡើងជារៀងរាល់ថ្ងៃធ្វើឲ្យវៀតណាមមើលឃើញថា ជាសមរភូមិជាយុទ្ធសាស្ត្រតែមួយគត់ ។ វៀតណាមបេះធ្វើឲ្យប្រពៃណីផ្នែកយោធារបស់ខ្លួនទំនើបឡើងដោយអនុលោមទៅតាមបទពិសោធន៍នៃការតស៊ូរបស់ដូនតាខ្លួនទល់នឹងប្រទេសចិន ដែលធ្វើសង្គ្រាមប្រជាជនតាមគំនិត ម៉ៅ ។ ប៉ុន្តែ ខុសប្លែកពីពួកកុម្មុយនីស្តចិន វៀតណាមពុំមានកន្លែងសម្រាប់ការពារដែនដីដ៏ធំល្វឹងល្វើយដើម្បីរៀបចំទ័ពរបស់ពួកគេឡើងវិញមុននឹងចេញទៅសាកល្បងនឹងឧត្ដមភាពរបស់សត្រូវឡើយ ។ ពួកគេពុំអាចធ្វើសម្បទានដើម្បីពន្យារពេលទេ ។ ចំណុចខ្សោយនេះបានក្លាយទៅជាជាក់ស្ដែង នៅពេលដែលប្រទេសបារាំងប្រើប្រាស់ទំហំដែនដីទាំងមូលរបស់ឥណ្ឌូចិន ។ នៅឆ្នាំ១៩៤៧ ពួកបារាំងបានចាប់ផ្ដើមធ្វើការវាយលុកក្នុង

វិសាលភាពយ៉ាងធំប្រឆាំងនឹងកន្លែងការពារមាំទាំនានារបស់វៀតមិញ ចាប់ពីប្រទេសឡាវ និងប្រទេសកម្ពុជា ។ ប្រវត្តិវិទូខាងកងទ័ព វីល្លីយ៉ាំ ឌឺរលី បានកត់សម្គាល់ថា “បទពិសោធន៍នេះ បានបង្ហំឲ្យវៀតណាមប្រមើលមើលការបដិវត្តន៍នៅប្រទេសឡាវនិងកម្ពុជាថា ជាមធ្យោបាយសម្រាប់វាយប្រហារពួកបារាំងពីចំហៀង និងធ្វើឲ្យកងទ័ពបារាំងមួយផ្នែកបែងធ្វើសកម្មភាពកើត”[២៣] ។

នៅឆ្នាំ១៩៥០ នៅពេលដែលវៀតមិញរៀបចំការវាយបករបស់ខ្លួនប្រឆាំងទល់នឹងពួកបារាំង ឧត្តមសេនីយ៍ យ៉ាប ដែលជាអ្នកបញ្ជាប្រតិបត្តិការសឹកទាំងអស់បានតែងនិពន្ធសៀវភៅស្តើងមួយដែលជាឃ្លាំងព័ត៌មានពិតប្រាកដស្តីពីយុទ្ធសាស្ត្ររបស់វៀតណាមនៅក្នុងតំបន់នេះ ។ គាត់បានសរសេរថា “ឥណ្ឌូចិន គឺជាទីតាំងយុទ្ធសាស្ត្រនិងជាសមរភូមិរួមតែមួយគត់ ។ ដោយមូលហេតុនេះហើយដែលវាគ្មានប្រយោជន៍ទាល់តែសោះក្នុងការរំពឹងពីឯករាជ្យភាពរបស់ប្រទេសវៀតណាម ដរាបណាប្រទេសកម្ពុជា និងឡាវនៅតែស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រពត្តិនិយមនោះ ហើយយើងក៏ពុំអាចលែលកឲ្យប្រទេសកម្ពុជាមួយនិងប្រទេសឡាវមួយឯករាជ្យបានដែរ ដរាបណាវៀតណាមនៅតែត្រូវត្រួតត្រាដោយពួកចក្រពត្តិ ។ ពួកអាណានិគមសុទ្ធតែធ្លាប់ប្រើប្រាស់ប្រទេសកម្ពុជាដើម្បីវាយប្រហារមកលើប្រទេសវៀតណាម ។ ប្រទេសឡាវនិងកម្ពុជា បានក្លាយទៅជាមូលដ្ឋានក្រោយជាបណ្តោះអាសន្នដែលសត្រូវតែងតែរួចផុតពីការវាយប្រហារជានិច្ច ក្នុងពេលដំណាលគ្នាដែលសមរភូមិនៅឥណ្ឌូចិនជាកន្លែងដែលងាយរងគ្រោះខ្លាំងទៅវិញ ។ ដោយហេតុនេះ យើងត្រូវតែបើករណសិរ្សប្រយុទ្ធនៅឡាវ-កម្ពុជាដោយមោះមុត និងដោយកម្លាំងទ័ពទាំងអស់របស់យើង”[២៤] ។

ដោយភ្ជាប់ទង្វើនិងសម្តី វៀតមិញបានវាយប្រហារជាបន្តបន្ទាប់នៅភាគខាងជើង ភាគកណ្តាល និងភាគខាងត្បូងប្រទេសឡាវ ព្រមទាំងភាគកណ្តាលវៀតណាមផងដែរ មុននឹងកៀងពួកបារាំងឲ្យធ្លាក់ទៅក្នុងអន្ទាក់នៅឌៀនបៀនភូយ៉ាងប្រយ័ត្នប្រយែងបំផុត ។ ក្នុងពេលជាមួយគ្នានោះ កងទ័ពវៀតណាមមួយចំនួនតូចបានរួបរួមនឹងខ្មែរឥស្សរៈហើយធ្វើទុក្ខបុកម្នេញរំខានពួកបារាំងដែលនៅកម្ពុជា ។ ដោយលើកទង់ជ័យសសុំចុះចាញ់ បន្ទាយឌៀនបៀនភូបានផ្តល់ជាសញ្ញានៃការចាកចេញរបស់ពួកបារាំង ពុំត្រឹមតែពីវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែពីឥណ្ឌូចិនទាំងមូល ។

សត្រូវរួមរបស់អ្នកជាតិនិយម គឺប្រទេសបារាំងដែលពីពេលនេះទៅត្រូវបានបណ្តេញចេញពីសមរភូមិឥណ្ឌូចិនអស់ហើយ ។ ក៏ប៉ុន្តែក្នុងបណ្តាឆ្នាំក្រោយៗមកទៀត ព្រឹត្តិការណ៍ផ្សេងៗនៃការប្រយុទ្ធគ្នារបស់វៀតណាម ដើម្បីបង្រួបបង្រួមប្រទេសរបស់ខ្លួនឡើងវិញ ហាក់ដូចជាអះអាងបន្ថែមនូវសុពលភាពនិក្ខេបបទរបស់យ៉ាប ឲ្យរឹតតែជាក់ច្បាស់ឡើងទៀត ។ ពួកគូសត្រូវនឹងការបង្រួបបង្រួមប្រទេសវៀតណាមឡើងវិញ តែងតែត្រូវការដែនដីកម្ពុជានិងឡាវជាប្រទេសជិតខាងខ្លួនជានិច្ច ក្នុងការទប់ស្កាត់ការរុលមកមុខរបស់កុម្មុយនីស្តក៏ដូចក្រុងហាណូយដែរ ដើម្បីធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងទាំងឡាយរបស់ខ្លួនសម្រេចជោគជ័យ ។ ដូចដែលលោក ឌឺរលី

បានកត់សម្គាល់គឺ មុននឹងបង្កឲ្យមានសង្គ្រាមឥណ្ឌូចិនលើកទី២ សហរដ្ឋអាមេរិកដែលសមគំនិតនឹងប្រទេសថៃ បានឆ្លៀតទាញអត្ថប្រយោជន៍ពីអស្ថិរភាពនយោបាយនៅប្រទេសឡាវ ដោយរៀបចំឈរជើងនៅតំបន់វាលរាបដដែល ជាទីដែលពួកបារាំងធ្លាប់វាយវៀតមិញកាលពីមុនៗ ។ តាមរបៀបដូចគ្នានេះ ការបែងចែកប្រទេសវៀតណាមតាមបណ្ដោយខ្សែស្របទី១៧ជាបណ្ដោះអាសន្ន ដែលសម្រេចដោយសន្និសីទក្រុងហ្សឺណែវ បានបង្ខំឲ្យបក្សពលករវៀតណាមដែលកាន់អំណាចនៅភាគខាងជើងប្រើប្រាស់ផ្លូវវៀងជាច្រើនរបស់ប្រទេសឡាវ ដើម្បីរក្សាការទាក់ទងជាមួយអង្គការចាត់តាំងរបស់ខ្លួននៅភាគខាងត្បូង ។ នៅវៀតណាមខាងត្បូងតែម្ដង ជាទីដែលសង្គ្រាមទ័ពព្រៃជឿនលឿនទៅមុខ គេសម្គាល់ឃើញមានខ្សែបណ្ដាញផ្លូវលំមួយពុះកាត់តាមព្រៃភ្នំឆ្ពោះមកតំបន់ភាគឦសានប្រទេសកម្ពុជាឆ្លងកាត់តាមបរិព័ទ្ធភូមិសម្បូរទៅដោយភ្នំនៃប្រទេសឡាវផងនេះគឺជាផ្លូវលំហូជីមិញដ៏ល្បីល្បាញ ជាប្រព័ន្ធផ្លូវដ៏សាំញ៉ាំមួយដែលអាចបើករថយន្តបាន មានបណ្ដោយទាំងអស់ប្រវែងប្រហែល១៣.០០០គីឡូម៉ែត្រ ។ ក្នុងលំដាប់ដែលផ្លូវលំនេះក្លាយជាខ្សែរយៈទាក់ទងដ៏សំខាន់ស្មើអាយុជីវិតរបស់ពួកកុម្មុយនីស្តឆ្ពោះមកភាគខាងត្បូងនោះ សហរដ្ឋអាមេរិកក៏បង្កើនសង្គ្រាមរបស់ខ្លួនដែលមិនប្រកាសចេញមុខប្រឆាំងនឹងវៀតណាមកាន់តែខ្លាំងឡើងៗដែរ ។ អាមេរិកាំងបានផ្គត់ផ្គង់សម្ភារសឹកមួយផ្នែកសម្រាប់កងទ័ពភូមិន្ទឡាវ ហើយមួយផ្នែកទៀតសម្រាប់អ្នកស៊ីឈ្នួលច្បាំងដែលគេជ្រើសរើសពីក្នុងបណ្ដាកុលសម្ព័ន្ធនៅតាមមូលដ្ឋាននោះ ។ គ្រោះថ្នាក់ចាប់មានរូបរាងច្បាស់លាស់នៅភាគខាងត្បូង វៀតកុងបានចាប់ផ្ដើមរៀបចំបណ្ដាទីជម្រកនិងទីតាំងបោះទ័ពបណ្ដោះអាសន្ននៅម្ខាងព្រំដែនរបស់ខ្លួនគឺកម្ពុជាដែលតាមគោលការណ៍ជាប្រទេសអព្យាក្រឹតមួយ ។

រដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០ប្រឆាំងនឹងសម្ដេច សីហនុ និងការលុកលុយប្រទេសកម្ពុជាដែលមានបន្តបន្ទាប់គ្នាមិនដាច់ដោយពួកអាមេរិកាំង បានធ្វើឲ្យព្រំដែនចុងក្រោយត្រូវរលំរលាយ ។ ឥណ្ឌូចិនទាំងមូលបានក្លាយទៅជាសមរភូមិជាយុទ្ធសាស្ត្រតែមួយនិងដូចពីមុនឡើងវិញ ៖ ការច្បាំងគ្នាដើម្បីបង្រួបបង្រួមវៀតណាមជាថ្មី បានប្រព្រឹត្តទៅក្នុងព្រៃស្បាតរបស់ប្រទេសកម្ពុជានិងតំបន់ព្រៃភ្នំនៅប្រទេសឡាវ ។ ដោយធ្វើឲ្យបរាជ័យនៅខែកុម្ភៈ ឆ្នាំ១៩៧១ ចំពោះការវាយបកយ៉ាងសម្បើមអស្ចារ្យមួយរបស់ពួកអាមេរិកាំង និងវៀតណាមខាងត្បូង ក្នុងគោលដៅយាយីប្រទេសឡាវនិងកាត់ផ្ដាច់ផ្លូវលំហូជីមិញហើយដោយវាយបំបាក់ប្រតិបត្តិការសឹកធំៗដែលផ្ដើមធ្វើដោយ លន់ នល់ ក្នុងឆ្នាំដដែលនោះ វៀតណាមខាងជើងបានត្រួតត្រាទីតាំងមួយខាងកម្លាំងទ័ពនៅឥណ្ឌូចិនដោយឥតប្រកែកបាន ។ កិច្ចប្រឹងប្រែងដ៏សម្បើមក្នុងការជួយបណ្ដុះបណ្ដាលនិងការជួយឧបត្ថម្ភរបស់វៀតណាមដល់ពួកប៉ាថេតឡាវនិងខ្មែរក្រហមពិតជាជំនួយមួយដែលពួកគេត្រូវការបំផុត ។ នៅពេលនោះសមរភូមិប្រយុទ្ធបានត្រូវរៀបចំជាស្រេចដើម្បីវាយប្រយុទ្ធផ្ដាច់ព្រ័ត្រនៅនិទាឃរដូវឆ្នាំ១៩៧៥ ។ និក្ខេបបទរបស់ យ៉ាប ដែលតែងនិពន្ធកាលពីម្ភៃប្រាំឆ្នាំមុន ហើយដែលបង្ហាញថា ឥណ្ឌូចិនជា«សមរភូមិប្រយុទ្ធតែមួយ

គត់»នោះ ពិតជាត្រឹមត្រូវដូចគាត់គិតទុកមែន ។ តែប្រាំខែក្រោយមកប៉ុណ្ណោះ ចលនាបដិវត្តទាំងអស់បានទទួលជោគជ័យនៅក្នុងប្រទេសទាំងបី ។

សន្តិភាពបានកើតមាន ប្រទេសវៀតណាមបានខំប្រឹងបង្កបង្កើតឲ្យមានខ្សែបណ្តាញសម្ព័ន្ធភាពមួយក្រោមលេសទំនាក់ទំនងពិសេស ពិតហើយគឺសំដៅធានាសន្តិសុខផ្ទាល់របស់ខ្លួន ប៉ុន្តែក៏លើកតម្កើងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចមួយក្នុងរយៈពេលវែងជាមួយកម្ពុជានិងឡាវដែរ ដោយឈរលើមូលដ្ឋាននៃភាពដូចគ្នាខាងមនោគមវិជ្ជា ។ បន្តិចម្តងៗ ក្រុងហាណូយបានដឹងពីគំនិតជាតិនិយមយ៉ាងមោះមុតរបស់ពួកខ្មែរក្រហម ពីអរិភាពកាន់តែរីកធំឡើងៗរបស់គេចំពោះវៀតណាមក្នុងបណ្តាឆ្នាំចុងក្រោយនៃសង្គ្រាម និងពីគំនិតឆ្វេងជ្រុលហួសហេតុរបស់ពួកគេទៀតផង ។

រហូតមកដល់ពេលនេះ កត្តាជាយុទ្ធសាស្ត្របានឈ្នះលើការវិភាគរបស់វៀតណាមអំពីស្ថានការណ៍នៅឥណ្ឌូចិន ។ បើអ៊ីចឹង វៀតណាមគឺជាអ្នកបន្តទ្រឹស្តីផ្នែកយោធារបស់សន្តតិវង្ស ង្វៀន ដោយរបៀបដ៏ជាក់លាក់មួយ ។ ប៉ុន្តែ ក្នុងដំណាក់កាលនៃការកសាងនិងការពង្រឹងប្រទេសឡើងវិញបន្ទាប់ពីសង្គ្រាម បញ្ហាខាងមនោគមវិជ្ជានិងសេដ្ឋកិច្ចបានចាប់មានសារសំខាន់ជាថ្មី ។ បើសិនជាកម្ពុជាផ្តាច់ស្ពានមេត្រីជាមួយប្រទេសវៀតណាមហើយអនុញ្ញាតឲ្យពួកសត្រូវរបស់វៀតណាមបោះទីតាំងនៅលើទឹកដីរបស់ខ្លួន នៅពេលនោះ ការគំរាមកំហែងដែលធ្លាប់ធ្វើឲ្យ ង្វៀន ទ្រីភុង និង វ៉ៃង្វៀនយ៉ាប ព្រួយបារម្ភខ្លាំងបំផុតនោះបានលេចចេញជាថ្មី ។ម្យ៉ាងវិញទៀត ការអនុម័តប្រកាន់យកដោយប្រទេសកម្ពុជានូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្វេងជ្រុលហួសហេតុមួយ អាចធ្វើឲ្យគម្រោងការរបស់វៀតណាមក្នុងសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងការប្រើប្រាស់រួមគ្នានូវប្រភពធនធានរបស់ប្រទេសទាំងពីរនោះ ប្រែត្រឡប់អស់ ។

ប៉ុន្តែជាដំបូង វៀតណាមចូលចិត្តសង្កត់ធ្ងន់ទៅលើភាពជាបងប្អូនដែលលត់ដំក្នុងការតស៊ូរួមជាជាងទៅលើការព្រួយបារម្ភខាងផ្នែកសេដ្ឋកិច្ច ឬបញ្ហាសន្តិសុខរបស់ខ្លួន ។ «បំណុលឈាម»មួយ បានចងភ្ជាប់ពួកឡាវនិងកម្ពុជាទៅនឹងវៀតណាម បន្ទាប់ពីការធ្វើពលិកម្មយ៉ាងច្រើនដែលលះបង់ដោយវៀតណាម នៅលើសមរភូមិប្រយុទ្ធនៃឥណ្ឌូចិន ។ វ៉ី ដុងយ៉ាង អនុរដ្ឋមន្ត្រីការបរទេសវៀតណាមបាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា ៖ «យើងទទូចឲ្យមានទំនាក់ទំនងពិសេសយ៉ាងខ្លាំង ពីព្រោះប្រវត្តិសាស្ត្រពិភពលោកគឺគ្មានគំរូ ស្តីពីទំនាក់ទំនងដូចប្រភេទនេះទេ ៖ ប្រជាជនបីប្រទេសបានប្រឡូកក្នុងការប្រយុទ្ធតស៊ូរួមគ្នាមួយ ដោយរំលែក ស្រូវ អង្ករ អំបិល និងគ្រាប់រំសេវ ជួយគ្នាទៅវិញទៅមក» ។ តាមគាត់យល់ ការស្ថាបនា និងការការពាររបស់ប្រទេសទាំងបី ត្រូវតែមានជាចាំបាច់ដើម្បីបន្តកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធនេះ ។

វៀតណាមពុំដែលនិយាយរំពុកជាចំហអំពីគំនិតស្តីពីការដាក់ប្រើរួមគ្នានូវប្រភពធនធាននៅឥណ្ឌូចិនសោះឡើយ ។ វៀតណាមគ្រាន់តែផ្តល់គំនិតស្តីពីសហប្រតិបត្តិការមួយដើម្បីធ្វើអាជីវកម្មលើទន្លេមេគង្គ

ប៉ុណ្ណោះ ។ ប៉ុន្តែតាមទស្សនៈខាងសេដ្ឋកិច្ច អ្នកធ្វើផែនការនៅក្រុងហាណូយនឹងរៀបចំឥណ្ឌូចិនជា«កន្លែងរស់» *(Espace Vital)* របស់គេ ។ ជាមួយពលរដ្ឋប្រហែល៦០លាននាក់ រស់នៅប្រមូលផ្តុំលើចម្រៀកដីតូចចង្អៀតមួយ ដែលមួយភាគធំជាតំបន់ព្រៃភ្នំ (សរុបទាំងអស់ដីដែលដាំដុះបានមាន៦លានហិកតា) ប្រទេសវៀតណាមមានផ្ទៃដីកសិកម្មសម្រាប់ប្រជាជនម្នាក់ៗតិចជាងគេបំផុតក្នុងចំណោមប្រទេសដែលមានដីតិចជាងគេនៅអាស៊ីអាគ្នេយ៍ ។ នៅឆ្នាំ២០០០ប្រទេសនេះនឹងមានពលរដ្ឋដល់ទៅ៩០លាននាក់ ។ សម្រាប់ក្រុងហាណូយ ការធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាងនៅឥណ្ឌូចិនដែលមានប្រជាពលរដ្ឋតិច ប៉ុន្តែមានសម្បត្តិធម្មជាតិច្រើន គឺជាភាពចាំបាច់មួយ ។

ដោយនិយាយរបៀបមិនច្បាស់លាស់អំពីការធ្វើផែនការមួយសម្រាប់ឥណ្ឌូចិន មន្ត្រីផែនការជាន់ខ្ពស់ម្នាក់របស់វៀតណាម ចេ វៀតតាន់ បានបញ្ចេញគំនិតយោបល់នៅដើមឆ្នាំ១៩៨០ថា ៖ «លើមូលដ្ឋាននៃស្ថានភាពជាយុទ្ធសាស្ត្រ ដែលពឹងពាក់គ្នាទៅវិញទៅមករវាងប្រទេសវៀតណាម, ប្រទេសឡាវនិងកម្ពុជា វាចាំបាច់ត្រូវភ្ជាប់បណ្តាតំបន់ដែលមានលក្ខណៈយុទ្ធសាស្ត្រសំខាន់ជាមួយនឹងបណ្តាតំបន់ដែលមានលក្ខណៈសេដ្ឋកិច្ចខ្លាំង, រៀបចំពង្រាយនិងបែងចែកកម្លាំងការងារនិងប្រជាជនឲ្យស្មើគ្នា ដោយរបៀបបញ្ចូលតំបន់ទាំងឡាយដែលផលិតស្រូវ, តំបន់ឧស្សាហកម្ម, ហេដ្ឋារចនាសម្ព័ន្ធនានាផង...»[២៥] ។

គឺទាល់តែក្រោយពីការលេចធ្លោឡើងយ៉ាងច្បាស់នូវភាពតានតឹងរវាងចិន-វៀតណាម ទើបក្រុងហាណូយចាប់ផ្តើមសំអាងលើទឡ្ហីករណ៍ផ្សេងៗដែលមានលក្ខណៈយុទ្ធសាស្ត្រ ជាគុណប្រយោជន៍ដល់ទំនាក់ទំនងពិសេសរបស់ខ្លួន ។ កាសែតប្រចាំថ្ងៃរបស់កងទ័ពវៀតណាម «គន់ដូយញ៉ិនហ្សិន» បានប្រកាសនៅខែមេសា ១៩៧៩ ដូចនេះថា «តាំងពីជាងមួយសតវត្សរ៍មកហើយ ប្រវត្តិសាស្ត្ររវាងវៀតណាម ឡាវ និងកម្ពុជាតែងតែលាយឡំទៅដោយជោគវាសនាជាមួយគ្នាជានិច្ច ។ នៅពេលដែលប្រទេសមួយក្នុងចំណោមប្រទេសទាំងបីត្រូវគេលុកលុយ ឬភ្ជាប់ជារណប ឯករាជ្យភាពឬសេរីភាពរបស់ប្រទេសពីរផ្សេងទៀត ក៏ត្រូវរងការគំរាមកំហែងដូចគ្នា ហើយសន្តិភាពក៏ពុំអាចកើតមានគ្រប់ប្រទេសបានដែរ ។ ដោយហេតុនេះ សត្រូវរបស់ប្រទេសណាមួយ គឺជាសត្រូវរបស់ប្រទេសទាំងបីដោយចៀសមិនរួច ។ ការថែរក្សាឯកភាព សម្ព័ន្ធភាពក្នុងការប្រយុទ្ធសុទ្ធតែជាលក្ខខណ្ឌចាំបាច់របស់បដិវត្តក្នុងប្រទេសទាំងបី» ។ ដោយជំរុញទ្រឹស្តីនេះទៅមុខទៀត វៀតណាមបានអះអាងយ៉ាងរហ័សថា ពីបទពិសោធន៍ជាប្រវត្តិសាស្ត្រនេះ មុខជាលេចចេញ«ច្បាប់»មួយ ដែលពួកសត្រូវមានសម្រាប់បង្កហេតុនៅឥណ្ឌូចិន ដោយហេតុថា ឯកភាពនេះធានាដល់ឯករាជ្យរបស់ប្រទេសទាំងបី ទន្ទឹមនឹងនេះ ពួកមហាអំណាចខាងក្រៅក៏ខំប្រឹងប្រែងរៀបចំការគ្រួតគ្រាទាំងមូលរបស់ខ្លួនដែរ ដោយនៅពេលដំបូងគេធ្វើឲ្យប្រទេសទាំងនេះទាស់ទែងបែកបាក់គ្នា តមកទៀតចូលកាន់កាប់ប្រទេសទាំងបីម្តងមួយៗ ។ ឧត្តមសេនីយ៍វៀតណាមម្នាក់បានប្រកាសឲ្យដឹងនៅឆ្នាំ១៩៨៤ថា «ក្នុងការឃុបឃិតដើម្បីភ្ជាប់ឥណ្ឌូចិនជារណបនិងពង្រីក

ឥទ្ធិពលរបស់ពួកគេនៅអាស៊ី-អាគ្នេយ៍ ពួកប្រតិកិរិយាប៉េកាំងមិនប្រើវិធីអ្វីផ្សេងពីនេះឡើយ»[២៦] ។

## អ្នកការពារប្រចាំឧបទ្វីបឥណ្ឌូចិន

ការបង្កើត «ច្បាប់» ទាំងនេះក្នុងប្រវត្តិសាស្ត្ររបស់ឥណ្ឌូចិន គឺប្រហែលជាមានលក្ខណៈប្រកាន់បក្សពួកខ្លះ ។ ក៏ប៉ុន្តែ អ្វីដែលប្លែកនោះគឺប្រវត្តិសាស្ត្រនិងភូមិសាស្ត្រនយោបាយ (ការសិក្សាពីឥទ្ធិពលនៃបណ្តាកត្តាខាងភូមិសាស្ត្រទៅលើនយោបាយអន្តរជាតិ) បានបង្ហាញឲ្យឃើញថា ការប្រឆាំងជំទាស់របស់ចិន ចំពោះចំណង់គ្របសង្កត់លើគេរបស់វៀតណាមនៅឥណ្ឌូចិន មានលក្ខណៈមិនប្រែប្រួលឡើយ ។ លក្ខណៈចម្បងគេក្នុងប្រវត្តិនៃទំនាក់ទំនងផ្សេងៗរបស់ប្រទេសចិនជាមួយចំណែកនៃដែនដីគោកអាស៊ីអាគ្នេយ៍ គឺការទោរទន់ទៅរកការតាំងខ្លួនជាអ្នកការពារសណ្តាប់ធ្នាប់និងស្ថិរភាពមិនលំអៀងនៅក្នុងតំបន់ ។ ពិតហើយថា លើកលែងតែការលុកលុយប្រទេសវៀតណាមដោយរាជវង្ស មិញ នៅឆ្នាំ១៨០៧ និងការបញ្ជូនកងនាវារបស់ចិនមកក្នុងដែនសមុទ្រអាស៊ីអាគ្នេយ៍នៅដើមសតវត្សទី១៥ ប្រទេសចិនពុំបានប្រើកម្លាំងទ័ព ដើម្បីដើរតួនាទីជាអ្នកការពារឡើយ ។ តាមធម្មតា យូរៗម្តង ព្រះរាជាណាចក្រមួយឬមួយទៀត ក្នុងចំណោមព្រះរាជាណាចក្រដែលចំណុះនៅក្នុងតំបន់ បានអំពាវនាវចំពោះប្រទេសចិនដើម្បីរំងាប់គោលបំណងចង់ឈ្លានពានរបស់បណ្តាប្រទេសជិតខាង ហើយដោយហេតុនេះ ព្រះចៅអធិរាជមិនដែលខកខានស្តីប្រដៅប្រទេសចំណុះ ដែលត្រូវចោទប្រកាន់សោះឡើយ ។

ក្នុងការស្តីប្រដៅរបៀបឪពុកប្រដៅកូននិងមានលក្ខណៈបែបខុងជឺ ព្រះចៅអធិរាជ យ៉ុងលី បានបញ្ជូនទៅឲ្យព្រះមហាក្សត្រប្រទេសថៃ នូវពាក្យចោទប្រកាន់ផ្សេងៗរបស់នគរចម្ប៉ា ម៉ាឡាកា និង ស៊ូម៉ាត្រា ដែលប្តឹងបរិហារពីការឈ្លានពានរបស់ថៃ ។ ព្រះចៅអធិរាជបានបង្គាប់បញ្ជាថា ៖ «ចាប់ពីឥឡូវនេះទៅត្រូវធ្វើតាមច្បាប់, ត្រូវដើរតាមបណ្តាគោលការណ៍ដ៏ត្រឹមត្រូវ, ការពារព្រំដែនរបស់អ្នក, ត្រូវមានសេចក្តីថ្លៃថ្នូរជាមួយបណ្តាប្រទេសជិតខាងរបស់អ្នក ដោយរបៀបធ្វើយ៉ាងណា ដើម្បីត្រេកត្រអាលនូវគុណប្រយោជន៍ នៃសន្តិភាពដ៏ធំធេងជារៀងរហូត»[២៧] ។

ពីក្រោយតួនាទីជាព្រះចៅអធិរាជមិនលំអៀង មានបិទបាំងនូវបំណងរបស់ចិនក្នុងការថែទាំភាពស្ងប់ស្ងាត់នៅភាគខាងត្បូង និងសម្រេចធ្វើឲ្យមានតុល្យភាពកម្លាំងមួយរវាងរដ្ឋតូចៗក្នុងតំបន់ ដែលធ្លាប់ការពារស្ថិរភាពផ្ទាល់របស់ខ្លួន ។ កាស្រ្តីបន្ទោសរបស់ព្រះចៅអធិរាជ ពុំអាចរារាំងមិនឲ្យវៀតណាម ភ្ជាប់ទឹកដីនគរចម្ប៉ា និងមិនឲ្យពួកថៃវាយប្រហារម៉ាឡាកាបានឡើយ ប៉ុន្តែ ការវាតទីទឹកដីរបស់បណ្តាប្រទេសចំណុះនៅភាគខាងត្បូង ពុំបានធ្វើឲ្យគ្រោះថ្នាក់ដល់សន្តិសុខរបស់ប្រទេសចិន ហើយក៏មិនធ្វើឲ្យប៉ះពាល់ដល់ភាពប្រសើរខ្ពង់ខ្ពស់ជាងគេរបស់ខ្លួនដែរ ។ ទោះបីជាប្រទេសចំណុះនានាទម្លាប់ធ្វើអ្វីចឹងក៏ដោយ ក៏ប្រទេសទាំងនោះបានធ្វើឲ្យ“ចក្រភពកណ្តាល” លែងខឹងសម្បាដែរ ដោយសម្តែងនូវការសុំទោសទៅតាមផ្លូវច្បាប់ និងដោយបញ្ជូនសួយសារអាករទៅថ្វាយ ។

*នៅក្នុងអតីតកាល មានហេតុផលសំខាន់មួយដែលឃាត់មិនឲ្យប្រទេសចិនធ្វើអន្តរាគមន៍ដោយកម្លាំងយោធានៅភាគខាងត្បូង ៖ ជារឿយៗ ប្រទេសចិនតែងតែប្រមូលផ្តុំការយកចិត្តទុកដាក់របស់ខ្លួនទៅលើភាគពាយ័ព្យជានិច្ច ។ ក្នុងរយៈពេលជាច្រើនសតវត្សមកហើយ ពួកចរកជន (ជនរសាត់អណ្តែតឥតមានលំនៅប្រាកដប្រជា) នៅអាស៊ីកណ្តាល-ម៉ុងហ្គោល, ឃីតង់ (Khitan) ហើយក្រោយមក រុស្ស៊ីបានធ្វើការគំរាមកំហែងយ៉ាងធ្ងន់មកលើខ្លួន ។ ព្រះចៅអធិរាជ ហុងវូ ដែលបង្កើតសន្តតិវង្ស មិញ បន្ទាប់ពីបរាជ័យរបស់ពួកម៉ុងហ្គោល បានបង្គាប់ដោយដាច់ខាតមិនឲ្យពួកក្សត្រស្នងតំណែងពីព្រះអង្គ ចូលលុកលុយបណ្តារដ្ឋតូចៗដែលគ្មានអារ្យធម៌ទាំងទៅហួសពីមហាសមុទ្រនានាទាំងក្នុងតំបន់ព្រៃភ្នំរបស់រដ្ឋទាំងនោះ ដោយគ្មានហេតុផលដែលគួរយកជាការបានឡើយ ។ ព្រះអង្គបានអះអាងនៅឆ្នាំ១៣៧១ថា «បើសិនរដ្ឋទាំងនោះមិនធ្វើឲ្យរំខានដល់ប្រទេសចិនទេ វាមិនមានបញ្ហាត្រូវវាយប្រហារប្រទេសទាំងនោះឡើយ ។ ប៉ុន្តែ ចំពោះពួកអនារ្យជននៅភាគពាយ័ព្យដែលរួមបង្កជាការគំរាមកំហែងមួយចំពោះប្រទេសចិនជាច្រើនជំនាន់មកហើយ យើងត្រូវតែត្រៀមខ្លួនធ្វើអន្តរាគមន៍ប្រឆាំងនឹងពួកគេជាដាច់ខាត»[២៨] ។*

*ការសាកល្បងមួយអំពីការបង្គាប់បញ្ញានេះ បានលេចឡើងឲ្យឃើញនៅចុងសតវត្សទី១៩ នៅពេលដែលព្រះចៅអធិរាជចិនមួយអង្គត្រូវសម្រេចចិត្តប្រឈមមុខនឹងគ្រោះថ្នាក់ណាមួយក្នុងចំណោមគ្រោះថ្នាក់ជាច្រើនដែលគំរាមកំហែងប្រទេសជាតិក្នុងពេលដំណាលគ្នា នៅភាគខាងជើងនិងភាគខាងត្បូង ។ នៅឆ្នាំ១៨៨២ ឯកសារមួយរបស់ចិនបានពណ៌នាពីប្រទេសវៀតណាមថាជា«របាំងមួយសម្រាប់អាណាចក្រកណ្តាល» ទុកគ្រាន់ការពារប្រទេសចិនភាគខាងត្បូង ។ បើទុកជាវាស្ថិតនៅក្រៅរាជាណាចក្រយើងក៏ដោយ ក៏«យើងពុំអាចបោះបង់ចោលដែរ» ។ ក៏ប៉ុន្តែពីរឆ្នាំក្រោយមក ក្រោមការកៀបសង្កត់របស់បារាំងនៅភាគខាងត្បូងចាប់ពីវៀតណាមទៅនិងការគំរាមកំហែងពីសង្គ្រាមមួយរវាងរុស្ស៊ី-ជប៉ុននៅភាគខាងជើង សន្តតិវង្ស ជីង ដែលថមថយកម្លាំងបានបដិសេធកាតព្វកិច្ចបែបខុងជឺនិយមរបស់ខ្លួនដែលត្រូវការពារព្រះមហាក្សត្ររបស់វៀតណាមដែលជាស្តេចចំណុះខ្លួន ។ មន្ត្រីម្នាក់របស់រាជវង្ស ជីង បានប្រាប់ឲ្យដឹងថា «ក្នុងជម្លោះបច្ចុប្បន្ន [រវាងប្រទេសចិននិងបារាំងពីរឿងប្រទេសវៀតណាម] ការគាំពារប្រទេសចំណុះមួយគឺជាបញ្ហាតូចតាច ចំណែកការពង្រឹងកិច្ចការពារអាណាចក្ររបស់ខ្លួនគឺជាបញ្ហាសំខាន់ជាង» ។[២៩] នៅជំនាន់នោះ ដោយបារម្ភនឹងសន្តិសុខផ្ទាល់របស់ខ្លួនប្រទេសចិនដែលព្រឺខ្លាចពីការវាយប្រហាររបស់រុស្ស៊ី-ជប៉ុននៅភាគខាងជើង បានចុះហត្ថលេខាលើសន្ធិសញ្ញាទៀនស៊ីន នៅឆ្នាំ១៨៨៥ ជាមួយប្រទេសបារាំងហើយបោះបង់ចោលអធិបតេយ្យភាពរបស់ខ្លួនលើប្រទេសវៀតណាម ។*

*នៅឆ្នាំ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិនបានរៀបចំខ្លួនឈានចូលក្នុងពិភពលោកសម័យទំនើបខាងវិស័យទំនាក់ទំនងដោយស្មើភាពគ្នារវាងរដ្ឋនានា ។ ក្នុងឋានៈជារដ្ឋម៉ាក្សស៊ីសនិយម ប្រទេសចិនត្រូវទទួលបន្ទុក*

ប្រើសញ្ញាណ “អន្តរជាតិនិយមវណ្ណៈអធន” ដោយខានមិនបាន ។ តាមពិត អ្វីដែលទាក់ទងនឹងនយោបាយបរទេសនៃប្រវត្តិសាស្ត្រនិងកន្ទុលដែលមានរាប់សតវត្សរ៍មកហើយក្នុងការរ៉ាប់រងសន្តិសុខរបស់ខ្លួន បានមានឥទ្ធិពលជាងមនោគមវិជ្ជាម៉ាក្សស៊ីសដែលថ្មីបំផុត ហើយម្យ៉ាងទៀតត្រូវនាំចូលមកពីលោកខាងលិចផង ។ ភាពដូចគ្នាផ្នែកមនោគមវិជ្ជារវាងចិនកុម្មុយនីស្ត និងវៀតណាមខាងជើងគឺមានតម្លៃតែក្នុងរបៀបចាត់ការដាក់ស្តែងដែលប្រទេសទាំងពីរចុះសម្រុងគ្នាជាមួយផលប្រយោជន៍ជាតិរៀងៗខ្លួនប៉ុណ្ណោះ ។

តាំងពីការកកើតចលនាកុម្មុយនីស្តនៅវៀតណាម ហូជីមិញនិងបណ្តាសមមិត្តរបស់គាត់បានថែរក្សាចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយបក្សកុម្មុយនីស្តចិន ។ ពួកមេដឹកនាំវៀតណាមមួយចំនួនធំបានទទួលការបណ្តុះបណ្តាលផ្នែកនយោបាយនិងយោធានៅប្រទេសចិន និងធ្វើកម្មសិក្សាក្នុងកងទ័ពរំដោះរបស់ ម៉ៅ ថែមទៀត ។ មិនយូរប៉ុន្មាន ក្រោយការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ក្រុងប៉េកាំងបានទទួលស្គាល់រដ្ឋាភិបាលរបស់ ហូ ដែលពេលនោះស្ថិតនៅក្នុងព្រៃនៅឡើយ ក្នុងឋានៈជាសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ សម្រាប់ជាលើកទីពីរហើយក្នុងប្រវត្តិសាស្ត្រ- លើកទីមួយគឺការធ្វើអន្តរាគមន៍របស់ក្រុមទង់ខ្មៅ (Pavillons Noirs) ប្រឆាំងពួកបារាំង ប្រហែលនៅឆ្នាំ១៨៨០ - ដែលគ្រឿងសាស្ត្រាវុធនិងទាហានរបស់ចិនបានឆ្លងកាត់ព្រំដែនមកជួយប្រទេសវៀតណាមប្រយុទ្ធទល់នឹងសត្រូវបរទេសមួយ ។ [ទង់ខ្មៅគឺក្រុមទាហានមិនរៀបរយ(គ្មានឯកសណ្ឋានដូចទាហានធម្មតា) របស់ចិនដែលប្រយុទ្ធនឹងពួកបារាំងនៅតុងកឹង ជាពិសេសនៅឆ្នាំ១៨៨៣-១៨៨៥ -កំណត់របស់អ្នកបកប្រែ] ។ ការផ្គត់ផ្គង់សម្ភារសឹកដ៏សម្បើមរបស់ចិនបានជួយឲ្យ យ៉ាប ទទួលជ័យជម្នះជាប្រវត្តិសាស្ត្ររបស់គាត់លើពួកបារាំងនៅឌៀនបៀនភូក្នុងឆ្នាំ១៩៥៤ ។ ក្រោយមក ក្រុងប៉េកាំងបានអួតខ្លួនថា ទីប្រឹក្សាជាន់ខ្ពស់ចិនជាច្រើននាក់ជាពិសេសឧត្តមសេនីយ៍ ចេន កាង បានប្រែក្លាយខ្លួនជាអ្នកយុទ្ធសាស្ត្រម្នាក់ក្នុងចំណោមអ្នកយុទ្ធសាស្ត្រពិតប្រាកដទាំងឡាយ ។ នេះជាអំនួតក្អេងក្អាងដែលធ្វើឲ្យវៀតណាមអស់សំណើច ។ អ្វីខ្លះទៅអាចជាតួនាទីពិតប្រាកដរបស់ចិនក្នុងចម្បាំងនេះ? ព្រឹត្តិការណ៍ផ្សេងៗដែលមានមកខាងក្រោយៗទៀតបានបង្ហាញថាការចូលប្រឡូករបស់ចិន មានហេតុផលតម្រូវឲ្យធ្វើដូច្នេះ ដោយសារការព្រួយបារម្ភដែលខ្លួនត្រូវល្បងឲ្យដឹងដើម្បីសន្តិសុខផ្ទាល់របស់ប្រទេសខ្លួននៅតាមព្រំដែនភាគខាងត្បូងដូចគ្នានឹងមនោសញ្ចេតនារបស់ខ្លួនដែលមានចំណងផ្នែកមនោគមវិជ្ជាជាមួយវៀតមិញដែរ ។

បន្ទាប់ពីការចេញផ្សាយឯកសារសម្ងាត់ខ្លះៗរបស់សន្និសីទក្រុងហ្សឺណែវស្តីពីឥណ្ឌូចិន (ឆ្នាំ១៩៥៤) ការលេចមុខរបស់ប្រទេសចិនសម័យ ម៉ៅ ជាលើកដំបូងលើឆាកអន្តរជាតិ-ឥឡូវនេះ គេបានថ្លឹងថ្លែងចំណុចអ្វីខ្លះ ដែលប្រទេសចិនខិតមករកបញ្ហាឥណ្ឌូចិនយ៉ាងគួរឲ្យឆ្ងល់ ព្រោះតាំងពីដើម វាមិនដែលអើពើងសោះ ។ លោក ប៉ូលមូស អ្នកឯកទេសដ៏ល្បីល្បាញខាងបញ្ហាវៀតណាម ជាអតីតទីប្រឹក្សាស្ថានការជាន់ខ្ពស់របស់បារាំងនៅឥណ្ឌូចិនបានពោលអះអាងនៅឆ្នាំ១៩៦៥ថា នៅក្រុងហ្សឺណែវប្រទេសចិនបានធ្វើសម្បទានយ៉ាងច្រើនឲ្យពួក

បារាំងក្នុងគោលបំណងបំបាត់មិនឲ្យវៀតណាមធ្វើម្ចាស់លើឥណ្ឌូចិនទាំងស្រុង ។ ដប់បួនឆ្នាំក្រោយមក ប្រវត្តិវិទូប្រាំង់ស័រហ្សុយ៉ូ ក្នុងការសិក្សាជាលើកដំបូងនូវឯកសារទាំងឡាយក្នុងបណ្ណសារដ្ឋានរបស់បារាំង ដែលនិយាយពីតួនាទីរបស់ប្រទេសចិននៅក្រុងហ្សឺណែវនោះ ក៏បានសម្រេចធ្វើសេចក្តីសន្និដ្ឋានមួយដូចគ្នាបេះបិទ ។

## អ្នកខុងជីនិយមម្នាក់នៅហ្សឺណែវ

គំនិតផ្តួចផ្តើមមួយរបស់ពួកចិនបានអនុញ្ញាតឲ្យសន្និសីទចេញរួចពីភាពទាល់ច្រកដំបូងមួយក្នុងចំណោមភាពទាល់ច្រកជាច្រើន ។ រដ្ឋាភិបាលតស៊ូខ្មែរនិងឡាវដែលប្រទេសវៀតណាមធ្លាប់ជួយទ្រទ្រង់បានទាមទារឲ្យខ្លួនបានចូលរួមសម័យប្រជុំនៅហ្សឺណែវដែរ ។ ក្រុងប៉េកាំងបានធ្វើការកៀបសង្កត់ទៅលើប្រទេសវៀតណាមដើម្បីឲ្យឈប់គាំទ្រការទាមទារនេះ ។ ប្រធានគណៈប្រតិភូចិន ជូ អេនឡាយ ពុំយល់ស្របតាមទស្សនៈរបស់វៀតណាមទេ ដែលថារដ្ឋាភិបាលតស៊ូទាំងពីរនេះជាតំណាងពិតប្រាកដរបស់ប្រជាជនឡាវនិងខ្មែរនោះ ។ គាត់ក៏បានរារាំងមិនឲ្យក្រុងហាណូយបើកការវាយប្រយុទ្ធនៅកម្ពុជា ដើម្បីជួយពង្រឹងស្ថានភាពរបស់ចលនាតស៊ូខ្មែរដែរ[៣០] ។ កង្វល់ដ៏ធំបំផុតរបស់ ជូ គឺបញ្ចៀសការធ្វើអន្តរាគមន៍មួយរបស់អាមេរិកាំងនៅឥណ្ឌូចិន ដែលអាចប្រទាញប្រទេសចិនឲ្យធ្លាក់ទៅក្នុងជម្លោះមួយរឹតតែធំឡើងទៀត ។ នៅពេលដែលគ្រោះថ្នាក់នេះ ហាក់ដូចជាទៅឆ្ងាយហើយ នយោបាយការទូតរបស់ចិនក៏ប្រឹងយកចិត្តទុកដាក់រារាំងមិនឲ្យពួកអាមេរិកាំងឈរជើងក្នុងតំបន់នេះដែរ ។ ជូ អេនឡាយ បានប្រាប់ឲ្យពួកបារាំងដឹងជាឯកជនពីការទទួលស្គាល់ដោយប្រទេសចិននូវ“រដ្ឋាភិបាលស្និទ្ធបស្ចិមប្រទេស”មួយដែលមាននៅប្រទេសនោះស្រាប់ ។ ជូ បានថ្លែងប្រាប់អ្នកការទូតបារាំងថា “បើសិនជារបបរាជាធិបតេយ្យបច្ចុប្បន្ននៅឡាវនិងកម្ពុជាទទួលបានការយល់ព្រមពីប្រជាជនហើយ ខ្ញុំមិនយល់ថា ហេតុអ្វីក៏គេមិនរក្សាទុកឲ្យនៅដដែលទៅ” ។ គាត់បានបញ្ជាក់ថា ប្រទេសចិនប្រាថ្នាចង់ឲ្យព្រះរាជាណាចក្រទាំងពីរក្លាយទៅជាប្រទេសមានសន្តិភាពនិងមានប្រជាធិបតេយ្យតាមគំរូប្រទេសឥណ្ឌូនេស៊ី ភូមា និងឥណ្ឌាដែរ ។ គាត់ក៏មិនយល់ទាស់ក្នុងការដែលប្រទេសទាំងពីរទៅរួបរួមនឹងសហភាពបារាំងវិញទេ ប៉ុន្តែគាត់បានព្រមានថា “យើងនឹងមិនពេញចិត្តឲ្យប្រទេសឡាវ និងកម្ពុជាក្លាយជាមូលដ្ឋានទ័ពរបស់អាមេរិកាំងឡើយ... ។ រឿងនេះនឹងក្លាយទៅជាការគំរាមកំហែងមួយសម្រាប់សន្តិសុខរបស់ប្រទេសចិនដែលយើងទាំងអស់គ្នាលែងរវល់គិតគូរទៅហើយ”[៣១] ។

ក៏ប៉ុន្តែ នេះពុំមែនជាបំណងរុញពួកអាមេរិកាំងឲ្យឆ្ងាយពីព្រំដែនចិននូវវត្តមានដ៏មានគ្រោះថ្នាក់តែម្យ៉ាងប៉ុណ្ណោះទេ ដែលជំរុញឲ្យ ជូ ទទួលស្គាល់ព្រះរាជាណាចក្រឡាវនិងកម្ពុជា និងជួយជំរុញឲ្យមានការដកថយកងទ័ពវៀតមិញចេញពីប្រទេសទាំងពីរនេះ ។ កិច្ចព្រមព្រៀងក្រុងហ្សឺណែវមិនយល់ព្រមផ្តល់ឯករាជ្យភាពទាំងស្រុងឲ្យវៀតមិញទេ ពីព្រោះកិច្ចព្រមព្រៀងបានគ្រោងគិតនូវការបែងចែកប្រទេសវៀតណាមជាបណ្តោះអាសន្នក្នុងការរង់ចាំការបោះឆ្នោតទូទាំងប្រទេស ។ ប៉ុន្តែ ជូ បានបញ្ជាក់បំភ្លឺប្រាប់ពួកបារាំងជាគូសន្ទនារបស់គាត់ថា ប្រទេស

ចិនអនុគ្រោះចំពោះអត្ថិភាពប្រទេសវៀតណាមពីរ និងចំពោះការបង្កើតរដ្ឋច្រើននៅតាមព្រំដែនរបស់ខ្លួន ។ ក្នុងកាយវិការមួយដែលចម្លែកខុសធម្មតា ជូ បានអញ្ជើញ ផាំ វ៉ាន់ដុង រដ្ឋមន្ត្រីទីមួយនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមជាមួយនឹងគណៈប្រតិភូឥណ្ឌូចិនផ្សេងៗទៀតដែលក្នុងនោះមានទាំងតំណាងរបបបាវដាយ [អធិរាជប្រទេសវៀតណាមពីឆ្នាំ១៩៣២-១៩៤៥ ដែលត្រូវបង្ខិតបង្ខំឲ្យដាក់រាជ្យដោយវៀតមិញនៅឆ្នាំ ១៩៤៥ និងជាប្រមុខរដ្ឋរបស់វៀតណាមពីឆ្នាំ១៩៤៥-១៩៥៥-កំណត់របស់អ្នកបកប្រែ] ដែលទ្រទ្រង់ដោយពួកអាមេរិកាំងនិងបារាំងផង ចូលរួមបរិភោគអាហារពេលល្ងាចមួយ ។ ក្នុងពេលបរិភោគបាយ ជូ បានឈានរហូតដល់ស្នើឲ្យគណៈប្រតិភូវៀតណាមខាងត្បូងបង្កើតស្ថានតំណាងមួយនៅក្រុងប៉េកាំងថែមទៀត ។ ដុង មានអាការៈភ្ញាក់ផ្អើលមែនទែន ដែល ជូ បានបកស្រាយថា “ប្រាកដហើយ ផាំ វ៉ាន់ដុង ជាអ្នកជិតស្និទ្ធជាងគេរបស់យើងខាងផ្នែកមនោគមវិជ្ជា ប៉ុន្តែប្រការនេះពុំមែនហាមមិនឲ្យមានតំណាងភាគខាងត្បូងម្នាក់នោះឡើយ ។ សរុបទៅ តើអ្នកទាំងពីរពុំមែនជាជនជាតិវៀតណាមទេឬ? ហើយយើងទាំងអស់សុទ្ធតែជាជនជាតិអាស៊ីដូចតែគ្នាមែនទេ?» ។

ក្នុងរយៈពេលម្ភៃឆ្នាំ ដែលមានបន្ទាប់ពីកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ប្រទេសចិនបានខំប្រឹងជាប់ជាប្រចាំក្នុងការថែទុកឥណ្ឌូចិនមួយឲ្យនៅដាច់ជាកង់ៗ មិនចំណុះបណ្តាមហាអំណាចធំៗតាមមធ្យោបាយគ្រប់បែបយ៉ាងដែលខ្លួនមាន ។ មធ្យោបាយទាំងនោះនឹងផ្តើមពីនយោបាយការទូតសម្ងាត់ទៅរកការរៀបសង្កត់ផ្នែកសេដ្ឋកិច្ចដោយឆ្លងកាត់តាមការពឹងផ្អែកលើកម្លាំងទ័ព ។ រហូតមកដល់ការចាប់ផ្តើមការធ្វើអន្តរាគមន៍ ដោយផ្ទាល់ពីសំណាក់ពួកអាមេរិកាំងនៅប្រទេសឡាវនៅឆ្នាំ១៩៦៣ ទើបក្រុងប៉េកាំងប្រឹងប្រែងជួយបណ្តាសមមិត្តប៉ាថេតឡាវរបស់ខ្លួនតែមិនច្រើនដូចកាលជួយរដ្ឋាភិបាលអព្យាក្រឹតចម្រុះមួយ ដែលអាចបង្កទៅជារដ្ឋទ្រនាប់មួយនៅភាគខាងត្បូងខ្លួនទេ ។ ពួកចិនក៏ដូចសូវៀតមិនសូវជាចូលចិត្តប្រើប្រាស់ការតស៊ូដោយអាវុធ ដើម្បីផ្តល់សន្ទុះដល់ការបង្រួបបង្រួមភាគខាងជើងនិងខាងត្បូងវៀតណាមឡើយ[៣៧] ។

ការគាំទ្រផ្នែកយោធារបស់ក្រុងប៉េកាំងចំពោះការប្រឹងប្រែងធ្វើសង្គ្រាមដែលផ្តើមឡើងដោយក្រុងហាណូយនៅប្រទេសឡាវនិងកម្ពុជាបានរីកចម្រើនឡើងសម្រាប់គោលដៅដំបូង គឺដើម្បីទប់ពួកអាមេរិកាំងឲ្យនៅឆ្ងាយពីឥណ្ឌូចិន ហើយគោលដៅទីពីរគឺ ដើម្បីប្រជែងជាមួយក្រុងមូស្គូក្នុងការទាក់ទាញចិត្តគំនិតពួកកុម្មុយនីស្តឥណ្ឌូចិន ជាអាទិ៍គឺពួកកុម្មុយនីស្តវៀតណាម ។ ប្រទេសចិនកំពុងធ្វើខ្លួនជាជើងឯកខាងការតស៊ូរំដោះជាតិប្រឆាំងនឹងចក្រពត្តិនិយមនិងខ្ញុំកញ្ជះរបស់វា ដូច្នេះករណីយកិច្ចរបស់ខ្លួនបានបង្គាប់ឲ្យគាំទ្រការប្រយុទ្ធតស៊ូរបស់វៀតណាមដែរ ។ ជាមួយការទម្លាក់គ្រាប់បែកដំបូងៗរបស់អាមេរិកនៅឆ្នាំ១៩៦៤ និងបណ្តាឆ្នាំជាបន្តបន្ទាប់មកទៀត ការបង្កើតបណ្តាញមូលដ្ឋានទ័ពអាមេរិកាំងមួយ និងការបញ្ជូនទាហានអាមេរិកាំងចំនួន៥០០.០០០នាក់មកវៀតណាមខាងត្បូង បានធ្វើឲ្យមូលហេតុសំខាន់មួយក្នុងចំណោមមូលហេតុសំខាន់ៗនៃគវិយាបថនិយម

*កណ្ដាលដែលប្រកាន់យកដោយប្រទេសចិននៅហ្សឺណែវនោះត្រូវបាត់បង់សារសំខាន់ទាំងអស់ ។ នៅចំពោះមុខការគំរាមកំហែងធ្វើការវាយលុកវៀតណាមខាងជើងតាមផ្លូវគោកពីសំណាក់ពួកអាមេរិកាំង និងការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសនៅជិតៗព្រំដែនរបស់ខ្លួន បានធ្វើឲ្យក្រុងប៉េកាំងត្រៀមធ្វើពលិកម្មយ៉ាងធំធេងដើម្បីទ្រទ្រង់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងអត់ធ្មត់ទុកបណ្ដោយឲ្យក្រុងហាណូយសម្ដែងតួនាទីដ៏មានអំណាចលើសលប់ជាងគេនៅតណ្ហូចិនផង ។*

*ជាមួយនឹងការបង្កើនសង្គ្រាមនៅវៀតណាមឲ្យរឹតតែខ្លាំងឡើង ដែលសម្រេចដោយក្រុងវ៉ាស៊ីនតោន ក្នុងការប៉ុនប៉ងទប់ស្កាត់ «លទ្ធិវាតទីនិយមរបស់ចិន» នៅអាស៊ី-អាគ្នេយ៍ គ្រោះថ្នាក់នៃការវាយប្រហារដោយផ្ទាល់មួយប្រឆាំងនឹងចិនលែងអាចបញ្ចៀសបានហើយចាប់ពីពេលនេះទៅ ។ ហួសពីករណីយកិច្ចអន្តរជាតិនិយមធម្មតា ជំនួយរបស់ចិនចំពោះការប្រយុទ្ធរបស់ពួកកុម្មុយនីស្តវៀតណាមបានក្លាយទៅជា«អាជ្ញាបញ្ញា»មួយដោយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់ប្រទេស ។ ចាងឈិញ ប្រពន្ធរបស់ ម៉ៅ បាននិយាយប្រាប់អ្នកសរសេរជីវប្រវត្តិរបស់គាត់សញ្ជាតិអាមេរិកាំងជាសម្ងាត់ថា «បើសិនជាវៀតណាមខាងជើងមិនវាយប្រយុទ្ធទេ ពេលនោះគ្មានអ្វីអាចបញ្ចៀសមិនឲ្យសត្រូវវាយប្រហារពួកចិនឡើយ»[៣៣] ។*

## «ធីវ នៅឆ្ងាយពីអំបោសរបស់អ្នកណាស់, សមមិត្ត...»

*ប៉ុន្តែ វាដូចជាមិនទំនងដែលប្រទេសចិនវាយតម្លៃ ជួយក្រុងហាណូយដើម្បីធ្វើឲ្យឈាមទាហានអាមេរិកាំងហូររហាចថា ជាមធ្យោបាយដ៏ស័ក្តិសិទ្ធិក្នុងការធ្វើឲ្យសត្រូវជាចក្រពត្តិចុះខ្សោយនោះ ។ តាមពិត ចិនហាក់ដូចជា«ស្វាគមន៍» ដោយការធូរស្បើយក្នុងចិត្តអំពីវត្តមានរបស់កងទ័ពអាមេរិកាំងនៅក្បែរព្រំដែនរបស់ខ្លួនដែរ ព្រោះជាកិច្ចធានាទល់នឹងការវាយប្រហារដោយអាវុធបរមាណូជាយថាហេតុមួយ ។ នៅខែមិថុនា ឆ្នាំ១៩៦៥ នៅទីក្រុងគែរ(រដ្ឋធានីប្រទេសអេហ្ស៊ីប) រដ្ឋមន្ត្រីទី១ ជូ អេនឡាយ បាននិយាយប្រាប់លោក ណាស្សែរ (ស្លាប់នៅឆ្នាំ១៩៧០) ប្រធានាធិបតីអេហ្ស៊ីបជាសម្ងាត់ថា «យើងខ្លាចណាស់ ដែលអ្នកនយោបាយនិយមប្រើធម៌ក្ដៅរបស់អាមេរិកាំងខ្លះ ជំរុញឲ្យមានការវាយប្រហារដោយអាវុធបរមាណូប្រឆាំងនឹងចិន ហើយយើងចាត់ទុកការជាប់ដៃប្រយុទ្ធរបស់ពួកអាមេរិកាំងនៅតណ្ហូចិនថា ជាការធានារ៉ាប់រងមួយទប់ទល់នឹងគ្រោះថ្នាក់នេះ ពីព្រោះសាច់ឈាមរបស់គេស្ថិតនៅជិតបង្កើយនឹងក្រញ៉ាំរបស់យើង ។ បើសហរដ្ឋអាមេរិកបញ្ជូនទ័ពមកវៀតណាមច្រើនឡើងកាលណា យើងរឹតតែពេញចិត្តកាលនោះដែរ ត្បិតយើងដឹងថា ពួកគេស្ថិតនៅក្នុងកណ្ដាប់ដៃយើង ហើយយើងអាចធ្វើឲ្យឈាមពួកគេហូរទៅតាមចំណង់របស់យើង»[៣៤] ។*

*នៅចន្លោះឆ្នាំ១៩៦៥ និង១៩៦៨ ពួកចិនបានបញ្ជូនទាហាន កម្មករ និងអ្នកបច្ចេកទេសសរុបទាំងអស់ប្រហែល៣២០.០០០នាក់ ដើម្បីរ៉ាប់រងតភ្ជាប់ផ្លូវរថភ្លើងមួយរវាងប្រទេសចិននិងវៀតណាម រៀបចំប្រព័ន្ធ*

ការពារដែនអាកាស និងបំពេញបេសកកម្មមួយចំនួនខាងជំនួយបច្ចេកទេសឲ្យខានតែបានដាច់ខាត ។ វត្តមានរបស់គេគឺជាយុទ្ធវិធីមួយដែលរៀបចំយ៉ាងប៉ិនប្រសប់ដើម្បីរារាំងសហរដ្ឋអាមេរិកឲ្យបោះបង់គំនិតចូលលុកលុយវៀតណាមខាងជើងឬគំរាមប្រទេសចិនភាគខាងត្បូង ។ ក្រុងប៉េកាំងក៏ធានារ៉ាប់រងការដឹកជញ្ជូនបណ្តាបក្ខជន និងទីប្រឹក្សាយោធារបស់វៀតណាមទៅប្រទេសឡាវ ដោយឆ្លងកាត់តាមប្រទេសចិនដែរ ។ ចិនបានផ្តល់ឡានកាមីញ៉ុងចំនួន៣០.០០០គ្រឿងទៅឲ្យវៀតណាម ហើយដោយសារឡានទាំងនោះ គ្រឿងសម្ភារសឹករបស់ចិនរាប់ពាន់តោនបានត្រូវដឹកតម្រង់ទៅកាន់គោលដៅតាមផ្លូវលំហូជីមិញ ។ ពួកចិនក៏ព្រមព្រៀងគ្នាជាមួយសម្តេចសីហនុ ដើម្បីដឹកអាវុធនិងស្បៀងអាហារឆ្លងកាត់តាមប្រទេសកម្ពុជាយកទៅឲ្យវៀតកុងនៅភាគខាងកើតប្រទេសកម្ពុជាដែរ ។

នៅខែមេសា ឆ្នាំ១៩៨០ ខ្ញុំ(អ្នកនិពន្ធ) បានធ្វើដំណើរទៅក្រុងប៉េកាំងដើម្បីធ្វើសម្ភាសន៍ ហាន នានឡុង អនុរដ្ឋមន្ត្រីការបរទេសចិនដែលជាដៃស្តាំរបស់សពរដ្ឋមន្ត្រីទី១ ជូ អេនឡាយ និងជាអ្នកផ្តើមគំនិតម្នាក់ក្នុងចំណោមអ្នកផ្តើមគំនិតជាច្រើន ស្តីពីនយោបាយតណ្ហូចិនរបស់ប្រទេសចិន ។ ខ្ញុំសួរគាត់ថា ក្នុងសម័យសង្គ្រាមបន្ទាប់ពីគាំទ្រវត្តមានរបស់វៀតណាមនៅប្រទេសឡាវនិងកម្ពុជា ហេតុអ្វីក៏ចិនបែរជាជំទាស់ប្រឆាំងនៅពេលនេះទៅវិញ? ជាមនុស្សឆាប់ខឹងប្រឡោត ហាន បានឆ្លើយប្រាប់ខ្ញុំថា គេមិនអាចប្រៀបធៀបស្ថានភាពដែលឈ្នះពីម្សិលជាមួយស្ថានភាពបច្ចុប្បន្នទេ «នៅជំនាន់នោះ វៀតណាមសុទ្ធតែត្រូវបង្ខំចិត្តឲ្យផ្លាស់ប្តូរទីមកខាងក្នុងដែនដីរបស់ប្រទេសឡាវនិងកម្ពុជា ដោយសារភាពចាំបាច់ខានមិនបានក្នុងការប្រយុទ្ធតស៊ូទល់នឹងចក្រពត្តិនិយមអាមេរិកាំង ។ ពិតហើយ ពេលនោះយើងបានគាំទ្រពួកគេ... ប៉ុន្តែ យើងមិនពេញចិត្តឲ្យប្រទេសមួយដែលកាលពីដើមធ្លាប់ត្រូវជិះជាន់ដោយមហាអំណាចចក្រពត្តិមួយ ចាប់ផ្តើមជិះជាន់បណ្តាប្រទេសជាបងប្អូនផ្សេងទៀតបន្ទាប់ពីទទួលបានជ័យជម្នះផ្តាច់ព្រ័ត្រនោះទេ» ។

ហាន បានបញ្ជាក់អះអាងប្រាប់ខ្ញុំផ្ទុយនឹងអ្វីៗដែលទំនងជាការពិតថា ពួកចិន «មិនដែលត្រូ ហូ ជីមិញ រំឭកពីគំនិតបង្កើតសហព័ន្ធតណ្ហូចិនមួយ»ទាល់តែសោះ ។ ដើម្បីបង្ហាញឲ្យច្បាស់ពីចំណុចណាដែលថ្នាក់ដឹកនាំវៀតណាមបច្ចុប្បន្ន"ក្បត់"មាគ៌ាម៉ាក្សស៊ីសពិតប្រាកដរបស់ហូជីមិញនោះ ក្រុងប៉េកាំងបានកំណត់កាលបរិច្ឆេទជាផ្លូវការ គឺចាប់ពីឆ្នាំ១៩៧៥មក ដែលគោលដៅអនុត្តរភាពរបស់វៀតណាមមកលើតណ្ហូចិនបានលេចរូបរាងពិតប្រាកដគឺពុំមែនមុនកាលបរិច្ឆេទនេះទេ ។ ប៉ុន្តែជាឯកជន បណ្តាមេដឹកនាំចិន ជាពិសេស វ៉ាង គន់មុី ភរិយាមេម៉ាយរបស់ លីវ ចាវជី បានរិះគន់នូវការសន្យារបស់ ហូ ជាគុណប្រយោជន៍សម្រាប់សហព័ន្ធតណ្ហូចិនមួយ[៣៥] ។

នៅខែមីនា ឆ្នាំ១៩៨២ អ្នកទទួលខុសត្រូវជាន់ខ្ពស់មួយរូបនៃទីភ្នាក់ងារព័ត៌មានចិនថ្មី ហើយជាមួយគាត់ខ្ញុំបានរំឭកប្រាប់ពីមហិច្ឆតាតណ្ហូចិនដ៏ចាស់គំរិលរបស់វៀតណាមនោះ បាននិយាយរៀបរាប់ប្រាប់ខ្ញុំនូវវាក្យខ័ណ្ឌ

មួយនៃកម្មវិធីនយោបាយរបស់បក្សពលករវៀតណាមនៅឆ្នាំ១៩៥១ ទាក់ទងទៅនឹងការបង្កើតសហព័ន្ធឥណ្ឌូចិនមួយថា «បើទោះជាក្នុងពេលមានសង្គ្រាមប្រឆាំងទល់នឹងសហរដ្ឋអាមេរិកក៏ដោយ ក៏វៀតណាម [ដែលពេលនោះដឹកនាំដោយ ហូ ជីមិញ] មិនដែលបោះបង់គំនិតនេះសោះឡើយ ។ ការរៀបចំឲ្យមានសហព័ន្ធមួយរបស់ឥណ្ឌូចិនគឺជាគោលដៅដែលពួកគេមិនដែលភ្លេចទាល់តែសោះ ។ ក្រោមលេសការពារផ្លូវលំ ហូជីមិញ ពួកគេបានបញ្ជូនទ័ពយ៉ាងច្រើនទៅកាន់ភាគខាងក្រោមប្រទេសឡាវនិងប្រទេសកម្ពុជា ។ នៅទីបញ្ចប់នៃសង្គ្រាម ពួកគេមិនត្រឹមតែមិនដកកងទ័ពរបស់ខ្លួនទៅវិញទេ ផ្ទុយទៅវិញពួកគេថែមទាំងបានបញ្ជូនទ័ពថ្មីៗចូលទៅក្នុងតំបន់នានា ជាពិសេសនៅប្រទេសឡាវភាគខាងលើថែមទៀត» ។

ទស្សនៈរបស់ចិនអំពីតួនាទីរបស់វៀតណាមនៅឥណ្ឌូចិននេះ ពុំមែនជាការសរសេរសម្រួលប្រវត្តិសាស្ត្រជាថ្មីធម្មតានោះទេ ។ ប្រទេសចិនប្រហែលពុំបានបង្ការជាមុននូវការប៉ុនប៉ងត្រួតត្រាជាចំហមួយពីសំណាក់វៀតណាម ដូចដែលរាជវង្ស ហាន ធ្លាប់អះអាងពីរឿងនេះឡើយ ។ ប៉ុន្តែក្រោយមកមានកត្តាជាច្រើន ដែលធ្វើឲ្យគេគិតថា ដោយនៅតែបន្តជួយប្រទេសនេះយ៉ាងស្ពុកស្ពម្ភក្នុងពេលសង្គ្រាម ក្រុងប៉េកាំងនឹកព្រួយបារម្ភស្រេចទៅហើយពីតួនាទីរបស់ប្រទេសវៀតណាមដែលនឹងទៅជាអ្នកនាំមុខគេនៅឥណ្ឌូចិន ។ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍៦០ ប្រទេសចិនបានស្ថាបនាផ្លូវយុទ្ធសាស្ត្រមួយដែលភ្ជាប់ពីខេត្តយុនណានមកភាគខាងជើងប្រទេសឡាវ ។ ទាហានជាងរបស់ចិនប្រហែល២០.០០០នាក់ បានមកបោះទីតាំងនៅប្រទេសឡាវ ក្រោមការគាំពារពីកងកាំភ្លើងធំប្រឆាំងយន្តហោះជាច្រើនដើម ។ តួនាទីរបស់ពួកនេះមិនកំណត់ត្រឹមតែការពារផ្លូវមុខរបស់ចិនប៉ុណ្ណោះទេ តែក៏ត្រូវធ្វើឲ្យមានតុល្យភាពខាងកម្លាំងជាមួយវត្តមានរបស់វៀតណាមដែរ ក្នុងការប្រមើលមើលអនាគតនៃការវាយប្រហារជាយថាហេតុមួយពីសំណាក់ពួកអាមេរិកាំង ។ បន្ទាប់ពីបានជួបពិភាក្សាជាមួយ ជូអេនឡាយ នៅឆ្នាំ១៩៧៤ ស្ដីពីបំណងដើរតាមគន្លងនេះរួចមក ហង់រី គីស្ស៊ីងហ្គ័រ បានសម្រេចដោយសេចក្ដីពេញចិត្តយ៉ាងច្បាស់មួយថា វត្តមានរបស់ពួកចិននៅប្រទេសឡាវអាចឲ្យគេការពារស្ថានភាពមួយ «ពីចំហៀងវៀតណាមដែលអាចធ្វើជាឧបសគ្គចំពោះការត្រួតត្រាជាយថាហេតុនៃសម្ពន្ធមិត្ត ដែលគ្រាន់តែសន្មត [របស់គេ] ក្នុងឥណ្ឌូចិនទាំងមូល»[៣៦] ។

នៅចុងទសវត្សរ៍៦០ និងនៅដើមទសវត្សរ៍៧០ កិច្ចប្រឹងប្រែងទាំងឡាយរបស់ពួកចិន ដើម្បីបំបែកសមាសភាពខ្លះរបស់ប៉ាថេតឡាវចេញពីភាពនៅក្រោមអំណាចរបស់វៀតណាមនោះ បានធ្វើឲ្យមានការបែកបាក់គ្នាយ៉ាងខ្លាំង ៖ យ៉ាងហោច ជនជាតិឡាវស្និទ្ធចិនម្នាក់បានត្រូវគេលួចសម្លាប់[៣៧] ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ប៉ុល ពត បានធ្វើដំណើរទៅប្រទេសចិននៅចុងឆ្នាំ១៩៦៥ ហើយបានទទួលការគាំទ្រពី ម៉ៅ ចំពោះនយោបាយឯករាជ្យមិនចំណុះក្រុងហាណូយរបស់គាត់ទៀតផង ។ ប៉ុន្តែរដ្ឋប្រហារនៅក្រុងភ្នំពេញក្នុងខែមីនា ឆ្នាំ១៩៧០ បានបង្កើតឲ្យមានស្ថានភាពថ្មីមួយ គឺសហប្រតិបត្តិការរវាងបក្សទាំងបីរបស់ឥណ្ឌូចិនបាន

ក្លាយទៅជាលក្ខណៈចាំបាច់មួយ ។

នៅដើមដំបូង តាមព្រះរាជតម្រិះដួចផ្តើមរបស់ សម្តេច សីហនុ ដែលទើបត្រូវទម្លាក់ពីតំណែងថ្មីៗ សន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិនមួយបានបើកធ្វើនៅកង់តុង នាខែមេសា ឆ្នាំ១៩៧០ ដែលពេលនោះ សមាសភាពចូលរួមក្រៅពី សម្តេច សីហនុ គឺមាន ផាំ វ៉ាន់ដុង ព្រះអង្គម្ចាស់ សុផានុវង្ស នៃប៉ាថេតឡាវ និង ង្វៀងហ៊ុយថូ នៃរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងផងដែរ ។ សន្និសីទបានចេញសេចក្តីថ្លែងការណ៍មួយ ដែលរួមមានការព្រមានមួយប្រឆាំងនឹងអំណាចគ្របសង្កត់របស់ភាគីមួយក្នុងចំណោមភាគីទាំងអស់មកលើភាគីផ្សេងទៀត ។ សេចក្តីថ្លែងការណ៍បានចែងលក្ខខណ្ឌច្បាស់ថា "ផ្តើមចេញពីគោលការណ៍ដែលថា ការរំដោះ និង ការការពារប្រទេសនីមួយៗជាភារកិច្ចរបស់ប្រជាជនខ្លួន ភាគីទាំងអស់ដែលប្រឈមមុខដាក់គ្នាត្រូវប្រកាន់ពាក្យសន្យាធ្វើនូវអ្វីៗគ្រប់បែបយ៉ាងដែលជាសិទ្ធិអំណាចរបស់ខ្លួនដើម្បីផ្តល់នូវការគាំទ្រគ្នាទៅវិញទៅមក ស្របតាមបំណងរបស់ភាគីដែលពាក់ព័ន្ធ និងឈរលើមូលដ្ឋាននៃការគោរពគ្នាទៅវិញទៅមក" ។ ចំណុចមួយទៀតបាន សង្កត់បញ្ជាក់ថា សហប្រតិបត្តិការទៅថ្ងៃមុខដើម្បីកសាងប្រទេសនីមួយៗឡើងវិញ ត្រូវតែ"អនុលោមទៅតាម ការជ្រើសរើសរបស់ប្រទេសនីមួយៗនោះ" ។ បើទុកជាមានប្រើពាក្យពេចន៍ ប្រុងប្រយ័ត្នទាំងនេះដែលជាគំនិត ផ្តួចផ្តើមរបស់ពួកចិននិងខ្មែរក្រហមក៏ដោយ ក៏គំនិតនៃការលើកឲ្យទៅជាធម្មនុញ្ញភាពនូវសហប្រតិបត្តិការរវាង ប្រជាជនឥណ្ឌូចិនគឺមិនបានសម្រេចលទ្ធផលឡើយ ។ ក្នុងឱកាសនៃកិច្ចសម្ភាសន៍មួយនៅខែមេសា ឆ្នាំ១៩៧៩ សម្តេច សីហនុ បានមានបន្ទូលប្រាប់ខ្ញុំថា ដៃគូរបស់ខ្ញុំគឺពួកខ្មែរក្រហមរួមនឹងពួកចិនផង បានទិតៀនយ៉ាងខ្លាំងនូវការផ្តល់យោបល់របស់ខ្ញុំដែលសុំឲ្យមានការបើកប្រជុំសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិនលើកទី២ នៅក្រុងហាណូយ នៅឆ្នាំ១៩៧១ ។ ការប្រជុំនោះនឹងត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃការពិគ្រោះយោបល់គ្នាដោយ ទៀងទាត់សំដៅរឹតចំណង សាមគ្គីភាពរវាងសម្ព័ន្ធមិត្តនានា ។ ការស្ទាក់ស្ទើររបស់ចិន បានបង្ហាញឲ្យឃើញដើមហេតុ ជាពិសេសតាមរយៈគោលបំណងរបស់ខ្លួន ដែលចិនមិនចង់ធ្វើឲ្យរាំងស្ទះដល់ភាពធូរស្រាល ដែលខ្លួន ចាប់ផ្តើមជាមួយក្រុងវ៉ាស៊ីនតោនឡើយ ។ ប៉ុន្តែ បើពិនិត្យឲ្យជ្រៅជាងនេះ ការដែលចិនបញ្ចៀសមិនឲ្យមាន សន្និសីទថ្មីមួយនោះគឺ ខ្លាចវាជួយពង្រឹងស្ថានភាពគន្លឹះផ្នែកយោធារបស់ក្រុងហាណូយនៅឥណ្ឌូចិនឲ្យរឹតតែរឹងមាំឡើងនោះឯង ។

នៅខែធ្នូ ឆ្នាំ១៩៧១ នាទីក្រុងប៉េកាំង សម្តេច សីហនុ បានមានបន្ទូលជាសម្ងាត់ជាមួយអតីតនាយករដ្ឋមន្ត្រីបារាំង ព្យែរ ម៉ងដេស ហ្វ្រង់ ថា ព្រះអង្គដូចជាមិនចង់បោះបង់ឥណ្ឌូចិនឲ្យស្ថិតនៅក្រោមការត្រួតត្រាពី "អំណាច"តែមួយគឺក្រុងហាណូយនោះទេ ព្រោះថា ការគ្មានស្ថិរភាពដែលមានជាបន្តមកនឹងបណ្តាលឲ្យខូចប្រយោជន៍សម្រាប់ពិភពលោកទាំងមូល ។ "ខ្ញុំធ្លាប់មានបន្ទូលពីរឿងនេះ ជាមួយ ជូ អេនឡាយ ដែលមានទស្សនៈដូចខ្ញុំដែរថា បណ្តាប្រទេសនៅឥណ្ឌូចិនត្រូវតែឲ្យស្ថិតនៅជាអព្យាក្រឹតទាំងស្រុងដដែល ។ ប្រទេសចិននឹងមាន

ប្រទេសទាំងនោះជាបង្អែក»[៣៨] ។

អតីតនាយករដ្ឋមន្ត្រីបារាំងបានចោទសួរបញ្ហានេះដោយផ្ទាល់ចំពោះ ជូ អេនឡាយ ដែលជាអតីតគូសន្ទនារបស់គាត់នៅសន្និសីទក្រុងហ្សឺណែវនិងអ្នកទទួលខុសត្រូវជាន់ខ្ពស់ចិនជាច្រើននាក់ទៀតដែរ ។ សេចក្ដីសន្និដ្ឋានរបស់គាត់គឺ «វាច្បាស់ណាស់ដែលថា ប្រទេសចិនប្រាថ្នាបញ្ចៀសមិនឲ្យអានុភាពមួយដែលត្រួតត្រាដោយវៀតណាមខាងជើងពង្រីកការត្រួតត្រារបស់គេមកលើឥណ្ឌូចិនទាំងមូលឡើយ ។ ពួកចិនបាននិយាយពីឯករាជ្យភាពនៃលក្ខណៈនយោបាយរបស់ប្រទេសនីមួយៗ ឡាវ កម្ពុជា និងវៀតណាមខាងត្បូងដែរ»[៣៩] ។

សម្រាប់ពួកចិនយល់ថា កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅខែមករា ឆ្នាំ១៩៧៣ បានរួមបន្ថែមជាកិច្ចធានាមួយប្រឆាំងទល់នឹងអនុត្តរភាពរបស់វៀតណាម ។ នៅដើមឆ្នាំ១៩៧៣ ជូ បានគូសបញ្ជាក់ប្រាប់ឯកអគ្គរដ្ឋទូតបារាំង អេទីយែន ម៉ាណាក់ ថា ប្រទេសចិនយកចិត្តទុកដាក់ខ្លាំងបំផុតទៅលើមាត្រាទី២០នៃកិច្ចព្រមព្រៀងដែលគ្រោងទុកនូវ «ការដកកងទ័ពរបស់បរទេសទាំងអស់» ចេញពីប្រទេសកម្ពុជានិងឡាវ ។ គាត់និយាយថា «យើងនឹងមិនទៅ[កម្ពុជា]ទេ ប៉ុន្តែយើងក៏ពុំអាចយល់ព្រមឲ្យអ្នកណាផ្សេងទៀតទៅទីនោះដែរ»[៤០] ។

នៅឆ្នាំ១៩៧២ សហរដ្ឋអាមេរិកក៏ត្រូវញ៉ាំងឲ្យជឿជាក់ដែរថា ក្រុងប៉េកាំងចង់ឲ្យមាន«ការបំបែកឥណ្ឌូចិនជាបីប្រទេស» ។ ដោយក្រុងវ៉ាស៊ីនតោនមានទស្សនៈដូចគ្នា ការបន្ធូរភាពតានតឹងរវាងចិន-អាមេរិកាំងនឹងជួយសម្រួលដល់រឿងនោះ[៤១] ។

បន្ទាប់ពីការបញ្ចេះអរិភាពជាចំហរវាងចិននិងវៀតណាមរួចមក នៅក្រុងហាណូយគេបានផ្សាយរឿងនិទានចំអន់នយោបាយខ្លីៗថា ម៉ៅ ធ្លាប់បាននិយាយទូន្មាន ផាំ វ៉ាន់ដុង ឲ្យដោះស្រាយបញ្ហារបស់ខ្លួន ដែលមានសព្វថ្ងៃដាច់ដោយឡែកពីវៀតណាមខាងត្បូង ។ រឿងនេះកើតមានឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៧២ ។ ម៉ៅ បានប្រកាសប្រាប់ ដុង ថា «គេមិនអាចបោសសំរាមដែលនៅឆ្ងាយបានទេ បើសិនជាដងអំបោសខ្លីពេក ។ ប្រទេសតៃវ៉ាន់ស្ថិតនៅឆ្ងាយពេកពីអំបោសរបស់យើង ហើយ ធីវ ដែលនៅវៀតណាមខាងត្បូងក៏នៅឆ្ងាយខ្លាំងពីអំបោសរបស់លោកដែរ សមមិត្ត! យើងទាំងអស់គ្នាត្រូវសុខចិត្តទទួលហេតុការណ៍នេះ» ។ គេអះអាងថា ដុង បានរ៉ាប់រងនឹងប្រធាន ម៉ៅ ថា អំបោសរបស់វៀតណាមមានដងវែងណាស់[៤២] ។ ដោយមិនបដិសេធរឿងនិទានចំអកនយោបាយនេះ នៅឆ្នាំ១៩៧៣ ក្រុងប៉េកាំងបានបញ្ជាក់បំភ្លឺក្រោយមកថា តាមយោបល់របស់ខ្លួន ក្រុងហាណូយត្រូវតែអត់ធ្មត់បន្តិច មុននឹងផ្ដើមការតស៊ូដើម្បីបង្រួបបង្រួមប្រទេសឡើងវិញ ។ ប្រការនេះនឹងធ្វើឲ្យស្មុគស្មាញដល់អន្តរាគមន៍របស់អាមេរិកាំងមួយថ្មីថែមទៀត ។

## ជាពិសេសគ្មានវៀតណាមដែលបង្រួបបង្រួមតែមួយទេ

អ្វីដែលជាជំហររបស់ចិនស្ដីពីបញ្ហានៃការបង្រួបបង្រួមវៀតណាមឡើងវិញ គឺក្រុងប៉េកាំងបានប្រើងប្រែង

រក្សាទំនាក់ទំនងដោយឯករាជ្យយ៉ាងជាក់ប្រាកដជាមួយរណសិរ្សរំដោះជាតិដែលនៅភាគខាងត្បូង ។ ការត្រៀមបម្រុងផ្សេងៗដែលផ្តើមដោយពួកចិនដើម្បីនាំគ្រឿងសាស្ត្រាវុធ ស្បៀងអាហារ និងក្រដាសប្រាក់ទៅផ្តល់ឲ្យរណសិរ្សរំដោះជាតិដោយឆ្លងកាត់តាមប្រទេសកម្ពុជាពុំមែនដោយសារតែហេតុផលសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែប្រហែលជាដោយចេតនារបស់ចិនក្នុងការរក្សាទំនាក់ទំនងដោយផ្ទាល់មួយជាមួយអ្នកបដិវត្តន៍វៀតណាមខាងត្បូងផងដែរ ។ បន្ទាប់ពីបដិវត្តវប្បធម៌ នៅឆ្នាំ១៩៦៦-៦៧ក្រុងហាណូយបានរៀបចំគ្រឿងទប់មួយចំពោះការសាយភាយនៃការឃោសនារបស់ចិននៅភាគខាងជើងប្រទេស ប៉ុន្តែឥទ្ធិពលរបស់ក្រុងប៉េកាំងបានបន្តមានមកលើពួកកុម្មុយនីស្តមួយផ្នែកនៅខាងត្បូងទៀតតាមរយៈខ្សែបណ្តាញសម្ងាត់ជាច្រើន ។

អ្នកជំនាញការអាមេរិកាំងម្នាក់បានកត់សម្គាល់ថា តាមពិត នៅពេលដែលសង្គ្រាមវិវត្តឈានទៅរកលក្ខណៈគួរឲ្យពេញចិត្តសម្រាប់ក្រុងហាណូយ និងពេលដែលពួកអាមេរិកាំងចាប់ផ្តើមការដកថយកងឯកភាពប្រយុទ្ធរបស់ខ្លួនដោយសំអាងលើទ្រឹស្តីនិចសុននោះ ប្រទេសចិនបានបង្កើនការប្រឹងប្រែងរបស់ខ្លួនទ្វេឡើងទៀតដើម្បីរៀបចំឲ្យមានការទាក់ទងគ្នាដោយផ្ទាល់ជាមួយប្រទេសឡាវនិងកម្ពុជា ប៉ុន្តែក៏ជាមួយអ្នកបដិវត្តន៍នៅភាគខាងត្បូងវៀតណាមផងដែរ[៤៣] ។

ទ្រឿង ញូតាង អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូងដែលរត់ភៀសខ្លួនចេញពីប្រទេសនៅឆ្នាំ១៩៧៩ បានអះអាងបញ្ជាក់ចំពោះមុខខ្ញុំ(អ្នកនិពន្ធ)ថា ប្រទេសចិនបានរក្សាទំនាក់ទំនងផ្សេងៗ«យ៉ាងជិតស្និទ្ធបំផុត»ជាមួយរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ។ តាមការរៀបរាប់របស់គាត់ថា «ពួកចិនហាក់ដូចជាដឹងខ្លួនមុនគាំងពីដំបូងថា ភាគខាងជើងមានលទ្ធភាពគ្រប់យ៉ាងក្នុងការដាក់បង្ខំឲ្យមានបែបផែនទស្សនៈរបស់ខ្លួននៅភាគខាងត្បូង ។ ដោយហេតុនេះហើយ ទើបពួកចិនគាំទ្ររដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ។ គឺពួកចិននេះដែរ ដែលទទូចឲ្យដាក់បញ្ចូលសិទ្ធិស្វ័យសម្រេចរបស់ភាគខាងត្បូងក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនោះ»[៤៤] ។

តាង បានលើកឧទាហរណ៍មួយអំពីការគោរពរបស់ចិនចំពោះអត្តសញ្ញាណអ្នកភាគខាងត្បូងប្រាប់ខ្ញុំដែរ ។ គាត់ធ្លាប់បានធ្វើដំណើរមួយទៅក្រុងប៉េកាំងនៅខែកុម្ភៈ ឆ្នាំ១៩៧៥ ក្នុងឋានៈជាមេដឹកនាំគណៈប្រតិភូមួយនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ។ អ្នកបដិវត្តន៍ភាគខាងត្បូងពុំបានស្នាក់នៅក្នុងនិវេសនដ្ឋានជាមួយនឹងគណៈប្រតិភូរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមទេ ។ ពួកចិនបានរៀបពិធីបដិសណ្ឋារកិច្ចពីរដាច់ដោយឡែកពីគ្នា ហើយអ្វីដែលមិនសូវគ្រចះគ្រចង់ គឺពុំមែនបដិសណ្ឋារកិច្ចដែលផ្តល់ឲ្យរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នឡើយ ។ ការវិភាគដែលអះអាងដោយ តាង ពីជំហររបស់ចិន-ដែលឥឡូវនេះវាមានដំណើរត្រូវគ្នាពេញលេញ-បានបញ្ជាក់បន្ថែមក្នុងករណីខ្លះនូវអ្វីដែលនាំមកនិយាយដោយ លោក ហ្វ្រង់ស័រ មីសូហ្វ ជាបេសកជនពិសេសរបស់រដ្ឋមន្ត្រីការបរទេសបារាំង ។ បន្ទាប់ពីដំណើរមួយទៅក្រុងប៉េកាំង នៅដើមឆ្នាំ១៩៧៦ ដែលនៅ

ពេលនោះគាត់បានជួបធ្វើការសន្ទនាជាមួយមន្ត្រីខ្ពស់ៗ មីសូហ្វ បានប្រកាសឲ្យដឹងដូច្នេះថា "ពួកចិននិយាយថា វាមិនសំខាន់ប៉ុន្មានទេដែលមានវៀតណាមពីរ ឬបីនោះ ។ ចំណុចសំខាន់គឺគ្មានវៀតណាមរួមគ្នាតែមួយឡើយ"[៤៥] ។

បួនឆ្នាំក្រោយមក វៀតណាមបានអះអាងថា នៅខែមេសា ១៩៧៥ ក្រុងប៉េកាំងបានសុំកុំឲ្យខ្លួនធ្វើការវាយលុកផ្ដាច់ព្រ័ត្រទៅលើក្រុងព្រៃនគរ នេះជាការឃោសនាប្រហែលដូចទង្វើករណ៍ផ្សេងៗជាច្រើនទៀតរបស់វៀតណាមដែរ តាំងពីការកាត់ផ្ដាច់ដោយចំហរបស់គេជាមួយប្រទេសចិន ។ ប៉ុន្តែលោក ហ៊ីលីព រីឈ័រ ដែលធ្វើជាឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងហាណូយ នៅចន្លោះឆ្នាំ១៩៧៣ និង១៩៧៥ បានបញ្ជាក់ប្រាកដណាស់ថា នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ គឺប្រាំបួនថ្ងៃមុនការដួលរលំនៃក្រុងព្រៃនគរ ក្រុងប៉េកាំងបានព្រមានក្រុងហាណូយពីគ្រោះថ្នាក់ដែលនឹងមានក្នុងការ"រុញអំបោសទៅឆ្ងាយពេក"ដែលនេះជាការលើកឡើងវិញនូវពាក្យប្រៀបធៀបដែលធ្លាប់ប្រើដោយ ម៉ៅ កាលពីឆ្នាំ១៩៧២ដែរ[៤៦] ។

ឥរិយាបថរបស់វៀតណាម បានផ្លាស់ប្ដូរដូចគ្នានៅបណ្ដាឆ្នាំជាបន្តបន្ទាប់មកទៀត ។ ថ្វីបើគាត់បំពេញមុខងារបម្រើផលប្រយោជន៍ជាតិរបស់វៀតណាមក៏ដោយ ក៏ ហូ ជីមិញ តែងយកចិត្តទុកដាក់ថែរក្សាយ៉ាងហោចនូវទម្រង់នៃទំនាក់ទំនងជាប្រពៃណីរបស់ប្រទេសគាត់ជាមួយប្រទេសចិននៅគ្រប់កាលៈទេសៈជានិច្ច ។ គាត់បានសរសេរលិខិតថ្លែងអំណរគុណដោយដៃគាត់ផ្ទាល់ជាច្រើនច្បាប់ផ្ញើទៅឲ្យ ម៉ៅ ហើយក្នុងសេចក្ដីថ្លែងការណ៍ជាសាធារណៈទាំងឡាយរបស់ខ្លួន បណ្ដាមេដឹកនាំវៀតណាមតែងសម្ដែងការគោរពជានិច្ចចំពោះប្រទេសចិន ។ វៀតណាមដែលប្រហែលជាដឹងខ្លួនជាងពួកចិននោះ បានរក្សាតាំងពីយូរយារមកហើយនូវគំរូមួយនៃទំនាក់ទំនងផ្សេងៗ ដែលខ្លួនព្រមឲ្យប្រទេសចិនមានតួនាទីជា"បងធំ"នោះ ។ ហ្វ្រង់ស័រ ហ្សូយ៉ូ បានកត់សម្គាល់ថា នៅដើមទសវត្សរ៍៦០ពួកមេដឹកនាំវៀតណាម បានប្រើប្រាស់លក្ខណៈគោរពចំពោះ ម៉ៅ ដូចគ្នានឹងបណ្ដាព្រះមហាក្សត្ររបស់វៀតណាមយកសួយសារអាករទៅថ្វាយព្រះចៅអធិរាជប្រទេសចិនកាលពីដើមដែរ ។ ដោយអនុវត្តតាមការនាំសួយសារអាករទៅថ្វាយព្រះចៅអធិរាជចិនពីដើម ហូ តែងបានចាត់បញ្ជូនមន្ត្រីរាជការជាន់ខ្ពស់ជាច្រើននាក់ទៅកាន់ព្រំដែនភ្លាមដើម្បីអមការពាររដ្ឋមន្ត្រីនានារបស់ចិន ដែលធ្វើដំណើរមកប្រទេសវៀតណាមជានិច្ច ។ ដោយចាត់ទុកថា ប្រទេសចិនប្រកាន់ឥរិយាបថជាអធិរាជមួយដែលមានលក្ខណៈកាន់ជើងម្ខាងៗចំពោះប្រទេសវៀតណាមនោះ លោក ហ្សូយ៉ូ យល់ថា "អ្វីៗដែលកម្រឃើញនេះ គឺវាស្មុគស្មាញលំបាកយល់ណាស់ ។ តាមពិតគេអាចរកឃើញសំណល់នៃរឿងរ៉ាវមួយកំភូសធំដែលពួកមេដឹកនាំវៀតណាមប្រព្រឹត្តខ្លួនដោយឯកឯងជា"ស្ដេចចំណុះគេ"[៤៧] ។ ដោយការការពារផលប្រយោជន៍ជាតិរបស់ខ្លួនគ្មានឈប់ឈរ ដែលនឹងជំរុញឲ្យពួកគេបំពានប្រទេសចិននោះ វៀតណាមនៅតែគោរពតាមទម្រង់ផ្សេងៗដែលទទួលដំណែលពីអតីតកាលមក ។

ក៏ប៉ុន្តែ ការគោរពដែលមានតែសំបកក្រៅនេះ នៅទីបំផុតបានរលុបរលាយបន្តិចម្ដងៗ ជាបឋម ដោយ

*ភាពធ្ងន់ធ្ងរនៃជម្លោះចិន-សូវៀត តមកហើយជាពិសេស បន្ទាប់ពីដំណើរជាប្រវត្តិសាស្ត្ររបស់ប្រធានាធិបតីនិចសុន ទៅកាន់ប្រទេសចិន ដែលវៀតណាមប្រដូចទៅនឹងការផ្លាស់ប្តូរទៅរកភាពជាសត្រូវនឹងគ្នាមួយ ។ ប្រទេសចិននិងសហភាពសូវៀតដែលក្រុងហាណូយប្រកាសនៅឆ្នាំ១៩៧២ដោយមិនបញ្ចេញឈ្មោះ សុទ្ធតែ"ត្រូវរុញឲ្យកប់ភក់គួរឲ្យអាណិតនៅលើផ្លូវនៃការសម្របសម្រួលគ្នាដែលឥតឲ្យពេញចិត្ត និងថោកទាប"[៤៨] ។*

*បន្ទាប់ពីជ័យជម្នះដ៏គួរឲ្យភ្ញាក់ផ្អើលរបស់ខ្លួននាឆ្នាំ១៩៧៥ ប្រទេសវៀតណាមដែលខ្លាំងពូកែ និងដែលជឿជាក់លើខ្លួនឯងខាងកម្លាំងទ័ពនោះមិនងាយធ្វើឲ្យអន្តរាយនូវអ្វីដែលខ្លួនចាត់ទុកជាផលប្រយោជន៍ជាតិ ដើម្បីបំពេញចិត្តប្រទេសចិនឡើយ ។ ម្យ៉ាងទៀត វៀតណាមក៏សម្រេចចិត្តធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់ខ្លួន ជាមួយប្រទេសចិនមានលក្ខណៈថ្មីដែរ ។ ភ័ស្តុតាងនៃការគោរពចំពោះ"មហាយក្ស"ខាងជើង បើទោះជាមានតែទម្រង់ក្រៅក៏ដោយ ក៏លែងត្រូវកាលៈទេសៈទៀតហើយ ។ ដោយក្លាយទៅជាប្រទេស"ពេញលក្ខណៈ"វៀតណាមបានប្រុងប្រៀបខ្លួនទទួលរ៉ាប់រងការចាត់ចែងដឹកនាំការបដិវត្តន៍ក្នុងអាស៊ីអាគ្នេយ៍រួចជាស្រេច ។*

*ប៉ុន្តែ គឺមានតែនៅឆ្នាំ១៩៧៥ប៉ុណ្ណោះដែលលេខាបក្ស ឡេ យន់ សម្តែងឲ្យឃើញដោយរបៀបជាក់ស្តែងនូវភាពក្រអឺតក្រអោងរបស់វៀតណាម ដោយចៀសវាងមិនអញ្ជើញបណ្តាភ្ញៀវរបស់គាត់ទៅចូលរួមពិធីជប់លៀងលាគ្នាឡើយ ។ ពួកមេដឹកនាំកុម្មុយនីស្តចិន ប្រហែលជាមិនសង្ឃឹមរក្សាទុកជាមួយប្រទេសវៀតណាមនូវទំនាក់ទំនងផ្សេងៗរបៀបជាប្រទេសចំណុះទៀតទេមើលទៅ ។ ម្យ៉ាងទៀត ការរំជួលចិត្តដ៏ខ្លាំងក្លាដែលអុជអាលឲ្យកើតជាទំនាស់នៅប្រទេសចិន ដោយ"ភាពក្រអឺតក្រទមបែបមើលងាយ" និង"ចិត្តខ្មៅរមិលគុណ"របស់វៀតណាមតាំងពីការចាប់ផ្តើមនៃជម្លោះ បានធ្វើឲ្យនឹកឃើញគំរូមួយនៃទំនាក់ទំនងផ្សេងៗនៅសតវត្សរ៍មួយផ្សេងទៀត ។ ការរំជួលចិត្តនេះ មានអត្ថន័យសំខាន់មួយគឺ ការខកចិត្តរបស់ពួកចិន ចំពោះការបះបោរនៃប្រទេសតូចជិតខាងខ្លួនក៏ដូច"អំពើអាក្រក់"របស់ពួកវៀតណាម ។ ប្រទេសវៀតណាមនៅតែត្រូវសន្មតថាជា"សាច់ញាតិជិតស្និទ្ធបំផុត"នឹងប្រទេសចិន ដូចដែលព្រះចៅអធិរាជ យ៉ុងលី បានកត់សម្គាល់កាលពី៥០០ឆ្នាំមុនទៀតឬ? ។*

*នៅទីបញ្ចប់ ក្រុងហាណូយបានជម្នះនឹងប្រទេសចិន ដើម្បីស្វែងរកចងមិត្តភាពនឹងសហភាពសូវៀតហើយត្រង់នេះឯងគឺជាមូលហេតុសំខាន់មួយក្នុងចំណោមមូលហេតុសំខាន់ៗនៃការប្រឆាំងជំទាស់របស់ចិនគ្រប់ការប៉ុនប៉ងដាក់អនុត្តរភាពទាំងស្រុងរបស់វៀតណាមនៅឥណ្ឌូចិន-ដែលមានលក្ខណៈខ្លាំងក្លា និងលក្ខណៈជាការឈ្លានពានជាងពេលណាៗទាំងអស់ ។ ការបង្កើតទំនាក់ទំនងនយោបាយដែលតាមសំបកក្រៅមានលក្ខណៈជិតស្និទ្ធរវាងប្រទេសទាំងពីរ ភាពពឹងផ្អែកផ្នែកសេដ្ឋកិច្ចនិងយោធារបស់ប្រទេសវៀតណាមចំពោះក្រុងមូស្គូបានរួមបង្កជាការគំរាមមួយ ដែលប្រទេសចិនពុំដែលប្រឈមមុខតាំងពីឆ្នាំ១៩៤៩មក ។ ព្រះចៅអធិរាជ ហុងវូបានទូន្មានបណ្តាអ្នកស្នងតំណែងពីព្រះអង្គកុំឲ្យលុកលុយរដ្ឋគ្មានអារ្យធម៌មួយនៅភាគខាងត្បូង ដោយគ្មានមូលហេតុសមហេតុសមផល ពីព្រោះសម្រាប់ប្រទេសចិន ការគំរាមកំហែងសំខាន់បំផុត គឺមកពីភាគខាងជើង*

ជានិច្ច ។ ប៉ុន្តែ បន្ទាប់ពីការដកថយទាំងប្រញាប់ប្រញាល់របស់មហាអំណាចអាមេរិកាំង នៅក្រោយពេលសង្គ្រាមឥណ្ឌូចិនលើកទីពីរផុតរលត់នៅឆ្នាំ១៩៧៥ ប្រទេសចិនប្រហែលជាប្រឈមមុខនឹងគ្រោះថ្នាក់ថ្មីមួយទាំងស្រុង ។ ក្រៅពីទ័ពថ្មើរជើងហាសិបកងពលធំរបស់សូវៀត និងការដាក់ពង្រាយមីស៊ីល និងកងអាកាសចរដ៏សម្បើមនៅភាគខាងជើង ឥឡូវនេះ ប្រទេសចិនត្រូវឈមមុខតទល់នឹងទស្សនវិស័យនៃសម្ពន្ធភាពសូវៀត-វៀតណាមមួយ ចំពោះដំណើររបស់ពួកសូវៀតមកព្រំដែនភាគខាងត្បូងរបស់ខ្លួនថែមទៀត ។ ជាច្រើនឆ្នាំក្រោយមក មេដឹកនាំវៀតណាមម្នាក់ឈានរហូតដល់បកស្រាយថា សម្ពន្ធភាពរបស់ប្រទេសខ្លួនជាមួយក្រុងមូស្គូគឺជាការការពារបំម្រុងទុកជាមុនតែមួយគត់ប្រឆាំងនឹងប្រទេសចិន ។ គាត់បានអះអាងថា ៖ «ក្នុងប្រវត្តិសាស្ត្រទាំងមូល យើងធ្លាប់រួចផុតពីគ្រោះថ្នាក់របស់ចិនតែពីរករណីប៉ុណ្ណោះ ៖ ប្រទេសចិនមួយដែលទន់ខ្សោយនិងបែកបាក់ ឬប្រទេសចិនមួយដែលគំរាមកំហែងដោយពួកអានារ្យជនមកពីភាគខាងជើង ។ សព្វថ្ងៃនេះ រុស្ស៊ីគឺជាពួកអនារ្យជនរបស់យើង»[៤៩] ។

ការបង្កើតទំនាក់ទំនងចិន-អាមេរិកាំងនៅឆ្នាំ១៩៧២ ទីបំផុតបានរុញ«ខ្លែងចចក» គឺចក្រពត្តិនិយមអាមេរិកឲ្យឃ្លាតឆ្ងាយពីមាត់ទ្វាររបស់ប្រទេសចិន ។ ប៉ុន្តែ នៅភាគខាងជើង «ខ្លា»សូវៀតនៅតែបន្តស្រែកគ្រហឹមជានិច្ច ។ តាមចិនឲ្យដឹងថា តាំងពីឆ្នាំ១៩៧៨ សូវៀតបម្រុងតែនឹងពង្រីងជម្រកថ្មីមួយនៅភាគខាងត្បូងទៅហើយ ។ ក្នុងបរិបទជាយុទ្ធសាស្ត្រមួយបែបនោះ តើអធិរាជចិនអង្គណានឹងធ្មើតធ្មើថ្លង់ចំពោះការអំពាវនាវឲ្យជួយពីអ្នកស្មោះត្រង់ភាគខាងត្បូងមួយ ដែលត្រូវប្រឈមមុខនឹងការគំរាមកំហែងដូចអាណាចក្រកណ្តាលដែរនោះ? ។ ពិតហើយ ទោះបីជាមានភាពដូចគ្នាផ្នែកមនោគមវិជ្ជារបស់ខ្លួនជាមួយប្រទេសចិនរបស់ ម៉ៅ ក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យដែលចេះតែរអើលបំផុតនោះ ពុំមែនជាប្រទេសចំណុះមួយទេ ។ ប៉ុន្តែ បទពិសោធន៍កន្លងមករបស់ប្រទេសចិន ក៏ដូចការភ័យបារម្ភបច្ចុប្បន្នរបស់ខ្លួន បានតម្រូវឲ្យចិនគ្រាប់តាមទាំងផងដីតផងល់ នូវការប្រព្រឹត្តមួយនៃបណ្តាអតីតព្រះចៅអធិរាជរបស់ខ្លួនចំពោះប្រទេសវៀតណាមនិងកម្ពុជាដែលមានរាប់សតវត្សរ៍មកហើយ ។

# ជំពូកទី៥
# ជំនោរខ្យល់ពីទិសខាងលិច

ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៧ យន្តហោះប្រតិកម្ម Starlifter ពណ៌ទឹកប្រាក់និងខៀវនៃកងអាកាសចរអាមេរិកាំងបានផ្អៀងស្លាបផ្ដើមធ្វើការចុះចតរបស់ខ្លួននៅលើដីវាលប្រមុះជ្រូកដែលលយចូលទៅក្នុងទន្លេក្រហម ។ នៅលើយន្តហោះ ឯកអគ្គរដ្ឋទូត ឡេអូណារដ៍ វូដខូក បានសម្លឹងមើលវាលស្រែទាំងឡាយដែលកាត់ខ្វាត់ខ្វែងជាក្រឡាចត្រង្គដោយទំនប់ និងប្រឡាយទឹកតាមបង្អួចយន្តហោះ ។ មេដឹកនាំសហជីព វូដខូក មិនដែលដាក់ជើងជាន់ប្រទេសវៀតណាមទាល់តែសោះ ទាំងភាគខាងជើង ទាំងភាគខាងត្បូង ។ ប៉ុន្តែ គាត់មិនមែនមិនដឹងថា ប្រភេទបឹងមូលធំៗដែលធ្វើឲ្យទេសភាពមើលទៅមានស្នាមរទុះៗជារណ្ដៅគ្រាប់បែកឡើយ ។ ភ្លៀងធ្លាក់ខ្លោកៗមួយមេយ៉ាងធំបានបំពេញរណ្ដៅធំៗទាំងនេះ ដែលបន្សល់ទុកដោយកងអាកាសចរអាមេរិកាំង ។ នៅមានស្នាមរបួសជាច្រើនទៀតដែលត្រូវព្យាបាល និងចំណងទាក់ទងផ្សេងៗដែលធ្វើឲ្យខូចទឹកចិត្ត ក៏ត្រូវចងភ្ជាប់ឡើងវិញមុនពេលដែលជំពូកនៃប្រវត្តិសាស្រ្តរបស់អាមេរិកាំងដែលមានជោគជ័យតិចតួចនេះត្រូវបិទ ។

វូដខូក ផ្ទាល់ដែលជាប្រធានសហជីពឧស្សាហកម្មរថយន្តសហរដ្ឋអាមេរិក (United Auto Workers Union) បានត្រូវអមដំណើរដោយឥស្សរជនអាមេរិកាំងបួននាក់ទៀត ។ គាត់មានបេសកកម្មដើម្បីចាប់ផ្ដើមបើកទំព័រមួយថ្មី ។ លោកប្រធានាធិបតី ជីមី ខាធ័រ ដែលទើបជាប់ឆ្នោតក្នុងពេលថ្មីៗបានប្រគល់សេចក្ដីទុកចិត្តឲ្យលោក វូដខូក ដឹកនាំគណៈប្រតិភូដំបូងមួយធ្វើដំណើរទៅកាន់ក្រុងហាណូយ និងក្រុងវៀងច័ន្ទ ដើម្បីសាកល្បងស្វែងរកដំណោះស្រាយមួយអំពីបញ្ហាទាហានអាមេរិកាំងដែលចាត់ទុកថា បាត់ខ្លួននៅឥណ្ឌូចិនបន្ទាប់ពីសង្គ្រាមផុតរលត់ទៅ ។ នៅពេលដែលយន្តហោះចាប់ផ្ដើមទៅជិតដល់អាកាសយានដ្ឋាន យ៉ា ឡាំ ដោយហោះហើរពីលើដែនដីមួយដែលស្ទើរតែប្រែក្លាយទៅជាដីខ្សោះជីជាតិ និងដេរដាសទៅដោយខ្ទមស្លឹករខេករខាក និងដើមឫស្សីស៊ុបទ្រុប លោក វូដខូក បានដណ្ដឹងសួរក្នុងចិត្តថា ការទទួលស្វាគមន៍របស់រដ្ឋធានី“ជាសត្រូវ”នឹងត្រៀមបម្រុងចំពោះគណៈប្រតិភូរបស់គាត់ដោយរបៀបណាទៅ ។ គូសន្ទនារបស់គាត់ក្នុងគ្រប់សម័យប្រជុំការងារនិងជាអ្នកការទូតវៀតណាមក្នុងចំណោមអ្នកការទូតវៀតណាមដែលជោគជាំក្នុងចម្បាំងជាងគេ គឺអនុរដ្ឋមន្រ្តីការបរទេស ផាន់ ហៀន ។ ប៉ុន្តែ តើអ្នកណាដែលនឹងមកទទួលស្វាគមន៍គាត់នៅចំណតអាកាសយាន? ពួកមេដឹកនាំលំដាប់ទីពីរឬ? ។

ខ្យល់ក្ដៅនិងសើមបន្តិចៗ បានបក់ផាត់មកប៉ះមុខគាត់កាលបើគាត់ដាក់ជើងជាន់លើក្បាលជណ្ដើរយន្តហោះភ្លាម ។ ទីបំផុត អាកាសយានិកបានពន្លត់ម៉ាស៊ីនប្រតិកម្ម ។ ភាពស្ងៀមស្ងាត់មួយ ដែលធ្វើឲ្យហ៊ឹងត្រចៀកបានកើតមានឡើងនៅទីនោះ ។ ពេលនេះគាត់កំពុងស្ថិតនៅទីក្រុងហាណូយហើយ ។ មិនដល់ប្រាំឆ្នាំមុនផង ទីនេះគឺជាស្ថាននរក ។ នៅពេលបុណ្យណូអែលឆ្នាំ១៩៧២ ហ្វូង យន្តហោះបេ-៥២ ដែលបញ្ជូនដោយលោកប្រធានា

ធិបតី និចសុន បានសម្លាប់ប្រជាជនស៊ីវិលរាប់ពាន់នាក់ ដោយកម្ទេចមន្ទីរពេទ្យធំជាងគេនៅទីក្រុងហាណូយឲ្យបាក់បែកខ្ទេចខ្ទី ក្នុងការវាយប្រហារយ៉ាងខ្លាំងក្លាខ្ពស់ដល់កម្រិតជាលើកចុងក្រោយមួយ ទោះបីជាកងកម្លាំងកាំភ្លើងធំបាញ់យន្តហោះរបស់វៀតណាម ព្រួសគ្រាប់កាំភ្លើងសំដៅយន្តហោះទម្លាក់គ្រាប់បែកយក្សទាំងនោះ ដែលហោះកប់ពពកមើលមិនឃើញក្នុងកម្ពស់ជាច្រើនគីឡូម៉ែត្រក៏ដោយ ។ ថ្ងៃនេះ នៅជើងជណ្តើរយន្តហោះ គាត់មើលឃើញចំពោះមុខគាត់តែអាកាសយានដ្ឋានដ៏តូចមួយ និងហ្វូងមនុស្សមួយក្រុមតូចជាមួយបាច់ផ្កាប៉ុណ្ណោះ ។ កិច្ចការរបស់គាត់គឺធ្វើដំណើរវៀនទាហានដែលបាត់ខ្លួនឲ្យបានពិតប្រាកដបំផុត តាមដែលអាចធ្វើទៅបាន រួមទាំងក្រុមយានិកនៃយន្តហោះបេ-៥២ ដែលត្រូវបាញ់ធ្លាក់នៅពីលើប្រទេសវៀតណាមផង ។ នៅនឹងតុចរចា ប្រធានសហជីពខស្សរាហកម្មរថយន្តអាមេរិកាំង លោក វូដខូក មានទម្លាប់ទៅជួបបណ្តាមនុស្សដែលមានអំណាចដើម្បីចរចាទល់មុខគ្នា ។ ប៉ុន្តែ អ្នកដែលគាត់នឹងត្រូវជួបដើម្បីល្បងចរចាពីកិច្ចព្រមព្រៀងសហប្រតិបត្តិការមួយ ពុំមែនមានអំណាចសម្រេចដូចវង្វង់មេដឹកនាំក្រុមហ៊ុន General Motors ឬ Chrysler ឡើយ ។ ពួកនោះសុទ្ធតែជាសមមិត្តរួមអាវុធរបស់ ហូ ជីមិញ ។ ពួកគេធ្លាប់បានវាយប្រយុទ្ធដោយគ្មានឈប់ឈរក្នុងរយៈពេលសាមសិបឆ្នាំ ដើម្បីសម្រេចគោលដៅរបស់ពួកគេ ។ តើគាត់មានសមត្ថភាពគ្រប់គ្រាន់ទេ? តើគាត់នឹងសម្រេចបើកទំព័រមួយថ្មី និងរៀបចំស្ពានភាពសម្រាប់ការទាក់ទងប្រកបដោយសន្តិភាពជាមួយគូសត្រូវពីម្សិលឬទេ? ។

នៅពេលគាត់ចុះពីយន្តហោះ វូដខូក បានឃើញពីចម្ងាយនូវមនុស្សដែលត្រូវលូកដៃមកចាប់ដៃគាត់ គឺពុំមែនជាអ្នកកាន់មុខងាររាយរងនៃក្រសួងការបរទេសទេ ប៉ុន្តែគឺពិតជា ផាន់ ហៀន ផ្ទាល់ខ្លួនឯងតែម្តង ដែលសើចញញឹមយ៉ាងស្រស់ ។ មានរូបរាងតូចល្អិត ហៀន គឺជាតួយ៉ាងមន្ត្រីពេញលក្ខណៈដែលគួរសមរាក់ទាក់និងទុកចិត្តខ្លួនឯង ។ បន្ទាប់ពីពិធីទទួលស្វាគមន៍យ៉ាងខ្លីមួយ វូដខូក និង បណ្តាសហការីរបស់គាត់ គឺព្រឹទ្ធសមាជិក ម៉ៃម៉ាន់ហ្វៀល, ឯកអគ្គរដ្ឋទូត ស្ហាល យ៉ូស, សមាជិក សុននី ម៉ុងហ្គូម៉េរី និងអ្នកស្រីសមាជិកនៃអង្គការសិទ្ធិមនុស្ស ម៉ារីយ៉ាន អ៊ីដែលម៉ាន រួមទាំងអ្នកកាសែតមួយក្រុមតូចផងបានឡើងរថយន្ត ហើយក្បួនដង្ហែជាកិត្តិយសបានធ្វើដំណើរតាមផ្លូវកាត់ឆ្ពោះមកកាន់ទីក្រុងហាណូយ ។ នេះជាចម្ងាយផ្លូវមួយដែលនៅទីបំផុតមានចម្ងាយវែងជាងការគិតទុកជាមុនបន្តិច ។ បន្ទាប់ពីបើកជ្រែកហ្វូងអ្នកថ្មើរជើងក្បួនដង្ហែបានទៅដល់ស្ពាន ឡុង បៀន ដ៏ល្បីល្បាញ ។ ចរាចរណ៍ដ៏មមាញឹកនៃហ្វូងរទេះគោ ឡានកាមីញ៉ុងនិងអ្នកជិះកង់ច្រើនឥតគណនា បានធ្វើឲ្យស្ទះផ្លូវនៅពេលទៅជិតដល់មហាសំណង់នេះ ។ សម្រាប់ហេតុផលផ្សេងៗដែលប្រហែលជាចម្លែកគួរឲ្យឆ្ងល់ គឺច្បាប់ចរាចរប្រកាន់ស្តាំត្រូវផ្លាស់ប្តូរនៅកន្លែងនេះ ។ ដើម្បីឆ្លងកាត់ស្ពាន យានយន្តទាំងអស់ត្រូវតែទៅតាមផ្លូវវាងមួយមុននឹងចូលមកក្នុងជួរខាងឆ្វេង ។ នេះជាលក្ខណៈដែលស្ទើរតែ ផុតសម័យទៅហើយ ។ ហៀន បានរៀបរាប់ប្រាប់ វូដខូក ថា ស្ពាននេះដែលកសាងឆ្លងកាត់លើទន្លេក្រហម ដោយពួកបារាំងធ្លាប់ត្រូវរងការទម្លាក់គ្រាប់បែកក្នុងពេលសង្គ្រាម ហើយវាពុំទាន់បានជួសជុលនៅឡើយទេ ។ គាត់មិនបាច់នឿយហត់នឹងពន្យល់ថា យានយន្តគ្រប់ប្រភេទដែល

ត្រូវបង្ខំឲ្យផ្លាស់ប្តូរដូវបែបនេះគឺបណ្តាលមកពីផលវិបាកនៃសង្គ្រាមដែរ ។

នៅពេលកំពុងច្បាំងគ្នាពេញទំហឹង កំពង់ផែហៃហ្វុង នៅភាគខាងកើតក្រុងហាណូយ គឺជាមជ្ឈមណ្ឌលគមនាគមន៍ដ៏សំខាន់ស្មើអាយុជីវិត ។ គ្រឿងសម្ភារសឹកនិងស្បៀងអាហាររាប់ពាន់តោន បានរើដាក់ចុះនៅទីនេះ មុននឹងត្រូវដឹកទៅកាន់ក្រុងហាណូយនិងភាគខាងត្បូង ។ ក្បួនរថយន្តដឹកជញ្ជូនគ្មានផ្លូវណាផ្សេងក្រៅពីឆ្លងកាត់ស្ពានឡុងបៀន ដែលក្នុងរយៈពេលជាច្រើនឆ្នាំបានចាប់ផ្តើមស្រុតខាងផ្នែកដែលប្រើប្រាស់ដោយរថយន្តកាំមីញ៉ុងផ្ទុកសម្ភារពេញៗជាច្រើនគ្រឿងបើកមកពីហៃហ្វុងឡើយ ។ ផ្លូវគមនាគមន៍ជាយុទ្ធសាស្ត្រទាំងអស់សុទ្ធតែត្រូវទ្រុឌទ្រោម ។ ពួកវិស្វករចិននិងរុស្ស៊ី បានខំប្រឹងប្រែងទល់ទ្រមហាសំណាង់នេះដោយគ្មានជោគជ័យ ។ វៀតណាមខ្លួនឯងបានរកឃើញដំណោះស្រាយមួយមានលក្ខណៈសាមញ្ញបំផុត ។ កសិករដែលរែកបន្លែផ្សេងៗនៅខាងចុងដងរែកឬស្សីមួយ បានផ្លាស់ប្តូរស្មានៅពេលដែលស្មាម្ខាងចាប់ផ្តើមចុករោយ ។ វៀតណាមគ្រាន់តែផ្លាស់ប្តូរច្បាប់នៃការធ្វើចរាចរនៅលើស្ពានប៉ុណ្ណោះជាការស្រេច : រថយន្តកាំមីញ៉ុងទាំងឡាយដែលផ្ទុកសម្ភារពេញៗមកពីហៃហ្វុងត្រូវតែប្រកាន់ផ្លូវខាងឆ្វេង ដែលពីមុនត្រូវប្រើប្រាស់ដោយរថយន្តកាំមីញ៉ុងទាំងឡាយដែលគ្មានដឹកអ្វីមកពីក្រុងហាណូយ ។ របៀបចាត់ការសាមញ្ញនេះ បានបង្ហាញឲ្យឃើញលទ្ធផលដូចបំណង ។

ទោះបីជាមានការបាត់បង់ជីវិតមនុស្ស ការបំផ្លិចបំផ្លាញនិងការឈឺចាប់ដោយសារសង្គ្រាមក៏ដោយ ក៏នៅតាមដងផ្លូវនានា ហ្វូងមនុស្សមិនសម្តែងឲ្យឃើញការស្អប់ខ្ពើមណាមួយ ដែលអាចមើលឃើញប្រឆាំងនឹងពួកអាមេរិកាំងឡើយ ។ អ្នកទទួលខុសត្រូវវៀតណាម ដែលអមដូនដំណើរ វូដខូក និងគណៈប្រតិភូគាត់រហូតដល់និវេសនដ្ឋានដែលដាក់ឲ្យគាត់ប្រើប្រាស់ដោយរដ្ឋាភិបាល ហាក់ដូចជាព្រមានឲ្យពួកគាត់ចាប់អារម្មណ៍ថា វានឹងមានគ្រោះថ្នាក់ណាស់ដែលចេញដើរដោយគ្មានអ្នកអមការពារ ។ ប្រជាជននៅតែមាន“កំហឹងយ៉ាងខ្លាំង” ប្រឆាំងនឹងពួកអាមេរិកាំងនៅឡើយ ។ ប៉ុន្តែ បន្ទាប់ពីការចាកចេញរបស់អ្នកជូនដំណើរបណ្តាសមាជិកនៃគណៈប្រតិភូបានចេញទៅក្រៅដោយលួចលាក់ ។ ដោយដើរកំសាន្តតាមដងផ្លូវនានា ពួកគេបានត្រូវធ្វើឲ្យងឿងឆ្ងល់ ដែលប្រទះឃើញមនុស្សម្នាមានលក្ខណៈរួសរាយរាក់ទាក់ និងគួរឲ្យចូលចិត្ត ។ នៅព្រឹកថ្ងៃបន្ទាប់ វូដខូក និងព្រឹទ្ធសមាជិក ម៉ៃ ម៉ាន់ហ្វៀល បានដើរក្រឡឹងជុំវិញបឹង ហ័ន គៀម-មានន័យថា ដាវដែលរកឃើញវិញ-ដែលនៅចំពីក្រោយនិវេសនដ្ឋានរបស់គាត់ ។ វូដខូក បានចាប់អារម្មណ៍នឹងរឿងព្រេងនិទានរបស់វៀតណាមទាក់ទងនឹងបឹង(និងដាវទិព្វរបស់បឹង) នេះណាស់ ដែលនាំឲ្យនឹកឃើញដល់រឿងព្រេងនិទានរបស់ព្រះមហាក្សត្រ អាធឿរដែរ ។ ក្នុងរបៀបនិទានរបស់វៀតណាមបានរៀបរាប់ថា ដាវ មួយបានផុសចេញពីបឹង ដែលអាចឲ្យវីរបុរសម្នាក់វាយឈ្នះពួកឈ្លានពានចិន ។ បន្ទាប់ពីជ័យជម្នះ ដាវ បានអណ្តែតឡើងទៅលើមេឃ ដោយបញ្ចេញពន្លឺរស្មីនៃមហិទ្ធិឫទ្ធិដ៏មហាស្ចារ្យរបស់ខ្លួនឡើងចាំងភ្នែកមុននឹងធ្លាក់ចុះមកវិញ ហើយនាំយកទៅក្រោមទឹកបឹងដោយអណ្តើកមួយក្បាល ។

មានភ្លៀងធ្លាក់យ៉ាងខ្លាំងកាលពីយប់មុន ដើមឈើទាំងឡាយនៅមាត់បឹងម្ខាងទៀត មានទឹកសន្សើមដក់ជាប់ស្លឹកឡើងសក្បុស ។ ពួកប្រជាជនវៀតណាមបានយកកន្លែងនោះដើម្បីហាត់ប្រាណនៅពេលព្រឹកតាមក្បាច់គុណតៃជិ (T'ai Chi) ។ ប្រជាជនដទៃទៀត អង្គុយនៅលើកៅអីវែងៗ សម្លឹងមើលផ្ទៃទឹកបឹង ។ វ៉ូដខូក បានឃើញក្មេងស្រីពីរនាក់ពីចម្ងាយដែលកំពុងអង្គុយប្រហោងពិនិត្យមើលរបស់ចម្លែកក្នុងថ្នុកមួយ ។ ក្មេងស្រីម្នាក់ក្នុងចំណោមក្មេងទាំងពីរបានសម្គាល់ឃើញពួកបរទេសភ្ញាម ហើយបានស្រែកផ្អើលគេផ្អើលឯង ។ ពួកនាងបានងើបឈរឡើងក្នុងចលនាព្រមគ្នា ។ វ៉ូដខូក តែងតែនិយាយរៀបរាប់ក្រោយមកថា ស្រីជំទង់ម្នាក់ក្នុងចំណោមស្រីជំទង់ជាច្រើន បានងាកខ្លួនបែរមករកគាត់ ។ នៅពេលនោះគាត់មើលឃើញថា មុខក្មេងស្រីដ៏ស្រស់ស្អាតនេះមានសម្លាកមួយគួរឲ្យខ្លាច ។ គាត់បាននិយាយដោយក្រៀមក្រំថា «នៅពេលនេះនាងនៅមិនទាន់ត្រូវធ្វើឲ្យខូចមុខមាត់ទេ ប៉ុន្តែ ប្រាកដណាស់ នាងនឹងមានមុខមាត់ស្អាតឡើងវិញនៅថ្ងៃក្រោយ» ។

អង្គុយទល់មុខ ផាន់ ហៀន នៅតុមួយ វ៉ូដខូក នឹកឃើញពីខបទូវហេតុ នៅពេលដែលគាត់ប្រឹងប្រែងបញ្ចប់ជំពូកដែលធ្វើឲ្យពិបាកចិត្តនេះ ។ កាលពីយប់មុំរិល គាត់មានការជួបគ្នាដែលមិនបានគិតទុកជាមុនមួយជាមួយរដ្ឋមន្ត្រីការបរទេស ង្វៀន ឌុយទ្រិញ ។ លោករដ្ឋមន្ត្រីបានធ្វើដំណើរមកដល់ខឿនខាងលើនៃនិវេសនដ្ឋានរបស់គាត់ដើម្បីសម្តែងការស្វាគមន៍ចំពោះគណៈប្រតិភូគាត់ ។ រឿងដែលនាំមកនូវការសោកពិសោធមួយមានលក្ខណៈផ្ទាល់ខ្លួនបន្តិចចំពោះការចាប់ផ្តើមពិភាក្សានេះ ដោយគាត់មានគំនិតប្រសិទ្ធពរដល់បុណ្យខួបកំណើតដ៏សប្បាយរីករាយមួយដល់លោកព្រឹទ្ធសមាជិក ម៉ៃ ម៉ាន់ហ្វៀល ផងដែរ ។ វ៉ូដខូក បានបញ្ជាក់ប្រាប់ ទ្រិញ ថា «ខ្ញុំសង្ឃឹមថានៅចុងបញ្ចប់នៃការស្នាក់អាស្រ័យរបស់យើង យើងនឹងបង្កើតឲ្យមានគ្រឹះនៃការខិតចូលជិតគ្នាមួយរវាងប្រទេសយើងទាំងពីរ» ។ ប៉ុន្តែ លោករដ្ឋមន្ត្រីការបរទេសដែលជាមនុស្សមាឌតូច បបូរមាត់ស្តើងដូចបបូរមាត់ត្រីនិងរបៀបមើលមុតជាទីបំផុតមានលក្ខណៈជាមនុស្សម៉ឺងម៉ាត់ នឹងកិច្ចការណាស់ ។ គាត់បានឆ្លើយតបនឹង វ៉ូដខូក យ៉ាងខ្លីថា ៖ «គ្មានលុយ គឺគ្មានបញ្ជីអ្នកបាត់ខ្លួនអ្វីទាំងអស់» ។ តាមពាក្យពេចន៍នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ពួកអាមេរិកាំងត្រូវយល់ព្រមសងការខូចខាតដោយសារសង្គ្រាម មុនពេលដែលវៀតណាមចាប់ផ្តើមគិតគូរពីការសន្យាផ្ទាល់របស់ពួកគេ និងស្វែងរកទាហានអាមេរិកាំងដែលបាត់ខ្លួន[៧] ។

វ៉ូដខូក ក៏ជាមនុស្សមិនទោរទន់ដូចគាត់ដែរ ។ គាត់ពោលអាងថា អំណឹះតទៅកិច្ចព្រមព្រៀងក្រុងប៉ារីសមានលក្ខណៈហួសសម័យទៅហើយ បញ្ហាអាចដោះស្រាយបានដោយឈរលើមូលដ្ឋានមនុស្សធម៌តែប៉ុណ្ណោះ ។ វ៉ូដខូក បានប្រកាសចំពោះលោក ទ្រិញ ថា ៖ «យើងមិនមែនមកពីចុងម្ខាងទៀតនៃពិភពលោកដើម្បីធ្វើសង្គ្រាមពាក្យសម្តីគ្មានបានប្រយោជន៍នោះទេ» ។ ការជួបគ្នាបានបញ្ចប់ទៅដោយការមិនចុះសម្រុងគ្នាមួយ ។

ការពិភាក្សាជាផ្លូវការរបស់គណៈប្រតិភូអាមេរិកាំងជាមួយលោក ផាន់ ហៀន មិនទំនងជាចាប់ផ្តើមដោយប្រផ្នូលល្អឡើយ ។ វ៉ូដខូក បានអានសេចក្តីថ្លែងការណ៍ដែលគាត់បានរៀបចំទាក់ទងទៅនឹងសេចក្តីសម្រេច

ផ្នែកមនុស្សធម៌មួយអំពីបញ្ហាទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ (M.I.A.: Missing in Action) ។ ចំណែកខាងលោក ហៀន វិញមិនបោះបង់សំណើរបស់គាត់ក្នុងការជួសជុលការខូចខាតដោយសារសង្គ្រាមឡើយ ។ ក្នុងការឈប់សម្រាកមួយភ្លែតជុំវិញ វ៉ូដខូក បានស្នើគូសន្ទនារបស់គាត់ភ្លាម ដើម្បីសុំជួបក្រៅផ្លូវការមួយតតួតែពីរនាក់ជាមួយអ្នកបកប្រែវៀតណាមម្នាក់ជាសាក្សី ។ ដោយពិត លោក វ៉ូដខូក និង ម៉ាន់ហៀល ទើបនឹងប្រកាន់យកការសម្រេចចិត្តរបស់គាត់អំបាញ់មិញនេះឯង ៖ បើចង់ធ្វើឲ្យលែងរអែងចិត្តគ្នា គឺមានតែជួបចរចាតតួតែពីរនាក់ដោយសេចក្ដីស្មោះត្រង់ទៅវិញទៅមកប៉ុណ្ណោះ ។ ការជួបគ្នានឹងនៅតែក្រៅផ្លូវការជានិច្ច ។ វ៉ូដខូក បានពន្យល់ប្រាប់អ្នកបកប្រែថា ៖ «បើគ្មានអ្វីចេញរួចទេ យើងត្រូវធ្វើហាក់ដូចជាការជួបគ្នានេះមិនដែលកើតមានសោះ» ។ ដោយជួបគ្នាតតួជាមួយ ផាន់ ហៀន លោក វ៉ូដខូក បានចាប់និយាយត្រង់ៗតែម្ដង ។ គាត់បានបញ្ជាក់ថា គណៈប្រតិភូដែលបញ្ជូនមកដោយលោកប្រធានាធិបតី ខាធ័រ នេះ បានរួមបង្កសម្រាប់ប្រទេសវៀតណាមនូវសំណាងមួយដែលគេគ្មានសង្ឃឹមទុក ដើម្បីជំរុញដំណើរនៃការធ្វើឲ្យមានប្រក្រតីភាពមួយ ៖ «លោកនឹងមិនជួបជាថ្មីនូវគណៈប្រតិភូមួយ ដែលប្រកបដោយសមាសភាពជាទីពេញចិត្តដូចជាពេលនេះទេ» ។ ប្រធានគណៈប្រតិភូអាមេរិកាំងបានរំលឹកប្រាប់ ផាន់ ហៀន ជាសម្ងាត់ថា ៖ «លោកធ្លាប់ដឹងជំហររបស់ខ្ញុំក្នុងពេលសង្គ្រាមហើយ ។ លោកក៏ដឹងពីជំហររបស់ ស្ទាល យ៉ូស និង ម៉ារីយ៉ាន អ៊ីដែលម៉ាន ដែរ ។ មនុស្សតែម្នាក់គត់ [ក្នុងចំណោមគ្នាយើង] ដែលមានឥរិយាបថខុសពីគេឯងគឺសមាជិកសភា សុននី ម៉ុងហ្គូម៉េរី ប៉ុន្តែ យ៉ាងហោចណាស់ លោកក៏ដឹងយ៉ាងពិតប្រាកដថា លោកត្រូវសម្រេចបែបណាក្នុងរឿងនេះហើយ ។ បើយើងនៅតែបរាជ័យ លោកអាចនិយាយពាក្យលាចាកគ្នាដោយគួរសមចំពោះការធ្វើឲ្យមានប្រក្រតីភាពសម្រាប់ដប់ប្រាំឆ្នាំខាងមុខទៀត» ។ គាត់បានបន្ថែមថា នៅពេលនោះ វាជាឱកាសប្រសើរមួយដើម្បីលុបបំបាត់សោកនាដកម្មទាំងឡាយដែលទើបមានថ្មីៗ ។ នៅព្រឹកនោះ វ៉ូដខូក បាននិយាយប្រាប់ ហៀន ពីការរំជួលចិត្ត របស់គាត់ ពីសម្ភាកលើផ្ទៃមុខរបស់ក្មេងស្រីតូចម្នាក់ ដែលនេះជាសម្ភាកមួយទំនងជាបង្កឡើងដោយគ្រាប់បែកអាមេរិកាំងហើយ ។ «យើងត្រូវសម្រេចចិត្តនៅព្រឹកនេះ បើសិនជាប្រភេទនៃរឿងរ៉ាវនេះអាចកើតមានម្ដងទៀត» ។ នៅពេលកំពុងនិយាយ វ៉ូដខូក បានឃើញទឹកភ្នែកហូរកាត់ផ្ទៃថ្ពាល់របស់អ្នកបកប្រែដែលធ្វើឲ្យគាត់មានការងឿងឆ្ងល់ដែរ ។ ហៀន គ្រាន់តែនិយាយប៉ុណ្ណោះថា «លោកមានលក្ខណៈស្មោះត្រង់ណាស់ ។ តើត្រូវធ្វើ អ្វីទៀត? ត្រឡប់ទៅតុចរចា?» ។ វ៉ូដខូក ដែលពោរពេញដោយសេចក្ដីសង្ឃឹមបានឆ្លើយតបថា គឺបញ្ហានេះឯងដែលយើងស្ថិតនៅទីនេះ[៣] ។

ពេលត្រឡប់មកតុចរចាដែលក្រាលដោយក្រណាត់ស្ដើងមានសាច់ម៉ដ្ឋពណ៌បៃតង ហៀន បាន រង់ចាំឲ្យគេនាំយកវ៉ាលិសតូចមួយពីក្រសួងការបរទេសមកប្រគល់ឲ្យគាត់ ។ គាត់ដកចេញសំណុំឯកសារចំនួនបីពីវ៉ាលិស ៖ «ល្អ! មានបញ្ហាបីដែលត្រូវព្រមព្រៀងគ្នា ៖ បញ្ហាទាហានបាត់ខ្លួន ការធ្វើឲ្យមានប្រក្រតីភាព និងការជួសជុលផ្នែកសេដ្ឋកិច្ច ។ នេះជាបញ្ហាដាច់ដោយឡែកពីគ្នា ប៉ុន្តែ វាជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ» ។ នេះ

ហើយជាចំណុចនៃការពិចារណាដែល វ៉ូដខូក បម្រុងខ្លួនទទួលយល់ស្របទាំងអស់ ។ ហៀន បានប្រកាសថា គណៈប្រតិភូអាចនាំទៅមាតុភូមិវិញនូវសាកសពទាហានបាត់ខ្លួនមួយឈុតដំបូង ចំនួនដប់ពីរនាក់ដែលរកឃើញអត្តសញ្ញាណដោយវៀតណាម ។ ហៀន ក៏ប្រាប់ព័ត៌មាន វ៉ូដខូក ថា ការិយាល័យពិសេសមួយបានត្រូវបង្កើតឡើងដើម្បីប្រមូលព័ត៌មានផ្សេងៗស្ដីពីទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ និងប្រមូលអដ្ឋិធាតុអ្នកទាំងនោះដាយថាហេតុ ។ ហៀន បានបញ្ជាក់ថែមទៀតថា : «ការបើអ៊ីៗអាចធ្វើបាន ប្រទេសវៀតណាមនឹងផ្ដល់ដំណឹងដល់សហរដ្ឋអាមេរិកនូវព័ត៌មានផ្សេងៗដែលអាចប្រើប្រាស់បាន និងប្រគល់ឲ្យវិញនូវសាកសពទាំងឡាយដែលរកឃើញនៅពេលក្រោយ ។ ប៉ុន្ដែ ដោយហេតុថា ការធ្វើសហប្រតិបត្តិការរបស់វៀតណាមស្ដីពីបញ្ហាទាហានបាត់ខ្លួនត្រូវតែពិនិត្យមើលក្រោមទស្សនៈមនុស្សធម៌នោះ ហៀន បានសង្កត់បញ្ជាក់ថា វាជាការត្រឹមត្រូវដែលសហរដ្ឋអាមេរិកត្រូវបង្ហាញឲ្យឃើញលក្ខណៈមនុស្សធម៌ដូចគ្នាដែរ ដោយជួសជុលការបំផ្លិចបំផ្លាញខ្លះៗដែលកើតឡើងក្នុងរយៈពេលមានសង្គ្រាម ។ ដោយគិតទៅដល់ភាពមានទៅមានមក ក្រុងវ៉ាស៊ីនតោនត្រូវតែធ្វើអ្វីមុនគេបន្ដិចបន្តួចជាដរាប ។ វ៉ូដខូក បាននិយាយនឹង ហៀន ថា លោកប្រហែលជាចាត់ទុកជំនួយដែលលោកស្នើសុំយើងជា«ការជំពាក់គុណមួយ ដែលលោកត្រូវតែបំពេញទៅតាមមនសិការនិងសតិនៃការទទួលខុសត្រូវរបស់លោកហើយមើលទៅ» ។ ចំពោះលក្ខណៈផ្សេងៗដែលអាចទទួលបានជំនួយនេះ ហៀន បានបញ្ជាក់ប្រាប់ វ៉ូដខូក ថា ប្រទេសវៀតណាមបើកចំហចំពោះសំណើទាំងអស់[៤] ។

វ៉ូដខូក វាយតម្លៃថា នេះគឺជាជំហរមិនហួសហេតុមួយ ។ ការជួសជុលការខូចខាតដោយសារសង្គ្រាមលែងត្រូវចងភ្ជាប់នឹងខទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីសទៀតហើយ ។ អ្នកចរចាអាមេរិកាំងបានប្រកាសថា : «យើងមានបំណងជំរុញឲ្យពួកគេធ្វើសហប្រតិបត្តិការសម្រាប់ហេតុផល ផ្នែកមនុស្សធម៌ ហើយក្នុងហេតុផលប្រភេទដូចគ្នានេះ ដែលតម្រូវឲ្យយើងជួយប្រជាជនវៀតណាម ស្ដារប្រទេសជាតិរបស់ខ្លួនឡើងវិញ» ។

ពីរខែក្រោយមក ផាន់ ហៀន បានអះអាងបន្ថែមប្រាប់ខ្ញុំ (អ្នកនិពន្ធ) ថា វ៉ូដខូក បានយល់ព្រមជដែកពិភាក្សាពីយថាភាពនៃជំនួយមនុស្សធម៌អាមេរិកាំងមួយចំពោះប្រទេសវៀតណាម ។ តាមគេអះអាងដូចដែលលោក វ៉ូដខូក បញ្ជាក់ពីរឿងនេះដែរថា ទោះបីជាជំនួយដោយផ្ទាល់ទាំងអស់ត្រូវបដិសេធក៏ដោយ ក៏លោកប្រធានាធិបតីដែលមានអំណាចដ៏ទូលំទូលាយ អាចជួយប្រទេសវៀតណាមបានរួចទើបសុំការអនុម័តយល់ព្រមពីសភាជាន់ទាបជាក្រោយ ។

ហៀន បានបញ្ជាក់ថា ទន្ទឹមនឹងនេះ ប្រទេសវៀតណាមមានបំណងរៀបចំឲ្យមានទំនាក់ទំនងការទូតឡើងវិញជាមួយសហរដ្ឋអាមេរិកដែរ ប៉ុន្ដែ ការប្រឹងប្រែងរបស់គាត់ក្នុងន័យនេះ គឺសម្រេចនៅត្រង់ឆន្ទៈរបស់អាមេរិកាំងដែលត្រូវ«បោះបង់ចោលកំហុសផ្នែកនយោបាយកន្លងមក» និងជាពិសេសដកបម្រាមផ្នែកពាណិជ្ជកម្ម និង

ឆ្នោតវេតូរបស់ខ្លួនមិនឲ្យប្រទេសវៀតណាមចូលអង្គការសហប្រជាជាតិ ។

គណៈប្រតិភូរបស់អាមេរិកាំង គោងតែទៅចូលរួមសម្តែងការគួរសមនឹងនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ថែមទៀត ដែលជាកាតព្វកិច្ចជាផ្លូវការចុងក្រោយមួយមុនការចេញដំណើររបស់គាត់ ។ នៅពេលដែលគណៈប្រតិភូឈានជើងចូលក្នុងបរិវេណវិមានប្រធានាធិបតី ផាំ វ៉ាន់ដុង ដែលជា«ចាស់ទុំរបស់បដិវត្តន៍»បាននៅរង់ចាំគណៈប្រតិភូក្រោមរោងថែវទទឹងខ្លោងទ្វារមួយ ។ ថ្ពាសទូលាយ សក់ល្បាយអាចម៍ខ្លាសិតទៅក្រោយ បបូរមាត់ស្តើងហើយក្របួច និងអាវពណ៌ប្រផេះរបស់គាត់ បានធ្វើឲ្យគាត់មានបុកពាជា មនុស្សថ្លៃថ្នូរនិងស្រគត់ស្រគំម្នាក់ ។ ប៉ុន្តែ នៅព្រឹកនេះ ស្នាមញញឹមមួយបានធ្វើឲ្យការសម្លឹងមើលរបស់គាត់មានពន្លឺស្រស់ថ្លា ។

បន្ទាប់ពីការចាប់រលាក់ដៃដ៏រាក់ទាក់ ដុង បានអញ្ជើញភ្ញៀវរបស់គាត់ចូលក្នុងបន្ទប់ទទួលភ្ញៀវ ។ ក្រោមការសម្លឹងមើលពីរូបសំណាកពាក់កណ្តាលខ្លួនរបស់សពប្រធាន ហូ ជីមិញ ដែលលេចធ្លោឡើង ក្នុងបន្ទប់ វូដខូក បានអង្គុយលើកៅអីវែងមួយក្បែរ ដុង ជា«សត្រូវ»កាលពីពេលកន្លងមកថ្មីៗ ។ អ្នកទាំងពីរបានសើចញញឹមពីមុខកែវម៉ាស៊ីនថតជាច្រើនរបស់អ្នកកាសែត ។ សម្រាប់វៀតណាមទីបំផុតនេះ គឺម៉ោងនៃជ័យជម្នះ ។ បេសកជនរបស់មហាអំណាចសត្រូវដែលចាញ់សង្គ្រាម បានមកទទូចសុំរៀបចំទំនាក់ទំនងរវាងប្រទេសទាំងពីរជាថ្មី ។ សហរដ្ឋអាមេរិកនឹងក្លាយទៅជាសត្រូវដូចប្រទេសបារាំងដែលចាញ់ ដូចគ្នា កាលពីពេលកន្លងមកមិនយូរប៉ុន្មាននេះទៅជាដៃគូដែលមានឯកសិទ្ធិមែនឬ? ។ ក្រុងហាណូយបានបណ្តោយខ្លួនឲ្យលុកលុយដោយមនោសញ្ចេតនាសប្បាយអណ្តែតអណ្តូងមួយ ដែលពិបាកទប់ ។ ដុង បាននិយាយទៅកាន់ វូដខូក ថា ៖ «ខ្ញុំជឿថា បំណងរបស់លោកប្រធានាធិបតី ខាធ័រ (គឺ) ផ្តើមជជែកពិភាក្សាពីការទាស់ទែងគ្នារបស់យើងជាមួយលក្ខណៈចិត្តគំនិតថ្មីមួយ ។ បើសិនជាអ៊ីចឹងមែនយើងត្រូវតែជម្នះឲ្យបាន» ។ វូដខូក បានបង្ហាញភ័ស្តុតាងពីលក្ខណៈនៃចិត្តគំនិតថ្មីនេះដោយថ្លែងសរសើរពី «សេចក្តីថ្លៃថ្នូរ និងសេចក្តីក្លាហាន»របស់ប្រជាជនវៀតណាម ។ គាត់បានថ្លែងថា «តាំងពីយូរយារណាស់មកហើយ ព្រឹត្តិការណ៍ប្រកបដោយទុក្ខសោកទាំងឡាយបានធ្វើឲ្យប្រទេសយើងទាំងពីរឃ្លាតចេញពីគ្នា»[៥] ។ ក្នុងឱកាសសន្និសីទកាសែតមួយ ដែលគាត់បានធ្វើបន្តិចក្រោយមកនៅទីក្រុងហាណូយ គាត់បានបញ្ជាក់ថា ការសន្ទនាប្រកបដោយលក្ខណៈវិជ្ជមាននិងស្ថាបនានេះ បានរួមបង្កជា«ភាពចាប់ផ្តើមនៃដំណើរមួយសំដៅធ្វើឲ្យទៅជាពិតនូវទស្សនវិស័យនៃការធ្វើឲ្យទំនាក់ទំនងអាមេរិក-វៀតណាមមានប្រក្រតីភាពឡើងវិញ» ។

បរិយាកាសក្នុងរយៈពីរថ្ងៃនេះមានលក្ខណៈប្រកបដោយមិត្តភាពមែនទែន ដែលលោក វូដខូក ជឿថាអាចសុំពីពួកម្ចាស់ផ្ទះរបស់គាត់នូវការយោគយល់មួយដែលមានលក្ខណៈសាមញ្ញបន្តិច ។ នៅពេលដែលគណៈប្រតិភូអាមេរិកាំងចូលរួមក្នុងការលើកមឈូសដែកមានផ្ទុកអដ្ឋិធាតុទាហានអាមេរិកដាក់ក្នុងយន្តហោះមួយ វូដខូក បានទាញ ផាន់ ហៀន ទៅឆ្ងាយពីគេ ហើយបានបង្ហាញនូវពាក្យសុំមួយក្នុងនាមនៃសមាជិកម្នាក់របស់

*គណៈប្រតិភូគាត់ គឺលោកវរសេនីយ៍ឯក ប៉ូល ម៉ាធ័រ (Paul Mather) ព្រោះថាគាត់បានដឹងតាមរយៈអន្តរក្សរបស់ ខេនឃ៊ីន ថា ស្រីគូដណ្តឹងវៀតណាមរបស់ ម៉ាធ័រ ពុំអាចចាកចេញពីក្រុងព្រៃនគរ នៅឆ្នាំ១៩៧៥ទេ ។ តើគេអាចធ្វើឲ្យអ្នកទាំងពីរជួបជុំគ្នាបានទេ? ។ ហៀន បានកត់ទុកហើយនិយាយថា គាត់នឹងពិនិត្យមើលនូវអ្វីដែលគាត់អាចនឹងធ្វើបាន ។ ពីរ-បីខែក្រោយមក នាងក្រមុំវៀតណាមបានចាកចេញពីប្រទេសវៀតណាម ហើយបានរៀបការនឹង ម៉ាធ័រ ។ បើទុកជាមានការសប្បាយអណ្តែតអណ្តូងដែលបង្កឡើងដោយទស្សនវិស័យនៃការខិតចូលជិតគ្នាមួយរវាងប្រទេសទាំងពីរក៏ដោយ ក៏ការជួបជុំរបស់ ម៉ាធ័រ និងស្រីគូដណ្តឹងគាត់ដែលអស់សង្ឃឹមទៅហើយ និងការបញ្ជូនមកមាតុភូមិវិញនូវអដ្ឋិធាតុទាហានអាមេរិកាំងបាត់ខ្លួនដប់ពីរនាក់ គឺប្រហែលជាលទ្ធផលស្ថិតស្ថេរយូរអង្វែងតែមួយគត់នៃដំណើររបស់ វូដខូក ក្នុងទីបំផុតហើយមើលទៅ ។*

## **រង់ចាំភ្លៀងដុល្លារ**

*នៅនិទាឃរដូវឆ្នាំ១៩៧៥ ទូរទស្សន៍របស់អាមេរិកាំងបានចាក់ផ្សាយនូវរូបភាពស្តីពីការរត់គេចខ្លួន ដ៏កោលាហលនៃហ្វូងអ្នកភៀសខ្លួន និងពួកបុគ្គលិកអាមេរិកាំងនៅមុខការរុលចូលរបស់កងទ័ពកុម្មុយនីស្តមកកាន់ក្រុងព្រៃនគរ ។ មិនយូរប៉ុន្មានក្រោយមក ក្រុងវ៉ាស៊ីនតោនហាក់ដូចជាត្រូវធ្វើឲ្យភ្លឹកភ្លាំងស្មារតីភ្លាមៗចំពោះអ្វីៗទាំងអស់ដែលទាក់ទងនឹងឥណ្ឌូចិន ។ ការខ្ទប់លុយចំនួន១៥០លានដុល្លារដែលវៀតណាមមាននៅសហរដ្ឋអាមេរិក ការហាមឃាត់ផ្នែកសេដ្ឋកិច្ចយ៉ាងគំហុកដែលបញ្ញតិទៅលើប្រទេសកម្ពុជា និងវៀតណាម ការរំដើបរំជួលមួយរយៈខ្លីដោយសាររឿងវ៉ាវនាវាម៉ាយ៉ាហ្គេនៅខែឧសភា បន្ទាប់ពីនោះមក គឺលែងមានរឿងអ្វីទាំងអស់ ៖ ឥណ្ឌូចិនទើបនឹងលិចលង់យ៉ាងជ្រៅនៅក្រោមភាពមិនអើពើរបស់ពួកអាមេរិកាំង[៦] ។*

*ការធ្វើឲ្យធុញទ្រាន់និងភាពមិនមានផលប្រយោជន៍របស់សហរដ្ឋអាមេរិក ស្ទើរតែមានទំហំផ្ទុយនឹងការអន្ទះអន្ទែងរបស់វៀតណាមក្នុងការរៀបចំទំនាក់ទំនងឡើងវិញជាមួយគូសត្រូវកាលពីម្សិលរបស់គេ ។ តាំងពីមុនការបញ្ចប់នៃសង្គ្រាម ក្រុងហាណូយជឿជាក់ថា ការពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយលោកខាងលិច ជាពិសេសជាមួយសហរដ្ឋអាមេរិក គឺជាកិច្ចការដែលត្រូវធ្វើមុនគេដោយខានមិនបានសម្រាប់ការស្តារប្រទេសឡើងវិញ ។*

*ប៉ុន្មានថ្ងៃបន្ទាប់ពីជ័យជម្នះរបស់កុម្មុយនីស្តនៅទីក្រុងព្រៃនគរ ខ្ញុំ(អ្នកនិពន្ធ) បានសួរកងទ័ពម្នាក់ដែលកំពុងយាមល្បាតនៅខាងមុខស្ថានទូតអាមេរិកាំងថា ៖ ហេតុអ្វីបានជាមិនឃើញទង់ជ័យរបស់«រណសិរ្សរំដោះជាតិ» (F.N.L) បង្ហូតឡើងនៅលើអគារដូចនៅលើស្ថានទូតលោកខាងលិចឯទៀតៗដែល«រំដោះ»បានអ៊ីចឹង? «គេមិនអនុញ្ញាតិឲ្យយើងបង្ហូតឡើងទេ» ។ នេះពុំមែនជាការភ្លេចមួយរបស់អ្នកធ្វើការក្នុងការិយាល័យឡើយ ។ ប្រទេសវៀតណាមសប្បាយលោតកញ្ឆេងដែលបានឈ្នះសង្គ្រាម ប៉ុន្តែ គេចង់បានជាពិសេសសន្តិភាពទៀត ។ នៅខែកក្កដា ឆ្នាំ១៩៧៥ នាទីក្រុងហាណូយ ខ្ញុំបានសាកសួរលោក វ៉ាង ទុង និពន្ធនាយកកាសែតញ៉ានហ្សិនជាកាសែត*

ប្រចាំថ្ងៃរបស់បក្ស នៅពេលដែលគាត់គិតចង់ចុះផ្សាយ“ឯកសារក្រុងព្រៃនគរ” ។ នេះជាបរិមាណឯកសារសម្ងាត់របស់អាមេរិកាំងដ៏សម្បើមដែលរឹបអូសបានក្នុងរដ្ឋធានីវៀតណាមខាងត្បូង ក្នុងចំណោមនោះមានឯកសារថតចម្លងដាក់ខ្សែអាត់ ការរៀបរាប់ពីប្រតិបត្តិការទាំងអស់របស់សេ.អ៊ី.អា.នៅប្រទេសវៀតណាមផង ។ ឯកសារទាំងនេះត្រូវបោះបង់ចោលដោយក្រុមមនុស្សនៃការិយាល័យ C.I.O. (Central Intelligence Office) របស់វៀតណាមដែលមានលក្ខណៈដូចគ្នានឹង C.I.A. ដែរ ។ ទុង ជាមនុស្សប្រាកដប្រជាណាស់ ៖ ប្រទេសវៀតណាមមិនមានចេតនារិះគន់អំពីអតីតកាល និងរពឹសដៃយកដែកទៅរុកដំបៅរបស់អាមេរិកាំងឡើយ ។ វៀតណាមនៅចងចាំទើសតឡូវនូវសម្ដីសន្ទនារបស់ ហូ ជីមិញ កាលពីឆ្នាំ១៩៥៤ ។ បន្ទាប់ពីបរាជ័យរបស់បារាំងនៅ ឌៀន បៀន ភូ (Dien Bien Phu) ហូ បានបង្គាប់បញ្ជាកុំឲ្យនិពន្ធនាយកកាសែតប្រចាំថ្ងៃរបស់បក្សចុះផ្សាយអ្វីដែលបង្ហាញឲ្យឃើញជំនឿជឿជាក់ហួសហេតុចំពោះ ជ័យជម្នះដែលទទួលបាន ។ ហូ បានពន្យល់ថា “ក្នុងដំណាក់កាលថ្មីដែលផ្ដើមឡើងនៅពេលខាងមុខ យើងត្រូវការមិត្តភាពនិងសហប្រតិបត្តិការរបស់ប្រទេសបារាំង” ។

នៅពេលនោះ ទុង បានទុកឲ្យខ្ញុំនៅតែមិនដឹងពីមូលហេតុប្រាកដប្រជាដែលមានភាពជាដើមហេតុនៃភាពរឹងត្អឹងរបស់វៀតណាមក្នុងការបង្កើតទំនាក់ទំនងដោយស្មោះត្រង់ជាមួយសហរដ្ឋអាមេរិក គឺសេចក្ដីសង្ឃឹមទទួលបានការបរិច្ចាគប្រាក់ចំនួន៤.៧០០លានដុល្លារ (ក្រោមទម្រង់ជាជំនួយសេដ្ឋកិច្ច) ដែលសន្យាជាសម្ងាត់ដោយលោកប្រធានាធិបតី និចសុន ក្នុងឱកាសនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសឡើយ ។ ទម្រាំតែរដ្ឋាភិបាលអាមេរិកមានឆន្ទៈគោរពការសន្យារបស់ខ្លួន ប្រទេសវៀតណាមបានចាប់ផ្ដើមចែចង់បណ្ដាធនាគារិកនិងអ្នកជំនួញរបស់សហរដ្ឋអាមេរិកស្រេចទៅហើយ ។ មិនដល់ពីរខែក្រោយការដួលរលំនៃទីក្រុងព្រៃនគរផង បណ្ដាអ្នកតំណាងរបស់ធនាគារអាមេរិក (Bank of America) និងធនាគារ First National City Bank បានត្រូវអញ្ជើញមកកាន់ប្រទេសវៀតណាម ដើម្បីសិក្សាពីមធ្យោបាយផ្សេងៗក្នុងការរៀបចំទំនាក់ទំនងផ្នែកពាណិជ្ជកម្មនិងហិរញ្ញវត្ថុឡើងវិញ ។ ក្នុងពេលជាមួយគ្នានោះ វៀតណាមបានប្រាប់ឲ្យបណ្ដាក្រុមហ៊ុនប្រេង ដែលកាលពីអតីតកាលធ្លាប់រុករកប្រេងនៅក្នុងដែនទឹករបស់ខ្លួនដឹងថា វៀតណាមនឹងស្វាគមន៍ក្រុមហ៊ុនទាំងនោះជាថ្មី ។

នៅថ្ងៃទី៣ ខែមិថុនា គឺមួយខែតែប៉ុណ្ណោះបន្ទាប់ពីការដួលរលំនៃទីក្រុងព្រៃនគរ ផាំ វ៉ាន់ដុង បានឡើងនិយាយនៅវេទិការដ្ឋសភាជាតិដើម្បីជំរុញជាខឡារិកឲ្យសហរដ្ឋអាមេរិកធ្វើឲ្យទំនាក់ទំនងរបស់ខ្លួន ជាមួយប្រទេសវៀតណាមមានប្រក្រតីភាពឡើងវិញ និងផ្ដល់នូវជំនួយមួយសម្រាប់ការស្ដាបនាប្រទេសរបស់គាត់ជាថ្មីដូចដែលសហរដ្ឋអាមេរិកធ្លាប់បានសន្យានៅទីក្រុងប៉ារីស ។ ការអំពាវនាវនេះ ត្រូវបានប្រានចោលដោយក្រុងវ៉ាស៊ីនតោន ។ វ៉ាង ទុង បានប្រកាសប្រាប់ភ្ញៀវអាមេរិកាំងមួយក្រុមនៅខែវិច្ឆិកា ឆ្នាំ១៩៧៥ថា ៖ “នៅប្រទេសវៀតណាមវាជាប្រពៃណីទៅហើយ ក្នុងឱកាសនៃពិធីបុណ្យផ្សេងៗ ដែលគេរៀបចំការប្រកួតបោក

ចំបាប់ ហើយនៅក្រោយចប់ការប្រកួតគឺគូប្រឆាំងទាំងពីរបានចាប់ឱបគ្នា ។ ប្រទេសវៀតណាមបានប្រុងប្រៀបធ្វើដូចគ្នានេះដែរ តែប្រធានាធិបតី ហ៊្វរដ៍ មិនព្រម» ។

នៅខែដដែល លោក ហង់រី គីស៊្សីងហ្គ័រ បានបង្ហាញនូវកាយវិការមួយដែលបណ្ដាលឲ្យមានសេចក្ដីសង្ឃឹមខ្លះៗ ។ ឆ្លើយតបទៅនឹងការដោះលែងដោយក្រុងហាណូយនូវជនជាតិអាមេរិកាំងប្រាំបួននាក់ដែលចាប់បាននៅវៀតណាមខាងត្បូងកាលពីខែមីនា រដ្ឋមន្ត្រីការបរទេសអាមេរិកាំងបានអនុញ្ញាតឲ្យអង្គការសាសនានិងមនុស្សធម៌ជាច្រើនបញ្ជូនជំនួយមកប្រទេសវៀតណាម ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា លោក ហង់រី គីស៊្សុងហ្គ័រ បានប្រកាសថា ទំនាក់ទំនងរបស់សហរដ្ឋអាមេរិកជាមួយប្រទេសវៀតណាម «នឹងពុំនៅតែក្រោមចំណុះអតីតកាលទេ» ។ សហរដ្ឋអាមេរិកបានប្រកាសខ្លួនត្រៀមឆ្លើយតបទៅនឹងការសម្ដែងឲ្យឃើញសុឆន្ទៈទាំងអស់«បើសិនជាបណ្ដារដ្ឋាភិបាលនៅឥណ្ឌូចិនបង្ហាញឲ្យឃើញលក្ខណៈ«យោគយល់»ចំពោះការព្រួយបារម្ភរបស់ពួកអាមេរិកាំងនិងបណ្ដាប្រទេសជិតខាងខ្លួននៅអាស៊ី ហើយបើសិនជាវៀតណាមប្រកាន់យកឥរិយាបថ«ស្ថាបនា»មួយស្ដីពីបញ្ហាធ្វើជំរឿនទាហានអាមេរិកាំងបាត់ខ្លួនចំនួន៨៣២នាក់ និងការធ្វើមាតុភូមិនិវត្តន៍នូវអដ្ឋិធាតុរបស់ពួកគេ សហរដ្ឋអាមេរិកក៏ត្រៀមខ្លួនធ្វើដូចគ្នាទៅវិញទៅមកដែរ» ។

វិចារណកថាមួយរបស់កាសែតញូវយ៉កថែម បានវាយតម្លៃដោយខ្លួនឯងថា ៖ «នេះហើយគឺការចាប់ផ្ដើមប្រកាន់យកឥរិយាបថដ៏ទន់ភ្លន់មួយគួរឲ្យសរសើរយ៉ាងខ្លាំងចំពោះបណ្ដារបបកុម្មុយនីស្តនៅឥណ្ឌូចិន ប៉ុន្តែ វាពិតជានៅសល់ផ្លូវដែលត្រូវដើរតទៅទៀត»[៧] ។ អត្ថបទបានឲ្យយោបល់ថា សហរដ្ឋអាមេរិកត្រូវបោះបង់ល្បែងបោះឆ្នោតវេតូរបស់ខ្លួនដូចដែលខ្លួនធ្លាប់ធ្វើនៅខែសីហា ដើម្បីហាមឃាត់ការទទួលប្រទេសវៀតណាមឲ្យចូលអង្គការសហប្រជាជាតិទៅ ។

ប៉ុន្តែ ក្រុងវ៉ាស៊ីនតោនមានបំណងបំភ្លេចប្រទេសវៀតណាមចោល ថែមទាំងមិនអភ័យទោសឲ្យទៀត ។ ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីខិតកាន់តែជិតមកដល់ ។ សម្រាប់ការបោះឆ្នោតរើសបេក្ខភាពដំបូង លោក ហ្សេរ៉ាល់ ហ៊្វរដ៍ ត្រូវតទល់នឹងគូប្រជែងនិយមស្ដាំគឺលោក រ៉ូណាល់ រីហ្គេន ។ ការគិតពីសេចក្ដីសង្ឃឹមដែលចង់ឲ្យទទួលយកនូវអ្វីៗដែលជាអាទិភាពរបស់វៀតណាម ទាក់ទងទៅនឹងការរាំងខ្ទប់ផ្នែកសេដ្ឋកិច្ចរបស់អាមេរិកាំងគឺស្ទើរតែគ្មានទាំងស្រុង ។ នៅពាក់កណ្ដាលការជ្រើសរើសបេក្ខភាពសម្រាប់តំណែងប្រធានាធិបតី គីស៊្សីងហ្គ័របានពង្រឹងជំហររបស់អាមេរិកាំងក្រោយពីបានពិចារណារួចជាស្រេច ។ គាត់បានឲ្យដឹងថា ការបញ្ជូនមកមាតុភូមិវិញនូវអដ្ឋិធាតុទាហានបាត់ខ្លួន ក៏ដូចការធ្វើជំរឿនទាហានបាត់ខ្លួនដែលរកមិនឃើញដាន «គឺជាអ្វីៗដែលត្រូវធ្វើមុនគេដាច់ខាត បើមិនអ៊ីចឹងទេ សហរដ្ឋអាមេរិកមិនអាចប្រមើលមើលការធ្វើឲ្យមានប្រក្រតីភាពមួយឡើយ» ។ គីស៊្សីងហ្គ័រ បានប្រកាសជាឯកជនផងដែរនៅមុខគណៈកម្មការទទួលបន្ទុកបញ្ហាមនុស្សបាត់ខ្លួននៅអាស៊ីអាគ្នេយ៍ថា វាពិបាកនឹងបង្ខំឲ្យក្រុងហាណូយបោះបង់សំណើសុំជំនួយរបស់ខ្លួនណាស់ ដរាបណាបញ្ហាស្ដីពី

ទាហានបាត់ខ្លួននៅតែដោះស្រាយមិនទាន់ស្រេចបាច់នោះ ។ គាត់បានដៅថា ៖ «បើសិនជាពុំមានទាហានបាត់ខ្លួនទេ ពួកគេនឹងត្រូវបង្ខំឲ្យយល់ស្របតាមជំហររបស់យើង ។ ប៉ុន្តែពេលណាយើងបង្ហាញការច្រាស់ច្រាល់របស់យើងចំពោះរឿងរបស់គេ ពេលនោះពួកគេទៅជាកាន់តែរឹងរូសឡើង»[៨] ។

ប៉ុន្តែ ក្រុងហាណូយ មិនដែលបោះបង់សេចក្ដីសង្ឃឹមទទួលបានដុល្លារក្នុងលំអាននៃការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតឡើយ ។ ដោយបញ្ជាក់អះអាងថា ពួកគេពុំអាចគោរពមាត្រានៃកិច្ចព្រមព្រៀងក្រុងប៉ារីសទាក់ទងនឹងការធ្វើជំរឿនទាហានអាមេរិកាំងបាត់ខ្លួនក្នុងការប្រយុទ្ធទេ ដរាបណាសហរដ្ឋអាមេរិកមិនប្រកាន់ពាក្យសន្យារបស់ខ្លួនក្នុងការផ្ដល់ជំនួយផ្នែកសេដ្ឋកិច្ចមួយ ប៉ុន្តែ នៅខែធ្នូ ឆ្នាំ១៩៧៥ ពួកវៀតណាមបានអនុញ្ញាតឲ្យមានការប្រគល់សាកសពទាហានអាមេរិកាំងបីនាក់ ។ ពួកគេក៏បានប្រគល់ផងដែរនូវសាកសពទាហានម៉ារីនចុងក្រោយពីរនាក់ដែលត្រូវសម្លាប់នៅភាគខាងត្បូង និងប្រគល់ឈ្មោះទាហានបាត់ខ្លួនដប់ពីរនាក់ថែមទៀត ។ ការគន់គូររបស់ក្រុងហាណូយដែលមានសភាពសុទិដ្ឋិនិយមបន្តិចគឺថា ក្រុងវ៉ាស៊ីនតោនត្រូវតបស្នងមកវិញឲ្យដូចគ្នានិងដកចេញនូវការប្រឆាំងជំទាស់របស់ខ្លួនចំពោះការផ្ដល់ជំនួយផ្នែកសេដ្ឋកិច្ចមួយមកឲ្យវៀតណាម ។ ប៉ុន្តែពុំទាន់មានអ្វីមួយទទួលបានផលប្រយោជន៍សោះ ។ ដើម្បីបើកទ្វារប្រទេសអាមេរិក ប្រទេសវៀតណាមបានប្រើប្រាស់ល្បិចកលមួយទៀតដោយគ្មានទទួលជោគជ័យធំដុំឡើយ ។ វៀតណាមបានបង្ហាញដើម្បីទាក់ចិត្តពីយថាភាពនៃការចុះហត្ថលេខាលើកុងត្រាជីកខួងអណ្ដូងប្រេងក្នុងដែនសមុទ្ររបស់ខ្លួន ។ មុនការដួលរលំនៃក្រុងព្រៃនគរ គេវាយតម្លៃថាចំនួនទឹកប្រាក់ដែលធ្វើវិនិយោគមានប្រហែល១០០លានដុល្លារ ដោយក្រុមហ៊ុនអាមេរិកាំងជិតម្ភៃក្នុងការធ្វើអាជីវកម្ម អណ្ដូងប្រេងនៅប្រទេសវៀតណាម ។ ក្រុមហ៊ុនម៉ូប៊ីល និង ស្ហែល បានធ្វើឲ្យប្រេងបាញ់ចេញពីក្នុងដីមកហើយ ។ ការដួលរលំរបស់វៀតណាមខាងត្បូងបានកើតឡើងដោយមិនដឹងខ្លួនមុនពេលដែលក្រុមហ៊ុនទាំងនោះ អាចនិយាយដោយការជឿជាក់ថា ការរកឃើញរបស់ពួកគេអាចធ្វើអាជីវកម្មតាមផ្លូវជំនួញបាន ។ ចាប់ពីខែកក្កដា ឆ្នាំ១៩៧៥ អ្នកតំណាងនៃក្រុមហ៊ុនប្រេងអាមេរិកាំងនានា បានជួបអ្នកទទួលខុសត្រូវវៀតណាម ជាសម្ងាត់នៅទីក្រុងប៉ារីសក្នុងគោលបំណងធ្វើការខួងអណ្ដូងប្រេងឡើងវិញ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អ្នកតំណាងខ្លះក្នុងចំណោមនោះ ត្រូវបានអញ្ជើញឲ្យទៅកាន់ក្រុងហាណូយ ដើម្បីដាក់ជូនពិនិត្យនូវសំណើរបស់ខ្លួន[៩] ។ ការធ្វើប្រតិបត្តិការខួងប្រេងបានចាប់ផ្ដើមភ្លាមដោយគ្មានអែអង់ រដ្ឋាភិបាល ហ្វ័រដ៍ បានបដិសេធមិនដកការរាំងខ្ទប់ផ្នែកសេដ្ឋកិច្ចឡើយ ទោះបីជាមានការកៀបសង្កត់របស់មជ្ឈដ្ឋានអ្នករកស៊ីប្រេងក៏ដោយ ដរាបណាវៀតណាមមិនទាន់ចាត់ចែងឲ្យមានការធ្វើជំរឿនទាហានអាមេរិកបាត់ខ្លួនដោយពេញលេញ ។

នៅសរទរដូវឆ្នាំ១៩៧៦ ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពជ្រួលច្របល់ខ្លាំងដោយការធ្វើវិសុទ្ធកម្ម (ការបោសសម្អាត) យ៉ាងឃោរឃៅ ហើយប្រទេសចិនកំពុងស្ថិតក្នុងសម័យអន្តរកាល ។ ក្នុងរយៈពេលនោះ របៀបឃោសនាជ្រើសរើសប្រធានាធិបតីនៅសហរដ្ឋអាមេរិកមានសភាពកាន់តែខ្លាំងក្លា ។ បេក្ខជនគណបក្ស

*ប្រជាធិបតេយ្យ ហ្ស៊ីមមី ខាធ័រ បានបន្ទោសប្រធានាធិបតី ហ្សេរ៉ាល់ហ្វ័រដ៍ ថា មិនយកចិត្តទុកដាក់បញ្ជូនគណៈកម្មការមួយទៅអង្កេតពីទាហានអាមេរិកបាត់ខ្លួនក្នុងការប្រយុទ្ធ និងមិនផ្តើមធ្វើការចរចាជាមួយក្រុងហាណូយ ។ តាមសម្តីលោក ខាធ័រ ថា នេះជាការមិនយកចិត្តទុកដាក់មួយដែលគួរឲ្យសោកស្តាយក្រៃលែង ។ ដោយជាក់ស្តែង ការយកចិត្តទុកដាក់របស់ ខាធ័រ ចំពោះទាហានបាត់ខ្លួន គឺមានលក្ខណៈសក្តិសមជាអ្នកនយោបាយយ៉ាងខ្លាំង ។*

## ដើមហេតុផ្សេងៗនៃការយល់ច្រឡំមួយ

*ខាធ័រ បានតែងតាំង ស៊ីរុស វ៉ាន់ស៍ ឲ្យធ្វើជារដ្ឋមន្ត្រីការបរទេស និង រីឆាដ ហូលប្រ៊ូក ជាអនុរដ្ឋមន្ត្រីការបរទេសទទួលបន្ទុកកិច្ចការអាស៊ីនិងប៉ាស៊ីហ្វិក ។ អ្នកទាំងពីរបានចូលរួមគ្រប់ការសាកល្បងទាំងអស់ សំដៅផ្តល់សន្ទុះដល់ការស្វែងរកដំណោះស្រាយសន្តិភាពនៅប្រទេសវៀតណាម ។ ដោយសំអាងលើបទពិសោធន៍ពីបញ្ហាវៀតណាមរបស់គាត់ វ៉ាន់ស៍ បានវាយតម្លៃថា ការធ្វើឲ្យមានប្រក្រតីភាពក្នុងទំនាក់ទំនងផ្សេងៗជាមួយក្រុងហាណូយ នឹងជួយឲ្យមានការបន្ថយភាពពឹងផ្អែករបស់ប្រទេសវៀតណាមចំពោះ ក្រុងមូស្កូ និងក្រុងប៉េកាំង ។ ម្យ៉ាងវិញទៀត ហូលប្រ៊ូក ហាក់ដូចជាមានប្រផ្នូលថា ការធ្វើឲ្យមានប្រក្រតីភាពនេះ នឹងសម្តែងតួនាទីដ៏សំខាន់ក្នុងការបង្កើតនូវទំនាក់ទំនងស្ថាបនាមួយរវាងប្រទេសវៀតណាម និងសមាគមអាស៊ានថែមទៀត ។ ដោយរំឭកពីហេតុផលផ្សេងៗនៃផលប្រយោជន៍របស់ខ្លួនសម្រាប់កិច្ចការនៅអាស៊ី ជាមួយលោកប្រធានាធិបតី ខាធ័រ ហូលប្រ៊ូក បានថ្លែងប្រាប់គាត់ថា ៖ «គឺនៅអាស៊ីចុងបូព៌ាដែលសហរដ្ឋអាមេរិកបានពើបប្រទះនឹងបញ្ហាច្រើនជាងគេ ក្នុងអំឡុង៣០ឆ្នាំចុងក្រោយនេះ ។ សង្គ្រាមចុងក្រោយទាំងបីរបស់យើងបានចាប់ផ្តើមនៅទីនោះ ហើយបញ្ហានៃការទទួលខុសត្រូវក្នុងការបាត់បង់ប្រទេសចិន, ប្រទេសកូរ៉េ, ប្រទេសវៀតណាម និងប្រទេសកម្ពុជា បានទៅជាចំណុចសំខាន់នៃការជជែកពិភាក្សាខាងនយោបាយដ៏ក្តៅគគុករបស់យើង ។ ខ្ញុំគិតថារដ្ឋាភិបាលរបស់លោកអាចនឹងធ្វើឲ្យឃើញរបត់មួយ ។ យើងអាចនឹងរៀបចំនយោបាយប្រទាក់គ្នាមួយ ដែលនឹងបញ្ចប់ស្ថានភាពនេះ ហើយប្រកាន់យកឥរិយាបថមួយចំពោះអាស៊ី»[១០] ។*

*ក្នុងឋានៈជាអភិបាលរដ្ឋ ហ្សេអ័រហ្ស៊ី (Géorgie) លោក ខាធ័រ មិនដែលប្រកាន់ជំហស្តីពីសង្គ្រាមនៅវៀតណាមទេ ។ គាត់ត្រូវធ្វើចាប់អារម្មណ៍តិចតួចពីទ្រឹស្តីផ្នើមៗទាំងនោះ ដែលប៉ុនប៉ងបង្កើតរបៀបរបបថ្មីមួយនៅអាស៊ី ។ ហូលប្រ៊ូក បាននិយាយប្រាប់ខ្ញុំថា «ខ្ញុំមិនគិតថា លោក ខាធ័រ មិនសូវមានទស្សនៈទៅលើបញ្ហានេះទេ ៖ រឿងតែមួយគត់ ដែលធ្វើឲ្យគាត់ជាប់ចិត្តក្នុងប្រទេសវៀតណាម គឺអំណាចជានិមិត្តរូបរបស់គាត់ ពីព្រោះគាត់បានត្រូវជ្រើសតាំងឲ្យធ្វើជាប្រធានាធិបតីក្រោយសម័យសង្គ្រាម ។ គាត់យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមបែបជានិមិត្តរូបមួយ ហើយគាត់ក៏យកចិត្តទុកដាក់ខ្លាំងក្នុង*

ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិននិងគុយបាផងដែរ ។ គាត់ចង់ធ្វើឲ្យមានប្រក្រតីភាពជាមួយមនុស្សទាំងអស់» ។ ក្នុងឋានៈជាប្រធានាធិបតីទីមួយបន្ទាប់ពីសម័យសង្គ្រាម គាត់ចាប់ផ្ដើមប្រមូលផ្ដុំប្រជាជនក្នុងប្រទេសឡើងវិញ និងធ្វើឲ្យសហរដ្ឋអាមេរិកមានកិត្តិស័ព្ទជាថ្មីនៅបរទេស ។ ដូច្នេះ គាត់ត្រូវតែធ្វើឲ្យគេបំភ្លេចប្រទេសវៀតណាមពីអារម្មណ៍ ហើយក្នុងន័យនេះកាយវិការដំបូងរបស់គាត់គឺលើកលែងទោសទាំងស្រុងចំពោះអ្នកមិនសុខចិត្តចុះញ៉ូមទាំងអស់ ។ មធ្យោបាយមួយទៀត ដើម្បីបំភ្លេចអតីតកាលគួរឲ្យឈឺចាប់នេះ គឺស្ថិតនៅត្រង់ទទួលឲ្យបាននូវព័ត៌មានទាំងអស់ស្ដីពីទាហាន២.៥០០នាក់ដែលស្លាប់នៅឥណ្ឌូចិន ក្នុងចំណោមនោះមាន៨០០នាក់ត្រូវចាត់ទុកថា បាត់ខ្លួនក្នុងការប្រយុទ្ធ[១១] ។

ការទាមទារដោយទទូចរបស់រដ្ឋាភិបាល ហ្វ័រដ៍ ដើម្បីតម្រូវឲ្យមានការធ្វើជំរឿនទាហានបាត់ខ្លួនពេញលេញមួយមុនការធ្វើឲ្យមានប្រក្រតីភាពទាំងស្រុងគឺខ្វះលក្ខណៈប្រាកដនិយមបន្តិច ។ តាមការពិត បញ្ហានេះធ្លាប់បាត់សកម្មភាពម្ដងទៅហើយ ។ ក្នុងរយៈពេលនៃការឃោសនាបោះឆ្នោត លោកប្រធានាធិបតី ហ្វ័រដ៍ បានបញ្ចេញបុកខ្ពង់ខ្ពស់និងថ្លៃថ្នូរក្នុងឥរិយាបថមិនបន្ធូរដៃមួយ ដើម្បីប្រឆាំងនឹងការចោទប្រកាន់ផ្សេងៗដែលមានលក្ខណៈភ្លីភ្លើគ្មានដឹងខុសត្រូវ ។ កិច្ចការចាំបាច់របស់ ខាធ័រ ត្រូវបានជួយសម្រួលដោយរបាយការណ៍មួយរបស់គណៈកម្មការទទួលបន្ទុកបញ្ហាជនបាត់ខ្លួននៅអាស៊ីអាគ្នេយ៍ ដែលដឹកនាំដោយសមាជិកសភាសាធារណរដ្ឋ សុននី ម៉ុងហ្គូម៉េរី ដោយសន្និដ្ឋានថា ពុំមានជនជាតិអាមេរិកាំងណាម្នាក់ ហើយក៏គ្មានអ្នកទោសណាម្នាក់រស់រានមានជីវិតនៅឥណ្ឌូចិន ឬនៅទីដទៃដែរ ។ របាយការណ៍បានបន្ថែមថា ៖ «ការធ្វើជំរឿនពេញលេញមួយគឺមិនអាចធ្វើបានឡើយ ដូច្នេះ មិនត្រូវសង្ឃឹមលើបណ្ដារដ្ឋាភិបាលនៅឥណ្ឌូចិនទេ»[១២] ។

ការចាប់ប្រតិបត្តិកម្មវិធីនយោបាយការបរទេសរបស់រដ្ឋាភិបាលថ្មី ហាក់ដូចជាពុំមានចោទឡើងនូវឧបសគ្គធំដុំទេ ទោះជាយ៉ាងណាក៏ដោយក៏នៅមានចំណុចមួយទៀតគឺ ការបិទជំពូកសង្គ្រាមនៅវៀតណាម ។ សហរដ្ឋអាមេរិកបានបោះបង់នូវសេចក្ដីសង្ឃឹមទាំងស្រុងចំពោះការធ្វើជំរឿនពេញលេញនៃទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ ។ វាលែងជាការធ្វើជំរឿនមួយដែល«ពេញលេញក៏ដូចអាចទទួលយកបាន»ទៀតហើយ ។ ដូច្នេះ សហរដ្ឋអាមេរិកគិតថា ក្រុងហាណូយនឹងសម្ដែងឲ្យឃើញលក្ខណៈសហការ ដោយហេតុថា គេបានបន្តបោកយកជំនួយមនុស្សធម៌ដោយល្បិចដ៏ប៉ិនប្រសប់ ។ ក្នុងអនុស្សរណៈមួយដែលធ្វើឡើងសម្រាប់គម្រោងការផ្សេងៗរបស់ប្រធានាធិបតីថ្មីខាងវិស័យនយោបាយការបរទេស វ៉ាន់ស៍ បានជំរុញឲ្យបញ្ជូនគណៈប្រតិភូមួយតំណាងប្រធានាធិបតីទៅកាន់ឥណ្ឌូចិននៅខែតុលា ឆ្នាំ១៩៧៦ ដើម្បីពិភាក្សាពីបញ្ហាទាហានបាត់ខ្លួន ។ នៅទីក្រុងហាណូយ ប្រេសិតតំណាងប្រធានាធិបតីនឹងត្រូវប្រគល់អំណាចឲ្យប្រកាស-ក្នុងនាមនៃវ៉ាន់ស៍-ថា «សហរដ្ឋអាមេរិកបានប្រុងប្រៀបជាស្រេចដើម្បីដាក់ជូនសភាជាន់ទាបពិនិត្យនូវកម្មវិធីជំនួយមនុស្សធម៌មួយក្នុងវិស័យសាងសង់លំនៅដ្ឋាននិងសុខាភិបាលកាលបើយើងទទួលបានការធ្វើជំរឿនមួយស្ដីពីទាហានបាត់ខ្លួនភ្លាម»[១៣] ។

ប្រការនេះប្រហែលជាការផ្ដើមគំនិតខាងនយោបាយការបរទេសលើកដំបូងរបស់លោក ខាធ័រ ។ បីខែបន្ទាប់ពីការប្រកាសចូលកាន់មុខតំណែង គណៈបេសកកម្មរបស់ប្រធានាធិបតីដែលដឹកនាំដោយលោក ឡេអូណារដ៍ វូដខូក បានឡើងយន្តហោះមកកាន់ក្រុងហាណូយ ។ មន្ត្រីនៅក្រសួងការបរទេសម្នាក់បានទទួលស្គាល់ថា ៖ «ការចាប់អារម្មណ៍តែមួយគត់ក្នុងការបញ្ជូនគណៈបេសកកម្មរបស់ វូដខូក គឺបញ្ជាក់ឲ្យដឹងជាក់ស្ដែងពីមរណភាពរបស់ទាហានបាត់ខ្លួនទាំងអស់» ។ បញ្ហាពុំមែនមានតែផ្នែកមនុស្សធម៌ប៉ុណ្ណោះទេ ប៉ុន្តែ មានផ្នែកហិរញ្ញវត្ថុផងដែរ ។ ដូច្នេះ មន្ទីរបញ្ចកោណ បានចាត់ចែងផ្ទេរប្រាក់បំណាច់របស់ពួកគេទៅឲ្យអ្នកបាត់ខ្លួនជាស្រេចក្នុងពេលដែលការស្លាប់របស់អ្នកទាំងនោះ នៅមិនទាន់បង្ហាញភ័ស្តុតាងជាផ្លូវការនៅឡើយ ។

លោក ខាធ័រ ពេញចិត្តនឹងលទ្ធផលជាច្រើន ។ ដោយសង្ឃឹមលើជោគជ័យផ្នែកនយោបាយការបរទេសលើកដំបូងមួយ ខាធ័រ បានចាត់ទុកប្រតិកម្មរបស់វៀតណាមចំពោះគណៈបេសកកម្មរបស់ វូដខូក ថាមានលក្ខណៈ «អំណោយផលយ៉ាងខ្លាំង» និងបានសម្ដែងឲ្យឃើញនូវការពេញចិត្តរបស់គាត់ចំពោះអ្វីៗទាំងអស់ដែលវៀតណាមធ្លាប់បានផ្ដល់ឲ្យរួចមកហើយស្ដីពីបញ្ហាទាហានបាត់ខ្លួន ។ គាត់បានសង្កត់បញ្ជាក់ថា ៖ «ខ្ញុំជឿថា អ្វីៗទាំងអស់គឺប្រហែលជាវៀតណាមអាចផ្ដល់ឲ្យ ខ្ញុំគ្មានមធ្យោបាយណាមួយបង្ហាញឲ្យឃើញថា វៀតណាមបានធ្វើជំរឿនទាហានបាត់ខ្លួនទាំងអស់ ដែលពួកគេមានព័ត៌មានផ្សេងៗស្ដីពីពួកនោះទេ ប៉ុន្តែ ខ្ញុំអាចនិយាយថា ពួកគេមានសុឆន្ទៈ»[១៤] ។

ឆន្ទៈក្នុងការធ្វើសហប្រតិបត្តិការពិតប្រាកដរបស់វៀតណាមបានធ្វើឲ្យលេចឡើងនូវលទ្ធផលជាច្រើនផ្ទុយគ្នានឹងខ្មែរក្រហមដែលធ្វើឲ្យ ខាធ័រ ទទួលរងនូវការផ្ដើនបំបាក់មុខពិតប្រាកដមួយ ។ គណៈប្រតិភូរបស់ វូដខូក ពុំបានទទួលការឆ្លើយតបណាមួយទៅនឹងសំណើសុំអនុញ្ញាតធ្វើដំណើរទៅកាន់ក្រុងភ្នំពេញរបស់ខ្លួនឡើយ ។ តាំងពីក្រុងវៀងច័ន្ទ រដ្ឋធានីរបស់ប្រទេសឡាវជាទីដែលគណៈប្រតិភូស្នាក់នៅមួយរយៈពេលត្រឡប់មកពីប្រទេសវៀតណាម វូដខូក បានផ្ដើមធ្វើសេចក្ដីស្នើការជាចុងក្រោយមួយ ។ មន្ត្រីម្នាក់នៃក្រសួងការបរទេសដែលទៅជាមួយគណៈប្រតិភូ បានទៅកាន់ស្ថានទូតកម្ពុជាប្រជាធិបតេយ្យដើម្បីរិះរកផ្លូវឲ្យបានទទួលការអនុញ្ញាតទៅទស្សនកិច្ចប្រទេសនេះ ។ ប៉ុន្តែ ដូចគ្នានឹងប្រទេសកម្ពុជាផ្ទាល់របស់គេដែរ ស្ថានទូតនេះនៅតែបិទទ្វារជិតស្លុង ។ ក្រោយពីមន្ត្រីរូបនេះគោះទ្វារក្នុងរយៈពេលកន្លះម៉ោង ភរិយារបស់ឯកអគ្គរដ្ឋទូតខ្មែរក្រហមដែលក៏ជាលេខាទីមួយរបស់ប្ដីគាត់ បានបើកទ្វារដើម្បីទទួលព័ត៌មានដែលសរសេរដោយលោក វូដខូក ។ «លោកឯកអគ្គរដ្ឋទូតមិននៅទេ» នាងនិយាយទៅកាន់បេសកជនអាមេរិក តាមចន្លោះទ្វារដែលបង្ហើបបន្តិចមុននឹងបិទទ្វារលាន់គ្រាំងស្ទើរប៉ះច្រមុះគាត់ ។ ការឆ្លើយតបរបស់ក្រុងភ្នំពេញត្រូវបានផ្សព្វផ្សាយតាមវិទ្យុជាតិ ៖ «កំហឹងវណ្ណៈរបស់ប្រជាជនកម្ពុជា នៅតែប្រឆាំងនឹងពួកចក្រពត្តិអាមេរិកាំងនិងពួកឆ្កែបំរើវាដល់ទីបំផុត ។ ប្រជាជនកម្ពុជាស្រឡាញ់ឯករាជ្យភាព អធិបតេយ្យភាព និងសេរីភាពរបស់ខ្លួនជាទីបំផុត ។ ពួកយើងមិនអាចទទួលយល់ព្រម

តាមពាក្យសុំរបស់ពួកចក្រពត្តិអាមេរិកក្នុងការបញ្ជូនគណៈប្រតិភូមួយ ដើម្បីមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យបានឡើយ ។ ពួកយើងមិនអាចលែលកជួបគណៈប្រតិភូនេះបានទេ ទោះជានៅកន្លែងណាក៏ដោយ» ។

លោក ខាធ័រ មានចិត្តរីករាយគួរសមចំពោះការបន្ធូរបន្ថយថ្មីដែលសម្តែងឲ្យឃើញដោយពួកវៀតណាម ។ គាត់បានកត់សម្គាល់ថា កាលពីពេលកន្លងមក វៀតណាមធ្លាប់ប្រកាសថា ពួកគេនឹងមិនចរចា ហើយនឹងមិនផ្តល់ព័ត៌មានបន្ថែមតិចតួចណាមួយស្តីពីទាហានបាត់ខ្លួនក្នុងការប្រយុទ្ធឡើយ ដរាបណាសហរដ្ឋអាមេរិកនៅតែបដិសេធមិនសងការខូចខាតដោយសារសង្គ្រាម ។ ប៉ុន្តែឥឡូវនេះ ពួកគេបានផ្តល់គំនិតឲ្យមានការរៀបចំកិច្ចប្រជុំជាថ្មីនៅទីក្រុងប៉ារីស ដោយគ្មានកម្រិតលក្ខខណ្ឌអ្វីជាមុន ។ តាមការឲ្យដឹងរបស់លោក ខាធ័រ គឺវៀតណាមបានប្រាប់លោកថា ៖ «យើងកុំធ្វើឲ្យការស្រុះស្រួលគ្នានិងការមិនត្រូវគ្នាកាលពីអតីតកាលគាំងនៅដដែល ។ ចូរយើងបែរឆ្ពោះទៅរកអនាគតវិញ» ។ ដោយឥតក្រែងរអែងទាំងស្រុងចំពោះចេតនាផ្សេងៗរបស់វៀតណាម គាត់បានសន្និដ្ឋានពីរឿងនេះថា ក្រុងហាណូយបានត្រៀមលះបង់ចោលការទាមទាររបស់ខ្លួនពីយូរមកហើយ–ការផ្តល់ជំនួយមួយរបស់សហរដ្ឋអាមេរិកក្នុងការស្តាបនាប្រទេសឡើងវិញ ។ ប៉ុន្តែ សេចក្តីរាយការណ៍របស់ វូដខូក មានលក្ខណៈច្បាស់លាស់គ្មានឲ្យមន្ទិល ៖ ដោយមិននិយាយចំថា ជំនួយនេះជាបញ្ហាអាទិភាពក្នុងការធ្វើឲ្យទំនាក់ទំនងការទូតមានប្រក្រតីភាពឡើងវិញ វៀតណាមបានដៅបញ្ជាក់យ៉ាងច្បាស់ថា បញ្ហាទាំងពីរនេះគឺជាប់ទាក់ទងនឹងគ្នា ។

ការប្រកែករបស់ក្រុងហាណូយ មានរយៈពេលពុំយូរឡើយ ។ បីថ្ងៃក្រោយមក ក្នុងបទសម្ភាសន៍មួយជាមួយទីភ្នាក់ងារព័ត៌មានវៀតណាម ផាន់ ហៀន បានឆ្លើយបដិសេធដោយមិនចំពោះទៅនឹងការបកស្រាយរបស់លោក ខាធ័រ ។ គាត់បានថ្លែងប្រាប់គណៈបេសកកម្មរបស់ វូដខូក ថា ប្រទេសវៀតណាមប្រាថ្នាបើកទំព័រជាថ្មីក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយសហរដ្ឋអាមេរិក ប៉ុន្តែគាត់បានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីយ៉ាងណា «វាពិបាកបដិសេធទៅលើអតីតកាលតែម្យ៉ាងបានទេ ។ នៅតាមផ្លូវនៃការធ្វើឲ្យមានប្រក្រតីភាព នៅមានឧបសគ្គជាច្រើនទៀតដែលត្រូវពុះពារ[១៥] ។

ទោះជាការភាន់ប្រឡំក្នុងការវិនិច្ឆ័យនេះមិនគ្រប់គ្រាន់ក៏ដោយ ក៏លោក ខាធ័រ បានបន្ថែមចំពោះភាពមិនច្បាស់លាស់នេះដោយពាក្យសម្តីដែលមានន័យមិនជាក់លាក់ថែមទៀត ។ ដោយលើកយកមកជជែករកការពិតថា សហរដ្ឋអាមេរិកមានកាតព្វកិច្ចត្រូវជួយប្រទេសវៀតណាមដែរឬទេនោះ លោក ខាធ័រ មិនវែកញែកដោយជាក់លាក់ពីយថាភាពនេះឡើយ ។ ប្រធានាធិបតីអាមេរិកាំងបានប្រាប់ឲ្យដឹងថា ៖ «ខ្ញុំនឹងធ្វើប្រតិកម្មដោយការយោគយល់ បើសិនជាវាកើតមានដោយគាប់ចួនក្នុងភាពបន្តគ្នានៃការធ្វើឲ្យមានប្រក្រតីភាពឡើងវិញនូវទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ទម្រង់នៃជំនួយផ្នែកសេដ្ឋកិច្ចខ្លះៗដែលត្រូវចាប់ផ្តើមជាថ្មី» ។

តើជំនួយរបស់អាមេរិកាំងជាសារសំខាន់មួយ ឬផ្ទុយទៅវិញជាផ្នែកដែលចូលមកបំពេញបន្ទ្រប់មួយក្នុងការធ្វើឲ្យមានប្រក្រតីភាពឡើងវិញ? ។ ខាធ័រ ពុំបានប្រកាន់ជំហរដោយភាពច្បាស់លាស់ពេញលេញជាគុណប្រយោជន៍ដល់ដំណោះស្រាយទីមួយទេ ។ ពួកមេដឹកនាំក្រុងហាណូយ បានត្រូវជំរុញដោយសមហេតុសមផលឲ្យធ្វើការកៀបសង្កត់ ដើម្បីបង្ខំឲ្យដោះស្រាយបញ្ហាទីពីរ ។ ជ័យជម្នះរបស់លោក ខាធ័រ និងអេគីបរបស់គាត់ដែលសុទ្ធតែជាសមាសភាពនិយមកណ្ដាល ហើយដែលល្បីល្បាញដោយសារការប្រឆាំងនឹងសង្គ្រាមរបស់ពួកគេ បានធ្វើឲ្យសេចក្ដីសង្ឃឹមរបស់ក្រុងហាណូយលេចឡើង ។ គណៈបេសកកម្មរបស់ វូដខូក ដែលរួមមានសមាសភាពនិយមកណ្ដាលបានធ្វើឲ្យវៀតណាមរឹតតែជឿថែមទៀតក្នុងគំនិតថា សហរដ្ឋអាមេរិកត្រូវតែលុបលាងបទឧក្រិដ្ឋរបស់ខ្លួន[១៦] ។ ក្រោយការចូលកាន់មុខតំណែងរបស់គាត់បន្តិច ខាធ័រ បានរវៀសរវៃចាត់បញ្ជូនគណៈប្រតិភូមួយយ៉ាងរហ័ស និងពង្រឹងភាពប្រាកដក្នុងចិត្តរបស់គាត់ថា ប្រទេសវៀតណាមនៅតែជាចំណុចកណ្ដាលនៃនយោបាយរបស់អាមេរិកាំងជានិច្ច ហើយថាក្រុងវ៉ាស៊ីនតោនបានប្រុងប្រៀបបង់តម្លៃនៃការធ្វើឲ្យមានប្រក្រតីភាពជាស្រេច ។ ជាអ្នកម៉ាក្សស៊ីសនិយមត្រឹមត្រូវ ពួកមេដឹកនាំវៀតណាមបានរក្សាជាប់ក្នុងចិត្តជានិច្ចនូវអ្វីដែលពួកគេវាយតម្លៃ ពីកត្តាកំណត់ផ្នែកសេដ្ឋកិច្ចដែលនៅពីក្រោមការធ្វើអន្តរាគមន៍របស់ចក្រពត្តិ និងជឿជាក់ថា សក្ដានុពលផ្នែកសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម (ប្រភពធនធានធម្មជាតិ និងហត្ថពលិកដែលមានគុណសម្បត្តិ) ល្មមគ្រប់គ្រាន់នឹងធ្វើឲ្យពួកមូលធនិកអាមេរិកាំងត្រឡប់មកវិញ ។ ការផ្ដល់ជំនួយមួយទៅឲ្យប្រទេសវៀតណាមនឹងផ្ដល់គុណប្រយោជន៍ចំពោះឧស្សាហកម្មរបស់អាមេរិកថែមទៀត ។ កាលពីឆ្នាំ១៩៧៣ គណៈកម្មការសេដ្ឋកិច្ចចម្រុះអាមេរិកាំង-វៀតណាមមួយ បានសម្រេចឈានដល់គម្រោងកិច្ចព្រមព្រៀងមួយដែលតាមរយៈនេះ សហរដ្ឋអាមេរិកបានសន្យាប្រើប្រាស់នូវកម្មវិធីជំនួយមួយដែលមានទឹកប្រាក់សរុប១.៥០០លានដុល្លារ ហើយប្រទេសវៀតណាមត្រូវប្រើប្រាស់៨៥ភាគរយនៃទឹកប្រាក់នេះសម្រាប់ទិញ ផលិតផលរបស់អាមេរិកាំងវិញ ។ ក្រៅពីការស្រេកឃ្លានផលកម្រៃរបស់ពួកមូលធនិក ក្រុងហាណូយក៏យល់ឃើញថា អាចទុកចិត្តលើចិត្តសប្បុរសដែលមានពីកំណើតរបស់ពួកអាមេរិកាំង និងគំនិតអាក្រក់របស់គេចំពោះប្រទេសវៀតណាមដែរ ។ អ្នកដើរដើម្បីសន្តិភាពរាប់ពាន់នាក់ អ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញប្រមាណដប់នាក់នៃសភាជាន់ទាបអាមេរិក ដែលកាលពីពេលថ្មីៗធ្លាប់ប្រកាន់ជំហរប្រឆាំងសង្គ្រាមនឹងជំរុញឲ្យមានការធ្វើឲ្យទំនាក់ទំនងផ្សេងៗមានភាពប្រក្រតីដោយជាក់លាក់ និងការលែងខ្ចប់ជំនួយមួយសម្រាប់ការស្ដាបនាប្រទេសវៀតណាមឡើងវិញហើយ ។

អ្វីៗទាំងអស់បង្ហាញឲ្យឃើញថា រដ្ឋាភិបាល ខាធ័រ ប្រហែលជាមិនយល់ពីជំហររបស់វៀតណាមបន្តិចសោះ ។ ទោះជាវៀតណាមប្រកាន់សេចក្ដីសង្ឃឹមទទួលបានជំនួយអាមេរិកាំងដ៏សមល្មមមួយក៏ដោយ ក៏ពុំប្រាកដថា ពួកគេវាយតម្លៃសក្ដិសមនឹងទទួលរង្វាន់មួយសម្រាប់សហប្រតិបត្តិការរបស់គេស្ដីពីបញ្ហាទាហានបាត់ខ្លួន

ដែរទេ ប៉ុន្តែ ពីព្រោះតាមការយល់ឃើញរបស់ពួកគេថា នេះជាបំណុលផ្នែកសីលធម៌មួយរបស់សហរដ្ឋអាមេរិកទៅវិញ ។

ជាក់ច្បាស់ណាស់ដែលមិនមានអ្នកណាម្នាក់នៅក្រុងវ៉ាស៊ីនតោនធ្លាប់គិតស្មានថា វៀតណាមបានសំអាងយកតែមែនទែនលើអំណោយដ៏សប្បុរសរបស់អាមេរិកាំង –នេះជារបៀបបកស្រាយរបស់ជនឥណ្ឌូចិនអំពីផែនការ ម៉ារស្ហាល (Plan Marshall)– ដើម្បីស្តាបនាប្រទេសរបស់ខ្លួន ដែលបំផ្លិចបំផ្លាញដោយសង្គ្រាមឡើងវិញ ។ ក៏ប៉ុន្តែ... មន្ត្រីជាន់ខ្ពស់ម្នាក់របស់វៀតណាមបានបញ្ជាក់ប្រាប់ខ្ញុំក្នុងពេលរៀបចំធ្វើផែនការសេដ្ឋកិច្ចទីមួយក្រោយសម័យសង្គ្រាមថា បន្ទាប់ពីជ័យជម្នះរបស់ ខាធ័រ ភ្លាម វៀតណាមបានដាក់បញ្ចូលក្នុងការគិតទុកជាមុនរបស់ខ្លួនជាស្រេចនូវជំនួយមួយដែលមានទឹកប្រាក់៤.៧០០លានដុល្លារ ដែលសន្យាផ្តល់ឲ្យកាលពីឆ្នាំ១៩៧៣ ។ តាមមន្ត្រីជាន់ខ្ពស់វៀតណាមម្នាក់ទៀតថា “គឺការគៀនបង្ខំជាបន្ទាន់របស់ពួកអ្នកទទួលខុសត្រូវធ្វើផែនការសេដ្ឋកិច្ច ជាពិសេស ឡេ ថាញ់ងី ទើបវៀតណាមសម្រេចចិត្តបង្ហាញនូវចំណុចមិនអាចផ្លាស់ប្តូរបាននេះក្នុងភាពចាំបាច់ខានមិនបាននៃជំនួយមួយ សម្រាប់ការស្តារប្រទេសឡើងវិញ ដោយចាត់ទុកថា ជាបញ្ហាដែលត្រូវជជែកពិភាក្សាមុនគេក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយសហរដ្ឋអាមេរិក”[១៧] ។

ជាច្រើនឆ្នាំក្រោយមក រីឆាដ ហូលប្រ៊ុក ដែលខ្ញុំប្រាប់ឲ្យដឹងពីផែនការរបស់វៀតណាម ដើម្បីទាញយកលុយដែលសន្យាដោយប្រធានាធិបតី និចសុន បានលាន់មាត់ថា ៖ “ពួកគេប្រហែលជាឡប់ស្មារតីអស់ហើយ” ។

ហូលប្រ៊ុក ដែលជាមនុស្សដ៏អស្ចារ្យសម្រាប់នយោបាយការបរទេសរបស់អាមេរិកាំង គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលធ្លាប់ឆ្លងមេរោគវៀតណាម ។ បីឆ្នាំនៅប្រទេសវៀតណាមសម្រាប់មុខតំណែងដំបូងរបស់គាត់នៅបរទេស ៖ បទពិសោធន៍នេះបានអន្ទោលតាមគាត់អស់មួយជីវិត ។

ត្រូវតែងតាំងដោយលោក ខាធ័រ និង ស៊ីរុស វ៉ាន់ស៍ ជាអនុរដ្ឋមន្ត្រីការបរទេសទទួលបន្ទុកកិច្ចការអាស៊ីខាងកើត ហូលប្រ៊ុក បានយល់ឃើញថា នេះជាឱកាសដើម្បីកំណត់នយោបាយអាស៊ីមួយដោយលក្ខណៈប្រាកដនិយមហើយ[១៨] ។ ក្នុងគំនិតរបស់គាត់ ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម និងប្រទេសចិនត្រូវតែរៀបចំឡើងជាដំណាក់កាលដំបូង ហើយក្នុងដំណាក់កាលដំបូងនេះ ការធ្វើឲ្យមានប្រក្រតីភាពក្នុងទំនាក់ទំនងជាមួយប្រទេសវៀតណាមគឺជាអាទិភាពដាច់ខាត ។ សហការីម្នាក់ក្នុងចំណោមសហការីរបស់គាត់នៅក្រសួងការបរទេសបាននិយាយថា ៖ “Dick ជាមនុស្សដែលត្រូវធ្វើឲ្យខ្វល់ចិត្តដោយសារប្រទេសវៀតណាម ។ គាត់ចង់មានចំណែកក្នុងប្រវត្តិសាស្ត្រដែរ ក្នុងឋានៈជាអ្នកនាំអាទិ៍ការផ្សះផ្សាជាមួយប្រទេសនេះ ពីព្រោះការផ្សះផ្សានេះនឹងបញ្ចប់ជាស្ថាពរនូវជំពូកដ៏គួរឲ្យឈឺចាប់មួយនៃនយោបាយការបរទេសរបស់អាមេរិកាំង” ។

រដ្ឋាភិបាលលោក ខាធ័រ ក៏មានមូលហេតុផ្សេងៗក្នុងការធ្វើឲ្យទំនាក់ទំនងជាមួយប្រទេសវៀតណាមមានប្រក្រតីភាពឡើងវិញដែរ ។ នៅឱកាសមួយ លោកប្រធានាធិបតីផ្ទាល់បានលើកយកមកនិយាយពីប្រភពធន

ធានធម្មជាតិដ៏សំខាន់របស់វៀតណាមថែមទៀត ជាពិសេសប្រេងកាត ។ ទន្ទឹមនឹងនោះ ដោយមិនចង់បណ្តោយឲ្យពួកអឺរ៉ុបនិងជប៉ុនដណ្តើមកន្លែងខ្លួននៅប្រទេសវៀតណាម ពួកធនាគារិក អ្នកជំនួញ និងពួកខស្សរាហករប្រេងរបស់អាមេរិកាំងបានធ្វើការកៀបសង្កត់ ដើម្បីឲ្យរដ្ឋាភិបាលដករបាំងពាណិជ្ជកម្មចេញ ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ ក្រុងហាណូយបានចេញផ្សាយជាសាធារណៈនូវច្បាប់វិនិយោគឯកជនមួយ សម្រាប់ជនបរទេសដែលមានលក្ខណៈសេរីគួរឲ្យភ្ញាក់ផ្អើលដែលកាលពី ពីរ-បីខែមុន ពួកធនាគារិកអាមេរិកាំងខ្លះអាចដឹងសេចក្តីព្រាងច្បាប់នេះរួចទៅហើយ ។

ទស្សនៈផ្នែកសេដ្ឋកិច្ចអំពីបញ្ហានេះ គឺមិនអាចកាត់ផ្តាច់បានពីការពិចារណាផ្នែកការទូត ដែលមានលក្ខណៈទូលំទូលាយជាងឡើយ ។ វ៉ាន់ស៍ និង ហូលប្រ៊ូក ជឿថា ដោយជំពាក់ចិត្តនឹងឯករាជ្យភាពរបស់ខ្លួនខ្លាំងពេក ប្រទេសវៀតណាមចូលចិត្តប្រកាន់យកនយោបាយតុល្យភាពមួយរវាងមហាអំណាចនានាជាងដោយសារស្ថានភាពពីងផ្អែករបស់គេទាំងស្រុងមួយចំពោះពួកសូវៀត ។ អ្នកទាំងពីរយល់ឃើញថាអវត្តមាននៃអ្នកតំណាងការទូតរបស់អាមេរិកាំងនៅប្រទេសវៀតណាម បានបង្អាក់ពួកគេមិនឲ្យមានកម្លាំងទប់មួយទល់នឹងឥទ្ធិពលរបស់សូវៀតនៅតំបន់អាស៊ីអាគ្នេយ៍ ។ ក្នុងសារណារបស់គាត់ វ៉ាន់ស៍ បានសង្កត់បញ្ជាក់ថា "ខ្ញុំធ្លាប់មានអារម្មណ៍ថា ការបង្កើតទំនាក់ទំនងការទូតជាធម្មតាជាមួយប្រទេសវៀតណាម ដែលបណ្តាប្រទេសជាមិត្តរបស់យើងនៅអាស៊ីសុទ្ធតែចង់បានយ៉ាងខ្លាំងនោះ នឹងបើកឱកាសឲ្យយើងបង្កើនឥទ្ធិពលរបស់យើងទៅលើប្រទេសនេះ និងផ្តល់នូវមធ្យោបាយមួយសម្រាប់ជួយឲ្យប្រទេសវៀតណាមដោះខ្លួនផុតពីភាពនៅក្នុងចំណុះខាងនយោបាយនិងយោធាហួសប្រមាណពីសហភាពសូវៀត ឬប្រទេសចិន"[១៩] ។ មានតែ ប៊ីកញ្ញូ ប្រ៊ីហ្សីនស្គី ទីប្រឹក្សាសន្តិសុខម្នាក់ប៉ុណ្ណោះ ដែលបង្ហាញឲ្យឃើញភាពមិនអើពើចំពោះអ្វីដែលគាត់ហៅថា "ជាបញ្ហាបន្ទាប់បន្សំដូចបញ្ហាវៀតណាមអ៊ីចឹង" ។ ការខ្វែងគំនិតគ្នា ក្នុងការវាយតម្លៃនេះនឹងផ្តុកទៅដោយផលវិបាកយ៉ាងច្រើន[២០] ។

## ទីបញ្ចប់នៃការយល់ច្រឡំ

មួយខែបន្ទាប់ពីលោក វូដខូក ត្រឡប់ពីវៀតណាមមកវិញ វៀតណាមនិងពួកអាមេរិកាំង បានចាប់ផ្តើមចរចាជាថ្មីនៅទីក្រុងប៉ារីស ។ លើកនេះ រង្វង់នៃបញ្ហាផ្សេងៗដែលលើកយកមកជជែកពិភាក្សាដោយសត្រូវទាំងពីរ គឺមានលក្ខណៈទូលំទូលាយជាងមុនច្រើន ។ ការចរចាក៏រួមបញ្ចូលបញ្ហាធ្វើឲ្យមានប្រក្រតីភាពដែរ ។ ខែឧសភា ជាខែដែលអ្វីៗមានលក្ខណៈអធិកអធម ហើយទស្សនវិស័យអំពីជោគជ័យ ក៏គួរជាទីសង្ឃឹមបំផុត ។ ទោះបីជាមានរបាំងពាណិជ្ជកម្មដែលនៅជាធរមានក៏ដោយ ក៏រដ្ឋាភិបាលលោក ខាធ័រ បានអនុញ្ញាតឲ្យដឹកជំនួយមនុស្សធម៌មួយជាឯកជនទៅប្រទេសវៀតណាម ដែលមានតម្លៃជាទឹកប្រាក់៥លានដុល្លារ ។ នៅខែមករា ដោយប្រកាន់គំនិតផ្ទុយពីនយោបាយរបស់រដ្ឋាភិបាល ហ៊័រដ៍ លោក ខាធ័រ មិនបានជំទាស់នឹងការផ្តល់ប្រាក់កម្ចី

មួយដោយអង្គការសហប្រជាជាតិ ដើម្បីធ្វើហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍មួយឡើយ ។ ក្នុងការធ្វើសម្ភាសន៍មួយមុនការចេញដំណើររបស់គាត់ពីទីក្រុងវ៉ាស៊ីនតោនទៅកាន់ក្រុងប៉ារីស លោក ហូលប្រ៊ុក ពុំបានបដិសេធថា សហរដ្ឋអាមេរិកបានផ្ដល់ដោយមិនចំពោះនូវជំនួយមួយដល់ប្រទេសវៀតណាមឡើយ ។ បណ្ដាទស្សនកិច្ចនៅទីក្រុងហាណូយនៃអ្នកតំណាងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (F.M.I.) នៅខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់មក ទស្សនកិច្ចរបស់អ្នកតំណាងធនាគារពិភពលោក នៅខែមករា ឆ្នាំ១៩៧៧ បានធ្វើឲ្យវៀតណាមសង្ឃឹមថា ជំនួយរបស់អាមេរិកាំងនឹងឆ្លងកាត់តាមស្ថាប័នទាំងពីរនេះ ដែលត្រួតត្រាយ៉ាងជិតដល់ដោយសហរដ្ឋអាមេរិក ។ របាយការណ៍សម្ងាត់របស់ធនាគារពិភពលោក ដែលគាត់តែងបន្ទាប់ពីការវិលត្រឡប់នៃបណ្ដាអ្នកជំនាញការរបស់ខ្លួននឹងមានដំណើរល្អទៅតាមន័យនេះ ៖ ដោយលើកសរសើរពីការខំប្រឹងប្រែងរបស់រដ្ឋាភិបាលវៀតណាមដើម្បីបើកឲ្យប្រើប្រាស់នូវប្រភពធនធានធម្មជាតិ និងទាញយកផលប្រយោជន៍ពីសក្ដានុពលដ៏ទូលំទូលាយរបស់ខ្លួន យើងសុំកុំឲ្យអ្នកជំហរផ្ដល់ប្រាក់រាំងខ្ទប់«ជំនួយធំដុំមួយ» តាមលក្ខខណ្ឌដែលមានកំណត់ ។ ក្នុងរយៈពេលនៃការស្ដាបនាប្រទេសឡើងវិញបន្ទាប់ពីសង្គ្រាមដ៏វែងអន្លាយមួយ ប្រទេសវៀតណាមត្រូវការពេលវេលាមួយរយៈ ដើម្បីតម្រង់ទិសសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ តាមការប្រែប្រួលនៃបណ្ដាគោលដៅថ្មីក្នុងពេលប្រទេសមានសន្តិភាព»[២១] ។

នៅថ្ងៃទី២៧ ខែមេសា ឯកអគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំប្រទេសថៃបានវាយទូរលេខទៅក្រុងវ៉ាស៊ីនតោនដើម្បីជូនព័ត៌មានដល់បណ្ដាចៅហ្វាយនាយរបស់ខ្លួនអំពីសេចក្ដីសង្ឃឹមរបស់ក្រុងហាណូយ ។ ដោយស្រង់សម្ដីឯកអគ្គរដ្ឋទូតប្រទេសបែលហ្ស៊ិកប្រចាំរដ្ឋធានីរបស់វៀតណាមមកនិយាយជាសំអាង គាត់បានរាយការណ៍ថាវៀតណាមបាយវាយតម្លៃយ៉ាងមុតមាំអំពីការផ្ដល់ជំនួយមួយរបស់អាមេរិកាំង បន្ទាប់ពីការធ្វើឲ្យមានប្រក្រតីភាព ហើយថាក្នុងទស្សនវិស័យនេះ ពួកគេទន្ទឹងរង់ចាំដោយអន្ទះសានូវការបើកគណៈបេសកកម្មការទូតរបស់សហរដ្ឋអាមេរិកតូចមួយនៅទីក្រុងហាណូយ នាចុងឆ្នាំ១៩៧៧[២២] ។ ក្នុងសំបុត្រឆ្លើយឆ្លងមួយទៀត មន្ត្រីស្ថានទូតបានរៀបរាប់បញ្ចូលនូវសម្ដីសន្ទនារបស់អ្នកឲ្យការណ៍ម្នាក់ដែលថា «នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង បានសម្ដែងឲ្យឃើញទឹកចិត្តសោមនស្សរីករាយយ៉ាងខ្លាំង»ចំពោះអនាគតនៃទំនាក់ទំនងរវាងអាមេរិកនិងវៀតណាម ។

លទ្ធផលនៃការចរចាដែលប្រព្រឹត្តទៅពីថ្ងៃទី៣ ដល់ទី៤ ខែឧសភា ក្នុងអគារមួយនៃអតីតគណៈបេសកកម្មវៀតកុងនៅក្រុងប៉ារីស ហាក់ដូចជាធ្វើឲ្យមានការខកចិត្តយ៉ាងសោះកក្រោះមួយ ។ ផាន់ ហៀន បានរំឭកពីលិខិតដែលលោក និចសុន ផ្ញើមកឲ្យនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ដែលក្នុងនោះ ប្រធានាធិបតីអាមេរិកាំងបានសន្យាបង់ប្រាក់ដល់ប្រទេសវៀតណាមចំនួន៣.២៥០លានដុល្លារ ដោយគិតជាជំនួយសម្រាប់ការស្ដារប្រទេសឡើងវិញ បូកបន្ថែមនឹងការផ្ដល់វត្ថុធាតុដើមទៀត ដែលគិតជាទឹកប្រាក់មានចំនួនដល់ទៅ១.២៥០លានដុល្លារ ។ រដ្ឋាភិបាលលោក ខាធ័រ បានឲ្យដឹងថា ខ្លួនពុំអាចធ្វើតាមកិច្ចសន្យានេះបានទេ ។ ហូលប្រ៊ុក បាននិយាយប្រាប់ខ្ញុំ

(អ្នកនិពន្ធ) ជាសម្ងាត់ថា ៖ «គាត់បានទទួលការណែនាំឲ្យស្នើពួកវៀតណាមទទួលស្គាល់ទៅវិញទៅមក ដោយមិនគិតថាអ្វីដែលត្រូវជជែកមុន ឬជជែកក្រោយទេ និងសម្តែងឲ្យដឹងនូវបំណងរបស់យើងដែលចង់ឃើញប្រទេសវៀតណាមធ្វើសមាហរ័ណទាំងស្រុងក្នុងតំបន់អាស៊ីអាគ្នេយ៍មួយ ដែលប្រកបដោយស្ថិរភាពនិងសន្តិភាព» ។ អ្នកចរចាអាមេរិកាំងបាននិយាយប្រាប់ ហៀន ពីសមានចិត្តទាំងមូលរបស់គាត់ចំពោះស្ថានភាពប្រកបដោយគ្រោះថ្នាក់ដែលប្រទេសវៀតណាម ត្រូវរងទទួលបន្ទាប់ពីការបំផ្លិចបំផ្លាញដោយសារសង្គ្រាម ប៉ុន្តែបដិសេធមិនធ្វើការសន្យាចំពោះការផ្តល់ជំនួយជាយថាហេតុមួយរបស់អាមេរិកាំងឡើយ ។ គាត់បានបំភ្លឺថា ជំនួយមួយបែបនោះអាចនឹងគ្រោងគិត បន្ទាប់ពីការបង្កើតទំនាក់ទំនងផ្នែកការទូតរួច ប៉ុន្តែប្រាកដណាស់គឺពុំមែនមុនទេ ។ ការធានាថា សហរដ្ឋអាមេរិកនឹងលែងបោះឆ្នោតវេតូរបស់ខ្លួនក្នុងការចូលជាសមាជិកអង្គការសហប្រជាជាតិរបស់វៀតណាម ពុំមែនជាការភ្ញាក់ផ្អើលដែលធ្វើឲ្យសប្បាយមុនសម្រាប់គូសន្ទនារបស់គាត់ទេ ពីព្រោះក្រុងហាណូយបានរក្សាទុកហេតុការណ៍នេះក្នុងចិត្តសម្រាប់ជាការពិសោធន៍តាំងពីឥឡូវនេះទៅហើយ ។

ខេនឃ្វីន ដែលនៅជំនាន់នោះជាទីប្រឹក្សាពិសេសរបស់ ហូលប្រ៊ុក នៅនឹកឃើញថា ក្នុងអំឡុងនៃការចរចាស្រាប់តែចៅហ្វាយនាយរបស់គាត់ដែលឈរឈ្ងោកលើតុបានប្រកាសថា «លោករដ្ឋមន្ត្រី! យើងទុករឿងដែលធ្វើឲ្យយើងមិនត្រូវគ្នាមួយជុំ ។ យើងចេញពីប្រជុំ ហើយប្រកាសប្រាប់អ្នកសារព័ត៌មានរួមគ្នាថា យើងបានសម្រេចចិត្តធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់យើងមានប្រក្រតីភាពហើយ» ។ ហៀន បានបដិសេធ ។ គាត់បានគ្រើនរំឭកថា សហរដ្ឋអាមេរិកត្រូវតែជួយបិទស្នាមរបួសដោយសារសង្គ្រាមឡើងវិញ ។ តាមការឲ្យដឹងរបស់ឃ្វីន គឺវៀតណាមគិតថាទទួលបានជ័យជម្នះផ្នែកសីលធម៌មួយ ហើយប្រការនេះឯងដែលលេចឡើងជាមូលហេតុនៃការចចេសរបស់គេ ។ ជ័យជម្នះនៅឆ្នាំ១៩៧៥ ពិតជាសកម្មភាពស្របច្បាប់របស់បក្សគេតាំងពី ៤០ឆ្នាំកន្លងមក ។ ប្រជាជាតិផ្សេងៗទៀតដែលចាញ់សង្គ្រាម ជាពិសេស ប្រទេសជប៉ុន និងប្រទេសបារាំងសុទ្ធតែទទួលស្គាល់ដោយយល់ព្រមបង់តម្លៃសម្រាប់ជួសជុលការខូចខាត ដោយសារសង្គ្រាមឡើងវិញ ។ ជ័យជម្នះផ្នែកសីលធម៌នេះនឹងពុំពេញលេញទេ ប្រសិនបើពួកអាមេរិកាំងត្រឡប់មកប្រទេសវៀតណាមវិញដោយពុំបានសងថ្លៃការខូចខាតបណ្តាលមកពីសង្គ្រាម ។

រឿងរ៉ាវបានប្រែទៅជាអាក្រក់នៅមុនពេលបញ្ចប់ទឹកទីមួយនៃការចរចានៅទីក្រុងប៉ារីស ។ ការលាតត្រដាងដោយវៀតណាម អំពីការសន្យាជាសម្ងាត់របស់ប្រធានាធិបតី និចសុន និងការនិយាយបញ្ចិតបញ្ចៀងដែលទើបមានថ្មីៗក្នុងការផ្តល់ជំនួយដោយមិនចំពោះមួយដល់ប្រទេសវៀតណាម ហាក់ដូចជាការទះកំផ្លៀងសភាជាន់ទាបអាមេរិកមួយដៃអ៊ីចឹង ។ បំណងចង់បានជំនួយយ៉ាងខ្លាំងដែលពិបាកបន្ទន់បានត្រូវធ្វើឲ្យកម្រើកឡើងវិញភ្លាម ដែលទាំង វ៉ាន់ស៍ ទាំង ហូលប្រ៊ុក ពុំបានគ្រោងគិតជាមុនឡើយ ។ ទោះបីជាលោក ខាធ័រ យកចិត្តទុកដាក់ពិគ្រោះជាមួយសភាជាន់ទាប មុននឹងបញ្ជូនលោក ហូលប្រ៊ុក ទៅទីក្រុងប៉ារីសក៏ដោយ ក៏ក្រុមប្រឆាំង

អភិរក្សនិយមបានកញ្ច្រោលឡើងប្រឆាំងនឹងគំនិតផ្តួចផ្តើមទាំងអស់ ជាគុណប្រយោជន៍ដល់ការធ្វើឲ្យមានប្រក្រតីភាពមួយ ។ នៅថ្ងៃទី៤ ខែឧសភា សភាជាន់ខ្ពស់កំពុងពិភាក្សា ពីសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកសេដ្ឋកិច្ចទៅឲ្យបរទេស នៅពេលដែលពាក្យសម្តីដែល ហៀន និយាយ ក្នុងអំឡុងនៃការធ្វើសន្និសីទកាសែតរបស់គាត់នៅក្រុងប៉ារីស បានត្រូវកត់ត្រាដោយម៉ាស៊ីនទូរអក្សលីលេខ ។ តាមសម្តីគាត់ថា សហរដ្ឋអាមេរិកត្រូវមានកាតព្វកិច្ចជួយប្រទេសវៀតណាម ។ នៅពេលនោះ គេឃើញ លោក វីល្លីយ៉ាំ អាសប្រ៊ុក ជាអ្នកតំណាងរាស្ត្រគណបក្សសាធារណរដ្ឋលើកគ្រវីសេចក្តីចម្លងនៃសេចក្តីប្រកាសនេះ និងស្រែកឡូឡាទាមទារធ្វើការបោះឆ្នោតមួយ ដោយបង្ខំឲ្យក្រសួងការបរទេសបោះបង់គម្រោងការនេះទៅវិញ ។ ការស្នើកែច្បាប់ (វិសោធនកម្ម) របស់គាត់ ដោយហាមឃាត់មិនឲ្យរដ្ឋាភិបាលអាមេរិកាំង "ចរចាពីការផ្តល់ជំនួយសេដ្ឋកិច្ចមួយ ការសងការខូចខាតដោយសារសង្គ្រាម ឬទម្រង់វិភាគទានផ្នែកហិរញ្ញវត្ថុមួយចំនួន ទោះជាទម្រង់បែបណាក៏ដោយ" ជាមួយប្រទេសវៀតណាមបានត្រូវអនុម័តនៅថ្ងៃនោះ ដោយការបោះឆ្នោតយល់ព្រម២៦៦សំឡេងប្រឆាំង១៣១សំឡេង ។ វ៉ាន់ស៍ បានគោរពធ្វើតាម ។ គាត់បានប្រកាសថា "យើងបានធ្វើឲ្យវៀតណាមដឹងយ៉ាងច្បាស់ថាយើងនឹងមិនបង់ប្រាក់ជាសាហ៊ុយ ជួសជុលការខូចខាតដោយសង្គ្រាមឡើយ"[២៣] ។

នៅថ្ងៃទី៧ ខែមិថុនា ពេលដែល ហៀន ធ្វើដំណើរទៅកាន់ស្ថានទូតអាមេរិកស្ថិតនៅតាមវុក្ខវិថីហ្កាប្រ៊ីយែល ក្នុងទីក្រុងប៉ារីសសម្រាប់ដំណាក់កាលទីពីរនៃការចរចាជាមួយ ហូលប្រ៊ុក គាត់លែងស្ថិតនៅក្នុងស្ថានភាពចិត្តគំនិតដូចមុនទៀតហើយ ។ ប្រាកដណាស់ នេះជាលើកដំបូងហើយដែលមេដឹកនាំក្រុងហាណូយម្នាក់ត្រូវបើកឲ្យចូលក្នុងស្ថានទូតអាមេរិកាំងមួយ ប៉ុន្តែ វៀតណាមបានវិនិច្ឆ័យពីការលួងចិត្តនេះរាងស្តួចស្តើងបន្តិច ។ អ្វីដែលសំខាន់សម្រាប់វៀតណាម គឺសេចក្តីសង្ឃឹមពីជំនួយរបស់អាមេរិកាំងដ៏សម្បើមមួយ ។ នៅថ្ងៃទី១៩ ខែឧសភា ក្រុងហាណូយបានផ្សព្វផ្សាយលិខិតសម្ងាត់របស់ប្រធានាធិបតី និចសុន ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៣ ដែលផ្ញើមកឲ្យលោក ផាំ វ៉ាន់ដុង ដោយមានសេចក្តីថា "រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងជួយកសាងប្រទេសវៀតណាមខាងជើងឡើងវិញបន្ទាប់ពីសង្គ្រាម ដោយគ្មានលក្ខខណ្ឌខាងនយោបាយឡើយ" ។ និចសុន បញ្ជាក់ថាការរួមវិភាគទានរបស់អាមេរិកាំង"នឹងមានក្បែរ ៗ ៣.២៥០លានដុល្លារ សម្រាប់រយៈពេល៥ឆ្នាំ" ។ សម្រាប់ក្រុងហាណូយ លិខិតនេះមានភាពហាក់ដូចជាសន្ទឹកបៀធំជាងគេមួយ ។ ប៉ុន្តែ ក្នុងពេលថ្មីៗនេះ អ្នកដែលធ្វើបាតុកម្មនៅមុខមន្ទីរបញ្ចកោណដើម្បីទាមទារសន្តិភាពលែងមាននៅទីនោះទៀតហើយ ឥឡូវនេះគឺជារឿងតម្រូវឲ្យផ្តល់ជំនួយមួយសម្រាប់ប្រទេសវៀតណាមទៅវិញ ។ អាក្រក់ជាងនេះទៅទៀត ការកាន់កាប់ភាគខាងត្បូងដោយកម្លាំងទ័ព ការជន់ជោរនៃហ្វូងជនភៀសខ្លួនដែលកំពុងរត់ចេញពីប្រទេសនិងព័ត៌មានផ្សេងៗទាក់ទងនឹងការចាប់អ្នកនយោបាយប្រឆាំងរាប់ពាន់នាក់ដាក់ឃុំឃាំងបានធ្វើឲ្យសភាជាន់ទាបអន់ចិត្ត ។ ការសន្យាសម្ងាត់របស់ប្រធានាធិបតីបាត់កេរ្តិ៍ឈ្មោះម្នាក់ ដែលធ្វើឡើងមុនការដួលរលំនៃក្រុងព្រៃនគរគឺគ្មានតម្លៃនិងមិនបានការ ។

នៅពេលដែល ហូលប្រ៊ូក ចូលតុអង្គុយទល់មុខ ដាន់ ហៀន រណ្ដៅនៃការសង្ស័យមួយដែលមើលមិនឃើញ និងគំនុំ មានសភាពទៅជាក្រហូងយ៉ាងខ្លាំង ។ លោក ហ្វ្រង់ ស៊ីវើត ទទួលបន្ទុកបញ្ហាទាហានបាត់ខ្លួននៅក្រសួងការបរទេសអាមេរិកាំង ហើយដែលត្រូវអញ្ជើញទៅចូលរួមក្នុងការចរចានៅខែឧសភា និងមិថុនា បានត្រូវធ្វើឲ្យភ្ញាក់ផ្អើលអំពីលក្ខណៈនិងការនិយាយដោយប្រយ័ត្នប្រយែងរបស់ ហូលប្រ៊ូក លើកនេះ ដែលតាមទម្លាប់គាត់ជាមនុស្សរាក់ទាក់ជាងគេ ។ ស៊ីវើត និយាយថា “ខ្ញុំដណ្ដឹងសួរក្នុងចិត្តថា តើ Dick (ជាឈ្មោះហៅក្រៅរបស់ ហូលប្រ៊ូក) បានទទួលសេចក្ដីបង្គាប់យ៉ាងម៉ឺងម៉ាត់ពីរឿងនេះមែនឬ ។ ទាល់តែនៅពេលក្រោយមកទើបខ្ញុំដឹងនូវអ្វី ដែលធ្វើឲ្យគាត់អន់ចិត្ត” ។ នៅមុនការចេញដំណើររបស់គាត់ទៅក្រុងប៉ារីស ហូលប្រ៊ូក បានត្រូវឲ្យព័ត៌មានដោយ អេហ្វ.ប៊ី.អាយ.(F.B.I.)ថា ចារបុរសម្នាក់ក្នុងផ្ទៃរដ្ឋាភិបាល ហើយប្រហែលក្នុងផ្ទៃក្រសួងការបរទេសដែរ បានបញ្ជូនទៅឲ្យវៀតណាមនូវសារទូរលេខសម្ងាត់ទាំងឡាយ ដែលត្រៀមទុកសម្រាប់ពួកអាមេរិកាំង ។ ខេនឃ៊ីន នឹកឃើញថា យើងមិនបានដឹងព័ត៌មានអ្វីដែលវៀតណាមដឹងទេ ប៉ុន្តែ យើងមិនអាចគេចចេញពីការចាប់អារម្មណ៍ដ៏ចម្លែករបស់វៀតណាមនៅអង្គុយទល់មុខយើង ដែលប្រហែលជាត្រូវផ្ដល់ព័ត៌មានគ្រប់គ្រាន់ដូចយើងដែរ ចំពោះការណែនាំដែលយើងបានទទួលសម្រាប់ការចរចាដែលកំពុងតែប្រព្រឹត្តទៅនេះ” ។ ប៉ុន្តែ បើពិនិត្យឲ្យជ្រៅជ្រះទៅការរកឃើញរឿងចារកម្មនេះ ពុំបានធ្វើឲ្យដំណើរការចរចាផ្លាស់ប្ដូរធំដុំឡើយ វៀរលែងតែអាកប្បកិរិយារបស់ ហូលប្រ៊ូក ។ ពួកអាមេរិកាំងបានសន្និដ្ឋានពីរឿងនេះថា បើសិនវៀតណាមដឹងពីការណែនាំរបស់យើង ពួកគេមុខជាដឹងថា យើងក៏គ្មានអ្វីនឹងផ្ដល់ឲ្យដូចដែល Dick ធ្លាប់បានប្រកាសជាសាធារណៈឲ្យដឹងរួចមកហើយដែរ ។

អ្វីដែល ហូលប្រ៊ូក ផ្ដល់ឲ្យ-យ៉ាងច្រើនត្រឹមតែការសន្យាផ្ដល់ជំនួយមិនប្រាកដប្រជាមួយដោយមិនចំពោះប៉ុណ្ណោះ បន្ទាប់ពីការធ្វើឲ្យទំនាក់ទំនងមានប្រក្រតីភាព-ពុំមែនជារបស់ដែល ហៀន ចង់បានទេ ។ វៀតណាម ដែលទើបនឹងផ្ដល់ឲ្យដំណឹងថ្មីៗស្ដីពីទាហានបាត់ខ្លួនម្ដងទៀត មានបំណងចង់ឲ្យអាមេរិកាំងតបគុណមកវិញ ។ ហៀន បានតួញត្អែរដាក់ ហូលប្រ៊ូក ថា “តើឲ្យត្រឡប់ទៅក្រុងហាណូយវិញ ដោយដៃទទេយ៉ាងម៉េច? ព្រោះការិយាល័យស្រាវជ្រាវដែលបញ្ជូនមកឲ្យខ្ញុំ (ដាន់ ហៀន) នូវព័ត៌មានស្ដីពីទាហានអាមេរិកបាត់ខ្លួននឹងសួរខ្ញុំថា តើខ្ញុំមានបានទទួលអ្វីជាថ្នូរមកវិញទេ ។ ហូលប្រ៊ូក ក៏តួញត្អែរទៅវិញថា រដ្ឋាភិបាលរបស់ខ្ញុំរកធ្វើអ្វីពុំកើតដោយសភាជាន់ទាបដែរ ។ ទឡ្ហីករណ៍នេះពុំមានឥទ្ធិពលទៅលើ ហៀន ឡើយ ។ ហៀន បានស៊ើកសម្ដីមកវិញថា “តើលោកធ្វើយ៉ាងណា បើសិនជារដ្ឋសភាជាតិរបស់វៀតណាមបោះឆ្នោតអនុម័តច្បាប់មួយដោយហាមឃាត់មិនឲ្យមានការស្វែងរកទាហានអាមេរិកបាត់ខ្លួន?” ។ ពួកវៀតណាមបានសម្ដែងឲ្យឃើញការប្រុងប្រៀបសម្រុះសម្រួលគ្នាអំពីចំនួនទឹកប្រាក់ និងរបៀបបង់ប្រាក់ជាស្រេច ៖ “សម្រាប់យើងមួយដុល្លារគឺមួយដុល្លារ យើងមិនគិតថាវាចេញមកពីកន្លែងណាទេ” ។ ហូលប្រ៊ូក បានឆ្លើយតបវិញថា ៖ “យើងនឹងជួយលោក

*តាមរយៈអង្គការអន្តរជាតិផ្សេងៗ» ។ ហៀន បានប្រាប់ខ្ញុំជាសម្ងាត់ថា ៖ «ប៉ុន្តែ នៅពេលដែលខ្ញុំសួរគាត់ពីចំនួនទឹកប្រាក់នៃជំនួយនេះ គាត់ចៀសវាងមិនឆ្លើយតបនឹងខ្ញុំឡើយ»ទុកណាជាយើងនិយាយបូរបាច់ដោយឡែកនៅក្រោយពេលចប់កិច្ចប្រជុំសន្និសីទក៏ដោយ ។ នៅពេលនេះតែម្តង ការខកចិត្តនិងភាពក្រៀមក្រំបានលេចឡើងនៅលើផ្ទៃមុខរបស់គាត់ ថ្វីត្បិតតែគាត់មានអាការៈស្ងៀមស្ងាត់និងសើចញញឹមក៏ដោយ ។ ហូលប្រ៊ុក បានសាកល្បងធ្វើឲ្យ ហៀន ជឿជាក់លើគាត់ដោយបំភ្លឺថា សភាជាន់ទាបជារឿងមួយ ហើយសេតវិមានជារឿងមួយទៀត ។ តាមគាត់ថា គេមិនគួរទាញសេចក្តីសន្និដ្ឋានជាស្ថាពរពីការបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រឡើយ ។ ហៀន បាននិយាយប្រាប់ខ្ញុំថា «បាទ! ខ្ញុំយល់ព្រម ។ អ្វីដែលធ្វើឲ្យទាស់ចិត្តគឺក្រសួងការបរទេសពុំមានសេចក្តីក្លាហានឲ្យដំណឹងដល់សភាជាន់ទាបនិងទស្សនៈជាជំហរផ្ទាល់របស់ក្រសួងស្តីពីបញ្ហាជំនួយដល់ប្រទេសវៀតណាមនេះឯង»[២៤] ។*

*បរាជ័យនេះ រួមទាំងការរំដើបរំជួលដែលផុសផុលឡើងក្នុងជួរពួកអភិរក្សនិយមផង គឺជាសញ្ញាឲ្យដឹងពីទីបញ្ចប់នៃគំនិតផ្តួចផ្តើមនយោបាយការបរទេសលើកដំបូងរបស់ប្រធានាធិបតី ខាធ័រ ។ តាមការពិត វ៉ូដខូក បានទទួលស្គាល់រឿងនេះក្រោយមកថា រដ្ឋាភិបាលពុំបានវាស់ស្ទង់ទំហំនៃការប្រឆាំងជំទាស់របស់ពួកមេខ្លោងនៃសភាជាន់ទាបនិងបណ្តាមជ្ឈដ្ឋានអ្នកស្នេហាសេរីភាពអំពីការផ្តល់ជំនួយមួយទៅឲ្យប្រទេសវៀតណាមឡើយ ។ នៅខែមិថុនា រដ្ឋសភាជាតិបានអនុម័តដោយសំឡេងលើសលប់នូវវិសោធនកម្ម គម្រោងច្បាប់មួយស្តីពីការផ្តល់ជំនួយផ្នែកសេដ្ឋកិច្ចទៅឲ្យបរទេស ។ អត្ថបទច្បាប់នេះដែលបង្ហាញជូនដោយលោក ឡេស្ទ័រ វ៉ូល អ្នកតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យ បានបដិសេធដោយដាក់លាក់មិនទទួលដឹងឮនូវពាក្យសម្តីរបស់ប្រធានាធិបតី និចសុន ថា ៖ ទឹកប្រាក់ចំនួន៣.២៥០លានដុល្លារដែលសន្យាផ្តល់ឲ្យវៀតណាមនឹងមិនត្រូវផ្តល់ឲ្យទេ ។ ពេលបើកធ្វើការពិភាក្សា លោកប្រធានាធិបតី ខាធ័រ បានបញ្ជូនលិខិតមួយទៅឲ្យប្រធានសភា ដើម្បីសុំឲ្យគាត់ធ្វើយ៉ាងណាកុំឲ្យសេរីភាពដែលបណ្តាធនាគារអន្តរជាតិមានក្នុងការផ្តល់ទឹកប្រាក់កម្ចីត្រូវកម្រិតកំណត់ដោយការធ្វើវិសោធនកម្ម(សេចក្តីស្នើកែច្បាប់)មួយនោះ ។ ប៉ុន្តែ ជាការឥតប្រយោជន៍ ។ ដោយមិនរវល់នឹងអនុសាសន៍របស់ប្រធានាធិបតី អ្នកតំណាងរាស្ត្របានអនុម័ត វិសោធនកម្មច្បាប់មួយដោយសំឡេងភាគច្រើនលើសលប់ហាមប្រាមមិនឲ្យមូលធនរបស់អាមេរិកាំងឆ្លងកាត់«ដោយផ្ទាល់ឬដោយប្រយោល»ព្រំដែនប្រទេសវៀតណាម-ក៏ដូចព្រំដែនប្រទេសកម្ពុជា ឡាវ និងប្រទេសអ៊ូហ្គង់ដាដែរ ។*

*ទោះបីជាលោក ហូលប្រ៊ុក និង វ៉ាន់ស៍ នៅតែជាសកម្មជននៃការធ្វើឲ្យមានប្រក្រតីភាពមួយជាមួយប្រទេសវៀតណាមក៏ដោយ ក៏អ្នកទាំងពីរមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីផ្តើមធ្វើការប្រយុទ្ធជាមួយវិមានកាពីតូល (វិមានដែលជាទីស្នាក់ការរបស់គណបក្សប្រជាធិបតេយ្យ និងគណបក្សសាធារណរដ្ឋនិយម) ដែរ រួមទាំងការផ្តល់ជំនួយមួយត្រឹមតែមនុស្សធម៌ក៏មិនបានផង ។ ដោយលែងភ័យខ្លាចអ្វីទាំងអស់ នៅខែសីហា លោក ខាធ័រ បាន*

ចុះហត្ថលេខាជាមួយប្រទេសប៉ាណាម៉ានូវសន្ធិសញ្ញាដ៏ចម្រូងចម្រាសមួយស្តីពីបញ្ហាព្រែកជីក (ប៉ាណាម៉ា) ។ ហេតុអ្វីបានជាគាត់ប្រថុយគ្រោះថ្នាក់ដោយយកអ្នកខ្លះដែលមានភក្តីភាពចំពោះសន្ធិសញ្ញាជាសត្រូវទៅវិញ ហើយប្រកាន់ជំហរមួយអំពីបញ្ហាវៀតណាមដែលមិនជាទីពេញចិត្តរបស់ប្រជាពលរដ្ឋភ្លាមៗបែបនេះ? ។

ទោះជាលោក ហូលប្រ៊ូក និងអេគីបរបស់គាត់បានជួប ផាន់ ហៀន ជាថ្មីនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៧ ក្តី សេចក្តីសង្ឃឹមក្នុងការធ្វើឲ្យមានប្រក្រតីភាពនៅតែធ្វើឲ្យខ្វល់គំនិតដដែល ។ កិច្ចការរបស់ចារបុរសវៀតណាម ក៏មានចំណែកក្នុងរឿងនេះដែរ ។

ដោយពិត ចាប់ពីមានដំណឹងសម្ងាត់មួយដែលផ្តល់ដោយ ឃ្វីន ក្នុងអំឡុងសរទរដូវ ក្រុមអេហ្វ.ប៊ី.អាយ. បានរកឃើញអត្តសញ្ញាណមន្ត្រីរដ្ឋការអាមេរិកាំងដែលសង្ស័យថាជាអ្នកឲ្យការណ៍ទៅវៀតណាម ហើយបានតាមដានដោយការលួចស្តាប់ការសន្ទនាតាមទូរស័ព្ទ ។ សម្រាប់ជាលើកដំបូងបង្អស់ នៅពេលដែលគាត់ឃើញសំណៅថតចម្លងនៃសារទូរលេខសម្ងាត់ជាច្រើនដែលអេហ្វ.ប៊ី.អាយ.ប្រគល់ឲ្យ ហូលប្រ៊ូក នៅខែមិថុនា ឃ្វីន បាននឹកពិភាលក្លាមថា អ្នកប្រព្រឹត្តល្មើសប្រហែលជាមានសាច់ញាតិនិងចំណងមនោសញ្ចេតនានៅប្រទេសវៀតណាមហើយមើលទៅ និងទំនងជាអ្នករងគ្រោះពីការគំរាមហែកគេ្តីមួយផងក៏មិនដឹង ។ គាត់គិតទៅដល់លោក រ៉ូណាល់ ហ៊ុមហ្វ្រី ដែលជានិយោជិកម្នាក់នៅមជ្ឈមណ្ឌលប្រតិបត្តិការនៃទីភ្នាក់ងារព័ត៌មានសហរដ្ឋអាមេរិក *(United States Information Agency)* ដែលមកជួបគាត់នៅខែមីនា ដើម្បីស្នើឲ្យគាត់ជួយធ្វើឲ្យមិត្តនារីរបស់គាត់នៅប្រទេសវៀតណាមបានចាកចេញពីប្រទេសនេះ ។ នៅពេលនោះ ឃ្វីន បានត្រៀមខ្លួនចេញដំណើរទៅក្រុងហាណូយជាមួយនឹង វូដខូក ដែរ ។ ខុសប្លែកពី វូដខូក ដែលនិយាយប្រាប់វៀតណាមដោយផ្ទាល់ពីបញ្ហាគូដណ្តឹងរបស់វរសេនីយ៍ឯក ម៉ាធ័រ, ឃ្វីន បានទៅជួបមន្ត្រីស្ថានទូតស៊ុយអែដ ដើម្បីឲ្យជួយជំរុញសំណុំឯកសារអន្តោប្រវេសន៍របស់មិត្តស្រី ហ៊ុមហ្វ្រី ជឿនទៅមុខ ។

ការតាមឃ្លាំមើលដែលបំពេញដោយអេហ្វ.ប៊ី.អាយ បានទទួលផ្លែផ្កា ។ ហ៊ុមហ្វ្រី ដែលមិនដឹងគេតាមដានបានទៅជួប ឃ្វីន ម្តងម្កាល ដើម្បីនិយាយពីរឿងក្មេងស្រីប្រាប់គាត់ និងស៊ើបសួរពីវឌ្ឍនភាពនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ។ ឃ្វីន បានដំណាលថា ៖ “នៅពេលនោះ ខ្ញុំពិបាកអត់ទ្រាំធ្វើហាក់ដូចជាឥតមានរឿងហេតុអ្វីកើតឡើងណាស់” ។ ហ៊ុមហ្វ្រី ដែលឥតសង្ស័យអ្វីទាល់តែសោះ បានបន្តចម្លងឡើងវិញនូវសារទូរលេខសម្ងាត់ទាំងអស់របស់ក្រសួងការបរទេសដែលធ្លាក់ក្នុងដៃគាត់ មុននឹងប្រគល់ទៅឲ្យ ដេវីដ ទ្រឿង ។ ទ្រឿង ជាយុទ្ធិកជនសន្តិភាពនិយមម្នាក់ និងជាកូនប្រុសរបស់អតីតបេក្ខជនប្រធានាធិបតី ត្រាន់ ឌិញ ហ្សូ ដែលពេលនោះត្រូវចាប់ដាក់គុកទៅហើយ ។ តួនាទីរបស់គាត់គឺ បញ្ជូនឯកសារទាំងនេះឲ្យទៅដល់គណៈប្រតិភូរបស់វៀតណាមនៅអង្គការសហប្រជាជាតិ ឬស្ថានទូតវៀតណាមនៅទីក្រុងប៉ារីស ។

ទីបំផុត នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានលះបង់គំនិតមិនទទួលប្រាក់កាសណាមួយពីពួកអាមេរិកាំង

ឡើយ មុនការធ្វើទំនាក់ទំនងការទូតមានប្រក្រតីភាពឡើងវិញ ។ ប៉ុន្តែ ដោយមិនដឹងថា ការប៉ុនប៉ងស៊ើបការណ៍របស់វៀតណាមត្រូវអេហ្វ.ប៊ី.អាយ.ដឹងឮ ពួកគេនៅតែទាមទារថា សហរដ្ឋអាមេរិកត្រូវតែសន្យាជួយពួកគេជានិច្ច ។ ជាឧទាហរណ៍ នៅពេលដែល ហៀន ចូលទៅអង្គុយនៅតុចរចាទល់មុខនឹង ហូលប្រ៊ុក ជាលើកទីបី គាត់នៅតែនិយាយដោយគ្មានប្រាកដក្នុងចិត្តពីសំណើសុំជំនួយរបស់គាត់ម្តងទៀត ។ ក្នុងរយៈពេលនៃការឈប់សម្រាកខ្លីមួយ គាត់សង្ឃឹមថា «ឱកាសដើម្បីនិយាយតទល់គ្នាតែពីរនាក់ជាមួយអ្នកចរចាអាមេរិកាំងមកដល់ហើយ ។ ដោយនិយាយជាភាសាបារាំងគ្មានចាំបាច់រកអ្នកបកប្រែ និងគ្មានសរសេរក្រដាស ហៀន បានសួរទៅ ហូលប្រ៊ុក ថាតើ លោកនៅចាំដំណាក់កាល ក និង ខ នៃកិច្ចព្រមព្រៀងដែលព្រាងដោយអ្នកចរចាអាមេរិកាំងនិងវៀតណាមកាលពីឆ្នាំ១៩៦៦ទេ? ។ដំណាក់កាល ក គឺរួមមានការបញ្ឈប់ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅប្រទេសវៀតណាម ។ ចំណែកដំណាក់កាល ខ គឺសម្រាប់ប្រើជាក្របខ័ណ្ឌនៃការដាក់ឲ្យប្រើប្រាស់ដោយភាគីទាំងពីរនូវការប្រុងប្រៀបមួយចំនួនតូចដែលត្រូវរក្សាជាការសម្ងាត់ ។ ហៀន បានឲ្យយោបល់អំពីការបន្តឡើងវិញនូវសកម្មភាពមួយប្រភេទដូចគ្នានេះ ។ នៅក្នុងរយៈកាលដំបូង ប្រទេសទាំងពីរនឹងធ្វើឲ្យទំនាក់ទំនងរបស់ខ្លួនមានប្រក្រតីភាពឡើងវិញ ហើយក្នុងរយៈកាលទីពីរ គឺបន្ទាប់ពីការធ្វើឲ្យមានប្រក្រតីភាព សហរដ្ឋអាមេរិកនឹងប្រកាសជាឯកតោភាគីនូវការផ្តល់ជំនួយមួយជាទម្រង់អ្វីក៏ដោយទៅឲ្យប្រទេសវៀតណាម ។ វៀតណាមប្រាថ្នាថា ពួកអាមេរិកាំងត្រូវប្រកាន់ការសន្យាមួយតាមរបៀបក្រៅផ្លូវការចំពោះរឿងនេះនៅដំណាក់កាល ខ ។ ហៀន បានអង្វរករថា ៖ «គ្រាន់តែខ្សឹបដាក់ត្រចៀកខ្ញុំពីតួលេខដែលលោកស្នើជូនគឺបានហើយ» ។ ហូលប្រ៊ុក នឹកឃើញឆ្លើយតបថា ៖ «ខ្ញុំសោកស្តាយណាស់ ខ្ញុំពុំត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះឡើយ ។ គាត់ក៏ប្រានបោលពីការឲ្យដករបាំងផ្នែកពាណិជ្ជកម្មដែលនឹងរួមបង្កជាជំហានដំបូងមួយឆ្ពោះទៅរកការធ្វើឲ្យមានប្រក្រតីភាពឡើងវិញដែរ ។ ក្រុងហាណូយដែលទើបនឹងចេញផ្សាយជាសាធារណៈនូវច្បាប់វិនិយោគទុនរបស់ខ្លួន គ្មានចង់បានអ្វីក្រៅពីបញ្ចូលបណ្តាក្រុមហ៊ុនរបស់អាមេរិកាំងក្នុងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់ប្រទេសឡើយ ។ តាមមន្ត្រីផ្លូវការអាមេរិកាំងម្នាក់ ដែលចូលរួមក្នុងសម័យប្រជុំថា ៖ «វៀតណាមហាក់ដូចជាភ្ញាក់ផ្អើលនៅពេលដែល ហូលប្រ៊ុក ឆ្លើយតបទៅគេវិញថា មិនអាចទៅរួចទេ» ។[២៥]

ក៏ប៉ុន្តែ ហូលប្រ៊ុក បានឲ្យយោបល់-ម្យ៉ាងទៀត នេះគឺជាសំណើថ្មីតែមួយរបស់គាត់-ថា ប្រទេសទាំងពីរត្រូវបង្កើតឲ្យមានគណៈបេសកកម្មទំនាក់ទំនងក្នុងរដ្ឋធានីផ្ទាល់រៀងៗខ្លួន ។ នេះជារូបមន្តអន្តរកាលដើម្បីរង់ចាំការបង្កើតទំនាក់ទំនងការទូតពេញលេញ បន្ទាប់ពីការដោះស្រាយបញ្ហាដែលនៅមានចប់សព្វគ្រប់ ។ ដោយគិតទៅដល់ការបើកគណៈបេសកកម្មទំនាក់ទំនងនៅក្រុងប៉េកាំងនិងក្រុងវ៉ាស៊ីនតោនកាលពី ខែកុម្ភៈ ឆ្នាំ១៩៧៣ ហៀន បានឆ្លើយតបថា «យើងមិនចង់ធ្វើដូចពួកចិនទេ» ។ បួនឆ្នាំក្រោយមក ការណ៍ដែលថាការធ្វើឲ្យមានប្រក្រតីភាពពេញលេញនូវទំនាក់ទំនងផ្សេងៗរវាងប្រទេសទាំងពីរដែលនៅពុំទាន់បានសម្រេចគឺពុំមែនជាការលើកទឹកចិត្ត

មួយសម្រាប់វៀតណាមទេ ។ ក្រុងហាណូយប្រហែលជាសោកស្ដាយយ៉ាងឈឺចាប់នូវការបដិសេធនេះ នៅពេលដែលដំណើរនៃការធ្វើឲ្យមានប្រក្រតីភាពរវាងចិន-អាមេរិកាំងបានចាប់ផ្ដើមដោយពិតប្រាកដនៅឆ្នាំដដែលនោះ ។

ដោយជាក់ស្ដែង វៀតណាមពុំយល់ពីចំណុចរអាក់រអួលខ្លះនៃរឿងរ៉ាវ (វ័រធីហ្គេត)-ដែលពីដំបូងជាព្រឹត្តិការណ៍ល្អមួយកើតមានចំពេល-ដែលនឹងបំផ្លាញផលប្រយោជន៍របស់ពួកគេចាប់ពីថ្ងៃនេះទៅឡើយ ។ នៅសហរដ្ឋអាមេរិក ការសុំលាលែងពីតំណែងរបស់ប្រធានាធិបតី និចសុន បានបង្កឲ្យមានចលាចលខាងនយោបាយមួយភ្លាម ដែលលទ្ធផលច្បាស់ជាងគេគឺការធ្វើឲ្យតំណែងប្រធានាធិបតីចុះខ្សោយ ។ នៅនិទាឃរដូវឆ្នាំ១៩៧៥ ពួកមេដឹកនាំក្រុងហាណូយបានចាប់ឱកាសអស់សង្ឃឹមនេះ ហើយចាប់ផ្ដើមការប្រយុទ្ធដូចផ្គរលាន់របស់ខ្លួននៅភាគខាងត្បូងភ្លាម ។ នៅពេលនេះ ការចុះខ្សោយនៃតំណែងប្រធានាធិបតី គឺជាឧបសគ្គធំបំផុតក្នុងការបង្ខំឲ្យដកបំរាមជំនួយអាមេរិកាំង ពីព្រោះវាធ្វើឲ្យសភាជាន់ទាបមានអំណាចរឹតតែខ្លាំងឡើង ។ លោក និចសុន បានបំពានសាធារណៈមតិតាមអំណាចចិត្តខ្លួន ដោយបញ្ជូនយន្តហោះបេ-៥២ ទៅទម្លាក់គ្រាប់បែកលើទីក្រុងហាណូយ ដោយសន្យាផ្ដល់ជំនួយទៅឲ្យគូសត្រូវរបស់ខ្លួនជាសម្ងាត់ ហើយវៀតណាមសង្ឃឹមថា ខាធ័រ នឹងទៅជានិចសុន ម្នាក់ដែលស្រឡាញ់សន្តិភាព ។ ប៉ុន្តែ វៀតណាមមិនយល់ថា បន្ទាប់ពីរឿងរ៉ាវវ័រធីហ្គេត និងបរាជ័យផ្នែកយោធានៅឥណ្ឌូចិន ការតថ្លៃគ្នាជាសម្ងាត់តាមរបៀប និចសុន-គីស៊ីងហ្គ័រ លែងត្រូវកាលៈទេសៈទៀតហើយនៅសហរដ្ឋអាមេរិក ។ មិនយូរប៉ុន្មាន ពួកគេបានសម្គាល់ឃើញដោយស្រឡាំងកាំងថា ប្រទេសរបស់គេលែងមានជំហរខ្លាំងហើយនៅលើឆាកនយោបាយអាមេរិកាំង ហើយថា ដោយប្រឈមមុខនឹងការប្រឆាំងរបស់សភាជាន់ទាប ខាធ័រ បានចុះចាញ់ព្រមគ្នានឹងការដាក់ឲ្យពិនិត្យឡើងវិញនូវការសន្យាដែលធ្វើឡើងតាមរយៈវ៉ូដខូក ក្នុងការផ្ដល់ជំនួយមនុស្សធម៌មួយផង ។ សម្រាប់ប្រទេសវៀតណាមអំណឹះតទៅ ការជ្រើសរើសរវាងលទ្ធភាពពីរគឺជារឿងធម្មតាមួយក្នុងចំណោមរឿងធម្មតាជាច្រើន ៖ ឬមួយបោះបង់គំនិតលែងបង្ខំឲ្យគេធ្វើតាមលក្ខខណ្ឌរបស់ខ្លួន ឬលះបង់ចោលសេចក្ដីសង្ឃឹមទាំងអស់ដើម្បីទាញគុណប្រយោជន៍ពីប្រាក់ដុល្លារ និងបច្ចេកវិជ្ជារបស់អាមេរិកាំង ហើយបែរទៅរកក្រុងមូស្គូវិញ ។

បរាជ័យក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយសហរដ្ឋអាមេរិកនិងអលទ្ធភាពក្នុងការបង្កើតទំនាក់ទំនងផ្នែកពាណិជ្ជកម្ម បានរួមបង្កជាការខកចិត្តដ៏សម្បើមសម្រាប់ប្រទេសវៀតណាម ។ ក្នុងនោះក៏មានបរាជ័យ នៃនយោបាយបើកទ្វារឲ្យមូលធនបរទេសចូលដែរ ដែលលទ្ធផលជាក់ស្ដែង គឺប្រាក់កម្ចីមួយចំនួន៣៥លានដុល្លារពីអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងប្រាក់កម្ចីមួយចំនួន៤៩លានដុល្លារពីអង្គការសហប្រជាជាតិទុកសម្រាប់ធ្វើហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍មួយ ។

ធនាគារិកអាមេរិកាំងម្នាក់ដែលកំពុងធ្វើទស្សនកិច្ចនៅក្រុងហាណូយ បាននិយាយប្រាប់ខ្ញុំជាសម្ងាត់ថា ៖ «គាត់ត្រូវធ្វើឲ្យងឿងឆ្ងល់ ពីភាពចេះឱនលំទោនតាមកាលៈទេសៈនិងការនិយមសាច់ការ» ដែលសម្ដែងឲ្យឃើញ

ដោយពួកអ្នកចរចាររបស់វៀតណាមក្នុងទំនាក់ទំនងរបស់គេជាមួយអ្នករកស៊ីលោកខាងលិច ។ ក៏ប៉ុន្តែ ទោះបីជាមានការនិយមសាច់ការ និងលក្ខណៈសេរីនិយមខ្លាំងនៃច្បាប់វិនិយោគរបស់វៀតណាមនេះក៏ដោយ ក៏ពួកវិនិយោគិនបរទេសមិនបន្ទឹមកកាន់ក្រុងហាណូយដែរ ។ អ្នកដែលសាកល្បងធ្វើការពិសោធន៍ បានត្រូវធ្វើឲ្យបាក់ទឹកចិត្តយ៉ាងឆាប់រហ័ស ដោយសារបែបបទការិយាធិបតេយ្យរបស់វៀតណាម និងបរិយាកាសសង្ស័យដែលរក្សាឲ្យស្ថិតស្ថេរដោយផ្នែកសន្តិសុខ ។ សេចក្តីសង្ឃឹមរបស់វៀតណាមចង់ឃើញការកកើតឡើងនូវចំណងទាក់ទងមិត្តភាពនិងសហប្រតិបត្តិការជាមួយអឺរ៉ុបខាងលិច បានត្រូវរារាំងដោយភាពមិនអើពើនិងមិនយោគយល់មួយ ។

ដើម្បីបង្ហាញឲ្យឃើញច្បាស់នូវឆន្ទៈរបស់ប្រទេសខ្លួនក្នុងការបើកទ្វារឆ្ពោះទៅរកបស្ចិមប្រទេស នាយករដ្ឋមន្ត្រីវៀតណាមបានជ្រើសរើសប្រទេសបារាំងសម្រាប់ដំណើរជាលើកដំបូងរបស់គាត់ទៅបរទេស នៅក្រោយពេលបញ្ចប់មហាសន្និបាតបក្ស ។ គាត់ចង់បញ្ចូលរដ្ឋធានីផ្សេងៗទៀតនៅអឺរ៉ុបខាងលិចក្នុងដំណើរគោចររបស់គាត់ជុំវិញទ្វីបនោះដែរ ដើម្បីបង្កើនថែមទៀតនូវសារសំខាន់នៃសុឆន្ទៈរបស់គាត់ ។ ប៉ុន្តែ ដោយខ្លាចក្រែងមានការជំទាស់ខាងក្នុងប្រទេស និងដោយចង់ទុកឲ្យអាមេរិកជាអ្នកផ្តួចផ្តើមគំនិត ភាគច្រើននៃបណ្តាប្រទេសនៅអឺរ៉ុបខាងលិច លើកលែងតែប្រទេសដាណឺម៉ាក ន័រវែស និង ហ្វាំងឡង់ បានបដិសេធដោយគួរសមមិនទទួលស្វាគមន៍ ដុង នៅពេលគត់បញ្ចប់ទស្សនកិច្ចនៅប្រទេសបារាំងឡើយ ។ ចម្លើយរបស់ទីភ្នាក់ងារដាណឺម៉ាកដើម្បីអភិវឌ្ឍន៍ ដែលរៀបចំជួយដល់ប្រទេសវៀតណាម"ក្នុងព្រំដែនកំណត់មួយ"នោះគឺមានលក្ខណៈគ្រាន់តែជាតំណាងប៉ុណ្ណោះ[២៦] ។

ដំណើរជាប្រវត្តិសាស្ត្ររបស់ ដុង ទៅកាន់ប្រទេសបារាំង ក៏ត្រូវកត់សម្គាល់ដោយនិមិត្តរូបផ្សេងៗ និងដោយការជួបគ្នាជាថ្មីដ៏រំជួលចិត្ត ជាងដោយការសន្យាផ្តល់ហិរញ្ញវត្ថុជាក់លាក់ ។ លោកប្រធានាធិបតី វ៉ាឡេរីហ្ស៊ីស្ការដ៍ ដេស្តាំង បានរៀបចំជូនអតីតអ្នកបដិវត្តន៍នូវពិធីបដិសណ្ឋារកិច្ចដ៏រុងរឿងមួយនៅវិមាន អេលីសេ ។ កិច្ចព្រមព្រៀងមិនសំខាន់ចំនួនពីរផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ចនិងវប្បធម៌បានត្រូវចុះហត្ថលេខា ។ អំណោយរបស់លោកខាងលិច ដែលក្រុងហាណូយសង្ឃឹមយ៉ាងខ្លាំងនៅពុំទាន់មកដល់ទេ ។ អ្នកការទូតបារាំងម្នាក់បានអះអាងពីរឿងនេះនៅពេលក្រោយមកថា : វៀតណាមបានត្រឡប់ទៅវិញទាំងក្រៀមក្រំ ហើយការខកចិត្តរបស់គេ មានទំហំស្មើនឹងសេចក្តីសង្ឃឹមរបស់គេដែរ"[២៧] ។

នៅប្រទេសវៀតណាម សេចក្តីសង្ឃឹមនិងការខកចិត្តស្រាប់តែកើតមានដោយមិនបានប្រុងមុននៅក្នុងផ្ទៃប្រទេសចំកាលៈទេសៈមួយសំខាន់បំផុត ដោយសារការកើតមានព្រមគ្នានូវវិបត្តិសេដ្ឋកិច្ច និងការប្រឈមមុខយ៉ាងខ្លាំងក្លារវាងអ្នកប្រកាន់តាមមនោគមវិជ្ជានិងអ្នកនិយមសាច់ការ ។ ឆ្នាំ១៩៧៧គឺជាឆ្នាំអពមង្គលមួយ ។ អ្វីៗហាក់ដូចជាត្រូវធ្វើឲ្យប្រែត្រឡប់ទាំងអស់ ។ នៅខែកុម្ភៈ ផលដំណាំនៅភាគខាងជើងបានទទួលរងការខូចខាត

យ៉ាងសម្បើម ដោយសារអាកាសធាតុគ្រាំគ្រាខ្លាំងមួយ ។ តមកទៀត ប្រទេសនេះ បានទទួលរងនូវភាពរាំងស្ងួតដ៏ធ្ងន់ធ្ងរជាច្រើនខែបន្តដោយគ្រោះទឹកជំនន់មួយដែលបណ្តាលឲ្យមានការវិនាសដ៏ធំ ហើយនៅទីបំផុតការខ្វះស្បៀងអាហារដ៏សម្បើមមួយ ។ នៅខែមីនាឆ្នាំដដែល ប្រទេសវៀតណាមបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងបណ្តាប្រទេសជាមិត្ត ប៉ុន្តែ មិនសូវជាបានជោគជ័យធំដុំឡើយ ។ ចំណែកផ្នែកឧស្សាហកម្មរបស់ខ្លួនក៏បានរងទទួលការខ្វះខាតប្រេងឥន្ធនៈនិងគ្រឿងបន្លាស់ផងដែរ ។

គេប្រហែលជានៅតែមិនដឹងពីភាគល្អិតល្អន់នៃការជជែកពិភាក្សារបស់ការិយាល័យនយោបាយនៃគណបក្សកុម្មុយនីស្តវៀតណាមទាក់ទងទៅនឹងការសម្រេចសំខាន់ៗខាងផ្នែកនយោបាយក្រៅប្រទេស និងក្នុងប្រទេសផងទេ ។ ប៉ុន្តែ នៅទីក្រុងហាណូយ អ្នកសង្កេតការណ៍ដែលយកចិត្តទុកដាក់ខ្លាំងជាងគេ មិនភ្លេចនឹងធ្វើឲ្យលេចឡើងនូវសញ្ញានៃការបែកបាក់គ្នាក្នុងផ្ទៃនៃក្រុមមេដឹកនាំឡើយ[២៨] ។

ប្រាកដហើយ គណបក្សកុម្មុយនីស្តវៀតណាមត្រូវបែកបាក់ជាពីរ ។ ការពិភាក្សាខាងនយោបាយបានប្រព្រឹត្តទៅយ៉ាងវក់វីរវាងអ្នកដែលដើរតាមគូប្រជែងទាំងសងខាង ។ អ្នកនិយមកណ្តាលដែលមាននាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ជាមេខ្លោង បានអួតសរសើរពីការធ្វើសហប្រតិបត្តិការដ៏ជិតស្និទ្ធមួយ ជាមួយបណ្តាប្រទេសលោកខាងលិច ដែលមានឧស្សាហកម្មជឿនលឿននិងការផ្លាស់ទ្រង់ទ្រាយវៀតណាមខាងត្បូងជាលំដាប់លំដោយជាមួយគោលដៅទាញយកផលប្រយោជន៍ប្រសើរលើសគេពីមូលធននិងភាពប៉ិនប្រសប់ក្នុងការចាត់ការគ្រប់គ្រងកិច្ចការរបស់ប្រទេសទាំងនោះ ។ អ្នកផ្សេងទៀត ដែលមាន ទ្រឿង ជិញ នៅជួរទីមួយនិងជាអ្នកនាំពាក្យរបស់ក្រុមនេះ បាននិយាយពីគោលដៅដំបូងគឺការកសាងសង្គមនិយម ការរក្សាភាពស្អាតបរិសុទ្ធផ្នែកមនោគមវិជ្ជា និងការប្រយុទ្ធប្រឆាំងនឹង«ការជ្រៀតចូលនិងការបំផ្លាញសង្គមដែលដឹកនាំដោយខ្មាំងសត្រូវ» ។ ពួកនេះបានជំទាស់ចំពោះសេរីកម្មផ្នែកសេដ្ឋកិច្ច (ការធ្វើឲ្យមានសេរីភាពជាងមុន) និងការបើកទ្វារទៅរកបស្ចិមប្រទេស និងទិតៀនពីភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរទ្រង់ទ្រាយលទ្ធិសង្គមនិយមនៅភាគខាងត្បូងវៀតណាមដែលទើបរំដោះថ្មីៗ ព្រោះជាកន្លែងបង្ករោគ បង្កអំពើពុករលួយនិងភាពអាប់ឱន ដែលនៅពេលនេះ ភាគខាងជើងក៏ត្រូវឆ្លងរោគនេះដែរ ។ ដោយឆ្លៀតទាញយកប្រយោជន៍ ពីដំណើរទៅអឺរ៉ុបរបស់នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ទ្រឿង ជិញ បានផ្តើមធ្វើការវាយប្រហារដ៏ខ្លាំងក្លាមួយ ប្រឆាំងនឹងការដឹកនាំប្រកបដោយគ្រោះថ្នាក់នៃជួរអ្នកការិយាធិបតេយ្យនិយម ហើយអំពាវនាវឲ្យពង្រឹងវិន័យខ្លាំងថែមទៀត ក្នុងចំណោមអង្គការរបស់រដ្ឋាភិបាល ។ ប៉ុន្តែ ពួកក្រុមអ្នកប្រកាន់តឹងបានត្រូវធ្វើឲ្យជឿស៊ប់ក្នុងគំនិតថា បស្ចិមប្រទេសជាសត្រូវនឹងប្រទេសវៀតណាមតាំងពីកំណើត ។ សហរដ្ឋអាមេរិកបានបដិសេធដោយចចេសមិនទទួលស្គាល់ការទទួលខុសត្រូវផ្នែកសីលធម៌របស់ខ្លួន ហើយប្រទេសជប៉ុននិងប្រទេសបារាំង ក៏មានចំណែកក្នុងគណយេ្យមិនថ្លៃថ្នូមួយនៃប្រាក់បំណុលចាស់និងប្រាក់បដិភាគតិចតួចដែរ ។ នៅទីបំផុត របៀបនិយាយចាក់ដោតក្នុងការសន្ទនាទាំងឡាយរបស់ ផាំ វ៉ាន់ដុង

*នៅទីក្រុងប៉េកាំង នាដើមខែមិថុនា បានបំផ្លាញសេចក្តីសង្ឃឹមផ្សេងៗ ដែលទុកដាក់ដោយពួកវៀតណាមក្នុងលទ្ធិប្រតិបត្តិនិយមរបស់ពួកមេដឹកនាំចិនថ្មី និងក្នុងទស្សនវិស័យនៃការធ្វើឲ្យទំនាក់ទំនងជាមួយក្រុងប៉េកាំងមានសកម្មភាពឡើងវិញ ។*

*អ្នកសង្កេតការណ៍បារាំងម្នាក់នៅទីក្រុងហាណូយបានធ្វើឲ្យគេកត់សម្គាល់ពីរឿងនេះថា ៖ “នៅពាក់កណ្តាលឆ្នាំ១៩៧៧ ជួរអ្នកនយោបាយថ្មីមួយបានផុសចេញឡើង ។ នៅប្រទេសវៀតណាម ការផ្លាស់ប្តូរបានកើតឡើងក្នុងសភាពស្ងប់ស្ងៀមដូចសព្វដង ដោយគ្មានការប្រកាសខ្វះខ្វារ និងគ្មានការថ្កោលទោសពួកអ្នកចាញ់ជាសាធារណៈឡើយ ។ មាគ៌ានយោបាយថ្មី បានសម្តែងចេញតាមរយៈការពង្រឹងនយោបាយផ្ទៃក្នុងមួយ ។ បើនិយាយពីនយោបាយក្រៅប្រទេសវិញ គឺវាបានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពមិនអើពើមួយកាន់តែរីកធំឡើងៗចំពោះបស្ចិមប្រទេស និងការរឹតបន្តឹងចំណងទាក់ទងមួយជាមួយប្លុកសង្គមនិយមក្នុងគ្រប់វិស័យទាំងអស់”[២៩] ។*

*នៅចុងខែមិថុនា ឆ្នាំ១៩៧៧ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ដែលរួមប្រជុំពេញអង្គបានអនុម័តកម្មវិធីសមូហភាវូបនីយកម្មដីធ្លី និងសម្រេចបង្កើនកិច្ចការផ្នែកមនោគមវិជ្ជាឲ្យរឹតតែខ្លាំងឡើង[៣០] ។ កម្មវិធីនេះបានកំណត់នៅដើមទសវត្សរ៍៨០ ថាជាការបញ្ចប់ទាំងស្រុងនូវការធ្វើឲ្យវិស័យកសិកម្ម នៅភាគខាងត្បូងមានលក្ខណៈសង្គមនិយម ។ វិធានការសំខាន់ៗផ្សេងទៀតនឹងមានតាមក្រោយ សំដៅធ្វើការលុបបំបាត់ពាណិជ្ជកម្មនិងឧស្សាហកម្មបែបមូលធននិយម ។ ការបង្កើបបន្តិចឲ្យខ្យល់លោកខាងលិចចូល ហាក់ដូចជាបិទដោយខ្លួនឯងវិញ ។*



(លោក) តេង ស៊ាវពីង ថ្លែងសុន្ទរកថានៅសួនច្បារសេតវិមានជាមួយនឹងអ្នកបកប្រែរបស់លោក និង ខាតធ័រ ប្រធានាធិបតីសហរដ្ឋ អាមេរិក នាថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៩ ។ តេង ស៊ាវពីង ជម្រាបលោកប្រធានាធិបតី ខាធ័រ ឲ្យដឹងអំពីផែនការលុកលុយ ប្រទេសវៀតណាមរបស់លោក



មេដឹកនាំសូវៀត អាឡិចស៊ី កុស្សុីហ្គីន ជាមួយ លោកនាយរដ្ឋមន្ត្រីវៀតណាម ផាំ វ៉ាន់ដុង



ការឈឺចាប់ក្នុងសម័យ លន់ នល់ ឆ្នាំ១៩៧២



យុទ្ធនារីវៀតណាមកំពុងក្ដង់កាំភ្លើងបណ្ដើរទាហានចិន
ដែលត្រូវចាប់បានជាឈ្លើយសឹក



ហេង សំរិន



ហ៊ុន សែន



ហេង សំកៃ



សមាជិកការិយាល័យនយោបាយវៀតណាម
ហ័ង វ៉ាន់ហន នៅទីក្រុងប៉េកាំងបន្ទាប់ពីការ
ផ្តាច់ខ្លួនចុះចូលនឹងប្រទេសចិន



រដ្ឋមន្ត្រីការបរទេសវៀតណាម ង្វៀន កូថាច់



នាយករដ្ឋមន្ត្រីវៀតណាម ផាំ វ៉ាន់ដុង



លោកឧត្តមសេនី ត្រាន់ វ៉ាន់ត្រា មេបញ្ជាការរង
នៃកងទ័ពកុម្មុយនីស្តនៅវៀតណាមខាងត្បូង



ហ៊ាំង ទុង និពន្ធនាយកកាសែតប្រចាំថ្ងៃរបស់បក្ស
វៀតណាម

Jim Gerrand Photo



ឡេ យន់ អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម

Jim Gerrand Photo



សូផា វង្ស ប្រធានាធិបតីសាធារណរដ្ឋ
ប្រជាធិបតេយ្យប្រជាមានិតឡាវ

Jim Gerrand Photo



ង៉ឺ ខៀន



Photo courtesy Richard Holbrooke

គំនរចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរឃុំឃាំង
ទួលស្លែង



Jim Gerrand Photo

លលាដ៍ក្បាលតម្រៀបជាជួរនៅក្នុងរណ្តៅសាកសព



PRK Information Service photo

ជនរងគ្រោះនៅក្នុងគុកទួលស្លែងដ៏ល្បីល្បាញ



សម្តេចព្រះ នរោត្តម សីហនុ ជួបជាមួយអ្នកនិពន្ធនៅទីក្រុងព្យុងយ៉ាងនាខែកុម្ភៈ ឆ្នាំ១៩៨១

Photo courtesy Richard Holbrooke



និទាឃរដូវ ឆ្នាំ១៩៨០ ទិដ្ឋភាពឈ្មួញខ្មែរកំពុងធ្វើដំណើរទៅកាន់ប្រទេសថៃ។ ទាហានវៀតណាមឈរយាមការពារស្ពាន



អ្នកម្នាង មុនិក សីហនុ



គេហដ្ឋាននៅតាមផ្លូវមួយខាងឆ្វេងខាងត្បូងផ្សារអូរឫស្សីមានផ្ទុកសុទ្ធតែម៉ាស៊ីនដេរ



និទាឃរដូវ ឆ្នាំ១៩៧៨ ទិដ្ឋភាពសម្លាប់រង្គាលរបស់
ខ្មែរក្រហមនៅក្នុងខេត្តហាទៀង របស់វៀតណាម

# ជំពូកទី៦
# ខ្យល់ទិសខាងកើតមានប្រៀបជាង

ការសង់សណ្ឋាគារមួយនៅមាត់បឹងមួយ និងវិមានតម្កល់សពមួយធ្វើពីថ្មើមថ្មពណ៌ប្រផេះនិងថ្មក្រានីតនៅទីក្រុងហាណូយ និងការទូទាត់ប្រាក់សម្រាប់ការកសាងសមិទ្ធផលផ្សេងៗដែលមានសារសំខាន់ក្នុងឆ្នាំបន្ទាប់ពីសង្គ្រាមចប់ តាមពិតគឺបន្ទាប់ពីការចាកចេញរបស់ពួកបារាំងនោះត្រូវបានស្ថាបនាស្រេចបាច់យ៉ាងឆាប់រហ័ស ។ ពិតណាស់ វិមានតម្កល់សព ហូ ជីមិញ មានលក្ខណៈធំត្រដែតត្រដឹម ។ វិមាននេះលេចធ្លោឡើងលើទីលានបាឌិញ ដែលមានលក្ខណៈដូចទីលានក្រហមនៅម៉ូស្គូដែរ ។ នៅពេល ហូ ស្លាប់ ពួកសូវៀតបានណែនាំឲ្យផ្ទេរសពរបស់គាត់មកទីក្រុងមូស្គូសិន ដើម្បីអប់សាកសពនិងរក្សាទុកឲ្យផុតពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ វៀតណាមបានប្រកែកថា ប្រជាជាតិបរទេសមួយ ទោះជាត្រូវជំរុញដោយបំណងល្អក៏ដោយ ក៏មិនត្រូវធ្វើជាអ្នកទទួលរក្សាទុកសាកសពមេដឹកនាំជាទីសក្ការៈរបស់ខ្លួនដែរ ។ ជំនួសប្រការនេះ អ្នកអប់សពរបស់សូវៀតបានត្រូវចាត់បញ្ជូនមកកាន់ក្រុងហាណូយជាបន្ទាន់ ។ បន្ទាប់មក សាកសពត្រូវបានផ្ទេរទៅដាក់ក្នុងរូងមួយយ៉ាងជ្រៅដែលជីកខាងក្រោមកូនភ្នំមួយ ដោយរង់ចាំឲ្យយន្តហោះទម្លាក់គ្រាប់បែកទាំងឡាយរបស់អាមេរិកាំង ព្រមហោះហើរទៅកាន់ទីដទៃទៀតសិន ។ ដោយមានជំនួយរបស់រុស្ស៊ី វិមានតម្កល់សពបានកសាងរួចរាល់ទាន់ពេលសម្រាប់ការប្រារព្ធពិធីបុណ្យជ័យជម្នះ នៅឆ្នាំ១៩៧៥ ។ តាំងពីពេលនោះមក វិមាននេះគឺជាកន្លែងមួយដែលអ្នកទេសចរទៅទស្សនាច្រើនជាងគេបំផុត ។

និយាយដោយខ្លីទៅ វិមានតម្កល់សព ហូ ជីមិញ បានកំណត់នូវទីបញ្ចប់នៃសម័យមួយ ។ ក៏ប៉ុន្តែ សណ្ឋាគារថាំងឡូ មានន័យថា សណ្ឋាគារជ័យជម្នះដែលកសាងដោយពួកគុយបា ត្រូវបានចាត់ទុកថាជាការផ្តល់សម្ពុះដល់ខស្សរាហកម្មផ្នែកសណ្ឋាគាររបស់វៀតណាមដែលកំពុងរៀបចំឲ្យមានលក្ខណៈទំនើបទាន់សម័យ ។ វាបានជំនួសសណ្ឋាគារម៉េត្រូប៉ូលចាស់ ដែលដាក់ឈ្មោះថ្មីថា ថុងញិត ជាអតីតមហាសណ្ឋាគាររបស់ក្រុងហាណូយ ដែលមានមកតាំងពីជំនាន់អាណានិគមម៉្លេះ ។ សណ្ឋាគារថាំងឡូជាមួយនឹងបន្ទប់រាងបួនជ្រុងទ្រវែងរបស់ខ្លួន ដែលបំពាក់ទៅដោយម៉ាស៊ីនត្រជាក់ គ្រឿងសង្ហារិមទំនើប ប្រកទ្វារបង្អួចនៃសាលបរិភោគ រកបឹងដាក់សុទ្ធតែកញ្ចក់នោះ អំណឹះតទៅគឺជាទីកន្លែងដ៏ល្អឆើតឆាយជាងគេរបស់រដ្ឋធានី ។ សណ្ឋាគារនេះបានទទួលរៀបចំធ្វើជាកន្លែងបដិសណ្ឋារកិច្ចដែលផ្តល់ដោយមន្ត្រីស្ថានទូតសូវៀតក្នុងឱកាសនៃពិធីបុណ្យខួបបដិវត្តន៍ខែតុលាម្តងៗ ។

ដើម្បីសាកល្បងស្វែងយល់ពីទឹកចិត្តរបស់វៀតណាមលំអៀងទៅខាងណាៗនោះ អ្នកការទូតដែលបំពេញមុខងារនៅក្រុងហាណូយ មិនភ្លេចនឹងសង្កេតមើលពិធីទទួលបដិសណ្ឋារកិច្ចដែលផ្តល់ដោយបណ្តាមន្ត្រីនៃស្ថានទូត

ចិននិងសូវៀតឡើយ ។ អ៊ីចឹងហើយបានជាប្រទេសទាំងពីរប្រជែងគ្នាសម្ដែងឲ្យឃើញមិត្តភាពនិងភក្ដីភាពរបស់ខ្លួន ហើយវៀតណាមបានប្រឹងប្រែងទប់ខ្លួនមិនលំអៀងទៅខាងណាទាំងអស់ ។ អ្នកការទូតបានថ្លឹងថ្លែង ដោយយកចិត្តទុកដាក់ចំពោះអត្ថបទផ្សេងៗក្នុងសារព័ត៌មានប្រចាំថ្ងៃរបស់បក្សកុម្មុយនីស្ដវៀតណាម ដែលសរសេរសម្រាប់ប្រទេសចិននិងសហភាពសូវៀត ហើយប្រឹងប្រែងកំណត់អ្នកណាមួយ ដែលបានទទួលគុណប្រយោជន៍ពីការបោះពុម្ពផ្សាយអត្ថបទនេះ ។ ពួកគេបានប្រៀបធៀបសំណៅដើមនៃសេចក្ដីរាយការណ៍របស់សូវៀត និងចិន ទៅតាមរបៀបបកស្រាយ ដែលស្រង់យកទៅចុះផ្សាយក្នុងកាសែតរបស់វៀតណាម ដើម្បីសាកល្បងបង្ហាញពីភាពខុសគ្នាផ្នែកមនោគមវិជ្ជាដែលអាចកើតឡើងបាន ។ ឧទាហរណ៍ នៅខែកញ្ញា ឆ្នាំ១៩៧៥ ពេលដែលឧត្ដមសេនីយ៍ ចេន ស៊ីលៀន សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្ដចិន បរិហារពី«អនុត្តរភាពនិយម» នៅពេលកំពុងធ្វើទស្សនកិច្ចនៅទីក្រុងហាណូយ កាសែតទាំងឡាយរបស់វៀតណាមមិននិយាយពីពាក្យនេះឡើយ ។ អ្នកការទូតបានទាញសេចក្ដីសន្និដ្ឋានពីរឿងនេះដែលក្លាយទៅជាកាតព្វកិច្ចទៅហើយ ហើយបានបញ្ជូនដំណឹងនេះជាទូរលេខទៅកាន់រដ្ឋធានីរៀងៗខ្លួន ។

ដោយរបៀបដូចគ្នា ការធ្វើបដិសណ្ឋារកិច្ចរបស់សូវៀតនិងចិននៅក្រុងហាណូយ ជាឱកាសដ៏មានតម្លៃសម្រាប់ស្ទាបស្ទង់ពីកម្រិតនៃទំនាក់ទំនងផ្សេងៗរបស់វៀតណាមជាមួយបណ្ដាប្រទេសសង្គមនិយមជាបងប្អូន និងប៉ាន់ប្រមាណពីដំណើរប្រែប្រួលដោយថាហេតុរបស់វា ។ ក្នុងឱកាសពិធីបដិសណ្ឋារកិច្ចទាំងនេះ អ្នកការទូតមិនគ្រាន់តែកត់សម្គាល់ពួកភ្ញៀវរបស់វៀតណាមតាមឋានានុក្រមប៉ុណ្ណោះទេ ពួកគេបានទុកភ្នែកម្ខាងសម្លឹងមើលនាឡិការបស់គេជានិច្ច ដើម្បីផ្ទៀងពីពេលវេលាដែលពួកគេមកកាន់ទីនេះ ។ ដូច្នេះ តាមគោលការណ៍ដែលរៀបចំគឺថាពួកមេដឹកនាំវៀតណាមបានត្រូវបង្ខំឲ្យចំណាយពេលវេលាទៅចូលរួមក្នុងពេលជាមួយគ្នា ក្នុងពិធីបដិសណ្ឋារកិច្ចរបស់ចិនផងនិងសូវៀតផង ។ ម្នាក់ៗដែលបំពានគោលការណ៍នេះនឹងយល់ខ្លួនឯង ។

ប៉ុន្តែក្នុងរាត្រីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ គេមិនចាំបាច់ប្រើបច្ចេកទេសផ្ទៀងពេលវេលាឡើយ ។ កាលពីខែតុលាមុន ដើម្បីជាកាយវិការកាន់មរណទុក្ខបន្ទាប់ពីមរណភាពរបស់ ម៉ៅ សេទុង មន្ត្រីស្ថានទូតចិន បានលុបចោលការប្រារព្ធពិធីបុណ្យជាតិ ។ ចាប់តាំងពីពេលនោះមក វាទៅជាគ្មានប្រយោជន៍ក្នុងការប្រមាណពីពេលវេលាដែលប្រើដោយពួកមន្ត្រីវៀតណាម ដើម្បីចូលរួមក្នុងពិធីបដិសណ្ឋារកិច្ចរបស់សូវៀតឡើយ ដោយខ្វះចំណុចសម្រាប់ប្រៀបធៀប ។ ទោះជាយ៉ាងណា អ្នកសង្កេតការណ៍ខាងការទូត មិនបៀមការខកចិត្តរបស់គេយូរឡើយ ព្រោះថាក្នុងឱកាសដ៏ជាក់លាក់នេះហើយដែលនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ជាភ្ញៀវកិត្តិយសក្នុងពិធីបដិសណ្ឋារកិច្ចត្រូវសម្រេចចិត្តដើម្បីថ្កោលទោសក្រុងមូស្គូ ជាសាធារណៈដោយសម្ដីគំរោះគំរើយមួយនៅមុខអន្តទូតជាច្រើន ។ ការលើកកែវប្រសិទ្ធិពរចំពោះជ័យជម្នះបដិវត្តន៍ខែតុលា ស្ទើរតែមិនទាន់ចប់ស្រួលបួលផង លោក ផាំ វ៉ាន់ដុង បានដើរចេញពីតុ ។ តាមរយៈសហការីម្នាក់ក្នុងចំណោមសហការីរបស់គាត់ គាត់បានសុំជួបឯកអគ្គរដ្ឋទូតបារាំង

ស្ទាល ម៉ាឡូ ដើម្បីធ្វើការសន្ទនាជាឯកជនមួយក្នុងបន្ទប់ជាប់គ្នានោះ ។ ដុង និង ម៉ាឡូ បានស្ថិតនៅក្នុងបន្ទប់បិទទ្វារជិតអស់រយៈពេល២០នាទី ។ ពេញរយៈពេលនោះ ភ្ញៀវរបស់គាត់គឺលោកឯកអគ្គរដ្ឋទូតស្ទាពឺន នៅតែធ្វើដើយ ភ្នែកសម្លឹងកែវស្រាសំប៉ាញរបស់គាត់មិនដក ។ «លោកនាយករដ្ឋមន្ត្រីបាននិយាយប្រាប់ខ្ញុំថា គាត់មានចិត្តសប្បាយរីករាយណាស់ ចំពោះគំនិតធ្វើដំណើរទៅប្រទេសបារាំងនៅពេលឆាប់ៗខាងមុខ» នេះជាសម្តីរបស់ ម៉ាឡូ ដែលនិយាយប្រាប់សហការីម្នាក់ក្នុងចំណោមសហការីរបស់គាត់នៅពេលក្រោយមក ។ តាមលោកឯកអគ្គរដ្ឋទូតបារាំងថា គ្មានកិច្ចការអ្វីធ្ងន់ធ្ងរឬប្រញាប់ប្រញាល់ត្រូវបានរំពឹកក្នុងឱកាសនៃការសន្ទនានេះទេ ។ ការធ្វើដំណើររបស់ ដុង ទៅកាន់ប្រទេសបារាំង គ្រាន់តែគ្រោងទុកជាមុនក្នុងរយៈពេលជាច្រើនខែប៉ុណ្ណោះ ។ ដោយជាក់ស្តែងមូលហេតុនៃការលើបបាត់ដំយូរលង់របស់នាយករដ្ឋមន្ត្រីវៀតណាម គឺគាត់មានបំណងផ្សេងទៀត ។ ម៉ាឡូ បានកត់សម្គាល់របៀបលេងសើច ថា ដុង ហាក់ដូចជាមិនប្រញាប់ប្រញាល់បញ្ចប់កិច្ចសំណេះសំណាលនិងទៅជួបម្ចាស់ផ្ទះ សូវៀតនៅតុអាហារវិញឡើយ ។ នៅទីបំផុត កាលបើចប់ការសន្ទនាហើយ លោកនាយករដ្ឋមន្ត្រីបានលើកដៃ ជាសញ្ញាមិត្តភាពទៅកាន់ស្ទាពឺន ហើយក៏លាចេញទៅ ។

តាមមតិរបស់អ្នកការទូតទាំងអស់ថា កាយវិការប្លែកពីធម្មតានេះ ពិតជាគិតទុកជាមុនដោយការិយាល័យនយោបាយជារបៀបបញ្ជូនសារដែលប្រទេសវៀតណាមយកចិត្តទុកដាក់ចំពោះទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសបារាំង ហើយប្រហែលជាមួយបស្ចិមប្រទេសទាំងមូលច្រើនជាងជាមួយក្រុងមូស្គូ ។ មួយរយៈបន្ទាប់ដំណឹងដែលនិយាយតៗគ្នាបានលេចឮសុសសាយក្នុងមជ្ឈដ្ឋានអ្នកការទូតថា អាកប្បកិរិយាប្លែកពីធម្មតារបស់ ដុង នៅល្ងាចនោះ គឺជាការឆ្លើយតបរបស់វៀតណាមទៅនឹងការកៀបសង្កត់ដែលមានស្នៀតល្បិចកលយ៉ាងប្រសប់របស់រុស្សីផងដែរ ។ ប្រទេសវៀតណាមជាមិត្តមួយរបស់សហភាពសូវៀត ប៉ុន្តែពុំមែនជាប្រទេសនៅក្រោមបង្គាប់មួយដែលគេធ្វើបាបទេ[១] ។

វគ្គនៃហេតុការណ៍បន្ទាប់បន្សំនៅសណ្ឋាគារថាំងឡូនេះ បានធ្វើឲ្យឃើញជាក់ស្តែងនូវការផ្លាស់ប្តូរ ដែលបានកើតឡើងដោយមិនបានប្រុងមុនក្នុងទំនាក់ទំនងរបស់វៀតណាមជាមួយក្រុងមូស្គូតាំងពីចុងទសវត្សរ៍៥០ ។ នៅជំនាន់នោះ គឺវៀតណាមស្ទើរតែមិនទាន់លើកស្ទួយតម្កើងសហភាពសូវៀតថាជាអ្នកបំភ្លឺផ្លូវបុកសង្គមនិយមផងទេ ។ ពួកគេបានបាត់បង់ជំនឿពីកំណើតរបស់ខ្លួនចំពោះរៀមច្បងសង្គមនិយមជាបងប្អូន ។ ជាងនេះទៅទៀត ក្តីសង្ឃឹមក្នុងការបង្រួបបង្រួមជាតិឡើងវិញ កំពុងធ្វើឲ្យកើតមានរូបរាង ហើយទស្សនវិស័យក្នុងការពង្រីកមូលដ្ឋានទាំងឡាយនៃនយោបាយការបរទេសរបស់គេក៏កំពុងផ្តល់នូវសារសំខាន់ដែរ ដែលធ្វើឲ្យវៀតណាមលែងរួញរានឹងបង្ហាញភាពប្រាកដក្នុងចិត្តរបស់ខ្លួនចំពោះក្រុងមូស្គូទៀតហើយ ។ ការចាប់អារម្មណ៍អំពីសេរីភាពថ្មីៗនេះ បានបញ្ចប់យ៉ាងឆាប់រហ័ស ។ បញ្ហាផ្សេងៗជាមួយប្រទេសចិននិងប្រទេសកម្ពុជា ភាពកាន់តែធ្ងន់ធ្ងរនៃវិបត្តិផ្នែកសេដ្ឋកិច្ច ដំណើរស្រុតចុះនៃការបើកទ្វារឆ្ពោះទៅរកបស្ចិមប្រទេស ៈ ទាំងអស់នេះបាននាំឲ្យចុះថយ

ប្រកបដោយគ្រោះថ្នាក់នូវលទ្ធភាពក្នុងការធ្វើសកម្មភាព ដើម្បីទៅដល់គោលដៅអ្វីមួយរបស់ប្រទេសវៀតណាម ។ វៀតណាមចាំបាច់ត្រូវតែលេបភាពក្រអឺតក្រអោងរបស់ខ្លួនមកវិញ ។ ពេលវេលាគឺការជួបគ្នាជាថ្មីជាមួយក្រុងមូស្គូទៀត ។

## «នោះហើយជាមាគ៌ារំដោះជាតិរបស់យើង!»

ការដាក់ស្នេហ៍របស់ប្រទេសវៀតណាមចំពោះសហភាពសូវៀត មានឫសគល់តាំងពីដើមសតវត្សរ៍ទី ២០ ។ អ្នកជាតិនិយមវៀតណាមសុទ្ធតែជាអ្នកជំពាក់គុណរដ្ឋាភិបាលអាណានិគមបារាំងដោយមិនចំពោះ ដែលបានពង្រីកទស្សនវិស័យសម្រាប់អនាគតរបស់គេ ។ ដោយសារអាណានិគមនេះហើយដែលវៀតណាមបានឮគេនិយាយពីបដិវត្តន៍បុលឆេវិចជាលើកដំបូង ។ រហូតមកទល់នឹងការមកដល់របស់ពួកបារាំង ពិភពដែលពួកបញ្ញវន្តវៀតណាមតែងមមៃគិតគឺប្រទេសចិន ។ អ្នកអក្សរសាស្ត្រចិនបានផ្តល់ឲ្យវៀតណាមនូវក្របខ័ណ្ឌសម្រាប់ប្រឹក្សាគំនិតទស្សនវិជ្ជា នយោបាយ និងសង្គម ។ ពួកបារាំងបានធ្វើឲ្យទិដ្ឋភាពផ្សេងៗ មិនគ្រាន់តែសំដៅទៅរកអឺរ៉ុបប៉ុណ្ណោះទេ ប៉ុន្តែ សំដៅទៅរកពិភពលោកផងដែរ ។ គឺនៅឆ្នាំ១៩២០ ដែល ហូ ជីមិញ បានបង្ហាញឲ្យដឹងពីលទ្ធិកុម្មុយនីស្តដោយការមើលសៀវភៅរបស់ លេនីន ក្នុងល្វែងបន្ទប់ដ៏តូចរបស់គាត់នៅទីក្រុងប៉ារីស ។ ហូ បានសរសេរ សែសិបឆ្នាំក្រោយមកថា «វាធ្វើឲ្យខ្ញុំជ្រួលច្របល់ក្នុងចិត្តស្ងើចសរសើរ និងមានសេចក្តីសង្ឃឹមយ៉ាងច្បាស់ ។ ខ្ញុំរំភើបចិត្តនឹងរឿងនេះរហូតស្រក់ទឹកភ្នែក» ។ ទោះជានៅតែម្នាក់ឯងក្នុងបន្ទប់របស់ខ្ញុំក៏ដោយ ក៏ខ្ញុំនិយាយឮៗ ហើយបញ្ចេញកាយវិការហាក់ដូចជាឈរនៅពីមុខហ្វូងមនុស្សយ៉ាងច្រើនមួយ ៖ «បណ្តាជនរួមជាតិដែលរងទុក្ខវេទនាជាទីស្នេហា យើងត្រូវការរបស់នេះ ហើយនេះគឺជាមាគ៌ានៃការរំដោះជាតិរបស់យើង!»[២] ។

បួនឆ្នាំក្រោយមក ហូ បានស្ថិតនៅទីក្រុងមូស្គូ ។ ដោយក្លាយទៅជាយុទ្ធជនរបស់បដិវត្តន៍អន្តរជាតិ គាត់ខកខានមិនបានជួបវីរបុរសរបស់គាត់ គឺ លេនីន ដែលស្លាប់ពីរបីម៉ោងមុនការទៅដល់របស់គាត់បន្តិច ។ គាត់បានសិក្សា បន្ទាប់មកបង្រៀននៅសាកលវិទ្យាល័យបូព៌ាប្រទេស នៅទីក្រុងមូស្គូ ហើយបានជួបស្គាល់ ហ្សូហ្សេពស្តាលីន និងឥស្សរជនសំខាន់ៗរបស់បក្សជាច្រើនទៀត ជាពិសេស រ៉ាដិក, ហ្ស៊ីណូវីយេវ និង ឌីមីត្រូហ្វ ។ នៅទីនោះ មនុស្សជាច្រើនបានបង្កើតឲ្យមានចំណងទាក់ទងផ្សេងៗជាមួយបក្សកុម្មុយនីស្តសហភាពសូវៀត និងការបដិវត្តន៍របស់សូវៀត ដែលនឹងបង្ហាញឲ្យឃើញសារសំខាន់ដ៏ធំមិនត្រឹមតែចំពោះអាណានិគមបារាំងនៅឥណ្ឌូចិនប៉ុណ្ណោះទេ ប៉ុន្តែ ចំពោះសហភាពសូវៀតផ្ទាល់ថែមទៀត ។ នៅចុងឆ្នាំ១៩២៤ ហូ បានចាកចេញពីទីក្រុងមូស្គូទៅកង់តុងជាទីដែលគាត់ទទួលបន្ទុកធ្វើឲ្យគប់ភ្លើងបដិវត្តន៍រីកសាយទៅទៀត ក្នុងឋានៈគាត់ជាតំណាងអង្គការអន្តរជាតិកុម្មុយនីស្តសម្រាប់ចុងបូព៌ាប្រទេស ។ ប្រាំមួយឆ្នាំក្រោយមក គាត់បានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន (P.C.I.) ។ អ្វីដែលនៅសល់គឺជាចំណែកមួយនៃប្រវត្តិសាស្ត្រ[៣] ។

តាមភូមិសាស្ត្រ ទោះបីជាចម្ងាយដ៏ធំធេងមួយខណ្ឌចែកភាគខាងត្បូងប្រទេសចិននិងប្រទេសវៀតណាម ជាទីដែលបក្សកុម្មុយនីស្តឥណ្ឌូចិនធ្វើប្រតិបត្តិការដោយលួចលាក់ម្ភៃឆ្នាំបន្ទាប់ពីការស្នាក់នៅរបស់ ហូ ជាលើកដំបូងនៅទីក្រុងមូស្គូក៏ដោយ ក៏សហភាពសូវៀតនៅតែជាអ្នកបំភ្លឺផ្លូវសម្រាប់អ្នកបដិវត្តន៍វៀតណាមជានិច្ច ។ ការគាំទ្ររបស់អ្នកបដិវត្តន៍វៀតណាមចំពោះនយោបាយការបរទេសរបស់រុស្ស៊ីបានប្រព្រឹត្តទៅដោយគ្មានលក្ខខណ្ឌ ពីព្រោះសហភាពសូវៀតជា«កំពែងការពារឲ្យបដិវត្តន៍ពិភពលោកអាចរីកធំធាត់» ដូចដែលឯកសារមួយរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ចុះកាលបរិច្ឆេទឆ្នាំ១៩៣៥ បានអះអាងបន្ថែមពីរឿងនេះដែរ ហើយដែលការបំផ្លាញដោយពួកចក្រពត្តិ «នឹងរុញច្រានចលនាពិភពលោកឲ្យថយក្រោយអស់រាប់សិបឆ្នាំ» ។

ភាពស្មោះត្រង់របស់ពួកកុម្មុយនីស្តវៀតណាម បានត្រូវធ្វើឲ្យរង្គោះរង្គើសម្រាប់ជាលើកដំបូងនៅឆ្នាំ ១៩៤៥ ។ ការគាំទ្ររបស់ធានីបដិវត្តន៍ពិភពលោក (ក្រុងមូស្គូ) ចំពោះវៀតណាមមានមិនគ្រប់គ្រាន់ទេ ក្នុងកាលៈទេសៈដ៏សំខាន់នាពេលនោះ ។ នៅខែសីហា ឆ្នាំ១៩៤៥ ដោយឆ្លៀតឱកាសនៃការបាក់ទ័ពរបស់បារាំងនៅមុខការរុលចូលមកឥណ្ឌូចិនរបស់ជប៉ុន ពួកកុម្មុយនីស្តវៀតណាមបានដណ្តើមអំណាចនៅក្រុងហាណូយ ហើយបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ម្យ៉ាងទៀត ស្តាលីន ក៏ដូចប្រធានាធិបតីអាមេរិក ហារី ទ្រូម៉ាន់ បានធ្វើជាមិនដឹងមិនឮចំពោះការអំពាវនាវរបស់ ហូ ជីមិញ ឡើយ ។ គាត់បានចៀសវាងមិនទទួលស្គាល់រដ្ឋថ្មីនិងបដិសេធមិនផ្តល់នូវការគាំទ្រចំពោះ ហូ ថែមទៀត ។ ជោគជ័យរបស់បដិវត្តន៍វៀតណាមគ្រាន់តែជាដំណើរផ្លាស់ប្តូរព្រឹត្តិការណ៍បន្ទាប់បន្សំប៉ុណ្ណោះសម្រាប់ក្រុងមូស្គូ ។ តាមការយល់ឃើញរបស់ខ្លួន អាសនៈជាច្រើនដែលពួកកុម្មុយនីស្តបារាំងទទួលបាននៅសភា គឺមានសារសំខាន់មួយផ្សេងទៀត ដោយមិននិយាយពីការពង្រីងឥទ្ធិពលរបស់ខ្លួននៅអឺរ៉ុប ក្រោយសម័យសង្គ្រាមឲ្យរឹតតែរឹងមាំឡើងផងទេ[៤] ។ រហូតមកដល់ពេលដែលបក្សកុម្មុយនីស្តបារាំងបាត់បង់សេចក្តីសង្ឃឹមទាំងអស់ក្នុងការឡើងកាន់អំណាច ហើយក្នុងលំអាននេះ ពេលដែលបក្សកុម្មុយនីស្តវៀតណាមចាប់ផ្តើមបរិហារពីសង្គ្រាមរបស់«ចក្រពត្តិ» ទើបក្រុងមូស្គូបែរមកយកចិត្តទុកដាក់ចំពោះការប្រយុទ្ធតស៊ូរបស់វៀតណាមនិងផ្តល់នូវការគាំទ្រ ។ ប៉ុន្តែ នៅពេលនោះសហភាពសូវៀតមិនទាន់បង្ហាញឲ្យឃើញនូវការរវៀសរវៃហួសប្រមាណមួយ ដើម្បីទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមទេ ។ នៅខែមករា ឆ្នាំ១៩៥០ ដោយយកតម្រាប់តាមសាធារណរដ្ឋប្រជាមានិតចិនដែលទើបបង្កើតថ្មី នៅទីបំផុតក្រុងមូស្គូបានទទួលស្គាល់រដ្ឋាភិបាលរបស់ ហូ ដែលពេលនោះកំពុងស្ថិតនៅក្នុងព្រៃម៉ាគីទាំងមិនសប្បាយចិត្ត[៥] ។

ប៉ុន្តែ ការទទួលស្គាល់នេះ ប្រហែលពុំមែនជាការបំភាន់ឡើយ ។ ក្រុងមូស្គូ និងក្រុងប៉េកាំងត្រូវបានធ្វើឲ្យខ្វល់ខ្វាយតទៅទៀត ដើម្បីស្វែងរកការសម្របសម្រួលមួយជាមួយពួកបារាំងជាងគាំទ្រប្រទេសវៀតណាមរហូតដល់ជ័យជម្នះផ្តាច់ព្រ័ត្រ ។ ទឡ្ហីករណ៍របស់គេគឺថា ពួកគេពុំអាចធានាការគាំទ្រចំពោះ ហូ ជីមិញ ទេ ក្នុងករណីដែលមានអន្តរាគមន៍របស់អាមេរិកាំងនៅឥណ្ឌូចិន ។ តាមការពិត ស្តាលីន បានចុះកិច្ចសន្យាមួយជាមួយ

ប្រទេសបារាំង ដោយក្រុងមូស្គូនឹងជួយសម្រួលដល់ដំណោះស្រាយមួយអំពីសង្គ្រាមនៅឥណ្ឌូចិន ដែលនាំឲ្យខូចប្រយោជន៍ពួកកុម្មុយនីស្តវៀតណាម ហើយជាថ្នូរមកវិញ ពួកបារាំងនឹងជំទាស់ចំពោះសហគមន៍អឺរ៉ុបដែលទទួលបន្ទុកខាងកិច្ចការពារ ។ នៅក្នុងឱកាសនៃសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ ការកៀបសង្កត់ដែលធ្វើទៅលើបណ្ដាសម្ពន្ធមិត្ររបស់វៀតណាមដោយពួកចិន និងសូវៀតមានដូចជា ពួកវៀតណាមត្រូវតែបោះបង់ការដណ្ដើមកាន់កាប់ទឹកដីរបស់កងទ័ពវៀតមិញ ហើយបណ្ដាសមមិត្តឡាវ និងខ្មែររបស់ខ្លួន បានត្រូវបង្ខំឲ្យទទួលស្គាល់ភាពត្រឹមត្រូវតាមច្បាប់នៃបណ្ដារបបប្រឆាំងកុម្មុយនីស្តនៅប្រទេសឡាវ និងកម្ពុជាដែរ ។ ម្យ៉ាងទៀត វៀតណាមត្រូវតែឲ្យសច្ចាប័នដល់ការបែងចែកប្រទេសរបស់ខ្លួនជាបណ្ដោះអាសន្ន ដោយយកខ្សែស្របទី១៧ ជាបន្ទាត់ព្រំដែនដែលនឹងមានរយៈពេលម្ដងមួយឆ្នាំ[៦] ។ នៅឆ្នាំ១៩៨០ ខ្ញុំបានកាត់សម្ដីឯកអគ្គរដ្ឋទូតប្រទេសវៀតណាម ដែលត្អូញត្អែរនៅចំពោះមុខខ្ញុំអំពីភាពមិនស្មោះត្រង់ដែលពួកចិនសម្ដែងឲ្យឃើញនៅទីក្រុងហ្សឺណែវ ៖ តើសហភាពសូវៀតមានចំណែកទទួលខុសត្រូវមួយដូចគ្នាដែរទេ? ។ គាត់បានឆ្លើយមកខ្ញុំវិញ ដោយធ្វើសញ្ញាបង្ហាញខ្ញុំរបៀបជានិមិត្តរូបនូវថតតុបិទជិតមួយថា ៖ «អា៎! អ្វីៗទាំងអស់ស្ថិតនៅក្នុងនេះ ។ យើងនឹងនិយាយពីរឿងនេះនៅពេលឱកាសមកដល់» ។ ពិភពលោកគោងតែរង់ចាំម្ដប្រាំឆ្នាំ ដើម្បីបានដឹងនូវអ្វីដែលវៀតណាមតិះដៀលពីឥរិយាបថរបស់ប្រទេសចិន នៅឆ្នាំ១៩៥៤នាទីក្រុងហ្សឺណែវ ។

ចាប់តាំងពីកាលបរិច្ឆេទនេះ-១៩៥៤-សម្ដីប្រើដោយឡែកសម្រាប់ភាសាបដិវត្តន៍ចាប់ពីថ្ងៃនេះទៅ គឺលែងលាក់លៀមទៀតហើយ ទោះជាតិចតួចក៏គ្មានដង ព្រោះវាស្ដែងពេក ៖ តាមការពិត ក្រុងមូស្គូ យកចិត្តទុកដាក់នឹងប្រទេសវៀតណាមតិចតួចមែនទែន យ៉ាងហោចអ្វីដែលកើតមានឡើងមិនធ្វើឲ្យប៉ះពាល់ដល់ជំហររបស់សូវៀតនៅអឺរ៉ុប ឬទំនាក់ទំនងរបស់សូវៀតជាមួយសហរដ្ឋអាមេរិកនិងប្រទេសចិន ។ រុស្ស៊ី បានចាប់ផ្ដើមផ្ដល់ឲ្យទៅប្រទេសវៀតណាមនូវជំនួយដ៏ត្បិតត្បៀតមួយ ខាងផ្នែកសេដ្ឋកិច្ចនិងយោធា ។ ប៉ុន្តែ រុស្ស៊ីមិនរវល់ធ្វើអ្វីទាំងអស់ ដើម្បីអនុញ្ញាតឲ្យមានការអនុវត្តន៍មាត្រានៃកិច្ចព្រមព្រៀងហ្សឺណែវ ដែលតម្រូវឲ្យបណ្ដាប្រទេសហត្ថលេខីរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៥៦ ក្នុងគោលបំណងធ្វើការបង្រួបបង្រួមប្រទេសឡើងវិញ ។ គំនិតនៃការផ្ដើមធ្វើការតស៊ូដោយអាវុធនៅភាគខាងត្បូង បានធ្វើឲ្យពួកសូវៀតទីទើរយ៉ាងខ្លាំង ។ នីគីតា គ្រូតឆេវ បានវាយតម្លៃថា ការផ្សងព្រេងមួយបែបនោះ ដែលដឹកនាំប្រឆាំងនឹងសម្ពន្ធមិត្តមួយរបស់ពួកអាមេរិកាំង គឺបោទឲ្យមានបញ្ហាឡើងវិញដល់ភាពធូរស្រាលជាមួយសហរដ្ឋអាមេរិកដែលគាត់ប្រឹងប្រែងលើកស្ទួយឡើង ។ គាត់និយាយថា ៖ «លទ្ធផលនៃសង្គ្រាមទ័ពព្រៃ មុខជាបង្កឲ្យមានការភាន់ប្រែខ្លាំងមួយ ក្នុងពិភពលោកមិនខាន» ។ រឿងនេះបានធ្វើឲ្យ វៀតណាមភ្ញាក់ផ្អើលស្រឡាំងកាំង[៧] ។

មិនយូរប៉ុន្មាន វៀតណាមបានបន្ថយបន្តិចម្ដងៗនូវការយកចិត្តទុកដាក់ចំពោះអនុសាសន៍របស់ គ្រូតឆេវ ទាក់ទងនឹងភាពចាំបាច់ក្នុង«ដំណាក់កាលឆ្លងកាត់ដោយសន្តិវិធី» ឆ្ពោះទៅរកលទ្ធិសង្គមនិយមនិងការបង្រួបបង្រួម

*ជាតិ ។ នៅចំពោះមុខការកៀបសង្កត់ដ៏មុឹងម៉ាត់ដែលផ្តើមដោយប្រធានាធិបតី ង៉ូ ឌិញយៀម ពួកកុម្មុយនីស្តនៅភាគខាងត្បូងវៀតណាមបានផ្តើមការតស៊ូដោយអាវុធដោយឯកឯង ។ នៅឆ្នាំ១៩៦០ សង្គ្រាមទ័ពព្រៃបានរាលដាលក្នុងទំហំច្រើនគួរសមជាមួយនិងការប្រសិទ្ធិពររបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តនៅទីក្រុងហាណូយ ដែលជាហេតុធ្វើឲ្យខូចប្រយោជន៍ដល់ក្រុងមូស្គូផង ។ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងហ្សឺណែវថ្មីនៅឆ្នាំ១៩៦៣ វៀតណាមបានត្រូវធ្វើឲ្យក្តៅក្រហាយមិនបាត់ ចំពោះប្រការដែលពួកសូវៀតចាប់ផ្តើមហាមឃាត់ជាឯកតោភាគីនូវការប្រើប្រាស់ប្រទេសឡាវជាតំបន់ឆ្លងកាត់ឆ្ពោះទៅវៀតណាមខាងត្បូង ។ ប៉ុន្តែការជាប់ដៃប្រយុទ្ធមិនទាន់ដល់ពេលវេលាទេ ក្នុងពេលដែលក្រុងហាណូយប្រើប្រាស់ផ្លូវលំហូជីមិញកាន់តែច្រើនឡើងៗ ដើម្បីទ្រទ្រង់ភាគខាងត្បូង ។ ព្រមជាមួយគ្នា ក្នុងហេតុការណ៍ទាំងនោះដែលប្រើវិធីកាន់តែខ្លាំងត្រូវបានកត់សម្គាល់ដោយការទម្លាក់គ្រាប់បែករបស់កងអាកាសចរអាមេរិកាំងនៅភាគខាងជើង និងការឡើងគោករបស់កងទ័ពអាមេរិកាំងនៅភាគខាងត្បូងនាឆ្នាំ១៩៦៥ បានជំរុញឲ្យក្រុងមូស្គូពង្រឹងការគាំទ្ររបស់ខ្លួនចំពោះក្រុងហាណូយរឹតតែខ្លាំងឡើង ។ ការកើនឡើងនូវការវិវាទជាមួយប្រទេសចិន ក៏ជួយឲ្យមានការគាំទ្រនេះដែរ ។ រហូតមកដល់ការធ្លាក់ពីអំណាចរបស់ គ្រូតឆេវ នៅឆ្នាំ១៩៦៤ និងចរិតលក្ខណៈនៃអ្នកស្នងតំណែងគាត់ គឺពុំមានអ្នកណាម្នាក់ជួយចាត់ចែងនាំផ្លូវសូវៀតឲ្យចាប់ផ្តើមគិតគូរអំពីបញ្ហាវៀតណាមជាថ្មីឡើយ ។*

*ដើម្បីឆ្លើយតបនឹងការចោទប្រកាន់របស់ចិនពីលទ្ធិសើរើនិយមនិងការឃុបឃិតជាមួយសហរដ្ឋអាមេរិក ពួកមេដឹកនាំថ្មីនៅវិមានក្រឹមឡាំង គោងតែសម្តែងឲ្យឃើញនូវសុឆន្ទៈសង្គមនិយមរបស់ខ្លួន ដោយជួយឧបត្ថម្ភគាំទ្រប្រទេសវៀតណាម ទោះបីជាគ្រឿងសព្វាវុធដែលផ្តល់ដោយពួកសូវៀតបម្រុងទុកសម្រាប់ការពារវៀតណាមខាងជើងប្រឆាំងនឹងការវាយលុកតាមផ្លូវអាកាសរបស់អាមេរិកាំងក៏ដោយ ក៏ដូចជាជួយក្នុងការពង្រឹងសង្គ្រាមទ័ពព្រៃនៅភាគខាងត្បូងដែរ ។ ពេញរយៈពេលនៃសង្គ្រាម ក្រុងមូស្គូនៅតែប្រុងប្រយ័ត្នបង្ការជាមុននូវលទ្ធភាពនៃការរាលដាលជម្លោះមួយជានិច្ច ។ បន្ទុកដែលផ្តល់ឲ្យខ្លួននូវតួនាទីជាអ្នកផ្គត់ផ្គង់គ្រឿងអាវុធ បានធ្វើឲ្យពួកសូវៀតសាកល្បងប្រើប្រាស់តួនាទីនេះដើម្បីធ្វើឲ្យភាពធូរស្រាលជាមួយអាមេរិកលឿនទៅមុខ និងបង្ហាញឲ្យឃើញឧត្តមភាពរបស់ខ្លួនទល់នឹងក្រុងប៉េកាំងផង ។ បើនិយាយខាងផ្នែកហិរញ្ញវត្ថុ ៧៥ភាគរយនៃសម្ភារសឹកធុនធ្ងន់ដែលប្រើប្រាស់ដោយវៀតណាមគឺបានមកពីក្រុងមូស្គូ ប៉ុន្តែរុស្ស៊ីបានយកចិត្តទុកដាក់មិនផ្តល់គ្រឿងសព្វាវុធគ្រប់ប្រភេទនៅក្នុងកណ្តាប់ដៃខ្លួន ដែលធ្វើឲ្យការច្បាំងគ្នារីករាលដាលឡើយ ។ ឧត្តមសេនីយ៍វៀតណាមខាងជើងម្នាក់ដែលត្រូវចាប់ជាឈ្លើយសឹក បានបន្ទោសពួកសូវៀតថា បានផ្តល់មីស៊ីលសមុទ្រ-សមុទ្រទៅឲ្យ "ណាស្សែរ (ប្រធានាធិបតីអេហ្ស៊ីប) និង បេន បែលឡា (ប្រធានាធិបតីអាល់ហ្សេរី) នៅពេលដែលពួកគេតែងតែបដិសេធជានិច្ចមិនផ្តល់មីស៊ីលនេះមកឲ្យខ្លួន ដើម្បីប្រយុទ្ធតទល់នឹងនាវា Yankee Station និង Dixie Station (ជាកងនាវាចម្បាំងរបស់អាមេរិកាំង) នៅលំហសមុទ្ររបស់វៀតណាមឡើយ"[៨] ។ វៀតណាមបាននាំមក*

និយាយប្រាប់ខ្ញុំជាញឹកញយប្រកបដោយសេចក្តីពេញចិត្តផង នូវរឿងនិទានខ្លីៗបែបចំអកមួយដែលខ្ញុំសូមសារភាពថា មិនអាចពិនិត្យបញ្ជាក់ឲ្យដឹងខុសត្រូវ មែនឬមិនមែនឡើយ ។ អ្នកបច្ចេកទេសនៅហាណូយនឹងសម្រេចជោគជ័យ ដោយការព្យាយាមក្នុងការកែប្រែប្រព័ន្ធតម្រង់បាញ់របស់មីស៊ីលទាំងឡាយដែលផ្តល់ឲ្យដោយពួកសូវៀត និងបញ្ចប់នូវភាពបាញ់មិនត្រូវនៃហ្វូងយន្តហោះបេ-៥២របស់អាមេរិកាំង ។ រុស្ស៊ីហាក់ដូចជាត្រូវធ្វើឲ្យស្រឡាំងកាំងដោយលទ្ធផលនៃបច្ចេកទេសនេះ ៖ មុនបង្ហួសពួកសូវៀតបានប្រគល់ទៅឲ្យវៀតណាមដោយចេតនានូវអាវុធផ្សេងៗដែលមិនអាចបាញ់ទៅដល់យន្តហោះទម្លាក់គ្រាប់បែកធំៗទេ ដោយបារម្ភខ្លាចបង្កហេតុនឹងពួកអាមេរិកាំង ។

ដូណាល់ ហ្សាហ្គូរីយ៉ា ជាអ្នកឯកទេសខាងបញ្ហាសូវៀតដ៏ឆ្នើមម្នាក់បានពិពណ៌នាពីជំហររបស់ក្រុងមូស្គូលើបញ្ហាវៀតណាមនៅពាក់កណ្តាលទសវត្សរ៍៦០ថា “សហភាពសូវៀតបានចាត់ទុកសង្គ្រាមនេះពុំមែនដូចរឿង Armageddon (សង្គ្រាមអវកាស?)មួយទេ ប៉ុន្តែជាការផ្តើមគំនិតមួយដែលខុសកាលៈទេសៈ និងដែលអាចមានផលអាក្រក់ទៅថ្ងៃមុខ ហើយបានត្រឹមតែធ្វើឲ្យស្មុគស្មាញដល់នយោបាយការបរទេសរបស់ខ្លួន និងបង្កើតឲ្យមានបញ្ហាពិបាកដោះស្រាយថ្មីមួយប៉ុណ្ណោះ ។ ចំពោះរឿងនេះ គោលដៅរបស់វាពុំមែនចេញមកពីមហិច្ឆតាផ្ទាល់របស់សូវៀតទេ ដោយរបៀបម្យ៉ាងគឺវាត្រូវបង្ខំឲ្យទទួលដោយគូសត្រូវទាំងពីរគឺ ប្រទេសចិន និងសហរដ្ឋអាមេរិក ។ ប្រទេសរុស្ស៊ីមិនចង់ឲ្យចិននិងសហរដ្ឋអាមេរិកទទួលបានជ័យជម្នះមួយឡើយ ព្រោះថាជ័យជម្នះរបស់ប្រទេសទាំងពីរនឹងបំផ្លាញកិត្យានុភាពរបស់ខ្លួន ។ សម្រាប់រុស្ស៊ី ច្រកចេញដ៏ប្រសើរជាងគេ នឹងមានលក្ខណៈជាការប្រកួតឥតឈ្នះចាញ់មួយ”[៩] ។

នៅពេលដែលវៀតណាម ខំប្រឹងបញ្ចុះបញ្ចូលក្រុងមូស្គូឲ្យបញ្ចេញភាពមោះមុតជាងមុនចំពោះក្រុងវ៉ាស៊ីនតោន ដោយលើកពីបំណងដឹកនាំបក្សកុម្មុយនិស្តរបស់ពួកសូវៀតនោះ ជម្លោះដែលកាន់តែរាលដាលខ្លាំងឡើងរវាងសហភាពសូវៀតនិងប្រទេសចិនបានចោទជាបញ្ហាធ្ងន់ធ្ងរមួយចំពោះក្រុងហាណូយ ។ បើទុកជាមានការទាស់ទែងគ្នា ដែលកើតមានតាមកាលៈទេសៈជាមួយក្រុងមូស្គូនិងប៉េកាំងក្តី ក៏ថ្នាក់ដឹកនាំរបស់វៀតណាមនៅតែសន្និដ្ឋានដោយខ្ជាប់ខ្ជួនពីភាពចាំបាច់នៃសាមគ្គីភាពក្នុងជួរសង្គមនិយមដែរ ។ វៀតណាមភ័យខ្លាចថា ការទាស់ទែងគ្នាបានត្រឹមតែផ្តល់ប្រយោជន៍ឲ្យ“ពួកចក្រពត្តិនិយម”និងធ្វើឲ្យខូចខាតដល់ការតស៊ូរបស់ប្រជាជនវៀតណាមប៉ុណ្ណោះ ។ ក្នុងអតីតកាល ហូ ជីមិញ ធ្លាប់ធ្វើការសាកល្បងជាច្រើនដើម្បីផ្សះផ្សាមហាយក្សទាំងពីរ ប៉ុន្តែនៅឆ្នាំ១៩៦៦ វៀតណាមហាក់ដូចជាបណ្តោយទៅតាមកម្មវាសនាចំពោះការបែកបាក់នៃបក្សកុម្មុយនិស្ត ។ ពួកគេបានសម្រេចចិត្តដោយចេតនា ដើម្បីទាញយកប្រយោជន៍ពីការប្រកួតប្រជែងរវាងចិននិងសូវៀត ។ ជំហរកណ្តាលរបស់គេដែលមានកម្រិតស្មើគ្នារវាងក្រុងមូស្គូនិងក្រុងប៉េកាំងបានអនុញ្ញាតឲ្យវៀតណាម ទទួលបានអត្ថប្រយោជន៍ជាអតិបរមាមួយទាំងសងខាង ។

## តម្លៃនៃឯករាជ្យភាព

ហូ ជីមិញ បានត្រូវទាក់ទាញចិត្តដោយលទ្ធិម៉ាក្ស-លេនីននិងសហភាពសូវៀត ពីព្រោះរបស់ទាំងអស់នេះជាភាពគួរឲ្យសង្ឃឹមមួយសម្រាប់ឯករាជ្យប្រទេសរបស់គាត់ ។ ការគិតមមៃដូចគ្នានេះ អំពីការបង្រួបបង្រួមប្រទេសឡើងវិញបន្ទាប់ពីសន្និសីទហ្សឺណែវ បានកំណត់ដោយច្បាស់លាស់នូវឥរិយាបថរបស់ប្រទេសវៀតណាមក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តចំពោះបណ្ដាប្រទេសសង្គមនិយមជាបងប្អូន ។ ទោះបីជានៅក្នុងផ្ទៃបក្សរបស់ខ្លួនមាននិន្នាការខាងមនោគមវិជ្ជាមិនស្របគ្នាក៏ដោយ ក៏បក្សកុម្មុយនីស្តរបស់វៀតណាមមិនដែលមានអ្នកស្និទ្ធសូវៀត អ្នកស្និទ្ធចិនឡើយ ប៉ុន្តែ គឺមានតែអ្នកស្និទ្ធវៀតណាមដ៏មោះមុតប៉ុណ្ណោះ ។ រឿងរ៉ាវ ហ័ង មិញជិញ គឺជាករណីដោយឡែកមួយ ៈ បណ្ដាសមាជិកនៃគណៈដឹកនាំបក្សត្រូវបានបណ្ដេញចេញ ព្រោះតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងបរទេស ។ នៅឆ្នាំ១៩៦៧ ជិញ ដែលពេលនោះ ជាប្រធានសាលានយោបាយបក្ស និងមន្ត្រីមួយចំនួនត្រូវបានចាប់ខ្លួនដោយសារការធ្វើចារកិច្ចឲ្យសហភាពសូវៀត ។ ការកម្ចាត់អ្នកដែលគេសន្មតថាជាពួកសមាសភាពស្និទ្ធចិនរបស់បក្ស បានកើតមានឡើងនៅក្រោយឆ្នាំ១៩៧៥ ។

នយោបាយរបស់ក្រុងហាណូយពុំមែនគ្រាន់តែដើរតាមផ្លូវកណ្ដាលមួយប៉ុណ្ណោះទេ ប៉ុន្តែជានយោបាយមិនចូលបក្សសម្ពន្ធផងដែរ ដោយសំអាងលើការសម្រេចមួយតាំងពីដំបូង ។ បញ្ហាទាំងអស់សម្រាប់វៀតណាមគឺត្រូវកំណត់ថា តើក្រុងមូស្គូ ឬ ក្រុងប៉េកាំង ដែលមានស្ថានភាពប្រសើរជាងគេ ដើម្បីជួយធ្វើឲ្យសម្រេចគោលដៅខ្ពស់បំផុតរបស់ខ្លួនដោយពិតប្រាកដ ។ ការរារែករបស់វៀតណាមនៅចន្លោះទាំងសងខាង គឺពុំអាចបកស្រាយដោយរបៀបផ្សេងពីនេះឡើយ[១០] ។ នៅឆ្នាំ១៩៦៣ ពេលដែល គ្រុត ឆេវ ប្រឆាំងនឹងសង្គ្រាមរំដោះជាតិ ដោយយកលេសថា វាមុខជាបង្កឲ្យមានគ្រោះថ្នាក់ដល់សន្តិភាពពិភពលោក ប្រទេសវៀតណាមបានបង្ខិតខ្លួនចូលអែបប្រទេសចិន ដើម្បីបរិហារជាសាធារណៈពីភាពធូរស្រាល និងកិច្ចព្រមព្រៀងមិនរីកសាយអាវុធនុយក្លេអ៊ែរ ។ ប៉ុន្តែ នៅឆ្នាំ១៩៧២ ពេលដែលលោក រីឆាដ និចសុន ធ្វើដំណើរទៅក្រុងមូស្គូនិងក្រុងប៉េកាំង ដោយមិនបោះបង់ការទម្លាក់គ្រាប់បែកនៅភាគខាងជើងវៀតណាមនោះ ក្រុងហាណូយបានថ្កោលទោសជាសាធារណៈពី "កាលានុវត្តនិយម"(ការនិយមដើរស្របតាមកាលៈទេសៈ) របស់ប្រទេសសង្គមនិយមទាំងឡាយ ។ ក្នុងកាលៈទេសៈនេះ ក្រុងហាណូយនឹកស្ដាយក្រោយថា ការការពារផលប្រយោជន៍ដែលគិតចំពោះខ្លួននិងទាក់ទងនឹងផលប្រយោជន៍ជាតិបានដើរមុនលទ្ធិ"អន្តរជាតិនិយមវណ្ណៈអធន" គឺមុនការគាំទ្រដល់ការប្រយុទ្ធតស៊ូនៅវៀតណាម ដើម្បីការបង្រួបបង្រួមជាតិរបស់ខ្លួន ។

មុនបង្អស់ ក្រុងមូស្គូដែលចង់ការពារភាពធូរស្រាលជាមួយក្រុងវ៉ាស៊ីនតោន និងដោយភ័យខ្លាចថា ការផ្សងព្រេងរបស់វៀតណាមមុខជាប្រទាញខ្លួនឲ្យធ្លាក់ក្នុងជម្លោះមួយរីកកាន់តែធំដោយ ស្វាគមន៍ជាមួយនឹងលក្ខខណ្ឌច្បាស់លាស់មួយចំពោះការវាយលុកដែលផ្ដើមដោយក្រុងហាណូយប្រឆាំងនឹងភាគខាងត្បូងនៅនិទាឃរដូវ

ឆ្នាំ១៩៧៥ ។ រុស្ស៊ីមិនដឹងថា តើពួកគេសប្បាយចិត្តនឹងទស្សនវិស័យផ្សេងៗដែលស្នើឲ្យមានការបង្រួបបង្រួមប្រទេសវៀតណាមឡើងវិញ ឬក៏ភ័យខ្លាចផលវិបាកផ្សេងៗដែលអាចកើតមានពីយុទ្ធនាការយោធាមួយឬក៏យ៉ាងណា ។ ជាពិសេស រុស្ស៊ីមិនចង់ឲ្យកងទ័ពអាមេរិកាំងវិលត្រឡប់មកប្រទេសវៀតណាមវិញទេ ព្រោះវានឹងធ្វើឲ្យពួកគេស្ថិតនៅក្នុងជំហរពិបាកដោះស្រាយមួយដែលត្រូវជ្រើសរើសរវាងការចុះចាញ់និងការធ្វើសង្គ្រាមដោយប្រើវិធីកាន់តែខ្លាំង ។ នៅពេលដែលក្រុងវ៉ាស៊ីនតោនផ្ដើមទាក់ទងជាមួយពួកសូវៀត ដើម្បីស្នើឲ្យទប់សកម្មភាពរបស់វៀតណាម ពួកគេបានសុខចិត្តធ្វើតាមទាំងទើសទាល់ ប៉ុន្តែ បានឆ្លៀតឱកាសនេះ ដើម្បីបញ្ជាក់ប្រាប់ពួកអាមេរិកាំងពីការនៅជាកណ្ដាលរបស់ខ្លួនដែរ ។ ក្នុងសារលិខិតសម្ងាត់មួយដែលផ្ញើជូនប្រធានាធិបតីហ្វ័រដ៍ មួយសប្ដាហ៍មុនការដួលរលំនៃទីក្រុងព្រៃនគរ ក្រុងមូស្គូបានសង្កត់បញ្ជាក់អំពីហេតុការណ៍ថា «គោលបំណងរបស់វៀតណាម ពុំមែនធ្វើឲ្យស្រអាប់រូបភាពសហរដ្ឋអាមេរិកទេ»[១១] ។ គេមិនអាចនិយាយដោយពិតប្រាកដថា វៀតណាមប្រកាន់តាមពាក្យ សន្យានេះដែរឬក៏អត់ទេ ។ ដោយវាយប្រហារមូលដ្ឋានអាកាស តាន់សឺនញឹក ពួកគេបានធ្វើឲ្យការបន្ដជម្លៀសបុគ្គលិកចេញតាមយន្ដហោះដឹកនាំធំៗមិនអាចប្រព្រឹត្តទៅបាន និងបានបង្ខំឲ្យពួកអាមេរិកាំងធ្វើការដកថយមួយតាមឧទ្ធម្ភាគចក្រទាំងប្រញាប់ប្រញាល់និងខូចមុខមាត់ចាប់ពីលើដំបូលអគារទាំងឡាយនៅទីក្រុងព្រៃនគរ ។ សេចក្ដីរាយការណ៍ក្នុងសារព័ត៌មានរបស់សូវៀតអំពីព្រឹត្តិការណ៍នេះនៅតែថ្លឹងថ្លែងជានិច្ច ។ ម្យ៉ាងទៀត ក្នុងលិខិតសម្ដែងការអបអរសាទរដែលក្រុងមូស្គូបញ្ជូនទៅក្រុងហាណូយ គឺពួកសូវៀតប្រយ័ត្នមិនរៀបរាប់បញ្ចូលឈ្មោះសហរដ្ឋអាមេរិកនៅក្នុងនោះឡើយ ដើម្បីចៀសវាងយកដែកទៅរុកដំបៅអាមេរិកាំង[១២] ។

ក៏ប៉ុន្តែ ទោះបីជាមានការប្រុងប្រយ័ត្នទាំងស្រុងរបស់ខ្លួនក៏ដោយ ក៏ក្រុងមូស្គូអាចដឹងថា ប្រទេសវៀតណាមដែលជាប់ជំពាក់នឹងជម្លោះមួយពាន់ឆ្នាំរបស់ខ្លួនជាមួយប្រទេសចិនជានិច្ចនោះ នៅពេលនេះ ហេងស៊ីយ អាចផ្លាស់ប្ដូរចិត្តមកចូលខាងខ្លួនក៏ថាបាន ។ ក្រុងហាណូយអាចក្លាយទៅជាសម្ពន្ធមិត្រមិនអាចវាយតម្លៃបានមួយដើម្បីទប់ប្រទេសចិននិងបម្រើជាឈ្នាន់សម្រាប់ឥទ្ធិពលរបស់សូវៀតនៅអាស៊ីអាគ្នេយ៍ ។ រដ្ឋាភិបាលរបស់សូវៀតអាចពេញចិត្តនឹងការបើកឲ្យប្រើប្រាស់ដែលគ្រោងទុកជាមុននូវកំពង់ផែនានារបស់វៀតណាម ហើយទំនងជាឱកាសពង្រីកមែកធាងរបស់ខ្លួនផង ។ ប៉ុន្មានថ្ងៃបន្ទាប់ពីការដួលរលំនៃទីក្រុងព្រៃនគរ អ្នកត្រួតពិនិត្យសូវៀតបានចាប់ផ្ដើមមកដល់ក្រុងហាណូយយ៉ាងច្រើន ដើម្បីបញ្ជាក់ពីការគាំទ្ររបស់ពួកគេចំពោះវៀតណាម និងដើម្បីទាមទារចំណែកនៃការទទួលខុសត្រូវរបស់គេក្នុងលទ្ធផលសម្រេចប្រកបដោយជ័យជម្នះនេះ ។ បន្ទាប់ពីការរាវែកនិងការគាំទ្រដ៏ប្រយ័ត្នប្រយែងក្នុងរយៈពេលជាច្រើនឆ្នាំ អំណឹះតទៅក្រុងមូស្គូបានបោះពួយទៅជួបអ្នកឈ្នះយ៉ាងលឿន ហើយហាក់ដូចជាត្រៀមបម្រុងបង់តម្លៃរបស់ដែលបាត់ហើយរកឃើញវិញ ជាស្រេចទោះបីវាជាធ្វើឡើងទាំងទើសទាល់ក៏ដោយ ។ មន្ត្រីជួរការសូវៀតម្នាក់បាននិយាយរអ៊ូរទាំប្រាប់រដ្ឋមន្ត្រី

*ការបរទេសរបស់គាត់គឺលោក អង់ដ្រេ ហ្វ្រូមីកូ នៅខែកញ្ញា ឆ្នាំ១៩៧៥ថា ការធុញទ្រាន់របស់យើងគឺយើងលែងសម្គាល់ឃើញអ្វីឲ្យបានប្រសើរក្រៅតែពីឆ្លើយតៅគេ(វៀតណាម)វិញថា ទេប៉ុណ្ណោះ ។ មនុស្សមិនសូវដឹងខុសត្រូវទាំងនោះ បានចាប់ផ្តើមប្រកាន់អាកប្បកិរិយាធ្វើអ្វីៗទាំងអស់តែម្នាក់ឯង ហើយនៅពេលនេះ ពួកគេបានសុំពីយើងនូវរបស់ដែលយើងឲ្យមិនកើតទៀត»[១៣] ។*

*នៅថ្ងៃទី៨ ខែឧសភា គឺតែបួនថ្ងៃប៉ុណ្ណោះបន្ទាប់ពីការសម្រុកចូលដ៏ខ្សុរខ្សារនៃហ្វូងរថក្រោះ T.៥៤ របស់សូវៀតទៅក្នុងវិមានប្រធានាធិបតីនៅទីក្រុងព្រៃនគរ នាវាផ្ទុកទំនិញរបស់សូវៀតឈ្មោះ នីណា សាហ្កាយដាស និងនាវាដឹកប្រេងឥន្ធនៈឈ្មោះ កុមសូម៉ូឡេត ព្រីម៉ូរីយ៉ា បានចូលចតនៅកំពង់ផែដាណាង នៅវៀតណាមខាងត្បូង ។ ពីរសប្តាហ៍ទៀត នាវាថ្មីៗរបស់សូវៀតនឹងបើកចូលមកចតនៅកំពង់ផែក្រុងព្រៃនគរ ដោយផ្ទុកសុទ្ធតែស្បៀងអាហារ និងប្រេងឥន្ធនៈ ។ «កាយវិការប្រកបដោយមនុស្សធម៌»នេះ មានគោលដៅតែមួយគត់គឺ ដើម្បីទទួលបានការដឹងគុណរបស់វៀតណាម ។ ពួកសូវៀតប៉ុនប៉ងបង្កើតទម្លាប់មួយនិងបើកផ្លូវឆ្ពោះទៅរកការប្រើប្រាស់កំពង់ផែនានានៅភាគខាងត្បូងឲ្យកាន់តែទៀងទាត់ ហើយជាពិសេសខាងផ្នែកយោធា ។ ប៉ុន្តែ ដោយវាយតម្លៃពីជំនួយផ្នែកសេដ្ឋកិច្ចនិងបច្ចេកទេសរបស់ពួកសូវៀត, ក្រុងហាណូយមានបំណងបន្តដឹកនាំវិស័យនយោបាយការបរទេសរបស់ប្រទេសទៅតាមចំណង់របស់ខ្លួន ។ ក្នុងពេលជាមួយគ្នាដែលវៀតណាមបដិសេធមិនឲ្យប្រើប្រាស់កំពង់ផែរបស់ខ្លួន ពួកគេក៏បានប្រានចោលការស្នើឲ្យខ្លួនចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាពមួយជាមួយពួកសូវៀតផងដែរ[១៤] ។ ពិតហើយ ពួកវៀតណាមដឹងថា ខ្លួនមានភាពជិតស្និទ្ធនឹងក្រុងមូស្គូជាងក្រុងប៉េកាំងខាងផ្នែកមនោគមវិជ្ជា ប៉ុន្តែ សេចក្តីលំអៀងនេះ មុខជាជំរុញឲ្យពួកគេលះបង់ភាពអព្យាក្រឹតដែលពួកគេធ្លាប់សម្តែងឲ្យឃើញក្នុងជម្លោះរវាងចិន-សូវៀតមិនខាន ។ ការសម្រេចចងសម្ពន្ធភាពមួយតាមផ្លូវច្បាប់ជាមួយក្រុងមូស្គូ ទោះជាមិននិយាយអំពីការអនុញ្ញាតឲ្យសូវៀតប្រើប្រាស់នូវកំពង់ផែនានារបស់ខ្លួនក៏ដោយ ក៏វាបានរួមជាការបង្កហេតុមួយចំពោះប្រទេសចិនដែរ ហើយប្រការនេះមិនមានក្នុងបំណងទាំងឡាយរបស់វៀតណាមឡើយ ។*

*មិនដឹងថា ពួកចិនត្រូវបានឬមិនត្រូវបានផ្តល់ដំណឹងឲ្យដឹងពីការបដិសេធនេះទេ ហើយនៅបន្តការសង្ស័យពីចេតនាផ្សេងៗរបស់ពួកសេរីនិយមវៀតណាមចំពោះពួកសូវៀតតទៅទៀត ។ តាមគេនិយាយថា ជាច្រើនសប្តាហ៍បន្ទាប់ពីក្រុងព្រៃនគរដួលរលំ លោកប្រធាន ម៉ៅ បានរំឭកនៅមុខលោក គូគ្រិត ប្រាមោជ្ជ នាយករដ្ឋមន្ត្រីថៃដែលស្ថិតនៅមួយរយៈខ្លីក្នុងរដ្ឋធានីរបស់ចិនអំពីគម្រោងធ្វើសញ្ញ័យខ្លះៗ នៅក្នុងតំបន់ដែលគាត់ធ្លាប់បានជួយជ្រោមជ្រែងវៀតណាម ។ តាមយោបល់របស់គាត់ថា វៀតណាម«ជាប៉ុស្តិ៍ជួរមុខរបស់ចក្រពត្តិនិយមសូវៀតនៅអាស៊ី»[១៥] ។*

*បើសិនជាគេធ្វើទិទស្សន៍ថា នេះពិតជាសម្តីរបស់ ម៉ៅ មែន វានឹងពិបាកសន្និដ្ឋានពីចេតនាផ្សេងៗរបស់*

វៀតណាមណាស់ ។ ការដណ្ដើមកាន់កាប់ទីក្រុងព្រៃនគរគឺជាការបានសម្រេចបំណងដ៏ខ្ពង់ខ្ពស់មួយ ។ បំណងដ៏ខ្ពង់ខ្ពស់នេះគឺ ហូ ជីមិញ និងបណ្ដាសមមិត្តរបស់គាត់បានស្វែងរកតាមរយៈបទពិសោធន៍និងការតូចចិត្តជាច្រើនដែលពុំធ្លាប់មានពីមុនមក ។ ចាប់ពីពេលនេះទៅ បក្សកុម្មុយនីស្តវៀតណាមដឹងថា ខ្លួនមានសេរីភាពជាងពេលណាៗទាំងអស់ ក្នុងការប្រកាន់យកផ្លូវដែលខ្លួនជ្រើសរើស ។ គ្មានអ្នកណាចេះនិយាយពីមោទនភាពរបស់ប្រទេសវៀតណាមជាងលោក វ៉ាង ទុង និពន្ធនាយកកាសែតញ៉ានហ្សិនឡើយ ។ រួមជាមួយ ហូ ជីមិញ ទុង ធ្លាប់បានទ្រាំទ្រក្នុងការតស៊ូរបស់ចលនាវៀតមិញដើម្បីឯករាជ្យភាព, ចម្បាំងនៅឌៀនបៀនភូ និងបណ្ដាឆ្នាំដ៏យូរលង់ និងភ័យខ្លាចក្នុងការវាយប្រយុទ្ធប្រឆាំងនឹងពួកអាមេរិកាំង ។ នៅខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំបានទៅលេងគាត់នៅក្នុងបន្ទប់ការិយាល័យដ៏តូចដែលមានទីតាំងនៅក្នុងអគារនៃគេហដ្ឋានចំណាស់មួយនាទីក្រុងហាណូយ ។ ពីមាត់បង្អួចទៅនិងតាមស្លឹកឈើត្រសុំត្រសាយ គេមើលឃើញបឹងហ័នគៀមពីចម្ងាយជាបឹងដែលមានដាវទិព្វរបស់វីរបុរសវៀតណាមម្នាក់ដែលធ្វើការប្រយុទ្ធ ដើម្បីឯករាជ្យភាពកប់នៅក្នុងនោះ ។ ទុង ដែលមានស្បែកមុខជ្រីវជ្រួញដោយសារពេលវេលា ហាក់ដូចជាឡើងផ្លត់ក្លាមនៅពេលដែលគាត់និយាយមកកាន់ខ្ញុំក្នុងស្នាមញញឹមមួយថា ៖ “សព្វថ្ងៃ យើងខ្ញុំទាំងអស់គ្នាមានសេរីភាពនិងអំណាចជាងមុន ដែលយើងមិនដែលមានដូចពេលនេះទេ” ។ ការផុតរលត់នៃសង្គ្រាមបានធ្វើឲ្យបាត់ទាំងស្រុងនូវការបង្ខិតបង្ខំភាគច្រើនដែលរឹតត្បិតស្វ័យភាពនយោបាយរបស់វៀតណាម ។ ទុង មិនលាក់លៀមឡើយពីការណ៍ដែលថា ជ័យជម្នះផ្ដាច់ព្រ័ត្របានមានឡើង ទោះបីជាមានការកៀបសង្កត់ពីក្រុងមូស្គូ និងក្រុងប៉េកាំងដែលយកចិត្តទុកដាក់មិនធ្វើឲ្យសហរដ្ឋអាមេរិកទាល់ច្រកក៏ដោយ ។ ទុង បានប្រាប់ខ្ញុំថា ក្រុងហាណូយបានឈ្នះសង្គ្រាមប្រឆាំងនឹងកងទ័ពដែលមានកម្លាំងលើសលប់គឺកងទ័ពជាសត្រូវរបស់ខ្លួន ប៉ុន្តែក៏ឈ្នះកងទ័ពជាបណ្ដាមិត្តខ្លួនដែរ[១៦] ។ ជាឯកជន ពួកមេដឹកនាំផ្សេងៗទៀត បានសម្ដែងឲ្យគេឃើញលក្ខណៈឆាប់ជឿទុកចិត្តគេ និងលក្ខណៈត្រង់គ្មានល្បិចកល ដែលធ្វើបុកក្រអឺតក្រអោងនឹងការដែលប្រទេសវៀតណាមរៀបចំធ្វើការវាយលុកផ្ដាច់ព្រ័ត្ររបស់ខ្លួននៅភាគខាងត្បូង ដោយមិនប្រាប់រឿងនេះទាំងស្រុងឲ្យបណ្ដាសម្ពន្ធមិត្រសង្គមនិយមរបស់ពួកគេដឹងឡើយ ។ នៅប៉ុន្មានថ្ងៃចុងក្រោយនៃខែមេសា ឆ្នាំ១៩៧៥ ក្រុងហាណូយពុំបានយកចិត្តទុកដាក់នឹងការព្រមានដែលបញ្ចេញឲ្យដឹងដាច់ដោយឡែកដោយពួកចិន និងពួកសូវៀតផងទេ ព្រោះប្រទេសទាំងពីរនេះភ័យខ្លាចថា ការវាយដណ្ដើមក្រុងព្រៃនគរដោយកម្លាំងទ័ព មុខជាបង្កឲ្យមានអន្តរាគមន៍ថ្មីមួយរបស់អាមេរិកាំងជាមិនខាន ។

ទុង បានលើកឧទាហរណ៍ជាច្រើនមកប្រាប់ខ្ញុំអំពីសេរីភាពទើបទទួលថ្មីៗនេះ ដែលក្រុងហាណូយអាចបញ្ចេញមតិរបស់ខ្លួនដោយពេញលេញ ។ ឧទាហរណ៍ “យើងគាំទ្ររដ្ឋាភិបាលឥណ្ឌាប្រឆាំងនឹងការរួមគំនិតក្បត់របស់ពួកចក្រពត្តិនិយម ទោះបីជាប្រទេសចិនពុំសប្បាយចិត្តក៏ដោយ ។ យើងគាំទ្រគណបក្សកុម្មុយនីស្តព័រទុយហ្គាល់ប្រឆាំងនឹងការប្រើកលល្បិចរបស់គណបក្សសង្គមនិយម ទោះបីជាគណបក្សកុម្មុយនីស្តផ្សេងទៀត

ជាច្រើនរិះគន់ចំពោះខ្លួនក៏ដោយ» ។ ក្រុងហាណូយបាននិយាយបញ្ចិតបញ្ចៀងចំពោះការប្រឆាំងជំទាស់របស់ក្រុងប៉េកាំងពីការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ននៅឥណ្ឌូកាលពីខែមិថុនាមុន និងការទិតៀនរបស់ចិនប្រឆាំងនឹងគណបក្សកុម្មុយនីស្តព័រទុយហ្កាល់ដែលត្រូវចាត់ទុកជាឧបករណ៍មួយរបស់សូវៀត ។ មន្ត្រីវៀតណាមផ្សេងៗទៀត បាននិយាយប្រាប់ខ្ញុំជាសម្ងាត់ថា ពួកគេពុំអបអរនឹងភាពឥតអៀនខ្មាសនៃនយោបាយសម្របសម្រួលដែលប្រកាន់យកដោយក្រុងមូស្គូក្នុងទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយសហរដ្ឋអាមេរិកទេ ហើយលើសពីនេះគឺការអំពាវនាវរបស់សូវៀតជាគុណប្រយោជន៍ដល់ការបង្កើតប្រព័ន្ធសន្តិសុខរួមមួយនៅអាស៊ីដែលរឿងនេះពួកគេគ្មានឃើញអ្វីក្រៅតែពីការប៉ុនប៉ងធ្វើសម្ពន្ធភាពមួយប្រឆាំងចិនឡើយ ។ នៅឆ្នាំ១៩៦៩ ពួកសូវៀតធ្លាប់បានបញ្ចេញគំនិតប្រមូលផ្តុំប្រទេសនៅអាស៊ីទាំងអស់ឲ្យចូលរួមក្នុងសម្ពន្ធភាពមួយសំដៅប្រឆាំងប្រទេសចិន ។ មួយឆ្នាំក្រោយមក ក្នុងរយៈពេលនៃការធ្វើសម្ភាសន៍មួយជាលើកទីពីរ វ៉ាង ទុង បានញែករឿងនេះដោយពាក្យគួរឲ្យចងចាំពីរឃ្លា ហើយនិយាយប្រាប់ខ្ញុំថា ៖ «វាមានភាពទីទៃពីគ្នាធំៗរវាងប្រទេសនានានៅអាស៊ី ។ តើត្រូវគិតគូររំលាយប្រទេសទាំងនេះឲ្យទៅជាវត្ថុតែមួយដោយរបៀបយ៉ាងដូចម្តេច? តើគិតចង់រួមកម្លាំងជា ស៊ូហារតូ (ឥណ្ឌូនេស៊ី) និង សេនីប្រាមោជ(នៅប្រទេសថៃ) ដោយមធ្យោបាយណា?» ។

ប្រាកដណាស់ ក្រុងហាណូយពុំបានត្រៀមខ្លួនលែងគាំទ្រការតស៊ូបដិវត្តន៍នៅក្នុងប្រទេសអាស៊ីផ្សេងៗ ដើម្បីបើកឱកាសឲ្យពួកសូវៀតទាក់ទាញបណ្តារបប«ប្រតិកិរិយា»ក្នុងតំបន់ក្នុងគម្រោងមួយឡោមព័ទ្ធប្រទេសចិនឡើយ ។ អ្នកកាសែតវៀតណាមម្នាក់បានលាន់មាត់នៅមុខខ្ញុំកាលពីខែមេសា ឆ្នាំ១៩៧៧ថា «ពួកសូវៀតលែងមានអ្វីដែលពួកគេមានទៀតហើយ» ។ «ពួកគេចង់ឲ្យមានភាពធូរស្រាលជាមួយសហរដ្ឋអាមេរិក ដើម្បីអាចប្រើប្រាស់ភាពប៉ិនប្រសប់ទាំងអស់របស់ខ្លួនក្នុងការផលិតរថយន្ត និងម៉ាស៊ីនត្រជាក់សម្រាប់ទីផ្សារក្នុងប្រទេសរបស់គេ ។ ពួកគេពុំមានផលប្រយោជន៍ណាមួយ ដើម្បីគាំទ្រការប្រយុទ្ធតស៊ូក្នុងការរំដោះប្រទេសតតិយលោកឡើយ លើកលែងតែដើម្បីបង្កើតជាឧបសគ្គដល់ប្រទេសចិនប៉ុណ្ណោះ» ។

បន្ទាប់ពីជ័យជម្នះដែលធ្វើឲ្យស្រឡាំងកាំងរបស់ខ្លួន ក្រុងហាណូយបានដល់ក្តីសប្បាយរីករាយក្រៃលែង ។ អ្វីៗអាចធ្វើបានទាំងអស់សម្រាប់អ្នកដែលបានបង្ក្រាបរដ្ឋដ៏មានអំណាចបំផុតនៃពិភពលោក ។ ដោយសម្បូរហត្ថពលករដែលមានជំនាញ, កសិកម្មរីកត្រកុំត្រកាល, ធនធានក្រោមដីស្តុកស្តម្ភ-ប្រហែលមានប្រេងកាតផង-ទឹកសម្បូរត្រី ប្រទេសវៀតណាមអាចកសាងសេដ្ឋកិច្ចដ៏រឹងមាំមួយលើមូលដ្ឋានទាំងនេះ ទោះបីគេអាចប្រយុទ្ធតស៊ូនឹងបិសាចអាមេរិកាំងឈ្នះហើយក្តី ។ ការសុខកាយសប្បាយចិត្តនេះ បានរលាយបាត់យ៉ាងឆាប់រហ័ស ក្នុងលំដាប់ដែលតថភាពផ្នែកសេដ្ឋកិច្ចបានលេចឡើងឲ្យឃើញកាន់តែច្បាស់ឡើងៗ ។ ដើម្បីកសាងប្រទេសដែលត្រូវហិនហោចដោយសារសង្គ្រាមឡើងវិញ គេត្រូវតែខំប្រឹងឲ្យបានសម្រេចនូវជំនួយផ្នែកសេដ្ឋកិច្ចនិងបច្ចេកទេសមួយ ។ ការគ្រប់គ្រងប្រជាជាតិមួយដែលរួបរួមឡើងវិញ គឺជាបន្ទុកបន្ថែមមួយទៀត ។ បើនិយាយឲ្យខ្លីទៅ

ឯករាជ្យ ដែលទទួលបានថ្មីៗ នៅប្រទេសវៀតណាមគឺជាការសាកល្បងដ៏តឹងតែងមួយ ។ នៅទីក្រុងហាណូយ គេហាមមិនឲ្យនិយាយទិតៀនជាឯកជនអំពីទម្រង់ខ្លះៗនៃនយោបាយរបស់សូវៀតឡើយ ប៉ុន្តែ ជាសាធារណៈវិញ គេសម្ដែងឲ្យឃើញការព្រមព្រៀងទាំងស្រុងមួយជាមួយក្រុងមូស្គូ ។ ខុសប្លែកពីដំណើររបស់គាត់ទៅទីក្រុងប៉េកាំង នៅខែកញ្ញា ឆ្នាំ១៩៧៥ ទស្សនកិច្ចរបស់ ឡេ យន់ នៅក្រុងមូស្គូនាខែតុលាឆ្នាំដដែល បានបើកឱកាសឲ្យមានការតាក់តែងសេចក្ដីថ្លែងការណ៍រួមមួយ ដែលប្រទេសវៀតណាមអះអាងនឹងសហភាពសូវៀតពីការគាំទ្ររបស់ខ្លួនចំពោះនយោបាយការបរទេសរបស់សូវៀត និងលាតត្រដាងស្ដីពីភាពចាំបាច់ដើម្បី“ធ្វើឲ្យមានភាពធូរស្រាលតាមដំណើរមួយដែលមិនអាចប្រែត្រឡប់បាន” ។ សម្រាប់ក្រុងប៉េកាំង ពាក្យ“ភាពធូរស្រាល” គឺជាពាក្យស្ទើរតែប្រមាថជាចំហមួយ ។ វៀតណាមផ្ទាល់បានបរិហារនៅខែតុលា ឆ្នាំ១៩៧៤ ពីការរួមគំនិតក្បត់របស់អាមេរិកាំង សំដៅបំបែកបំបាក់ប្រទេសកុម្មុយនីស្ដនានា និងលាក់គំនិតថា គោលដៅពិតប្រាកដរបស់សហរដ្ឋអាមេរិកគឺ “ការកម្ទេចចលនារំដោះជាតិទាំងអស់”[១៧] ។ ជាច្រើនខែក្រោយមក មេដឹកនាំវៀតណាមម្នាក់បាននិយាយដោះសាពីការប្រែត្រឡប់នេះនៅចំពោះមុខអ្នកមានសមានចិត្តម្នាក់គឺលោក ភីធ័រ លីមគីកូ និពន្ធនាយកកាសែត Journal of Contemporary Asia ដែលកំពុងធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមថា ៖ “ឯករាជ្យភាពមានតម្លៃថ្លៃណាស់ ។ រៀងរាល់ពេលដែលយើងសម្ដែងឲ្យឃើញឯករាជ្យ យើងត្រូវបាត់សេចក្ដីត្រូវការមួយថែមទៀត ។ កាលណាជំហររបស់យើងប្រែប្រួលទៅជាអាក្រក់ កាលនោះទំហំនៃជំនួយរបស់បណ្ដាប្រទេស“ជាបងប្អូន”ក៏ចុះថយដែរ”[១៨] ។

មួយខែបន្ទាប់ពីការវិលត្រឡប់របស់ ឡេ យន់ ពីទីក្រុងមូស្គូ កាសែតរបស់វៀតណាមមួយបានរំឭកដោយប្រើពាក្យចំអកបញ្ឈឺចិត្តថា ជ័យជម្នះមានន័យថា ទីបញ្ចប់នៃអំណោយរបស់បណ្ដាប្រទេសជាមិត្ត ។ “នៅពេលមានសង្គ្រាម យើងបានទទួលជំនួយមួយដែលគេឲ្យដោយឥតគិតថ្លៃ ។ ប៉ុន្តែ អណើះតទៅ ទំនាក់ទំនងរបស់យើងជាមួយបណ្ដាប្រទេសជាមិត្តនិងជាបងប្អូន ស្ថិតនៅត្រង់ការប្រើពាក្យពេចន៍ដូច្នេះ ៖ សងបំណុលវិញ នូវអ្វីដែលអ្នកបានខ្ចី ធ្វើឲ្យដើមទុនរបស់អ្នកមានផ្លែផ្កា ទិញដើម្បីដូរ ។ ប្រការទាំងអស់នេះ គឺធ្វើឡើងក្នុងនាមនៃជំនួយ និងផលប្រយោជន៍ទៅវិញទៅមក”[១៩] ។

ការស្ដារប្រទេសវៀតណាមក្រោយសម័យសង្គ្រាមឡើងវិញ ត្រូវការជាចាំបាច់នូវជំនួយដ៏សម្បើមមួយពីប្រទេសក្រៅ ។ រដ្ឋាភិបាលក្រុងហាណូយចូលចិត្តស្នើសុំជំនួយពីបណ្ដាប្រទេសលោកខាងលិចជាជាងពីប្លុកសង្គមនិយម ដោយសារតែប្រទេសទាំងនោះមានបច្ចេកវិជ្ជាជឿនលឿនជាង ។ ប៉ុន្តែ ចលនាមិនចូលបក្សសម្ពន្ធត្រូវការឲ្យរក្សាសមតាមួយដែលលំបាកតម្រូវចិត្តបំផុត ។ វៀតណាមបានបំភ្លឺដូច្នេះចំពោះ លោក ហ្វីលីព រីឈ័រ ឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងហាណូយថា អ្វីដែលមានតែក្នុងគំនិតដើម្បីពង្រឹងឯករាជ្យនយោបាយរបស់យើង គឺរបៀបចាត់ចែងមួយ“ដែលមានបួនភាគី” ប្លុកសូវៀតនិងប្រទេសចិនផ្គត់ផ្គង់ពាក់កណ្ដាលនៃជំនួយអឺរ៉ុបខាងលិច

សហរដ្ឋអាមេរិក ប្រទេសជប៉ុន និងកាណាដា ផ្គត់ផ្គង់ពាក់កណ្តាលទៀត[២០] ។ ពីមុនមកក្រុងហាណូយចូលចិត្តរក្សាសមតាមួយក្នុងទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយក្រុងមូស្គូនិងក្រុងប៉េកាំងជាង ។ ក៏ប៉ុន្តែ បើចង់បានទទួលជំនួយ ហាណូយត្រូវតែកែប្រែតវិយាបថរបស់ខ្លួន ហើយបើគិតឲ្យសព្វៗទៅគួរតែលំអៀងទៅខាងក្រុងមូស្គូប្រសើរជាង ។ មុនដំបូង ពីព្រោះសហភាពសូវៀតជាប្រទេសមានភោគសម្បត្តិនិងអានុភាពជាងប្រទេសចិន ហើយជាពិសេសបន្ទាប់មក ពីព្រោះផលប្រយោជន៍របស់ខ្លួនគឺថា ប្រទេសវៀតណាមត្រូវតែក្លាយទៅជារដ្ឋខ្លាំងមួយ ។ ដូចដែលគេនឹកស្មាន ប្រទេសចិនបានបដិសេធមិនសន្យាផ្តល់ជំនួយក្នុងរយៈពេលវែងឡើយ ។ ផ្ទុយទៅវិញ ក្រុងមូស្គូបានសន្យាផ្តល់ជំនួយដល់ការធ្វើឲ្យបានសម្រេចនូវផែនការប្រាំឆ្នាំ១៩៧៦-១៩៨០របស់វៀតណាមតាមកិច្ចសន្យាផ្តល់ហិរញ្ញវត្ថុដែលកំណត់ជាស្រេច ។ នៅខែតុលា ឆ្នាំ១៩៧៥ កិច្ចព្រមព្រៀងផ្តល់ជំនួយមួយជាលើកដំបូងសម្រាប់ការស្តារប្រទេសឡើងវិញត្រូវបានចុះហត្ថលេខា ។ ក្រុងមូស្គូបានសន្យាផ្តល់ហិរញ្ញវត្ថុចំនួន៦០ភាគរយត្រូវជា ២.១០០លានដុល្លារក្នុងការចំណាយដែលរាប់បញ្ចូលក្នុងផែនការសម្រាប់រយៈកាលឆ្នាំ១៩៧៦-៨០[២១] ។

ច្បាស់ណាស់ នេះជាអំណោយដែលគិតតែប្រយោជន៍ខ្លួន ។ ជាថ្នូរទៅវិញ ប្រទេសវៀតណាម ត្រូវតែផ្តល់នូវការគាំទ្ររបស់ខ្លួនចំពោះនយោបាយក្រៅប្រទេសសូវៀត-អាមេរិកាំង ។ ក៏ប៉ុន្តែ ពួកមេដឹកនាំវិមានក្រឹមឡាំងបានវាយតម្លៃយ៉ាងកណ្តាលថា ក្រុងហាណូយបានខ្នះខ្នែងពង្រីកភាពធូរស្រាលនេះ ដោយប្រែផ្លាស់ទំនាក់ទំនងផ្ទាល់របស់ខ្លួនជាមួយបរទេសដែរ ។ ដោយយល់ពីស្មារតីឯករាជ្យរបស់ប្រទេសវៀតណាម ក្រុងមូស្គូភ័យខ្លាចយ៉ាងខ្លាំងពីការបាត់បង់ផ្នែកមួយនៃឥទ្ធិពលរបស់ខ្លួន ។ តាំងពីដើមរហូតដល់ចុងឆ្នាំ១៩៧៦ ពួកសូវៀតបានឃ្លាំមើលជាមួយការព្រួយបារម្ភពីការខំប្រឹងរបស់ក្រុងហាណូយក្នុងគោលបំណងបង្កើតទំនាក់ទំនងផ្នែកការទូតនិងសេដ្ឋកិច្ចជាមួយបស្ចិមប្រទេស និងទៅចូលរួមជាមួយចលនាមិនចូលបក្សសម្ព័ន្ធ ។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយផ្នែកសេដ្ឋកិច្ចតែពីរ-បីខែប៉ុណ្ណោះ ការសប្បាយរីករាយខ្លាំងរបស់សូវៀតចំពោះប្រទេសវៀតណាមដែលជា "ប៉ុស្តិ៍ជួរមុខនៃលទ្ធិសង្គមនិយម" បានចាប់ផ្តើមប្រែជាសោះអង្គើយ ។

ក្រុងហាណូយមានភាពដូចគ្នាផ្នែកមនោគមវិជ្ជាថែមទៀតជាមួយក្រុងមូស្គូ ក៏ដូចជាមួយក្រុងប៉េកាំង ប៉ុន្តែផលប្រយោជន៍របស់ខ្លួនប្រាកដជាមិនឲ្យឡូកឡំនឹងជម្លោះរបស់ប្រទេសទាំងពីរទេ ។ ដូចរបាយការណ៍សម្ងាត់មួយរបស់សូវៀត ដែលទុកសម្រាប់តែការសន្ទនាកំពូលរវាងសូវៀត-វៀតណាម នៅខែតុលា ឆ្នាំ១៩៧៥ បានសង្កត់បញ្ជាក់ពីរឿងនេះថា សម្រាប់ឱកាសនេះ "វៀតណាមយល់ឃើញថា មិនទាន់ដល់កាលវេលាដែលត្រូវកាន់ជើងខាងណាៗក្នុងជម្លោះ" ដែលធ្វើឲ្យប្រទេសចិនប្រឈមមុខនឹងសហភាពសូវៀតទេ[២២] ។ ពួកមេដឹកនាំវៀតណាមមានការបារម្ភដោយឡែកមិនបណ្តោយឲ្យភាគខាងត្បូង ដែលទើបរំដោះបានថ្មីៗក្លាយទៅជារបស់ដែលខ្លួនអាចខាតបង់ក្នុងការប្រជែងគ្នារវាងចិន និងសូវៀតឡើយ ។ នៅភាគខាងត្បូង ពួកមេដឹកនាំ

វៀតណាមបានប្រគល់ការធ្វើឲ្យសម្រេចខាងផ្នែកសេដ្ឋកិច្ចខ្លះៗ ទៅឲ្យបណ្ដាប្រទេសផ្សេងៗដូចជាប្រទេសបារាំង, ន័រវ៉ែស, ឥណ្ឌា និងប្រទេសជប៉ុនជាដើម ។ ចំណែករុស្ស៊ី និងពួកចិនបានត្រូវគេបោះបង់ចោលដាច់អហង្ការ ។ ដោយធ្វើឲ្យក្ដៅក្រហាយចំពោះការបដិសេធរបស់វៀតណាម មិនអនុញ្ញាតឲ្យបើកស្ថានកុងស៊ុលមួយនៅទីក្រុងហូ ជីមិញ ពួកសូវៀតបានគំរាមចាប់បង្ខំឲ្យនាវាទាំងឡាយរបស់ខ្លួនធ្វើពហិការមិនចូលចតនៅកំពង់ផែរដ្ឋធានីភាគខាងត្បូងដែរ ។ ប៉ុន្តែ វៀតណាមបានដោះស្រាយបញ្ហានេះដូចគ្នានឹងពួកចិន- នេះជាការសម្ដែងឲ្យឃើញភាពមិនលំអៀងយ៉ាងល្អ ។ វៀតណាមបានហាមឃាត់មិនឲ្យប្រទេសទាំងពីរបើកស្ថានកុងស៊ុលនៅភាគខាងត្បូងដូចគ្នា នៅពេលដែលពួកបារាំងបានត្រូវអនុញ្ញាតឲ្យរក្សាស្ថានកុងស៊ុលរបស់គេដដែល ហើយអ្នកការទូតនិងអ្នកកាសែតលោកខាងលិចបានធ្វើដំណើរទៅភាគខាងត្បូងសឹងតែដោយសេរី[២៣] ។

នៅខែឧសភា ឆ្នាំ១៩៧៥ អ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានតាស្ស (TASS) នៅទីក្រុងហាណូយ ដែលទើបនឹងដើរមើលប្រទេសនេះរួមជាមួយសហភាគរៈ(អ្នកមានវិជ្ជាជីវៈដូចគ្នា) កុម្មុយនីស្តជាច្រើននាក់បានត្អូញត្អែរយ៉ាងល្វីងជូរចត់ពី «ភាពអយុត្តិធម៌» ដែលវៀតណាមអនុញ្ញាតឲ្យតែបណ្ដាអង្គការសារព័ត៌មានចក្រពត្តិដូចជាទីភ្នាក់ងារព័ត៌មានបារាំង, អេភី, រ៉យទ័រ និង យូ.ភី.អាយ. ធ្វើការនៅក្រុងហូជីមិញ នៅពេលដែលវៀតណាមបដិសេធមិនឲ្យខ្លួនបើកការិយាល័យមួយនៅទីនោះឡើយ ។ នៅនិទាឃរដូវឆ្នាំ១៩៧៦ អ្នកការទូតឥណ្ឌាម្នាក់ដែលបំពេញមុខងារនៅក្រុងហាណូយបាននិយាយប្រាប់ខ្ញុំជាសម្ងាត់ថា «របៀបដែលអ្នកការទូតសូវៀតយាយីរំខានបណ្ដាសហភាគរៈរបស់ពួកគេដែលត្រូវបណ្ដេញចេញពីក្រុងព្រៃនគរ ដើម្បីស្វែងរកព័ត៌មានផ្សេងៗគឺពិតជាគួរឲ្យអាណិតមែនទែន» ។

ឡេ យន់ បានធ្វើឲ្យរុស្ស៊ីក្ដៅក្រហាយយ៉ាងខ្លាំងក្នុងឱកាសនៃមហាសន្និបាតបក្សកុម្មុយនីស្តសហភាពសូវៀតលើកទី២៥ នៅខែមីនា ឆ្នាំ១៩៧៦ ដោយគាត់ព្យាយាមសួរពីប្រធានបទឯករាជ្យភាព ។ នៅថ្ងៃបន្ទាប់គឺជាថ្ងៃដែលអ្នកមនោគមវិជ្ជានៃបក្សកុម្មុយនីស្តសូវៀត មីខាអ៊ីល ស៊ូស្លូវ បរិហារពីការនិយាយប្រកាន់តាមទ្រឹស្ដីតិចតួចពេករបស់បក្សកុម្មុយនីស្តបារាំងហើយហាក់ដូចជាគាប់ជួន ព្រោះ ឡេ យន់ បានចូលរួមបរិភោគបាយថ្ងៃត្រង់ជាមួយលោក ហ្សរក ម៉ារឆេ- អគ្គលេខាបក្សកុម្មុយនីស្តបារាំង- ដែរ ។ ក្នុងសន្ទរកថារបស់គាត់ ឡេ យន់ បានគូសបញ្ជាក់ថា បក្សកុម្មុយនីស្តនានាគឺបង្កើតឡើងដើម្បីស្វែងរក «របៀបដែន, ទម្រង់ និងរបៀបប្រឆាំងផ្សេងៗ តម្រូវទៅតាមស្ថានភាពនៃប្រទេសរៀងៗខ្លួនរបស់ពួកគេ»[២៤] ។

នៅខែសីហា ឆ្នាំ១៩៧៦ ផាំ វ៉ាន់ដុង បានធ្វើជាតំណាងប្រទេសវៀតណាមរួមគ្នាតែមួយទៅចូលរួមសន្និសីទកំពូលនៃបណ្ដាប្រទេសមិនចូលបក្សសម្ពន្ធនៅទីក្រុងកូឡុំបូ ។ វៀតណាមមានការពេញចិត្តយ៉ាងខ្លាំងចំពោះសេចក្ដីរាប់អានដែលប្រទេសជាច្រើននៃពិភពតតិយលោកសម្ដែងឲ្យឃើញ នៅពេលដែលពួកគេបានជួបប្រទេសទាំងនោះជាលើកដំបូងបង្អស់ ក៏ប៉ុន្តែ បែរជាត្រូវធ្វើឲ្យភ្ញាក់ផ្អើលដោយការមិនចូលចិត្តរបស់សហភាព

*សូវៀតទៅវិញ ។ នៅពេលត្រឡប់ពីកូឡុំបូមកវិញ ង៉ូ ឌៀន បាននិយាយអាថ៌កំបាំងប្រាប់ជនកុម្មុយនីស្តអ៊ីតាលីម្នាក់ថា ៖ «ពួកសូវៀតនឹងត្រូវធ្វើអ្វីៗជាច្រើនទៀត ដើម្បីកែលំអរូបភាពជានិមិត្តរូបរបស់ខ្លួន»[២៥] ។*

*នៅខែកញ្ញា ឆ្នាំ១៩៧៦ ក្រុងហាណូយត្រូវបានទទួលឲ្យចូលជាសមាជិកអង្គការរូបិយវត្ថុអន្តរជាតិ ហើយនៅខែមករា ឆ្នាំ១៩៧៧ បានទទួលឥណទានមួយចំនួន៣៦លានដុល្លារ ។ ប្រទេសវៀតណាមជារដ្ឋសង្គមនិយមដំបូងគេដែលបានចូលជាសមាជិកអង្គការរូបិយវត្ថុអន្តរជាតិ ដែលតាមក្រុងមូស្គូថាជា«ឧបករណ៍សំខាន់បំផុតរបស់ចក្រពត្តិនិយមសម្រាប់ធ្វើអាជីវកម្មលើបណ្តាប្រទេសដែលកំពុងរីកលូតលាស់»[២៦] ។*

*តាមការពិត ក្រុងមូស្គូ ក្រុងប៉េកាំងនិងប្រទេសសង្គមនិយមឯទៀតៗដែលស្ថិតនៅដោយឡែកពីអង្គការរូបិយវត្ថុអន្តរជាតិ គឺសម្រាប់ហេតុផលមួយផ្សេងទៀត ។ បណ្តារដ្ឋជាសមាជិក ត្រូវបង្ហាញអង្គការរូបិយវត្ថុអន្តរជាតិពីសមតុល្យនៃតុល្យការផ្នែកសេដ្ឋកិច្ចនិងចំនួនទឹកប្រាក់នៃរូបិយប័ណ្ណបម្រុងរបស់ខ្លួន គឺដូចបង្ហាញឲ្យសត្រូវដឹងពីការសម្ងាត់របស់រដ្ឋអ៊ីចឹង! ។ ដូចដែលគេគិតទុកជាមុន ពួកសូវៀតមិនភ្លេចនឹងរិះគន់ការចូលជាសមាជិកនេះឡើយ ។ ប៉ុន្តែ នៅពេលដែលពួកគេដឹងពីបទបញ្ញត្តិទាំងឡាយនៃការវិនិយោគរបស់បរទេសដែលគ្រោងការដោយក្រុងហាណូយ ហើយដោយការទទូចឲ្យពួកវិនិយោគិនលោកខាងលិចចូលមករកស៊ី ពួកសូវៀតបានចាប់ផ្តើមមិនទុកចិត្តពីការតម្រង់ទិសផ្នែកមនោគមវិជ្ជារបស់វៀតណាមភ្លាម ។ អ្នកការទូតសូវៀតនៅក្រុងហាណូយមិននិយាយអ្វីទាំងអស់ ដើម្បីបិទបាំងការឈ្លើសចិត្តរបស់គេ ដោយវិនិច្ឆ័យជាមុនពីបរាជ័យនៃការសាកល្បងកសាងលទ្ធិសង្គមនិយមជាមួយប្រាក់របស់បណ្តាប្រទេសលោកខាងលិចនេះ ។ អ្នកការទូតសូវៀតម្នាក់បានកត់សម្គាល់ប្រាប់សហភាគរៈឥណ្ឌាម្នាក់នៅទីក្រុងហាណូយជាមួយការចំអករដែលលែងច្រឡំថា ៖ «យើងធ្លាប់ដឹងហើយ អ្វីដែលពួកយូហ្គោស្លាវីពឹងលើការវិនិយោគរបស់បស្ចិមប្រទេស»[២៧] ។*

*ការអាក់អន់ចិត្តរបស់ពួកសូវៀតបានកើនឡើងថែមទៀតនៅពេលដែលប្រទេសវៀតណាមប្រកាសពីការបដិសេធរបស់ខ្លួនមិនចូលជាសមាជិកក្រុមប្រឹក្សាសង្គហសេដ្ឋកិច្ចឬអង្គការកូម៉េកុង (COMECON : Council for Mutual Economic Assiatance) ។ នៅដើមឆ្នាំ១៩៧៧ អ្នកការទូតវៀតណាមម្នាក់បានប្រាប់រឿងស្ងាត់កំបាំងឲ្យខ្ញុំដឹងថា ៖ «ពួកសូវៀតបានកៀបសង្កត់ឲ្យប្រទេសសង្គមនិយមទាំងអស់ចូលជាសមាជិកអង្គការកូម៉េកុង ។ ប៉ុន្តែក្រៅពីប្រទេសគុយបា គ្មានប្រទេសមិនមែនអឺរ៉ុបណាមួយចូលរួមឡើយ ហើយយើងក៏មិនមានបំណងចូលដូចគ្នា ។ យើងនឹងធ្វើឲ្យពួកចិនអាក់អន់ចិត្ត»[២៨] ។*

*នៅរដូវក្តៅឆ្នាំ១៩៧៦ ពួកសូវៀតហាក់ដូចជាបោះបង់ចោលមិនកសាងរោងចក្រស្លដែកថែបមួយបញ្ចូលជាមួយគ្នានឹងរោងចក្រផលិតកាំភ្លើងធំនៅប្រទេសវៀតណាមឡើយ ។ ដោយគ្មានកាកធ្យូងថ្មនិងគ្មានរ៉ែដែកគ្រប់គ្រាន់-វត្ថុទាំងអស់នេះដែលប្រទេសវៀតណាមខ្វះ-ភ្លាមនោះ ពួកសូវៀតប្រាប់ថា សំណើនេះពុំសមស្របទេ ។ ការផ្គត់ផ្គង់គ្រឿងបន្លាស់សម្រាប់កង់ទ័ពមានសភាពយឺតយ៉ាវ ហើយការដ្ឋានកសាងទំនប់វារីអគ្គិសនី*

ដែលបើកសម្ពោធដោយសូវៀតលើទន្លេដា នៅវៀតណាមខាងជើង តាមការពិតគឺគ្មានសកម្មភាពធ្វើអ្វីទាំងអស់ ។ ដើម្បីបង្ហាញឲ្យឃើញការក្តៅក្រហាយរបស់ខ្លួន ក្រុងហាណូយបានអនុម័តមាត្រាមួយនៃគម្រោងនេះដោយមិនបញ្ចូលពួកសូវៀតផងទេ ។ វៀតណាមបានចាប់ផ្តើមគ្រោងគិតពីលទ្ធភាពបើកការដ្ឋានសាងសង់ទំនប់វារីអគ្គិសនីតាមគម្រោងរបស់ខ្លួន ។ ក្នុងគោលដៅនេះពួកគេបានផ្តើមស្នាបស្ទង់យោបល់ធនាគារអភិវឌ្ឍន៍អាស៊ីនិងបណ្តាប្រទេសលោកខាងលិចដោយស្ងាត់កំបាំងដើម្បីសាកល្បងបញ្ចៀកពីការជួយជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុដែលត្រូវការខានមិនបាន ។ គណៈបេសកកម្មសេដ្ឋកិច្ចរបស់អូស្ត្រាលី ដែលស្នាក់អាស្រ័យមួយរយៈនៅប្រទេសវៀតណាមនាដំណាច់ឆ្នាំ១៩៧៦ បានភ្ញាក់ផ្អើលក្នុងចិត្តពីភាពច្បាស់លាស់នៃបញ្ហាផ្សេងៗរបស់គូសន្ទនាខ្លួនអំពីតម្លៃនៃការស្ថាបនាទំនប់វារីអគ្គិសនីមួយប្រភេទដូចទំនប់វារីអគ្គិសនីដែលកំពុងមានសកម្មភាពនៅប្រទេសអូស្ត្រាលីដែរ ។ វៀតណាមពុំមាននិយាយពីរឿងនេះថែមទៀតទេ ប៉ុន្តែ ដាក់ច្បាស់ណាស់ថា ពួកគេកំពុងស្វែងរកអ្នកជំហរចេញប្រាក់ថ្មីម្នាក់ទៀត ។ រីតតែចេញមុខជាងនេះទៀត ពួកគេបានប្រឹងប្រែងស្វែងរកការផ្តល់ហិរញ្ញវត្ថុមួយផងដែរ សម្រាប់ជំនួសគម្រោងសាងសង់រោងចក្រស្លដែកថែបដែលបោះបង់ចោលដោយពួកសូវៀត ។ ជាសាធារណៈ ពួកគេចៀសវាងមិនធ្វើអត្ថាធិប្បាយទាំងអស់ស្តីពីការបោះបង់គ្នាឯងរបស់រុស្ស៊ី ប៉ុន្តែ ពួកគេបានបង្កាប់ឲ្យធ្វើការសិក្សាមួយដែលអាចធ្វើបាននៅគ្រឺហ្សូត៍-ឡ្វ័រ (Creusot-Loire)[២៩] ។

ប្រទេសវៀតណាមបានរំពឹកពួកសូវៀតថា ខ្លួនត្រូវការជំនួយមួយភ្លាមៗមុននឹងផ្តើមសហប្រតិបត្តិការពេញលេញជាមួយប្លុកសង្គមនិយមនិងបំពេញតម្រូវការផ្សេងៗដោយបង្កើនការនាំចេញរបស់ខ្លួនទៅកាន់សហភាពសូវៀត ទោះបីជានៅខែកក្កដា ឆ្នាំ១៩៧៦ អ្នកទទួលខុសត្រូវខាងផែនការរបស់វៀតណាម ឡេ ថាញ់ងី ដែលត្រឡប់ពីដំណើរដ៏យូរមួយនៅក្រុងមូស្គូ និង ប៉ែរឡាំងខាងកើតគ្មានបានទទួលអ្វីបន្តិចសោះក៏ដោយ[៣០] ។

ត្រូវធ្វើឲ្យមួម៉ៅដោយការខ្វះស្បៀងអាហារនិងវត្ថុធាតុដើម ព្រោះតែការនាំចេញយ៉ាងសម្បើមទៅកាន់សហភាពសូវៀតសម្រាប់ទ្រទ្រង់ការនាំចូលរបស់ខ្លួន វៀតណាមបានបង្ហាញឲ្យឃើញជារឿយៗនូវការមិនសប្បាយចិត្តរបស់គេចំពោះក្រុងមូស្គូ តាមរយៈការព្រមានរបស់អ្នកទទួលខុសត្រូវនៅក្រោមឱវាទខ្លួន ។ នៅខែកញ្ញា ឆ្នាំ១៩៧៦ ទស្សនាវដ្តីផ្នែកទ្រឹស្តីរបស់បក្សកុម្មុយនីស្តវៀតណាមឈ្មោះ *Hoc Tap* បានជំរុញឲ្យ“គិតគូរពីការផ្លាស់ប្តូរផ្សេងៗដែលកើតមានដោយចៃដន្យក្នុងការធ្វើសហប្រតិបត្តិការជាអន្តរជាតិ ហើយលើមូលដ្ឋាននេះត្រូវយកចិត្តទុកដាក់ថែមទៀតអំពីនយោបាយខ្លួនទុបត្ថម្ភខ្លួនដោយខ្លួនឯង និងការបង្កើនផលិតផលសម្រាប់នាំចេញ”[៣១] ។ ជាជំនួសការតបវិញភ្លាមៗ វៀតណាមបានកាត់បន្ថយទីប្រឹក្សាយោធាសូវៀតមួយចំនួន ។ បន្ទាប់ពីមហាសន្និបាតបក្សកុម្មុយនីស្តវៀតណាមនៅខែធ្នូ ឆ្នាំ១៩៧៦ ចំនួននេះបានថយចុះពី៨០មក៤០នាក់ បន្ទាប់មកនៅខែមេសា ឆ្នាំ១៩៧៧ សល់តែ២៥នាក់ប៉ុណ្ណោះ ។ ចំនួនទឹកប្រាក់ប្រចាំឆ្នាំនៃជំនួយយោធារបស់សូវៀតមកឲ្យវៀតណាមបានធ្លាក់ចុះដោយឡើងមិនលើសពី ២០លានដុល្លារឡើយ ។ ទំនាក់ទំនងផ្សេងៗរវាង

*សូវៀត-វៀតណាមបានថមថយ ក្នុងពេលដែលអ្នកការទូតសូវៀតដែលបំពេញមុខងារនៅក្រុងហាណូយចាប់ផ្ដើមសម្ដែងភាពទោមនស្សជាចំហពី«ភាពរមិលគុណរបស់វៀតណាម» ។ នៅនិទាឃរដូវឆ្នាំ១៩៧៧ អ្នកការទូតអាស៊ីម្នាក់បានត្រូវធ្វើឲ្យភ្ញាក់ផ្អើល ដែលសម្គាល់ឃើញពួកសូវៀតភ័យខ្លាចណាស់ក្រែងប្រទេសវៀតណាមចូលខាងបុកមូលធននិយម ។ ជាពិសេសប្រទេសជប៉ុន ក៏ធ្វើឲ្យពួកសូវៀតព្រួយខ្លាចដែរ ។ ពួកសូវៀតក្រែងរអែងថា ប្រទេសវៀតណាម -ជាមួយវត្ថុធាតុដើមនិងទីផ្សារក្នុងប្រទេសរបស់ខ្លួន- មុខជាជួយធ្វើឲ្យប្រទេសជប៉ុនរឹងមាំថែមទៀត ដែលជាគូប្រជែងមិនមែនកុម្មុយនីស្តសំខាន់បំផុតរបស់គេនៅអាស៊ីខាងកើត ។ ម្យ៉ាងទៀត ការសះជានឹងគ្នារវាងប្រទេសទាំងពីរក៏បណ្ដាលឲ្យមានការភ័យខ្លាចថា ប្រទេសវៀតណាមដែលអត់ទ្រាំពុំបាននឹងការទាក់ទាញមូលធន និងបច្ចេកវិជ្ជារបស់បស្ចិមប្រទេសមុខជាមិនបែរមករកសម្ពន្ធមិត្តសង្គមនិយមរបស់ខ្លួនវិញឡើយ[៣៧] ។*

*នៅចុងឆ្នាំ១៩៧៦ វៀតណាមបានបំបាត់ឥរិយាបថដែលធ្វើឲ្យពួកសូវៀតខកចិត្ត ដោយយកចិត្តទុកដាក់បញ្ចេញទស្សនវិស័យដ៏រុងរឿងរបស់លោកខាងលិចឲ្យឃើញវិញ ។ ការចរចាផ្សេងៗបានបន្តស្ដីពីយថាភាពនៃការផ្ដល់ជំនួយផ្នែកសេដ្ឋកិច្ចមួយរបស់ជប៉ុន ។ នៅទីក្រុងហាណូយ និងទីក្រុងប៉ារីស ការរៀបចំប្រុងប្រៀបផ្សេងៗនៃដំណើរទស្សនកិច្ចជាផ្លូវការរបស់ ផាំ វ៉ាន់ដុង ទៅកាន់ប្រទេសបារាំងកំពុងប្រព្រឹត្តទៅយ៉ាងមមាញឹក ។ នៅខែកក្កដា ឆ្នាំ១៩៧៦ ផាន់ ហៀន អនុរដ្ឋមន្ត្រីការបរទេសវៀតណាម បានធ្វើដំណើរប្រកបដោយផ្លែផ្កាមួយតាមបណ្ដាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីភាគអាគ្នេយ៍ ។ នៅខែតុលា សហរដ្ឋអាមេរិកបានស្នើចាប់ផ្ដើមធ្វើការប្រជុំដើម្បីចរចាជាមួយប្រទេសវៀតណាម ។ នៅទីបំផុត ជ័យជម្នះរបស់លោក ហ្ស៊ីមមី ខាធ័រ ក្នុងការជ្រើសរើសប្រធានាធិបតីបានបង្កើតឲ្យមានបរិយាកាសទុកចិត្តនិងសេចក្ដីសង្ឃឹមថ្មីមួយនៅទីក្រុងហាណូយ ។ គឺក្នុងបរិបទអនុគ្រោះនេះហើយ ដែលបណ្ដាលឲ្យ ផាំ វ៉ាន់ដុង ធ្វើផ្ដើនបំបាក់មុខឯកអគ្គរដ្ឋទូតសូវៀត ជាសាធារណៈក្នុងឱកាសនៃការធ្វើបដិសណ្ឋារកិច្ចក្នុងពិធីបុណ្យរំលឹកខួបបដិវត្តន៍ខែតុលានោះ ។*

## ស៊ូស្លូវ ចេញដំណើរ

*អធិករណ៍ជាមួយក្រុងមូស្គូបានប្រែទៅជារឹតតែជាក់ស្ដែងថែមទៀតនៅក្នុងឱកាសមហាសន្និបាតបក្សពលករវៀតណាមលើកទី៤ នាខែធ្នូ ឆ្នាំ១៩៧៦ ដែលត្រូវប្រសិទ្ធនាមថ្មីនៅពេលនោះថា បក្សកុម្មុយនីស្តវៀតណាម ។ ដប់ប្រាំមួយឆ្នាំបានកន្លងទៅតាំងពីមហាសន្និបាតចុងក្រោយ ។ ដោយរួមប្រជុំដើម្បីកំណត់ដោយច្បាស់លាស់នូវមាគ៌ានយោបាយជាផ្លូវការនៃប្រជាជាតិមួយ ដែលអំណឹះតទៅរួបរួមគ្នាតែមួយ មហាសន្និបាតនេះបានបង្ហាញជាថ្មីនូវរបត់ដ៏សំខាន់មួយក្នុងជីវភាពនយោបាយរបស់ប្រទេស និងបញ្ចេញឲ្យឃើញបុព្វហេតុនៃការចង់បានឯករាជ្យរបស់ខ្លួនយ៉ាងខ្លាំង ។ ទោះបីជាមានការកៀបសង្កត់របស់ក្រុងមូស្គូម្ដងហើយម្ដងទៀត*

ក៏ដោយ ក៏វៀតណាមបដិសេធមិនអញ្ជើញ“ក្រុមសិទ្ធសូវៀត”មួយគឺចលនាកុម្មុយនីស្តឥណ្ឌា ដែលពេលនោះកំពុងបែកបាក់គ្នាដែរ ។ ពួកគេពេញចិត្តអញ្ជើញក្រុមមិនចូលបក្សសម្ព័ន្ធ មួយក្រោមឈ្មោះថា បក្សកុម្មុយនីស្តឥណ្ឌា(ម៉ាក្សនិយម) ជាង ព្រោះក្រុមនេះរិះគន់ ទាំងក្រុងមូស្គូទាំងក្រុងប៉េកាំង ។ ពួកគេបានព្រមព្រៀងគ្នាអញ្ជើញបក្សកុម្មុយនីស្តចិនដែរ ប៉ុន្តែតាំងពីមានបដិវត្តន៍វប្បធម៌ ពួកចិនបានកំណត់ទុកដូចជាគោលការណ៍មិនទៅចូលរួមក្នុងមហាសន្និបាតបក្សកុម្មុយនីស្តបរទេសនានាឡើយ ។ វត្តមានរបស់ពួកសូវៀតពុំចោទជាបញ្ហាទេ ។ ប៉ុន្តែ គណៈប្រតិភូរបស់សូវៀតដែលដឹកនាំដោយលោក មីខាអ៊ីល ស៊ូស្លូវ អ្នកមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តសហភាពសូវៀតនឹងត្រូវអនុគ្រោះឲ្យអង្គុយនៅប៉ែកខាងមុខវេទិកា ។ ដូចគណៈប្រតិភូសូវៀតដែរ ពួកកុម្មុយនីស្តបារាំងនិងអ៊ីតាលីក៏ត្រូវផ្តល់សិទ្ធិពិសេសដោយឲ្យស្នាក់នៅភូមិគ្រឹះដាច់ដោយឡែកពីគេ ទោះបីជាក្រុងមូស្គូចោទថាជាការនិយមលទ្ធិកុម្មុយនីស្តអឺរ៉ុប ផ្ទុយពីលទ្ធិដែលគេនិយមទូទៅក៏ដោយ ។

បរិយាកាសទៅជាមានសភាពតានតឹងភ្លាម ។ ស៊ូស្លូវ បានសាកល្បងបញ្ចុះបញ្ចូល ឡេ យន់ ចំនួនបីដងឲ្យធ្វើសមាហរណ៍ប្រទេសវៀតណាមទៅក្នុងប្លុកសូវៀត ប៉ុន្តែឥតបានផល ។ ដោយប្រើការកៀបសង្កត់ជាសាធារណៈក្នុងសន្ទរកថាមួយដែលថ្លែងនៅចំពោះមុខមហាសន្និបាត ស៊ូស្លូវ បានស្នើឲ្យវៀតណាមចូលជាសមាជិកអង្គការកូម៉េកុងដោយមិនបញ្ចេញឈ្មោះចំឡើយ ។ គាត់អះអាងថា “វាមានលទ្ធភាពថ្មីៗជាច្រើន ដែលគួរពិចារណាក្នុងការធ្វើឲ្យសហប្រតិបត្តិផ្នែកសេដ្ឋកិច្ចរវាងបណ្តាប្រទេសសង្គមនិយមឲ្យរឹតតែស៊ីជម្រៅឡើង”[៣៣] ។ បណ្តាគណៈប្រតិភូអាល្លឺម៉ង់ខាងកើត ប៉ូឡូញ និង ឆេកូស្លូវ៉ាគី បានអះអាងត្រង់ៗតែម្តង ៖ “ក្នុងការបញ្ចប់ការកសាងលទ្ធិសង្គមនិយម ការចូលជាសមាជិកអង្គការកូម៉េកុង និងការធ្វើសម្ព័ន្ធភាពដែលមិនអាចសាបសូន្យជាមួយសហភាពសូវៀត គឺជាមធ្យោបាយដែលមិនអាចជំនួសបាន” ។

គេមិនបានសម្រេចឈានដល់ការសម្របសម្រួលណាមួយទេ ។ ដើម្បីបង្ហាញពីការអាក់អន់ចិត្តរបស់ខ្លួន ស៊ូស្លូវ បានបំព្រួញការស្នាក់នៅ ហើយវិលត្រឡប់ទៅក្រុងមូស្គូវិញតាមយន្តហោះផ្ទាល់ខ្លួនរបស់គាត់ មុនការបិទមហាសន្និបាតទៅទៀត ។ ក្នុងរយៈពេលប្រាំមួយខែបន្ទាប់មក ប្រទេសវៀតណាមបានទទួលរងភាពជូរចត់ពីកំហឹងរបស់សូវៀតចំពោះការសាកល្បងរបស់ខ្លួននេះ ។ ជំនួយដែលសន្យាផ្តល់ឲ្យនៅឆ្នាំ១៩៧៥ មានរយៈពេលយូរខុសប្លែកពីធម្មតា ទើបបានមកដល់ប្រទេសវៀតណាម ។ នេះជាភាពគាប់ជួនដ៏ចម្លែក ព្រោះនៅខែមេសា ឆ្នាំ១៩៧៧ ក្នុងពេលដែល ផាំ វ៉ាន់ដុង ត្រៀមខ្លួនចាប់ផ្តើមដំណើរលើកដំបូងរបស់គាត់ទៅកាន់អឺរ៉ុបខាងលិច ពួកសូវៀតបានបញ្ឈប់លែងប្រគល់មកឲ្យប្រទេសវៀតណាមនូវការផ្គត់ផ្គង់វត្ថុចាំបាច់ផ្សេងៗ ដែលប្រទេសជាតិត្រូវការជាខ្លាំង ។ ខស្សរាហកម្មធុនកណ្តាលរបស់ខ្លួន បានទទួលរងការខ្វះគ្រឿងផ្គត់ផ្គង់ពីរមុខមួយគឺប្រេងឥន្ធនៈ ដែលសហភាពសូវៀតជាអ្នកផ្តល់ឲ្យដ៏សំខាន់ ហើយពីរគឺ គ្រឿងបន្លាស់ផ្សេងៗ ។

អ្នកការទូតសូវៀតម្នាក់ ដែលបំពេញការងារនៅក្រុងហាណូយបាននិយាយចំអកឡកឡឺយដោយការ

សប្បាយរីករាយនៅមុខសមភាគីឥណ្ឌូម្នាក់ថា «វៀតណាមឆាប់អន់ចិត្តណាស់ចំពោះរឿងដែលគេកំពុងនិយាយអំពីឯករាជ្យរបស់ខ្លួន ប្រទេសនេះមុខជាចៀសមិនផុតពីបរាជ័យឡើយ ។ សេដ្ឋកិច្ចរបស់គេស្រុតចុះ ។ វាល្អណាស់ដែលនិយាយពីឯករាជ្យ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំនឹងធ្វើអ្វីមួយវិញវាប្រសើរជាង»[៣៤] ។ វិបត្តិសេដ្ឋកិច្ចមានសភាពរីតតែដុនដាបទៅៗ បញ្ហាផ្សេងៗខាងនយោបាយការបរទេសកើនឡើងកាន់តែច្រើនហើយពួកសូវៀតហាក់ដូចជាសម្រេចចិត្ត «ទុកប្រទេសវៀតណាមឲ្យស្ថិតនៅក្នុងស្ថានភាពពិបាក»តែម្នាក់ឯង ។

ក្នុងអំឡុងពេលធ្វើសង្គ្រាម អង្ករត្រូវបានផ្ដល់ឲ្យដោយប្រទេសចិនដោយមិនគិតលុយ (រហូតដល់២៥ម៉ឺនតោន) ដែលអនុញ្ញាតឲ្យវៀតណាមចៀសផុតពីការខ្វះស្បៀងអាហារ ។ ចំណែកវៀតណាមខាងត្បូងក៏ទទួលជំនួយអាមេរិកាំងរបៀបដូចគ្នាដែរ ។ ប្រទេសវៀតណាមដែលមិនចំណុះអ្នកណា ពុំទទួលបានការជួយជ្រោមជ្រែងដូច្នេះទេ ។ ប្រទេសចិនបានបញ្ឈប់ការផ្ដល់ជំនួយរបស់ខ្លួននៅឆ្នាំ១៩៧៥ ។ នៅពេលដែលវៀតណាមត្រឡប់បែរទៅរកក្រុងមូស្គូ សូវៀតបានអះអាងនឹងវៀតណាមថា «ជំនួយខាងស្បៀងអាហារ» នឹងងាយទទួលបានស្រួលជាងមុន បើសិនប្រទេសវៀតណាមចូលជាសមាជិកអង្គការកូមេ៉កុង ។

សន្តិសុខផ្ទាល់របស់ខ្លួនចាប់ផ្ដើមធ្វើឲ្យប្រទេសវៀតណាមព្រួយបារម្ភផងដែរ ចាប់តាំងពីដើមឆ្នាំ១៩៧៧ ។ ទំនាក់ទំនងផ្សេងៗជាមួយប្រទេសកម្ពុជាបានទទួលរងនូវការធ្លាក់ចុះមិនឈប់ឈរ ។ នៅខែកុម្ភៈ ហ័ង វ៉ាន់ឡូ អនុរដ្ឋមន្ត្រីការបរទេសបានធ្វើដំណើរជាសម្ងាត់មកកាន់ក្រុងភ្នំពេញ ដើម្បីស្នើធ្វើការប្រជុំកំពូលមួយរវាងប្រទេសឥណ្ឌូចិន ប៉ុន្តែឥតបានការ ។ នៅប្រទេសកម្ពុជា ការកម្ចាត់ជនជាតិភាគតិចវៀតណាម និងការសម្លាប់សមាសភាពជនទាំងឡាយដែលសង្ស័យថាមានសមានចិត្តនឹងក្រុងហាណូយបានចាប់ផ្ដើមនៅខែមេសា ដែលនេះជាសញ្ញាដំបូងនៃការវាយប្រហារដោយទ្រង់ទ្រាយធំរបស់ខ្មែរក្រហមនៅតាមព្រំដែនវៀតណាម ។ នៅប្រទេសឡាវ មានក្រុមប្រឆាំងកុម្មុយនីស្តជាច្រើនបានឃុបឃិតគ្នាប្រឆាំងនឹងរដ្ឋាភិបាលប៉ាថេតឡាវជាសម្ពន្ធមិត្តរបស់វៀតណាម នៅពេលដែលប្រទេសថៃនៅរក្សាទុកការរាំងខ្ទប់ផ្នែកសេដ្ឋកិច្ចមួយប្រឆាំងនឹងប្រទេសនេះដែលជាប្រទេសគ្មានផ្លូវចេញទៅសមុទ្រ ។ នៅនិទាឃរដូវឆ្នាំ១៩៧៧ សេចក្ដីសង្ឃឹមក្នុងការផ្សះផ្សាជាមួយប្រទេសចិនរឹតតែថយចុះថែមទៀត ។ នៅខែកុម្ភៈ ក្រុងប៉េកាំងបានឆ្លើយតបដោយការបដិសេធសំណើសុំជំនួយរបស់ក្រុងហាណូយ និងស្នើឲ្យពិភាក្សាឡើងវិញពីកម្រងកោះនានានៅសមុទ្រចិនខាងត្បូង ដោយអះអាងជាជាសាធារណៈពីការទាមទារទឹកដីរបស់ខ្លួននិងបដិសេធការចរចា ។ ការរវាំងប្រយ័ត្នបានបង្ខំឲ្យវៀតណាមត្រៀមខ្លួនទប់ទល់ដោយកម្លាំងយោធាជាស្រេច ។

បន្ទាប់ពីបរាជ័យរបស់ខ្លួន កងទ័ពរបស់ប្រធានាធិបតី ធីវ បានទុកជាមរតកឲ្យប្រទេសវៀតណាមនូវបរិមាណគ្រឿងសព្វាវុធអាមេរិកាំងដ៏សន្ធឹកសន្ធាប់ ។ ដោយគ្មានគ្រឿងបន្លាស់ និងដោយគ្មានបុគ្គលិកដែលមានសមត្ថភាពថែទាំ គ្រឿងអាវុធទាំងអស់នឹងខូចខាតលែងប្រើការបានយ៉ាងឆាប់រហ័ស ។ ដោយចិត្តស្មោះឬដោយ

ហេតុផល វៀតណាមគិតថា សហភាពសូវៀតជាប្រទេសតែមួយគត់ ដែលខ្លួនត្រូវបែរទៅរក ដើម្បីទទួលបានសម្ភារសឹកធុនធ្ងន់ និងការបណ្តុះបណ្តាលខាងកងទ័ព ។

ប្រឹងប្រែងកែលំអទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយបស្ចិមប្រទេសឲ្យបានប្រសើរជាងមុន គឺជារឿងមួយ ប៉ុន្តែ ប្រទេសវៀតណាមត្រូវតែទទួលស្គាល់ថា ខ្លួនលែងអាចបណ្តោយឲ្យទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយក្រុងមូស្គូធ្លាក់ចុះទៀតហើយ ។ តថភាពខាងភូមិសាស្ត្រ ភាពចាំបាច់ខាងសេដ្ឋកិច្ចនិងយោធា ដែលសំខាន់ស្មើអាយុជីវិត បានជំរុញទៅរកការផ្សះផ្សាជានាទីងគ្នាឡើងវិញ ។ ប៉ុន្តែ ក្រុងមូស្គូពុំមែនជាអ្នកចុះញ៉មនៅមុខគូសត្រូវ ហើយវៀតណាមក៏មិនមានបំណងនឹងអង្វរសូមទោសរុស្ស៊ីដែរ ។ ទោះជាយ៉ាងណា ការផ្តួចផ្តើមគំនិតក្នុងការផ្សះផ្សាដោយរបៀបឥតខ្មោះនិងពេញលេញនេះ បែរជាធ្លាក់មកលើ ដុង របៀបបញ្ឈឺទៅវិញដែលកាលពីប្រាំខែមុន គឺគាត់នេះឯងដែលបានធ្វើការបញ្ឈឺចិត្តឯកអគ្គរដ្ឋទូតសូវៀតជាសាធារណៈ ។

ពួកសូវៀតបានដាក់ការកៀបសង្កត់ ដើម្បីនឹងធ្វើឲ្យការស្នាក់អាស្រ័យរបស់ ដុង នៅប្រទេសបារាំងត្រូវកាត់បន្ថយមកត្រឹមបីថ្ងៃ ដែលតាមការគ្រោងទុកពីដំបូងគឺបីសប្តាហ៍[៣៥] ។ ដោយហេតុនេះ ដំបូងគាត់បានឈប់នៅក្រុងមូស្គូក្នុងរយៈពេលប្រាំថ្ងៃ ទើបបន្តដំណើរឆ្ពោះទៅកាន់ក្រុងប៉ារីស បន្ទាប់មក វិលត្រឡប់មកស្នាក់នៅសហភាពសូវៀតមួយខែទៀត ដែលនឹងលេចឡើងឲ្យឃើញរបត់ជាប្រវត្តិសាស្ត្រមួយនៃប្រទេសវៀតណាមសម័យថ្មី ។ ដូច្នេះ មុននឹងធ្វើដំណើរទៅកាន់ទីក្រុងប៉ារីស ដុង បានជួបជាមួយលោក អាឡិចស៊ី កុស្ស៊ីហ្គិន ដែលបានពិភាក្សាគ្នាពី «បញ្ហាផលប្រយោជន៍រួម» ។ ការទទួលបដិសណ្ឋារកិច្ចគឺមានលក្ខណៈខ្វះភាពកក់ក្តៅ ។ ឋានន្តរសក្តិមធ្យមនៃមន្ត្រីទាំងឡាយដែលជូនដំណើរ ដុង ទៅអាកាសយានដ្ឋានពេលគាត់ចេញដំណើរទៅក្រុងប៉ារីសនៅថ្ងៃទី២៥ ខែមេសា ជាសញ្ញាបង្ហាញឲ្យដឹងពីការមិនសប្បាយចិត្តរបស់សហភាពសូវៀតហើយ ។

## «នៅពេលគេផឹកទឹក គេមិនត្រូវភ្លេចប្រភពវា»

នៅដើមខែឧសភា ឆ្នាំ១៩៧៧ ដុង បានត្រឡប់មកសហភាពសូវៀតវិញ ។ ការស្នាក់អាស្រ័យដ៏យូររបស់គាត់នៅទីនោះ នៅតែរុំព័ទ្ធដោយអាថ៌កំបាំងជានិច្ច ។ នៅពេលដែលគាត់លេចមុខជាថ្មី នៅថ្ងៃទី៦ ខែមិថុនា ដើម្បីជួប ឡេអូនីត ប្រេសណេវ អ្វីៗដែលបិទបាំងមិនឲ្យឃើញ បានធ្វើឲ្យការសង្ស័យរលាយអស់ ។ ប្រទេសវៀតណាមនិងសហភាពសូវៀត ហាក់ដូចជាបង្ហាញឲ្យឃើញនូវការស្រុះស្រួលគ្នាជាថ្មី ។ គេបានដឹងពីស្ថានភាពទាំងឡាយ និងតម្លៃនៃការជានាទីងគ្នា តែនៅពេលដែលម្នាក់ៗធ្វើការបកស្រាយពីហេតុការណ៍ផ្សេងៗរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែ តាមព័ត៌មានបន្តិចបន្តួចដែលគេមានរួចមកហើយ វាច្បាស់ណាស់ថា ភាពកាន់តែធ្ងន់ធ្ងរនៃវិបត្តិសេដ្ឋកិច្ច និងបរាជ័យនៃនយោបាយសុំធ្វើការចរចារបស់ខ្លួននេះហើយ ដែលរុញប្រទេសវៀតណាមឲ្យធ្លាក់ទៅក្នុងដៃក្រុងមូស្គូនោះ[៣៦] ។

ដោយតាមដានតាំងពីក្រុងមូស្គូ ចំពោះការប្រព្រឹត្តទៅនៃការចរចាគ្នានៅក្រុងប៉ារីសស្តីពីការធ្វើឲ្យមានប្រក្រតីភាពរវាង ផាន់ ហៀន និង រីឆាដ ហូលប្រ៊ុក (ថ្ងៃទី៣ និង ទី៤ ខែឧសភា) ហើយទទួលបរាជ័យបានធ្វើឲ្យ ដុង ឆ្ងល់ស្រឡាំងកាំង ។ រដ្ឋាភិបាលលោក ខាធ័រ បានធ្វើឲ្យសេចក្តីសង្ឃឹមទាំងប៉ុន្មានរបស់វៀតណាមរលាយអស់ ។ នៅថ្ងៃទី៥ ខែឧសភា សភាជាន់ទាបរបស់អាមេរិកបានបោះឆ្នោតធ្វើវិសោធនកម្មច្បាប់ ដែលហាមឃាត់ការពិភាក្សាទាំងអស់ជាមួយប្រទេសវៀតណាម ដូចជា«ការសងការខូតខាតដោយសារសង្គ្រាម ជំនួយឬទម្រង់ខ្លះៗនៃវិភាគទានខាងហិរញ្ញវត្ថុទោះជាទម្រង់បែបណាក៏ដោយ» ។ ដំណឹងមិនល្អផ្សេងៗបានទៅដល់ក្រុងហាណូយយ៉ាងច្រើន ។ ក្នុងរាត្រីថ្ងៃទី៣០ ខែមេសា ខ្មែរក្រហមបានបើកធ្វើការវាយប្រហារយ៉ាងធំមួយប្រឆាំងនឹងភូមិនានារបស់វៀតណាមនៅជាប់ព្រំដែនកម្ពុជា ។ ឡេ ឌឹកថូ អ្នកឯកទេសនយោបាយការបរទេសដ៏ឆ្នើមនៃការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាមបានធ្វើដំណើរទៅទីក្រុងមូស្គូជាសម្ងាត់ ។ គាត់នឹងចូលរួមជាមួយ ដុង ក្នុងការពិភាក្សាដ៏សំខាន់សម្រាប់អនាគតនៃទំនាក់ទំនងរបស់ប្រទេសទាំងពីរ ។ អ្នកការទូតនៃបណ្តាប្រទេសអឺរ៉ុបខាងកើតដែលបំពេញមុខងារនៅក្រុងហាណូយ នៅទីបំផុតក៏ទម្លាយឲ្យដឹងព័ត៌មានផ្សេងៗស្តីពីទស្សនកិច្ចសម្ងាត់នេះរបស់ ថូ និងការសន្ទនាដ៏យូរនៅទីក្រុងមូស្គូដែរ ។ ប្រាំមួយឆ្នាំក្រោយមក មន្ត្រីជាន់ខ្ពស់សូវៀតម្នាក់បាននិយាយអាថ៌កំបាំងប្រាប់ខ្ញុំថា ៖ «ការជួបគ្នាដ៏ម៉ឺងម៉ាត់ជាហូរហែមួយ ពិតជាកើតមាននៅក្រុងមូស្គូ ក្នុងខែឧសភានិងមិថុនាមែន ហើយការជួបគ្នានេះ បានបើកឱកាសឲ្យមានការខិតចូលជិតគ្នាមួយ រវាងប្រទេសវៀតណាម និងសហភាពសូវៀត ។ ក៏ប៉ុន្តែ គាត់បដិសេធមិនសន្មតថា ការប្រែត្រឡប់របស់វៀតណាមនេះជាការទទួលដោយគំរោះគំរើយរបស់អាមេរិកាំងទេ ។ បើតាមគេនិយាយថា គឺប្រទេសចិន និងការគំរាមកំហែងរបស់កម្ពុជាទេ ដែលធ្វើឲ្យវៀតណាមសម្រេចចិត្តបែបនោះ ។ ត្បិតអីបញ្ហានេះនៅពុំទាន់ដោះស្រាយរួចរាល់ទេ ៖ តើជំហររបស់វៀតណាមចំពោះប្រទេសកម្ពុជានឹងមានបែបណា? ។ នៅពេលដែលខ្ញុំសួរគាត់ថា នៅពេលនោះបើមេដឹកនាំរបស់វៀតណាមស្នើឲ្យពួកសូវៀតពិនិត្យពីគំនិតនៃការធ្វើសន្ធិសញ្ញាជាមួយប្រទេសឡាវ គាត់បានផ្តល់ចម្លើយដែលមានបន្តប់អាថ៌កំបាំងនេះមកខ្ញុំវិញថា ៖ «វាពិតជាធម្មតាដែលប្រទេសវៀតណាមត្រូវពិគ្រោះជាមួយសហភាពសូវៀតស្តីពីបញ្ហាមួយដែលមានសារសំខាន់បែបនេះ» ។

ទោះជាខ្លឹមសារនៃការសន្ទនានៅក្រុងមូស្គូមានអ្វីខ្លះក៏ដោយ, ក៏ការខិតចូលជិតគ្នារវាងប្រទេសវៀតណាម និងប្លុកសូវៀត បានចេញជាលទ្ធផលច្បាស់លាស់បំផុត ។ នៅចុងខែឧសភា ប្រទេសវៀតណាម បានក្លាយទៅជាសមាជិករបស់ធនាគារអន្តរជាតិផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងធនាគារអន្តរជាតិផ្នែកវិនិយោគដែលឧបត្ថម្ភដោយសហភាពសូវៀត បន្ទាប់ពីខ្លួនបានចូលជាសមាជិកអង្គការកូម៉េកុងជាលើកដំបូង ។ នៅថ្ងៃទី៦ ខែមិថុនា គឺបួនថ្ងៃបន្ទាប់ពីបរាជ័យនៃការចរចារវាងអាមេរិក-វៀតណាមវគ្គទីពីរនៅទីក្រុងប៉ារីស ផាំ វ៉ាន់ដុង បានជួប ប្រេសណេវ តាមផ្លូវការ ។ តាមសារព័ត៌មានរបស់សូវៀតបានឲ្យដឹងថា ភាគីទាំងពីរបានកត់សម្គាល់

«ដោយការពេញចិត្តដែលនយោបាយអន្តរជាតិនិយមរបស់បក្សកុម្មុយនីស្តទាំងពីរ បានរួមវិភាគទានជួយពង្រឹងមិត្តភាពរវាងប្រទេសទាំងពីរឲ្យរឹតតែរឹងមាំឡើងថែមទៀត» ។ ចាប់ពីថ្ងៃនេះទៅក្រុងមូស្គូលែងនិយាយពីប្រទេសវៀតណាមជាមួយភាពច្រឡោតទៀតហើយ ដោយរំឭកពី«សារសំខាន់ស្មើអាយុជីវិតនៃសហប្រតិបត្តិការគ្រប់បែបយ៉ាងរវាងសហភាពសូវៀតនិងប្រទេសវៀតណាម»វិញ ។ ដូចជានិម្មិត បំពង់បង្ហូរប្រេងដែលរីងស្ងួតបានចាប់ផ្តើមហូរឡើងវិញ ។ នៅចុងខែមិថុនា គឺមួយខែបន្ទាប់ពីការសន្ទនាដំបូងៗ នៅទីក្រុងមូស្គូ ឡេថាញ់ងី បានធ្វើដំណើរទៅកាន់រដ្ឋធានីរបស់សូវៀតជាថ្មី ។ រុស្ស៊ីបានសន្យាផ្តល់ឲ្យគាត់ នូវ«ឥណទានសំខាន់ៗដែលផ្តល់នូវភាពងាយស្រួលដល់ការសងបំណុល»វិញ ដើម្បីផ្គត់ផ្គង់ហិរញ្ញវត្ថុចំពោះការដ្ឋានសែសិបកន្លែងដែលក្រុងមូស្គូយល់ព្រមស្ថាបនានៅប្រទេសវៀតណាម ។ ពួកសូវៀតបានប្រកាសឲ្យដឹងពីការសម្រេចចិត្ត «បង្កើនល្បឿនក្នុងការផ្តល់ទំនិញខស្សរាហកម្មរបស់ខ្លួន»ផងដែរ ។ ងី ដែលសប្បាយរីករាយខ្លាំងបានប្រកាសថា ការចរចានៅក្រុងមូស្គូ បានទទួលផ្លែផ្កាប្រកបដោយ«ជោគជ័យយ៉ាងធំធេងមួយ» ហើយថា កិច្ចព្រមព្រៀងដែលចុះហត្ថលេខាសម្រេច គឺជា«ភ័ស្តុតាងជាក់ស្តែងនៃសាមគ្គីភាព មិត្តភាពនិងសហប្រតិបត្តិការជាបងប្អូន» រវាងប្រទេសទាំងពីរ[៣៧] ។

គ្មានអ្វីមានភាពជានិមិត្តរូបដ៏គួរឲ្យចាប់អារម្មណ៍នៃការបែរត្រឡប់ជាយុទ្ធសាស្ត្ររបស់វៀតណាមប្រសើរជាងការអញ្ជើញកងទ័ពសូវៀតទៅទស្សនកិច្ចនៅភាគខាងត្បូងឡើយ ។ តាំងពីមួយឆ្នាំកន្លះមកហើយ វៀតណាមបានជំទាស់មិនព្រមទទួលការស្នើសុំបើកស្ថានកុងស៊ុលទាំងអស់របស់សូវៀតនិងចិន នៅទីក្រុងហូជីមិញ ។ ក៏ប៉ុន្តែនៅចុងខែកក្កដា គណៈប្រតិភូសូវៀតមួយដែលមានសមាជិកម្ភៃមួយនាក់ បានទៅដល់ទីក្រុងដាណាំងជាសម្ងាត់ ប្រហែលនេះជាផលនៃការសន្ទនាកាលពីខែឧសភា-មិថុនានៅក្រុងមូស្គូហើយមើលទៅ ។ ទោះយ៉ាងណាក៏ដោយ ក៏ការធ្វើដំណើរនេះត្រូវរុំព័ទ្ធដោយភាពអាថ៌កំបាំងបំផុត ។ យន្តហោះធុនអ៊ីលីយូឈីន៦២ ជាច្រើនគ្រឿងបានហោះទៅចុះចតនៅដាណាំងដោយផ្ទាល់ ដើម្បីចៀសពីក្រុងហាណូយ និងការសម្លឹងមើលរបៀបចង់ដឹងរឿងគេរបស់អ្នកការទូត ។ ប៉ុន្តែ ពួកសូវៀតមានចិត្តសប្បាយរីករាយយ៉ាងខ្លាំងចំពោះសេចក្តីព្យាយាមរបស់ខ្លួន ដែលដំណឹងនេះបានលេចព្ភុសុសសាយយ៉ាងឆាប់រហ័សក្នុងមជ្ឈដ្ឋានអ្នកការទូតនៅទីក្រុងហាណូយ ។ ទស្សនកិច្ចក្រៅផ្លូវការនេះបានកំណត់នូវការចាប់ផ្តើមទំនាក់ទំនងជាថ្មី ដែលពីរឆ្នាំក្រោយមកបាននាំទៅដល់ការធ្វើសម្ពន្ធភាពផ្នែកយោធាមួយទៅតាមផ្លូវច្បាប់ទៀត ។ គណៈប្រតិភូដែលក្នុងនោះមានតំណាងកងទ័ពទាំងបីប្រភេទ បានដើរពិនិត្យមើលនៅដាណាំង ឆកសមុទ្រកាំរាញ់ ញ៉ាត្រាង និងកន្លែងដែលមានផលប្រយោជន៍ខាងយុទ្ធសាស្ត្រជាច្រើនកន្លែងទៀតនៅភាគខាងត្បូង ។ គណៈប្រតិភូប្រហែលជាបានវាយតម្លៃពីសេចក្តីត្រូវការផ្នែកយោធារបស់ប្រទេសវៀតណាមសម្រាប់រយៈពេលដប់ឆ្នាំខាងមុខផងដែរ ។ ពួកសូវៀតបានចំណាយពេលវេលាក្នុងការស្រាវជ្រាវជាលើកដំបូងមួយនូវឧបករណ៍យោធារបស់អាមេរិកាំង ដែលរឹបអូសបានដោយ

វៀតណាមប្រហែលគ្រាន់តែដើម្បីវាយតម្លៃ ពីសក្តានុពលផ្នែកពាណិជ្ជកម្មរបស់អាវុធទាំងនោះប៉ុណ្ណោះ ។ ចាប់ពីខែតុលា ប្រទេសវៀតណាមបានចាប់ផ្តើមប្រគល់រថយន្តម៉ាកអាមេរិកាំងសម្រាប់ដឹកជញ្ជូនទ័ពជាច្រើនគ្រឿងទៅឲ្យប្រទេសអេត្យូពី ដែលជាម៉ូយអាវុធថ្មីរបស់ក្រុងមូស្គូ តាមការផ្តួចផ្តើមគំនិតរបស់ក្រុងហាណូយឬការសម្របសម្រួលជាមួយក្រុងមូស្គូ ។ បន្ទាប់ពីទស្សនកិច្ចរបស់គណៈប្រតិភូយោធាសូវៀត ក្រុងមូស្គូបានយល់ព្រមផ្តល់ឲ្យប្រទេសវៀតណាមនូវនាវាមុជទឹកធុនដំនំពីរគ្រឿង នាវាពិឃាតពីរគ្រឿង នាវាល្បាតជាច្រើនគ្រឿង និងយន្តហោះប្រដេញទម្លាក់គ្រាប់បែកមិច-២១បួនកង ។ ចំនួនទីប្រឹក្សាយោធារបស់សូវៀតនៅប្រទេសវៀតណាម ដែលកាត់បន្ថយគ្មានប្រែប្រួលតាំងពីឆ្នាំ១៩៧៦បានកើនឡើងជាថ្មី ក្នុងគោលបំណងបណ្តុះបណ្តាលវៀតណាមឲ្យចេះប្រើគ្រឿងសព្វាវុធនិងយន្តហោះទាំងឡាយដែលពួកគេទើបនឹងទទួល ។ នៅចុងឆ្នាំ១៩៧៨ គេដឹងថា ចំនួនទីប្រឹក្សាយោធាសូវៀតនៅប្រទេសវៀតណាមមាន៦០០នាក់ ។ ចំនួនទឹកប្រាក់នៃជំនួយយោធារបស់សូវៀតបានឡើងដល់៧៥លានដុល្លារ[៣៨] ។

មិនយូរប៉ុន្មាន ក្រុងហាណូយបានផ្តើមធ្វើយុទ្ធនាការស្វាបស្ទង់ចម្លើយក្នុងចំណោមប្រជាជនខ្លួន ម្យ៉ាងទៀតក៏ដូចក្នុងចំណោមសត្រូវរបស់ខ្លួនដែរ ស្តីពីអត្ថន័យនៃការពង្រឹងចំណងទាក់ទងមិត្តភាពរបស់ខ្លួនជាមួយក្រុងមូស្គូ ។ ពិធីបុណ្យខួបលើកទី៦០នៃបដិវត្តន៍បុលឆេវិច បានផ្តល់ឲ្យក្រុងហាណូយនូវឱកាសល្អឥតខ្ចោះ ក្នុងការផ្តើម «ខែមិត្តភាពមួយរវាងវៀតណាម-សូវៀត» ។ សារព័ត៌មាននិងទូរទស្សន៍បាននិយាយនិងថ្លែងសរសើរពីសហភាពសូវៀតនិងជំនួយដ៏សប្បុរសដែលប្រទេសនេះផ្តល់ឲ្យប្រទេសវៀតណាម ។ ក្នុងរយៈពេលតែមួយខែមុនពិធីបុណ្យខួប គណៈប្រតិភូរបស់សូវៀតប្រាំបីក្រុម -តាំងពីថ្នាក់ឧត្តមសេនីយ៍រហូតដល់សមិទ្ធិករភាពយន្ត- បានមកកាន់ប្រទេសវៀតណាមជាបន្តបន្ទាប់ ។ សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តសហភាពសូវៀតម្នាក់បានធ្វើសន្និសីទនៅទូទាំងប្រទេសស្តីពីប្រធានបទដ៏សំខាន់នៃបដិវត្តន៍ បុលឆេវិច ។ ដោយបោះបង់នូវការប្រុងប្រយ័ត្នដែលជាទម្លាប់របស់ខ្លួនចំពោះក្រុងប៉េកាំង ក្រុងហាណូយបានលាតត្រដាងឲ្យដឹងពីទស្សនកិច្ចនៃគណៈប្រតិភូយោធាសូវៀតដ៏ធំមួយដែលដឹកនាំដោយឧត្តមសេនីយ៍ យ៉េពីស្ហេវ ប្រធានការិយាល័យនយោបាយកងទ័ពនិងកងម៉ារីនសូវៀត ។ ប៉ុន្តែ ពួក វៀតណាមពុំនិយាយឲ្យដឹងទាំងអស់ទេ ៖ សមាជិកគណៈប្រតិភូបួនរូប-អ្នកជំនាញនៃកងទ័ពម៉ារីន-បានត្រូវអនុញ្ញាតឲ្យទៅពិនិត្យ ឆកសមុទ្រកាំរ៉ាញ់ និងកំពង់ផែញ៉ាត្រាង ក្នុងលក្ខណៈសម្ងាត់បំផុត ។ ពួកសូវៀតមានបំណងពិនិត្យមើល ទីតាំងនាវាចរនានាដែលបន្សល់ទុកដោយពួកអាមេរិកាំងឲ្យបានដិតដល់ ។ ពិតហើយវៀតណាមនៅមិនទាន់បណ្តោយឲ្យក្រុងមូស្គូប្រើប្រាស់ទីតាំងនាវាចរទាំងនេះទេ ប៉ុន្តែការដែលអនុញ្ញាតឲ្យមានទស្សនកិច្ចនេះ សឲ្យឃើញថា វៀតណាមបានពិចារណាពីអត្ថប្រយោជន៍ផ្សេងៗដែលពួកគេនឹងបានទទួលក្នុងការធ្វើទំនើបកម្មប្រទេសរបស់ខ្លួនដោយពួកសូវៀតស្រេចទៅហើយ ។

នៅនិទាឃរដូវឆ្នាំ១៩៧៧ សារព័ត៌មានរបស់វៀតណាមដែលពុំដែលនិយាយមួយម៉ាត់ពីគម្រោងជំនួយ

ផ្សេងៗរបស់សូវៀតសោះនោះ នៅពេលនេះបានគាំទ្រក្រុងមូស្គូដោយការកោតសរសើរជាច្រើន។ ឡេ យន់ បានថ្លែងឲ្យដឹងជាឧឡារិកថា “នៅពេលគេផឹកទឹក គេមិនត្រូវភ្លេចប្រភពទេ” ។ ប្រភពដែលគាត់ថ្លែងឲ្យដឹងនេះ គឺសហភាពសូវៀត ។ ក្នុងនាមនៃការគាំទ្រដ៏ធំធេងនិងមិនអាចវាយតម្លៃបាន គាត់បានសម្តែងឲ្យដឹងពី “មនោសញ្ចេតនាដឹងគុណដ៏ជ្រាលជ្រៅនិងពិតប្រាកដ”របស់គាត់ថែមទៀត ។ ដោយអនុលោមទៅតាមខែនៃការប្រារព្ធពិធីនេះ ឡេ យន់ អគ្គលេខាបក្សដែលអមដំណើរដោយ ទ្រឿង ជិញ មនុស្សទីពីរនិងជាអ្នកទ្រឹស្តីនៃការិយាល័យនយោបាយបានឡើងយន្តហោះឆ្ពោះទៅកាន់ក្រុងមូស្គូ ដើម្បីចូលរួមពិធីបុណ្យរំលឹកខួបអនុស្សាវរីយ៍បដិវត្តន៍ខែតុលា ។ មួយឆ្នាំបន្ទាប់ពីពិធីបដិសណ្ឋារកិច្ចដ៏ក្រៀមក្រំក្នុងចិត្តនៅសណ្ឋាគារថាំងឡ នាទីក្រុងហាណូយ ទំនាក់ទំនងផ្សេងៗរវាងសូវៀត-វៀតណាមបានវិលត្រឡប់រកចំណុចចេញដំណើរដោយពិតប្រាកដ ។ ពាក្យស្លោកមួយក្នុងចំណោមពាក្យស្លោកជាទីសំណព្វរបស់ ម៉ៅ សេទុង គឺ ៖ “ខ្យល់ខាងកើតមានប្រៀបលើខ្យល់ខាងលិច” ប៉ុន្តែ ក្រុងប៉េកាំងរកពុំឃើញមូលហេតុណាមួយឲ្យសប្បាយចិត្តទេ នៅពេលដែលទំនាយនេះលេចចេញរូបរាងឡើងពិតប្រាកដនៅប្រទេសវៀតណាមនោះ ។

# ជំពូកទី៧
# ភាពស្ងប់ស្ងាត់មុនខ្យល់ព្យុះ

នេះជាគ្រាចុងក្រោយបំផុតដែលខ្ញុំមានបំណងជួបនិយាយនឹងលោក សង់ដ័រ ហ្គីយ៉ូរី ជាអ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មាន M.T.I. របស់ហុងគ្រីនៅទីក្រុងហាណូយ ។ ប៉ុន្តែ ខ្ញុំធ្លាប់បានជួបបុរសហុងគ្រីរូបនេះដែលមានដំណើរប៉ុងពៀច និងស្កមកំព្រឹងម្តងរួចមកហើយ គឺនៅមុនការរំដោះទីក្រុងព្រៃនគរ ។ នៅពេលនោះ គាត់ជាអ្នកការទូត ជាសមាជិកម្នាក់នៃគណៈប្រតិភូហុងគ្រីប្រចាំគណៈកម្មការអន្តរជាតិខាងការឃ្លាំមើល និងការត្រួតពិនិត្យជាអង្គការចតុភាគីដែលបង្កើតឡើងដោយហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស ដើម្បីពិនិត្យមើលការអនុវត្តន៍បទឈប់បាញ់គ្នា ។ វត្តមានរបស់ ហ្គីយ៉ូរី និងអ្នកការទូតដទៃទៀតនៃប្លុកសូវៀតនៅកណ្តាលបេះដូងក្រុងព្រៃនគរដែលនៅពេលនោះត្រូវរុញច្រានផ្ទុះទាល់ច្រកក្នុងការប្រយុទ្ធស្លាប់រស់មួយទល់នឹងលទ្ធិកុម្មុយនីស្ត បានរួមបង្កជាភាពចម្លែកមួយក្នុងចំណោមភាពចម្លែកជាច្រើនរបស់សង្គ្រាម ដូចវត្តមានរបស់គណៈប្រតិភូវៀតណាមខាងជើងនិងវៀតកុងនៅក្នុងបរិវេណព័ទ្ធលួសបន្លានៃមូលដ្ឋានអាកាសចរតាន់សឺនញឹកជាដើម ។ គណៈប្រតិភូនេះ មានចំណែកមួយនៅក្នុងគណៈកម្មការយោធាចម្រុះដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងក្រុងប៉ារីសដែរ ។ ខុសប្លែកពីណៈប្រតិភូវៀតណាមកុម្មុយនីស្ត ដែលត្រូវបង្ខាំងក្នុងសំណង់បណ្តោះអាសន្ន ប្រក់ស័ង្កសី និងការពារដោយកងទ័ព សមាជិកទាំងឡាយនៃគណៈប្រតិភូហុងគ្រីនិងប៉ូឡូញត្រូវបានរៀបចំឲ្យស្នាក់នៅក្នុងភូមិគ្រឹះនានាដែលប្រកបដោយផាសុកបំផុត ។ ហ្គីយ៉ូរី ស្នាក់នៅសណ្ឋាគារ អាស្ទ័រ ស្ថិតនៅតាមផ្លូវទុយដូ ចំកណ្តាលទីក្រុងដែលជាសង្កាត់មួយមានភាពអ៊ូអរជាងគេនៃទីក្រុងព្រៃនគរ ។ គាត់បានធ្វើការទាក់ទងជាមួយអ្នកកាសែតខ្លះៗ ប៉ុន្តែ ក៏បានចងមិត្តភាពជាមួយបណ្តាសមាជិកនៃគណៈប្រតិភូវៀតណាមនៅតាន់សឺនញឹកផងដែរ ហើយពិសេសបំផុត ជាមួយវរសេនីយ៍ត្រី (សក្តិបួន) ភួង ណាំ ជាមនុស្សធាត់ដុះពោះនិងពាក់វ៉ែនតា ដែលទទួលបន្ទុកទំនាក់ទំនងជាមួយអ្នកកាសែត ។ ជាអ្នកមានដើមកំណើតនៅដែនដីសណ្តទន្លេមេគង្គ ណាំ ជាមនុស្សមានលក្ខណៈរួសរាយរាក់ទាក់និងចូលចិត្តលេងសើច ។

ប៉ុន្តែ នៅថ្ងៃដែលធ្វើឲ្យឈ្លក់ថប់ដង្ហើមនាខែកញ្ញា ឆ្នាំ១៩៧៧នេះ ណាំ មានលក្ខណៈតឹងចិត្ត និងប្រាស់ប្រាល់ ។ ការងាររបស់គាត់ពុំមានផ្លាស់ប្តូរទេ ។ គាត់នៅតែជាសមាជិកផ្នែកព័ត៌មានរបស់កងទ័ពដដែល ។ ប៉ុន្តែចាប់ពីថ្ងៃនេះទៅ នាយចៅហ្វាយរបស់គាត់គឺរដ្ឋាភិបាលដែលបង្រួមតែមួយនៃប្រទេសវៀតណាមនៅក្រុងហូជីមិញ ។ ក្នុងអំឡុងពេលសង្គ្រាម គាត់ធ្លាប់បានឆ្លងកាត់ការលំបាកជាច្រើនឆ្នាំនៅទីក្រុងហាណូយ និងរត់គេចខ្លួនក្នុងទីក្រុងនេះទាំងញាប់ញ័ររន្ធត់ ។ បន្ទាប់ពីចម្បាំងផុតរលត់គាត់បានសម្រេចចិត្តមករស់នៅក្រោមផ្ទៃមេឃសន្តោសប្រណីនៃក្រុងព្រៃនគរវិញ ។ ការទទួលបន្ទុកអ្នកកាសែតបរទេស គឺជាចំណែកមួយក្នុងមុខការរបស់គាត់

ហើយ ណាំ ត្រូវបានប្រគល់បេសកកម្មមើលថែការពារអ្នកឆ្លើយឆ្លងព័ត៌មានថ្មីសញ្ជាតិហុងគ្រី ដែលទើបឡើងយន្តហោះនៅទីក្រុងហាណូយកាលពីពេលថ្មីៗនេះថែមទៀត ។ នៅពេលជួបគ្នាដំបូងធ្វើឲ្យគាត់ពេញចិត្តរួមដូនដំណើរមិត្តចាស់និងរំឭកពីអនុស្សាវរីយ៍ល្អៗ នៅមុខដបប៊ីយែរតូចៗតែម្តង ។

នៅព្រឹកថ្ងៃទី២៦ ខែកញ្ញា កម្មវិធីបានផ្លាស់ប្តូរភ្លាមៗ ណាំ បានត្រូវកោះហៅដោយឧត្តមសេនីយ៍ ត្រាន់ វ៉ាន់ត្រា មេបញ្ជាការយោធភូមិភាគទី៧ដែលរួមមានក្រុងហូជីមិញ និងបណ្តាខេត្តភាគខាងលិចជាប់ព្រំប្រទល់នឹងប្រទេសកម្ពុជា ។ លោកឧត្តមសេនីយ៍ធ្លាប់ដឹកនាំធ្វើការវាយដណ្តើមកាន់កាប់ក្រុងព្រៃនគរដោយផ្ទាល់ កាលពីខែមេសា ឆ្នាំ១៩៧៥ គាត់ជាវីរបុរសនៅភាគខាងត្បូងដែលគេស្គាល់គ្រប់គ្នា ។ នៅព្រឹកនោះ គាត់ពិតជាមានកំហឹងយ៉ាងខ្លាំង ។ ពីរយប់មុន កងទ័ពខ្មែរក្រហមបានឡោមព័ទ្ធវាយប្រហារ ខេត្តតាយនិញ ដោយសម្លាប់ជនស៊ីវិលអស់ប្រមាណមួយរយនាក់ ។ នេះជាលើកទីពីរហើយដែលពួកខ្មែរក្រហមបើកការឆ្មក់វាយប្រហារដែលបណ្តាលឲ្យមនុស្សស្លាប់ច្រើននៅប្រទេសវៀតណាម ដោយជ្រើសរើសវាយឆ្មក់តែយប់ថ្ងៃសៅរ៍រៀងរាល់លើកចំពេលដែលអ្នកទទួលខុសត្រូវខាងយោធានៅតាមមូលដ្ឋានទាំងនោះត្រូវបានអនុញ្ញាតឲ្យសម្រាកពីការងារ ដើម្បីទៅសាកសួរសុខទុក្ខគ្រួសាររបស់ពួកគេនៅទីក្រុងហូជីមិញ ។ លើកនេះឧត្តមសេនីយ៍ ត្រា បានបញ្ជាឲ្យកងទ័ពម្នាក់ៗស្ថិតនៅតាមប៉ុស្តិ៍របស់ខ្លួននិងចាប់ផ្តើមឲ្យត្រៀមសម្ភារសឹកនិងភ័ស្តុភារជាស្រេច ដើម្បីទប់ទល់នឹងការឆ្មក់វាយប្រហារដោយមិនឲ្យដឹងខ្លួនមុនរបស់ខ្មែរក្រហម ។ គាត់បានទៅពិនិត្យមើលភូមិនានាដែលត្រូវខ្មែរក្រហមលុកលុយបំផ្លិចបំផ្លាញដោយខ្លួនឯង ហើយដែលធ្វើឲ្យគាត់ព្រឺរន្ធត់ចំពោះអំពើព្រៃផ្សៃដែលគាត់បានឃើញ ។ ពិភពលោកទាំងមូលនឹងត្រូវជូនដំណឹងឲ្យដឹងពីរឿងនេះ ។ លោកឧត្តមសេនីយ៍បានស្នើឲ្យ ណាំ អមការពារអ្នកកាសែតហុងគ្រីរូបនេះទៅកាន់ទីកន្លែងផ្សេងៗដែលមានការសម្លាប់ប្រហារឥតអាសូរ ។

នៅរសៀលថ្ងៃច័ន្ទនេះ ហ្គីយ៉ូរី បានធ្វើដំណើរទៅកាន់វិហារកាតូលិកមួយនៅបរិវេណខាងក្រៅទីក្រុង ដើម្បីធ្វើសម្ភាសបព្វជិតវៀតណាមដែលនិយមកែទម្រង់ម្នាក់ឈ្មោះ ចាន់ ទិន ជាអ្នកដែលគាត់ស្គាល់រាប់អានតាំងពីមុនការរំដោះម្ល៉េះ ។ ណាំ ដែលមានអាការៈស្រពាប់ស្រពោនបានដើរចូលទៅក្នុងភ្លាម ដោយកាត់ផ្តាច់ការធ្វើសម្ភាសន៍របស់គាត់ គាត់បានសុំអង្វរឲ្យ ហ្គីយ៉ូរី ត្រឡប់ទៅសណ្ឋាគារគាត់វិញ ។ ហ្គីយ៉ូរី នឹកឆ្ងល់តែម្នាក់ឯងថា តើសំណួរទាំងឡាយដែលគាត់ចោទសួរ ចាន់ ទិន មានលក្ខណៈរិះគន់ចំពោះរបបកុម្មុយនីស្តត្រង់ៗពេកទេដឹង? នៅពេលត្រឡប់មកដល់សណ្ឋាគារវិញ ណាំ ដែលលាក់សេចក្តីខ្វះមិនឲ្យដឹង គ្រាន់តែធ្វើការបញ្ជាក់យ៉ាងខ្លីថា ៖ "សូមលោករៀបចំអីវ៉ាន់សម្រាប់ដំណើរមួយដែលមានរយៈពេលពីរថ្ងៃ" ។

ទស្សនកិច្ចមិនដឹងខ្លួនមុននេះ ដែលគាត់បានដឹងនៅព្រឹកថ្ងៃបន្ទាប់ពេលគាត់ចេញដំណើរពីសណ្ឋាគារ គឺបាននាំគាត់ទៅដល់ភូមិមួយនៅខេត្តតាយនិញ ។ តាំងពីសាមសិបឆ្នាំមកហើយ ដែលគាត់ដើរតាមការបដិវត្តន៍ ភ្នែក ណាំ មានទម្លាប់នឹងទស្សនីយភាពមនុស្សស្លាប់និងឈុតឆាកសាហាវឃោរឃៅឡើងស៊ាំទៅហើយ ។ ចំណែក

ហ្គីយ៉ូរី ក៏ដូចគ្នាដែរ ក្នុងក្របខ័ណ្ឌនៃសកម្មភាពផ្សេងៗរបស់គាត់សម្រាប់គណៈកម្មការអន្តរជាតិខាងការឃ្លាំមើលនិងការត្រួតពិនិត្យ ។ ប៉ុន្តែ ម្នាក់ៗមានគំនិតចង់ឃើញនូវអ្វីដែលពួកគេនឹងត្រូវមើលនៅថ្ងៃនេះ ។ ក្នុងផ្ទះនីមួយៗ ពោរពេញទៅដោយសាកសពដែលកំពុងស្អុយរលួយរាយដេរដាសលើដី សាកសពបុរស-ស្ត្រី និងកូនក្មេងនៅលាយឡំគ្នា ខ្លះត្រូវកាត់ក្បាល ខ្លះទៀតត្រូវវះពោះ កាត់ដៃ-ជើង និងខ្វេះភ្នែក ។ មួយឆ្នាំក្រោយមកនៅពេលនឹកឃើញទស្សនីយភាពនេះ ណាំ នៅរកកលចង់ក្អួតនៅឡើយ ។ ដោយកាន់ម៉ាស៊ីនថតជាប់ដៃ ហ្គីយ៉ូរី បានថតពីគ្រប់ជ្រុងជ្រោយទាំងអស់យ៉ាងជក់ចិត្ត ។ ហ្វីលថតរបស់គាត់ ដែលទិញទុកបានត្រូវគាត់ប្រើស្ទើរតែអស់ ។ គាត់គិតថា រូបថតទាំងនេះនឹងធ្វើឲ្យពិភពលោកទាំងមូលរំជួលញាប់ញ័រក្នុងចិត្តមិនខាន ។ម្យ៉ាងទៀត គាត់បានទៅជាអ្នកកាសែតបរទេសដំបូងដែលបានជួបពួកអតីតកម្មាភិបាលខ្មែរក្រហម ដែលភៀសខ្លួនទៅប្រទេសវៀតណាម ។ ក្នុងរយៈពេលនៃការសន្ទនាភ្លាមៗ ឥតព្រាងទុកជាមុន ដែលគាត់បានធ្វើជាមួយខ្មែរក្រហមខ្លះក្នុងចំណោមនោះនៅតាមតំបន់ព្រំដែន គាត់បានសាកសួរយកព័ត៌មានពីការសម្លាប់មនុស្សទាំងហ្វូងៗដែលពេលនេះកំពុងកើតមាននៅប្រទេសកម្ពុជាផងដែរ ។ ក្រោយមកគាត់បានទទួលស្គាល់ថា "រហូតមកដល់ពេលនេះ ខ្ញុំញញើតញញើមក្នុងការទទួលស្គាល់ពីតថភាពនៃការបង្ហូរឈាម ពីព្រោះបញ្ហានេះជាបញ្ហាពិសិដ្ឋ(ប៉ះពាល់មិនបាន)របស់ក្រុងហាណូយ ។ ជាដូវការ ទំនាក់ទំនងផ្សេងៗរបស់ប្រទេសទាំងពីរមានលក្ខណៈស្រស់ស្រាយ និងប្រកបដោយភាតរភាព" ។ នៅពេលនេះ សហសេវិកវៀតណាមទាំងពួងរបស់គាត់បានតឿនឲ្យគាត់"ផ្តល់ព័ត៌មានប្រាប់សាធារណមតិពិភពលោកបានដឹងដោយឆាប់រហ័សបំផុត" ។

គាត់នៅពុំទាន់អស់ការងឿងឆ្ងល់របស់គាត់ទេ ។ ទើបតែត្រឡប់មកដល់សណ្ឋាគារវិញមិនទាន់ស្រួលបួលផង បន្ទាប់ពីការបំពេញការងារមួយថ្ងៃដ៏មមាញឹក-ធូលីដី កម្តៅថ្ងៃ និងជាប់ក្លិនស្អុយ-ស្រាប់តែមានអ្នកទទួលខុសត្រូវផ្នែកសន្តិសុខម្នាក់មករកជួបគាត់ ។ គេបានដកហូតហ្វីលថតរូបនិងកំណត់ហេតុខ្លីៗរបស់គាត់ដោយទទូច "សូម"កុំឲ្យគាត់និយាយប្រាប់មនុស្សណាម្នាក់ទៀតនូវអ្វីដែលគាត់បានឃើញ ទោះជាអ្នកកាសែតហុងគ្រីដូចគាត់ដែលកំពុងស្នាក់នៅក្នុងសណ្ឋាគារជាមួយគ្នាក៏ដោយ ។ ទូរស័ព្ទត្រូវកាត់ផ្តាច់ គាត់ប្រហែលជាត្រូវកំណត់ឲ្យនៅតែក្នុងសណ្ឋាគារយ៉ាងប្រាកដ ។ ពីរថ្ងៃក្រោយមក ហ្គីយ៉ូរី ដែលធ្វើឲ្យពិបាកចិត្តដោយសារការសាកល្បងនេះ បានធ្វើដំណើរតាមយន្តហោះត្រឡប់ទៅក្រុងហាណូយវិញ[១] ។

ភួង ណាំ បានទទួលការស្តីបន្ទោសយ៉ាងធ្ងន់ ។ អ្នកកាន់អំណាចពុំចូលចិត្តការធ្វើដំណើររបស់គាត់រួមជាមួយអ្នកកាសែតបរទេសម្នាក់ទេ ។ ដើម្បីធ្វើដំណើរទៅកាន់តំបន់"រសើប"មួយ ការអនុញ្ញាតរបស់ក្រសួងការបរទេសគឺជារឿងចាំបាច់ ។ តាមពិត ហ្គីយ៉ូរី និង ណាំ បានដឹងភ្លាមថាការិយាល័យនយោបាយពុំយល់ស្របតាមគំនិតផ្តួចផ្តើមរបស់ឧត្តមសេនីយ៍ ត្រា ទេ ហើយការិយាល័យនយោបាយបានសម្រេចធ្វើការត្រួតពិនិត្យព័ត៌មានទាំងអស់ដែលទាក់ទងនឹងការវាយប្រហាររបស់ខ្មែរក្រហម ។ ត្រា បានទទួលការបង្គាប់បញ្ជាឲ្យផ្អាកការប្រុងប្រៀប

រៀបចំធ្វើការវាយសងសឹករបស់គាត់ ។ សង្គ្រាមជាមួយប្រទេសកម្ពុជាគឺជាកិច្ចការមួយធ្ងន់ធ្ងរមែនទែន ព្រោះតែប្រគល់រឿងនេះទៅឲ្យកងទ័ពម្នាក់ដែលធ្វើអ្វីៗទៅតាមតែសន្ទុះចិត្ត ។ ម្យ៉ាងទៀតកម្ពុជា ពុំមែនជាប្រទេសមួយដែលចោទជាបញ្ហាទេ ។ ស្រមោលគំរាមកំហែងរបស់ប្រទេសចិន បានបង្ហាញទ្រង់ទ្រាយឡើងពីផ្នែកខាងក្រោយរបស់វៀតណាម ។ ដូច្នេះអ្វីៗដែលជាប់ពាក់ព័ន្ធទាំងអស់-យោធា សេដ្ឋកិច្ចនិងការទូត-ក្នុងជម្លោះដោយអាវុធជាយថាហេតុមួយជាមួយប្រទេសកម្ពុជាត្រូវតែថ្លឹងថ្លែងដោយហ្មត់ចត់ ។ ប៉ុន្មានសប្តាហ៍ក្រោយមក ត្រា បានត្រូវ"ដំឡើងសក្តិ"ជាអនុរដ្ឋមន្ត្រីការពារប្រទេស ជាមុខងារស្រណុកមួយដែលបង្ហាញពីអត្ថប្រយោជន៍ឲ្យគាត់នៅតែក្នុងការិយាល័យមួយ ។ អ្នកទទួលខុសត្រូវវៀតណាមម្នាក់បានបកស្រាយពីរឿងនេះជាឯកជនថា ៖ "នៅប្រទេសវៀតណាមគេមិនបញ្ចុះសក្តិនិងបំបាក់មុខអ្នកណាម្នាក់ទេ ។ បើសិនជាអ្នកមិនធ្វើការងារអ្វីអ្នកនោះនឹងត្រូវរុញទៅក្នុងឋានានុក្រមជាមួយនឹងប្រាក់បំណាច់ដូចស្តេច និងឋានៈខ្ពង់ខ្ពស់មួយ!" ។ ត្រា ពុំមានភ័ព្វសំណាងដូចនេះទេ ។ នៅឆ្នាំបន្ទាប់ គាត់ត្រូវបានគេដកហូតងារចេញដោយស្រួលតែម្តង ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ង្វៀន បានកោះហៅ ហ្គីយ៉ូរី ទៅក្រសួងការបរទេសដើម្បីប្រគល់ហ្វីលរូបថត កាសែតរ និងកំណត់ខ្លីៗរបស់គាត់មកឲ្យគាត់វិញ ។ នៅថ្ងៃដដែលនោះ ចាំបាច់ត្រូវអះអាងថា ខ្មែរក្រហមបានចាប់ផ្តើមបរិហារពី"ការឈ្លានពាន"របស់វៀតណាមដែរ ។ ជំនួសឲ្យការសុំទោស ង្វៀន បានប្រគល់ទៅឲ្យអ្នកកាសែតនូវប្រតិកម្មផ្លូវការលើកដំបូងរបស់ប្រទេសវៀតណាម ចំពោះព្រឹត្តិការណ៍ដែលកើតមានថ្មីៗនេះ ។ អំណឹះតទៅ ការសម្ងាប់រង្គាលនៅតាយនិញ គឺជានាទីរបស់ប្រវត្តិសាស្ត្រ ។ តាមការពិត ការវាយប្រហារដែលបន្តឡើងភ្លាមៗនៅមុនដំណើរជាផ្លូវការលើកដំបូងរបស់ ប៉ុល ពត ទៅប្រទេសចិន គឺគ្មានបំណងអ្វីក្រៅពីបង្ហាញឲ្យពួកចិនដឹងពីការប្តេជ្ញាដាច់ខាតប្រឆាំងវៀតណាមរបស់កងទ័ពកម្ពុជាឡើយ ។ ស្តេហ្វេន ហ៊ីឌ័រ បានធ្វើសម្ភាសកម្មាភិបាល និងកងទ័ពខ្មែរក្រហមមួយចំនួនធំ ច្រើនជាងអ្នកឯកទេសខាងបញ្ហាកម្ពុជាខ្លះទៀត ។ តាមមតិរបស់គាត់ថា ការវាយប្រហារនៅថ្ងៃទី២៤ ខែកញ្ញា ទៅលើខេត្តតាយនិញ ដែលបន្តឡើងដោយកងពលធំលេខ៣និងលេខ៤នៃភូមិភាគបូព៌ារបស់កម្ពុជា គឺជាសញ្ញាបង្ហាញឲ្យឃើញភាពនៅក្រោមឱវាទពីរយ៉ាង ។ ម្យ៉ាងគឺសកម្មភាពកើតចេញពីជំនឿមោះមុតដែលសម្តែងឡើងដោយពួកមេបញ្ជាការកងទ័ពក្នុងការប្រល័យជីវិតវៀតណាម ហើយនេះជាសក្ខីភាពមួយនៃស្មារតីភក្តីរបស់គេចំពោះ ប៉ុល ពត នៅពេលដែលការស្វែងរកអ្នកដែលមានសមានចិត្តនឹងវៀតណាម កំពុងតែមានសកម្មភាពពុះពោរយ៉ាងខ្លាំងក្នុងទូទាំងប្រទេសហើយ ម្យ៉ាងទៀត នេះជា"ជំនួន"មួយដែលពួកខ្មែរក្រហមបង្ខំឲ្យប្រទេសចិនធ្វើសកម្មភាពអ្វីមួយ[៧] ។

## សង្គ្រាមមួយដែលមិនចេញមុខ

នៅសរទរដូវឆ្នាំ១៩៧៧ រឿងរ៉ាវដ៏គួរឲ្យព្រឺខ្លាចបំផុតជាច្រើនបានចាប់ផ្តើមលេចឮសុសសាយនៅទីក្រុង

ហូជីមិញ (អតីតក្រុងព្រៃនគរ) ។ រឿងនិទានផ្សេងៗរបស់អ្នករស់រានមានជីវិតពីការសម្លាប់រង្គាល ដែលប្រព្រឹត្តឡើងនៅកម្ពុជាបានរាលដាលពីមាត់មួយទៅមាត់មួយ ។ ក្នុងពេលដំណាលគ្នានោះ អ្នកភៀសខ្លួនវៀតណាមឯទៀតៗបានរត់គេចខ្លួនរួចទៅដល់ប្រទេសម៉ាឡេស៊ីនិងថៃ ។ អ្នកទាំងនេះក៏បានរៀបរាប់ពីភាពសាហាវព្រៃផ្សៃក្នុងការវាយឆ្មក់របស់ខ្មែរក្រហមនៅតាមព្រំដែនដូចគ្នា ។ ប៉ុន្តែ ពិភពខាងក្រៅគ្មានបានដឹងពីរឿងនេះទាល់តែសោះ ។ ជាផ្លូវការគេគ្រាន់តែនិយាយបញ្ឆៀងៗពីឧបទ្ទវហេតុជាច្រើន ដែលមានលក្ខណៈធម្មតាៗប៉ុណ្ណោះ ។ ការត្រួតត្រារបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយ គឺដូចគ្នានឹងការហាមឃាត់ឲ្យនៅស្ងៀមស្ងាត់ដែលចាប់បង្ខំឲ្យពួកបរទេសគោរពតាមដូចករណីលោក សង់ដ័រ ហ្គីយ៉ូរី ដែលជាអ្នកគាំទ្រអ៊ីចឹង រហូតដល់ការប្រឌិតពីទំនាក់ទំនងជាធម្មតាររវាងប្រទេសទាំងពីរអាចត្រូវថែរក្សាឲ្យស្ថិតនៅក្នុងស្ថានភាពដដែលផង ។ ក្នុងអំឡុងពេលនោះការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាម បានរៀបចំធ្វើការសងសឹករបស់ខ្លួនវិញក្នុងសភាពស្ងប់ស្ងាត់បំផុត ។ បួនថ្ងៃក្រោយការវាយប្រហាររបស់ខ្មែរក្រហម វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយលិខិតសរសើរមួយជូន ប៉ុល ពត យ៉ាងសោះកក្រោះក្នុងឱកាសនៃការត្រឡប់មកគ្រប់គ្រងប្រទេសឡើងវិញប្រកប ដោយជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជា ។

វៀតណាមបានគិតគូរពីការវាយបកមកវិញក្នុងរយៈពេលជាច្រើនខែ ។ យ៉ាប បានធ្វើដំណើរទៅពិនិត្យសមរភូមិដោយខ្លួនឯងដើម្បីវាយតម្លៃស្ថានការណ៍នៅទីនោះ ។ នៅទីបំផុត ក្នុងខែតុលា ឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានចាប់ធ្វើប្រតិបត្តិការយោធាជាលើកដំបូងរបស់ខ្លួនដោយសម្ងាត់ ។ រថក្រោះមួយខ្សែបានជ្រៀតចូលជម្រៅ២៤គីឡូម៉ែត្រមកក្នុងទឹកដីកម្ពុជានៅខេត្តស្វាយរៀង បន្ទាប់មកធ្វើហាក់ដូចជាដកថយទៅវិញ ។ កងទ័ពថ្មើរជើងខ្មែរក្រហមមួយកងវរសេនាតូច បានដេញតាមហើយឆ្លងកាត់ព្រំដែនចូលទៅក្នុងទឹកដីវៀតណាម ។ ខ្សែទ័ពទីពីររបស់វៀតណាមនៅរង់ចាំពួកនេះរួចជាស្រេច ។ ដោយត្រូវវាយប្រហារក្នុងពេលដំណាលគ្នាពីមុខផង និងពីចំហៀងផង កងទ័ពរបស់កម្ពុជាបានត្រូវឡោមព័ទ្ធជាប់ក្នុងអន្ទាក់នេះ ។ កងទ័ពខ្មែរក្រហមជាងមួយរយនាក់បានត្រូវវៀតណាមចាប់ខ្លួន ។ ប៉ុន្តែការខាតបង់ក្នុងឱកាសនេះ ហាក់ដូចជាពុំបានបង្អន់នូវភាពពុះកញ្ជ្រោលរបស់ខ្មែរក្រហមដែលចូលចិត្តចម្បាំងឡើយ [៣] ។

គួរឲ្យឆ្ងល់ដែរ "សៀវភៅខ្មៅ" ដែលបោះពុម្ពផ្សាយដោយរបប ប៉ុល ពត នៅខែកញ្ញា ឆ្នាំ១៩៧៨ ពុំមានសរសេរបញ្ចូលការឈ្លានពាននេះក្នុងការរៀបរាប់ដ៏វែងគួរឲ្យធុញទ្រាន់នៃបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងវៀតណាមឡើយ ។ គេគោងតែសន្និដ្ឋានថា ការវាយបកផ្នែកយោធានេះពិតជាធ្វើឲ្យវៀតណាមរាវែកមែនទែន ។ ដោយរបៀបដូចគ្នា សៀវភៅខ្មៅក៏ពុំមាននិយាយឲ្យដឹងជាសាធារណៈពីការប៉ុនប៉ងធ្វើរដ្ឋប្រហារស្និទ្ធវៀតណាមសម្រាប់រយៈពេលពេញមួយឆ្នាំ១៩៧៧ដែរ ។ ប៉ុន្តែវៀតណាមធ្លាប់ត្រូវគេចោទប្រកាន់ថាជាប្រភពដើមនៃការប៉ុនប៉ងលួចសម្លាប់ ប៉ុល ពត ជាច្រើនលើកនៅចន្លោះឆ្នាំ១៩៧៥និង១៩៧៦ ។ នៅ

ដើមរដូវក្តៅឆ្នាំ១៩៧៧ ខ្មែរក្រហមគ្រាន់តែប្តឹងបរិហារពីការរៀបចំនូវ«ផែនការវាយលុកដ៏ធំធេង»មួយប៉ុណ្ណោះ[៤] ប៉ុន្តែពុំបានផ្តល់ភាពជាក់លាក់ផ្សេងៗទៀតក្រៅពីនេះឡើយ ។ តាមការពិត តាមការយល់ដឹងរបស់វៀតណាមថា លើកនេះការរៀបចំប្រុងប្រៀបធ្វើរដ្ឋប្រហារប្រាកដប្រជាដែលមិនដែលសាកល្បងប្រឆាំងនឹង ប៉ុល ពត បានចាប់ផ្តើមមាននៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ រដ្ឋប្រហារនេះមានរួមបញ្ចូលពួកកម្មាភិបាលខ្មែរក្រហមដែលបែកបាក់បក្សពួករបស់ភូមិភាគបូព៌ាផង ។ កន្លែងលាក់ទុកស្បៀងអាហារជាច្រើនត្រូវបានរៀបចំនៅក្នុងព្រៃជ្រៅក្នុងគោលបំណងធ្វើការបះបោរមួយដែលមិនទាន់ដល់ឱកាស[៥] ។

តើក្រុងហាណូយមានដើរតួនាទីណាមួយក្នុងការរៀបចំរដ្ឋប្រហារនេះទេ? តាមរបៀបគិតទៅម្យ៉ាងថា គេច្បាស់ជាឆ្លើយដោយភាពវិជ្ជមាន ប៉ុន្តែគ្មានអ្នកណាម្នាក់អាចបញ្ជាក់ពីរឿងនេះឲ្យបានពិតប្រាកដឡើយ ។ អ្នកវិភាគនៃក្រុមស៊ើបការណ៍សម្ងាត់ និងអ្នកឯកទេសបស្ចិមប្រទេសបានសាកសួរខ្មែរក្រហមរាប់រយនាក់ដែលនឹកស្តាយក្រោយនិងពួកកុម្មុយនីស្តវៀតណាមដែលរត់ចូលខាងសត្រូវផងដែរ ។ ពួកគេបានពិនិត្យមើលដោយហ្មត់ចត់នូវចម្លើយសារភាពដ៏ច្រើនសន្ធឹកសន្ធាប់របស់អ្នកទោសជាតិខ្មែរនៅទួលស្លែងជាឈ្មោះសាលាដ៏ល្បីនៅក្រុងភ្នំពេញដែលខ្មែរក្រហមប្រែក្លាយទៅជាគុកវិញ ប៉ុន្តែគ្មានបានផលអ្វីទាំងអស់ ។ បើសិនវៀតណាមបានសម្រេចជោគជ័យក្នុងការបំផ្លាញគម្រោងការពួកចារបុរសខ្មែរក្រហមពិតមែន បើសិនជាពួកគេពុះពារខុបសគ្គដែលកំពុងបង្ខាំងប្រទេសកម្ពុជាហើយចូលទាក់ទងជាមួយអ្នករួមគំនិតក្បត់នៅខាងក្នុងបាន ក៏បច្ចុប្បន្នស្នាដៃនេះនៅតែគ្មាននរណាដឹងនៅឡើយ ។ ផ្ទុយទៅវិញវាប្រាកដណាស់ថា ចាប់ពីឆ្នាំ១៩៧៧ ក្រុងហាណូយបានចាប់ផ្តើមបង្កើតមូលដ្ឋានសម្រាប់ចលនាប្រឆាំងនឹង ប៉ុល ពត នៅប្រទេសវៀតណាមផ្ទាល់ស្រេចទៅហើយ ។

ការសម្លាប់រង្គាលជាច្រើនលើកនៅតាយនិញ និងការគិតទុកជាមុនដែលពួកគេស្មានខុសបានរួមបង្កជារបត់មួយក្នុងទំនាក់ទំនងរវាងខ្មែរ-វៀតណាម ក៏ដូចក្នុងដំណើរជីវិតរបស់កម្មាភិបាលខ្មែរក្រហមជាច្រើននាក់ដែលឆ្លងចូលទៅប្រទេសវៀតណាមក្នុងឱកាសនោះ ដែលមាន ហ៊ុន សែន ម្នាក់នៅក្នុងចំណោមនោះដែរ ។ គាត់ជាមេបញ្ជាការកងវរសេនាធំមួយដែលបោះទីតាំងនៅតំបន់ចន្លោះព្រំដែនខេត្តក្រចេះ និងខេត្តកំពង់ចាម ។ នៅដើមឆ្នាំ១៩៧៧ គាត់បានទទួលបទបញ្ជាពីសេនាធិការកងទ័ពឲ្យរៀបចំកងឯកភាពរបស់ខ្លួន ដើម្បីវាយប្រហារចូលក្នុងខេត្តតាយនិញជម្រៅ១៥គីឡូម៉ែត្រ ។ ការវាយប្រហារតាមផ្លូវគោក ដែលគ្រោងទុកនៅថ្ងៃទី៣០ ខែឧសភា ត្រូវបានប្រគល់ភារកិច្ចឲ្យកងឯកភាពរបស់ភូមិភាគបូព៌ាជាច្រើនកង ដោយមានការទ្រទ្រង់ពីកងកាំភ្លើងធំរបស់កងពលធំលេខ៤ផង ។ ប៉ុន្តែ មេបញ្ជាការជាច្រើននាក់ដែលដឹកនាំបញ្ជាកងវរសេនាធំ និងកងវរសេនាតូចបានបដិសេធមិនធ្វើតាមបញ្ជានោះឡើយ ។ ពួកគេបានត្រូវចាប់ខ្លួននិងយកទៅសម្លាប់ចោលទាំងអស់ ។ ហ៊ុន សែន ជាមេទ័ពមានវ័យក្មេងជាងគេក្នុងចំណោមមេបញ្ជាការទ័ពរបស់ភូមិភាគមានការជឿជាក់ពិតប្រាកដចំពោះសេនាធិការដែលប្រគល់ភារៈឲ្យគាត់ដឹកនាំប្រតិបត្តិការទាំងនេះ ។ ការរៀបរាប់ដែលគាត់

អះអាងប្រាប់អ្នកកាសែត ស្តេហ្វេន ហ៊ីដ័រ នៅពេលក្រោយមកមិនមែនអត់ប្រយោជន៍នោះទេ "ខ្ញុំយល់ដឹងឆាប់រហ័សថា ខ្ញុំពុំអាចធ្វើអំពើមួយបែបនោះបានទេ ។ ដូច្នេះខ្ញុំពុំមានការជ្រើសរើសណាផ្សេងទៀតក្រៅពីរត់ចូលព្រៃជាមួយយុទ្ធជនមួយភាគរបស់ខ្ញុំឡើយ គឺនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧"[៦] ។ ក្រោយនោះបន្តិចគាត់បានឆ្លងកាត់ព្រំដែនទៅនៅប្រទេសវៀតណាម ។

នៅទីបំផុត ផែនការបានត្រូវសម្រេចអនុវត្តនៅថ្ងៃទី២៨ ខែកញ្ញា ។ "ជោគជ័យ"របស់ប្រតិបត្តិការនេះបាននាំទៅដល់ការតែងតាំងមេបញ្ជាការម្នាក់ឈ្មោះ ហេង សំរិន ឲ្យកាន់តំណែងដឹកនាំ ដែលនឹងក្លាយទៅជាសម្ព័ន្ធមិត្តដ៏សំខាន់របស់វៀតណាមនៅកម្ពុជា ។ មានមាឌល្អិត សម្បុរស្បែកស្រគាំ ក្នុងអាយុ៤៣ឆ្នាំ សំរិនបញ្ចេញឲ្យឃើញលក្ខណៈស្រគត់ស្រគំ ដែលគាត់កម្របោះបង់ចរិតបុកពានេះណាស់ ។ បងគាត់និងគាត់សុទ្ធតែជាសមាជិកនៃក្បាលម៉ាស៊ីនគណៈកម្មាធិការបក្សប្រចាំភូមិភាគបូព៌ា ។ តើគាត់មានមុខនាទីអ្វីទៅដែលបានចូលរួមដោយផ្ទាល់ក្នុងការឈ្លានពានដ៏ឃោរឃៅរបស់ខ្មែរក្រហមទៅលើប្រទេសវៀតណាមនោះ? គេមិនបានដឹងពីរឿងនោះទេ ។ ប៉ុន្តែគេដឹងថា គាត់ត្រូវបានជ្រើសតាំងភ្លាមៗជាប្រធាន"សមរភូមិផ្លូវជាតិលេខ៧" នៅព្រំដែនប្រទេសវៀតណាម ។ ដោយហេតុនេះ គាត់ក៏ក្លាយទៅជាមនុស្សទី២នៃឋានានុក្រមកងទ័ពប្រចាំភូមិភាគនោះ ។ "របស់អ្វីក៏ដោយសុទ្ធតែមានចំណែកអាក្រក់របស់វា" ។ ប៉ុន្មានខែក្រោយមក ការទទួលខុសត្រូវលើសមរភូមិនេះបានធ្វើឲ្យ ប៉ុល ពត ខឹងដាច់ក្បាលដាច់កន្ទុយ នៅពេលដែលកងទ័ពរបស់គាត់បង្ហាញឲ្យឃើញថាគ្មានសមត្ថភាពប្រយុទ្ធតទល់នឹងវៀតណាម ។ ដូច្នេះ ដើម្បីសង្គ្រោះជីវិតខ្លួនផង គាត់ត្រូវតែរត់ភៀសខ្លួនទៅប្រទេសវៀតណាម[៧] ។

បញ្ហារបស់កម្ពុជាបានក្លាយទៅជាចំណុចសំខាន់ក្នុងការជួបពិភាក្សាគ្នាជាសម្ងាត់នៅក្រុងមូស្គូ រវាងពួកមេដឹកនាំវៀតណាម និងបណ្តាសមភាគីសូវៀតរបស់ពួកគេក្នុងអំឡុងរដូវក្តៅឆ្នាំ១៩៧៧ ។ ពួកសូវៀតមានព័ត៌មានផ្សេងៗផ្ទាល់ខ្លួនរបស់ពួកគេស្តីពីឧបាយកលធ្វើវិទ្ធង្សនាផ្សេងៗរបស់វៀតណាម ៖ នៅខែ វិច្ឆិកា ឆ្នាំ១៩៧៧ អ្នកការទូតម្នាក់ដែលបំពេញមុខងារនៅក្រុងហាណូយបាននិយាយប្រាប់សហសេវិកឥណ្ឌាម្នាក់ឲ្យដឹងថា ចលនាតស៊ូទល់នឹងខ្មែរក្រហមកំពុងចាត់ចែងរៀបចំឲ្យមានដំណើរឡើងហើយ ។ ក្បាលម៉ាស៊ីនដឹកនាំចលនានេះគឺក្រុមមួយមានមនុស្សពីដប់នាក់ទៅដប់ប្រាំនាក់ហើយក្នុងចំណោមនោះ យ៉ាងហោចណាស់មានបីនាក់ជាអតីតសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិនដែលកាលពីមុនបង្កើតឡើងដោយវៀតណាម[៨] ។ អ្នកការទូតរូបនេះពុំបានបញ្ជាក់ថា ចលនាតស៊ូនេះធ្វើប្រតិបត្តិការមកខាងក្នុងប្រទេសកម្ពុជា ឬសកម្មភាពផ្សេងៗរបស់ខ្លួនកំណត់ត្រឹមតែក្នុងប្រទេសវៀតណាមឬក៏យ៉ាងណាទេ ។

នៅសរទរដូវឆ្នាំ១៩៧៧ ខ្មែរក្រហមដែលបោះបង់បក្សពួកមួយក្រុម ក្នុងចំណោមនោះមាន ហ៊ុន សែន, ប៉ែម សាមិន និង ប៊ូ ថង-ដែលអ្នកទាំងអស់នេះនឹងសម្តែងតួនាទីសំខាន់លើសលប់ជាងគេមួយក្នុងការប្រយុទ្ធ

ប្រឆាំងនឹង ប៉ុល ពត-បានរៀបចំចលនារបស់ខ្លួននៅប្រទេសវៀតណាម ។ រឿងរ៉ាវនៅ តាយនិញ នៅទីបំផុតបានធ្វើឲ្យវៀតណាមរំជួលចិត្ត ។ តាំងពីខែឧសភា ឆ្នាំ១៩៧៧ អ្នកទាំងនេះគ្រាន់តែវាយតបវិញទល់នឹងការទម្លាក់គ្រាប់បែកតាមផ្លូវអាកាស ឬការបាញ់គ្រាប់កាំភ្លើងធំផ្ទោងដាក់ខ្លះៗប៉ុណ្ណោះ ហើយដោយលាក់ការណ៍សម្ងាត់ទៀត ។ របៀបធ្វើសកម្មភាពផ្សេងៗទៀត មានលក្ខណៈជាភាពចាំបាច់មួយចាប់តាំងពីថ្ងៃនេះទៅ ។

ខ្មែរក្រហមដែលបោះបង់ចោលជួរ ពុំមែនជាភ្នាក់ងារបង្កហេតុទេ ។ វៀតណាមរារែកក្នុងចិត្តយ៉ាងយូរមុននឹងជឿលើអ្នកទាំងនោះ បន្ទាប់ពីការសួរចម្លើយនិងការសង្កេតពិនិត្យជាច្រើនខែ ។ វាមានភស្តុតាងថា អ្នកខ្លះក្នុងចំណោមខ្មែរក្រហមបោះបង់ចោលជួរទាំងនោះ ជាពិសេស ហ៊ុន សែន បានឲ្យដំណឹងដល់វៀតណាមជាមុនពីផែនការលំអិតនៃការវាយប្រហារទៅលើតាយនិញផងដែរ ដែលនេះជាសក្ខីភាពនៃសុឆន្ទៈរបស់គេ[៩] ។ ភ្លាមៗព័ត៌មានទាំងនោះប្រហែលជាពុំទាន់ធ្វើឲ្យវៀតណាមជឿប្រាកដប្រជាទេលើកលែងតែព័ត៌មាននោះមិនទាន់បានបញ្ជូនទៅឲ្យបញ្ជាការកងទ័ពរបស់ភូមិភាគ ។ ប៉ុន្តែ ក្នុងឱកាសនៃការចាប់ផ្តើមធ្វើសកម្មភាពវាយប្រហារ ពួកប្រជាជនស៊ីវិលវៀតណាមត្រូវបានទុកចោលទាំងស្រុងដោយគ្មានការការពារឡើយ ។ មិនយូរប៉ុន្មានក្រោយមកវៀតណាមបានត្រូវធ្វើឲ្យនឹកឃើញទៅរកជួបអ្នកបោះបង់បក្សពួកប្រាំបីនាក់ដែលរត់មកកាលពីពេលថ្មីៗ ដើម្បីពិភាក្សាពីអនាគតនយោបាយរបស់ប្រទេសកម្ពុជា[១០] ។

អ្នកភៀសខ្លួនកម្ពុជាមានបំណងតែម្យ៉ាងប៉ុណ្ណោះ គឺត្រឡប់ទៅកម្ពុជាវិញដើម្បីវាយប្រយុទ្ធ ។ ក្រុងហាណូយយល់ច្បាស់ប្រាកដថា នេះហើយជា"ភ័ព្វសំណាងបន្ថែមមួយ"ក្នុងអន្តរាគមន៍របស់ខ្លួនដែលអាចឲ្យសម្រេចលទ្ធផលច្រើនប្រការ ។ ក្នុងអតីតកាលថ្មីៗ វៀតណាមធ្លាប់ធ្វើអន្តរាគមន៍ពីរដងរួចមកហើយ ដើម្បីជួយផ្តួលរំលំរបបកាន់អំណាចមួយនៅក្រុងភ្នំពេញក្នុងអំឡុងទសវត្សរ៍៤០-៥០ ប្រឆាំងនឹងពួកបារាំង និងក្នុងអំឡុងឆ្នាំ១៩៧០ប្រឆាំងនឹង លន់ នល់ ។ ប៉ុន្តែមុននឹងសម្រេចចិត្តជាថ្មីម្តងទៀត វៀតណាមបានរៀបចំការសាកល្បងជាលើកចុងក្រោយមួយ ដើម្បីបំបែកប្រទេសចិនឲ្យឃ្លាតចេញពីប្រទេសកម្ពុជាសិន ។ សារលិខិតដែលពួកគេផ្ញើទៅឲ្យក្រុងប៉េកាំងលើកនេះគឺជាសេចក្តីអំពាវនាវមួយ និងជាការព្រមានរបៀបធ្វើពើមួយសម្រាប់ការពារផលវិបាកផ្សេងៗដែលកើតមានដោយសារការបន្តកិច្ចគាំទ្ររបស់ចិនចំពោះប្រទេសកម្ពុជា ។

## ឡេ យន់ ស្ទង់ចិត្តចិន

ការគាំទ្រនេះនឹងមានរហូតដល់ពេលណាទៅ? ពួកមេដឹកនាំវៀតណាមបានទទួលស្គាល់ដោយរីករាយថាពួកគេពុំទាន់អាចបញ្ចេញទស្សនៈជាស្ថាពរមួយបានទេមុនសរទរដូវឆ្នាំ១៩៧៧ ។ វ៉ាង ទុង បានធ្វើការសន្និដ្ឋានជាមុនស្រេចនូវភាពសោះអង្គើយនៃទំនាក់ទំនងរវាងចិន-កម្ពុជា បន្ទាប់ពីការដួលរលំនៃ"បនបួននាក់" ។ តាមយោបល់គាត់ថា ទ្រឹស្តីប្រតិបត្តិនិយមរបស់ តេង ស៊ាវពីង និងទ្រឹស្តីឆ្វេងជ្រុលហួសហេតុរបស់ខ្មែរក្រហម ពុំអាច

“ចុះសម្រុងគ្នា”បានឡើយ ។ ប្រាកដណាស់ តាំងពីមានការបដិសេធយ៉ាងដាក់លាក់ ដោយប្រទេសចិនក្នុងឆ្នាំ ១៩៧៧ចំពោះការស្នើសុំរបស់វៀតណាមដើម្បីបន្ថែមជំនួយសេដ្ឋកិច្ចឲ្យខ្លួននោះ បានធ្វើឲ្យគំនិតយល់ប្រឡំផ្សេងៗរសាត់បាត់អស់ ។ ក្រុងហាណូយយល់កាន់តែច្បាស់ជាលំដាប់ថា ខ្លួនត្រូវតែបោះបង់សេចក្តីសង្ឃឹមក្នុងការសម្របសម្រួលទំនាក់ទំនងផ្សេងៗរបស់ខ្លួនទាំងអស់ជាមួយក្រុងប៉េកាំង ។ ប៉ុន្តែនៅសល់ប្រទេសកម្ពុជាទៀត ។ បញ្ហាទាំងអស់គឺចង់ដឹងថា តើការចងគំនុំប្រឆាំងវៀតណាមរបស់ពួកចិន វាជារឿងដែលជំរុញឲ្យពួកគេឆ្លើយតបនឹងការបង្កហេតុរបស់ខ្មែរក្រហមឬមួយយ៉ាងណា ។ ចេញពីទស្សនៈនេះ ការទទួលយ៉ាងអឺកអធឹក ដែលក្រុងប៉េកាំងរៀបចំទទួល ប៉ុល ពត នៅសរទរដូវឆ្នាំ១៩៧៧ គឺជាប្រផ្នូលមិនល្អមួយ ។ លើសពីនេះទៀត ការរិះគន់ផ្សេងៗដែលស្ទើរតែគ្មានលាក់លៀមប្រឆាំងនឹងវៀតណាម ក៏បើកឱកាសឲ្យមេដឹកនាំខ្មែរក្រហមហ៊ានប្រព្រឹត្តអ្វីៗតាមអំពើចិត្តខ្លួនដែរ ។ នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ មុនការចេញដំណើររបស់ ប៉ុល ពត អ្នកចរចាដ៏ឆ្នើមជាងគេរបស់វៀតណាមឈ្មោះ ផាន់ ហៀន បានធ្វើដំណើរជាសម្ងាត់ទៅកាន់ក្រុងប៉េកាំង ដើម្បីស្នើឲ្យពួកមេដឹកនាំចិនជួយរៀបចំឲ្យមានការជួបគ្នាមួយរវាងគាត់ និងកម្ពុជា ។ តាមពិតនេះគឺជាល្បិចមួយសម្រាប់សាកល្បងរកឲ្យឃើញនូវជំហររបស់ចិន ក្នុងជម្លោះដែលកំពុងកើតមានរវាងប្រទេសទាំងពីរផង ។ ប្រទេសចិនបានទទួលយល់ព្រម ប៉ុន្តែ ការជួបគ្នាពីរលើករវាង ហៀន និងអ្នកតំណាងកម្ពុជានៅទីក្រុងប៉េកាំង បានប្រព្រឹត្តទៅមិនជាប្រសើរឡើយ ។ គេប្រជែងគ្នានិយាយតែពីភាពជូរចត់និងរឿងគ្មានខ្លឹមសារប៉ុណ្ណោះ ។ កម្ពុជាបានរិះគន់យ៉ាងខ្លាំងក្លានូវអំពើឈ្លានពាន ការធ្វើវិទ្ធង្សនា និងវិទ្ធង្សនាកម្មដែលប្រព្រឹត្តឡើងជាបន្តបន្ទាប់ដោយប្រទេសវៀតណាម ។ ច្បាស់ជាងនេះទៅទៀត កម្ពុជាបានចោទប្រកាន់ក្រុងហាណូយថាបានបញ្ចុះបញ្ចូលឲ្យមានរដ្ឋប្រហារមិនបានសម្រេចជាច្រើនលើកប្រឆាំងនឹងរបប ប៉ុល ពត ។ ជាការឆ្លើយតប ហៀន បានថ្កោលទោសចំពោះការចូលលុកលុយដ៏កំរោលព្រៃផ្សៃរបស់កម្ពុជាចូលក្នុងទឹកដីវៀតណាមដែរ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ បានស្នើឲ្យមានការបើកកិច្ចចរចាថែមទៀតដើម្បីកាត់បន្ថយភាពតានតឹងនៅតាមព្រំដែន ។ កម្ពុជាបានស៊កសម្តីវិញភ្លាមថា គ្មានការចរចាណាមួយអាចលើកយកមកពិនិត្យឡើយ ដរាបណាវៀតណាមពុំព្រមបោះបង់ឧបាយកល វិទ្ធង្សនា និងសកម្មភាពវិទ្ធង្សនាកម្មរបស់ខ្លួននោះ ។ សម្រាប់វៀតណាមនេះជាសំណើដែលពុំអាចទទួលយកបាន ព្រោះវាប្រៀបដូចជាទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួនមុនការចាប់ផ្តើមនៃការពិភាក្សាអ៊ីចឹង[១១] ។

ហៀន ដែលជាមនុស្សគួរឲ្យអាណិត ក៏ទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសចិនដែរ ។ នៅថ្ងៃទី៧ ខែតុលា មានការជួបពិភាក្សាគ្នាដ៏យូរជាលើកដំបូងមួយនៅទីក្រុងប៉េកាំង ក្នុងចំណោមការជួបទ្វេភាគីជាហូរហែមួយក្នុងគោលបំណងកំណត់ព្រំដែនគោក(សរុប១.២៧៥គីឡូម៉ែត្រ) និងព្រំដែនសមុទ្រ(ឈូងសមុទ្រតុងកឹង)ឲ្យហើយស្រេចជាស្ថាពររវាងប្រទេសទាំងពីរ ។ ការប្រជុំចរចាបានបន្តក្នុងរយៈពេលដប់ខែជាមួយនឹងការផ្អាកជាច្រើនលើករហូតទាល់តែចាប់ផ្តើមផ្ទុះឡើងនូវការប្រទូសរ៉ាយគ្នា ទើបការជួបសន្ទនាគ្នាត្រូវ

បញ្ឈប់ទាំងស្រុង[១៧] ។

នៅខែតុលា គឺមួយសប្តាហ៍ក្រោយការចេញដំណើររបស់ ហៀន ក្រុងហាណូយបានប្រកាសជាសាធារណៈពីវត្តមានរបស់គណៈប្រតិភូយោធាសូវៀតមួយក្រុមនៅលើទឹកដីរបស់ខ្លួន ។ នេះជាការព្រមានមួយដែលបង្កប់ទៅដោយអាថ៌កំបាំង ៖ ការបង្កើនកិច្ចគាំទ្រគ្រប់បែបយ៉ាងរបស់ចិនចំពោះកម្ពុជានឹងបណ្តាលឲ្យមានការពង្រឹងសហប្រតិបត្តិការសូវៀត-វៀតណាមកាន់តែខ្លាំងឡើងដែរ[១៣] ។

ប៉ុន្តែប្រទេសចិនបានធ្វើសកម្មភាពមុនរួចជាស្រេច ។ មុននេះបន្តិច ចិនបានសន្យាចូលរួមពង្រឹងសក្តានុពលកងទ័ពរបស់សម្ព័ន្ធមិត្តខ្មែរក្រហមរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់បំផុត ។ គេសាកល្បងដណ្តឹងសួរក្នុងចិត្តថា តើក្រុងប៉េកាំងមិនរៀបចំមិត្តភក្តិទាំងឡាយឲ្យមានស្ថានភាពអនុគ្រោះមួយ (គេនឹកគិតទៅដល់ ហ័ង វ៉ាន់ហាន ជាអ្នករត់ចោលបក្សពួកចូលខាងសត្រូវនៅថ្ងៃខាងមុខ) ដែលជាអ្នកធ្លាប់យកចិត្តទុកដាក់ផ្តល់ព័ត៌មានឲ្យដឹងពីការប្រែប្រួលដែលមិនបានគិតទុកជាមុននៃការខិតចូលជិតគ្នារវាងប្រទេសវៀតណាមនិងសហភាពសូវៀតទេឬ[១៤] ។

ទោះជាយ៉ាងណាក៏ដោយ ខណៈដែលមានហេតុការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្ររបស់ខ្លួន ប្រទេសចិនតែងតែបង្ហាញឲ្យឃើញរបៀបពិភាល់មួយជានិច្ចទាក់ទងទៅនឹងប្រទេសវៀតណាម ។ នៅថ្ងៃទី៥ ខែតុលា គឺពីរថ្ងៃបន្ទាប់ពីការមកដល់ក្រុងប៉េកាំងរបស់ ហៀន និងប្រាំថ្ងៃមុនការមកដល់ក្រុងហាណូយរបស់ យ៉េ ពីស្ទេវសេនានុពន្ធយោធាប្រចាំស្ថានទូតចិននៅក្រុងភ្នំពេញបានចុះហត្ថលេខាក្នុងនាមអគ្គសេនាធិការនៃក្រសួងការពារប្រទេសចិននូវពិធីសារមួយក្នុងការផ្គត់ផ្គង់គ្រឿងសព្វាវុធមកឲ្យកម្ពុជា ដែលជាការធ្វើឲ្យទៅជាពិតនូវកិច្ចព្រមព្រៀងជាបឋមក្នុងការផ្តល់ជំនួយយោធាឥតសំណង ដែលចុះហត្ថលេខាដោយភាគីទាំងពីរកាលពីខែកុម្ភៈ ឆ្នាំ១៩៧៦ ។ កិច្ចការទាំងអស់សុទ្ធតែត្រូវរុំព័ទ្ធទៅដោយលាក់ការណ៍សម្ងាត់បំផុត ។ សម្ភារជំនួយមានតាំងពីវិទ្យុផ្សាយនិងចាប់សំឡេងតូចៗរហូតដល់យន្តហោះប្រដេញ... ។ ពិធីសារនោះក៏មានគ្រោងនូវការផ្គត់ផ្គង់សម្ភារចាំបាច់គ្រប់បែបយ៉ាងក្នុងការបង្កើតកងទ័ពទាំងបីផ្នែករបស់កម្ពុជាផងដែរគឺសម្រាប់កងទ័ពជើងគោក ជើងទឹក និងជើងអាកាស[១៥] ។

ផ្ទុយទៅវិញ ប្រទេសចិនបានកាត់បន្ថយយ៉ាងសន្ធឹកសន្ធាប់ នូវចំនួននៃការទាក់ទងតាមផ្លូវអាកាសជាទៀងទាត់របស់ខ្លួន ជាមួយក្រុងហាណូយ ។ ការទាក់ទងតាមផ្លូវអាកាសរវាងក្រុងហាណូយនិងក្រុងកង់តុងដោយយន្តហោះទ្រីដង់ (Trident) នៃក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលចិនព្រមទាំងការទាក់ទងតាមផ្លូវរថភ្លើងរហូតដល់ក្រុងហុងកុង បានរួមបង្កជាផ្លូវចេញដ៏សំខាន់ទៅរកពិភពក្រៅសម្រាប់ជនបរទេសដែលរស់នៅក្នុងរដ្ឋធានីរបស់វៀតណាម ។ ជារឿយៗ កន្លែងអង្គុយទាំងអស់ត្រូវកក់ទុកមុនជាច្រើនសប្តាហ៍ ។ ប្រាកដណាស់ផលវិបាកផ្សេងៗខាងពាណិជ្ជកម្មដែលលេចចេញពីការសម្រេចចិត្តនេះ សម្រាប់ពួកចិនបានក្លាយជារឿងបន្ទាប់បន្សំទៅវិញ ។ អ្វីដែលត្រូវវាយតម្លៃគឺការសម្តែងឲ្យឃើញការមួហ្មងរបស់ខ្លួន ។ ក្រោមលេសដ៏មិនទំនងមួយ ក្រុមហ៊ុន

*អាកាសចរណ៍ចិនបានកាត់បន្ថយជើងហោះហើរពីពីរដងទៅមួយដងវិញ ក្នុងចំនួនជើងហោះហើរប្រចាំសប្ដាហ៍របស់ខ្លួន គិតចាប់តាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៧តទៅ ។*

*ម្ខាងបានបន្ថយល្បឿនទាក់ទងគ្នា ម្ខាងទៀតបែរជាបង្កើនល្បឿនទៅវិញ ។ នៅក្រុងភ្នំពេញ អ្នកបច្ចេកទេសចិនបានរៀបចំបង្កើតមជ្ឈមណ្ឌលទូរគមនាគមន៍មួយតាំងពីខែតុលា ឆ្នាំ១៩៧៧ម្ល៉េះ ។ ខ្សែទូរលេខដោយផ្ទាល់មួយនិងខ្សែទាក់ទងតាមវិទ្យុជាច្រើនខ្សែបានត្រូវបើកសម្ពោធយ៉ាងអធិកអធមនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ រហូតមកដល់ថ្ងៃខែនេះ ការទាក់ទងតាមវិទ្យុរបស់ស្ថានទូតចិនជាមួយក្រុងប៉េកាំង គឺជាខ្សែទាក់ទងតែមួយគត់របស់ក្រុងភ្នំពេញជាមួយពិភពខាងក្រៅ[១៦] ។*

*អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម ឡេ យន់ ដែលទើបតែត្រឡប់ពីទីក្រុងមូស្គូមិនទាន់ស្រួលបួលផងបានចេញដំណើរទៅកាន់ក្រុងប៉េកាំងទៀត ទៅតាមទម្លាប់ថ្លឹងឲ្យស្មើគ្នាខាងផ្នែកការទូតរបស់វៀតណាម ។ ប៉ុន្តែលើកនេះ គាត់ពុំមែនជាអ្នកធ្វើឲ្យជញ្ជីងស្មើគ្នាទេ ។ អ្នកការទូតវៀតណាមម្នាក់បានពន្យល់ប្រាប់ខ្ញុំថា "សមមិត្ត ឡេ យន់ បានទៅរករឿងសត្រូវដល់សំបុករបស់វាតែម្ដង តាមគំរូវីរបុរស លី ធឿងគៀត* (Ly Thuong Kiet) *របស់យើង" ។ វីរបុរសដែលគាត់និយាយនេះ គឺព្រះមហាក្សត្រមួយអង្គរបស់វៀតណាមនៅសតវត្សរ៍ទី១១ ដែលដឹកនាំប្រកបដោយជោគជ័យនូវការធ្វើសង្គ្រាមការពារជាមុនមួយនៅលើទឹកដីរបស់ចិន ដើម្បីយកប្រៀបលើការលុកលុយមួយដែលហាក់ដូចជាចៀសមិនផុត ។*

*ក្នុងឱកាសនៃការជួបសន្ទនាគ្នា មេដឹកនាំវៀតណាមបានចាប់ផ្ដើមនិយាយបញ្ចើចបញ្ចើពីមោទនភាពជាតិរបស់ចិន ។ គាត់បានថ្លែងដោយលក្ខណៈរម្យទមគួរឲ្យឆ្ងល់ចំពោះប្រធានបក្សកុម្មុយនីស្តចិន ហ៊្វា គួហ្វេង ថា "យើងជាប្អូនពៅរបស់សមមិត្ត យើងស្ថិតនៅប៉ែកខាងសមមិត្តជានិច្ច ហើយយើងនឹងមិនផ្លាស់ប្ដូរជំហរសោះឡើយ ទោះជាមានអ្វីកើតឡើងក៏ដោយ"[១៧] ។*

*ប៉ុន្តែ ឡេយន់ បានធ្វើឲ្យកត់សម្គាល់ថា បើទុកជាមានអធិករណ៍ជាមួយប្រទេសចិនស្ដីពីបញ្ហាជាយុទ្ធសាស្ត្រសំខាន់ៗក៏ដោយ ក៏ប្រទេសវៀតណាមចៀសវាងគ្រប់ការរិះគន់ជាសាធារណៈដែរ គឺខុសប្លែកពីពួកសូវៀត ជាឧទាហរណ៍ ហើយគាត់ងឿងឆ្ងល់ថា ពួកចិនហាក់ដូចជាមិនដឹងគុណគាត់ពីរឿងនេះសោះ ។ អ្វីដែលមិនស្មោះត្រង់នឹងគ្នា គាត់មិនភ្លេចរំឭកថា ការគាំទ្រដល់ការកសាងលទ្ធិសង្គមនិយមនៅប្រទេសវៀតណាម គឺជាកាតព្វកិច្ចអន្តរជាតិមួយក្នុងចំណោម "កាតព្វកិច្ចអន្តរជាតិជាច្រើន" របស់ប្រទេសចិនក្នុងនាមនៃសពនាយករដ្ឋមន្ត្រី ជូ អេនឡាយ ។ បន្ទាប់ពីបានសម្ដែងការសោកស្ដាយចំពោះមរណភាពរបស់ ម៉ៅ សេទុង, ជូ អេនឡាយ និង ជូតិ រួចមក យន់ បានឆ្លៀតឱកាសនេះដើម្បីជម្រាបជូននូវការត្រិះរិះពិចារណារបស់គាត់អំពីនយោបាយក្នុងប្រទេសរបស់ចិន ដែលជាប្រការធ្វើឲ្យប៉ះពាល់សើៗដល់ការខ្វះសេចក្ដីគួរសមយ៉ាងជាក់ច្បាស់ ។ គេគ្មានសង្ស័យឡើយថា ពួកមេដឹកនាំថ្មីរបស់ចិន"នឹងមិនអនុញ្ញាតឲ្យវណ្ណៈកេងប្រវ័ញ្ចមួយចំនួនតូចងើបក្បាលឡើងវិញបានទេ ទោះជា*

មានអ្វីកើតឡើងក៏ដោយ ហើយពួកគេនឹងរវាំងប្រយ័ត្នដើម្បីធ្វើឲ្យប្រទេសចិនថ្មីនៅតែ(ក្រហម) ជានិច្ច»[១៨] ។

ឡេ យន់ បានទទួលបរាជ័យ ។ គាត់ពុំអាចបញ្ចុះបញ្ចូលឲ្យពួកចិនបន្ថយការគាំទ្ររបស់គេចំពោះពួកខ្មែរក្រហមបានឡើយ ។ ផ្ទុយទៅវិញ ក្រុងប៉េកាំងបានចោទប្រកាន់ប្រទេសវៀតណាមថាបានធ្វើទុក្ខបុកម្នេញប្រទេសជិតខាងខ្លួនដែលទន់ខ្សោយ ហើយប៉ុនប៉ងដាក់នឹមត្រួតត្រាលើប្រទេសនោះដោយជ្រកក្រោមផ្លាកបង្កើត“ទំនាក់ទំនងពិសេស”ទាំងបង្ខំរវាងប្រទេសទាំងពីរថែមទៀត ។ ពេលនោះ ហ្វា ហៀបនឹងបញ្ជាក់អះអាងនូវការគាំទ្ររបស់ប្រទេសចិនចំពោះកម្ពុជាជាសាធារណៈប្រឆាំងនឹងវៀតណាមទៅហើយ ។ ដោយថ្លែងក្នុងពិធីជប់លៀងមួយដែលរៀបចំជាកិត្តិយសចំពោះ ឡេ យន់, ហ្វា បានគូសបញ្ជាក់ថា ប្រទេសរបស់គាត់បានតាំងចិត្ត “ចងសម្ព័ន្ធភាពជាមួយប្រទេសទាំងអស់ដែលរងគ្រោះពីការឈ្លានពានរបស់ពួកចក្រពត្តិ និងពួកសង្គម-ចក្រពត្តិ (social-imperialiste) និងជាមួយប្រទេសទាំងអស់ដែលស្ថិតនៅក្រោមការធ្វើវិទ្ធង្សនា ការជ្រៀតជ្រែក ការគ្របសង្កត់ និងការរំលោភជិះជាន់របស់បរទេស” ។ ប្រទេសចិនចូលរួមជួយសម្រួលដល់“ការបង្កើតរណសិរ្សទូលំទូលាយមួយប្រឆាំងនឹងអនុត្តរភាពនិយមនៃមហាអំណាចធំៗ” ផងដែរ ។

ការរករឿងរបស់ចិនមានលក្ខណៈច្បាស់លាស់ណាស់ ។ ឡេ យន់ បានឆ្លើយតបនឹងរឿងនេះដោយប្រកាសជាសាធារណៈថា ប្រទេសវៀតណាមនឹងមិនអនុញ្ញាតឲ្យ “មហាអំណាចចក្រពត្តិឬប្រតិកិរិយាណាមួយទោះជាមហាអំណាចណាក៏ដោយ កៀបសង្កត់ឯករាជ្យភាពនិងសេរីភាពរបស់វៀតណាមឡើយ”[១៩] ។ “អនុត្តរភាពនិយម” “មហាអំណាចប្រតិកិរិយា” សុទ្ធតែជាការនិយាយជៀមជាមទៅវិញទៅមកដែលគេអាចមើលធ្លុះដល់គ្រឿងក្នុង ។

ក្នុងការជួបសន្ទនាគ្នាមុនៗ ពួកមេដឹកនាំវៀតណាមធ្លាប់មានឱកាសប្រានចោលដោយសេចក្ដីគួរសមនូវការស្នើសុំឲ្យខ្លួនចូលរួមជាមួយប្រទេសចិនក្នុងសម្ព័ន្ធភាពប្រឆាំងសូវៀតមួយ ។ ពួកមេដឹកនាំវៀតណាមតែងតែយកចិត្តទុកដាក់ថ្លែងអំណរគុណព្រមគ្នាចំពោះប្រទេសចិន និង“បណ្ដាប្រទេសសង្គមនិយមជាបងប្អូន”ផ្សេងទៀត (ហៅម្យ៉ាងទៀតគឺប្លុកសូវៀតដែលច្រើនតែជាបណ្ដាប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើត បច្ចុប្បន្នត្រូវរលំរលាយអស់ហើយ) ចំពោះជំនួយដែលប្រទេសទាំងអស់នោះផ្ដល់ឲ្យប្រទេសខ្លួន»[២០] ជានិច្ច ។ ប៉ុន្ដែលើកនេះ ឡេ យន់ បានធ្វើរឿងមួយជ្រុលហួសហេតុបន្តិច ។ គាត់បានថ្លែងសរសើរសូវៀតដោយចេញឈ្មោះជាចំហធ្វើឲ្យពួកម្ចាស់ផ្ទះអាក់អន់ស្រពន់ចិត្តខ្លាំងមែនទែន ។ តាំងពីយូរយារណាស់មកហើយ ភាពគួរសមតែសំបកក្រៅដែលបិទបាំងការពិតនៃភាពតានតឹងរវាងចិន-វៀតណាម នៅពេលនេះបានប្រេះឆ្លាយប្រកបដោយគ្រោះថ្នាក់បំផុត ។ ធាតុផ្សំផ្សេងៗនៃជម្លោះដែលនឹងមកដល់នាពេលខាងមុខ បានស្ថិតនៅតាមទីកន្លែងរបស់វាចាប់ពេលនេះទៅហើយ ។

ការសន្យារបស់ពួកចិនក្នុងការគាំទ្រប្រទេសកម្ពុជាគឺមាននៅក្នុងការសន្ទនាដ៏ពុះកញ្ជ្រោលជាមួយ ឡេ យន់

*ដែលមានមកក្រោយៗទៀត ។ ក្នុងការស្រាវជ្រាវជាសម្ងាត់មួយអំពីនយោបាយឥណ្ឌូចិនរបស់ប្រទេសចិន ចេង ពាវ អគ្គលេខាគណៈកម្មាធិការយោធារបស់បក្សកុម្មុយនីស្តចិនបានសម្គាល់ថា ៖ ចាប់ពី ខែវិច្ឆិកា ឆ្នាំ ១៩៧៧ «ការខ្វែងគំនិតគ្នារវាងប្រទេសវៀតណាមនិងកម្ពុជាបានក្លាយទៅជារឿងធំ ទាល់តែលែងតម្រូវឲ្យយើងបិទបាំងរឿងនេះយូរតទៅទៀត ។ កិច្ចប្រឹងប្រែងទាំងប៉ុន្មានរបស់យើងតាំងពីការរំដោះប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ ដើម្បីរារាំងកុំឲ្យបដិបក្ខភាពនេះផ្ទុះឡើង នៅទីបំផុត ឃើញថាគ្មានបានប្រយោជន៍អ្វីទាំងអស់ ។ សម្រាប់មូលហេតុនេះហើយបានជានៅខែធ្នូ គណៈកម្មាធិការមជ្ឈិមបក្សបានសម្រេចចិត្តមូលមតិគ្នា ផ្តល់នូវការគាំទ្រពេញទំហឹងចំពោះកម្ពុជានិងអនុញ្ញាតឲ្យកម្ពុជាពង្រឹងខ្លួនឡើងថែមទៀត ដើម្បីប្រឈមមុខទល់នឹងស្ថានការណ៍ថ្មី ដែលទំនងជាចេញមកអំពីបរាជ័យនៃការចរចាគ្នាហើយមើលទៅ»[២១] ។*

*ហួសអំពីសមានចិត្តដែលខ្លួនរងទទួលដើម្បីប្រទេសកម្ពុជា ហើយដោយមិនបដិសេធពីប្រយោជន៍របស់ខ្លួនក្នុងនាទីជាឧបករណ៍របស់ក្រុមអ្នកតស៊ូទល់នឹងអនុត្តរភាពរបស់វៀតណាម ក្រុមមេដឹកនាំចិនចូលចិត្តធ្វើការចរចាក្នុងរយៈពេលយូរជាជាងការប្រឈមមុខដាក់គ្នា ។ ពិតហើយ វាមានភស្តុតាងជាច្រើនដែលបញ្ជាក់ថា ដូចជាការលើកទឹកចិត្តជួយដោយគ្មានគិតចំពោះ ប៉ុល ពត នៅឆ្នាំ១៩៧៧ជាដើម ដែលប្រហែលចាំបាច់ធ្វើឲ្យគេបកស្រាយបែបជាការឆ្លុះបញ្ចាំងឲ្យឃើញពីការតស៊ូដណ្តើមឥទ្ធិពលគ្នា ដែលបន្តអន្ទ្រនបក្សកុម្មុយនីស្តចិននៅជំនាន់នោះ ។ ជ្បិតអី តាមពីក្រោយ តេង ស៊ាវពីង ពួកមេដឹកនាំខាងខ្មែរប្រតិបត្តិនិយមបានវាយតម្លៃពួកខ្មែរក្រហមថាជា Procuste ថ្មី [ក្នុងរឿងព្រេងនិទានក្រិច Procuste គឺមេចោរប្លន់នៅ Attique ដែលត្រូវសម្លាប់ដោយ Thésée (ស្តេចប្រទេសក្រិច) ។ វាចូលចិត្តចងសន្ធឹងពួកជនរងគ្រោះនៅលើគ្រែមួយ ។ បើសិនជាជនរងគ្រោះមានមាឌធំពេក វាធ្វើឲ្យខ្លីដោយកាត់ជើងទាំងពីរចេញ បើមាឌតូចពេកវាចាប់ហែកតែម្តង-កំណត់របស់អ្នកបកប្រែ] ហើយមេដឹកនាំទាំងនោះរារែកដើម្បីគាំទ្រ ការបង្កហេតុប្រឆាំងវៀតណាមរបស់ពួកគេយូរតទៅទៀត[២២] ។*

## ការគាំទ្រមួយដែលមិនសូវមុឺងម៉ាត់

*តើគេឆ្ងល់យ៉ាងណាទៅ កាលបើមនុស្សដែលត្រូវចាត់តាំងដើម្បីមកសម្តែងការគាំទ្ររបស់ចិនចំពោះកម្ពុជា ក្រោយពីបរាជ័យនៃកិច្ចចរចាផ្សេងៗជាមួយ ឡេ យន់ ជាមនុស្សដាច់ខាតម្នាក់ដែលគេស្គាល់ជាទូទៅនោះ? ។ ចេន យ៉ុងហ្វី ឧបនាយករដ្ឋមន្ត្រីនិងជាសមាជិកការិយាល័យនយោបាយ គឺជាមនុស្សដើរស្របតាមស្ថានការណ៍ ។ ស្នាដៃដ៏ល្បីល្បាញរបស់គាត់ក្នុងការដឹកនាំប្រជាសហគមន៍ «តាចាយ» ជាទីដែលគាត់ខ្នះខ្នែងរៀបចំដាក់ឲ្យអនុវត្តដំបូន្មានរបស់ ម៉ៅ ស្តីពី «ភាពឯករាជ្យម្ចាស់ការខាងវិស័យកសិកម្ម»នោះ បានរុញច្រានគាត់ ឲ្យឈានឡើងដល់កំពូលនៃឋានានុក្រមបក្សយ៉ាងឆាប់រហ័ស ។ «ដើរតាមគំរូសហករណ៍ តាចាយ» គឺជាពាក្យស្លោកដែលទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ភ្លាមៗដោយសារ ម៉ៅ ។ ខាងនយោបាយ ចេន*

ប្រហែលពុំមែនជា«មនុស្សសំខាន់»ម្នាក់ទេ ប៉ុន្តែ គាត់មាន«របៀបនិយាយ»ដូចខ្មែរក្រហមដែរ ដូច្នេះគាត់មានភ័ព្វវាសនាទាំងស្រុងក្នុងការធ្វើឲ្យ ប៉ុល ពត យល់ចិត្តគ្នា ។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៧ ចេន បានឡើងយន្តហោះឆ្ពោះមកក្រុងភ្នំពេញ ។ ការស្នាក់អាស្រ័យដ៏កម្ររបស់គាត់មានថិរវេលាដប់ថ្ងៃ ។ ដើម្បីបន្ទរព្រឹត្តិការណ៍នេះ ទីភ្នាក់ងារព័ត៌មានចិនថ្មីបានចុះផ្សាយបទអត្ថាធិប្បាយមួយមានចំណងជើងថា ៖ «មិត្តភាពកម្ពុជា-ចិន បានចាក់ឫសយ៉ាងជ្រៅនិងរីកលូតលាស់ត្រកុំត្រកាល» ដែលរំព្ញកឡើងវិញពីអត្ថិភាពនៃចំណងទាក់ទងជាប្រវត្តិសាស្ត្ររវាងចិន-កម្ពុជា និងនិយាយពីការគាំទ្ររបស់ចិនចំពោះ ប៉ុល ពត ម្តងទៀត ។ ចេន បានធ្វើដំណើរទៅកាន់តំបន់ព្រំដែនជាទីដែលការវាយប្រយុទ្ធគ្នាកំពុងប្រព្រឹត្តទៅ ។ ការធ្វើដំណើរនេះត្រូវបានប្រកាសឲ្យដឹងជាសាធារណៈដោយកម្ពុជា ប្រហែលដើម្បីធ្វើឲ្យប្រទេសវៀតណាមចាប់អារម្មណ៍ហើយមើលទៅ ប៉ុន្តែក្នុងសុន្ទរកថាទាំងប៉ុន្មានរបស់គាត់ ចេន ចៀសវាងមិននិយាយដោយចំៗពីការវាយប្រយុទ្ធគ្នានេះទេ ។ គេមិនដឹងថាតើ ចេន មានស្ថិតនៅកន្លែងនោះទេ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៧ ក្នុងពេលដែលមានការវាយប្រហាររបស់វៀតណាមក្នុងតំបន់មួយ ដែលគេហៅថា«ចំពុះសេក»នោះ? ។ ប៉ុន្តែប្រាកដណាស់ថា គាត់បានសម្តែងការគាំទ្ររបស់ចិនចំពោះកម្ពុជា ដោយពាក្យពេចន៍មិនសូវលះថា[២៣] «គ្មានអ្នកណាម្នាក់អាចនៅពាំងពីមុខរវាងយើងទាំងពីរបានទេ ។ ប្រទេសចិន និងកម្ពុជាជាបងប្អូននឹងគ្នាអស់កាលជារៀងរហូត»[២៤] ។

ការនិយាយរបៀបស្ទាក់ស្ទើររបស់ចិននេះ ប្រហែលជាធ្វើឲ្យកម្ពុជាទាស់ចិត្តខ្លាំងដែលនឹងបកស្រាយឲ្យដឹងថា ឧបនាយករដ្ឋមន្ត្រី វ៉ាន់ វ៉ើត -អនាគតជាអ្នករងគ្រោះដោយការបោសសម្អាតរបស់ ប៉ុល ពត- មានករណីយកិច្ចត្រូវតែពន្យល់ឲ្យបានច្បាស់លាស់និងជាក់លាក់ដើម្បីចៀសវាងការភន្តច្រឡំផ្សេងៗ ៖ «ប្រទេសកម្ពុជានឹងមិនបណ្តោយឲ្យគេធ្វើឲ្យប្រែក្លាយជាថ្មីម្តងទៀតទៅជារណបប្រទេសណាមួយជាដាច់ខាត ។ កម្ពុជានឹងមិនអត់ឱនចំពោះការរំលោភបំពានណាមួយមកលើដែនដីឬដែនទឹករបស់ខ្លួនទៀតឡើយ ។ សមមិត្តចិនរបស់យើងអាចសម្គាល់ឃើញនូវការប្តេជ្ញាចិត្តរបស់កងទ័ពបដិវត្តន៍កម្ពុជាហើយ ដែលសម្រេចចិត្តធ្វើឲ្យបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ខ្លួនទទួលបានជោគជ័យពិតប្រាកដរហូតដល់ទីបំផុត» ។ ទំនងជាអ៊ីចឹងមែន ។ ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ចេន អំពីរឿងនេះមានលក្ខណៈលាក់លៀមគួរឲ្យកត់សម្គាល់ ។ ភក្តីភាព និងវីរភាពរបស់កងទ័ពកម្ពុជាគ្មានពេលណាមួយដែលមិនត្រូវរំព្ញកនោះឡើយ ។

ផ្ទុយទៅវិញ ចេន បានអបអរសរសើរយ៉ាងកក់ក្តៅនូវគោលគំនិតនៃដំណើរទាំងបន្ទុំមួយឆ្ពោះទៅកាន់លទ្ធិកុម្មុយនីស្តដែលមានតម្លៃបំផុតសម្រាប់ ប៉ុល ពត ។ សហករណ៍កសិកម្ម? តាមមតិរបស់ ចេន សហករណ៍ទាំងនោះបានដើរតួនាទីដ៏សំខាន់មួយក្នុង«ការធ្វើឲ្យសកម្មភាពវិទ្ធង្សនាផ្សេងៗរបស់សត្រូវបរាជ័យនិងការពង្រឹងអំណាចផ្តាច់ការវណ្ណៈអធន»ថែមទៀត ។ នេះគឺជានយោបាយផ្ទៃក្នុងរបស់ខ្មែរក្រហម? ។ តាមយោបល់ ចេន ដដែលថា វាជានយោបាយមានលក្ខណៈ«ត្រឹមត្រូវបំផុត» ។[២៥]

## អន្តរាគមន៍ដើម្បីសម្រុះសម្រួលការវិវាទ

*ខុសគ្នាតែពីរថ្ងៃប៉ុណ្ណោះ ចេន យ៉ុងហ្សី អាចជួបគ្នានឹងប្រធានាធិបតីឡាវ គឺព្រះអង្គម្ចាស់ សូផានុវង្ស នៅអាកាសយានដ្ឋានពោធិចិនតុងមិនខាន ។ ទស្សនកិច្ចរបស់ព្រះអង្គ គឺពិតជាមកសម្រុះសម្រួលការវិវាទរវាងកម្ពុជា-វៀតណាមយ៉ាងប្រាកដ ។ ជាសម្ព័ន្ធមិត្តរបស់វៀតណាមសម្រាប់ហេតុផលផ្សេងៗដែលកត់សម្គាល់ដោយនយោបាយជាក់ស្ដែង និងសម្បជញ្ញៈដែលរួមបញ្ចូលទាំងផលប្រយោជន៍របស់ខ្លួនផង ក្រុមមេដឹកនាំឡាវបានសង្កេតពិនិត្យប្រកបការព្រួយបារម្ភតិចតួចពីភាពតានតឹងដែលចេះតែកើនឡើងរវាងបណ្ដាប្រទេសជិតខាងខ្លួន ។ នៅឆ្នាំ១៩៧៤ ខៀវ សំផន និង អៀង សារី ធ្លាប់បានទៅធ្វើទស្សនកិច្ចនៅតំបន់សាមនឿដែលរំដោះបានដោយប៉ាថេតឡាវដែរ ។ ដូច្នេះពួកគេពុំអាចបដិសេធមិនទទួលប្រមុខរដ្ឋរបស់ឡាវបានឡើយ នៅពេលដែល "លិខិតស្នើសុំ" បានត្រូវដាក់ជូនតាមរយៈស្ថានទូតរបស់ខ្លួនប្រចាំក្រុងវៀងច័ន្ទនោះ ។*

*ព្រះអង្គម្ចាស់បានយាងមកដល់ភ្នំពេញនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៧ ។ ពិធីទទួលបដិសណ្ឋារកិច្ចដ៏ឧឡារិកមួយត្រូវបានរៀបចំឡើងនៅអាកាសយានដ្ឋាន ប៉ុន្តែការជួបគ្នារបស់ទ្រង់ជាមួយ ប៉ុល ពត បានត្រឹមតែទុកឲ្យមានសេចក្ដីសង្ស័យខ្លះប៉ុណ្ណោះ : ការផ្ដាច់មិត្តភាព គឺពិតជាជៀសមិនផុត ។ ដំណឹងស្ដីពីការជួបគ្នានេះពុំត្រូវបានផ្សព្វផ្សាយជាសាធារណៈទេតាមការស្នើសុំរបស់កម្ពុជា ។ ក្នុងនិវេសនដ្ឋានសម្រាប់បណ្ដាប្រមុខរដ្ឋបរទេសស្ថិតនៅតាមមាត់ទន្លេសាប បរិយាកាសមានសភាពតឹងតែងយ៉ាងខ្លាំង ។ សូផានុវង្ស បានសាកល្បងបញ្ចុះបញ្ចូល ប៉ុល ពត កុំឲ្យកាត់ផ្ដាច់ឯកភាពរវាងប្រទេសទាំងបីនៅឥណ្ឌូចិន ដែលធ្លាប់រងទុក្ខវេទនារាប់សិបឆ្នាំក្នុងការប្រយុទ្ធប្រឆាំងនឹងសត្រូវរួម ។ ប៉ុន្តែតាមការនិយាយរបស់អ្នកទទួលខុសត្រូវជាន់ខ្ពស់ឡាវម្នាក់ថា : "ប៉ុល ពត គ្មានចង់ដឹងចង់ឮអ្វីទាំងអស់ ។ គាត់និយាយទ្រគោះបោះបោកប្រឆាំងនឹងវៀតណាមគ្មានឈប់" ។ ចំណែកមេដឹកនាំខ្មែរក្រហមក៏ពុំអាចញុំាងឲ្យ សូផានុវង្ស ជឿពីភាពចាំបាច់ក្នុងការរក្សាការពារឯករាជ្យភាពរបស់ប្រទេសឡាវ ចំពោះមុខប្រទេសវៀតណាមបានដែរ ។ និយាយដោយខ្លី ការជួបពិភាក្សាគ្នានេះបានប្រែត្រឡប់ទៅជាការនិយាយគ្នាស្ដាប់លែងបានតែម្ដង ។*

*ក៏ប៉ុន្តែ "ស្ដេចក្រហម" ដែលអាជីពជាអ្នកបដិវត្តន៍របស់ព្រះអង្គជាប់ទាក់ទងយ៉ាងជិតស្និទ្ធនឹងបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់ហូជីមិញនោះ ពុំចង់ចាកចេញពីភ្នំពេញ ដោយមិនទាន់ធ្វើឲ្យទស្សនៈរបស់ព្រះអង្គត្រូវគេដឹងឮជាសាធារណៈទេ ។ ឱកាសត្រូវបានផ្ដល់ឲ្យព្រះអង្គក្នុងពិធីបដិសណ្ឋារកិច្ចមួយជាកិត្តិយសដល់ទ្រង់ ។ ដោយចាប់មានបន្ទូលព្រះអង្គប្រកាសនៅចំពោះមុខភ្ញៀវនិងម្ចាស់ផ្ទះថា គណបក្សកុម្មុយនីស្តឡាវ "សម្រេចបន្តភារកិច្ចដ៏ជាញជ័យរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនតទៅទៀត ហើយវាយប្រយុទ្ធប្រកៀកស្មាគ្នាជាមួយបណ្ដាប្រជាជនកម្ពុជានិងវៀតណាមជាបងប្អូនជានិច្ច" ។ ព្រះអង្គក៏ឆ្លើយតបដោយបញ្ចិតបញ្ចៀងចំពោះការរិះគន់របស់កម្ពុជាទាក់ទងទៅនឹងប្រភេទ "ទំនាក់ទំនងអន្តររដ្ឋ" ដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងវៀតណាម-ឡាវផងដែរ ។*

តាមយោបល់ព្រះអង្គថា នេះគឺជា«គំរូនៃនយោបាយមិត្តភាពនិងជាអ្នកជិតខាងល្អមួយ ដែលតំណាងឲ្យគោលការណ៍របស់យើងទាំងស្រុងក្នុងទំនាក់ទំនងផ្សេងៗជាអន្តរជាតិ» ។ ភាពស្ងប់ស្ងាត់ដែលនាំឲ្យតុញតុះក្នុងចិត្តបានកើតមានក្នុងទីប្រជុំអ្នកស្តាប់ទាំងមូល ។ អ្នកការទូតនិងពួកមន្ត្រីខ្មែរឡើងបែកញើសជោកថ្ងាស ។ គេគោងតែរំពឹកថា ថ្ងៃនោះមានសភាពក្តៅស្អុះស្អាប់ចម្លែកខុសពីធម្មតាសម្រាប់ខែធ្នូ ដែលជាខែត្រជាក់បំផុត ។ ដល់វេនដែលខៀវ សំផន ឡើងថ្លែងសុន្ទរកថាម្តង គាត់បានទិតៀនប្រទេសឡាវដោយមិនចំពោះអំពីសម្ពន្ធ័ភាពរបស់ខ្លួនជាមួយប្រទេសវៀតណាម និងការអនុញ្ញាតឲ្យកងទ័ពវៀតណាមមកបោះទីតាំងលើទឹកដីរបស់ខ្លួន ។ ការរំពឹករបស់គាត់មានលក្ខណៈច្បាស់លាស់ណាស់ ។ ទំនាក់ទំនងរវាងប្រទេសទាំងពីរមានសង្ឃឹមអាចរីកលូតលាស់ទៅបានទាល់តែពួកគេជៀសវាងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ផងខ្លួនទៅវិញទៅមក ។ ជាពិសេសប្រទេសនីមួយៗត្រូវតែការពារកុំឲ្យទឹកដីរបស់ខ្លួនអាចត្រូវប្រើជាមូលដ្ឋានសម្រាប់ការធ្វើអន្តរាគមន៍មួយប្រឆាំងនឹងប្រទេសជិតខាងខ្លួន ។

ទោះជាមានភាពតានតឹងដែលមិនទាន់ចេញមកច្បាស់ក៏ដោយ ក៏គូសន្ទនាទាំងពីរពុំលះបង់ភាពរាក់ទាក់នឹងគ្នាដែលមានតែសំបកក្រៅដែរ ។ អៀង សារី ត្រូវបានទ្រង់ សូផានុវង្ស អញ្ជើញទៅបរិភោគបាយល្ងាចមួយនៅស្ថានទូតឡាវ ។ ចំណែកព្រះអង្គបានយាងទៅក្រុងសៀមរាបដូចដែលគ្រោងទុកជាមុន តាមយន្តហោះ ដេសេ-៣ កញ្ចាស់មួយគ្រឿង ដែលរួចផុតពីគ្រោះថ្នាក់កាលពីសម័យសង្គ្រាមលោកលើកទី២ ដើម្បីធ្វើទស្សនកិច្ចនៅប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ។ ការធ្វើដំណើរនេះមិនអាចបំភ្លេចបានឡើយ ជាពិសេសដោយសារអ្នកបើកយន្តហោះរបស់កម្ពុជាជាយុវជនក្មេងៗដែលទើបនឹងមកពីធ្វើកម្មសិក្សាថ្មីៗនៅប្រទេសចិន ។ អ្នកការទូតម្នាក់ដែលហែហមទ្រង់ សូផានុវង្ស បានរំពឹកថា «ពេលហោះឡើង និងពេលចុះសក់ក្បាលពួកយើងឡើងបះប្រូង ។ ទាល់តែចុះមកដល់ដីវិញទើបយើងបានធូរស្រាលក្នុងចិត្ត»[២៦] ។

ថ្ងៃទី២៦ ខែធ្នូ គឺបួនថ្ងៃបន្ទាប់ពីព្រះអង្គត្រឡប់មកប្រទេសវិញ រដ្ឋមន្ត្រីការបរទេសវៀតណាម ង្វៀន ឌុយទ្រិញ បានចេញដំណើរទៅប្រទេសឥណ្ឌូនេស៊ី ដោយឈប់សំចតរយៈពេលខ្លីនៅក្រុងវៀងចន្ទ័ ។ សូផានុវង្ស បានប្រាប់ ទ្រិញ ឲ្យដឹងពីការលំបាកផ្សេងៗក្នុងការសន្ទនាគ្នាដែលទ្រង់ទើបនឹងធ្វើជាមួយ ប៉ុល ពត ។ ទ្រិញ បានស្តាប់ព័ត៌មាននេះដោយយកចិត្តទុកដាក់ ដោយមិននិយាយឲ្យ សូផានុវង្ស ដឹងថា ក្នុងពេលជាមួយគ្នានោះកងទ័ពរបស់វៀតណាមជាច្រើនខ្សែ បានសម្រុកចូលទៅក្នុងប្រទេសកម្ពុជា តាមពីក្រោយហ្វូងរថក្រោះឡើយ ។ ដោយមិនឲ្យប្រពន្ធ័ឃោសនាពិភពលោកទាំងមូលដឹង សង្គ្រាមឥណ្ឌូចិនទីបីដែលមេដឹកនាំឡាវប្រាថ្នាជៀសវាងបំផុតនោះ បានចាប់ផ្តើមរួចស្រេចទៅហើយ ។

វៀតណាមបានបញ្ចេញប្រើក្នុងប្រតិបត្តិការនូវចំនួនទាហានថ្មើរជើងដ៏សម្បើមមួយ ក្នុងនោះមានកងឯកភាពឆ្នើមមួយ គឺកងពលធំលេខ៩-ដែលគាំទ្រដោយកងកាំភ្លើងធំជាច្រើនដើម ។ ការវាយប្រហារដោយ

ស្រុះគ្នាបានចាប់ផ្ដើមចេញពីចំណុចនៅតាមបណ្ដោយព្រំដែនចំនួនប្រាំមួយកន្លែងដោយចែកចេញជាពីរមុខព្រួញសំដៅមករករដ្ឋធានីតែម្ដង ។ ពីមុខទ័ពរថក្រោះតេ-៥៤ និងអ៊ឹម-១១៣ ជាច្រើនគ្រឿង បានត្រាយផ្លូវតាមផ្លូវជាតិលេខ១និងលេខ៧ ឆ្ពោះមកកាន់ក្រុងភ្នំពេញ ។ គោលដៅរបស់វៀតណាម ដូចដែល វ៉ាង ទុង ប្រាប់ខ្ញុំឲ្យដឹងនៅពេលក្រោយមកគឺ «ទី១ ៖ ដេញកម្ចាត់ខ្មែរក្រហមឲ្យចេញផុតពីទឹកដីរបស់យើងទី២ ៖ វាយបំបាក់ពួកគេឲ្យបាក់ស្បាតម្ដង ដើម្បីឲ្យខ្មែរក្រហមយល់ថា ការមិនតបតរបស់យើងគ្រាន់តែជាសំបកក្រៅប៉ុណ្ណោះ ហើយថាផ្លូវតែមួយដែលអាចមានគឺផ្លូវនៃការចរចាគ្នា»[២៧] ។

គោលដៅទីមួយក្នុងចំណោមគោលដៅទាំងនោះបានទទួលជោគជ័យសឹងតែគ្មានជួបការលំបាក ។ កងទ័ពរបស់វៀតណាមដែលគាំទ្រដោយការបាញ់កាំភ្លើងធំស្រោចដូចភ្លៀង បានទន្ទ្រានចូលកម្ពុជាដូចហ្វូងស្រមោច ។ កងទ័ពខ្មែរក្រហមជាងមួយរយនាក់បានត្រូវសម្លាប់ ឬរបួសក្នុងប្រតិបត្តិការបោសសម្អាតជាច្រើនកន្លែង ។ ក្នុងចំណោមកងទ័ពដែលត្រូវរបួស អ្នកដែលមានភ័ព្វវាសនាបានត្រូវបញ្ជូនមកក្រុងភ្នំពេញតាមអង្រឹងសែង ។ ប៉ុន្តែមន្ទីរពេទ្យជាច្រើនពុំមានគ្រែពុំគ្រប់គ្រាន់សម្រាប់ទទួលអ្នករបួសទាំងនោះទេ ។ ឈាមក៏ខ្វះខាតសម្រាប់បញ្ចូលឲ្យអ្នករបួស ។ ការអែអង្គាសឈាមមួយបានរៀបចំឡើងជាបន្ទាន់ពីក្រុមមេដឹកនាំមួយក្ដាប់តូច និងក្រុមគ្រួសាររបស់ពួកគេដែលរស់នៅប្រមូលផ្ដុំគ្នានៅតាមជាយរដ្ឋធានី ។ ភាពចាំបាច់ដែលត្រូវតែធ្វើជាបន្ទាន់ក្នុងស្ថានភាពមួយបែបនេះ បានបង្ហាញឲ្យឃើញនូវការភ័ន្តច្រឡំយ៉ាងធំរបស់ការបដិវត្តន៍ខ្មែរក្រហម ។ គ្រូពេទ្យជាវណ្ណៈនាយទុនរាប់រយនាក់បានត្រូវបញ្ជូនឲ្យទៅធ្វើការទាំងបង្ខំនៅជនបទ ។ ក្នុងនោះគ្រូពេទ្យមួយចំនួនធំត្រូវបានសម្លាប់ចោល ។ នៅពេលនេះ មន្ទីរពេទ្យទាំងអស់សុទ្ធតែត្រូវកាន់កាប់ដោយបុគ្គលិកពេទ្យក្មេងៗជាកូនប្រជាកសិករដែលបានរៀនសូត្រផ្នែកវេជ្ជសាស្ត្របន្តិចបន្តួចប៉ុណ្ណោះ ក៏ក្លាយជា«ពេទ្យបដិវត្តន៍»តែម្ដង ។ ការសាកល្បងបញ្ចូលឈាមឲ្យអ្នករបួសរបស់ពួកពេទ្យទាំងនោះ បានទទួលលទ្ធផលដោយភយន្តរាយមួយ[២៨] ។

ការទប់ទល់ដែលឥតសណ្ដាប់ធ្នាប់នៃកងទ័ពភូមិភាគរបស់ខ្មែរក្រហម មិនបានសម្រេចជោគជ័យឡើយ ហើយត្រូវបានកម្ទេចដោយកងរថក្រោះនិងការបាញ់សន្ធាប់យ៉ាងសម្បើមពីសំណាក់សត្រូវ ។ តាមទិសសំដៅមកក្រុងភ្នំពេញ តំបន់ជុំវិញក្រុងកំពង់ចាមដែលជាទីក្រុងដ៏សំខាន់ស្ថិតតាមដងទន្លេមេគង្គត្រូវវាយដណ្ដើមបានដោយមិនចាំបាច់ប្រយុទ្ធ ។ កងទ័ពវៀតណាមមួយខ្សែទៀតបានមកដល់មាត់ទ្វារខេត្តស្វាយរៀងដែរ ។ ខ្សែការពារជាច្រើនកន្លែងសុទ្ធតែត្រូវវៀតណាមវាយទម្លុះទម្លាយទាំងអស់ ។ ពិតណាស់ បណ្ដាកងឯកភាពរបស់ភូមិភាគបូព៌ា ព្រមទាំងកងពលលេខ៤(នៅក្រោមឱវាទមជ្ឈិម) ដែលបញ្ជាដោយ ហេង សំរិន បានបាក់ទ័ពរត់បែកខ្ញែកគ្នានៅមុខការរុលចូលរបស់កងពលវៀតណាមជាច្រើនកង ។

បណ្ដាមេដឹកនាំក្រុងភ្នំពេញ ដែលត្រូវធ្វើឲ្យស្រឡាំងកាំងដោយការវាយលុកដ៏សម្បើមខុសប្លែកពីធម្មតារបស់វៀតណាម និងដែលត្រូវធ្វើឲ្យឡប់ស្មារតីដោយការបាក់ទ័ពរត់រប៉ាត់រប៉ាយរបស់កងទ័ពភូមិភាគបូព៌ា ពុំបាន

សាកល្បងអនុវត្តកសន្តិភាពដូចដែលវៀតណាមធ្លាប់នឹកស្មានឡើយ ។ នៅថ្ងៃទី២៥ ខែធ្នូ សម័យប្រជុំវិសាមញ្ញមួយរបស់គណៈដឹកនាំខ្មែរក្រហមបានបើកធ្វើនៅក្រុងភ្នំពេញ ។ គេបានសម្រេចចិត្តបញ្ជូនទ័ពជំនួយទៅកាន់រណសិរ្សបូព៌ា ហើយជាពិសេសឆ្លើយតបនឹងការវាយលុកផ្នែកយោធា ដោយការបង្កើនការវាយលុកផ្នែកនយោបាយកាន់តែខ្លាំងឡើង ។ ប៉ុល ពត និងក្រុមរបស់គាត់សន្និដ្ឋានថា អាចធ្វើទៅបានដើម្បីដាក់ប្រទេសវៀតណាមឲ្យនៅត្រឹមការទប់ទល់ប៉ុណ្ណោះ ដោយបរិហារចំពោះមុខពិភពលោក ពីការកាន់កាប់ភាគខាងកើតប្រទេសកម្ពុជា ។ ប្រាកដហើយទំនាក់ទំនងផ្នែកការទូតច្បាស់ជាត្រូវកាត់ផ្តាច់ ។ គ្រប់យ៉ាងឆ្ពោះទៅការរៀបចំ "វាយប្រហារ"ខាងការទូត ដែលខ្មែរក្រហមហាក់ដូចជាមិនខ្វាយខ្វល់ហួសហេតុពីការវាយបករបស់ខ្លួនឡើយ ។ ខ្មែរក្រហមជឿជាក់ថា "យើងអាចទប់ទល់ពួកវៀតណាមបាន ។ នៅពេលប្រកាសផ្សាយដំណឹងនេះជាសាធារណៈពិភពលោកទាំងមូលនឹងបញ្ចេញប្រតិកម្មមិនខាន"[២៩] ។

## ការផ្តាច់មិត្តភាព

គី មិញ លេខាធិការទីមួយនៃស្ថានទូតវៀតណាមប្រចាំប្រទេសកម្ពុជា បានចាប់ផ្តើមការងារតាមទម្លាប់ប្រចាំថ្ងៃរបស់គាត់ដោយស្តាប់វិទ្យុក្រុងភ្នំពេញ ដែលជាមធ្យោបាយតែមួយគត់ គាត់អាចទទួលបានព័ត៌មានផ្សេងៗស្តីពីជីវភាពរបស់របប ប៉ុល ពត ។ រៀងរាល់ថ្ងៃរសៀល សេចក្តីចម្លងជាភាសាបារាំងមួយពីការផ្សាយតាមវិទ្យុនៅពេលព្រឹកត្រូវបានចែកឲ្យគ្រប់ស្ថានទូតទាំងអស់ ។ ប៉ុន្តែ មិញ ដែលចេះនិយាយភាសាខ្មែរឥតខ្ចោះនោះ ចូលចិត្តស្តាប់ដំណឹងផ្សេងៗតាមវិទ្យុវិញជាជាងរង់ចាំសេចក្តីបកប្រែដែលគេចែកឲ្យ ។ ព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧នេះ កើតមានរឿងចម្លែកមួយខុសពីសព្វដង ។ ជំនួសការចាក់ផ្សាយបទភ្លេងបដិវត្តន៍មួយចំនួន និងព័ត៌មានផ្សេងៗតាមទម្លាប់ វិទ្យុបានចាប់ផ្តើមការផ្សាយរបស់ខ្លួននៅវេលាម៉ោង ៦ព្រឹកដោយសេចក្តីប្រកាសពិសេសមួយ ដែលកំណត់នូវការផ្តើមការឃោសនាយ៉ាងខ្នះខ្នែងមួយប្រឆាំងនឹងវៀតណាម ដែលមិនដែលឮសោះក្នុងការទំនាក់ទំនងផ្សេងៗ រវាងបណ្តាប្រទេសសង្គមនិយម"ជាបងប្អូន" :

"ដោយចាត់ទុកការឈ្លានពានដ៏ឃោរឃៅ និងព្រៃផ្សៃដែលទើបនឹងប្រព្រឹត្តឡើងដោយប្រទេសវៀតណាមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនស្លូតត្រង់របស់យើង ដោយចាត់ទុកអាកប្បកិរិយា អមិត្ត និងបំណងអាក្រក់របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម...រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានសម្រេចចិត្តកាត់ផ្តាច់រាល់ទំនាក់ទំនងការទូតទាំងអស់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមជាបណ្តោះអាសន្ន ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នេះតទៅរហូតទាល់តែកងទ័ពឈ្លានពានវៀតណាមដកថយពីទឹកដីដ៏ពិសិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យនិងបរិយាកាសមិត្តភាពមួយរវាងប្រទេសទាំងពីរត្រូវបានកែលម្អឡើងវិញ"[៣០] ។

បួនម៉ោងក្រោយមក អ្នកនាំសារម្នាក់ដែលមានទឹកមុខម៉ឺងម៉ាត់ក្នុងនាមរដ្ឋមន្ត្រីការបរទេសរបស់កម្ពុជា

បានមកដល់ស្ថានទូត ដែលក្នុងសារនោះមានន័យជាសេចក្តីប្រកាសបណ្តេញចេញតែម្តង ៖ បុគ្គលិកស្ថានទូតរបស់វៀតណាមបានត្រូវសុំឲ្យចាកចេញពីក្រុងភ្នំពេញក្នុងសប្តាហ៍នេះ ។ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ គឺ មិញ និងសហការីរបស់គាត់ បានធ្វើដំណើរទៅក្រុងហូជីមិញ តាមយន្តហោះពិសេសមួយគ្រឿងដែលគេជូលមក ។ អវត្តមានរបស់គាត់ ប្រហែលជាមានរយៈពេលខ្លីបំផុត ព្រោះមួយឆ្នាំក្រោយមកគាត់បានវិលត្រឡប់មកក្រុងភ្នំពេញ "ដែលត្រូវបានរំដោះ"វិញតាមក្បួនរថក្រោះរបស់កងទ័ពវៀតណាម ។ ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំក្រុងហាណូយ សុខ ឃាង មានសំណាងតិចជាង មិញ ទៅទៀត ។ ក្នុងឱកាសនៃការចេញដំណើររបស់ ឃាង គាត់បានឱបថើបលាគ្នា ជាមួយមិត្តវៀតណាមម្នាក់ នេះជារឿងឆ្គងប្រហែលមួយដែលគេចមិនផុតពីខ្សែភ្នែកអ្នកការទូតចិន ដែលមានវត្តមាននៅអាកាសយានដ្ឋានឡើយ ។ មិនដឹងថា តើហេតុការណ៍នេះ វាជាមូលហេតុនៃភ័ព្វអាក្រក់របស់គាត់ ឬយ៉ាងណាទេ ព្រោះគាត់បានត្រូវសម្លាប់ក្រោយពីត្រឡប់មកក្រុងភ្នំពេញវិញ បានតែចំនួនបីខែប៉ុណ្ណោះ[៣១] ។

ខ្មែរក្រហមសុទ្ធតែមានហេតុផល ។ ការប្រកាសផ្សាយដែលធ្វើឡើងដោយវិទ្យុភ្នំពេញ ពិតជាធ្វើឲ្យពិភពលោកទាំងមូលភ្ញាក់ផ្អើលស្រឡាំងកាំងមែន ។ មិនដល់បីឆ្នាំផង ក្រោយពីការបញ្ចប់ជម្លោះឥណ្ឌូចិន សង្គ្រាមបានចាប់កម្រើកជាថ្មីម្តងទៀត ។ ប្រទេសកុម្មុយនីស្តពីរដែលជាអតីតសម្ពន្ធ័មិត្តបានវាយប្រយុទ្ធគ្នាជាចំហដោយបញ្ចប់យ៉ាងគំហុកនូវការនិយាយដៀមដាម និងការគំរាមហែកកេរ្តិ៍គ្នារាប់ខែមកហើយស្តីពីអធិករណ៍ ដែលស្ងាត់ៗរបស់ប្រទេសគេទាំងពីរ ។ ភ្លាមៗនោះ តុល្យភាពកម្លាំងក្នុងអាស៊ីភាគអាគ្នេយ៍បានត្រូវធ្វើឲ្យភាន់ប្រែ ។

ឱកាសដែលជ្រើសរើសដោយខ្មែរក្រហមអាចពុំប្រសើរទេ ។ ការផ្តាច់ទំនាក់ទំនងជាសាធារណៈរបស់គេ បានធ្វើឲ្យក្រុងហាណូយខ្វាយខ្វល់ចិត្តខ្លាំងមែនទែន ដោយសាររដ្ឋមន្ត្រីការបរទេសរបស់ខ្លួនទើបនឹងចាប់ផ្តើមដំណើរទស្សនកិច្ចមួយនៅតាមបណ្តាប្រទេសមិនមែនកុម្មុយនីស្តក្នុងអាស៊ីអាគ្នេយ៍ ដើម្បីសាកល្បងរៀបចំឲ្យមានទំនាក់ទំនងជាអ្នកជិតខាងល្អជាមួយប្រទេសទាំងនោះ ។ វាទំនងថា វៀតណាមមិនបានបង្ការជាមុនចំពោះប្រតិកម្មឆាប់រហ័សរបស់កម្ពុជាឡើយ ។ ម្តងនេះ ការយកចិត្តទុកដាក់របស់សាធារណជនពិភពលោក បានផ្តោតទៅលើ"សង្គ្រាមរវាងសមមិត្តនិងសមមិត្ត"ហើយ ។ គេគោងតែធ្វើប្រតិកម្មតបតវិញ ។ ក្រុមអ្នកធ្វើការខាងការឃោសនាជាផ្លូវការនឹងអាចសប្បាយរីករាយខ្លាំង ។ ក្រុងហាណូយបានចាប់ផ្តើមផ្សព្វផ្សាយជាសាធារណៈដោយពាក្យពេចន៍ច្បាស់លាស់នូវព័ត៌មានយ៉ាងច្រើន ទាក់ទងទៅនឹងការរំលោភបំពានរបស់ខ្មែរក្រហម ជាពិសេសការវាយប្រហារផ្ទួនៗប្រឆាំងនឹងប្រទេសវៀតណាម ។

តើក្រុងភ្នំពេញមានពិគ្រោះជាមួយក្រុងប៉េកាំងទេ មុននឹងប្រព្រឹត្តកំហុសដែលកែមិនកើតនេះ? តើពួកចិនត្រូវបានផ្តល់ព័ត៌មានឲ្យតែប៉ុណ្ណឹងទេឬ? ការរាវែកចិត្តរបស់ ចេន យ៉ុងហ្វី កាលពីដប់ថ្ងៃមុនក្នុងការប្រកាន់ជំហរជាចំហស្តីពីជម្លោះព្រំដែនហាក់ដូចជាសឲ្យឃើញថា វាគ្មានបានការអ្វីទេ ហើយថាការផ្តាច់ទំនាក់

ទំនងការទូតត្រូវបានសម្រេចដោយក្រុងភ្នំពេញ ដើម្បីបង្ខំឲ្យប្រទេសចិនធ្វើអ្វីមួយផ្ទុយនឹងឆន្ទៈរបស់ខ្លួន[៣២] ។

សមាសភាពផ្សេងទៀតក៏ជួយគាំទ្រក្នុងន័យនេះដែរ ។ ឧទាហរណ៍ ហេតុអ្វីបានជាពួកមេដឹកនាំ កម្ពុជាពុំកត់សម្គាល់ថា ជំនួយយោធាដែលប្រទេសចិនសន្យាផ្ដល់ឲ្យបែរជាត្រូវពន្យារទៅវិញ? (តាមការពិត ប្រទេសចិនត្រូវការពេលវេលាមួយឆ្នាំកន្លះ ដើម្បីប្រកាន់តាមពាក្យសន្យារបស់ខ្លួនកាលពីខែកុម្ភៈ ឆ្នាំ១៩៧៦)? ។ ហេតុអ្វីបានជាពួកមេដឹកនាំខ្មែរក្រហមពុំភ្ញាក់ផ្អើលនឹងការរវាំងប្រយ័ត្នរបស់តេង? ។ នៅខែតុលា ឆ្នាំ១៩៧៦ តេង ដែលត្រូវសាកសួរដោយអ្នកកាសែតម្នាក់ស្ដីពីជម្លោះនេះ បានប្រកាសថា “បញ្ហាទាំងអស់នឹងសម្រេចជាលទ្ធផលដោយខ្លួនឯង ។ យើងយល់ស្របចំពោះការបើកឲ្យមានការចរចាគ្នាពិតប្រាកដ ។ យើងចៀសវាងមិនវិនិច្ឆ័យចំពោះអ្វីដែលមានលក្ខណៈត្រឹមត្រូវនិងអ្វីដែលមិនមានឡើយ”[៣៣] ។ កាលពីមួយឆ្នាំមុន ប៉ុល ពត បានចោទប្រកាន់មេដឹកនាំចិនយ៉ាងព្រងើយថា ធ្វើខ្លួនជា“អ្នកប្រឆាំងបដិវត្តន៍ម្នាក់” ។ តេង កំពុងពង្រឹងជំហររបស់គាត់ក្នុងផ្ទៃបក្សកុម្មុយនីស្តចិន ពួកខ្មែរក្រហមអាចត្រូវការដាក់បណ្ដាសម្ពន្ធ័មិត្តរបស់ខ្លួនពីមុខស្ថានភាពមួយដែលគេមិនអាចប្រែក្រឡាស់បាន[៣៤] ។

ដើម្បីបង្ហាញឲ្យឃើញសាមគ្គីភាពជាមួយកម្ពុជា អ្នកការទូតចិនដែលបំពេញមុខងារនៅក្រុងហាណូយ មិនអាចធ្វើអ្វីកើតក្រៅតែពីអមជូនដំណើរអ្នកការទូតខ្មែរទៅកាន់អាកាសយានដ្ឋានក្នុងដំណើរត្រឡប់មកក្រុងភ្នំពេញវិញប៉ុណ្ណោះ ដោយឆ្លងកាត់តាមទីក្រុងប៉េកាំង ។ ប៉ុន្តែ ប្រទេសចិនមិនសប្បាយទាល់តែសោះ ចំពោះការកើនឡើងយ៉ាងខ្លាំងនៃជម្លោះរវាងប្រទេសទាំងពីរនិងការផ្ដាច់ទំនាក់ទំនងការទូតរបស់ពួកគេ ។ ទីភ្នាក់ងារព័ត៌មានចិនថ្មីបានស្រង់យកមកចុះផ្សាយទាំងស្រុងនូវការចោទប្រកាន់ផ្សេងៗរបស់កម្ពុជា ប៉ុន្តែក៏មានរៀបរាប់បញ្ចូលនូវការពោលអះអាងរបស់វៀតណាមយ៉ាងខ្លីផងដែរ ។ វាគ្មានសង្ស័យឡើយថា ពួកចិនមានចិត្តលម្អៀងមកលើកម្ពុជា ដោយគ្រាន់តែមិននិយាយជាចំហប៉ុណ្ណោះ ប៉ុន្តែ លំនាំដែលកាសែតរបស់គេវែកញែកពីជម្លោះ ហាក់ដូចជាផ្ដល់នូវអាទិភាពនៃការចរចាជាជាងការបង្កើនសង្គ្រាម ។ ក្រុងប៉េកាំងពុំបានបង្ហាញការកៀបសង្កត់ដោយផ្ទាល់ទៅលើក្រុងហាណូយនៅឡើយទេ ។ ភស្តុតាងគឺថានៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ ពួកចិនបានបន្តកិច្ចព្រមព្រៀងផ្ដល់ជំនួយហិរញ្ញវត្ថុប្រចាំឆ្នាំទៅឲ្យវៀតណាមទៀតដោយមិនចាំបាច់ពិភាក្សាគ្នាទេ ។ នៅជំនាន់នោះ ហេតុការណ៍នេះមិនរបូតផុតពីអ្នកជំនាញការខ្លះនៃរដ្ឋាភិបាលអាមេរិកាំងឡើយ ដែលកត់សម្គាល់ថា “ពួកចិនអាចពន្យារការចុះហត្ថលេខាលើកិច្ចព្រមព្រៀង បើសិនជាពួកចិនចង់សម្ដែងឲ្យឃើញនូវការប្រឆាំងរបស់គេចំពោះក្រុងហាណូយ”[៣៥] ។ ក្រុងប៉េកាំងបានយល់ព្រមសម្របសម្រួលឲ្យមានការជួបគ្នាថ្មីមួយរវាងកម្ពុជានិងវៀតណាមថែមទៀតដែលឃើញថា ឥតបានផលដូចកាលពីប្រជុំលើកមុនដែរ[៣៦] ។

ជាថ្មីម្ដងទៀត អ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់តែងតែធ្វើដំណើរយ៉ាងប្រញាប់មកកាន់ក្រុងភ្នំពេញដោយនាំសំបុត្រមួយពីថ្នាក់ដឹកនាំចិនមកផង ។ លើកនេះគឺលោកស្រី តេង យីងឆាវ ជាអ្នកនយោបាយនិយម

កណ្ដាលម្នាក់ ។ ពិតហើយប្រទេសចិនខ្វាយខ្វល់ណាស់ពីសន្តិសុខរបស់កម្ពុជាដែលប្រឈមមុខនឹងឧត្តមភាពយោធាដ៏លើសលប់របស់វៀតណាម និងគ្រោះថ្នាក់ផ្សេងៗដែលបណ្ដាលមកពីនយោបាយបក្ខហេតុរបស់ខ្លួនផង ។ ប៉ុន្តែមូលហេតុនៃការព្រួយបារម្ភចម្បងរបស់ចិនគឺផ្សេងពីនេះ ។ ដោយពិត បើសិនជាចិនបណ្ដោយខ្លួនឲ្យប្រទាញទៅរកការធ្វើអន្តរាគមន៍ដោយយោធានៅកម្ពុជា ខ្លួនច្បាស់ជាទទួលរងគ្រោះថ្នាក់ពីការរីករាលដាលនៃជម្លោះនេះមិនខាន ហើយទំនងជាអាចធ្វើឲ្យចំណងទាក់ទងរវាងវៀតណាមនិងសូវៀតរឹតតែរឹងមាំឡើងថែមទៀត ។ ប្រាកដណាស់ ផលប្រយោជន៍របស់ចិនពុំមែនបណ្ដោយឲ្យជម្លោះរបស់ឥណ្ឌូចិនរបូតផុតពីការត្រួតត្រាទាំងស្រុងឡើយ ។ ចំណែកលោកស្រី គេង ក៏មិនសូវដាក់សេចក្ដីសង្ឃឹមលើក្រុងភ្នំពេញប៉ុន្មានដែរ ។ លោកស្រីជាមនុស្សមានគុណវិបត្តិដោយសារគាត់ជាភរិយាមេម៉ាយនៃសពរដ្ឋមន្ត្រីទី១ ជូ អេនឡាយ ដែលការស្លាប់របស់គាត់បានធ្វើឲ្យខ្មែរក្រហមមួយចំនួនធំរីករាយសប្បាយក្នុងចិត្ត ។ ម្យ៉ាងទៀត លោកស្រីក៏ជាមិត្តជិតស្និទ្ធនឹងសម្ដេច សីហនុដែរ ដែលពេលនោះ ព្រះអង្គត្រូវខ្មែរក្រហមដាក់កំហិតឲ្យស្ថិតនៅតែក្នុងនិវេសនដ្ឋានរបស់ទ្រង់នៅក្នុងរដ្ឋធានីប៉ុណ្ណោះ[៣៧] ។

## «នៅពេលដែលកន្ទុយបក់ឆ្កែ»

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ លោកស្រី គេង បានមកដល់ភ្នំពេញអមដំណើរដោយសហការីជាច្រើនរូប ក្នុងនោះមានអនុរដ្ឋមន្ត្រីការបរទេស ហាន នានឡុង និងអ្នកឯកទេសខាងបញ្ហាអាស៊ីអាគ្នេយ៍ជាច្រើនរូបទៀត ។ ការសម្ដែងឲ្យឃើញពិធីធ្វើបដិសណ្ឋារកិច្ចដ៏អធិកអធមដែលត្រៀមបម្រុងសម្រាប់លោកស្រីប្រហែលពុំមែនរៀបចំរបៀបបំភាន់ភ្នែកនោះទេ ។ នៅឱកាសនេះ ប្រទេសចិនបានទទួលរងបរាជ័យមួយយ៉ាងប្រាកដ ។ តាមការពិត តាំងពីសរទរដូវឆ្នាំ១៩៧៧ ក្រុងប៉េកាំងបានកៀបសង្កត់ខ្មែរក្រហមឲ្យពង្រីកមូលដ្ឋាននយោបាយរបស់ខ្លួន និងអនុញ្ញាតឲ្យសម្ដេច សីហនុ វិលមកកាន់អំណាចវិញ ។ ប៉ុន្តែលោកស្រី គេង ពុំអាចទៅជួបសម្ដេច សីហនុ បានទេ ព្រោះ ប៉ុល ពត បានជំទាស់នឹងរឿងនេះ ។ លោកស្រីបានប្រគល់ឲ្យខ្មែរក្រហមនូវសារលិខិតមួយដែលផ្ញើថ្វាយសម្ដេច សីហនុ ដោយព្រះរាជបុត្រីមួយអង្គក្នុងចំណោមព្រះរាជបុត្រីរបស់ព្រះអង្គគឺព្រះអង្គម្ចាស់ក្សត្រី បុប្ផាទេវី នាដការបាំនៅក្រុងប៉ារីស ។ ខ្មែរក្រហមមិនដែលយកសារលិខិតនេះទៅថ្វាយព្រះអង្គសោះឡើយ ។ នៅពេលដែលលោកស្រីជូនយោបល់ថា កម្ពុជាត្រូវខ្នះខ្នែងដោះស្រាយបញ្ហាផ្សេងៗរបស់ខ្លួនជាមួយវៀតណាមដោយការចរចាគ្នានោះ លោកស្រីបានពើបប្រទះនឹងការបដិសេធមួយជាថ្មីម្ដងទៀត ។ ក្នុងសន្ទរកថាជាសាធារណៈមួយ គេង យីងជាវ បានអះអាងជាថ្មីនូវការគាំទ្ររបស់ប្រទេសចិន ចំពោះគោលការណ៍ទាំងប្រាំនៃនយោបាយសន្តិសហវិជ្ជមានដែលតាមយោបល់លោកស្រីថា «ប្រទេសទាំងអស់ក្នុងពិភពលោករួមទាំងបណ្ដាប្រទេសសង្គមនិយមផង ត្រូវតែប្រតិបត្តិតាមគោលការណ៍នេះ ដើម្បីសាកល្បង

ដោះស្រាយទំនាស់ផ្សេងៗរបស់ខ្លួនតាមការចរចា»[៣៨] ។

ប្រធានសភាតំណាងប្រជាជន នួន ជា បានឆ្លើយតបនឹងលោកស្រី គេង វិញថា «ប្រជាជនកម្ពុជាសុទ្ធតែជាអ្នកស្នេហាជាតិមាតុភូមិដ៏មោះមុត ប៉ុន្តែប្រកបទៅដោយវិចារណញ្ញាណ ។ ពួកគេមិនដែលបង្កជម្លោះនឹងអ្នកណាម្នាក់ឡើយ ហើយក៏មិនដែលមានបំណងនឹងបង្កដែរ» ។ ប៉ុន្តែ «ប្រជាជនកម្ពុជានឹងវាយប្រយុទ្ធដាច់ខាតប្រឆាំងនឹងអំពើវិទ្ធង្សនានិងវិច្ឆេទកម្មដែលប្រព្រឹត្តឡើងនៅក្នុងផ្ទៃប្រទេស ដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងនឹងការប្រមិចប្រមោចទឹកដីនៅតាមតំបន់ព្រំដែន ប្រឆាំងគ្រប់ការឈ្លានពាននិងគោលបំណងវាតទីពីខាងក្រៅ»ទាំងអស់ [៣៩] ។

ទោះជាការឆ្លើយបដិសេធដោយប្រយោលនេះនៅមិនទាន់គ្រប់គ្រាន់ក៏ដោយ ក៏ក្រុងភ្នំពេញបានសង្កត់បញ្ជាក់យ៉ាងខ្លាំងទៅលើចំណុចមួយ ៖ តាមរយៈវិទ្យុរបស់ខ្លួនបានផ្សាយដែលគេប្រាកដជាកំណត់ថា ការរិះគន់មួយដែលស្ទើរតែគ្មានលាក់លៀម ស្តីពីជំហររបស់ចិនមុនពេលពួកភ្ញៀវចិនរៀបចាកចេញពីប្រទេសទៅវិញ ដោយហេតុថាពួកគេកំពុងស្ថិតនៅអង្គរនៅឡើយនាពេលរសៀលថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៨ នោះ ។ បទអត្ថាធិប្បាយដែលផ្សាយតាមវិទ្យុមានលក្ខណៈជាបំណងមួយស្រេចទៅហើយ ៖ «ប្រជាជនកម្ពុជាគោរពដោយម៉ឺងម៉ាត់ចំពោះគោលការណ៍ឯករាជ្យភាព អធិបតេយ្យភាព និងភាពម្ចាស់ការ ហើយបែងចែកដាច់ស្រឡះរវាងមិត្តនិងសត្រូវនៅក្នុងពិភពលោកទាំងមូល... ។ ប្រទេសកម្ពុជាជាប្រទេសមួយតូច ប្រភពធនធានរបស់ខ្លួនក៏ខ្សត់ខ្សោយនិងមានប្រជាជនតិច... ។ ប៉ុន្តែ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាជនរបស់យើងមានលក្ខណៈអង់អាចក្លាហានបំផុត» ។ ជំនួយរបស់ចិន? ។ កម្ពុជា«មានទំនុកចិត្តលើកម្លាំងរបស់ខ្លួនឯងផ្ទាល់» ។ ពិតហើយ! ចំពោះមុខការឈ្លានពាន និងការប៉ុនប៉ងភ្ជាប់ទឹកដីរបស់វៀតណាម ប្រទេសកម្ពុជាពុំអាចមិនត្រូវការជំនួយគាំទ្រពីបណ្តាមិត្តភក្តិរបស់ខ្លួនឡើយ ប៉ុន្តែក្នុងលក្ខខណ្ឌថា ប្រទេសទាំងនោះត្រូវចាត់ទុកកម្ពុជាដោយស្មើភាពគ្នា ។ នៅពេលនោះ វិទ្យុខ្មែរក្រហមបាននិយាយបញ្ចិតបញ្ចៀងមិនច្បាស់លាស់មួយ ចំពោះការប៉ុនប៉ងសម្ងំតគំរាមខ្លះ ដែលនឹងធ្វើឲ្យមហាអំណាចជាមិត្តមួយក្លាយជាអ្នកគួរបន្ទោសទៅវិញ ៖ «យើងចេះបែងចែករវាងមិត្តពិតប្រាកដ និងមិត្តក្លែងក្លាយច្បាស់លាស់ ។ មិត្តពិតប្រាកដគោរពយើងនិងស្រឡាញ់យើង ពីព្រោះពួកគេមិនបង្កអ្វីឲ្យប៉ះពាល់ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីយើងជាថ្មីឡើយ ។ ជាការពិតណាស់ មិត្តរបស់យើងពុំមែនជាមិត្តដែលនាំមកផ្តល់ឲ្យយើងនូវជំនួយជាសម្ភារមួយទេ ប៉ុន្តែ ចេះផ្តល់នូវសារសំខាន់ខ្លះចំពោះយើង ។ ការសាមគ្គីគ្នាពិតប្រាកដ គឺការគោរពគ្នាទៅវិញទៅមករបស់ប្រទេសនីមួយៗទោះធំក្តីតូចក្តី ។ វាមិនមែនឲ្យប្រទេសមួយ ជិទាស់នឹងសិទ្ធិក្តោបក្តាប់អនាគតផ្ទាល់របស់ខ្លួនទេ...»[៤០] ។

ភាពរបឹងរឹងរូសរបស់ ប៉ុល ពត បានបន្ថយលទ្ធភាពក្នុងការធ្វើសកម្មភាពរបស់ក្រុងប៉េកាំង ។ ពេញថិរ-វេលានៃរដូវរងាឆ្នាំ១៩៧៧ ប្រទេសចិនក៏ព្រួយបារម្ភអំពីនយោបាយ«ធ្វើឲ្យមានភាពធូរស្រាល» ចំពោះមុខ

ក្រុងមូស្គូរបស់រដ្ឋាភិបាល ខាធ័រ (Carter ប្រធានាធិបតីអាមេរិកពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៨១)ផងដែរ ដែលតាមការមើលឃើញរបស់ខ្លួនថា នេះគ្រាន់តែជាការបង្ហាញឲ្យឃើញពីភាពទន់ខ្សោយប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ប្រទេសចិនពុំចង់បន្តរឿងដោយឥតប្រយោជន៍នឹងក្រុងមូស្គូ ដោយគាំទ្រកម្ពុជាជាចំហប្រឆាំងនឹងវៀតណាមឡើយ ។ ការផ្តើមពិភាក្សាដ៏ប្រុងប្រយ័ត្ននេះបានគំរាមធ្វើឲ្យចិនបាត់បង់មិត្តភាពជាមួយសម្ព័ន្ធមិត្តដ៏ប្រសើរជាងគេនៅអាស៊ីអាគ្នេយ៍-ប្រតិកម្មរបស់កម្ពុជា បានបង្ហាញឲ្យឃើញយ៉ាងច្បាស់រួចមកហើយ ។ ដូច្នេះ ចិនត្រូវតែធ្វើការជ្រើសរើសមួយ ។ ក្រុងប៉េកាំងបានបោះបង់យុទ្ធវិធី ដើម្បីប្រើយុទ្ធសាស្ត្រវិញ ។ វាទំនងថា ក្រុមអ្នកប្រកាន់នយោបាយឆ្វេងក្នុងផ្ទៃក្រុមមេដឹកនាំចិនកើតមានការជិនណាយនឹងធ្វើការកៀបសង្កត់ទៅលើសម្ពន្ធមិត្របដិវត្តន៍មួយ ដើម្បីបញ្ជាយុទ្ធវិធីសាមញ្ញមួយណាស់ ។ ប៉ុន្តែ មូលហេតុផ្សេងៗទៀត អាចជំរុញឲ្យក្រុងប៉េកាំងបោះបង់អព្យាក្រឹតភាពមិនដាច់ខាតរបស់ខ្លួន ។ ភាពរីកមិនរួចនៃកិច្ចសហការសូវៀត-វៀតណាមគឺមានលក្ខណៈរបៀបនេះឯង ដូចគ្នានឹងការឃោសនាវាយលុកប្រឆាំងចិនដែលបន្តឡើងភ្លាមៗ ដោយពួកសូវៀត ឬភាពកាន់តែធ្ងន់ធ្ងរនៃបណ្តាជនជាតិចិននៅប្រទេសវៀតណាមដែរ ។ នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ ហ្គ្រីហ្គូរីរ៉ូម៉ាណូវ សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តសូវៀត បានធ្វើដំណើរដោយឥតព្រាងទុកជាមុនមួយទៅកាន់ក្រុងហាណូយនិងក្រុងហូជីមិញ ។ នៅថ្ងៃទី២១ ខែកុម្ភៈ វៀតណាមបានចេញផ្សាយជាសាធារណៈនូវសេចក្តីថ្លែងការណ៍មួយដែលមិនខុសពីការថ្កោលទោសប្រទេសចិនតាមផ្លូវការឡើយ ។ តាមពិត វិទ្យុហាណូយបានផ្សាយឲ្យដឹងថា មហាអំណាចបរទេសមួយបានប្រើប្រាស់ទឹកដីកម្ពុជាដើម្បីឈ្លានពានប្រទេសវៀតណាម ។ “ពួកចក្រពត្តិនិយមនិងពួកប្រតិកិរិយាអន្តរជាតិ បានជួយឧបត្ថម្ភកម្ពុជាឲ្យបង្កើត និងបំពាក់អាវុធឲ្យកងទ័ពចំនួនដប់ពីរកងពលធំ មានទាំងកាណុងធំបាញ់បានរយៈឆ្ងាយនិងយន្តហោះប្រយុទ្ធជាច្រើនគ្រឿង ដែលពីមុននេះបន្តិចកងទ័ពកម្ពុជាមិនដែលមានប្រើប្រាស់ឡើយ”[៤១] ។

ប្រទេសចិនបានបញ្ចប់យ៉ាងឆាប់រហ័សនូវការប្រឹងប្រែងទាំងប៉ុន្មានរបស់ខ្លួន ដើម្បីធ្វើឲ្យសម្រេចដំណោះស្រាយមួយដោយកិច្ចចរចា ទោះជាចិនចុះចាញ់ការគំរាមហែកកេរ្តិ៍របស់ ប៉ុល ពត ទោះ ជាចិនដឹងភ្លាមៗពីទំហំនៃគោលដៅខាងយោធារបស់វៀតណាមក៏ដោយ ។ ដោយហេតុនេះ អព្យាក្រឹតភាព(ភាពជាអ្នកកណ្តាល)របស់ខ្លួនតាមដែលគេសម្គាល់ឃើញគឺត្រូវចប់ ។ ក្នុងពេលជាមួយគ្នានោះ កប៉ាល់ចិនជាច្រើនគ្រឿងបានចាប់ផ្តើមរើគ្រឿងសម្ភារសឹកដាក់ចុះនៅកំពង់ផែកំពង់សោមមានកាណុង១៣០មីល្លីម៉ែត្រ ដែលបាញ់បានរយៈឆ្ងាយ កាំភ្លើងប្រឆាំងរថក្រោះទំហំធំ រថក្រោះថលជលិក(ចុះទឹកក៏បានលើគោកក៏បាន)មួយចំនួនធំ[៤២] ។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ រដ្ឋមន្ត្រីទី១ ហ្វា គួហ្វេង បានបោះបង់ជាផ្លូវការមិនផ្តើមចលនាធ្វើឲ្យរីកចម្រើនដល់ដំណោះស្រាយមួយលើមូលដ្ឋាននៃគោលការណ៍សន្តិសហវិជ្ជមានទាំងប្រាំឡើយ ។ គាត់ថ្លែងថា “គ្មានប្រទេសណាមួយមានសិទ្ធិស្វះស្វែងបង្កើតអនុត្តរភាពរបស់ខ្លួនក្នុងតំបន់មួយនៃពិភពលោកបានឡើយ ហើយក៏គ្មាន

សិទ្ធិបង្ខំឲ្យប្រទេសណាមួយផ្សេងទៀតធ្វើតាមឆន្ទៈរបស់ខ្លួនដែរ (គឺសំដៅទៅលើវៀតណាមយ៉ាងច្បាស់) ។ តាមយោបល់យើងគឺត្រង់នេះហើយជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់ដែលអាចបង្ហាញថា តើប្រទេសមួយបានប្រតិបត្តិទៅតាមគោលការណ៍សន្តិសហវិជ្ជមានដែរឬក៏អត់»[៤៣] ។

នៅដើមខែមករា ឆ្នាំ១៩៧៨ ពេលដែលសង្គ្រាមតាមរលកធាតុអាកាសរវាងក្រុងភ្នំពេញនិងក្រុងហាណូយកំពុងពុះកញ្ជ្រោលខ្លាំង កងឯកភាពជាច្រើនរបស់កម្ពុជាដែលដកយកមួយភាគពីបណ្តាកងពលធំនៃភូមិភាគកណ្តាលបានធ្វើចលនាឆ្ពោះមកភាគខាងកើត ។ កងពលធំទាំងនោះបានត្រូវដឹកនាំបញ្ជាដោយមនុស្សសំខាន់បីនាក់របស់របបនេះ គឺរដ្ឋមន្ត្រីក្រសួងការពារប្រទេស សុន សេន មេបញ្ជាការភូមិភាគកណ្តាល កែ ពក និង ភូមិភាគនិរតី តាម៉ុក ។ ប៉ុន្តែកងទ័ពរបស់ក្រុងហាណូយបានវាយប្រយុទ្ធដកថយនិងវិលទៅកាន់មូលដ្ឋាននានារបស់ខ្លួនវិញ ដោយមិនចង់ឲ្យមានការប៉ះទង្គិចគ្នាឡើយ ។

ក្នុងគោលបំណងបិទបាំងបរាជ័យគ្រាដំបូងរបស់ខ្លួន ពេលនោះខ្មែរក្រហមបានចាប់ផ្តើមប្រើយុទ្ធនាការយ៉ាងខ្លាំងក្លាបន្ថែមទៀតដើម្បីបង្ហាញឲ្យឃើញថា «ការដកថយប្រកបដោយសុច្ឆន្ទៈរបស់វៀតណាម» គឺជា «មហាជ័យជម្នះជាប្រវត្តិសាស្ត្រ»មួយ ។ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ គឺត្រូវចារឹកជាអក្សរមាសក្នុងតារាងថ្ងៃខែឆ្នាំនៃប្រវត្តិសាស្ត្រ ទុកដូចជាថ្ងៃគួរឲ្យចងចាំដែលខ្មែរបានវាយកម្ចាត់កម្ចាយកងទ័ពឈ្លានពានដ៏ខ្លាំងពូកែរបស់វៀតណាម ។ ដើម្បីអបអរជ័យជម្នះ«បាយមួយចាន»ទៀតបានត្រូវអង្គការបន្ថែមឲ្យនៅតាមរោងបាយនានាដែលបម្រុងទុកសម្រាប់ពួកកម្មាភិបាលនៃរបប ។ រឿងរ៉ាវដែលមិនគួរឲ្យជឿទាំងនេះ បានចាប់ផ្តើមផ្សព្វផ្សាយឲ្យដឹងឮនៅក្នុងឱកាសសមិទ្ធិផ្សេងៗនិងកន្លែងជាច្រើនទៀត ។ ឧទាហរណ៍ គេនិយាយថា ពួកយុទ្ធជនដ៏អង់អាចក្លាហាននិងដ៏ខ្លាំងពូកែអស្ចារ្យរបស់យើងបានកម្ទេចរថក្រោះរបស់វៀតណាមដាំងដប់គ្រឿង ហើយថា ពួកគេបានយករថក្រោះទាំងអស់ទៅរំលាយកែច្នៃធ្វើជាចានបាយចានសម្លជាដើម ។

មិនយូរប៉ុន្មាន ការធ្វើពិធីដ៏អឺកអធឹកនេះ ត្រូវបានជំនួសដោយរលកថ្មីមួយនៃការសម្លាប់រង្គាល ។ បើសិនវៀតណាមសម្រេចជោគជ័យវាយចូលជ្រៅក្នុងទឹកដីកម្ពុជាជម្រៅ៣៣គីឡូម៉ែត្រ ហើយប្រជាជនខ្មែររាប់ពាន់នាក់បានឆ្លៀតឱកាសនោះរត់ទៅជ្រកកោននៅក្នុងទឹកដីវៀតណាមគឺមិនអាចថាអ្នកទទួលខុសត្រូវរបស់ភូមិភាគបូព៌ាសុទ្ធតែជាក្រុមមនុស្សក្បត់ឡើយ ។ យ៉ាងហោច នេះគឺជាការដេញរកហេតុផលរបស់គណៈមជ្ឈិមបក្ស ។ មិនយូរប៉ុន្មានក្រោយមក មេបញ្ជាការកងពលលេខ៤បានត្រូវសម្លាប់ដោយសន្តិសុខម្នាក់ដែលឈ្មោះត្រង់នឹង ប៉ុល ពត បាញ់មួយគ្រាប់ចំក្បាល[៤៤] ។

ក្នុងលំនាំផ្សាយដូចសព្វដងរបស់ខ្លួន វិទ្យុក្រុងភ្នំពេញបានប្រកាសរបៀបបញ្ឆៀងថា ភារកិច្ចថ្មីដែលជាកាតព្វកិច្ចសម្រាប់ប្រទេសជាតិ គឺចាប់ពីថ្ងៃនេះតទៅត្រូវការពារ «មន្ទីរក្រសួងនានាដោយកម្ទេចពួកសត្រូវដែលយកកន្លែងទាំងនោះធ្វើជាជម្រករបស់វា ខ្លាំងមួយចំនួនតូចបានលាក់ខ្លួននៅទីនោះតាំងពីយូរមកហើយ

ខ្លះទៀតកំពុងជ្រៀតចូលកាលពីពេលថ្មីៗនេះ» ។ ប្រជាជនកម្ពុជាទាំងអស់ត្រូវតែជម្រុះចេញពីសតិអារម្មណ៍របស់ខ្លួនជាដាច់ខាតនូវកំអែលសង្គមចក្រពត្តិនិយម មូលធននិយមនិងប្រតិកិរិយា...និងកម្ទេចវណ្ណៈកេងប្រវ័ញ្ចទាំងអស់...កម្ចាត់ចោលគំនិតបុគ្គលនិយម សួនតួនិយម និងកសាងប្រទេសដោយល្បឿនលឿនរហ័សជាទីបំផុត»[៤៥] ។ ការដាក់ឲ្យអនុវត្តនយោបាយនេះ មានរួមបញ្ចូលការបន្ថែមពេលម៉ោងធ្វើការ ការបន្ថយរបបអាហារ ការបង្កើនយ៉ាងខ្លាំងក្លាក្នុងការស្វែងរកនិងការកម្ទេចអ្នកដែលមានគំនិតមិនល្អ ។ បណ្ដាខេត្តដែលត្រូវវៀតណាមលុកលុយ បានទទួលរងនូវការបោសសម្អាតនិងសម្លាប់ខ្លាំងជាងគេ ។

អ្នករងគ្រោះដែលមានមុខមុនគេ គឺពួកកម្មាភិបាលខ្មែរក្រហមនិងគ្រួសារទាំងមូលរបស់ពួកគេ ។ ចាប់ផ្ដើមនៅខែមករា ឆ្នាំ១៩៧៨ រលកនៃការបោសសម្អាតថ្មីដែលមានលក្ខណៈសាហាវព្រៃផ្សៃជាពិសេសនោះ បានឡើងដល់កម្រិតខ្ពស់បំផុតនៅខែឧសភា ជាមួយការសម្លាប់រង្គាលយ៉ាងច្រើនដែលមានជាបន្តបន្ទាប់ពីការប៉ុនប៉ងធ្វើបះបោរមិនបានសម្រេចមួយ ។ អ្នកទទួលខុសត្រូវសំខាន់ជាងគេក្នុងយុទ្ធនាការកាប់សម្លាប់នេះ គឺដៃស្ដាំរបស់ ប៉ុល ពត ឈ្មោះ តាម៉ុក ជាបក្ខជនកុម្មុយនីស្ដដើងចាស់ម្នាក់ដែលដាក់សេចក្ដីទុកចិត្តទៅលើមេដឹកនាំកំពូលរបស់ខ្លួនទាំងស្រុង ។ នេះជាគោត្រនាមតែមួយគត់របស់កសិកររូបនេះ ដែលមានរាងកាយស្គមកំព្រឹង, ក្បាលឡើងត្រងោល និងភ្នែកមុត ដែលគ្រប់គ្រាន់ញាំងឲ្យគាត់បង្កើតសប្បដិភ័យបាន ។ កងទ័ពរបស់គាត់ដែលមានប្រភពដើមនៅភូមិភាគនិរតី មានលក្ខណៈលេចធ្លោជាងគេ ដោយសារភាពឃោរឃៅដាច់ឡែកមួយទាំងស្រុង ។ ក្រោមការបង្គាប់បញ្ជារបស់គាត់ កងទ័ពទាំងនេះបានប្រព្រឹត្តអំពើកាប់សម្លាប់យ៉ាងហួសប្រមាណ ជាពិសេសនៅភាគខាងកើតប្រទេស ។ ហើយនេះគ្រាន់តែជាការសាកឲ្យដឹងជាបឋមប៉ុណ្ណោះ ។ ក្នុងលំដាប់ដែលកម្ពុជាប្រជាធិបតេយ្យប្រែក្លាយប្រទេសខ្លួនឲ្យទៅជាជំរំឃុំឃាំងមួយនោះ ការសម្លាប់មនុស្សទាំងហ្វូងបានរាលដាលយ៉ាងឆាប់រហ័សពាសពេញផ្ទៃប្រទេស[៤៦] ។

នៅពេលដែលរបប ប៉ុល ពត រៀបចំខ្លួនយ៉ាងចេញមុខដើម្បីសាកល្បងឲ្យដឹងកម្លាំង ដោយបោសសម្អាតជួរទ័ពរបស់ខ្លួនផ្ទាល់ ដោយពង្រឹងបន្ថែមចំនួនមនុស្សនិងគ្រឿងយុទ្ធោបករណ៍ឲ្យកងទ័ពរបស់ខ្លួននោះ វៀតណាមបែរជាចូលចិត្តរៀបចំអ្វីៗដោយស្ងាត់កំបាំងជាង ។

## ក្រុងហាណូយរៀបចំផែនការផ្សេងៗសម្រាប់ប្រទេសកម្ពុជា

តាំងពីការបង្រួបបង្រួមប្រទេសឡើងវិញ រៀងរាល់រដូវរងា ពួកមេដឹកនាំជាន់ខ្ពស់របស់វៀតណាម បានចាកចេញពីភាពត្រជាក់និងការចុះអ័ព្ទនៅក្រុងហាណូយ ដើម្បីមករកពន្លឺព្រះអាទិត្យនៅភាគខាងត្បូងវិញ គឺនៅជិតនាន់ចូលឆ្នាំថ្មីរបស់វៀតណាម ។ ប្រាកដណាស់ នេះជាឱកាសដ៏ប្រសើរដើម្បីដើរទស្សនកិច្ចតាមរោងចក្រ, សហករណ៍និងបន្ទាយទាហានទាំងឡាយ និងធ្វើបាឋកថាជាសាធារណៈអបអរចំពោះ “ការចាប់ផ្ដើមកសាងលទ្ធិ

សង្គមនិយមដ៏ជាញជ័យ» ។ ប៉ុន្តែ ក្នុងចន្លោះទស្សនកិច្ចពីរ ភាពត្រជាក់ស្រួលនៃធាតុអាកាស បានដរុញឲ្យមានការធ្វើវិស្សមកាលជាធម្មតា ។ ប៉ុន្តែ ឆ្នាំនេះគឺលែងដូចមុនទៀតហើយ ។ នៅភាគខាងត្បូង បានកើតមានព្រឹត្តិការណ៍ធំៗជាច្រើន ដែលពុំមានការទាក់ទងណាមួយនឹងការធ្វើទេសចរណ៍ទេ ។ នៅដំណាច់ខែមករា ឆ្នាំ១៩៧៨ បណ្តាសមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមបានមកជួបគ្នាយ៉ាងស្ងាត់កំបាំងជាថ្មីនៅក្រុងហូជីមិញសម្រាប់ការជួបប្រជុំជាហូរហែមួយ ដើម្បីអនុម័តគម្រោងការផ្សេងៗ ។ ការកាត់ផ្តាច់ចំណងទាក់ទងការទូតដោយខ្មែរក្រហមបានធ្វើឲ្យវៀតណាមទាស់ចិត្តយ៉ាងខ្លាំង ។ ជម្លោះដែលវៀតណាមយកចិត្តទុកដាក់រក្សាទុកជាការសម្ងាត់នោះ នៅពេលនេះបានលេចឡើងនៅលើ«ទំព័រទីមួយ»នៃកាសែតនានាក្នុងពិភពលោកទាំងមូល ។ អាក្រក់ជាងនេះទៅទៀត វៀតណាមត្រូវបានចោទប្រកាន់ជាថ្មីនិងត្រូវសង្ស័យថា មានបំណង«លេបត្របាក់» ប្រទេសជិតខាងខ្លួនដែលទន់ខ្សោយជាង ។ វីរបុរសនៃការប្រយុទ្ធតស៊ូប្រឆាំងនឹងចក្រពត្តិពីម្សិល នៅពេលនេះបានត្រឡប់មកដើរតួជាចក្រពត្តិតូចមួយវិញ ។

ការិយាល័យនយោបាយរបស់បក្សកុម្មុយនីស្តវៀតណាមបានប្រឹងប្រែងរៀបចំតុល្យការនៃការចូលលុកលុយ កាលពីខែធ្នូ ឆ្នាំ១៩៧៧ ។ ខ្មែរក្រហមធ្លាប់ត្រូវវៀតណាមកែតម្រង់ផ្លូវកុំឲ្យដើរខុសដែរ ប៉ុន្តែ ពួកគេពុំដែលបង្ហាញឲ្យឃើញថា មានបំណងកែប្រែឡើយ ។ បរាជ័យផ្នែកយោធារបស់ខ្មែរក្រហមពុំបង្កឲ្យមានរដ្ឋប្រហារដែលសង្ឃឹមដោយវៀតណាម ទាំងក៏ពុំធ្វើឲ្យរដ្ឋអំណាចរបស់គេវិនាសអន្តរាយដែរ ។ មានតែជនជាតិខ្មែរ៦០.០០០នាក់ប៉ុណ្ណោះ ដែលបានសម្រេចចាកចេញពីប្រទេសតាមពីក្រោយកងទ័ពវៀតណាម ។ តាំងពីឆ្នាំ១៩៧៥ មានប្រជាជនកម្ពុជា វៀតណាម និងចិន សរុបទាំងអស់ ៣០០.០០០នាក់ បានរត់គេចចេញពីរបប ប៉ុល ពត ទៅរស់នៅម្ខាងទៀតនៃព្រំដែនប្រទេស ។ ក្រុងហាណូយគ្មានដែលនិយាយមួយម៉ាត់ ប៉ុន្តែពេលនេះជាពេលដែលត្រូវបង្ហាញប្រាប់ពិភពលោកឲ្យដឹងពីការចាកចោលស្រុកទាំងហ្វូងទាំងហ្វូងនេះហើយ ។ វាបង្កជាភស្តុតាងជាក់ស្តែងនៃសេចក្តីឃ្លើនខ្លើម ដែលបំផុសឡើងដោយប្រទេសកម្ពុជារបស់ ប៉ុល ពត ។ ក្រុងហាណូយក៏ទទូចសុំអន្តរាគមន៍ពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនផងដែរ ។

នៅខែមីនា ឆ្នាំ១៩៧៨ ខ្ញុំ(អ្នកនិពន្ធ)មានឱកាសបានទៅទស្សនានៅជំរំបេនសាញ់ ជាកន្លែងដែលពពាក់ពពូនទៅដោយអ្នកភៀសខ្លួនខ្មែរ ដែលមកទើរនៅត្រឹមខេត្តតាយនិញរបស់វៀតណាមនេះ ។ «ជំរំ»នេះគ្មានអ្វីក្រៅតែជាដីវាលស្ងួតហួតហែង និងក្រាលដោយធូលីដ៏ធំល្វឹងល្វើយ និងជាទីដែលប្រមូលផ្តុំទៅដោយកូនខ្ទមធ្វើពីឫស្សីនិងប្រក់ចំបើងឲ្យតែបានៗប៉ុណ្ណោះ ។ ខ្ញុំអាចសន្ទនាគ្នាដោយសេរីជាមួយអ្នកភៀសខ្លួនទាំងនោះ ដែលតាមការពិត ជាតួមនុស្សមានលក្ខណៈពិសេសជាងមុន ។ ការចាប់អារម្មណ៍យ៉ាងច្បាស់លាស់បំផុតរបស់ខ្ញុំ គឺថាការទទួលឲ្យស្នាក់អាស្រ័យរបស់វៀតណាម គឺមានហេតុផលមួយផ្សេងទៀតក្រៅពីហេតុផលសប្បុរសធម៌ ។ ខ្ញុំបានជួបសួរយុវនារីសាស្ត្រាចារ្យម្នាក់ដែលវៀតណាមចាត់ឲ្យទទួលបន្ទុកនិយាយលាតត្រដាងប្រាប់អ្នកសារព័ត៌មានពី

ភាពសាហាវឃោរឃៅរបស់ខ្មែរក្រហមថា ៖ «តើអ្នកត្រឡប់ទៅកម្ពុជាវិញទេ?» ។ នាងបានឆ្លើយជាភាសាបារាំងទាំងមិនប្រាកដក្នុងខ្លួនថា «ចាំ! នៅពេលដែលប្រទេសទាំងមូលត្រូវបានរំដោះ» ។ រំដោះដោយអ្នកណា? វាជាស្ថានភាពលំបាកយ៉ាងជាក់ស្តែង សម្រាប់អ្នកទទួលខុសត្រូវវៀតណាមនៅទីនោះ នៅពេលដែលនាងឆ្លើយថា «ប្រាកដណាស់ដោយកងទ័ពវៀតណាម» ។ វាទំនងជាគូសន្ទនារបស់ខ្ញុំបានទទួលការបង្គាប់បញ្ជាដាច់ខាតមិនឲ្យលើកនិយាយពីអត្ថិភាពនៃចលនាតស៊ូមួយដែលកំពុងតែជ្រើសរើសមនុស្សឲ្យធ្វើទ័ពនៅវៀតណាមនោះឡើយ ។ អ្នកភៀសខ្លួនឯទៀតៗបាននិយាយប្រាប់ខ្ញុំដាច់ឯកជនថា ក្នុងជំរំតាយនិញតែមួយគត់ មានមនុស្សប្រុសស្រីប្រហែល២ពាន់នាក់ត្រូវបានជ្រើសរើសឲ្យចូលធ្វើទ័ពដើម្បីវាយប្រយុទ្ធប្រឆាំងនឹងរបបប៉ុលពត ។ ដូច្នេះ ក្នុងពេលដែលឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួនចាប់ផ្តើមរ៉ាប់រងនូវការផ្គត់ផ្គង់ស្បៀងអាហារដល់អ្នកនៅរស់ក្នុងជំរំនេះ វៀតណាមក៏ទទួលបន្ទុកផ្គត់ផ្គង់ខ្មែរដែលបម្រុងសម្រាប់ការប្រយុទ្ធទៅតាមបែបបទរបស់ខ្លួនដែរ ។ តើមានការរីកលូតលាស់ដូចម្តេចខ្លះតាំងពី ម៉ៅ សេទុង និងទ្រឹស្តីសង្គ្រាមប្រជាជនរបស់គាត់ដែលសំអាងលើការគាំទ្ររបស់ប្រជាជន និងការដាក់ខ្លួនឲ្យស្ថិតនៅក្នុងចំណោមអ្នកទាំងនោះ«ដូចត្រីនៅក្នុងទឹក» ។

ក្នុងឱកាសនៃសម័យប្រជុំរបស់ការិយាល័យនយោបាយនៅខែមករា ឡេ ឌឹកថូ ជា«ដើងចាស់ខាងបញ្ហាកម្ពុជា» បានផ្តើមធ្វើការពិភាក្សាស្តីពីកម្រិតនៃការប្រឈមមុខគ្នានៅពេលខាងមុខឆាប់ៗនេះ ។ ង្វៀន កូថាច់ រដ្ឋមន្ត្រីការបរទេសវៀតណាមបានបញ្ជាក់អះអាងប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា ៖ «ការជួបពិភាក្សាដ៏តឹងតែងដែល ឡេយន់ បានធ្វើនៅក្រុងប៉េកាំងកាលពីខែវិច្ឆិកា ឆ្នាំ១៩៧៧នោះ បានញ៉ាំងឲ្យគាត់ជឿថា ពួកមេដឹកនាំចិនពុំរួញរានឹង«ប្រើប្រាស់ប៉ុលពតប្រឆាំងនឹងយើង»ឡើយ ។ ម្យ៉ាងទៀត ក្រោយពីទស្សនកិច្ចរបស់សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តចិនម្នាក់នៅកម្ពុជាតែពីរសប្តាហ៍ប៉ុណ្ណោះ ការកាត់ផ្តាច់ទំនាក់ទំនងការទូតនេះ បានបង្ខំឲ្យវៀតណាមគ្រោងគិតពីការធ្វើអន្តរាគមន៍ក្នុងទំហំយ៉ាងធំមួយនៅកម្ពុជា ។ តាមមតិរបស់ ថាច់ ដដែលថា ៖ «វាកាន់តែច្បាស់ហើយថា ប្រទេសចិនបានរៀបចំធ្វើសង្គ្រាម ហើយយើងត្រូវតែលើកយកការជ្រើសរើសរបស់យើងមកពិចារណាជាថ្មីដែរ» ។ និយាយម្យ៉ាងទៀតថា យើងត្រូវតែបង្កើនការប្រុងប្រៀបរៀបចំផ្នែកយោធា និងសាកល្បងធ្វើឲ្យមានការខិតចូលជិតគ្នាផ្នែកការទូតជាមួយសហរដ្ឋអាមេរិក និងបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ទៀត ។ ពេលវេលាដែលត្រូវផ្តឹការកៀបសង្កត់ផ្នែកយោធានិងការអំពាវនាវជាចំហឲ្យមានការងើបបះបោរមួយប្រឆាំងនឹង ប៉ុល ពត បានមកដល់ហើយ ។ ដូច្នេះ មួយផ្នែក គឺត្រូវបង្កើតកងទ័ពរបស់ចលនាតស៊ូខ្មែរមួយ ហើយមួយផ្នែកទៀត គឺសាកល្បងធ្វើការផ្តួចផ្តើមគំនិតខាងវិស័យការទូតឡើងវិញ ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយជាសាធារណៈនូវផែនការដំបូងមួយស្តីពីការស្វែងរកដំណោះស្រាយបញ្ហាកម្ពុជាមានបីចំណុច ៖ ការដកកងទ័ពដែលប្រឈមមុខគ្នាចំនួន៥គីឡូម៉ែត្រពីព្រំដែនរៀងខ្លួន ការចុះហត្ថលេខាលើសន្ធិសញ្ញាមិនឈ្លានពានគ្នាមួយ និងការត្រួតពិនិត្យព្រំដែនជាអន្តរជាតិ ។

អ្នកទទួលខុសត្រូវរបស់វៀតណាមម្នាក់ បានទទួលស្គាល់ចំពោះមុខខ្ញុំ(អ្នកនិពន្ធ) ថា ៖ «យើងដឹងថា ខ្មែរក្រហមនឹងមិនយល់ព្រមតាមសំណើទាំងនេះឡើយ ប៉ុន្តែយ៉ាងហោចណាស់ភាពទទួលខុសត្រូវក្នុងការបដិសេធនេះនឹងធ្លាក់ទៅលើពួកគេ» ។ រឿងរ៉ាវនេះបានបើកឱកាសឲ្យមានការឃោសនាជ្រុលហួសហេតុមួយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ បណ្តាប្រទេសក្នុងប្លុកសូវៀតបានយល់ស្របតាមផែនការរបស់វៀតណាមដែលពួកគេវិនិច្ឆ័យថា «សមហេតុសមផល» ។ ដូចការទាយទុកជាមុន ក្រុងភ្នំពេញបានច្រានចោលផែនការនេះរបៀបពេបជ្រាយដោយកត់សម្គាល់ថា នេះគ្រាន់តែជាមធ្យោបាយគំរាមមួយបូកផ្សំនឹងការប៉ុនប៉ងបំភ័ន្តសាធារណមតិអន្តរជាតិប៉ុណ្ណោះ ។

នៅចុងខែមករា ឆ្នាំ១៩៧៨ ឧត្តមសេនីយ៍ ហ្គ្រីហ្គូរីអ៊ីវិច ប៉ាឡូវស្គី អគ្គមេបញ្ជាការកងទ័ពជើងគោករុស្ស៊ីបានធ្វើដំណើរមកកាន់ប្រទេសឡាវតាមយន្តហោះពិសេសផ្ទាល់របស់គាត់ ដើម្បីធ្វើ«ទស្សនកិច្ចជាមិត្តភាព»មួយ ។ នៅវៀងសៃភាគខាងជើងប្រទេស គាត់បានជួបជាមួយរដ្ឋមន្ត្រីការពារប្រទេសវៀតណាម វ៉ី ង្វៀនយ៉ាប ជាសម្ងាត់ដើម្បីពិភាក្សាគ្នាពីបញ្ហាស្ថានការណ៍នៅកម្ពុជា ។ តាមអ្នកមាត់រអិលខ្លះថា ការឲ្យយោបល់របស់ ប៉ាឡូវស្គី ចំពោះវៀតណាមគឺ «រៀបចំពលប្រហារក្រុងប្រាគជាថ្មី»* ។ ឧត្តមសេនីយ៍ ប៉ាឡូវស្គី យល់ឃើញច្បាស់ណាស់ថា ពួកចិនគ្មានលទ្ធភាពមកជួយសម្ពន្ធ័មិត្តខ្មែររបស់ខ្លួនទេ ។ ដូច្នេះ វាអាចឲ្យវៀតណាមបើករថក្រោះរបស់ខ្លួនរហូតមកដល់ភ្នំពេញ និងទម្លាក់ ប៉ុល ពត ពីតំណែងបានដូចទម្លាក់ អាឡិចសង់ដ័រ ឌុបសិច នៅឆ្នាំ១៩៦៨ដែរ ។ ប៉ុន្តែ យ៉ាប មិនព្រមស្តាប់ការណែនាំនេះឡើយ ។ គាត់បានឆ្លើយតបវិញថា ជនជាតិវៀតណាមនឹងដោះស្រាយបញ្ហានេះ«តាមរបៀប»របស់ខ្លួន ។

## កងទ័ពមួយដែលចេញពីភាពមិនច្បាស់លាស់

នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ ការិយាល័យនយោបាយវៀតណាមបានរួមប្រជុំគ្នាជាថ្មីនៅជាយក្រុងហូជីមិញ ។ សម័យប្រជុំបានប្រព្រឹត្តទៅក្នុងអតីតសាលាបណ្តុះបណ្តាលប៉ូលិសរបស់ ធីវ (បច្ចុប្បន្នគេហៅសាលា ធូឌឹក) ដែលស្ថិតនៅឆ្ងាយពីទីប្រជុំជន ។ ពួកមេដឹកនាំវៀតណាមបានសិក្សាគម្រោងការមួយចប់ចុងចប់ដើមក្នុងការបង្កើតបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយ និងការរៀបចំចាត់តាំងចលនាតស៊ូមួយ ។ ក្នុងចន្លោះពេលនោះ ឡេ យន់ និង ឡេ ឌឹកថូ បានជួបធ្វើការពិភាក្សាគ្នាជាបន្តបន្ទាប់ ដំបូងជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលនិរទេសខ្លួនទៅវៀតណាមខាងជើងតាំងពីឆ្នាំ១៩៥៤ បន្ទាប់មកជាមួយអ្នកដែលរួចរស់ជីវិតខ្លះ ពីការបោសសំអាតរបស់ ប៉ុល ពត[៤៧] ។

ក្នុងចំណោមអាណិកជនខ្មែរប្រហែល១.០០០នាក់ ដែលកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ១៩៥៤ គ្រោងទុកឲ្យទៅតាំងនៅក្រុងហាណូយនោះ គឺមានតិចតួចណាស់ដែលដំអក់នៅវៀតណាមខាងជើង ។ ភាគច្រើន

*បានត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីចូលរួមក្នុងការតស៊ូប្រឆាំងអាមេរិកាំង ។ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលនៅរស់រានជីវិតពីឥទ្ធិពលនៃសង្រ្គាមផង និងការបោសសម្អាតរបស់ពួក ប៉ុល ពត ផង ។ ដូច្នេះ អ្នកសូម ចូលខ្លួនក្នុងគណៈដឹកនាំបក្សថ្មីបានត្រឹមបង្កជាក្រុមយ៉ាងតូចមួយដែលខ្វល់ខ្វាយជាបឋម គឺធ្វើយ៉ាងណាឲ្យតែខ្លួន បានរស់សិនប៉ុណ្ណោះ ។ ក្នុងចំណោមនោះមាន ប៉ែន សុវណ្ណ អាយុ៤០ឆ្នាំធ្លាប់ស្ថិតនៅវៀតណាមតាំងពីឆ្នាំ ១៩៥៤ និងត្រូវបានបណ្តុះបណ្តាលក្នុងសាលាបក្សនិងសាលាយោធាជាច្រើនកន្លែង ហើយជាមេបញ្ជាការម្នាក់ ក្នុងកងទ័ពរបស់វៀតណាម ។ ចាន់ស៊ី និង ខាង សារិន និងយោធាជាច្រើននាក់ទៀត ដែលមានឋានន្តរសក្តិស្មើ គ្នា ។ តាំង សារីម ប្រធានបុគ្គលិកនៅអណ្តូងរ៉ែធ្យូងថ្មហុងហ្គៃ ។ កែវ ចិន្តា អ្នកនិយាយព័ត៌មានជាភាសាខ្មែរតាម វិទ្យុហាណូយ ។ ជា សុទ្ធ អ្នកនិពន្ធនៅទីភ្នាក់ងារព័ត៌មានវៀតណាម ។ ក្នុងចំណោមអ្នករត់គេចខ្លួនថ្មីៗក៏គួររៀប រាប់បញ្ចូលកម្មាភិបាលនយោបាយខ្លះដូចជា ហែម សាមិន, យស់ ប៉ោ, ហ៊ុន សែន និង ប៊ូ ថង ផងដែរ ។*

*ត្រូវបញ្ចេញភ្លាមៗពីកន្លែងធ្វើការដ៏គោកយ៉ាកនិងជំរំជនភៀសខ្លួន ជាទីដែលពួកគេធុញថប់ក្នុងការរង់ចាំ មនុស្សទាំងនេះបានត្រូវគេនាំទៅបង្ហាញខ្លួននៅចំពោះមុខពួកមេដឹកនាំវៀតណាមសំខាន់ៗ ដែលរហូតមកទល់នឹង ពេលនេះ ពួកគេធ្លាប់ស្គាល់តែតាមរយៈរូបថតប៉ុណ្ណោះ ។ តាមការប្រែប្រួលដោយចៃដន្យមួយ ពួកគេត្រូវបាន ហៅឲ្យចូលខ្លួនមកទទួលធ្វើជាមេដឹកនាំថ្មីមួយរបស់កម្ពុជា ដែលស្ថិតក្នុងភាពមិនច្បាស់លាស់នៃប្រវត្តិសាស្ត្រនៅ ឡើយ ។ ឡេ ឌឹកថូ បានប្រាប់ព័ត៌មានឲ្យពួកគេដឹងថា ពេលវេលាបានមកដល់ហើយ ដើម្បីរឹតចំណងសហប្រតិបត្តិ ការផ្សេងៗឡើងវិញ សម្រាប់ជនកុម្មុយនីស្តទាំងអស់នៃប្រទេសទាំងពីរ ។ ម្នាក់ៗត្រូវយកចិត្តទុកដាក់ពង្រីក របនាសម្ពន្ធ័ខាងយោធា និងនយោបាយសម្រាប់អនាគតចលនាតស៊ូមួយឲ្យកាន់តែរីកធំធាត់ឡើង ។*

*ដោយជួបមេដឹកនាំកម្ពុជាម្នាក់ ក្នុងចំណោមមេដឹកនាំទាំងនោះក្នុងឱកាសនៃទស្សនកិច្ចរបស់ខ្ញុំ (អ្នកនិពន្ធ) នៅជំរំបេនសាញ់ ខ្ញុំពុំដឹងពីតួនាទីដែលគាត់ត្រូវសម្តែងក្នុងយុទ្ធសាស្ត្ររបស់វៀតណាមភ្លាមៗបានទេ ។ នៅថ្ងៃ នោះ អេគីបទូរទស្សន៍មួយក្រុមក៏ស្ថិតនៅទីនោះដែរ ។ នៅមុខកាមេរ៉ាជាច្រើន ស្ត្រីម្នាក់បានរៀបរាប់ពីជីវភាព ប្រចាំថ្ងៃនៅកម្ពុជា ក្រោមរបប ប៉ុល ពត ។ អ្នកភៀសខ្លួនមួយហ្វូងបានទៅចោមរោមជុំវិញនាងយ៉ាងណែន ។ ខ្ញុំបានឆ្លៀតឱកាសនោះដើម្បីគេចខ្លួនចេញឆ្ងាយបន្តិចពីគេ ហើយដោយរួចផុតពីមគ្គុទ្ទេសក៍នាំផ្លូវរបស់ខ្ញុំ ខ្ញុំបាន ផ្តើមធ្វើការសន្ទនាជាមួយមនុស្សជាច្រើនតាមតែប្រទះ ។ ដូច្នេះខ្ញុំមានឱកាសបានជួបនិយាយជាមួយជនម្នាក់ ឈ្មោះ ថុង ប៉ាក់ ជាអតីតបុគ្គលិករដ្ឋការនៃរបប លន់ នល់ ដែលខ្សឹបដាក់ត្រចៀកខ្ញុំថា រៀងរាល់យប់អ្នកភៀស ខ្លួនបានត្រូវបង្ខំឲ្យប្រជុំរៀនសូត្រនយោបាយដើម្បីរៀបចំការប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម ។ ភ្លាមនោះ គាត់ បានចង្អុលប្រាប់ខ្ញុំឲ្យឃើញមនុស្សទាបកន្ទៀម្នាក់ពាក់មួកកងទ័ពវៀតណាមជំនាន់អាណានិគម ហើយស្រែកថា «នុ៎ះ! លោក ឌុក គឺគាត់នេះហើយ ដែលជាអ្នកបើកការប្រជុំរៀនសូត្រ!» ។*

*អាវសឺមីពណ៌សដៃខ្លី ខោកាគីជើងវែង និងស្បែកជើងសង្រ្រែកកៅស៊ូ នេះឯងគឺជាឯកសណ្ឋានរបស់*

“លោកឌុក” ។ មុខមូលរបស់គាត់មានលក្ខណៈផ្ទុយនឹងការមិនទុកចិត្តមួយដ៏ជាក់លាក់ នៅពេលដែលខ្ញុំសាកល្បងឲ្យគាត់រៀបរាប់ពីប្រវត្តិរបស់គាត់ ។ គាត់មិនដឹងរឿងច្រើននូវអ្វីដែលគាត់អាចដំណាលប្រាប់ជនបរទេសម្នាក់ទេ ។ ទោះបីជារហស្សនាមរបស់គាត់ និងរបៀបស្លៀកពាក់មានបែបផែនជាវៀតណាមក៏ដោយ ក៏គាត់គឺជាខ្មែរពូជល្អម្នាក់ដែរ ។ ដូចសមាជិកបក្សប្រជាជនបដិវត្តន៍កម្ពុជារាប់ពាន់នាក់ផ្សេងទៀត ឌុក បានស្ថិតនៅក្រុងហាណូយតាំងពីឆ្នាំ១៩៥៤ តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវតម្រូវ ។ នៅឆ្នាំ១៩៧១ គាត់បានមកចូលរួមក្នុងចលនាតស៊ូប្រឆាំង លន់ នល់ ប៉ុន្តែបីឆ្នាំក្រោយមក គាត់ត្រូវត្រឡប់ទៅប្រទេសវៀតណាមវិញ ទាំងប្រញាប់ប្រញាល់ដើម្បីគេចពីការបង្ក្រាបរបស់ខ្មែរក្រហម ។ គាត់បានរស់នៅបីឆ្នាំបន្ទាប់ក្រោយមកទៀត ក្នុងភូមិមួយនៅដែនដីសណ្តទន្លេមេគង្គក្នុងឋានៈជាកម្មករកសិកម្មម្នាក់ ។ បន្ទាប់ពីនោះ គាត់បានចូលខ្លួនជាថ្មី តាមការអំពាវនាវរបស់បដិវត្តន៍ ។ អំណឹះតទៅ គាត់បានត្រូវចាត់ឲ្យទទួលបន្ទុកជ្រើសរើសនិងបង្ហាត់បង្រៀនអនាគតកម្មាភិបាលរបស់ចលនាតស៊ូក្នុងផ្ទៃនៃសហគមន៍ជនភៀសខ្លួនខ្មែរនៅទីនោះ ។ បីឆ្នាំក្រោយមកទៀត ខ្ញុំ(អ្នកនិពន្ធ) បានធ្វើដំណើរទៅកាន់ក្រុងភ្នំពេញហើយបានស៊ើបដឹងថា លោក ឌុក និងលោក យស់ ប៉ោ មេដឹកនាំរណសិរ្សសង្គ្រោះជាតិកម្ពុជាគឺជាមនុស្សតែមួយ ។ ដោយគ្មានប្រាថ្នានឹងទៅធ្វើស្រែចម្ការនៅដែនដីសណ្តទន្លេមេគង្គ គាត់បែរជាទៅរស់នៅក្រុងហាណូយបីឆ្នាំ មុននឹងមកធ្វើជាអ្នកចាត់ចែងការងារនៅជំរំជនភៀសខ្លួននេះ ។

បេន សាញ់ ពុំមែនជាករណីមួយដាច់ដោយឡែកពីគេទេ ។ នៅភាគខាងត្បូងវៀតណាម តាំងពីមានការកាត់ផ្តាច់ចំណងការទូតមក ជំរំដែលមានប្រភេទដូចគ្នាជាច្រើនបានរីកដុះដាលស្ទើរតែគ្រប់កន្លែង ថ្វីបើស្ថិតក្នុងលក្ខណៈសម្ងាត់បំផុតក៏ដោយ ។ ពួកមេដឹកនាំក្រុងហាណូយបានចាប់ផ្តើមផ្តល់លក្ខណៈសម្បត្តិដោយឡែកសម្រាប់អ្នកទាំងនោះ គឺការបង្កើតកងទ័ពព្រៃមួយ ។ វាហាក់ដូចជាធ្វើឲ្យសប្បាយដែលកត់សម្គាល់ថា ដើម្បីធ្វើឲ្យសម្រេចនូវ“ការរំដោះ”ប្រទេសកម្ពុជាជាលើកទីពីរ ពួកគេបែរជាប្រើអ្វីៗទាំងអស់ដែលបណ្តាក្លូសត្រូវកាលពីពេលថ្មីៗរបស់គេ-សហរដ្ឋអាមេរិកនិងរបបរបស់ ធីវ-បោះបង់ចោលទៅវិញ ។ ជាឧទាហរណ៍ ក្នុងតំបន់ជាយក្រុងហូជីមិញ អតីតមជ្ឈមណ្ឌលបណ្តុះបណ្តាលប៉ូលិសរបស់របប ធីវ ឈ្មោះ ធូ ឌឹក ដែលព័ទ្ធជុំវិញដោយរបងលួសបន្លាខ្ពស់ៗបានត្រូវបក្សកុម្មុយនីស្តខ្មែរដែលទើបបង្កើតថ្មីៗយកទៅប្រើការ ហើយដែលអត្ថិភាពស្ថិតក្នុងភាពសម្ងាត់នៅឡើយ ។ អតីតមូលដ្ឋានអាមេរិកាំងនៅ ស៊ិន ឡុក និង ឡុង យ៉ាវ ក្បែរទីក្រុងហូជីមិញ ព្រមទាំងវាលចំណតឧទ្ធម្ភាគចក្រយោធានៅ វី ថាញ់ ក្នុងដែនដីសណ្តទន្លេមេគង្គ ត្រូវបានគេបញ្ចូលទៅក្នុងការត្រៀមបម្រុងផ្សេងៗសម្រាប់ប្រើដោយលួចលាក់ដើម្បីប្រឆាំងនឹង ប៉ុល ពត[៤៨] ។ ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ កងពលតូចទី១ដែលជាកងទ័ពខ្មែរបែកចេញពីបក្ខពួក ត្រូវបានប្រសិទ្ធិនាមជាផ្លូវការក្នុងឱកាសនៃពិធីបុណ្យមួយ ដែលហាមមិនឲ្យអ្នកក្រៅចូល[៤៩] ។ នៅចុងឆ្នាំនោះ កងពលតូចជាច្រើនផ្សេងទៀត -ដែលកម្លាំងពិតប្រាកដស្មើនឹងមួយកងវរសេនាតូច- សុទ្ធតែត្រៀមលក្ខណៈរួចជាស្រេចក្នុងការចូលរួមវាយលុករបស់វៀតណាមនៅប្រទេសកម្ពុជា ។

## ការប្រយុទ្ធដែលមិនពិត, ការសម្លាប់រង្គាលដែលពិតប្រាកដ

*ក្នុងពេលជាមួយគ្នានោះ ការឃោសនាបានចាប់ផ្ដើមមានសន្ទុះយ៉ាងខ្លាំងក្លា ។ កាសែតនានា និងវិទ្យុបានផ្សព្វផ្សាយនូវបទយកព័ត៌មានយ៉ាងច្រើនស្ដីពីអំពើសាហាវយង់ឃ្នងរបស់ខ្មែរក្រហម ។ ទ្វារចេញចូលរបស់ប្រទេសបានបើកសម្រាប់អ្នកកាសែតបរទេស ។ ក្នុងអំឡុងពីរឆ្នាំកន្លងទៅ គឺតាំងពីការចាកចេញរបស់ខ្ញុំពីទីក្រុងព្រៃនគរ ខ្ញុំត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរទៅប្រទេសវៀតណាមមិនលើសពីពីរដងឡើយ ។ ប៉ុន្តែ នេះពុំមែនមកពីខ្ញុំមិនសាកល្បងនោះទេ ។ ខ្ញុំបានត្រូវវៀតណាមអញ្ជើញជាថ្មី ទុកណាជាដំណើរចុងក្រោយរបស់ខ្ញុំមានតាំងពីបីខែមុនក៏ដោយ ។ ខ្ញុំបានទៅដល់ទីក្រុងហាណូយនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៨ ។ អ្នកទទួលខុសត្រូវវៀតណាមបានធ្វើឲ្យខ្ញុំដឹងយ៉ាងរហ័សថា ដំណើររបស់ខ្ញុំនឹងមិនមានគោលដៅអ្វីផ្សេងក្រៅពីឲ្យខ្ញុំរាយការណ៍ពីបញ្ហារបស់កម្ពុជានោះទេ ។ ពុំមានការជួបអ្នកទទួលខុសត្រូវនៃគណៈកម្មការផែនការ និងទៅទស្សនាសហករណ៍មួយនៅដែនដីសណ្ដទន្លេក្រហមដូចដែលខ្ញុំមានបំណងទេ ។ ផាំ វ៉ាន់គួង ជាអ្នកមានបេសកកម្មនាំផ្លូវអ្នកកាសែតដែលធ្វើដំណើរមកវៀតណាមរយៈពេលខ្លី បាននិយាយប្រាប់ខ្ញុំថា ៖ «លោកគោងតែយល់ឲ្យបានច្បាស់ពីដើមហេតុនៃការទាស់ទែងគ្នារបស់យើង ជាមួយប្រទេសកម្ពុជា» ។*

*ក្នុងសង្គ្រាមឃោសនាពិតប្រាកដនេះ អ្នកអុជកាំជ្រួចដែលទទួលបន្ទុកបញ្ជាបាញ់ឲ្យស្រុះគ្នាគឺអនុរដ្ឋមន្ត្រីការបរទេស វ៉ី ដុងយ៉ាង ខ្លួនឯងផ្ទាល់ ។ នៅថ្ងៃទី៥ ខែមីនា សហភាគរៈ (អ្នកមានវិជ្ជាជីវៈដូចគ្នា) អ៊ីរ៉ុបពីររូប- រ៉ូឡង់ ព្យែរប៉ារ៉ាំងហ្គូ នៃកាសែតឡឺម៉ុង និង កាវ៉ែល វ៉ាន់ វ៉ុលហ្វិរេន នៃកាសែត NRC Handelsblad និងរូបខ្ញុំផ្ទាល់ត្រូវបានអញ្ជើញជាឯកជនឲ្យទៅចូលរួមពិសាអាហារពេលល្ងាចមួយព្រមទាំងផ្ដល់ព័ត៌មានផ្សេងៗផង ។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកឃើញអនុស្សាវរីយ៍ដ៏ជាក់លាក់មួយ ៖ ដំណើរកម្សាន្តរបស់ខ្ញុំនាវេលាព្រឹកថ្ងៃសៅរ៍នៅខេមដេវីសក្នុងមូលដ្ឋានអាកាសតាន់សឺនញឹកនាទីក្រុងព្រៃនគរ កាលពីឆ្នាំ១៩៧៤-៧៥ ។ ខ្ញុំបានចូលរួមមិនដែលខានក្នុងសន្និសីទកាសែតជាច្រើនលើក ដែលរៀបចំដោយវរសេនីយ៍ឯកក្នុងសម្លៀកបំពាក់ពណ៌បៃតងម្នាក់ នៅក្នុងអគាររបស់គណៈប្រតិភូវៀតកុងដែលមានការយាមការពារយ៉ាងហ្មត់ចត់ ។ ពិតហើយ នេះជារូបភាពក្រៅបញ្ចោតមួយ ៖ គេមិនអាចអះអាងថា គណៈប្រតិភូនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន (វៀតកុង) បានជ្រោមជ្រែងយ៉ាងខ្លាំងដល់ការការពារបទឈប់បាញ់គ្នា ដូចដែលកិច្ចព្រមព្រៀងក្រុងប៉ារីសតម្រូវឲ្យខ្លួនគោរពឡើយ ។ យ៉ាងហោច ការជួបគ្នានេះនៅមុខពែងកាហ្វេមួយប្រភេសជ្ជៈថ្មីអាចឲ្យអ្នកសារព័ត៌មានរក្សាការទាក់ទងជាមួយផ្នែកម្ខាងទៀតដែរ ។ នៅពេលនោះគេបានបម្រើយើងនូវស្រា Lua moi ជាស្រាខ្លាំងរបស់វៀតណាមធ្វើពីអង្ករដែលលោកវរសេនីយ៍ឯក យ៉ាង គូសន្ទនារបស់យើងហាក់ដូចជាចូលចិត្តណាស់ ។ នៅយប់នោះលោក យ៉ាង ដដែលនេះនឹងធ្វើខ្លួនជាភ្ញៀវរបស់ខ្ញុំក្នុងការបរិភោគអាហារពេលល្ងាចម្ដង ។*

*រូបរាងរបស់ យ៉ាង ហាក់ដូចជាពុំប្រែប្រួលសោះ ។ ថ្ពាល់របស់គាត់នៅតែដដែល ភ្នែកមូលតូចៗ និងភ្លឺ*

ចិញ្ចៀចដដែល ។ ខ្លួនប្រាណរាងស្តើងជាងមុនបន្តិច ប្រហែលមកពីគាត់ពាក់អាវសដៃខ្លីហើយមើលទៅ និងមានអាការៈស្ងប់ស្ងៀមជាងមុន ។ គាត់ចេះនិយាយភាសាបារាំង, អង់គ្លេស និងអេស្ប៉ាញ៉ុលយ៉ាងស្ទាត់ ព្រោះកាលពីដើមគាត់ធ្លាប់បានធ្វើជាឯកអគ្គរដ្ឋទូតរបស់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នប្រចាំប្រទេសគុយបា ។ បើទុកជារូបសម្រស់គាត់មិនអាចប្រកែកបានក៏ដោយ ក៏គាត់ជាជនបដិវត្តន៍ដែលមានអំណាចម្នាក់ ។ ប្រាកដណាស់ថា គោលបំណងរបស់គាត់គឺគ្មានអ្វីក្រៅតែពីញុំាងឲ្យ“បណ្តាមិត្តចាស់សម័យនៅ តាន់ សឺនញឹក” ជឿពីភាពត្រឹមត្រូវនៃបុព្វហេតុរបស់វៀតណាមប៉ុណ្ណោះ ។ ការនិយាយម្នាក់ឯងរបស់គាត់មានថិរវេលាបីម៉ោងដែលស្ទើរតែគ្មានកាត់ជាអន្លើដោយការកត់សម្គាល់ផ្សេងៗ ដែលធ្វើឲ្យខូលចិត្តស្តីពីការប្រយុទ្ធរវាងបងប្អូនឯងនិងការចំអកបញ្ឈឺចិត្តខ្លាំងៗចំពោះ ប៉ុល ពត និងពួកយុទ្ធិកជនរបស់គាត់ (ប៉ុល ពត) នៅបរទេសឡើយ ។ ការបកស្រាយរបស់ យ៉ាង ពីការប្រយុទ្ធគ្នាពោរពេញទៅដោយការទម្លាយប្រាប់រឿងស្ងាត់កំបាំងជាច្រើន ។

វាជាហេតុការណ៍មិនធ្លាប់មានពីមុន ដែលដំណើររបស់យើងមិនស្ថិតនៅក្រោមការកំហិតណាមួយ ។ យើងមានសេរីភាពធ្វើអ្វីតាមចិត្ត ។ ប៊ួយ ហ៊ុយញ៉ាន ជាអ្នកទទួលខុសត្រូវទំនាក់ទំនងជាមួយអ្នកកាសែតបរទេសបានបញ្ជាក់ប្រាប់យើងថា “លោកអាចធ្វើដំណើរទៅទីណាស្រេចតែចិត្តលោកនៅតាមបណ្តោយព្រំដែនកម្ពុជារហូតដល់អ្វីដែលជាការយល់ឃើញរបស់លោកត្រូវបានបំពេញតាមសេចក្តីត្រូវការ” ។ ការផ្តល់នូវសេរីភាពមួយដូច្នេះ គឺអាចមានដោយសារតែទទួលបានការអនុញ្ញាតបណ្តាអង្គការថ្នាក់លើរបស់របបនេះប៉ុណ្ណោះ ។ គេត្រូវតែដណ្តើមយកឈ្នះលើការមិនព្រមជឿអ្វីៗទាំងអស់របស់អ្នកកាសែត ៖ នៅលើសមរភូមិ ការពិតនឹងបង្ហាញថាវៀតណាមពុំមានអ្វីដែលត្រូវលាក់បាំងទាល់តែសោះ ព្រោះពួកគេជាអ្នករងគ្រោះពីការឈ្លានពានរបស់ខ្មែរក្រហម ហើយថាគោលបំណងវាតទីនិយមរបស់ពួកគេគ្រាន់តែជារឿងនិទានដែលប្រឌិតឡើងដោយ ប៉ុល ពត ប៉ុណ្ណោះ ។

ពិតណាស់ តាយនិញ គឺជាចំណុចក្តៅមួយ ។ ទីរួមខេត្តមានដីករណ្តៅយ៉ាងច្រើនដូចរន្ធបាយខ្មុំ ។ នៅគ្រប់ទីកន្លែងមានសុទ្ធតែជម្រកក្រោមដី ៖ ក្រោមចិញ្ចើមថ្នល់, ក្បែរអគារទាំងឡាយរបស់រដ្ឋាភិបាល និងក្នុងសួនច្បារភូមិគ្រឹះនានា ។ នៅភាគខាងជើងទីក្រុងចម្ងាយពីរបីគីឡូម៉ែត្រដែលជាព្រំដែនរបស់កម្ពុជាគឺជាភូមិ តាន់ ឡាប (Tan Lap) ៖ ខ្ទមស្លឹកពីរជួរ ធ្វើពីភក់ហាលស្ងួត តាមបណ្តោយផ្លូវរដិបរដុបមួយ ។ កាលពីប្រាំមួយខែមុនខ្មែរក្រហមបានបន្សល់ទុកនៅទីនេះត្រឹមតែគេហដ្ឋានបាក់បែកមួយគំនរប៉ុណ្ណោះ ។ គឺនៅក្នុងភូមិនេះហើយដែលហ្គីយ៉ូរី ធ្លាប់បានថតរូបស្តីពីការសម្លាប់រង្គាលដ៏ល្បីល្បាញរបស់គាត់ មុននឹងត្រូវគេដកហូតយក ។ ចំណែកយើងវិញ យើងគ្មានលំបាកបន្តិចសោះក្នុងការជួបសំណេះសំណាលជាមួយអ្នកនៅរស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នកនៅរស់រានមានជីវិតដ៏កម្រជាច្រើនគឺស្ត្រីវ័យក្មេងម្នាក់ឈ្មោះ ង្វៀន ធីគូ ។ នាងយំអណ្តឺតអណ្តកបណ្តើររៀបរាប់ប្រាប់យើងពីការសម្លាប់ប្រហារឥតអាសូរបណ្តើរ ។ ប្អូនប្រុសនាង និងនាងដែលរស់រានមានជីវិតនេះ

*គឺដោយសារតែធ្វើពុតជាស្លាប់ក្រោមសាកសពមួយគំនរប៉ុណ្ណោះ ។*

*ភូមិនានាត្រូវបំផ្លិចបំផ្លាញ, ស្រែទាំងឡាយត្រូវបោះបង់ចោល, ផ្លូវខ្មោចមានរាប់រយ ៖ ទស្សនីយភាពរបៀបដូចគ្នានេះ បានកើតមានម្តងហើយម្តងទៀតនៅតាមបណ្តោយព្រំដែន ។ យើងអាចស្តាប់ឮពីមាត់ពួកអ្នកនៅរស់រានមានជីវិតផ្ទាល់នូវការនិទានពីអំពើសាហាវយង់ឃ្នងផ្សេងៗ ដែលប្រព្រឹត្តដោយឯកឯង របៀបដូចសម័យយុគកណ្តាលអឺចឹង ។ ការសង្ស័យប្រហែលលែងមានទៀតហើយ ចំពោះតថភាពនៃការប្រយុទ្ធគ្នាគ្មានអាណិតអាសូរនេះ ដែលបិទបាំងភ្នែកពិភពលោកយូរយារមកហើយ ។ ភ័ស្តុតាងផ្សេងៗដែលធ្វើឲ្យអំពល់គឺនៅទីនោះ ។*

*ប៉ុន្តែ គ្មានអ្វីអាចឲ្យសន្និដ្ឋានពីការវាយប្រហារថ្មីៗរបស់កម្ពុជាដូចគ្នានឹងការវាយប្រហារកាលពីឆ្នាំមុនឡើយ ។ តាមការសន្និដ្ឋានរបស់ខ្ញុំគឺថា វៀតណាមបានផ្តួចផ្តើមគំនិតឡើងវិញមុនគេ ។ តើត្រូវពន្យល់ផ្សេងពីនេះថា គេអាចធ្វើដំណើរដោយងាយស្រួលទៅកាន់តំបន់ព្រំដែនដោយរបៀបណា? ។ ខ្ញុំបានសម្គាល់ឃើញស្លាកស្នាមឆ្លងកាត់ច្បាស់ក្រឡែតរបស់រថក្រោះមួយខ្សែលើផ្លូវហុយទ្រលោមមួយ នៅចន្លោះតាយនិញនិងព្រំដែន ព្រមទាំងស្នាមរថយន្តយោធាមួយគ្រឿងផ្ទុកពេញទៅដោយស្បៃ ដែលតាមខ្ញុំស្មានគឺ យកទៅផ្គត់ផ្គង់ឲ្យកងទ័ព ។ ប្រាកដណាស់ នៅទីនោះដែលស្ថានភាពភូមិសាស្ត្រអនុញ្ញាត កងទ័ពរបស់វៀតណាម បានរុញច្រានកម្លាំងទ័ព ជាខ្សែក្រវាត់ការពាររបស់ខ្លួនទៅក្នុងប្រទេសកម្ពុជា ។ វៀតណាមដឹងខ្លួនថា ត្រូវតែធ្វើជាម្ចាស់លើស្ថានការណ៍យោធា ហើយពួកគេមិនរួញរាក្នុងការនាំអ្នកកាសែតបរទេសដែលព្រួយបារម្ភពីសន្តិសុខរបស់គេផ្ទាល់ ទៅកាន់តំបន់ព្រំដែន ដើម្បីបង្ហាញប្រាប់ពីស្លាកស្នាមនៃការបំផ្លិចបំផ្លាញដែលបង្កឡើងដោយខ្មែរក្រហមឡើយ ។*

*មិនយូរប៉ុន្មាន ខ្ញុំបានទទួលការអះអាងបញ្ជាក់ពីគោលបំណងផ្សេងៗរបស់វៀតណាម ក្នុងឱកាសនៃទស្សនកិច្ចរបស់យើងនៅភូមិអានភូ ក្បែរចូវដុក ។ នៅទីនោះមានភ័ស្តុតាង ជាក់ស្តែងជាច្រើនដែលជាអំពើវាយប្រហាររបស់កងទ័ពថ្មើរជើងនិងកងកាំភ្លើងធំខ្មែរក្រហមកាលពីពេលថ្មីៗ ។ គំនរផ្ទះបាក់បែកនៅហុយផ្សែងនៅឡើយ ។ អ្នកភូមិកំពុងប្រញាប់ប្រញាល់ប្រមូលទ្រព្យសម្បត្តិរបស់ពួកគេទុកមួយដុំ មុននឹងដឹកជញ្ជូនទៅដាក់ក្នុងទីជម្រកនានាតាមតែប្រទះ ។ ក៏ប៉ុន្តែ គេដឹងយ៉ាងច្បាស់ថា អ្នកកាសែតនៃសារព័ត៌មានរបស់វណ្ណៈគហបតីតែងតែឃ្លាំមើលអ្វីដែលនាំឲ្យចាប់អារម្មណ៍ខ្លាំងជានិច្ច ។ ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះក្នុងចំណោមគ្នាយើងទំនងជាមិនជឿដាច់ខាតថា គ្រាប់កាំភ្លើងធំដែលយើងឮសូរឆ្លាចពីលើក្បាលរបស់យើងត្រូវបាញ់ចេញមកពីទីតាំងរបស់ខ្មែរក្រហមទេ ។ បន្ទាប់ពីមួយរយៈខ្លី អ្នកបកប្រែរបស់ខ្ញុំ ហ៊ុយ វ៉ាន់តាំ បានឲ្យយោបល់ថា ៖ "តោះយើងចេញទៅខាងក្រៅភូមិវិញ អស់លោកប្រហែលជាអាចមើលឃើញការប្រយុទ្ធគ្នាពីចម្ងាយ" ។ គេបានផ្តល់ឲ្យយើងនូវកែវយិតមួយដែលណែនាំឲ្យយើងមើលទៅកន្លែងដើមឈើមួយដើមនៅម្ខាងទៀតនៃវាលស្រែដែលកំណត់ព្រំដែនជាមួយប្រទេសកម្ពុជា ។ កងទ័ពវៀតណាមម្នាក់នៃក្រុមអ្នកអមការពាររបស់យើងបានឈរនៅ*

ក្បែរឫស្សីមួយគុម្ព ។ គាត់មានស្ពាយវិទ្យុទាក់ទងមួយនៅលើខ្នងផង ។ ដោយចាប់កាន់ក្បាលមីក្រូ គាត់ស្រែកឡូឡាមិនដឹងរឿងអ្វីខ្លះទេ ព្រោះយើងស្តាប់ពុំយល់ ។ នៅក្បែរយើង នាយទាហានម្នាក់បានស្រែកចំទាលថា ៖ «ប្រញាប់ចូលលេណដ្ឋានភ្លាម!» ។ ពីរបីវិនាទីក្រោយ សំឡេងនៃការបាញ់ផ្លោងគ្រាប់កាំភ្លើងធំមួយបានលាន់ឮមកដល់ភូមិដែលស្ថិតនៅពីក្រោយយើងអមទៅដោយសំឡេងលាន់សូរផ្ទុះ ។ គ្រាប់កាំភ្លើងបានផ្ទុះនៅក្នុងសំណុំដើមឈើដែលយើងកំពុងតែសង្កេតពិនិត្យ ។ នាយទាហានដែលមានសំឡេងល្អើយរហិតរហៃ បានប្រកាសដោយរត់រកជម្រកខ្លួនឯងថា ៖ «ខ្មែរក្រហមវាយប្រហារហើយ!» ។ យើងឮការបាញ់កាំភ្លើងត្បាល់ខ្លះ និងការបាញ់ប្រាវៗនៃអាវុធស្វ័យប្រវត្តិយ៉ាងច្រើន ។ ជាថ្មីម្តងទៀត គេបានសុំឲ្យយើងចូលទីជម្រក ។ គ្រាប់កាំភ្លើងធំមួយគ្រាប់ទៀតបានហោះលាន់សូរផ្ទុះខាងលើក្បាលរបស់យើង ហើយផ្ទុះនៅជិតដើមឈើទាំងនោះ ។

តើមានអ្វីដែលត្រូវសើច ពិតណាស់គឺការផាររបស់អ្នកដែលចូលចិត្តខ្លាំងនឹងអ្វីមួយ ។ អ្នកទទួលខុសត្រូវដែលជូនដំណើរយើងតាំងពីទីក្រុងហូជីមិញបានធ្វើទឹកមុខក្រញូវ ។ ជាការគួរឲ្យសោកស្តាយណាស់ដែល ប៉ុលពត ពុំមែនជាមនុស្សចូលចិត្តរៀបចំការវាយប្រហារពិតប្រាកដមួយ ដើម្បីបំពេញបំណងរបស់យើងនោះ! ។

យើងបានត្រូវចំអកឲ្យរហ័សបំផុត ៖ មិនដល់១៦០គីឡូម៉ែត្រពីទីនោះផង ការប្រយុទ្ធគ្នាមែនទែនបានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លានៅចំណុចមួយទៀតនៃព្រំដែន ។ វៀតណាមបានខំប្រឹងវាយរុញច្រានពួកអ្នកលុកលុយខ្មែរក្រហមយ៉ាងស្វិតស្វាញ ។ បីថ្ងៃក្រោយមក គេបានមកដាស់ខ្ញុំដែលដេកក្នុងបន្ទប់សណ្ឋាគារមួយនៅក្រុងហូជីមិញ ដើម្បីប្រគល់ឲ្យខ្ញុំនូវសេចក្តីណែនាំមួយខុសប្លែកពីធម្មតា ។ គាំ បានឲ្យដំណឹងខ្ញុំថា អ្នកកាសែតទាំងអស់ត្រូវទៅជួបជុំគ្នាមួយម៉ោងក្រោយនៅអាកាសយានដ្ឋានតាន់សឺនញឹក ។ គោលបំណងពុំមានបញ្ជាក់ឲ្យដឹង ។

នៅពេលម៉ោងដែលមកគ្នា គឺនៅចំណតអាកាសយានតាន់សឺនញឹក មនុស្សស្ទើរតែមកតាន់តាប់ទៅហើយ ។ ក្រៅពីអ្នកឆ្លើយឆ្លងព័ត៌មានលោកខាងលិច នៅទីនោះក៏មានក្រុមអ្នកកាន់ម៉ាស៊ីនថតភាពយន្តគុយបា និងប៉ូឡូញ និងអ្នកថតរូបព្រមទាំងអ្នកថតភាពយន្តរបស់វៀតណាមមួយហ្វូងដែរ ដែលហៀបនឹងចេញដំណើរទៅហាទៀង ទាំងអស់គ្នា ។ បេះដូងរបស់ខ្ញុំញាប់ញ័រជាខ្លាំង នៅពេលដែលខ្ញុំឃើញយន្តហោះរបស់យើងពីចម្ងាយ ។ ដំបូង ខ្ញុំស្មានតែសត្វសម័យបុរេប្រវត្តិសាស្ត្រ ។ ប៉ុន្តែពុំមែនទេ នេះពិតជាឧទ្ធម្ភាគចក្រម៉ាក *Chinook* មួយគ្រឿងដែលរូបរាងប្រែទៅជាកំពឹកកំពកមូលៗ ហើយពណ៌ថ្នាំដែលលាប-ពីដើមពណ៌បៃតង-គ្រាន់តែជាអនុស្សាវរីយ៍មិនច្បាស់ប៉ុណ្ណោះ ។ នេះជាខ្មោចសេះកញ្ចាស់ដ៏ល្អមួយរបស់កងទ័ពអាមេរិកាំងនៅប្រទេសវៀតណាម ។ គំនូរសម្គាល់តែមួយគត់ដែលធ្វើឲ្យអារម្មណ៍មិនសូវរីករាយក្នុងទស្សនីយភាពគួរឲ្យស្រងាកចិត្តនេះ គឺរូបសញ្ញាផ្កាយពណ៌លឿងនិងផ្ទៃពណ៌ក្រហមនៃកងទ័ពអាកាសរបស់វៀតណាមនៅលើតួយន្តហោះ ។ បង្អួចពីរក្នុងចំណោមបង្អួចទាំងអស់របស់យន្តហោះ គ្រាន់តែជាប្រហោងប្រហង្ហុងប៉ុណ្ណោះ ។ ការប្រទាក់ផ្ទាក់គ្នាមួយនៃខ្សែភ្លើងជាច្រើនដែលធ្លាក់រណែងរណោងនៅក្នុងបន្ទប់អ្នកជិះ មើលទៅមានសភាពគួរឲ្យស្រងេះស្រងោចណាស់ ។ ផ្ទុយ

នឹងសេចក្តីសង្ឃឹមទាំងអស់ ម៉ាស៊ីនយន្តហោះបានចាប់ផ្តើមបញ្ឆេះហើយហោះនាំយើងចេញទៅ ។ ដោយប្រថុយក្រឡេកមើលទៅក្រៅ ខ្ញុំសម្លឹងគយគន់មួយសន្ទុះនូវគ្រឿងទ្រទ្រង់តួយន្តហោះទាំងមូលដែលមើលទៅទន់ល្មូតដូចឥតឆ្អឹងនិងប្រឡាក់ខ្មៅៗ ដែលជាមរតកមួយរបស់ *Oncle Sam* ឬ *Uncle Sam* [ជាពាក្យអង់គ្លេសដែលប្រើជាការហៅសហរដ្ឋអាមេរិករបៀបចំអក ហើយពាក្យនេះទាញចេញមកពីពាក្យ *U.S.Am (United States of América)*] ទុកឲ្យប្រទេសវៀតណាមសង្គមនិយម ។

យើងបានហោះពីលើតំបន់វាលកក់យ៉ាងឆាប់រហ័ស ដែលមានពាសពេញទៅដោយមាត់រណ្តៅគ្រាប់បែកនិងគ្រាប់កាំភ្លើងធំ បន្ទាប់មកដែនដីសណ្តទន្លេមេគង្គ ដែលមានវិសាលភាពធំល្វឹងល្វើយឡើងបៃតងស្រងាត់និងកាត់ខ្វាត់ខ្វែងទៅដោយប្រឡាយទឹកពណ៌ដាំដែងជាច្រើន ។ កំសួលខ្យល់គ្រជាក់មួយបានបក់ចូលមកប៉ះយើងតាមបង្អួចបែកទាំងពីរ ។ បន្ទាប់ពីការចុះចតមួយរយៈខ្លី ដើម្បីចាក់ប្រេងបន្ថែមនៅកន់ធី ធានីនៃដែនដីសណ្តខទ្ធម្តាគចក្រ *Chinook* បានហោះឡើងជាថ្មីឆ្ពោះទៅហាឡៀងតែម្តង ។

ដោយសម្លឹងមើលមូលដ្ឋានអាកាសកន់ធី ដែលជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានធំៗកសាងនៅប្រទេសវៀតណាមដោយពួកអាមេរិកាំង និងស្តាប់សំឡេងយន្តហោះ *A.37* ជាផលិតផលរបស់អាមេរិកកំពុងពេទ៍ម៉ាស៊ីននៅលើផ្លូវហោះហើរ ដោយមានភ្ជាប់គ្រាប់បែកនៅក្រោមស្លាបទាំងសងខាងរបស់វាផង បានហោះឡើងតាមទំនងសំដៅទៅប្រទេសកម្ពុជា ខ្ញុំក៏ស៊ើចញឹមៗ ។ កាលពីបីឆ្នាំមុន នៅពេលដែលសហរដ្ឋអាមេរិកនៅកំពុងវាយប្រយុទ្ធនឹង«កម្ពុជាអ្នកគាំទ្រក្រុងហាណូយ» នៅឡើយ ហង់រី គីស៊្សីងហ្គ័រ បដិសេធមិនទទួលស្គាល់ថា វៀតណាមគ្មានសមត្ថភាពញាំងខ្មែរក្រហមឲ្យលុះក្នុងអំណាចរបស់ខ្លួន ដូចដែល ឡេ ឌឹកថូ អះអាងប្រាប់គាត់ឡើយ[៥០] ។ បើគិតឲ្យហ្មត់ចត់ទៅ លទ្ធិកុម្មុយនីស្តរបស់កម្ពុជា មិនមែនជាការបង្កើតមួយរបស់វៀតណាមទេឬ? ។

ការប្រជុំផ្តល់ព័ត៌មានដែលពួកយើងបានចូលរួមក្នុងរយៈពេលនៃការធ្វើដំណើររហូតដល់ចំណតអាកាសយានហាឡៀង គឺត្រូវបានធ្វើឡើងដោយមានដែនទីផ្សេងៗរបស់សេនាធិការអាមេរិកាំងជាជំនួយផង ។ ប៉ុន្តែ អ្នកបង្រៀនយើងនិយាយពុំមានសំនៀងរបៀបអ្នកតិចសាស់ *(Texas)* សោះ ហើយទីតាំងទាំងឡាយរបស់សត្រូវដែលគូសដោយខ្មៅដៃនៅលើដែនទី ពុំមែនសរសេរឲ្យឃើញច្បាស់ជាអក្សរ *"V.C"* (វៀតកុង) ឬ*K.C* (ខ្មែរកុម្មុយនីស្ត ដែលជាការហៅជាផ្លូវការរបស់អាមេរិកាំងក្នុងរយៈពេលសង្គ្រាម) ឡើយ ។ ត្បិតអី ចាប់ពីថ្ងៃនេះទៅសត្រូវគឺកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត សង្គ្រាមនេះរៀបចំឡើង ដោយសម្ភារសឹកថ្មីជាមួយសម្ភារសឹកចាស់... ។

អាកាសយានដ្ឋានហាឡៀង មានសភាពស្ទើរតែស្ងាត់សូន្យ ។ នៅឯនាយឆ្ងាយ គេឃើញកំសួលផ្សែងពណ៌សហុយចេញពីរោងចក្រស៊ីម៉ង់ត៍មួយ ដែលមិនយូរប៉ុន្មានត្រូវខ្យល់បក់នាំយកទៅលំហអាកាស ដែលមានពណ៌ខៀវស្រស់ថ្លា ។ នៅចុងផ្លូវ ភេសជ្ជៈត្រជាក់ៗនិងនំប៉ីស្គីបានត្រូវរៀបបម្រុងជាស្រេចនៅលើកម្រាលគុ

ពណ៌សមួយ ដើម្បីបម្រើបំណងយើង ។ នេះជាទម្លាប់ប្លែកគួរឲ្យចង់ដឹងនៅប្រទេសវៀតណាមកុម្មុយនីស្ត ព្រោះក្នុងប្រទេសនេះ គ្មានរឿងអ្វីអាចមានឡើងដោយឥតមានគណៈកម្មាធិការណាមួយចូលខ្លួកខ្លាំរៀបចំពិធីបដិសណ្ឋារកិច្ចមួយឡើយ ។ ក្រោមកម្ដៅព្រះអាទិត្យគ្មានប្រណីមេត្តានេះ ដបសូដាជាច្រើនដែលក្ដៅខណ្ហៗ លាយក្រូចពោធិសាត់ក៏ទទួលស្វាគមន៍ភ្ញៀវ ទោះជាភ្ញៀវណាមកដល់ក៏ដោយ ។

បន្ទាប់ពីការប្រមូលផ្ដុំព័ត៌មានចុងក្រោយមួយ ដែលធ្វើឡើងដោយវរសេនីយ៍ត្រី វ៉ាង ចូវ ដែលចូលចិត្តឈឺឆ្អាលជួយគេ យើងបានចេញដំណើរទៅកាន់ហាទៀង ។ ទីក្រុងដែលក្នុងពេលថ្មីៗនេះមានមនុស្សតិចជាង ៣០.០០០នាក់ នៅថ្ងៃនេះមានសភាពស្ទើរតែអស់មនុស្សរលីង ហើយហាងលក់ទំនិញនិងផ្ទះសម្បែងសុទ្ធតែបិទទ្វារ ។ អំបែងគ្រាប់កាំភ្លើងធំនៅរាយពាសពេញលើដី ។ នៅចំណោតកំពង់ផែ អ្នកវង្វេងមិនដឹងទៅណា នៅឈរវង់ចាំដោយមានកន្ត្រក, បាវក្រចៅ ឬកានដ៍រេចងព្យួរខាងចុងឈើវែងមួយលីលើស្មា ឬដាក់គរគ្នាលើកង់ និងរទេះរុញផង ។ ក្បួនរថយន្តរបស់យើងបានឈប់នៅពេលចេញផុតពីទីក្រុង ។ នៅហួសឆ្ងាយពីទីនោះ គឺដីស្រែរបស់ឃុំមីឌុក ដែលលាតសន្ធឹងរហូតដល់ភ្នំតូចៗនៅក្បែរព្រំដែនរបស់ប្រទេសកម្ពុជា ។ យើងបានឆ្លងកាត់វាលស្រែដោយថ្មើរជើង ដែលធ្វើឲ្យដីហុយឡើងសំពោងគ្របពីលើក្បាលរបស់យើង ។ ក្នុងខណៈដែលយើងដើរចូលទៅជិតដល់ខ្ទមតូចៗប្រក់ស្បូវនៅជាប់ជើងភ្នំ ក្លិនស្អុយអសោចមួយដែលធ្វើឲ្យឈ្ងក់ដង្ហើម នៅតែវិលវល់នៅទីនោះ ៖ នេះជាក្លិនមនុស្សស្លាប់ប្រាកដណាស់ ។ នៅកណ្ដាលគំនរបាក់បែកនៃគេហដ្ឋាននានា លេណដ្ឋានមួយត្រូវបានគេលើកយករបស់ទើសទែងចេញ ។ មនុស្សប្រមាណដប់ពីរនាក់ កំពុងជីករណ្ដៅកប់សាកសពនៅត្រង់នោះក្នុងសភាពស្ងប់ស្ងាត់ ដោយបែកញើសប៉ុនៗគ្រាប់ពោត ។ នៅក្បែរផ្ទះមួយដែលចំហផ្លុងគេបានកប់សាកសពដប់ប្រាំនាក់ មានប្រុស ស្រី និងកូនក្មេង ។ មិនឆ្ងាយប៉ុន្មានពីទីនោះ ដំបង ព្រនង់ ដែលទំនងជាខ្មែរក្រហមប្រើសម្លាប់មនុស្សនៅរាយប៉ាយលើដីនៅឡើយ ។ ក្នុងនោះមានដំបងមួយត្រូវគេបុកទម្លុះប្រដាប់ភេទស្រីម្នាក់ដែលត្រូវចងកន្ត្រកដៃជើងទាំងខ្លួនប្រាណនៅលគក ។ កូនទាំងពីររបស់នាងត្រូវគេកាត់ជាកំណាត់ៗ ។ សាកសពខ្លះត្រូវកាត់ក្បាលបាត់ ។ សាកសពខ្លះទៀត ដែលធ្លាយពោះវៀនចេញមកក្រៅត្រូវបាំងបាត់ក្រោមការចោមរោមនៃហ្វូងរុយក្បាលខៀវ ។ ដោយរកកលចង់ក្អួត ខ្ញុំគោងតែសម្រាកមួយសន្ទុះនៅក្រោមដើមឈើមួយដើមមុននឹងបន្តដើរមើលទៀត ។ គេហដ្ឋានទាំងអស់ដោយគ្មានលើកលែងបានផ្ដល់នូវទស្សនីយភាពធ្វើឲ្យភ័យខ្លាចដូចការយល់សប្តិអាក្រក់ ។ ចំណែកសត្វទាំងឡាយក៏ខ្មែរក្រហមសម្លាប់គ្មានត្រាប្រណីដែរ ។ ខ្មោចគោ និងឆ្កែងាប់ស្អុកស្អឹងនៅក្នុងរណ្ដៅក្បែរមាត់ផ្លូវ ។ នៅជិតហាទៀង ខាងក្រោយទួលខ្ពស់មួយដែលខ្មែរក្រហមជ្រកពួនក្នុងរយៈពេលនៃការវាយប្រហាររបស់វៀតណាម ខ្ញុំមើលឃើញសាកសពកងទ័ពខ្មែរក្រហមពីរនាក់ ។ ខ្មែររត់គេចខ្លួននេះបានបន្សល់ទុកក្បែរខ្លួននូវអាវុធមួយគំនរ ៖ កាំភ្លើងអាកា-៤៧, គ្រាប់បេ-៤០ និងកាំភ្លើងបាញ់មិនធាក់ថយផលិតនៅប្រទេសចិន ។

ង្វៀន វ៉ាន់ហ័ន អាយុ២៥ឆ្នាំ និងប្រពន្ធរបស់គាត់បានត្រូវដាស់ឲ្យភ្ញាក់ពីដំណេកនៅពេលទៀបភ្លឺថ្ងៃទី១៨ ខែមីនា ដោយសម្រែកជាភាសាខ្មែរថា ៖ “ចូល! ចូល!” និងដោយសំឡេងស្រែកថ្ងូររបស់អ្នកភូមិ ។ ក្នុងភាពងងឹត អ្នកទាំងពីរបានរត់គេចខ្លួនទៅកាន់កូនភ្នំមួយដែលមានព្រៃឈើពាសពេញនៅជិតនោះ ជាកន្លែងដែលពួកគេលាក់ខ្លួនក្នុងរយៈពេលពីរថ្ងៃ ។ នៅព្រឹកថ្ងៃបន្ទាប់ ពីកន្លែងសង្កេតមើលរបស់គាត់នៅលើភ្នំ ហ័ន អាចមើលឃើញខ្មែរក្រហមដឹកបាវស្រូវ និងទ្រព្យសម្បត្តិកំប៉ិកកំប៉ុកទាំងអស់របស់ប្រជាជនក្នុងភូមិតាមរទេះយកចេញទៅ ។ ខ្ញុំខំប្រឹងសម្លឹងមើលខ្ទមតូចៗទាំងនេះ ដែលធ្វើពីភក់សម្លូតនិងឫស្សីដោយឥតអំពើ ខ្ញុំពិបាកជឿថា ខ្ទមទាំងនេះអាចមានអ្វីដែលបង្ហាញឲ្យឃើញភ័ស្តុតាងសម្រាប់ការលួចប្លន់ណាស់ ។ តើមានអ្វីដែលអាចជាដើមហេតុបណ្តាលឲ្យមានក្រុមអ្នកសម្លាប់មនុស្ស? ភ័ស្តុតាងគួរទទួលយកបានតែមួយគត់ ដែលខ្ញុំអាចលើកមកបង្ហាញគឺពាក្យស្លោកជាភាសាខ្មែរមួយដែលយកធ្យូងសរសេរក្រវេមក្រវាមនៅលើទ្វារមួយថា “ទីនេះស្រុកយើង” ។ ការរំឭកឲ្យឃើញនូវអ្វីៗដែលកន្លងយូរមកហើយ គឺប្រហែលជា៣០០ឆ្នាំមុន ដែនដីសណ្តទន្លេមេគង្គទាំងមូលរួមទាំងហាទៀងផងគឺជាទឹកដីរបស់កម្ពុជា ។ ដូច្នេះ ភាគច្រើននៃប្រជាជននៅឃុំមីឌុក និងអ្នករងគ្រោះ គឺសុទ្ធតែមានដើមកំណើតខ្មែរ ។

រឿងទាំងអស់នេះ បានរួមបង្កជាចំណោទបិទមុខមួយសម្រាប់ខ្ញុំ ។ ដោយស្វែងរកឫសគល់មួយនៃការសម្លាប់ប្រហារឥតអាសូរនេះ ខ្ញុំនៅតែមិនដឹងដូចមនុស្សស្ទើរតែគ្រប់គ្នាពីអ្វីដែលកើតមាននៅប្រទេសកម្ពុជាបន្ទាប់ពីការវាយលុយរបស់វៀតណាមនៅខែធ្នូដែរ ។ ខ្ញុំមិនដឹងទាល់តែសោះពីការចង់ធ្វើអ្វីៗឲ្យធំអស្ចារ្យដែលសណ្ឋិតក្នុងចិត្តគំនិតខ្មែរក្រហមបន្ទាប់ពីជ័យជម្នះជាប្រវត្តិសាស្ត្រដែលមិនប្រាកដនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ឡើយ ។ ក្រោយមក អៀង សារី បានបំភ្លឺប្រាប់អ្នកកាសែតបរទេសថា ដោយឆ្លើយតបចំពោះការលុកលុយរបស់វៀតណាម “យើងត្រូវតែចាប់ផ្តើមធ្វើការវាយលុកឡើងវិញ ហើយរុញច្រានវៀតណាមឲ្យចូលយ៉ាងជ្រៅទៅខាងក្នុងព្រំដែនផ្ទាល់របស់ពួកគេ”[៥១] ។

យើងបានត្រឡប់មកកាន់ក្រុងហូជីមិញវិញ ។ សក្តីភាពដំបូងមួយ - ដែលនាំឲ្យខ្លោចផ្សាក្នុងចិត្ត - ទើបនឹងធ្វើឲ្យយើងដឹងពីការពិតនៃសង្គ្រាម ដែលធ្វើឲ្យ“សមមិត្ត”ជាបងប្អូននៅឥណ្ឌូចិនប្រយុទ្ធតទល់គ្នា ។ ក្រោយនោះមិនយូរប៉ុន្មាន ខ្ញុំបានដំណឹងថា ការសម្រេចបញ្ជូនអ្នកកាសែតទៅហាទៀងតាមខទ្ទម្ភាគបក្រមុនពេលដែលសាកសពទាំងឡាយត្រូវបញ្ចុះ បានត្រូវសម្រេចដោយ ឡេ ឌឹកថូ ផ្ទាល់ ដែលអំណឹះតទៅ នៅក្រុងហាណូយការចាត់ចែងពីបញ្ហានយោបាយរបស់កម្ពុជាត្រូវធ្លាក់មកលើគាត់ ។ ប៉ុល ពត បានផ្តល់លទ្ធភាពឲ្យគាត់ចេញពីយ៉ាងច្រើន ហើយគាត់មិនទុកឲ្យឱកាសក្នុងការឃោសនាដ៏ល្អប្រសើរមួយកន្លងផុតឡើយ ។ ក្នុងរយៈពេលនោះប្រទេសកម្ពុជាបានប្រឹងប្រែងដូចគ្នា ដើម្បីទទួលបានការគាំទ្រពីបរទេស ។ នៅថ្ងៃតែមួយដែលពួកយើងទៅទស្សនាហាទៀង ប៉ុល ពត បានទទួលជួបអ្នកកាសែតយូហ្គោស្លាវីមួយក្រុមនៅក្នុងនិវេសនដ្ឋានមួយ ស្ថិតនៅ

តាមមាត់ទន្លេសាបនាទីក្រុងភ្នំពេញដែរ ។ នេះជាក្រុមអ្នកកាសែតដំបូងបង្អស់ដែលត្រូវបានអនុញ្ញាតឲ្យចូលប្រទេសកម្ពុជាតាំងពីជ័យជម្នះរបស់ខ្មែរក្រហម ។ ប៉ុល ពត បានបំភ្លឺថា ប្រទេសកម្ពុជាសាកល្បងដោះស្រាយជម្លោះរបស់ខ្លួនជាមួយប្រទេសវៀតណាម «ដោយគិតទៅតាមស្ថានភាពជាក់ស្តែង» ។ «បើសិនជាប្រទេសវៀតណាមប្រកាន់ឥរិយាបថមិត្តភាពមួយចំពោះយើងនោះ គ្មានហេតុផលណាមួយដែលថា បញ្ហានេះមិនត្រូវបានដោះស្រាយដោយឆាប់រហ័សឡើយ»[៥៧] ។

វ៉ី ដុងយ៉ាង បានបង្ហាញពីរបៀបលៃលករបស់គាត់ក្នុងការបង្កើតទំនាក់ទំនងប្រកបដោយមិត្តភាពរវាងប្រទេសទាំងពីរប្រាប់យើងដោយត្រង់ៗថា ៖ «មានតែដំណោះស្រាយពីរប៉ុណ្ណោះ ដែលអាចមានលទ្ធភាពធ្វើទៅរួចចំពោះការប៉ះទង្គិចគ្នានេះ ។ ឬមួយរបបរបស់កម្ពុជាត្រូវផ្លាស់ប្តូរនយោបាយ ឬមួយប្រជាជនកម្ពុជាទទួលរ៉ាប់រងផ្លាស់ប្តូររបបដោយខ្លួនឯង» ។

# សម្តេច ព្រះនរោត្តម សីហនុ : ក្នុងគុកខ្មែរក្រហម

សម្រាប់ជាលើកដំបូងហើយក្នុងជីវិតរបស់ព្រះអង្គដែលសម្តេច សីហនុ ត្រូវបានកម្ចាត់ចេញពីមុខងារសាធារណៈ ហើយគ្រាន់តែជាបុគ្គលសាមញ្ញម្នាក់ប៉ុណ្ណោះ ដែលនៅជុំវិញព្រះអង្គគឺភាពស្ងាត់ជ្រងំ ។ និវេសនដ្ឋានរបស់ព្រះអង្គនៅក្នុងព្រះបរមរាជវាំង ដែលហ៊ុមព័ទ្ធដោយរបងខ្ពស់ៗ ប្រៀបដូចជាទ្រុងមាសមួយដែលយាមការពារដោយយុវកសិករក្មេងៗ ស្លៀកពាក់ខោអាវពណ៌ខ្មៅ និងដែលគេស្គាល់ព្រោះតែភាពមិនដែលញញឹមនេះឯង ។ អតីតព្រះប្រមុខរដ្ឋពុំអាចចាកចេញពីជម្រករបស់ព្រះអង្គដោយគ្មានការអនុញ្ញាតពីអង្គការឡើយ ។ វាប្រាកដហើយដែលព្រះអង្គពុំដែលមានព្រះទ័យចង់ចេញទៅក្រៅទោះជាទីណាក៏ដោយ ។ កន្ទុលពីការទទួលស្បៀងអាហារពីអង្គការ ក៏ព្រះអង្គមិនធ្លោយឲ្យដឹងដែរ ។ រៀងរាល់ព្រឹក យុទ្ធជនម្នាក់តែងជិះកង់យករបបស្បៀងអាហារប្រចាំថ្ងៃជាត្រីជាបន្លែមកថ្វាយព្រះអង្គជានិច្ច ។ អតីតនាយករដ្ឋមន្ត្រីរបស់ព្រះអង្គគឺលោក ប៉ែន នុត រួមទាំងលេខាធិការផ្ទាល់របស់ព្រះអង្គ គឺអ្នកស្រី សោ សារ៉ុត ត្រូវបានយល់ព្រមឲ្យរួមចំណែកក្នុងការជាប់ឃុំរបស់ព្រះអង្គដែរ ។ ប៉ុន្តែពួកគេបានត្រូវចាត់ចែងឲ្យរស់នៅនិវេសនដ្ឋានដាច់ដោយឡែកពីគ្នានៅក្នុងក្រុងភ្នំពេញ ។ តាំងពីពេលដែលបុត្រីជាច្រើនអង្គរបស់ព្រះអង្គ និងក្រុមគ្រួសាររបស់អ្នកទាំងនោះត្រូវបណ្តេញចេញពីនិវេសនដ្ឋានមក"ពិភពរស់នៅ"របស់សម្តេច សីហនុ បានរួមតូចទៅៗយ៉ាងចម្លែក ។ ក្នុងព្រះបរមរាជវាំងមានតែអ្នកម្នាង ម៉ូនិក និងបុត្រាទាំងពីររបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ សីហមុនី និង នរិន្ទ្រពង្ស ប៉ុណ្ណោះ ។

អ្នកម្នាង ម៉ូនិក បានមានបន្ទូលរៀបរាប់ប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា "ចាប់តាំងពីការសុំលាលែងពីតំណែងរបស់សម្តេច (នៅខែមេសា ឆ្នាំ១៩៧៦) ពួកយើងលែងបានឃើញអ្វីដែលមានជីវិតទៀតហើយ ។ ទោះបីជាអ្នកបម្រើក៏ត្រូវគេដកយកចេញអស់ដែរ" ។ ជាលើកដំបូងហើយក្នុងជីវិតរបស់អ្នកម្នាង ម៉ូនិក ដែលមានករណីយកិច្ចត្រូវដណ្តាំស្លម្ហូបអាហារជារៀងរាល់ថ្ងៃដើម្បីចិញ្ចឹមបីបាច់គ្រួសារ ។ ក្នុងអំឡុងនៃការគង់ប្រថាប់និរទេសព្រះកាយរយៈពេលប្រាំឆ្នាំនៅក្រុងប៉េកាំង ដូ អេនឡាយ ដែលធ្លាប់ស្គាល់ច្បាស់ពីចំណូលសោយម្ហូបឆ្ងាញ់ៗរបស់សម្តេច បានរៀបចំដាក់ចុងភៅម្នាក់ក្នុងចំណោមចុងភៅចំណានៗប្រចាំក្រុងប៉េកាំង ដែលមានឯកទេសខាងធ្វើម្ហូបបារាំងឲ្យទៅនៅបម្រើព្រះអង្គតាមសព្វព្រះទ័យ ។ ប៉ុន្តែ ឥឡូវនេះ គឺអ្នកម្នាង ម៉ូនិក ជាអ្នកបំពេញកិច្ចការផ្ទះសព្វសារពើតាំងពីការដាំស្ល និងដាំបន្លែបន្តិចបន្តួចដោយមានបុត្ររបស់ព្រះអង្គ សីហមុនី ជួយខ្លះៗផង ។ អ្នកម្នាងនិងព្រះរាជបុត្រក៏មានដាំចេកខ្លះដែរ ។

ពេលវេលាហាក់ដូចជានៅនឹងថ្កល់ ។ ស្ងាត់សូន្យពុំមានឮសូរសំឡេងអ្វីមួយឡើយ ។ សម្តេច សីហនុ ទ្រាំអត់សង្កត់ព្រះហឫទ័យដោយស្ងាត់ស្ងៀម ។ ព្រះវិហារព្រះកែវមរកតដ៏ស្រស់ស្អាត ដែលនៅក្បែរព្រះបរមរាជវាំងត្រូវបោះបង់ចោល ។ ភាពស្ងប់ស្ងាត់ដូចនៅវាលកប់ខ្មោចមួយបានសណ្ឋិតនៅទីនោះ ហើយត្រូវធ្វើឲ្យរំខានម្តង

ម្កាលដោយសារសំឡេងទទះស្វាបហើររបស់ហ្វូងសត្វព្រាបប៉ុណ្ណោះ ។ សម្តេចបានកាត់ព្រះទ័យ ធ្វើយ៉ាងណាមិនបណ្តោយឲ្យព្រះរាជសុខភាពខាងផ្លូវចិត្តចុះខ្សោយឡើយ ។ ដោយភ័ព្វល្អ ព្រះអង្គនៅមានកម្មសិទ្ធិវិទ្យុធំមួយគ្រឿងម៉ាក ហ្គ្រុនឌិក (Grundig) ដែលជាអំណោយរបស់ ខៀវ សំផន ដែរ ។ នេះជា"បង្អួច"របស់ព្រះអង្គបើកទៅរកពិភពលោក ជាមធ្យោបាយទំលាយភាពដដែលៗដ៏គួរឲ្យព្រឺខ្លាចតែមួយគត់ ដែលមានទាំងយប់ទាំងថ្ងៃមិនចេះចប់ ។ រៀងរាល់ព្រឹកនិងរៀងរាល់យប់ ព្រះអង្គខំប្រឹងរាវចាប់ប៉ុស្តិ៍វិទ្យុទូទាំងពិភពលោកអស់រយៈពេលជាច្រើនម៉ោងដូចជាវិទ្យុ ប៊ីប៊ីស៊ី សំឡេងសហរដ្ឋអាមេរិក វិទ្យុអូស្ត្រាលី វិទ្យុបារាំងអាំទែរ វិទ្យុអិនហាស់ការបស់ជប៉ុន និងវិទ្យុហាណូយជាដើម ។ ដោយមានប្រដាប់ស្តាប់សំឡេងពាក់លើព្រះកេស ព្រះអង្គទ្រង់សណ្តាប់ព័ត៌មានទាំងអស់នៅប្រទេសកម្ពុជា ប៉ុន្តែក៏សណ្តាប់ព័ត៌មានរបស់តំបន់និងពិភពលោកផងដែរ ។

សម្តេចទ្រង់ព្រះសណ្តាប់ជាមួយទឹកព្រះទ័យរីករាយលាយឡំទៅដោយរបៀបកម្សាន្តមួយ អំពីព័ត៌មានផ្សេងៗទាក់ទងនឹងព្រះអង្គ ។ ពិភពលោកពុំទាន់ភ្លេចរូបព្រះអង្គទេ ។ អ្នកយកព័ត៌មានម្នាក់បានអះអាងថា ត្រូវធ្វើឲ្យអាក់អន់ព្រះទ័យ ដោយសារអ្វីដែលព្រះអង្គទតឃើញ ព្រះអង្គក៏បាត់មាត់លែងចេញព្រះវាចាតែម្តង ។ អ្នកយកព័ត៌មានម្នាក់ទៀតដែលនិយាយសំអាងតាមសម្តីរបស់ អៀង សារី បានបញ្ជាក់ថា សម្តេច បានគង់ប្រថាប់ដោយសុខស្រួលបំផុតក្នុងព្រះរាជដំណាក់ព្រះអង្គ ហើយថាព្រះអង្គបានទ្រង់លិខិត"សារណា"(ប្រវត្តិរឿងដើម) របស់ព្រះអង្គទៀតផង ។ ប៉ុន្តែ សារី ក៏មានសេចក្តីឆ្លើយដោះសាផ្សេងៗទៀតសម្រាប់ត្រៀមដោយឡែកដែរ ។ នៅនិទាឃរដូវ ឆ្នាំ១៩៧៧ អៀង សារី បាននិយាយនៅប្រទេសម៉ាឡេស៊ីស្តីពីរឿងអាថ៌កំបាំងទាក់ទងនឹងសម្តេច សីហនុ មានបន្ទូល ។ សម្តេចធ្លាប់បានប្រកាសថា : "បើសិនជាខ្ញុំបានជួបពួកបរទេស ខ្ញុំនឹងមានកម្លាំងបន្តធ្វើនយោបាយតទៅទៀត" ។

លិខិតទូរលេខទាំងឡាយរបស់អ្នកឆ្លើយឆ្លងព័ត៌មានដែលបញ្ជូនមកតាំងពីព្រំដែនថៃ-កម្ពុជា ឬពីរដ្ឋធានីឯទៀតនៅអាស៊ីបានបង្ហាញឲ្យឃើញនូវការចាប់អារម្មណ៍ថែមទៀត ។ ប៉ុន្តែតាមរយៈទូរលេខទាំងនេះ អ្វីដែលបង្ហាញពីស្ថានការណ៍នៅកម្ពុជាតាមរយៈលិខិតសារទូរលេខទាំងនោះបានត្រឹមតែធ្វើឲ្យព្រះអង្គព្រួយព្រះទ័យនិងថប់បារម្ភប៉ុណ្ណោះ ។ ដោយឯកឯង ព្រះអង្គទ្រង់ជ្រាបថា រឿងនិទានផ្សេងៗស្តីពីសេចក្តីឈឺចាប់ ការកាប់សម្លាប់ការដាក់ទោសដោយបង្ខំឲ្យធ្វើការជាទម្ងន់ដែលនាំមកនិយាយដោយពួកអ្នកភៀសខ្លួនខ្មែរប្រាប់គេ ប្រាប់ឯងនោះសុទ្ធតែជាការពិត ។ ជាឧទាហរណ៍ព្រះអង្គទ្រង់ជ្រាបតាមរយៈអ្នកយាមព្រះអង្គថា កម្រិតនៃការប្រើអំពើរឃោរឃៅ និងការសប្បាយដោយធ្វើឲ្យអ្នកឯទៀតឈឺចាប់វេទនារបស់អ្នកផប់នឹងទ្រឹស្តីកុម្មុយនីស្ត ក្មេងៗអាចកើតឡើងមែន ។

នៅជំនាន់នោះ គេមិនដែលប្រុងប្រយ័ត្នខ្លាំងដូច្នេះឡើយនៅក្រុងភ្នំពេញ ។ ដោយហេតុនេះហើយ បានជារៀងរាល់ព្រឹក សម្តេច សីហនុ តែងយកព្រះទ័យទុកដាក់សណ្តាប់សេចក្តីរាយការណ៍របៀបឃោសនារបស់វិទ្យុ

ខ្មែរក្រហមដោយបើកសំឡេងវិទ្យុខ្លាំងៗនិងបើកបង្ហួចចំហទាំងអស់ ។ ពេលដែលព្រះអង្គធ្វើរបៀបនេះដើម្បីឲ្យអ្នកយាមដឹងឮរួចហើយ ព្រះអង្គយកប្រដាប់ស្តាប់សំឡេងមកពាក់នឹងព្រះកេសភ្លាម ដើម្បីសណ្តាប់ព័ត៌មានផ្សេងៗជុំវិញពិភពលោកម្តង ។ ព្រះអង្គបានថតចម្លងទុកនូវសេចក្តីអត្ថាធិប្បាយមួយចំនួនតាមរយៈម៉ាញ៉េមួយគ្រឿងក្នុងគោលបំណងសម្រាប់ទ្រង់ព្រះសណ្តាប់ឡើងវិញ និងវិភាគដំណឹងទាំងនោះដោយល្អិតល្អន់ ។

ទម្លាប់នេះពុំមែនគ្មានគ្រោះថ្នាក់នោះទេ ។ ថ្ងៃមួយនៅចុងឆ្នាំ១៩៧៦ព្រះអង្គដឹងថា ខៀវ សំផន មានបំណងនាំព្រះអង្គយាងទៅធ្វើទស្សនកិច្ចមួយនៅតាមខេត្តជាមួយគាត់ ។ ដូច្នេះ ព្រះអង្គត្រូវតែទុកចោល "កាសែ្សត" ថតសំឡេងដែលនឹងនាំឲ្យមានការសង្ស័យនៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ សម្តេច សីហនុ បានរំពឹកថា "សម្តេចបានចំណាយពេលពេញមួយយប់ដើម្បីអាត់បទចម្រៀងទាំងអស់ដែលព្រះអង្គអាចចាប់បានតាមវិទ្យុទាំងរហន់ក្នុងគោលបំណងលុបចោលព័ត៌មានផ្សេងៗដែលព្រះអង្គបានថតទុកកាលពីថ្ងៃមុន" ។

ដំណើរទស្សនកិច្ចជាមួយ ខៀវ សំផន នៅតាមខេត្តមួយចំនួនបានបើកឱកាសឲ្យព្រះអង្គទតឃើញច្បាស់នូវលក្ខណៈដ៏ធំធេងនៃ "នយោបាយមហាលោតផ្លោះ" ដែលផ្តើមធ្វើដោយខ្មែរក្រហម ។ ព្រះអង្គបានទតឃើញការដ្ឋានធំដែលមានពលករប្រុស-ស្រីរាប់ពាន់នាក់ខំប្រឹងជីកប្រឡាយទឹកយ៉ាងវែងរាប់គីឡូម៉ែត្រ ក្នុងសភាពស្ងប់ស្ងាត់គួរឲ្យអាណិត ។ ទិដ្ឋភាពនេះមានលក្ខណៈដូចទីលានយ៉ាងធំមួយមានសុទ្ធតែមនុស្សស្លៀកពាក់ខ្មៅធ្វើការពពាក់ពពូនដូចហ្វូងស្រមោច ។ តើអ្នកទាំងនោះមើលស្គាល់ព្រះអង្គពីចម្ងាយទេ? បើសិនជាពួកគេមើលស្គាល់សម្តេច សីហនុ មែន ក៏ពួកគេមានការខ្លាចរន្ធត់ណាស់ក្នុងការមកគោរពព្រះអង្គដូចកាលពីដើម ។ មានតែម្តងគត់ដែលហ្វូងប្រជាជនឈរនៅតាមចិញ្ចើមថ្នល់ជាតិមើលស្គាល់ព្រះអង្គ នៅពេលដែលរថយន្តមែរសីដេសពណ៌សរបស់សម្តេចឈប់ង៉ក់ ។ មនុស្សមួយចំនួនបានមើលឃើញព្រះភ័ក្ត្រព្រះអង្គតាមកញ្ចក់រថយន្ត ។ ពួកគេនាំគ្នាស្រែកឡើងថា "សម្តេចឪ! សម្តេចឪ" ហើយក៏ស្ទុះរត់តម្រង់ទៅរកព្រះអង្គភ្លាម ។ សម្តេច សីហនុ ដែលត្រូវធ្វើឲ្យរំភើបញាប់ញ័រព្រះទ័យបានមានបន្ទូលខ្សឹបដាក់អ្នកម្នាង ម៉ូនិក ថា "បុណ្ណឹងគ្រប់គ្រាន់ហើយ! ខ្ញុំទៅសំណេះសំណាលជាមួយពួកគេសិន" ហើយព្រះអង្គបម្រុងបើកទ្វារចុះពីរថយន្ត ។ ខៀវ សំផន ដែលនៅអង្គុយក្បែរអ្នកបើកបរបានបញ្ចេញទឹកមុខដូចបិសាចម្នាក់ និងនិយាយទៅកាន់សម្តេចថា "សូមព្រះអង្គរម្ងាប់អារម្មណ៍ និងសូមយាងមកគង់ក្នុងរថយន្តវិញ" ។ ចំណែកអ្នកម្នាង ម៉ូនិក បានអង្វរករឲ្យព្រះអង្គគង់នៅស្ងៀម កុំជិតទាស់នឹងបញ្ហារបស់គេ ។ ក្រោយមកអ្នកម្នាងបានមានបន្ទូលប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា ៖ តាមយោបល់របស់ខ្ញុំ(អ្នកម្នាង)ការដែល ខៀវ សំផន ធ្វើដូច្នេះគឺដើម្បីផលប្រយោជន៍ របស់សម្តេចតែប៉ុណ្ណោះ ។ ខៀវ សំផន ពុំចង់ធ្វើឲ្យព្រះអង្គប្រឈួន ព្រោះតែហ្វូងប្រជាជនទាំងនោះទេ ទាំងមិនចង់ឲ្យព្រះអង្គប្រថុយគ្រោះថ្នាក់នឹងការបះបោរមួយរបស់ប្រជារាស្ត្រផង ។ សម្តេច សីហនុ សព្វព្រះទ័យធ្វើតាមអ្នកម្នាងនិងយាងត្រឡប់មកកាន់រថយន្តវិញ ដែលបញ្ឆេះម៉ាស៊ីនចេញដំណើរទៅយ៉ាងរហ័សដូចបោះព្ួយ ។ អ្នកម្នាង ម៉ូនិក ក្រឡេកក្រោយឃើញប្រជាជនទាំងនោះលុត

ជន្លន់ចុះនិងស្អាបអន្លែលដីដែលសម្តេចទើបនឹងដាក់ព្រះបាទអម្បាញ់មិញនេះ ។

សម្រាប់សម្តេចក៏ដូចជាសម្រាប់ប្រជាជនខ្មែររាប់លាននាក់ ការថែរក្សាជីវិតរបស់ខ្លួនឲ្យគង់វង្សគឺជាក្តីកង្វល់មួយគ្រប់ពេលវេលា ។ សម្តេចត្រូវតែលេបមោទនភាពរបស់ព្រះអង្គទុកក្នុងព្រះទ័យ និងត្រូវតែយល់ព្រមបន្ទាបព្រះកាយតាមគេឯង ។ នេះជាតម្លៃដែលត្រូវបង់ ។ ក្រោយមកព្រះអង្គបានមានបន្ទូលប្រាប់រឿងអាថ៌កំបាំងមួយថា មានពេលមួយនោះ ព្រះអង្គមានព្រះទ័យសាកល្បងរើបម្រះដែរ ។ ប៉ុន្តែកាន់តែតស៊ូប្រឆាំងនឹងពួកគេខ្លាំងឡើងកាលណា គេកាន់តែរឹតបន្តឹងលើសមុនទៅទៀត ។ ពួកគេបានដកបុគ្គលិកធ្វើការរបស់ព្រះអង្គចេញទាំងអស់ ហើយកាត់ផ្តាច់ការទាក់ទងគ្រប់បែបយ៉ាងជាមួយព្រះអង្គទៀត ។ ពេញមួយឆ្នាំ១៩៧៧ ព្រះអង្គមិនដែលឃើញ ខៀវ សំផន ចូលមកគាល់ទាល់តែសោះ ។ នៅទីបំផុត ក្រោយពីមានជម្លោះដ៏យូរនិងយ៉ាងខ្លាំងជាមួយអ្នកម្នាង ម៉ូនិក ស្តីពីបញ្ហានៃការមិនព្រមចំណុះគេរួចមក សម្តេច សីហនុ បានព្រមចុះចាញ់ដើម្បីសេចក្តីសុខក្នុងគ្រួសារនិងញាតិវង្សរបស់ព្រះអង្គ ។ តាមបន្ទូលផ្ទាល់របស់ព្រះអង្គថា ព្រះអង្គបានយល់ព្រមលើកសរសើរខ្មែរក្រហម ។ ព្រះអង្គបានមានបន្ទូលនៅពេលក្រោយមកថា “ស្ថានភាពរបស់យើងត្រូវបានកែលម្អប្រសើរជាងមុនបន្តិច ប៉ុន្តែការបញ្ឆោរកផលប្រយោជន៍ទាំងនេះដែលខ្ញុំពុំដែលនឹកគិតម្តងណាសោះ សុទ្ធតែជាអំពើដែលធ្វើឲ្យអាប់កិត្តិយស ។ ខ្ញុំមិនដែលត្រូវគេបំបាក់មុខដូច្នេះទាល់តែសោះក្នុងមួយជីវិតខ្ញុំ” ។ អ្វីដែលជាការលួងលោមចិត្តតែមួយគត់គឺ“ស្នៀត”នេះប្រហែលជាបានជួយស្រោចស្រង់សម្តេច និងក្រុមគ្រួសាររបស់ព្រះអង្គឲ្យផុតពីគ្រោះថ្នាក់ដល់ជីវិតផងដែរ ។

ពិតណាស់ ភាពកាន់តែធ្ងន់ធ្ងរនៃជម្លោះជាមួយវៀតណាម យ៉ាងហោចក៏ជាចំណែកជួយសង្គ្រោះ“ស្ថានភាពអាក្រក់” របស់ព្រះអង្គខ្លះដែរ ។ ខ្មែរក្រហមបានផ្តើមធ្វើយុទ្ធនាការសម្លាប់រង្គាលរបស់ខ្លួនតាមរបៀបជាក្បួនទូវជនជាតិខ្មែរដើមកំណើតជាវៀតណាម ឬជនដែលត្រូវសង្ស័យថាមានសមានចិត្តចំពោះប្រទេសវៀតណាមដោយឥតបានផ្តល់ព័ត៌មានឲ្យសម្តេច សីហនុ ដឹងឡើយ ។ នៅខែមេសា ឆ្នាំ១៩៧៧ កើតមានការវាយឆ្មក់ដំបូងៗទៅលើភូមិវៀតណាមទាំងឡាយនៅតាមព្រំដែនពីសំណាក់ខ្មែរក្រហម ។ បណ្តាមេដឹកនាំចិនខ្លះបានប៉ាន់ប្រមាណយ៉ាងត្រឹមត្រូវអំពីគ្រោះថ្នាក់ផ្សេងៗដែលលេចចេញពីនយោបាយផ្សងព្រេងរបស់កម្ពុជាប្រជាធិបតេយ្យចំពេលមួយដែលប្រទេសរបស់ខ្លួនស្ថិតនៅឯកោទាំងស្រុងលើឆាកអន្តរជាតិ ។ គឺក្នុងហេតុផលនេះហើយដែលពួកមេដឹកនាំចិនបានណែនាំ ប៉ុល ពត ក្នុងឱកាសនៃការស្នាក់អាស្រ័យរបស់គាត់នៅក្រុងប៉េកាំងកាលពីខែកញ្ញា-តុលា ឆ្នាំ១៩៧៧ថា ត្រូវអនុញ្ញាតឲ្យសម្តេច សីហនុ យាងចូលស្រុកវិញ ហើយប្រើប្រាស់ព្រះកិត្តិស័ព្ទ និងប្រជាប្រិយភាពរបស់ព្រះអង្គដើម្បីកែលម្អរូបភាពកម្ពុជាប្រជាធិបតេយ្យនៅឯបរទេសជាថ្មី ។ ដើម្បីបង្ហាញឲ្យឃើញនូវការយកចិត្តទុកដាក់ចំពោះជោគវាសនារបស់មិត្តគាត់ លោកប្រធាន គីម អ៊ីលស៊ុង បានផ្ញើ “ផ្លែប៉ោម” មួយកន្ត្រកមកថ្វាយសម្តេចតាមរយៈ ប៉ុល ពត ដែរ ។

*នេះគឺជាជំនូនដ៏គួរជាទីរីករាយមួយដែលមិនដឹងខ្លួនជាមុន ។ ទង្វើតែមួយគត់ដែល ប៉ុល ពត ព្រមបំពេញមុខការនេះបង្ហាញឲ្យឃើញច្បាស់ថា គាត់ពិបាកនឹងជៀសវាងពីសម្តេច សីហនុ ណាស់ ។ ដោយតម្រូវឲ្យ ប៉ុល ពត ព្រមទទួលយកជំនូនទៅថ្វាយសម្តេច សឲ្យឃើញថា គឹម អ៊ីលស៊ុង ពិតជាយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្ហាញមិត្តភាពរបស់គាត់ ។ ប្រការនេះក៏ជាកម្លាំងលើកទឹកចិត្តមួយដែរ ។ សម្តេច សីហនុ ពុំបណ្តោយឲ្យកន្លងទៅនូវឱកាសទម្លាយភាពរស់នៅឯកោទាំងស្រុង ដែលក្នុងនោះព្រះអង្គបានត្រូវបង្ខាំងឲ្យនៅតែក្នុងវាំងតាំងពីដើមឆ្នាំ១៩៧៧ទេ ។ សម្តេចបានសរសេរចុតហ្មាយជាលើកដំបូងផ្ញើទៅឲ្យ ប៉ុល ពត ដើម្បីសម្តែងនូវ«ការដឹងគុណដ៏ជ្រាលជ្រៅ»របស់ព្រះអង្គ ។ លើកទីពីរ ក្នុងឱកាស«បុណ្យខួបកំណើតបក្សកុម្មុយនីស្តកម្ពុជាដ៏ជាញជ័យ» និងលើកទីបី ដើម្បីអបអរសរសើរ ប៉ុល ពត ចំពោះ«ជោគជ័យក្នុងដំណើរទស្សនកិច្ចរបស់គាត់នៅប្រទេសចិន និងកូរ៉េខាងជើង» ។ សារលិខិតទាំងនេះបានត្រូវផ្សព្វផ្សាយតាមវិទ្យុភ្នំពេញយ៉ាងឆាប់រហ័ស ។ សម្តេច សីហនុ បានកត់សម្គាល់របៀបលេងសើចថា អត្ថបទនៃសារលិខិតរបស់ព្រះអង្គបានត្រូវកែប្រែន័យរបៀបធ្វើយ៉ាងណាឲ្យទាល់តែ«ជំនូនដ៏សប្បុរស»នោះ ត្រឡប់ទៅជារបស់ ប៉ុល ពត ផ្ទាល់ទៅវិញ ។ របៀបបកស្រាយផ្សាយតាមវិទ្យុក៏ដូចគ្នាដែរ បានធ្វើឲ្យសម្តេចដឹងថា ព្រះអង្គរំភើបព្រះទ័យប៉ុនណានឹង«មនោសញ្ចេតនាមិត្តភាពនិងការស្រឡាញ់ថ្នាក់ថ្នមដ៏កក់ក្តៅ ដែលបក្សកុម្មុយនីស្តកម្ពុជាគិតគូរចំពោះព្រះអង្គ» ។ អនុស្សាវរីយ៍តែមួយនេះបានធ្វើឲ្យព្រះអង្គនៅតែចង់ផ្ទុះសំណើច ។ តាមពិតការដែលវិទ្យុភ្នំពេញរៀបរាប់បញ្ចូលព្រះនាមព្រះអង្គក្នុងបទអត្ថាធិប្បាយរបស់ខ្លួន គឺជាប្រផ្នូលមួយដែលធ្វើឲ្យព្រះអង្គសប្បាយព្រះទ័យជាង«ផ្លែប៉ោម»របស់ គឹម អ៊ីលស៊ុង ទៅទៀត ។ នេះគឺជាការស្នើមួយក្នុងភាពងងឹតដែលព័ទ្ធជុំវិញព្រះអង្គ ។*

# ជំពូកទី៨
# ការអុជអាលឱ្យរឹតតែមានរឿងធំ

ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ គឺជាថ្ងៃថ្មីមួយដែលប្រហែលជាគ្មានរឿងអាក្រក់កើតឡើងនៅទីក្រុងហូជីមិញឡើយ ។ បន្តិចម្តងៗ ព្រះអាទិត្យបានរះឡើងចោលកាំរស្មីមកលើកន្លែងសាងសង់នានាដែលស្ថិតក្នុងសភាពស្ងប់ស្ងាត់នៅឡើយ និងលើចុងឈើនានាដែលនៅត្រើយម្ខាងទៀតនៃទន្លេហូរកាត់ក្រុងព្រៃនគរ ។ នៅតាមមាត់ប្រាំងទន្លេ ជនជាតិចិន និងវៀតណាមយ៉ាងច្រើន ដែលស្លៀកពាក់ខោអាវភីហ្សាម៉ានិងអាវកាក់កំពុងហាត់ប្រាណតាមក្បាច់គុន តៃជិ ។ តាមមហាវិថីផ្លៀងហ៊ុយ និងនៅជុំវិញផ្សារធំ អ្នករស់នៅតាមចិញ្ចើមថ្នល់ អ្នកអត់ទីជម្រកកំពុងតែដេកលក់នៅឡើយដោយសណ្តូកខ្លួនផ្ទាល់ដី ។ អ្នករត់ឆៃកែវកំពុងរំកិលយានយឺតៗតាមផ្លូវក្រាលកៅស៊ូដើម្បីស្វែងរកម៉ូយដំបូងរបស់ខ្លួន ។ នៅកាច់ជ្រុងផ្លូវឡេថាញ់តុង ស្ត្រីចំណាស់លក់មីម្នាក់បានចាប់ផ្តើមរៀបចំតុកៅអីរបស់ខ្លួន ។ គ្មានអ្នកណាម្នាក់បង្ហាញឲ្យឃើញនូវការយកចិត្តទុកដាក់ស្តាប់បទចម្រៀងបដិវត្តន៍និងការឃោសនាដែលលាន់ឮពីប្រដាប់បំពងសំឡេងដែលគេរៀបចំនៅទីលានឡាមសុង នៅកណ្តាលទីក្រុងបន្តិចសោះឡើយ ។ ក្នុងពន្លឺដ៏ស្រទន់នៃពេលព្រឹកព្រហាម បណ្តាជនក្នុងទីក្រុងហាក់ដូចជានឹកស្រមៃទៅដល់ពេលវេលាមួយដែលខ្លួនធ្លាប់ហៅ«ទីក្រុងព្រៃនគរ»នៅឡើយ ។

ដំណើរចាប់មានសកម្មភាពឡើងវិញរបស់ទីក្រុងនៅពេលព្រឹកនោះ មានសភាពធ្វើឲ្យគេភ្ញាក់ផ្អើលបំផុត ។ រថយន្តយោធាជាច្រើនគ្រឿងបានលេចធ្លោឡើងភ្លាមៗដោយមិនដឹងជាចេញពីកន្លែងណាមក ។ ពួកប៉ូលិសដែលមានឯកសណ្ឋានពណ៌ប្រផេះក្រមៅ ទាហាននៃកងទ័ពវៀបរយ និងពួកនិស្សិតរាប់ពាន់នាក់ដែលមានប៉ាន់ដៃពណ៌ក្រហមបានលោតចុះព្រឹបៗពីរថយន្តទាំងនោះ ហើយចាប់ផ្តើមរាយគ្នាជាក្រឡាចក្រត្រួតត្រាព័ទ្ធជុំវិញទីក្រុងភ្លាម ។ ប្រត្តិបត្តិការដ៏ធំបំផុតមានរបៀបជាយោធាដែលអនុវត្តដោយរបបកុម្មុយនីស្តចាប់តាំងពីការផុតរលត់ទៅនៃសង្គ្រាម បានចាប់ផ្តើមហើយ ។ សត្រូវរបស់គេពេលនេះគឺ ក្រុមអ្នកជំនួញជាគហបតីដែលសេចក្តីសម្រេចអំពីជោគវាសនារបស់ខ្លួនទើបនឹងត្រូវប្រកាសតាមសេចក្តីជូនដំណឹងមួយ ដែលផ្សព្វផ្សាយដោយវិទ្យុរបស់រដ្ឋាភិបាល ។ ពួកប៉ូលិសដែលប្រដាប់អាវុធគ្រប់ដៃនៅឈរប្រុងដើងការពីមុខហាងទំនិញនានាកណ្តាលទីក្រុង ប៉ុន្តែមួយផ្នែកធំនៃកងទ័ពបានធ្វើចលនាឆ្ពោះទៅច្រឹឡឹង ជាទីក្រុងភ្លោះមួយរបស់ទីក្រុងហូជីមិញ ដែលមានជនជាតិចិនរស់នៅភាគច្រើនបំផុត ។ ត្រូវដាស់ឲ្យភ្ញាក់ពីដំណេកទាំងស៊ើងមមើងដោយសារភាពញ៉ូរកក្រើកនេះ អាណិកជនចិនរាប់ពាន់នាក់ដែលមិនសូវកក់ក្តៅក្នុងចិត្តបានមើលឃើញប៉ូលិសយ៉ាងច្រើនកាន់អាវុធភ្ជង់មកមុខនៅគ្រប់ទីកន្លែង ចំណែកទាហានស្ម័គ្រចិត្តនៅឈររាយគ្នាព័ទ្ធជុំវិញសង្កាត់តាមរបៀបជាក្បួន ។ មនុស្សភាគច្រើនជឿថា នេះគ្រាន់តែជាការបង្ហាញកម្លាំងធម្មតាមួយរបស់ពួកអាជ្ញាធរប៉ុណ្ណោះ ។ គេគិតថា កម្លាំងទាំងនេះនឹង

ធ្វើការចាប់ខ្លួនមនុស្សមួយចំនួន ជាការសងសឹកទៅនឹងការច្រួលច្របល់ដែលធ្វើឲ្យទីក្រុងវឹកវរកាលពីប៉ុន្មានថ្ងៃមុន ។

ដោយពិត កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ច្រឹឡឹងដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្មរបស់រដ្ឋធានីភាគខាងត្បូងគឺជាកន្លែងដែលកើតមានព្រឹត្តិការណ៍មួយប្លែកខុសពីធម្មតា ។ ការចាប់ខ្លួនយុវជនចិនម្នាក់ដែលរឹងទទឹងក្នុងពេលដែលកងទ័ពកំពុងកេណ្ឌអ្នកដែលមានអាយុត្រូវធ្វើទាហាន បានបណ្ដាលឲ្យមានការប្រមូលផ្ដុំគ្នាពាក់ពួនហើយបានប្រែក្លាយយ៉ាងឆាប់រហ័សទៅជាបាតុកម្មមួយដែលកើតឡើងឯងៗប្រឆាំងនឹងរបបដឹកនាំប្រទេស ។ រូបថតមួយសន្លឹករបស់ ម៉ៅ សេទុង ត្រូវបានបាតុករលើកគ្រវីឡើងលើ ។ មនុស្សប្រមាណ២០០នាក់ភាគច្រើនជាអាណិកជនចិន បានដើរដង្ហែជាក្បួននៅតាមផ្លូវនានានៃក្រុងច្រឹឡឹងដោយស្រែកបន្ទរពាក្យស្លោកដដែលៗ ។ ពួកបាតុករបានទាមទារឲ្យបញ្ជូនពួកគេទៅមាតុប្រទេសវិញ ដោយបដិសេធការនិរទេសទៅកាន់“តំបន់សេដ្ឋកិច្ចថ្មី” ដែលពិបាកក្នុងការរស់នៅនិងការជ្រើសរើសយុវជនក្មេងៗបញ្ចូលទៅក្នុងកងទ័ពវៀតណាមដោយបង្ខំ ។ ទស្សនវិស័យនៃករណីយកិច្ចបម្រើជាទាហានគ្មានឋានន្តរសក្តិ ដែលគេប្រើឲ្យស្លាប់ក្នុងជម្លោះព្រំដែនជាមួយប្រទេសកម្ពុជាដែលកាន់តែស្រួចស្រាល់ឡើងៗនោះ គ្មានអ្វីធ្វើឲ្យពួកគេមានទឹកចិត្តសោះ ។ ពួកប៉ូលិសបានវាយសម្រុកបំបែកហ្វូងបាតុករដោយប្រើដំបង ហើយបានចាប់មនុស្សប្រហែលដប់ពីរនាក់ ។

វាលេចរូបរាងយ៉ាងឆាប់រហ័ស ៖ ការពង្រាយកម្លាំងប៉ូលិសនៅថ្ងៃទី២៤ ខែមីនា នេះគឺតម្រង់ទៅរកគោលដៅធំផ្សេងមួយទៀត ។ ទីក្រុងច្រឹឡឹងនឹងត្រូវប្រហារចំបេះដូងតែម្ដង ។ មនុស្សប្រដាប់អាវុធទាំងនេះ បានឈរប្រុងជើងការតាមដងផ្លូវជាប់ជានិច្ច ខណៈដែលទាហានស្ម័គ្រចិត្តក្មេងៗចូលឆែកឆេររបៀបជាក្បួនតាមផ្ទះនិងហាងលក់ទំនិញទាំងឡាយដើម្បីស្វែងរកមាសនិងរូបិយប័ណ្ណផ្សេងៗដែលត្រូវយកទៅតម្កល់ទុកក្នុងឃ្លាំង ។ ពួកគេក៏ធ្វើបញ្ជីសារពើភ័ណ្ឌកត់ត្រាទ្រព្យសម្បត្តិទាំងអស់ដែលរដ្ឋាភិបាលមានបំណងរឹបអូសធ្វើជាទ្រព្យសម្បត្តិរដ្ឋដែរ ។ ការរុករើតំបន់នេះបានបើកឱកាសឲ្យគេរកឃើញបរិមាណដុំមាសនិងលុយដុល្លារមួយចំនួនធំ ដែលត្រូវគេដឹកជញ្ជូនយកទៅទុកនៅកន្លែងសុវត្ថិភាពយ៉ាងរហ័ស ។ បម្រាមមួយ ត្រូវបានប្រកាសឡើងសម្រាប់អ្នកជំនួញទាំងអស់ ដោយហាមមិនឲ្យលក់ដូរទ្រព្យសម្បត្តិទាំងឡាយដែលបានចុះបញ្ជីសារពើភ័ណ្ឌនិងដែលប្រកាសថាជារបស់ជាតិរួចហើយទេ ។ ប្រជាជនវៀតណាមសាមញ្ញដែលមិនសប្បាយនឹងឃើញការរលំដួលនៃអាណត្តិរបស់ទីក្រុងច្រឹឡឹង បានដើរនិយាយបរិហារថា ៖ រដ្ឋាភិបាលបានរឹបអូសមាសរហូតដល់ប្រាំពីរតោនឯណោះ ។ តាមការឆ្លើយឲ្យការណ៍របស់អ្នកទេសចរបរទេសម្នាក់ ក្នុងចំណោមអ្នកទេសចរបរទេសដ៏កម្រមាន ដែលមានវត្តមានផ្ទាល់នឹងកន្លែងបាននិយាយថា “ទីក្រុងហូជីមិញ ហាក់ដូចជាត្រូវធ្វើឲ្យឆ្លល់ស្រឡាំងកាំង ។ ដោយទ័លប្រាជ្ញមិនដឹងគិតយ៉ាងណា មនុស្សជាច្រើនបានរត់ឆ្លេឆ្លាចុះឡើងប្រៀបដូចកណ្ដុរជាប់ទ្រុងក្នុងភាពអស់សង្ឃឹមហួសកម្រិត” ។ អាណិកជនចិនដប់ប្រាំបីនាក់បានធ្វើអត្តឃាតនៅក្រោយថ្ងៃដ៏ច្របល់វឹកវរនោះ ។

រដ្ឋាភិបាលវៀតណាមមិនដែលលាក់បាំងគោលបំណងរបស់ខ្លួនក្នុងការបង្កើតឲ្យមានលទ្ធិសង្គមនិយម នៅ

ភាគខាងត្បូងតាមកាលបរិច្ឆេទដែលខ្លួនកំណត់នៅឆ្នាំ១៩៨០ឡើយ ។ ប៉ុន្តែ ដំណើរកើតឡើងភ្លាមៗ និងប្រតិបត្តិការដ៏មានទ្រង់ទ្រាយធំធេងនេះបានធ្វើឲ្យពិភពលោកភ័ន្តភាំងស្រឡាំងកាំង ។ តាំងពីឆ្នាំ១៩៧៥ រដ្ឋាភិបាលថ្មីរបស់កុម្មុយនីស្តបានដាក់ឲ្យមានការកែទម្រង់ខាងរូបិយវត្ថុមួយ ដែលបណ្តាលឲ្យប្រជាជនវៀតណាម នៅភាគខាងត្បូងរលាយហិនហោចទ្រព្យសម្បត្តិអស់ ។ តាំងពីនោះមក រដ្ឋបានខ្នះខ្នែងជាច្រើនលើកច្រើនសាដើម្បីបង្កើនការត្រួតត្រារបស់ខ្លួនទៅលើសហគ្រាសឯកជននានានិងដាក់បន្ទុំឲ្យបង់ពន្ធកាន់តែធ្ងន់ឡើងៗ ។ ប៉ុន្តែ ក្នុងការរឹតបន្តឹងនេះ វាហាក់ដូចជាមានចន្លោះប្រហោងមួយដែលអ្នកជំនួញចិនចិត្តស្លុយអាចចេញរួចជានិច្ច ។ លើកនេះពួកគេត្រូវវាយដុំបំផ្លិចឲ្យលែងកម្រើកកើតតែម្តង ។ ទាហានស្ម័គ្រចិត្តក្មេងៗរាប់ពាន់នាក់ដែលបានហ្វឹកហាត់ជាពិសេសនៅកន្លែងផ្សេងៗឆ្ងាយដាច់ពីគេឯង បានមកជួយពួកកម្មាភិបាលបក្សនិងភ្នាក់ងាររបស់រដ្ឋដែរ ។ ការចូលទៅឆែកឆេរក្នុងសហគ្រាសទាំងឡាយកាន់តែកើនច្រើនឡើងៗ អ្វីៗដែលសំខាន់សុទ្ធតែត្រូវត្រួតពិនិត្យលើកលែងតែភោជនីយដ្ឋានចេញ ។ តែមួយភ្លែតសោះ គ្រួសារចំនួន៣០.០០០បានត្រូវគេដណ្តើមយកទ្រព្យសម្បត្តិអស់រលីងពីខ្លួន និងដកហូតមធ្យោបាយចិញ្ចឹមជីវិតថែមទៀត ។ ថ្ងៃទី៣ ខែឧសភា ក្រដាសប្រាក់របស់វៀតណាមខាងត្បូងត្រូវលុបបំបាត់ចោល ។ អ្នករក្សាទុកលុយច្រើនៗបានបាត់បង់អ្វីៗទាំងស្រុង ឬស្ទើរតែទាំងអស់ ។ តាមច្បាប់គេអាចប្តូរក្រដាសប្រាក់ដែលអស់តម្លៃជាមួយនឹងក្រដាសប្រាក់ថ្មីបាន ប៉ុន្តែចំនួនក្រដាសប្រាក់ដែលរដ្ឋបញ្ចេញឲ្យធ្វើចរាចរមានតិចតួចបំផុត[1] ។

ការផ្លាស់ទ្រង់ទ្រាយភាគខាងត្បូងឲ្យទៅជារបបសង្គមនិយមដែលគេប្រកាសឲ្យដឹងតាំងពីយូរមកហើយនោះ នៅទីបំផុតបានចាប់ផ្តើម ។ ការវាយប្រហារចំៗប្រឆាំងនឹងរបបមូលធននិយមបានកើតមានព្រមគ្នាជាមួយនឹងការចាប់ផ្តើមអំពើប្រទូសរ៉ាយដោយចេញមុខរវាងប្រទេសវៀតណាមនិងប្រទេសចិនសង្គមនិយមដែរ ។

ដ្បិតរហូតមកដល់កាលបរិច្ឆេទនេះ ការវាយប្រហារដោយពាក្យសម្តីរវាងប្រទេសទាំងពីរមានសភាពដូចជាដាវនៅក្នុងស្រោមនៅឡើយ ។ ចាប់ពីពេលនេះទៅ រឿងនោះគ្មានអីទាក់ទងនឹងជម្លោះជាចំហរវាងវៀតណាមនិងកម្ពុជាទេ ។ ក្រុងហាណូយគ្រាន់តែនិយាយបរិហារជាសាធារណៈពី«ពួកប្រតិកិរិយាអន្តរជាតិ» ដែលផ្គត់ផ្គង់អាវុធឲ្យខ្មែរក្រហមប៉ុណ្ណោះ ចំណែកក្រុងប៉េកាំងវិញបានវាយប្រហារចំពោះ«អ្នកចេញមុខកាន់ជើងគំនិតអនុត្តរភាពនិយម»...ដោយចៀសវាងមិនបញ្ចេញឈ្មោះអ្នកទាំងនោះផងទេ ។ ប៉ុន្តែការវាយប្រហារទៅលើក្រុងច្រឹឡឹង និងការចាកចោលស្រុកទាំងហ្វូងៗជាបន្តបន្ទាប់គ្នា របស់ជនជាតិចិននៅវៀតណាមបានផ្លាស់ប្តូរអ្វីៗទាំងស្រុង ។ ប្រទេសចិនបានថ្កោលទោសជាផ្លូវការចំពោះប្រតិបត្តិការរបស់វៀតណាមនេះ ។ ក្នុងពេលជាមួយគ្នានោះ នៅប្រទេសកម្ពុជា បរាជ័យនៃការងើបបះបោរមួយប្រឆាំងនឹង ប៉ុល ពត ប្រហែលជានឹងនាំឲ្យមានអន្តរាគមន៍មួយរបស់វៀតណាមប្រឆាំងនឹងប្រទេសនេះដោយចៀសមិនផុត ។ម្យ៉ាងទៀត ការជាប់ដៃរបស់វៀតណាមក្នុងជម្លោះជាចំហមួយជាមួយប្រទេសចិន បានធ្វើឲ្យសហប្រតិបត្តិការរវាងវៀតណាមនិងសហភាពសូវៀត

មានល្បឿនកាន់តែលឿនទៅមុខសឹងតែដោយស្វ័យប្រវត្តិ ។ អ្វីៗទាំងអស់ស្ថិតនៅតាមកន្លែងស្រេច ដើម្បីនឹងបើកផ្លូវទៅរកជម្លោះមួយដែលនឹងហៀរហួសពីព្រំដែនវៀតណាម និងកម្ពុជាទៅទៀត ។

ការចូលលុកលុយរបស់ពួកកុម្មុយនីស្តវៀតណាមប្រឆាំងនឹងក្រុងច្រឺឡឹងដែលជាមជ្ឈមណ្ឌលមូលធននិយមដ៏សំខាន់ ពុំមែនកើតឡើងដោយឥតព្រាងទុកជាមុននោះទេ ។ ពិតហើយ គេអាចបើកធ្វើយុទ្ធនាការនេះក្រោយពីការចេញដំណើររបស់អ្នកកាសែតបរទេសទាំងអស់ដែលមកស៊ើបអង្កេតអំពីការបង្កហេតុរបស់ខ្មែរក្រហមនៅតាមព្រំដែននៃប្រទេសទាំងពីរតែប៉ុណ្ណោះ ។ ចំណែកខ្ញុំ(អ្នកនិពន្ធ) ខ្ញុំបានស្ថិតនៅទីក្រុងហូជីមិញ រហូតដល់ថ្ងៃទី២០ ខែមីនា ។ ខ្ញុំបានធ្វើដំណើរទៅសួរសុខទុក្ខមិត្តភក្តិចាស់ៗនៅក្នុងទីក្រុងច្រឺឡឹង និងបរិភោគបាយជាមួយពួកគេយ៉ាងសប្បាយរីករាយក្នុងភោជនីយដ្ឋានចិននានាដែលមានមនុស្សស៊ីផឹកចង្អៀតណែន ។ ភាពផ្ទុយគ្នារវាងផ្សារច្រឺឡឹងដែលមានមនុស្សកុះករ និងពោរពេញទៅដោយទំនិញនាំចូលដោយគេចពន្ធ ឬផលិតក្នុងស្រុក និងតុតាំងទំនិញនៅផ្សារទីក្រុងហាណូយដែលគ្មានទំនិញដាក់ព្រោះត្រូវដកហូតគ្មានសល់យ៉ាងគួរឲ្យអាណិត បានធ្វើឲ្យខ្ញុំស្រឡាំងកាំង ។ អ្នកអមដំណើរខ្ញុំសុទ្ធតែជាវៀតណាមខាងជើងដែលមកពីក្រសួងការបរទេសបានឈរសម្លឹងមើលទំនិញសម្ភារប្រើប្រាស់គ្រប់មុខ ក្នុងទូកញ្ចក់ទាំងភ្ញាក់ភ្លាំង ដោយសារពួកគេទើបតែបានឃើញជាលើកដំបូងបំផុត ប៉ុន្តែបានដកថយមកវិញ នៅពេលដែលឃើញប័ណ្ណតម្លៃរបស់វា ។ ខ្ញុំបានឮប្រជាជនរអ៊ូរទាំពីអាកប្បកិរិយាពួកកម្មាភិបាលក្រុងហាណូយតាំងពីពេលនោះម្ល៉េះ ដែលត្រូវចោទប្រកាន់ថា បានដណ្តើមភាគខាងត្បូង ហើយខ្ញុំដណ្តឹងសួរក្នុងចិត្តថា តើភាគខាងជើងដែលមានរបៀបរបបរស់នៅតឹងរ៉ឹងត្រូវការពេលវេលាប៉ុន្មានដើម្បីទប់ទល់នឹង«មន្តស្នេហ៍»របស់ទីក្រុងច្រឺឡឹងបាន? ឡេ ក្វាងចាន់ អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍នៃអតីតរដ្ឋធានីភាគខាងត្បូង បាននិយាយប្រាប់ខ្ញុំថា «ភារកិច្ចរបស់យើងគឺត្រូវធ្វើឲ្យទីក្រុងមួយទាំងមូលឆ្ពោះទៅរកការបង្កើនផលិតផលឧបភោគ-បរិភោគ ទីក្រុងមួយដែលប្រើប្រាស់ពេលវេលាទាំងអស់សម្រាប់ការផលិត ដើម្បីឲ្យសក្តិសមនឹងឈ្មោះហូជីមិញ» ។ គូសន្ទនារបស់ខ្ញុំនៅតែមិនប្រាកដសោះក្នុងការរៀបរាប់អំពីដំណើរផ្លាស់ប្តូរសង្គមទាំងស្រុងនេះ ។

ខ្ញុំបានវិលត្រឡប់ទៅក្រុងហាណូយវិញនៅថ្ងៃ២៣ ខែមីនា ដូចដែលគ្រោងទុកជាមុន ។ ការចេញដំណើររបស់ខ្ញុំពីប្រទេសវៀតណាមត្រូវបានកំណត់ជាមុនសម្រាប់ថ្ងៃស្អែកព្រឹក ។ ប៉ុន្តែខ្ញុំមានពេលវេលារកឃើញមូលហេតុផ្សេងៗនៃការទាមទារដោយទទូចរបស់វៀតណាមដែលកាត់បន្ថយការស្នាក់អាស្រ័យរបស់យើង ។ ក្នុងឱកាសលៀងសាយភោជន៍ដែលរៀបចំឡើងសម្រាប់យើងដោយគណៈកម្មាធិការទំនាក់ទំនងវប្បធម៌ជាមួយបរទេស ខ្ញុំបានជួបសំណេះសំណាលជាមួយ ហុង ហា អ្នកទទួលខុសត្រូវអត្ថបទផ្នែកសេដ្ឋកិច្ចរបស់កាសែតញ៉ានហ្សិន អំពីបញ្ហាជាច្រើនស្តីពីការកសាងលទ្ធិសង្គមនិយមនៅវៀតណាមខាងត្បូង ។ បីឆ្នាំក្រោយ ការរំដោះថ្មីបើមានការកែទម្រង់ខាងរូបិយវត្ថុដែលមានលក្ខណៈប្រឆាំងនាយទុនក៏ដោយ ក៏សេដ្ឋកិច្ចនៅភាគខាងត្បូងនៅតែ

ពីផ្នែកដាសំខាន់លើការផ្ដើមគំនិតរបស់ឯកជនជានិច្ច ។ ស្ទើរតែគ្រប់វិស័យខាងផ្នែកឧស្សាហកម្ម និងពាណិជ្ជកម្ម ខាងស្រូវអង្ករ ដែលជាផ្នែកយុទ្ធសាស្ត្រសំខាន់បំផុតនោះ សុទ្ធតែត្រូវត្រួតត្រាដោយពួកសហគ្រិនឯកជនចិនទាំងអស់ ។ តាមការវាយតម្លៃខ្លះថា ច្រឹឡឹងជាទីក្រុងតែមួយគត់ដែលក្រសោបទ្រព្យធនជារូបិយវត្ថុភាគខាងត្បូងដល់ទៅពាក់កណ្ដាល ហើយភាគច្រើននៃទុនជាមាសនិងរូបិយប័ណ្ណកំពុងក្លាយទៅជារបស់មួយដែលប្រឆាំងឥទ្ធិពលផ្នែកសេដ្ឋកិច្ចដ៏មានសក្ដានុពល[២] ។ ច្រឹឡឹង ជា«បេះដូងមូលធននិយមមួយដែលកំពុងលោតក្នុងខ្លួនប្រាណសង្គមនិយមវៀតណាម» ។ តាមមតិរបស់ ហុង ហា ថា ប្រការនេះជាសញ្ញាប្រាប់ឲ្យដឹងនូវការអត់ឃ្លាន ផ្សារងងឹត និងអតិផរណាដែលធ្វើឲ្យមានអន្តរាយដល់ភាគខាងត្បូងជាសាធារណៈ ។ ខ្ញុំសួរថា តើលោកគ្រោងដោះស្រាយបញ្ហានេះដោយរបៀបណាទៅ? ហុង បានឆ្លើយតបមកខ្ញុំវិញជាមួយការញញឹមរបៀបចំអកលេងថា «យើងបានគិតគូរពីរឿងនេះហើយ» ។ ថ្ងៃស្អែកឡើង កម្មាភិបាលបក្សនិងសមាជិកនៃកម្លាំងសន្តិសុខរាប់ពាន់នាក់បានចាប់ផ្ដើមធ្វើ«ការវះកាត់បេះដូង»មួយយ៉ាងធំសម្បើម ។

ក្រោយមកខ្ញុំបានដឹងថា ការរៀបចំប្រុងប្រៀបធ្វើការវាយប្រហារប្រឆាំងនឹងមូលធននិយមនិងឥទ្ធិពលសេដ្ឋកិច្ចរបស់ជនជាតិចិននៅភាគខាងត្បូង បានមានឡើងព្រមគ្នានឹងការរៀបចំប្រុងប្រៀបមួយទាក់ទងនឹងកម្ពុជាផងដែរ ។ ក្នុងចលនាព្រមគ្នាតែមួយ ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមដែលរួមប្រជុំនៅពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ១៩៧៨បានសម្រេចចិត្តបង្កើតឲ្យមានចលនាតស៊ូមួយប្រឆាំង ប៉ុល ពត និងដើម្បីសន្តិសុខប្រទេសបានពិនិត្យពិច័យពីផលវិបាកទាំងឡាយ ដែលលេចចេញពីការត្រួតត្រាផ្នែកសេដ្ឋកិច្ចដោយពួកជនជាតិចិននៅភាគខាងត្បូងទៀតផង ។ គេស្ថិតនៅក្នុងស្ថានភាពជិតដល់ការប្រឈមមុខមួយថ្មីនិងធ្ងន់ធ្ងរជាមួយកម្ពុជា ដែលជាសម្ពន្ធមិត្តរបស់ប្រទេសចិនហើយ ។ ការមន្ទិលរបស់វៀតណាមប្រឆាំងនឹងសហគមន៍ចិនដ៏មានអំណាចបានត្រូវពង្រឹងថែមទៀតនៅខែមករា តាមរយៈនយោបាយថ្មីដែលផ្ដើមឡើងដោយក្រុងប៉េកាំងចំពោះជនជាតិចិននៅបរទេសដែលអំពាវនាវឲ្យអ្នកទាំងនោះរួបរួមគ្នា គាំទ្រការតស៊ូ«ប្រឆាំងអនុត្តរភាព»ចាប់ពីថ្ងៃនេះតទៅ ។ នៅពាក់កណ្ដាលខែមីនា ឆ្នាំ១៩៧៨ ការិយាល័យនយោបាយវៀតណាមបានរួមប្រជុំគ្នាជាថ្មីនៅទីក្រុងហូជីមិញក្នុងលក្ខណៈសម្ងាត់បំផុត ដើម្បីរៀបចំបញ្ចប់ផែនការល្អិតល្អន់ចុងក្រោយរបស់ខ្លួនក្នុងការវាយលុកប្រឆាំងទីក្រុងច្រឹឡឹង ។ ការសម្រេចចិត្តដែលហាក់ដូចជាវាសនាតម្រូវនេះ នឹងបណ្ដាលឲ្យមានការចាកចោលស្រុកទាំងហ្វូងៗមួយ ក្នុងចំណោមការចាកចោលស្រុកទាំងហ្វូងទាំងហ្វូងយ៉ាងធំសម្បើមក្រោយសម័យសង្គ្រាម ។ ការសម្រេចចិត្តនេះនឹងបន្ថែមទំហំនៃការរើសអើងជាតិសាសន៍ថ្មីមួយទៅក្នុងជម្លោះផ្សេងៗដែលកំពុងធ្វើឲ្យអ្នកជាតិនិយមនៅអាស៊ីប្រឈមមុខដាក់គ្នាផងដែរ ។

## បណ្ឌិត ហេ្សខីល *(Jekyll)* និងលោក ហៃដ៍ *(Hyde)* នៅសង្កាត់ចិន**

ភាពតានតឹងរវាងចិន-វៀតណាមនៅរដូវក្ដៅឆ្នាំ១៩៧៨ គ្រាន់តែជាវគ្គមួយនៃប្រវត្តិសាស្ត្រដ៏យូរលង់មួយប៉ុណ្ណោះដែលដើមកំណើតរបស់វាក៏ច្រឡំបល់នឹងដើមកំណើតរបស់ប្រជាជាតិវៀតណាមដែរ តិចឬច្រើនតែងតែបង្កឲ្យមានជម្លោះមួយរវាងគ្នានឹងគ្នាជានិច្ច ។ ការធ្វើអន្តោប្រវេសន៍លើកដំបូងរបស់ជនជាតិចិនចូលមករស់នៅក្នុងប្រទេសវៀតណាមមានឫសគល់តាំងពីសតវត្សរ៍ទីបីមុនគ្រិស្តសករាជម៉្លេះ ។ ក្នុងរយៈពេលពីរពាន់ឆ្នាំជាបន្តបន្ទាប់មកទៀត-ហើយជាពិសេសក្នុងថិរវេលា៩០០ឆ្នាំនៃការត្រួតត្រារបស់ចិនលើភាគខាងជើងវៀតណាម-រលកនៃការធ្វើអន្តោប្រវេសន៍របស់ជនជាតិចិន មានទាំងទាហានរំសាយ អ្នករាជការ អ្នកធ្លាប់ជាប់គុក និងពួករត់ចោលជួរ បានចូលមករស់នៅវៀតណាមបន្តគ្នាបណ្ដាក់ដូចខ្សែ ។ ប្រឈមមុខនឹងការចូលមកយ៉ាងកុះករ ឥរិយាបថរបស់បណ្ដាមេដឹកនាំប្រទេសវៀតណាមដែលឯករាជ្យ តែងតែបង្ហាញឲ្យឃើញលក្ខណៈពីរយ៉ាងផ្ទុយគ្នាជានិច្ច ៖ ពួកគេព្រមទទួលដោយរីករាយនូវការរួមកម្លាំងរបស់ជនជាតិចិន ដើម្បីពង្រឹងរបបរបស់ខ្លួន ប៉ុន្តែក៏ព្រឺខ្លាចពួកចិនទាំងនោះបង្កជាឧបសគ្គផ្សេងៗ នៅថ្ងៃណាមួយដែរ ។ ពួកអន្តោប្រវេសន៍ចិនបានរួបរួមជាសហគមន៍មួយដែលសុទ្ធសឹងជាអ្នកស្រឡាញ់ការងារ និងគោរពវិន័យដែលអាចរួមវិភាគទានក្នុងការកាប់ឆ្ការរានដីថ្មី, ការតាំងជាអាណានិគមលើដីថ្មីៗ ការអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មនិងការលាតសន្ធឹងនៃអធិបតេយ្យភាពរបស់វៀតណាមថែមទៀត ។ នៅសតវត្សរ៍ទី១៧ អ្នកកាន់ជើងសន្តតិវង្សមិញ *(Ming)* រាប់រយពាន់នាក់ដែលគេដកហូតសិទ្ធិ ហើយដែលកំពុងរត់គេចពីអ្នកឈ្លានពានម៉ាន់ជូ *(Mandchou)* បានមកដល់ក្រុងព្រៃនគរ ចំណែកមេដឹកនាំខ្មែរដែលគ្រាន់តែមានឈ្មោះថា ជាអ្នកគ្រប់គ្រងនោះ ពុំដឹងប្រកាន់យកឥរិយាបថបែបណាឡើយចំពោះនិគមជនប្រដាប់អាវុធទាំងនេះ ។ ហេតុនេះហើយបានជាមេដឹកនាំខ្មែរបានស្នើសុំឲ្យប្រមុខនៃសន្តតិវង្សង្វៀន របស់វៀតណាមជួយព្រះអង្គផង ។ ដោយមិនបង្អង់យូរ មេដឹកនាំសន្តតិវង្ស ង្វៀន បានបង្ខំឲ្យអ្នកទាំងនោះគោរពតាមខ្លួននិងយកទៅដាក់ឲ្យរស់នៅកន្លែងមួយមិនឆ្ងាយពីព្រៃនគរប៉ុន្មានឡើយ ទីនោះគឺស្ថិតនៅត្រង់ផ្សារច្រឹឡឹងបច្ចុប្បន្ននេះ ។ ដើម្បីជាថ្នូរទីក្រុងព្រៃនគរបានទទួលស្គាល់សិទ្ធិអធិរាជលើប្រទេសចំណុះរបស់សន្តតិវង្ស ង្វៀន ។ ក៏ប៉ុន្តែ ទាហានចិនមួយក្រុមផ្សេងទៀតដែលដឹកនាំដោយម៉ាក់គូ *(Mac Cu)* បានមកតាំងនៅតំបន់ ហាទៀង *(Ha Tien)* ដែលនៅពេលនោះជាដីរបស់កម្ពុជានៅឡើយ ។ ម៉ាក់គូ ដែលប្រកាសខ្លួនឯងជា "ព្រះរាជានៅហាទៀង" បានរៀបចំ ដែនដីរបស់ខ្លួនទៅជាកន្លែងពាណិជ្ជកម្មដ៏រីកលូតលាស់មួយនិងពង្រីកការត្រួតត្រារបស់ខ្លួនទៅលើបណ្ដាខេត្តជិតខាងទៀត ។ ព្រះអង្គបានសម្រេចដាក់ខ្លួននៅក្នុងឱវាទ(ខាងនយោបាយ) ព្រះចៅអធិរាជ ង្វៀន ដោយហេតុនេះ ព្រះអង្គបានពង្រីកដែនដីរបស់វៀតណាមរហូតមកដល់ព្រំដែនភាគខាងត្បូងបច្ចុប្បន្នរបស់ខ្លួន[៣] ។

ប៉ុន្តែដោយប្រើប្រាស់ពួកនិគមជនចិនទាំងនេះ ពួកមេដឹកនាំវៀតណាមពុំដែលធ្វេសប្រហែសនឹងពួកអ្នក

ទាំងនោះឡើយ ។ ពួកនេះសុទ្ធតែមានដើមកំណើតនៅប្រទេសដ៏ធំល្វឹងល្វើយមួយដែលធ្លាប់មានមហិច្ឆតាយកប្រទេសវៀតណាមដាក់ជាចំណុះ ហើយប្រការនេះឯងដែលគ្រប់គ្រាន់ធ្វើឲ្យពួកគេត្រូវជាប់សង្ស័យមិនចេះចប់ ។ ក្នុងរយៈពេលនៃការបះបោររបស់បងប្អូនត្រកូល តៃសុន បីនាក់ដែលបានដឹកនាំការបះបោរមួយប្រឆាំងនឹងព្រះចៅអធិរាជវៀតណាមនៅសតវត្សរ៍ទី១៨នោះ ជនជាតិចិននៅច្រឹឡឹងមួយម៉ឺននាក់បានត្រូវពួកបះបោរសម្លាប់យ៉ាងរង្គាល ។ ក្នុងអំឡុងពេលដែលមានសភាពធូរស្រួលខ្លះ ពួកជនជាតិចិនរស់នៅមានសេរីភាពបរិបូរណ៍និងរកស៊ីធ្វើមានធ្វើបាន ប៉ុន្តែនៅតែរស់នៅដាច់ដោយឡែកពីប្រជាជនវៀតណាមជានិច្ច ។ នៅឆ្នាំ១៨៤០ អធិរាជ មិញ ម៉ាង នៃសន្តតិវង្ស ង្វៀន ដែលធ្លើងឆ្ងល់ដោយសម្គាល់ឃើញមន្ត្រីជាន់ខ្ពស់ អមព្រះរាជាសៀមអនុញ្ញាតឲ្យពួកជនជាតិចិនរស់នៅរួមគ្នាជាមួយប្រជាជនក្នុងស្រុកនោះ បាននិយាយទុកជាមុនថា ការធ្វេសប្រហែសមិនបំបែកជនជាតិទាំងនោះឲ្យរស់នៅដាច់ដោយឡែកពីគ្នា នឹងនាំទៅដល់ការដួលរលំប្រទេសសៀមមិនខាន[៤] ។

អ្នកឯកទេសជប៉ុនម្នាក់ខាងបញ្ហាទាំងនេះបានកត់សម្គាល់ដោយត្រឹមត្រូវបំផុតថា «ជនជាតិចិននៅវៀតណាមគឺខុសគ្នាតិចតួចពីរឿងប្រលោមលោកមានចំណងជើងថា បណ្ឌិត ហ្សេខឹល និងលោក ហៃដ៍ ៖ ពួកគេសុទ្ធតែជាមនុស្សប្រកបដោយគ្រោះថ្នាក់ដែលត្រូវតែឃ្លាំមើលឲ្យជិតដល់ជានិច្ច និងជាសហគមន៍មួយដែលគេអាចប្រើប្រាស់ជាប្រយោជន៍យ៉ាងអស់ពីចិត្តផង... ។ បណ្ដាអធិរាជនៃសន្តតិវង្ស ង្វៀន ដែលជាអ្នកផ្ដល់សេចក្ដីអនុគ្រោះដល់សហគមន៍ចិន ក៏ព្រួយបារម្ភអំពីទំនាក់ទំនងផ្សេងៗរបស់ពួកនេះជាមួយប្រទេសកំណើតរបស់គេដែរ ដោយប្រើប្រាស់ពួកនេះដើម្បីឲ្យយកការណ៍អំពីស្ថានការណ៍នៅប្រទេសចិន ក្នុងគោលបំណងកែលម្អទំនាក់ទំនងរវាងប្រទេសទាំងពីរឲ្យរឹតតែប្រសើរឡើង»[៥] ។

ថ្វីបើបក្សកុម្មុយនីស្តវៀតណាមហាក់ដូចជាទទួលដំណែលដែលមានភិនភាគពីរផ្ទុយគ្នាដ៏សំខាន់ក៏ដោយ ក៏ឥរិយាបថរបស់ខ្លួនចំពោះចិនមានលក្ខណៈជាក់លាក់ណាស់ ដោយសារភាពដូចគ្នាផ្នែកមនោគមវិជ្ជារវាងក្រុងប៉េកាំង និងហាណូយក្នុងទសវត្សរ៍៥០និង៦០ និងដោយសារវៀតណាមត្រូវការកិច្ចគាំទ្រផ្នែកសម្ភារសឹកក្នុងការតស៊ូដើម្បីការបង្រួបបង្រួមប្រទេសរបស់ខ្លួនឡើងវិញ ។ តាមការពិតសហគមន៍ចិននៅភាគខាងជើងមានចំនួនតិចតួចប៉ុណ្ណោះ (១៥ភាគរយក្នុងចំនួនជនជាតិចិនទាំងអស់ដែលរស់នៅវៀតណាម) ហើយភាគច្រើនមានមុខរបរជាកម្មករ អ្នកធ្វើការក្នុងអណ្ដូងរ៉ែ និងអ្នកនេសាទ ដូច្នេះការដាក់ពួកគេឲ្យមានក្របខ័ណ្ឌដោយបក្សពុំបង្ហាញឲ្យឃើញនូវការលំបាកធំដុំទេ ។ លក្ខន្តិកៈរបស់ពួកអាណិកជនប្រមាណដប់ម៉ឺននាក់នេះ ក្នុងប្រទេសសង្គមនិយមជាបងប្អូនមួយពុំមានទាក់ទងនឹងច្បាប់ផ្សេងៗរបស់ប្រទេសជាតិទេ ប៉ុន្តែមានត្រឹមតែការព្រមព្រៀងគ្នាមួយរវាងបក្សនិងបក្សប៉ុណ្ណោះ ។ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៥៥ ដែលមានខ្លឹមសារថា «ដាក់ពួកអាណិកជនចិនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សពលករវៀតណាម» និងមិនតម្រូវឲ្យជ្រើស

រើសក្លាមៗនូវសញ្ជាតិណាមួយខុសពីជនរួមជាតិរបស់ខ្លួនដែលតាំងលំនៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀតដែលទើបនឹងបានឯករាជ្យថ្មីៗឡើយ ។ ពួកគេអាចរស់នៅប្រទេសវៀតណាម និងរក្សាសញ្ជាតិចិនបានលុះណាតែនៅទីបំផុតក្លាយទៅជាពលរដ្ឋវៀតណាមដែរ ។

ក្នុងអំឡុងពេល២៣ឆ្នាំ ដែលមានបន្តបន្ទាប់ពីកិច្ចព្រមព្រៀងដែលធ្វើឡើងដោយពាក្យសម្ដីនេះ ក្រុងហាណូយពុំដែលធ្វើអ្វីមួយដើម្បីបង្ខិតបង្ខំពលរដ្ឋចិនរបស់ខ្លួនឲ្យចូលសញ្ជាតិវៀតណាមឡើយ ។ ប៉ុន្តែនៅឆ្នាំ ១៩៦១ ប្រទេសចិនបានព្រមតាមសំណើមួយរបស់វៀតណាមដែលប្រែជាឲ្យពួកចិននៅវៀតណាមខាងជើងទាំងអស់ចូលសញ្ជាតិ ដោយគ្រាន់តែសន្យាផ្តល់ទិដ្ឋាការផ្នែកទេសចរណ៍ឲ្យជនជាតិចិននៅវៀតណាម ដែលសុំទៅសួរសុខទុក្ខគ្រួសាររបស់ខ្លួននៅប្រទេសចិនប៉ុណ្ណោះ[៧] ។

ស្ថានភាពពិសេសនេះបានធ្វើឲ្យជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកអាណិកជនចិនមានភាពងាយស្រួល និងផ្តល់ឲ្យពួកគេនូវឋានៈជាជនជាតិភាគតិចមួយដែលមានឯកសិទ្ធិ ។ កេ ស៊ិន់ ជាជនជាតិចិននិងជាអតីតអ្នកតាំងលំនៅក្រៅស្រុកនៅក្រុងហាណូយ បាននិយាយរំឭកថា "ពួកយើងបានទទួលនូវភាពល្អប្រសើរជាងគេ ពីទាំងសងខាង ។ នៅភាគខាងជើង ពួកជនជាតិ ហ៊ា (ជនជាតិវៀតណាមដើមកំណើតចិន) បានក្រេបជញ្ជក់អត្ថប្រយោជន៍គ្រប់បែបយ៉ាងពីសញ្ជាតិវៀតណាមដោយគ្មានទទួលផលពិបាកណាមួយឡើយ ។ ប្រហែលជានៅឆ្នាំ ១៩៧០ វៀតណាមបានសាកល្បងឲ្យពួកយើងចូលសញ្ជាតិ ប៉ុន្តែ ភាគច្រើនបំផុតក្នុងចំណោមពួកយើងមើលពុំឃើញមានអ្វីដែលចំណេញពីបញ្ហានេះទេ ។ យើងមានសិទ្ធិរហូតដល់ទៅបោះឆ្នោតទៀតផង ។ គេចាត់ទុកពួកយើងជាជនជាតិវៀតណាមពេញលក្ខណៈ លើកលែងតែពួកយើងរីងរូសក្នុងការស្រង់ឈ្មោះ ដើម្បីចូលធ្វើទាហានប៉ុណ្ណោះ"[៨] ។

ឯកសិទ្ធិក្រោយនេះ ជាឯកសិទ្ធិដែលមានតម្លៃលើសលប់ក្នុងប្រទេសមួយដែលគ្រួសារនីមួយៗតែងតែបាត់បង់សមាជិកម្នាក់ក្នុងចំណោមសមាជិកគ្រួសាររបស់ខ្លួនដែលចេញទៅធ្វើសង្គ្រាមរំដោះជាតិ ។ ដូចដៃគូរបស់ខ្លួននៅប្រទេសចិនដែរ អ្នកជំនួញចិននៅវៀតណាមខាងជើងក៏ទ្រាំទ្រនឹងផលវិបាកផ្សេងៗពីការកែទម្រង់សង្គមនិយមដូចគ្នា ប៉ុន្តែពុំទទួលរងការឈឺចាប់ដោយសារការប្រកាន់ពូជសាសន៍ណាមួយឡើយ ។ តាមពិតមានមន្ត្រីរដ្ឋការមួយចំនួនធំដែលចេញអំពីជនជាតិភាគតិចចិនបានកាន់កាប់មុខតំណែងសំខាន់ៗនៅក្នុងជួរបក្សនិងរដ្ឋាភិបាលទៀតផង ។ ក្រោមរបបប្រឆាំងកុម្មុយនីស្តនៃសាធារណរដ្ឋវៀតណាមខាងត្បូង សហគ្រាសទាំងឡាយដែលគ្រប់គ្រងដោយពួកចិនសុទ្ធតែរកស៊ីមានបាន ប៉ុន្តែ ពួកថៅកែៗបានត្រូវបង្ខិតបង្ខំដោយ ង៉ូឌិញយៀម [ជាអ្នកនយោបាយវៀតណាមខាងត្បូង(១៩០១-១៩៦៣) ។ គាត់បានធ្វើជារដ្ឋមន្ត្រីទី១នៅវៀតណាមខាងត្បូងក្នុងឆ្នាំ១៩៥៤ ហើយបានប្រកាសប្រទេសនេះជាសាធារណរដ្ឋនៅឆ្នាំ១៩៥៥ ។ ជាប្រធានាធិបតីដែលទ្រទ្រង់ដោយសហរដ្ឋអាមេរិក (១៩៥៦-១៩៦៣) គាត់បានរៀបចំបង្កើតជារបប

ផ្ដាច់ការមួយ ។ គាត់បានត្រូវគេសម្លាប់ក្នុងឱកាសនៃការធ្វើរដ្ឋប្រហារមួយ-កំណត់របស់អ្នកបកប្រែ] ឲ្យប្រកាន់យកសញ្ជាតិវៀតណាមក្រោមការគំរាមបញ្ឈប់សកម្មភាពទាំងអស់របស់ពួកគេ ។ ក្រុងប៉េកាំងបានតវ៉ាប្រឆាំងនឹងការរើសអើងជាតិសាសន៍នេះ ដោយមានការគាំទ្រពីរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងផង ។ ត្រូវគេត្រាដោយក្រុងហាណូយ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូងបានសន្យាឲ្យពួកចិននៅភាគខាងត្បូងជ្រើសរើសសញ្ជាតិរបស់ខ្លួនដោយសេរីបន្ទាប់ពីការរំដោះប្រទេសជាតិរួច ។

ក៏ប៉ុន្តែ ឥរិយាបថរបស់ពួកកុម្មុយនីស្តវៀតណាមបានចាប់ផ្ដើមផ្លាស់ប្ដូរនៅចុងសតវត្សរ៍៦០ នៅពេលដែលការច្របល់វឹកវរនៃបដិវត្តន៍វប្បធម៌បានសាយភាយមកដល់សហគមន៍ចិននៅវៀតណាមខាងជើង ។ នៅពេលដែលពួកឆ្មាំក្រហមនៅប្រទេសចិនថ្កោលទោសក្រុងហាណូយ និងប៉ុនប៉ងបញ្ឈប់ការផ្គត់ផ្គង់សម្ភារសឹករបស់ចិន ពួកម៉ៅនិយមក្នុងសហគមន៍ចិននៅវៀតណាមខាងជើងបានបន្តការបដិវត្តវប្បធម៌ផ្ទាល់របស់ខ្លួនដោយចោទបក្សកុម្មុយនីស្តវៀតណាមថាមានគំនិតសេរីនិយម[៩] ។

## នាគក្រោកពីដំណេក

ដូចអ្នកទទួលខុសត្រូវវៀតណាមទទួលស្គាល់រឿងនេះដែរថា គឺចាប់តាំងពីមានបដិវត្តន៍វប្បធម៌ ហើយជាពិសេសចាប់តាំងពីដំណើរទស្សនកិច្ចរបស់ប្រធានាធិបតី និចសុន នៅប្រទេសចិនក្នុងឆ្នាំ១៩៧២ ដែលមេដឹកនាំថ្នាក់កំពូលនៃឋានានុក្រមបក្សកុម្មុយនីស្តវៀតណាមបានចាប់ផ្ដើមគិតថា គេគោងតែឈប់ទុកចិត្តពួកមន្ត្រីរដ្ឋការដែលចេញមកពីជនជាតិភាគតិចចិន ។ ចំណងដែលបង្កើតដោយការសន្យាផ្នែកមនោគមវិជ្ជា រួមគ្នាសម្រាប់សហគមន៍ទាំងពីរបានចាប់ផ្ដើមរលាខ្សោក ។ បន្ទាប់ពីដំណើររបស់ និចសុន បើក្រុងប៉េកាំងលែងគួរឲ្យទុកចិត្តហើយ ហេតុអ្វីបានជាពួកមន្ត្រីរដ្ឋការដើមកំណើតចិននៅមានមុខតំណែងទៀត ទោះបីជាពួកនេះ ជាមនុស្សជំនាន់ទីពីរក៏ដោយ? ។ ទំនាក់ទំនងផ្សេងៗរវាងរដ្ឋនិងរដ្ឋកំពុងធ្លាក់ក្នុងស្ថានភាពអាក្រក់ ការមិនទុកចិត្តគេឯង និងគំនិតប្រឆាំងចិនរបស់វៀតណាមដែលមានក្នុងចិត្តតាំងពី២០០០ឆ្នាំនៃប្រវត្តិសាស្ត្របានផុសឡើងជាថ្មី ។ ពួកមន្ត្រីរដ្ឋការ"ចិន" ថែមទាំងត្រូវគេប្រគល់ភារកិច្ចថ្មីៗឲ្យកាន់កាប់ដោយស្ងាត់កំបាំងទៀតផង ។ អំណឹះតទៅពួកគេលែងមានមធ្យោបាយទទួលបានព័ត៌មានច្បាស់លាស់ទៀតហើយ ។

នៅឆ្នាំ១៩៧៥ ពួកមេដឹកនាំវៀតណាមមានជំនឿប្រាកដក្នុងចិត្តយ៉ាងជាក់លាក់ថា ៈ ក្រុងប៉េកាំងពុំសប្បាយចិត្តនឹងឃើញការលេចឡើងនូវប្រទេសវៀតណាមមួយដែលរួមគ្នាឡើងវិញ និងខ្លាំងពូកែឡើយ ។ វៀតណាមមិនដែលភ្លេចសោះឡើយពីគ្រោះថ្នាក់មើលមិនឃើញ ដែលបង្ហាញឡើងដោយប្រទេសចិន ទោះជាស្ថិតក្នុងអារម្មណ៍សប្បាយរីករាយនៅពេលមានជ័យជម្នះក៏ដោយ ។ គេដំណាលថា នៅខែឧសភា ឆ្នាំ១៩៧៥ អគ្គលេខាបក្ស ឡេ យន់ ពេលមកដល់មូលដ្ឋានអាកាស តាន់ សឺនញឹក នៅក្រុងព្រៃនគរភ្លាមបានពោលអះអាង

ថា ៖ «គ្រោះគំរាមកំហែងធំៗពីរគឺគ្រោះអត់ឃ្លាន និងពួកប្រតិកិរិយាចិន»សុទ្ធតែជាមូលហេតុចម្បងនៃការលំបាកផ្សេងៗរបស់ប្រទេសជាតិ ។ តាមការឲ្យដឹងរបស់សមាជិកការិយាល័យនយោបាយវៀតណាមម្នាក់ ថាការដែលគាត់ពុំនិយាយដៀមដាមដោយត្រង់ៗពីការឈ្លានពានដោយថាហេតុមួយរបស់ចិន គឺពីព្រោះថា «បញ្ហានេះពុំទាន់ចោទឡើងទេនៅសម័យនោះ» ប៉ុន្តែ «ដោយឡែក យើងត្រូវតែប្រុងប្រយ័ត្នជាប់ជានិច្ច»[១០] ។

ជំនួយរបស់ចិនចំពោះប្រទេសវៀតណាមត្រូវបានកាត់បន្ថយចាប់ពីអំឡុងឆ្នាំ១៩៧៦-៧៧ ហើយទំនាក់ទំនងរវាងប្រទេសទាំងពីរក៏ធ្លាក់ចុះបន្តិចដែរ ។ ដូច្នេះក្រុងហាណូយបានកាត់បន្ថយលក្ខណៈសម្រុះសម្រួលបន្តិចម្តងៗចំពោះសហគមន៍ចិនក្នុងប្រទេសរបស់ខ្លួនដែលមានចំនួនដល់ទៅមួយលាននាក់ហើយ ដែល«សេចក្តីស្មោះត្រង់»របស់ពួកនេះ ហាក់ដូចជាធ្វើឲ្យខ្លួនមន្ទិលសង្ស័យតាំងពីក្រោយការរំដោះប្រទេសរួចម្ល៉េះ ។ ផ្ទុយទៅវិញ វៀតណាមយល់ឃើញថា ចាំបាច់ត្រូវតែពង្រឹងការត្រួតត្រារបស់ខ្លួនឲ្យកាន់តែរឹងមាំឡើងថែមទៀត ។ ជាពិសេស បក្សកុម្មុយនីស្តវៀតណាមពុំពេញចិត្តទាល់តែសោះ ដែលពួកចិននៅក្រុងច្រឹងឡឹងហ៊ានលើកទង់ជាតិសាធារណរដ្ឋប្រជាមានិតចិននិងគ្រវីរូបថត ម៉ៅ សេទុង នៅថ្ងៃបន្ទាប់ពីការរំដោះ ។ សម្រាប់ពួកនាយទុនចិន នៅក្រុងច្រឹងឡឹង -ក្នុងអតីតកាលជាអ្នកស្ថិតនៅក្រោមការឧបត្ថម្ភគាំពាររបស់របបប្រឆាំងកុម្មុយនីស្តដ៏ខ្លាំងបំផុតរបស់តៃវ៉ាន់- នេះទំនងជាបាតុកម្មមួយដែលប្រព្រឹត្តឡើងស្របតាមកាលៈទេសៈសុទ្ធសាធក្នុងគោលបំណងបង្ហាញឲ្យពួកមេដឹកនាំថ្មី(ចិន)ឃើញថា ទោះជាមានអ្វីកើតឡើងក៏ដោយ ក៏ពួកគេមានទឹកចិត្តនិយមឆ្វេងដែរ ។ វៀរលែងតែពួកគេមិនចង់បង្ហាញថា ពួកគេមានក្រុងប៉េកាំងជាអ្នកគាំទ្រដ៏មានអំណាចមួយប៉ុណ្ណោះ ។ មួយវិញ្ញែកនោះ ពួកគេ(ចិននៅក្រុងច្រឹងឡឹង)ពុំនឹកសង្ស័យថា កាយវិការរបស់គេអាចធ្វើឲ្យពួកមេដឹកនាំក្រុងហាណូយអាក់អន់ចិត្តឡើយ ពីព្រោះពួកគេមិនដឹងថា ទោះជាមានការអះអាងពីមិត្តភាពជាផ្លូវការក៏ដោយ ក៏ហេតុនៃការអន្តរាយមួយមានសភាពកាន់តែជ្រៅទៅៗរវាងប្រទេសទាំងពីរដែរ ។ គេបានដកហូតយកទង់ជាតិចេញទាំងអស់ ។

រដ្ឋាភិបាលវៀតណាមខាងជើងពុំមានចេតនាប្រកាន់តាមពាក្យសន្យាដែលសម្រេចជាមួយពួកចិន ដោយរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងទាល់តែសោះ ។ វាពុំមែនបញ្ហាដែលត្រូវអនុញ្ញាតឲ្យពួកទាំងនោះជ្រើសរើសសញ្ជាតិរបស់គេទេ ។ ជាច្រើនឆ្នាំក្រោយមក នៅពេលដែលខ្ញុំរំឭកសួរពីពាក្យសន្យានេះចំពោះឯកអគ្គរដ្ឋទូតវៀតណាមម្នាក់នៅទីក្រុងប៉េកាំង ចម្លើយរបស់គាត់ឆ្លើយមកវិញគឺមានលក្ខណៈច្បាស់លាស់បំផុត «យើងបានទទួលយកការពិតមួយ ៖ ជនជាតិចិនស្ទើរតែទាំងអស់នៅប្រទេសវៀតណាមសុទ្ធតែមានសញ្ជាតិវៀតណាម ។ សម្រាប់យើងវាហាក់ដូចជាគ្មានប្រយោជន៍អ្វីនឹងធ្វើឲ្យស្ថានភាពនេះច្របូកច្របល់ទេ ។ យ៉ាងម៉េចក៏ដោយ ក៏សេចក្តីថ្លែងការណ៍ផ្សេងៗគឺជារឿងមួយ ហើយការពិតគឺជារឿងមួយទៀត»[១១] ។

ការពិតនៅប្រទេសវៀតណាមឆ្នាំ១៩៧៥ ដែលបង្រួបបង្រួមឡើងវិញនិងជឿជាក់លើកម្លាំងរបស់ខ្លួន ដូច្នេះលែងមានអ្វីទាក់ទងជាមួយបណ្តាឆ្នាំដំបូងៗនៃអត្ថិភាពប្រទេសវៀតណាមខាងជើង ដែលពេលនោះមាន

លក្ខណៈជិតស្និទ្ធនិងកំពុងពឹងផ្អែកប្រទេសចិនយ៉ាងខ្លាំងទៀតហើយ ។ តើមានផលប្រយោជន៍អ្វីទៅដែលក្រុងហាណូយបើកប្រថុយបង្កឲ្យមានការវិនាសដ៏ធំនេះ? ។ ការដែលក្រុងប៉េកាំងទទួលស្គាល់ពីសិទ្ធិការពារអាណិកជនរបស់ខ្លួន បានធ្វើឲ្យគេនឹកឃើញដល់មធ្យោបាយធ្វើអន្តរាគមន៍ដ៏ខ្លាំងមួយនៅភាគខាងត្បូង ។ នៅដើមឆ្នាំ១៩៧៦ ពលរដ្ឋទាំងអស់នៅភាគខាងត្បូងដែលមានដើមកំណើតចិន ត្រូវបានបង្ខិតបង្ខំឲ្យចូលសញ្ជាតិវៀតណាម ។ ប្រទេសចិនពុំបានតវ៉ាប្រឆាំងតាមផ្លូវការឡើយ ។ ប៉ុន្តែនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧ ក្នុងឱកាសនៃការសន្ទនាមួយជាមួយ ផាំ វ៉ាន់ដុង លោកឧបនាយករដ្ឋមន្ត្រីចិន លី ស៊ាននាន បានចោទប្រកាន់វៀតណាមថាបានក្បត់នឹងពាក្យសន្យាផ្សេងៗរបស់ខ្លួន[១២] ។ ម្យ៉ាងទៀត ភាគខាងត្បូងលែងជាកម្មវត្ថុនៃការពិភាក្សាទៀតហើយ ។ នៅនិទាឃរដូវឆ្នាំ១៩៧៧ ប្រទេសវៀតណាមបានចាប់ផ្តើមធ្វើឲ្យច្បាស់ប្រាកដនូវស្ថានភាពនៃអ្នករស់នៅតាមព្រំដែនរបស់ខ្លួនគឺជនជាតិដើមកំណើតចិន ឬសមាជិកនៃបណ្តាជនជាតិភាគតិច ។ អ្នកស្រុកនៃតំបន់សម្បូរទៅដោយភ្នំនេះ ជាទូទៅសុទ្ធតែមានគ្រួសារស្ថិតនៅទាំងសងខាងព្រំដែន ។ ពួកគេត្រាច់ចរពីប្រទេសមួយទៅប្រទេសមួយបានដោយសេរីហើយថែមទាំងស្របច្បាប់ទាំងអស់ដើម្បីរកស៊ីជួញដូរឬមូលហេតុគ្រួសារ ។ ដោយភ័យខ្លាចឥទ្ធិពល ដែលប្រទេសចិនអាចប្រើមកលើពួកនេះ ជាពិសេសដោយសារអានុភាពខាងសេដ្ឋកិច្ចរបស់ចិនផងក្រុងហាណូយបានចាប់ផ្តើមដេញចេញពីស្រុកនូវជនទាំងឡាយណាដែលជ្រើសយកសញ្ជាតិចិន ដោយមិនឲ្យលេចព្ញខ្វរខ្វាយឡើយ[១៣] ។

ក្នុងរយៈពេលយូរយារមកហើយ ភាពមន្ទិលរបស់វៀតណាមប្រឆាំងចិនមានដើមហេតុជាសំខាន់ពាក់ព័ន្ធទៅនឹងសន្តិសុខប្រទេសនេះឯង ។ ប៉ុន្តែឥទ្ធិពលនៃមជ្ឈដ្ឋានអ្នកជំនួញរបស់ចិនបានបន្ថែមឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងវិស័យសេដ្ឋកិច្ចថែមទៀត ។ នៅរដូវក្តៅឆ្នាំ១៩៧៧ ការអនុម័តកម្មវិធីធ្វើសមូហភាវូបនីយកម្មមួយទៅលើកម្មសិទ្ធិដីធ្លីនៅភាគខាងត្បូងដោយបក្សកុម្មុយនីស្តវៀតណាម បានធ្វើឲ្យការកសាងលទ្ធិសង្គមនិយមនៅទីនោះកាន់តែមានសន្ទុះឈានឡើង ។ គណៈកម្មាធិការមួយបានត្រូវបង្កើតឡើង ដើម្បីអនុញ្ញាតឲ្យផ្នែកឧស្សាហកម្ម និងមជ្ឈដ្ឋានអ្នកជំនួញឯកជនបង្ហាញនូវសំណើផ្សេងៗក្នុងទិសដៅរាំងខ្ទប់សកម្មភាពពួកនេះឲ្យស្ថិតក្នុងព្រំដែនមួយយ៉ាងចង្អៀត ។ នៅឆ្នាំ១៩៧៧ ផលិតផលស្បៀងបានធ្លាក់ចុះយ៉ាងគំហុកដែលអាចផ្តល់នូវគ្រោះមហន្តរាយនិងបង្កឲ្យមានការស្តុកទុកទំនិញស្បៀងដើម្បីលក់តម្លើងថ្លៃ និងការរីកលូតលាស់នូវទីផ្សារងងឹតទៀតផង ។ សម្រាប់រដ្ឋាភិបាលគឺជាពេលដែលត្រូវរួសរាន់ពង្រឹងការត្រួតត្រារបស់ខ្លួនទៅលើទីផ្សារ ។ នៅពេលសន្តិសុខប្រទេសត្រូវគំរាមកំហែងដោយការវាយប្រហារកាន់តែខ្លាំងឡើងៗពីសំណាក់ខ្មែរក្រហម និងដោយចលនាតស៊ូរបស់រណសិរ្សរួបរួមដើម្បីការរំដោះពូជសាសន៍ដែលត្រូវជិះជាន់(F.U.L.R.O) ព្រមទាំងក្រុមប្រឆាំងកុម្មុយនីស្តផ្សេងទៀតនោះ គេពុំអាចអត់ឱនឲ្យមានភាពប្របូកប្របល់ផ្នែកសេដ្ឋកិច្ច ដែលជាប្រភពដើមនៃចលាចលក្នុងសង្គមនៅក្នុងរដ្ឋធានីភាគខាងត្បូងដូច្នេះបានទេ[១៤] ។

សម័យប្រជុំនាខែកុម្ភៈ ឆ្នាំ១៩៧៨ របស់ការិយាល័យនយោបាយបានបើកឱកាសឲ្យមានការពិចារណាដ៏ស៊ីជម្រៅមួយ ស្តីពីផលវិបាកចៀសមិនផុតដែលអាចកើតមានពីវិធានការថ្មីៗដែលប្រកាសផ្សាយជាសាធារណៈដោយប្រទេសចិនទាក់ទងទៅនឹងអាណិកជនរបស់ខ្លួនដែលរស់នៅឯនាយសមុទ្រ ។ ក្នុងអំឡុងពេលបដិវត្តន៍វប្បធម៌ គណៈកម្មាធិការសម្រាប់កិច្ចការជនជាតិចិននៅឯនាយសមុទ្រពុំសូវមានឱកាសបញ្ចេញសកម្មភាពរបស់ខ្លួនទេ ។ តាមការពិតនយោបាយរបស់ចិនខាងវិស័យនេះមានភាពកំពុងពេញទៅដោយការច្របូកច្របល់ ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៧ គឺចំពេលដែលវៀតណាមចាប់ផ្តើម“សម្អាត”ព្រំដែនរបស់ខ្លួនជាមួយចិន ក្រុងប៉េកាំងបានចាប់ផ្តើមយកចិត្តទុកដាក់ជាលំដាប់ចំពោះសមត្ថភាពនិងដើមទុនរបស់ពួកចិនដែលរស់នៅឯបរទេស ។ នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨ អត្ថបទមួយរបស់ លីង ចេងហ្ស៊ី ចេញផ្សាយនៅក្នុង“ទិនានុប្បវត្តិប្រជាជន”បានអត្ថាធិប្បាយយ៉ាងល្អិតល្អន់ស្តីអំពីជំហរថ្មីរបស់ប្រទេសចិនក្នុងបញ្ហានេះ ។ ពីពេលនេះទៅ“ជនជាតិចិនដែលរស់នៅឯនាយសមុទ្រគឺជាចំណែកមួយនៃប្រជាជាតិចិន ហើយអនាគតរបស់គេក៏ត្រូវបានចងភ្ជាប់នឹងប្រទេសចិនផងដែរ” ។ ប្រធានគណៈកម្មាធិការសម្រាប់កិច្ចការជនជាតិចិននៅឯនាយសមុទ្របានបញ្ជាក់យ៉ាងច្បាស់លាស់ឲ្យជនរួមជាតិខ្លួនទាំងនោះបង្កបង្កើតជា“រណសិរ្សបង្រួបបង្រួមអ្នកស្នេហាជាតិមាតុភូមិដ៏ទូលំទូលាយមួយ” ប្រឆាំងនឹង“អនុត្តរភាពនិយម” ។ ម្យ៉ាងទៀតក្រៅពីជនជាតិចិននៅឯនាយសមុទ្រ គាត់បាននិយាយទៅកាន់“មិត្តទាំងអស់ជាបរទេស ដែល(សម្គាល់ខ្លួនឯង)ជាអ្នកមានដើមកំណើតចិនដែរ” ។ ប្រធានគណៈកម្មាធិការនេះបានអះអាងថា ប្រទេសចិននឹងមិនគ្រាន់តែធានាការគាំពារបណ្តាអាណិកជនរបស់ខ្លួននៅឯនាយសមុទ្រប៉ុណ្ណោះទេ ប៉ុន្តែ ប្រទេសចិននឹងត្រៀមបម្រុងទទួលស្វាគមន៍អ្នកទាំងនោះជាស្រេច និងចាត់វិធានការគ្រប់បែបយ៉ាងសម្រាប់“អ្នកទាំងឡាយណាដែលប្រាថ្នាវិលត្រឡប់មកប្រទេសចិនវិញ ដើម្បីរួមចំណែកក្នុងការកសាងមាតុភូមិរបស់ខ្លួន ឬគ្រាន់តែមករស់នៅជាពលរដ្ឋធម្មតាក៏បាន” ។ ចំពោះអ្នកទាំងឡាយដែលជ្រើសរើសចូលសញ្ជាតិប្រទេសដែលទទួលខ្លួនឲ្យស្នាក់នៅគឺនៅតែជា“បងប្អូននិងមិត្តរបស់យើង”ជានិច្ច[១៥] ។

ក៏ប៉ុន្តែ សេចក្តីប្រកាសដែលមិនសូវធ្វើឲ្យស្រឡាំងកាំងនេះមានន័យថា សមាជិកទាំងអស់នៃជនជាតិចិនដែលរស់នៅរាយប៉ាយពាសពេញពិភពលោកទោះជាមានសញ្ជាតិអ្វីក៏ដោយ សុទ្ធតែត្រូវអំពាវនាវឲ្យរួបរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុងមូស្គូនិងអ្នកគាំទ្ររបស់គេ ហើយថាពួកចិនទាំងនោះត្រូវបានធានានូវការគាំទ្រពីសំណាក់ក្រុងប៉េកាំងថែមទៀត ។ ចាប់ពីដើមឆ្នាំ១៩៧៨ ស្ថានទូតចិននៅក្រុងហាណូយ បានចាប់ផ្តើមបំភ្លឺពីនយោបាយរបស់ខ្លួនចំពោះសហគមន៍ចិននៅវៀតណាមដែរ ។ លិខិតឆ្លងដែនជាច្រើនបានត្រូវប្រគល់ដោយស្ងាត់កំបាំងទៅឲ្យអ្នកមានៗចិនខ្លះ ដែលមានគោលបំណងចង់វិលត្រឡប់ទៅប្រទេសកំណើតវិញ ដោយបិទហាងលក់ទំនិញ និងភោជនីយដ្ឋានរបស់ខ្លួនចោល ។ ការបង្កើននូវសញ្ជាតិគតរកតែផលប្រយោជន៍ទាំងនេះបានត្រូវវិនិច្ឆ័យយ៉ាងម៉ឺងម៉ាត់បំផុតនៅទីក្រុងហាណូយដោយហេតុថា ក្នុងពេលជាមួយគ្នានោះ ក្រុងប៉េកាំងបានប្រកាន់

យកស្ថានភាពខាងផ្លូវនយោបាយមួយជាមួយប្រទេសកម្ពុជាកាន់តែជិតស្និទ្ធឡើងៗ ។ ពេលវេលាដើម្បីធ្វើការសម្រេចចិត្តជាស្ថាពរមួយបានមកដល់ហើយ ។ គេត្រូវតែបំបាត់បញ្ហាទាំងអស់ជាមួយទីក្រុងប្រ៊ីឡឹង[១៦] ។

វៀតណាមហាក់ដូចជាពុំបានការពារជាមុនចំពោះអ្វីដែលប្រទេសចិនបានថ្កោលទោសជាសាធារណៈអំពីនយោបាយអរិភាពរបស់ខ្លួនឡើយ ។ នៅចុងខែមីនា អ្នកការទូតវៀតណាមម្នាក់បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ)ជាសម្ងាត់ថា "ប្រទេសចិននឹងមិនប្រថុយប្រថានធ្វើឲ្យខូចកិត្យានុភាពអន្តរជាតិរបស់ខ្លួនដោយធ្វើការវាយប្រហារមកលើយើងទេ" ។ គាត់បានបន្ថែមថា "យើងនឹងឆ្លើយទទួលសារភាពទាំងអស់ ។ ពុំមានអ្វីក្រៅពីនេះទេ"[១៧] ។

វៀតណាមបានកំណត់ជាគោលនូវព្រឹត្តិការណ៍ដែលថា ក្នុងពេលថ្មីៗនេះ ពួកចិនបានចាប់ផ្តើមធ្វើការវាយលុកប្រលោមស្នេហ៍មួយសំដៅទៅរកបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ។ ដោយយកចិត្តទុកដាក់ខ្លាំងនឹងបុព្វហេតុជនជាតិចិននៅឯនាយសមុទ្រយ៉ាងចេញមុខ វៀតណាមមុខជាបន្ទោសពីរឿងដែលនៅតែមានជានិច្ចនៅក្នុងតំបន់ គឺកងទីប្រាំរបស់ចិន [ជាឈ្មោះកងអាសាស្ម័គ្រ ដែលគួសត្រូវបន្ទំបង្កប់ខ្លួននៅក្នុងកងទ័ពទៅវិញទៅមក ។ ប្រយោគនេះចាប់ផ្តើមមាននៅពេលដែលឧត្តមសេនីយ៍ ហ្វ្រង់កូ ឡោមព័ទ្ធទីក្រុងម៉ាឌ្រីក (១៩៣៦-១៩៣៩) ដោយប្រើទ័ពបួនកងជាមធ្យោបាយ ហើយនៅក្នុងទីក្រុងនោះ គឺអ្នកមានសមានចិត្តនឹងគាត់ដែលរួមបង្កជាកម្លាំងទីប្រាំ-កំណត់របស់អ្នកបកប្រែ] ហើយដែលត្រូវបំផ្លាញឲ្យអស់ ។ ម្យ៉ាងទៀត ការវាយលុកប្រឆាំងនឹងទីក្រុងប្រ៊ីឡឹងមិនគឺសំដៅប្រឆាំងនឹងលទ្ធិមូលធននិយមមុនអ្វីទាំងអស់ទេឬ? វៀតណាមសង្ឃឹមថា ពួកចិននឹងយករឿងនេះទៅពិចារណាមិនខាន ។ ខ្លឹមសារផ្ទាល់នៃមតិណែនាំរបស់រដ្ឋាភិបាលចុះថ្ងៃទី២៤ ខែមីនា ហាក់ដូចជាដៅឲ្យឃើញនូវចេតនាបង្ករជាមុនមួយនូវការរិះគន់ទាំងអស់ពីសំណាក់ក្រុងប៉េកាំង : "ការសម្រេចចិត្តបញ្ចប់សកម្មភាពផ្សេងៗរបស់អ្នកជំនួញឯកជននឹងត្រូវដាក់ឲ្យអនុវត្តដោយគ្មានផ្លាស់ប្តូរនៅគ្រប់ក្រុងនិងខេត្តទាំងអស់នៅភាគខាងត្បូង ដោយមិនគិតអំពីសញ្ជាតិនិងសាសនាឡើយ" ។ ក៏ប៉ុន្តែដើម្បីបញ្ចៀសគ្រប់ហេតុការណ៍ដែលកើតមានដោយមិនបានដឹងជាមុន ប្រជាជនត្រូវបានណែនាំឲ្យ"ប្រុងប្រយ័ត្នចំពោះការរួមគំនិតក្បត់របស់ពួកប្រតិកិរិយាទាំងអស់-ន័យដែលគេមិនបាច់សម្តែងឲ្យចំ គឺក្រុងបេកាំង-សំដៅធ្វើឲ្យខូចនយោបាយ និងបំបែកបំបាក់អ្នកធ្វើការរបស់យើង"[១៨] ។

នេះជាការគន់គូរមួយដែលភ័ន្តច្រឡំធំណាស់ ។ ប្រទេសចិនយល់ថាព្រឹត្តិការណ៍ផ្សេងៗនៅក្រុងប្រ៊ីឡឹងគឺជាការបង្កហេតុជាចំហមួយប្រឆាំងនឹងនយោបាយរបស់ខ្លួនចំពោះអាណិកជនចិនទូទៅដែលរស់នៅបរទេស ហើយទៅហួសពីនោះគឺការប្រឆាំងនឹងតួនាទីជាមហាអំណាចប្រចាំតំបន់របស់ខ្លួនផង ។ កិត្យានុភាពរបស់ខ្លួនចំពោះក្រសែភ្នែកជនជាតិចិន១៥លាននាក់នៅអាស៊ី-អាគ្នេយ៍ គឺជាកម្មវត្ថុនៃការពិភាក្សាខាងនយោបាយមួយ ។ បើទុកជាការប្រកាន់ជំហរកាលពីពេលថ្មីៗរបស់ខ្លួនមានភាពម៉ឺងម៉ាត់ក៏ដោយ ក៏វាបង្ហាញឲ្យឃើញថា ខ្លួនមិនអាចធានាការពារសហគមន៍ចិននៅប្រទេសវៀតណាម ដោយដាក់លាក់បានឡើយ ។ ម្យ៉ាងទៀត ឥរិយាបថ

ស្មៀមស្ងាត់របស់ចិនចំពោះបញ្ហានេះ បានជួយជំរុញឲ្យគូប្រឆាំងទាំងអស់របស់ខ្លួនក្នុងតំបន់ខំប្រឹងធ្វើគ្រាប់តាមឥរិយាបថរបស់គេដោយឥតល្អៀង ស្ដីពីលទ្ធិស្នេហាជាតិជ្រុលហួសហេតុរបស់វៀតណាមដែរ ។

ក្រុងប៉េកាំងបានរៀបចំធ្វើប្រតិកម្មតបតពេញមួយខែ ។ ប៉ុន្តែភាពស្ងៀមស្ងាត់នេះ ប្រហែលជាមិនបំភាន់ទេ ៖ ភាពតានតឹងបានកើនឡើង ។ អាណិកជនចិនរាប់ពាន់នាក់ដែលកំពុងរត់គេចចេញពីវៀតណាមខាងជើងបានចាប់ផ្ដើមស្វែងរកទីស្នាក់អាស្រ័យនៅម្ខាងទៀតនៃព្រំដែន ។ នៅភាគខាងត្បូង ពួកពាណិជ្ជករចិនច្រើនជាងនេះទៀតដែលគេដកហូតទ្រព្យសម្បត្តិអស់រលីងពីខ្លួន ត្រូវបានបញ្ជូនទៅ“តំបន់សេដ្ឋកិច្ចថ្មី” ។ ប្រទេសចិនបានជ្រើសរើសថ្ងៃប្រារព្ធពិធីបុណ្យខួបលើកទីបីនៃការបញ្ចប់សង្គ្រាមនៅវៀតណាមជានិមិត្តរូប ដើម្បីបញ្ចេញការជេរប្រមាថជាលើកដំបូងរបស់ខ្លួន និងចាប់ផ្ដើមបង្ហាញភាពជាសត្រូវនឹងគ្នា ។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ក្នុងឱកាសទទួលភ្ញៀវចិនមួយចំនួនតូចដែលរស់នៅឯនាយសមុទ្រ លីវ ចេងហ្ស៊ី បានប្រកាសឲ្យដឹងថា ជនជាតិចិនដែលរស់នៅវៀតណាមមួយចំនួនធំបាន “វិលត្រឡប់មកប្រទេសចិនវិញទាំងរហន់” ។ ដោយមិនបំផ្លើសទំហំព្រឹត្តិការណ៍ គាត់បានលើកឡើងអំពីការព្រួយបារម្ភរបស់អាជ្ញាធរចិន ដែលបានតាមដាន“ការវិវត្តន៍នៃស្ថានការណ៍នោះដោយយកចិត្តទុកដាក់យ៉ាងដិតដល់បំផុត” ៖ បើសិនប្រទេសចិនជំរុញឲ្យពួកចិននៅឯនាយសមុទ្រប្រកាន់យកសញ្ជាតិរបស់ប្រទេសដែលពួកគេស្នាក់នៅ ខ្លួនពុំអាចអត់ឱនចំពោះ“ការប៉ុនប៉ងណាមួយសំដៅបង្ខិតបង្ខំពួកចិន ដែលរស់នៅតាមប្រទេសទាំងនោះឡើយ”[១៩] ។

ដប់ពីរថ្ងៃក្រោយមក ក្រុងប៉េកាំងបានបង្កើនការកៀបសង្កត់មួយកម្រិតថែមទៀត ដោយព្រមានក្រុងហាណូយស្ងាត់ៗពីការបញ្ឈប់ការងារនៅការដ្ឋានចំនួនម្ភៃមួយកន្លែង ដែលផ្ដល់ហិរញ្ញវត្ថុដោយពួកចិន នៅពេលខាងមុខឆាប់ៗ ។ ចំណែកសម្ភារបរិក្ខារព្រមទាំងមូលនិធិនឹង “ត្រូវផ្ទេរមកមាតុប្រទេសវិញ សម្រាប់ប្រើប្រាស់ក្នុងការផ្ដល់ការងារ និងការទទួលឲ្យស្នាក់នៅរបស់បងប្អូនចិនដែលត្រូវបណ្ដេញចេញពីវៀតណាមវិញ” ។ ប្រវត្តិសាស្ត្របានកើតមានច្រំដែលៗ ប៉ុន្តែដោយលំនាំប្លែកពីធម្មតា ។ នៅឆ្នាំ១៩៦០ ដើម្បីបង្ហាញនូវការអាក់អន់ចិត្តចំពោះក្រុងប៉េកាំង ពួកសូវៀតក៏ធ្លាប់បញ្ឈប់ជំនួយសេដ្ឋកិច្ចរបស់ខ្លួនទៅឲ្យចិនយ៉ាងគំហុកដែរ ។ ការសម្រេចចិត្តនេះដែលបរិហាយ៉ាងខ្លាំងដោយប្រទេសចិនបានធ្វើឲ្យការការផ្ដាច់មិត្តភាពកាន់តែលឿនដល់ទីបញ្ចប់ ។ ប៉ុន្តែក្រុងប៉េកាំងរង់ចាំឲ្យដំណើរទស្សនកិច្ចរបស់លោក ប៊ីកញូ ប្រ៊ីហ្សីនស្គី ដែលជាអ្នកប្រឆាំងសូវៀតខ្លាំងក្លាបំផុតនិងជាទីប្រឹក្សាសន្តិសុខជាតិអាមេរិកបញ្ចប់ទៅសិន ទើបចាប់ដំណើរការវាយប្រហារដោយពាក្យសម្ដីជាលើកដំបូងមួយទៅតាមគោលការណ៍ ។ ក្នុងសេចក្ដីថ្លែងការណ៍មួយដែលផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ការិយាល័យទទួលបន្ទុកកិច្ចការជនជាតិចិននៅឯនាយសមុទ្រ បានបរិហារពី“ការធ្វើទុក្ខបុកម្នេញមកលើពួកអាណិកជនចិននៅវៀតណាម ដែលជាអ្នករងគ្រោះពីការបណ្ដេញចេញមិនសមហេតុផលមួយ” ដោយថ្កោលទោសចំពោះ “ការបណ្ដេញចេញនិងការវិលត្រឡប់ទាំងបង្ខំមកប្រទេសចិនវិញនូវជនជាតិចិនមួយចំនួនយ៉ាងធំ

ក្នុងចំណោមអ្នកដែលរស់នៅទីនោះ»ផង ។ សេចក្ដីថ្លែងការណ៍បានគូសបញ្ជាក់ថា ភាគច្រើននៃអ្នកដែលត្រូវបណ្ដេញចេញបានត្រូវគេប្រមាថ ធ្វើបាប ឆក់ ប្លន់ និងវាយដំ «នៅពេលមកដល់ទឹកដីចិនពួកគេនៅសល់តែអីវ៉ាន់ដែលស្ពាយនៅលើខ្នងប៉ុណ្ណោះ» ។ វៀតណាមក៏ត្រូវចោទប្រកាន់ថា «បានចាត់ចែងធ្វើការចាប់ខ្លួនមនុស្សយ៉ាងច្រើន ប្រើអំពើឃោរឃៅនិងការកាប់សម្លាប់ទៅលើរូបកាយអាណិកជនចិន» នៅក្រុងហូជីមិញថែមទៀត ។ ក្រុងប៉េកាំងបានព្រមានក្រុងហាណូយថា វៀតណាមត្រូវតែទទួលខុសត្រូវចំពោះផលវិបាកផ្សេងៗនៃអំពើ«ផ្ដាច់ការ សាហាវព្រៃផ្សៃ និងរំលោភលើច្បាប់អន្តរជាតិទាំងនេះ»[២០] ។

ក្នុងចន្លោះពេលនោះ ជនជាតិចិន៧០.០០០នាក់ បានចាកចេញពីប្រទេសវៀតណាមរួចជាស្រេចទៅហើយ ។ គេនឹងប្រហែលពុំដឹងថា ការចាកចោលស្រុកទេសទាំងហ្វូងៗនេះ ចាប់ផ្ដើមដោយរបៀបបែបណាឡើយ ។ ហេតុអ្វីបានជាប្រទេសចិនយល់ព្រមបើកព្រំដែនរបស់ខ្លួន? ។ ហេតុអ្វីបានជាចិនអែអង់យូរម្ល៉េះ មុននឹងប្រកាសប្រាប់ឲ្យសាធារណមតិអន្តរជាតិដឹង? ។ រឿងរ៉ាវទាំងអស់នេះមានផ្ទុកទៅដោយសេចក្ដីក្រេវក្រោធហួសហេតុ ហើយពិបាកសសោះកុំឲ្យច្រឡំបល់គ្នានូវសំណុំនៃការចោទប្រកាន់ និងប្រឆាំងការចោទប្រកាន់ទៅវិញទៅមករបស់អ្នកនាំអាទ៏ណាស់គឺ ពួកអតីតបងប្អូនរួមអាវុធដែលក្លាយទៅជាសត្រូវមិនអាចសម្រុះសម្រួលគ្នាបាន ។ ពួកចិនបានចោទប្រកាន់វៀតណាមថា បានធ្វើទុក្ខបុកម្នេញជនរួមជាតិខ្លួនហើយបានប្រើប្រាស់កម្លាំងទ័ពជូនដំណើរទៅដល់ព្រំដែនថែមទៀត ។ វៀតណាមបានចោទប្រកាន់ពួកចិនថា ជាអ្នកអុជអាលឲ្យមានការលើកគ្នាចាកចោលស្រុកទាំងហ្វូងៗនិងបំផ្លោងពាក្យចចាមអារ៉ាមបង្កើលបំភ័យផ្សេងៗដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ខ្លួនបាត់ស្ថិរភាព និងប៉ុនប៉ងធ្វើឲ្យនយោបាយវៀតណាមផ្អៀងទៅរកចិនថែមទៀត ។ ការបំភ្លឺទាំងនេះគ្មានហេតុផលណាមួយដែលញុាំងឲ្យជឿជាក់ពេញលេញទេ ហើយក៏គ្មានអ្វីមួយបំភ្លឺឲ្យដឹងពីទំហំនៃហេតុការណ៍ដែលកើតឡើងនេះដែរ ។ នៅពាក់កណ្ដាលខែមិថុនា ឆ្នាំ១៩៧៨ ចំនួននៃអ្នកភៀសខ្លួនបានកើនដល់ដប់បីម៉ឺនបីពាន់នាក់ ។ ម្យ៉ាងទៀត ការចាកចោលស្រុកទាំងហ្វូងៗ ពុំមែនមានភាពដូចគ្នានៅគ្រប់ទីកន្លែងទេ ទោះបីជាសកម្មភាពរបស់វាទាំងនៅភាគខាងជើង និងនៅភាគខាងត្បូង បានប្រព្រឹត្តទៅក្នុងពេលជាមួយគ្នាក៏ដោយ ។ នៅភាគខាងជើង រឿងនេះពុំមានពាក់ពន្ធ័ដោយផ្ទាល់ទៅនឹងការប្រុងប្រៀបដែលប្រកាន់យកប្រឆាំងនឹងពួកនាយទុនចិននៅទីក្រុងច្រឹឡឹងទេ ។ ពិតហើយ វាមានទាក់ទងទៅនឹងអ្នកជំនួញធំៗមែន ប៉ុន្តែយូរទៅទៀតមុខជាទាក់ទងនឹងពួកកម្មករ អ្នកធ្វើការក្នុងអណ្ដូងរ៉ែ និងអ្នកនេសាទត្រីមិនខាន ។ គេអាចគិតថា ក្រុងហាណូយចូលចិត្តធ្វើដូចជាគ្មានរឿងអ្វីកើតឡើងសោះអ៊ីចឹង ។ ការដែលថាកំពង់ផែហៃហ្វុង ជាមាត់ច្រកសំខាន់បំផុតរបស់វៀតណាមខាងជើងឆ្ពោះទៅរកពិភពក្រៅ រួមទាំងបណ្ដាអណ្ដូងរ៉ែធ្យូងថ្ម និងកន្លែងនេសាទជាច្រើននឹងពើបប្រទះការគាំងដំណើរទាំងស្រុងដោយសារតែការចាកចេញយ៉ាងប្រញាប់ប្រញាល់របស់អ្នកធ្វើការចិននេះឯងដែលនឹងត្រូវជដែកការពារ ជាដាងយល់ព្រមនឹងរឿងនេះ ។ ប៉ុន្តែ ផ្ទុយទៅវិញ អ្នកនេសាទត្រីក្រីក្រ និងកម្មករខ្វះសមត្ថភាព

*ទាំងនេះដែលមានចំនួនរាប់ពាន់នាក់ពុំមែនជាមនុស្សដែលក្រុងប៉េកាំងលើកទឹកចិត្តឲ្យត្រឡប់មកប្រទេសកំណើតវិញ ដើម្បីជួយធ្វើ«ទំនើបកាវូបនីយកម្មទាំងបួន»នោះទេ ។ តាមការពិត គោលសំខាន់ដែលយើងរៀបបម្រុង វាលេចចេញថា ដោយគ្មានទាក់ទងនឹងការញុះញង់របស់ក្រុងហាណូយ និងក្រុងប៉េកាំង ការចាកចោលស្រុកទាំងហ្វូងទាំងហ្វាយនេះបានប្រព្រឹត្តទៅតាមសន្ទុះដោយឡែកមួយ ហើយពុំបម្រើផលប្រយោជន៍ទាំងប្រទេសវៀតណាម ទាំងប្រទេសចិន ។ គេនៅចាំថា អ្វីៗទាំងអស់ចាប់ផ្ដើមឡើងដោយ ការសម្រេចចិត្តរបស់វៀតណាម ក្នុងការបណ្ដេញពួកអាណិកជនចិនទាំងអស់នៅតាមតំបន់ព្រំដែនភាគខាងជើង ដើម្បីធានាសន្តិសុខប្រទេសរបស់ខ្លួន ។ តមកទៀត មានការរឹតបន្តឹងនាយទុននៅក្រុងប្រីឡឹង បន្ទាប់មកការធ្វើទុក្ខបុកម្នេញពួកឈ្មួញតូចតាច និងម្ចាស់ភោជនីយដ្ឋាននៅក្រុងហាណូយដែលត្រូវធ្វើបាបដោយសារ«ភោគទ្រព្យដែលបានមកមិនត្រឹមត្រូវ» និងភាពឃឺតឃ៉ាវក្នុងការបង់ពន្ធរបស់ពួកគេ ។ ចាប់តាំងពីខែកុម្ភៈ ដើម្បីបន្ថែមឲ្យគ្រប់ បុណ្យខួបថ្មីពីរបានត្រូវប្រារព្ធឡើងដើម្បីរំឭកជ័យជម្នះដែលទទួលបានដោយវីរបុរសជាតិ ឡេ ឡយ និង ត្រាន់ ហ៊ុងដាវ ទៅលើអ្នកឈ្លានពានចិន ។ ពិធីបុណ្យទាំងពីរនេះមិនសូវធ្វើឲ្យពួកចិននៅប្រទេសវៀតណាមកក់ក្ដៅក្នុងចិត្តប៉ុន្មានទេ ។*

## ក្រុមហ៊ុនដឹកជញ្ជូនម្ចាស់កប៉ាល់ចាស់ៗតាមសមុទ្រ

*នៅដើមឆ្នាំ១៩៧៨ ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំក្រុងហាណូយបានចាប់ផ្ដើមចេញលិខិតឆ្លងដែនយ៉ាងច្រើនឲ្យអាណិកជនចិនមួយចំនួន ។ ប៉ុន្តែ មូលហេតុចម្បងនៃការចាកចេញទាំងហ្វូងនេះគឺពាក្យចចាមអារ៉ាមដែលលេចឮសុសសាយក្នុងសហគមន៍ជនជាតិចិនអំពីសង្គ្រាមមួយរវាងប្រទេសចិននិងវៀតណាម ដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។ នៅពេលយប់ ខិត្តប័ណ្ណជាច្រើនដែលពុំអាចដឹងចេញពីប្រភពណា បានត្រូវគេយកទៅស៊កតាមទ្វារផ្ទះនានា ដោយជំរុញឲ្យជនជាតិចិនចាកចេញនិងចូលរួមក្នុងការស្ថាបនាប្រទេសជាតិរបស់ខ្លួន ។ ការបចេសរើសរូសដែលអាចកើតមានសុទ្ធតែត្រូវគំរាមកំហែងដោយការសងសឹក ។ ពីក្រោយយុទ្ធនាការធ្វើឲ្យមានពាក្យចចាមអារ៉ាមនេះ ក្រុងហាណូយជឿថាគឺ«សមាសភាពជនអាក្រក់ក្នុងផ្ទៃសហគមន៍ជនជាតិវ៉ា» ។ ទន្ទឹមនឹងនោះ ក្រុងប៉េកាំងក៏ចោទប្រកាន់ការិយាល័យសន្តិសុខសាធារណៈរបស់វៀតណាមដែរ ។ គោលដៅនៃយុទ្ធនាការនេះពុំមានលក្ខណៈច្បាស់លាស់ឡើយ ។ ស្ហាលបឺណ័រត៍អាចធ្វើសម្ភាសជាមួយជនភៀសខ្លួនជាច្រើននាក់នៅភាគខាងជើង ដោយសារការចេះភាសាចិននិងភាសាវៀតណាមរបស់គាត់ ។ គាត់សន្និដ្ឋានថា «មូលហេតុរបស់អ្នកដែលសម្រេចចិត្តរត់ភៀសខ្លួនពីភាគខាងជើងមានច្រើនណាស់ ។ មុនដំបូងគឺមានការភ័យខ្លាចនូវអ្វីដែលពួកគេអាចត្រូវរងគ្រោះនៅក្នុងការវាយស្មាន(ទៅលើអ្វីមួយដែលគេទុកថានឹងមាន) អំពីសង្គ្រាមមួយរវាងប្រទេសចិននិងប្រទេសវៀតណាម ដែលទំនងជាពិតខ្លាំងឡើងៗ ។ បន្ទាប់មកគឺការជំពាក់ចិត្តចំពោះសញ្ជាតិរបស់គេដែលរឿងនោះពួកគេពុំមានបំណងបោះបង់ចោលទាល់តែសោះ ។ នៅទីបំផុតគឺការព្រួយបារម្ភខ្លះៗទាក់ទងនឹង*

ការធ្លាក់ចុះផ្នែកជីវភាពរស់នៅរបស់គេ ហើយជាទូទៅគឺមនោសញ្ចេតនាដែលកាន់តែរីកធំឡើងៗដោយសារការរេចរឹលនូវបុព្វសិទ្ធិផ្សេងៗ ដែលពួកគេមានក្នុងឋានៈជាជនបរទេសតាំងនៅក្រៅស្រុកជាអចិន្ត្រៃយ៍»[២១] ។

ទោះបីជាមានការសន្និដ្ឋានអំពីដើមហេតុនៃពាក្យចចាមអារ៉ាមទាំងនោះក៏ដោយ ក៏វាប្រាកដថាវៀតណាមពុំបានយកចិត្តទុកដាក់ឲ្យម៉ឺងម៉ាត់ដើម្បីរារាំងការចាកចោលស្រុកកំណើតទាំងហ្វូងនេះឡើយ ។ ដោយគិតអំពីចម្ងាយផ្លូវ ពីភាពខ្វះខាតខ្សោយខាងមធ្យោបាយដឹកជញ្ជូន ហើយជាពិសេសលក្ខខណ្ឌ ដែលតម្រូវឲ្យធ្វើតាមដោយសារវិធានការផ្នែកសន្តិសុខក្នុងការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់មនុស្ស គេពិបាកវិនិច្ឆ័យដោយមធ្យោបាយរបៀបណា ដែលហ្វូងអ្នកភៀសខ្លួនមួយច្រើនបែបនោះអាចធ្វើដំណើរទៅដល់ព្រំដែន ដោយគ្មានការសុំគ្រលុំពីរដ្ឋអំណាចនោះ? ។ ទោះជាយ៉ាងណាក៏ដោយ ការវាយស្ទាបដោយឥតមានអ្វីសំអាងដែលរក្សាទុកក្នុងគំនិតពួកមេដឹកនាំក្រុងហាណូយមានមិនលើសពីបីខែឡើយ ។ ការវាយស្ទាបនេះបានត្រូវកម្ចាត់ចេញតាំងពីពេលដែលប្រទេសចិនចាប់ផ្តើមថ្កោលទោសប្រទេសវៀតណាមជាសាធារណៈ ។ នៅថ្ងៃទី៣០ ខែឧសភា ក្រុងប៉េកាំង បានលុបចោលគម្រោងជំនួយថ្មីចំនួនហាសិបមួយគម្រោងដែលត្រូវផ្តល់ឲ្យប្រទេសវៀតណាម សរុបទៅ ការលុបចោលគម្រោងទាំងនេះបានឡើងដល់ចំនួនចិតសិបពីរហើយ ។ ការសម្រេចចិត្តនេះ ធ្វើឡើងផ្ទុយនឹងគោលការណ៍របស់ខ្លួនដែលផ្សព្វផ្សាយឲ្យគេដឹងឮគ្រប់តែពេលដោយប្រទេសចិនខ្លួនឯងថា មិនត្រូវប្រើប្រាស់ជំនួយសេដ្ឋកិច្ចធ្វើជាមធ្យោបាយកៀបសង្កត់ខាងផ្នែកនយោបាយឡើយ ។ កាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត ប្រការនេះមានន័យថា តែមួយខែក្រោយប៉ុណ្ណោះមធ្យោបាយផ្សេងៗដែលលម្អៀងទៅរកការស្រុះស្រួលគ្នាបានរលាយបាត់អស់តែមួយខែក្រោយមកប៉ុណ្ណោះពីជម្លោះត្រូវបានធ្វើឲ្យគេដឹងឮជាសាធារណៈ[២២] ។

ការលុបចោលជំនួយរបស់ចិននឹងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់វៀតណាម ដែលរកកលតែរលំដួលទៅហើយនោះ ។ ប៉ុន្តែ វានឹងជួយបំបាត់ការស្ទាក់ស្ទើរចិត្តចុងក្រោយរបស់វៀតណាម ដើម្បីបែរទៅចូលរួមជាមួយអង្គការកូមេកុងវិញ [COMECON អក្សរពេញគឺ Council for Mutual Economic Assistance ។ បារាំងហៅថា C.A.E.M ខ្មែរហៅក្រុមប្រឹក្សាសង្គហសេដ្ឋកិច្ចបង្កើតឡើងក្នុងឆ្នាំ១៩៤៩ នៅក្រុងមូស្គូសហភាពសូវៀត ។ ជំនាន់នោះមានសមាជិកដប់ប្រទេស សុទ្ធតែកាន់លទ្ធិសង្គមនិយមគឺ ប៊ុលហ្គារី, ហុងគ្រី, ប៉ូឡូញ, រូម៉ានី, ឆេកូស្លូវ៉ាគី, សហភាពសូវៀត(សមាជិកស្ថាបនិក) , សាធារណរដ្ឋប្រជាធិបតេយ្យ អាល្លឺម៉ង់ (កាលនោះមិនទាន់រួបរួមគ្នា) , ម៉ុងហ្គោលី, គុយបា និងវៀតណាម ។ ចំណែកឯប្រទេសអាល់បានី ដែលជាសមាជិកស្ថាបនិកមួយដែរនោះបានដកខ្លួនចេញនៅឆ្នាំ១៩៦១ ។ អង្គការនេះមានទីស្នាក់ការនៅក្រុងមូស្គូ ប៉ុន្តែ បន្ទាប់ពីសង្គ្រាមត្រជាក់បញ្ចប់ទៅអង្គការនេះក៏រលត់រលាយទៅតាមនោះដែរ -កំណត់របស់អ្នកបកប្រែ] ។ តាំងពីការជួបប្រជុំកំពូលដែលប្រព្រឹត្តទៅជាសម្ងាត់នៅក្រុងមូស្គូ ក្នុងអំឡុងរដូវក្តៅឆ្នាំ១៩៧៧ សេចក្តីសម្រេចមួយត្រូវបានរៀបចំសម្រាប់ទិសដៅនេះរួចជាស្រេច ។ ក្រុងហាណូយបានផ្តល់នូវការយល់ព្រមរបស់ខ្លួនចំពោះគោលការណ៍

សុំចូលជាសមាជិករបស់អង្គការនេះដែលត្រូវតែកើតមាន«ទៅតាមកាលវេលា» ។ ការត្រៀមបម្រុងនេះ គឺមានជាប់ពាក់ព័ន្ធនឹងការព្រួយបារម្ភរបស់វៀតណាមដែលមិនទំនាស់នឹងប្រទេសចិនដោយការសុំចូលជាសមាជិកអង្គការមួយដែលគ្រប់គ្រងដោយពួកសូវៀតឡើយ យ៉ាងហោច ដរាបណាការធ្វើឲ្យមានប្រក្រតីភាពតែសំបកក្រៅមួយនឹងអាចរក្សាបានក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរ[២៣] ។ ពីពេលនេះទៅក្រុងហាណូយអាចធ្វើអ្វីៗបានដោយគ្មានទើសទាល់ឡើយ ។ ប្រទេសវៀតណាមបានចូលជាសមាជិកអង្គការកូមេកុងជាផ្លូវការនៅថ្ងៃទី២៨ ខែមិថុនា (១៩៧៨) ។ ពេលនោះគឺក្រុងមូស្គូជាអ្នកឈ្នះនៅទឹកទីមួយក្នុងការប្រកួតរវាងចិន-វៀតណាម... ។

ជម្លោះដែលប្រើវិធីកាន់តែខ្លាំងឡើងចេះតែមានជាបន្តមកទៀត ។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៨ ក្រុងប៉េកាំងបានប្រកាសឲ្យដឹងពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ជូននាវាពីរគ្រឿងទៅវៀតណាម ដើម្បី«ដឹកជញ្ជូនជនជាតិចិនដែលរងគ្រោះពីការធ្វើទុក្ខបុកម្នេញត្រឡប់មកប្រទេសវិញ» ។ សម្រាប់ក្រុងហាណូយយល់ថា ការសម្រេចចិត្តជាឯកតោភាគីនេះ បានបង្ហាញឲ្យឃើញពី«នយោបាយការទូតប្រើនាវា»ម្ដង ។ អ្នកធ្វើអត្ថាធិប្បាយផ្លូវការម្នាក់របស់វៀតណាមបានសម្ដែងការក្រោធខឹងថា «នេះជាបុកពាក្រអឺតក្រអាងមើលងាយគេឯងកម្រិតខ្ពស់បំផុត ។ សមុទ្រចិនខាងត្បូងពុំមែនជាដែនសមុទ្រមួយរបស់ចិនទេ ។ ហៃហ្វុងនិងក្រុងហូជីមិញ ក៏ពុំមែនជាកំពង់ផែដែលបណ្ដានាវារបស់ចិនអាចចេញចូលស្រេចតែចិត្តដែរ»[២៤] ។

សម្រាប់ប្រជាជនវៀតណាមយល់ថា នេះជាឱកាសល្អណាស់ដើម្បីទាញយកអត្ថប្រយោជន៍មួយដោយបរិហារជាសាធារណៈពីភាពផ្ទុយគ្នានៃនយោបាយរបស់ចិន ។ តើពួកអាណិកជនចិនដែលរស់នៅប្រទេសកម្ពុជាត្រូវគេធ្វើបាបដូចគ្នាដែរឬទេ? តើរឿងនេបណ្ដាលឲ្យមានបញ្ហាដល់ការគាំទ្ររបស់ចិនចំពោះខ្មែរក្រហមដែរទេ? អ្នកធ្វើអត្ថាធិប្បាយវិទ្យុក្រុងហាណូយបាននិយាយចំអកឡកឡឺយទៀតថា «បើប្រទេសចិនចង់ជួយសង្គ្រោះអាណិកជនខ្លួនដែលរងគ្រោះពីការរំលោភធ្វើបាបមែន គឺនៅកម្ពុជាឯណោះទេដែលចិនត្រូវបញ្ជូននាវារបស់ខ្លួនទៅយ៉ាងលឿនបំផុត»នោះ[២៥] ។

ប្រតិបត្តិការជួយសង្គ្រោះពួកចិននៅវៀតណាមបានជំរុញទៅរកបរាជ័យមុនជាស្រេច ។ ការទទូចរបស់ចិនដែលគ្រាន់តែចង់ដឹកជញ្ជូន«ពួកចិនដែលជាអ្នករងគ្រោះដោយការរំលោភធ្វើបាប»ត្រឡប់ទៅមាតុប្រទេសវិញ ដែលមានគោលបំណងដោយប្រើកលល្បិចឲ្យគេទទួលស្គាល់ជាផ្លូវការនូវគំនិតដែលថា មាន«ការធ្វើបាប»ពិតប្រាកដនោះគឺជារឿងដែលក្រុងហាណូយពុំទទួលស្គាល់ឡើយ ។ ម្យ៉ាងទៀត ពួកវៀតណាមក៏មិនទទួលស្គាល់ពីការស្ថិតមាន«ជនជាតិចិននៅវៀតណាម»ដែរ ប៉ុន្តែថាមានតែជនជាតិហ័រ (ជនជាតិវៀតណាមដើមកំណើតចិន)ប៉ុណ្ណោះ ។ មិនគ្រាន់តែថ្កោលទោសការផ្ដួចផ្ដើមគំនិតរបស់ចិនប៉ុណ្ណោះទេ ក្រុងហាណូយបានប្រឹងប្រែងប្រើប្រាស់រឿងនេះជាគុណប្រយោជន៍របស់ខ្លួនថែមទៀត ដោយបង្កើតឲ្យមានស្ថានការណ៍មួយដែលសាំញ៉ាំពិបាកដោះស្រាយបំផុត គឺស្នើឲ្យប្រទេសចិនទទួលយកជនជាតិហ័រទាំងអស់ដែលចង់ចាកចេញពីប្រទេស

វៀតណាម ក្រោយពីការពិនិត្យសំណុំឯកសាររបស់ពួកគេរួចរាល់ ហើយប្រគល់ឲ្យមនុស្សទាំងអស់នូវទិដ្ឋាការមួយម្នាក់ៗ ។ វាពិតជាពិបាកណាស់សម្រាប់ប្រទេសចិន ដែលត្រូវទទួលបន្ទុកយកអ្នកភៀសខ្លួនចំនួន មួយលានពីរសែននាក់ដោយឥតព្រាងទុកជាមុនបែបនេះ ។ ម្យ៉ាងទៀត បើខ្លួនសុខចិត្តព្រមទទួលយកជនជាតិវៀតណាមដើមកំណើតចិន ទាំងនោះ ហាក់ដូចជាដាក់ខ្លួនរងទទួលការចោទប្រកាន់ផ្សេងៗពីបទជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់វៀតណាមមិនខាន ។

ប្រទេសចិនប្រហែលជាមិនដែលជឿសោះថា ក្រុងហាណូយនឹងបណ្តាលឲ្យគេធ្វើដូច្នេះ ហើយក្នុងពេលដដែលនោះ ក៏ទទួលស្គាល់ពីការធ្វើទុក្ខបុកម្នេញប្រជាជនចិនដែលតាំងទីលំនៅក្រៅស្រុករបស់ខ្លួនដែរ ។ កប៉ាល់ពីរគ្រឿងដែលចិន ស្នើបញ្ជូនទៅនោះ អាចដឹកយកអ្នកភៀសខ្លួនបានតែ២.២០០នាក់ប៉ុណ្ណោះ ។ ប្រទេសចិនទំនងជាគ្មានគោលដៅណាផ្សេងក្រៅតែពីធ្វើឲ្យប្រទេសវៀតណាមស្ថិតក្នុងស្ថានភាពលំបាកជាសាធារណៈ និងបង្ហាញឲ្យពួកចិនដែលរស់នៅឯនាយសមុទ្រឃើញថា ខ្លួនតែងព្រួយបារម្ភពីជោគវាសនារបស់ពួកជានិច្ចនោះឡើយ ។

ការប្រជុំចរចាគ្នាស្តីពីរឿងនេះបានស៊ីពេលអស់ប្រាំមួយសប្តាហ៍ ដោយផ្តោតជាសំខាន់ទៅលើទម្រង់បែបបទនៃការវិលត្រឡប់របស់អ្នកភៀសខ្លួន និងភាពលម្អិតនៃការចូលចតរបស់នាវាទាំងពីរគ្រឿង ។ ការប្រជុំចរចារនេះបានបើកឱកាសឲ្យមានយុទ្ធនាការឃោសនាដ៏អឺងកងមួយទៅវិញទៅមក ។ នៅទីបំផុត គម្រោងការនេះ បានត្រូវគេបោះបង់ចោលនៅខែកក្កដា ឆ្នាំ១៩៧៨ ។ អ្នកការទូតចិនមួយក្រុមដែលបញ្ជូនមកដើម្បីរៀបចំការបើកស្ថានកុងស៊ុលរបស់ប្រទេសចិននៅក្រុងហូជីមិញ ត្រូវរង់ចាំដោយអត់ធ្មត់ចំនួនបីខែនៅក្រុងហាណូយមុននឹងត្រឡប់ទៅក្រុងប៉េកាំងវិញដោយគ្មានបានទទួលលទ្ធផលអ្វីនាំទៅជាមួយផងទេ ។ តាមផ្លូវការគេពុំអាចអនុញ្ញាតឲ្យក្រុមនេះធ្វើដំណើរទៅកាន់ភាគខាងត្បូងបានឡើយ ដោយសារហេតុផលសន្តិសុខ ។ តាមការឲ្យដឹងរបស់ក្រុងហាណូយថា ការបើកស្ថានកុងស៊ុលនឹងអាចប្រព្រឹត្តទៅបាននៅត្រីមាសទីបីនៃឆ្នាំ១៩៧៨ ដូច្នេះគឺពិតជាក្រោយកាលបរិច្ឆេទដែលកំណត់សម្រាប់ការជម្លៀសអ្នកដែលដាក់ពាក្យសុំត្រៀមចេញដំណើរជាប្រាកដ ។ ដោយអនុលោមតាមការកំណត់ប្រាំមួយសប្តាហ៍ ក្នុងការរង់ចាំកណ្តាលសមុទ្រក្បែរឆ្នេរប្រទេសវៀតណាម នាវាចិនទាំងពីរគ្រឿងបានចាកចេញទៅវិញដោយស្ងាត់កំបាំងឆ្ពោះទៅកំពង់ផែរបស់ខ្លួនឈ្មោះហាំងពុយ នៅភាគខាងត្បូងប្រទេសចិន ។ នៅលើនាវារបស់គេមានកម្មករឈើមួយចំនួន, គ្រឿងចានឆ្នាំងបាក់បែក ហើយអស្មិមានះបានត្រូវធ្វើឲ្យថ្នាំងថ្នាក់ ។ ការជន់ជោរគ្មានដាច់នៃជនភៀសខ្លួនទាំងហ្វូង ដែលលើកទឹកចិត្តជាចំហដោយក្រុងហាណូយតាំងពីខែឧសភា បេះតែមានបន្តគ្មានធូរស្រាក តាមផ្លូវគោកថែមទៀត ហើយបានឡើងដល់កម្រិតមួយរហូតទាល់តែពួករដ្ឋអំណាចចិនត្រូវតែដកបដា«ស្វាគមន៍ការត្រឡប់មកប្រទេសវិញ» ដែលដាក់នៅតាមប៉ុស្តិ៍ទាំងឡាយជាប់ព្រំដែនគ្មានសល់ ។ គ្រប់ចំណុចទ្វារចូលទាំងអស់សុទ្ធតែត្រូវបិទទ្វារចាក់សោយ៉ាងប្រយ័ត្ន

ប្រយែង ។

គិតឲ្យសព្វៗទៅ វគ្គនៃរឿងនាវាទៅយកជនភៀសខ្លួនបានលេចឡើងជា រឿងដែលធ្វើឲ្យខូលយ៉ាងខ្លាំង សម្រាប់ក្រុងប៉េកាំង ហើយផ្ទុយទៅវិញ បានរួមបង្កជាអត្ថប្រយោជន៍មិនសង្ឃឹមទុកមួយសម្រាប់ការឃោសនារបស់ក្រុងហាណូយថែមទៀត ។ ក្នុងការផ្សាយមួយដែលផ្សាយដោយវិទ្យុក្រុងហាណូយតម្រង់ទៅរកតំបន់អាស៊ីអាគ្នេយ៍ អ្នកធ្វើអត្ថាធិប្បាយម្នាក់បានព្រមានជាឧទាហរណ៍ថា "ការប្តូរគំនិតភ្លាមៗរបស់ចិនចំពោះប្រទេសវៀតណាមគឺជារឿងគ្រប់គ្រាន់នឹងធ្វើឲ្យរដ្ឋាភិបាលនានានៅក្នុងតំបន់ព្រួយបារម្ភហើយ ។ បើសិនជារដ្ឋាភិបាលទាំងនោះមិនបង្កើនការប្រុងប្រយ័ត្នឲ្យរឹតតែខ្លាំងថែមទៀតទេ គឺច្បាស់ជាត្រូវបាត់បង់អ្វីៗទាំងអស់មិនខាន"[២៦] ។ តាមការពិត ប្រទេសចិនត្រូវធ្វើឲ្យខូលខ្លាយខ្លាំងមែនទែនរហូតទាល់តែខ្លួនវាយតម្លៃថាត្រូវតែបង្ហាញនូវភាពធូរស្រាលខ្លះៗ ចំពោះបណ្តាឯកអគ្គរដ្ឋទូតនៃប្រទេសជាសមាជិកអាស៊ាននៅទីក្រុងប៉េកាំង ។ ការបញ្ចេញប្រតិកម្មចំពោះការរំលោភបំពានរបស់វៀតណាមប្រឆាំងនឹងអាណិកជនរបស់ខ្លួនគឺជា"ករណីដោយឡែក"មួយ ពីព្រោះការធ្វើប្រតិបត្តិការដែលបង្កដោយក្រុងហាណូយមានចំណែកនៃការរួមគំនិតដ៏ធំមួយដែលរៀបចំប្រទាក់ក្រឡាដោយពួកសូវៀតដែរ ។

ប្រតិកម្មបែបជ្រួលច្របល់ក្នុងចិត្តនិងដែលឥតពិចារណារបស់ក្រុងប៉េកាំងបានត្រឹមតែធ្វើឲ្យជនជាតិចិននៅប្រទេសវៀតណាមរងគ្រោះថែមទៀតប៉ុណ្ណោះ ។ សេចក្តីថ្លែងការណ៍ដែលតម្លើងទឹកចិត្តតាមរបៀប "បងប្អូនយើងនៅប្រទេសវៀតណាមរង់ចាំតាំងពីយូរយារមកហើយនូវថ្ងៃដែលយើងនឹងនាំពួកគេត្រឡប់មកមាតុប្រទេសវិញ"[២៧] បានជំរុញឲ្យមានសេចក្តីសង្ឃឹមមិនប្រាកដ ។ សេចក្តីថ្លែងការណ៍នេះបានប្រទាញជនជាតិចិនរាប់ពាន់នាក់នៅភាគខាងជើងឲ្យចេញដំណើរទៅកាន់ព្រំដែន និងជនជាតិចិនរាប់រយពាន់នាក់ទៀត នៅទីក្រុងប្រ៊ីឡឹងស្នើសុំឲ្យបញ្ជូនពួកគេទៅមាតុប្រទេសវិញជាផ្លូវការ ។ នាខែមិថុនា នៅទីក្រុងហូជីមិញ ក្រុមអ្នកធ្វើការទទួលបន្ទុកចុះបញ្ជីអ្នកប្រាថ្នាចេញដំណើរ មានការងាររធ្វើយ៉ាងច្រើនដោយក្នុងមួយសប្តាហ៍មានមនុស្សដាក់ពាក្យសុំចំនួនសាមសិបពាន់នាក់ [២៨] ។

តាមការពិត ភាគច្រើននៃពួកចិនដែលជ្រើសយកការបញ្ជូនទៅមាតុប្រទេសវិញបានយល់ឃើញក្នុងរឿងនេះនូវមធ្យោបាយមួយ ដើម្បីធ្វើនិរប្រវេសន៍ទៅនៅប្រទេសមួយផ្សេងទៀតក្នុងឱកាសណាមួយជាលើកទីពីរ ។ ប៉ុន្តែសម្រាប់វៀតណាមយល់ថា ពួកនោះបានរួមផលប្រយោជន៍តែមួយជាមួយសត្រូវរបស់ខ្លួន ។ បំណងដែលសម្តែងឲ្យឃើញដោយសហគមន៍ចិនដើម្បីវិលត្រឡប់ទៅប្រទេសចិនកុម្មុយនីស្តវិញ បានពង្រឹងឲ្យការគិតមមៃពិតប្រាកដរបស់វៀតណាម ដែលមិនទុកចិត្តគេឯងអំពីកម្លាំងទីប្រាំរបស់ចិន រឹតតែមាំឡើងថែមទៀត ។ ជាជាងបង្ខិតបង្ខំអ្នកជំនួញនៅក្រុងប្រ៊ីឡឹង ឲ្យប្តូរគំនិតទៅធ្វើស្រែចម្ការដោយបញ្ជូនពួកគេទៅដាក់នៅក្នុងតំបន់សេដ្ឋកិច្ចថ្មីតាមរបៀបអ្នកអត់ការងាររធ្វើដើមកំណើតវៀតណាម គឺរដ្ឋាភិបាលគ្រាន់តែចង់យក

ពួកនេះចេញឲ្យបាត់ពីមុខពីមាត់ប៉ុណ្ណោះ ។ ម្យ៉ាងទៀត រដ្ឋាភិបាលក៏បានទទួលផលកម្រៃមួយ“ដាក់ហោប៉ៅ” នៅពេលឆ្លងកាត់ដែរ ។ នយោបាយនិរប្រវេសន៍ដែលរៀបចំឡើងដោយក្រុងហាណូយ គឺជាភាពអត់អៀនខ្មាសយ៉ាងពេញលេញមួយ ។ អ្នកជំនួញម្នាក់នៅទីក្រុងប្រ៊ីឡឹងបានបំភ្លឺថា “ដោយហេតុថា យើងមិនមាននិស្ស័យខាងការងារស្រែចម្ការ យើងបានបដិសេធមិនទៅជនបទទេ ហើយទោះជាយ៉ាងណាក៏ដោយ យូរបន្តិចយើងទាំងអស់គ្នានឹងត្រូវភៀសខ្លួនចេញ ។ ចំណែកឯរដ្ឋាភិបាលយល់ថាត្រឹមត្រូវណាស់ដែលដកហូតមាសរបស់យើង និងបណ្ដោយឲ្យយើងចេញដំណើរទៅទីណាក៏បាន”[២៩] ។

ពេញថិរវេលានៃរដូវក្ដៅឆ្នាំ១៩៧៨ ការិយាល័យផ្នែកសន្តិសុខសាធារណៈរបស់វៀតណាមបានបើកក្រុមការងារជាច្រើននៅក្នុងបណ្ដាទីក្រុងស្ថិតនៅតាមឆ្នេរសមុទ្រភាគខាងត្បូង និងឲ្យគេធ្វើទូកកប៉ាល់យ៉ាងច្រើនសម្រាប់ដឹកជញ្ជូនជនជាតិចិន (ឬវៀតណាមដែលធ្វើខ្លួនជាចិន) ដោយទារជាមុននូវថ្លៃឈ្នួលជ្រុលហួសហេតុជាមាសនិងជាដុល្លារតែម្ដង[៣០] ។ ប្រតិបត្តិការដែលអ្នកការទូតបស្ចិមប្រទេសដាក់សម្មតិនាមឲ្យថា “ក្រុមហ៊ុនដឹកជញ្ជូនម្ហូបកំប៉ុងចាស់ៗតាមសមុទ្រ”នោះ នៅទីបំផុតបានទទួលលទ្ធផលគឺក្នុងរយៈពេលពីរឆ្នាំមានមនុស្សប្រហែល ២៥ម៉ឺននាក់រត់ចេញតាមទូក ដែលក្នុងនោះមនុស្សពីសាមសិបទៅសែសិបពាន់នាក់ បានបាត់បង់ជីវិតនៅក្នុងសមុទ្រ[៣១] ។

## នៅភូមិភាគបូព៌ា ៖ ការបោសសម្អាតមួយចាប់ផ្ដើម

ការប្រយុទ្ធដ៏សាហាវរបស់“មេនាគ”ប្រឆាំងនឹង“កូននាគ”បានទាក់ទាញនូវការយកចិត្តទុកដាក់ពីពិភពលោកទាំងមូលមួយរយៈខ្លីដែរ ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ប្រទេសកម្ពុជាក៏ទទួលរងនូវការកាប់សម្លាប់ខ្ពស់ដល់កម្រិតមួយដែលមានលក្ខណៈធំធេងណាស់ ប្រៀបបីដូចជាបង្កឲ្យការធ្វើអន្តរាគមន៍របស់វៀតណាមរឹតតែឆាប់មកដល់ ។ ម្យ៉ាងទៀត អ្នកឯកទេសចំណានៗដែលចាំឃ្លាំមើលភ័ស្តុតាងទាំងឡាយស្ដីពីប្រទេសដែលកាត់ផ្ដាច់ពីពិភពលោកនេះ ដោយការយកចិត្តទុកដាក់ស្ដាប់ការផ្សាយរបស់វិទ្យុភ្នំពេញ និងសេចក្ដីអះអាងរបស់អ្នកភៀសខ្លួនកម្ពុជាដែលទើបមកដល់ថ្មីៗ អាចសង្ស័យពីទំហំនៃសោកនាដកម្មដែលបង្កចលាចលតាមស្រុកស្រែនិងចម្ការកៅស៊ូរបស់កម្ពុជានៅភាគខាងកើត ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៨ ប្រទេសចិនបានចាប់ផ្ដើមគ្រោះតិះដៀលប្រឆាំងប្រទេសវៀតណាមយ៉ាងចាស់ដៃ ព្រមពេលមានទស្សនកិច្ចប្រកបដោយផ្លែផ្ការបស់ ប្រ៊ីហ្សឺនស្គី នៅទីក្រុងប៉េកាំង ។ នៅថ្ងៃពុធ ទី២៤ ខែឧសភាដដែល ក្នុងចម្ងាយពីទីនោះប្រមាណ៣.០០០គីឡូម៉ែត្រ ការវាយប្រហារដែលមានទម្រង់ខុសប្លែកពីមុនទាំងស្រុងមួយបានផ្ដើមឡើង នៅក្នុងប្រជុំជនតូចមួយរបស់កម្ពុជាឈ្មោះថាសួង ។ ប៉ុល ពត បានបញ្ជូនកងពលធំជាច្រើនរបស់ភូមិភាគកណ្ដាល ទៅឡោមព័ទ្ធមន្ទីរសេនាធិការរបស់បក្សភូមិភាគបូព៌ា មុននឹងចាត់ចែងធ្វើការចាប់ខ្លួន“ពួកក្បត់” ពោលគឺពួកមេដឹកនាំគណៈកម្មាធិការបក្សដែលត្រូវ

សង្ស័យពីបទឃុបឃិតជាមួយប្រទេសវៀតណាម ។ មេដឹកនាំមួយចំនួនតូចបានត្រូវចាប់ខ្លួនធ្វើទារុណកម្មកៀបយកចម្លើយសារភាព បន្ទាប់មកយកទៅសម្លាប់ចោល ។ សោ ភឹម លេខាបក្សភូមិភាគបូព៌ា និងជាអតីតដៃស្តាំរបស់ ប៉ុល ពត បានធ្វើអត្តឃាត ។ អ្នកទាំងឡាយដែលប្រឹងប្រែងទប់ទល់នឹងកងទ័ពរបស់ ប៉ុល ពត បានរត់ភៀសខ្លួនទៅប្រទេសវៀតណាម ដូចជាធ្វើឲ្យកម្លាំងនៃចលនាតស៊ូខ្មែរនៅទីនោះកាន់តែរីកធំឡើងថែមទៀត ។ ការសម្លាប់ពួកកម្មាភិបាល និងកងទ័ពរបស់ភូមិភាគបូព៌ាយ៉ាងរង្គាលរង្គំ បានធ្វើឲ្យសេចក្តីសង្ឃឹមចុងក្រោយបំផុតអំពីការធ្វើរដ្ឋប្រហារប្រឆាំងនឹងក្រុមមេដឹកនាំខ្មែរក្រហមត្រូវរលាយសាបសូន្យ ។ ពុំមានការដោះស្រាយណាផ្សេងទៀត ក្រៅពីពឹងផ្អែកលើកម្លាំងប្រយុទ្ធរបស់វៀតណាមឡើយ ។

នៅថ្ងៃទី២៥ ខែមិថុនា ដោយធ្វើឲ្យមានការភ្ញាក់ផ្អើលស្រឡាំងកាំងជាទូទៅមួយ វិទ្យុភ្នំពេញបានប្រកាសជាសាធារណៈថា ការប៉ុនប៉ងធ្វើរដ្ឋប្រហារមួយដែលរៀបចំជាសម្ងាត់ដោយប្រទេសវៀតណាម និងក្រុមសេ.អ៊ី.អា. ទើបនឹងត្រូវយើងកម្ទេចចោល ។ ការប្រើកម្លាំងផ្ទួបគ្នាដែលរៀបចំដោយអ្នកដែលតាំងខ្លួន ជាមេគំនិតនោះគឺមិនទំនងជាពិតទាំងស្រុងទេ ។ ប៉ុន្តែ ការឃោសនារបស់វៀតណាមបាននិយាយអំពីការបះបោរនៅប្រទេសកម្ពុជាដំណាលគ្នានឹងអ្នកអង្កេតការណ៍បានសន្និដ្ឋានអំពីរឿងនេះថា នៅទីនោះ កើតមានព្រឹត្តិការណ៍ធ្ងន់ធ្ងរដោយឡែកមែន ។ ប៉ុន្តែគេគោងតែរង់ចាំពីរឆ្នាំ ដើម្បីបានដឹងពីព្រឹត្តិការណ៍ពិតប្រាកដ និងអត្ថន័យពេញលេញរបស់វា ។ ប៉ុន្តែផលនៃការបះបោររបស់ភូមិភាគបូព៌ា និងការបង្ក្រាបជាប់បន្តគ្នាហូរហែអំពីដំណើរនៃព្រឹត្តិការណ៍ផ្សេងៗនៅតណ្ហូចិនគឺមានច្រើនអនេក ។ ព្រឹត្តិការណ៍ទាំងនោះ ផ្តល់នូវឱកាសឲ្យគេបញ្ចប់នៅពេលនេះតែម្តង ។

ជាមួយនឹងការបោសសម្អាតនៅភូមិភាគបូព៌ា យុទ្ធនាការប្រឡាក់ទៅដោយឈាមដែលផ្តើមឡើង ដោយ ប៉ុល ពត នៅក្នុងភូមិភាគផ្សេងៗទៀត ដើម្បីធ្វើឲ្យមាគ៌ានយោបាយរបស់គាត់មានប្រៀបជាងគេនោះបានស្គាល់នូវ ភាពខ្លាំងដល់កម្រិតមួយ ។ កម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាភូមិភាគរដ្ឋបាលចំនួន៧គឺ ៖ ឧត្តរ បូព៌ា ឦសាន និរតី បស្ចិម ពាយ័ព្យ និងភូមិភាគកណ្តាល ។ តំបន់រដ្ឋបាលជាច្រើនទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ធ្លាប់ត្រូវអនុម័តរួចមកហើយដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលធ្វើសកម្មភាពលួចលាក់ និងក្នុងរយៈពេលប្រាំឆ្នាំនៃការប្រយុទ្ធតស៊ូដោយអាវុធ(១៩៧០ - ១៩៧៥) ។ កងឯកភាពប្រចាំភូមិភាគជាច្រើនកង ដែលនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីមជ្ឈិមបក្សធ្លាប់មានស្វ័យភាពដ៏ជាក់លាក់មួយប្រហែលមកពីភាពលំបាកក្នុងការទាក់ទងគ្នាច្រើនជាងមូលហេតុសន្តិសុខ ។ ក្នុងរយៈពេលបួនឆ្នាំដំបូងនៃរបបនេះគណៈមជ្ឈិមបក្សបានប្រឹងប្រែងដាក់បង្ខំឲ្យមានរបៀបដឹកនាំតាមលំដាប់លំដោយមួយចេញពីថ្នាក់លើត្រង់ទៅបណ្តាមេដឹកនាំភូមិភាគតែម្តង ដោយរក្សាទុករបាំងមួយយ៉ាងតឹងរ៉ឹងរវាងភូមិភាគនានាមិនឲ្យទាក់ទងគ្នាបានឡើយ ។ ដោយពឹងផ្អែកលើភូមិភាគកណ្តាលនិងនិរតី នៅឆ្នាំ១៩៧៦ - ៧៧ ប៉ុល ពត បានចាប់ផ្តើមកម្ចាត់ចោលមេដឹកនាំភូមិភាគឧត្តរនិងពាយ័ព្យភ្លាម ។ ការខ្វែងគំនិតគ្នាជាច្រើន ដែលផ្តោតជាសំខាន់នៅលើសង្វាក់នៃការ

ធ្វើបដិវត្តន៍និងរបៀបអនុវត្តផ្សេងៗ ។ អ្នកប្រឆាំងបានទិតៀនមាគ៌ាឆ្វេងជ្រុលហួសហេតុនិងផ្សងព្រេងនិយមរបស់ ប៉ុល ពត ថាពួកគេគ្មានជំនឿពីដំណើរឆ្ពោះទៅរកលទ្ធិកុម្មុយនីស្តក្នុងរយៈពេលមួយយ៉ាងខ្លីទេ ហើយក៏មិនយល់ព្រមចំពោះការប្រព្រឹត្តគ្មានអាណិតអាសូរដែលត្រៀមបម្រុងសម្រាប់ប្រជាជនទីក្រុងដែរ ។ ពួកគេបានទិតៀននយោបាយផ្សងព្រេងនិយមរបស់ ប៉ុល ពត ចំពោះប្រទេសវៀតណាមថែមទៀត-នេះជាអំពើក្បត់ដែលសមនឹងស្លាប់ ។ ភាគច្រើននៃអ្នករងគ្រោះពីការធ្វើវិសុទ្ធកម្មផ្សេងៗសុទ្ធតែជឿថាមានការគំរាមកំហែងរបស់វៀតណាមមែន : តាមមតិពួកគេថា ចាំបាច់ត្រូវតែកែប្រែការភ័ន្តច្រឡំក្នុងការដឹកនាំប្រទេស គឺដើម្បីធានាជោគជ័យរបស់បដិវត្តន៍កម្ពុជា និងផ្តល់ឲ្យប្រទេសជាតិនូវមធ្យោបាយផ្សេងៗសម្រាប់ការពារខ្លួនដោយខ្លួនឯង ។ ការវិនិច្ឆ័យស្ថានការណ៍មួយគឺជាសញ្ញាដែលឲ្យដឹងហេតុមុន... ។ សម្រាប់ ប៉ុល ពត និងក្រុមមានភក្តីមួយក្តាប់តូចរបស់គាត់ ការចោទប្រកាន់ពីអំពើក្បត់បើតាមយោបល់លោក ហ៊ីឌ័រ គឺជាមធ្យោបាយងាយស្រួលមួយ ដើម្បីគេចចេញពី«ការពិភាក្សាតទល់គ្នាខាងផ្នែកនយោបាយ ដែលក្នុងនោះពួកគេមិនប្រាកដជាមានប្រៀបលើគាត់ឡើយ ហើយម្យ៉ាងទៀតមុខជានឹងបង្កឲ្យមានភាពបាក់បែកគ្នាក្នុងបក្ស»[៣២] ទៀតផង ។

ការប្រឆាំងទាំងអស់ទល់នឹង ប៉ុល ពត ដូចជាការប្រឆាំងរបស់ភូមិភាគបូព៌ាគឺមានលក្ខណៈខ្លាំងក្លាជាងគេ ។ តាំងពីការចាប់កំណើតរបស់ចលនាខ្មែរឥស្សរៈប្រឆាំងបារាំងក្នុងអំឡុងទសវត្សរ៍៤០ ភូមិភាគនេះបានសហការយ៉ាងជិតស្និទ្ធជាមួយពួកកុម្មុយនីស្តវៀតណាម ។ ភាពនៅកៀកព្រំដែនជាមួយប្រទេសវៀតណាម និងវត្តមាននៃពួកកម្មករវៀតណាមក្នុងចម្ការកៅស៊ូនានារបស់កម្ពុជា បានធ្វើឲ្យការទាក់ទងគ្នាមានភាពងាយស្រួលបំផុត ។ ក្នុងអំឡុងពេលដំបូងៗនៃការប្រយុទ្ធតស៊ូទល់នឹង លន់ នល់ គឺក្នុងភូមិភាគនេះហើយដែលពួកវៀតណាមបានជួយរៀបចំនិងបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រកងទ័ពខ្មែរក្រហម ។ សហប្រតិបត្តិការដ៏យូរលង់នេះហាក់ដូចជាដៅឲ្យឃើញទម្រង់នយោបាយរបស់ពួកកុម្មុយនីស្តខ្មែរ ដែលជាអ្នកការពារទស្សនៈនៃការខិតទៅជិតលទ្ធិម៉ាក្សស៊ីសជាប្រពៃណីមួយក្នុងការផ្លាស់ទ្រង់ទ្រាយលទ្ធិសង្គមនិយម ។ ដោយធ្វើ«តាមគំរូរបស់វៀតណាម» ពួកគេបានសង្កត់បញ្ជាក់អំពីភាពចាំបាច់ក្នុងការប្រើប្រាស់ប្រភពធនធានផ្សេងៗដែលអាចប្រើប្រាស់បាន-របស់ពួកគហបតីឬអ្នកដទៃទៀត-ដើម្បីបង្កើនការផលិត ។ ការលុបបំបាត់វណ្ណៈផ្សេងៗពុំមែនជាអាទិភាពទេ ។ ក្រុមដែលដឹកនាំដោយ ប៉ុល ពត ពិតជាត្រូវញាំងឲ្យលុះក្នុងឥទ្ធិពលម៉ៅ និងគំនិតរបស់គាត់ស្តីពីការតស៊ូវណ្ណៈសមភាពក្នុងសង្គម និងការបន្តតស៊ូដោយឥតឈប់ឈរ[៣៣] ។

គេមិនដឹងថា តើការខ្វែងគំនិតគ្នាទាំងនេះត្រូវបានពិភាក្សាតទល់គ្នាក្នុងផ្ទៃបក្ស ឬថាតើពួកកុម្មុយនីស្តរបស់ភូមិភាគបូព៌ាប្រថុយតស៊ូតាមផ្លូវនយោបាយនឹង ប៉ុល ពត ឬក៏យ៉ាងណាទេ ។ ទោះបីជាយ៉ាងណាក៏ដោយ វាហាក់ដូចជាអ្នកទាំងនោះមិនព្រមអនុវត្តន៍រាល់វិធានការឆ្វេងជ្រុល និងព្រៃផ្សៃហួសហេតុ ដែលសម្រេចឡើងដោយមជ្ឈិមទេ ។ ក្នុងរយៈពេលបីឆ្នាំដំបូងនៃការកាន់អំណាចរបស់ខ្មែរក្រហម ភូមិភាគបូព៌ាបានផ្គត់ផ្គង់ស្បៀងអាហារ

ឲ្យប្រជាជនបានប្រសើរជាងគេ ហើយការរស់នៅរបស់"អ្នកថ្មី" -ប្រជាពលរដ្ឋទីក្រុងដែលគេបំបែកមិនឲ្យនៅជុំគ្នា- ក៏មិនសូវលំបាកលំបិនដូចនៅកន្លែងដទៃទៀតដែរ[៣៤] ។

ក៏ប៉ុន្តែ វាជាការពិតថា ភូមិភាគបូព៌ាក៏មានចំណែកក្នុងការសម្លាប់រង្គាលដែរ ។ ជាឧទាហរណ៍ ជនជាតិចាមជាងប្រាំមួយម៉ឺននាក់ភាគច្រើនមានដើមកំណើតនៅខេត្តកំពង់ចាម ត្រូវបានខ្មែរក្រហមប្រហារជីវិត ព្រោះតែជំនឿសាសនាអ៊ីស្លាមរបស់ខ្លួន ។ កងទ័ពរបស់ភូមិភាគបូព៌ាខ្លះបានធ្វើឲ្យគេសម្គាល់ខ្លួនដោយសារការប្រព្រឹត្តអំពើសាហាវយង់ឃ្នងប្លែកពីធម្មតាទៅលើប្រជាជនស៊ីវិលវៀតណាមដោយមានការ"ឲ្យដៃ"របស់មជ្ឈិមផង ។ ប៉ុន្តែ ផលវិបាកនៃការមិនចុះសម្រុងគ្នាខាងផ្នែកនយោបាយឬជំនឿមិនទុកចិត្តគេឯង បាននាំទៅដល់ការនិយាយដោះសាតែរៀងខ្លួន ។ ភូមិភាគបូព៌ាជាប្រភពផ្តល់កម្មាភិបាលយ៉ាងច្រើនសម្បើមដែលមានក្រុមអ្នកបែកបក្សពួក ឬអ្នកដែលត្រូវសម្លាប់មុនពេលដែលមិនអាចប៉ុនប៉ងធ្វើអ្វីទាំងអស់ [៣៥] ។

## "ក្បាលយួន ខ្លួនខ្មែរ"

ប្រវត្តិរបស់ភូមិភាគបូព៌ាគឺជាប់ទាក់ទងនឹងប្រវត្តិរបស់ សោ ភឹម ដោយមិនអាចកាត់ផ្តាច់ពីគ្នាបាន ។ សោ ភឹម មានដើមកំណើតជាកសិករដែលមានរូបរាងធាត់ក្រទ្រល ដុះក្បាលពោះ មុខមូលដូចព្រះច័ន្ទគឺជាមនុស្សធ្លាប់បានដឹកនាំចលនាកុម្មុយនីស្តនៅភូមិភាគនេះរបស់ប្រទេសកម្ពុជា ក្នុងអំឡុងពេលមួយភាគបួននៃសតវត្សរ៍មកហើយ ។ នៅឆ្នាំ១៩៥៤ គាត់ក៏មានមុខនៅក្នុងចំណោមជនកុម្មុយនីស្តខ្មែររាប់ពាន់នាក់ដែលត្រូវប្រមូលផ្តុំគ្នាជាថ្មីនៅទីក្រុងហាណូយ ប៉ុន្តែគាត់បានលួចវិលត្រឡប់មកកម្ពុជាវិញ ដើម្បីរៀបចំកសាងបក្សជាថ្មី ។ នៅឆ្នាំ១៩៦៣ គាត់បានឡើងឋានៈចូលក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស(ស្មើនឹងការិយាល័យនយោបាយដែរ) ។ គណៈអចិន្ត្រៃយ៍នេះដែលមានសមាជិកប្រាំរូប គឺគ្រប់គ្រងដោយពួកបញ្ញវន្តប្រឆាំងវៀតណាមរបស់ ប៉ុល ពត ហើយមានតែគាត់(សោ ភឹម)ម្នាក់ប៉ុណ្ណោះ ដែលមានដើមកំណើតជាកសិករ ។ ក្នុងអំឡុងបណ្តាឆ្នាំធ្វើសង្គ្រាមទ័ពព្រៃប្រឆាំងរបប លន់ នល់ គាត់បានក្លាយទៅជានាយអគ្គសេនាធិការរងនៃកងទ័ពរបស់ខ្មែរក្រហម ។ ក្នុងអំឡុងទសវត្សរ៍៦០និង៧០ គាត់បានចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយពួកកុម្មុយនីស្តវៀតណាម បើទុកជាមានការរង្កៀសចិត្តគ្នាម្តងម្កាលក៏ដោយ ។ ឥទ្ធិពលរបស់គាត់ក្នុងភូមិភាគក្រោយឆ្នាំ១៩៧៥មានរឹតតែខ្លាំងឡើងថែមទៀត នៅពេលដែលគាត់បានកាន់កាប់មុខតំណែងពីរតែម្នាក់ឯងគឺសមាជិកគណៈអចិន្ត្រៃយ៍ផង និងជាលេខាបក្សភូមិភាគផង ។ មនុស្សជាច្រើនវាយតម្លៃថា ភូមិភាគបូព៌ាត្រូវជំពាក់គុណគាត់ចំពោះភាពសម្បូរណ៍សប្បាយដែលមិនទៀងរបស់ភូមិភាគនេះ ប៉ុន្តែ អ្នកឯកទេសនៅតែពិចារណានៅឡើយ អំពីតួនាទីរបស់គាត់នៅក្នុងការសម្លាប់រង្គាលនៅទឹកដាច់ព្រ័ត្រ ។

គេនឹកឃើញថា ការគ្មានសមត្ថភាពរបស់កងទ័ពភូមិភាគបូព៌ាក្នុងការទប់ទល់ប្រឆាំងនឹងការលុកលុយ

របស់វៀតណាមនៅខែធ្នូ ឆ្នាំ១៩៧៧ ត្រូវបានអះអាងបន្ថែមដោយរលកនៃការបោសសម្អាតមួយថ្មីទៀត ។ ក្នុងភាពច្របូកច្របល់ដែលកើតមានបន្ទាប់ពីការដកថយរបស់កងទ័ពក្រុងហាណូយ កងឯកភាពទ័ពមួយចំនួនរបស់ភូមិភាគបូព៌ា បានបាញ់កាំភ្លើងតទល់គ្នាជាមួយកម្លាំងទ័ពជំនួយរបស់មជ្ឈិមដែលទើបនឹងមកដល់ពីភូមិភាគកណ្តាល ។ ដោយកងឯកភាពទាំងនេះបាក់ទ័ពរត់ខ្ចាត់ខ្ចាយនៅចំពោះមុខការរុលមកមុខរបស់វៀតណាមកាលពីមុន នៅពេលនេះកងទ័ពទាំងនោះត្រូវជាប់សង្ស័យយ៉ាងខ្លាំងពីការឃុបឃិតជាមួយសត្រូវ ។ ម្តងមួយៗ កម្មាភិបាលទ័ពទាំងអស់ដែលមាននាទីជានិរសាររបស់ភូមិភាគបូព៌ា ព្រមទាំងបណ្តាមេបញ្ជាការកងពលធំរបស់ភូមិភាគកណ្តាលដែលចូលរួមក្នុងការប្រយុទ្ធនេះ ត្រូវបានកោះហៅមកក្រុងភ្នំពេញដើម្បី“ប្រជុំ” ហើយត្រូវបាត់ខ្លួនដោយគ្មានឃើញវិលត្រឡប់ទៅវិញជារៀងរហូត ។ ឯកសារជាច្រើននៅគុកទួលស្លែងបានបង្ហាញថា រហូតមកដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៨ ចំនួនអ្នកទោសដែលមកពីភូមិភាគបូព៌ាមាន៤០៩នាក់ គឺច្រើនលើសពីចំនួនអ្នកទោសមកពីភូមិភាគពាយ័ព្យរហូតដល់ទៅដប់ដង ។ នៅថ្ងៃបន្ទាប់ មនុស្សចំនួនម្ភៃប្រាំបីនាក់ទៀតត្រូវខ្មែរក្រហមយកមកដាក់គុកនៅទួលស្លែងដែលសុទ្ធតែមកពីភូមិភាគបូព៌ាទាំងអស់ ។ មេបញ្ជាការកងពលធំទាំងពីររបស់ភូមិភាគកណ្តាលដែលបោះទីតាំងប្រចាំនៅភូមិភាគបូព៌ា ក៏ត្រូវបានចាប់ខ្លួនផងដែរ ។ មេបញ្ជាការម្នាក់ក្នុងចំណោមពីរនាក់ដែលដឹកនាំបញ្ជាកងពលធំលេខ២៩០ មានឈ្មោះថា ហេង តាល់ ដែលគ្រប់គ្រងបញ្ជាលើកងពលធំលេខ២៩០ ។ គាត់គឺជាបងប្អូនបង្កើតរបស់ ហេង សំរិន[៣៦] ។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ វិទ្យុក្រុងភ្នំពេញបានផ្សព្វផ្សាយសារដ៏ចម្លែកមួយដោយអំពាវនាវឲ្យធ្វើការកាប់សម្លាប់ពូជសាសន៍វៀតណាម និង“ការបោសសម្អាត”ក្នុងជួរកងទ័ពរបស់កម្ពុជាខ្លួនឯងផ្ទាល់ ៖ អ្វីៗទាំងអស់គ្រាន់តែជាតួលេខប៉ុណ្ណោះ ។ យុទ្ធម្នាក់ក្នុងជួររបស់យើងត្រូវតែសម្លាប់វៀតណាមឲ្យបានសាមសិបនាក់ ។ ...និយាយម្យ៉ាងទៀត ការខូចខាតរៀងខ្លួននឹងស្ថិតនៅក្នុងផលធៀបគឺមួយទល់នឹងសាមសិប ដែលតម្រូវឲ្យយើងមិនបាច់បញ្ជូនមនុស្សប្រាំបីលាននាក់(ប្រជាជនដែលប៉ាន់ស្មាននៅប្រទេសកម្ពុជា) ឲ្យចូលប្រយុទ្ធទេ ។ ដូច្នេះយើងត្រូវការមនុស្សតែពីរលាននាក់ប៉ុណ្ណោះ សម្រាប់កម្ទេចវៀតណាមចំនួនហាសិបលាននាក់ ហើយយើងនឹងនៅសល់ប្រជាជនប្រាំមួយលាននាក់ទៀត” ។ ការចាប់ផ្តើមធ្វើមួយដែលប្រកបដោយមហិច្ឆតាក្នុងការទាមទារឲ្យមានការចូលប្រយុទ្ធទាំងស្រុងពីសំណាក់កងទ័ព បក្ស និងប្រជាជនទាំងមូល “យើងត្រូវតែបោសសម្អាតជួរទ័ពនិងបក្សរបស់យើងឲ្យស្អាតបរិសុទ្ធ ហើយក៏ត្រូវបោសសម្អាតក្នុងជួរមហាជនឲ្យដូចគ្នាដែរ ក្នុងគោលបំណងបន្តការវាយប្រយុទ្ធ ដើម្បីការពារទឹកដីរបស់យើងនិងពូជសាសន៍ខ្មែរ”[៣៧] ។

ក្នុងឋានៈជាថ្នាក់ដឹកនាំម្នាក់តើ សោ ភឹម មានពាក់ព័ន្ធនឹងនយោបាយចម្លែកខុសគេនេះដែរឬទេ? តើគាត់មានផ្តល់សេចក្តីយល់ព្រមក្នុងការបោសសម្អាតផ្សេងៗរបស់មជ្ឈិមបក្សដែរទេ? អ្នកស្រាវជ្រាវសញ្ជាតិអូស្ត្រាលីម្នាក់គឺលោក ប៊ែន យៀរនិន ដែលចេះនិយាយភាសាខ្មែរស្ទាត់ជំនាញ និងដែលបានចំណាយពេល

វេលាយ៉ាងច្រើនដើម្បីសិក្សាពីប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជាជឿថា ស៊ើវតែពេញរយៈពេលនៃការបោសសម្អាត សោ ភឹម មានជំងឺនៅដេកព្យាបាលខ្លួននៅឡើយ ហើយក៏ពុំមានអ្នកណាផ្តល់ដំណឹងពីរឿងនេះឲ្យគាត់ដឹងដែរ ។ ទីបំផុត នៅពេលដែលគាត់បានដឹងពីការចាប់ខ្លួនមេបញ្ជាការកងពលធំទាំងពីររបស់ភូមិភាគកណ្តាល ដែលបោះទ័ពប្រចាំការនៅភូមិភាគបូព៌ា(កងពលធំលេខ២៨០ និង២៩០) គាត់ចាប់ផ្តើមខឹងសម្បារយ៉ាងខ្លាំង ប៉ុន្តែដំបូន្មានស្លូតស្តើងរបស់គាត់គឺត្រូវជំរុញ“ឲ្យម្នាក់ៗយកចិត្តទុកដាក់តាមដានសភាពការណ៍ និងធ្វើការប្រុងប្រយ័ត្នខ្ពស់ដោយខ្លួនឯង” ។ តាមមតិលោក បែ៊ន យៀរនិន ថា សោ ភឹម បានត្រូវញ៉ាំងមិនឲ្យធ្វើអ្វីមួយកើតឡើយ ដោយសារសតិសម្បជញ្ញៈគោរពវិន័យបក្សរបស់គាត់ និងភាពប្រាកដក្នុងចិត្តរបស់គាត់ថា ការចាប់ខ្លួនមនុស្សយ៉ាងច្រើននិងការសម្លាប់មនុស្សយ៉ាងវង្គាលនេះ ពុំអាចឆ្លុះបញ្ចាំងឲ្យឃើញពីសារជាតិពិតប្រាកដរបស់បដិវត្តន៍ឡើយ ។ នៅពេលដែលការបោសសម្អាតរីករាលដាលកាន់តែខ្លាំងឡើងៗ ហើយដែលគ្មានអ្វីអាចបញ្ឈប់បាននោះ គាត់ហាក់ដូចជាត្រូវធ្វើឲ្យភាន់ភាំងស្រឡាំងកាំងលែងធ្វើអ្វីកើត ។ ផ្ទុយទៅវិញតាមយោបល់លោក ស៊ើវហ្វេន ហ៊ីឌ័រ ថា បន្ទាប់ពីការវាយបុកទម្លុះរបស់វៀតណាមនៅខែធ្នូ សោ ភឹម បានត្រូវរ៉ូវគ្នាជាមួយ ប៉ុល ពត ដើម្បីកម្ចាត់សមាជិកនៃបញ្ជាការដ្ឋានកងទ័ពរបស់ខ្លួនជាច្រើននាក់ ។ សម្រាប់មេដឹកនាំម្នាក់របស់កម្ពុជាប្រជាធិបតេយ្យ របៀបតែមួយគត់ក្នុងការយករួចខ្លួនចំពោះបរាជ័យមួយ គឺមានតែទម្លាក់ការទទួលខុសត្រូវចំពោះអំពើក្បត់ទៅលើអ្នកនៅក្រោមបង្គាប់ខ្លួនប៉ុណ្ណោះ ។ ចំពោះ ហ៊ីឌ័រ យល់ថា “វាពិតប្រាកដណាស់នូវអ្វីដែល សោ ភឹម បានដឹកនាំនៅពេលប្រើងប្រែងទ្រទ្រង់វិបុលភាពមិនប្រាកដមួយក្នុងភូមិភាគបូព៌ា និងសាកល្បងចាត់ចែងរៀបចំកងទ័ពទាំងតំបន់ ក៏ដូចជាមូលដ្ឋាន ប៉ុន្តែគាត់ពុំបានដឹងថា ខ្លួនគាត់ផ្ទាល់ជាមនុស្សដែលត្រូវសង្ស័យដែរទេ”[៣៨] ។

បើពិនិត្យឲ្យជ្រៅជ្រះទៅ តើបានការអ្វីបើ សោ ភឹម ដែលជាមេដឹកនាំប្រកបដោយចេតនាត្រឹមត្រូវម្នាក់ ប៉ុន្តែជាមនុស្សគ្មានពិសោធន៍ ត្រង់គ្មានល្បិចកលប្តូជាពេជ្ឈឃាតម្នាក់ដែលស៊ុមគ្រលុំនឹង ប៉ុល ពត ត្រូវបាត់បង់សេចក្តីទុកចិត្តទៅហើយនោះ? អ្វីដែលត្រូវគិតគឺថា ការព្យាយាមទាំងអស់សង្ឃឹមរបស់គាត់ ដើម្បីរើបម្រះចេញពីដង្កៀបដែលរួបរឹតមកលើគាត់ មុខជាបញ្ឆេះឲ្យមានសង្គ្រាមស៊ីវិលមួយដែលកាន់តែសាហាវព្រៃផ្សៃឡើងៗរហូតដល់មានការចូលធ្វើអន្តរាគមន៍សាជាថ្មីរបស់វៀតណាម ដែលលើកនេះមានទំហំធំធេងបំផុត ។

នៅចុងខែឧសភា ឆ្នាំ១៩៧៨ កែ ពក មេដឹកនាំភូមិភាគកណ្តាលដែល ប៉ុល ពត ចាត់ឲ្យទទួលភារកិច្ចដឹកនាំធ្វើការបោសសម្អាតផ្សេងៗបានផ្ញើទៅឲ្យ សោ ភឹម នូវ“សំបុត្រអញ្ជើញប្រជុំ”មួយ ។ ភឹម បានដឹងប្រាកដពីអ្វីដែលគាត់ត្រូវប្រកាន់អាកប្បកិរិយាយ៉ាងណាៗហើយក្នុងរឿងនេះ ។ ដោយវៃឆ្លាតគាត់បានបញ្ជូននិរសារបីនាក់ដែលក្នុងនោះមានថ្នាក់ដឹកនាំបក្សជាន់ខ្ពស់ម្នាក់ផងឲ្យទៅស៊ើបសួរពីកម្មវត្ថុនៃការប្រជុំនេះ ប៉ុន្តែគ្មានឃើញអ្នកណាម្នាក់វិលត្រឡប់មកវិញសោះ ។

នៅថ្ងៃទី២៨ ខែឧសភា កងទ័ពរបស់ភូមិភាគកណ្តាលដែលត្រូវជួយពង្រឹងកម្លាំងបន្ថែមកាលពីពេលថ្មីៗ

ដោយរថក្រោះមួយកង បានហ៊ុមព័ទ្ធមន្ទីរបក្សភូមិភាគបូព៌ានៅសួង ដែលមានចម្ងាយប្រមាណ៣០គីឡូម៉ែត្រ ពីព្រំដែនវៀតណាម ។ មេដឹកនាំភូមិភាគមួយចំនួនធំបានត្រូវចាប់ខ្លួននិងសម្លាប់ចោល ។ ប៉ុន្តែ ភឹម បានរត់គេចចេញឆ្ងាយទៅហើយ ដែលអមដំណើរដោយប្រពន្ធ កូនៗ និងអង្គរក្សជាច្រើននាក់របស់គាត់ដោយភៀសខ្លួនតាមឡានហ្ស៊ីបមួយគ្រឿងក្នុងបំណងទៅឲ្យដល់ក្រុងភ្នំពេញ ។ តាមលោក ប៉ែន យៀវនិន ឲ្យដឹងថា គាត់ធ្លាប់បានប្រកាសប្រាប់បណ្តាសហការីរបស់គាត់ថា កែ ពក និងរដ្ឋមន្ត្រីការពារប្រទេស សុន សេន ដែលដឹកនាំធ្វើការវាយប្រហារនេះ សុទ្ធតែជាមនុស្សក្បត់ហើយគាត់សង្ឃឹមថា នឹងបានទទួលលិខិតចាប់ខ្លួនគាត់ពីគណៈមជ្ឈិមបក្សទៀតផង ។ តាមយោបល់ ហ៊ីឌ័រ ថា "ភឹម ជឿថាកងទ័ពរបស់ភូមិភាគកណ្តាលបានប្រព្រឹត្តហួសពីបទបញ្ជារបស់មជ្ឈិម ។ ដោយហេតុនេះ គាត់បញ្ជាឲ្យកូនចៅរបស់គាត់ប្រយុទ្ធតទល់ទៅវិញ រហូតទាល់តែធ្វើយ៉ាងណាឲ្យ ប៉ុល ពត សម្រេចចិត្តបញ្ឈប់ការវាយប្រយុទ្ធនេះ ។ ដូច្នេះវាទំនងជាពិតដែលគាត់គ្មានដឹងខ្លួនថា គាត់បានក្លាយទៅជាគោលដៅដែលត្រូវវាយប្រហារពីសំណាក់គណៈដឹកនាំមជ្ឈិមបក្សឡើយ នៅពេលដែល ប៉ុល ពត ត្រូវញ៉ាំងឲ្យជឿជាក់តាំងពីខែឧសភា ឆ្នាំ១៩៧៨មកថា គាត់(សោ ភឹម)ជាមេដឹកនាំ"បក្សពលករកម្ពុជា"លួចលាក់មួយដែលបង្កើតឡើងដោយវៀតណាម និង សេ.អ៊ី.អា. ដើម្បីដណ្តើមអំណាចនៅកម្ពុជា"[៣៩] ។

សោ ភឹម បានបោះទីតាំងរបស់គាត់នៅតាមមាត់ទន្លេមេគង្គមិនឆ្ងាយពីទីក្រុងភ្នំពេញប៉ុន្មានឡើយ ដោយសង្ឃឹមថា ប៉ុល ពត នឹងមានសុភវិនិច្ឆ័យក្នុងរឿងនេះជាមិនខាន ។ មុននឹងប្រថុយចូលទៅក្នុងរដ្ឋធានី គាត់បានបញ្ជូននិរសារម្នាក់ឲ្យរៀបចំការទាក់ទងគ្នាជាដំបូងមួយ ។ នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨ "គណៈកម្មាធិការទទួលបដិសណ្ឋារកិច្ច" មួយបានធ្វើដំណើរមកជួបគាត់ក្រោមទម្រង់ជាកប៉ាល់ពីរគ្រឿងដែលផ្ទុកណែនទៅដោយកម្លាំងទ័ព ។ ភឹម ចាប់នឹកសង្ស័យចំពោះអ្វីៗដែលនៅរង់ចាំគាត់ជាស្រេច ។ គាត់បានដកកាំភ្លើងខ្លីរបស់គាត់បាញ់ចំកណ្តាលដើមទ្រូងស្លាប់បាត់បង់ជីវិតភ្លាមមួយរំពេច[៤០] ។

ប្រតិបត្តិការថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨ គឺជាការផ្តើមនូវវគ្គចុងក្រោយនៃប្រវត្តិសាស្ត្រ ដែលប្រឡាក់ទៅដោយឈាមរបស់កម្ពុជាប្រជាធិបតេយ្យ ។ មិនយូរប៉ុន្មាន គេនឹងឈានទៅដល់ទីជម្រៅ នៃភាពគួរឲ្យរន្ធត់ឥតឧបមា ។ ការបម្រាញ់នៅឭដីផ្ទៃក្នុងបក្សរហូតមកដល់ពេលនេះ នៅតែព័ទ្ធជុំវិញដោយការលាក់ការណ៍សម្ងាត់ជានិច្ច ។ អ្នករងគ្រោះសុទ្ធតែត្រូវទាក់ទាញឲ្យចេញពីភូមិដ្ឋានរបស់ពួកគេ ក្រោមលេសជា"ការអញ្ជើញមួយ" - ទៅតាមលទ្ធភាពជ្រើសរើសៈ"ការពិគ្រោះយោបល់តាមទម្លាប់មួយ" "ការចូលរួមប្រជុំរៀនសូត្រ" "ការប្រជុំបន្ទាន់មួយ" -ឬ"ការទទួលភារកិច្ចថ្មី" ដែលគេចង់ប្រគល់ឲ្យ"អ្នកទាំងនោះ"បំពេញ ។ ការអញ្ជើញទាំងអស់នៅពេលនោះ សុទ្ធតែត្រូវប្រគល់ឲ្យផ្នែកសន្តិសុខជាអ្នកអនុវត្ត ។ ក្នុងរយៈពេលបួនឆ្នាំ"អ្នកដែលត្រូវអញ្ជើញ" ប្រមាណម្ភៃពាន់នាក់ ត្រូវបានធ្វើទារុណកម្មក្នុងគោលបំណងគាបយកចម្លើយសារភាពផ្សេងៗ បន្ទាប់មកត្រូវសម្លាប់ចោលទាំងអស់នៅមណ្ឌលឃុំឃាំងទួលស្លែង ។ ប៉ុន្តែអាថ៌កំបាំងដែលនាំមុខសកម្មភាពផ្សេងៗរបស់បក្ស

នៅតែក្រាស់ឃ្មឹកដដែល ហើយមធ្យោបាយសម្រាប់ទាក់ទងគ្នារវាងភូមិភាគជាច្រើនគឺគ្មានតែម្ដង ។ ដូច្នេះពុំមានការភ័យឆ្អែឆ្អាចុះឡើងឡើយ ។ ពិតហើយ វិធីផ្សេងៗរបស់បក្សគឺជំរុញឲ្យមានការភ័យខ្លាចនឹងការមន្ទិលសង្ស័យ ប៉ុន្តែក៏គ្មានអ្វីលើសពីហ្នឹងទៀតដែរ ។ ផ្ទុយទៅវិញ ដោយបញ្ជូនរថក្រោះជាច្រើនគ្រឿងទៅវាយដណ្ដើមយកទីស្នាក់ការបក្សភូមិភាគនៅស្ទួង គឺដូចជា ប៉ុល ពត សម្រេចចិត្តបង្ហាញមុខចុះដែរ ។ អ្នកដែលរួចរស់ជីវិតពីគ្រោះថ្នាក់នេះបានបាត់បង់ការយល់ច្រឡំចុងក្រោយរបស់ខ្លួន ។ នៅថ្ងៃបន្ទាប់ពីការវាយប្រហារគឺ ថ្ងៃទី២៥ ខែឧសភា បណ្ដាមេបញ្ជាការ និងយុទ្ធជនទាំងអស់នៃកងពលធំលេខ៤និងលេខ៥ (មេបញ្ជាការកងវរសេនាតូចនិងកងវរសេនាធំជាច្រើន) ត្រូវបានកោះអញ្ជើញឲ្យទៅចូលរួមសម័យប្រជុំមួយ ។ នៅពេលទៅដល់ក្លាម អ្នកទាំងអស់នោះបានត្រូវគេឲ្យដោះខោអាវចេញរួចចងស្លាបសេក និងចាប់ដាក់លើរថយន្តកាមីញ៉ុងជាច្រើនគ្រឿង ។ នៅពេលទៅដល់តំបន់ដីវាលគ្មានមនុស្សមួយ ពួកនេះបានត្រូវគេប្រានទម្លាក់មកដី ហើយយកកាំភ្លើងយន្តបាញ់រះសម្លាប់ចោលតែម្ដង ។ ម្នាក់ក្នុងចំណោមនោះបានរួចផុតពីគ្រោះថ្នាក់នៅមានជីវិតយ៉ាងចម្លែកគួរឲ្យឆ្ងល់ ។ គាត់បានរត់ភៀសខ្លួនទៅដល់វៀតណាម ជាទីដែលគាត់មានករណីយកិច្ចធ្វើជាកសិណសាក្សីថែមទៀត[41] ។

ហេង សំរិន ដែលជាមេបញ្ជាការកងពលធំលេខ៤បានដឹងថា ប្អូនប្រុសរបស់គាត់បានបាត់ខ្លួន ។ គាត់មិនបង្អែបង្អង់យូរឡើយ ៖ ជាមួយយុទ្ធជនប្រមាណមួយពាន់នាក់ដែលនៅស្មោះត្រង់ជាមួយគាត់បាននាំគ្នាគេចខ្លួនរត់ចូលព្រៃក្លាម ។ ទា សាប៊ុន កម្មាភិបាលតំបន់ម្នាក់ដែលជាប្រធានកងឈ្លបមូលដ្ឋានបានចាប់ផ្ដើមប្លន់ដណ្ដើមយកឃ្លាំងអាវុធរបស់ភូមិភាគ ដើម្បីរកកាំភ្លើងនិងគ្រាប់រ៉ុក្កែតប្រឆាំងរថក្រោះ ។ ពួកកងឈ្លបបានប្រយុទ្ធតទល់នឹងកងទ័ពរបស់ភូមិភាគកណ្ដាលក្នុងអំឡុងពេលប្រហែលបីសប្ដាហ៍ មុននឹងដកថយចូលទៅក្នុងព្រៃ ។ បណ្ដាមេដឹកនាំផ្សេងទៀតរបស់តំបន់ជាពិសេស ជា ស៊ីម, ម៉ាត់ លី, ម៉ែន ឆន, អ៊ុក ប៊ុនឈឿន និង ស៊ីម កា បានរត់ចូលព្រៃជាមួយកម្លាំង៣.០០០នាក់ដោយមានអាវុធកាន់គ្រប់ដៃ និងប្រជាជនស៊ីវិលមានចំនួនច្រើនជាងដប់ដង ។ រហូតមកដល់ដំណាច់ខែកក្កដា ក្នុងខេត្តចំនួនបីរបស់ភូមិភាគបូព៌ា (កំពង់ចាម ស្វាយរៀង និង ព្រៃវែង) កងទ័ពរបស់ភូមិភាគកណ្ដាលបានទទួលរងយាយីការរំខានជាប់ជាប្រចាំ ។ ដោយឆ្លៀតឱកាសពេលដែលខ្មែរក្រហមរត់ភៀសខ្លួនចេញ អ្នកភូមិមួយចំនួនយ៉ាងធំបាននាំគ្នាវាយកម្ទេចផ្ទះបាយរួម និងបែកចែកគោក្របីទ្រព្យសម្បត្តិដែលគេប្រមូលដាក់រួម ។

ចាប់តាំងពីខែមិថុនា ដោយឈមមុខនឹងអានុភាពនៃគ្រឿងសាស្ត្រាវុធដែលផលិតនៅប្រទេសចិន កងរថក្រោះ ព្រមទាំងកងទ័ពដ៏ស្នៀមរបស់ភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក ការប្រយុទ្ធតស៊ូដែលប្រព្រឹត្តទៅឯងៗរបស់កងឈ្លប ដែលបង្កើតឡើងទាំងប្រញាប់ប្រញាល់នោះ ពុំអាចយកប្រៀបលើពួកនិរតីបានឡើយ ។ នៅខែកក្កដា កម្រិតនៃការវាយប្រយុទ្ធគ្នាបានថយចុះបន្តិចម្ដងៗ ។ ការសងសឹកបានចាប់ផ្ដើមហើយ ។ ការកាប់សម្លាប់យ៉ាងសាហាវឥតអាណិតអាសូរ បានប្រព្រឹត្តទៅជាខ្សែសង្វាក់មួយខុសប្លែកពីមុន ដែលភូមិភាគ

បូព៌ាមិនធ្លាប់ទទួលរងកាលពីពេលកន្លងមក ។ តាមការយល់ឃើញរបស់ ប៉ុល ពត និងបណ្ដាសមាជិករបស់គាត់ថា ប្រជាជនខ្មែរនៅភូមិភាគបូព៌ាទាំងអស់បានបង្ហាញលក្ខណៈពិតប្រាកដរបស់ខ្លួនហើយ គឺជាពួក“ក្បាលយួនខ្លួនខ្មែរ” ដែលត្រូវតែកម្ទេចចោលឲ្យអស់[៤៧] ។ ជាក់ស្តែងគេបានកាប់សម្លាប់អ្នកបះបោរ ដែលចាប់បាននិងក្រុមគ្រួសាររបស់អ្នកទាំងនោះ ហើយក៏កម្ទេចភូមិទាំងមូលដែលធ្លាប់ផ្តល់ជម្រកដល់ពួកនោះផងដែរ ។ អ្នកដែលមានភ័ព្វវាសនាអាក្រក់ទាំងនោះត្រូវបានដឹកជញ្ជូនឆ្ពោះទៅរកសេចក្តីស្លាប់តាមរថយន្តកាមីញ៉ុងទាំងអស់ ។ ពីរឆ្នាំក្រោយមក ខ្ញុំ(អ្នកនិពន្ធ)ត្រូវបានគេជូនដំណើរទៅមើលគំនរឆ្អឹងខ្មោចមួយ ក្នុងចំណោមគំនរឆ្អឹងខ្មោចជាច្រើនកន្លែងនៅខេត្តកំពង់ចាម ដែលតាមការប៉ាន់ស្មានថាមានមនុស្សប្រហែល ៥០.០០០នាក់ត្រូវបានយកមកសម្លាប់នៅទីនោះ ។ នៅក្រោមម្លប់ដើមស្វាយជាច្រើនដើម គេប្រទះឃើញតែឆ្អឹងឆ្អែងលលាដ៍ក្បាលមនុស្សប្រុសស្រីនិងកូនក្មេងគ្រប់វ័យស្ថិតនៅប្រឡូកប្រឡល់គ្នាហាក់ដូចជាកម្រាលមួយ ដែលមើលទៅគួរឲ្យក្រៀមក្រំក្នុងចិត្តអួលណែនក្នុងដើមទ្រូង... ។

ក្នុងភូមិភាគទាំងមូល ការបង្ក្រាបដ៏គួរឲ្យតក់ស្លុតនេះ ទំនងជាធ្វើឲ្យមានមនុស្សស្លាប់ចំនួនជាង១០០.០០០នាក់ ។ មួយភាគបីនៃប្រជាជន-អ្នកដែលគេសង្ស័យហើយដែលត្រូវតែកម្ចាត់ចោល-ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងតំបន់គ្រុនចាញ់នានានៅភូមិភាគខាងលិចប្រទេសកម្ពុជា ។ ដោយមិនទាន់សម្លាប់ផងចំនួន ពាក់កណ្តាលនៃអ្នកដែលត្រូវជម្លៀសបានបាត់បង់ជីវិតទៅហើយដោយសារការអត់ឃ្លានឬជំងឺតម្កាត់ផ្សេងៗ ។

ដើម្បីរត់គេចពីការកម្ចាត់ដ៏សាហាវយង់ឃ្នងនេះ ពពួកមេដឹកនាំការបះបោរនិងប្រជាជនស៊ីវិលត្រូវតែស្វែងរកទីលាក់ខ្លួននៅក្នុងព្រៃទឹកដោកខ្លួនប្រាណក្រោមតំណក់ទឹកភ្លៀងរលឹមជាប់នៃរដូវមូសុង ។ ដោយខ្វះស្បៀងអាហារ ថ្នាំពេទ្យ ខោអាវ និងគ្រាប់រំសេវ បានធ្វើឲ្យការប្តេជ្ញាចិត្តរបស់ពួកគេថមថយចុះ ។ ដូច្នេះការជ្រើសរើសគឺសាមញ្ញ ៖ ចុះចូល-ដូចគ្នានឹងធ្វើអត្តឃាតដែរ- ឬសាកល្បងផ្សងសំណាងរបស់ខ្លួនជាមួយនឹងវៀតណាម ។ ការជ្រើសរើសផ្លូវទីពីរពុំមែនថាអត់គ្រោះថ្នាក់នោះទេ ។ ដោយពិតអ្នករត់ចោលជួរយ៉ាងច្រើនពីបណ្តាកងពលធំរបស់ភូមិភាគកណ្តាល ក៏មានចំណែកពាក់ព័ន្ធនៅក្នុងការវាយឆ្មក់ជាច្រើនលើកប្រឆាំងទៅលើភូមិនានារបស់វៀតណាមនៅតាមព្រំដែនដែរ ។ ការផ្លាស់ប្តូរជំហរភ្លាមៗ សម្រាប់ពួកកម្មាភិបាល ដែលទ្រទ្រង់ក្នុងចិត្តនូវការឃោសនាប្រឆាំងវៀតណាមតាំងពីច្រើនឆ្នាំមកហើយ ពុំមែនងាយស្រួលទេ ។ ខ្មែរឥស្សរៈមួយចំនួនតូចដែលនៅរស់រានមានជីវិត ហើយដែលកាលពីដើម ធ្លាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយវៀតណាម ត្រូវបានចាត់ឲ្យទៅធ្វើជាអ្នកនាំផ្លូវ ។ ចាប់តាំងពីដំណាច់ខែមិថុនា វិទ្យុក្រុងហាណូយបានចាប់ផ្តើមផ្សាយជាភាសាខ្មែរដោយអំពាវនាវឲ្យប្រជាជនងើបបះបោរឡើង ។ កម្មាភិបាលខ្មែរជាច្រើននាក់ដែលប្រជាជនធ្លាប់ស្គាល់ ហើយដែលមនុស្សទាំងអស់ជឿថាស្លាប់បាត់ទៅហើយនោះ បាននិយាយទៅកាន់ជនរួមជាតិរបស់ខ្លួនតាមរយៈវិទ្យុនេះដើម្បីសុំឲ្យជួយចូលរួមក្នុងបុព្វហេតុនេះផង ។ ហេង សំរិន បងប្អូនរបស់ ហេង សំរិន បានដើរតួនាទីជាភ្នាក់ងារ

ទំនាក់ទំនងក្នុងរឿងនេះ ។ ជាអតីតអ្នកដឹកនាំរបស់ភូមិភាគបូព៌ា(ដូចបងប្អូនរបស់គាត់ដែរ) គាត់បានភៀសខ្លួនទៅប្រទេសវៀតណាមកាលពីពេលមុននេះបន្តិច ។ ហេង សំរិន បាននិយាយរឿងសម្ងាត់ផ្ទាល់ខ្លួនរបស់គាត់ប្រាប់ខ្ញុំ(អ្នកនិពន្ធ) ថា "ទីបំផុតយើងទាំងអស់គ្នាដឹងថា យើងពុំអាចមានលទ្ធភាពផ្តួលរំលំ ប៉ុល ពត ដោយមធ្យោបាយផ្ទាល់របស់យើងបានទេ ។ យើងមានតែទៅសុំការជួយឧបត្ថម្ភពីវៀតណាមប៉ុណ្ណោះ" ។ កាលពីពេលកន្លងមកមិនយូរប៉ុន្មាន គាត់ក៏មានចំណែកក្នុងនាទីជាអគ្គបញ្ជាការក្រុមភ្នាក់ងារទំនាក់ទំនងរបស់ភូមិភាគបូព៌ា ដើម្បីរក្សាការទាក់ទងជាមួយអង្គភាពផ្សេងៗរបស់បក្ស និងជាមួយប្រទេសវៀតណាមថែមទៀត ។ ដូច្នេះ គាត់ស្គាល់ និងរាប់អានជាមួយវៀតណាមច្បាស់ណាស់ ។ នៅខែមករា ឆ្នាំ១៩៧៨ នៅពេលគាត់ភៀសខ្លួនចេញពីប្រទេស ហើយទៅដល់ព្រំដែនវៀតណាម គាត់បានត្រូវដឹកតាមឧទ្ធម្ភាគចក្រនាំទៅកាន់ក្រុងព្រៃនគរភ្លាម ។ បន្តិចក្រោយមកគាត់បានជួបនឹងខ្មែរក្រហមមានគំនិតប្រឆាំងដទៃទៀតជាច្រើននៅអតីតសាលាប៉ូលិសមួយឈ្មោះធូឌឹក ។

គណបក្សកុម្មុយនីស្តវៀតណាមបានប្រឹងប្រែងរៀបចំចលនាតស៊ូខ្មែរមួយឲ្យដំណើរការតាំងពីពេលនោះមកម្ល៉េះ ។ ការបង្ហាត់ក្បួនយោធាសម្រាប់យុទ្ធជនដំបូងៗបានចាប់ផ្តើម ។ ពីព្រោះគេលែងសង្ឃឹមលើការគាំទ្រជាយថាហេតុមួយពីសំណាក់ប្រជាជនខ្មែរនៅប្រទេសកម្ពុជាភាគខាងកើតទៀតហើយ ដោយសារអង្គការបក្សនៅទីនោះទើបនឹងត្រូវបង្ក្រាបស្ទើររំលាយសូន្យ ។ ក្តីសង្ឃឹមក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរមួយក្នុងផ្ទៃបក្ស -បន្ទាប់ពីរដ្ឋប្រហារមួយ- បានរលាយខ្សុល ហើយក៏លំបាកក្នុងការយកខ្មែរដែលហ៊ឹកហ៊ឺននៅប្រទេសវៀតណាមឲ្យជ្រៀតចូលទៅក្នុងប្រទេស ដើម្បីរៀបចំការងើបបះបោរមួយរួមជាមួយនឹងអ្នកមានគំនិតប្រឆាំងដែលស្ថិតនៅផ្ទាល់ទីនោះផងដែរ ។

វៀតណាមបានចាប់ផ្តើមការទាក់ទងជាមួយក្រុមអ្នកពួនក្នុងព្រៃដើម្បីតស៊ូជាច្រើនក្រុមទៀត ។ នៅដើមខែកញ្ញា ពួកគេបានធ្វើការវាយលុកថ្មីមួយដោយកងរថក្រោះចូលមកផ្ទៃក្នុងប្រទេសកម្ពុជា ។ គោលដៅរបស់ពួកគេលើកនេះគឺការទាក់ទងជាមួយ ហេង សំរិន និងអ្នកមានជំនឿលើគាត់ ដែលដកថយចូលទៅក្នុងព្រៃ ហើយអមការពារដំណើរអ្នកទាំងអស់នេះរហូតហួសព្រំដែនខ្មែរចូលទៅប្រទេសវៀតណាម ។ ដោយហេតុនេះហើយដែល ហេង សំរិន, ជា ស៊ីម និងខ្មែរក្រហមដែលនៅគង់វង្សជីវិតអាចទៅដល់ប្រទេសវៀតណាមដោយសុវត្ថិភាពនោះ ។ អនាគតរដ្ឋាភិបាលកម្ពុជាស្និទ្ធវៀតណាមអាចរៀបចំឡើងបានហើយ[៤៣] ។

ឡេ ឌឹកថូ បានចាកចេញពីក្រុងហាណូយតាមយន្តហោះឆ្ពោះមកទីក្រុងហូជីមិញ ។ អមដំណើរដោយអ្នកជំនាញការបក្សជាច្រើនរូបដែលមានឯកទេសខាងបញ្ហាកម្ពុជា គាត់បានជួបប្រាស្រ័យជាមួយខ្មែរក្រហមដែលមានគំនិតប្រឆាំងព្រមទាំងអ្នកនិរទេសខ្លួនតាំងពីយូរមកហើយខ្លះទៀត ជាពិសេស ប៉ែន សុវណ្ណ និង ជា សុទ្ធ នៅធូឌឹក អស់រយៈពេលពីរថ្ងៃ (២១-២២ ខែកញ្ញា ឆ្នាំ១៩៧៨) ។ តាមកិច្ចព្រមព្រៀងរួមមួយ គេបានសម្រេចថា សកម្មភាពយោធាផ្តាច់ព្រ័ត្រមួយនឹងត្រូវដំណើរការនៅខែធ្នូ ឆ្នាំ១៩៧៨ ក្នុងអំឡុងរដូវប្រាំងគឺមុន

ចាប់ផ្តើមរដូវប្រាំងកាត់ ។ គេបានធ្វើការយ៉ាងមមាញឹកដើម្បីបង្កើត«រណសិរ្សសាមគ្គីសង្គ្រោះជាតិ»មួយដែលក្នុងនាមចលនានេះ ការប្រយុទ្ធតស៊ូត្រូវតែចាប់ផ្តើមដំណើរការពីពេលនោះទៅ[៤៤] ។

## ប្រទេសចិនមមៃគិតពីការរួមគំនិតក្បត់មួយ

នៅរដូវក្តៅឆ្នាំ១៩៧៨ស្ថានការណ៍មានសភាពច្របូកច្របល់យ៉ាងខ្លាំង ទោះជាអ្នកសង្កេតបរទេសក៏មិនដឹងពីរឿងនេះដែរ ។ ការងើបបះបោរនិងការបង្ក្រាបយ៉ាងឃោរឃៅនៅភាគបូព៌ាប្រទេសកម្ពុជា, ជនជាតិចិនរាប់ពាន់នាក់ដែលប្រាថ្នាឆ្លងទៅប្រទេសខ្លួនបានរស់នៅពាក់ពពូនក្នុងទីក្រុងឡាងសុង ជាទីក្រុងនៅជាប់ព្រំដែនចិន-វៀតណាម ហើយទីបំផុត ការបង្កើតសមយុទ្ធយោធារបស់សូវៀតនៅតាមព្រំប្រទល់របស់ចិនៈ កម្លាំងនិងឧបករណ៍ចាំបាច់ទាំងអស់សម្រាប់ជម្លោះក្នុងទំហំធំមួយ ត្រូវបានរៀបចំបម្រុងស្រេចបាច់អស់ហើយ ។ សម្រាប់ក្រុងប៉េកាំងយល់ថា ការប្រព្រឹត្តមិនល្អមកលើពួកអាណិកជនចិនពុំមែនជាភាពចាំបាច់ដាច់ខាតមួយក្នុងការផ្លាស់ទ្រង់ទ្រាយលទ្ធិសង្គមនិយមនៅប្រទេសវៀតណាមទេ ហើយក៏ពុំមែនជាអំពើរើសអើងជាតិសាសន៍ដែរ ប៉ុន្តែប្រាកដណាស់ នេះជាធាតុផ្សំមួយនៃនយោបាយរបស់សូវៀត សំដៅឡោមព័ទ្ធប្រទេសចិនតែម្តង ។ ជម្លោះរវាងវៀតណាម-កម្ពុជាក៏មានចំណែកក្នុងការវាយលុកមួយរបស់ក្រុងមូស្គូ ប្រឆាំងនឹងឧត្តមភាពប្រចាំតំបន់របស់ចិនដែរ ។ ក្នុងរឿងនេះ ប្រទេសវៀតណាមដែលជា«កម្លាំងអនុត្តរភាពជួរទីពីរ» គ្រាន់តែជាឧបករណ៍មួយរបស់ក្រុងមូស្គូប៉ុណ្ណោះ ។ ផ្ទុយទៅវិញ តាមការយល់ឃើញរបស់ក្រុងហាណូយថា ការចូលចិត្តបង្ហូរឈាមនៅប្រទេសកម្ពុជា និងការវាយប្រហាររបស់ខ្មែរក្រហមមកលើដែនដីរបស់ខ្លួន គឺជាផ្នែកបំពេញបន្ថែមនៃផែនការដ៏ទូលំទូលាយមួយ ដែលរៀបចំយ៉ាងប៉ិនប្រសប់ដោយប្រទេសចិន ដើម្បីកម្ទេចប្រទេសវៀតណាមឲ្យសាបសូន្យ ។ ជាពិសេស ក្រុងមូស្គូព្រួយបារម្ភនឹងការលេចឡើងនូវការរួមជាសម្ព័ន្ធមួយរវាងប៉េកាំងនិងក្រុងវ៉ាស៊ីនតោន ។ ក្នុងកាលៈទេសៈនេះ ការពង្រឹងសហប្រតិបត្តិការរបស់ខ្លួនជាមួយក្រុងហាណូយដែលខ្លួនប៉ងប្រាថ្នាតាំងពីយូរមកហើយ នៅតែជារឿងសំខាន់ស្មើអាយុជីវិត ។ នៅសេតវិមាន ជាទីដែលទស្សនៈប្រឆាំងសូវៀតរបស់ ប្រ៊ីហ្សីនស្គីមានឥទ្ធិពលខ្លាំង គេគ្មានសម្គាល់ឃើញក្នុងជម្លោះរវាងខ្មែរ-វៀតណាមក្រៅតែពីថា នេះជាសង្គ្រាមប្រយោលមួលរវាង ក្រុងមូស្គូ និងក្រុងប៉េកាំងឡើយ ។ ដូច្នេះសហរដ្ឋអាមេរិកត្រូវតែផ្តល់នូវការទ្រទ្រង់ជាយុទ្ធសាស្ត្ររបស់ខ្លួនចំពោះប្រទេសចិន ។

សម្រាប់ក្រុងមូស្គូ នេះជាពេលវេលាដ៏ល្អ ប៉ុន្តែក៏មានគ្រោះថ្នាក់ផងដែរ ។ សម្តីនិយាយបញ្ឈឺចិត្តនិងទ្រគោះបោះបោកដែលឆ្លើយឆ្លងគ្នាជាសាធារណៈរវាងប្រទេសចិននិងប្រទេសវៀតណាម គឺជាលាភពិតប្រាកដមួយដែលគេគ្មានសង្ឃឹមទុក ។ រុស្ស៊ីមើលឃើញភ្លាមនូវឱកាសដែលខ្លួនរង់ចាំជាយូរមកហើយ ដើម្បីទាក់ទាញក្រុងហាណូយឲ្យមកចូលខាងខ្លួន ។ រឿងរ៉ាវជនជាតិចិននៅប្រទេសវៀតណាមបានបើកឱកាសឲ្យសូវៀតលើក

យកប្រធានបទឃោសនាពីមុនមួយមកនិយាយឡើងវិញ និងបរិហារតែពីសតែពាសពីអំពើសម្ងាត់ប្រកបដោយកលល្បិចនៃកម្លាំងទីប្រាំ ដែលមានសមានចិត្តនឹងចិននៅអាស៊ីអាគ្នេយ៍ ។ ដូច្នេះពួកគេបានដៅឲ្យឃើញនូវចំណុចផ្សេងៗ ដែលទុកជាមានតម្លៃក្រៃលែង ។ ដោយប្រែត្រឡប់ពាក្យពោលសរសើរ ក្រុងមូស្គូ បានបរិហារដោយការទាមទារដោយទទូចពី"អនុត្តរភាពនិយមនៃមហាអំណាច" និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់វៀតណាមដែលប្រទេសចិនជាអ្នកប្រព្រឹត្តល្មើស ។

ប៉ុន្តែ ដំណើរទស្សនកិច្ចរបស់ ប្រ៊ីហ្សីនស្គី នៅប្រទេសចិនក្នុងខែឧសភា ឆ្នាំ១៩៧៨ និងពាក្យសម្ដីដែលគាត់និយាយគឺមានលក្ខណៈដែលនាំឲ្យគេផ្អើលភ័យព្រួយ ដោយហេតុថា ការផ្ទេរបច្ចេកវិជ្ជាយោធានិងការផ្ដល់អាវុធរបស់អាមេរិកាំងទៅឲ្យប្រទេសចិនត្រូវបានលើកយកមកជជែកពិភាក្សាគ្នា ។ នៅថ្ងៃទី២៥ ខែមិថុនា អគ្គលេខាបក្សកុម្មុយនីស្តសូវៀត ឡេអូនីត ប្រេសណេវបានបង្ហាញរូបរាងនៅមុខគេដោយផ្ទាល់ខ្លួនឯង ។ ការរិះគន់របស់គាត់អំពីនយោបាយចិនចំពោះសហរដ្ឋអាមេរិក មានលក្ខណៈខ្លាំងក្លាមួយមិនធ្លាប់មានពីមុនមក ។ តាមគាត់ថា អ្នកនៅសហរដ្ឋអាមេរិកដែលលេង"សន្លឹកបៀចិន" បានបន្តធ្វើនយោបាយ"ប្រកបដោយគ្រោះថ្នាក់មួយនិងមើលមិនឃើញវែងឆ្ងាយនឹងសោកស្ដាយយ៉ាងឈឺចាប់ពីរឿងនេះនៅថ្ងៃណាមួយមិនខាន"[៤៥] ។

សហភាពសូវៀត បានពង្រឹងរឹតតែខ្លាំងនូវសហប្រតិបត្តិការរបស់ខ្លួនដោយសម្ងាត់ជាមួយក្រុងហាណូយ ។ ចំណែកឯការិយាល័យនយោបាយរបស់វៀតណាម ដែលរួមប្រជុំនៅពាក់កណ្ដាលខែកុម្ភៈបានប្រកាន់យកសេចក្ដីសម្រេចចិត្តសំខាន់ៗមួយចំនួនទាក់ទងចំពោះប្រទេសកម្ពុជា និងប្រទេសចិន ។ ដោយអនុលោមទៅតាមការដែលត្រូវធ្វើរបស់ខ្លួន សេចក្ដីសម្រេចគឺថា ការដាក់កងទ័ពវៀតណាមឲ្យប្រយុទ្ធនៅកម្ពុជា ប្រហែលជាបង្កឲ្យមានការវាយតបភ្លាមៗមួយរបស់ចិនមិនខាន ។ ដើម្បីប្រឈមនឹងការគំរាមនេះ ក្រុងហាណូយត្រូវការការពារផ្នែកខាងក្រោយរបស់ខ្លួនសិន ។ អ្នកទទួលខុសត្រូវវៀតណាមម្នាក់បាននិយាយប្រាប់ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅក្រុងហាណូយជាសម្ងាត់នាថ្ងៃមួយថា "យើងយកតម្រាប់តាមប្រទេសរបស់លោក" ។ នៅឆ្នាំ១៩៦៩ សហភាពសូវៀតបានបញ្ចុះបញ្ចូលឲ្យប្រទេសឥណ្ឌាចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាពនិងសហប្រតិបត្តិការមួយ ។ កិច្ចព្រមព្រៀងនេះមានខសំខាន់មួយដែលអះអាងពីគោលការណ៍នៃការគាំទ្រខាងផ្នែកយោធារបស់សូវៀត ។ ឥណ្ឌានៅរង់ចាំមើលសំណើអស់រយៈពេលពីរឆ្នាំ ។ ប៉ុន្តែ ទៀងមិនឈ្នះទាល់ ៈ ការប៉ះទង្គិច ដោយអាវុធដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗជាមួយប្រទេសប៉ាគីស្ថាននិងគ្រោះថ្នាក់នៃការសន្ទ្រាមួយរបស់ចិនជាគុណប្រយោជន៍ដល់ប្រទេសនេះ នៅទីបំផុតបាននាំឲ្យប្រទេសឥណ្ឌាចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងដាក់ខ្លួននៅក្រោមការគាំពាររបស់រុស្ស៊ីគឺឥណ្ឌាត្រូវតែរកអ្នកធានាជាមហាអំណាចផុតលេខមួយ ។ បីខែក្រោយមក កងទ័ពរបស់ឥណ្ឌាបានវាយឈ្នះប្រទេសប៉ាគីស្ថាន-ជាជ័យជម្នះដែលនាំទៅដល់ការបង្កើតប្រទេសបង់ក្លាដេសឯករាជ្យមួយ ។

នៅទីបំផុត ក្រុងហាណូយក៏សើរើពិនិត្យឡើងវិញនូវគម្រោងសន្ធិសញ្ញាមួយដែលស្នើដោយពួកសូវៀតតាំងពីឆ្នាំ១៩៧៥ គឺបន្ទាប់ពីជ័យជម្នះនៅភាគខាងត្បូងភ្លាម ។ នៅដើមខែមិថុនា ឧត្តមសេនីយ៍ យ៉ាប បានធ្វើដំណើរជាសម្ងាត់ទៅកាន់ក្រុងមូស្គូ ដើម្បីដាក់ជូនពួកមេដឹកនាំសូវៀតពិនិត្យនូវពង្រាងសន្ធិសញ្ញាដំបូងមួយ ។ គាត់បានឆ្លៀតឱកាសនេះ ដើម្បីបន្លាញពីលក្ខណៈនៃសេចក្តីត្រូវការផ្នែកយោធារបស់ប្រទេសគាត់ផងដែរ ។ នៅតាមផ្លូវឆ្ពោះទៅក្រុងមូស្គូ យន្តហោះរបស់ យ៉ាប តែងតែចុះចតនៅក្រុងញូវដែលី(ដើម្បីចាក់សាំង ឬដាក់អ្នកដំណើរ)ក្នុងលក្ខណៈអាថ៌កំបាំងបំផុត ។ គាត់បានជួបរដ្ឋមន្ត្រីការពារប្រទេសនិងរដ្ឋមន្ត្រីការបរទេសរបស់ឥណ្ឌានៅចំណតអាកាសយាន ហើយបានស្នើឲ្យជួយប្រទេសគាត់សម្រាប់ការបង្កើតរោងចក្រផលិតអាវុធមួយដើម្បីធ្វើអាវុធធុនស្រាល ។ ដោយដឹងពីលក្ខណៈដែលចៀសមិនរួចនៃការប្រយុទ្ធរបស់ខ្លួនជាមួយប្រទេសកម្ពុជានិងប្រទេសចិន ប្រទេសវៀតណាមមិនចង់ពឹងផ្អែកតែទៅលើពួកសូវៀតមួយទេសម្រាប់ការផ្គត់ផ្គង់អាវុធឲ្យខ្លួន ។ ពីរឆ្នាំក្រោយមក អ្នកទទួលខុសត្រូវថ្នាក់ខ្ពស់ម្នាក់របស់ឥណ្ឌាបាននិយាយរឿងអាថ៌កំបាំងប្រាប់ខ្ញុំថា ការស្នើសុំរបស់ យ៉ាប ត្រូវបានច្រានចោលយ៉ាងគួរសមដោយអះអាងថា ឥណ្ឌាពុំមានប្រភពធនធានគ្រប់គ្រាន់ ។ គាត់អាចសម្រេចពីរឿងនេះដោយរបៀបផ្សេងទៀតជាមួយលោកស្រីនាយករដ្ឋមន្ត្រី ឥន្ទ្រា គន្ធី ដែលជាឆ្មបបង្កើតរដ្ឋបង់ក្លាដេស ។ ប៉ុន្តែរដ្ឋាភិបាលដែលទទួលតំណែងបន្តពីគាត់គឺលោក ម៉ូរ៉ាហ្ស៊ីដីសៃ ជាប្រមុខរដ្ឋាភិបាលនិយមស្តាំលើកដំបូង មិនចង់ចូលពាក់ព័ន្ធនឹងសម្ព័ន្ធមិត្តមួយរបស់សូវៀតក្នុងការផ្សងព្រេងមួយដែលមើលឃើញជាក់ស្តែងប្រឆាំងនឹងប្រទេសចិនឡើយ ។

ក្រុងមូស្គូ អាចត្រឹមតែត្រេកអរនឹងដំណើរមានមកវិញនៃផលប្រយោជន៍ដែលសម្តែងឲ្យឃើញដោយក្រុងហាណូយ ដើម្បីធ្វើការសម្រេចចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយប៉ុណ្ណោះ ។ នៅដំណាច់ខែមិថុនា នីកូឡៃ ហ្វ៊ីរុយប៊ីន អនុរដ្ឋមន្ត្រីការបរទេសសូវៀតបានទទួលរ៉ាប់រងបំបាត់ឧបសគ្គសំខាន់ៗដែលមាននៅក្នុងគម្រោងសន្ធិសញ្ញា ។ វាជាពេលដែលរដ្ឋាភិបាលវៀតណាមត្រូវជ្រើសរើសឱកាសដែលឲ្យប្រយោជន៍បំផុតសម្រាប់ការចុះហត្ថលេខា ។ វាពុំមែនជាបញ្ហាបង្អើលក្រុងប៉េកាំង ដោយការផ្សព្វផ្សាយឲ្យដឹងពុតអាថ៌កំបាំងមួយដែលបញ្ចេញមុនពេលវេលាឡើយ ប៉ុន្តែផ្ទុយទៅវិញ គេត្រូវតែប្រាប់ឲ្យដឹងក្នុងកាលដ៏គួរ បើសិនជាគេចង់រារាំងក្រុងប៉េកាំងឲ្យបោះបង់ចោលដំណោះស្រាយមួយដោយកម្លាំងយោធា ។ ការិយាល័យនយោបាយ ក៏មិនចង់ធ្វើឲ្យសៅហ្មងដល់ទស្សនវិស័យនៃការធ្វើឲ្យមានប្រក្រតីភាពមួយជាមួយសហរដ្ឋអាមេរិកដោយបន្ទុំល្បឿនព្រឹត្តិ-ការណ៍ផ្សេងៗដែរ[៩៦] ។

រហូតមកដល់ពេលនេះ ការរៀបចំប្រុងប្រៀបផ្នែកភ័ស្តុភារនិងការដាក់ពង្រាយទ័ពសម្រាប់ការប្រយុទ្ធគ្នាដែលនឹងមកដល់នៅពេលខាងមុខបានប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស ។ នៅខែសីហា ស្ពានអាកាសមួយបានត្រូវរៀបចំឲ្យមានឡើងរវាងប្រទេសទាំងពីរតាមការស្នើសុំរបស់វៀតណាម នៅពេលដែលការផ្គត់សព្វាវុធតាមផ្លូវ

*សមុទ្របានឡើងដល់កម្រិតមួយដែលមិនធ្លាប់មានពីមុនមក ។ នៅដាណាង យន្តហោះអង់តូណូវ-១២ (Antonov-12) ធំៗជាច្រើនគ្រឿង បានរើសម្ភារៈចេញជាប់រហូតមានកាណុងបាញ់បានឆ្ងាយ មីស៊ីល រ៉ាដា និងគ្រាប់រំសេវសម្រាប់ពង្រឹងការការពាររបស់វៀតណាមឲ្យរឹតតែរឹងមាំឡើងថែមទៀត ។ យន្តហោះប្រដេញទម្លាក់គ្រាប់បែកមិច-២១ជាច្រើនគ្រឿង ដែលរើចេញពីនាវានៅកំពង់ផែដាណាង និងដាក់ផ្គុំនៅទីងកន្លែង បានហោះឆ្ពោះទៅភាគខាងជើង ហើយចុះចតនៅជិតព្រំដែនរបស់ចិន ។*

*នៅទីក្រុងមូស្គូក៏ដូចនៅប៉េកាំង សង្គ្រាមឃោសនាបានឡើងដល់កម្រិតខ្ពស់បំផុត-ម្ខាងប្រឆាំងចិន ម្ខាងទៀត ប្រឆាំងសូវៀត ។ បីសប្តាហ៍ក្រោយពេលដែលប្រទេសចិនចាប់ផ្តើមបរិហារពី"ការកាត់កាល់លែងរាប់រក, ការធ្វើទុក្ខបុកម្នេញ និងការបណ្តេញចេញ" ដែលពួកអាណិកជនចិននៅប្រទេសវៀតណាមជាអ្នករងគ្រោះដំណាក់កាលថ្មីមួយទៀតត្រូវបានឆ្លងកាត់ ៈ វៀតណាមគ្រាន់តែជារណបរបស់ពួកសូវៀតប៉ុណ្ណោះ គឺជា"ពួកគុយបានៅអាស៊ី" ។ និយាយម្យ៉ាងទៀត "សង្គម-ចក្រពត្តិនិយមសូវៀត" គឺជា"អ្នកញុះញង់និងជាអ្នកគាំទ្រសំខាន់បំផុត" ដល់វិធានការផ្សេងៗប្រឆាំងចិនដែលប្រកាន់យកដោយប្រទេសវៀតណាម[៤៧] ។*

*ការវាយលុកដោយពាក្យសម្តីបានបន្តកើនរឹតតែខ្លាំង ។ មិនយូរប៉ុន្មាន ក្រុងប៉េកាំងបានសម្រេចគាំទ្រប្រទេសកម្ពុជាប្រឆាំងនឹងប្រទេសវៀតណាមជាចំហ ។ ចាប់ពីពាក់កណ្តាលខែមិថុនា ដោយមានការយល់ស្របពីខ្មែរក្រហមផង ពួកចិនបានចាប់ផ្តើមបរិហារពីគោលបំណងវាតទីនិយមរបស់វៀតណាមប្រឆាំងនឹងបណ្តាប្រទេសជិតខាងខ្លួន ។ បើតាមបទវិចារណកថាមួយរបស់ទិនានុប្បវត្តិប្រជាជនចេញ ខែកក្កដា បានសរសេរថា ពួកគេ "វាយបុកឡឹត" បន្ទាប់ពីជ័យជម្នះរបស់គេលើសហរដ្ឋអាមេរិក និងការប្រមូលបានបរិមាណគ្រឿងសព្វាវុធអាមេរិកាំងយ៉ាងច្រើន ។ តទៅទៀត "ពួកគេច្បាស់ជាអន្តរាយដោយការលោភលន់ ចង់បានរបស់គេហួសហេតុមិនខាន" ។ ពួកគេគ្មានគិតឃើញអ្វីក្រៅតែពីបង្កើត"អធិរាជ"របស់គេទៅ លើភូមិភាគអាស៊ីភាគអាគ្នេយ៍ ប៉ុណ្ណោះ ហើយក្នុងទស្សនវិស័យនេះ ពួកគេបានប្រឹងប្រែង"បង្កើតសហព័ន្ធឥណ្ឌូចិនមួយ"នៅក្រោមការគ្រប់គ្រងរបស់គេថែមទៀត ។*

*សម្រាប់ពួកចិន ទៅហួសឆ្ងាយពីលក្ខណៈតំបន់និយមដាច់មុខរបស់ខ្លួន ជម្លោះរវាងខ្មែរ-វៀតណាម បាននាំទៅដល់អត្ថន័យទាក់ទងទៅនឹងពិភពលោកមួយយ៉ាងឆាប់រហ័ស ។ តាមការមើលឃើញរបស់ចិនថា នយោបាយវាតទីនិយមរបស់វៀតណាម និងបំណងប្រាថ្នារបស់ពួកសូវៀតសំដៅទៅរកភាពខ្ពង់ខ្ពស់ជាងគេបំផុតលើពិភពលោកគ្រាន់តែជាទ្រង់ទ្រាយពីរនៃធាតុភាពតែមួយប៉ុណ្ណោះ ។ បញ្ហាប្រទេសកម្ពុជា និងអាណិកជនចិននៅបរទេសលែងមាននៅក្នុងអធិករណ៍រវាងប្រទេសសង្គមនិយមទាំងពីរទៀតហើយ ដែលការចរចាផ្សេងៗល្មមគ្រប់គ្រាន់អាចលុបបំបាត់បាន ។ តាមពាក្យសម្តីរបស់អ្នកធ្វើអត្ថាធិប្បាយចិនម្នាក់ថា ៈ "វាមានការរួមគំនិតក្បត់មួយប្រឆាំងនឹងប្រទេសចិន ។ អធិករណ៍រវាងប្រទេសកម្ពុជានិងវៀតណាម និងកលឧបាយប្រឆាំងចិនរបស់អ្នកកាន់*

អំណាចវៀតណាម បានលេចឡើងឲ្យឃើញច្បាស់ក្នុងរឿងនេះ-ហើយជាពិសេស ការធ្វើទុក្ខបុកម្នេញនិងការបណ្តេញពួកអាណិកជនចិននិងការប្រើប្រាស់បញ្ហាបណ្តាជនជាតិចិននៅបរទេស ដើម្បីធ្វើឲ្យកើតមានការបែកបាក់គ្នារវាងប្រទេសចិននិងប្រជាជាតិនានានៅអាស៊ីអាគ្នេយ៍ ។ មហាអំណាចផុតលេខសូវៀតជាមួយនឹងគោលដៅអនុត្តរភាពផ្ទាល់របស់ខ្លួន បានបម្រើជាអ្នកធានា និងអ្នកគាំទ្រគួរឲ្យទុកចិត្តចំពោះនយោបាយអនុត្តរភាពប្រចាំតំបន់របស់វៀតណាម ដែលជា“កូនអុក”របស់ខ្លួន[៤៨] ។

## ទឹកពេញព្រៀបកែខ

រលកនៃពាក្យសម្តីទ្រគោះបោះបោកសំដៅទៅរកប្រទេសវៀតណាមនិងសហភាពសូវៀតនោះ បានឆ្លុះបញ្ចាំងឲ្យឃើញការផ្លាស់ប្តូរនយោបាយ ដែលកើតមានដោយដួននៅប្រទេសចិន នាដើមរដូវក្តៅឆ្នាំ១៩៧៨ ។ ខ្មោចប្រធាន ម៉ៅ ធ្លាប់ត្រូវញាំងឲ្យជឿជាក់ពីលក្ខណៈដែលចៀសមិនរួចនៃការប្រឈមមុខដាក់គ្នារវាងប្រទេសចិន និងចក្រពត្តិនិយមពិភពលោក ។ ក្នុងទស្សនៈវិស័យនេះ ម៉ៅ បានជំរុញឲ្យប្រជាជនគាត់ពង្រីងផ្នែកមនោគមវិជ្ជា រៀបចំស្តុកគ្រាប់ធញ្ញជាតិ និងជីកលេណដ្ឋានក្រោមដីជាច្រើន ។ ប៉ុន្តែចាប់តាំងពីគាត់ស្លាប់ -ក៏ដូចតាំងពីការដួលរលំនៃពួកវ៉ាឌីកាល់ដែរ- ក្រុមមេដឹកនាំថ្មីរបស់ចិនបានសម្រេចចិត្តដោយញញើតញញើមក្នុងការប្រកាន់ជំហរមួយដែលមានលក្ខណៈសុទិដ្ឋិនិយមបំផុត ។ អំណឹះតទៅ វាហាក់ដូចជាមានយោបល់ខុសគ្នាអំពីរណសិរ្សរួបរួមមួយដោយទទួលគុណប្រយោជន៍ពីការគាំទ្រជាអន្តរជាតិដ៏ទូលំទូលាយមួយប្រឆាំងនឹងសត្រូវសំខាន់បំផុតរបស់ខ្លួនគឺក្រុងមូស្គូ ។ បន្ទាប់ពីការប្រកាសឲ្យដឹងនៅខែមីនា ឆ្នាំ១៩៧៨ នូវផែនការដប់ឆ្នាំក្នុងការធ្វើទំនើបកម្មប្រកបដោយមហិច្ឆតាដ៏ធំធេងមួយ ប្រទេសចិនត្រូវការសន្តិភាពរយៈពេលវែងមួយដើម្បីរៀបចំខ្លួនសម្រាប់សង្គ្រាមពិភពលោក ។ ប្រទេសចិនសន្និដ្ឋានថា អាចពន្យារពេលបានដោយរារាំងផែនការផ្សេងៗរបស់សត្រូវក្នុងពេលមិនទាន់ផ្តើមតែម្តង ។ អ្នកទទួលខុសត្រូវចិនបានប្រកាសប្រាប់អ្នកឯកទេសសហរដ្ឋអាមេរិកទទួលបន្ទុកបញ្ហាការពារជាតិ ម៉ៃឃឹលភីលស្បូរី នៅខែឧសភា ឆ្នាំ១៩៧៨ថា “បស្ចិមប្រទេសត្រូវតែធ្វើឲ្យមានចលាចលដល់ជាយុទ្ធសាស្ត្ររបស់ពួកសូវៀត” ។ “សម្រាប់ប្រការនេះ គេត្រូវតែធ្វើការប្រកួតប្រជែងនឹងឥទ្ធិពលរបស់ពួកសូវៀតនៅក្នុងបណ្តាប្រទេសតតិយលោកខ្លះ ដែលមានលក្ខណៈយុទ្ធសាស្ត្រសំខាន់មួយដោយឯកោប្រទេសទាំងនោះខាងផ្នែកការទូត ហើយមិនត្រូវភ្លេចពីភាពកម្សោយនៃរបៀបរៀបចំខាងសង្គមកិច្ចនិងសេដ្ឋកិច្ចរបស់សហភាពសូវៀត និងភាពផុយស្រួយនៃស្ថិរភាពខាងជាតិសាសន៍របស់សូវៀតផងទេ”[៤៩] ។ ក្នុងចំណោមបណ្តាប្រទេសតតិយលោកដែលមាន“សារសំខាន់ជាយុទ្ធសាស្ត្រដ៏ធំ”ប្រាកដណាស់ ប្រទេសចិនក៏ចាត់ប្រទេសវៀតណាមចូលទៅក្នុងចំណោមនោះដែរ ។ វាគួរឲ្យចាប់អារម្មណ៍ណាស់ ដែលសម្គាល់ឃើញថា ការផ្លាស់ប្តូរទស្សនៈនយោបាយរបស់ចិនប្រហែលមានឡើងព្រមគ្នាជាមួយនឹងទស្សនកិច្ចរបស់ ប្រ៊ីហ្សីនស្គី នៅទីក្រុងប៉េកាំង ។ តាម

លោក មីស្ហែលអូកសេនបឺក អ្នកឯកទេសបញ្ហាប្រទេសចិននៅក្រុមប្រឹក្សាសន្តិសុខជាតិ ដែលរួមដំណើរជាមួយប្រឹហ្សឺនស្គី ទៅប្រទេសចិនបាននិយាយថា «ភាពរមួរាំងរម៉ោកដែលពួកចិនបរិហារជាសាធារណៈពីអំពើវៀចក្បត់របស់វៀតណាម បានបង្កជាទស្សនៈដែលមិនបានប្រុងទុកជាមុនក្នុងការសន្ទនាផ្សេងៗ»[៥០] ។

ព័ត៌មានមួយដែលលាតត្រដាងដោយពួកជប៉ុន ហើយដែលត្រូវអះអាងបញ្ជាក់ក្រោយមកទៀតបានបង្ហុលភស្តុតាងថា នៅឆ្នាំ១៩៧៨ ក្នុងឱកាសនៃសម័យប្រជុំមួយរបស់ការិយាល័យនយោបាយដែលពួកចិនបានសម្រេចចិត្ត«ឆ្លើយតបចំពោះអំពើបង្កហេតុផ្សេងៗរបស់វៀតណាម»និង«មិនរាថយនៅមុខការសាកល្បងប្រើកម្លាំងឡើយ បើសិនជាវៀតណាមផ្តើមធ្វើការផ្សងព្រេងមួយខាងយោធា»[៥១] ។ ផែនការជាបន្ទាន់មួយទំនងជាត្រូវរៀបចំជាស្រេចនៅជំនាន់នោះ ដែលរយៈពេលរបស់វាត្រូវបានបញ្ជាក់ពីរខែក្រោយមកទៀត ។ ពួកមេដឹកនាំចិន បានឃ្លាំមើលដោយយកចិត្តទុកដាក់ចំពោះស្ថានការណ៍យោធានៅកម្ពុជា ហើយក៏ព្រួយបារម្ភពីផលអាក្រក់នៃការដួលរលំដែលអាចកើតមានរបស់ខ្មែរក្រហមដែរ ។ អ្នកទទួលខុសត្រូវយោធាខ្លះបានថ្លែងពីចេតនារបស់ខ្លួនក្នុងការបញ្ជូនអ្នកស្ម័គ្រចិត្តរបស់ចិនមកកម្ពុជា ដោយអះអាងថា បើមិនធ្វើអន្តរាគមន៍ទេ ប្រទេសចិនមុខជាបាត់បង់ផ្នែកដ៏សំខាន់មួយក្នុងតំបន់នេះមិនខាន ។ ប៉ុន្តែគំនិតនេះបាន ត្រូវប្រានចោលជាបន្ទាន់សម្រាប់មូលហេតុផ្សេងៗខាងនយោបាយនិងសេដ្ឋកិច្ចក៏ដូចខាងយោធា ។ «កុំអាងលើអ្នកដទៃឲ្យធ្វើចុងភៅជំនួសខ្លួន» : សុភាសិតចិននេះប្រហែលជាបកស្រាយឲ្យដឹងពីឥរិយាបថរបស់ក្រុងប៉េកាំងហើយ ។ ថ្ងៃមួយ អ្នកទទួលខុសត្រូវចិនម្នាក់បានបំភ្លឺប្រាប់ខ្ញុំថា «បើគិតឲ្យហ្មត់ចត់ទៅ គោលការណ៍របស់ ម៉ៅ គឺថាការការពារឯករាជ្យភាព និងអធិបតេយ្យភាពរបស់ប្រទេសមួយ ជាសំខាន់ត្រូវតែជាស្នាដៃរបស់ប្រជាជនប្រទេសនោះផ្ទាល់» ។ យោបល់ផ្សេងៗទៀត ដែលមានគុណប្រយោជន៍ជាងគេ ក៏ត្រូវបានគេលើកយកមកពិនិត្យពិភាក្សាដែរ ។ ទីមួយគឺភាពស្ថិតនៅឆ្ងាយខាងផ្នែកភូមិសាស្ត្ររបស់ប្រទេសកម្ពុជា និងឧបសគ្គក្នុងការផ្គត់ផ្គង់ដឹកជញ្ជូនភស្តុភារនិងសម្ភារបរិក្ខារកងទ័ព ។ ទីពីរ គឺគ្រោះថ្នាក់ដែលបង្កឡើងដោយការចូលប្រយុទ្ធមួយដោយផ្ទាល់របស់ពួកសូវៀតរួមគ្នានឹងវៀតណាម ។ នៅទីបំផុត ប្រទេសចិនអាចក្រែងរអែងថា ការធ្វើអន្តរាគមន៍ខាងយោធាមួយនៅកម្ពុជាអាចធ្វើឲ្យបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ភ័យខ្លាចអាចធ្វើឲ្យបស្ចិមប្រទេសមិនសប្បាយចិត្ត ហើយអាចធ្វើឲ្យផែនការទំនើបភាវូបនីយកម្មរបស់ខ្លួនភាន់ប្រែអស់ ។ ក្រុងប៉េកាំងបានយល់ព្រមបង្កើនល្បឿនក្នុងការប្រគល់សម្ភារសឹក បង្កើនចំនួនទីប្រឹក្សាយោធារបស់ខ្លួន ប៉ុន្តែនៅទីបំផុតបានសម្រេចទុកឲ្យប្រទេសកម្ពុជារបស់ ប៉ុល ពត «ដោះកុនតែម្នាក់ឯងទៅវិញ» ។

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រទេសចិនមិនអាចបណ្តោយឲ្យប្រទេសវៀតណាមគំរាមកំហែងសម្ពន្ធមិត្តតែមួយរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ និងបណ្តេញអាណិកជនរបស់ខ្លួនដោយគ្មាននរណាដាក់ទោស ហើយក៏មិនធ្វើស្ងួតបូតនឹងសត្រូវចចេសមានះរបស់ខ្លួនដែរ ។ បណ្តាមេដឹកនាំកុម្មុយនីស្តចិន ដែលមាន តេង ស៊ាវពីង

ជាអ្នកដឹកមុខ បានសម្រេចចិត្តធ្វើនូវអ្វីដែលបណ្តាព្រះចៅអធិរាជចិនជំនាន់មុនអនុវត្តកន្លងមក នៅពេលដែលព្រះអង្គសម្គាល់ថាប្រទេសវៀតណាមបង្ហាញឲ្យឃើញ“ភាពក្រអឺតក្រទម” គឺព្រះអង្គតែងតែដាក់ទណ្ឌកម្មមួយទៅលើប្រទេសនេះជានិច្ច ។ បើទោះជាជំនួយដែលផ្តល់ឲ្យដោយប្រទេសចិនក្នុងសម័យសង្គ្រាម មានច្រើនសន្ធឹកសន្ធាប់យ៉ាងណាក៏ដោយ -ក្រុងប៉េកាំងបានវាយតម្លៃជំនួយនេះថា មានចំនួនទឹកប្រាក់ដល់ទៅ ម្ភៃកោដិដុល្លារ-ក៏វៀតណាមអួតថាបានប្រទេចប្រទេសចិនដែលខ្លួនលែងខ្លាចដែរ ។ នៅខែសីហា ឆ្នាំ១៩៧៨ អ្នកទទួលខុសត្រូវចិនម្នាក់ដែលសោកស្តាយចំពោះ“ការរមិលគុណ”របស់វៀតណាមបាននិយាយដើមយ៉ាងឈឺចាប់ថា “វៀតណាមសុទ្ធតែជាមនុស្សចិត្តខ្មៅ” ។

លក្ខណៈប្រឆាំងរបស់ចិនចំពោះវៀតណាម ប្រាកដជាពុំមានលក្ខណៈប្រកបដោយវិចារណញ្ញាណទាំងស្រុងទេ ។ មនោសញ្ចេតនាផ្សេងៗក៏មានចំណែករបស់វានៅក្នុងនោះដែរ ។ នៅក្នុងផ្ទៃក្រុមមេដឹកនាំរបស់ចិន អ្នកដែលបង្ហាញឲ្យឃើញនូវការស្អប់ខ្ពើមវៀតណាមខ្លាំងក្លាជាងគេគឺ តេង ស៊ាវពីង ដែលមានលក្ខណៈប្លែកបន្តិច នៅពេលដែលគេនឹកឃើញពីសេចក្តីសង្ឃឹមផ្សេងៗរបស់ក្រុងហាណូយដែលចាប់ផ្តើមមាននៅពេលដែល តេង ត្រឡប់មកកាន់អំណាចវិញ ។ ពាក្យសន្ទាផ្ទាល់ខ្លួនរបស់ តេង ក្នុងការយកចិត្តទុកដាក់គាំទ្រប្រទេសវៀតណាមក្នុងអំឡុងពេលមានសង្គ្រាម ប្រហែលលេចឡើងឲ្យឃើញពីទំហំធំធេងនៃការខកចិត្តរបស់គាត់នៅមុខការអន្តរាយនៃសម្ព័ន្ធភាពមួយ ។ អ្នកការទូតថៃម្នាក់ដែលជួបទាក់ទងនឹង តេង ក្នុងឱកាសជាច្រើននៅនឹកឃើញថា “ទឹកមុខរបស់គាត់តែងផ្លាស់ប្តូរមិនដែលខាន កាលបើនិយាយដល់បញ្ហាវៀតណាមម្តងៗ ។ សម្អប់របស់គាត់មានលក្ខណៈចេញមកពីខាងក្នុងតែម្តង” ។ នៅពេលគេរំឭកពីពួកវៀតណាមនៅចំពោះមុខគាត់ៗតែងជះសម្តីទាំងកំហឹងដោយចាត់ទុកពួកនោះសុទ្ធតែជា“ឆ្កែ”ពេញៗមាត់ ។ ក្នុងពេលធ្វើសន្និសីទកាសែតមួយនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ គាត់បានថ្លែងថា វៀតណាមជា“ពួកយូកូង នៅទិសខាងកើត”ថែមទៀត ។ ការទើសទាល់ចិត្តរបស់នាយករដ្ឋមន្ត្រីថៃ គ្រៀងសាក់ ឆូម៉ាណន្ត ដែលនៅអង្គុយក្បែរ តេង មានលក្ខណៈអាចឲ្យគេមើលឃើញច្បាស់នឹងភ្នែក ។ ដោយហេតុនេះ នៅខែសីហា ឆ្នាំ១៩៧៨ មនោសញ្ចេតនារបស់ប្រទេសចិនគឺមានលក្ខណៈច្បាស់លាស់ណាស់ដែលវាមិនដូចគោលបំណងរបស់ខ្លួនទេ ។

បីឆ្នាំក្រោយមក ខ្ញុំ(អ្នកនិពន្ធ) បានដឹងតាមរយៈអ្នកទទួលខុសត្រូវចិនម្នាក់ថា នៅដើមខែកក្កដា ឆ្នាំ១៩៧៨ ក្នុងឱកាសសម័យប្រជុំប្រចាំសប្តាហ៍មួយក្នុងចំណោមសម័យប្រជុំសប្តាហ៍របស់ខ្លួន ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តចិនបានសម្រេច “ផ្តល់មេរៀនមួយឲ្យវៀតណាម” ដើម្បីដាក់ទោសចំពោះ“អាកប្បកិរិយាពោរពេញដោយភាពរមិលគុណនិងភាពក្រអឺតក្រអោង”របស់គេ ។ ដោយពិភាក្សាគ្នាក្នុងសភាពសម្ងាត់បំផុតនោះ ការអនុម័តសេចក្តីសម្រេចចិត្តនេះពុំមានការយល់ព្រមជាឯកច្ឆ័ន្ទទេ ប៉ុន្តែនៅទីបំផុត តេង បានអះអាងប្រកបដោយជោគជ័យថាប្រតិបត្តិការយោធាដែលមានកំណត់មួយប្រឆាំងនឹងវៀតណាម នឹងធ្វើឲ្យក្រុងមូស្គូយល់ថា

ប្រទេសចិននឹងមិនបណ្ដោយឲ្យគេសម្លុតគំរាមបានឡើយ ។ ចិនបានវិនិច្ឆ័យក្នុងបញ្ហានេះទុកជាមុនថា បើសិនជាពួកសូវៀតពុំទៅជួយវៀតណាមទេ ពួកនេះនឹងទម្លាក់ការសង្ស័យទៅលើសម្ព័ន្ធមិត្តរបស់ខ្លួន ហើយនឹងអាចធ្វើឲ្យជំហររបស់សូវៀតក្នុងពិភពតតិយលោកចុះទន់ខ្សោយមិនខាន ។ តាមប្រភពព័ត៌មានដដែលបានឲ្យដឹងថា ដើម្បីឲ្យមានប្រសិទ្ធភាព តេង ស៊ាវពីង បានសង្កត់បញ្ជាក់យ៉ាងយូរអំពីប្រតិបត្តិការយោធារបស់ចិនដែលមិនត្រូវបង្ហាញថាជាជម្លោះមួយដើម្បីផលប្រយោជន៍ជាតិពិតប្រាកដទេ ប៉ុន្តែត្រូវធ្វើឲ្យឃើញថា នេះជាផ្នែកនៃយុទ្ធសាស្ត្រមួយប្រឆាំងអនុត្តរភាពពិភពលោកវិញ ។ ការិយាល័យនយោបាយបានសម្រេចចិត្តពន្យារការប្រតិបត្តិ ហើយបានបង្កើនកិច្ចប្រឹងប្រែងទូទៅឡើងថែមទៀត ក្នុងគោលបំណងសម្របសម្រួលឲ្យមានការខិតចូលជិតគ្នាមួយជាមួយសហរដ្ឋអាមេរិក ប្រទេសអាស៊ីមិនមែនកុម្មុយនីស្តនិងបស្ចិមប្រទេសរួចរាល់សិន[៥២] ។

នៅចុងខែកក្កដា ឆ្នាំ១៩៧៨ រដ្ឋមន្ត្រីការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ សុន សេន បានធ្វើដំណើរទៅទីក្រុងប៉េកាំង ដើម្បីទទួចសុំពីប្រទេសចិននូវកិច្ចសន្យាផ្នែកយោធាមួយប្រឆាំងនឹងវៀតណាម ។ គេធ្វើឲ្យគាត់ធុញទ្រាន់ដោយនិយាយច្រំដែលៗប្រាប់គាត់ពីគុណសម្បត្តិនៃ “ភាពឯករាជ្យម្ចាស់ការ” គ្រប់តែឱកាស ។ តេង ស៊ាវពីង -កាលពីមុនត្រូវខ្មែរក្រហមមើលងាយទុកដូចជាអ្នកប្រឆាំងបដិវត្តន៍- បានសម្ដែងឲ្យឃើញអាកប្បកិរិយាតឹងរ៉ឹងយ៉ាងចម្លែក ដោយស៊ីកសម្ដីទៅ សុន សេន វិញទាំងគំរោះគំរើយថា ជំនួយរបស់ចិននឹងក្លាយទៅជាឥតប្រយោជន៍ បើសិនជាពួកមេដឹកនាំកម្ពុជាមិនបោះបង់ចោលនយោបាយ“ចង្អៀតចង្អល់និយម”របស់ខ្លួន និងមិនព្រមបង្កបង្កើតរណសិរ្សរួបរួមដ៏ទូលំទូលាយមួយប្រឆាំងនឹងសត្រូវវៀតណាម ។ ពួកចិនបានបង្គាប់បញ្ជាដាច់ខាតឲ្យខ្មែរក្រហមយាង សម្ដេច សីហនុ ទៅធ្វើជាមេដឹកនាំរដ្ឋាភិបាលវិញ ហើយខិតខំកែលម្អរូបភាពប្រទេសរបស់ខ្លួននៅក្រៅប្រទេសឲ្យកាន់តែប្រសើរជាងមុនផង ។ ពួកចិនក៏ទូន្មានឲ្យ សុន សេន ត្រៀមខ្លួនសម្រាប់សង្គ្រាមទ័ពព្រៃយូរអង្វែងមួយដោយជីកលេណដ្ឋាន រៀបចំកន្លែងលាក់ទុកអាវុធនិងកេណ្ឌប្រមូលមហាជនផងដែរ ។ ដូច្នេះ ក្នុងករណីដែលមានការឈ្លានពានជាថ្មីរបស់វៀតណាម របៀបប្រយុទ្ធនេះហាក់ដូចជាឲ្យផលប្រយោជន៍ជាងការប្រយុទ្ធតស៊ូមួយចំពីមុខ ។ ទីបំផុត ប្រទេសចិនបានសន្យាថា នឹងធ្វើការគាបសង្កត់ទៅលើប្រទេសវៀតណាមដោយគ្មានការបញ្ជាក់ច្បាស់លាស់ផ្សេងពីនេះឡើយ[៥៣] ។

ខ្លួនខបត្តម្ភខ្លួនដោយខ្លួនឯងប្រើធ្វើមិនបាន គេគោងតែឈានឲ្យដល់ចំណុចមួយដើម្បីវិភាគពីព្រឹត្តិការណ៍ផ្សេងៗដោយប្រាកដប្រជា ។ ស្ពានអាកាសមួយដែលមិនធ្លាប់មានពីមុនមកត្រូវបានបង្កើតឡើងដើម្បីដឹកជញ្ជូនគ្រឿងសាស្ត្រាវុធនិងគ្រាប់រំសេវឆ្ពោះមកកម្ពុជា ។ ដោយបូកបន្ថែមជាមួយការហោះហើរចំនួនពីរជើងប្រចាំសប្ដាហ៍តាមប្រទេសឡាវ ក្រុមយន្តហោះមួយដែលមានយន្តហោះប៊ូអ៊ីង៧០៧ចំនួនប្រាំគ្រឿងបានរ៉ាប់រងភ្ជាប់ការទាក់ទងរវាងខេត្តកំពង់សោមនិងក្រុងភ្នំពេញតាមសមុទ្រចិនខាងត្បូងដោយទៀងទាត់ ។ ក្រៅពីគ្រឿងអាវុធប្រទេសចិនបានបញ្ជូនទីប្រឹក្សាយោធារាប់រយនាក់ថែមទៀត ។ តាមការសន្និដ្ឋានរបស់ពួកភ្នាក់ងារសម្ងាត់

អាមេរិកថា នៅចុងឆ្នាំ១៩៧៨ ចំនួនទីប្រឹក្សាចិនមានដល់ទៅ៥.០០០នាក់ឯណោះ ។

ចំណែកការរៀបចំប្រុងប្រៀបផ្សេងៗសម្រាប់ការវាយលុកផ្ទាល់របស់ខ្លួនវិញ ប្រទេសចិនបានសម្រេចចាប់ផ្តើមវាយលុកលើសមរភូមិការទូតមុន ។ សន្ធិសញ្ញាសន្តិភាព និងមិត្តភាពដែលខ្លួនចរចាតាំងពីយូរយារមកហើយជាមួយប្រទេសជប៉ុន នៅទីបំផុតត្រូវបានចុះហត្ថលេខានៅខែសីហា ឆ្នាំ១៩៧៨ ដោយមានការគាំទ្រដាសម្ងាត់ពីសំណាក់ ប្រឹហ្សឹនស្គី ផង ។ ខសំខាន់មួយដែលត្រូវជជែកគ្នានៃសន្ធិសញ្ញានេះចែងថា ភាគីទាំងពីរសូមសម្តែងនូវការប្រឆាំងជំទាស់របស់ខ្លួនគ្រប់រូបភាពអនុត្តរភាពនិយម ។ នេះជាការវាយលុកផ្នែកការទូតលើកដំបូងដែលសម្រេចបានដោយក្រុងប៉េកាំង ហើយដែលនាំឲ្យអន្តរាយដល់ផលប្រយោជន៍ក្រុងមូស្គូទៀតផង ។ ដំណាក់កាលថ្មីមួយនៃដំណើរធ្វើឲ្យមានប្រក្រតីភាពជាមួយសហរដ្ឋអាមេរិកបានចាប់ផ្តើមជាមួយការតែងតាំងលោក ឡេអូណារដ៍ វូដខូក និង ចាយ ហ្សេមិន ឲ្យធ្វើជាមេដឹកនាំគណៈបេសកកម្មទំនាក់ទំនងគ្នាយ៉ាងចេញមុខ ។ ស្របពេលជាមួយគ្នានោះ ប្រព័ន្ធផ្សព្វផ្សាយរបស់ចិនបានចាប់ដំណើរការ“ប្រលោមស្នេហ៍” ទៅកាន់ប្រទេសនានានៅអាស៊ីអាគ្នេយ៍ដែរ -ដែលមិនទុកចិត្តយូរមកហើយចំពោះបដិវត្តន៍របស់ប្រទេសចិន- ដើម្បីបម្រើកិច្ចរៀបចំដំណើរទស្សនកិច្ចផ្សះផ្សាគ្នាដ៏ធំដែល តេង ស៊ាវពីង នឹងត្រូវធ្វើនៅពេលឆាប់ៗ ដោយចាប់ផ្តើមក្នុងបណ្តាប្រទេសមិនមែនកុម្មុយនីស្តក្នុងតំបន់ឥណ្ឌូចិនទៅ ។

រដូវក្តៅឆ្នាំ១៩៧៨ បានឈានដល់ទីបញ្ចប់ ។ ពួកចិននិងវៀតណាមបានរៀបចំផែនការចម្បាំងរបស់ខ្លួនដោយសម្ងាត់ ។ ប៉ុន្តែមុននឹងចាប់ផ្តើមច្បាំងគ្នាគេ ត្រូវការពេលវេលាដើម្បីប្រមូលការគាំទ្រមួយចំនួនសិន ។ ក្នុងការរត់ប្រណាំងល្បឿនដែលផ្តើមធ្វើដោយក្រុងហាណូយនិងក្រុងប៉េកាំង មិត្តភាពនិងការគាំទ្ររបស់សហរដ្ឋអាមេរិកដែលថ្មីៗនេះ ព្រមព្រៀងគ្នានៅក្រោមាត់ទ្វារអាស៊ី គឺជាការប្រថុយខាតដែលនាំទៅរកលទ្ធផលចុងក្រោយមួយ ។

# ជំពូកទី៩
# Yankee ត្រឡប់មកវិញមក!

*លោក រីឆាដ ហូលប្រ៊ុក បានចាប់ផ្ដើមពីគោលការណ៍ថា គឺនៅចំកណ្ដាលផហ្វូងមនុស្សដែលការសម្ងាត់មួយត្រូវបានការពារជិតល្អបំផុត ។ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨ អនុរដ្ឋមន្ត្រីការបរទេសបានរួមប្រជុំក្រុមអ្នកបរិបាជ៏តូចរបស់គាត់នៅក្នុងកន្លែងមួយនៃស្ថានបេសកកម្មអាមេរិកាំង ប្រចាំអង្គការសហប្រជាជាតិសម្រាប់ជាលើកទីពីរក្នុងរយៈពេលមួយសប្ដាហ៍ ។ គេកំពុងស្ថិតនៅកណ្ដាលសម័យប្រជុំពេញអង្គនៃមហាសន្និបាតអង្គការសហប្រជាជាតិ ហើយដូចសព្វដង ការច្របូកច្របល់គឺមានកម្រិតខ្ពស់បំផុត ។ នៅតាមរុក្ខវិថីលេខ១ ការធ្វើចរាចរតាមផ្លូវបានប្រព្រឹត្តទៅសន្សឹមៗដោយសារចលនារថយន្តក្នុងស្រុក និងយានយន្តទេសចរណ៍ ។ ក្បួនរថយន្តផ្លូវការជាច្រើនគ្រឿង បានត្រាយផ្លូវមួយឆ្ពោះទៅទីស្នាក់ការអង្គការសហប្រជាជាតិទាំងពិបាក ។ បណ្ដាប្រធានាធិបតី នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសនៃពិភពលោកទាំងមូលសរុបទៅ១៤០ប្រទេសបានទៅកាន់ទីណាត់ជួបនៅសង្កាត់មេនហាតាន់ ដោយប្រុងប្រៀបខ្លួនបន្ទាប់ៗគ្នាដើម្បីធ្វើជាវាគ្មិន នៅក្នុងមហាសន្និបាត និងចូលរួមក្នុងពិធីជប់លៀង, ពិធីបដិសណ្ឋារកិច្ច និងសម័យប្រជុំគ្រប់ប្រភេទ ។ ហូលប្រ៊ុក បានរកឃើញមន្ត្រីជាតួយ៉ាង ដើម្បីសន្ទនាដោយស្ងាត់កំបាំងជាមួយវៀតណាមស្ដីពីការបង្កើតទំនាក់ទំនងផ្នែកការទូតរវាងប្រទេសទាំងពីរ ។ តាំងពីការបណ្ដេញអ្នកតំណាងរបស់វៀតណាមចេញពីអង្គការសហប្រជាជាតិនៅខែកុម្ភៈឆ្នាំដដែល ព្រោះតែរឿងរ៉ាវចារកម្មមិនច្បាស់លាស់មួយ គំនិតនៃការខិតចូលជិតគ្នាមួយជាមួយប្រទេសវៀតណាមពុំមានអ្វីដែលធ្វើឲ្យសាធារណមតិអាមេរិកាំងចាប់អារម្មណ៍ឡើយ ។ ដូច្នេះ ការប្រកាសដែលធ្វើមុនពេលវេលាស្ដីពីការជួបគ្នាទាំងនេះមុខជានឹងធ្វើឲ្យប្រធានាធិបតី ខាតធ័រ ជួបការលំបាកមិនខាន ។*

*អ្វីៗបានមានឡើង ដូចដែលគ្រោងទុកជាមុន ។ សារព័ត៌មានពុំដឹងដំណឹងស្ដីពីការជួបរបស់ ហូលប្រ៊ុក កាលពីប្រាំថ្ងៃមុនជាមួយអនុរដ្ឋមន្ត្រីការបរទេស ង្វៀន កូថាច់ ឡើយ ។ ដូច្នេះនៅរសៀលថ្ងៃទី២៧ ខែកញ្ញា នេះ ហូលប្រ៊ុក, ហ្វ្រង់វីសន័រ មីស្ទែល អូសេនបឺក ជានាយទាហាននៅក្នុងក្រុមប្រឹក្សាសន្តិសុខជាតិ និងសហការីពីររូបនៅក្រសួងការបរទេសបាននាំគ្នាឡើងជិះរថយន្តតាក់ស៊ីពីរគ្រឿងដោយគ្មានអ្នកណាម្នាក់ចាប់ភ្ញាក់ពួកគេឡើយ ។ ពួកគេបានធ្វើដំណើរទៅកាន់កន្លែងណាត់ជួបគ្នាជាមួយវៀតណាមដោយសម្ងាត់ជាលើកទីពីរ ។ បន្ទប់ទាំងឡាយនៃអគារគណៈបេសកកម្មដ៏តូចរបស់វៀតណាមដែលមើលមិនឃើញ ព្រោះកប់បាត់នៅក្នុងមហាគ្រឹះមួយកសាងអំពីឥដ្ឋនិងកញ្ចក់កម្ពស់៣៥ជាន់នៅតាមផ្លូវ Waterside Plaza ពុំមានក្របខ័ណ្ឌអ្វីដែលសមនឹងទទួលព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយបែបនេះទាល់តែសោះ ។ ហូលប្រ៊ុក ប្រហែលជាជឿជាក់ថា ការប្រជុំជាមួយ ថាច់ ជាថ្មីនេះនឹងបើកឱកាសឲ្យមានការចេញដំណើរថ្មីមួយ ។ បន្ទាប់ពីកិច្ចព្រមព្រៀង ខេម ដេវីដ (Camp David) ដែលចុះ*

ហត្ថលេខាកាលពីមួយសប្ដាហ៍មុនរវាងលោក ម៉េណាហេម បេហ្គិន (Menaham Begin) នាយករដ្ឋមន្ត្រីអ៊ីស្រាអែល និងលោក អានួអារ៍ អាល់សាដាត (Anouar al-Sadate) ប្រធានាធិបតីអេហ្ស៊ីប ការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងហាណូយនឹងជាជោគជ័យមួយថែមទៀតក្នុង«ថង់យាម»របស់លោក ខាធ័រ ។

ក៏ប៉ុន្តែ លោក ហូលប្រ៊ុក បានត្រូវធ្វើឲ្យស្រឡាំងកាំងនៅក្នុងឱកាសនៃការជួបគ្នាលើកដំបូងនាថ្ងៃទី២២ ខែកញ្ញា ចំពោះការប្រកាន់គំនិតខ្ជាប់ខ្ជួនរបស់វៀតណាម ដែលចចេសសំអាងលើការបង់ប្រាក់សម្រាប់ជួសជុលការខូចខាតដោយសារសង្គ្រាមជាថ្នូរនឹងការធ្វើឲ្យមានប្រក្រតីភាពដដែល ។ ផាច់ បាននាំមកជាមួយគាត់នូវឯកសារមួយសំណុំធំដែលមានផ្ទុកសេចក្ដីថ្លែងការណ៍ទាំងអស់ ទាំងផ្លូវការឬមិនផ្លូវការ ដែលនៅក្នុងនោះ ពួកគេបានថ្លែងពីបំណងរបស់ខ្លួនជាគុណប្រយោជន៍ដល់ការធ្វើឲ្យមានប្រក្រតីភាពមួយ ដោយគ្មានលក្ខខណ្ឌតាំងពីខែកក្កដា ឆ្នាំ១៩៧៨មកម្ល៉េះ ។ នេះជាការខាតបង់កម្លាំងឥតប្រយោជន៍ ។ ជាថ្មីម្ដងទៀត ផាច់ ដែលដាក់បន្ទុយមិនទាន់ស្រួលបួលផង បានចាប់ផ្ដើមច្រៀងចម្រៀងដដែលៗស្ដីពីកាតព្វកិច្ចខាងសីលធម៌របស់អាមេរិកាំងចំពោះប្រទេសវៀតណាម ដោយលើកឡើងវិញនូវទឡ្ហីករណ៍ឥតបានការដូចពីមុន ដែលនាំទៅដល់បរាជ័យកាលពីឆ្នាំ ១៩៧៧ ។ គាត់បានរាយការណ៍ប្រាប់នាយចៅហ្វាយគាត់គឺ រដ្ឋមន្ត្រីការបរទេស លោក ស៊ីរុស វ៉ាន់ស៍ ថា ៖ «អស្ចារ្យណាស់លោក! ពួកគេ(វៀតណាម) នៅតែទាមទារលុយពីយើងជានិច្ច» ។

ប៉ុន្តែ នៅពេលប្រជុំលើកទីពីរ ហូលប្រ៊ុក ដែលស្គាល់កលល្បិចនៃការចរចារបស់វៀតណាមមានការប្រាកដក្នុងចិត្តថា ផាច់ មុខជាបោះបង់ការទាមទាររបស់ខ្លួនមិនខាន ។ ដូច្នេះ តើត្រូវពន្យល់របៀបបែបណា ដែលអ្នកចរចាវៀតណាមមិនព្រមបញ្ឈប់ការចរចាជាស្ថាពរនៅពេល ហូលប្រ៊ុក ប្រកាសនៅថ្ងៃទី២២ ខែកញ្ញានោះថា តាមគាត់យល់ វាគ្មានប្រយោជន៍នឹងបន្តនិយាយគ្នាក្នុងន័យដដែលៗអ៊ីចឹងទេ ។ លោកអនុរដ្ឋមន្ត្រីទុកចិត្តខ្លាំងមែនទែនចំពោះអំពើរបស់គាត់ ដែលគាត់បានសុំឲ្យអូសេនបឺកចូលរួមអង្គុយក្បែរគាត់នៅក្នុងគ្រប់ការប្រជុំចរចា ។ បឹកញូ ប្រ៊ីហ្សីនស្គី បានវិនិច្ឆ័យដោយមិនពេញពីការបង្កើតទំនាក់ទំនងឡើងវិញជាមួយប្រទេសវៀតណាម ដែលគាត់ចាត់ទុកជា«រណប»ធម្មតាមួយរបស់ពួកសូវៀត ហើយអាក្រក់ជាងនេះទៅទៀត គឺក្រុងហាណូយជាសត្រូវចេញមុខរបស់ប្រទេសចិនដែលគាត់យល់ថា ជាអនាគតសម្ព័ន្ធមិត្តជាយុទ្ធសាស្ត្ររបស់អាមេរិកផង ។ ហូលប្រ៊ុក បាននិយាយស្មានតែខ្លួនឯងថា ឲ្យតែវៀតណាមបោះបង់ការទាមទាររបស់ពួកគេនៅចំពោះមុខ អូសេនបឺក ដែលជាអ្នកឯកទេសខាងបញ្ហាអាស៊ីអមលោក ប្រ៊ីហ្សីនស្គី វានឹងពិបាកធ្វើឲ្យក្រុមប្រឹក្សាសន្តិសុខជាតិរារាំងគាត់មិនឲ្យធ្វើអ្វីកើតណាស់ ។

លំនាំពាក្យពេចន៍ដែលនិយាយចេញនៅក្នុងពេលប្រជុំ ពុំមែនជាទម្លាប់ដែលគេធ្លាប់ប្រើឡើយ ។ ផាច់ ដែលស្លៀកពាក់សម្លៀកបំពាក់ពណ៌ខៀវ បានទទួលស្វាគមន៍ពួកអាមេរិកាំង នៅពេលអ្នកទាំងនេះមកដល់ស្ថានគណៈបេសកកម្ម ។ បន្ទាប់ពីការចាប់រលាក់ដៃគ្នាមួយសន្ទុះមក អ្នកទាំងអស់បានចូលអង្គុយជុំវិញតុកម្រាល

*បែតងត្រង់ជ្រុងបន្ទប់មួយ ដែលទើបរៀបចំដាក់តុទូតាំងសម្រាប់ពិធីទទួលភ្ញៀវដូចតាមទម្លាប់ ។ អ្នកទាំងអស់បានត្រូវធ្វើឲ្យភ្ញាក់ផ្អើលនឹងដំណើររហ័សរហួនដូចមនុស្សមានវ័យនៅក្មេងរបស់ ផាច់ ដែលយ៉ាងហោចទើបតែមានអាយុហាសិបបីឆ្នាំប៉ុណ្ណោះ ។ ប៉ុន្តែ មនុស្សដែលញញឹមរីករាយជាប់នេះ ធ្លាប់មានបទពិសោធន៍ផ្នែកសង្គ្រាមនិងផ្នែកការទូតជាច្រើនឆ្នាំមកហើយ ។ ដោយឆ្លៀតឱកាសក្នុងពេលសម្រាកខ្លីមួយជុំវិញពែងតែ ផាច់ បាននិយាយប្រាប់រឿងអាថ៌កំបាំងរបស់គាត់ខ្លះៗ ។ ជាវរសេនីយ៍ទោក្នុងកងទ័ពវៀតមិញ គាត់បានចូលរួមនៅក្នុងការឡោមព័ទ្ធបន្ទាយរបស់បារាំងជាប្រវត្តិសាស្ត្រនៅឌៀនបៀនភូ ។ ពីរឆ្នាំក្រោយមក ផាច់ បានចាប់ផ្ដើមអាជីពជាអ្នកការទូតរបស់គាត់ក្នុងឋានៈជាអគ្គកុងស៊ុលប្រចាំក្រុងញូវដែលលី ។ គឺនៅជំនាន់នោះ ហើយដែលគាត់រៀនពីបែបបទល្អៗរបស់អឺរ៉ុបតាមមធ្យោបាយផ្ទាល់របស់គាត់ ។ ដោយចេះនិយាយភាសាបារាំងស្ទាត់ទៅហើយ គាត់ក៏រៀនចេះភាសាអង់គ្លេសយ៉ាងឆាប់រហ័ស ។ ការចេះភាសាអង់គ្លេសនិងបទពិសោធន៍ផ្នែកការទូតរបស់គាត់នឹងឃើញថា មានប្រយោជន៍មែនទែនក្នុងទសវត្សរ៍៧០ ពេលដែលគាត់ធ្វើការចរចាដ៏វែងអន្លាយជាមួយលោក ហង់រី គីស៊ីងហ្គ័រ នៅទីក្រុងប៉ារីស ដែលនៅពេលនោះគាត់ធ្វើជាសហការីរបស់ ឡេ ឌឹកថូ ។ ឥឡូវនេះ គាត់គឺជានាយចៅហ្វាយម្ដង ។ គាត់បានចាប់ផ្ដើមធ្វើសេចក្ដីថ្លែងការណ៍របស់គាត់ជាភាសាវៀតណាម ហើយវាច្បាស់ណាស់ថា គាត់គ្មានផ្លាស់ប្ដូរជំហរទាល់តែសោះ ។ គាត់និយាយម្ដងហើយម្ដងទៀតថា សហរដ្ឋអាមេរិកនឹងមិនទៅក្រុងហាណូយដោយដៃទទេទេ ។ ដូច្នេះលោក ហូលប្រ៊ុក ត្រូវតែរៀបរាប់ពីហេតុផលផ្សេងៗឡើងវិញ ដែលហាមមិនឲ្យសហរដ្ឋអាមេរិកធ្វើកិច្ចសន្យាណាមួយអំពីរឿងនេះឡើយ ។ រយៈពេលមួយម៉ោងកន្លះក្នុងការនិយាយឆ្លើយឆ្លងគ្នាដែលឥតបានការ គាត់បានប្រមូលឯកសារផ្សេងៗ ហើយរៀបទុកដាក់នៅក្នុងកាបូបទុកឯកសាររបស់គាត់ ។ ការសន្ទនាបានបញ្ចប់យ៉ាងគំហុក ។ «លោក ផាច់ យើងបានធ្វើអ្វីៗតាមតែអាចធ្វើបាន ។ បើទោះ ជាអ្វីៗទាំងអស់ដែលលោកនិយាយប្រាប់យើងត្រូវបញ្ចប់ការជជែកពិភាក្សាក៏ដោយ» ។ លោក ផាច់ បានតបមកវិញថា ចុះបើយើងនាំគ្នាផឹកតែសិន? ។*

*ពួកគេនាំគ្នាងើបចេញពីតុទាំងអស់គ្នា ។ នៅចុងម្ខាងទៀតនៃបន្ទប់ ទឹកតែ កាហ្វេ នំក្រៀមៗ និងនំក្រៀបធ្វើពីអង្ករដែលសុទ្ធតែនៅថ្មី ត្រូវបានរៀបចំបម្រុងជាស្រេច ដើម្បីបម្រើគោលបំណងភ្ញៀវ ។ នៅម្ខាងទៀតនៃ* East River *(ជាព្រែកស្ថិតនៅចន្លោះសង្កាត់នៅក្រុងញូវយ៉កគឺសង្កាត់មេនហាតង់ និង ប្រ៊ុកឃ្លីន) ផ្ទៃមេឃពណ៌ខៀវបានប្រែពណ៌សន្សឹមៗ ទៅជាស្វាយព្រលែតវិញ ។ អូសេនបឺក បានបញ្ចេញអាការៈធ្វើមុខក្រញូវមិនព្រមនិយាយស្ដីពេញមួយរសៀល ។ រឿងទាំងអស់នេះ បានបណ្ដាលឲ្យគាត់ចេះតែសង្ស័យមិនអស់មិនហើយ ។ គាត់មិនជឿថា វៀតណាមមានបំណងចរចាអំពីការធ្វើឲ្យមានប្រក្រតីភាពក្នុងរយៈពេលខ្លីឡើយ ដែលតាមគាត់យល់ រឿងនេះនឹងធ្វើឲ្យលោក ហូលប្រ៊ុក ស្ថិតនៅក្នុងស្ថានភាពជាអ្នកដើមចោទវិញម្ដង ។ ផាច់ ដឹងថាអ្នកណាជាអូសេនបឺក ហើយៗគាត់ប្រាកដជាដឹងខ្លួនពីការខានបានចំណេញផលប្រយោជន៍របស់គាត់ទៀតផង ។ ផាច់*

ចេះចាប់ផ្ដើមជាមួយ អូសេនបឺក នូវការសន្ទនាមិនសូវសំខាន់មួយជាមួយគាត់ក្នុងឋានៈជាមន្ត្រីជាន់ខ្ពស់ ។ អូសេនបឺក ធ្វើហាក់ដូចជាមិនឮ ។ គាត់បន្តសម្លឹងមើលទៅដំបូលអគារទាំងឡាយនៃសង្កាត់ឧស្សាហកម្ម ឃ្វីន ដែលលេចរូបរាងឡើងក្នុងផ្ទាំងកញ្ចក់នៃបន្ទប់ ។ អូសេនបឺក បានដំណាលក្រោយមកថា “គ្មានអ្វីត្រូវនិយាយទាំងអស់ ខ្ញុំសម្រេចមិននិយាយមួយម៉ាត់ទៅកាន់អ្នកណាម្នាក់ឡើយ ។ នេះជាលើកដំបូងហើយ ដែលខ្ញុំជួបជនជាតិវៀតណាមម្នាក់” ។ ដោយទម្លាយភាពស្ងៀមស្ងាត់ដែលពិបាកទ្រាំមួយ ហូលប្រ៊ូក បានប្រញាប់ធ្វើឲ្យការសន្ទនាមានសន្ទុះឡើងវិញ ។

បន្ទាប់ពីបរិភោគ(ឲ្យមានកម្លាំងឡើងវិញ)រួច គាត់បានស្នើនៅពេលហៀបនឹងសុំលាថា “យើងនិយាយគ្នាបន្តិចថែមទៀត” ។ ពេលត្រឡប់មកកាន់តុវិញ ថាច់ បានប្រែទៅជាមនុស្សម្នាក់ទៀតភ្លាម ។ “យល់ព្រម ខ្ញុំនឹងនិយាយប្រាប់លោកពីអ្វីដែលលោកចូលចិត្ត ។ យើងយល់ព្រម ដើម្បីលើកទុកទៅពេលក្រោយនូវការពិនិត្យមើលបញ្ហាផ្សេងៗទៀត ។ ជាដំបូង យើងធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់យើងមានប្រក្រតីភាពសិន ដោយគ្មានលក្ខខណ្ឌជាមុនឡើយ” ។ ហូលប្រ៊ូក បានរំពឹកថា ៈ “អស្ចារ្យណាស់! តែមួយរំពេចសោះ អ្វីៗបានប្រែក្លាយទៅជាងាយស្រួលទាំងអស់ ។ នោះគឺកិច្ចព្រមព្រៀងមួយដែលពុំអាចសម្រេចបានក្នុងរយៈពេលពីរឆ្នាំ បែរជាត្រូវចុះហត្ថលេខាក្នុងរយៈពេលតែដប់នាទីទៅវិញ” ។ ថាច់ បានស្នើឲ្យ ហូលប្រ៊ូក ចុះហត្ថលេខាលើពិធីសារព្រមព្រៀងមួយ ។ “យើងមានម៉ាស៊ីនអង្គុលីលេខមួយនៅខាងក្រោមសហការីទាំងឡាយរបស់យើងអាចគិតគូរគាត់តែងខ្លឹមសារពិធីសារនេះហើយ ក្នុងពេលដែលយើងអង្គុយផឹកតែអស់មួយពែង” ។ ហូលប្រ៊ូក ដែលសប្បាយសើងហោះបានឆ្លើយតបថា “នេះជាការរីកចម្រើនមួយប្រកបដោយន័យស្ថាបនាបំផុត និងជាការបោះជំហានទៅមុខមួយដ៏សំខាន់” ។ ប៉ុន្តែ គាត់បានច្រានចោលមិនយល់ព្រមតាមអត្ថបទដែលតែងភ្លាមៗគ្មានព្រាងទុកជាមុន ទោះជាអត្ថបទអ្វីក៏ដោយ ដូចដែល ថាច់ ស្នើគាត់ឡើយ ។ “ខ្ញុំនឹងបញ្ជូនសំណើរបស់លោកទៅប្រធានាធិបតីខ្ញុំ ។ យើងនឹងពិនិត្យមើលសំណើនេះដោយការយកចិត្តទុកដាក់បំផុត ហើយយើងនឹងប្រាប់លោកឲ្យដឹងជាមុនកាលបើយើងយល់ថា វាអាចបោះជំហានទៅមុខហើយ” ។ ទោះជាយ៉ាងណាក៏ដោយ ថាច់ ចង់បានថា កិច្ចព្រមព្រៀងអាចត្រូវចុះហត្ថលេខានៅក្នុងសប្ដាហ៍ទីមួយនៃខែតុលា ក្នុងរយៈពេលនៃការស្នាក់អាស្រ័យនៅក្រុងញូវយ៉ករបស់រដ្ឋមន្ត្រីការបរទេស ង្វៀន ឌុយទ្រិញ ។ ប៉ុន្តែតាម ហូលប្រ៊ូក យល់ថា វាមិនប្រាកដថា ចម្លើយមួយរបស់អាមេរិកាំងអាចសម្រេចទាន់ក្នុងរយៈពេលនេះទេ ។

ថាច់ និយាយថា “ខ្ញុំនឹងស្ថិតនៅទីក្រុងញូវយ៉ករហូតដល់ថ្ងៃទី២០ ខែតុលា” ។ ដោយមិនបានដឹងមុន បរិយាកាសនៃការប្រជុំដែលឲ្យប្រផ្នូលអាក្រក់រហូតមកដល់ពេលនេះបានផ្លាស់ប្ដូរទាំងស្រុង ។ គេបានរំពឹកពីការបើកស្ថានទូតអាមេរិកាំងមួយនៅទីក្រុងហាណូយក្នុងអគារផ្សេងៗ ដែលកាន់កាប់ដោយអតីតស្ថានកុងស៊ុលអាមេរិកាំងកាលពីសម័យអាណានិគមបារាំង ។ អតីតស្ថានទូតប្រទេសវៀតណាមខាងត្បូងនៅទីក្រុងវ៉ាស៊ីនតោន

*ដែលនៅទំនេរត្រូវបាន ហូលប្រ៊ូក ប្រគល់ឲ្យ ផាច់ ទាំងទឹកមុខស្រស់ញញឹម ។ ផាច់ បានពិភាក្សាស្រេចទៅហើយពីចំនួនបុគ្គលិកនៃស្ថានទូតនីមួយៗ បទបញ្ញត្តិផ្សេងៗដែលត្រូវប្រកាន់យកសម្រាប់ការទាក់ទងគ្នា និងហិបអ្នកការទូត ។ និយាយដោយខ្លី គេធ្វើអ្វីៗដោយហ្មត់ចត់បំផុត ។*

*នៅពេលដែល ហូលប្រ៊ូក ដែលមានទឹកមុខស្រស់ស្រាយសុំលា ផាច់ ដែលបញ្ចេញស្នាមញញឹមស្រស់ស្រាយដែរនោះ ស្រមោលរាត្រីកាលបានធ្លាក់គ្របមកលើក្រុងញូវយ៉កទាំងមូល ។ ប៉ុន្តែ រាត្រីនេះហាក់ដូចជាសេតារុណ (ពន្លឺសបំព្រាងដែលលេចឡើងនៅជើងមេឃមុនព្រះអាទិត្យរះ) ថ្មីមួយសម្រាប់ទំនាក់ទំនងរវាងអាមេរិក-វៀតណាម ។*

*លែងមានអ្វីមួយរារាំងការធ្វើឲ្យមានប្រក្រតីភាពទៀតហើយ ។ នយោបាយការបរទេសរបស់អាមេរិកាំងនៅអាស៊ី បានមកដល់ផ្លូវបែកជាបួនហើយ ។ រហូតមកដល់ពេលនេះ ស៊ីរុស វ៉ាន់ និង ប៊ីកញូ ប្រ៊ីហ្ស៊ីនស្គី អាចបន្តយុទ្ធសាស្ត្រផ្ទុយគ្នាចំពោះប្រទេសចិននិងអាស៊ីភាគអាគ្នេយ៍ ដោយឥតឲ្យភាពមិនស្របគ្នាផ្ទុះឡើងជាសាធារណៈឡើយ ។ ឥឡូវនេះ គេត្រូវតែសម្រេចដោយម៉ឺងម៉ាត់ ។ ម្ខាងគឺប្រទេសវៀតណាមនិងប្រទេសចិន ហើយម្ខាងទៀតគឺ ប្រទេសកម្ពុជានិងប្រទេសវៀតណាម ដែលសុទ្ធតែស្ថិតនៅលើផ្លូវនៃការប្រឈមមុខដាក់គ្នាដោយអាវុធមួយដាក់ជាមិនខាន ដែលក្នុងនោះសហភាពសូវៀតទំនងជានឹងចូលពាក់ព័ន្ធដែរ ។ ក្នុងនាមនៃការប្រឆាំងតទល់នឹងពួកសូវៀត គេចាំបាច់ត្រូវកាន់ជើងប្រទេសចិន និងសម្ព័ន្ធមិត្តខ្មែរក្រហមរបស់ចិនដែលគេមិនចូលចិត្តសេពគប់ដូចដែល ប្រ៊ីហ្ស៊ីនស្គី ទូន្មានឲ្យអនុវត្តតាមដែរឬ? ឬមួយនេះជាទស្សនៈរបស់ វ៉ាន់ស៍ និង ហូលប្រ៊ូក ដាក់ខ្លួនឲ្យឆ្ងាយពី ជម្លោះមួយដែលពន្លិចឬសគល់ទាំងអស់របស់វាទៅក្នុងប្រវត្តិសាស្ត្រជាតិនៃបណ្តាប្រទេសអ្នកនាំអាទិ៍? ឯណាទៅជាផលប្រយោជន៍របស់សហរដ្ឋអាមេរិកនៅអាស៊ី? ក្នុងការបង្កើតរួមគ្នានូវទំនាក់ទំនងផ្នែកការទូតជាមួយប្រទេសវៀតណាមនិងប្រទេសចិន? ឬក្នុងការបដិសេធមិនបើកធ្វើការចរចាជាមួយវៀតណាម ដើម្បីទទួលបានផលប្រយោជន៍ពីក្រុងប៉េកាំង? ។ មហាអំណាចកុម្មុយនីស្តសំខាន់បំផុតទាំងពីរនៅអាស៊ីបានចាប់ផ្តើមធ្វើការទាក់ទងនឹងសហរដ្ឋអាមេរិកហើយ ។ មហាអំណាចទាំងពីរ ប្រាថ្នាចង់ដើរតួនាទីសំខាន់មួយនៅអាស៊ីផងដែរ ។ នេះជាពេលដែល ហ្ស៊ីមី ខាធ័រ ត្រូវសម្រេចពីតួនាទីនេះថា វានឹងមានលក្ខណៈបែបណា ជាកម្លាំងធ្វើឲ្យមានតុល្យភាព ឬជាសម្ព័ន្ធមិត្តរបស់ភាគីមួយក្នុងចំណោមភាគីជម្លោះទាំងអស់ ។*

## វៀតណាមសុំពឹងសហរដ្ឋអាមេរិក

*ទំនាក់ទំនងអាមេរិក-វៀតណាមបានស្គាល់នូវភាពសោះកក្រោះខ្លាំងមែនទែនមួយ ក្នុងរយៈពេលដប់ខែចុងក្រោយ ដែលមានមុនការជួបគ្នាជាថ្មីនៅឆ្នាំ១៩៧៨ ។ ក្នុងឱកាសនៃសម័យប្រជុំចរចាលើកចុងក្រោយរវាង ហូលប្រ៊ូក និង ផាន់ ហៀន កាលពីដើមខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានបោះបង់មិនយកជំនួយផ្នែកសេដ្ឋកិច្ច*

របស់អាមេរិកាំងធ្វើជាអាទិភាពក្នុងការធ្វើឲ្យមានប្រក្រតីភាពទេ ។ ប៉ុន្តែ ហៀន បាននិយាយទទូច ដើម្បីឲ្យសហរដ្ឋអាមេរិកធ្វើការសន្យាជួយប្រទេសវៀតណាមដោយមាត់ទទេ បន្ទាប់ពីការបង្កើតទំនាក់ទំនងផ្នែកការទូតឡើងវិញ ។ ការប្រជុំបានទទួលលទ្ធផលនៅទីកបង្ហើយដោយបរាជ័យមួយ ។

ពីរខែក្រោយមក ព្រឹត្តិការណ៍អាក្រក់បានកើតមានជាថ្មីជាមួយការចោទប្រកាន់បុគ្គលិកម្នាក់នៃទីភ្នាក់ងារស៊ើបការណ៍របស់អាមេរិកាំងឈ្មោះ រ៉ូណាល់ ហ៊ុមហ្វ្រី និងអ្នកសមគំនិតសញ្ជាតិអាមេរិកាំង-វៀតណាមម្នាក់របស់គាត់ឈ្មោះ ដេវីដ ទ្រឿង ថា បានធ្វើចារកិច្ចជាគុណប្រយោជន៍ដល់ប្រទេសវៀតណាម ។ ឈ្មោះឯកអគ្គរដ្ឋទូតវៀតណាមនៅអង្គការសហប្រជាជាតិ ឌិញ បាធី ធ្លាប់ត្រូវបញ្ចេញឲ្យដឹងថាជាមេគំនិតម្នាក់ក្នុងចំណោមមេគំនិតទាំងឡាយនៃប្រតិបត្តិការនេះ ។ ការពារដោយអភ័យឯកសិទ្ធិការទូត គាត់បានត្រូវបណ្តេញចេញ ។

តាមការពិត រឿងរ៉ាវចារកិច្ចនេះបើប្រៀបធៀបទៅមិនមែនជារឿងសំខាន់ទេ ។ ពិតហើយក្នុងចំណោមឯកសារដែលគេលួចដក មានឯកសារខ្លះត្រូវចាត់ថ្នាក់“សម្ងាត់”ក៏ពិតមែន ប៉ុន្តែទោះជាយ៉ាងណាក៏វាមិនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់សហរដ្ឋអាមេរិកដែរ ។ ឯកសារខ្លះទៀត ពុំមានបង្ហាញឲ្យឃើញលក្ខណៈអាថ៌កំបាំងបន្តិចសោះឡើយ ។ ឧទាហរណ៍ ឯកសារមួយក្នុងចំណោមឯកសារទាំងនោះបានរាយការណ៍ពីការប្រកាន់ជំហរដ៏ដាក់លាក់របស់អ្នកការទូតឥណ្ឌា និងយូហ្គោស្លាវី ដែលបំពេញមុខងារនៅទីក្រុងហាណូយ ។ ឯកសារមួយទៀតមាននិយាយពីសេចក្តីសន្និដ្ឋានរបស់គណៈបេសកកម្ម វូដខូក ទៅលើការផ្សះផ្សាជាមួយប្រទេសវៀតណាម ហើយឯកសារមួយទៀត ថ្វីត្បិតតែចាត់ថ្នាក់ថា “សម្ងាត់” គឺមានរៀបរាប់ល្អិតល្អន់តែពីជើងហោះហើរនៃយន្តហោះអ៊ែរហ្វ្រង់នៅពេលចេញដំណើរ និងពេលមកដល់ទីក្រុង ហូជីមិញក្នុងរយៈពេលមួយខែប៉ុណ្ណោះ ។ និយាយដោយខ្លី គ្មាន“ស្នៀត”ណាមួយរបស់ក្រុមស៊ើបការណ៍សម្ងាត់របស់វៀតណាម ដែលអាចគំរាមកំហែងដល់សន្តិសុខរបស់សហរដ្ឋអាមេរិកាំងឡើយ ។ ប៉ុន្តែ គឺត្រឹមត្រូវណាស់ ដោយសារតែឯកសារផ្សេងៗដែលលួចយកមិនមានសារសំខាន់ទើប អេហ្វ.ប៊ី.អាយ (F.B.I.) មិនប្តឹងរឿងនេះទៅតុលាការ ។ ពិសេសលើកលែងតែការប្តឹងប្តល់ទៅតុលាការពីរឿងចារកិច្ច នោះនឹងមិនលាតត្រដាងការសម្ងាត់របស់រដ្ឋឲ្យគេដឹងនៅកន្លែងសាធារណៈ ។ ម្យ៉ាងទៀត ការប្រញាប់ប្រញាល់រៀបចំឲ្យប្រកាសថា ឯកអគ្គរដ្ឋទូតវៀតណាមជាជនដែលគេមិនគាប់ចិត្តមុខជាធ្វើឲ្យជនម្នាក់ក្នុងចំណោមជនច្រើននាក់ភ្ញាក់ផ្អើល ជាពិសេសនៅក្រសួងការបរទេស ។ តើការប្រញាប់ប្រញាល់នេះ បង្ហាញឲ្យឃើញហាក់ដូចជាបំណងធ្វើការសងសឹកមួយដូចដែលវៀតណាមអះអាងមែនឬទេ? រ៉ូបឺត អូកលី ជាអនុប្រធានរបស់ ហូលប្រ៊ូក សម្រាប់កិច្ចការអាស៊ីអាគ្នេយ៍បានអះអាងថា ក្រុងហាណូយមិនដែលយល់ពីប្រតិកម្មរបស់អាមេរិកាំងសោះឡើយ ។ គាត់បានបន្ថែមថា “ប៉ុន្តែ ច្បាប់និងតថភាពនៃនយោបាយខាងក្នុងប្រទេសរបស់យើងមានអត្ថិភាពនៅឡើយ ហើយយើងពុំមានការជ្រើសរើសទេ”[១] ។

រឿងរ៉ាវនេះនឹងមិនស័ក្តិសមសរសេរកត់ត្រាទុកនៅទំព័រខាងក្រោម ក្នុងប្រវត្តិសាស្ត្រនៃការធ្វើចារកម្ម

*រវាងខាងកើតនិងខាងលិចឡើយ បើវាមិនប៉ះពាល់ដល់ទំនាក់ទំនងរវាងអាមេរិកាំង-វៀតណាមយូរអង្វែងទេ ។ អូកលី បានសម្គាល់ថា "ចាប់ពីពេលនេះទៅ ការរីកចម្រើនជាបណ្ដោះអាសន្នទាំងអស់ក្នុងការចរចាបានត្រូវបញ្ឈប់ ។ ក្រុងវ៉ាស៊ីនតោននៅមិនទាន់យល់ពីការសម្រេចចិត្តបណ្ដេញអ្នកតំណាងវៀតណាម ដែលកើតឡើងចំពេលដែលក្រុងហាណូយកំពុងតែពិនិត្យមើលដោយល្អិតល្អន់នូវនយោបាយការបរទេសរបស់ខ្លួនឡើយ" ។*

*ក្នុងឱកាសនៃការប្រជុំរបស់ខ្លួននៅខែមករា ឆ្នាំ១៩៧៨ ការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម បានសម្រេចធ្វើឲ្យការជួបប្រជុំជាមួយក្រុងវ៉ាស៊ីតោនមានសម្ទុះជាថ្មីស្ដីពីបញ្ហានៃការធ្វើឲ្យមានប្រក្រតីភាព និងផ្ដើមចលនាធ្វើការផ្សះផ្សាមួយជាមួយពិភពមិនមែនកុម្មុយនីស្ត ទោះជាបង់ខាតជំនួយផ្នែកសេដ្ឋកិច្ចមួយរបស់អាមេរិកាំងក៏ដោយ ។ ក្នុងពេលជាមួយគ្នានោះ ការិយាល័យនយោបាយរបស់វៀតណាមក៏បានសម្រេចចាប់ផ្ដើមធ្វើការរៀបចំប្រុងប្រៀបខាងយោធាប្រឆាំងនឹងប្រទេសចិននិងប្រទេសកម្ពុជាផងដែរ[៧] ។*

*នេះជាការលះបង់ដែលនាំឲ្យឈឺចាប់ខាងផ្លូវចិត្ត ។ មុនដំបូង ពីព្រោះប្រទេសវៀតណាមត្រូវការប្រាក់ខ្លាំងមែនទែន ។ បន្ទាប់មក ពីព្រោះការលះបង់នេះជាការទទួលសារភាពនៃបរាជ័យផ្នែកការទូតមួយ ។ ថ្វីបើទទួលបានជ័យជម្នះយោធាដ៏សម្បើមមួយក៏ដោយ ក៏ក្រុងហាណូយមិនអាចចាប់បង្ខំឲ្យអ្នកចាញ់ធ្វើការសងប្រាក់ជួសជុលការខូចខាតដោយសារសង្គ្រាម ជាថ្នូរនឹងការបង្កើតទំនាក់ទំនងផ្នែកការទូតឡើងវិញដែរ ។ ប៉ុន្តែ ការយកចិត្តទុកដាក់ដល់សន្តិសុខរបស់ប្រទេស បានឈ្នះលើការយកចិត្តទុកដាក់ផ្សេងៗទៀត ។ តាំងពីចុងឆ្នាំមុនព្រឹត្តិការណ៍ផ្សេងៗបានលេចទម្រង់ឡើងមិនជាល្អឡើយ ។ វៀតណាមមិនអាចគ្រោងគិតធ្វើការតតាំងទាំងប្រទេសចិនផង ប្រទេសកម្ពុជាផងនៅក្នុងពេលតែមួយ ដោយគ្មានការបន្ថែមជំនួយខាងយោធារបស់សូវៀតបានទេ ។ បំណងនៃភាពមិនចំណុះអ្នកដទៃរបស់គេនឹងត្រូវប៉ះពាល់ដោយសាររឿងនោះជាក់ជាមិនខាន ។ ការបើកស្ថានទូតអាមេរិកមួយនៅទីក្រុងហាណូយ នឹងមានលក្ខណៈជាកម្លាំងទប់មួយចំពោះឥទ្ធិពលរបស់សូវៀត ។ ម្យ៉ាងទៀត ការបើកស្ថានទូតនេះនឹងជាមធ្យោបាយប្រឆាំងនឹងកលល្បិចផ្សេងៗរបស់ចិនសំដៅឯកោប្រទេសវៀតណាមខាងការទូតផង ។*

*រឿងអាស្រូវនៃការបណ្ដេញឯកអគ្គរដ្ឋទូតវៀតណាមនៅអង្គការសហប្រជាជាតិបានធ្វើឲ្យស្នាមរបួសដែលពិបាកសះជាឈឺចាប់ឡើងវិញ ។ ទំនាក់ទំនងទ្វេភាគីបានចាប់ផ្ដើម"គោះតើយ"ជាថ្មី ។ សម័យប្រជុំលើកទីបួននៃការចរចារវាង រីឆាដ ហូលប្រ៊ុក និង ផាន់ ហៀន ដែលគ្រោងធ្វើនៅខែកុម្ភៈនឹងត្រូវលុបចោល ។*

## ក្រុងហាណូយរៀបចំការចាប់ផ្ដើមធាក់ធងមុន

*ប៉ុន្តែ ក្រុងហាណូយ លែងប្រកាន់ជំហរកិចកុកយូរទៀតហើយ ។ ដំណើររបស់ប្រ៊ីហ្សីនស្គីទៅកាន់ប្រទេសចិនគឺជារឿងដែលគួរឲ្យព្រួយបារម្ភ ហើយជាងនេះទៅទៀត សេចក្ដីថ្លែងការណ៍របស់គាត់ដែលកំពុងគាំទ្រក្រុង*

ប៉េកាំងប្រឆាំងនឹង"អ្នកការពារអនុត្តរភាពនិយមប្រចាំតំបន់" ដែលជាការនិយាយបញ្ចិតបញ្ចៀងទៅរកប្រទេសវៀតណាម ក៏ធ្វើឲ្យវៀតណាមនឹកបារម្ភដែរ ។ ភាពតានតឹងជាមួយប្រទេសចិនបានកើនឡើង គ្រប់គ្នាកំពុងរៀបចំខ្លួនធ្វើការប្រឈមមុខគ្នានៅលើរណរង្គ(ទីចម្បាំង) របស់កម្ពុជា ។ ការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងវ៉ាស៊ីនតោនគឺជារឿងបន្ទាន់បំផុត ។ តាមលោក ហ្វ្រេដ ប្រោន (Fred Brown) មន្ត្រីនៅក្រសួងការបរទេសថា "វៀតណាមមានបំណងធ្វើឲ្យមានប្រក្រតីភាពនៅមុនថ្ងៃបុណ្យការងារ[សូមបញ្ជាក់ថា នៅសហរដ្ឋអាមេរិក និងកាណាដា "ទិវាបុណ្យការងារ" បានប្រារព្ធធ្វើនៅថ្ងៃច័ន្ទ ទី១ នៃខែកញ្ញា] ឬយ៉ាងយូរនៅថ្ងៃបុណ្យ"អរគុណព្រះជាម្ចាស់" [*Thanksgiving day* : ជាបុណ្យដែលប្រារព្ធនៅសហរដ្ឋអាមេរិកនៅថ្ងៃព្រហស្បតិ៍ទី៤ នៃខែវិច្ឆិកា (កំណត់អ្នកបកប្រែ)] ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងការរង់ចាំការជួបគ្នាថ្មីមួយជាមួយពួកអាមេរិកាំង ផាន់ ហៀន បានប្រកាសជាពិសេសនៅក្នុងសន្និសីទកាសែតមួយដែលប្រព្រឹត្តទៅនៅទីក្រុងតូក្យូនាខែកក្កដាថា ក្រុងហាណូយបោះបង់មិនយកបញ្ហាជំនួយអាមេរិកាំង មកធ្វើជាអាទិភាពក្នុងការធ្វើឲ្យមានប្រក្រតីភាពឡើយ : "នេះជាឥរិយាបថថ្មីមួយ ដោយតាំងចិត្តបែរឆ្ពោះទៅរកអនាគត[ដែលបញ្ចេញឲ្យឃើញ]ពីខាងវៀតណាមវិញ" ។ អំណឹះតទៅ អាមេរិកាំងនឹងត្រូវបានស្វាគមន៍នៅប្រទេសវៀតណាម បើសិនជាពួកគេបង្ហាញឲ្យឃើញការប្រុងប្រៀបផ្សេងៗ ប្រកបដោយមិត្តភាព និងស្មារតីសហប្រតិបត្តិការពិតប្រាកដមួយ ។ ប៉ុន្តែ ហៀន បានបញ្ជាក់ថា "បើសិនពួកគេមកដោយដៃទទេ នោះការទទួលស្វាគមន៍គ្រាន់តែមិនសូវរាក់ទាក់ប៉ុណ្ណោះ"[៣] ។

បន្ទាប់ពីក្រុងតូក្យូ ហៀន បានធ្វើដំណើរទៅកាន់ទីក្រុងកង់បែរ៉ា-ប្រទេសអូស្ត្រាលី-ទៀត ជាទីដែលគាត់អះអាងបន្ថែមនូវសេចក្តីប្រកាសពីមុនរបស់គាត់ ក្នុងអំឡុងនៃការជួបសន្ទនាជាមួយនាយករដ្ឋមន្ត្រីអូស្ត្រាលី ម៉ាល់ខូម ហ្វ្រេហ្ស័រ និងរដ្ឋមន្ត្រីការបរទេស អាន់ឌ្រូ ភីខុក ។ លោក ភីខុក បាននិយាយប្រាប់ខ្ញុំថា "មុនការមកដល់របស់ ហៀន ខ្ញុំ(ភីខុក) បានជួបសន្ទនាតាមទូរស័ព្ទចំនួនពីរដង បើមិនអ៊ីចឹងទេគឺបីដងជាមួយ ឌីក (ឈ្មោះហៅក្រៅរបស់ ហូលប្រ៊ុក) អំពីបញ្ហាឥរិយាបថថ្មីរបស់វៀតណាម ។ ខ្ញុំបានរំឭកប្រាប់គាត់ដែរ បន្ទាប់ពីការសន្ទនារបស់យើង ។ ហូលប្រ៊ុក មានលក្ខណៈសុទិដ្ឋិនិយមណាស់នៅពេលបន្ទាប់មកទៀត"[៤] ។

ទីបំផុត នៅពេលដែលវៀតណាមសម្រេចចិត្តប្រកាសពីដំណឹងនេះដោយផ្ទាល់នៅខែកក្កដា ចំពោះអ្នកទទួលខុសត្រូវអាមេរិកាំងម្នាក់ សេចក្តីរំភើបញាប់ញ័ររបស់ ហូលប្រ៊ុក បានកើនឡើងទ្វេ ។ ក្រុងហាណូយបានបញ្ជូនគណៈប្រតិភូមួយទៅកាន់ក្រុងហូណូលូលូ ជាការឆ្លើយតបនឹងការអញ្ជើញពីមុនមួយរបស់អាមេរិកាំង ឲ្យទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកោសល្យវិច័យសាកសពអតីតទាហានបាត់ខ្លួន (Joint Casualty Resolution Center) និងបណ្តាបច្ចេកវិជ្ជាដ៏អស្ចារ្យរបស់មជ្ឈមណ្ឌលនេះ ជាទីដែលអ្នកបច្ចេកទេសនៃវិជ្ជាស្ថានកោសល្យវិច័យ បានកែសម្រួលបង្កើយនូវវិធីសាស្ត្រនានាដែលអនុញ្ញាតឲ្យគេរកឃើញអត្តសញ្ញាណបុគ្គលម្នាក់ដោយចាប់ផ្តើមពីឆ្អឹងមួយដុំឬសក់មួយកញ្ចុំទៅ ។ ដូច្នេះសហរដ្ឋអាមេរិកសង្ឃឹមបញ្ចុះបញ្ចូលឲ្យវៀតណាមស្វែងរក

កងទ័ពអាមេរិកាំងដែលបាត់ខ្លួនក្នុងការប្រយុទ្ធកាន់តែសកម្មថែមទៀត ។ ការជួបគ្នាមានលក្ខណៈរាក់ទាក់និងមិត្តភាពដ៏កម្រមាន ។ វូហ័ង ជាមន្ត្រីម្នាក់របស់រដ្ឋមន្ត្រីការបរទេសវៀតណាមបានសម្តែងឲ្យឃើញលក្ខណៈរួសរាយខ្លាំងណាស់ ដែលនេះគឺជាដំណើរលើកដំបូងរបស់គាត់ទៅកាន់សហរដ្ឋអាមេរិក ។ គាត់បាននិយាយប្រាប់លោក ហ្វ្រង់ ស៊ីវ៉រ នៅក្រសួងការបរទេសទទួលបន្ទុកបញ្ហាទាហានអាមេរិកបាត់ខ្លួនជាសម្ងាត់ថា "ខ្ញុំមិនដែលដេកលក់ស្រួលដូច្នេះទេក្នុងមួយជីវិតខ្ញុំ" ។ បន្ទាប់ពីទស្សនកិច្ចនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកោសល្យវិច័យអតីតទាហានបាត់ខ្លួន គណៈប្រតិភូទាំងពីរបាននិយាយពីសហប្រតិបត្តិការរវាងប្រទេសទាំងពីរម្តង ។ ដើម្បីបញ្ចប់ ហ្វ្រេដ ប្រ៊ោន បាននាំ ហ័ង ទៅកន្លែងចិញ្ចឹមសត្វទឹក ។ នៅពេលសម្ងឹងមើលចលនារបស់ត្រីដូហ្វាំងនោះហើយដែល ហ័ង បញ្ចេញឲ្យដឹងនូវពាក្យមួយឃ្លាដោយស្ងៀមស្ងាត់ថា ប្រទេសវៀតណាមនឹងលែងនិយាយពីការផ្តល់ជំនួយមួយរបស់អាមេរិកាំង ធ្វើជាអាទិភាពក្នុងការធ្វើឲ្យមានប្រក្រតីភាពទៀតហើយ ។ នៅទីបំផុត នេះជាការប្រកាសដ៏ច្បាស់លាស់និងគ្មានឲ្យមន្ទិលមួយដែលចេញពីបបូរមាត់របស់វៀតណាម ។ ប្រ៊ោន ដែលសប្បាយរីករាយខ្លាំងបានដើរសំដៅទៅកាប៊ីនទូរស័ព្ទមួយដើម្បីហៅទៅ ហូលប្រ៊ុក នៅទីក្រុងវ៉ាស៊ីនតោន ។ ហូលប្រ៊ុក បានថ្លែងថា នេះជាដំណឹងដ៏ល្អដោយបញ្ជាក់ថា គាត់ប្រញាប់ចង់ឮពាក្យនេះចេញពីមាត់វៀតណាមផ្ទាល់ ។

ហូលប្រ៊ុក គ្មានធ្វើឲ្យលេចចេញសេចក្តីទុកចិត្តរបស់គាត់ ដែលរកបានមកវិញបន្តិចសោះទេ ។ ពិតហើយនៅក្រសួងការបរទេស មន្ត្រីម្នាក់ៗរីករាយក្នុងចិត្តណាស់ពីលទ្ធភាពមានតំណែងមួយនៅទីក្រុងហាណូយ ប៉ុន្តែក្រសួងការបរទេសនៅតែពុំទាន់ទទួលដំណឹងស្តីពីការផ្លាស់ប្តូរជំហរមួយរបស់វៀតណាមតាមផ្លូវការទេ ។ តាមការពិត គ្មានការជួបគ្នាណាមួយត្រូវគ្រោងទុកក្នុងតារាងកាលវិភាគឡើយ ហេតុដូចនេះហើយបានជាក្រុងហាណូយពុំមានហេតុផលណាមួយបញ្ជូនទៅឲ្យពួកអាមេរិកាំងនូវដំណឹងជាផ្លូវការមួយនោះ ។ ហូលប្រ៊ុក ដែលចង់ចៀសវាងពីចំណាប់អារម្មណ៍របស់សាធារណជនទៅលើព្រឹត្តិការណ៍ថ្មីៗ ពុំបានបន្តនិយាយពីសំណើរបស់វៀតណាមដើម្បីផ្តើមការសន្ទនាមួយឈុតថ្មីនៅទីក្រុងប៉ារីសនាខែសីហាផងទេ ។ ដូចដែលយើងបានដឹងមកហើយថាគាត់ចូលចិត្តជួបអនុរដ្ឋមន្ត្រីការបរទេសវៀតណាមជាងក្នុងឱកាសនៃការទៅចូលរួមប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិរបស់គាត់នៅខែកញ្ញា ។ តាមទស្សនៈមួយផ្នែកការទូត វាមានប្រយោជន៍ជាងដែលមិនត្រូវលាតត្រដាងពីការចាប់ផ្តើមការចរចាឡើងវិញជាមួយក្រុងហាណូយនៅពេលដែលគ្រោះថ្នាក់នៃសង្គ្រាមមួយរវាងចិន-វៀតណាមលេចទ្រង់ទ្រាយឡើងកាន់តែច្បាស់នោះ ។ ចំណែកវៀតណាមវិញយល់ថា ពុំមានផលប្រយោជន៍ណាមួយដែលត្រូវបង្ហាញដោយដាក់លាក់ខ្លាំងនូវសន្ទឹកបៀរបស់គេ មុនការចាប់ផ្តើមឡើងវិញនូវការប្រជុំពិភាក្សាជាមួយពួកអាមេរិកាំងឡើយ ។ ដូច្នេះ ពួកគេរឹតត្បិតដោយខ្លួនឯងនូវការនិយាយបញ្ចិតបញ្ចៀងជាសាធារណៈ និងការបញ្ជាក់បន្ថែមជាឯកជនក្នុងរយៈពេលជាច្រើនខែ ។ ក្នុងឱកាសស្នាក់អាស្រ័យរបស់គាត់នៅទីក្រុងហាណូយជាមួយគណៈប្រតិភូមួយរបស់សភាជាន់ខ្ពស់ លោក ហ្សន ភី. មីថា ពិតជាសាកល្បងធ្វើឲ្យបាន

ទទួលការបំភ្លឺអ្វីៗដែលមិនទាន់ច្បាស់ឲ្យកាន់តែច្បាស់ថែមទៀត ។ គាត់បានសួរទាំងគំរោះគំរើយថា ប្រទេសវៀតណាម ពិតជាបោះបង់អ្វីៗដែលជាអាទិភាពរបស់ខ្លួនមែនឬ? ។ ចម្លើយរបស់ ហៀន មានលក្ខណៈពិបាកយល់បន្តិច ៖ «យើងបានបង្ហាញភាពទន់ភ្លន់ហើយ» ។ ដោយគៀនឲ្យបញ្ជាក់ ហៀន បានចំអន់ មីថា ថា «ណ្ហើយ! រឿងនេះទុកឲ្យអ្នកចរចានិយាយគ្នាវិញ» និងទុកឲ្យ រីឆាដ ហូលប្រ៊ុក បំពេញកិច្ចការរបស់គាត់ចុះ»[៥] ។

ប៉ុន្តែ ដោយមិនសប្បាយចិត្តពីការលើកពេលការជួបគ្នាជាមួយ ហូលប្រ៊ុក វៀតណាមពិតជា សង្ឃឹមសម្រេចបានកិច្ចព្រមព្រៀងមួយនៅខែកញ្ញានាទីក្រុងញូវយ៉កមិនខាន ។ ទស្សនកិច្ចជាបន្តបន្ទាប់របស់សមាជិកសភាអាមេរិកាំងជាច្រើនរូបក្នុងអំឡុងរដូវក្តៅ បានបង្កើនការរំភើបញាប់ញ័រខ្លាំងដែលកើនចេញពីការសន្ទនាក្នុងពេលថ្មីៗថែមទៀត ។ គណៈប្រតិភូសភាជាន់ខ្ពស់ដែលដឹកនាំដោយលោក សុននី ម៉ុងហ្គូម៉េរី ប្រាកដជាពុំអញ្ជើញ ផាំ វ៉ាន់ដុង និង ផាន់ ហៀន ឲ្យធ្វើដំណើរមកកាន់សហរដ្ឋអាមេរិកទេមើលទៅ? ។ ជាថ្នូរមកវិញ វៀតណាមពុំបានប្រគល់អដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួនដប់ប្រាំរូបមកឲ្យគណៈប្រតិភូឡើយ ។

នៅពេលត្រឡប់មកដល់ក្រុងវ៉ាស៊ីនតោនវិញ ម៉ុងហ្គូម៉េរី បានសុំឲ្យរដ្ឋាភិបាលបន្តការសន្ទនាគ្នាជាថ្មី កុំបង្អង់យូរ ដើម្បីបង្កើតទំនាក់ទំនងផ្នែកការទូតនិងពាណិជ្ជកម្មទាំងស្រុងឡើងវិញជាមួយប្រទេសវៀតណាម ។ មីថា បានអះអាងបន្ថែមថា ៖ «ផ្តើមការចរចាឡើងវិញឬ? ប៉ុន្តែ វៀតណាមគ្រាន់តែសួរពីរឿងនេះប៉ុណ្ណោះ» ជាពិសេសពីព្រោះ«ពួកគេខ្លាចប្រទេសចិន»[៦] ។ សមាជិកសភាមួយក្រុមទៀតដែលបញ្ជូនទៅក្រុងហាណូយតាមការផ្តើមគំនិតរបស់ព្រឹទ្ធសមាជិក អេដវឺដ កេណ្ណឺឌី នៅពេលត្រឡប់មកវិញក៏បង្ហាញសេចក្តីសន្និដ្ឋានដូចគ្នាដែរ ។ របាយការណ៍អំពីបេសកកម្មរបស់គាត់ដែលថ្លែងនៅមុខគណៈកម្មការនីតិកម្មព្រឹទ្ធសភាបានសន្និដ្ឋានយ៉ាងច្បាស់ថា «ប្រាកដហើយ យើងបានឈានមកដល់ចំណុចមិនអាចត្រឡប់ក្រោយមួយ ។ យើងត្រូវតែធ្វើការសម្រេចចិត្តជាប្រវត្តិសាស្ត្រមួយអំពីរឿងនយោបាយការបរទេស... ។ អំណឹះតទៅ យើងមានលទ្ធភាពបំពេញដោយសន្តិវិធីនូវអ្វីដែលយើងធ្លាប់ខំប្រឹងធ្វើតាំងពីយូរយារមកហើយ ដោយកម្លាំងយោធាដើម្បីការពារផលប្រយោជន៍របស់អាមេរិកាំងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដោយការពារឯករាជ្យភាពរបស់វៀតណាមពីការគ្របសង្កត់ពីខាងក្រៅទាំងអស់»[៧] ។ អ្នកគូររូបកំប្លែងស្លូតម្នាក់បានកត់សម្គាល់ថា ផាំ វ៉ាន់ដុង អាចនឹងបញ្ជាក់ឡើងវិញពីសេចក្តីរាយការណ៍ របស់អតីតរដ្ឋមន្ត្រីការបរទេសអាមេរិក ឌៀន រឹស ដែលថា «វត្តមានរបស់អាមេរិក [មានលក្ខណៈ]ចាំបាច់ខានមិនបានក្នុងការការពារសន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍»[៨] ។

វៀតណាមបានតាមឃ្លាំមើលជាមួយការព្រួយបារម្ភនូវការបែរទៅស្និទ្ធចិនរបស់ ប្រ៊ីហ្សីនស្គី ប៉ុន្តែពួកគេជឿថា ក្រុងវ៉ាស៊ីនតោននឹងមិនយល់ព្រមភ្ជាប់ទំនាក់ទំនងជាមួយចិនវិញទេ ពិតហើយដោយសារបារម្ភពីផលប្រយោជន៍របស់ខ្លួនដែលគេយល់ដឹងបាន ។ នៅពេលនោះ វាដល់ពេលហើយដែលត្រូវបោះជំហានទៅមុខទៀតនិងចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយជាមួយក្រុងមូស្គូ ។ ការធានាទាំងពីរនេះទល់នឹងការកៀបសង្កត់និង

កលល្បិចផ្សេងៗរបស់ចិន និងបើកឱកាសឲ្យវៀតណាមផ្តើមធ្វើការវាយលុកខាងយោធាមួយប្រឆាំងនឹងរបបរបស់ ប៉ុល ពត ដោយពេញដៃពេញជើង ។ ក្រុងហាណូយពុំដឹងខ្លួនថា ហេតុការណ៍ផ្សេងៗនៅក្រុងវ៉ាស៊ីនតោនបានប្រែប្រួលហើយទេ ។ ដោយមិនឲ្យមនុស្សគ្រប់គ្នាដឹងក្រៅតែពីសហការីជិតស្និទ្ធមួយក្តាប់តូចរបស់លោកប្រធានាធិបតី ផែនការមួយត្រូវបានរៀបចំនៅដំណាច់ខែមិថុនា ។ ផែនការនោះបានគ្រោងធ្វើការបង្កើតទំនាក់ទំនងខាងការទូតពេញលេញឡើងវិញជាមួយប្រទេសចិន នៅមុនខែធ្នូ ឆ្នាំ១៩៧៨[9] ។

ក្នុងអនុស្សរណៈមួយចុះកាលបរិច្ឆេទថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៧ ប្រ៊ីហ្សីនស្គី បានរំឭក ខាធ័រ ថា សេចក្តីសម្រេចចិត្តសំខាន់ៗដែលគាត់ប្រកាន់យក គឺទាក់ទងនឹងប្រទេសចិនពុំមែនប្រទេសវៀតណាមទេ ។ គាត់បានបញ្ចេញយោបល់ថា «ការចម្រើនលូតលាស់នៃទំនាក់ទំនងផ្សេងៗរវាងប្រទេសយើងទាំងពីរ[សហរដ្ឋអាមេរិក និងប្រទេសចិន] នឹងធ្វើឲ្យតុល្យភាពនៃកម្លាំងទាំងអស់នៅក្នុងពិភពលោកប្រែប្រួលយ៉ាងដាច់ខាត» ។ ប៉ុន្តែថា «ការបង្កើតទំនាក់ទំនងឡើងវិញជាមួយប្រទេសវៀតណាម បានត្រឹមតែរាំងរាការរីកលូតលាស់នេះប៉ុណ្ណោះ»[10] ។

នៅថ្ងៃទី៥ ខែកក្កដា គឺប្រាំមួយថ្ងៃមុនពេលដែល ហៀន ផ្សព្វផ្សាយជាសាធារណៈពីជំហរថ្មីរបស់វៀតណាមនៅទីក្រុងតូក្យូ ការជួបប្រជុំដើម្បីចរចារវាងចិន-អាមេរិកាំងស្តីពីការធ្វើឲ្យមានប្រក្រតីភាពបានចាប់ផ្តើមនៅទីក្រុងប៉េកាំង ។ ដោយពន្យារការចរចាជាមួយក្រុងហាណូយ ហូលប្រ៊ុក ដែលគ្មានពិភាល់ពីរឿងនេះបានអះអាងនូវការជួយជ្រោមជ្រែងចំពោះប្រទេសចិន ក្នុងការរត់ប្រណាំងដែលប្រទេសនេះបានផ្តើមជាមួយប្រទេសវៀតណាម សម្រាប់ការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងវ៉ាស៊ីនតោន ។ បច្ច័យដែលជាដើមហេតុប្រឆាំងចិន ដោយចេញមុខខ្លាំងរបស់ប្រទេសវៀតណាម គឺច្បាស់ជាបង្កឲ្យមានការស្ទាក់ស្ទើរខ្លះៗដោយចៀសមិនរួច ហើយដែលធ្វើឲ្យខ្លួនខាតបង់នូវសេចក្តីទុកចិត្ត ។ ផ្ទុយមកវិញ អាថ៌កំបាំងទាំងមូលដែលកំពុងព័ទ្ធជុំវិញការប្រជុំដើម្បីចរចារវាងចិន-អាមេរិកាំង បានទ្រទ្រង់ការចរចាឲ្យផុតពីការរិះគន់ទាំងអស់ ។

## ការត្រឡប់មកវិញរបស់ គេង

បន្ទាប់ពីការចាប់ផ្តើមដ៏ហ៊ឹកហ៊ាក់មួយ ទំនាក់ទំនងរវាងប្រទេសចិននិងសហរដ្ឋអាមេរិកបានត្រូវបញ្ឈប់ក្នុងរយៈពេលយ៉ាងយូរ ។ ទស្សនកិច្ចជាសម្ងាត់របស់ ហង់រី គីស្សីងហ្គ័រ នៅទីក្រុងប៉េកាំងកាលពីឆ្នាំ១៩៧១បានបើកឲ្យមានទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់ប្រធានាធិបតី និចសុន នៅខែកុម្ភៈ ឆ្នាំ១៩៧២ ។ ម៉ៅ ដែលមានគំនិតមមៃពីការគំរាមរបស់សូវៀត បានធ្វើអ្វីៗទាំងអស់ដើម្បីសម្រួលឲ្យមានការខិតចូលជិតគ្នាមួយរវាងប្រទេសទាំងពីរ ដោយដាក់ឲ្យអនុវត្តនូវទ្រឹស្តី«រណសិរ្សរួបរួម»ដ៏ឆ្នើមរបស់គាត់ ៖ «ចងសម្ពន្ធភាពជាមួយសត្រូវឆ្ងាយរងដើម្បីតទល់នឹងសត្រូវធំ» ។ នៅដើមឆ្នាំ១៩៧៣ ស្ថានបេសកកម្មសម្រាប់ទំនាក់ទំនងគ្នាបានបើកនៅទីក្រុងវ៉ាស៊ីនតោន និងក្រុងប៉េកាំង ។ ប៉ុន្តែ ការផ្តើមការទាក់ទងផ្នែកសេដ្ឋកិច្ចនិងវប្បធម៌នេះពុំបានស្ថិតស្ថេរយូរឡើយ

ម្យ៉ាងដោយសាររឿងអាស្រូវ Watergate [លុបចេញជាអគារច្រើនជាន់មួយនៅទីក្រុងវ៉ាស៊ីនតោន និងជាទីស្នាក់ការរបស់គណបក្សប្រជាធិបតេយ្យ នៅឆ្នាំ១៩៧២ ។ នៅថ្ងៃទី១៧ ខែមិថុនា បុរសប្រាំនាក់ត្រូវប៉ូលិសចាប់ខ្លួន នៅពេលកំពុងរៀបចំបង្កប់មីក្រូហ្វូននៅទីនោះ ។ អ្នកកាសែតបង្ហាញថា មីក្រូហ្វូនទាំងនោះគឺសម្រាប់ប្រធានាធិបតីប្រើលួចស្តាប់ការពិភាក្សាគ្នារបស់គណបក្សប្រជាធិបតេយ្យ ក្នុងពេលដែលគាត់ឈរឈ្មោះបោះឆ្នោតនៅឆ្នាំ១៩៧២ម្តងទៀត ។ ដោយត្រូវជ្រើសតាំងជាថ្មី ប្រធានាធិបតី និចសុន បានខំសាកល្បងដោះខ្លួនពីរឿងនេះ បន្ទាប់មកបានសុំលាលែងពីមុខតំណែងនៅខែសីហា ឆ្នាំ១៩៧៤(កំណត់អ្នកបកប្រែ)] និងម្យ៉ាងទៀត ដោយសារការកើនឡើងយ៉ាងខ្លាំងក្នុងការតស៊ូដើម្បីអំណាចនៅប្រទេសចិនផង ។ ក្រុងប៉េកាំងបានសម្គាល់ឃើញដោយក្រសែភ្នែកយ៉ាងអាក្រក់នូវការប្រឹងប្រែងទាំងឡាយ ដែលសម្តែងឲ្យឃើញដោយរដ្ឋាភិបាលអាមេរិកាំង ដើម្បីធ្វើឲ្យមានភាពធូរស្រាលជាមួយក្រុងមូស្គូ ។ ម្យ៉ាងទៀតពួកចិនបានត្រូវធ្វើឲ្យខ្វល់ខ្វាយក្នុងចិត្តពីការស្រូតរូតបន្តិច ដែលប្រធានាធិបតី ហ្វ័រដ៍ សម្តែងឲ្យដឹងក្នុងការបន្តនយោបាយរបស់លោក និចសុន សំដៅលះបង់តៃវ៉ាន់ ដើម្បីធ្វើឲ្យទំនាក់ទំនងផ្សេងៗជាមួយប្រទេសចិនមានប្រក្រតីភាពពេញលេញ ។

ប៉ុន្តែ នៅដើមឆ្នាំ១៩៧៨ ស្ថានការណ៍នៅប្រទេសចិនបានប្រែត្រឡប់ទាំងស្រុងជាថ្មីម្តងទៀតដែលជាហេតុនាំឲ្យភាពចាំបាច់នៃការធ្វើសម្ពន្ធភាពជាមួយអាមេរិកាំងកើតមានជាថ្មី ។ តាំងពីការចាប់ខ្លួន“បនបួននាក់” នៅចុងឆ្នាំ១៩៧៦ ពួកមេដឹកនាំប្រតិបត្តិនិយមនិងនិយមផ្លូវកណ្តាលដែលប្រមូលផ្តុំជុំវិញ តេង ស៊ាវពីង បានចាប់ផ្តើមផ្តល់នូវសារសំខាន់ដល់ការធ្វើទំនើបកម្មខាងផ្នែកសេដ្ឋកិច្ច ។ តេង ដែលធ្វើឲ្យមាននីតិសម្បទាឡើងវិញនៅខែកក្កដា ឆ្នាំ១៩៧៧ បានប្រកាន់យកស្ថានភាពខាងផ្លូវនយោបាយភ្លាមក្នុងការចោទជាបទឧក្រិដ្ឋទាំងស្រុងអំពីការធ្វើនយោបាយរបស់ពួកវ៉ាឌីកាល់នៅក្នុងប្រទេសក៏ដូចនៅក្រៅប្រទេស ។ តាម តេង ថា នយោបាយការបរទេសរបស់ចិនដែលផ្អែកលើការតស៊ូវណ្ណៈមានលក្ខណៈតឹងរ៉ឹងខ្លាំងពេក[១១] ។

គាត់បានរុញតាមរបៀបជាក្បួននូវ“កូនអុក”ជាច្រើនរបស់គាត់ចូលក្នុងបក្ស រដ្ឋាភិបាល និងកងទ័ព ហើយការធ្លាក់ចុះនៃទំនាក់ទំនងជាមួយសហភាពសូវៀតនិងប្រទេសវៀតណាម បានផ្តល់ការអនុគ្រោះយ៉ាងច្រើន ដល់ តេង ពីព្រោះវានាំឲ្យមានការខិតចូលជិតគ្នាមួយជាមួយបស្ចិមប្រទេសដោយចៀសមិនរួច ។ ពិតហើយ ប៊ីកញូ ប្រ៊ីហ្សីនស្គី បានធ្វើឲ្យសម្រេចនូវគំនិតបង្កើតរណសិរ្សរួបរួមមួយប្រឆាំងក្រុងមូស្គូនិងសម្ព័ន្ធមិត្តវៀតណាមរបស់គេ ។ ប្រាកដណាស់ហើយ បច្ច័យដែលជាដើមហេតុរបស់ពួកអាមេរិកាំងនិងពួកចិនមានលក្ខណៈផ្សេងពីគ្នា ៖ សម្រាប់ទីប្រឹក្សារបស់ ខាធ័រ សារសំខាន់គឺការជម្រុលទៅមុខរបស់សូវៀតនៅទ្វីបអាហ្វ្រិក ដែលគាត់បានឃ្លាំមើលជាមួយមនោសញ្ចេតនារកធ្វើអ្វីមិនកើតលាយឡំទៅដោយកំហឹង ហើយសម្រាប់ តេង វិញយល់ថាអ្វីដែលសំខាន់គឺរឿងរបស់វៀតណាម ។ ប៉ុន្តែ រឿងទាំងអស់នេះ វាតម្រង់ទៅរកគោលដៅតែមួយដូចគ្នា ។ មនុស្សទាំងពីររូបនេះ មានអ្វីៗទាំងអស់ដែលត្រូវគ្នា ហើយការមានផលប្រយោជន៍រួមគ្នានេះ បានរារាំងសហរដ្ឋ

អាមេរិកមិនឲ្យលម្អៀងទៅខាងណាបានឡើយរវាងមហាអំណាចកុម្មុយនីស្តទាំងពីរដែលប្រជែងគ្នានៅអាស៊ី ។

ទោះបីជាប្រក្រតីភាពជាមួយប្រទេសចិន និងប្រទេសវៀតណាម គឺជាគោលដៅមួយក្នុងចំណោមគោលដៅជាអាទិភាពនៃនយោបាយការបរទេសថ្មីរបស់អាមេរិកាំងក៏ដោយ ក៏ការរីកលូតលាស់មិនសូវមានអ្វីគួរឲ្យចាប់អារម្មណ៍ដែរ បន្ទាប់ពីការចូលកាន់អំណាចមួយឆ្នាំរបស់ ខាធ័រ ។ តាមការពិត បញ្ហាពុំមែនកើតមានដោយពិតប្រាកដក្នុងទីបំផុតដូចគ្នាទេ ។ តាំងពីដំបូង វាបង្ហាញឲ្យឃើញការទាស់ទែងគ្នាថែមទៀតជាមួយប្រទេសចិន ។ ជាមួយវៀតណាម រឿងរ៉ាវទាំងនោះ បើប្រៀបធៀបគ្នាទៅគឺមានលក្ខណៈងាយស្រួលជាង ៖ វៀតណាមគ្រាន់តែយល់ព្រមសហការក្នុងការស្វែងរកទាហានអាមេរិកបាត់ខ្លួននិងបោះបង់ជាមុននូវការទាមទារសំណងខូចខាតដោយសារសង្គ្រាមប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ការប្រែក្លាយស្ថានបេសកកម្មទំនាក់ទំនងដែលតាំងនៅក្រុងប៉េកាំង និងក្រុងវ៉ាស៊ីនតោនទៅជាស្ថានទូតពេញលក្ខណៈបានតម្រូវឲ្យពួកអាមេរិកាំងធ្វើសម្បទានជាចាំបាច់ ។ ដូច្នេះ ពួកចិនបានបដិសេធមិនសន្យាបោះជំហានទៅមុខទៀតទេ ក្នុងផ្លូវនៃការធ្វើឲ្យមានប្រក្រតីភាពឡើងវិញ ដរាបណាសហរដ្ឋអាមេរិកពុំទាន់កាត់ផ្តាច់ទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយតៃវ៉ាន់ និងរំលាយសន្ធិសញ្ញាផ្តល់ជំនួយផ្នែកយោធាដែលចងភ្ជាប់ប្រទេសទាំងពីរទេនោះ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ប្រធានការិយាល័យទំនាក់ទំនងរបស់ចិននៅទីក្រុងវ៉ាស៊ីនតោនគឺ ឧត្តមសេនីយ៍ ហ័ង ហ្សិន បានច្រានចោលទាំងគំរោះគំរើយនូវសំណើរបស់អាមេរិកាំងដែលសុំឲ្យមានដំណើរមួយមកកាន់សហរដ្ឋអាមេរិករបស់មេដឹកនាំជាន់ខ្ពស់ចិនម្នាក់ ។ ជាដំបូង គាត់បានទាមទារឲ្យសហរដ្ឋអាមេរិកបិទស្ថានទូតរបស់តៃវ៉ាន់សិន ។ លោក ខាធ័រ បានខឹងច្រឡោត ។ ក្នុងសារណារបស់គាត់ អតីតប្រធានាធិបតីរូបនេះបានកត់ត្រាថា «ប្រទេសចិនប្រហែលជានៅតែចាត់ខ្លួនឯងជាអាណាចក្រកណ្តាលដែលសង្ឃឹមថាភាគសេសសល់នៃពិភពលោកមុខជាទទួលស្គាល់ភាពត្រឹមត្រូវនៃជំហរផ្សេងៗជាគោលការណ៍របស់ខ្លួនហើយមើលទៅ»[១២] ។

## ក្រសួងការបរទេសទល់នឹងក្រុមប្រឹក្សាសន្តិសុខជាតិ

អ្វីៗបានបន្តឲ្យមានការលែងអត់ទ្រាំតទៅទៀត ប៉ុន្តែ លោក ខាធ័រ នឹងត្រូវវាយតម្លៃពី«បញ្ហាជាគោលការណ៍»ទាំងនោះ ។ នៅដើមរដូវក្តៅឆ្នាំ១៩៧៧ ខាធ័រ បានសម្រេចចិត្តបំពេញតាមការទាមទាររបស់ក្រុងប៉េកាំងក្រោមលក្ខខណ្ឌថា សហរដ្ឋអាមេរិកអាចរក្សាទំនាក់ទំនងក្រៅផ្លូវការរបស់ខ្លួនជាមួយតៃវ៉ាន់តទៅទៀត ហើយថាសហរដ្ឋអាមេរិកបានធ្វើឲ្យសម្រេចនូវការធានាក្នុងការដោះស្រាយប្រកបដោយសន្តិវិធីមួយនូវជម្លោះរវាងប្រទេសចិនទាំងពីរ ។ គោលដៅរបស់គាត់គឺជំរុញក្រុងប៉េកាំងឲ្យយកចិត្តទុកដាក់កាន់តែកើនឡើងជាលំដាប់ពីការព្រួយបារម្ភរបស់អាមេរិកាំង ។ នៅខែសីហា គឺមួយខែបន្ទាប់ពីការតែងតាំងឡូអូណារដ៍ វូដខូកឲ្យធ្វើជាប្រធានការិយាល័យទំនាក់ទំនងរបស់អាមេរិកាំង លោក ស៊ីរុស វ៉ាន់ស៍ បានធ្វើដំណើរទៅកាន់ប្រទេសចិន

ដើម្បីបំបាត់ការខ្វែងគំនិតគ្នាខ្លះៗ ។ គាត់បានស្នើទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិនថា ជារដ្ឋាភិបាលស្រប ច្បាប់តែមួយគត់ ហើយមិនបន្តសន្ធិសញ្ញាផ្តល់ជំនួយផ្នែកយោធាជាមួយតៃវ៉ាន់ឡើងវិញឡើយ ។ ប៉ុន្តែ វ៉ាន់ស៍ បានប្រាប់រដ្ឋមន្ត្រីការបរទេសចិន ហួងហួ ឲ្យដឹងថា គាត់ចង់បានការយល់ព្រមរបៀបសម្ងាត់ពីប្រទេសចិនផងដែរ ដើម្បីនឹងឲ្យបុគ្គលិកការទូតរបស់អាមេរិកាំងស្ថិតនៅតៃវ៉ាន់[13] ។

ហ្វ័រដ៍ និង គីស្សឹងហ្គ័រ ប្រហែលជាទៅឆ្ងាយជាងនេះ ។ សំណើរបស់ វ៉ាន់ស៍ បានដៅឲ្យឃើញដំណើរថយក្រោយមួយ ព្រោះវាបន្តផ្អែកលើអាទិភាពនៃប្រទេសចិនពីរនិងនៅតែរក្សាក្រុមអ្នកតំណាងការទូតមួយនៅតៃវ៉ាន់ ដែលគាត់មិនហ៊ាននិយាយពីឈ្មោះរបស់វាឡើយ ។ ប៉ុន្តែ ពួកចិនពុំច្រានចោលសំណើនេះភ្លាមៗទេ ។ ទន្ទឹមនឹងនោះ វ៉ាន់ស៍ បានបន្ទុយពាក្យយ៉ាងច្បាស់ថា ជំហររបស់អាមេរិកាំងអាចវិវត្តថែមទៀត ប៉ុន្តែពុំទាន់សម្តែងឲ្យឃើញនៅពេលឥឡូវនេះទេ ។ ដោយហេតុថា ពួកចិនត្រូវការការពន្យារពេលមួយមុននឹងដោះស្រាយការធ្វើឲ្យមានប្រក្រតីភាព ដូច្នេះមិនត្រូវប្រញាប់ប្រញាល់ពេកទេ ។ នៅតែប្រព័ន្ធផ្សព្វផ្សាយប៉ុណ្ណោះដែលមានសកម្មភាព ។ ក្រុងប៉េកាំងមិនចង់ឲ្យការជួបគ្នានេះទទួលបរាជ័យឡើយ ។ តាមលោក វីល្លីយ៉ាំ គ្លីសធីន អ្នកឯកទេសដ៏ល្បីល្បាញខាងបញ្ហាចិននៅក្រសួងការបរទេសបានឲ្យដឹងថា ពួកមេដឹកនាំចិនបានផ្តោតការយកចិត្តទុកដាក់បំផុត ចំពោះការតាក់តែងសេចក្តីថ្លែងការណ៍បញ្ចប់សម្រាប់អ្នកសារព័ត៌មាន ។ ព័ត៌មានមួយដែលចេញពីក្រុងវ៉ាស៊ីនតោនបានមកបំផ្លាញអ្វីៗឲ្យខូចការមុនកំណត់ពេលទាំងអស់ ។ ព័ត៌មាននេះបញ្ជាក់ថា អ្នកចរចាចិនបានបង្ហាញឲ្យឃើញលក្ខណៈមិនរឹងរូសច្រើនជាងការដែលគ្រោងទុក ។ តេង ដែលខឹងច្រឡោតគោតគូងបានធ្វើប្រតិកម្មដោយសម្តីគំរោះគំរើយ ។ គាត់បានប្រកាសប្រាប់និពន្ធនាយកកាសែតអាមេរិកាំងមួយក្រុមថា បេសកកម្មរបស់ វ៉ាន់ស៍ បានទទួលលទ្ធផលត្រឹមតែធ្វើឲ្យមានការខ្វះភាពកក់ក្តៅមួយក្នុងទំនាក់ទំនងចិន-អាមេរិកាំងប៉ុណ្ណោះ ។ ឧបទ្ទវហេតុនេះដែលខុសប្លែកខ្លាំងពីធម្មតា បានកំណត់នូវការបញ្ឈប់មួយក្នុងដំណើរលូតលាស់នៃការធ្វើឲ្យមានប្រក្រតីភាព ។ រឹតតែធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺដើមដំបូងប្រហែលបណ្តាលពីជម្លោះធ្ងន់ធ្ងរមួយរវាង ប៊ីកញ្ចូ ប្រ៊ីហ្សីនស្គី និងក្រសួងការបរទេសស្តីពីឥរិយាបថដែលត្រូវប្រកាន់យកចំពោះប្រទេសចិនដែលនឹងមានផលប្រតិយាគដ៏ធំធេងនៅអាស៊ីហើយមើលទៅ ។

តើការលេចធ្លាយរឿងនេះចេញមកពីប្រភពណា មូលហេតុមកពីកំហឹងរបស់ តេង ស៊ាវពីង? ប៉ុន្តែ ស៊ីរូស វ៉ាន់ស៍ ដែលតែងតែប្រយ័ត្នប្រយែងនិងគួរសម មិនរួញរានឹងវិនិច្ឆ័យក្នុងរឿងនេះថា ជាការប៉ុនប៉ងបំផ្លាញនយោបាយរបស់គាត់ដោយចេតនា ហើយពុំមែនដោយគ្មានការរំជួលចិត្តទេដែលគាត់បានរំឭកចំពោះមុខខ្ញុំនូវ“ដំណើរមិនបានសម្រេចផល” របស់គាត់នៅប្រទេសចិនថា “យើងបានជួបធ្វើការសន្ទនាប្រកបដោយផ្លែផ្កាខ្លាំងណាស់ ប៉ុន្តែជាអកុសល ស្រាប់តែមនុស្សសំខាន់ម្នាក់បានផ្សព្វផ្សាយរឿងនេះឲ្យដឹងជាសាធារណៈ-មនុស្ស សំខាន់ម្នាក់ក្នុងចំណោមជាច្រើននាក់នៅសេតវិមាន ។ ខ្ញុំមានវិបត្តិផ្លូវចិត្តពីបញ្ហានេះ ។ ការប្រកួតជាមួយ

*គេង ស៊ាវពីង បានត្រូវរឹតបន្តឹងនិងទាមទារឲ្យមានការបេះលាក់អាថ៌កំបាំងបំផុត លើកលែងតែវាមិនបរាជ័យទាំងស្រុង។ ហើយរឿងបានកើតមានឡើង»[១៨] ។ នៅចំពោះមុខខ្ញុំ ប្រឺហ្សីនស្គី បានបដិសេធដោយដាក់លាក់ ពីការទទួលខុសត្រូវទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខជាតិក្នុងរឿងរ៉ាវនេះ ។ តាមគាត់ឲ្យដឹងថា ពួកចិនបានធ្វើប្រតិកម្មជាអវិជ្ជមានចំពោះសំណើផ្សេងៗរបស់ វ៉ាន់ស៍ ពីព្រោះថា «ពួកគេពុំទាន់បានប្រុងប្រៀបខ្លួន និងយល់ថា ដំណើរនៃការធ្វើឲ្យមានប្រក្រតីភាពលឿនជាងចំណង់របស់គេខ្លាំងពេក ហើយថាសហរដ្ឋអាមេរិកខ្វះភាពម៉ឺងម៉ាត់ចំពោះសូវៀតផង»[១៥] ។*

*តាមការពិត ការលេចធ្លាយរឿងសម្ងាត់ប្រហែលពុំអាចបកស្រាយពីភាពគំរោះគំរើយនៃប្រតិកម្មរបស់ គេង ស៊ាវពីង តែម្នាងបានទេ។ គេអាចសន្និដ្ឋានថា ពួកចិនយល់ថា ក្រុងវ៉ាស៊ីនតោនផ្តល់សារសំខាន់ដល់ការបន្ធូរបន្ថយភាពតានតឹងជាមួយសហភាពសូវៀត និងការបញ្ចប់កិច្ចព្រមព្រៀងមួយស្តីពីការកម្រិតកំណត់ការរត់ប្រណាំងខាងសព្វាវុធ ជាងការធ្វើឲ្យមានប្រក្រតីភាពខាងការទូតជាមួយប្រទេសចិន។ នៅក្នុងប្រទេស គេង ពុំមានសេរីភាពគ្រប់គ្រាន់ដើម្បីចាត់ការទេ ហើយការធ្វើឲ្យមាននីតិសម្បទាវិញរបស់គាត់មានលក្ខណៈនៅថ្មីៗណាស់ ។ គាត់ត្រូវតែរួបរួមជាមួយពួកម៉ៅនិយមបរិសុទ្ធនិងប្រកាន់តឹង ជាពិសេសប្រធានបក្សហ្វាគួហ្វេង ។ ដូច្នេះ គាត់អាចនឹងត្រូវជំរុញឲ្យផ្តល់នូវសក្ខីភាពនៃការរឹងរូស និងការស្រឡាញ់ជាតិមាតុភូមិរបស់គាត់ស្តីពីបញ្ហាតៃវ៉ាន់ ដើម្បីតម្រូវចិត្តពួកនិយមឆ្វេងសិន។*

*ចាប់ពីចុងឆ្នាំ១៩៧៧ ប្រឺហ្សីនស្គី បានបង្កើនការកៀបសង្កត់របស់គាត់រឹតតែខ្លាំង ។ តាមគាត់យល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន បានបង្កជាមធ្យោបាយប្រឆាំងនឹងលទ្ធិវាតទីនិយមរបស់សូវៀតនៅអាហ្វ្រិកជាងពេលណាៗទាំងអស់ ។ ស្របគ្នានោះ គាត់បានប្រឹងប្រែងជំទាស់នឹងការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតជាមួយប្រទេសវៀតណាម ដែលប៉ងប្រាថ្នាយ៉ាងខ្លាំងដោយ វ៉ាន់ស៍ និង ហូលប្រ៊ូក ផងដែរ ។ សម្រាប់គាត់បញ្ហានេះមាន«សារសំខាន់បន្ទាប់បន្សំ»ប៉ុណ្ណោះ[១៦] ។ គាត់បានបំភ្លឺប្រាប់ ខាធ័រ នៅពាក់កណ្តាលខែវិច្ឆិកាថា បើសិនជាសាធារណមតិសង្ស័យពីភាពម៉ឺងម៉ាត់នៃនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកគឺជាសំខាន់ បណ្តាលមកពីបញ្ហាប្រទេសគុយបា វៀតណាម ការចរចាស្តីពីការកម្រិត អាវុធយុទ្ធសាស្រ្ត (S.A.L.T. អក្សរពេញ Strategic Arms Limitation Talks) និងប្រទេសកូរ៉េនេះឯង[១៧] ។*

*តើការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន មានលក្ខណៈរំខានដល់ការចរចាស្តីពីការកម្រិតអាវុធយុទ្ធសាស្រ្តមែនឬ? ។ ដោយផ្ទុយពី វ៉ាន់ស៍, ប្រឺហ្សីនស្គី មិនជឿដូច្នោះទេ ។ គាត់យល់ឃើញថា ហេតុអ្វីបានជាសហរដ្ឋអាមេរិកត្រូវតែយោគយល់ដល់ភាពឆាប់ប្រកាន់របស់ក្រុងមូស្គូ នៅពេលដែលការចរចាដែលកំពុងប្រព្រឹត្តទៅ ពុំជំរុញឲ្យពួកសូវៀតបន្ថយគំនិតវាតទីដ៏ខ្លាំងក្លារបស់ពួកគេពីម្ខាងទៅម្ខាងពិភពលោកនោះ? ។ កិច្ចសហការរវាងចិន-អាមេរិកាំង ដែលផ្តើមគំនិតឡើងដោយរូបគាត់ គឺជា«ការតបវិញភ្លាមៗជាយុទ្ធសាស្រ្ត»មួយ*

ដើម្បីបង្ខំឲ្យពួកសូវៀតឈប់"ប្រើប្រាស់ភាពធូរស្រាលជាមធ្យោបាយ ធ្វើឲ្យបណ្ដាទីតាំងផ្នែកភូមិសាស្ត្រ-នយោបាយនិងយុទ្ធសាស្ត្ររបស់ពួកគេ" នៅមជ្ឈិមបូព៌ានិងក្នុងតំបន់រាងស្នែងក្របីនៃ ទ្វីបអាហ្វ្រិករីតតែវិសេសឡើង ។ គំនិតប្រើប្រាស់"សន្លឹកបៀចិន" បានចាប់ផ្ដើមបញ្ចេញឲ្យគេដឹងឮហើយ ។

តាមរយៈលោក មីស្ហែល អូសេនបឺក លោក ប្រ៊ីហ្សីនស្គី បានឲ្យក្រុងប៉េកាំងដឹងថា គាត់ប្រុងប្រៀបខ្លួនជាស្រេចនឹងធ្វើដំណើរទៅប្រទេសចិន បើទោះជាគេអញ្ជើញចុងមាត់ចុង-កក៏ដោយ ។ អូសេនបឺក បានបញ្ជាក់ថា ពួកចិននឹងសម្រេចចិត្ត "ប្រថុយប្រើការប្រជែងគ្នារវាងបុគ្គលិកនៃក្រុមប្រឹក្សាសន្តិសុខជាតិ និងបុគ្គលិកក្រសួងការបរទេស ដែលពួកគេត្រូវបានប្រាប់ឲ្យដឹងពីរឿងនេះដោយលោក ហង់រី គីស្ស៊ីងហ្គ័រ" ហើយថា ពួកគេ "នឹងបែរទៅពួកមេដឹកនាំអាមេរិកាំងណាដែលមានទស្សនៈជាយុទ្ធសាស្ត្រស្របទៅតាមទស្សនៈរបស់ពួកគេ"[១៨] ។

នៅដើមខែវិច្ឆិកា ប្រ៊ីហ្សីនស្គី បានទទួលការអញ្ជើញមួយឲ្យទៅកាន់ប្រទេសចិន ។ ភ្លាមនោះ វ៉ាន់ស៍ បានខំប្រឹងពន្យល់លោក ខាធ័រ ឲ្យប្រឆាំងនឹងការធ្វើដំណើរនេះ ដែលមុខជានឹងរារាំងដល់ការចរចាដែលផ្ដើមធ្វើដោយក្រសួងការបរទេសមិនខាន ។ ភាពតានតឹងរវាងមនុស្សទាំងពីរដែលមិនបង្ហាញលក្ខណៈមកក្រៅ បានផ្ទុះឡើងជាចំហ ។ ប៉ុន្តែ ប្រ៊ីហ្សីនស្គី មានប្រៀបជាងមួយគឺមុខតំណែងរបស់គាត់ បានធ្វើឲ្យគាត់នៅកៀកកិតនឹងលោកប្រធានាធិបតីជានិច្ច ។ គាត់ចេះឆ្លៀតឱកាសដើម្បីអះអាងពីបុព្វហេតុរបស់គាត់ ដែលរដ្ឋមន្ត្រីការពារប្រទេស ហារ៉ូលប្រោន ក៏គាំទ្រគាត់ដែរ ។ ទីបំផុត នៅពាក់កណ្ដាលខែមីនា ខាធ័រ បានទោរទន់ទៅរក ប្រ៊ីហ្សីនស្គី ហើយមិនរវល់នឹងការឲ្យយោបល់ផ្ទុយរបស់ វ៉ាន់ស៍ ឡើយ ។

ការសម្រេចរបស់ប្រធានាធិបតីគឺផ្ទុកទៅដោយផលវិបាកជាច្រើន ។ ការសម្រេចនេះបានអនុញ្ញាតឲ្យ ប្រ៊ីហ្សីនស្គី បង្កើតឲ្យមានជាមួយក្រុងប៉េកាំងនូវការសន្ទនាពីយុទ្ធសាស្ត្ររួមមួយ ហើយក្នុងទស្សនៈនេះត្រូវជំរុញការធ្វើឲ្យប្រក្រតីភាពនៃទំនាក់ទំនងចិន-អាមេរិកកាន់តែជឿនទៅមុខទៀត ។ ប៉ុន្តែ ហួសអំពីនោះ វារួមបន្កជាការមិនទទួលស្គាល់មួយចំពោះនយោបាយតុល្យភាពដែលបន្តធ្វើដោយ វ៉ាន់ស៍ ផងដែរ ។ ត្បិតអី វ៉ាន់ស៍ មិនទាន់មានបំណងក្នុងការធ្វើឲ្យមានប្រក្រតីភាព -ដែលគាត់គឺជាអ្នកស្នើដំបូងម្នាក់ក្នុងចំណោមអ្នកស្នើដំបូងៗ- ជាមួយប្រទេសចិនទេ មុននឹងត្រូវបញ្ចូលទៅក្នុងយុទ្ធសាស្ត្រប្រឆាំងសូវៀតរួមគ្នាមួយ ។ ផ្ទុយទៅវិញ តាមគាត់យល់ការធ្វើឲ្យមានប្រក្រតីភាពនេះគឺជារឿងដែលមិនអាចបំបែកចេញពីការចរចាដ៏ល្អិតល្អន់ស្ដីពីការកម្រិតអាវុធយុទ្ធសាស្ត្រដែលកំពុងប្រព្រឹត្តទៅឡើយ ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ គាត់បានព្យាយាមស្នើទៅកាន់ប្រធានាធិបតីថា កិច្ចការទាំងពីរត្រូវដឹកនាំធ្វើឲ្យបានល្អប្រសើរនៅមុនដំណាច់ឆ្នាំ ។ ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន ពិតជានឹងជួយសម្រួលដល់ការឲ្យសច្ចាប័នលើកិច្ចព្រមព្រៀងស្ដីពីការកម្រិតអាវុធយុទ្ធសាស្ត្រ ដោយជំរុញឲ្យសភាជាន់ទាបធ្វើអ្វីមួយជាប្រយោជន៍ដល់រដ្ឋាភិបាលផង ។ វ៉ាន់ស៍ បានកត់ត្រាក្នុងសតិរបស់គាត់ថា "ខ្ញុំតែងតែមានគំនិតនិយាយគ្រប់ពេលពី"ការលេងសន្លឹកបៀចិន"ថា វាជាយុទ្ធវិធីប្រកប

ដោយគ្រោះថ្នាក់ណាស់ ហើយលើសពីនេះទៀត នៅពេលដែលជោគជ័យ ឬបរាជ័យនៃការចរចាស្តីពីការកម្រិតអាវុធយុទ្ធសាស្ត្រមិនដឹងជាយ៉ាងណាផងនោះ»[១៩] ។

ប៉ុន្តែដោយមិនឲ្យ វ៉ាន់ស៍ ដឹង ប្រ៊ីហ្ស៊ីនស្គី បានផ្តើមធ្វើការវាយលុកទាក់ទាញមួយទៅកាន់ពួកមេដឹកនាំចិន ។ ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៨ គាត់បានជួបសន្ទនាជាសម្ងាត់ជាមួយ ហានស៊ូ ប្រធានការិយាល័យទំនាក់ទំនងស្តីទីរបស់ចិននៅទីក្រុងវ៉ាស៊ីនតោន ដែលនៅក្នុងពេលនោះ គាត់មានឱកាសលាតត្រដាងពីជំហរផ្សេងៗទាក់ទងនឹងសហភាពសូវៀតថែមទៀតដែលខុសគ្នាយ៉ាងខ្លាំងពីជំហររបស់ វ៉ាន់ស៍[២០] ។

មុននឹងឡើងយន្តហោះទៅកាន់ក្រុងប៉េកាំង ប្រ៊ីហ្ស៊ីនស្គី បានទទួលការផ្តាំផ្ញើពី ខាធ័រ ថាគាត់បានចុះហត្ថលេខាខាងក្រោមមតិណែនាំមួយដែលគាត់តែងដោយខ្លួនគាត់ផ្ទាល់ ជាមួយនឹងការជួយរបស់ អូសេនបឺក និងដែលកំណត់ពីជំហរអាមេរិកាំងដោយជាក់ច្បាស់ ។ មតិណែនាំនេះ នៅទីបំផុតនឹងធ្វើឲ្យជម្លោះរវាងចិននិងវៀតណាមមានលក្ខណៈជាអន្តរជាតិ ហើយជំរុញឲ្យសហរដ្ឋអាមេរិកខិតទៅខាងក្រុងប៉េកាំងកាន់តែកៀក ។ ទំនាក់ទំនងផ្សេងៗជាមួយប្រទេសចិនបានរួមបង្កជា «លក្ខណៈសំខាន់មួយនៃនយោបាយពិភពលោករបស់សហរដ្ឋអាមេរិក» ។ ប្រទេសទាំងពីរមានកង្វល់ខាងផ្នែកយុទ្ធសាស្ត្រក្នុងរយៈពេលវែងដូចគ្នា ហើយជាបឋមគឺ«ការជំទាស់រួមគ្នាចំពោះគំនិតបង្កើតអនុត្តរភាពទាំងអស់ ទាំងក្នុងពិភពលោកឬក្នុងតំបន់» ។ ន័យដ៏ធំគឺគេអាចមើលធ្លុះ ៈ ក្រុងវ៉ាស៊ីនតោនកាន់ជើងប្រទេសចិនប្រឆាំងសហភាពសូវៀត និងប្រទេសវៀតណាមដែលក្រុងប៉េកាំងចោទប្រកាន់ជារឿយៗថា មានបំណងតម្រូវឲ្យធ្វើតាម«អនុត្តរភាពប្រចាំតំបន់»របស់ខ្លួន ។ ម្យ៉ាងទៀតសហរដ្ឋអាមេរិកបានប្រកាសឲ្យដឹងពីការប្រឆាំងរបស់ខ្លួន ចំពោះគម្រោងការរបស់សូវៀតដែល«ប្រើប្រាស់ប្រទេសវៀតណាម(ហើយប្រហែលជាថ្ងៃណាមួយតែវ៉ាន់ដែរ) ដើម្បីហ៊ុមព័ទ្ធប្រទេសចិន»[២១] ។

## ប្រ៊ីហ្ស៊ីនស្គី នៅលើ«មហាកំពែងចិន»

ពីរសប្តាហ៍ក្រោយពេលដែលក្រុងប៉េកាំងប្រាប់ឲ្យដឹងជាសាធារណៈពីការព្រួយបារម្ភរបស់ខ្លួនទាក់ទងទៅនឹងការចាកចោលស្រុកទាំងហ្វូងៗរបស់ជនជាតិចិនពីប្រទេសវៀតណាម នៅថ្ងៃទី១៩ ខែឧសភា ប្រ៊ីហ្ស៊ីនស្គី រួមជាមួយអ្នកទទួលខុសត្រូវមួយចំនួនតូចនៃក្រុមប្រឹក្សាសន្តិសុខជាតិ ក្រសួងការបរទេសនិងមន្ទីរបញ្ចកោណ បានឡើងយន្តហោះធ្វើដំណើរទៅកាន់ប្រទេសចិនតាមយន្តហោះបូអ៊ីង៧០៧មួយគ្រឿងនៃកងអាកាសចរសហរដ្ឋអាមេរិក ។ ទស្សនកិច្ចនឹងប្រែទៅជាទស្សនកិច្ចរបស់ទីប្រឹក្សាសន្តិសុខតែម្នាក់ឯងវិញ ដូចដែល ហូលប្រ៊ុក បង្ហាញឲ្យដឹងពីរឿងនេះភ្លាមថា ប្រ៊ីហ្ស៊ីនស្គី មានបំណងបដិសេធការសន្ទនាកម្រិតខ្ពស់នៅទីក្រុងប៉េកាំង ។ ក្រៅពីគាត់ អនុប្រធានរបស់ ស៊ីរុស វ៉ាន់ស៍ បានសាកល្បងប្រើលកល្បិចទាំងអស់សង្ឃឹមមួយ ដើម្បីឲ្យគេរាយការណ៍ពីការសម្រេចចិត្តនេះ ។ គាត់បានវាយទូរលេខទៅ វូដខូក នៅការិយាល័យទំនាក់ទំនងរបស់អាមេរិកាំងប្រចាំរដ្ឋធានី

ចិន ឲ្យប្រញាប់ប្រញាល់ទៅកាន់ទីក្រុងតូក្យូជាទីដែលក្រុមរបស់ ប្រ៊ីហ្ស៊ីនស្គី ត្រូវចុះចត(ដើម្បីចាក់សាំង) ២៤ម៉ោងក្រោយ ។ ដោយត្រូវធ្វើឲ្យស្រឡាំងកាំង អ្នកការទូតអាមេរិកាំងបានជឿក្នុងរយៈមួយភ្លែតនោះ ពីការផ្លាស់ប្តូរទិសនយោបាយមួយនៅនាទីចុងក្រោយ ។ មិនយូរប៉ុន្មានពួកគេយល់ថា នេះគ្រាន់តែជាវគ្គចុងក្រោយនៃជម្លោះរវាង វ៉ាន់ស៍ និង ប្រ៊ីហ្ស៊ីនស្គី ប៉ុណ្ណោះ ។ ហូលប្រ៊ុក មានបំណងចង់ឲ្យ វូដខូក ជួយសុំទោសប្រធានាធិបតី ខាធ័រ ក្នុងនាមរូបគាត់ ដើម្បីឲ្យគាត់ទទួលបានការអនុញ្ញាតទៅចូលរួមការប្រជុំដើម្បីចរចាផង ។ វូដខូក បានបដិសេធដោយគួរសមថា គាត់មិនធ្វើអន្តរាគមន៍ក្នុងរឿងនេះទេ ។ អារម្មណ៍របស់ ហូលប្រ៊ុក បានប្រែទៅជាមួម៉ៅខ្លាំងណាស់ ។ តាមសាក្សីអាមេរិកាំងម្នាក់ថា ការស្នាក់អាស្រ័យរបស់គាត់នៅទីក្រុងប៉េកាំង គ្រាន់តែជាការផឹកស៊ីរមួយប៉ុណ្ណោះ ។ ក្រោយមកសហការីម្នាក់របស់ ប្រ៊ីហ្ស៊ីនស្គី បានសន្និដ្ឋានថាការបដិសេធនេះជា«កន្ទុះខាតការព្រមព្រៀងគ្នារវាងមនុស្សទាំងពីរ» ។ ចំណែកឯ វីល្លីយ៉ាំ ក្លីសធីន ដែលជាអ្នករងគ្រោះផ្ទាល់ពីការកាត់កាល់លែងរាប់រកនេះ ចូលចិត្តបកស្រាយរឿងនេះថា ជាការបង្ហាញឲ្យឃើញភាពច្រណែនខាងវិជ្ជាជីវៈជាង ។ ហូលប្រ៊ុក និង ប្រ៊ីហ្ស៊ីនស្គី បានចំណាយកម្លាំងរបស់ខ្លួន ដោយមិនគិតអ្វីទាំងអស់នៅក្នុងរយៈពេលនៃការឃោសនាបោះឆ្នោតរបស់លោក ខាធ័រ ដែលពួកគេបានផ្តល់ជាកម្លាំងយ៉ាងខ្លាំងក្នុងចំណោមអ្នកឯទៀតៗដល់ក្រុមអ្នកជំនាញការខាងនយោបាយការបរទេស ។ អ្នកទាំងពីរមានគោលដៅយ៉ាងខ្ពស់ ប៉ុន្តែនៅទីបំផុត ប្រ៊ីហ្ស៊ីនស្គី បានមានប្រៀបជាង ។ ប៉ុន្តែ ហូលប្រ៊ុក បានមានសិទ្ធិចូលធ្វើការនៅសេតវិមាន និងមិនរួញរាឆ្លៀតយកប្រយោជន៍អំពីមុខតំណែងគាត់ឡើយ ហើយគូប្រជែងរបស់គាត់នៅតែចងគំនុំនឹងគាត់ជានិច្ច ។ ដូចដែល ក្លីធីន អះអាងពីរឿងនេះថា ប្រ៊ីហ្ស៊ីនស្គី បានចាត់ទុក ហូលប្រ៊ុក ជា«អ្នកមានថ្មីម្នាក់ដែលពោរពេញដោយអំនួត» ហើយគាត់មិនចង់ចែករំលែកជោគជ័យនៃដំណើរទៅក្រុងប៉េកាំងរបស់គាត់ជាមួយ ហូលប្រ៊ុក ឡើយ ។

ទោះជាយ៉ាងណាក៏ដោយ ពួកចិនទំនងជាបន្តបកស្រាយខុសទៅហេតុនេះថា ជាសញ្ញានៃការមិនទុកចិត្តមួយប្រឆាំងនឹងសហការីម្នាក់របស់ វ៉ាន់ស៍ ហើយពួកគេបានឆ្លៀតទាញយកផលប្រយោជន៍ពីការប្រេះឆា ដែលលេចឡើងឲ្យឃើញពីក្នុងរដ្ឋាភិបាល ខាធ័រ ព្រមគ្នាទាំងផ្ទាល់ខ្លួនផង ទាំងខាងមនោគមវិជ្ជាផង ។

ការគិតគូររបស់ ប្រ៊ីហ្ស៊ីនស្គី គឺថា គាត់ត្រូវតែពន្យល់ពួកចិនឲ្យជឿពិតប្រាកដពីការសម្រេចចិត្តប្រឆាំងសូវៀតរបស់រដ្ឋាភិបាល ខាធ័រ ដើម្បីបន្ទន់ចិត្តពួកគេស្តីអំពីបញ្ហាទំនាក់ទំនងក្រៅផ្លូវការរវាងសហរដ្ឋអាមេរិកនិងតៃវ៉ាន់ ។ ហើយបើសិនជាពួកគេនៅតែតឹងតែងអំពីចំណុចនេះ គេអាចសង្ឃឹមថា ទស្សនវិស័យនៃសហប្រតិបត្តិការមួយខាងវិស័យការពារជាតិ នឹងនាំពួកគេទៅរកការខិតចូលជិតគ្នាមួយជាមួយសហរដ្ឋអាមេរិក ដោយមានឬគ្មានការបង្កើតទំនាក់ទំនងផ្នែកការទូត ។ ប្រ៊ីហ្ស៊ីនស្គី បានជម្រាប តេង ស៊ាវពីង ថា សហរដ្ឋអាមេរិកទទួលយល់ព្រមតាមលក្ខខណ្ឌផ្សេងៗរបស់ចិន ស្តីពីការកាត់ផ្តាច់ទំនាក់ទំនងជាផ្លូវការជាមួយតៃវ៉ាន់ ជាការជ្រើសរើសរវាងលទ្ធភាពពីរដែលនៅខែសីហា ឆ្នាំ១៩៧៧ វ៉ាន់ស៍ ធ្លាប់ការពារនៅចំពោះមុខគាត់ ។ ប្រ៊ីហ្ស៊ីនស្គី

បញ្ជាក់ថា ការសម្រេចចិត្តគឺចេញអំពីប្រធានាធិបតី ខាងក្រៅ ។ ដើម្បីបង្ហាញឲ្យឃើញពីបំណងជាក់លាក់របស់អាមេរិកាំង គាត់បាននាំទៅជាមួយគាត់នូវ"ជំនូន"យ៉ាងច្រើន ដែលសម្រាប់ធ្វើឲ្យមានការគាប់អារម្មណ៍ខ្លាំង ។

សាមុយអែល ហាន់ធីងតុន សមាជិកក្រុមប្រឹក្សាសន្តិសុខជាតិ និងជាអតីតសហការីនៃរដ្ឋាភិបាលប្រធានាធិបតី ហ្សុនសុន ដែលជាអ្នកឯកទេសខាងការប្រយុទ្ធប្រឆាំងការបះបោរនៅប្រទេសវៀតណាម ត្រូវបានប្រគល់ភារកិច្ចឲ្យបញ្ជូនទៅឲ្យពួកចិននូវ"អនុស្សរណៈរបស់ប្រធានាធិបតីលេខ១០" ជាឯកសារសម្ងាត់បំផុតផ្តុកទៅដោយការវិភាគមួយស្តីពីស្ថានការណ៍ពិភពលោក ដែលប្រមើលមើលស្ថានភាពកម្លាំងយោធារបស់សូវៀត ។ កិច្ចការនេះសំដៅញុំាងឲ្យប្រទេសចិនជឿថា ក្រុងវ៉ាស៊ីនតោនបានចាត់ទុកចិនជាសម្ពន្ធមិត្រមិនលំអៀងមួយ ជាភាគីដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការរួមកម្លាំងគ្នាក្រៅផ្លូវការមួយដើម្បីប្រឆាំងក្រុងមូស្គូ ។ ប្រ៊ីហ្សីនស្គី បានប្រកាសឲ្យដឹងថា បទបញ្ជាទាំងឡាយរបស់អាមេរិកាំងទាក់ទងនឹងការលក់ទៅឲ្យប្រទេសចិននូវបច្ចេកវិជ្ជាយោធានឹងត្រូវសម្របសម្រួលគ្នា ។ ម្យ៉ាងទៀត អំណឹះតទៅបណ្តាប្រទេសសម្ពន្ធមិត្ររបស់អាមេរិកនឹងមានសេរីភាពលក់អាវុធទៅឲ្យក្រុងប៉េកាំងតាមបំណង ។ ដើម្បីបន្ថែមទម្ងន់ទៅលើការសម្រេចផ្ទាល់ខ្លួនរបស់គាត់ ប្រ៊ីហ្សីនស្គី បានដាក់អ្នកឯកទេសខាងបញ្ហានេះពីររូបនៅអមជាប់គាត់គឺលោក បេនហ្សាមីន អ៊ុយបឺម៉ាន់ ទីប្រឹក្សាទីស្តីការប្រធានាធិបតីទទួលបន្ទុកផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិជ្ជានិងលោក ម័រតុន អាប្រាម៉ូវិត អនុរដ្ឋលេខាធិការនៅក្រសួងការពារប្រទេសទទួលបន្ទុកបញ្ហាផ្សេងៗទាក់ទងនឹងសន្តិសុខអន្តរជាតិ ។

អាប្រាម៉ូវិត ដែលចេះនិយាយភាសាចិន បានត្រូវប្រគល់ភារកិច្ចជាពិសេសដោយមន្ទីរបញ្ចកោណឲ្យធ្វើការអង្កេតដំបូងៗស្តីពីការបញ្ចូលជាយុទ្ធសាស្ត្រនូវការធ្វើសហប្រតិបត្តិការខាងយោធាដោយថាហេតុមួយជាមួយប្រទេសចិន[២២] ។ គាត់ជាមន្ត្រីនៃក្រសួងការពារប្រទេសអាមេរិកាំងទីមួយដែលធ្វើដំណើរទៅកាន់ប្រទេសចិន ហើយគាត់បានឆ្លៀតឱកាសនោះ ដើម្បីជួបសមភាគីចិនម្នាក់ដោយស្ងាត់កំបាំងក្នុងចំណោមសមភាគីចិនរបស់គាត់ ។ តាមការអះអាងរបស់សាក្សីម្នាក់ដែលបានចូលរួមក្នុងការសន្ទនាគ្នាថា "នោះគឺជាការនិយាយម្នាក់ឯងដ៏យូរមួយ ។ ក្នុងរយៈពេលជាងមួយម៉ោង អាប្រាម៉ូវិត បានផ្តល់ដំណឹងដល់បណ្តាគូសន្ទនារបស់គាត់នូវព័ត៌មានផ្សេងៗដែលសម្ងាត់បំផុតស្តីពីការដាក់ពង្រាយកងទ័ពរបស់សូវៀតនៅតាមបណ្តោយព្រំដែនចិន" ។ នេះប្រហែលជាលើកដំបូងហើយដែលប្រទេសទាំងពីរសហការគ្នាកម្រិតខ្ពស់បំផុត ក្នុងវិស័យព័ត៌មាន(សម្ងាត់) ។ ជាពិសេស អាប្រាម៉ូវិត បានប្រាប់ពួកចិនឲ្យដឹងនូវព័ត៌មានផ្សេងៗស្តីពីអាវុធយុទ្ធសាស្ត្ររបស់សូវៀតថែមទៀត ។ គាត់បានដកចេញពីកាបូបយួររបស់គាត់នូវរូបថតជាច្រើនសន្លឹកដែលថតពីអាកាសគឺ ឋបនភ័ណ្ឌយោធានិងកងរថក្រោះដែលប្រមូលផ្តុំគ្នាយ៉ាងច្រើននៅព្រំដែនរបស់ចិនដែលធ្វើឲ្យគូសន្ទនារបស់គាត់ភ្ញាក់ផ្អើលផងនិងរីករាយផង ។ ចំណែកលោក បេនហ្សាមីន អ៊ុយបឺម៉ាន់ បានជួបធ្វើការសន្ទនាដាច់ដោយឡែកជាមួយពួកចិនទាក់ទងទៅនឹងសហប្រតិបត្តិការដោយថាហេតុមួយរវាងចិន និងអាមេរិកាំងខាងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា

ហើយជាពិសេសក្នុងវិស័យនៃការប្រមូលព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិកអំពីសហភាពសូវៀត ។ ការជជែកពិភាក្សាទំនងជាប្រកបដោយផ្លែផ្កា ព្រោះមួយឆ្នាំក្រោយមកវាបានសម្រេចផលនាំឲ្យមានការតាំងស្ថានីយលួចស្តាប់មួយរបស់អាមេរិកាំងនៅលើដែនដីចិនសម្រាប់តាមឃ្លាំមើលការសាកល្បងអាវុធមីស៊ីលរបស់ពួកសូវៀត[២៣] ។

ប៉ុន្តែ ដោយប្រយ័ត្នយ៉ាងខ្លាំងស្តីពីសហប្រតិបត្តិការជាមួយប្រទេសចិនខាងវិស័យការពារ វ៉ាន់ស៍ ផ្ទាល់ពុំបានជំទាស់នឹងគម្រោងបង្កើតស្ថានីយលួចស្តាប់ឡើយ ។ នេះជាមធ្យោបាយដ៏ប្រសើរដើម្បីពិនិត្យមើលការអនុវត្តន៍កិច្ចព្រមព្រៀងកាត់បន្ថយអាវុធយុទ្ធសាស្ត្ររបស់ពួកសូវៀត ហើយសភាជាន់ទាបមុខជានឹងត្រូវធ្វើឲ្យចាប់អារម្មណ៍ពីរឿងនេះក្នុងពេលផ្តល់សច្ចានុម័តមិនខាន ។

ការបង្ហាញដើមហេតុទាំងឡាយរបស់ ប្រ៊ីហ្សីនស្គី មានលក្ខណៈខុសគ្នាទាំងស្រុង ។ សមាជិកម្នាក់នៃក្រុមរបស់គាត់បាននិយាយឲ្យដឹងថា «ប៊ីក ខំប្រឹងយកចិត្តយកថ្លើមពួកចិន ដោយស៊ីកសៀតសម្តីថា ព័ត៌មានផ្សេងៗដែលយើងទើបនឹងផ្តល់ឲ្យ អាចគ្រាន់តែជាការភ្ញាក់ឲ្យដឹងជាមុនមួយប៉ុណ្ណោះ» ។ នៅពេលត្រឡប់មកទីក្រុងវ៉ាស៊ីនតោនវិញ វីល្លីយ៉ាំ ក្វីធីន បានគាក់តែងអនុស្សរណៈមួយប្រកបដោយសម្តីជូរចត់បំផុត ដែលក្នុងនោះគាត់បានចោទប្រកាន់ ប្រ៊ីហ្សីនស្គី ថា បានសម្ញែងជាគ្រឿងទាក់ចិត្តពួកចិនឲ្យមានសង្ឃឹមពីជំនួយអាមេរិកាំងមួយនៅក្នុងវិស័យខ្លះៗ ដែលមិនដែលជជែកពិភាក្សាក្នុងលំដាប់ថ្នាក់ដឹកនាំជាន់ខ្ពស់សោះ ហើយដែលនៅមិនទាន់យល់ព្រមនៅឡើយ ។ វ៉ាន់ស៍ បានអបអរសរសើរការវិភាគនេះយ៉ាងក្លៀវក្លា ។ ប្រ៊ីហ្សីនស្គី ធ្វើហាក់ដូចជាឥតមានរឿងហេតុអ្វីកើតឡើងទាំងអស់ ។

នៅទីក្រុងប៉េកាំង ទីប្រឹក្សាសន្តិសុខជាតិបានដុតបញ្ឆេះការខ្វះអំណត់របស់ចិន ដោយសង្កត់បញ្ជាក់នៅចំពោះមុខ ហ័ង និង តេង ស៊ាវពីង ពីភាពចាំបាច់ពង្រឹងសហប្រតិបត្តិការទៅលើ«បញ្ហាផ្សេងៗថែមទៀត ដូចជាបញ្ហាអាហ្វហ្គានីស្ថាន ការផ្តល់ជំនួយទៅឲ្យប្រទេសប៉ាគីស្ថាន និងការជួយតំបន់អាស៊ីអាគ្នេយ៍ជាដើម ដែលជាការឆ្លើយតបទៅនឹងការទ្រទ្រង់របស់សូវៀតចំពោះគំនិតវាតទីនិយមរបស់វៀតណាម»[២៤] ។ សេចក្តីប្រកាសនេះស្ទើរតែយល់ព្រមចំពោះសម្ព័ន្ធភាពរបស់ប្រទេសចិនជាមួយខ្មែរក្រហមដែរ ដោយហេតុថា ក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល កម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ជាប្រទេសតែមួយគត់ដែលតស៊ូទប់ទល់នឹង«លទ្ធិវាតទីនិយមរបស់វៀតណាម» ។ សាក្សីដដែលបានកត់សម្គាល់ជាឯកជនថា «ប៊ីក បានជឿដោយគ្មានព្រីស្មៀបបន្តិចនូវការវិភាគរបស់ចិន ស្តីពីការគំរាមកំហែងរបស់សូវៀត និងពីតួនាទីរបស់ពួកវៀតណាមដែលគ្រាន់តែរណបរបស់រុស្សីប៉ុណ្ណោះ ។ គាត់យល់ឃើញថាល្អថែមទៀត នៅពេលពួកចិនពន្យល់ប្រាប់គាត់ថា មធ្យោបាយតែមួយគត់ដើម្បីបណ្តេញរុស្សីចេញពីតំបន់គឺជួយសម្រួលឲ្យមានការខិតចូលជិតគ្នាមួយរវាងសូវៀត-វៀតណាម ដែលតាមពួកចិនថា នឹងនាំទៅរកការប៉ះទង្គិចរវាងសម្ពន្ធមិត្រនានា ដោយចៀសមិនផុត»[២៥] ។ ដោយរបៀប

*ម្យ៉ាង ប្រ៊ីហ្សីនស្គី បានធ្វើឲ្យទៅជាផ្លូវការនូវជំហរថ្មីរបស់អាមេរិកាំង ដោយអបអរសរសើរជាសាធារណៈក្នុងឱកាសពិធីជប់លៀងមួយ នូវការប្រឆាំងរបស់ចិនចំពោះ"អនុត្តរភាពពិភពលោកនិងតំបន់" ។ នៅពេលដែលដំណឹងដឹងមកដល់គាត់ វ៉ាន់ស៍ ដែលពុំបានផ្ដល់នូវការយល់ព្រមរបស់គាត់បានខឹងច្រឡោតតោគតូង ។ គាត់បានកត់សម្គាល់ដោយគ្មានអត់អធ្យាស្រ័យថា "នេះជាសម្ដីល្ងីល្ងើមួយសុទ្ធសាធ ។ សុន្ទរកថារបស់ ប្រ៊ីហ្សីនស្គី និងសម្ដីសន្ទនារបស់គាត់នៅមហាកំពែងគឺធ្វើឲ្យពួកចិនត្រូវចិត្តប្រាកដណាស់ ប៉ុន្តែពួកគេនឹងពុំបានសម្រេចលទ្ធផលច្បាស់លាស់អ្វីទាំងអស់"[២៦] ។*

*នៅជើងមហាកំពែងតែម្ដង ប្រ៊ីហ្សីនស្គី បានបញ្ចេញសម្ដីទៅកាន់អ្នកបកប្រែចិនរបស់គាត់ ណាន់ស៊ី តាង នូវការបន្ដុះបង្អាប់(ដោយមើលងាយថា គូប្រឆាំងគ្មានសមត្ថភាពនឹងធ្វើអ្វីកើត) យ៉ាងសោះកក្រោះមួយថា "អ្នកទីមួយដែលឈរលើកំពូល[របស់មហាកំពែង]នឹងទៅប្រយុទ្ធនឹងពួករុស្ស៊ីនៅប្រទេសអេត្យូពី" ។ គាត់មានប្រៀបលើយុទ្ធការនៅប្រទេសចិនរបស់គាត់ដោយគ្មានពិបាកធ្វើឲ្យស្រឡាំងកាំងគ្រប់គ្នា ។ នៅពេលចុះមកវិញ ពួកគេបានជួបគ្នានឹងសិស្សនាយទាហានរបស់កងម៉ារីនជាច្រើននាក់ ដែលកំពុងឈរថតរូបជាក្រុម ។ ដោយកំសៀកខ្លួនយ៉ាងប្រសប់ចូលទៅកណ្ដាលចំណោមពួកនោះ ប្រ៊ីហ្សីនស្គី បានសួរថា "នៅពេលនេះ តើកម្លាំងអ្វីដែលធ្វើឲ្យអ្នកទាំងអស់គ្នាថតរូបជាមួយអ្នករិះគន់សូវៀតខ្លាំងជាងគេនៅលើពិភពលោក?" ។ ពួកសិស្សនាយទាហានកងម៉ារីននៅតែឈរមិងមាំងដោយងឿងឆ្ងល់ ។ ពួកគេនឹកមិនឃើញបន្តិចសោះឡើយពីអត្តសញ្ញាណរបស់ "បិសាចប្រមុះវែង"នេះ ។*

*ទោះបីជាការធ្វើគ្រាប់ដោយឆ្គងគួរឲ្យអស់សំណើចទាំងនេះបណ្ដាលឲ្យ វ៉ាន់ស៍ ក្ដៅក្រហាយក៏ដោយ ក៏គេត្រូវតែទទួលស្គាល់ថា ដំណើររបស់ ប្រ៊ីហ្សីនស្គី ទៅប្រទេសចិនបានផ្ដល់នូវសម្ទុះថ្មីមួយដល់អភិក្រមនៃការធ្វើឲ្យមានប្រក្រតីភាពដែរ ។ ម្យ៉ាងទៀត ការគាំទ្រនិងការយោគយល់ដែលទីប្រឹក្សាអាមេរិកាំងបង្ហាញឲ្យឃើញបានរួមបង្កសម្រាប់ តេង ស៊ាវពីង នូវសន្ទឹកបៀធំជាងគេមួយ (ដែលអាចឲ្យសម្រេចលទ្ធផលច្រើនប្រការ) ហើយដោយសារប្រការនេះ តេង អាចធ្វើឲ្យទស្សនៈទាំងឡាយរបស់គាត់មានប្រៀបជាងនៅក្នុងសម័យប្រជុំផ្ដាច់ព្រ័ត្រនៃការិយាល័យនយោបាយរបស់បក្សកុម្មុយនីស្តចិននៅខែកក្កដា ឆ្នាំ១៩៧៨ ដែលបានសម្រេចចិត្ត "ផ្ដល់មេរៀនមួយចំពោះប្រទេសវៀតណាម" ។*

*មួយខែបន្ទាប់ពីការវិលត្រឡប់មកវិញរបស់ ប្រ៊ីហ្សីនស្គី ភាពស្រុះស្រួលគ្នាតែសម្បកក្រៅមួយហាក់ដូចជាត្រូវធ្វើឲ្យមានឡើងវិញ រវាងបណ្ដាទីប្រឹក្សានយោបាយរបស់ ខាធ័រ ។ វ៉ាន់ស៍ ហារ៉ូលប្រោន ប្រ៊ីហ្សីនស្គី និងហាមីលតុន ហ្សកដង់ បានសម្រេចដោយមានការយល់ព្រមពីប្រធានាធិបតីផងថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិននឹងមានឡើងនៅពាក់កណ្ដាលខែធ្នូ ។ នៅដើមខែកក្កដានាទីក្រុងប៉េកាំង វូដខូក បានប្រគល់ឲ្យពួកចិននូវរបាយការណ៍ពិស្ដារដំបូងមួយក្នុងចំណោមរបាយការណ៍ពិស្ដារបន្ដបន្ទាប់គ្នាមួយស្ដីពីការដោះស្រាយ*

ជម្លោះផ្សេងៗទាក់ទងទៅនឹងកោះតៃវ៉ាន់ ។ ក្រោយមក ស៊ីរុស វ៉ាន់ស៍ បានលាតត្រដាងថា ៖ “ហូលប្រ៊ុក និង ខ្ញុំមានគំនិតប្រើប្រាស់រលកធាតុអាកាសដែលបម្រុងទុកសម្រាប់សេតវិមាន(ក្រោមឈ្មោះសម្ងាត់ថា“Voyager”) ដើម្បីទាក់ទងគ្នាជាមួយវូដខូក” ក្នុងគោលបំណងរឹតត្បិតគ្រោះថ្នាក់នៃការលេចធ្លាយរឿងសម្ងាត់[២៧] ។ ការលេងល្បិចរបស់គាត់បានឡងមកលើខ្លួនឯងវិញហើយ ប្រ៊ីហ្សីនស្គី នឹងទាញទឡ្ហីករណ៍ពីរឿងនេះ ដើម្បីផ្តាច់ក្រសួងការបរទេសចេញនៅពេលដែលត្រូវប្រកាន់យកការសម្រេចចិត្តសំខាន់ៗបំផុត ។

## គម្រោងការផ្សេងៗក្នុងការបើកស្ថានទូតនៅក្រុងហាណូយ

បន្ទាប់ពីការប្រជុំនៅថ្ងៃទី២៧ ខែកញ្ញានាទីក្រុងញូវយ៉ក ផ្នែកដែលទទួលបន្ទុកកិច្ចការវៀតណាម នៅក្រសួងការបរទេសបានបង្កើតក្រុមការងារមួយ ដើម្បីកំណត់ពីភាគល្អិតល្អន់នៃការអនុវត្តន៍ក្នុងការបើកស្ថានទូតអាមេរិកាំងនៅទីក្រុងហាណូយ ។ ត្រូវប្រាប់ឲ្យដឹងពីឧបសគ្គផ្សេងៗដែលត្រូវប្រឈមមុខដោយសារការយល់ព្រមរហ័សពេក បណ្តាស្ថានទូតបស្ចិមប្រទេសខ្លះ-ស្ថានទូតអូស្ត្រាលី អាល្លឺម៉ង់ខាងលិច-និងជាពិសេសហូលប្រ៊ុក មានបំណងធ្វើឲ្យមានការព្រមព្រៀងជាមួយនឹងវៀតណាមជាមុនសិន ។ មន្ត្រីពីររូបនៃក្រសួងការបរទេសគឺលោករ៉ូបឺតអូកលីនិងស៊្ទីវលីនបានត្រូវចាត់ឲ្យជួយផ្តុងផ្តើម ដើម្បីធ្វើឲ្យបានសម្រេចរឿងនេះ អ្នកទាំងពីរបានជួបសហការីម្នាក់របស់ ថាច់ គឺ ត្រាន់ ក្វាងកូ ជាច្រើនលើកនៅទីក្រុងញូវយ៉ក ។ បញ្ហាផ្សេងៗដែលនៅមិនទាន់ដាច់ស្រេចមានរួមបញ្ចូលផងដែរនូវចំនួនអ្នកការទូតដែលចាត់តាំងឲ្យបំពេញមុខងារនៅស្ថានទូតរបៀបដឹកជញ្ជូនហិបការទូត ឬការអនុញ្ញាតឲ្យចុះចតនៅអាកាសយានដ្ឋានក្រុងហាណូយដែលចាំបាច់ត្រូវប្រើយន្តហោះប្រភេទ C-5A Galaxy មួយគ្រឿងសម្រាប់ធ្វើការដឹកជញ្ជូនសម្ភារៈផ្សេងៗរបស់ស្ថានទូត ។

នៅក្រសួងការបរទេស គេចាប់ផ្តើមពិចារណាពីសមាសភាពបុគ្គលិកសម្រាប់ស្ថានទូតដែលត្រូវបើកនៅពេលខាងមុខ ។ សម្រាប់ហេតុផលផ្សេងៗផ្នែកសន្តិសុខដែលឲ្យមន្ទិលសង្ស័យ ខេនយ៉ឺន បានណែនាំ ហូលប្រ៊ុកចៅហ្វាយនាយរបស់គាត់ កុំឲ្យយកអ្នកការទូតណាមួយដែលរៀបការនឹងស្ត្រីវៀតណាម ។ ឌូកក្លាស ភីក អតីតភ្នាក់ងារសន្តិសុខម្នាក់របស់សហរដ្ឋអាមេរិក ធ្លាប់បានរស់នៅជាច្រើនឆ្នាំនៅទីក្រុងព្រៃនគរ ជាទីដែលគាត់ទទួលបន្ទុកវិភាគឯកសារផ្សេងៗដែលរឹបអូសបានពីវៀតកុង និងរបាយការណ៍ស្ទួរចម្លើយទាំងឡាយ ។ តាមបណ្តាញសម្ងាត់របស់គាត់នៅមន្ទីរបញ្ចកោណ គាត់បានដឹងដំណឹងស្តីពីការធ្វើឲ្យមានប្រក្រតីភាព ដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ហើយគាត់បានដាក់បេក្ខភាពនឹងគេ ។ ប៉ុន្តែ តាមធម្មតាអ្នកស្ម័គ្រចិត្តមិនមានច្រើនគ្នាទេ ។ ក្រុងហាណូយក៏មិននិយាយពីរឿងលុយកាក់ដែរ ។ សហការីម្នាក់របស់លោក ស៊្ទីវ លីន បានអង្វរគាត់នៅត្រង់កន្លែងបត់នៃរបៀងផ្លូវមួយនៅទីស្តីការក្រសួងការបរទេស “ខ្ញុំឮគេនិយាយថា លោកកំពុងស្វែងរកមនុស្សទៅធ្វើការនៅក្រុងហាណូយ ។ ស៊្ទីវ ខ្ញុំសូមអង្វរសូមលោកធ្វើហាក់ដូចជាមិនដែលឮគេនិយាយពីខ្ញុំទៅចុះ” ។

ឥឡូវនេះ វានៅតែធ្វើឲ្យសាធារណមតិនិងសភាជាន់ទាបយល់ព្រមចំពោះការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមប៉ុណ្ណោះ ។ ការស្ទាបស្ទង់មតិបានសម្តែងឲ្យឃើញនូវការពេញចិត្តច្រើនគួរសម ។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៨ គឺពីរថ្ងៃក្រោយពេលដែល ថាច់ បដិសេធមិននិយាយពីជំនួយផ្នែកសេដ្ឋកិច្ចជាមុនក្នុងការធ្វើឲ្យមានប្រក្រតីភាព ហ្វូដឌីង ខាធ័រ អនុរដ្ឋមន្ត្រីក្រសួងកិច្ចការសាធារណៈបានបញ្ជូនទៅឲ្យ ហូលប្រ៊ុក នូវសេចក្តីសន្និដ្ឋាននៃការធ្វើអង្កេតមតិសាធារណជនមួយដែលសម្រេចធ្វើឡើងដោយបណ្តាញទូរទស្សន៍ *N.B.C. News* ៖ «មតិភាគច្រើនមួយជាគុណប្រយោជន៍ដល់ការទទួលស្គាល់[ប្រទេសវៀតណាម] អាចនឹងថមថយទៅវិញ លុះត្រាតែ«ការធ្វើឲ្យមានប្រក្រតីភាព» នេះមិនរួមបញ្ចូលការផ្តល់ជំនួយហិរញ្ញវត្ថុដ៏ច្រើនមួយ ។ ប៉ុន្តែ ព្រំដែននៃជំនួយនេះបានត្រូវបញ្ជាក់ដោយជាក់លាក់ ហើយម្យ៉ាងទៀត សាធារណជនយល់ឃើញថា វៀតណាមបានធ្វើការប្រឹងប្រែងយ៉ាងខ្លាំងដើម្បីផ្តល់នូវការបំភ្លឺអំពីទាហានអាមេរិកដែលបាត់ខ្លួនក្នុងការប្រយុទ្ធ» ។

មុននឹងតតាំងនឹងសមាជិកល្បីៗនៃសភាជាន់ទាប ហូលប្រ៊ុក បានឲ្យក្រុមការងារក្នុងក្រសួងរបស់គាត់រៀបចំរបាយការណ៍មួយ ដែលពន្យល់វែកញែកយ៉ាងជាក់លាក់ពីកាលានុវត្តភាព(ភាពគួរដល់កាល) នៃការធ្វើឲ្យមានប្រក្រតីភាព ។ ឯកសារនេះមានចំណងជើងថា *ការបង្កើតទំនាក់ទំនងការទូតឡើងវិញជាមួយប្រទេសវៀតណាម ៖ អាទិភាពមួយដែលត្រូវធ្វើមុនគេ* បានគូសបញ្ជាក់ថា ប្រទេសនេះមុខជាក្លាយទៅជារណរង្គនៃការប្រយុទ្ធមួយរវាងសហភាពសូវៀតនិងប្រទេសចិន ពួកសូវៀតបានបង្កើនវត្តមានរបស់គេនៅទីនោះនិងបានពង្រឹងការគាំទ្ររបស់គេចំពោះវៀតណាមនៅក្នុងជម្លោះជាមួយកម្ពុជា ។ «វត្តមានមួយរបស់អាមេរិកាំងនៅក្រុងហាណូយ អាចឲ្យយើងដឹងព័ត៌មានកាន់តែប្រសើរពីការវិវត្តន៍នៃការប្រកួតប្រជែងរវាងចិន-សូវៀត និងផ្តល់ដល់ពួកមេដឹកនាំវៀតណាមនូវការជ្រើសរើសដ៏ជាក់លាក់មួយ ដើម្បីឈរក្នុងជួរមហាអំណាចកុម្មុយនីស្តមួយឬមួយទៀត» ។ ដរាបណាមិនទាន់បានបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម «សហរដ្ឋអាមេរិកនឹងមិនបង្កើតឲ្យមានអំណាចណាមួយនៅក្នុងប្រទេសនេះទេ ហើយនឹងទទួលព័ត៌មានមិនល្អពីអ្វីដែលកើតមាន ឬមុខជានឹងកើតមាន» ។ ការដាក់ស្ថានទូតមួយនៅក្រុងហាណូយ«នឹងមានភាពកាន់តែងាយស្រួល [ដើម្បីទទួលព័ត៌មានផ្សេងៗស្តីពីទាហានអាមេរិកបាត់ខ្លួនក្នុងការប្រយុទ្ធ] ជាងការទាក់ទងបន្ទាប់បន្សំ ដូចពួកគេបានទទួលបច្ចុប្បន្ននៅទីក្រុងបាងកក ឬនៅក្រុងប៉ារីស ឬការជួបគ្នាដោយកាលៈទេសៈដូចដែលអ្នកទទួលខុសត្រូវខ្លះនៃរដ្ឋាភិបាល ឬសមាជិកខ្លះនៃសភាជាន់ទាបអាចធ្វើបាន» ។ នៅទីបំផុត ក្រុមអ្នកធ្វើការនៅស្ថានទូត នឹងអាចជួយសហគ្រាសទាំងឡាយរបស់អាមេរិកាំងឲ្យប្រឈមមុខទល់នឹងការប្រកួតប្រជែងរបស់ក្រុមហ៊ុនបរទេសផ្សេងៗទៀត ។

ក្នុងពេលជាមួយគ្នានោះ ក្រុមការងារដែលទទួលបន្ទុកពិនិត្យទម្រង់អនុវត្តទាំងឡាយនៃប្រតិបត្តិការ

បានពើបប្រទះនឹងឧបសគ្គជាច្រើន ។ អ្នកខ្លះគ្រាន់តែដឹងថាអ្វីទៅដែលដូចអតីតស្ថានកុងស៊ុលអាមេរិកនៅក្រុងហាណូយ? វរសេនីយ៍ឯក ម៉ៃខឹល អីឡេន នៃការិយាល័យកិច្ចការនយោបាយយោធានៅក្រសួងការបរទេស បានមានឱកាសថតអគារនោះកាលពីពីរខែមុនពេលដែលគាត់រួមដំណើរជាមួយគណៈប្រតិភូមួយនៃសភាជាន់ទាបទៅធ្វើទស្សនកិច្ចនៅទីក្រុងហាណូយ ។ គាត់មិនពិបាកបន្តិចសោះឡើយក្នុងការរកទីតាំងស្ថានកុងស៊ុល ដែលស្ថិតនៅតាមដងវិថីហាយបាទ្រុង ចំកណ្តាលទីក្រុង ។ “គឺជាអគារពណ៌បៃតងតែមួយគត់គឺពណ៌បៃតងដូចប្រាក់ដុល្លារអ៊ីចឹង” ។ បញ្ហាតែមួយគឺនៅពេលដែលគាត់ប្រុងប្រៀបថតវិមានប្រវត្តិសាស្ត្រនេះ ដែលទើបតែលាបពណ៌ឡើងវិញថ្មីៗ ដើម្បីបម្រើគោលបំណងអ្នកកាន់កាប់នៅពេលខាងមុខ ស្រាប់តែកងទ័ពវៀតណាមម្នាក់បានមកឈរពាំងពីមុខត្រង់ចន្លោះកណ្តាល ។ ដូច្នេះ ហ្វីលរូបថតមានលក្ខណៈព្រិលមិនច្បាស់ ប៉ុន្តែនេះជារូបថតតែមួយគត់ដែលក្រសួងការបរទេសមាន ។ ក្នុងស្ថានភាពនេះ វាពិបាកនឹងធ្វើគម្រោងការផ្សេងៗក្នុងការរៀបចំណាស់ ។ ដោយភ័ព្វល្អ មានមន្ត្រីម្នាក់បានរើរកឃើញប្លង់អគារនោះដែលគេកប់ចោលយូរមកហើយ ។ មីស្ហែល អូសេនបឺក បានដំណាលថា “ថ្ងៃមួយដែលខ្ញុំទៅកាន់ក្រសួងការបរទេស ខ្ញុំបានត្រូវធ្វើឲ្យភ្ញាក់ផ្អើលដែលរកឃើញឯកសារគួរឲ្យចាប់ចិត្តដ៏ក្រាស់មួយដុំ ដែលពួកគេបានរៀបចំស្តីពីបែបបទអនុវត្តទាំងឡាយក្នុងការធ្វើឲ្យមានប្រក្រតីភាព បញ្ហាផ្អាកសកម្មភាពផ្សេងៗរបស់វៀតណាមនៅសហរដ្ឋអាមេរិក, ការកំណត់ទីតាំងស្ថានទូត, ការប្រាស្រ័យទាក់ទងគ្នា និងបញ្ហាសេសសល់”[២៨] ។

ក្រសួងការបរទេសបានសម្រេចឲ្យ ដឹនីស ហាធ័រ ដែលជាសហការីម្នាក់របស់ អីឡេន នៅការិយាល័យកិច្ចការនយោបាយ ដែលចេះនិយាយភាសាវៀតណាមដូចគាត់ដែរឲ្យធ្វើដំណើរទៅក្រុងហាណូយនៅខែធ្នូ ដើម្បីចាប់ផ្តើមពិនិត្យមើលទីតាំងសម្រាប់សាងសង់ស្ថានទូតនិងផែនការរៀបចំមួយ ។

ប៉ុន្តែជាដំបូង ហាធ័រ បានទៅពិនិត្យពិច័យអគារផ្សេងៗនៃអតីតស្ថានទូតវៀតណាមខាងត្បូងនៅទីក្រុងវ៉ាស៊ីនតោនសិន មុននឹងប្រគល់ឲ្យក្រុងហាណូយប្រើប្រាស់ ។ នេះគឺការស្រាវជ្រាវតាំងពីដើមមកវិញ ។ កម្រាលព្រំសុទ្ធតែដុះផ្សិត ហើយរូបគំនូរដែលព្យួរនឹងជញ្ជាំងឡើងប្រេះបែកស្រកា ប៉ុន្តែបើពិនិត្យឲ្យល្អិតល្អន់អ្វីៗទាំងអស់ពុំមានផ្លាស់ប្តូរទេ តាំងពីការចាកចេញរបស់អ្នកការទូតវៀតណាមខាងត្បូងកាលពីខែមីនា ឆ្នាំ ១៩៧៥ ។ ទស្សនាវដ្តីថៃម និងញូវស៊ិច ចាស់ៗដែលរៀបរាប់ពីព្រឹត្តិការណ៍នៃការដួលរលំរបស់ក្រុងព្រៃនគរនៅរាត់រាយលើតុជាមួយចានគ្រិចជាច្រើន ដែលបញ្ជាក់ឲ្យដឹងពីការបរិភោគអាហារចុងក្រោយមួយ ។ ការិយាល័យទទួលបន្ទុកមើលខុសត្រូវអគារផ្សេងៗរបស់បរទេស (Bâtiments étrangers) បានបដិសេធមិនទទួលបន្ទុកធ្វើការជួសជុលដែលចាំបាច់ខានមិនបានទេ បើទុកជាមានការសន្យាដែលធ្វើជាមួយការិយាល័យនេះពីការសងប្រាក់នៅពេលខាងមុខក៏ដោយ ។ រួចមកហើយដែលការចំណាយសម្រាប់អសង្ហារិមកម្មរថយន្តផ្សេងៗរបស់អតីតស្ថានទូតត្រូវធ្លាក់មកលើការិយាល័យនេះ! ។

អ្វីៗទាំងនេះគ្មានបានប្រយោជន៍សោះឡើយ ។ ដោយមិនឲ្យក្រសួងការបរទេសដឹង សេតវិមានកំពុងតែតម្រូវឲ្យព្រឹត្តិការណ៍ផ្សេងៗប្រព្រឹត្តទៅតាមដំណើរមួយខុសគ្នាទាំងស្រុង ។

## ក្រុងវ៉ាស៊ីនតោនបច្ចាញពីគោលបំណងផ្សេងៗរបស់ចិន

នៅក្រោយពេលចប់ការសន្ទនាជាមួយ ថាច់ នារសៀលយប់ថ្ងៃទី២៧ ខែកញ្ញា ហូលប្រ៊ុក និងអេគីប របស់គាត់បានចាកចេញពីស្ថានគណៈបេសកកម្មរបស់វៀតណាម ហើយការបើកស្ថានទូតមួយរបស់អាមេរិកាំងទំនងជាពិត ។ ប៉ុន្តែ អ្នកខ្លះនៅតែសង្ស័យមិនអស់មិនហើយ ។ មីស្វែល អូសេនបឹក នឹកឃើញសម្តីដែលនិយាយទៅកាន់ ហូលប្រ៊ុក ថា “ឌីក (ជាឈ្មោះហៅក្រៅរបស់ ហូលប្រ៊ុក) វៀតណាមបានបោកបញ្ឆោតលោកគឺពួកគេចំអកឲ្យលោក” ។ ហូលប្រ៊ុក បានត្រូវធ្វើឲ្យភ្ញាក់ផ្អើលពីភាពស៊ិតស្វាញរបស់ ថាច់ ដែលខាំក្រាញនឹងការទាមទារជំនួយផ្នែកសេដ្ឋកិច្ចរបស់គាត់ : “ទាល់តែដល់នាទីចុងក្រោយ ទើបគាត់បោះបង់ការទាមទារជាអាទិភាពនេះក្រោមការឆាឆៅរំខានរបស់ហូលប្រ៊ុក ។ បន្ទាប់ពីនោះទៅ ថាច់ មានបំណងថាត្រូវរៀបចំឲ្យមានពិធីសារព្រមព្រៀងគ្នាមួយ ទោះបីជាគាត់ដឹងថានេះពុំមែនជាទំនៀមទម្លាប់ការទូតក៏ដោយ” ។ អូសេនបឹក បានត្រូវញ៉ាំងឲ្យជឿជាក់ថា វៀតណាមគ្រាន់តែបញ្ឆោតពិភពលោកប៉ុណ្ណោះ ហើយចង់បង្ហាញខ្លួនថាជាមេគំនិតនៃការធ្វើឲ្យមានប្រក្រតីភាព ប៉ុន្តែគ្មានបំណងធ្វើឲ្យចេញជាលទ្ធផលពិតប្រាកដទេ ។ តាមគាត់យល់ ភាពបន្តគ្នានៃព្រឹត្តិការណ៍ផ្សេងៗនៅសរទរដូវឆ្នាំ១៩៧៨បានទាញប្រទេសទាំងពីរទៅរកទិសផ្ទុយគ្នា ។ “ដៃទាំងពីរលូកទៅរកគ្នា ប៉ុន្តែប្រាកដណាស់ថាវានឹងមិនឈោងដល់គ្នាបានទេ”[២៩] ។

អូសេនបឹក មានបំណងបកស្រាយរឿងរ៉ាវឡើងវិញ បន្ទាប់ពីការប៉ះទង្គិចគ្នាមួយគ្ការមែនឬ? ឬមួយការដឹងហេតុមុនរបស់គាត់ទំនងជាផ្អែកទៅលើការដឹងថា គាត់មានអរិភាពនឹង ប្រ៊ីហ្សីនស្គី ចំពោះការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមទេដឹង? ពីព្រោះនៅទីបំផុត គាត់គ្មានសង្ស័យសោះឡើយថា នៅពេលនោះ ក្រុងហាណូយបានត្រៀមធ្វើពលិកម្មយ៉ាងច្រើនដើម្បីឈានទៅដល់កិច្ចព្រមព្រៀងមួយ ។ ការរាវែករបស់ ថាច់ ដូចដែល ហូលប្រ៊ុក យល់ធ្លុះពីរឿងនេះគឺគ្រាន់តែជាល្បិចកលមួយនិងជាការសាកល្បងចុងក្រោយមួយ ដើម្បីធ្វើឲ្យទទួលបានពីសហរដ្ឋអាមេរិកនូវការសន្យាផ្តល់ផ្នែកហិរញ្ញវត្ថុមួយប៉ុណ្ណោះ ។ វៀតណាមយល់ឃើញថា ពួកគេមិនអាចប្រទះគ្រោះថ្នាក់ធំដុំទេ បើគ្រាន់តែភាន់ច្រឡំបន្តិចបន្តួចនោះ ហើយពួកគេជឿថា កិច្ចព្រមព្រៀងនឹងសម្រេចចេញជារូបរាងឡើងភ្លាមបន្ទាប់ពីការបោះបង់មិននិយាយពីអាទិភាពនៃការផ្តល់ជំនួយជាមុនរបស់ខ្លួន ។

ហូលប្រ៊ុក គ្មានគំនិតទុទិដ្ឋិនិយមដូច អូសេនបឹក ទាល់តែសោះ ។ គាត់មិនបង្ហាញឲ្យឃើញថា ឧបសគ្គផ្សេងៗមិនសូវសំខាន់ទេ ប៉ុន្តែ គាត់ក៏មិនជឿថា ឧបសគ្គទាំងនោះមិនអាចពុះពារបានដែរ ។ ទស្សនៈរបស់

ប្រ៊ីហ្សិនស្គី មិនមែនថា គាត់មិនដឹងនោះទេ ។ ក៏ប៉ុន្តែ គាត់ព្រួយបារម្ភពីការចូលពាក់ព័ន្ធដោយថាហេតុក្នុងសង្គ្រាមព្រំដែនមួយ រវាងវៀតណាមនិងកម្ពុជាព្រោះតែមហាអំណាចនានា ។ មុនបន្តិចនៃការជួបរបស់គាត់ជាមួយ ថាច់ យន្តហោះឈ្លបយកការណ៍មួយរបស់អាមេរិកាំង ដែលកំពុងហោះហើរក្បែរឆ្នេរសមុទ្រភាគកណ្ដាលប្រទេសវៀតណាមបានចាប់បានការទាក់ទងគ្នាតាមវិទ្យុដែលបង្ហាញឲ្យដឹងថា កងទ័ពឆ្មើមរបស់វៀតណាមមួយកងពលធំកំពុងតែវាយបណ្ដាក់គ្នានៅតាមព្រំដែនរបស់កម្ពុជា ។ ការធ្វើចលនារបស់កងទ័ពត្រូវបានប្រកាសឲ្យដឹងជាសាធារណៈថា នៅទីនេះនិងទីនោះ ។ រ៉ាហ្វាអែល យុនហ៊្គីរិច ជាអ្នកឯកទេសដ៏ឆ្នើមលើសគេខាងបញ្ហាឥណ្ឌូចិន នៅក្នុងផ្នែកស៊ើបការណ៍សម្ងាត់នៃក្រសួងការបរទេសបាននិយាយទុកជាមុន នៅខែសីហាថា វៀតណាមនឹងមិនត្រូវការពេលវេលាប្រាំមួយខែដើម្បីផ្ដួលរំលំរបប ប៉ុល ពត ទេ[៣០] ។

ការខិតចូលជិតគ្នាច្បាស់លាស់បំផុតរវាងសូវៀត-វៀតណាម ដែលជាភ័ស្ដុតាងនៃការចូលជាសមាជិកអង្គការកូមេកុងក្នុងពេលថ្មីៗ បានរួមបង្កជាមូលហេតុព្រួយបារម្ភមួយទៀត ។ ហូលប្រ៊ុក បានបង្ហើបរឿងនេះប្រាប់ ថាច់ ដែរ ។ ថាច់ បានឆ្លើយប្រាប់គាត់វិញថា «ចេតនារបស់យើងចំពោះប្រទេសកម្ពុជាមានលក្ខណៈជាការការពារខ្លួនសុទ្ធសាធ ។ នេះជារឿងមួយដែលគួរទទួលយកបាន ហើយពួកអាមេរិកាំងត្រូវបានប្រាប់ឲ្យដឹងពីការឆ្មក់វាយប្រហាររបស់ខ្មែរក្រហម ដែលទើបមានថ្មីៗនៅម្ខាងទៀតនៃព្រំដែន ។ យុនហ៊្គីរិច បាននិយាយប្រាប់ខ្ញុំជាសម្ងាត់ថា «តាមការពិត ហូលប្រ៊ុក និងយើង ទាំងអស់គ្នាបានកាន់ជើងពួកវៀតណាមអំពីបញ្ហានេះរហូតដល់ចុងឆ្នាំ១៩៧៨, ថាអ៊ីចឹងទៅចុះ ។ វៀតណាមបានត្រូវខ្មែរក្រហមរំលោភបំពានទៅលើទឹកដីផ្ទាល់របស់គេ ក៏ដូចរំលោភពួកថៃដែរបើឱកាសហុចឲ្យ ។ សម្រាប់យើង ប៉ុល ពត គឺជាឆ្កែឆ្កួតមួយក្បាល ជាមនុស្សដែលគេមិនចូលចិត្តគ្រប់គ្នានៅក្នុងតំបន់ និងជាគំរូភេរវជនផង»[៣១] ។

វ៉ាន់ស៍ និង ហូលប្រ៊ុក គិតថា វត្តមានរបស់អាមេរិកាំងនៅក្នុងតំបន់ដ៏វឹកវរនេះនឹងដើរតួនាទីធ្វើឲ្យធូរស្រាលមួយ ។ គឺក្រោមទស្សនៈនេះហើយដែលអ្នកទាំងពីរមានបំណងធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតជាមួយប្រទេសចិននិងប្រទេសវៀតណាម ។ ដ្បិតអី បើសិនជាជម្លោះផ្ទៃក្នុងលទ្ធិកុម្មុយនីស្តរួមបង្កជាការគំរាមកំហែងមួយចំពោះស្ថិរភាពតំបន់ វាអាចជាឱកាសធ្វើឲ្យឥទ្ធិពលរបស់អាមេរិកាំងនៅអាស៊ីកម្រើកឡើងវិញដែរ ។ រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី លោក អេនឌ្រូ ភីខូក បានយល់ស្របនឹងទស្សនៈនេះទាំងស្រុង ។ ការប្រកាសឲ្យដឹងជាសាធារណៈនូវការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាម បានធ្វើឲ្យគាត់ពោរពេញទៅដោយការសប្បាយរីករាយយ៉ាងខ្លាំង បើទោះបីជាគាត់ជឿថា អាចនៅមានដំណើរវែងឆ្ងាយទៅមុខទៀតក៏ដោយ ។ ភីខូក បាននិយាយប្រាប់គេឯងថា «នៅពេលដែលព្រឹត្តិការណ៍ផ្សេងៗកើតមានឡើង ដូច្នេះខ្ញុំយល់ថា វាគួរដល់ពេលវេលាដែលបណ្ដាប្រទេសខ្លះ-ប្រទេសអូស្ត្រាលីជាឧទាហរណ៍ ប៉ុន្តែ ប្រទេសកាណាដា និង នូវ៉ែលហ្សេឡង់ដែរ-ត្រូវចាប់ផ្ដើមបន្តការសន្ទនាផ្នែកការទូតឡើងវិញជាមួយប្រទេសកម្ពុជាហើយ ដោយកុំភ្លេចប្រាប់ឲ្យ

ប្រទេសចិនដឹងពីគំនិតផ្ដួចផ្ដើមទាំងអស់ដែលនឹងត្រូវប្រកាន់យកទៅតាមទិសនេះផង ។ ខ្ញុំបានផ្ដល់គំនិតដល់ វ៉ាន់ស៍ និង ហូលប្រ៊ុក អំពីរឿងនេះ ព្រោះថាក្នុងនោះ ខ្ញុំមើលឃើញមធ្យោបាយបង្ការទុកជាមុននូវផលអវិជ្ជមាន ដែលអាចកើតមានដោយថាហេតុពីការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាមទៅលើទំនាក់ទំនង ផ្សេងៗរវាងប្រទេសចិន និងសហរដ្ឋអាមេរិក»[៣២] ។ ហូលប្រ៊ុក គ្មានរក្សាទុកអនុស្សាវរីយ៍ណាមួយក្នុងការ ជជែកពិភាក្សានេះទេ «ខ្ញុំមិនចាំអ៊ីទេគឺមានតែប៉ុណ្ណឹង ។ ប៉ុន្តែ ខ្ញុំពុំមានហេតុផលណាមួយធ្វើឲ្យសង្ស័យនូវអ៊ីដែល អេនទ្រូ បានអះអាងឡើយ»[៣៣] ។

នៅថ្ងៃទី២៧ ខែកញ្ញា ការសង្ខេបខ្លីៗនូវព្រឹត្តិការណ៍អន្តរជាតិទាំងឡាយ ដែលរៀបចំរៀងរាល់ថ្ងៃ ដោយក្រសួងការបរទេស ដើម្បីបម្រើគោលបំណងលោកប្រធានាធិបតី ពិតជាបានបញ្ចូលរបាយការណ៍ មួយស្ដីពីការជួបគ្នារវាង ហូលប្រ៊ុក និង ថាច់ ដែរ ។ របាយការណ៍នោះ មានអមទៅដោយកំណត់ខ្លីមួយ របស់ វ៉ាន់ស៍ ផង ដែលណែនាំដោយទទូចក្នុងការធ្វើឲ្យនូវទំនាក់ទំនងផ្នែក ការទូតជាមួយប្រទេសវៀតណាមមាន ប្រក្រតីភាពឆាប់រហ័ស ។ វាទំនងថា លោក ខាធ័រ បានជឿតាមគំនិតនេះរួចទៅហើយដោយហេតុថា នៅដើមខែ គាត់បានផ្ដល់ការបង្គាប់បញ្ជាឲ្យ ប្រ៊ីហ្សីនស្គី ប្រើគ្រប់លទ្ធភាពទាំងអស់ដើម្បីឈានទៅដល់«ការទទួលស្គាល់ ប្រទេសចិននិងប្រទេសវៀតណាមដំណាលគ្នា»[៣៤] ។

ប្រ៊ីហ្សីនស្គី បានបង្ហាញឲ្យឃើញការខ្វែងយោបល់របស់គាត់ជាមួយ វ៉ាន់ស៍ និង ហូលប្រ៊ុក ។ គាត់បាន ជំទាស់នឹងគម្រោង«បញ្ចូលប្រទេសវៀតណាមទៅក្នុងអភិក្រមនៃ[ការធ្វើឲ្យមានប្រក្រតីភាពចិននិងអាមេរិកាំង]» ។ ក្នុងយុទ្ធសាស្ត្រប្រឆាំងសូវៀតរួមរបស់ខ្លួន បញ្ហាផ្សេងៗក្នុងតំបន់បានដើរតួនាទីបន្ទាប់បន្សំមួយប៉ុណ្ណោះ ។ ការ ស្អប់ឈ្នានីសដែលមានរាប់សតវត្សមកហើយរវាងវៀតណាមនិងចិន ប្រហែលជាកន្លស់ចុងក្រោយរបស់គាត់ ។ គាត់វាយតម្លៃខុសពីការភ័យខ្លាចដែលប្រទេសចិនញុំាងឲ្យបណ្ដាប្រទេសជិតខាងរបស់ខ្លួនយកគំនិតធ្វើតាមនិង បដិសេធថា វៀតណាមព្រឺខ្លាចណាស់ចំពោះការរុលមកមុខមួយរបស់ចិនសំដៅមកទិសខាងត្បូង : «គ្មានអ៊ីអាច អះអាងពីគំនិតនេះឡើយ ទាំងតាមប្រវត្តិសាស្ត្រ ទាំងតាមយុទ្ធសាស្ត្រ» ។ តាមគាត់យល់ប្រទេសវៀតណាម គ្រាន់តែជា«អ្នកទទួលផលប្រយោជន៍ផ្សេងៗពីសហភាពសូវៀត»ប៉ុណ្ណោះ ហើយគាត់យល់ស្របនឹងការភ័យ ខ្លាចរបស់ប្រទេសចិនដែលឃើញប្រទេសវៀតណាមប្រែក្លាយទៅជាមូលដ្ឋានមួយរបស់សូវៀត ។ គាត់កត់ សម្គាល់ថា : «វ៉ាន់ស៍ និង ហូលប្រ៊ុក បានធ្វើយុទ្ធនាការជាគុណប្រយោជន៍ដល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយ ប្រទេសវៀតណាម ដែលតាមខ្ញុំយល់នេះជាការភាន់ច្រឡំមួយសុទ្ធសាធ ដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់ការខិត ចូលជិតគ្នាជាមួយប្រទេសចិន ជាពិសេសខាងផ្នែកយុទ្ធសាស្ត្រ» ។ ប្រ៊ីហ្សីនស្គី ចង់ប្រាស្រ័យការងារនឹង ហូលប្រ៊ុក ដែរ ។ «ខ្ញុំត្រូវធ្វើឲ្យជឿ ជាក់ថា ហូលប្រ៊ុក [ក្នុងឱកាសនៃការជួបគ្នានៅខែកញ្ញា ឆ្នាំ១៩៧៨ នាទីក្រុងញ៉ូវយ៉ក] គ្មានគោលបំណងអ៊ីក្រៅតែពីញុំាងឲ្យវៀតណាមបោះបង់ចោលសំណើសុំជំនួយផ្នែកសេដ្ឋកិច្ចរបស់គេប៉ុណ្ណោះ

ដើម្បីសម្រួលដល់ការធ្វើឲ្យមានប្រក្រតីភាព ហើយខ្ញុំរិះគន់មធ្យោបាយទាំងអស់របស់គាត់យ៉ាងខ្លាំង»[៣៥] ។

ប្រ៊ីហ្សីនស្គី នឹងពិភាក្សាជាមួយប្រធានាធិបតីពីភាពប៉ះទង្គិចដែលចៀសមិនផុត ក្នុងការសម្រេចចិត្តមួយបែបនោះ ហើយ វាន់ស៍ ដែលយល់ស្របតាមយោបល់របស់គាត់បានលើកការធ្វើឲ្យមានប្រក្រតីភាពជាមួយវៀតណាមទៅពេលក្រោយវិញ ។ ការបកស្រាយរបស់គាត់ពីព្រឹត្តិការណ៍ផ្សេងៗមានមកតាំងពីឆ្នាំ១៩៨១ ។ នៅកាលបរិច្ឆេទនេះ ប្រទេសវៀតណាមស្ទើរតែត្រូវថ្កោលទោសជាសាធារណៈពីបញ្ហាមនុស្សធម៌ទៅហើយ ។ ការកាន់កាប់ប្រទេសកម្ពុជាគឺជាអំពើដែលបានធ្វើជ្រុលទៅហើយមួយ ។ ប្រជាជនភៀសខ្លួនតាមទូករាប់ពាន់នាក់បានសាកល្បងរត់ចេញពីប្រទេស ។ តាមសម្ដីគាត់ដែលអួតខ្លួនថា គឺគាត់តែម្នាក់ឯងគត់ដែលធ្វើឲ្យបរាជ័យដល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងហាណូយ ។ គាត់ប្រហែលជាជឿពីអំណាចរបស់គាត់ជារដ្ឋបុរសម្នាក់ពិតមែន ។ ប៉ុន្តែក្នុងលំដាប់ទស្សនៈនេះ ឥស្សរជនម្នាក់ ទៀតក៏មានឋានៈអាចអួតខ្លួនបានដែរគឺ ឡេអូណារដ៍ វូដខូក ។ វូដខូក នេះឯងដែលជាអ្នកផ្ដើមដំណើរការធ្វើឲ្យមានប្រក្រតីភាពដោយដឹកនាំគណៈបេសកកម្មមួយរបស់ប្រធានាធិបតីទៅក្រុងហាណូយនៅនិទាឃរដូវឆ្នាំ១៩៧៧ ។

ក្នុងឋានៈជាប្រធានការិយាល័យទំនាក់ទំនងរបស់អាមេរិកាំងប្រចាំក្រុងប៉េកាំង គាត់មានបេសកកម្មចរចាស្វែងរកកិច្ចព្រមព្រៀងមួយក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន ។ ដូច្នេះ គេនឹកតែក្នុងចិត្តថា កម្រិតនៃការព្រួយបារម្ភរបស់គាត់ ប្រហែលជាផ្លាស់ប្ដូរយ៉ាងច្រើន តាំងពីការធ្វើដំណើររបស់គាត់ទៅទីក្រុងហាណូយ ។ ការចរចាជាមួយពួកចិន ដែលចាប់ផ្ដើមជាសម្ងាត់នៅខែកក្កដា នាទីក្រុងប៉េកាំង ពេលនោះគឺស្ថិតនៅក្នុងដំណាក់កាលប្រកបដោយគ្រោះថ្នាក់មួយ ។ វូដខូក អាចលុបបំបាត់ឧបសគ្គផ្សេងៗដែលនៅសល់ ហើយដែលត្រូវពុះពារឲ្យបាននៅក្នុងពិធីបរិភោគបាយមួយដែលផ្ដល់ជូនដោយរដ្ឋមន្ត្រីការបរទេសចិន ហួង ហួ នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៨ នាទីក្រុងញូវយ៉ក ។ ក្នុងឱកាសនោះ វ៉ាន់ស៍ ហូលប្រ៊ុក និង អូសេនបឺក បានរួមដំណើរជាមួយគាត់ដែរ ។ នៅយប់ដដែលនោះ លោក ហ្សុក ឃីនធីន បានរៀបចំនៅ Central Park កៀកនឹងស្ថានបេសកកម្មចិន នូវការដុតកាំជ្រួចប្លែកខុសគេមួយក្នុងចំណោមការដុតកាំជ្រួចប្លែកខុសគេរបស់គាត់ ។ ស្នូរនៃការផ្ទុះបានលាន់ឮទ្រហឹង ធ្វើឲ្យបង្អួចអគារនានាញ័ររណ្ដំ ។ បរិយាកាសដែលមានលាយការកំប្លែងនិងភ័យព្រួយនេះគឺវាត្រូវទៅតាមកាលៈទេសៈ ៖ ការជួបគ្នាបានប្រព្រឹត្តទៅប្រកបដោយលក្ខណៈដ៏រំដើបរំជួល ។ ហួងហួ បានរិះគន់ដោយត្រង់ៗគ្មានលាក់លៀម ។ គាត់បានតិះដៀល វ៉ាន់ស៍ យ៉ាងខ្លាំងពីការចចេសរបស់សហរដ្ឋអាមេរិកដែលរក្សាទំនាក់ទំនងការទូតជាមួយ តៃវ៉ាន់ និងលក់គ្រឿងសព្វាវុធទៅឲ្យទៀត ។ នៅម៉ោង១០យប់ គេគោងតែនឹកគិតទៅដល់អាហារពេលល្ងាច ។ ដោយរៀបចំយ៉ាងសម្រាំងនៅលើតុម្ហូបអាហាររបស់ចិនបានឡើងត្រជាក់អស់ ។ ហូលប្រ៊ុក បានរំឭកនៅនឹងមុខខ្ញុំពីភាពសោកសៅនៃការបរិភោគអាហារពេលល្ងាចដែលឡើងត្រជាក់មិនបេះចប់នេះ ។ «អីចឹងហើយ បានជាយើងពុំមានលទ្ធភាពងើបទៅមើលកាំជ្រួច ។ ហើយល្បិចទាំងនេះបានធ្វើឲ្យ

ព្យុះសូរសំឡេងគួរឲ្យខ្លាចយ៉ាងខ្លាំងដូចការបាញ់កាំភ្លើងត្បាល់ដែរ ។ គេនឹងសន្និដ្ឋានដូចនៅក្រុងព្រៃនគរក្នុងរយៈពេលមានសង្គ្រាមអ៊ីចឹង» ។

វ៉ូដខូក បានត្រូវធ្វើឲ្យអស់សង្ឃឹមគួរសម ។ ប៉ុន្តែ ពន្លឺនៃសេចក្តីសង្ឃឹមតូចមួយបានលេចឡើងព្រោះសហការីម្នាក់របស់ ហ្វូង បានមកជួបគាត់ជាសម្ងាត់ ដើម្បីស៊ើបសួរពីការធ្វើដំណើររបស់គាត់ទៅទីក្រុងប៉េកាំងវិញ ។ លើកនេះ គាត់ប្រាប្ធ្នាថា ម្តងនេះគេត្រូវព្រមព្រៀងគ្នាដោយគ្មានពន្យារពេលអំពីគោលការណ៍នៃការសន្ទនាជាហូរហែថ្មីមួយនៅក្នុងរដ្ឋធានីចិន ។ នេះប្រហែលជាការឲ្យសញ្ញាមួយហើយមើលទៅ ។ ដោយពិបាកនិយាយគ្នាជាមួយ វ៉ាន់ស៍ ពួកចិនប្រហែលជាសម្តែងឲ្យឃើញភាពឆាប់ស្រុះស្រួលជាមួយ វ៉ូដខូក ជាងដែលពួកគេដឹងថា គាត់ធ្វើការក្នុងក្រុមសហការីដ៏ជិតស្និទ្ធជាមួយ ខាធ័រ និង ប្រ៊ីហ្សីនស្គី ដែរ ។

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៨ ពេលដែល ខាធ័រ សួរគាត់នៅចំពោះមុខ ប្រ៊ីហ្សីនស្គីក្នុងការិយាល័យពងក្រពើនៃសេតវិមានថា តើគាត់ពេញចិត្តបន្តការប្រជុំដើម្បីចរចាជាមួយប្រទេសវៀតណាមឬទេ ចម្លើយរបស់គាត់គឺទេដាច់ខាត ។ វ៉ូដខូក បានពន្យល់ប្រាប់ប្រធានាធិបតីថា ក្នុងកាលៈទេសៈបច្ចុប្បន្ន ពួកគេ (វ៉ាន់ស៍ និង ហូលប្រ៊ុក) មានទឹកចិត្តធ្វើឲ្យបរាជ័យដល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិនតែម្តង ។ ពិតហើយការបង្ហាញដើមហេតុផ្ទាល់ខ្លួនរបស់គាត់មានលក្ខណៈច្បាស់លាស់ ៖ គាត់មិនចង់ប្រថុយធ្វើឲ្យមានអន្តរាយដល់បេសកកម្មដែលគេប្រគល់ឲ្យគាត់បំពេញនៅក្រុងប៉េកាំងឡើយ ។ ប៉ុន្តែ តើពួកចិនប្រកាសដោយជាក់លាក់ថា ខ្លួនប្រឆាំងនឹងការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាមដែរទេ? ។ វ៉ូដខូក បានសារភាពប្រាប់ខ្ញុំថា គាត់មិនដែលស្ទាបស្ទង់ពួកចិនពីចំណុចនេះឡើយ ដោយទុកឲ្យពួកភ្ញៀវអាមេរិកាំងខ្លះសួរពីរឿងនេះចុះ ។ ជួនកាលភ្ញៀវម្នាក់ក្នុងចំណោមច្រើននាក់បានសួរពួកចិនថា ៖ «តើលោកនឹងមានប្រតិកម្មបែបណាក្នុងលទ្ធភាពដែលយើងនឹងធ្វើឲ្យទំនាក់ទំនងរបស់យើងជាមួយប្រទេសវៀតណាមមានប្រក្រតីភាពឡើងវិញ? តាមធម្មតាចម្លើយគឺតែងតែប្រយ័ត្នប្រយែងជានិច្ច ប៉ុន្តែ គ្មានមេដឹកនាំចិនណាម្នាក់ សម្តែងឲ្យឃើញការប្រឆាំងដាច់អហង្ការឡើយ» ។ តាមការពិតបើ វ៉ូដខូក ភ័យខ្លាចប្រតិកម្មអវិជ្ជមានមួយនោះគឺគ្រាន់តែថាបញ្ហាមិនទាន់បានដោះស្រាយដោយជាក់លាក់ប៉ុណ្ណោះ ។ «ការចរចាជាមួយក្រុងប៉េកាំងបានផ្តើមនៅខែកក្កដា ហើយការសន្ទនារបស់ខ្ញុំជាមួយលោកប្រធានាធិបតីបានកើតមាននៅខែតុលា ។ ក្នុងរយៈពេលបីខែនេះ ដោយគ្មានពេលនិយាយពីប្រទេសវៀតណាមជាមួយពួកចិនទាល់តែសោះ ខ្ញុំអាចវាយតម្លៃរឿងនេះបន្តិចបន្តួចនៅពេលបច្ចុប្បន្នដែលយើងឈានដល់គោលដៅហើយ ព្រោះមិនចង់បង្កើតឲ្យមានការមន្ទិលសង្ស័យមកលើសុឆន្ទៈរបស់យើង»[៣៦] ។

ការបកស្រាយពីរដែលផ្ទុយគ្នាស្រឡះអំពីឥរិយាបថរបស់ចិន បានធ្វើឲ្យរដ្ឋាភិបាលអាមេរិកាំង បែកបាក់ជាពីរដែរ ៖ ម្ខាងគឺការបកស្រាយរបស់ ប្រ៊ីហ្សីនស្គី-វ៉ូដខូក ហើយម្ខាងទៀតគឺការបកស្រាយរបស់ ហូលប្រ៊ុក ។ ហូលប្រ៊ុក បានរៀបរាប់ប្រាប់ខ្ញុំថា ៖ «ខ្ញុំនៅនឹកឃើញដោយពេញលេញនូវសម្តីសន្ទនារបស់ពួកចិនក្នុងឱកាស

មហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៧៨ ៖ «ការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាម មិនទាក់ទងនឹងយើងទេ សូមលោកបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសណា ដែលលោកចង់ចុះ» ។ មនុស្សគ្រប់គ្នាយល់ថា វៀតណាមពុំមែនត្រេកអរទេ ប៉ុន្តែ ពួកគេសុខចិត្តខាំមាត់សង្កត់ចិត្ត (ព្រោះចៀសមិនរួច)»[៣៧] ។ លោក ខាធ័រ យល់ស្របតាមយោបល់របស់ ប្រ៊ីហ្សីនស្គី និង វូដខុក ។ គាត់យល់ឃើញថា «បញ្ហាចិនមានសារសំខាន់ជាសារវន្ត» ហើយគាត់បានសម្រេចថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមនឹងកើតមានបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រទេសចិនរួចហើយ[៣៨] ។

សេចក្តីសម្រេចរបស់ប្រធានាធិបតីនៅថ្ងៃទី១១ ខែតុលានេះ ស្ថិតនៅជារឿងសម្ងាត់បំផុត ។ នៅក្រសួងការបរទេស កម្រមានអ្នកដែលត្រូវដឹងពីរឿងសម្ងាត់នេះណាស់ ពេលដែលគេចាប់ផ្តើមធ្វើការរៀបចំប្រុងប្រៀបបើកស្ថានទូតអាមេរិកាំងនៅទីក្រុងហាណូយ ។ ហូលប្រ៊ុក និងបណ្តាសហការីជិតស្និទ្ធរបស់គាត់ផ្ទាល់ក៏មិនត្រូវបានប្រាប់ឲ្យដឹងពីមូលហេតុពិតប្រាកដនៃការលើកពេលនេះដែរ ប្រហែលដើម្បីចៀសវាងការប្រឈមមុខថ្មីមួយរវាង វ៉ាន់ស៍ និង ប្រ៊ីហ្សីនស្គី ហើយមើលទៅ ។ គេបានសាកល្បងធ្វើឲ្យគាត់ជឿថា គឺការពិនិត្យពិច័យអំពីនយោបាយក្នុងប្រទេសតែម្យ៉ាងប៉ុណ្ណោះ អាចប្រាប់ហេតុផលពីការសម្រេចចិត្តនេះ ៖ មួយខែមុនការបោះឆ្នោត ការសម្តែងនូវសមានចិត្តខ្លាំងពេកចំពោះប្រទេសវៀតណាមមុខជានឹងបណ្តាលឲ្យខូចខាតដល់ការបោះឆ្នោតជ្រើសរើសសមាជិកសភាជាន់ទាបមួយចំនួនធំឡើងវិញ ។ អ្នកជិតដិតនឹង ហូលប្រ៊ុក ម្នាក់បានកត់សម្គាល់ថា ៖ «ចាប់តាំងពីថ្ងៃទី២៧ ខែកញ្ញា ការបង្គាប់បញ្ជាផ្សេងៗរបស់សេតវិមានបានប្រែទៅជាច្បាស់លាស់ទាំងស្រុង ៖ គ្មានការធ្វើឲ្យមានប្រក្រតីភាពមុនការបោះឆ្នោតទេ»[៣៩] ។

## ហូលប្រ៊ុក ការពារតំណែងរបស់គាត់

នៅការិយាល័យទទួលបន្ទុកកិច្ចការអាស៊ីខាងកើត ពាក្យចចាមអារ៉ាមបានចាប់ផ្តើមលេចព្ធុសុសសាយទោះបីជាមានការប្រុងប្រយ័ត្នមិនឲ្យធ្លាយចេញក៏ដោយ ក៏ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរនៅឡើយ ។ ភាពតានតឹងបានកើនឡើងរវាងផ្នែកទទួលបន្ទុកកិច្ចការខាងវៀតណាមនិងខាងចិន ហើយផ្នែកខាងចិនកំពុងសម្របតាមជំហរភាគច្រើនរបស់ ប្រ៊ីហ្សីនស្គី ។ ប៉ុន្តែ គេត្រូវការឲ្យមានកូនខ្យល់ព្យុះមួយផ្ទុះឡើង-បន្ទាប់ពីមានសេចក្តីសម្រេចខ្វះៗដែលកំណត់ឲ្យ ហូលប្រ៊ុក ក្នុងឱកាសនៃការស្នាក់អាស្រ័យមួយនៅទីក្រុងបាងកក-ដើម្បីនឹងឲ្យការសម្រេចចិត្តរបស់សេតវិមាន ត្រូវបានដឹងព្ធទៅដល់មនុស្សគ្រប់គ្នា ។ ការចាប់ផ្តើមដំណើរការកិច្ចការនេះបានមានឡើងព្រមគ្នាជាមួយការបញ្ជូនជាសម្ងាត់ទៅឲ្យវៀតណាមនូវអ្វីដែលគេហៅថា អាទិភាពថ្មីក្នុងការធ្វើឲ្យមានប្រក្រតីភាពយ៉ាងគួរឲ្យឆ្ងល់ ព្រោះលើកនេះ អាមេរិកាំងជាអ្នកដាក់លក្ខខណ្ឌម្តង ។

*រ៉ូបឺត អូកលី បានធ្វើដំណើរទៅក្រុងញ៉ូវយកពីរលើក ដើម្បីពិភាក្សាជាមួយវៀតណាម ។ ក្រុមការងារដែលបង្កើតឡើងសម្រាប់ពិនិត្យមើលដោយល្អិតល្អន់នូវបញ្ហាផ្សេងៗ ដែលចោទឡើងដោយការបើកស្ថានទូតបានធ្វើការយ៉ាងសកម្ម ។ ក្នុងឱកាសនៃការជួបគ្នាលើកចុងក្រោយរបស់គាត់នៅថ្ងៃទី១៧ ខែតុលា អូកលី បានសម្គាល់ឃើញ ង្វៀន កូថាច់ អន្ទះអន្ទែងយ៉ាងខ្លាំង ។ ថាច់ រំអុកគាត់ថា "ប្រញាប់ឡើង! យើងចង់ដោះស្រាយបញ្ហានេះភ្លាមតែម្តង" ។ អូកលី បានពន្យារពេលដោយយកលេសថា ជាបឋមគាត់ត្រូវការពិនិត្យភាគល្អិតល្អន់ទាំងអស់ឲ្យស្រេចជាមុនសិន ។*

*ប៉ុន្តែ នៅថ្ងៃទី៣០ ខែតុលា ការយល់ទាស់ផ្សេងៗនិងសេចក្តីស្នើដែលគាត់ត្រូវទទួលភារៈបង្ហាញជូនដល់ត្រាន់ ក្វាងកូ គឺមានភាពខុសគ្នាទាំងស្រុង ។ មុននឹងចាប់ផ្តើមចរចាទៅមុខទៀត ពួកអាមេរិកាំងបានតម្រូវនៅពេលនេះថា វៀតណាមត្រូវពិនិត្យឡើងវិញនូវជំហររបស់ខ្លួនលើបីចំណុច ៖ បញ្ហាប្រទេសកម្ពុជា បញ្ហាទំនាក់ទំនងសូវៀត-វៀតណាម និងបញ្ហាជនភៀសខ្លួនតាមទូក ។ ពីរ-បីឆ្នាំក្រោយមក ផាំ បិញ អ្នកការទូតជាន់ខ្ពស់វៀតណាមម្នាក់បានធ្វើពើជាសួរថា "ហេតុអ្វីបានជាមានលក្ខខណ្ឌថ្មីទាំងនេះ? ។ ពីព្រោះថា តាំងពីខែខសភា ឆ្នាំ១៩៧៨ [ជាកាលបរិច្ឆេទនៃទស្សនកិច្ចរបស់ ប្រ៊ីហ្សីនស្គី នៅក្រុងប៉េកាំង] ពួកចិនបានសម្រេចចិត្តប្រកាន់នយោបាយអមិត្តមួយចំពោះប្រទេសវៀតណាម ហើយថាពួកអាមេរិកាំងបានចូលដៃខាងចិនទៀតផង"[៤០] ។*

*អ្វីដែល បិញ មិនបាននិយាយគឺថា ការឃុបឃិតរវាងសូវៀត-វៀតណាម មានភាពដូចគ្នានឹងការឃុបឃិតរវាងអាមេរិកាំង-ចិនដែរ ។ នៅព្រឹកថ្ងៃទី៣០ ខែតុលា (ត្រូវនឹងថ្ងៃទី២៩ ល្ងាចនៅក្រុងវ៉ាស៊ីនតោន) យន្តហោះ អ៊ីលីយូឈីន៦២ មួយគ្រឿងរបស់សូវៀតបានហោះឡើងពីអាកាសយានដ្ឋាន ណយ បៃ នៅក្រុងហាណូយ ដោយមានផ្ទុកមេដឹកនាំជាន់ខ្ពស់វៀតណាមជាច្រើនរូប[៤១] ។*

*មេដឹកនាំទាំងនោះ ប្រាកដជាសមាជិកការិយាល័យនយោបាយចំនួនពាក់កណ្តាលដែលអមដំណើរអគ្គលេខាបក្ស ឡេ យន់ ឆ្ពោះទៅក្រុងមូស្គូ ជាទីដែលគាត់នឹងចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយសំដៅបង្ការប្រតិកម្មមួយរបស់ចិន ដែលទំនងជាពិតក្នុងពេលដែលវៀតណាមធ្វើការវាយប្រហារប្រទេសកម្ពុជា ។ នៅទីក្រុងញូវយ៉ក ថាច់ បានរង់ចាំដោយអត់ធ្មត់ថា នៅទីបំផុត ពួកអាមេរិកាំងមុខជាសម្រេចចិត្តចុះហត្ថលេខាលើកិច្ចព្រមព្រៀងធ្វើឲ្យមានប្រក្រតីភាពមិនខាន ។ ក្នុងរយៈពេលមួយខែ ថាច់ ដែលត្រូវធ្វើឲ្យនឿយណាយបានឡើងយន្តហោះទៅកាន់ក្រុងមូស្គូម្តងទៀត ដោយឆ្លងកាត់តាមទីក្រុងប៉ារីស ។ ក្នុងរដ្ឋធានីរបស់សូវៀត នៅថ្ងៃទី៣ ខែវិច្ឆិកា គាត់បានចូលរួមពិធីមួយដែលរៀបចំឡើងក្នុងឱកាសនៃការចុះហត្ថលេខាសន្ធិសញ្ញាសូវៀត-វៀតណាម ។ ក្រុងហាណូយពុំអាចសម្រេចទទួលបានការទទួលស្គាល់ផ្នែកការទូតមួយរបស់អាមេរិកាំង ដែលត្រូវធ្វើជាអាទិ៍មុនការធ្វើសហប្រតិបត្តិខាងយោធាជាមួយពួកសូវៀតឡើយ ។*

*គេអាចផ្តល់ងសួរថា តើការប្តូរគំនិតភ្លាមៗរបស់ពួកអាមេរិកាំងជាផលនៃការរកឃើញរបស់គេអំពី*

ការប្រុងប្រៀបចុះហត្ថលេខាលើសន្ធិសញ្ញាវវាងសូវៀត-វៀតណាមមែនឬ? ពិតហើយ នៅថ្ងៃទី២៧ ខែតុលា ក្រុងហាណូយបានប្រកាសជាសាធារណៈថា ឡេ យន់ និង ផាំ វ៉ាន់ដុង នឹងធ្វើដំណើរទៅទស្សនកិច្ចជាផ្លូវការនៅទីក្រុងមូស្គូក្នុង«អនាគតឆាប់ៗខាងមុខ» ។ ប៉ុន្តែគេយល់ធ្លុះថានៅពេលនោះពួកគេនឹងចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ហើយនៅមានមួយជំហានទៀតដែលប្រហែលគ្មានអ្នកណាម្នាក់អាចសម្រេចបានទេ ។

ពិតហើយ ក្រសួងការបរទេសបានប្រឹងប្រែងបង្ហាញភស្តុតាងអំពីបរាជ័យនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមក្នុងកាលខាងក្រោយមកទៀត ។ តាមគេជឿថា ការបង្កើតទំនាក់ទំនងការទូត អាចធ្វើទៅបានបន្ទាប់ពីការចុះហត្ថលេខាលើសន្ធិសញ្ញាសូវៀត-វៀតណាម ការលុកលុយប្រទេសកម្ពុជា និងការបង្ហាញឲ្យដឹងពីរឿងជនភៀសខ្លួនតាមទូក ។ ការបកស្រាយនេះ ពុំគិតដល់អ្វីឡើយបើប្រៀបធៀបនឹងកាលប្បវត្តិឡើយ ។ ហេតុការណ៍សំខាន់ដំបូងពីរ ពិតជាកើតមានក្រោយថ្ងៃទី១១ ខែតុលា ជាកាលបរិច្ឆេទដែល ខាធ័រ ប្រកាន់យកការសម្រេចចិត្តរបស់គាត់ ។ ចំណែកការចាកចោលស្រុកទាំងហ្វូងៗនៃជនភៀសខ្លួនតាមទូកបានស្ថិតក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ខ្លាំងពិតប្រាកដ តែក្នុងរយៈពេលនៃរដូវក្តៅឆ្នាំ១៩៧៩ប៉ុណ្ណោះ[៤២] ។

ក្នុងការធ្វើសម្ភាសន៍ជាបន្តបន្ទាប់ដែលគាត់អនុញ្ញាតឲ្យខ្ញុំជួប ហូលប្រ៊ុក បានអះអាងជាច្រើនលើកច្រើនសាថា គ្មានពេលណាមួយដែលគាត់សម្រេចចិត្តពន្យារពេលការធ្វើឲ្យមានប្រក្រតីភាពដោយជាក់លាក់ឡើយ ។ ការអះអាងនេះ មានសភាពផ្ទុយគ្នាយ៉ាងពិតប្រាកដនឹងសក្ខីកម្មរបស់ ប្រ៊ីហ្សីនស្គី របស់ វ៉ូដខុក ហើយបើនិយាយឲ្យចំគឺរបស់លោក ខាធ័រ ផ្ទាល់ ។ តាមគាត់ថា ប្រទេសចិនពុំមានទំនាក់ទំនងណាមួយក្នុងរឿងនេះទេ ៖ «មនុស្សច្រើនណាស់ជឿថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម បានត្រូវលះបង់ដើម្បីជាគុណប្រយោជន៍ដល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន ។ តាមការពិតគឺ វៀតណាមផ្ទាល់ ដែលបង្កើតឲ្យមានស្ថានភាពមួយបែបនេះ រហូតទាល់តែពួកគេលែងមានលទ្ធភាពចូលរួមតទៅមុខទៀត» ។ ដូច្នេះ ការពន្យារពេលនឹងត្រូវបកស្រាយដោយហេតុផលបីយ៉ាង ៖ «ទីមួយ រឿងជនភៀសខ្លួនតាមទូក, ទីពីរ ព័ត៌មានផ្សេងៗដែលយើងមានស្តីពីការរៀបចំប្រុងប្រៀបធ្វើការលុកលុយប្រទេសកម្ពុជា និងទីបី ការបោះឆ្នោតជ្រើសរើសសភាជាន់ទាប»[៤៣] ។

តាមការពិត ភាពជួនគ្នានៃការបោះឆ្នោតនិងការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម -បញ្ហាដែលត្រូវជជែកគ្នាក្នុងកម្រិតខ្ពស់បំផុត- គឺជារឿងដែលធ្វើឲ្យតឹងចិត្ត ។ ប៉ុន្តែរឿងនេះ ធ្លាប់បានបកស្រាយថាគ្រាន់តែជាការយឺតយ៉ាវបន្តិចបន្តួចប៉ុណ្ណោះ ពុំមែនជាការកាត់ផ្តាច់ទេ ។ ដូច្នេះ ហូលប្រ៊ុក បានអះអាងនូវទឡ្ហីករណ៍ពីរទៀត ។ រដ្ឋាភិបាលនឹងត្រូវធ្វើឲ្យព្រួយបារម្ភពីប្រតិកម្មផ្សេងៗរបស់សាធារណជន ក្នុងការបើកស្ថានទូតមួយនៅទីក្រុងហាណូយ ចំពេលដែលស្ថានីយ៍ទូរទស្សន៍នានាផ្សព្វផ្សាយពាសពេញប្រទេសនូវរូបភាពជនភៀសខ្លួនតាមទូកដែលកំពុងរត់ចេញពីប្រទេសវៀតណាម ។ រដ្ឋាភិបាលភ័យខ្លាចក្រែងមានការផ្ទុះចេញនូវ

ការតវ៉ាប្រឆាំងមួយ ។ បន្ថែមពីរឿងនេះ គឺអត្ថិភាពនៃរបាយការណ៍សម្ងាត់មួយស្ដីពីការរៀបចំប្រុងប្រៀបធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសកម្ពុជា ។ ប៉ុន្តែ ទស្សីករណ៍ទាំងអស់នេះ នឹងរឹតតែធ្វើឲ្យជឿជាក់ដោយមិនអាចប្រកែកបាន បើសិនជា ហូលប្រ៊ុក និងបណ្ដាសហការីគាត់នៅក្រសួងការបរទេសបន្តធ្វើការងារពេញរយៈពេលនៃខែតុលា ដោយធ្វើហាក់ដូចជាគ្មានអ្វីកើតឡើងសោះ ស្ដីពីការបើកស្ថានទូតអាមេរិកាំងនៅទីក្រុងហាណូយ ។

នៅសរទរដូវឆ្នាំ១៩៧៨ ឯកសារមួយដែលប្រើសម្រាប់ពន្យល់អំពីដំហររបស់ក្រសួងការបរទេស បានផ្ដល់នូវការបកស្រាយមួយខុសគ្នាទាំងស្រុងស្ដីពីការកាត់ផ្ដាច់ការពិភាក្សាជាមួយប្រទេសវៀតណាម ។ ចំណែក អូកលី វិញ ហៀបនឹងទទួលស្គាល់នៅចំពោះមុខខ្ញុំទៅហើយថា លក្ខខណ្ឌថ្មីៗដែលដាក់ឲ្យវៀតណាមពិនិត្យនៅថ្ងៃទី ៣០ ខែតុលា គ្រាន់តែជាលេសមួយសំដៅបិទបាំងការផ្លាស់ប្ដូរគំនិតភ្លាមៗរបស់អាមេរិកាំងប៉ុណ្ណោះ ។ នៅខែកញ្ញា ហូលប្រ៊ុក ធ្លាប់បានពិភាក្សារឿងទាំងបីនេះជាមួយ ថាច់ ដែរ ដោយមិនធ្វើឲ្យមានឧបសគ្គណាមួយដល់ការធ្វើឲ្យមានប្រក្រតីភាពទេ ។ ដូច្នេះ អ្នកណាមួយដែលផ្ដល់បញ្ហាបន្ថែមឲ្យមានការយល់ទាស់ថ្មីៗទៀត? ។ ដើម្បីការពារខ្លួនពីរឿងនេះ អូកលី បានប្រកែកថា ៖ «ពុំមានការបង្គាប់បញ្ជារបស់សេតវិមានទេ ។ ភ្លាមៗនោះ អូសេនបឺក ក៏រកពុំឃើញអ្វីៗដែលបានកើតឡើង ហើយបានបញ្ចុះបញ្ចូលប្រធានាធិបតីឲ្យផ្ដល់ទៅ វ៉ាន់ស៍ នូវសេចក្ដីបង្គាប់ថ្មីៗទៀត» ។ តាមការសន្និដ្ឋាន នេះហើយជាគំនិតរបស់គាត់និងគំនិតរបស់ ហូលប្រ៊ុក ។ «យើងមានបំណងប្រាប់វៀតណាមឲ្យដឹងពីមូលហេតុផ្សេងៗ ដែលនាំទៅដល់បរាជ័យនៃការចរចាដែរ»[៨៤] ។

ខ្ញុំបានសួរ ហូលប្រ៊ុក ថា នៅពេលណាដែលគាត់ប្រាប់ឲ្យវៀតណាមដឹងពីការសម្រេចចិត្តរបស់ ខាង៍រ? ។ ប៉ុន្តែវាទំនងជាពិតដែលថា ក្នុងឱកាសនៃការធ្វើដំណើររបស់គាត់នៅអាស៊ីអាគ្នេយ៍ គាត់បានលាតត្រដាងថារឿងរ៉ាវខ្លះមានដំណើរមិនល្អទេ ។ នៅថ្ងៃទី៣១ ខែតុលា ទីភ្នាក់ងារព័ត៌មាន យូ.ភី.អាយ និងកាសែត ណាស្យុង នៅក្រុងបាងកក បាននាំមកនិយាយនូវសម្ដីសន្ទនាខ្លះៗដែលគេសន្មតថាជារបស់គាត់ ដែលថាការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាមអាចកើតមានមុនរយៈពេលពីរខែ ។ ការតវ៉ាជាបន្តបន្ទាប់តាមទូរស័ព្ទដែលហៅមកគាត់ពីទីក្រុងវ៉ាស៊ីនតោន គឺជាប្រផ្នូលមិនល្អមួយ ។ ហូលប្រ៊ុក បានប្រកែកយ៉ាងខ្លាំងក្លា ប៉ុន្តែលក្ខណៈខាងក្រៅនៃរឿងរ៉ាវគឺសុទ្ធតែផ្ទុយនឹងគំនិតគាត់ ៖ ព័ត៌មានបានចាប់ផ្ដើមលេចឮសុសសាយបន្ទាប់ពីការជួបរបស់គាត់ជាមួយនាយករដ្ឋមន្ត្រីថៃ គ្រៀងសាក់ ឆូម៉ាណន្ទ មួយសប្ដាហ៍ ។ ដូច្នេះ ការវិនិច្ឆ័យបានលេចចេញជាពិសេសពីក្នុងចំណោមសហការីគាត់នៅក្រសួងការបរទេសថា គាត់ទំនងជាបាននិយាយគួរឲ្យមន្ទិលមែន ហើយថា ម្យ៉ាងទៀតគាត់អាចជាអ្នកមិនចេះលាក់អាថ៌កំបាំងតាំងពីដំបូងមកផង ។

ក្រោយមក ខ្ញុំមានឱកាសបានធ្វើសម្ភាសសាក្សីជាច្រើននាក់ ទាំងអាមេរិកាំង ទាំងថៃ។ វាបង្ហាញថា ហូលប្រ៊ុក ពុំបានកំណត់កាលបរិច្ឆេទណាមួយចំពោះការបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមឡើយ ។ ជាមួយនឹង អាប្រាម៉ូវីត ដែលជំនាន់នោះជាឯកអគ្គរដ្ឋទូតនៅប្រទេសថៃ គាត់បានជម្រាប គ្រៀងសាក់

ឲ្យដឹងពីខ្លឹមសារនៃការសន្ទនារបស់គាត់ជាមួយ ផាច់ កាលពីខែកញ្ញា ដោយមិនភ្លេចរៀបរាប់ប្រាប់ពីការបោះបង់របស់វៀតណាម ដែលចង់ឲ្យសងការខូចខាតដោយសារសង្គ្រាមជាមុនសិនមុននឹងភ្ជាប់ទំនាក់ទំនងការទូតឡើងវិញផង ។ ពួកមេដឹកនាំថៃ បានសន្និដ្ឋានពីរឿងនេះដោយសមហេតុផលថា ការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ គឺច្បាស់ជាកើតមានក្នុងពេលឆាប់ៗ ។ ប៉ុន្តែ ប្រទេសថៃក៏ដូចប្រទេសទាំងអស់នៃសមាគមអាស៊ានភ័យខ្លាចក្រែងថា ក្នុងការប្រញាប់ប្រញាល់របស់គាត់ ដើម្បីធ្វើឲ្យទំនាក់ទំនងអាមេរិកាំង-វៀតណាមមានប្រក្រតីភាព ហូលប្រ៊ុក មុខជាភ្លេចគិតបណ្ដាមិត្តចាស់ៗរបស់គាត់នៅអាស៊ីមិនខាន ។ ដូច្នេះ ពួកមេដឹកនាំប្រទេសទាំងនេះបានផ្ដួចផ្ដើមគំនិតផ្សព្វផ្សាយឲ្យដឹងឮតាមសារព័ត៌មាននូវសម្ដីសន្ទនារបស់ ហូលប្រ៊ុក ដោយបន្ថែមបន្ថយតិចតួចក្នុងក្ដីសង្ឃឹមរាំងរាការប្រព្រឹត្តទៅនៃប្រតិបត្តិការរបស់គាត់ ។ ក្នុងអត្ថបទរបស់កាសែតណាស្យុង បាននិយាយសើៗបែបជាឧទាហរណ៍ ពិតណាស់ដើម្បីបម្រើគោលបំណងប្រទេសចិនថា ការធ្វើឲ្យមានប្រក្រតីភាពអាមេរិកាំង-វៀតណាម "ទំនងជានឹងកើតមានមុន" ការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិននិងសហរដ្ឋអាមេរិក ។ ការលេចធ្លាយរឿងសម្ងាត់បានបណ្ដាលឲ្យមានលទ្ធផលដែលគេទុកចិត្តលើ ។ ការនិយាយបដិសេធរបស់សេតវិមាននិងក្រសួងការបរទេសបានកើតមានពីរឬបីម៉ោងក្រោយមក ។ ដោយធ្វើឲ្យ ហូលប្រ៊ុក អន់ចិត្តបន្តិចបន្តួច អ្នកនាំពាក្យរបស់ក្រសួងការបរទេស ហូឌីង ខាធ័រ បានប្រកាសថា "គ្មានសមាជិកណាម្នាក់របស់រដ្ឋាភិបាលអាមេរិកាំងអាចអះអាងបញ្ជាក់ពីរឿងមួយបែបនោះទេ" ។ គាត់បានបញ្ជាក់"ប្រកបដោយភាពម៉ឺងម៉ាត់ចុងក្រោយ"ថា ៈ "រដ្ឋាភិបាលអាមេរិកាំងមិនទាន់ឈានដល់ការសម្រេចចិត្តណាមួយអំពីកាលបរិច្ឆេទនៃការធ្វើឲ្យមានប្រក្រតីភាពជាយថាហេតុមួយឡើយ ។ រដ្ឋាភិបាលពុំទាន់ឈានដល់កិច្ចព្រមព្រៀងណាមួយទាំងការត្រូវរ៉ូវណាមួយជាមួយវៀតណាមទេ" ។ នេះពុំមែនជាការពិតទេ ប៉ុន្តែ ខ្លឹមសារត្រូវទទួលបានយ៉ាងច្បាស់លាស់បំផុត ។ ក្រុងប៉េកាំងត្រូវបានធ្វើឲ្យបាត់ភ័យព្រួយ ហើយបណ្ដាសម្ព័ន្ធមិត្តនៅអាស៊ីអាគ្នេយ៍ក៏អ៊ីចឹងដែរ ។

ប្រ៊ីហ្សីនស្គី បានខឹងដាច់ក្បាលដាច់កន្ទុយ នៅពេលដែលគាត់ដឹងពីពាក្យចចាមអារ៉ាមផ្សេងៗមានប្រភពមកពីក្រុងបាងកក ដែលតាមគាត់យល់គឺបំផុសឡើងដោយ ហូលប្រ៊ុក ។ ប៉ុន្តែ គាត់នៅមិនទាន់អស់ការងឿងឆ្ងល់របស់គាត់នៅឡើយទេ ។ ស្ថានីយលួចស្ដាប់របស់សេ.អ៊ី.អា. ដែលមានបន្ទុកធ្វើចារកិច្ចលើការទាក់ទងគ្នាតាមទូរស័ព្ទនៅខាងក្នុងខុបទ្វីបឥណ្ឌូចិនបានចាប់បានសារមួយនៅថ្ងៃទី៣១ ខែតុលា ដែលមានលក្ខណៈស្ទើរតែធ្វើឲ្យអាជីពរបស់ ហូលប្រ៊ុក វិនាសអន្តរាយទៅហើយ ។ អូសេនបឺក មានអាការៈមិនមាំងពេញរយៈពេលនៃការអានសេចក្ដីចម្លងប្រចាំថ្ងៃដែលថតបានដោយភ្នាក់ងារស៊ើបការណ៍របស់គាត់ ។ នោះគឺជាអត្ថបទបញ្ជូនមកពីចម្ងាយមួយជាភាសាវៀតណាម ដែលអ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានវៀតណាមនៅទីក្រុងវៀងច័ន្ទ បញ្ជូនទៅការិយាល័យរបស់ខ្លួននៅទីក្រុងហាណូយ ។ អ្នកកាសែតរូបនោះបានទាញហេតុសំអាងតាម"ឥស្សរជនអាមេរិកាំងម្នាក់"ថា បន្ទាប់ពីការបោះឆ្នោតខែវិច្ឆិកា "រដ្ឋាភិបាល ខាធ័រ ប្រហែលជាអាចធ្វើឲ្យទំនាក់ទំនងរបស់

ខ្លួនមានប្រក្រតីភាពជាមួយប្រទេសវៀតណាមដំណាលគ្នានឹងប្រទេសចិនដែរ ហើយចៀសវាងថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិនមិនធ្វើឲ្យគាំងដល់ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមឡើយ» ។ ប៉ុន្តែ លិខិតទូរលេខបានបញ្ជាក់ពី«ការកៀបសង្កត់ដែល ប្រ៊ីហ្សីនស្គី ធ្វើទៅលើអ្នកទទួលខុសត្រូវនៅក្រសួងការបរទេស ដើម្បីញ៉ាំងឲ្យពួកនោះបន្តធ្វើការទាក់ទាញចិត្តប្រទេសចិនតទៅទៀត ហើយពឹងផ្អែករឿងទាំងអស់នោះ ដើម្បីប្រឆាំងនឹងប្រទេសវៀតណាម» ។ លិខិតទូរលេខនោះមានបំណងដើម្បីបញ្ចប់«ការទទួលស្វាគមន៍យ៉ាងកក់ក្ដៅ» ដែលត្រៀមដោយ ហូលប្រ៊ូក សម្រាប់អ្នកតំណាងម្នាក់របស់ប្រទេសវៀតណាមក្នុងឱកាសនៃពិធីទទួលបដិសណ្ឋារកិច្ចមួយនៅទីក្រុងវៀងច័ន្ទដែរ ។ អ្នកការទូតអាមេរិកាំង«បានប្រាប់គូសន្ទនារបស់គាត់ជាមួយការសប្បាយរីករាយលេចចេញមកក្រៅថា គាត់ទើបនឹងបានជួបធ្វើការសន្ទនាជាមួយ ផ្ទៀន កូថាច់ ហើយថា សហការីម្នាក់ក្នុងចំណោមសហការីជាច្រើននាក់របស់គាត់នៅទីក្រុងញូវយ៉ក បានធ្វើការប្រាស្រ័យទាក់ទងជាប់ជាប្រចាំជាមួយ ថាច់ ដដែលនេះ» ។ គាត់បានសម្ដែងឲ្យឃើញ«សុទិដ្ឋិនិយមយ៉ាងខ្លាំងចំពោះទស្សនវិស័យផ្សេងៗក្នុងការធ្វើឲ្យទំនាក់ទំនងរវាងប្រទេសទាំងពីរមានប្រក្រតីភាពឡើងវិញ» ។ អ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានវៀតណាមបានបកស្រាយសម្ដីសន្ទនារបស់ ហូលប្រ៊ូក ថា ជាសារមួយនិងជា«កាយវិការប្រកបដោយមិត្តភាព»មួយ ដែលបញ្ជូនទៅកាន់ប្រទេសវៀតណាម ។ ក្នុងទីកមុខស្លេកស្លាំង អូសេនបឺក បានដាក់អត្ថបទនេះនៅលើតុធ្វើការរបស់ ប្រ៊ីហ្សីនស្គី ហើយស្នើឲ្យលោក ខាធ័រ បណ្ដេញ ហូលប្រ៊ូក ចេញពីការងារ ។

នៅពេលដែលការខកចិត្តញាំញីគាត់ ហូលប្រ៊ូក ត្រូវគេឃើញនៅក្នុងទីក្រុងឡាស្យូ (Lashio) ស្ថិតនៅតាមផ្លូវ *Burma Road* [ជាផ្លូវជាតិដ៏សំខាន់នៅប្រទេសភូមាភ្ជាប់ទីក្រុងរ៉ង់ហ្គូនទៅប្រទេសចិន] ដែលជាស្រុកមួយមានទេសភាពស្រស់ត្រកាល ប៉ុន្តែនៅដាច់ឆ្ងាយពីគេ ហើយជាមួយទីក្រុងនេះ ក្រសួងការបរទេសបានរក្សាការទាក់ទងផ្សេងៗដោយទៀងទាត់ ។ ស្ថានទូតអាមេរិកាំងនៅទីក្រុងរ៉ង់ហ្គូនបានវាយទូរលេខទៅឲ្យគាត់ជាបន្ទាន់ ដើម្បីប្រាប់ដំណឹងផ្សេងៗដែលចេញមកពីក្រុងបាងកក និងការបដិសេធរបស់ក្រុងវ៉ាស៊ីនតោន ។ ម្យ៉ាងទៀត វ៉ាន់ស៍ បានសាកសួរទៅកាន់ ហូលប្រ៊ូក អំពីខ្លឹមសារពិតប្រាកដនៃសេចក្ដីប្រកាសរបស់គាត់ដែរ ។ ប្រាកដមែន ហូលប្រ៊ូក បានបដិសេធការទទួលខុសត្រូវទាំងអស់ ។ ក្រោយមក គាត់មានឱកាសបកស្រាយពីរឿងនេះថា «នៅជំនាន់នោះ វាមានភាពតានតឹងយ៉ាងខ្លាំងរវាងក្រសួងការបរទេស និងសេតវិមាន ។ គេបានសាកល្បងធ្វើឲ្យខ្ញុំទទួលរងការទទួលខុសត្រូវទាំងអស់អំពីបរាជ័យមួយ ។ ក្នុងរឿងរ៉ាវទីមួយគឺ អាប្រាម៉ូវីត បានប្រកែកដាច់អហង្ការពីសេចក្ដីសម្រេចចិត្តផ្សេងៗ ដែលគាត់ចាត់ទុកថាជារបស់ខ្ញុំ ។ វ៉ាន់ស៍ បានជួយការពារខ្ញុំទៅកាន់លោក ខាធ័រ ហើយអ្វីៗត្រូវបានព្រមព្រៀងគ្នា ។ ក្នុងរឿងរ៉ាវទីពីរក្រុមសេ.អ៊ី.អា. បានធ្វើអង្កេតហើយបានសន្និដ្ឋានពីប្រតិបត្តិការផ្សព្វផ្សាយព័ត៌មានភូតកុហកមួយ ដែលទំនងជារបស់សូវៀត»[៤៥] ។ តាមការពិត ហូលប្រ៊ូក បានត្រូវឲ្យរួចពិរុទ្ធដោយអត្ថបទរបស់អ្នកកាសែតពីររូបគឺលោក រូវឡង់ អ៊ីវ៉ាន និង រូបឺត ណូវ៉ាក់ ដែលពន្យល់វែក

ញែកយ៉ាងច្បាស់ថា របាយការណ៍ផ្ទៃក្នុងរបស់ទីភ្នាក់ងារព័ត៌មានវៀតណាម គឺជាឧបាយមួយរបស់សូវៀត សំដៅធ្វើឲ្យទំនាក់ទំនងចិន-អាមេរិកាំង គាំងដំណើរ និងធ្វើឲ្យកើតមានការបែកបាក់គ្នាក្នុងរដ្ឋាភិបាល ខាធ័រ[៤៦] ។

តាម ហូលប្រ៊ុក ថា ការប្រសព្វគ្នានៃហេតុការណ៍ទាំងពីរនេះគឺ ហេតុការណ៍នៅទីក្រុងបាងកកនិងហេតុការណ៍នៅទីក្រុងវៀងច័ន្ទ មានលក្ខណៈជាការឃុបឃិតគ្នាបម្រុងបំផ្លាញនរណាម្នាក់ ។ គាត់និយាយថា «នោះគឺហាក់ដូចជានរណាម្នាក់ បានផ្ដើមធ្វើឲ្យខ្ញុំវិនាសតាមរបៀបជាក្បួន» ។ តាមការពិត បើសិនជាកើតមានការឃុបឃិតមែន គឺពុំមែនជាស្នាដៃរបស់មេគំនិតតែម្នាក់ទេ ។ ការលេចធ្លាយរឿងសម្ងាត់នៅក្រុងបាងកកបើតាម ហូលប្រ៊ុក ថាជា«សេចក្ដីដកស្រង់ដែលភ័ន្តច្រឡំ»ក្នុងគោលបំណងធ្វើឲ្យអន្តរាយដល់ការចរចាររវាងអាមេរិកាំង-វៀតណាម ដែលជារឿងបម្រើផលប្រយោជន៍របស់ប្រទេសថៃ និងប្រទេសចិននៅមុនការបោះឆ្នោតជ្រើសរើសសភាជាន់ទាបអាមេរិកាំង ។ ក៏ប៉ុន្តែ លិខិតទូរលេខរបស់ទីភ្នាក់ងារព័ត៌មានវៀតណាម គឺមានលក្ខណៈបំផុសបំផុលប្រឆាំងចិន ។ ម្យ៉ាងទៀត ទូរលេខមិនដែលផ្សាយឲ្យដឹងទាល់តែសោះនូវអ្វីដែលអាចឲ្យគេគិតថា លិខិតទូរលេខនេះគ្រាន់តែបញ្ជូនចេញ ដើម្បីឲ្យពួកអាមេរិកាំង ឬពួកចិនស្ទាក់ចាប់បានប៉ុណ្ណោះ ។ អ្វីដែលមានសារសំខាន់ក្នុងរឿងនេះ គឺការបំភ្លៃលក្ខណៈពិតនៃព័ត៌មានផ្សេងៗដែលបញ្ជូន ដោយទីភ្នាក់ងារព័ត៌មានវៀតណាម ។ វាជាក់ប្រាកដណាស់ដែលថា ហូលប្រ៊ុក បានជួបភារធារីរបស់វៀតណាមនៅទីក្រុងវៀងច័ន្ទ ក្នុងឱកាសនៃពិធីបដិសណ្ឋារកិច្ចមួយដែលផ្ដល់ដោយសមភាគីអាមេរិកាំងរបស់គាត់ ។ ហូលប្រ៊ុក ដំណាលថា «ខ្ញុំនិយាយពាក្យសួស្ដីទៅកាន់គាត់ ប៉ុន្តែ ខ្ញុំប្រាថ្នាថាចង់«លើកដៃជាសញ្ញាមិត្តភាពដ៏កក់ក្ដៅ»ទៅរកគាត់ទៀត ដែលនេះគឺជាការបន្ទុចទ្រង់ទ្រាយនៃការពិតមួយ» ។ ហូលប្រ៊ុក បានការពារខ្លួនយ៉ាងខ្លាំងក្លា ដែលបានរិះគន់បុគ្គលប្ដូរយោបាយស្និទ្ធចិនរបស់ ប្រ៊ីហ្សីនស្គី របៀបដូចដែលគាត់ត្រូវរដ្ឋាភិបាលស្ដីបន្ទោសដោយមិនចំពោះដែរ ។

វាមិនទំនងទាល់តែសោះដែលថា ហូលប្រ៊ុក បាននិយាយបែបនេះទៅកាន់អ្នកការទូតវៀតណាមម្នាក់ ទោះបីជាមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់គាត់ក៏ដោយ ។ ប៉ុន្តែ លិខិតទូរលេខរបស់ទីភ្នាក់ងារព័ត៌មានវៀតណាមពុំបានបញ្ជាក់ពី«ឥស្សរជនថ្នាក់ខ្ពស់របស់អាមេរិកាំង» ដែលជ្រើសរើសគូសន្ទនាវៀតណាមម្នាក់ ដើម្បីនិយាយប្រាប់រឿងលាក់កំបាំងរបស់ខ្លួនឡើយ ។ វាគ្រាន់តែជាបញ្ហានៃ «ការសន្ទនាគ្នាជាសម្ងាត់»មួយប៉ុណ្ណោះ ។ អ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានវៀតណាមនៅទីក្រុងវៀងច័ន្ទ ដាងគៀន មានឱកាសបានជួបជជែកគ្នាជាមួយពួកអាមេរិកាំង គឺសមាជិកសហគមន៍សាសនាប្រូតេស្តង់ ដែលកំពុងស្នាក់នៅក្នុងរដ្ឋធានីវៀងច័ន្ទជាញឹកញយ រួមទាំងជាមួយអ្នកកាសែតលោកខាងលិច ដែលធ្វើដំណើរឆ្លងកាត់តាមទីនោះម្ដងម្កាលផង ។ គាត់អាចស្វែងយល់ពីពួកគេ-លើកលែងតែវាពុំមែនជាប្រភពការទូត-នូវប្រវត្តិនៃការបែកបាក់គ្នារវាង ប្រ៊ីហ្សីនស្គី និង ហូលប្រ៊ុក ។ ម្យ៉ាងទៀត វៀតណាមមានហេតុផលខ្លះៗ ដែលធ្វើឲ្យរីករាយក្នុងចិត្តអំពី ការណ៍ដែលថា អ្នកការទូតម្នាក់ក្នុងចំណោមអ្នកការទូតរបស់ពួកគេ ត្រូវបានអញ្ជើញឲ្យទៅនិវេសនដ្ឋានរបស់ភារធារីអាមេរិកាំងដែល

*នឹងអាចពន្យល់នូវសេចក្តីរាយការណ៍ពោរពេញទៅដោយការសប្បាយចិត្តបន្តិចបន្តួចចំពោះព្រឹត្តិការណ៍នោះ ដែលផ្តល់ដោយអ្នកឆ្លើយឆ្លងនៃទីភ្នាក់ងារព័ត៌មានវៀតណាម ។ នៅទីបំផុត វាអាចថា លោក ហូលប្រ៊ូក-នៅទីក្រុងវៀងច័ន្ទ ក៏ដូចនៅទីក្រុងបាងកកពីមុន-ធ្លាប់បានរំពុកប្រកបដោយគំនិតសុទិដ្ឋិនិយមដ៏ជាក់លាក់មួយ អំពីទស្សនវិស័យនៃការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំង-វៀតណាមផងដែរ ។ ដូច្នេះការប៉ាន់ស្មានមុនមួយអំពីល្បិចកលរបស់សូវៀតមិនអាចធឹបចេញទាំងស្រុងទេ ព្រោះវាទំនងខ្លាំងណាស់ដែលថា លិខិតទូរលេខនេះពិតជាលិខិតទូរលេខរបស់អ្នកឆ្លើយឆ្លងព័ត៌មានក្នុងស្រុកម្នាក់ ដែលកំពុងបញ្ជូនដំណឹងទៅឲ្យពួកចៅហ្វាយនាយរបស់គាត់ ។ បើគិតឲ្យហ្មត់ចត់ទៅ លិខិតទូរលេខត្រូវបានបញ្ជូននៅថ្ងៃបន្ទាប់ពីការចេញដំណើររបស់ ហូលប្រ៊ូក ទៅកាន់ប្រទេសភូមា ។ តើមានអ៊ីធម្មតាជាងនេះ? ។ ប៉ុន្តែ បើពិនិត្យឲ្យជ្រៅជ្រះទៅចំណុចសំខាន់ពុំមែននៅត្រង់នោះទេ ។ ហួសពីការដោះស្រាយតាមផ្លូវគំនិត អំពីការឃុបឃិតបម្រុងក្បត់ជាយថាហេតុមួយ រឿងរ៉ាវនៅក្រុងបាងកកនិងក្រុងវៀងច័ន្ទបង្ហាញឲ្យឃើញ ជាពិសេសថា រហូតមកដល់ពេលនេះ ហូលប្រ៊ូក មិនដឹងអ៊ីទាំងអស់អំពីការបន្ថយសកម្មភាពក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ។*

*ហូលប្រ៊ូក បានរួចខ្លួនពីការភ័យទាំងប្រផុតប្រដើយ ។ មហន្តរាយផ្ទាល់ខ្លួនត្រូវបានចៀសវាងទាំងពិបាក ។ ក៏ប៉ុន្តែ ការប្រឡូកប៉ូកប៉ាករបស់គាត់ជាមួយ ប្រ៊ីហ្សឹនស្គី និង អូសេនបឺក បានបន្សល់ដានផ្សេងៗ ដែលមិនអាចលុបបាន ។ ការទាក់ទងគ្នារបស់អ្នកទាំងនោះ មិនដែលបោះបង់ចោលអាកប្បកិរិយាប្រើសម្តីតឹងតែងដាក់គ្នាទាល់តែសោះ ។ ការខំប្រឹងប្រែងទាំងអស់របស់គាត់តាំងពីពីរឆ្នាំមកហើយ ដើម្បីភ្ជាប់ទំនាក់ទំនងឡើងវិញជាមួយប្រទេសវៀតណាមបានត្រូវធ្វើឲ្យរលាយសូន្យ ។ នៅពេលដែល ហូលប្រ៊ូក ត្រឡប់ចូលមកក្រុងវ៉ាស៊ីនតោនវិញនាដើមខែវិច្ឆិកា ទស្សនវិស័យនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម មិនដែលត្រូវទាត់ចោលដូចពេលនេះទេ ។ ដោយបញ្ចូលវាសនារបស់ខ្លួនជាមួយវាសនារបស់ប្រទេសចិន សហរដ្ឋអាមេរិកបានសម្រេចចិត្តបដិសេធតួនាទីនាំមុខគេ ដែលត្រូវបានមកខ្លួនវិញនៅអាស៊ី ។ នៅអាស៊ីជាទីដែលសង្គ្រាមស្ថិតនៅកៀកខ្លួនបំផុត ។*

# សម្តេច ព្រះនរោត្តម សីហនុ ៖ រួចផុតពីគ្រោះថ្នាក់

*នៅទីក្រុងភ្នំពេញវេលាព្រឹកថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ខ្យល់អាកាសមានសភាពត្រជាក់គួរសម ។ សម្តេច សីហនុ ចាប់បើកវិទ្យុម៉ាក ហ្វ្រាន់ឌិក របស់ព្រះអង្គ ដើម្បីសណ្តាប់ព័ត៌មានផ្សេងៗដែលផ្សាយចេញពីវិទ្យុភ្នំពេញ ។ តាមទម្លាប់ដូចសព្វដង ព្រះអង្គច្រើនមួលបើកសំឡេងឲ្យឮខ្លាំងៗក្នុងគោលបំណងមិនឲ្យពួកអ្នកយាមល្បាតដឹងពីសកម្មភាពផ្សេងៗរបស់ព្រះអង្គនៅក្នុងព្រះរាជដំណាក់ ហើយនេះគឺជាការធ្វើឲ្យអ្នកយាមទាំងនោះជឿពីគំនិតស្នេហាជាតិមាតុភូមិរបស់ព្រះអង្គ ច្រើនជាងស្តាប់ដំណឹងដោយពិតប្រាកដ ។ គួរឲ្យភ្ញាក់ផ្អើលមែន! ។ ថ្ងៃនេះ កម្មវិធីផ្សាយត្រូវបានកែប្រែ ។ ជំនួសការចាក់ផ្សាយចម្រៀងបដិវត្តន៍ស្តីពី វីរភាពកម្មករ កសិករ និងកងទ័ពដ៏ជាញជ័យរបស់កម្ពុជាប្រជាធិបតេយ្យ ការពិពណ៌នាមិនឈប់ឈរស្តីពីលទ្ធផលនៃការច្រូតកាត់ឬការកសាងកម្ពុជាថ្មី វិទ្យុបែរជាផ្សាយនូវដំណឹងមួយដែលធ្វើឲ្យស្រឡាំងកាំងទៅវិញ ។ រដ្ឋាភិបាលកម្ពុជាទើបនឹងកាត់ផ្តាច់ទំនាក់ទំនងផ្សេងៗខាងការទូតជាមួយប្រទេសវៀតណាម ដែលបានប្រព្រឹត្តល្មើសដោយ“ការឈ្លានពានមិនសមហេតុផល និងដែលមានលក្ខណៈធំធេងមួយ” ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។ សម្តេច សីហនុ ធ្លាប់ដឹងចិត្តពួកវៀតណាមច្បាស់លាស់ណាស់ ពិតមែនតែពេលនេះព្រះអង្គមិនដឹងប្រកាន់ព្រះឥរិយាបថបែបណាក្នុងរឿងនេះក៏ដោយ ៖ កិច្ចការរបស់ ប៉ុល ពត ពិបាកនឹងឲ្យព្រះអង្គចូលរួមណាស់ ។*

*នៅខែមីនា ឆ្នាំ១៩៧៣ ក្នុងឱកាសនៃព្រះរាជដំណើរតាមតំបន់រំដោះនានា ភាពតានតឹងដែលមិនទាន់ចេញជាក់ស្តែងរវាងខ្មែរក្រហម និង“សមមិត្ត”វៀតណាមគេចពុំផុតពីក្រសែព្រះនេត្ររបស់ព្រះអង្គឡើយ ។ តាំងពីពេលនោះមក ព្រះអង្គត្រូវចាំឃ្លាំមើលអធិករណ៍រវាងពួកនេះសិន ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ក្នុងឱកាសធ្វើព្រះរាជទស្សនកិច្ចមួយនៅទីក្រុងហាណូយ ផាំ វ៉ាន់ដុង បានទូលប្រាប់ព្រះអង្គនៅចំពោះមុខ ខៀវ សំផន ថាប្រទេសវៀតណាមមានសេចក្តីទុកចិត្តតែលើព្រះអង្គផ្ទាល់ប៉ុណ្ណោះ ។ ពីរឬបីសប្តាហ៍ក្រោយមក ពេលត្រឡប់មកក្រុងភ្នំពេញវិញ ខៀវ សំផន និង សុន សេន បានទូលប្រាប់ព្រះអង្គនូវទស្សនៈរបស់ខ្លួនស្តីពីវៀតណាមដោយគ្មានសំចៃមាត់ថា ជាអ្នកគំរាមកំហែងអត្ថិភាពប្រទេសកម្ពុជាផ្ទាល់ ។ តាមយោបល់អ្នកទាំងពីរថា ការគំរាមកំហែងនេះមិនត្រឹមតែធ្វើឲ្យយើងបេ្តជ្ញាបណ្តេញជនជាតិវៀតណាមទាំងអស់ចេញពីប្រទេសប៉ុណ្ណោះទេ ថែមទាំងផ្តល់ជាមធ្យោបាយសម្រាប់យើងចាប់បង្ខំដោយកម្លាំងទ័ពឲ្យក្រុងហាណូយទទួលស្គាល់ព្រំដែនសមុទ្រនិងដែនគោក“ប្រកបដោយយុត្តិធម៌”ជាងមុនទៀតផង ។*

*បើតាមការឃោសនារបស់វិទ្យុភ្នំពេញថា នៅដើមឆ្នាំ១៩៧៨ ត្រូវបានកត់សម្គាល់ដោយជោគជ័យដ៏អស្ចារ្យជាបន្តបន្ទាប់គ្នាមួយទៅលើពួកឈ្លានពានវៀតណាម ។ ប្រាកដហើយ គ្មានអ្នកណាម្នាក់គាំទ្រការពោលអាងទាំងនេះដែលគេផ្សព្វផ្សាយតាមវិទ្យុឡើយ ។ សម្តេច សីហនុ ដឹងច្បាស់ពីគ្រោះថ្នាក់យ៉ាងម៉េចៗហើយ*

*ចំពោះការតតាំងនឹងកងទ័ពវៀតណាមដែលដោតជាំក្នុងចម្បាំងទៅហើយនោះ ។ ប៉ុន្តែ ព្រះអង្គបានរក្សាទុកការថប់បារម្ភនេះតែក្នុងព្រះហឫទ័យប៉ុណ្ណោះ ។ ក្នុងសារលិខិតមួយផ្ញើទៅឲ្យ ប៉ុល ពត ព្រះអង្គបានស្នើឲ្យប្រើកិត្តិស័ព្ទរបស់ព្រះអង្គដើម្បីបម្រើជាតិមាតុភូមិដែរ ។ ប៉ុន្តែឥតបានការ ។ សម្តេចបានមានព្រះរាជបន្ទូលថា "ខ្មែរក្រហមមិនព្រមទទួលការស្នើរបស់ខ្ញុំក្នុងការបម្រើជាតិទេ ពីព្រោះពួកគេថា សេចក្តីសម្រេចចិត្តបានប្រកាន់យកស្រេចទៅហើយ : ជ័យជម្នះរបស់គេនឹងមានទំហំលើសពីជ័យជម្នះ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ទៅទៀត [ជាថ្ងៃដែលក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃពួកគេ]" ។ នៅពេលដែលព្រះអង្គទ្រង់ជ្រាបតាមវិទ្យុពីការអញ្ជើញមកដល់ក្រុងភ្នំពេញរបស់លោកជំទាវមេម៉ាយ ដូ អេនឡាយ គឺអ្នកស្រី តេង យីងជាវ នោះ សម្តេចបានទឹកសង្ឃឹមថាព្រះអង្គនឹងត្រូវបានអនុញ្ញាតឲ្យជួបសន្ទនាជាមួយគាត់មិនខាន ។ លោកស្រី តេង បានត្រូវជូនព័ត៌មានឲ្យដឹងថាសម្តេច សីហនុ ពុំចង់ជួបប្រាស្រ័យជាមួយអ្នកណាម្នាក់ទេ ។ ជាជំនួសលោកស្រីបានត្រូវ ខៀវ ប៉ុណ្ណារី ភរិយាមេដឹកនាំខ្មែរក្រហម (ប៉ុល ពត) អញ្ជើញចូលរួមក្នុងការស្រស់ស្រូបអាហារពេលល្ងាចមួយ រួមជាមួយបណ្តាភរិយានៃមេដឹកនាំខ្មែរក្រហមជាច្រើននាក់ទៀត ។ ពាក្យចាក់ដោតបញ្ឈឺចិត្តប្រឆាំងវៀតណាមនិងសម្តីក្អេងក្អាងពីរឿងចម្បាំងដែលផ្សាយចេញរាល់ថ្ងៃពីវិទ្យុភ្នំពេញ បានញុំាងឲ្យសម្តេចជឿថា ប៉ុល ពត នៅតែមិនព្រមមើលការពិតឲ្យចំពីមុខឡើយ ។*

*ដំណោះស្រាយផ្តាច់ព្រ័ត្រអំពីបញ្ហាវៀតណាម ដូចដែល ប៉ុល ពត គ្រោងគិតមិនបានធ្វើឲ្យសម្តេចជឿងឆ្ងល់ឡើយ ។ គេបានរំពុកតាមក្បួនទព្វន្តដ៏គួរឲ្យព្រឺខ្លាចតាមវិទ្យុក្រុងភ្នំពេញថា ជនជាតិខ្មែរម្នាក់ៗអាចសម្លាប់ជនជាតិវៀតណាមសាមសិបនាក់ ដូច្នេះយើងមានមនុស្សល្មមគ្រប់គ្រាន់ដើម្បីកម្ទេចប្រជាពលរដ្ឋហាសិបលាននាក់ដែលគេធ្វើជំរឿននៅប្រទេសវៀតណាម[១] ។*

*ត្រង់កន្លែងនេះ វាមានរឿងរ៉ាវដែលត្រូវសើចក៏ដូចត្រូវធ្វើឲ្យក្តៅក្រហាយដែរ ។ ក៏ប៉ុន្តែអ្វីដែលប្រាកដប្រជាមែនទែន គឺការអំពាវនាវឲ្យមានការងើបបះបោរមួយប្រឆាំងនឹង ប៉ុល ពត ដែលផ្សាយចេញពីវិទ្យុក្រុងហាណូយឯណោះ ។ ដូច្នេះ របបដែលគួរឲ្យខ្លាចរន្ធត់បានចាប់ផ្តើមរង្គោះរង្គើគ្រឹះខ្លួនឯង ។ សម្តេច សីហនុ ដែលបានដឹងរឿងនេះនៅខែកញ្ញា ឆ្នាំ១៩៧៨ ក៏ភ័យខ្លាចដែរ នៅពេលដែលព្រះអង្គសម្គាល់ឃើញជាថ្មីនូវកម្មវត្ថុនៃការប្រោសប្រណីរបស់ខ្មែរក្រហមនេះ ។ ខៀវ សំផន បានយាងព្រះអង្គទៅធ្វើទស្សនាចរថ្មីមួយនៅតាមខេត្ត ។ លើកនេះ គោលដៅគឺធ្វើឲ្យសម្តេចបានជួបទាក់ទងនឹងប្រជារាស្ត្ររបស់ព្រះអង្គ និងធ្វើឲ្យអ្នកទាំងនោះជឿថាសម្តេចផ្តល់នូវការគាំទ្រមួយមកលើរបបនេះទាំងស្រុង ។ នៅកំពង់ផែកំពង់សោមនិងនៅបាត់ដំបង ព្រះអង្គអាចយាងចូលទៅជិតពួកកម្មករដែលទទួលស្វាគមន៍ព្រះអង្គដោយការទះដៃអបអរសាទរ ។*

*សម្រាប់ពេលនេះ អ្វីៗក៏ល្អប្រសើរសម្រាប់ទទួលយកដែរ ។ នៅពេលត្រឡប់មកដល់ភ្នំពេញវិញ សម្តេច សីហនុ បានត្រូវអញ្ជើញឲ្យចូលរួមក្នុងពិធីមួយដែល ខៀវ សំផន ហៅថា "ការជប់លៀងដ៏ស្និទ្ធស្នាលមួយ*

ជាកិត្តិយសដល់អ្នកស្នេហាជាតិមាតុភូមិ» នៅក្នុងនិវេសនដ្ឋានរបស់រដ្ឋាភិបាល(ខាងកើតវត្តភ្នំ) ដែលគេត្រៀមទុកសម្រាប់តែទទួលភ្ញៀវជាន់ខ្ពស់របស់រដ្ឋប៉ុណ្ណោះ ។ ក្នុងឱកាសជប់លៀងដ៏សម្បូរម្ហូបពោរពាស ព្រះអង្គសង្ឃឹមថា នឹងជួបប្រទះអតីតអ្នករួមគំនិតនឹងព្រះអង្គគឺ ប៉ែន នុត ជាមិនខាន ។ ក៏ប៉ុន្តែ«វត្តមានសហការីដ៏ជិតស្និទ្ធរបស់ព្រះអង្គពីររូបគឺអតីតរដ្ឋមន្ត្រីការបរទេស សារិន ឆាក និងអតីតរដ្ឋមន្ត្រីផ្គត់ផ្គង់សព្វាវុធ ឌួង សំអុល បានធ្វើឲ្យព្រះអង្គភ្ញាក់ផ្អើលជាងគេ ។ អ្នកទាំងពីរមានអាការៈដូចឈើចុកចាប់ក្នុងខ្លួនយ៉ាងខ្លាំងរហូតស្ទើរតែមិនហ៊ានមើលមកព្រះអង្គ» ។ សម្តេច សីហនុ ទតស្ទើរតែមិនស្គាល់នូវរូបរាងស្គមកំព្រឹងនិងផ្ងក់ផ្ងើកៗរបស់ សារិន ឆាក ដែលជាបណ្ឌិតច្បាប់ដ៏ឆ្នើមម្នាក់ប្រែទៅជាយ៉ាងដូច្នេះសោះ ដែលនិក្ខេបបទបណ្ឌិតរបស់គាត់ស្តីពីព្រំដែនខ្មែរ-វៀតណាមនេះហើយដែលផ្តល់ឲ្យ ប៉ុល ពត ធ្វើជាទឡ្ហីករណ៍ សម្រាប់បន្ថែមទៅលើការទាមទារទឹកដីរបស់គាត់- នេះជាការចំអកបញ្ឈឺចិត្តដ៏ជូរចត់បំផុត ។ សារិន ឆាក ដែលស្ថិតនៅទីនេះមានទឹកមុខស្លេកស្លាំងដូចមុខខ្មោច បន្ទាប់ពីបានធ្វើការជាទម្ងន់ និងស៊ីអត់ស៊ីឃ្លានអស់ជាច្រើនឆ្នាំ ហើយក៏ជាកម្មវត្ថុនៃការយកចិត្តទុកដាក់ដូចសម្តេចដែរ ។ ក្នុងពេលបរិភោគបាយ អៀង សារី និង អៀង ធីរិទ្ធ ដែលធ្លាប់បញ្ជូនអ្នកសីហនុនិយម និងអ្នកតស៊ូមួយចំនួនដោយផ្ទាល់ឲ្យទៅរកសេចក្តីស្លាប់នោះ ក៏ខំប្រឹងប្រែងនឹងការយកចិត្តទុកដាក់នេះដូចគ្នា ។ ប្រាកដហើយ អ្នកកាន់ម៉ាស៊ីនថតម្នាក់បានត្រៀមខ្លួនថត ព្រឹត្តិការណ៍នេះទុកឲ្យស្ថិតនៅជាអមតៈ ។ ពីរ-បីសប្តាហ៍ក្រោយមក ក្នុងឱកាសនៃការធ្វើដំណើរទៅកាន់ ក្រុងញូវយ៉កដើម្បីចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិ អៀង សារី មិនភ្លេចចែករូបថត ពិធីជប់លៀងនេះឲ្យអ្នកការទូតនិងអ្នកកាសែតឡើយ ។ រូបថតមួយសន្លឹកអាចភូតកុហកបានមែនទេ? អាស្រ័យហេតុនេះហើយ ទោះបីជាមានពាក្យចចាមអារ៉ាមបំភិតបំភ័យបែបណាក៏ដោយ ក៏រូបថតនេះ បង្ហាញឲ្យឃើញថា សម្តេចពិតជានៅមានព្រះជន្មមែន ហើយថា ព្រះអង្គគង់នៅប្រទេសកម្ពុជាដូចបណ្តាអតីតសហការីរបស់ព្រះអង្គដែរ ព្រះអង្គនៅតែជារដ្ឋបុរសដ៏សំខាន់គួរឲ្យគោរពម្នាក់ដដែល ។

យ៉ាងហោច ដំណើរយាងត្រឡប់ដោយការយោគយល់របស់សម្តេច សីហនុ មកកម្ពុជាវិញ បានបណ្តាលឲ្យមានផលអាក្រក់មួយដែលមិនបានគិតទុកជាមុន ។ ខ្មែរក្រហមហាក់ដូចជាខ្វល់ខ្វាយនឹងសន្តិសុខរបស់ព្រះអង្គភ្លាមៗតែម្តង ។ ព្រះរាជដំណាក់របស់ព្រះអង្គក្នុងព្រះបរមរាជវាំងលែងមានសុវត្ថិភាពគ្រប់គ្រាន់ទៀតហើយ ។ ពួកគេនឹកគិតជាមួយនឹងការក្រែងរអែងថាសួនច្បារព្រះរាជវាំងមានសភាពល្ហល្ហេវឥតមានអ្វីការពារពីការវាយឆ្មក់របស់ហ្វូងខ្មាំងម្នាគចក្រសត្រូវសោះ ។ សម្តេច សីហនុ ពុំមែនជាមនុស្សដែលគេងាយបោកបញ្ឆោតនោះទេ ។ ការភ័យខ្លាចពិតប្រាកដរបស់ព្រះអង្គគឺខ្លាចវៀតណាមមកចាប់ពង្រត់ព្រះអង្គ ហើយបំបាត់អ្វីៗដែលអាចនាំឲ្យសម្រេចលទ្ធផលច្រើនប្រការរបស់ព្រះអង្គនៅលើឆាកអន្តរជាតិឯណោះ ។ សម្តេចបានត្រូវផ្ទេរឲ្យទៅគង់ប្រថាប់នៅក្នុងនិវេសនដ្ឋានមួយព័ទ្ធជុំវិញដោយរបងស៊ីម៉ង់ត៍ខ្ពស់ៗនិងលួសបន្លា ហើយមានទំហំតូចជាងមុនទៅទៀត ។ ការប្រុងប្រយ័ត្នទាំងនេះពុំមែនឥតប្រយោជន៍ឡើយ ។ រដ្ឋមន្ត្រីការបរទេសវៀតណាម ង្វៀន កូថាច់ បាននិយាយ

*ប្រាប់ខ្ញុំ(អ្នកនិពន្ធ)ជាច្រើន ឆ្នាំក្រោយមកទៀតថា វៀតណាមពិតជាបានរៀបចំគម្រោងការចាប់ពង្រត់សម្តេច សីហនុ មែន មុនពេលដែលព្រះអង្គមិនទាន់ផ្ទេរចេញពីព្រះបរមរាជវាំងទៅទៀត ។*

*នៅលើដំបូលអគារខ្ពស់មួយដែលនៅជិតនោះ ខ្មែរក្រហមបានដាក់តាំងគ្រឿងបំភ្លឺយ៉ាងច្រើន តម្រង់ទៅរកនិវេសនដ្ឋានថ្មីរបស់ព្រះអង្គជារៀងរាល់យប់ ។ សំណុំពន្លឺបានឆ្លងកាត់រនាំងស្វាបព្រិល (ដែលរូតបាន) ពីម្ខាងទៅម្ខាងបាចសាចរស្មីពេញបន្ទប់ ធ្វើឲ្យសម្តេច សីហនុ និងអ្នកម្នាង ម៉ូនិក ពិបាកផ្ទុំបំផុត ។ នៅក្នុងបន្ទប់នោះមើលទៅភ្លឺដូចពេលថ្ងៃអ៊ីចឹងខណៈដែលសម្តេច សីហនុ ដណ្តឹងសួរក្នុងព្រះទ័យថា តើអ្នកយាមរបស់ព្រះអង្គមានលួចសង្កេតពិនិត្យមើលសកម្មភាពព្រះអង្គនិងមហេសីតាមកែវយិតដែរទេ? ។*

*ក្រៅពីការជាប់រវល់សណ្តាប់ព័ត៌មានតាមវិទ្យុ សម្តេចបានចំណាយពេលវេលាទតសៀវភៅនិងរៀនភាសាអេស្ប៉ាញ៉ុលថែមទៀត ។ ការធ្វើម្ហូបអាហារគឺជាការកម្សាន្តតែមួយគត់របស់ព្រះអង្គក្នុងបណ្តាថ្ងៃដ៏អាប់អួនិងតឹងតែងទាំងនោះ ។ នេះគឺជាចំណង់ចំណូលព្រះទ័យដែលមានតាំងពីដើមមករបស់ព្រះអង្គ ។ ក្បួនធ្វើម្ហូបអាហារដែលព្រះអង្គចេះផ្សំគ្រឿងគ្រៅ គឺជាការបញ្ចូលគ្នាមួយរវាងរសជាតិខ្មែរនិងរសជាតិបារាំង ដែលព្រះអង្គមានការចេះដឹងយ៉ាងជ្រៅជ្រះ ។ នៅយប់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៨ ព្រះអង្គបានប្រញាប់ប្រញាល់បង្ហើយកិច្ចការចង្ក្រានបាយភ្លាមៗនៅពេលដែលអ្នកម្នាង ម៉ូនិក ស្រែកហៅព្រះអង្គឲ្យមកសណ្តាប់ព័ត៌មានតាមវិទ្យុ ។ ក្នុងព្រឹត្តិបត្រព័ត៌មានរបស់ខ្លួន វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកបានប្រកាសឲ្យដឹងថា លោក ម៉ាល់ខូម ខាដវែល អ្នកឯកទេសសញ្ជាតិអង់គ្លេសខាងបញ្ហាអាស៊ី ដែលកំពុងធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យរួមជាមួយអ្នកកាសែតលោកខាងលិចពីរនាក់ទៀត ត្រូវបានគេលួចសម្លាប់នៅក្នុងនិវេសនដ្ឋានរបស់គាត់នៅភ្នំពេញ ។ ពួករដ្ឋអំណាចកម្ពុជាបានទម្លាក់កំហុសទៅលើវៀតណាមពីអំពើមនុស្សឃាតដោយចេតនានេះ ។ សម្តេច សីហនុ ទ្រង់ព្រះតម្រិះថា រឿងនេះដូចជាមិនទំនងទាល់តែសោះ ។*

*សម្តេចទ្រង់ជ្រាបច្បាស់ណាស់ថា ក្នុងកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត គេមិនអាចជន្លៃលេងជាមួយនឹងសន្តិសុខរបស់អ្នកណាម្នាក់ឡើយ ។ ខាដវែល និងអ្នកកាសែតអាមេរិកាំងពីរនាក់ពិតជាបានត្រូវគេការពារយ៉ាងមធ្យ័ត ។ ដោយរបៀបណាទៅ ដែលកុម្ម៉ង់ដូមួយក្រុមអាចឆ្លងកាត់របាំងការពាររបស់ទាហានខ្មែរក្រហមដែលគេរៀបដាក់ជាប់ៗគ្នាដោយមិនឲ្យពួកនេះមើលឃើញទៀតនោះ? ។ ហេតុអ្វីបានជាពួកកុម៉ង់ដូស្គាល់ខាដវែល និងដឹងពីបន្ទប់ដែលគាត់ដេក? ។ សម្តេចបានគិតស្មានតែព្រះអង្គឯងថា ៖ បើសិនជាវៀតណាមអាចបញ្ចេញស្នាដៃមួយបែបនេះមែននោះ សន្តិសុខរបស់ ប៉ុល ពត ក៏ស្ថិតក្នុងគ្រោះថ្នាក់ដូចគ្នាដែរ ។ ទំនងជាពិតជាងនេះទៅទៀតគឺ ប៉ុល ពត ខ្លួនឯងតែម្តងដែលជាមេគំនិតក្នុងការលបធ្វើឃាតនេះ ។ អ្វីដែលសាស្ត្រាចារ្យសាកលវិទ្យាល័យអង់គ្លេសដែលជាអ្នកធ្លាប់កោតសរសើរខ្មែរក្រហមយ៉ាងខ្លាំងក្លាត្រូវរងទទួលនោះ គឺមានតែព្រះជាម្ចាស់ទេដែលអាចប្រាប់អាថ៌កំបាំងពីរឿងនេះបាន ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យព្រះអង្គនឹកឃើញដល់*

ជីវិតដុយស្រួយរបស់ព្រះអង្គផ្ទាល់ដែរ ។

រឿងរ៉ាវផ្សេងៗ បានវិវត្តទៅកាន់តែលឿន ។ បណ្តាស្ថានីយវិទ្យុរបស់បរទេសបានអះអាងបន្ថែមថា ប្រទេសវៀតណាមបានផ្តើមយុទ្ធនាការវាយប្រហារក្នុងទំហំធំមួយប្រឆាំងនឹងប្រទេសកម្ពុជាហើយ ហើយបាននិយាយរៀបរាប់ពីការប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាជាច្រើនកន្លែងទៀតផង ។ ដោយធ្លាប់ស្គាល់វៀតណាមច្បាស់លាស់ និងជាពិសេសស្គាល់ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប ដែលជាមេទ័ពល្បីល្បាញខ្លាំងបំផុតនោះ ព្រះអង្គពុំមានការភ្ញាក់ផ្អើលឡើយ ប៉ុន្តែបានដណ្តឹងសួរក្នុងព្រះទ័យពីទីបញ្ចប់ទៅវិញ ។ ក្នុងពេលរសៀលថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ កម្មាភិបាលខ្មែរក្រហមម្នាក់បានមកទូលសម្តេចនិងមហេសីថា ៖ ព្រះអង្គមានពេល១៥នាទីដើម្បីរៀបចំអីវ៉ាន់សម្រាប់ការយាងទៅកាន់ទិសដៅកំណត់ទុកមួយដែលគេមិនទាន់ដឹង ។ សម្តេចបានមានបន្ទូលទៅកាន់អ្នកម្នាង ម៉ូនិក ថា "ពេលវេលារបស់យើងមកដល់ហើយ" ។ ព្រះអង្គរៀបចំព្រះកាយឆ្ពោះទៅរកសេចក្តីស្លាប់ទេដឹង! ។ តាមការបញ្ជាក់ភ័ស្តុតាងជាច្រើនរបស់អ្នកភៀសខ្លួនខ្មែរ ដែលផ្សព្វផ្សាយដោយវិទ្យុទាំងឡាយរបស់បរទេសសម្តេច សីហនុ ទ្រង់ឈ្វេងយល់យ៉ាងច្បាស់ពីបែបផែនដែលខ្មែរក្រហមចាត់ចែងក្នុងរឿងនេះជាស្រេច ។ ក្រោមលេសដ៏សាមញ្ញមួយ ពួកជនរងគ្រោះបានត្រូវទាក់ទាញឲ្យចាកចេញពីផ្ទះរបស់ខ្លួន ហើយត្រូវបាត់មុខជារៀងរហូត ។ ពេលនេះគឺដល់វេនរបស់ព្រះអង្គម្តង ។ ព្រះអង្គធ្លាប់បានសម្រេចព្រះទ័យធ្វើអត្តឃាតដែរ ជាជាងបណ្តោយព្រះកាយឲ្យខ្មែរក្រហមដឹកយកទៅសម្លាប់ដូចគេដឹកកូនចៀមយកទៅកាន់ទីសត្តឃាត(កន្លែងសម្លាប់សត្វ) ។ ប៉ុន្តែ បេសកជនខ្មែរក្រហមបានត្រឡប់មកម្តងទៀត ដោយទូលស្នើឲ្យព្រះអង្គនាំយកម្ហូបអាហារក្រៀមដែលព្រះអង្គមានទាំងប៉ុន្មានទៅជាមួយផង ។ សម្តេចទ្រង់ដកដង្ហើមធំបន្ធូរព្រះខរា ។ សម្តេចទ្រង់ព្រះតម្រិះថា តើចាំបាច់ត្រូវយកស្បៀងអាហារទៅធ្វើអ្វី បើគេនាំទៅរកសេចក្តីស្លាប់ទៅហើយនោះ? ។

នៅល្ងាចថ្ងៃដដែល ខៀវ សំផន បានចូលមកគាល់សុំលាសម្តេច និងព្រះញាតិវង្ស ព្រះអង្គមុនពេលបែកគ្នា ព្រោះព្រះអង្គត្រូវយាងឆ្ពោះទៅកាន់ខេត្តបាត់ដំបងភាគខាងជើងប្រទេស ។ ខៀវ សំផន បានបញ្ជាក់ថា ពួកឈ្លានពានវៀតណាមបានបន្តដំណើររុលមកមុខរបស់គេ ហើយថា សម្តេច សីហនុ និងព្រះញាតិវង្សព្រះអង្គនឹងមានសន្តិសុខបណ្តោះអាសន្ន បើសិនជាស្ថិតនៅក្រៅរដ្ឋធានី ។ គាត់បានសន្យានឹង សម្តេច សីហនុ ថា នឹងទៅសួរសុខទុក្ខព្រះអង្គនៅបាត់ដំបងក្នុងពេលឆាប់ៗខាងមុខនេះ ។ នៅពេលសិទ្ធិប្រកាស(ពេលព្រលប់ក្រោយពេលព្រះអាទិត្យលិច) ក្បួនដង្ហែដោយរថយន្តជាច្រើនគ្រឿងបានចេញដំណើរលាន់កក្រើកដី ។ ស្ទើរតែមិនទាន់ចេញផុតពីភ្នំពេញផង អ្នកជិះក្នុងរថយន្តបានឮសូរសំឡេងគ្រាប់កាំភ្លើងធំដែលបាញ់មកពីទិសខាងកើតផ្ទុះលាន់ក្អិលៗនៅឯនាយឆ្ងាយសន្ធ្រាមជិតមកដល់មែនទែនហើយ ។

ខៀវ សំផន ពុំបានទូលរឿងរ៉ាវទាំងអស់ប្រាប់ព្រះអង្គទេ ។ នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ដដែលនោះ មុនពេលព្រឹកព្រលឹម កុម្ម៉ង់ដូ ដាត់កុង វៀតណាមពីរក្រុម បានសាកល្បងជ្រៀតចូលក្នុងក្រុងភ្នំពេញ ដើម្បីឆ្មក់

ចាប់យករូបសម្តេចផ្ទាល់ ប៉ុន្តែត្រូវទទួលបរាជ័យ ។ អ្នកដែលត្រូវវាយលុកបានជិះកាណូតកៅស៊ូជាច្រើនគ្រឿងឆ្លងកាត់ដៃទន្លេសាប ហើយបើកអែបមករកច្រាំងក្បែរព្រះបរមរាជវាំង ។ ភាគច្រើននៃអ្នកអស់នោះបានត្រូវសម្លាប់ ។ អ្នកនៅរស់ជីវិតម្នាក់ក្នុងចំណោមអ្នករស់រានមានជីវិតជាច្រើននាក់បានរត់គេចខ្លួនរហូតទៅដល់ប្រទេសថៃ ជាកន្លែងដែលជននោះនិយាយបើកកកាយពីការប៉ុនប៉ងមិនបានសម្រេចប្រាប់អ្នកស៊ើបការណ៍លោកខាងលិចខ្វេចខ្ទី ។ ក្រោយមកទើប សម្តេច សីហនុ ទ្រង់ជ្រាបពីរឿងនេះ គឺនៅពេលដែលព្រះអង្គបានក្លាយទៅជាមនុស្សមានសេរីភាពម្នាក់ ។ គោលដៅរបស់វៀតណាមក្នុងប្រតិបត្តិការនេះ គឺចង់ឲ្យសម្តេចទទួលភារកិច្ចធ្វើជាមេដឹកនាំចលនាតស៊ូមួយប្រឆាំងរដ្ឋាភិបាល ប៉ុល ពត ។

ការធ្វើដំណើរតាមផ្លូវជាតិលេខ៥ ដែលមានសភាពក្រហេងក្រហូងរហូតនោះ បានធ្វើឲ្យមានការនឿយហត់អស់កម្លាំងយ៉ាងខ្លាំង ។ សម្តេច សីហនុ បានគង់ប្រថាប់នៅស៊ីសុផុនក្បែរព្រំដែនប្រទេសថៃតាំងពីពីរថ្ងៃមកហើយ នៅពេលដែល ខៀវ សំផន មកទូលព្រះអង្គឲ្យដឹងមុនថា ព្រះអង្គអាចយាងត្រឡប់ចូលភ្នំពេញបាន ។ សត្រូវបានត្រូវវាយរុញច្រានឲ្យថយទៅវិញហើយ ។ ក៏ប៉ុន្តែការធ្វើដំណើរទៅនិងមកនេះ បង្ហាញឲ្យឃើញថាសម្រាប់ពេលនេះខ្មែរក្រហមពុំមានបំណងធ្វើឃាតព្រះអង្គឡើយ ។ ប៉ុន្តែ តទៅទៀត តើរឿងនេះនឹងទៅជាយ៉ាងណាចំពោះដំណើររុលមកមុខបន្តៗគ្នារបស់វៀតណាមនោះ? ។ ដោយផ្អែកនឹងការពោលអះអាងរបស់ ខៀវ សំផន សត្រូវពុំត្រូវបានវាយរុញច្រានទៅក្រោយវិញទេ ។ សំឡេងរណ្តំក្អិលៗនៃគ្រាប់កាំភ្លើងធំបានធ្វើឲ្យកញ្ចក់និវេសនដ្ឋានរបស់សម្តេចឡើងញ័ររញ្ជួយ ហើយហាក់ដូចជាកាន់តែខិតជិតមកសន្សឹមៗ ។

នៅល្ងាចថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ សម្តេច សីហនុ ត្រូវបានទទួលឲ្យជួបសវនាការដោយ“បងទីមួយ” គឺមេដឹកនាំកំពូលរបស់ខ្មែរក្រហមដោយផ្ទាល់ ។ គេបានមកដឹកសម្តេចហើយជូនព្រះរាជដំណើររហូតដល់អគារដ៏ស្កឹមស្កៃមួយកម្ពស់ពីរជាន់ ដែលមានទីតាំងស្ថិតនៅមាត់ទន្លេសាបចំខាងកើតវត្តភ្នំ ។ គឺជាអតីតនិវេសនដ្ឋានរបស់ទេសាភិបាលបារាំង ដែលកសាងឡើងតាមរចនាប័ទ្មបែបអាណានិគម ។ កាលពីដើម សម្តេច សីហនុ ធ្លាប់យកកន្លែងនេះធ្វើជាទីសំណាក់នៅសម្រាប់តែភ្ញៀវរដ្ឋាភិបាលប៉ុណ្ណោះ ។ សម្តេចពុំដែលបានជួបទល់មុខគ្នានឹង ប៉ុល ពត តាំងតែពីឆ្នាំ១៩៧៣ម៉្លេះ ។ ក្នុងឱកាសនៃដំណើរយាងទស្សនកិច្ចតាមតំបន់ រំដោះនានានៅកម្ពុជា កាលពីខែមីនាឆ្នាំនោះ ព្រះអង្គបានជួបនឹងមនុស្សម្នាក់ដែលនៅតែមានឈ្មោះថា សាឡុត ស ប៉ុណ្ណោះ ។ អ្នកទ្រឹស្តីកុម្មុយនីស្តដែលធ្លាប់រៀនសូត្រនៅសង្កាត់ឡាតាំង(ក្រុងប៉ារីស) បានបង្ហាញឲ្យសម្តេចឃើញថា គាត់ជាមនុស្សមានលក្ខណៈមឹះៗ និងសុភាពរាបសាម្នាក់មិនសូវយកចិត្តទុកដាក់បញ្ចេញមុខមាត់ប៉ុន្មានទេ ហើយច្រើនបណ្តោយឲ្យអ្នកដទៃទៀតនិយាយជំនួសគាត់ទៅវិញ ។

បុគ្គល ប៉ុល ពត ដែលប្រយ័ត្នក្នុងការនិយាយស្តីនិងក្រអឺតក្រទមនេះលែងមានទៀតហើយ ។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ក្នុងរយៈពេល៤ម៉ោង អាកប្បកិរិយា(ឫក្សពាចរិយា)របស់គាត់មានលក្ខណៈជាមេដឹកនាំ

ម្នាក់ ហើយបើគិតឲ្យសព្វគ្រប់ទៅ គឺមានលក្ខណៈបេះគួរសមនិងគួរឲ្យស្រឡាញ់ចាប់ចិត្តបំផុត ។ ថ្ងៃមួយ សម្តេច សីហនុ បានរំឭកពីបរិយាកាសនាល្ងាចនោះថា “ប៉ុល ពត ជាមនុស្សកំរោលម្នាក់ ប៉ុន្តែគាត់ហាក់ដូចជាគ្មានចំណុចណាមួយសម្តែងនូវការស្អប់ខ្ពើមមកលើខ្ញុំសោះ ។ គាត់បេះដាក់ខ្លួនយ៉ាងសុភាពដែលធ្វើឲ្យគេទន់ចិត្តស្រឡាញ់” ។ សម្តេចក៏ត្រូវធ្វើឲ្យងឿងឆ្ងល់ដោយការបេះប្រើពាក្យរាជស័ព្ទយ៉ាងឥតខ្ចោះរបស់គាត់ និងលក្ខណៈពិសេសក្នុងការគោរពឱនលំទោនចំពោះព្រះមហាក្សត្រ ប្រៀបដូចជាគោរពប្រណិប័តន៍ព្រះសង្ឃពុទ្ធសាសនាដែរ ។ “អៀង សារី បដិសេធមិនប្រើប្រាស់ពាក្យរាជស័ព្ទនេះជាមួយខ្ញុំទេ ។ សម្រាប់គាត់ ខ្ញុំគឺជាប្រជាពលរដ្ឋម្នាក់ដូចពលរដ្ឋដទៃៗទៀតដែរ” ។ ចំណែក ខៀវ សំផន បានប្រព្រឹត្តដោយរបៀបផ្សេងពីគ្នា ។ ថ្វីដ្បិតតែគាត់ប្រកាន់ទ្រឹស្តីសមភាពក៏ដោយ ក៏ ខៀវ សំផន និយាយទៅកាន់សម្តេចជាពាក្យរាជស័ព្ទដែរ ។ ក្រោយមកសម្តេចបានរៀបរាប់ថា “ល្ងាចនោះ ខ្ញុំពិតជាត្រូវធ្វើឲ្យភ្ញាក់ផ្អើលស្រឡាំងកាំង ។ ប៉ុល ពត និយាយរបៀបដូចគ្នានឹង ខៀវ សំផន ដែរ ។ នេះគឺជារឿងគួរឲ្យអស្ចារ្យណាស់! មិនគួរឲ្យជឿទាល់តែសោះ!” ។

ប៉ុល ពត បាននិយាយមកកាន់ខ្ញុំថា “ព្រះករុណាជាអម្ចាស់ ទូលបង្គំសូមអភ័យទោស ដែលខ្ញុំទម្លាប់ឲ្យ ខៀវ សំផន ធ្វើជាតំណាងចូលគាល់ព្រះអង្គ” ។ គាត់ឱនគោរពខ្ញុំដោយដៃប្រណម្យជាប់ និងបានប្រើប្រាស់ពាក្យ“ខ្ញុំ”តែមួយដងគត់ ប៉ុន្តែច្រើនប្រើពាក្យថា ខ្ញុំព្រះករុណាៗដូចគ្នានៅព្រះរាជវាំងអង់គ្លេស ។ ទោះជាយ៉ាងណាក៏ដោយ ក៏ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលដែរ” ។

ប៉ុល ពត បានទទូចយ៉ាងខ្លាំងក្នុងគោលបំណងសូមឲ្យសម្តេចយល់ព្រមធ្វើជាតំណាងប្រទេសកម្ពុជានៅអង្គការសហប្រជាជាតិ ។ ជាមួយមិត្តភាពជាច្រើនដែលព្រះអង្គមាននៅបរទេស ព្រះអង្គអាចធ្វើព្រះកាយឲ្យទៅជាអ្នកជួយសង្គ្រោះមួយអង្គយ៉ាងសំខាន់ ។ សម្តេចបានមានបន្ទូលតបថា ព្រះអង្គនៅតែស្រឡាញ់ប្រទេសជាតិ និងថ្កោលទោសការឈ្លានពានរបស់វៀតណាមជានិច្ច ។ សម្តេចបានសន្យានឹងខិតខំឲ្យអស់ពីសមត្ថភាពដើម្បីធានាកម្ពុជាឲ្យបានទទួលការគាំទ្រពីក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ។ អៀង សារី បានកាត់សម្តីដើម្បីបញ្ជាក់ប្រាប់ព្រះអង្គថា មានតែមហេសីព្រះអង្គម្នាក់ប៉ុណ្ណោះដែលរួមដំណើរជាមួយព្រះអង្គបានដោយសារមូលហេតុខ្វះកន្លែងអង្គុយនៅក្នុងយន្តហោះ ។ សម្តេច សីហនុ បានស្នើទៅ ប៉ុល ពត ថា “ឯកឧត្តម! សូមអនុញ្ញាតឲ្យបណ្តាសមាជិករាជវង្ស និងសហការីរបស់ខ្ញុំបានចេញទៅជាមួយខ្ញុំផង” ។ ប៉ុល ពត សម្លឹងមើល អៀង សារី ដែលអង្គុយនៅក្បែរសម្តេច ហើយនិយាយថា “សូមលោកជួយសម្រួលដើម្បីឲ្យអ្នកទាំងអស់បានឡើងជិះយន្តហោះគ្រប់ៗគ្នា” ។ ភ្លាមនោះ សម្តេច សីហនុ រំភើបព្រះទ័យឡើងស្រាលព្រះកាយខ្វាក ។ ព្រះអង្គភ័ន្តភាំងស្មារតីដោយថ្លែងអំណរគុណយ៉ាងច្រើន ទោះជាបានដឹងច្បាស់ពីអ្វីដែលបិទបាំងពីក្រោយការសន្តោសប្រណីនេះក៏ដោយ ៖ ប៉ុល ពត ទាល់ច្រកហើយ ។ មេដឹកនាំខ្មែរក្រហមបាននិយាយរំឭកយ៉ាងយូរពីប្រតិបត្តិការទាំងឡាយរបស់កងទ័ពប្រកបដោយគំនិតសុទិដ្ឋិនិយមមួយ ដែលប្រហែលជាមិនរំភើបនឹងអ្វីទាល់តែសោះថា

“ក្នុងរយៈពេលពីរខែ យើងនឹងបោសសម្អាតវៀតណាមឲ្យអស់” ។ សម្ដេច សីហនុ មានបន្ទូលឆ្លើយតបថា សូមសម្ដែងការអបអរសាទរលោកប្រធាន! ។ ប៉ុល ពត បានបន្តថា “ចាប់ពីពេលនេះទៅ សម្ដេចអាចយាងទៅប្រទេសចិនញឹកញាប់បានតាមតែព្រះអង្គសព្វព្រះទ័យ ។ សម្ដេចមានសេរីភាពធ្វើអ្វីៗតាមព្រះទ័យបានហើយ យើងនឹងចាំទទួលស្វាគមន៍ដោយរីករាយចំពោះដំណើរយាងនិវត្តន៍មកកាន់មាតុប្រទេសវិញរបស់ព្រះអង្គ ។ បើសិនជាព្រះអង្គសព្វព្រះទ័យគង់នៅជាមួយពួកយើងខ្ញុំប៉ុន្មានថ្ងៃក៏ដោយ ក៏យើងខ្ញុំរីករាយស្វាគមន៍ជានិច្ច” ។ អៀង សារី បានឲ្យយោបល់ដោយការងក់ក្បាលក្នុងទឹកមុខយ៉ាងមាំជាសញ្ញាថាយល់ព្រម ។ សម្ដេច សីហនុ ដែលធ្វើព្រះឱស្ឋចំហផ្លុងបានមានបន្ទូលឡើងដែរថា “ពិតមែនឬឯកឧត្តម! ខ្ញុំសូមអរគុណជាអនេកប្បការ” ។

សេរីភាពដែលជិតមកដល់កាលពីម្សិល ហាក់ដូចជារសាត់ទៅឆ្ងាយយ៉ាងរហ័សនៅព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ កាំភ្លើងធំរបស់វៀតណាម ប្រហែលពុំមែនស្ថិតនៅឆ្ងាយពីទីក្រុងភ្នំពេញប៉ុន្មានឡើយ ។ តើយន្តហោះប៊ូអ៊ីង៧០៧របស់ចិនអាចមកដល់គោលដៅ ហើយចុះចតនៅអាកាសយានដ្ឋានពោធិចិនតុងបានទេ? បន្ទាប់មកយន្តហោះត្រូវហោះចេញទៅវិញ ដោយមិនទទួលរងគ្រាប់កាំភ្លើងរបស់វៀតណាមដែរឬទេ? ។ អៀង សារី បានផ្ដាំផ្ញើសម្ដេចថា ក្នុងករណីដែលយន្តហោះចិនមិនបានមក សូមព្រះអង្គចាកចេញពីភ្នំពេញ ហើយភៀសខ្លួនរត់ចូលព្រៃវិញ ។ សម្ដេចបានមានបន្ទូលរំឭកថា “ខ្ញុំបានរៀបចំវ៉ាលិសពីរ ។ ក្នុងវ៉ាលិសមួយខ្ញុំបានរៀបដាក់សម្លៀកបំពាក់សម្រាប់ទៅក្រុងញូវយ៉ក ។ ក្នុងវ៉ាលិសមួយទៀត ខ្ញុំរៀបគ្រឿងម្ហូបកំប៉ុង អាវកាគីខោអាវពីហ្សាម៉ា ក្រមាមួយនិងស្បែកជើងហូជីមិញ (ជាស្បែកជើងធ្វើពីកង់ឡានចាស់ៗជាតួយ៉ាងមួយដែលមានតែពួកទ័ពព្រៃនៅឥណ្ឌូចិនប៉ុណ្ណោះប្រើប្រាស់)” ។ ដូច្នេះ តើព្រះអង្គត្រូវរត់ចូលព្រៃរួមដំណើរជាមួយខ្មែរក្រហមទាំងនេះ ដែលព្រះអង្គធ្លាប់មើលងាយមែនឬ? ។ ចម្លើយគឺបិទបាំងក្នុងផ្ទៃមេឃស្រអាប់ឯណោះ ដែលរេការសម្លឹងមើលដោយមិនចេះធុញទ្រាន់មកលើពួកអ្នកដំណើរជាតិចិននិងកម្ពុជា ដែលកំពុងហៀបនឹងចាកចេញឆ្ពោះទៅគោលដៅមួយ ។ ម្នាក់ៗផ្ទៀងត្រចៀកស្ដាប់ដោយខំប្រឹងញែកឲ្យដាច់នូវ“ស្នូរម៉ាស៊ីនដែលមកជួយសង្គ្រោះ” ជាមួយសំឡេងរណ្ដំនៃការបាញ់កាំភ្លើងធំតគ្នា ។ យន្តហោះមិក-១៩ផលិតនៅប្រទេសចិន ដែលមានគូរទង់ជាតិកម្ពុជាប្រជាធិបតេយ្យនៅចតតម្រៀបគ្នាជាជួរនៅចុងផ្លូវហោះហើរ ដោយមិនអាចធ្វើអ្វីកើតព្រោះគ្មានអ្នកបើកយន្តហោះ ។ នៅខាងលើអាកាសយានដ្ឋានពោធិចិនតុងព្រះអាទិត្យចាប់ផ្ដើមរះខ្ពស់ណាស់ទៅហើយ ។ ខ្យល់អាកាសមានសភាពស្ងប់ស្ងាត់នឹងថ្កល់ ។ សម្ដេច សីហនុ កំពុងទន្ទឹងរង់ចាំ“បក្សីសេរីភាព”មកទទួលយកព្រះអង្គទាំងអន្ទះសា ។

# ជំពូកទី១០
# ណូអែលក្រហម

សម្រាប់ឯកអគ្គរដ្ឋទូតឡាវ ខាំផាន វីឡាជិត និងសម្រាប់សហការីទាំងប្រាំមួយរូបរបស់គាត់ រាត្រីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩នោះ គឺជារាត្រីមួយដែលពួកគេមិនបានដេកពួនទាល់តែសោះ ។ សង្គ្រាមដែលប្រកបទៅដោយគ្រោះថ្នាក់ខ្លាំងកាន់តែមកកៀកណាស់ទៅហើយ ។ ភាពស្ងប់ស្ងាត់ដូចនៅវាលកប់ខ្មោចមួយ បានគ្របដណ្តប់មកលើរដ្ឋធានី ដែលត្រូវរំខានម្តងម្កាលដោយស្នូរសន្ធឹកនៃការបាញ់កាំភ្លើងធំតទល់គ្នាយ៉ាងខ្លាំង ។ បង្អួចកញ្ចក់របស់ស្ថានទូតឡើងញ័ររញ្ជួយ ។ បើទុកជាគាត់ភ្ញាក់ផ្អើលនឹងភាពកើតឡើងភ្លាមៗនេះក៏ដោយ ក៏ខាំផាន រង់ចាំព្រឹត្តិការណ៍ដែលមកបញ្ចប់ដែរ ។

គាត់បានសាកល្បងធ្វើឲ្យសហការីទាំងអស់របស់គាត់ស្ងប់ក្នុងចិត្ត ដោយបញ្ចុះបញ្ចូលឲ្យនាំគ្នាសូត្រធម៌បន់ស្រន់ព្រះពុទ្ធជាម្ចាស់ ។ ពួកគេសុទ្ធតែស្ថិតក្នុងវ័យជាយុវជនរស់នៅក្នុងស្ថានទូតដាច់ឡែកពីគេទាំងស្រុង និងឃ្លាតឆ្ងាយពីក្រុមគ្រួសាររបស់ខ្លួនថែមទៀត ដោយហេតុនេះពួកគេច្រើនត្រសុលរកគ្នាស្ទើរតែដូចកូនក្មេង ពេលដែលជួបហេតុការណ៍ភ័យខ្លាចអ្វីមួយ ។ តាំងពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ម្ល៉េះ អ្នកនៅស្ថានទូតឡាវ ហាក់ដូចជារស់នៅលើកោះមួយដែលស្ងាត់ជ្រងំ អស់សង្ឃឹមនិងដាច់ស្រយាលពីគេឯងក្នុងទីក្រុងមួយដែលធ្វើឲ្យខ្វល់ចិត្តក្នុងសភាពរង់ចាំតែការបង្ហើយឲ្យវិនាសអន្តរាយប៉ុណ្ណោះ ។ ព្រះពុទ្ធជាម្ចាស់បានប្រៀនប្រដៅឲ្យមនុស្សស្វែងរកផ្លូវទៅនិព្វាន ដើម្បីដោះខ្លួនឲ្យផុតពីវាលវដ្តសង្សារ ហើយក្នុងពេលជួបការលំបាកនេះ ពួកគេបានបែរទៅរកព្រះពុទ្ធដោយឯកឯង ។

ជារឿងចម្លែកមួយដែលឥស្សរជនម្នាក់បែប ខាំផាន សម្រេចចិត្តមកធ្វើជាតំណាងប្រទេសឡាវ សង្គមនិយមប្រចាំប្រទេសមួយដែលនិយមឆ្កួតជ្រុលនៃពិភពលោកនេះ ។ តាមការពិត មនុស្សដែលមានមាឌធំថ្វាសទូលាយ ការញញឹមរបៀបលីបលនិងមីះៗនេះពុំមែនរដ្ឋាភិបាលមិនចង់រក្សាទុកក្នុងប្រទេស ដោយសារគុណសម្បត្តិបដិវត្តរបស់គាត់នោះទេ ប៉ុន្តែគឺដោយសារគាត់ចេះនិយាយភាសាខ្មែរស្ទាត់ ហើយទស្សនៈរបស់គាត់ក្នុងជីវភាពរស់នៅ ក៏មានលក្ខណៈចូលចិត្តភាពស្ងប់ស្ងាត់មួយដែលនេះជាគុណសម្បត្តិចាំបាច់ក្នុងកម្ពុជារបស់ប៉ុល ពត ។ យុវកម្មាភិបាលបដិវត្តន៍ដែលធ្លាប់ឈ្នះរូបនេះមានសភាពស្ទើរតែឡប់ស្មារតីអស់ហើយ បន្ទាប់ពីការរស់នៅដាច់ពីគេទាំងស្រុងអស់រយៈមួយឆ្នាំមកហើយនោះ ។ គាត់ត្រូវតែជម្លៀសបុគ្គលិកចេញជាបន្ទាន់ ព្រោះរៀងរាល់ខែ ការទាក់ទងតាមផ្លូវអាកាសរវាងក្រុងវៀងច័ន្ទនិងក្រុងភ្នំពេញ មានតែមួយគត់ និងការហោះហើរមានតែមួយជើងប៉ុណ្ណោះ ។ នៅទីបំផុត គេបានបញ្ជូនគាត់ឲ្យត្រឡប់ទៅប្រទេសវិញតាមកាណូត ហើយការបើកឡើងតាមទន្លេមេគង្គទៅភាគខាងជើងមានរយៈពេលដល់ទៅជាងមួយសប្តាហ៍ឯណោះ ។

ប្រហែលសែសិបឆ្នាំមុន ខាំផាន ធ្លាប់បានស្នាក់អាស្រ័យនៅប្រទេសកម្ពុជាដែរ ។ ជាយុវបព្វជិតម្នាក់ គាត់បានរៀនសូត្រយកចំណេះវិជ្ជានៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅក្រុងភ្នំពេញ ។ ក្នុងរយៈពេលមួយភាគធំនៃជីវិតរបស់គាត់ គាត់ធ្លាប់បានធ្វើជាមន្ត្រីរដ្ឋបាលនិងអភិបាលក្រុងហ្លួងប្រាបាង ដែលជារាជធានីបរមបុរាណមួយ ហើយម្យ៉ាងទៀត ទីនោះក៏ជាមជ្ឈមណ្ឌលស្រាវជ្រាវខាងវិស័យព្រះពុទ្ធសាសនាដ៏សំខាន់ជាងគេបំផុតរបស់ប្រទេសជាតិផង ។ គាត់មិនដែលនឹកស្មានថា ក្នុងពេលណាមួយគាត់អាចក្លាយខ្លួនទៅជាអ្នកទូតទាល់តែសោះ ហើយប្រាកដណាស់ពុំមែនក្នុងប្រទេសមួយដែលប្រឆាំងនឹងសាសនាទេ ។ ទោះយ៉ាងណាក៏ដោយ ក៏ ខាំផាន មិនអាចច្រាលចោលការអំពាវនាវរបស់បក្សប្រជាជនបដិវត្តន៍ឡាវដែលតែងតែបង្ហាញនូវការអត់ឱនប្លែកពីធម្មតាមួយចំពោះព្រះពុទ្ធសាសនាដែរ ។

គាត់បានត្រឡប់មកប្រទេសកម្ពុជាម្តងទៀត បន្ទាប់ពីអវត្តមានចំនួនប្រាំបីឆ្នាំ ។ ប្រទេសនេះមានលក្ខណៈធ្វើឲ្យគាត់ស្ទើរតែមើលមិនស្គាល់ ។ រាជធានីដែលកាលពីដើមជាទីក្រុងមានសោភ័ណភាពល្អឥតទាស់ជាមួយបរិយាកាសរបៀបខេត្តបារាំងមួយនោះគឺអស់ផ្លូវកែហើយ ។ វត្តអារាមទាំងអស់លើកលែងតែវត្តមួយគត់ដែលនៅក្បែរព្រះបរមរាជវាំង សុទ្ធតែត្រូវបោះបង់ចោលគ្មានការថែទាំ ទោះបីជាមិនត្រូវគេប្រែក្លាយទៅជាជង្រុកដាក់ស្រូវ ឬកន្លែងធ្វើទឹកត្រីក៏ដោយ ។ ព្រះសង្ឃទាំងឡាយដែលចាកសិក្ខាបទត្រូវបានយកទៅសម្លាប់ ឬដាក់ទោសឲ្យធ្វើការជាទម្ងន់ ។ ខ្មែរក្រហមបានបង្ហាញដោយមោទនភាពឲ្យ ខាំផាន មើលខ្សែភាពយន្តឃោសនាមួយ ដែលគេឃើញអតីតព្រះសង្ឃជាច្រើនអង្គត្រូវយកទៅទឹមឲ្យអូសរទេះដូចសត្វគោ ។

ជីវិតមនុស្សប្រុសម្នាក់ពុំមានតម្លៃទេនៅកម្ពុជា ហើយនៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជីវិតហាក់ដូចជាទឹកមួយតំណក់លើស្លឹកឈូក ។ ស្ថានីយវិទ្យុបរទេសជាច្រើនបានផ្តល់ដំណឹងឲ្យដឹងពីការរុលមកមុខរបស់វៀតណាមចូលមកក្នុងទឹកដីកម្ពុជាដែរ ។ ឥឡូវនេះស្នូរនៃសង្គ្រាមកាន់តែមកកៀកមែនទែនហើយ ជាភ័ស្តុតាងថា ស្ថានការណ៍មានសភាពរឹតតែធ្ងន់ធ្ងរជាងការនិយាយរបស់វិទ្យុទៅទៀត ។ សម្រាប់ពួកឡាវ គ្រោះថ្នាក់គឺមានពិតប្រាកដ ៖ ព្រោះពួកគេជាអ្នកការទូតចុងក្រោយដែលស្ថិតនៅទីក្រុងភ្នំពេញ ។ ភាពមិនទៀងទាត់ក្នុងការទាក់ទងគ្នាតាមវិទ្យុទូរលេខម័រ្ស (morse) ជាមួយក្រុងវៀងច័ន្ទបានត្រូវផ្តាច់អស់រយៈប្រាំមួយថ្ងៃមកហើយ ។ ក្នុងទូរលេខចុងក្រោយរបស់គាត់ដែលបញ្ជូននៅពេលបុណ្យចូលឆ្នាំសកល ខាំផាន បានជូនដំណឹងប្រាប់មេកោយរបស់គាត់ពីអសន្តិសុខដែលកាន់តែរីកធំឡើងៗនៅក្នុងរដ្ឋធានីភ្នំពេញ ។ ដោយឆ្លើយតបមកវិញ រដ្ឋមន្ត្រីការបរទេសឡាវបានទូន្មានកុំឲ្យគាត់ស្ទន់ស្ទា និងឲ្យស្ថិតនៅតែក្នុងស្ថានទូត ។ ទុកជាយ៉ាងណាក៏ដោយ ក៏គាត់គ្មានជម្រើសណាផ្សេងទៀតដែរ ។ ទីក្រុងបានត្រូវកាត់ផ្តាច់ពីពិភពលោកទាំងស្រុង ។ ក្រោយមកទើប ខាំផាន រកឃើញពីមូលហេតុនៃការដាច់ទំនាក់ទំនងគ្នារបស់ក្រុងវៀងច័ន្ទគឺនៅពេលដែលស្ថានការណ៍ពុះកញ្ជ្រោលខ្លាំងនៅក្រុងភ្នំពេញ ការីតែមួយគត់ដែលកាន់ខាងទូរលេខនៅទីស្តីការក្រសួងការបរទេសឡាវកំពុងឈឺដេកជាប់នឹង

ត្រៃដោយសារភេគរាកមួល ។

នៅយប់ថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ ខាំផាន ត្រូវដាស់ឲ្យភ្ញាក់ពីដំណេកដោយសហការីម្នាក់ក្នុងចំណោមសហការីទាំងអស់របស់គាត់ដែលនិយាយទាំងភ័យញ័រប្រាប់គាត់ថា "ខ្មែរក្រហមកំពុងរៀបចំជម្លៀសបុគ្គលិកធ្វើការគ្រប់ស្ថានទូតទាំងអស់ ប៉ុន្តែប្រហែលជាគ្មានពួកយើងទេ" ។ ពីបង្អួចរបស់គាត់ទៅ ខាំផាន អាចសង្កេតឃើញភាពច្របូកច្របល់នៃហ្វូងមនុស្សដែលមាននៅលើផ្លូវថ្នល់ក្បែរនោះ ។ អ្នកទាំងនោះស្ថិតនៅក្នុងបរិវេណភូមិមួយ(ទីកន្លែងដែលនៅកណ្ដាលកន្លែងដទៃទៀត) មានសុទ្ធតែស្ថានទូត ។ ស្ថានទូតទាំងអស់សុទ្ធតែនៅទីនេះ ដោយប្រមូលដាក់មួយដុំចម្ងាយពីគ្នាប្រហែលមួយរយម៉ែត្រប៉ុណ្ណោះ ។ ពួកកងទ័ពរបស់កម្ពុជាជាអ្នកលើកប្រដាប់ប្រដាររបស់បុគ្គលិកស្ថានទូតដាក់លើរថយន្តកាមីញ៉ុងជាច្រើនគ្រឿងក្នុងពេលដែលអ្នកការទូតរៀបចំរថយន្តរបស់ខ្លួនផ្ទាល់ ។ បុគ្គលិកទូតឡាវម្នាក់បានសួរទៅកងទ័ពដែលនៅឈរមុខទ្វារចូលជាភាសាខ្មែរថា "តើមានរឿងអ្វីកើតឡើង!សមមិត្ត?" ។ "សម្រាប់ហេតុផលខាងសន្តិសុខអង្គទូតទាំងអស់នឹងត្រូវផ្ទេរបញ្ជូនទៅខេត្តបាត់ដំបងសិន ប៉ុន្តែគ្មានការណែនាំណាមួយសម្រាប់ពួកឡាវទេ" កងទ័ពនោះបានឆ្លើយតបមកវិញ ។ គឺច្បាស់លាស់ណាស់ ប៉ុល ពត ត្រូវការចំណាប់ខ្មាំង ហើយពួកឡាវដែលជាសម្ព័ន្ធមិត្តរបស់វៀតណាមជាមុខសញ្ញាដែលត្រូវជ្រើសរើសទុកជាមុនរួចស្រេច ។

ឯកអគ្គរដ្ឋទូតយូហ្គោស្លាវី មីហៃឡូ ឡុមប៉ា ធ្វើមុខមិនមាំងដោយនឹកឆ្ងល់ក្នុងចិត្តយ៉ាងខ្លាំង ។ ថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ នៅវេលាព្រឹកគាត់បានទៅជួប ប៉ុល ពត ដើម្បីនាំយកថ្នាំពេទ្យរបស់កាកបាទក្រហមយូហ្គោស្លាវីមួយចំនួនទៅប្រគល់ជូន ។ គាត់មើលទៅមេដឹកនាំខ្មែរក្រហមហាក់ដូចជាទុកចិត្តខ្លួនឯងខ្លាំងណាស់ ៈ ប៉ុល ពត ពោលប្រាប់ថា ការឈ្លានពានរបស់វៀតណាមដែលផ្ដើមយុទ្ធនាការនៅ ខែធ្នូ នឹងត្រូវយើងវាយឲ្យបាក់ទ័ពរត់ខ្ចាត់ខ្ចាយយ៉ាងឆាប់រហ័ស ។ ល្ងាចនោះ នៅពេលដែលអ្នកទទួលខុសត្រូវម្នាក់នៃក្រសួងការបរទេសមកប្រាប់ដំណឹងដោយសម្ដីមួយដែលគ្មានប្រាកដក្នុងខ្លួនថា គាត់ត្រូវតែ"ចាកចេញជាបណ្ដោះអាសន្ន"ពីរដ្ឋធានី ដំបូងគាត់ស្មានថាជាការហាត់រៀនការពារខ្លួនមួយប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលដែលអ្នកទទួលខុសត្រូវនោះបន្ថែមថា "សមមិត្តត្រូវតែចាកចេញក្នុងរយៈមួយម៉ោងទៀត" ស្រាប់តែគាត់បើកភ្នែកក្រឡង់និងមានទឹកមុខស្រឡាំងកាំងទៅវិញ ។ តើនេះជាទីបញ្ចប់របស់កម្ពុជាប្រជាធិបតេយ្យឬ? ប៉ុន្មានម៉ោងក្រោយមកក្បួនរថយន្តតូច និងរថយន្តកាមីញ៉ុងជាច្រើនគ្រឿងដែលផ្ទុកពេញទៅដោយពួកបុគ្គលិកស្ថានទូតបរទេសទាំងអស់ លើកលែងតែស្ថានទូតមួយ បានបើកបរឆ្ពោះទៅកាន់ខេត្តបាត់ដំបង ។ ឯកអគ្គរដ្ឋទូត ឡុមប៉ា បានប្រទះឃើញសមភាគីចិនរបស់គាត់ ស៊ុន ហាវ នៅទីនោះដែរ ដែលតាមធម្មតាគាត់ជាមនុស្សសប្បាយរីករាយណាស់ ប៉ុន្តែពេលនេះ គាត់ទាល់គំនិតមិនដឹងជាគិតយ៉ាងណាឡើយ ។ តាមប្រហែលទំនងជាគាត់ពិបាកទ្រាំទ្រនឹងការចាកចេញនេះហើយ ។

បន្ទាប់ពីស្នាក់នៅបាត់ដំបងមួយយប់ បុគ្គលិករបស់ស្ថានទូតយូហ្គោស្លាវីនិងចិនត្រូវចាប់ផ្ដើមធ្វើដំណើរ

ដែលនឿយស្មើរបាក់បង្កើនត្រឡប់មកភ្នំពេញវិញ ដើម្បីជិះយន្តហោះឆ្ពោះទៅក្រុងប៉េកាំងដូចដែលបានគ្រោងទុកជាមុន ។ ហេតុនេះនៅព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មានជនជាតិខ្មែរនិងចិនរាប់រយនាក់ នៅឈររង់ចាំក្នុងអាកាសយានដ្ឋានពោធិចិនតុង ក្រោមការបាញ់កាំភ្លើងធំផ្លោងដាក់គ្នាទៅវិញទៅមក ។ លើកលែងតែ ប៉ុល ពត គណៈដឹកនាំខ្មែរក្រហមស្ទើរតែទាំងអស់សុទ្ធតែមានមុខស្ថិតនៅទីនោះ ។ ឡុមប៉ា យល់ច្បាស់ពីមូលហេតុនៃការផ្លាស់ប្តូរការធ្វើដំណើរនេះភ្លាម នៅពេលដែលគាត់ក្រឡេកឃើញព្រះភក្ត្រ សម្តេច សីហនុ ដែលគាត់មិនដែលបានជួបសោះតាំងពីយូរមកហើយក៏ស្ថិតនៅក្នុងចំណោមនោះដែរ ។ “ពួកអ្នកធ្លាប់យាមឃ្លាំមើល” ព្រះអង្គបានមកសម្តែងការគោរពជម្រាបលាសម្តេចទាំងទើសទាល់ ។ ការសុំអនុញ្ញាតជួបសន្ទនាជាមួយសម្តេចដែល ឡុមប៉ា ស្នើសុំកាលពីឆ្នាំមុនក្នុងនាមមិត្តភក្តិចាស់របស់សម្តេចគឺ លោកសេនាប្រមុខ ហ្សូហ្សិបប្រូសទីតូ បានត្រូវបដិសេធយ៉ាងគួរសម ។ ដូច្នេះ ពេលនេះភាពជាប់ឃុំរបស់ព្រះអង្គបានផុតរលត់ហើយ ។ អៀង សារី ដើរចូលមកជិតឯកអគ្គរដ្ឋទូតយូហ្គោស្លាវីដោយនិយាយសុំទោសផង ។ សារី បានប្រាប់ឲ្យគាត់ដឹងថា មនុស្សច្រើនកុះករដូច្នេះ គណៈប្រតិភូរបស់លោកអាចមានត្រឹមតែបួនកៅអីប៉ុណ្ណោះក្នុងយន្តហោះ ។ ឯកអគ្គរដ្ឋទូតចិននិងយូហ្គោស្លាវីបានសម្រេចស្ថិតនៅទីនេះដោយទុកកៅអីរបស់ខ្លួនឲ្យពួកបុគ្គលិកនៅក្រោមបង្គាប់គាត់វិញ ។

នៅវេលាថ្ងៃត្រង់ យន្តហោះប៊ូអ៊ីង៧០៧ពណ៌ទឹកប្រាក់និងខៀវនៃអាកាសចរណ៍ស៊ីវិលចិនបានបន្ទាបខ្លួនចុះចតនៅពោធិចិនតុង ។ សម្តេច សីហនុ មានព្រះទ័យសប្បាយរីករាយរហូតស្រក់ព្រះជលនេត្រ ។ ជាថ្មីម្តងទៀត សម្តេចដែលសប្បាយព្រះទ័យនឹងសេរីភាពបានចាកចេញពីប្រទេសរបស់ព្រះអង្គ ។ សម្តេចចាប់ឱបឯកអគ្គរដ្ឋទូតយូហ្គោស្លាវីនិងមានបន្ទូលទាំងអួលអាក់ថា “សូមលោកពាំនាំការគោរពស្រឡាញ់របស់ខ្ញុំជម្រាបលោកប្រធានាធិបតី ទីតូ ផង ហើយសូមប្រាប់លោកថា ប្រជាជនយើងនឹងមិនចុះចាញ់ដាច់ខាត” ។ យន្តហោះបានហោះឡើងផុតពីដី ហើយក៏ពុំមានការចេញដំណើរតាមយន្តហោះណាផ្សេងទៀតដែរ ។ ឯកអគ្គរដ្ឋទូតទាំងពីរបានចាប់ផ្តើមដំណើរត្រឡប់មកបាត់ដំបងជាថ្មីម្តងទៀត ។

នៅពេលព្រឹកព្រហាមថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ការច្របូកច្របល់ដែលមិនអាចពណ៌នាបានៗកើតមាននៅជុំវិញស្ថានីយរថភ្លើងក្រុងភ្នំពេញ ។ មនុស្សជាច្រើនពាន់នាក់ទាំងស្រីទាំងប្រុសទាំងក្មេងក្មាង បានចាកចេញយ៉ាងកុះករតាមរថយន្តកាំមីញ៉ុង ម៉ូតូ កង់ ទៅគ្រប់ទិសទីរួមទាំងកម្មាភិបាលខ្មែរក្រហម និងក្រុមគ្រួសាររបស់គេផង ។ ពួកគេរត់ចេញពីកន្លែងស្នាក់នៅទៅកាន់តំបន់ជាយក្រុង ។ ដោយជាក់ស្តែង មនុស្សពុំបានចាកចេញពីទីក្រុងទាំងអស់ទេ ។ រថភ្លើងពីរខ្សែនៅឯស្ថានីយបានផ្ទុកពេញទៅដោយពួកយុទ្ធជនរបួសនិងប្រជាជនស៊ីវិលដែលភ័យស្លន់ស្លោស្រេចទៅហើយ ។ អៀង សារី និងបណ្តាសហការីរបស់គាត់នៃក្រសួងការបរទេសបានខិតខំរាំងខ្ទប់ហ្វូងមនុស្សមិនឲ្យប្រជ្រៀតឡើងជិះរថភ្លើងទេ ដើម្បីទុកកន្លែងសម្រាប់អ្នករបួសដែលចេះតែបន្តមកដល់គ្មានឈប់ ។ ព្រះអាទិត្យបានធ្វើឲ្យទូរថភ្លើងទាំងអស់ប្រែក្លាយបន្តិចម្តងៗទៅជាបន្ទប់សម្រាប់ឆ្អុងដែលធ្វើឲ្យអ្នក

ជិះឡើងបែកញើសសស្រាក់ ។ ម៉ោង៩ជាងបន្តិច ស្រាប់តែលេចមុខនិរសារម្នាក់មិនដឹងមកពីកន្លែងណាប្រាប់ថា កងទ័ពរបស់វៀតណាមស្ថិតនៅឆ្ងាយពីទីក្រុងតែប្រាំគីឡូម៉ែត្រប៉ុណ្ណោះ ។ សារី ចេញបញ្ជាឲ្យចេញដំណើរភ្លាម ។ តាមទូរថភ្លើង ហ្វូងមនុស្សបាននាំគ្នាលោតឡើងតោងមាត់ទ្វារឬបង្អួច និងឡើងទំពេញលើដំបូលថែមទៀត ។ ក្បួនរថភ្លើងទាំងពីរចាប់កម្រើកខ្លួនដ៏ធ្ងន់ពាប់ ហើយបើកឆ្ពោះទៅបាត់ដំបងដោយគ្មានបន្លង់ ។

ពីលើដំបូលរាបស្មើនៃស្ថានទូត ខាំផាន បានតាមសង្កេតមើលព្រឹត្តិការណ៍នេះយ៉ាងយកចិត្តទុកដាក់ ។ តើរឿងទាំងអស់នេះនឹងត្រូវបញ្ចប់ដោយរបៀបណាទៅ? ។ តាំងពីពេលព្រឹកព្រហាម សូរផ្ទុះនៃគ្រាប់កាំភ្លើងស្វ័យប្រវត្តិបានលាន់ឮឡើងភ្ជាប់ជាមួយនឹងការផ្ទុះនៃគ្រាប់កាំភ្លើងធំជាច្រើនកន្លែង ។ ពេលនោះម៉ោងជិតដប់ហើយ រថយន្តហ្ស៊ីបមួយគ្រឿងបានបើកចូលមកក្នុងបរិវេណភូមិអ្នកការទូតដើម្បីជម្លៀសពួកយុទ្ធជនក្មេងៗដែលចាំការពារនៅទីនោះ ។ មុននឹងឡើងជិះរថយន្ត យុទ្ធជនម្នាក់ក្នុងចំណោមនោះបានលើកកាំភ្លើងអាកា៤៧របស់ខ្លួន ហើយបាញ់រះយ៉ាងគឃ្លើនមកលើផ្នែកខាងមុខនៃស្ថានទូតឡាវ ប៉ុន្តែគ្មានអ្នកណាម្នាក់ត្រូវរបួសឡើយ ។ គ្រាប់កាំភ្លើងមួយគ្រាប់បានរត់មកប៉ះរូបថតរដ្ឋមន្ត្រីទី១ កៃសនភូមិវិហាន ដែលជ្រុះធ្លាក់មកដីបែកខ្ទាយ ។

ដំណើរវក់វីពិតប្រាកដមួយហាក់ដូចរាតត្បាតពេញក្នុងទីក្រុងនេះ ដែលគេជឿថាលែងមានអ៊ីកម្រើកទៅហើយ ។ យូរៗម្តងរថយន្តកាំមីញ៉ុងជាច្រើនគ្រឿងដែលផលិតនៅប្រទេសចិននិងដែលមានផ្ទុកមនុស្សពេញៗបានបើកបរយ៉ាងអស់ល្បឿនតាមមហាវិថីព្រះមុនីវង្ស ។ ខ្ទម្ភាគចក្រជាច្រើនគ្រឿងពណ៌បៃតង បានបង្ហាញរូបរាងឡើងនៅក្នុងលំហមេឃដ៏សែនក្តៅនាព្រឹកនោះ ។ សូរកង្រំពងដែលគួរឲ្យព្រឺខ្លាចនេះបានលប់លើសំឡេងកាំភ្លើងធំមួយភ្លែតៗដែរ ។ ពិភពមួយហាក់ដូចជារលំរលាយក្រោមក្រសែភ្នែករបស់ ខាំផាន ដែលនឹកគិតស្ងាត់ៗថាតើ ប៉ុល ពត មានស្ថិតនៅក្នុងខ្ទម្ភាគចក្រមួយក្នុងចំណោមខ្ទម្ភាគចក្រទាំងនោះដែរទេ? ។ ប្រហែលនៅវេលារសៀល គាត់បានស្តាប់ឮច្បាស់គ្មានច្រឡំនូវសូរកង់ប្រវាក់លាន់ទ្រហឹងមួយ ។ ដោយឈ្ងោកតាមបង្អួច គាត់អាចមើលឃើញពីចម្ងាយតាមចន្លោះផ្ទះថ្មពីរជួរនូវចំណែកមួយនៃមហាវិថីព្រះមុនីវង្ស ដែលជាផ្លូវធំជាងបង្អស់ក្នុងទីក្រុង ។ រថក្រោះមួយគ្រឿងដែលមានដោតទង់ជាតិពណ៌ក្រហមនិងលឿងបានលេចឡើងក្នុងពពកផ្សែងពណ៌ខៀវ បន្ទាប់មករថក្រោះមួយហើយមួយទៀត ចេះតែលេចចេញជាបន្តគ្នា ។ ខាំផាន ស្រែកថា "នោះន៎រថក្រោះច្រើនណាស់" បន្ទាប់មកដើម្បីជាកិត្តិយសដល់អ្នកទាំងនោះ គាត់ក៏ស្រែកឲ្យបុគ្គលិករបស់គាត់"លើកទង់ជាតិឡើង!" ។

មួយម៉ោងក្រោយមក លេខាទីពីរនៃស្ថានទូតបានល្បងប្រថុយចេញទៅខាងក្រៅ ។ ដោយកាយវិការចម្លែក គាត់បានទាក់ទាញនូវការយកចិត្តទុកដាក់ពីទាហានល្បាតវៀតណាមមួយក្រុមតូចដែលដើរចុះតាមមហាវិថីដ៏ស្ងាត់ជ្រងំនេះ ។ ដោយភ្ញាក់ផ្អើល វៀតណាមបានភ្ជង់កាំភ្លើងតម្រង់មករកគាត់នៅពេលដែលគាត់យកដៃទាំងពីរដាក់លើក្បាល ។ កាលបើពួកនោះដើរមកជិត គាត់ក៏យកដៃចង្អុលបង្ហាញស្ថានទូតរបស់ខ្លួនហើយប្រាប់

ឈ្មោះនិងមុខងាររបស់គាត់ទៅកងទ័ពខ្មែរម្នាក់ដែលឃើញមានតែម្នាក់គត់ក្នុងក្រុមនេះ ។ នៅយប់នោះ ទាហានវៀតណាមដប់ពីរនាក់បានមកជួយយាមកាមស្ថានទូតឡាវ ។ សុបិនអាក្រក់បានបញ្ចប់ ។ ខាំផាន ដែលសប្បាយស្ទើរឆ្កួតនោះបានរៀបពិធីជប់លៀងយ៉ាងធំមួយចំពោះ"អ្នករំដោះ"ទាំងនេះ[១] ។

## អ្នកណាដែលត្រូវការសន្ធិសញ្ញាមិត្តភាពមួយ?

ក្នុងពេលដែលក្រុមអ្នកការទូតឡាវ ប្រារព្ធពិធីជ័យជម្នះនៅក្រុងភ្នំពេញរួមជាមួយអ្នកគាំពារថ្មីរបស់ពួកគេ មនុស្សទាំងអស់មិនទាន់បាត់ងឿងឆ្ងល់នឹងរឿងនេះនៅឡើយ ។ អ្វីដែលភ្ញាក់ផ្អើលជាងនេះទៅទៀតគឺថា មិនដល់ពីរសប្តាហ៍ផង ប្រទេសវៀតណាមអាចសម្រេចជោគជ័យវាយបំបាក់ប្រទេសសង្គមនិយមជិតខាងខ្លួន និងកម្ចាត់ចេញពីអំណាចនូវសម្ព័ន្ធមិត្តតែមួយគត់របស់ប្រទេសចិននៅអាស៊ីអាគ្នេយ៍ ។ តាមការពិត សង្គ្រាមផ្ទៃកបន្ទោរនេះបានត្រូវសម្រេចជាច្រើនខែមកហើយ ដោយការរៀបចំប្រុងប្រៀបយ៉ាងសម្ងៀមទាំងផ្នែកការទូត និងយោធានៅប្រទេសវៀតណាមក៏ដូចនៅប្រទេសចិន ។ សន្ធិសញ្ញាសូវៀត-វៀតណាមត្រូវបានបន្តដោយការរៀបចំឲ្យមានទំនាក់ទំនងការទូតរវាងចិន-អាមេរិកាំងឡើងវិញ ។ ការចូលលុកលុយប្រទេសកម្ពុជាដោយប្រទេសវៀតណាម បានកើតមានមុនការឈ្លានពានប្រទេសវៀតណាម ដោយប្រទេសចិនបន្តិច ។ ក្នុងរយៈពេលបីខែ ព្រំដែននយោបាយនៅអាស៊ីនឹងត្រូវធ្វើឲ្យភាន់ប្រែទាំងអស់ ។

បន្ទាប់ពីការបណ្តេញជនជាតិចិនពីប្រទេសវៀតណាម ក្នុងអំឡុងរដូវក្តៅឆ្នាំ១៩៧៨ ក្រុងហាណូយបានប្រឹងប្រែងបង្ហាញឲ្យឃើញថា ប្រទេសចិនជាអ្នកគំរាមកំហែងមួយសម្រាប់ស្ថិរភាពនៅអាស៊ីភាគអាគ្នេយ៍ទាំងមូល ដោយសាកល្បងធ្វើឲ្យមានការខិតចូលជិតគ្នាមួយជាមួយបណ្តាប្រទេសនៃសមាគមអាស៊ានផង ៖ វៀតណាមត្រូវតែការពារអព្យាក្រឹតភាពរបស់ខ្លួនក្នុងការវិវាទដែលនឹងមកដល់នៅពេលខាងមុខ ។ នេះជាការផ្លាស់ប្តូរគំនិតភ្លាមៗគួរឲ្យកត់សម្គាល់គឺក្នុងរយៈពេលជាច្រើនឆ្នាំមកហើយ ដែលវៀតណាមធ្លាប់តែបញ្ចេញអាការៈមើលងាយចំពោះអង្គការអាស៊ាននេះដែលបង្កើតឡើងក្នុងឆ្នាំ១៩៦៧ពេលដែលសង្គ្រាមវៀតណាមកំពុងផ្ទុះពេញទំហឹងហើយថា នេះគ្រាន់តែជា"ផលមួយនៃនយោបាយអន្តរាគមន៍ និងឈ្លានពានរបស់ចក្រពត្តិនិយមអាមេរិកាំងប៉ុណ្ណោះ"[២] ។

ប៉ុន្តែ នៅដើមរដូវក្តៅឆ្នាំ១៩៧៦ ដោយចៀសវាងភាពស្និទ្ធស្នាលរបស់ខ្លួនយ៉ាងប្រយ័ត្នប្រយែងនោះ ក្រុងហាណូយបែរជាយល់ព្រមតាមសំណើរបស់សមាគមអាស៊ានក្នុងការធ្វើឲ្យមានប្រក្រតីភាពទំនាក់ទំនងការទូត និងពង្រីកសហប្រតិបត្តិការជាទ្វេភាគីថែមទៀត ។

ក្នុងលំដាប់ដែលការវិវាទជាមួយប្រទេសចិនមានសភាពគំរាមកំហែងកាន់តែខ្លាំងឡើងៗ វៀតណាម អាចនឹងបោះបង់ខដាក់លក្ខខណ្ឌផ្សេងៗដែលពួកគេអាចទទួលរងផលអាក្រក់ចំពោះការដឹកនាំស្និទ្ធស្និមប្រទេសជា

ចំហរបស់សមាគមអាស៊ានដែរ ។ មិនយូរប៉ុន្មានបញ្ហាទាំងអស់អាចឲ្យដឹងថា ក្រុងហាណូយឬក្រុងប៉េកាំងនឹងទទួលបានជោគជ័យក្នុងការទាក់ទាញ“ចិត្តនិងគំនិត” បណ្ដាប្រទេសប្រឆាំងកុម្មុយនីស្តយ៉ាងខ្លាំងក្លាក្បែរខាងខ្លួន ។ នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានបើកយុទ្ធនាការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជាក្នុងលក្ខណៈសម្ងាត់បំផុត រហូតដល់ចេញទម្លាក់សាមសិបដងក្នុងមួយថ្ងៃក៏មាន ។ ក្នុងពេលជាមួយគ្នានោះ វៀតណាមបានសម្ដែងឲ្យដឹងពីការត្រៀមជជែកពិភាក្សាគ្នាដោយផ្ទាល់ជាមួយសមាគមអាស៊ាន និងជាមួយប្រទេសសមាជិកនីមួយៗដាច់ដោយឡែកពីគ្នាផងដែរ ដែលរហូតមកដល់ពេលនោះសុទ្ធតែបដិសេធមិនចរចាជាមួយ ដោយការមិនទុកចិត្ត ។ នៅខែកក្កដា ផាន់ ហៀន បានធ្វើដំណើរទៅកាន់ប្រទេសម៉ាឡេស៊ី ។ នៅទីនោះ គាត់បានចាប់ផ្ដើមបង្ហាញខ្លួនជាអ្នករៀបចំធ្វើឲ្យតំបន់នេះទៅជាតំបន់សន្តិភាព និងអព្យាក្រឹតភាពមួយ ជាមួយគេជាមួយឯង ។

“យុទ្ធនាការប្រលោមស្នេហ៍” បានបន្តទៅទៀតជាមួយដំណើរជាប្រវត្តិសាស្ត្រនៅខែកញ្ញា របស់រដ្ឋមន្ត្រីទីមួយ ផាំ វ៉ាន់ដុង ។ នៅទីក្រុងកូឡាលំពួរ ដុង បានដាក់កម្រងផ្កានៅវិមានរំឭកវិញ្ញាណក្ខន្ធទាហានម៉ាឡេស៊ីដែលស្លាប់ដោយការវាយប្រយុទ្ធក្នុងសង្គ្រាមស៊ីវិលមួយ ។ ជាឯកជន គាត់ឈានរហូតដល់សុំអភ័យទោសចំពោះ“ម្ចាស់ផ្ទះ”អំពីជំនួយដែលក្រុងហាណូយធ្លាប់បានផ្ដល់ឲ្យពួកខុទ្ទាមម៉ាឡេស៊ីថែមទៀត ។ នៅទីក្រុងបាងកកដុង បានសន្យាចំពោះពួកថៃនូវការមិនគាំទ្ររបស់ខ្លួនដល់គណបក្សកុម្មុយនីស្តថៃដែលខុសច្បាប់ឡើយ ។ តាមការពិត គោលដៅរបស់គាត់គឺធ្វើយ៉ាងម៉េចសម្រេចឲ្យបានសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការមួយជាមួយបណ្ដាប្រទេសនៃសមាគមអាស៊ានដែលនឹងធ្វើឲ្យការខិតចូលជិតគ្នាជាថ្មីរបស់វៀតណាមអំពីទំនាក់ទំនងផ្សេងៗក្នុងតំបន់ទៅជាផ្លូវការឡើង ។ ទន្ទឹមនឹងនោះ សមាគមអាស៊ានក៏មិនទាន់សម្រេចចិត្តភ្លាមៗដែរ ដូចនេះហើយបានជាការស្នើរបស់ ដុង បានត្រូវច្រានចោលដោយសេចក្ដីគួរសម ។ ក៏ប៉ុន្តែ សមាគមអាស៊ានបានយល់ព្រមចេញផ្សាយសេចក្ដីថ្លែងការណ៍មួយដែលគ្រាន់តែឲ្យល្អមើលប៉ុណ្ណោះ ដោយគូសបញ្ជាក់ពីមិត្តភាពដែលកំពុងបង្រួបបង្រួមភាគីទាំងពីរ ។

ប្រទេសវៀតណាមពុំបានសម្រេចជោគជ័យក្នុងការទាក់ទាញប្រទេសថៃឲ្យចូលក្នុងសម្ព័ន្ធភាពមួយប្រឆាំងចិនទេ តែក៏មិនបញ្ចេញពាក្យឲ្យច្បាស់លាស់ដែរ ។ សេចក្ដីថ្លែងការណ៍បានត្រូវផ្សព្វផ្សាយជាសាធារណៈដោយ ដុង ហើយ គ្រៀងសាក់ នាយករដ្ឋមន្ត្រីថៃបានហាមឃាត់មិនឲ្យប្រទេសទាំងពីរ “ប្រព្រឹត្តអំពើ វិទ្ធង្សនាដោយចំពោះ ឬដោយប្រយោលប្រឆាំងនឹងប្រទេសមួយ ឬមួយទៀតឡើយ” និងហាមប្រើប្រាស់ក្នុងទំនាក់ទំនងរបស់ពួកគេនូវ“ការអាងកម្លាំងទ័ពឬការគំរាមកំហែង”ផងដែរ ។ ពួកថៃបានប្រឆាំងជំទាស់នឹងការដាក់បញ្ចូលក្នុងអត្ថបទនៃសេចក្ដីថ្លែងការណ៍ នូវវាក្យខណ្ឌមួយដែលហាមឃាត់ការប្រើប្រាស់ទឹកដី“ប្រទេសទីបី”ណាមួយក្នុងគោលដៅបង្កឲ្យមានអរិភាពនឹងគ្នា ។ ពាក្យនិយាយបញ្ជិតបញ្ជៀងទៅរកប្រទេសចិន និងកម្ពុជានេះ មានលក្ខណៈអាចឲ្យគេយល់ន័យបាន ។

គម្រោងការទាំងឡាយរបស់វៀតណាមស្ថិតក្នុងស្ថានភាពត្រូវធ្វើឲ្យភាន់ប្រែអស់ ។ ការចុះហត្ថលេខាលើសន្ធិសញ្ញាមួយជាមួយសមាគមអាស៊ាននឹងបង្កបានជាខែលការទូតមួយប្រភេទ ដែលជ្រកក្រោមខែលនេះវៀតណាមអាចចាប់ផ្ដើមធ្វើការផ្សងព្រេងរបស់ខ្លួនក្នុងកម្ពុជាមិនខាន ។ ដោយភាពឆោតល្ងង់គួរឲ្យភ្ញាក់ផ្អើលមួយ វៀតណាមសង្ឃឹមថា ការបើកធ្វើកិច្ចចរចាខាងការទូតនឹងលុបបំបាត់សេចក្ដីភ័យខ្លាចផ្សេងៗដែលប្រទេសខ្លួនមាន ហើយវានឹងបង្ហាញឲ្យឃើញពីប្រុងប្រៀបប្រកបដោយមិត្តភាពរបស់ពួកគេចំពោះសមាគមអាស៊ាន នៅពេលដែលពួកគេចូលធ្វើអន្តរាគមន៍ដោយយោធានៅប្រទេសកម្ពុជា ។ ពួកមេដឹកនាំក្រុងហាណូយគិតថា ការសម្រេចកិច្ចព្រមព្រៀងជាខកគោភាគី ជាបន្តបន្ទាប់ជាមួយបណ្ដាប្រទេសជិតខាងខ្លួននៅភាគខាងត្បូង និងកិច្ចព្រមព្រៀងធ្វើឲ្យមានប្រក្រតីភាពមួយជាមួយសហរដ្ឋអាមេរិកនឹងជួយសម្រាលការប្រឆាំងសន្ធិសញ្ញាមួយដែលពួកគេបានសម្រេចចិត្តចុះហត្ថលេខាជាមួយក្រុងមូស្គូដែរ ។

ដោយពិត ដំណើរប្រឹងប្រែងផ្នែកការទូតដែលអនុវត្តដោយវៀតណាមនៅសរទរដូវគឺ ស្ដែងចេញយ៉ាងច្បាស់សម្រាប់គោលដៅផ្នែកយោធាច្រើនជាង ។ ក្រុងហាណូយបានរៀបចំកាលវិភាគមួយទុកជាស្រេចទៅហើយ ។ នៅចុងរដូវក្ដៅឆ្នាំ១៩៧៨ បណ្ដាប្រទេសនៃសមាគមអាស៊ានមានការងឿងឆ្ងល់ខ្លះៗដែរ ពីការទទូចរបស់វៀតណាមក្នុងគោលបំណងធ្វើយ៉ាងណាឲ្យដំណើរទស្សនកិច្ចរបស់ ផាំវ វ៉ាន់ដុង បានប្រព្រឹត្តទៅនៅខែតុលាឆ្នាំ១៩៧៨ យ៉ាងយូរបំផុត ។ អ្នកការទូតមួយចំនួនធំបានធ្វើការសន្និដ្ឋានថា ក្រុងហាណូយចង់ធ្វើឲ្យបានមុន តេងស៊ាវពីង ដែលដំណើរទស្សនកិច្ចនៅប្រទេសថៃ សិង្ហបុរី របស់គាត់ត្រូវបានគ្រោងទុកនៅក្នុងខែវិច្ឆិកាឆ្នាំនោះ ។ ប៉ុន្ដែមិនត្រឹមតែប៉ុណ្ណឹងទេ ក្រុងហាណូយថែមទាំងបានធ្វើការកៀបសង្កត់យ៉ាងខ្លាំងទៅលើបណ្ដាប្រទេសខ្លះនៃសមាគមអាស៊ាន ដើម្បីបង្ខិតបង្ខំប្រទេសទាំងនោះឲ្យបង្ហាញឆន្ទៈរបស់ខ្លួន(ប្រកាន់យកខាងណាៗ)ជាគុណប្រយោជន៍ដល់កិច្ចព្រមព្រៀងមិត្តភាពមួយទៀតផង ។ ឧទាហរណ៍ អ្នកការទូតម៉ាឡេស៊ី ដែលមានមុខតំណែងប្រចាំនៅរដ្ឋធានីរបស់វៀតណាម–តាំងពីឯកអគ្គរដ្ឋទូតរហូតដល់លេខាទីពីរ–សុទ្ធតែត្រូវដាក់ឲ្យស្ថិតនៅក្រោមការឆាឆៅរំខានមួយដោយពិតប្រាកដ ។ គូសន្ទនារបស់ពួកគេ ច្រើនចោលសម្ដីយ៉ាងច្បាស់ថា ក្រុងហាណូយអាចនឹងសើរើពិនិត្យឡើងវិញនូវនយោបាយមិត្តភាពរបស់ខ្លួនជាមួយប្រទេសម៉ាឡេស៊ី បើសិនជាទស្សនកិច្ចរបស់ ផាំ វ៉ាន់ដុង ពុំបានទទួលជោគជ័យមួយទេនោះ[៣] ។ តាមប្រហែល“ជោគជ័យ”គឺមានន័យថា ការចុះហត្ថលេខាលើសន្ធិសញ្ញាដែលស្នើឡើងដោយវៀតណាម ។ ព្រមជាមួយគ្នានោះ នៅចុងម្ខាងទៀតនៃពិភពលោកគឺនៅទីក្រុងញូវយ៉ក រដ្ឋមន្ត្រីការបរទេសវៀតណាម ង្វៀន កូថាច់ ក៏កៀបសង្កត់រដ្ឋាភិបាលអាមេរិកាំងឲ្យចុះហត្ថលេខាលើអត្ថបទមួយ ដែលកំណត់យ៉ាងច្បាស់ពីគោលការណ៍នៃការរៀបចំទំនាក់ទំនងការទូតជាខកគោភាគីមួយឡើងវិញដែរ ។

វៀតណាមបានរៀបចំកម្មវិធីធ្វើការឈ្លានពានរបស់ខ្លួនមកលើប្រទេសកម្ពុជា នៅក្នុងខែធ្នូ ព្រោះជារដូវ

ប្រាំងដែលងាយស្រួលឲ្យរថក្រោះបើកបរ ហើយក៏ចំរដូវប្រូតកាត់ដែរ នេះជាចំណុចសំខាន់បំផុតសម្រាប់ធានាការផ្គត់ផ្គង់ស្បៀងដល់ចលនាតស៊ូខ្មែរ ដែលបានហ៊ឹកហាត់នៅប្រទេសវៀតណាមតាំងពីដើមឆ្នាំ១៩៧៨មក ។ វៀតណាមមិនចង់ឲ្យថ្ងៃខែដែលគេកំណត់ទុកកៀកគ្នាខ្លាំងពេកទៅនឹងថ្ងៃចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពជាមួយក្រុងមូស្គូទេ ពីព្រោះភាពកៀកគ្នានេះអាចបណ្ដាលឲ្យគេជឿថា នេះជាឥទ្ធិពលរបស់ពួកសូវៀតដោយផ្ទាល់ក្នុងការចាប់ផ្ដើមការប្រយុទ្ធគ្នានេះ ។ វៀតណាមនឹកគិតឥតឈប់ឈរថា សន្ធិសញ្ញាត្រូវចុះហត្ថលេខាឲ្យបានមុនសរទរដូវ គឺរបៀបដូចពួកគេធ្វើការកៀបសង្កត់ស៊ើរតែក្នុងពេលជាមួយគ្នាទៅលើសហរដ្ឋអាមេរិក និងបណ្ដាប្រទេសនៃសមាគមអាស៊ានដែរ ។ វៀតណាមខំប្រឹងស្វែងរកការគាំពារពីពួកសូវៀត ប៉ុន្តែពុំមែនត្រូវបង់តម្លៃអ្វីក៏ដោយនោះទេ ហើយក៏មិនត្រូវធ្វើឲ្យសម្ព័ន្ធភាពនេះបិទគ្រប់ច្រកទ្វារសម្រាប់បស្ចិមប្រទេស ទាំងក៏មិនត្រូវធ្វើឲ្យជម្លោះរបស់ខ្លួនជាមួយប្រទេសចិននិងកម្ពុជានាំឆ្ពោះទៅភាពឯកោទាំងស្រុងមួយដែរ ។ ក្នុងគ្រប់ករណីពិសេសទាំងអស់ នយោបាយការទូតដ៏សកម្មមួយនឹងធ្វើឲ្យវៀតណាមមានស្ថានភាពល្អប្រសើរជាងមុនសម្រាប់ជជែករកខុសត្រូវជាមួយពួករុស្ស៊ី ។

## ក្រុងមូស្គូផ្ដល់នូវការធានារបស់ខ្លួន

ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីដំណើរព័ទ្ធជុំវិញអាស៊ីអាគ្នេយ៍របស់ ផាំវ៉ាន់ដុង នៅពាក់កណ្ដាលខែតុលា ឆ្នាំ១៩៧៨ គម្រោងការផ្សេងៗរបស់វៀតណាមហាក់ដូចជារងផលប៉ះពាល់យ៉ាងខ្លាំង ។ ដុង ពុំបានសម្រេចធ្វើឲ្យការមន្ទិលសង្ស័យរបស់សមាគមអាស៊ានថយចុះឡើយ ដោយហេតុនេះ គាត់ត្រូវតែបោះបង់ចោលភ្លាមនូវគំនិតទាំងអស់អំពីរឿងសន្ធិសញ្ញា ។ នៅខែសីហានិងកញ្ញា ភ្លៀងបានបង្អុរយ៉ាងខ្លាំងដែលមិនធ្លាប់មានពីមុនមកនៅប្រទេសវៀតណាម–ព្យុះសង្ឃរានិងទឹកជំនន់–នៅដែនដីទន្លេក្រហម ទន្លេមេគង្គ និងភាគកណ្ដាលប្រទេស ។ ផលិតផលកសិកម្មប្រមាណ១,៥លានតោនត្រូវបានបំផ្លាញ ហើយសត្វចិញ្ចឹមចំនួន ២០ភាគរយក៏ត្រូវវិនាសអន្តរាយ ។ ឱនភាពផ្នែកផលិតផលកសិកម្មដែលជាហេតុនៃការអន្តរាយពិតប្រាកដបានកើនឡើងក្នុងសមាមាត្រដ៏សម្បើម ។ តាមការវាយតម្លៃនៅពេលនោះគឺ៣លានតោន[៤] ។

យោធភូមិភាគទី៩ដែលមានបន្ទុកធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជា ត្រូវបានបំផ្លាញដោយទឹកជំនន់ទន្លេមេគង្គរួមទាំងភាគខាងកើតប្រទេសកម្ពុជាផង ។ ប្រការនេះដូចជាឲ្យដំណឹងដល់រថក្រោះទាំងឡាយរបស់វៀតណាមអំពីស្ថានភាពដីដែលបែកភក់ប៉ប៉ិចប៉ប៉ាច់ដែរ យកល្អគឺទាល់តែក្រោយរដូវភ្លៀង ។ អ្វីដែលធ្វើឲ្យរឹតតែព្រួយបារម្ភថែមទៀត គឺគេគ្មានទទួលបានដំណឹងអ្វីសោះពីសហរដ្ឋអាមេរិក ។ រីឆាដ ហូលប្រ៊ុក បានចាប់ផ្ដើមដំណើរទស្សនាចរមួយនៅអាស៊ីក្នុងពេលដែល ថាច់ ធុញថប់ដោយការរង់ចាំយូរនៅទីក្រុងញូវយ៉ក ។

នៅដំណាច់ខែតុលា ឆ្នាំ១៩៧៨ ការិយាល័យនយោបាយរបស់បក្សកុម្មុយនីស្តវៀតណាមបានធ្វើការ

សម្រេចចិត្តថា ទោះបីជាស្ថានភាពដីមិនអំណោយផល (ការទទួលរងគ្រោះដោយមហន្តរាយទឹកជំនន់ទន្លេមេគង្គ) យ៉ាងណាក៏ដោយ ក៏ការចុះហត្ថលេខាលើសន្ធិសញ្ញាជាមួយក្រុងមូស្គូពុំអាចពន្យារពេលឲ្យយូរតទៅទៀតបានទេ ។ បន្ទាប់ពីការផ្អាកពីរលើក អ្នកចរចាបានចេញដំណើរឆ្ពោះទៅទីក្រុងមូស្គូម្តងទៀត ។ ផាច់ បានទទួលបញ្ជាឲ្យចាកចេញពីញូវយ៉កទៅជួបគ្នានៅទីនោះដែរ ។

នៅទីក្រុងមូស្គូនាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ យន្តហោះអ៊ីលីយូឈីន៦២មួយគ្រឿងដែលគេបានជួលជាពិសេសពីក្រុមហ៊ុនអាកាសចរណ៍ AEOFLOT របស់សូវៀតបានចុះចតនៅចំណតអាកាសយានដ្ឋានវ៉ុយកូវ៉ូក្រោមសំឡេងទះដៃអបអរយ៉ាងខ្លាំងពីអ្នកមកទទួល ។ សមាជិកការិយាល័យនយោបាយចំនួនប្រាំរូប សមាជិកគណៈកម្មាធិការមជ្ឈិមបក្សប្រាំបួនរូប និងអ្នកទទួលខុសត្រូវជាន់ខ្ពស់ជាងដប់រូបទៀតបានមកប្រមូលផ្តុំគ្នានៅទីនេះ ។ ពិធីធ្វើបដិសណ្ឋារកិច្ចមានលក្ខណៈរាក់ទាក់ប្លែកពីធម្មតា ។ ក្រោមការថតរូបភាពរបស់កាមេរ៉ាទូរទស្សន៍ជាច្រើនគ្រឿង ឡេអូនីដ ប្រេសណេវ [ជាអគ្គលេខាបក្សកុម្មុយនីស្តសូវៀតពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៨២] បានចាប់ឱបរឹតគ្នាយ៉ាងយូរជាមួយសមភាគីវៀតណាមរបស់គាត់ ឡេ យន់ ។ បន្ទាប់ពីការគោរពភ្លេងជាតិទាំងពីររួច ឡេ យន់ និង ផាំ វ៉ាន់ដុង បានដើរត្រួតកងកិត្តិយស បន្ទាប់មកគណៈប្រតិភូទាំងមូលបានចេញដំណើរទៅកាន់និវេសនដ្ឋានសម្រាប់ភ្ញៀវបរទេសស្នាក់នៅ ។ តាមបណ្តោយផ្លូវដែលត្រូវធ្វើដំណើរគេឃើញទង់ជាតិវៀតណាម និងសូវៀតរលាស់រវិចៗលាយចម្រុះគ្នាយ៉ាងស្អេកស្កះ ដោយមានចងបដាកាត់ទទឹងថ្នល់ប្រសិទ្ធិពរយ៉ាងច្រើន ដែលមានខ្លឹមសារជាអាទិ៍ថា “ស្វាគមន៍ដំណើរមកដល់របស់មិត្តវៀតណាម” និង “ជយោ! សាធារណរដ្ឋសង្គមនិយមវៀតណាមដែលជាកំពែងជួរមុខនៃលទ្ធិសង្គមនិយមនៅអាស៊ីអាគ្នេយ៍” ។

នៅទីបំផុត បំណងដ៏ខ្ជាប់ខ្ជួនរបស់ពួកសូវៀតដែលរក្សាទុកតាំងពីយូរយារមកហើយ ក្នុងការបញ្ចូលប្រទេសវៀតណាមក្នុងសម្ព័ន្ធភាពមួយប្រឆាំងប្រទេសចិនត្រូវបានសម្រេចនៅពេលនេះ ។ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ពួកមេដឹកនាំនៃប្រទេសទាំងពីរ បានជួបជុំគ្នាក្នុងមហាសាលនៃវិមានក្រឹមឡាំង ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការមួយដែលកំណត់សម្រាប់រយៈពេល២៥ឆ្នាំ ។ មាត្រាទី៦នៃអត្ថបទកិច្ចព្រមព្រៀងនេះបានបង្ហាញពីការធានាថា ប្រទេសវៀតណាមស្ទុះស្ទែងរកឲ្យបានការគាំទ្រមួយប្រឆាំងនឹងការវាយប្រហារដោយថាហេតុរបស់ចិន ៖ “បើសិនភាគីណាមួយក្នុងចំណោមភាគីទាំងពីរត្រូវវាយប្រហារ ឬ រងទទួលការគំរាមកំហែងពីការវាយប្រហារណាមួយ ប្រទេសហត្ថលេខីទាំងពីរត្រូវចូលរួមប្តឹងបរិហារចំពោះរឿងនេះជាបន្ទាន់ ដើម្បីកម្ចាត់ចោលការគំរាមកំហែងនេះ និងចាប់ផ្តើមអនុវត្តវិធានការសមស្របក្នុងការគាំពារសន្តិភាព និងសន្តិសុខរបស់ប្រទេសទាំងពីរ”[៥] ។

ប្រេសណេវ ដែលត្រូវធ្វើឲ្យសប្បាយរីករាយយ៉ាងខ្លាំងនឹងសេចក្តីព្យាយាមរបស់គាត់បានគូសបញ្ជាក់ថា សន្ធិសញ្ញានេះនឹងធ្វើឲ្យអ្នកទាំងឡាយដែលគ្មានផលប្រយោជន៍ណាមួយក្នុងមិត្តភាពរវាងប្រទេសវៀតណាមនិង

សហភាពសូវៀត អ្នកទាំងឡាយដែលគេងយកប្រយោជន៍ពីលើការបែកបាក់របស់ពួកសង្គមនិយម និងការឡើងដល់កម្រិតនៃភាពតានតឹងព្វដ៏ផ្ទៃក្នុងរបស់ខ្លួនមិនសប្បាយចិត្តឡើយ ។ គាត់បានបន្ថែមថា “ចាប់ពីពេលនេះទៅ សន្ធិសញ្ញានេះគឺជាតថភាពនយោបាយមួយ ហើយថាត្រូវតែយកចិត្តទុកដាក់នឹងរឿងនេះទោះជាពេញចិត្តឬមិនពេញចិត្តក៏ដោយ”[៦] ។

ពិតហើយ តថភាពនយោបាយ ប៉ុន្តែក៏មានតថភាពយោធាដែរ ដូចដែលគេនឹងរកឃើញរឿងនេះយ៉ាងឆាប់រហ័ស ។ “វិធានការសមស្រប” ដែលរំពឹកដោយមាត្រាទី៦នៃសន្ធិសញ្ញា ក៏មានដាក់បញ្ចូលនូវការអនុញ្ញាតឲ្យពួកសូវៀតរៀបចំដាក់មូលដ្ឋាននាវាចរណ៍និងអាកាសចរណ៍នៅលើទឹកដីរបស់វៀតណាមដែរ ។ សម្រាប់ប្រទេសវៀតណាម នេះជាតម្លៃដែលត្រូវបង់ដើម្បីទទួលបានការគាំពារពីសូវៀតប្រឆាំងនឹងប្រទេសចិន ការផ្គត់ផ្គង់បរិមាណអាវុធយុទ្ធភណ្ឌ និងសម្ភារបរិក្ខារផ្សេងៗយ៉ាងសន្ធឹកសន្ធាប់មួយព្រមទាំងកិច្ចសន្យាផ្ដល់ជំនួយសេដ្ឋកិច្ចមួយថែមទៀត ជាពិសេសការផ្ដល់គ្រាប់ធញ្ញជាតិចំនួន១,៥លានតោន ។ ប៉ុន្តែ នៅខែសីហា ឆ្នាំ១៩៧៨ នៅពេលដែលរាល់សេចក្ដីសង្ឃឹមក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយសហរដ្ឋអាមេរិកនៅមិនទាន់បាត់បង់នោះ ផាំ វ៉ាន់ដុង បានបញ្ជាក់ថា ប្រទេសរបស់គាត់មិនចង់ពឹងផ្អែកលើប្រទេសមួយក្នុងកិច្ចការរបស់ខ្លួនទេ ។ គាត់និយាយថា “តាំងពី៤០០០ឆ្នាំមកហើយ រៀងរាល់លើកដែលប្រទេសរបស់យើងបណ្ដែតបណ្ដោយពឹងផ្អែកតែអ្នកឧបត្ថម្ភគាំពារម្នាក់លទ្ធផលគឺការវិនាសហិនហោចមួយ”[៧] ។ បីខែក្រោយមក ស្ថានភាពប្រទេសវៀតណាមមានរបៀបដូចនោះឯង ។

បន្ទាប់ពីចុះហត្ថលេខាលើសន្ធិសញ្ញារួចមក ក្នុងឱកាសជប់លៀងមួយនៅវិមានក្រឹមឡាំង ឡេ យន់ បានប្រកាសថា ចាប់ពីពេលនេះទៅ ប្រទេសវៀតណាមមានមធ្យោបាយគ្រប់គ្រាន់ដើម្បី“បំពេញប្រកបដោយកិត្តិយសនូវបេសកកម្មដ៏ពិសិដ្ឋសម្រាប់ជាតិរបស់ខ្លួន” ព្រមទាំង“កាតព្វកិច្ចដ៏ខ្ពង់ខ្ពស់ជាអន្តរជាតិ”របស់ខ្លួនផង គឺការពារខ្លួនប្រឆាំងទល់នឹងប្រទេសចិន និងធ្វើអន្តរាគមន៍នៅប្រទេសកម្ពុជា ។ ការដឹងគុណរបស់វៀតណាមចំពោះពួកសូវៀត តាមមតិអ្នកសង្កេតការណ៍បរទេសខ្លះថា គឺធំណាស់ទៅរហូតទាល់តែធ្វើឲ្យវៀតណាមមានអារម្មណ៍ថា ដូចបានទទួល“អំណោយសម្រាប់ជីវិត”អ៊ីចឹង ។ ឡេ យន់ បន្ទន់ខ្លួនគោរព“ម្ចាស់ផ្ទះ”ពីរដងមុននឹងឡើងលើយន្តហោះត្រឡប់មកប្រទេសវិញ ។ ពេលនោះគឺថ្ងៃ៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

## ការរៀបចំប្រុងប្រៀបធ្វើសង្គ្រាមនៅព្រំដែនរបស់ចិន

ក្នុងអំឡុងនៃការស្នាក់អាស្រ័យនៅទីក្រុងមូស្គូរបស់គណៈប្រតិភូវៀតណាម ពួកចិនក៏មិននៅធ្វើព្រងើយដែរ ពួកគេបានរៀបចំបង្កើយជាសម្ងាត់ក្នុងការដឹកនាំបញ្ជា បញ្ជូនភ័ស្ដុភារ និងសម្ភារសឹករួចជាស្រេចសម្រាប់ការវាយលុករបស់ខ្លួនប្រឆាំងនឹងប្រទេសវៀតណាម ។ តាំងពីខែសីហា ឆ្នាំ១៩៧៨ ផ្នែកស៊ើបការណ៍សម្ងាត់

របស់អាមេរិកាំងបានរកឃើញសញ្ញាផ្សេងៗនៃការបង្កើនសកម្មភាពដ៏ខ្លាំងក្លាមួយនៅក្នុងយោធភូមិភាគហ្គាងហ្ស៊ូ ជាប់នឹងព្រំដែនប្រទេសវៀតណាម ។ បណ្ដាស្ថានីយផ្កាយរណបចារកម្មដែលកំពុងត្រូវប្រើជាភស្តុតាងបន្ថែមទៅលើចម្លើយជាសាក្សីរបស់អ្នកដំណើរអាមេរិកាំងនៅភាគខាងត្បូងប្រទេសចិននោះ បានបង្ហាញឲ្យដឹងថាកងយន្តហោះមិច-១៩ និងមិច-២១ មួយចំនួនធំរបស់កងអាកាសចរណ៍យោធាចិនបានរើផ្លាស់កន្លែងមកកាន់អាកាសយានដ្ឋាននានាដែលនៅកៀកព្រំដែនវៀតណាមជាងគេបំផុត ជាពិសេសនៅណាន់នីង [ទីរួមខេត្តហ្គាងស៊ី] និងគន់មីង [ទីរួមខេត្តយុនណាន] ។ កងរថក្រោះនិងកាំភ្លើងធុនធ្ងន់ក៏ត្រូវដឹកជញ្ជូនសំដៅមកភាគខាងត្បូងដែរ ។ នៅដើមខែវិច្ឆិកា ការរៀបចំបម្រុងទាំងនេះបានចប់សព្វគ្រប់ ។ ការប្រមូលផ្ដុំកងទ័ពរថក្រោះ និងកាំភ្លើងធំដ៏ច្រើនបានស្ថិតនៅតាមទីតាំងក្បែរបង្កើយនឹងព្រំដែន ។ កន្លែងស្តុកប្រេងឥន្ធនៈធំៗក៏បានកសាងរួចជាស្រេច ។ នៅពាក់កណ្ដាលខែវិច្ឆិកា ពួកអាមេរិកាំងបានស៊ើបដឹងពីការរៀបចំតាំងស្ថានីយបណ្ដាក់មួយសម្រាប់ឆ្លើយឆ្លងតាមទូរស័ព្ទ ដោយប្រើរលកធាតុអាកាសខ្លីនៅលើកំពូលភ្នំតូចមួយក្នុងខេត្តហ្គាងស៊ី ។ ស្ថានីយនេះអនុញ្ញាតឲ្យអគ្គសេនាធិការកងទ័ព និងគណៈកម្មាធិការកិច្ចការយោធារបស់បក្សកុម្មុយនីស្តចិន មានលទ្ធភាពទាក់ទងគ្នាដោយផ្ទាល់ជាមួយបញ្ជាការដ្ឋាននានារបស់កងទ័ពរំដោះប្រជាជនដែលស្ថិតនៅភាគខាងត្បូង[៨] ។

ចំពោះការរៀបចំប្រុងប្រៀបធ្វើសង្គ្រាមរបស់ចិន គេបានពឹងពាក់លើព័ត៌មានផ្សេងៗដែលអ្នករត់ចោលជួរម្នាក់នៃកងទ័ពរំដោះប្រជាជនចិនបាននិយាយប្រាប់ក្រុមស៊ើបការណ៍សម្ងាត់អាមេរិកាំង នេះពិតជាកំណប់ដំណឹងមួយយ៉ាងសំខាន់ ។ អ្នករត់ចោលជួរនេះមានឋានៈជាអនុសេនីយ៍ត្រីដែលបំពេញមុខងារនៅយោធភូមិភាគហ្គាងស៊ី ហើយដែលត្រូវបានចាប់ខ្លួនដោយប៉ូលិសហុងកុងក្នុងពេលដែលគាត់ប៉ុនប៉ងជ្រៀតចូលមកក្នុងទឹកដីអាណានិគមអង់គ្លេសដោយខុសច្បាប់ ។ ប៉ូលិសបានប្រគល់រូបគាត់ទៅឲ្យផ្នែកសួរយកការណ៍ខាងយោធារបស់អង់គ្លេសនិងអាមេរិកាំងនៅទីនោះ ហើយគាត់បានលាតត្រដាងថា នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៨ មេបញ្ជាការនៃកងឯកភាពរបស់គាត់បានថ្លែងសុន្ទរកថាមួយ ដោយរំឭកពីលទ្ធភាពដែលអាចមានសង្គ្រាមមួយប្រឆាំងវៀតណាមនៅពេលខាងមុខឆាប់ៗ ។ មិនយូរប៉ុន្មានក្រោយមកគឺនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៨ ឧត្តមសេនីយ៍ វ៉ៃ ហ្គូជីង ប្រធានកិច្ចការនយោបាយនៃកងទ័ពរំដោះប្រជាជនបានប្រកាសក្នុងសម័យប្រជុំមួយនៅណាន់នីងក្នុងពិធីបុណ្យខួបលើកទី២០នៃការបង្កើតភូមិភាគស្វយ័ត ហ្សួាង ក្នុងខេត្តហ្គាងស៊ីថា ប្រទេសវៀតណាមបានបង្កអំពើប្រទូសរ៉ាយយ៉ាងច្រើន ហើយថា ប្រទេសចិនមានគោលបំណង“ផ្ដល់មេរៀនមួយ” ចំពោះប្រទេសនេះ ។ វ៉ៃ អាយុ ៧២ឆ្នាំ ជាមេដឹកនាំជនជាតិភាគតិច ហ្សួាង នៅភូមិភាគនេះគឺជាមនុស្សម្នាក់ ដែលត្រូវរាប់បញ្ចូលក្នុងចំណោមអ្នកមាននិន្នាការនិយមផ្លូវកណ្ដាលរបស់បក្សកុម្មុយនីស្តចិន ហើយខាងផ្នែកយោធាគាត់គឺជាសម្ព័ន្ធមិត្តដ៏សំខាន់របស់ តេង ស៊ាវពីង ដែលជាជនខ្លាំងថ្មីម្នាក់របស់ប្រទេសទៀតផង ។ សុន្ទរកថារបស់គាត់បានឲ្យសញ្ញាដល់ការរៀបចំប្រុងប្រៀបនៅដំណាក់កាលចុងក្រោយសម្រាប់ធ្វើការលុកលុយយ៉ាងពិតប្រាកដ ។

ប្រជាជននៃភូមិភាគស្វយ័ត ហ្វាង នៃខេត្តហ្គាងស៊ី ដែលរស់នៅជាប់ព្រំដែនប្រទេសវៀតណាម គឺប្រមូលផ្តុំជាសំខាន់នូវជនជាតិភាគតិចដែលគេប្រទះឃើញនៅម្ខាងទៀតនៃព្រំដែនដែរ ។ វាសមហេតុសមផលណាស់ដែល វ៉ៃ ធ្លាប់មានមុខជួយខ្នះខ្នែងដោយផ្ទាល់ក្នុងការផ្តល់ជំនួយយោធារបស់ចិនទៅឲ្យពួកកុម្មុយនីស្តវៀតណាម ។ គាត់ធ្លាប់ធ្វើជាទីប្រឹក្សាយោធាអមបញ្ជាការដ្ឋានរបស់វៀតណាមនៅពេលដែលមានការឡោមព័ទ្ធឌៀនបៀនភូនៅឆ្នាំ១៩៥៤ ។ នៅពេលដែលបដិវត្តន៍វប្បធម៌កំពុងមានកំសួលពេញទំហឹង គាត់បានក្លាយទៅជាគោលដៅវាយប្រហាររបស់ពួកឆ្មាំក្រហមដែរ ពីព្រោះដោយសារគាត់ការពារសន្ធវាក់ក្នុងការផ្តល់គ្រឿងសព្វាវុធ ទៅឲ្យវៀតណាមដែលនាំឆ្លងកាត់តាមតំបន់របស់គាត់គ្រប់គ្រង ។ ដប់ពីរឆ្នាំក្រោយមក គឺមនុស្សដដែលនេះឯងដែលមានករណីយកិច្ចប្រកាសប្រាប់កងទ័ពរំដោះប្រជាជនថា ខ្លួនត្រូវទទួលភារកិច្ចដាក់ទណ្ឌកម្មប្រទេសវៀតណាមដោយសារ“ការរមិលគុណ”របស់គេ ។ នៅថ្ងៃបន្ទាប់ពីសុន្ទរកថា របស់គាត់សេនាធិការរបស់យោធភូមិភាគ ហ្គាងស៊ី ត្រូវបានផ្ទេរមកភាគខាងត្បូងកាន់តែឆ្ងាយថែមទៀត ក្នុងពេលដែលកងពលធំលេខ១របស់អ្នករត់ចោលជួរដែលត្រូវចាប់ខ្លួនបាននៅហុងកុង បានរៀបចំបោះទីតាំងនៅចម្ងាយពីរគីឡូម៉ែត្រពីព្រំដែន ហើយចាប់ផ្តើមហ្វឹកហ្វឺននិងប្រជុំរៀនសូត្រកូនទាហានរបស់ខ្លួនយ៉ាងសកម្ម[៩] ។ នៅពាក់កណ្តាលខែធ្នូ សៀវភៅស្តើងមួយដែលបោះពុម្ពរំលេចដោយរូបភាពពណ៌ត្រូវបានចែកចាយឲ្យបណ្តាកងឯកភាពទ័ពនានា ដែលបោះទីតាំងនៅតាមបណ្តោយព្រំដែន ។ សៀវភៅនេះពិពណ៌នាអំពីឯកសណ្ឋាននិងលក្ខណៈសម្គាល់គ្រឿងអាវុធផ្សេងៗគ្នារបស់កងទ័ពវៀតណាម ។

នៅពេលដែលប្រទេសចិនកំពុងធ្វើការរៀបចំប្រុងប្រៀបផ្នែកយោធាពេញទំហឹងនោះ តេង ស៊ាវពីង បានចាប់ផ្តើមធ្វើដំណើរទស្សនកិច្ចមួយទៅកាន់បណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ដែរ ។ ដំណើរបន្តបន្ទាប់គ្នារបស់គាត់ទៅកាន់ប្រទេសថៃ ម៉ាឡេស៊ី និង សិង្ហបុរី មានរយៈពេលប្រាំបួនថ្ងៃ ។ បេសកកម្មរបស់គាត់ស្ថិតនៅត្រង់ធ្វើឲ្យបណ្តាគូសន្ទនារបស់គាត់បាត់ភ័យព្រួយ ៈ ប្រទេសចិនចង់ធ្វើខ្លួនជាអ្នកធានា សន្តិសុខប្រចាំតំបន់ ។ ដោយហេតុនេះ តេង សង្ឃឹមរកឲ្យឃើញការគាំទ្រកាត់ក្នុងជម្លោះជាមួយប្រទេសវៀតណាម ។ បើទុកជាប្រទេសចិនបោះបង់ចោលតាំងពីដើមទសវត្សរ៍៧០ មិនសម្តែងឲ្យឃើញភាពប្រទូសរ៉ាយណាមួយចំពោះបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ហើយចាប់ផ្តើមរៀបចំទំនាក់ទំនងការទូតឡើងវិញជាមួយបណ្តាប្រទេសជាសមាជិកសមាគមអាស៊ាន (លើកលែងតែប្រទេសមួយ) ចាប់ពីឆ្នាំ១៩៧៥ក៏ដោយ ក៏បរិយាកាសក្នុងកិច្ចជួបសន្ទនាទាំងឡាយមានលក្ខណៈថ្មីសន្ធាងទាំងស្រុង ។ ប្រាកដហើយ ក្នុងរយៈពេលដ៏ជាក់លាក់មួយទំនាក់ទំនងផ្នែកពាណិជ្ជកម្មនិងវប្បធម៌បានរីកលូតលាស់គួរជាទីពេញចិត្ត ប៉ុន្តែការគាំទ្រដែលប្រទេសចិនបន្តផ្តល់ឲ្យពួកឧទ្ទាមកុម្មុយនីស្តថៃនិងម៉ាឡេស៊ី បាននាំឲ្យសៅហ្មងដល់ទំនាក់ទំនងជាខភគោភាគីយ៉ាងខ្លាំង ។ នៅទីក្រុងប៉េកាំង គេធ្លាប់ទាញហេតុផលថាទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋគ្មានទាក់ទងនឹងទំនាក់ទំនងជាបងប្អូន ដែលបក្សកុម្មុយនីស្តចិនថែរក្សាជាមួយ

បណ្តាគណបក្សខ្លះនោះទេ គ្មានអ្នកណាម្នាក់ដឹងថាត្រូវធ្វើយ៉ាងម៉េចឡើយ ។ បើទុកជាមានការប្រកែករបស់ចិនក៏ដោយ ក៏បណ្តារដ្ឋាភិបាលនៃសមាគមអាស៊ានដឹងយ៉ាងច្បាស់ថា ការផ្សាយរបស់វិទ្យុពួកកុម្មុយនីស្តថៃនិងម៉ាឡេស៊ីដែលអំពាវនាវឲ្យធ្វើការតស៊ូដោយអាវុធ សុទ្ធតែត្រូវផ្សាយចេញពីប៉ុស្តិ៍ផ្សាយសំឡេងរបស់ចិននៅយុនណាន ហើយថាគ្រឿងសព្វាវុធ និងលុយកាក់ដែលពួកខ្ទាមមានសម្រាប់ប្រើប្រាស់គឺចេញមកពីក្រុងប៉េកាំងដែរ ។ កាលពីពីរ-បីសប្តាហ៍មុន ផាំ វ៉ាន់ដុង បានអះអាងនឹងបណ្តាប្រទេសនៃសមាគមអាស៊ានជាសាធារណៈថា ប្រទេសវៀតណាមមិនគាំទ្រអំពើវិទ្ធង្សនាទេ ។ អាស្រ័យហេតុនេះ ប្រទេសចិនត្រូវដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពមួយដែលពិបាក ដោះស្រាយបំផុត ៖ ឬមួយចិនត្រូវយកគម្រាប់តាមប្រទេសវៀតណាមដោយមិនរវល់ដល់គោលការណ៍ទាំងឡាយរបស់ខ្លួន ឬមួយត្រូវប្រកាន់ជំហររបស់ខ្លួនដដែល ហើយប្រថុយប្រថានដាក់ខ្លួនឲ្យក្រុងហាណូយ ធ្វើការឃោសនាស្តីពី«ការគំរាមកំហែង»របស់ចិន? ។

តេង បានដោះស្រាយ«ភាពរារែកគំនិត»នេះ ដោយសម្រេចធ្វើការវាយលុកផ្នែកការទូតតែម្តង ។ ក្នុងឱកាសធ្វើសន្និសីទកាសែតមួយនៅក្រុងបាងកក ដោយឆ្លើយតបទៅនឹងសំណួរមួយស្តីពីចំណងទាក់ទងរបស់ប្រទេសចិនជាមួយពួកកុម្មុយនីស្តថៃ តេង បានឆ្លើយថា «ខ្ញុំមិនភូតកុហកដូច ផាំ វ៉ាន់ដុង ទេ» ។ «សម្តីស្មោះត្រង់គឺជាលក្ខខណ្ឌចាំបាច់ខានមិនបានក្នុងការរៀបចំឲ្យមានទំនាក់ទំនងល្អប្រសើររវាងរដ្ឋនិងរដ្ឋ»[១០] ។ តេង បានប្រកាន់ជំហរជាគោលការណ៍របស់គាត់ពីរឿងនេះតាមផ្លូវការថា ប្រទេសចិននឹងបន្តផ្តល់នូវការគាំទ្រមួយខាងផ្លូវចិត្តចំពោះបក្សកុម្មុយនីស្តជាបងប្អូនទាំងអស់ ។ ប៉ុន្តែជាឯកជន គាត់បានសន្យាជាមួយ គ្រៀងសាក់ នាយករដ្ឋមន្ត្រីថៃថា ឈប់គាំទ្រគណបក្សកុម្មុយនីស្តថៃហើយ ។ ការបោះបង់លែងគាំទ្រនេះប្រហែលជានៅតែជារឿងអាថ៌កំបាំង ព្រោះថា ក្នុងករណីផ្ទុយ ពួកសូវៀតនឹងឆក់ឱកាសសម្រុកចូលធ្វើការ វាយប្រហារមិនខាន ហើយនេះពុំមែនបាត់បង់ផលប្រយោជន៍តែប្រទេសចិនទេ សមាគមអាស៊ាន ក៏ត្រូវបាត់បង់ដែរ ។

## តេង ភាន់ចង្កូត

ដោយបដិសេធជាសាធារណៈមិនប្រើអំពើវិទ្ធង្សនា វៀតណាមបានទទួលអត្ថប្រយោជន៍មួយ សម្រាប់ប្រឆាំងនឹងប្រទេសចិនជាស្រេច ។ ប៉ុន្តែអត្ថប្រយោជន៍នេះត្រូវទុកជាមោឃៈ ដោយការប្រកាសឲ្យដឹងអំពីការចុះហត្ថលេខាលើសន្ធិសញ្ញាសូវៀត-វៀតណាមពីរថ្ងៃមុនការឡើងកាន់អំណាចរបស់ តេង ។ តាមការមើលឃើញរបស់សមាគមអាស៊ានយល់ថា ឆន្ទៈចង់បានឯករាជ្យភាពនិងការមិនចូលបក្សសម្ព័ន្ធដែលប្រកាសដោយក្រុងហាណូយបានធ្វើឲ្យបាត់បង់លក្ខណៈដែលនាំឲ្យជឿទាំងអស់ ។ សេចក្តីស្នើរបស់ តេង ស្តីពី«អនុត្តរភាពនិយមពីរ» គឺសូវៀតនិងវៀតណាមទទួលបានការគាំទ្រជាបន្ថែមទៀត ។

នៅថ្ងៃទី៦ ខែវិច្ឆិកា ក្នុងឱកាសជួបតទល់គ្នាតែពីរនាក់ តេង បានធ្វើឲ្យ គ្រៀងសាក់ ភ្ញាក់ផ្អើលព្រមគ្នា

ដោយភាពស្មោះត្រង់ និងការមិនអត់អធ្យាស្រ័យរបស់គាត់ ។ គាត់បាននិយាយប្រាប់ គ្រៀងសាក់ ថា "វាប្រហែលជាប្រាកដមែនដែលក្រុងភ្នំពេញត្រូវដួលរលំ ប៉ុន្តែទោះជាយ៉ាងណា សង្គ្រាមនឹងពុំចប់ទេ វាទើបនឹងចាប់ផ្ដើមតែប៉ុណ្ណោះ"[១១] ។

ប្រទេសចិនពុំយល់ស្របនឹងនយោបាយរបស់ ប៉ុល ពត ឡើយ ប៉ុន្តែចិនក៏ពុំអាចបោះបង់តំបន់មួយ ដែលមានលក្ខណៈសំខាន់ខាងយុទ្ធសាស្ត្របែបនេះទៅឲ្យវៀតណាមដែរ ។ តេង បានឲ្យដំណឹងមុនថា "ប្រទេសចិននឹងមិននៅស្ងៀមដោយមិនរៀបចំអ្វីនោះទេ យើងនឹងចាត់វិធានការផ្សេងៗដែលនឹងតម្រូវឲ្យយើងធ្វើ" ។ មេដឹកនាំចិនបានបន្ថយសម្ដីឲ្យដឹងដោយការទទូចថា វិធានការទាំងនេះអាចមានទម្រង់ជាការធ្វើអន្តរាគមន៍ខាងយោធាមួយ ។ ប៉ុន្មានថ្ងៃក្រោយមក តេង មានឱកាសលាតត្រដាងពាក្យសំអាងដដែលនេះ នៅមុខពួកមេដឹកនាំប្រទេសសិង្ហបុរីថែមទៀត ។ ឧបនាយករដ្ឋមន្ត្រីសិង្ហបុរី ស៊ីណាថាំប៊ី រ៉ាហ្សារ៉ាត់ណាំ បានកត់សម្គាល់ថា "ពួកចិនពុំមានទម្លាប់បោះបង់ស្នារតីរឹងរបស់គេឡើយ ។ ប៉ុន្តែ នៅពេលដែលនាយករដ្ឋមន្ត្រីទី១ លី ក្វាន់យូ សួរ តេង ពីរឿងវៀតណាម ខ្ញុំឃើញភ្នែករបស់គាត់ជះចេញនូវការក្ដៅក្រហាយយ៉ាងខ្លាំង ហើយគាត់ពុំមែនធ្វើពុតទេ" ។ គាត់ឆ្លើយថា ការរមិលគុណទាំងនោះត្រូវតែផ្ដន្ទាទោស ដោយបានបន្ថែមថា "យើងលែងយោគយល់ពួកគេទៀតហើយ ទាំងលុយកាក់ទាំងញើសឈាមរបស់ចិន" ។ តេង បានសឹកសម្ដីរបៀបមិនច្បាស់ថា "សូមលោកមើលលទ្ធផលចុះ ។ តើនឹងត្រូវផ្ដន្ទាទោសដោយរបៀបណា? យើងបានជ្រើសរើសរួចហើយ" ។ នៅខែកក្កដា ឆ្នាំ១៩៧៨ ពេលដែលការសម្រេចចិត្ត"ផ្ដល់មេរៀនមួយ"ឲ្យក្រុងហាណូយត្រូវបានប្រកាន់យកនោះ គឺវាគ្រាន់តែឆ្លើយតបទៅនឹងការរំលោភបំពានផ្សេងៗ ដែលប្រព្រឹត្តឡើងប្រឆាំងនឹងសហគមន៍ចិននៅប្រទេសវៀតណាមប៉ុណ្ណោះ ។ ប៉ុន្តែ នៅពេលនេះ តេង បានបង្ហាញព្រឹត្តិការណ៍ផ្សេងៗក្រោមទស្សនៈមួយខុសគ្នាយ៉ាងខ្លាំង ។ តាម តេង និយាយគោលដៅរបស់គាត់គឺការពារសន្តិសុខនិងស្ថិរភាព នៅអាស៊ីអាគ្នេយ៍ ហើយជាអាទិ៍នៅប្រទេសថៃ ។ ដំណើរមានគន្លាហូរហែនៃព្រឹត្តិការណ៍សំខាន់ៗដែលត្រូវដោះស្រាយដូចដែលរាយការណ៍ឲ្យដឹងដោយមេដឹកនាំចិន -ការលុកលុយរបស់កងទ័ពវៀតណាមដ៏ច្រើនសម្បើមបន្តដោយសង្គ្រាមតស៊ូដ៏យូរអង្វែងមួយរបស់កម្ពុជា- មានលក្ខណៈដូចទំនាយយ៉ាងចម្លែក ។ ប្រឈមមុខនឹងការវាតទីរបស់វៀតណាម គាត់បានធ្វើឲ្យឃើញពីភាពចាំបាច់ក្នុងការសហការគ្នាដ៏ជិតស្និទ្ធមួយរវាងប្រទេសថៃនិងប្រទេសចិន ។ ប៉ុន្តែ គ្រៀងសាក់ ដែលជាអ្នកចូលចិត្តនយោបាយតុល្យភាពជាប្រពៃណីរបស់ថៃ បានបង្ហាញឲ្យឃើញនូវការរារែកចិត្តខ្លះៗដែលរួមបញ្ចូលប្រទេសរបស់គាត់ឲ្យចូលវាក់វិនក្នុងជម្លោះផ្ទៃក្នុងមួយនៃលទ្ធិកុម្មុយនីស្ត ។ ផ្ទុយទៅវិញ គាត់បានសន្យាធ្វើអន្តរាគមន៍ ប៉ុន្តែបើសិនជាស្ថានការណ៍តម្រូវឲ្យគាត់ធ្វើប៉ុណ្ណោះ[១២] ។

នៅពេលដែលក្រុងប៉េកាំងបង្កើនការប្រគល់សម្ភារបរិក្ខារយ៉ាងសន្ធឹកសន្ធាប់ និងការបញ្ជូនទីប្រឹក្សាជាច្រើននាក់របស់ខ្លួនទៅប្រទេសកម្ពុជាដែលត្រូវកងទ័ពសត្រូវឡោមព័ទ្ធប្រទេសចិនគិតថា វាមានសារសំខាន់

ខ្លាំងណាស់ ដែលយន្តហោះរបស់ខ្លួនអាចហោះហើរពីលើដែនអាកាសរបស់ថៃឆ្ពោះទៅកាន់ក្រុងភ្នំពេញ ដោយហេតុថា ផ្លូវហោះហើរជាប្រពៃណីកាត់តាមប្រទេសឡាវជាសម្ព័ន្ធមិត្តរបស់វៀតណាមលែងផ្តល់នូវការធានាខាងសន្តិសុខគ្រប់គ្រាន់ទៀតហើយ ។ គ្រៀងសារក់ បានយល់ព្រមតាមសំណើរបស់ពួកចិន ។

ក្នុងពេលដែល តេង បន្តដំណើរទស្សនកិច្ចរបស់គាត់នៅអាស៊ីអាគ្នេយ៍ គណៈប្រតិភូមួយដែលដឹកនាំដោយ វ៉ាង ដុងស៊ីង (Wang Dong Xing) សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តចិនក៏មកដល់រដ្ឋធានីរបស់កម្ពុជាដែរ ។ តាមទំនង វ៉ាង ប្រហែលជាមកអះអាងឡើងវិញដោយច្បាស់លាស់នូវការគាំទ្ររបស់ចិនចំពោះប្រទេសកម្ពុជា ទុកណាជាអ្វីៗបង្ហាញឲ្យឃើញពីភាពជិតមកដល់នៃការវាយលុករបស់វៀតណាមក្នុងទំហំយ៉ាងធំមួយក៏ដោយ ។ តាមការពិត រឿងរ៉ាវទាំងនោះមិនសូវជាធម្មតាប៉ុន្មានទេ ។ វ៉ាង អតីតអង្គរក្សការពារ ម៉ៅ ដោយផ្ទាល់គឺជាគូប្រជែងខាងនយោបាយម្នាក់របស់ តេង ស៊ាវពីង ។ គាត់ត្រូវបានចាត់ឲ្យទៅនិយាយប្រាប់បណ្តាមេដឹកនាំនិយមឆ្វេងរបស់គាត់នៅទីក្រុងភ្នំពេញនូវសារមួយដែលមិនជាទីពេញចិត្ត- ដោយនិយាយតែពីរឿងសំខាន់ ៖ ការគាំទ្រជាសាធារណៈចំពោះ «ការតស៊ូដ៏ត្រឹមត្រូវដើម្បីការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី»របស់ប្រទេសកម្ពុជា ប៉ុន្តែ ពុំមានការសន្យាណាមួយអំពីការចូលរួមប្រយុទ្ធខាងយោធាឡើយ ។ ក្រុមមេដឹកនាំចិនបានបន្ថយពាក្យថា ពួកអ្នកឈ្លានពាន «ប្រហែលពុំអាចទប់ឲ្យនៅនឹងកន្លែងបានទេនៅពេលដំបូង» ប៉ុន្តែក្នុងទីបំផុតពួកគេនឹងត្រូវបរាជ័យមិនខាន ។ តាមយោបល់របស់ចិនថា យកល្អត្រូវរៀបចំខ្លួនធ្វើសង្គ្រាមយូរអង្វែងមួយតាមបែបដែនទ័ពព្រៃវិញប្រសើរជាងការធ្វើចម្បាំងរបៀបផ្ទួកបន្ទោរមួយដែលគាំទ្រដោយបរទេស[១៣] ។

តាមការពិត ការបង្ហាញកម្លាំងរបស់វៀតណាមនៅសរទរដូវឆ្នាំ១៩៧៨ នៅទីបំផុតបានធ្វើឲ្យ ប៉ុល ពត ចាប់អារម្មណ៍ហើយក៏ធ្វើឲ្យជំនឿទុកចិត្តពីភាពមិនចេះចាញ់របស់កម្ពុជារង្គោះរង្គើដែរ ។ ហេតុដូច្នេះហើយ បានជាគាត់ស្នើសុំ វ៉ាង ដុងស៊ីង នូវទាហានស្ម័គ្រចិត្តរបស់ចិន ដើម្បីមកវាយប្រយុទ្ធប្រឆាំងវៀតណាមនៅកម្ពុជានោះ ។ ស្ត្រីយុទ្ធិកជនបារាំងម្នាក់ដែលតស៊ូដើម្បីជ័យជម្នះនៃគំនិតមួយឈ្មោះ ឡូរ៉ង់ ពិច (Laurence Picq) បានផ្តល់នូវភ័ស្តុតាងដ៏សំខាន់មួយស្តីពីការភ្ញាក់ផ្អើលរបស់ខ្មែរក្រហមចំពោះការបដិសេធរបស់ចិនពីរឿងនោះ ។ ពិច ដែលរៀបការជាមួយអ្នកទទួលខុសត្រូវខ្មែរក្រហមដ៏សំខាន់ម្នាក់ធ្វើការនៅក្រសួងការបរទេស គឺជាអ្នកបម្រើការងារនៅក្រុងភ្នំពេញក្នុងឋានៈជាអ្នកបកប្រែនិងវាយអង្គុលីលេខ ។ នាងមានភារកិច្ចបកប្រែសុន្ទរកថាដែលត្រូវថ្លែងក្នុងឱកាសធ្វើពិធីបដិសណ្ឋារកិច្ចមួយជាកិត្តិយសដល់ វ៉ាង ។ នៅវេលាចុងក្រោយ ស្វាមីរបស់នាងដែលដើរមកទាំងដង្ហក់ខ្លាំងបានសុំឲ្យនាងលុបកថាខណ្ឌមួយចោល និងវាយសុន្ទរកថានេះឡើងវិញ ។ កថាខណ្ឌដែលលុបចោលនោះបញ្ជាក់ថា «រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តដឹងច្បាស់ថា ក្នុងករណីដែលមានសេចក្តីត្រូវការពួកគេអាចសង្ឃឹមលើជំនួយរបស់កងទ័ពចិនជាបងប្អូន»[១៤] ។ បណ្តាសមាជិកនៃគណបក្ស

ប្រតិភូចិនបាននាំមកថ្លែងនៅប្រទេសកម្ពុជានូវគោលការណ៍សំខាន់ៗដែលផ្ទុយគ្នាជាច្រើន ។ វ៉ាង ដុងស៊ីង បានឡដំណើងអំពីសេចក្តីអំពាវនាវរកទ័ពជំនួយដែលប្រកាសដោយពួកមេដឹកនាំប្រទេស ប៉ុន្តែទន្ទឹមនឹងនោះ ហ៊ូយ៉ាវបាង និង យូ ជូលី ដែលជាសម្ព័ន្ធមិត្តនយោបាយរបស់ តេង ស៊ាវពីង បានបង្ហាញនូវព័ត៌មានដំបូងៗស្តីអំពីនយោបាយមូលវិវដ្តនិយម(radicalisme)ផ្តេសផ្តាសរបស់ខ្មែរក្រហម និងដំណើរច្របូកច្របល់របស់សង្គមកម្ពុជាផង ។ ប្រការទាំងអស់នេះនឹងជួយទ្រទ្រង់ដល់ការពិភាក្សាគ្នាខាងផ្នែកនយោបាយដ៏ស៊ីជម្រៅមួយ ស្តីអំពីតួនាទីរបស់ប្រទេសចិននៅឥណ្ឌូចិនមិនខាន ។

ក្រោយបន្តិចពីការវិលត្រឡប់របស់ វ៉ាង និង តេង មកកាន់ក្រុងប៉េកាំងវិញ ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តចិនបានព្រមព្រៀងគ្នាបើកសម័យប្រជុំដ៏ទូលំទូលាយមួយដែលមានរបៀបវារៈដូចតទៅ : នយោបាយផ្ទៃក្នុងរបស់ចិន ប៉ុន្តែក៏មានរបៀបវារៈស្តីពីការទាក់ទងជាមួយសហរដ្ឋអាមេរិកនិងឥណ្ឌូចិនដែរ ។ សម័យប្រជុំដ៏វែងអន្លាយនេះ (ពីថ្ងៃទី១១ ខែវិច្ឆិកា ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨) បានដៅឲ្យឃើញការប្រែប្រួលដ៏សំខាន់មួយនៃនយោបាយរបស់ចិន ។ សម័យប្រជុំបានឲ្យសច្ចាប័នចំពោះការត្រួតត្រាប្រទេសដោយ តេង ស៊ាវពីង ដូចដែលអ្នកប្រាជ្ញខាងភាសាប្រវត្តិសាស្ត្រនិងវប្បធម៌របស់ចិន ហ្សឺហ្កេន ដូម ឲ្យឈ្មោះថា "ទូសម្រាប់បញ្ជារបស់គណៈកម្មាធិការមជ្ឈិមបក្ស (Tableau de Commande)" និយាយម្យ៉ាងទៀត គឺជាប៉ុស្តិបញ្ជាការដ៏សំខាន់នៃអំណាចផ្ទៃក្នុងគណៈកម្មាធិការមជ្ឈិមបក្ស[១៥] ។ តេង បានរុញ"កូនអុកទាំងឡាយ"របស់គាត់ទៅមុខដោយភាពឈ្លាសវៃបំផុត ។ គាត់បានធ្វើយុទ្ធនាការដោយប៉ិនប្រសប់តាមរយៈបណ្តាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្លូវការ មិទ្ទីងនានានិងការបិទប័ណ្ណប្រកាសដើម្បីបង្ខំឲ្យមានការតែងតាំងបក្ខពួករបស់គាត់ក្នុងគណៈកម្មាធិការមជ្ឈិមបក្ស និងដើម្បីបង្កឲ្យមានការផ្លាស់ប្តូរមួយនូវសមាសភាពនៃការិយាល័យនយោបាយថែមទៀត ។ ក្នុងចំណោមមិត្តភក្តិនយោបាយរបស់គាត់បួននាក់ដែលក្នុងនោះមានលោកស្រី តេង យីងជាវ ដែរ ត្រូវបានជ្រើសតាំងឲ្យធ្វើជាសមាជិកការិយាល័យនយោបាយយ៉ាងឆាប់រហ័ស ហើយសហការីដ៏ជិតស្និទ្ធបំផុតរបស់គាត់គឺហ្សាវ ហ្ស៊ីយ៉ាង ត្រូវបានតែងតាំងជាអគ្គលេខាគណៈកម្មាធិការមជ្ឈិម ។ មេដឹកនាំជាច្រើននាក់ដែលសុទ្ធតែត្រូវដំឡើងបុណ្យសក្តិក្នុងអំឡុងបដិវត្តវប្បធម៌ បានប្រឆាំងជំទាស់យ៉ាងខ្លាំងទៅនឹងការដឹកនាំបែបប្រតិបត្តិនិយមខាងវិស័យនយោបាយសេដ្ឋកិច្ចរបស់គាត់ ។ ក្នុងចំណោមនោះគឺមានប្រធានបក្ស ហ្វា គួហ្វេង ប្រធានសន្តិសុខជាតិ វ៉ាង ដុងស៊ីង និងចៅហ្វាយក្រុងប៉េកាំង វូ តិ (Wu De) ផង ។ ដោយត្រូវបង្ខំឲ្យធ្វើស្វ័យទិតៀនពួកទាំងនេះប្រហែលជាយល់ព្រមឲ្យមានការកាត់បន្ថយនូវអំណាចដែលមានពិតៗរបស់គេមិនខាន[១៦] ។

ផ្នែកខាងក្រោយរបស់គាត់ត្រូវបានធានា តេង អាចធ្វើឲ្យគេចាប់អារម្មណ៍ធ្វើតាមទស្សនៈផ្សេងៗរបស់គាត់ស្តីអំពីបញ្ហានយោបាយបរទេស ដែលក្នុងពេលថ្មីៗរឿងនេះតែងតែមានការជជែករក(ខុសត្រូវ) នៅឡើយ ។ ឧទាហរណ៍ដូចជាបញ្ហាកម្ពុជាជាដើម ។ បណ្តាមេដឹកនាំដែលស្តាប់តាមបង្គាប់ពួកឆ្វេងនិយម ហើយដែលមាន

ជាច្រើននាក់ធ្លាប់មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាសុទ្ធតែនិយាយការពារពួកខ្មែរក្រហមយ៉ាងស្វិតស្វាញ ។ ដំណើរលើបបាត់មួយភ្លែតរបស់គាត់ បានធ្វើឲ្យជំហររបស់ តេង រឹតតែខ្លាំងឡើងទៀត ដែលបដិសេធការទាក់ទងទាំងអស់ជាមួយពួកនោះខាងផ្នែកមនោគមវិជ្ជា ។ ដើម្បីប្រឆាំងទល់នឹងកម្លាំងប្រានរបស់វៀតណាម គោលដៅរបស់គាត់គឺរៀបចំឲ្យមានការព្ធួតដៃគ្នាដ៏ទូលំទូលាយមួយ ដោយប្រមូលផ្តុំក្រៅពីប្រទេសចិននូវបណ្តាប្រទេសមិនមែនកុម្មុយនីស្តភាគច្រើនក្នុងតំបន់ ។ យោបល់របស់ប្រវត្តិវិទូ ឃីង ចេន គឺថាចំណុចសំខាន់នៃការជជែកពិភាក្សាគ្នាស្តីពីនយោបាយការបរទេសរបស់ការិយាល័យនយោបាយ បានក្រឡឹងជុំវិញបញ្ហាស្តីពីការធ្វើអន្តរាគមន៍ផ្នែកយោធាជាយថាហេតុមួយនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ តាមគេអះអាងថា វ៉ាង ដុងស៊ីង មានបំណងថាយើងត្រូវឆ្លើយតបដោយអនុគ្រោះចំពោះការអំពាវនាវសុំជំនួយរបស់ ប៉ុល ពត ។ ក្នុងន័យដូចគ្នានេះ ស្នងការនយោបាយទី១របស់កងនាវាចរណ៍ចិន ស៊ូ ហ្សេនហួ បានជំរុញឲ្យធ្វើការបញ្ជូននាវាមួយកងទៅសមុទ្រខាងកើតដើម្បីជួយប្រទេសកម្ពុជា ការពារដែនសមុទ្ររបស់ប្រទេសនោះ ។ ចំណែកឯមេបញ្ជាការយោធភូមិភាគហ្គាងស៊ីឈ្មោះ ស៊ូ ស៊ីយូ វិញដែលជាអ្នកមានបទពិសោធន៍ម្នាក់បានប្រកាសថា គាត់ត្រៀមខ្លួនដឹកនាំកងទ័ពរបស់គាត់វាយលុកប្រទេសវៀតណាមស្រេចហើយ[១៧] ។

ប៉ុន្តែ តេង និងបក្ខពួករបស់គាត់បានប្រឆាំងជំទាស់យ៉ាងម៉ឺងម៉ាត់ចំពោះការធ្វើអន្តរាគមន៍មួយដោយផ្ទាល់ សម្រាប់ហេតុផលផ្សេងៗដែលគ្រោងទុកជាមុននិងមិនធ្វើអន្តរាយដល់កិច្ចប្រឹងប្រែងធ្វើទំនើបភាវូបនីយកម្មរបស់ប្រទេសជាតិផង ។ ជាពិសេស ចេង ប៉ាវ សមាជិកការិយាល័យនយោបាយទទួលបន្ទុកកិច្ចការអន្តរជាតិបានប្រកាសថា ៖ «តើបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងប្រទេសដទៃទៀតនៃពិភពលោកបញ្ចេញប្រតិកម្មបែបណាទៅ បើសិនជាយើងបញ្ជូនទាហានរបស់យើងទៅប្រទេសកម្ពុជា?» ។ «សេចក្តីសង្ឃឹមទាំងអស់ក្នុងការបង្កើតរណសិរ្សរួបរួមមួយប្រឆាំងអនុត្តរភាពនឹងត្រូវអន្តរាយមិនអាចបង្ការបាន ។ យើងនឹងលេចឡើងជាមហាអំណាចអនុត្តរភាពនិយមមួយវិញម្តង ។ តាម ចេង ប៉ាវ ថា សហភាពសូវៀតមិនចង់ឲ្យមានអន្តរាគមន៍មួយរបស់ចិននៅកម្ពុជាទេ ព្រោះថា អន្តរាគមន៍នេះអាចនឹងប្រមូលសាធារណៈមតិពិភពលោកប្រឆាំងនឹងប្រទេសចិន ហើយអាចបង្អាក់ការធ្វើទំនើបភាវូបនីយកម្មរបស់ខ្លួនថែមទៀត»[១៨] ។

ទុកជាគាត់ជំទាស់ចំពោះការបញ្ជូនទាហានស្ម័គ្រចិត្តទៅប្រទេសកម្ពុជាក៏ដោយ ក៏ តេង មិនសូវធ្វើខ្លួនជាអ្នកការពារការដាក់ទណ្ឌកម្មមួយទៅលើប្រទេសវៀតណាមដែរ ។ គាត់ចេះធ្វើឲ្យបក្សយល់ព្រមតាមទស្សនៈផ្សេងៗរបស់គាត់ ។ «ការវាយប្រហារមួយប្រឆាំងនឹងប្រទេសវៀតណាមបង្ហាញឲ្យឃើញថាជាអំពើការពារខ្លួនស្របច្បាប់មួយ» មានភាពហេងស៊យតិចតួចណាស់ដែលបង្កឲ្យមានការប្រឆាំងតបតភ្លាមៗមួយពីសូវៀតក្នុងទំហំយ៉ាងធំនោះ ។ ផ្អែកលើព័ត៌មានផ្សេងៗដែលបញ្ជូនមកដោយក្រុមស៊ើបការណ៍អាមេរិកាំង គាត់សន្និដ្ឋានថាកងទ័ពសូវៀតដែលប្រមូលផ្តុំយ៉ាងច្រើនសម្បើមនៅតាមព្រំដែនរបស់ចិន ពុំអាចធ្វើប្រតិបត្តិការវាយលុកទម្លុះ

*យ៉ាងលឿនសំដៅមកក្រុងប៉េកាំងបានទេ ហើយប្រទេសចិនអាចប្រឈមមុខនឹងការវាយលុកដែលមានកំណត់មួយ ។ តាមយោបល់ តេង ថា ម្យ៉ាងទៀតការធ្វើអន្តរាគមន៍បង្ការជាមុនមួយប្រឆាំងនឹងប្រទេសវៀតណាមនឹងពុំបង្កឲ្យមានការប្រឆាំងពីសហគមន៍អន្តរជាតិឡើយ ។ នៅទីបំផុត ការធ្វើអន្តរាគមន៍ពុំមានអ្វីបង្អាក់ទំនើបកម្មទាំងបួនរបស់យើងទេ ហើយប្រហែលជារារាំងប្រទេសវៀតណាមឲ្យបោះបង់ចោលគំនិតធ្វើឲ្យអាក់ដំណើរការធ្វើទំនើបកម្មនេះថែមទៀត ។ ទោះបីជាប្រទេសចិនសម្រេចឈានដល់គោលដៅត្រឹមតែ៧០ភាគរយនៃបណ្ដាគោលដៅយោធារបស់ខ្លួនក៏ដោយ ក៏ការធ្វើប្រតិបត្តិការល្មមតែសាកល្បងដែរ ។ ការមិនបានជោគជ័យនឹងរួមបង្កជាការប្រាប់ឲ្យដឹងដ៏មានតម្លៃអំពីភាពទន់ខ្សោយនៃកងទ័ពរំដោះប្រជាជននិងជាគ្រឿងលើកទឹកចិត្តសម្រាប់ការធ្វើទំនើបកម្មរបស់ខ្លួន ។ សំខាន់ជាងនេះទៅទៀត វានឹងបង្ហាញឲ្យសហភាពសូវៀតនិងប្រទេសវៀតណាមដឹងពីសមត្ថភាពរបស់ប្រទេសចិន ក្នុងការប្រឆាំងរាល់ការប៉ុនប៉ងហ៊ុមព័ទ្ធរបស់ពួកគេផង ។ តេង ស៊ាវពីង បានសន្និដ្ឋានថា យុទ្ធសាស្ត្ររបស់សូវៀតនឹងទទួលរងបរាជ័យមួយនៅអាស៊ីមិនខាន[១៩] ។*

*ការិយាល័យនយោបាយបក្សកុម្មុយនីស្តចិន បានឲ្យសេចក្ដីយល់ព្រមចំពោះការដឹកនាំទិសនេះថែមទៀត ។ ការិយាល័យនយោបាយក៏ផ្ដល់នូវការធានារបស់ខ្លួនក្នុងការពួតដៃគ្នាជាមួយសហរដ្ឋអាមេរិក ដោយទុកបញ្ហាតៃវ៉ាន់ទៅម្ខាងសិន ។ ចំពោះលោក មីស្តែល អូកសេនបឺក យល់ថា យថាភាពនៃសកម្មភាពយោធាមួយប្រឆាំងប្រទេសវៀតណាម «មុខជាត្រូវពិភាក្សាគ្នាពីអ្វីដែលទាក់ចិត្តច្រើនជាងមុនថែមទៀត ចំពោះការបញ្ចប់ដំណើរនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយសហរដ្ឋអាមេរិក ។ គេអាចគិតដូចគ្នាថា វាជួយពង្រឹងស្ថានភាពរបស់ តេង ឲ្យរឹតតែរឹងមាំឡើងក្នុងការប្រឈមមុខទល់នឹងអ្នកដឹកនាំទាំងអស់នៅប្រទេសចិន ដែលយល់ឃើញតម្លៃនៃការធ្វើឲ្យមានប្រក្រតីភាពខ្ពស់ខ្លាំងពេក»[២០] ។*

*នៅខែធ្នូ ឆ្នាំ១៩៧៨ តេង ស៊ាវពីង បានសំដែងឲ្យឃើញច្បាស់ដោយឥតប្រកែកបានក្នុងឋានៈជា «មនុស្សខ្លាំង»របស់បក្សដោយមធ្យោបាយយកឈ្នះសំខាន់បំផុតបីយ៉ាងរបស់គាត់ ៖ ការរួបរួមរលាយសាច់មួយ ដោយនយោបាយប្រតិបត្តិនិយមផ្នែកសេដ្ឋកិច្ច ឥរិយាបថចំពោះប្រទេសវៀតណាមនិងបំណងធ្វើឲ្យមានប្រក្រតីភាពពេញលេញរបស់គាត់ក្នុងទំនាក់ទំនងចិន-អាមេរិកាំង ។ គេឃើញថា ការផ្អាកទុកសិននូវនយោបាយឥណ្ឌូចិនរបស់ តេង បានកើតមានឡើងព្រមគ្នាជាមួយគម្រោងការផ្សេងៗរយៈពេលខ្លីរបស់លោក ហ្ស៊ីមីខាធ័រដែរ ។ នៅថ្ងៃទី២ ខែវិច្ឆិកា នៅពេលដែលប្រធានាធិបតីអាមេរិកាំងផ្ញើទៅឲ្យ តេង នូវសំណើចុងក្រោយរបស់អាមេរិកស្ដីពីការធ្វើឲ្យមានប្រក្រតីភាព តេង បានឲ្យយោបល់ថាអ្វីៗនឹងត្រូវដោះស្រាយនៅខែមករា ។ អូកសេនបឺក បានកត់សម្គាល់ថា ប្រធានាធិបតី ខាធ័រ (Carter) «បានធ្វើឲ្យមានការសប្បាយរីករាយមួយដែលប្រកាសប្រាប់ប្រជាពលរដ្ឋអាមេរិកាំងឲ្យដឹងនូវជោគជ័យធំៗបីសម្រាប់បុណ្យណូអែល ៖ ការសម្រេចបានកិច្ចព្រមព្រៀង ខេម ដាវីដ ការធ្វើឲ្យមានប្រក្រតីភាព[ជាមួយប្រទេសចិន] និងសន្ធិសញ្ញាកាត់បន្ថយអាវុធ*

*យុទ្ធសាស្ត្រទីពីរ (S.A.L.T.II)»*[៧១] ។

## ប្រទេសចិនប្រមូលធុនរបស់អាមេរិកាំង

*អ៊ីៗទាំងអស់បានត្រូវសម្រេចដោយងាយស្រួលតែក្នុងរវាងពីរឬបីថ្ងៃប៉ុណ្ណោះ ។ ថ្ងៃទី២ ខែវិច្ឆិកា ៖ ការបញ្ជូនទៅប្រទេសចិននូវសំណើចុងក្រោយទាំងឡាយរបស់អាមេរិកាំង ។ ថ្ងៃទី៣ ខែវិច្ឆិកា ៖ ការចុះហត្ថលេខាលើសន្ធិសញ្ញាសម្ព័ន្ធភាពយោធារវាងសូវៀត-វៀតណាម ។ ថ្ងៃទី៦ ខែវិច្ឆិកា ៖ ការចាប់ផ្ដើមដំណើរទស្សនកិច្ចរបស់ តេង ស៊ាវពីង នៅអាស៊ីអាគ្នេយ៍ ។ ភាពហេងស៊យនៃនយោបាយក្នុងប្រទេសរបស់អាមេរិកាំងនិងចិន-ជោគជ័យនៃឧបាយបែបការិយាធិបតេយ្យរបស់ ប្រ៊ីហ្សីនស្គី ប្រឆាំង វ៉ាន់ស៍ និង ហូលប្រ៊ុក ។ ការរៀបចំរបស់ក្រុមនិយមឆ្វេងនៃបក្សកុម្មុយនីស្តចិនដោយ តេង ស៊ាវពីង-និងការវិវត្តន៍នៃស្ថានភាពជាយុទ្ធសាស្ត្រហាក់ដូចជាតម្រង់ទៅរកគោលដៅតែមួយដូចគ្នា ៖ ការបង្កើតដោយឆាប់រហ័សនូវសម្ព័ន្ធភាពមួយរវាងចិន-អាមេរិកាំងដោយផ្អែកលើការគំរាមកំហែងធ្វើសង្គ្រាម ។ ពីរឆ្នាំក្រោយមក អ្នកទទួលខុសត្រូវចិនម្នាក់បាននិយាយរឿងអាថ៌កំបាំងប្រាប់ខ្ញុំថា «រហូតមកដល់សម័យប្រជុំរបស់ការិយាល័យនយោបាយនៅខែវិច្ឆិកា-ធ្នូ ហ៊ា គួហ្វេង បានសម្ដែងចេញការប្រឆាំងជិតទាស់ចំពោះការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងវ៉ាស៊ីនតោន បើយ៉ាងហោចណាស់ ការធ្វើឲ្យមានប្រក្រតីភាពត្រូវតែរួមបញ្ចូលការរក្សាទំនាក់ទំនងក្រៅផ្លូវការរវាងសហរដ្ឋអាមេរិកនិងតៃវ៉ាន់ផង» ។ តេង ជាអ្នកដែលចាត់ទុកការគំរាមរបស់សូវៀត-វៀតណាមជារឿងសំខាន់ពិតប្រាកដ ទាំងចំពោះប្រទេសចិនក៏ដូចសម្ព័ន្ធមិត្តកម្ពុជារបស់ខ្លួន ហើយជាអ្នកចូលចិត្តប្រកាន់ឥរិយាបថឆាប់ស្រុះស្រួលជាងមុនមួយស្ដីពីបញ្ហាតៃវ៉ាន់ ។ ការដាក់ប្រើសហប្រតិបត្តិការពហុសណ្ឋានជាមួយសហរដ្ឋអាមេរិកគឺជាការខាតបង់ដើម្បីបានអ៊ីមួយ ។*

*នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៨ ពួកចិនបានបន្ទយពាក្យឲ្យដឹងជាលើកដំបូងថា ពួកគេអាចយល់ព្រមធ្វើការសម្របសម្រួលមួយអំពីបញ្ហាកោះតៃវ៉ាន់ ។ កាលពីពីរថ្ងៃមុន ក្រុងហាណូយបានប្រកាសជាសាធារណៈពីការបង្កើតរណសិរ្សមួយដែលមានសុទ្ធតែអ្នកប្រឆាំងនឹងរបប ប៉ុល ពត គឺរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ នាថ្ងៃនោះ នៅពេលដែលឯកអគ្គរដ្ឋទូត វូដខូក ជួបរដ្ឋមន្ត្រីការបរទេសស្ដីទីរបស់ចិន ហាន នានឡុង ដើម្បីពិភាក្សាពីសំណើថ្មីៗរបស់អាមេរិកាំង គាត់បានសម្គាល់ឃើញភ្លាមៗនូវមនុស្សថ្មីៗជាច្រើន ដែលនៅអមជុំវិញគូសន្ទនារបស់គាត់ ។ សហការីពីរនាក់របស់លោករដ្ឋមន្ត្រី-ដែលគេពិនិត្យឃើញថា ជាអ្នកនិយមឆ្វេងបំផុតហើយដែលធ្លាប់ចូលរួមគ្រប់ការចរចាទាំងអស់-ពុំមានមុខនៅទីនោះទេ ៖ វ៉ាង ហៃរ៉ុង ជាក្មួយស្រីរបស់ ម៉ៅ និង ណាន់ស៊ី តាង អ្នកបកប្រែភាសាដែលមានឈ្មោះល្បី ។ ពួកគេត្រូវបានជំនួសដោយអ្នកការទូតអាជីពពីររូបវិញ ។ ហាន នានឡុង ផ្ទាល់ក៏ផ្លាស់ប្ដូររបៀបនិយាយដែរ ។ រហូតមកដល់ពេលនេះ ប្រទេសចិនមិនព្រម*

បោះបង់ចោលការប្រើកម្លាំងប្រឆាំងនឹងតៃវ៉ាន់ឡើយ ហើយក៏ប្រឆាំងផងដែរចំពោះអ្វីដែលសហរដ្ឋអាមេរិកលើកយកមកនិយាយជាឯកតោភាគីពីបំណងឈានទៅដល់ការដោះស្រាយដោយសន្តិវិធីមួយ ។ ប៉ុន្តែ នៅថ្ងៃទី៤ ខែធ្នូ ហាន បានប្រាប់ឲ្យ វូដខូក ដឹងថា ប្រទេសចិននឹង«មិនប្រកែកជាសាធារណៈ»ឡើយ បើសិនជាក្រុងវ៉ាស៊ីនតោនចេញផ្សាយជាសាធារណៈនូវសេចក្តីថ្លែងការណ៍មួយទៅតាមន័យនេះ ។ ម្យ៉ាងទៀត ឧបនាយករដ្ឋមន្ត្រី តេង ស៊ាវពីង ប្រាថ្នាជួបឯកអគ្គរដ្ឋទូតអាមេរិកាំងនៅពេលឆាប់ៗខាងមុខនេះដែរ ។

នៅថ្ងៃទី១៣ ខែធ្នូ ពេលដែល វូដខូក ឈានជើងចូលក្នុងវិមានប្រជាជនដ៏ធំស្កឹមស្កៃ នាទីក្រុងប៉េកាំង គាត់មិនដឹងថា តេង ស៊ាវពីង ដែលគាត់នឹងជួបជាលើកដំបូងនេះ បានសម្រេចធ្វើឲ្យពួកមេដឹកនាំជាន់ខ្ពស់បំផុតរបស់បក្សគាំទ្រគាត់ក្នុងគម្រោងការដាក់ទណ្ឌកម្មរបស់គាត់ចំពោះប្រទេសវៀតណាមឡើយ ។ មេដឹកនាំចិនមានសង្ឃឹមយ៉ាងខ្លាំងថា ការបង្កើតទំនាក់ទំនងការទូតជាមួយក្រុងវ៉ាស៊ីនតោននិងការធ្វើដំណើររបស់គាត់ទៅសហរដ្ឋអាមេរិកនៅពេលឆាប់ៗខាងមុខ-លោក ខាធ័រ បានបញ្ជូនសំបុត្រអញ្ជើញទៅគាត់កាលពីពីរថ្ងៃមុន-នឹងធ្វើឲ្យគាត់មានការគាំពារប្រកបដោយប្រសិទ្ធភាពជាស្ពាន់តទៅប្រឆាំងទល់នឹងការតបតដោយថាហេតុមួយរបស់ក្រុងមូស្គូ ។ គាត់មានបំណងបង្កើតរណសិរ្សរួមចិន-អាមេរិកាំងដ៏រឹងមាំមួយមុននឹងល្បងប្រជុយសំណាងចុងក្រោយរបស់គាត់នៅប្រទេសវៀតណាម ។ វូដខូក បានដឹងនូវរបាយការណ៍ផ្សេងៗរបស់ក្រុមស៊ើបការណ៍សម្ងាត់អាមេរិកាំង ដែលនិយាយអំពីការចល័តទ័ពនៅក្បែរព្រំដែនរបស់វៀតណាមតាំងពីខែវិច្ឆិកា ឆ្នាំ១៩៧៨មក ។ ប៉ុន្តែ គាត់នៅតែ«មិនព្រមជឿអ្វីៗទាំងអស់»ចំពោះយថាភាពមួយនៃការវាយប្រហាររបស់ចិន[២២] ។

ទោះជាយ៉ាងណាក៏ដោយ គេបានអះអាងថា អ្នកទទួលខុសត្រូវអាមេរិកាំងដែលចាប់ផ្តើមធ្វើក្នុងការចរចាដោយសម្ងាត់បំផុតជាមួយក្រុងប៉េកាំងបានសម្លឹងមើលដោយភ្នែកម្ខាង ដែលបង្ហាញលក្ខណៈអនុគ្រោះដល់ការរៀបចំប្រុងប្រៀបផ្នែកយោធារបស់ចិន ហើយព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរៀបចំប្រុងប្រៀបផ្នែកយោធារបស់វៀតណាម ។ សហរដ្ឋអាមេរិកមិនសួរនាំអ្វីទាំងអស់ក្រៅពីរួបរួមជាមួយប្រទេសចិនប្រឆាំងសូវៀត ។ ប៉ុន្តែគំនិតនេះហាក់ដូចជាមិនត្រូវពិនិត្យសើៗឡើយ ដែលថាក្រុងប៉េកាំងអាចប្រើប្រាស់ប្រក្រតីភាពចិន-អាមេរិកាំងដើម្បីធ្វើឲ្យសម្រេចនូវគោលដៅផ្នែកយោធាទាំងអស់របស់ខ្លួន នៅអាស៊ី-អាគ្នេយ៍ ។ វៀរលែងតែប្រទេសចិនមិនចូលចិត្តខាងណាជាងខាងណា ។ ប៉ុន្តែវាពិតថា បើពួកអាមេរិកាំងវាយតម្លៃប្រសើរជាងមុនពីតម្លៃដែលយកចិត្តទុកដាក់ខ្លាំងដោយក្រុងប៉េកាំងចំពោះការធ្វើឲ្យមានប្រក្រតីភាពនោះ ពួកគេនឹងអាចគេចវេះពីការធ្វើសម្បទានខ្លះៗអំពីបញ្ហាតៃវ៉ាន់មិនខាន ។

ក្នុងភាពធ្វើមិនដឹងដែលនេះជាបំណងផ្សេងៗរបស់ចិន វូដខូក បានត្រូវធ្វើឲ្យភ្ញាក់ផ្អើលទាំងរួសរាយ ។ តេង បាននិយាយប្រាប់គាត់ថា «យើងយល់ស្របតាមយោបល់របស់លោក ។ ខ្ញុំយល់ព្រមតាមការអញ្ជើញរបស់លោកប្រធានាធិបតី ខាធ័រ ទៅធ្វើទស្សនកិច្ចប្រទេសរបស់លោក» ។ អនុប្រធានាធិបតីចិនហាក់ដូចជា

បង្ហើឲ្យឆាប់ដែរ ។ គាត់និយាយប្រាប់ វូដខូក ជាសម្ងាត់ថា គាត់ប្រាថ្នាទៅកាន់សហរដ្ឋអាមេរិកនៅខែមករា ឆ្នាំ១៩៧៩ គឺមួយខែបន្ទាប់ពីការធ្វើឲ្យមានប្រក្រតីភាព[២៣] ។ រឿងទាំងនេះ មានលក្ខណៈប្លែកគួរឲ្យឆ្ងល់ខ្លាំង ដូចគ្នា ។ តេង បានយល់ព្រមជាមួយការយកចិត្តទុកដាក់នូវអ្វីដែលគាត់បានបដិសេធកាលពីមិនដល់មួយឆ្នាំកន្លះ មុន ។ ដោយពិត សំណើរបស់ ខាធ័រ បានធ្វើបន្តឡើងវិញនូវសំណើរបស់ វ៉ាន់ស៍ កាលពីខែសីហា ឆ្នាំ១៩៧៧ ។ ប្រធានាធិបតីអាមេរិកាំងមានបំណងពន្យារកិច្ចព្រមព្រៀងការពារជាមួយតៃវ៉ាន់មួយឆ្នាំទៀត និងបន្តលក់អាវុធ ដែលមានការជ្រើសរើសទៅឲ្យប្រទេសនេះ បន្ទាប់ពីការផុតកំណត់នៃកិច្ចព្រមព្រៀងនេះ ។ ចំណែកប្រទេសចិន វិញ ត្រូវតែតមមិនធ្វើប្រតិកម្មចំពោះការសង្កត់បញ្ជាក់ជាថ្មីពីបំណងរបស់អាមេរិកាំង ដើម្បីឈានទៅដល់ការ ស្វែងរកដំណោះស្រាយដោយសន្តិវិធីមួយអំពីបញ្ហានេះដែរ[២៤] ។

ខាធ័រ ត្រូវធ្វើឲ្យសប្បាយរីករាយយ៉ាងខ្លាំងចំពោះប្រតិកម្មរបស់ តេង ស៊ាវពីង ។ មូលដ្ឋាននៃកិច្ចព្រមព្រៀងធ្វើឲ្យមានប្រក្រតីភាពត្រូវបានធ្វើឲ្យកើតមាន ។ ប៉ុន្តែ ដើម្បីចៀសវាងថា ការលេចធ្លាយរឿងសម្ងាត់ ជាយថាហេតុបង្កឲ្យមានការប្រឆាំងពីពួកដែលធ្វើអ្វីៗជាគុណប្រយោជន៍ដល់តៃវ៉ាន់នៅសភាជាន់ទាប លោក ខាធ័រ បានសម្រេចចិត្តគំហុករឿងនោះតែម្តង ។ ជាជាងរង់ចាំថ្ងៃទី១ ខែមករា ដូចដែលគ្រោងទុកជាមុន លោក ខាធ័រ បានប្រកាសពីដំណឹងនេះភ្លាម ។ គាត់ចំអកឡកឡឺយថា “ដល់វេនដែលខ្ញុំត្រូវធ្វើឲ្យ តេង ភ្ញាក់ផ្អើលម្តង ហើយ” ។ វូដខូក បានទទួលការបង្គាប់បញ្ជាឲ្យស្នើសុំជួប តេង នៅព្រឹកថ្ងៃទី១៨ ខែធ្នូ និងស្នើឲ្យគាត់ប្រកាសពី កិច្ចព្រមព្រៀងជាសាធារណៈនៅថ្ងៃបន្ទាប់ ។ ការសរសេរសេចក្តីថ្លែងការណ៍រួមនៅពុំទាន់បានប្រុងប្រៀបនៅ ឡើយ ។ ដូច្នេះ សំណើរបស់គាត់បានប្រែត្រឡប់ទៅជាប្រកាសកិច្ចព្រមព្រៀងមុនពេលដែលវាមិនទាន់សម្រេច ជាផ្លូវការទៅវិញ! ប៉ុន្តែ តេង ដែលត្រូវធ្វើឲ្យស្រឡាំងកាំងបានយល់ព្រម ។

ការផ្លាស់ប្តូរគ្រោងការនេះ ពុំមានទាក់ទងនឹង ស៊ីរុស វ៉ាន់ស៍ ទេ ។ ការប្រឈមមុខដោយ ប្រ៊ីហ្សីនស្គី អំពី ការដឹកនាំនយោបាយរបស់ចិន បានប្រែទៅជាការចាញ់ប្រៀបគេជាស្ថាពរសម្រាប់គាត់ ។ វាលែងមានបញ្ហា រក្សាលំនឹងមួយក្នុងទំនាក់ទំនងផ្សេងៗជាមួយប្រទេសចិន និងវៀតណាម ដូចដែលគាត់និយាយណែនាំឲ្យធ្វើតាម ទៀតហើយ ៖ ការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតជាមួយក្រុងហាណូយត្រូវបានផ្អាកទាំងស្រុង ក្នុងអំឡុងពេល នៃការចរចាជាមួយក្រុមប៉េកាំង ។ ហើយរឿងនោះ លោកប្រធានាធិបតីលែងទុកជាសំខាន់ទៀតហើយនូវ យោបល់ឲ្យប្រុងប្រយ័ត្នរបស់គាត់ក្នុងការប្រើ“សន្លឹកបៀ”ចិន និងការព្រួយបារម្ភរបស់គាត់ពីការធ្វើឲ្យអន្តរាយ ដល់ទំនាក់ទំនងសូវៀត-អាមេរិកាំង ។ វ៉ាន់ស៍ បានផ្តល់នូវការយល់ព្រមរបស់គាត់ដើម្បីនឹងឲ្យការធ្វើឲ្យមាន ប្រក្រតីភាពជាមួយប្រទេសចិន ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ប៉ុន្តែ គ្មាន ករណីណាមួយត្រូវបានប្រកាសមុនទេ ។ គេអាចប្រមាណដឹងជាមុនថា ដំណឹងនេះនឹងធ្វើឲ្យរដ្ឋមន្ត្រីការបរទេស សូវៀត អង់ដ្រេ ហ្គ្រូមីកូ អន់ចិត្តដែលគាត់ត្រូវជួបគ្នាក្នុងរវាងខែធ្នូ ហើយថាដំណើរមានគគ្នាហូរហែនៃការចរចា

*ស្ដីពីការកម្រិតអាវុធយុទ្ធសាស្ត្រ (S.A.L.T) ដែលមិនចេះចប់នឹងត្រូវរងផលប៉ះពាល់ពីរឿងនេះ ។ ក៏ប៉ុន្តែ នៅថ្ងៃទី១៨ ខែធ្នូ លោក ខាធ័រ បានទូរស័ព្ទពីទីក្រុងហ្សេរូសាឡេម ដើម្បីប្រាប់គាត់ឲ្យដឹងថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន គឺត្រូវរុញទៅថ្ងៃទី១៥ ខែធ្នូវិញ ពោលគឺមុនការជួបរបស់គាត់ជាមួយ ហ្គ្រូមីកូ ។ វ៉ាន់ស៍ បាននិយាយត្រួសៗក្នុងនិក្ខេបបទរបស់គាត់ថា "ដំណឹងនេះគឺជាការធ្វើឲ្យទាស់ចិត្តពិតប្រាកដមួយ ។ នៅចំពេលដែលមានអាសន្ន ហើយក្នុងរយៈពេលប្រហែលប្រាំមួយម៉ោង ប្រ៊ីហ្សីនស្គី បានសម្រេចជោគជ័យក្នុងការបំបែកអនុរដ្ឋមន្ត្រីការបរទេស វ៉ារ៉េន គ្រីស្តូហ្វឺ និងរដ្ឋលេខាធិការ រីឆាដ ហូលប្រ៊ុក ចេញពីស្ថាប័នដែលមានអំណាចធ្វើការសម្រេចចិត្ត ។ អ្នកទាំងពីរពុំអាចផ្ដល់ដំណឹងឲ្យខ្ញុំពីអ្វីដែលបានកើតឡើងទេ"[៧៥] ។*

*នៅពេលដែល វ៉ាន់ស៍ ត្រៀមខ្លួនត្រឡប់មកទីក្រុងវ៉ាស៊ីនតោនវិញ-វាអាចថាគាត់មិនស្ថិតនៅទីនោះទេ នៅថ្ងៃដែលកើតមានព្រឹត្តិការណ៍សំខាន់-ខាធ័រ ដែលរហូតមកដល់ពេលនេះមានចិត្តរីករាយយ៉ាងខ្លាំង និង ប្រ៊ីហ្សីនស្គី ផ្ទាល់បានឆ្លៀតឱកាសប្រើការសង្ស័យមួយ ។ តើការប្រញាប់ប្រញាល់របស់ចិនប្រាប់ឲ្យដឹងអ្វីទៅ? ។ តើ តេង ស៊ាវពីង មិនពេបជ្រាយអំពីជំហររបស់ក្រុងវ៉ាស៊ីនតោនទាក់ទងនឹងកោះតៃវ៉ាន់ទេឬ? ។ ពួកគេប្រាកដជាមិនដឹងថា ការបង្កើនដំណើរចរចាឲ្យលឿនទៅមុខជួយធ្វើឲ្យងាយស្រួលដល់គម្រោងការផ្សេងៗខាងផ្នែកយោធារបស់ចិនឡើយ ។ វូដខូក បានរំពឹងហើយ ខាធ័រ បានផ្ញើមកឲ្យគាត់នៅវេលាព្រឹកថ្ងៃទី១៥ ខែធ្នូ (ត្រូវនឹងថ្ងៃទី១៨ល្ងាចម៉ោងនៅក្រុងវ៉ាស៊ីនតោន) នូវសារលិខិតបន្ទាន់មួយ ដើម្បីសុំឲ្យគាត់បញ្ជាក់ថា អ្វីៗទាំងអស់ពិតជាច្បាស់លាស់ហើយក្នុងចិត្តរបស់មេដឹកនាំចិន ។ គាត់បានផ្ទៀងផ្ទាត់ទៅតាមទម្លាប់នូវសេចក្ដីចម្លងការសន្ទនារបស់គាត់កាលពីថ្ងៃមុនជាមួយ តេង ប៉ុន្តែ ឥតមានទេ ៖ គ្មានការស្ដាប់ខុសគ្នាពុំបានណាមួយអាចមានឡើយ ។ ខាធ័រ ទទូចថា គាត់ត្រូវតែជួប តេង ម្ដងទៀតជាដាច់ខាត ។ គេព្រមព្រៀងគ្នាធ្វើការណាត់ជួបគ្នាថ្មីមួយ-លើកទីបីក្នុងរវាង២៤ម៉ោង-ជាមួយភាពរហ័សរហួនមួយខុសប្លែកពីធម្មតាទាំងស្រុង ។ មួយម៉ោងក្រោយមក វូដខូក ដែលរួមដំណើរជាមួយអនុប្រធានរបស់គាត់ ស្ដេផ្លឹលថុន រ៉យ (Stapleton Roy) បានជួប តេង នៅវិមានប្រជាជន ។*

*ជាដំបូង តេង មិនលាក់លៀមភាពអល់អែករបស់គាត់ឡើយ ប៉ុន្តែ ក្រោយពេលដែល វូដខូក និយាយឡើងវិញអំពីជំហររបស់អាមេរិកាំងក្នុងការបន្តលក់អាវុធទៅឲ្យតៃវ៉ាន់ តេង បានសម្ដែងកំហឹងភ្លាមថា ៖ "ហេតុអ្វីបានជាលើកបញ្ហានេះមកនិយាយទៀត?" ។ វូដខូក ផ្ទាល់ពុំអាចបញ្ចុះបញ្ចូល តេង ពីអត្ថប្រយោជន៍នៃការជួបគ្នានេះបានទេ ប៉ុន្តែ គាត់ខំប្រឹងប្រែងពន្យល់ថា តាមការមើលឃើញរបស់ប្រជាជនអាមេរិកាំង ការផ្ដល់អាវុធសម្រាប់ការពារឲ្យតៃវ៉ាន់គឺជាការធានាស្ថិរភាពរបស់ប្រទេសនេះ ។ វូដខូក បានដំណាលប្រាប់ខ្ញុំ ប្រៀបដូចជាគាត់ធ្វើឲ្យសាច់រឿងនោះលេចឡើងជាថ្មីអ៊ីចឹង ៖ "នៅពេលនេះ តេង បានស្ដីបន្ទោសឲ្យគាត់ដោយគ្មានយោគយល់នូវអ្វីដែលគាត់មានក្នុងចិត្តទាំងប៉ុន្មាន ។ ការតូចចិត្តរបស់គាត់ជាភាពដែលគេអាចមើលឃើញច្បាស់ដោយភ្នែកទទេ ។ ដោយឥតកោតក្រែង តេង បាននិយាយឡើងវិញពីជំហរប្រទេសរបស់គាត់ ៖ តៃវ៉ាន់ គឺជា*

ខេត្តមួយរបស់ចិន និងពុំមានសិទ្ធិណាមួយសហការជាមួយសហរដ្ឋអាមេរិកខាងវិស័យសព្វាវុធ នៅក្រោយពេលក៏ដូចមុនពេលធ្វើឲ្យមានប្រក្រតីភាពដែរ ។ គាត់បាននិយាយដោយម៉ឺងម៉ាត់ថា ៖ «យើងនឹងមិនសុខចិត្តជាដាច់ខាត» ។ វ៉ូដខូក បានពន្យល់គាត់ថា គាត់មិនស្វែងរកការព្រមព្រៀងរបស់ប្រទេសចិនស្ដីពីបញ្ហានេះទេ ។ អ្វីដែលគាត់យកចិត្តទុកដាក់ជាសំខាន់ គឺប្រក្រតីភាព ។ វ៉ូដខូក បានក្រើនរំលឹកថា «ទំនាក់ទំនងរវាងប្រទេសចិនដីគោកនិងកោះតៃវ៉ាន់ បានចាប់ផ្ដើមប្រែប្រួល ហើយទំនាក់ទំនងរបស់យើងជាមួយតៃវ៉ាន់ក៏ផ្លាស់ប្ដូរដូចគ្នាដែរ ។ សព្វថ្ងៃនេះ ឧបសគ្គផ្សេងៗដែលពុំអាចពុះពារបាននឹងត្រូវបំបាត់ដោយងាយស្រួលជាមួយនឹងពេលវេលា»[២៦] ។

តេង បាត់ប្រឡោតបន្តិចហើយបានសួរថា «តើត្រូវយ៉ាងដូចម្ដេច?» ។ វ៉ូដខូក បានឆ្លើយថា «ខ្ញុំសូមឲ្យយោបល់ដោយទទូចបន្ទឹថា យើងត្រូវបញ្ចប់នូវអ្វីដែលយើងបានចាប់ផ្ដើមហើយ ។ មេដឹកនាំចិនបានតបភ្លាមៗថា «យល់ព្រម!» ដែលធ្វើឲ្យគូសន្ទនារបស់គាត់ធូរស្បើយក្នុងចិត្តយ៉ាងខ្លាំង ។ បញ្ហាដែលទុកមិនទាន់ដោះស្រាយ គឺការលក់អាវុធទៅឲ្យតៃវ៉ាន់ ដែលនឹងធ្វើឲ្យលំបាកដល់ទំនាក់ទំនងចិន-អាមេរិកនៅពេលក្រោយ ។ សម្រាប់ពេលនេះ តេង ស៊ាវពីង ដែលជាបុរសខ្លាំងថ្មីរបស់ប្រទេសចិនបានទទួលជោគជ័យ ។ គាត់មានប្រៀបលើប្រទេសវៀតណាមក្នុងការប្រកួតដែលផ្ដើមដោយលួចលាក់ ដើម្បីដណ្ដើមយកមិត្តភាពរបស់អាមេរិកាំង ។

## ការរៀបចំប្រុងប្រៀបចុងក្រោយ

បើសិនការរៀបចំប្រុងប្រៀបខាងផ្នែកយោធានៅភាគខាងត្បូងប្រទេសចិនមិនធ្វើឲ្យសហរដ្ឋអាមេរិកព្រួយបារម្ភហួសប្រមាណនោះ ក៏វាគ្មានអ្វីត្រូវព្រួយបារម្ភពីការប្រមូលផ្ដុំទ័ពយ៉ាងច្រើននៅតាមព្រំដែនរបស់កម្ពុជាដែរ ។ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៨ កងពលធំជាច្រើនកងរបស់វៀតណាមដែលក្នុងនោះ មានកងឯកភាពឆ្នើមៗមួយចំនួនធំបានត្រូវដាក់ពង្រាយនៅតាមបណ្ដាខេត្តដូចជា ដាក់ឡាក់ តាយនិញ និង អានយ៉ាងដែលសុទ្ធតែជាខេត្តមានព្រំប្រទល់ជាប់កម្ពុជា ។ ប្រឈមមុខនឹងបញ្ហាខ្វះខាតគ្រឿងគ្រៅម៉ាស៊ីនយន្តហោះប្រដេញទម្លាក់គ្រាប់បែកធុន A-37 និង F-5 (ចាប់បានពីទាហានអាមេរិកាំង) ដែលពួកគេធ្លាប់ប្រើប្រាស់ប្រឆាំងនឹងខ្មែរក្រហមកាលពីខែមិថុនា វៀតណាមត្រូវបង្ខំចិត្តកែប្រែរបៀបប្រយុទ្ធរបស់ខ្លួនជាថ្មី ។ យន្តហោះមិច-១៩ និងមិច-២១ ជាច្រើនគ្រឿងដែលធ្វើនៅសហភាពសូវៀតបានត្រូវផ្ទេរពីភាគខាងជើងមកកាន់មូលដ្ឋាន ដូឡាយ, បៀន ហ៊ា និង កង់ ថឺ នៅភាគខាងត្បូងវិញ ។

ការចេញបញ្ជាសម្រាប់ការពារទាំងនេះពុំមែនជាការមើលងាយនោះទេ ព្រោះទីក្រុងហូជីមិញមានចម្ងាយហោះហើរមិនដល់កន្លះម៉ោងផងពីទីក្រុងភ្នំពេញ ។ មន្ត្រីអគ្គការសហប្រជាជាតិម្នាក់ដែលមុខងាររបស់គាត់តម្រូវឲ្យទៅភាគខាងត្បូងជាញឹកញាប់ បានមើលឃើញពីចម្ងាយជាមួយនឹងការភ្ញាក់ផ្អើលថា នៅតាមតំបន់ជុំវិញរដ្ឋធានីភាគខាងត្បូងមានរៀបចំតម្លើងកាំភ្លើងបាញ់យន្តហោះ និងប្រដាប់បាញ់កាំជ្រួចមីស៊ីលតម្រង់ទៅ

ភាគខាងលិចប្រចូងប្រាង ។ នៅទីជិតខាងទីតាំងសំខាន់ៗរបស់ទីក្រុងឃើញមានដីកលេណដ្ឋាន និងទីជម្រកសម្រាប់ការពារពីការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសថែមទៀត ។ នេះប្រហែលជាការរៀបចំធ្វើឲ្យប្រជាពលរដ្ឋដឹងខ្លួនជាមុន ចំពោះការផ្តើមធ្វើប្រតិបត្តិការប្រឆាំងនឹងប្រទេសកម្ពុជាហើយ ។ ប៉ុន្តែអ្នកយុទ្ធសាស្ត្រវៀតណាមក៏គ្រាន់គិតជាចាំបាច់នូវការគំរាមកំហែងពីការវាយប្រហារទាំងសងខាងព្រមគ្នា ពីសំណាក់ខ្មែរក្រហមដែលគាំទ្រដោយពួកចិន នៅតាមបណ្តាព្រំដែនភាគនិរតីនិងពីសំណាក់ពួកចិនផ្ទាល់នៅព្រំដែនភាគខាងជើងរបស់ខ្លួនផងដែរ ។ ការភ័យបារម្ភនេះគឺផ្អែកលើព័ត៌មានផ្សេងៗដែលប្រមូលបានដោយក្រុមស៊ើបការណ៍សម្ងាត់តាំងពីនិទាឃរដូវ ឆ្នាំ១៩៧៨ម្ល៉េះ ដែលបង្ហាញឲ្យដឹងតាមរយៈការបង្កើនរឹតតែច្រើននូវការប្រគល់រថក្រោះ រថពាសដែក និងយន្តហោះប្រដេញមិច១៩របស់ចិនមកឲ្យប្រទេសកម្ពុជា និងការបង្ហើកសាងព្រលានយន្តហោះយោធាថ្មីមួយដ៏ធំនៅកំពង់ឆ្នាំងថែមទៀត ។ វៀតណាមបានវាយតម្លៃថា ចំនួនកងទ័ព ទីប្រឹក្សានិងអ្នកបច្ចេកទេសចិនដែលទទួលភារកិច្ចរៀបចំកងទ័ពរបស់កម្ពុជាឲ្យធ្វើការវាយលុកមួយប្រឆាំងវៀតណាមខាងត្បូងមានចំនួនប្រហែល១០.០០០នាក់[៣៧] ។

ស្ថានភាពនយោបាយ និងការទូតពិភពលោកបានប្រែប្រួលយ៉ាងឆាប់រហ័ស ។ វៀតណាមចាំបាច់ត្រូវតែបញ្ឈប់ជាបន្ទាន់បំផុតតាមដែលអាចធ្វើទៅបាន នូវប្រតិទិននៃប្រតិបត្តិការយោធាទាំងឡាយរបស់ខ្លួន ។ ដោយឡែកពួកគេក៏ត្រូវធ្វើឲ្យខូលព្រួយដោយសារការប៉ុនប៉ងរបស់ខ្មែរក្រហមដែលចង់រំដោះខ្លួនពីស្ថានភាពឯកោ និងសម្អប់ជនបរទេសរបស់គេដែរ ។ នៅសរទរដូវឆ្នាំ១៩៧៨ តាមការបញ្ចុះបញ្ចូលរបស់ចិន ខ្មែរក្រហមបានផ្តើមធ្វើយុទ្ធនាការមួយដើម្បីកែលម្អរូបភាព ជាពិសេសរូបភាពដែលចូលចិត្តបង្ហូរឈាមរបស់គេឲ្យបានប្រសើរជាងមុន ។ តាំងពីដើមរដូវក្តៅរហូតដល់ចុងរដូវស្លឹកឈើជ្រុះ ការធ្វើទស្សនកិច្ចជាមិត្តភាពបានប្រព្រឹត្តទៅជាបន្តបន្ទាប់គ្នានៅប្រទេសកម្ពុជា ។ ជាពិសេសគេអាចកត់សម្គាល់ឃើញក្រុមតូចៗដែល និយមលទ្ធិម៉ាក្ស-លេនីនរបស់អាមេរិកាំង ក្រុមម៉ៅនិយមរបស់បែលហ្ស៊ិក ក្រុមសង្គមនិយមរបស់ជប៉ុន ។ នៅពេលត្រឡប់មកប្រទេសវិញ អ្នកខ្លះក្នុងចំណោមអ្នកទៅធ្វើទស្សនកិច្ចទាំងនោះ បានរាយការណ៍ឲ្យដឹងពី“វឌ្ឍនភាព”ដ៏គួរឲ្យស្ញប់ស្ញែងដែលសម្រេចធ្វើបាននៅប្រទេសកម្ពុជា ។ ក្នុងកាសែតញូវយ៉កថែមស៍ សមាជិកម្នាក់ក្នុងចំណោមអ្នកទៅធ្វើទស្សនកិច្ចទាំងនោះបានទទួលស្គាល់ថា ភាពជ្រុលហួសហេតុអាច ត្រូវប្រព្រឹត្តនៅទីនោះ ប៉ុន្តែគាត់បានជំទាស់ដោយដាក់លាក់ពី“រឿងមិនពិតនៃការសម្លាប់ប្រជាជនអស់ជាច្រើននាក់ដែលគេប្រឌិតនៅក្រុងបាងកក” ។ តាមមតិគាត់ថា នៅប្រទេសថៃមានអ្នកខ្លះពុំរួញរានឹង“បង់ប្រាក់៥០ដុល្លារទៅឲ្យអ្នកភៀសខ្លួនមួយចំនួនឡើយ ដើម្បីឲ្យពួកគេរៀបរាប់ពីរឿងពិសេសដ៏គួរឲ្យព្រឺខ្លាចទាំងនោះប្រាប់ពួកបរទេស”[៣៨] ។

ឧបនាយករដ្ឋមន្ត្រីរបស់កម្ពុជា អៀង សារី បានចាប់ផ្តើមដំណើរទស្សនកិច្ចមួយក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដើម្បីសាកល្បងធ្វើឲ្យមានការខិតចូលជិតគ្នាមួយជាមួយបណ្តាប្រទេសខ្លះ ជាពិសេសជាមួយប្រទេស

ថៃ ។ រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី និងថៃក៏បានធ្វើដំណើរមកប្រទេសកម្ពុជាដែរ ។ អៀង សារី បានផ្តើមធ្វើការនាំសម្រុះសម្រួលនេះដោយខ្លួនឯង ក្នុងឱកាសនៃសន្និសីទកាសែតមួយនៅក្រុងញូវយ៉កអំពីប្រធានបទ«យើងចង់ឲ្យអស់លោកមើលឃើញដោយផ្ទាល់ភ្នែកថាតើកម្ពុជារំលោភសិទ្ធិមនុស្សមែនឬអត់?» ។ យ៉ាងហោចណាស់គម្រោងការនេះបានធ្វើឲ្យទំនាក់ទំនងផ្សេងៗត្រូវបានកាត់ផ្តាច់ជាមួយអតីតកាលដែរ ៈ ចាប់ពីពេលនេះតទៅខ្មែរក្រហមចាប់គិតគូរខ្លាំងពីការទិតៀនរបស់សាធារណមតិអន្តរជាតិ ។ ពួកគេបានប្រគល់លិខិតអញ្ជើញមួយជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ខឹត វ៉ាល់ដែម ដោយសុំឲ្យគាត់ធ្វើដំណើរមកកាន់ប្រទេសកម្ពុជាដើម្បីវាយតម្លៃពីស្ថានភាពសិទ្ធិមនុស្សនៅទីនោះផ្ទាល់ ។ កាលបរិច្ឆេទមួយត្រូវបានកំណត់រួចជាស្រេចគឺខែកុម្ភៈឆ្នាំ១៩៧៩ ។ នៅខែវិច្ឆិកា ក្រុងភ្នំពេញបានយល់ព្រមអនុញ្ញាតឲ្យទីភ្នាក់ងារទេសចរណ៍មួយរបស់ថៃដែលជាកម្មសិទ្ធិរបស់លោក ឆាតឆៃ ឈុនហាវ៉ាន់ អតីតរដ្ឋមន្ត្រីការបរទេសថៃនិងជាមហាមិត្តម្នាក់របស់ប្រទេសចិនរៀបចំឲ្យមានដំណើរកម្សាន្តចំនួនមួយថ្ងៃនៅអង្គរវត្តចាប់ពីខែមករាតទៅ ។ ក៏ប៉ុន្តែអ្នកទេសចរដែលមកពីវៀតណាម អ៊ីស្រាអែល កូរ៉េខាងត្បូង តៃវ៉ាន់ និងអាហ្វ្រិកខាងត្បូង ពុំអាចចូលរួមបានទេ[២៩] ។ ឆាតឆៃ បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា «គឺពុំមែនផលកម្រៃទេ ដែលលើកទឹកចិត្តខ្ញុំឲ្យធ្វើដូច្នេះ ។ ខ្ញុំមានបំណងតែម្យ៉ាងប៉ុណ្ណោះ គឺចង់ឲ្យប្រទេសកម្ពុជាបើកចំហទ្វារ ហើយពួកចិនក៏មានបំណងដូចនេះដែរ»[៣០] ។

## ការស្វែងរកកិច្ចធានាមួយសម្រាប់សម្តេច

ការធ្វើឲ្យ សម្តេច សីហនុ មាននីតិសម្បទាផ្នែកនយោបាយឡើងវិញដោយខ្មែរក្រហមទំនងជាធ្វើឲ្យវៀតណាមព្រួយបារម្ភយ៉ាងខ្លាំងដែរចាប់ពីថ្ងៃនេះទៅ ។ គេនឹកឃើញថា ក្នុងអំឡុងនៃដំណើរមួយទៅអង្គការសហប្រជាជាតិនៅខែតុលា អៀង សារី បានចែកចាយរូបថតសម្តេចជាច្រើនសន្លឹកដែលបានថតក្នុងពេលមាន«ពិធីជប់លៀងដ៏ស្និទ្ធស្នាលមួយជាកិត្តិយសដល់អ្នកស្នេហាជាតិមាតុភូមិ»កាលពីខែមុន[៣១] ។

ពួកមេដឹកនាំក្រុងហាណូយភ័យខ្លាចថា ការរៀបចំ សម្តេច សីហនុ ឲ្យកាន់តំណែងវិញ អាចអនុញ្ញាតឲ្យខ្មែរក្រហមរំដោះខ្លួនចេញដោយមិនអាក្រក់ពេកពី«បញ្ជីពួកមនុស្សដែលគេមិនចូលចិត្ត» នៅពេលដែលពួកគេលែងមានអ្នកណារាប់អានទៅហើយនោះ ។ ដោយហេតុនេះ ពួកមេដឹកនាំក្រុងហាណូយមានគម្រោងការផ្ទាល់ខ្លួនជាច្រើនដើម្បីជាប្រយោជន៍ដល់សម្តេច ៈ ពួកគេនឹងប្រើប្រាស់ព្រះនាមព្រះអង្គដោយរីករាយ ដើម្បីទាក់ទាញការគាំទ្រចំពោះចលនាតស៊ូប្រឆាំង ប៉ុល ពត ទាំងខាងក្នុងក៏ដូចជាខាងក្រៅប្រទេស ។ នៅដើមខែតុលា ឆ្នាំ១៩៧៨ សមាជិកមួយរូបរបស់គណៈប្រតិភូវៀតណាមនៅអង្គការអ៊ុយណេស្កូ (U.N.E.S.C.O) បានធ្វើដំណើរដោយស្ងាត់ៗទៅកាន់ភាគខាងត្បូងប្រទេសបារាំង ដើម្បីជួបជាមួយព្រះរាជបុត្រមួយអង្គក្នុងចំណោមបុត្រជាច្រើនអង្គរបស់ សម្តេច សីហនុ គឺព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ។ ជាមួយព្រះកេសមូល, ព្រះនេត្រធំៗ

ញាក់ព្រិចៗ និងព្រះសិតាការមិនផ្លាស់ប្តូររបស់ព្រះអង្គ ។ ព្រះអង្គម្ចាស់ រណឫទ្ធិ មានរូបរាងនិងដំណើរដូចព្រះបិតាព្រះអង្គបេះបិទ ។ នៅទីនោះ ព្រះអង្គធ្វើជាគ្រូបង្រៀនផ្នែកច្បាប់នៅសាកលវិទ្យាល័យអេសអង់ប្រូវ៉ង់ ។ ភ្ញៀវរបស់ព្រះអង្គគឺអ្នកពាំនាំសំបុត្រមួយពីមិត្តវៀតណាមម្នាក់ដែលគេស្គាល់គ្រប់គ្នាមកជួបព្រះអង្គផ្ទាល់ ហើយបានបង្ហាញខ្លួនក្នុងឋានៈជាប្រេសិតដែលបញ្ជូនមកដោយរដ្ឋាភិបាលនៅក្រុងហាណូយផង ។ គាត់បានថ្លែងសរសើរ សម្តេច សីហនុ ពីតួនាទីរបស់ព្រះអង្គជាអ្នកកសាងប្រទេសកម្ពុជាទំនើប ។ គាត់បានទូលជម្រាបដំណឹងដល់បុត្ររបស់សម្តេចថា វៀតណាមសង្ឃឹម«រំដោះ»សម្តេចបានពីខ្មែរក្រហម ក្នុងគោលបំណងអាចឲ្យព្រះអង្គសម្តែងតួនាទីជាមេដឹកនាំម្នាក់របស់ចលនា ។ ប្រេសិតរបស់វៀតណាមបានទូលព្រះអង្គម្ចាស់ រណឫទ្ធិ ថា «យើងមានបំណងយ៉ាងខ្លាំងក្លាសូមឲ្យព្រះអង្គ(រណឫទ្ធិ) ចូលរួមជាមួយចលនាតស៊ូថ្មីរបស់កម្ពុជាក្នុងឋានៈជាតំណាងសម្តេច សីហនុ» ។ រណឫទ្ធិ បានថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះភ្ញៀវពីការខ្វាយខ្វល់ដែលប្រទេសវៀតណាមគិតគូរដល់ព្រះបិតាព្រះអង្គ ប៉ុន្តែសម្រាប់ព្រះអង្គផ្ទាល់ព្រះអង្គបានបដិសេធមិនចូលរួមឡើយ ។ ព្រះអង្គម្ចាស់ រណឫទ្ធិ បានមានបន្ទូលប្រាប់ខ្ញុំ(អ្នកនិពន្ធ) ជាសម្ងាត់ថា «ខ្ញុំគ្មានដឹងពីមូលហេតុនៃការជាប់ឃុំឃាំងរបស់ព្រះបិតាខ្ញុំទាល់តែសោះ ទាំងមិនដឹងថាវៀតណាមមានគំនិតធ្វើយ៉ាងម៉េចផងទេ» ។ បេសកជនរបស់វៀតណាមបានទូលដំណឹងប្រាប់ព្រះអង្គច្រើនជាងមុនបន្តិច ក្នុងឱកាសនៃដំណើររបស់គាត់មកជួបព្រះអង្គជាលើកទីពីរនៅពាក់កណ្តាលខែធ្នូ ៖ «គឺនៅមុនបុណ្យណូអែល មួយឬពីរសប្តាហ៍ ខ្ញុំទើបនឹងរៀបចំតុបតែងលម្អដើមសាប៉ាំង (Sapin) និងផ្កាភ្លើផ្សេងៗទៀតរួចរាល់ ។ លើកនេះ វៀតណាមបានស្នើឲ្យខ្ញុំព្រមទទួលតួនាទីជាអ្នកតំណាងពិសេសរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលការបង្កើតចលនានេះទើបនឹងត្រូវបានប្រកាសជាសាធារណៈ ។ ខ្ញុំបានបដិសេធជាថ្មីទៀត»[៣២] អសមត្ថភាពរបស់វៀតណាមដើម្បីធានាឲ្យបានការជួយជ្រោមជ្រែងពីសមាជិកមួយអង្គនៃពូជពង្សរបស់ សម្តេច សីហនុ ឬយ៉ាងហោចណាស់តស្សូរជនខ្មែរមិនមែនកុម្មុយនីស្តល្បីឈ្មោះម្នាក់ដែលគេស្គាល់គ្រប់គ្នា បានធ្វើឲ្យពួកគេខ្វល់គំនិតយ៉ាងខ្លាំង ។ បរាជ័យនេះពុំបានជួយពង្រឹងដល់ភាពគួរឲ្យគោរពរបស់ចលនាតស៊ូ ដែលពួកគេជាអ្នកឧបត្ថម្ភគាំពារឡើយ ទាំងក៏មិនបានបង្កើនសកម្មភាពដើម្បីសម្រេចគោលដៅអ្វីមួយដែលធ្វើឲ្យចុះថយស្រេចទៅហើយ ដោយការវាយលុកខាងទំនាក់ទំនងសាធារណៈដែលផ្តើមឡើងដោយខ្មែរក្រហមដែរ ។ បន្តិចទៀតវានឹងលែងមានពេលសង្ឃឹមថា ការចូលធ្វើអន្តរាគមន៍នៅប្រទេសកម្ពុជា អាចទទួលបានគុណប្រយោជន៍ពីការគាំទ្រឬការចូលដៃពីសំណាក់អន្តរជាតិទៀតហើយ ។ មានចំណុចវិជ្ជមានតែមួយប៉ុណ្ណោះ គឺនៅទីបំផុត វ៉ាល់ដែម បានប្រានចោលមិនធ្វើដំណើរមកកាន់កម្ពុជាប្រជាធិបតេយ្យឡើយ ។ សម្រាប់អ្វីដែលនៅសល់គឺការកែលម្អរូបភាពជាមុខមាត់របស់កម្ពុជា បន្ទាប់ពីការបើកទ្វាររបស់ខ្លួន-ពិតហើយដែលត្រូវឃ្លាំមើលយ៉ាងតឹងរ៉ឹង-ឆ្ពោះទៅពិភពលោកខាងក្រៅដែលធ្វើឲ្យស្មុគស្មាញ ប្រកបដោយគ្រោះថ្នាក់ដល់ផែនការទាំងឡាយរបស់វៀតណាមថែមទៀត ។ នេះគឺជាឱកាសធ្វើសកម្មភាពមួយត្រូវកាលៈទេសៈបំផុត ។

សម្ព័ន្ធភាពយោធាជាមួយក្រុងមូស្គូបានសម្រេចដោយកិច្ចព្រមព្រៀងមួយ មធ្យោបាយផ្សេងៗខាងការទូតបានបញ្ចប់ វៀតណាមអាចប្រមូលផ្តុំការយកចិត្តទុកដាក់ទាំងអស់របស់ខ្លួនទៅលើការរៀបចំប្រុងប្រៀបចុងក្រោយ ក្នុងការចូលធ្វើអន្តរាគមន៍នៅកម្ពុជាវិញ ។ ក្រុមមេដឹកនាំក្រុងហាណូយបានស្ថិតក្នុងស្ថានភាពមិនសូវចាប់បង្ខំដោយព្រឹត្តិការណ៍ផ្សេងៗឡើយ ។ ប្រាកដណាស់ អតីតកម្មាភិបាលខ្មែរក្រហមនិងអ្នកនិរទេសខ្លួនកម្ពុជាដែលហាត់ហ្វឹកហ្វឺននៅភាគខាងត្បូងវៀតណាមប្រហែល២០០នាក់បានសម្រេចចិត្តវាយប្រយុទ្ធ ប៉ុន្តែពួកគេនៅពុំទាន់បំបាត់បានការទាស់ទែងគ្នាខាងនយោបាយរបស់ខ្លួននៅឡើយ ។ ដូច្នេះ ពួកគេនៅពុំទាន់អាចបង្កើតបក្សកុម្មុយនីស្តថ្មីមួយរបស់កម្ពុជាដែលអាចដឹកនាំការប្រយុទ្ធបានដែរ ហើយពេលវេលាបានបង្ខំធ្វើកិច្ចការនេះឲ្យបានឆាប់ ។ ដូច្នេះ វៀតណាមពុំអាចរង់ចាំឲ្យមានពេលទំនេរក្នុងការ បើកសមាជមួយរបស់បក្ស និងការបោះឆ្នោតជ្រើសតាំងគណៈដឹកនាំមួយទេ ។ ការបង្កើតរណសិរ្សរំដោះកម្ពុជាមួយដោយប្រមូលផ្តុំអ្នកដែលមាននិន្នាការផ្សេងៗគ្នា គឺជាវិធានការបណ្តោះអាសន្នមួយដែលងាយស្រួលជាង ។ ដោយសាររបៀបនេះ នឹងអាចអនុញ្ញាតឲ្យកងទ័ពរបស់វៀតណាមធ្វើសកម្មភាពបានហើយ ។

ការបញ្ចុះបញ្ចូលទ្រឹស្តីនយោបាយ និងការបង្ហាត់បង្រៀនក្បួនយោធាដល់កងទ័ពខ្មែរដែលចាប់ផ្តើមតាំងពីដើមឆ្នាំ១៩៧៨ បានបង្កើនសកម្មភាពរឹតតែខ្លាំងឡើងថែមទៀត ។ ការប្រាស់ប្រាល់មានសភាពឡើងដល់កម្រិតខ្ពស់បំផុត ។ ប៉ុន្តែឧបសគ្គខាងភាសាបានបង្កឲ្យមានការលំបាកយ៉ាងច្រើន ហើយក៏ធ្វើឲ្យដំណើរប្រព្រឹត្តទៅនៃប្រតិបត្តិការខាងយោធាត្រូវរអាក់រអួលខ្លះៗ ។ អាស្រ័យហេតុនេះ វៀតណាមគោងតែអំពាវនាវរកជនជាតិភាគតិចខ្មែរក្រោមនៅដែនដីសណ្តទន្លេមេគង្គមកជួយក្នុងគម្រោងការនេះ ។ ជាអ្នកត្រូវជាប់សង្ស័យខាងផ្លូវនយោបាយយូរយារមកហើយ ដោយសារតែការចេះនិយាយពីរភាសារបស់ខ្លួន ពួកគេអាចបង្ហាញឲ្យឃើញជាអ្នកជំនួយការដ៏មានតម្លៃសម្រាប់កងទ័ពរបស់វៀតណាមដែលត្រូវចូលមកកម្ពុជានៅក្នុងកាលៈទេសៈនេះ ។ មេបញ្ជាការឈ្មោះ សាយ ប៉ាក់ (Say Pak) ជនកុម្មុយនីស្តកម្ពុជាដែលធ្លាប់រស់នៅក្រុងហាណូយតាំងពីឆ្នាំ១៩៥៤ ត្រូវបានវៀតណាមប្រគល់ភារកិច្ចឲ្យជ្រើសរើសយុវជនខ្មែរក្រោមចូលធ្វើកងទ័ពនៅខេត្តបាក់លីវ ក្នុងដែនដីសណ្ត ។ គាត់បានរៀបចំបើកសម័យប្រជុំជាសាធារណៈជាច្រើនលើក ដើម្បីបញ្ចុះបញ្ចូលយុវជនឲ្យចូលរួមក្នុងចលនារំដោះប្រទេសកម្ពុជា ហើយមិនកំណាញ់នឹងការសន្យាផ្សេងៗឡើយ ៖ បន្ទាប់ពីការរំដោះប្រទេសពេញលេញ អ្នកស្ម័គ្រចិត្តនឹងបានទទួល“មុខតំណែងទទួលខុសត្រូវផ្សេងៗក្នុងរដ្ឋាភិបាល”ដោយគ្មានពិបាក ។ ក្រោយពីធ្វើពិធីបញ្ចូលមួយ យុវជន៥០០នាក់បានត្រូវបញ្ជូនទៅ កាម៉ៅ (Ca Mau) ដើម្បីទទួលការបណ្តុះបណ្តាលខាងយោធា ។ នៅខែមករា ឆ្នាំ១៩៧៩ ក្រុមនេះនឹងត្រូវចូល រួមជាមួយកងឯកភាពរបស់វៀតណាមជាច្រើនទៀតក្នុងឱកាសនៃការវាយលុករបស់វៀតណាមមកលើខេត្តតាកែវនៅប្រទេសកម្ពុជា ។

## ការរៀបចំពិធីសម្ពោធ

ឌិញ កាន ជាអតីតនាយទាហានផ្នែកវិស្វកម្មនៃកងទ័ពរបស់វៀតណាមបានជួយជ្រោមជ្រែងដ៏សំខាន់អំពីអាថ៌កំបាំងក្នុងការរៀបចំប្រុងប្រៀបនេះ ។ កាន មានវាសនាត្រឡប់ទៅផ្ទះវិញ យ៉ាង ឡឹត ពីការរស់នៅមួយរយៈនៅជំរំអប់រំកែប្រែជាថ្មីមួយដែលត្រៀមសម្រាប់តែពួកនាយទាហានរបស់របបចាស់ប៉ុណ្ណោះ ។ សមត្ថភាពជាវិស្វកររបស់គាត់ដែលបណ្តុះបណ្តាលដោយពួកអាមេរិកាំងបានទាក់ទាញការយកចិត្តទុកដាក់មកលើរូបគាត់ ។ គេត្រូវការជំនួយរបស់គាត់ ដើម្បីស្ថាបនាផ្លូវថ្នល់និងស្ពានយ៉ាងច្រើននៅក្នុងខេត្តដាក់ឡាក់, សុងបេ និង តាយនិញ ដែលមានព្រំដែនជាប់ប្រទេសកម្ពុជា ។ ចាប់ពីរដូវក្តៅឆ្នាំ១៩៧៨មក គេមិនពិបាកកាត់ស្មានពីហេតុការណ៍ចម្លែកៗដែលកំពុងតែត្រូវរៀបចំជាសម្ងាត់ឡើយ ៖ រដ្ឋាភិបាលវៀតណាម បានឲ្យកងទ័ពរៀបចំចាត់ចែងជួសជុលផ្លូវទាំងអស់ដែលជាផ្លូវឆ្ពោះមកកាន់ប្រទេសកម្ពុជា ។ តាំងពីខែតុលា កងឯកភាពវៀតណាមជាច្រើនបានកាន់កាប់ចម្រៀកដីខ្លះៗរបស់កម្ពុជានៅតាមបណ្តោយព្រំដែន ។ នៅពាក់កណ្តាលខែវិច្ឆិកា កងទ័ពរបស់វៀតណាមបានធ្វើប្រតិបត្តិការយ៉ាងសំខាន់មួយ មកក្នុងខេត្តក្រចេះតាមបណ្តោយផ្លូវជាតិលេខ១៣ ។ ការប្រយុទ្ធស៊ីសាច់ហុតឈាមបានធ្វើឲ្យកងពលធំមួយរបស់ខ្មែរក្រហមស្ទើរតែរលាយសាបសូន្យ ។ ភូមិភាគនោះត្រូវបានប្រកាសថាជា«តំបន់រំដោះ» ប៉ុន្តែ «អ្នកដឹកនាំការងារនេះ»នៅតែធ្វើឲ្យ កាន នឹកគិតមិនយល់ជានិច្ចរហូតមកដល់ថ្ងៃមួយក្នុងខែវិច្ឆិកា ទើបគាត់ឃើញឧទ្ធម្ភាគចក្រមួយគ្រឿងបានហោះមកចុះចតនៅខាងមុខការិយាល័យធ្វើការរបស់គាត់ដែលនៅជិតព្រំដែន ។ នៅក្នុងឧទ្ធម្ភាគចក្រគាត់ឃើញ ឡេ ឌឹកថូ និងឧត្តមសេនីយ៍ ដុង វ៉ាន់កុង មេបញ្ជាការរងយោធភូមិភាគទី៧ បានអញ្ជើញមកដោយផ្ទាល់ ដើម្បីត្រួតពិនិត្យការរៀបចំសម្ពោធជាផ្លូវការនូវការបង្កើតចលនាតស៊ូរបស់កម្ពុជា និងការរៀបចំទីបញ្ជាការជួរមុខរបស់កងទ័ពវៀតណាមផង ។

ទីកន្លែងដែលសម្រេចយកដើម្បីប្រកាសពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាជាផ្លូវការស្ថិតនៅចម្ងាយបីគីឡូម៉ែត្រពីព្រំដែនវៀតណាមក្នុងទឹកដីកម្ពុជា ។ ទីនោះជាព្រៃរបោះតូចមួយចំកណ្តាលចម្ការកៅស៊ូមួយនាទិសខាងកើតទីប្រជុំជនស្នួល ។ កាន បាននាំប៊ុលដូហ្សែរមួយគ្រឿងរបស់កងទ័ពទៅទីនោះ ដើម្បីពង្រាបដីឲ្យស្មើល្អ ។ ក្រុមទាហាននៃកងពលធំលេខ៤៧៦បានរៀបចំដំឡើងវេទិកាមួយ និងប្រដាប់បំពងសំឡេងផង ។ នៅព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ប្រជាជនខ្មែរជាច្រើនពាន់នាក់បានមកប្រមូលផ្តុំគ្នានៅទីនោះ ក្រោមពន្លឺព្រះអាទិត្យដ៏ភ្លឺចិញ្ចាច ។ ភាគច្រើននៃអ្នកទាំងនោះត្រូវបានដឹកជញ្ជូនមកតាមឡានកាមីញ៉ុង ជាច្រើនគ្រឿងតាំងពីជំរំអ្នកភៀសខ្លួនទាំងឡាយនៅប្រទេសវៀតណាម ។ កងទ័ពជាច្រើនរយនាក់ -ជាខ្មែរក្រហមរត់ចោលជួរ ឬជាយុទ្ធជនរើសថ្មីដែលហាត់ហ្វឹកហ្វឺននៅប្រទេសវៀតណាម- បានស្លៀកពាក់បង្គួតឯកសណ្ឋានថ្មីទែង និងមួកពណ៌បៃតងរបស់ខ្លួនយ៉ាងខែងរ៉ែង ។ បទភ្លេងជាតិថ្មីមួយដែលច្រៀងជាក្រុមបានលាន់ឮឡើង នៅពេលដែលខ្យល់រំភើយៗបក់ទង់ជាតិប្រមាណដប់ដែលមានពណ៌ក្រហម និងពណ៌លឿង ជានិមិត្តរូបរបស់រណសិរ្សទើបបង្កើតថ្មីរលាស់

វរិច។ ។

សមាជិកគណៈកម្មាធិការទាំងដប់បួនរូប បានឡើងឈរបន្ទាញខ្លួនចំពោះមុខហ្វូងប្រជាជនម្តងមួយៗ ក្រោមការទះដៃអបអរសាទរយ៉ាងកងរំពង ។ បាច់ផ្កាដែលគេនាំពីប្រទេសវៀតណាមមក ត្រូវបានគេជូនចំពោះសមាជិកម្នាក់ៗ ។ ហេង សំរិន ជាប្រធានរណសិរ្សបានឡើងអានកម្មវិធីនយោបាយ នៅពេលដែលហ្វូងប្រជាជនបានស្រែកជយឃោសសម្តែងការគាំទ្រដោយបោះកណ្តាប់ទៅលើ ។ ក្រោយពីនោះ គាត់បានដើរសំដៅទៅមុខដើម្បីថ្លែងអំណរគុណ ឡេ ឌឹកថូ ដែលនៅឈរសង្កេតមើលពិធីនេះពីចម្ងាយហាក់ដូចជាមេមាន់មួយសប្បាយចិត្តនឹងកូនៗរបស់វាអីចឹង ។ ឡេ ឌឹកថូ និយាយមកកាន់ ហេង សំរិន ដោយរីកមុខស្រស់ប៉ប្រិមថា "ខ្ញុំមិននឹកស្មានថាសមមិត្តរៀបចំពិធីបានល្អដូច្នេះសោះ"[៣៣] ។

បន្ទាប់ពីធ្វើមិទ្ទីងរួច បណ្តាកងឯកភាពរបស់ចលនាតស៊ូនិងអ្នកដឹកនាំរណសិរ្សបានដើរពិនិត្យមើលភូមិជាច្រើននៅជាប់ព្រំដែនដែលខ្មែរក្រហមដកថយចេញទៅវិញបាត់អស់ ។ មេដឹកនាំទាំងនោះបានពន្យល់ប្រជាជនពីកម្មវិធី១១ចំណុចរបស់ខ្លួន ដើម្បីដណ្តើមយកជោគជ័យលើរបប ប៉ុល ពត និងរៀបចំជីវភាពគ្រួសារសេដ្ឋកិច្ចទីផ្សារ ប្រាក់កាស សាសនា ឡើងវិញនិងបញ្ចប់សង្គ្រាមព្រំដែនជាមួយប្រទេសវៀតណាម[៣៤] ។ ស្ថានីយវិទ្យុមួយនៅក្រុងហូជីមិញដែលដាក់នាមសម្រាប់ឱកាសនោះថា "សំឡេងរបស់ប្រជាជនកម្ពុជា" បានចាប់ផ្តើមផ្សព្វផ្សាយកម្មវិធីរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងរាយការណ៍ពីដំណើរប្រព្រឹត្តទៅនៃការប្រយុទ្ធផ្សេងៗ ។ ខិត្តប័ណ្ណរាប់ពាន់សន្លឹកដែលអំពាវនាវឲ្យមានការងើបបះបោរប្រឆាំងនឹង ប៉ុល ពត ត្រូវបានគេបាចពីលើយន្តហោះតាមបណ្តាខេត្តនានាដែលនៅជិតព្រំដែន ។

កាលពីម្ភៃប្រាំបីឆ្នាំមុន វៀតណាមធ្លាប់បានជួយឧបត្ថម្ភក្នុងការបង្កើតចលនារំដោះជាតិជាលើកដំបូងរបស់កម្ពុជាគឺរណសិរ្សឯកភាពឥស្សរៈ ដើម្បីវាយប្រយុទ្ធទល់នឹងការកាន់កាប់របស់បារាំង ។ ប្រាំបីឆ្នាំមុន វៀតណាមធ្លាប់បានភ្ជាប់វាសនារបស់ពួកគេជាមួយរណសិរ្សរួបរួមជាតិកម្ពុជាប្រឆាំងនឹងអាមេរិកាំងដែរ ។ ដូច្នេះនេះជាលើកទីបីហើយដែលវៀតណាមរៀបចំ"ចលនាតស៊ូរំដោះ"មួយនៅលើទឹកដីប្រទេសជិតខាងខ្លួន[៣៥] ។ ឡេ ឌឹកថូ ក៏ជាមនុស្សដែលគេស្គាល់រាប់អានយូរមកហើយ គាត់ធ្លាប់បានជួយបង្កើតរណសិរ្សឯកភាពឥស្សរៈតាំងពីពេលមុនមក ហើយចាប់តាំងពីឆ្នាំ១៩៦៦ គាត់គឺជាអ្នកទទួលខុសត្រូវខាងបញ្ហាកម្ពុជានៅការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម[៣៦] ។ មានភាពខុសគ្នាតែមួយប៉ុណ្ណោះ លើកនេះ សត្រូវពុំមែនជាអាណានិគមនិយមបារាំងឬចក្រពត្តិនិយមអាមេរិកាំងទេ ប៉ុន្តែជាអតីតសម័ន្ធមិត្តកុម្មុយនីស្តមួយទៅវិញ ។ ទង់ជាតិថ្មីរបស់ចលនានេះ គឺជានិមិត្តរូបនៃការត្រឡប់ទៅរកប្រពៃណីចាស់នៃសហប្រតិបត្តិការខ្មែរ-វៀតណាមដោយពេញលេញ ៖ រូបប្រាសាទកំពូលប្រាំពណ៌លឿងលើផ្ទៃពណ៌ក្រហម ។ និមិត្តរូបនេះដែលប្រើប្រាស់ជាលើកដំបូងដោយខ្មែរឥស្សរៈក្នុងទសវត្សរ៍៥០ បានត្រូវបោះបង់ចោលដោយក្រុមរបស់ ប៉ុល ពត នៅឆ្នាំ១៩៧៥ ហើយ

កម្ពុជាប្រជាធិបតេយ្យបានអនុម័តទង់ជាតិពណ៌ក្រហម ប្រាសាទពណ៌លឿង កំពូលបីវិញ ។

ប៉ុន្តែនិមិត្តរូបនិយមនេះ បានរបូតផុតពីភាគច្រើននៃសមាជិកថ្មីនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបច្ច័យជាដើមហេតុសំខាន់គឺការរស់រានមានជីវិតនៃក្រុមគ្រួសារ ឬបណ្តាមិត្តភក្តិរបស់ពួកគេដែលស្ថិតនៅក្រោមការក្តោបក្តាប់របស់ខ្មែរក្រហម ។ នេះជាការស្អប់ខ្ពើមរួមមួយចំពោះរបប ប៉ុល ពត ដែលប្រមូលផ្តុំក្រោមការដឹកនាំរបស់វៀតណាមនូវអ្នកដែលរួចផុតពីការសម្លាប់រង្គាលជាច្រើនគឺ អ្នកភៀសខ្លួន ដែលចេញពីវណ្ណៈមធ្យម, អ្នករត់ចោលជួរ និងអ្នកបែកបក្សពួកពីខ្មែរក្រហម ។ ភាគច្រើននៃសមាជិកគណៈដឹកនាំឬអ្នកចូលរួមធម្មតា សុទ្ធតែដក់ជាប់នូវការមិនជឿទុកចិត្តចំពោះចេតនាដ៏ជ្រាលជ្រៅរបស់ពួកវៀតណាម ។ ប៉ុន្តែពួកគេគ្មានឃើញជម្រើសណាផ្សេងក្រៅពីសម្រេចចិត្តធ្វើដូច្នេះ ដើម្បីសង្គ្រោះកម្ពុជាឡើយ ។ សមាជិកភាពគណៈកម្មាធិការកណ្តាលរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពលាយចម្រុះមួយដែលមិនស្ថិតស្ថេរ ៖ អតីតខ្មែរក្រហមប្រាំមួយនាក់ដែលមាន ហេង សំរិន ជាប្រធាន ពួកកុម្មុយនីស្តប្រកាន់តាមទ្រឹស្តីដែលស្និទ្ធវៀតណាម(ខ្មែរឥស្សរៈ)បួននាក់ បញ្ញវន្តទីក្រុងបីនាក់ និងព្រះសង្ឃមួយអង្គ[៣៧] ។

ពេញរយៈពេលនៃការធ្វើមិទ្ទីង កងទ័ពរៀបរយរបស់វៀតណាមជាច្រើនបានពង្រឹងស្ថានភាពការពារជុំវិញទីនោះ ។ អ្នកកាន់កាំភ្លើងបាញ់យន្តហោះបានរំពៃមើលទៅលើមេឃគ្មានឈប់ឈរទាំងនឹកបារម្ភក្នុងចិត្ត ។ ឌិញ កាន និងគ្នីគ្នារបស់គាត់បានទទួលបញ្ជាឲ្យកាប់ព្រៃឈើក្នុងតំបន់មួយស្ថិតនៅចម្ងាយប្រហែលពីរគីឡូម៉ែត្រនៅក្នុងទឹកដីនៃខេត្តក្រចេះរបស់កម្ពុជា ដែលត្រូវរៀបចំធ្វើជាបញ្ជាការដ្ឋានជួរមុខរបស់កងទ័ពវៀតណាម ។ គេបានដឹកជញ្ជូនកុងតឺន័រអាលុយមីញ៉ូមជាច្រើនដែលប្រមូលយកពីមូលដ្ឋាននានារបស់អាមេរិកាំងមកកាន់ទីនេះដែរ ។ គេបានសាងសង់ផ្ទះដំបូលប្រក់ស្បូវនិងលេណដ្ឋានធំៗយ៉ាងច្រើន ។ នៅក្រោមដើមឈើគេរៀបចំដាក់ម៉ាស៊ីនភ្លើង និងសម្ភារបរិក្ខារវិទ្យុទាក់ទង ។ បញ្ជាការដ្ឋាននេះដែលប្រសិទ្ធនាមថា ទៀន ផុង "ប៉ុស្តិ៍ជួរមុខ" នឹងបង្កឲ្យមានព្យុះសង្ឃរាមកលើប្រទេសកម្ពុជានៅពេលខាងមុខឆាប់ៗ ។

## គោលដៅគឺក្រុងភ្នំពេញ

ការផ្តល់សញ្ញាចាប់ផ្តើមការវាយលុកដោយយោធា ត្រូវបានកំណត់ធ្វើក្នុងសង្កាត់មួយនៃខេត្ត បាមេធួត ស្ថិតនៅលើតំបន់ខ្ពង់រាប ។ ការដណ្តើមយកទីក្រុងនេះបន្ទាប់ពីការប្រយុទ្ធដោយមិនឲ្យដឹងខ្លួនមុនមួយនាខែមីនា ឆ្នាំ១៩៧៥ បានកំណត់នូវការចាប់ផ្តើមបើក"យុទ្ធនាការហូជីមិញ"ដែលត្រូវបញ្ចប់ជាមួយការដួលរលំនៃទីក្រុងព្រៃនគរ ។ នៅពាក់កណ្តាលអធ្រាត្រថ្ងៃទី២៤ ខែធ្នូ ជួងរបស់ព្រះវិហារគ្រិស្តសាសនា បានបន្លឺឡើងនៅពេលដែលឧត្តមសេនីយ៍ ជូ ហ៊ុយម៉ាន់ អគ្គស្នងការនយោបាយនៃកងទ័ពប្រជាជនវៀតណាមបានលើកកាំភ្លើងខ្លីបាញ់ឡើងទៅលើមួយគ្រាប់ជាសញ្ញាឲ្យបើកការវាយលុកជាផ្លូវការដែលដឹកនាំដោយឧត្តមសេនីយ៍ ហ្វូង កាំ ។ អ្នក

ទទួលខុសត្រូវវៀតណាមម្នាក់បានរៀបរាប់ប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា “ឧត្តមសេនីយ៍ កាំ ស្គាល់ប្រទេសកម្ពុជាភាគខាងកើតដូចស្គាល់ហោប៉ៅរបស់គាត់ គាត់ធ្លាប់បានដឹកនាំប្រតិបត្តិយោធាសំខាន់ៗជាច្រើនប្រឆាំងនឹង លន់ នល់ ក្នុងអំឡុងទសវត្សរ៍៧០” ។

ក្រោមផ្ទៃមេឃដែលដេរដាសទៅដោយពន្លឺផ្កាយដេកៗ ស្នូរសន្ធឹកនៃរថក្រោះ តេ៥៤ និងឡានកាមីញ៉ុងជាច្រើនគ្រឿងដែលផ្ទុកពេញទៅដោយទាហាន បានចាប់ផ្ដើមចេញដំណើរតាមផ្លូវជាតិលេខ១៨ដែលនាំឆ្ពោះមកកាន់ប្រទេសកម្ពុជាក្រោមអាកាសធាតុត្រជាក់ស្រេង ។ ប្រាំថ្ងៃក្រោយមក ពួកគេបានវាយប្រហារបន្ទាយខ្មែរក្រហមនៅទីក្រុងក្រចេះឲ្យបាក់ទ័ពរត់រប៉ាត់រប៉ាយអស់[៣៨] ។

ក្រចេះជាទីក្រុងមួយដែលវៀតណាមស្គាល់ច្បាស់ដូចក្រយៅដៃក្រោយពេល“រំដោះ”បានពីកងទ័ពរបស់ លន់ នល់ នៅឆ្នាំ១៩៧០ ។ នៅទីនោះវៀតណាមបានបង្កើតមណ្ឌលហាត់ហ្វឹកហ្វឺនមួយសម្រាប់បណ្ដុះបណ្ដាលខ្មែរក្រហមជាច្រើនរយនាក់ឲ្យចេះប្រយុទ្ធតាមបែបកុម្មុយនីស្ត ។ ប្រាំបួនឆ្នាំក្រោយមក ពួកគេបានវាយផ្ដាច់យកទីក្រុងនេះពីកណ្ដាប់ដៃ“អតីតសិស្ស”របស់គេមកវិញដើម្បីប្រគល់ទៅឲ្យសម្ព័ន្ធមិត្តខ្មែរថ្មីរបស់ខ្លួនវិញម្ដង ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរបស់វៀតណាមដែលចុះមកពីប្រទេសឡាវតាមទន្លេមេគង្គបានដណ្ដើមកាន់កាប់ធានីនៃខេត្តស្ទឹងត្រែង ។ តាមពិត ការដួលរលំតំបន់ដ៏សំខាន់បំផុតទាំងពីរ ដែលស្ថិតនៅតាមដងទន្លេមេគង្គនោះបានកាត់ផ្ដាច់ខេត្តចំនួនបួននៅភូមិភាគឦសានរួចជាស្រេច ។ តំបន់ភ្នំសម្បូរទៅដោយព្រៃឈើនៃភូមិភាគឦសានដែលមានអ្នកស្រុកភ្នំរស់នៅតិចតួច សុទ្ធតែជាទីជម្រកស្ងាត់កំបាំងរបស់ចលនាប្រឆាំងនឹង លន់ នល់ កាលពីអំឡុងទសវត្សរ៍៧០ ។ កន្លែងទាំងនោះបានប្រែក្លាយទៅជា“តំបន់រំដោះ”សម្រាប់រណសិរ្សថ្មីរបស់កម្ពុជាជាថ្មីម្ដងទៀត ។

ក្នុងពេលជាមួយគ្នានោះ កងទ័ពរបស់យោធភូមិភាគទី៧ និងទី៩ ក្រោមអគ្គបញ្ជាការឧត្ដមសេនីយ៍ ឡេឌឹកអាញ់ (Le Duc Anh) ដែលមានកងរថក្រោះនាំមុខ បានបើកការវាយលុកយ៉ាងធំមួយតាមផ្លូវជាតិលេខ១និងលេខ៧ដែលនាំតម្រង់មករកទន្លេមេគង្គដូចគ្នា ។ មុនផ្ដើមធ្វើការវាយលុកនេះ កងទ័ពអាកាសរបស់វៀតណាមបានទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ទៅលើទីតាំងទាំងឡាយរបស់ខ្មែរក្រហមស្ទើរតែពេញមួយសប្ដាហ៍ទៅហើយ ។ ប៉ុល ពត បានប្រព្រឹត្តនូវកំហុសយ៉ាងធ្ងន់មួយព្រោះគាត់ប្រមូលផ្ដុំទ័ពប្រហែល ៣០.០០០នាក់ គឺត្រូវជាពាក់កណ្ដាលនៃចំនួនកងទ័ពរៀបរយរបស់ខ្មែរក្រហម ដាក់ពង្រាយរាងកោងដូចធ្នូសន្ធឹងតាមបណ្ដោយតំបន់ចំពុះសេក(ខេត្តស្វាយរៀង) និងតំបន់ផ្លែសន្ទូច (ស្រុកមេមត់ ខេត្តកំពង់ចាម) មិនឆ្ងាយពីព្រំដែនវៀតណាមប៉ុន្មានឡើយ ។ បន្ទាប់ពីការស្ទង់រកទីតាំងតាមអាកាសជាមុនរួចមក កងទ័ពទាំងនោះបាន ត្រូវសម្លាប់យ៉ាងរង្គាលដោយការវាយប្រហារផ្ទួបគ្នារវាងកងកាំភ្លើងធំ និងការទម្លាក់គ្រាប់បែករបស់វៀតណាម ។ កងទ័ពរបស់ ប៉ុល ពត បានបញ្ចេញឲ្យឃើញការតស៊ូរប៉េះរប៉ោះយ៉ាងគួរឲ្យឆ្ងល់ ។ កងទ័ពដែលមានដើមកំណើតជាប្រជាកសិករ

ទាំងនេះចេះសម្លាប់មនុស្សតែនឹងកាំបិតខ្វែវ ផ្កាក់ ប៉ុណ្ណោះ ប៉ុន្តែពួកគេពុំមានពេលវេលារៀនបើកបរយន្តហោះប្រដេញ ឬប្រើកាំភ្លើងយន្តបាញ់យន្តហោះឡើយ ។ ភាគច្រើននៃទីប្រឹក្សា និងគ្រូបង្ហាត់ចិន បានជម្លៀសខ្លួនចេញតាមសមុទ្រដោយគ្មានអែអង់ ដោយទុកឲ្យខ្មែរក្រហមដែលគ្មានបទពិសោធន៍ដោះកុនតែម្នាក់ឯង ។ នៅពេលដែលវៀតណាមចូលដល់ទីក្រុងភ្នំពេញដណ្តើមបានជយភណ្ឌ ពួកគេបានប្រទះឃើញយន្តហោះមិច-១៩ មានគូរទង់ជាតិកម្ពុជាប្រជាធិបតេយ្យថ្មីសន្លាងនៅតម្រៀបជាជួរក្នុងចំណតអាកាសយានដ្ឋានពោធិចិនតុងទាំងអស់ ហើយមានយន្តហោះខ្លះទើបនឹងយកចេញពីកេសថ្មីៗផង ។

បើទុកជាមានការគាំពារតាមផ្លូវអាកាសក៏ដោយ ក៏ការរុលទៅមុខរបស់កងទ័ពវៀតណាមតាមផ្លូវគោកពុំមែនងាយស្រួលនោះទេ ។ វរសេនីយ៍ឯក ប៊ួយទិន ដែលបានថតរូបពីលើខ្នងម៉ូតូរបស់គាត់នូវការវាយប្រយុទ្ធគ្នាផ្សេងៗបាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ)ថា ការច្បាំងគ្នាដែលសាហាវឃោរឃៅជាងគេ ក្នុងយុទ្ធនាការនេះមុនការដណ្តើមបានទីក្រុងភ្នំពេញ គឺបានកើតឡើងនៅក្នុងតំបន់ដ៏ស្ទួច ។ ការប្រយុទ្ធគ្នាដាច់ក្បាលដាច់កន្ទុយបានប្រព្រឹត្តទៅក្នុងរយៈពេលពីរថ្ងៃ ។ វៀតណាមបានសាកល្បងឆ្លងកាត់បរិវេណខ្សែការពារមួយដែលរៀបចំឡើងដោយការជីកប្រឡាយទឹក និងចម្ការមីនធ្វើជារបាំង ។ កាលបើឆ្លងកាត់ឧបសគ្គនេះរួចហើយ កងទ័ពបានប្រញាប់ប្រញាល់ឡើងតាមទន្លេមេគង្គទៅលើរហូតហួសពីធានីនៃខេត្តកំពង់ចាមទៅទៀត ។ ការវាយប្រយុទ្ធគ្នាធំៗពីរទៀតបានកើតមាននៅអ្នកលឿង ផ្លូវជាតិលេខ១ ដែលជាកំពង់ចម្លងចុងក្រោយតាមដងទន្លេមេគង្គមុននឹងទៅដល់ភ្នំពេញ និងនៅតានី(ខេត្តកំពត) តាមផ្លូវជាតិលេខ៣ ឆ្ពោះទៅរកតំបន់ឆ្នេរសមុទ្រ[៣៩] ។ កងឯកភាពកុម៉ង់ដូមួយក្រុមបានសម្រេចជោគជ័យទៅដល់មាត់ច្រាំងទន្លេសាបទល់មុខនឹងក្រុងភ្នំពេញ ។ នៅមុនពេលព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពួកគេបានសាកល្បងឆ្លងកាត់ទន្លេសាបដើម្បីទៅ"រំដោះ"សម្តេច សីហនុ ។ ការប៉ុនប៉ងនេះបានត្រូវបរាជ័យ ។ សម្តេច សីហនុ បានមានព្រះរាជបន្ទូលប្រាប់អាថ៌កំបាំងជាមួយខ្ញុំ(អ្នកនិពន្ធ) ដោយការសោកស្តាយថា "ពួកគេបានឆ្លងកាត់ដៃទន្លេសាបដើម្បីចាប់ពង្រត់ខ្ញុំ ហើយពួកគេបានត្រូវសម្លាប់ស្ទើរតែទាំងអស់ ។ ភ្លាមៗនោះ ខ្ញុំបានដណ្តឹងសួរក្នុងព្រះទ័យថា ហេតុអ្វីបានជា ខៀវ សំផន មកទូលខ្ញុំថា ខ្ញុំមានពេលដប់ប្រាំនាទីដើម្បីរៀបចំចេញដំណើរ? បន្ទាប់មក គេបាននាំខ្ញុំទៅកាន់ខេត្តបាត់ដំបងនិងស៊ីសុផុនទៅ"[៤០] ។

នៅថ្ងៃទី៨ ខែមករា វៀតណាមបានត្រួតត្រាត្រើយខាងកើតទន្លេមេគង្គទាំងអស់ សរុបទៅមានប្រាំពីរខេត្ត ប៉ុន្តែពួកគេលែងអាចសង្ឃឹមយក សម្តេច សីហនុ ឲ្យធ្វើជាអ្នកដឹកនាំរណសិរ្សគ្រប់គ្រង"តំបន់រំដោះ" ដ៏ល្បីងល្បើយទៀតហើយ ។

បន្ទាប់ពីការឈប់ផ្អាកមួយថ្ងៃ ក្នុងរាត្រីថ្ងៃ៨ ខែមករា ការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមបានដាក់បទបញ្ជាផ្តាច់ព្រ័ត្រមួយដែលត្រូវសម្រេចឲ្យបានដាច់ខាត"គោលដៅ ៖ ក្រុងភ្នំពេញ" ។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរបស់វៀតណាមបានឆ្លងកាត់ទន្លេមេគង្គនៅអ្នកលឿងនិងនៅខាងជើងកំពង់ចាម ។

ស្ពានបណ្តែតទឹកដែលផលិតនៅសូវៀតនិងកាណូតចម្លងធំៗរបស់អាមេរិកដែលនាំមកពីប្រទេសវៀតណាមបាន អនុញ្ញាតឲ្យរថក្រោះ រថយន្ត និងកងទ័ពឆ្លងមកត្រើយខាងលិចបានដោយងាយស្រួល ។ កងពលប្រាំបួនក្នុង ចំណោមកងពលធំទាំងដប់ពីររបស់វៀតណាម ដែលគាំទ្រដោយកងទ័ពរណសិរ្សបីកងវរសេនាធំទៀត បានហ៊ុម ព័ទ្ធទីក្រុងភ្នំពេញពីទិសអាគ្នេយ៍និងទិសខាងជើង ។ នៅពេលព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងធំរបស់ វៀតណាម បានចាប់ផ្តើមបាញ់ផ្លោងដាក់តំបន់ជាយក្រុងរបស់រដ្ឋធានីយ៉ាងសម្បើម ។ បន្ទាប់មក មាត់ច្រកចូល ទីក្រុងដ៏សំខាន់ជាងគេពីរ គឺផ្លូវជាតិលេខ១ និងផ្លូវជាតិលេខ៧បានស្ថិតនៅក្នុងស្ថានភាពត្រូវឃាំងខ្ទប់ដោយការ រុលមកមុខរបស់ជួរទ័ពវៀតណាមដែលសម្រុកចូលមកទាំងហ្វូងៗ ។

## ភាពសប្បាយរីករាយត្រូវបញ្ចប់

បើតាមភ័ស្តុតាងផ្សេងៗដែលត្រូវគ្នាស្តីពីថ្ងៃចុងក្រោយរបស់ក្រុងភ្នំពេញនោះអាចនឹងឲ្យគេយកទៅគាក់ តែងជាសាច់រឿងមួយក្នុងខ្សែភាពយន្តរបស់ ហ្វែលលីនី (*Fellini* - សមិទ្ធិករភាពយន្តសញ្ជាតិអ៊ីតាលី) បាន ។ មន្ទីរពេទ្យតែមួយគត់របស់ទីក្រុងដែលនៅបំពេញការងារ ឃើញមានហូរហៀរទៅដោយកងទ័ពត្រូវរបួសយ៉ាង ច្រើនដែលដឹកមកពីសមរភូមិ ។ អ្នករបួសប្រមាណមួយរយនាក់ដេកស្តូកស្តឹងនៅលើទីធ្លា និងតាមផ្លូវថ្នល់ខាងមុខ មន្ទីរពេទ្យដែលគ្របដណ្តប់ទៅដោយឈាមនិងសត្វរុយ ហើយស្រែកថ្ងូរដោយការឈឺចាប់នឹងមុខរបួស ។ នៅ កន្លែងដទៃទៀតក្នុងក្រុងភ្នំពេញ គឺជាពេលវេលានៃការសប្បាយរីករាយនិងការរៀបចំពិធីផ្សេងៗ ។ តាម ប្រពៃណី ការបើករដូវនេសាទបានប្រព្រឹត្តទៅនៅចុងខែធ្នូនិងដើមខែមករា ។ នៅព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ ឡានកាមីញ៉ុងពីរគ្រឿងបានដឹកត្រីយកមកឲ្យជំរំ“ប.៣០” ដែលជាជំរំកម្មាភិបាលបដិវត្តន៍តូចតាច និង ក្រុមគ្រួសាររបស់ពួកគេរស់នៅ ។ សម្រាប់អ្នកដែលស៊ីអត់ស៊ីឃ្លានតាំងពីច្រើនខែមកហើយនោះ ការឃើញ“ត្រី” នៅពេលនេះគឺជារបស់ដែលលើកកម្លាំងចិត្តយ៉ាងពិតប្រាកដ ។ ភ្លាមនោះ បរិយាកាសបានប្រែទៅជាការសប្បាយ រីករាយខុសពីសព្វដង ។ មនុស្សទាំងអស់ក្នុងជំរំបានប្រញាប់ប្រញាល់ធ្វើត្រីមុនពេលដែលវាស្អុយ ហើយបាន បរិភោគបាយថ្ងៃត្រង់យ៉ាងស្កប់ស្កល់ បន្ទាប់មក ពួកគេចាប់ផ្តើមរៀបចំត្រីដែលនៅសល់សម្រាប់អាហារពេល ល្ងាច និងប្រឡាក់ទុកសម្រាប់ខែខាងមុខទៀត ។ ប៉ុន្តែ ការសប្បាយរីករាយនេះមានរយៈពេលខ្លីបំផុត ។ បទបញ្ជា ត្រូវបានកំណត់ឲ្យរៀបចំខ្លួនចាកចេញជាបន្ទាន់ ។ ស្ត្រីម្នាក់ដែលមិនជឿបានសួរថា “ចាកចេញឥឡូវនេះឬ? ហើយចុះត្រីរបស់យើងធ្វើយ៉ាងម៉េចទៅ? ការភ័យស្លន់ស្លោមួយបានរាលដាលពេញជំរំទាំងមូល[៤១] ។

មិនឆ្ងាយពីទីនេះប៉ុន្មាន នៅរោងចក្រតម្បាញក្រុងភ្នំពេញក៏មានរឿងដូចគ្នានេះដែរ ។ ខ្មែរក្រហមបាន អនុញ្ញាតឲ្យកម្មករសម្លាប់សត្វជ្រូកនិងមាន់ ដើម្បីរៀបចំពិធីជប់លៀងមួយជាកិត្តិយសដល់បុណ្យខួបលើកទី១នៃ “ជ័យជម្នះជាប្រវត្តិសាស្ត្រ”លើប្រទេសវៀតណាម ។ ការរៀបចំប្រុងប្រៀបស្ទើរតែចប់សព្វគ្រប់ទៅហើយ

ស្រាប់តែកម្មករទាំងអស់បានទទួលបទបញ្ជាឲ្យធ្វើដំណើរជាបន្ទាន់ទៅចំណតរថភ្លើង ដើម្បីត្រៀមចាកចេញតាមផ្លូវដែក[៤៧] ។

វៀតណាម បានកំណត់ធ្វើការផ្អាកមួយក្នុងការវាយលុករបស់ខ្លួនតាំងពីយប់ថ្ងៃទី៣ ខែមករាម្ល៉េះ ហើយក្រុងភ្នំពេញនឹកស្មានទាំងខុសថា មានសន្តិសុខវិញហើយ ។ នៅយប់ថ្ងៃទី៥ ខែមករា ប៉ុល ពត ដែលជឿជាក់លើខ្លួនឯងប្រាកដនោះបានទូល សម្តេច សីហនុ ទុកជាមុនថា កងទ័ពរបស់គាត់ច្បាស់ជាបោសសម្អាតវៀតណាមឲ្យអស់មុនរយៈពេលពីរខែមិនខាន ។ តាមការឲ្យយោបល់របស់ក្រុងប៉េកាំង ខ្មែរក្រហមបានកសាងកន្លែងលាក់អាវុធយ៉ាងរឹងមាំជាច្រើននៅជួរភ្នំក្រវាញ សម្រាប់ករណីដែលពួកគេត្រូវបោះបង់រដ្ឋធានីទាំងប្រញាប់ប្រញាល់ ហើយក្នុងបទសម្ភាសន៍មួយដែលផ្តល់ដល់ទីភ្នាក់ងារព័ត៌មានចិនថ្មី នៅថ្ងៃទី១១ ខែធ្នូ ប៉ុល ពត បានប្រកាសថារដ្ឋាភិបាលរបស់គាត់រៀបចំ«សង្គ្រាមមួយដែលត្រូវប្រើរយៈពេលយូរនិងការប្រឹងប្រែងយ៉ាងខ្លាំង»ជាមួយវៀតណាមរួចស្រេចហើយ ។ ក៏ប៉ុន្តែ កម្ពុជាពុំបានស្មានទុកជាមុនពីការដួលរលំយ៉ាងទាន់ហន់មួយដូច្នេះសោះឡើយ ។ នៅពេលដែល ប៉ុល ពត ដឹងខ្លួនថា ជ័យជម្នះលែងមានហើយនោះ គឺវាហួសពេលទៅហើយ ។ មិនដល់ម្ភៃបួនម៉ោងផង រដ្ឋធានីត្រូវបញ្ចេញមនុស្សទៅក្រៅទាំងអស់ ។ អ្នករស់នៅក្នុងរដ្ឋធានីទាំងប៉ុន្មាន ត្រូវបោះបង់ពេលបាយមិនទាន់ហើយរបស់ខ្លួននិងត្រីរាប់តោនដែលទុកឲ្យស្អុយរលួយចោល ប៉ុន្តែក៏បោះបង់គ្រឿងសាស្ត្រាវុធគ្រាប់រំសេវយ៉ាងច្រើន និងឯកសារទាំងឡាយរបស់គុកទួលស្លែងដែលនាំឲ្យគ្រោះថ្នាក់ទៀតផង ។ «ឌុច» ដែលជាប្រធានគុកនិងជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលគេស្អប់រកជាងគេបំផុតរបស់របបនោះ វិះតែនឹងត្រូវគេទុកចោលនៅនឹងកន្លែង ប៉ុន្តែនៅទីបំផុត ឌុច បានចេញផុតពីភ្នំពេញដោយសុវត្ថិភាព ក្រោយការមកដល់របស់ពួកវៀតណាមបន្តិច ។ ឯកអគ្គរដ្ឋទូតចិននិងទីប្រឹក្សាជាច្រើនរយនាក់អាចចាកចេញទាន់ពេលវេលា ប៉ុន្តែ ដោយទុកចោលអ្វីៗទាំងអស់ដែលពួកគេមាន ។ វៀតណាមមានចិត្តរីករាយយ៉ាងខ្លាំង នៅពេលដែលរកឃើញបន្ទប់ក្រោមដីមួយរបស់ស្ថានទូតដែលផ្ទុកពេញទៅដោយស្រាកូញ៉ាក់របស់បារាំង ។

តើពួកគេជឿងឆ្ងល់នឹងការដួលរលំលឿនរហ័សរបស់ក្រុងភ្នំពេញមែនដែរឬទេ? ។ ទោះជាមកដល់សព្វថ្ងៃ ក៏គេលំបាកនឹងឆ្លើយឲ្យបានច្បាស់ពីរឿងនេះណាស់ ។ ក្នុងកម្រងអនុស្សាវរីយ៍របស់ឧត្តមសេនីយ៍ពីររូបដែលមានទាក់ទងនឹងរឿងនេះ[៤៣]បានរៀបរាប់ថា ៖ ដោយផ្ទុយនឹង«យុទ្ធនាការហូជីមិញ» ដើម្បីដណ្តើមទីក្រុងព្រៃនគរ គ្មានអ្វីដែលត្រូវសរសេរនៅថ្ងៃនេះស្តីពីការធ្វើអន្តរាគមន៍របស់វៀតណាមនៅកម្ពុជាឡើយ ។

គេបានដឹងក្នុងការបរិយាយពីយុទ្ធនាការនៅក្នុងឆ្នាំ១៩៧៥ថា នៅខែធ្នូ ឆ្នាំ១៩៧៨ ការិយាល័យនយោបាយរបស់វៀតណាមបានអនុម័តជាអាទិ៍នូវផែនការសកម្មភាពមួយ ដោយគ្រោងទុកជាមុននូវការបង្កើនរឹតតែខ្លាំងមួយក្នុងការតស៊ូនយោបាយ និងយោធារបស់កងទ័ពប្រជាជនវៀតណាមនៅរវាងឆ្នាំ១៩៧៥-៧៦ «ក្នុងគោលបំណងប្រមូលផ្តុំលក្ខណៈសម្បត្តិផ្សេងៗសម្រាប់ការវាយលុកជាទូទៅមួយ និងការងើបបះបោរមួយ...

ដើម្បីរំដោះភាគខាងត្បូង»[៤៤] ។

បន្ទាប់ពីការវាយលុកជាលើកដំបូងនៅខែមីនា ឆ្នាំ១៩៧៥ ទៅលើតំបន់ខ្ពង់រាបរួចមក របបរបស់វៀតណាមខាងត្បូងបានត្រូវវិនាសយ៉ាងឆាប់រហ័ស ដែលធ្វើឲ្យការិយាល័យនយោបាយរបស់បក្សកុម្មុយនីស្តវៀតណាមសម្រេចចិត្តឆក់យកឱកាសជាយុទ្ធសាស្ត្រនេះ ដើម្បីធ្វើការ“រំដោះទីក្រុងព្រៃនគរឲ្យបាននៅមុនរដូវភ្លៀងធ្លាក់” ។ ការដណ្តើមយកក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ តើការិយាល័យនយោបាយរបស់វៀតណាមបានឆក់ឱកាសជាថ្មីដូចការវាយយកទីក្រុងព្រៃនគរកាលពីបួនឆ្នាំមុនមែនឬ? ឬមួយវៀតណាមមានគោលបំណងតាំងតែពីដើមមកដើម្បីកាន់កាប់ទូទាំងប្រទេស និងលើកបន្តុបរបបអាយ៉ងមួយនៅទីនោះ? ។ បើវិនិច្ឆ័យរឿងនេះទៅតាមល្បឿនដែលវៀតណាមវាយដណ្តើមយកទីក្រុងភ្នំពេញនិងរៀបចំរដ្ឋាភិបាលថ្មីមួយនៅទីនោះ ភាគច្រើននៃអ្នកសង្កេតការណ៍បានសន្និដ្ឋានថា នេះជាគោលដៅរបស់វៀតណាមមែន” ។

តាមការពិត ឥឡូវនេះគេមានព័ត៌មានយ៉ាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អះអាងថា វៀតណាមគ្រាន់តែឆ្លៀតឱកាសដែលហុចឲ្យពួកគេ ដូចនៅក្នុងព្រៃនគរកាលពីឆ្នាំ១៩៧៥ដែរ ។ បទសម្ភាសន៍របស់មេដឹកនាំរណសិរ្សសាមគ្គីសង្គ្រោះជាតិពីររូប បានទៅជាគោលបង្អែកនៃសម្មតិកម្មដ៏មានសារសំខាន់បំផុតនេះ ។ ជា សុទ្ធ សមាជិកស្ថាបនិកម្នាក់ក្នុងចំណោមសមាជិកស្ថាបនិករបស់រណសិរ្ស និងជាសមាជិកការិយាល័យនយោបាយនៃបក្សប្រជាជនបដិវត្តកម្ពុជា បានទទួលស្គាល់នៅក្នុងឱកាសសន្ទនាគ្នាមួយជាមួយ ស៊ីហ្វេន ហ៊ីឌ័រ នៅឆ្នាំ១៩៨១ ថា នៅពេលចាប់ផ្តើមដំបូងៗរណសិរ្សពុំសង្ឃឹមដណ្តើមយកប្រទេសទាំងមូលបានទេ ។ “យើងសង្ឃឹមកាន់កាប់ប្រទេសត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ គឺត្រើយទន្លេមេគង្គម្ខាងហើយចំណែកដែលនៅសល់ទុកឲ្យ ប៉ុល ពត” ។ នេះជាជោគជ័យខាងយោធាដំបូងៗ របស់វៀតណាមដែលបណ្តាលឲ្យមានការផ្លាស់ប្តូរកម្មវិធីមួយ ។ នៅពេលនោះវៀតណាមបានសម្រេចវាយយកទីក្រុងភ្នំពេញតែម្តងទាន់អាចធ្វើទៅបាន ហើយចូលប្រឡូកក្នុងសង្គ្រាមមួយដែលត្រូវប្រើរយៈពេលយូរ និងការប្រឹងប្រែងយ៉ាងខ្លាំង ។ “យើងមិនសង្ឃឹមថា អាចដណ្តើមយកប្រទេសទាំងមូលបានភ្លាមៗឡើយ ។ យើងបានបើកការវាយលុករបស់យើង ហើយយើងពុំប្រទះនឹងការទប់ទល់ណាមួយទាល់តែសោះ ។ ពួកកងទ័ពរបស់ ប៉ុល ពត ចេះតែដកថយ យើងចេះតែរុលទៅមុខឆ្ងាយទៅៗ...នៅពេលដែលយើងដឹងពីស្ថានការណ៍ដែលក្រុងភ្នំពេញជម្លៀសមនុស្សអស់ យើងក៏បុកចូលទៅក្នុងបេះដូងរដ្ឋធានីតែម្តង ។ យើងពុំអាចបណ្តោយឲ្យទីក្រុងទទេស្អាតគ្មានមនុស្សនៅបានឡើយ”[៤៥] ។

សមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សប្រជាជនបដិវត្តកម្ពុជាម្នាក់ទៀតឈ្មោះ ហែម សាមិន បាននិយាយរឿងសម្ងាត់ប្រាប់ ស៊ីហ្វេន ហ៊ីឌ័រ ក្នុងពេលធ្វើសម្ភាសន៍មួយផ្សេងទៀតរបៀបដូចគ្នាដែរថា ៖ គម្រោងការដំបូងគឺវាយប្រហារនិង “ដណ្តើមកាន់កាប់តែត្រើយទន្លេមេគង្គម្ខាងប៉ុណ្ណោះ” ។ “ប៉ុន្តែ នៅពេលដែលយើងផ្តើមបើកការវាយលុកនិងសង្កេតឃើញថាដូចជាស្រួលយើងក៏ចាប់បន្តរុលទៅមុខទៀតទៅ”[៤៦] ។

ហេតុការណ៍ខ្លះៗដែលកើតឡើងត្រូវបានប្រើសម្រាប់បញ្ជាក់ពីចម្លើយជាសាក្សីទាំងនោះ ។ គេអាចរកឃើញសញ្ញាផ្សេងៗនៃការប្រញាប់ប្រញាល់ក្នុងចំណោមមេដឹកនាំរណសិរ្ស នៅចំពោះមុខដំណើរនៃព្រឹត្តិការណ៍ទាំងអស់ដែលលេចឡើងឲ្យឃើញ ។ ការវាយលុកបានចាប់ផ្ដើមនៅចុងខែធ្នូ ប៉ុន្តែទាល់តែដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ទើបរណសិរ្សផ្សព្វផ្សាយតាមវិទ្យុនូវកម្មវិធី“បន្ទាន់” មួយមានប្រាំបីចំណុចដែលត្រូវអនុវត្តក្នុង“តំបន់រំដោះនានា”នៅកម្ពុជា ។ កម្មវិធីនេះត្រូវបានអនុម័តនៅថ្ងៃទី៥ ខែមករា ។ ក្រោយពីការផ្អាកអស់ជាច្រើនលើក មហាសន្និបាតមួយបានប្រារព្ធធ្វើនៅមេមត់ក្នុងខេត្តកំពង់ចាមដើម្បីរៀបចំបក្សកុម្មុយនីស្តកម្ពុជាឡើងវិញ ។ មហាសន្និបាតបានត្រៀមរៀបចំបោះឆ្នោតជ្រើសរើសគណៈដឹកនាំថ្មីមួយនិងអនុម័តកម្មវិធីមួយថ្មីទៅហើយ ស្រាប់តែនៅពេលថ្ងៃត្រង់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិទ្យុបានផ្សាយដំណឹងដ៏គួរឲ្យរំភើបថា ៖ ក្រុងភ្នំពេញត្រូវបានរំដោះហើយ! ។ បក្សដែលទើបបង្កើតថ្មីត្រូវបានចាត់ចែងប្រតិភូចូលរួមមហាសន្និបាតចំនួន៦៦រូបឲ្យទទួលមើលខុសត្រូវកិច្ចការផ្សេងៗភ្លាមតែម្ដង[៤៧] ។

នៅថ្ងៃទី៨ ខែមករា ពួកមេដឹកនាំរណសិរ្សបានរង់ចាំការអនុញ្ញាតរបស់កងទ័ពវៀតណាម ដើម្បីធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ នៅពេលដែលវិទ្យុបានប្រកាសជាសាធារណៈថា បន្ទាប់ពីការរំដោះរដ្ឋធានីដោយ“កងទ័ពបដិវត្តនិងប្រជាជនកម្ពុជា” ក្រុមប្រឹក្សាបដិវត្តន៍មួយដែលមានសមាជិកប្រាំបីរូបបានត្រូវបង្កើតឡើងក្រោមការដឹកនាំរបស់ ហេង សំរិន ។ អតីតមេបញ្ជាការកងពលធំខ្មែរក្រហមដែលទើបនឹងភៀសខ្លួនទៅប្រទេសវៀតណាមស្ទើរតែមិនដល់បួនខែមុនផង បានស្ថិតនៅក្នុងស្ថានភាពត្រូវតម្កើងឲ្យធ្វើជាមេដឹកនាំប្រទេសភ្លាមមួយរំពេច ។

ហេតុការណ៍មួយផ្សេងទៀត មានគោលបំណងបង្ហាញឲ្យឃើញថា វៀតណាមបានប្រព្រឹត្តហួសពីចេតនាដំបូងៗរបស់ខ្លួនទៅទៀតគឺ ការណ៍ដែលក្រុងហាណូយប្រញាប់ប្រញាល់កេណ្ឌប្រមូលក្រុមអ្នកធ្វើការស៊ីវិលវៀតណាម -អ្នកបច្ចេកទេសនិងបុគ្គលិក- មកក្ដោបក្ដាប់ការងារនៅប្រទេសកម្ពុជាតែម្ដង ។ គេពិបាកជឿថានេះជាកំហុសធម្មតាមួយក្នុងការចាត់ចែងណាស់ ។ ក្រុមភ្នាក់ងារសម្ងាត់អាមេរិកាំងបានពិនិត្យឃើញថារថក្រោះរបស់វៀតណាមជាច្រើនគ្រឿងបានខូចនៅតាមផ្លូវជាតិលេខ៦មុនទៅដល់កំពង់ធំ ។ ខ្មែរក្រហមដែលបាក់ទ័ពបានបំផ្លាញរថក្រោះជាច្រើនគ្រឿង ។ គេត្រូវប្រើរយៈពេលមួយសប្ដាហ៍ ដើម្បីផ្គត់ផ្គង់ខ្សែរថក្រោះរបស់វៀតណាម ដូចជាការចាក់ប្រេង ផ្ដល់គ្រាប់រំសេវ ស្បៀងអាហារ ដើម្បីបានទៅដល់ក្រុងបាត់ដំបងទៀត[៤៨] ។

តាំងពីសប្ដាហ៍ទីបីនៃខែមករា ឆ្នាំ១៩៧៩ កងទ័ពរបស់វៀតណាមបានកាន់កាប់ “បេះដូងជាយុទ្ធសាស្ត្រ” របស់កម្ពុជា ទីក្រុងនិងផ្លូវជាតិសំខាន់ៗទាំងអស់ ប៉ុន្តែត្រូវរង់ចាំរហូតដល់ខែមេសា ឆ្នាំ១៩៧៩ និងការមកដល់នៃទ័ពជំនួយ ទើបវៀតណាមចាប់ធ្វើការបោសសម្អាតមូលដ្ឋានតាសាញ់ ដែលបង្កើតឡើងដោយខ្មែរក្រហមដែលរត់គេចខ្លួនទៅនៅក្បែរព្រំដែនថៃ ។

តាំងពីមានការហោះឡើងនៃយន្តហោះចុងក្រោយពីអាកាសយានដ្ឋានពោធិចិនតុង នៅថ្ងៃទី៦ ខែមករា និងការចេញដំណើរនៃរថភ្លើងចុងក្រោយ ពីចំណតអយស្ម័យយានក្រុងភ្នំពេញនៅព្រឹកថ្ងៃទី៧ ខែមករាដែលមាន អៀង សារី ជិះនៅលើនោះដែរ ព្រំដែនរបស់ថៃគឺជាមធ្យោបាយតែមួយគត់ដើម្បីចាកចេញពីប្រទេស ។ អ្នកការទូតមួយក្រុមធំដែលពីមុនបំពេញមុខងារនៅភ្នំពេញក្នុងស្ថានទូតចិន យូហ្គោស្លាវី និងប្រទេសផ្សេងៗទៀត និងទីប្រឹក្សានិងអ្នកបច្ចេកទេសចិនរាប់រយនាក់ បានស្វែងរកទីពំនាក់នៅប្រទេសថៃ ។ មន្ត្រីម្នាក់នៅក្រសួងការបរទេសថៃបាននិយាយថា "សម្រាប់ប្រទេសចិន នេះជាការអាម៉ាស់មុខមួយពុំធ្លាប់មានពីមុនមក" ។ រីតតែមិនដែលសោះទៅទៀត គឺអ្នកតំណាងម្នាក់នៃ"អាណាចក្រកណ្ដាល(ប្រទេសចិន) ត្រូវបានបង្ខំឲ្យរត់គេចពីប្រទេសមួយដែលស្ថិតក្រោមអំណាចរបស់ខ្លួនក្នុងមូលហេតុផ្សេងៗ ដែលធ្វើឲ្យខូចកិត្តិយសដូច្នេះឡើយ ។ ពិតណាស់ពួកថៃបានត្រៀមបម្រុងទទួលធ្វើបដិសណ្ឋារកិច្ច អ្នករត់គេចខ្លួនទាំងនេះយ៉ាងប្រសើរបំផុត ។ គេបានសម្រេចកិច្ចព្រមព្រៀងសម្ងាត់ជាច្រើនដោយអនុញ្ញាតឲ្យយន្តហោះ ប៊ូអ៊ីង ៧០៧ របស់ចិនចុះចតនៅអតីតមូលដ្ឋានអាមេរិកាំងនៅអ៊ូតាប៉ាវ ដើម្បីដឹកពួកចិនដែលជម្លៀសខ្លួនចេញពីកម្ពុជាត្រឡប់ទៅប្រទេសវិញ ។ មុនពេលនេះមិនយូរប៉ុន្មាន ក្រុងប៉េកាំងធ្លាប់បានបរិហារិះគន់មូលដ្ឋានទាំងនេះយ៉ាងខ្លាំងក្លាបំផុត ដោយចោទប្រកាន់ថាជាមូលដ្ឋានជួរមុខសម្រាប់បម្រើ"ការឈ្លានពានរបស់ចក្រពត្តិអាមេរិកាំង" ។

នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩ អៀង សារី ដែលហេវហត់ស្ទើរស្លាប់និងដែលស្រេកឃ្លានបានទៅដល់ព្រំដែនរបស់ថៃ ។ ក្នុងសភាពអ៊ូអរនៃហ្វូងមនុស្ស គាត់បានជ្រុះបាត់ស្បែកជើងទាំងអស់ ។ អ្នកការទូតចិននៅក្រុងបាងកក បាននាំយកស្បែកជើងនិងខោអាវថ្មីៗទៅឲ្យគាត់នៅទីនោះ ។ ឧទ្ធម្ភាគចក្រមួយគ្រឿងនៃកងអាកាសចរណ៍ថៃបានទៅដឹកយកគាត់និងសហការីទាំងប៉ុន្មានរបស់គាត់ ដែលក្នុងនោះមានទាំងអ្នកសារព័ត៌មានរបស់វិទ្យុក្រុងភ្នំពេញផង មកកាន់អាកាសយានដ្ឋាន ដូន មឿង នៅក្រុងបាងកកយ៉ាងស្ងាត់កំបាំងបំផុត ។ ពីទីនេះពួកគេបានជិះយន្តហោះមួយរបស់ក្រុមហ៊ុនថៃអន្តរជាតិសំដៅទៅក្រុងហុងកុង ដែលជាកន្លែងឈប់សំចតដំបូងមួយមុនទៅកាន់ប្រទេសចិនទៀត ។

## របសកម្មសម្ងាត់នៅអ៊ូតាប៉ាវ

ក្នុងចំណោមឯកសារទាំងឡាយដែលកង៍ទ័ពវៀតណាមរឹបអូសបាននៅមូលដ្ឋានតាសាញ់ គេឃើញមានសេចក្ដីចម្លងជាច្រើនស្ដីពីការសន្ទនារវាង អៀង សារី និងពួកមេដឹកនាំចិនចំនួនបួនឈុត ។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៩ គេង ស៊ាវពីង បានស្ដីបន្ទោស សារី ចំពោះ"យុទ្ធនាការបោសសម្អាត(ដែលគាត់បានដឹកនាំ) ថា មានលក្ខណៈជ្រុលហួសហេតុបន្តិច និងមានទំហំធំធេងពេក" ។ គាត់បាននិយាយនឹង សារី ដោយត្រង់ៗថា ការធ្វើវិសុទ្ធកម្មរបស់ខ្មែរក្រហមធ្វើឲ្យមានកំហុសដល់ប្រទេសចិននិងធ្វើឲ្យមាន"ផលអវិជ្ជមានយ៉ាងច្រើន" ។ គាត់បាន

រំពឹកថា ប្រទេសចិនធ្លាប់បានផ្តល់គំរូស្តីពីរណសិរ្សរួមគ្នាជាមួយ“សត្រូវពាយរង”រួចហើយ ជាពិសេសជាមួយជាង កាយចៀក ក្នុងរយៈពេលធ្វើសង្គ្រាមទល់នឹងប្រទេសជប៉ុន ហើយបាននិយាយណែនាំយ៉ាងខ្លាំងក្លាឲ្យ អៀង សារី សម្រេចធ្វើតាមគំរូសម្ព័ន្ធភាពនេះជាមួយ សម្តេច សីហនុ ដែរ ។ “ការមិនសម្រេចចងសម្ព័ន្ធភាពរវាងពួកយើងនឹងព្រះអង្គ គឺជាបរាជ័យមួយយ៉ាងធ្ងន់នៅពេលក្រោយ ។ ដូច្នេះ បើដល់កាលវេលាក្នុងអនាគតមួយឆាប់ៗនេះ ខ្ញុំសូមស្នើត្រៀមទុកមុខតំណែងប្រមុខរដ្ឋជូនសម្តេច សីហនុ វិញ ។ សមមិត្ត ប៉ុល ពត នឹងក្លាយទៅជារដ្ឋមន្ត្រីទី១ ទទួលខុសត្រូវក្រសួងការពារប្រទេសនិងជាអគ្គមេបញ្ជាការកំពូល” ។ តេង បានដាក់កិច្ចសន្យាដោយឥតញញើតថា បើសិនបក្សកុម្មុយនីស្តកម្ពុជាយល់ព្រមធ្វើតាមការណែនាំនេះ ពួកចិននឹង“ជួយជ្រោមជ្រែងកម្ពុជាឲ្យអស់ពីដៃពីជើង” ។ គាត់ក៏បានទូន្មានឲ្យ សារី កែប្រែរបៀបឃោសនារបស់ខ្មែរក្រហមផងដែរ ។ “សម្រាប់ពេលនេះ លោកមិនត្រូវលើកនិយាយពីបក្សកុម្មុយនីស្តទៀតទេ សូមលោកបំផុសពីការស្រឡាញ់ជាតិមាតុភូមិពីគំនិតជាតិនិយម និងលទ្ធិប្រជាធិបតេយ្យវិញប្រសើរជាង” ។

តេង បានប្រាប់ សារី ឲ្យដឹងថា ក្រុងប៉េកាំងបានទុកដាក់ឲ្យកម្ពុជាប្រើប្រាស់នូវថវិកាមួយមានទឹកប្រាក់ចំនួនប្រាំលានដុល្លារអាមេរិក ដែលអាចផ្តល់ឲ្យទៀតកាលបើអស់ ។ តេង បានសួរថា “តើលោកចង់ឲ្យយើងផ្តល់លុយតាមរយៈណា? តាមក្រុងបាងកក? តាមលោក គ្រៀងសាក់ ឬតាមរយៈធនាគារប្រទេសថៃ? សារី បានឲ្យយោបល់ដោយប្រុងប្រយ័ត្នថា : “សូមលោកតម្កល់លុយនៅស្ថានទូតចិនប្រចាំក្រុង បាងកកប្រសើរជាង”[៤៩] ។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៩ ពីរបីម៉ោងក្រោយពីបានចូលរួមក្នុងការជួបគ្នារវាង តេង និង សារី អ្នកយុទ្ធសាស្ត្រដ៏ឆ្នើមរបស់ចិនពីររូបគឺ ចេង ប៉ាវ ជាសមាជិកការិយាល័យនយោបាយ និងអនុរដ្ឋមន្ត្រីការបរទេស ហាន នានឡុង បានឡើងជិះយន្តហោះមួយគ្រឿងរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិ ដើម្បីបំពេញបេសកកម្មសម្ងាត់មួយ ។ ជើងហោះហើរដែលជួលដោយប្រញាប់ប្រញាល់សម្រាប់ ចេង និង ហាន ព្រមទាំងអ្នកទទួលខុសត្រូវជាន់ខ្ពស់ជាច្រើនរូបទៀតរបស់សេនាធិការកងទ័ពប្រជាជនបានតម្រង់មកកាន់ អ៊ូតា ប៉ាវ ។ នាយករដ្ឋមន្ត្រី គ្រៀងសាក់ បានធ្វើដំណើរតាមយន្តហោះទៅមូលដ្ឋានអាកាសចរណ៍នោះដើម្បីទទួលស្វាគមន៍គណៈប្រតិភូចិន ។ នៅថ្ងៃទី១៤ ខែមករា ពួកគេបានពិភាក្សាគ្នាពេញមួយថ្ងៃ ។ គេបានពិភាក្សាគ្នាពីទម្រង់បែបបទផ្សេងៗស្តីពីសហប្រតិបត្តិការចិន-ថៃក្នុងសង្គ្រាមនៅប្រទេសកម្ពុជា ។ គាត់បានហុចដៃឲ្យដោយសម្ងាត់តាំងពីពេលដែល តេង លើកឡើងពីយថាភាពនៃសហប្រតិបត្តិការមួយដើម្បីគាំទ្រខ្មែរក្រហម ។ ដោយមិនលះបង់អព្យាក្រឹតភាពរបស់ខ្លួន ពេលនេះ គ្រៀងសាក់ បានចាត់ចែងសម្រេចធ្វើសម្ព័ន្ធភាពមួយជាមួយក្រុងប៉េកាំងហើយ ។ ជាច្រើនឆ្នាំក្រោយមក អ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់របស់ថៃ បាននិយាយប្រាប់ខ្ញុំដោយស្ងាត់កំបាំងថា គឺក្នុងឱកាសនៃសម័យប្រជុំសម្ងាត់នេះហើយដែលកើតមានការសម្រេចចិត្តធ្វើសហប្រតិបត្តិការមួយរវាងប្រទេសចិននិង

ប្រទេសថៃ[៥០] ។ នៅក្រោយពេលជួបសន្ទនាគ្នានេះ ពួកមេដឹកនាំចិនបានឡើងយន្តហោះត្រឡប់ទៅក្រុងប៉េកាំងវិញជាមួយ ស៊ុន ហាវ ឯកអគ្គរដ្ឋទូតចិនដែលជម្លៀសខ្លួនចេញពីក្រុងភ្នំពេញ ហើយនៅក្នុងការបួបរបស់ពួកគេគឺកិច្ចព្រមព្រៀងមួយដែលមានសារសំខាន់ជាទីបំផុត ។ ក្រៀងសាក់ បានអនុញ្ញាតឲ្យចិនប្រើប្រាស់ទឹកដីរបស់ថៃដើម្បីផ្គត់ផ្គង់គ្រឿងសម្ភារចាំបាច់ និងស្បៀងដល់ខ្មែរក្រហម ។ គាត់បានយល់ព្រមផ្តល់នូវមធ្យោបាយផ្សេងៗក្នុងការដឹកជញ្ជូននិងការសម្រួលដល់ដំណើរឆ្លងកាត់របស់បុគ្គលិកយោធា និងសម្ភារបរិក្ខាររបស់កម្ពុជា ហើយក៏បានព្រមព្រៀងជួយសម្រួលនូវការធ្វើដំណើរទៅបរទេសរបស់ពួកមេដឹកនាំខ្មែរក្រហម ដោយឲ្យឆ្លងកាត់តាមប្រទេសថៃផងដែរ[៥១] ។ នេះគឺជាចំណុចចាប់ផ្តើមនៃការធ្វើសហប្រតិបត្តិការជាយុទ្ធសាស្ត្រដ៏មានសារសំខាន់បំផុត ដែលប្រទេសចិនបានពង្រីកនៅអាស៊ីអាគ្នេយ៍តាំងពីសង្គ្រាមវៀតណាមចប់ទៅ ។

នាវារបស់ចិនពីរគ្រឿងដែលធ្វើដំណើរឆ្ពោះមកប្រទេសកម្ពុជាជាមួយសម្ភារសឹករបស់ខ្លួន ចំពេលដែលមានការដួលរលំនៃក្រុងភ្នំពេញ បានទទួលបញ្ជាឲ្យឈប់សំចតនៅកំពង់ផែមួយរបស់ថៃក្បែរព្រំដែនសមុទ្ររបស់កម្ពុជា ។ ការចាត់ចែងផ្គត់ផ្គង់ជាបន្ទាន់មួយត្រូវបានធ្វើឡើងជាសម្ងាត់ដោយយន្តហោះរបស់ចិនជាច្រើនគ្រឿងរហូតដល់អតីតមូលដ្ឋានទ័ពអាកាសរបស់អាមេរិកាំងនៅ តាឃ្លី ។

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៩ គឺបីថ្ងៃបន្ទាប់ពីការជួបគ្នាជាសម្ងាត់រវាងចិន-ថៃ វិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ ដែលស្ងាត់លែងឮតាំងពីថ្ងៃ៧ ខែមករា បានចាប់ផ្តើមធ្វើការផ្សាយរបស់ខ្លួនឡើងវិញ ។ អ្នកនិយាយវិទ្យុពីមុន បានចាប់ផ្តើមវាយប្រហារប្រឆាំងពួកឈ្លានពានវៀតណាមឥតឈប់ឈរដូចសព្វមួយដង ។ ប៉ុន្តែ ពួកភ្នាក់ងារសម្ងាត់របស់អាមេរិកាំងបានសម្គាល់ឃើញនូវភាពខុសគ្នាដែលគួរឲ្យចាប់អារម្មណ៍មួយ ៖ លើកនេះប៉ុស្តិ៍ផ្សាយគឺស្ថិតនៅប្រទេសចិនវិញ ។

បណ្តាលមូលដ្ឋានសម្រាប់គាំទ្រការដឹកនាំ និងបញ្ជូនគ្រឿងប្រដាប់ប្រដាយោធាទៅឲ្យចលនាទ័ពព្រៃដែលប្រឆាំងវៀតណាមគឺតាំងនៅប្រទេសថៃ ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសចិនបានចាត់ចែងធ្វើការចល័តកងទ័ពរថក្រោះនិងយន្តហោះយ៉ាងសម្បើមមួយទៅកាន់ព្រំដែនរបស់វៀតណាម ដូចដែល តេង ធ្លាប់ព្រលយឲ្យដឹងក្នុងឱកាសនៃដំណើរទស្សនកិច្ចរបស់គាត់នៅក្រុងបាងកកកាលពីពីរខែមុនដែរ ។ ក្នុងឱកាសនៃទស្សនកិច្ចរបស់គាត់នៅទីក្រុងបាងកក ចេង ប៉ាវ បានខំប្រឹងធ្វើឲ្យ ក្រៀងសាក់ បាត់ភ័យព្រួយពីផលវិបាកផ្សេងៗដែលអាចកើតចេញពីសម្ព័ន្ធភាពថ្មីរបស់គាត់ជាមួយខ្មែរក្រហម ដោយលើកយកមកនិយាយពីការដាក់ទណ្ឌកម្មប្រទេសវៀតណាមនៅពេលខាងមុខផង ។ គាត់បាននិយាយប្រាប់មេដឹកនាំថៃថា «នេះពុំមែនជាគោលដៅសម្ចុតបំភ័យតែមួយមុខទេ ដែលប្រទេសចិនបញ្ជូនកងទ័ពទៅកាន់ គ័ងតុង និង យុន ណាន ៖ យើងបានប្រុងប្រៀបទប់ទល់នឹងប្រតិកម្មដែលអាចកើតមានទាំងអស់»[៥២] ។

## ប្រ៊ីហ្សីនស្គី ទទួលបានអត្ថប្រយោជន៍ថ្មីមួយ

បន្ទាប់ពីការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតជាមួយសហរដ្ឋអាមេរិក និងការបន្ធូរចំណងផ្សេងៗរវាងតៃវ៉ាន់និងក្រុងវ៉ាស៊ីនតោន ប្រទេសចិនអាចផ្ទេរកងពលធំទាំងប៉ុន្មានរបស់ខ្លួនដែលស្ថិតនៅតាមខេត្តជាប់ឆ្នេរសមុទ្រទល់មុខនឹងប្រទេសតៃវ៉ាន់មកកាន់ព្រំដែនសូវៀតនិងវៀតណាមវិញ ។ នៅចុងខែមករា ឆ្នាំ១៩៧៩ កងទ័ពរៀបរយចំនួនដប់ប្រាំពីរកងពលធំដែលមានចំនួនប្រមាណ២២៥.០០០នាក់ត្រូវបានដាក់ប្រមូលផ្តុំនៅតាមព្រំដែនរបស់វៀតណាម ។ យន្តហោះប្រដេញទម្លាក់គ្រាប់បែកជាង៧០០គ្រឿង ត្រូវជាមួយភាគប្រាំនៃកងអាកាសចរណ៍របស់ចិន មានគេឃើញសំចតនៅតាមចំណតយន្តហោះនានាក្បែរព្រំដែនវៀតណាមដែរ ។ ក្រុមស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិកបានឲ្យសញ្ញាអាសន្នជាថ្មីស្តីពីការប្រមូលផ្តុំទ័ពរបស់ចិនក្នុងអនុស្សរណៈមួយចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៩ និងទុកសម្រាប់ជម្រាបអ្នកទទួលខុសត្រូវជាន់ខ្ពស់របស់អាមេរិកាំងឲ្យបានដឹងពីរឿងនេះ ។ នៅក្នុងចំណោមអ្នកទាំងនោះ ជាពិសេសអ្នកនៅក្នុងក្រសួងការបរទេសមានអ្នកខ្លះព្រួយបារម្ភពីការរៀបចំប្រុងប្រៀបទាំងនេះដែលវាជាប្រផ្នូលថាច្បាស់ជាមានការវាយប្រហារមួយប្រាកដណាស់នៅមុនដំណើរទស្សនកិច្ចរបស់ តេង នៅសហរដ្ឋអាមេរិក ។ មន្ត្រីម្នាក់បាននិយាយជាសម្ងាត់ប្រាប់លោក ដុនអូបឺដ័រហ្វឺ ជាអ្នកឆ្លើយឆ្លងព័ត៌មានផ្នែកការទូតរបស់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ថា «យើងពុំដឹងនូវអ្វីដែល [តេង] ប្រើឧបាយកលសម្ងាត់ឡើយ» ។ គាត់ប្រហែលនាំពួកយើងឲ្យជាប់ដៃក្នុងការវាយប្រហាររបស់គាត់ផងក៏មិនដឹង ប្តុយ៉ាងហោចក៏ទទួលបានការសមគំនិតតែសម្បកក្រៅមួយដែរ»[៥៣] ។ រីឆាដ ហូលប្រ៊ុក អនុរដ្ឋមន្ត្រីការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីខាងកើតនិងប៉ាស៊ីហ្វិក បានកោះអញ្ជើញឯកអគ្គរដ្ឋទូតចិនចំនួនពីរលើកក្នុងសប្តាហ៍មុនការមកដល់របស់ តេង ដើម្បីប្រាប់គាត់ឲ្យដឹងមុនថា ការវាយប្រហារមួយប្រឆាំងប្រទេសវៀតណាមក្នុងរយៈពេលនៃដំណើរទស្សនកិច្ចរបស់ តេង នឹងធ្វើឲ្យសហរដ្ឋអាមេរិកទើសទាល់ក្នុងចិត្តយ៉ាងសម្បើម»[៥៤] ។

ប្រសិនបើពួកចិនបង្ហាញខ្លួនឡើងជាអ្នកចូលចិត្តយកអាសាគេ គឺពុំមែនតាមរយៈសេចក្តីរាប់អានចំពោះក្រុងវ៉ាស៊ីនតោននោះទេ ប៉ុន្តែពីព្រោះការវាយប្រហារនេះបានត្រូវរៀបចំកម្មវិធីសម្រាប់កាលបរិច្ឆេទមួយ នៅពេលខាងមុខទៀត ។ មន្ត្រីផ្លូវការចិនម្នាក់បានលាតត្រដាងអាថ៌កំបាំងប្រាប់ខ្ញុំ(អ្នកនិពន្ធ) នៅខែមីនា ឆ្នាំ១៩៧៩ ថា «នៅពេលដែលអនុប្រធានបក្សកុម្មុយនីស្តចិន តេង ស៊ាវពីង ចេញដំណើរឆ្ពោះទៅក្រុងវ៉ាស៊ីនតោន យើងបានកំណត់ថ្ងៃខែធ្វើការវាយប្រហាររួចស្រេចទៅហើយ ។ គាត់ពុំមែនទៅសហរដ្ឋអាមេរិកដើម្បីទទួលបានការយល់ព្រមពីពួកអាមេរិកាំងទេ ប៉ុន្តែ ការគាំទ្រខាងផ្លូវចិត្តចំពោះគាត់តែប៉ុណ្ណឹងគឺគ្រប់គ្រាន់ណាស់ទៅហើយ ។ ពួកចិនបានទទួលច្រើនលើសពីហ្នឹងទៅទៀត ហើយបានចាប់ផ្តើមធ្វើសង្គ្រាមប្រឆាំងវៀតណាម ដោយមានការឲ្យដៃជាសម្ងាត់ពីសហរដ្ឋអាមេរិកផង» ។ ដំណើរប្រែត្រឡប់មកវិញនូវរឿងរ៉ាវផ្សេងៗដែលគួរឲ្យអស់

សំណើចមិនសូវមានអ្នកណាកត់សម្គាល់ទេ ៖ ទំប្រឹងទប់«លទ្ធិវាតទីនិយមរបស់ចិន» គឺជាមូលហេតុចម្បង មួយក្នុងចំណោមមូលហេតុចម្បងៗនៃការធ្វើអន្តរាគមន៍របស់អាមេរិកាំងនៅប្រទេសវៀតណាម ។ និមិត្តសញ្ញារបស់ទីបញ្ជាការផ្តល់ជំនួយយោធានៅប្រទេសវៀតណាម(អក្សរកាត់M.C.A.V) គឺរូបដាវមួយរបស់អាមេរិកាំងកំពុងចាក់ទម្លុះមហាកំពែងដែលជានិមិត្តរូបប្រទេសចិនពីម្ខាងទៅម្ខាង ។

តេង បានប្រកាសដោយច្បាស់លាស់ពីគោលដៅផ្សេងៗ នៃដំណើរទស្សនកិច្ចរបស់គាត់លើកនេះ ។ គាត់មកដើម្បីស្វែងរកការគាំទ្រ និងការយោគយល់របស់ពួកអាមេរិកាំងចំពោះផែនការចូលលុកលុយប្រទេសវៀតណាមរបស់គាត់ ។ គាត់ត្រូវតែផ្តល់ការព្រមានមួយចំពោះក្រុងហាណូយ និងក្រុងមូស្គូព្រមទាំងធ្វើឲ្យពួកដែលមិនព្រមជឿអ្វីទាំងអស់ក្នុងបក្សកុម្មុយនីស្តចិនកោតស្ញែងផងដែរ ។ នៅល្ងាចនៃថ្ងៃទៅដល់ក្រុងវ៉ាស៊ីនតោនរបស់គាត់គឺថ្ងៃទី២៨ ខែមករា គាត់បាននិយាយនឹង ប្រឺហ្សីនស្គី ថាគាត់មានបំណងធ្វើការជួបគ្នាតត្តួ(តែពីរនាក់) មួយ ជាមួយប្រធានាធិបតី ខាធ័រ ដើម្បីពិភាក្សាគ្នាពីបញ្ហាប្រទេសវៀតណាម ។ នៅថ្ងៃបន្ទាប់ ពេលចាប់ផ្តើមបើកកិច្ចចរចានៅសេតវិមាន គាត់បានរំឭកប្រាប់ប្រធានាធិបតីអាមេរិកាំងថា «សហរដ្ឋអាមេរិកនិងប្រទេសចិនធ្លាប់បានស្គាល់រយៈកាលនៃការប្រឈមមុខដ៏យូរ និងដ៏លំបាកជាមួយវៀតណាម» ។ នៅពេលយប់គឺ ពេលរៀបចំខ្លួនដើម្បីទទួលទានអាហារពេលល្ងាច តេង បានស្នើលោក ខាធ័រ ដោយទទូចឲ្យមានការជួបគ្នាជាគណៈកម្មាធិការតូចមួយ ដើម្បីពិភាក្សាអំពីបញ្ហាអាថ៌កំបាំងផ្សេងៗ ។ ខាធ័រ បានដកខ្លួនចូលទៅកាន់ការិយាល័យរាងពងក្រពើជាមួយលោក ម៉ុនដេល, វ៉ាន់ស៍ រដ្ឋមន្ត្រីក្រសួងការបរទេស, ហារ៉ូល ប្រោន និង ប្រឺហ្សីនស្គី ដើម្បីស្តាប់ តេង រាយការណ៍ពីផែនការវាយប្រហារប្រទេសវៀតណាមរបស់គាត់ ។ ដោយបញ្ចេញផ្សែងបារីម៉ាកប៉ង់ដាពីមាត់ តេង បានប្រកាសដោយគ្មានព្រឹមថា ប្រទេសចិនមានកាតព្វកិច្ចធ្វើឲ្យស្លាក់ដំណើរការគន់គូរ ផ្នែកយុទ្ធសាស្ត្ររបស់សហភាពសូវៀត ។ «វាជាការចាំបាច់ណាស់ដែលយើងត្រូវខំប្រឹងទប់បង្អន់មហិច្ឆតាហួសប្រមាណរបស់វៀតណាមនិងផ្តល់មេរៀនតូចមួយដែលពួកគេសមនឹងទទួល» ។ គាត់បានធានាអះអាងថា ការវាយប្រហារនឹងធ្វើឡើងក្នុងទំហំតូចល្មមនិងមានកំណត់ ។ អ្វីដែលគាត់ត្រូវការគឺ «ការគាំទ្រខាងផ្លូវចិត្ត» របស់សហរដ្ឋអាមេរិកលើឆាកអន្តរជាតិប៉ុណ្ណោះ[៥៥] ។

ដោយស្នើឲ្យសហរដ្ឋអាមេរិកសម្រេចធ្វើសម្ព័ន្ធភាពមួយប្រឆាំងនឹងក្រុងមូស្គូ និងសុំឲ្យគាំទ្រដល់ការផ្តើមគម្រោងការរបស់គាត់ទល់នឹងវៀតណាម តេង បានឆ្លងផុតដំណាក់កាលថ្មីមួយនៃជម្លោះរវាង វ៉ាន់ស៍ ប្រឹហ្សីនស្គី ។ មួយថ្ងៃមុនដំណើរទស្សនកិច្ចរបស់តេង វ៉ាន់ស៍ បានប្រកាសថា នយោបាយរបស់សហរដ្ឋអាមេរិកចំពោះក្រុងមូស្គូ និងក្រុងប៉េកាំង«នឹងនៅតែលៃឲ្យស្មើគ្នាហើយនឹងមិនឲ្យផ្អៀងទៅម្ខាងៗឡើយ»[៥៦] ។

ក្រសួងការបរទេសបានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីជៀសវាងការចេញផ្សាយសេចក្តីថ្លែងការណ៍ផ្លូវការមួយដោយមិនចង់ឲ្យគេថា អាមេរិកបានភ្ជាប់ការព្រមានរបស់ខ្លួនទៅនឹងការព្រមានរបស់ប្រទេសចិន ដើម្បីប្រឆាំង

«អនុត្តរភាពនិយម»ឡើយ ។ ប៉ុន្តែជាថ្មីម្តងទៀត ប្រ៊ីហ្សីនស្គី បានទទួលជ័យជម្នះលើ វ៉ាន់ស៍ ។ ខាធ័រ ពុំយកចិត្តទុកដាក់នឹងការផ្តល់យោបល់របស់រដ្ឋមន្ត្រីការបរទេសគាត់ឡើយ ។ ត្រូវជំរុញដោយ ប្រ៊ីហ្សីនស្គី ខាធ័រ បានសម្រេចលុបចោលវាក្យខ័ណ្ឌមួយក្នុងសេចក្តីថ្លែងការណ៍រួម ដែលមានក្នុងសេចក្តីថ្លែងការណ៍ចិន-អាមេរិកាំងលើកមុនពីរ ។ ក្នុងការបារម្ភធ្វើឲ្យមានសមតាខាងនយោបាយមួយ គាត់បានបញ្ជាក់ដោយឡែកក្នុងរឿងនេះថា ទំនាក់ទំនងផ្សេងៗរវាងសហរដ្ឋអាមេរិកនិងប្រទេសចិនពុំមែន «សំដៅប្រឆាំងនឹងរដ្ឋដទៃៗទៀតឡើយ» ។ មុនការជួបគ្នារវាង តេង និង ខាធ័រ ប្រ៊ីហ្សីនស្គី បានល្បងសម្រួលការខ្វែងយោបល់គ្នាដែលអាចមានរបស់ប្រធានាធិបតីជាមួយនឹងគម្រោងដាក់ទណ្ឌកម្មចិនដែរ ។ «ខ្ញុំភ័យខ្លាចថា វ៉ាន់ស៍ បានបញ្ចុះបញ្ចូលប្រធានាធិបតីឲ្យធ្វើការគាបសង្កត់ទៅលើពួកចិនដើម្បីកុំឲ្យពួកគេប្រើកម្លាំងបាយ ។ បញ្ហានេះ បានត្រឹមតែញុំាងឲ្យពួកចិនជឿថា សហរដ្ឋអាមេរិកជា«ខ្លាក្រដាស»មួយប៉ុណ្ណោះ»[៥៧] ។ ប៉ុន្តែ នេះពុំមែនជាបញ្ហាត្រូវនិយាយបង្ហាញពីសមត្ថភាពធ្វើអ្វីបានតែប៉ុណ្ណឹងទេ ។ ប្រ៊ីហ្សីនស្គី បាននិយាយដោយខ្លួនឯងប្រាប់លោកប្រធានាធិបតីថា ដោយសារមិត្តភក្តិខ្លះក្នុងចំណោមមិត្តភក្តិរបស់គាត់ដូចលោកជាដើមបាន«ចូលឡុកឡំ យ៉ាងជ្រៅក្នុងការពិភាក្សាផ្សេងៗ ដែលមានមុនការសម្រេចចិត្តផ្តល់«មេរៀន»មួយដល់ប្រទេសវៀតណាមរបស់ចិន...គាត់ក៏វាយតម្លៃនូវអ្វីដែលឲ្យចំណេញផងដែរ»[៥៨] ។

## ចំពោះយើងជាចិន...

បើវិនិច្ឆ័យតាមការដំណាលរបស់ ខាធ័រ និង ប្រ៊ីហ្សីនស្គី មេដឹកនាំមាឌល្អិតរបស់ចិនដែលពិបាកនិយាយគ្នាឲ្យស្តាប់បាន បានធ្វើឲ្យគេភ្ញាក់ផ្អើលជាខ្លាំង ។ ចេញមកពីប្រទេសសត្រូវមួយមិនជាយូរប៉ុន្មាន គាត់បាននិយាយដោយអំណាចដើម្បីគ្រប់គ្រង«ការផ្តល់មេរៀន»ផ្សេងៗ[៥៩] ។ តាមសំអាងរបស់ ប្រ៊ីហ្សីនស្គី ថា សេចក្តីរាយការណ៍ដោយលោក តេង អំពីគម្រោងការវាយប្រហារប្រទេសវៀតណាមរបស់គាត់ គឺជា«ការបង្ហាញនយោបាយប្រើកម្លាំងសរុបតែម្នាក់ឯងនិងដ៏សម្បើមអស្ចារ្យ» ដែលគាត់មិនដែលដឹងមិនដែលឮសោះក្នុងអំឡុងបួនឆ្នាំដែលគាត់នៅសេតវិមាន ។ គាត់បានអះអាងថា «ខ្ញុំប៉ងជាសម្ងាត់ថា របៀបដែល តេង មានយោបល់ពីការពឹងផ្អែកលើការប្រើកម្លាំង អាចមានឥទ្ធិពលទៅលើបណ្តាអ្នកទទួលខុសត្រូវអាមេរិកាំងខ្លះដែលកំពុងកាន់កាប់មុខតំណែងសំខាន់ៗ»[៦០] ។ ដោយមិនភាន់ប្រឡំ គេអាចបញ្ជាក់ថា គាត់មានបំណងនិយាយសំដៅលោក វ៉ាន់ស៍ ជាពិសេស ។ វ៉ាន់ស៍ ដែលមិនពេញចិត្តនឹងរឿងមិនយល់ព្រមពឹងផ្អែក«ការផ្តល់មេរៀន» ក៏ភ័យខ្លាចក្រែងថា ការទទួលស្វាគមន៍ដែលត្រៀមបម្រុងសម្រាប់ តេង ដោយសេតវិមានអាចជំរុញឲ្យក្រុងមូស្គូសន្និដ្ឋានថា វាមានការព្រមព្រៀងគ្នាជាសម្ងាត់មួយ (ដើម្បីបំផ្លាញនរណាម្នាក់) រវាងប្រទេសចិននិងសហរដ្ឋអាមេរិកផងដែរ[៦១] ។ ខាធ័រ ពុំយកចិត្តទុកដាក់ពីរឿងនេះឡើយ ។ គាត់ជឿថា វ៉ាន់ស៍ «ហាក់ដូចជាចង់សម្តែងការសោកស្តាយរបស់

ខ្ជួន» ចំពោះទំនាក់ទំនងចិន-អាមេរិកាំង[៦២] ។

និយាយម្យ៉ាងទៀត គេង បានទទួលអ្វីៗដែលគាត់ត្រូវការស្ទើរតែទាំងអស់ ។ គាត់បានថ្កោលទោសសហភាពសូវៀតជាសាធារណៈ ដែលចោទឲ្យមានបញ្ហាឡើងវិញពីកិច្ចព្រមព្រៀងកម្រិតអាវុធយុទ្ធសាស្ត្រទី២ ដែលសហរដ្ឋអាមេរិកបានរៀបចំដោយអំណត់បំផុតជាមួយក្រុងមូស្គូ និងបានបន្ទឺពាក្យគំរាមកំហែងផ្សេងៗប្រឆាំងប្រទេសវៀតណាមផង ដោយគាត់ពោលពាក្យទាំងនេះនៅចំពោះមុខប្រធានាធិបតី ខាធ័រ ម្នាក់ដែលត្រូវធ្វើឲ្យស្រឡាំងកាំងដែលក្នុងនាមគាត់ជាម្ចាស់ផ្ទះមានការគួរសម គាត់គ្មាននិយាយអ្វីទាំងអស់ទោះជានិយាយប្រឆាំង ឬខ្ជួនដកខ្លួនពីជំហរផ្សេងៗរបស់ចិនក៏ដោយ ។ នៅថ្ងៃទី២៩ ខែមករា ក្នុងឱកាសនៃការជួបជាមួយគណៈកម្មាធិការតូចរបស់គាត់ជាមួយអនុប្រធានាធិបតីចិន ខាធ័រ បានសាកល្បងបញ្ចុះបញ្ចូលគាត់ទាំងខ្លាចចិត្ត ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់មិនឲ្យយោបល់ថា គម្រោងការផ្សេងៗរបស់ចិនអាចធ្វើឲ្យអន្តរាយដល់ទំនាក់ទំនងចិន-អាមេរិកាំងឡើយ ។ ទឡ្ហីករណ៍របស់ ខាធ័រ គឺថា វៀតណាមកំពុងស្ថិតនៅក្នុងស្ថានភាពកាន់តែឯកោឡើងៗនៅក្នុងពិភពលោក ដោយសារតែការកាន់កាប់ប្រទេសកម្ពុជា ហើយបើចិនវាយប្រហារពួកវៀតណាមនោះមុខជានឹងធ្វើឲ្យកម្រើកឡើងនូវសមានចិត្តផ្សេងៗជាគុណប្រយោជន៍ដល់វៀតណាមមិនខាន ។ ការប្តេជ្ញាចិត្តដាក់ទណ្ឌកម្មប្រទេសវៀតណាមរបស់ គេង នៅតែរឹងមាំគ្មានរង្គោះរង្គើ ហើយ ខាធ័រ អាចត្រឹមតែស្នើធ្វើការជួបគ្នាជាថ្មីមួយប៉ុណ្ណោះ ។ ការជួបគ្នាជាថ្មីបានប្រព្រឹត្តទៅនៅព្រឹកថ្ងៃបន្ទាប់ក្នុងការិយាល័យពងក្រពើ (នៃសេតវិមាន) នៅចំពោះមុខអ្នកបកប្រែភាសាតែម្នាក់គត់ ។ នៅពេលនោះ លោក ខាធ័រ បានប្រើវិធីមួយខុសប្លែកពីធម្មតា ។ គាត់បានអានដោយសំឡេងខ្លាំងៗនូវលិខិតសរសេរដៃមួយ ដែលសង្ខេបទឡ្ហីករណ៍ផ្សេងៗរបស់គាត់ប្រឆាំងនឹងការលុកលុយមួយនៅប្រទេសវៀតណាមមុននឹងប្រគល់ជូនភ្ញៀវរបស់គាត់ ។ គេអះអាងថាគោលដៅរបស់គាត់ គឺការសម្តែងឲ្យឃើញការប្រឆាំងជាផ្លូវការរបស់គាត់ ដោយប្រាថ្នាអស់ពីពោះពីពុងថា គេងមិនយកចិត្តទុកដាក់នឹងរឿងនេះឡើយ ។ ខាធ័រ បានអះអាងថា «ខ្ញុំមានអារម្មណ៍ថា ការសម្រេចចិត្តត្រូវបានប្រកាន់យកស្រេចទៅហើយ ។ ប្រទេសវៀតណាមនឹងត្រូវដាក់ទណ្ឌកម្ម»[៦៣] ។

ខ្លឹមសារខាងក្នុងលិខិតនៅតែជាអាថ៌កំបាំងដដែល ។ ប្រ៊ីហ្សីនស្គី បានថ្លែងក្រោយមកទៀតថា គំនិតផ្តួចផ្តើមរបស់ ខាធ័រ គឺជារឿងតែមួយគត់ដែលត្រូវនិយាយ ហើយគាត់នឹងបន្ថែមប្រកបដោយភាពស្មោះត្រង់គ្មានលាក់លៀមដែលធ្វើឲ្យទាស់គំនិតថា «យើងពុំអាចធ្វើសម្ព័ន្ធភាពតាមផ្លូវការជាមួយនឹងពួកចិន និងឧបត្ថម្ភគាំពារចំពោះអ្វីដែលគ្រាន់តែជាការឈ្លានពានដោយកម្លាំងទ័ព ដែលគិតទុកជាមុនស្រេចបានឡើយ ។ ក្នុងពេលជាមួយគ្នានោះ ការសន្យាពុំបានផ្តល់ផ្តាល់យើងឲ្យត្រូវតែថ្កោលទោសប្រទេសចិននៅអង្គការសហប្រជាជាតិនៅពេលក្រោយឡើយ» ។

ដោយភ័យខ្លាចថា ពួកចិនប្រកាន់យកការអះអាងទាំងនេះមែនទែន ប្រ៊ីហ្សីនស្គី បានប្រកាសប្រាប់រដ្ឋមន្ត្រី

ការបរទេសចិន ហួងហួ ក្នុងអំឡុងនៃការសន្ទនាជាឯកជនមួយនៅថ្ងៃដដែលថា មូលហេតុនៃការព្រួយបារម្ភពិតប្រាកដតែមួយគត់របស់អាមេរិកាំង គឺប្រតិកម្មដាយថាហេតុរបស់ពួកសូវៀត ។ គាត់បានសាកល្បង «លើកទឹកចិត្តពួកចិនឲ្យកំណត់ពេលវេលាធ្វើការវាយលុកឆាប់រហ័សមួយ ដាដាងប្រឡូកក្នុងជម្លោះយូរអង្វែងមួយ», នេះជាពាក្យដែល គេង បានសន្យានឹង ខាធ័រ តាំងពីពេលនោះម្ល៉េះ ។ ប្រ៊ីហ្សីនស្គី បានសរសេរក្នុងកម្រងអនុស្សាវរីយ៍របស់គាត់ថា «ដើម្បីជាសញ្ញាមិត្តភាព ខ្ញុំបានទៅកាន់ដំបូលរាបសម្រាប់ការហោះហើរនៃឧទ្ធម្ភាគចក្រនៅក្បែរវិមានក្រុងវ៉ាស៊ីនតោនដើម្បីជម្រាបលា គេង ។ ខ្ញុំមានបំណងធ្វើឲ្យគាត់ដឹងថា គាត់ទទួលបានការគាំទ្ររបស់សេតវិមាន, ខ្ញុំជឿថា គាត់សប្បាយចិត្តយ៉ាងខ្លាំងនឹងរឿងនេះ» ។ បើសិនជា ខាធ័រ យកចិត្តទុកដាក់បញ្ចុះបញ្ចូលប្រទេសចិនឲ្យវាយប្រហារប្រទេសវៀតណាមមែន កាយវិការជានិមិត្តរូបរបស់ ប្រ៊ីហ្សីនស្គី មិនសូវជ្រោមជ្រែងគាត់(ខាធ័រ)ក្នុងរឿងនោះប៉ុន្មានទេ ។ តាមការពិត ខាធ័រ ដែលត្រូវធ្វើឲ្យប្របូកប្របល់ចិត្តរវាងសន្តិនិយម (ការដោះស្រាយអធិករណ៍ដោយសន្តិវិធី) តាមបែបគ្រិស្តសាសនារបស់គាត់ និងភាពចាំបាច់ធ្វើខ្លួនជាប្រធានាធិបតីខ្លាំងម្នាក់ហាក់ដូចជាជ្រើសយកផ្លូវនៃ ភាពងាយស្រួលជាង : ការប្រឆាំងជំទាស់ដែលគ្រាន់តែមានទម្រង់ក្រៅមួយ និងការស៊ុមគ្រលុំរបៀបញាក់ភ្នែកដាក់គ្នាមួយ ។ នៅពេលដែលការលុកលុយរបស់ចិនដែលគេរង់ចាំយូរមកហើយបានចាប់ផ្តើម១៦ថ្ងៃ ក្រោយមក ក្រុងវ៉ាស៊ីនតោនបានខិតខំធ្វើយ៉ាងណាឲ្យក្រុងប៉េកាំងរួចផុតពីការសងសឹករបស់សូវៀត ដោយជំរុញឲ្យក្រុងមូស្គូប្រកាន់នយោបាយនិយមកណ្តាលមួយ ។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងកំណត់អាវុធយុទ្ធសាស្ត្រទី២ ដែលទាក់ទាញការយកចិត្តទុកដាក់របស់ពួកអាមេរិកាំង គឺផ្អែកលើការដឹកនាំល្អរបស់សហភាពសូវៀត[៦៤] ។

បើលោក ខាធ័រ និង ប្រ៊ីហ្សីនស្គី ធ្វើហាក់ដូចជាមិនសូវប្រឆាំងនឹងការវាយប្រហារប្រទេសវៀតណាមដោយប្រទេសចិនក៏ដោយ ក៏បណ្តាសមាជិកដ៏ឆ្នើមខ្លះនៃសភាជាន់ទាបបានគាំទ្រ គេង ដោយចេញមុខតែម្តង ។ ប្រធានសភា ទីប អូនៀល (Tip O'Neill) បានធ្វើការសន្ទនាមួយជាមួយអនុប្រធានាធិបតីចិននៅវិមានកាពីតូល ហើយគាត់បានប្រកាសប្រាប់លោកអនុប្រធានាធិបតីចិនថា បើពុំមានអ៊ីបញ្ឈប់គំនិតផ្សងព្រេងនិយមរបស់វៀតណាមទេ គេមុខជាប្រទះគ្រោះថ្នាក់នៃសង្គ្រាមលោកលើកទីបីមួយមិនខាន : នៅពេលដែលកងទ័ពជប៉ុនកាន់កាប់ដែនដីម៉ាន់ជូរី នៅឆ្នាំ១៩៣១ គ្មាននរណាម្នាក់ធ្វើអន្តរាគមន៍ទេ ហើយពិភពលោកកំពុងស្ថិតនៅក្នុងសង្គ្រាមលោកពេញទំហឹង ។ ដោយភ្ញាក់ផ្អើលបន្តិចបន្តួចពីការខិតចូលជិតគ្នាដែលមិនសមស្របតាមកាលៈទេសៈ គេង បានឆ្លើយតបនឹង អូនៀល ថា ទោះជាករណីប្រទេសវៀតណាមពុំមែនដូចសុទ្ធសាធនឹងករណីដទៃក៏ដោយ ក៏គាត់ចាំបាច់ត្រូវតែ«ផ្តល់មេរៀនមួយ»[៦៥] ឲ្យវៀតណាមដែរ ។

នៅក្រោយពេលចប់ការសន្ទនារបស់គាត់ជាមួយរដ្ឋាភិបាលនិងពួកមេដឹកនាំសភាជាន់ទាប គេង បានរៀបចំធ្វើសន្និសីទកាសែតមួយនៅទីក្រុងវ៉ាស៊ីនតោន ដែលគាត់បានប្រកាសថា : «សម្រាប់យើង យើងយល់ថា

វៀតណាមជាពួកគុយបានៅបូព៌ា ។ បើសិនជាគេមិនផ្ដល់មេរៀនឲ្យទេ ការបង្កហេតុនឹងមានរឹតតែខ្លាំង...។ ខ្ញុំអាចបញ្ជាក់ប្រាប់អស់លោកនូវរឿងពីរ ៖ ចំពោះយើងជាចិន យើងគិតនូវអ្វីដែល យើងនិយាយហើយមិនធ្វើដោយគ្មានពិចារណាទេ»[៦៦] ។

## ច្បាប់ក្បួននៃសង្គ្រាម

តេង មានលក្ខណៈជាមនុស្សប្រឡោតគ្មានដឹងខុសត្រូវ ប៉ុន្តែស្មោះត្រង់ ។ ការធ្វើឲ្យមានប្រក្រតីភាពទាំងប្រញាប់ប្រញាល់ជាមួយក្រុងវ៉ាស៊ីនតោន ការជួបសន្ទនាជាឯកជន និងសេចក្ដីថ្លែងការណ៍ជាសាធារណៈ សុទ្ធតែបានត្រិះរិះដោយផ្ចិតផ្ចង់ក្នុងផែនការវាយប្រហារប្រទេសវៀតណាមតាមគំនិតរបស់គាត់ ។ ដោយផ្ទុយនឹងគម្រោងការរបស់វៀតណាមដែលស្វែងរកលទ្ធផលពីការភ្ញាក់ផ្អើល ដោយបដិសេធនូវបំណងទន្ទ្រានចូលប្រទេសកម្ពុជានោះ យុទ្ធសាស្ត្ររបស់ពួកចិនច្រើនពឹងផ្អែកទៅលើការប្រឆាំងនឹងការបរិហារផ្សេងៗជាង ។ ដោយយកចិត្តទុកដាក់ផ្ដល់ព័ត៌មានដល់អ្នកដែលឈឺឆ្អាលអំពីបំណងផ្សេងៗរបស់ខ្លួន ក្រុងប៉េកាំងប្រាថ្នាបង្កើតបរិយាកាសយោគយល់គ្នាមួយ ថែមទាំងការស្រុះចិត្តគំនិតគ្នាមួយផងដែរជុំវិញ«សង្គ្រាមតាមក្បួនច្បាប់»របស់ខ្លួន ។ ពេលត្រឡប់មកពីសហរដ្ឋអាមេរិកវិញ តេង បានឈប់សំចតមួយរយៈខ្លីនៅក្រុងតូក្យូ ដើម្បីរាយការណ៍ប្រាប់ពួកមេដឹកនាំជប៉ុនពីគោលដៅធំៗ នៃផែនការវាយប្រហារប្រទេសវៀតណាមរបស់គាត់ ។ គាត់បានបន្ថែមថា គាត់បានប្រាប់ដំណឹងនេះដល់ប្រធានាធិបតី ខាធ័រ រួចហើយ[៦៧] ។ ការលាតត្រដាងនេះ និងការមិនមានប្រតិកម្មជាផ្លូវការរបស់ក្រុងវ៉ាស៊ីនតោន បានធ្វើឲ្យជប៉ុនស្ថិតនៅក្នុងភាពមន្ទិលសង្ស័យរបស់ខ្លួនជានិច្ច ៖ ពិតជាមានការព្រមព្រៀងគ្នាសម្ងាត់រវាងចិន-អាមេរិកាំងដាក់ជាប្រាកដ ។ គម្រោងការរបស់ក្រុងប៉េកាំងមិនសូវធ្វើឲ្យពួកជប៉ុនរីករាយប៉ុន្មានទេ ប៉ុន្តែដោយសារគោរពចំពោះសហរដ្ឋអាមេរិក ពួកជប៉ុនគ្រាន់តែសម្ដែងនូវការមិនយល់ស្របរបស់គេដោយប្រើពាក្យសម្ដីថ្លឹងថ្លែងជាទីបំផុតប៉ុណ្ណោះ[៦៨] ។

នៅថ្ងៃទី៩ ខែកុម្ភៈ គឺមួយថ្ងៃបន្ទាប់ពីការវិលត្រឡប់មកវិញរបស់គាត់ គណៈកម្មការយោធារបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន បានបើកសម័យប្រជុំមួយក្នុងរយៈពេលបីថ្ងៃក្រោមអធិបតីភាពរបស់ តេង ស៊ាវពីង ដើម្បីប្រកាន់យកការសម្រេចចិត្តជាស្ថាពរមួយ ។ តេង បានរាយការណ៍ប្រាប់គណៈកម្មការពីការទទួលស្វាគមន៍ដោយរាក់ទាក់ ដែលត្រៀមបម្រុងសម្រាប់គាត់នៅបណ្ដាប្រទេសលោកខាងលិចនិងសមាគមអាស៊ាន ។ នៅសល់តែបញ្ហាត្រូវពិនិត្យមើលដោយល្អិតល្អន់អំពីប្រតិកម្មផ្សេងៗដែលអាចកើតមានពីសហភាពសូវៀតប៉ុណ្ណោះ ។ តាមយោបល់របស់គាត់ថា រឿងនេះមានករណីពិសេសបី ៖ ឬមួយពួកសូវៀត គ្រាន់តែធ្វើការថ្កោលទោសតាមពាក្យសម្ដីមួយតែប៉ុណ្ណឹង ឬមួយពួកគេប្រើការឆ្មក់ចូលវាយប្រហាររបៀបដាក់ទណ្ឌកម្មដោយមានកម្រិតមួយពីម្ខាងទៀតនៃព្រំដែន ឬមួយពួកគេរៀបចំធ្វើការលុកលុយមួយក្នុងទ្រង់ទ្រាយធំ ។ តាមគាត់ស្មាន

យថាភាពទីបីគឺគ្មានសង្ឃឹមថា នឹងមានទេ ។ គាត់លម្អៀងទៅរកយថាភាពទីមួយដាង ។ ចំណែកយថាភាពទីពីរគឺប្រទេសចិននឹងត្រៀមធ្វើការប្រឈមមុខនឹងរឿងនេះរួចហើយ[៦៩] ។

ការដែល តេង ជឿជាក់អំពីការគ្មានប្រតិកម្មរបស់សូវៀត គឺដោយសារតែសន្ធិសញ្ញាកម្រិតអាវុធយុទ្ធសាស្ត្រទីពីរ ដែលគាត់ថ្កោលទោសដោយជាក់លាក់ ។ គាត់សន្និដ្ឋានថា ក្រុងមូស្គូបានត្រូវធ្វើឲ្យខ្វល់គំនិតមែនទែន ដោយសារសន្ធិសញ្ញាកម្រិតអាវុធយុទ្ធសាស្ត្រដើម្បីប្រឡូកក្នុងជម្លោះមួយ ។ គាត់សង្ឃឹមដែរថាសហរដ្ឋអាមេរិកនឹងគាបសង្កត់ទៅលើពួកសូវៀត ដើម្បីកុំឲ្យពួកគេធ្វើឲ្យអន្តរាយដល់សន្ធិសញ្ញាក្នុងការសម្រេចចិត្តធ្វើសកម្មភាពយោធាមួយប្រឆាំងនឹងប្រទេសចិន ។ តេង ធ្លាប់និយាយប្រាប់ពួកអាមេរិកាំង និងពួកជប៉ុនថាការវាយលុករបស់ខ្លួនមានលក្ខណៈកម្រិតកំណត់មួយ និងមានរយៈពេលមិនលើសពីម្ភៃថ្ងៃឡើយ ។ តាមមើលទៅគាត់ប្រហែលសង្ឃឹមថា សារនេះនឹងទៅដល់វិមានក្រឹមឡាំងដែរហើយមើលទៅ[៧០] ។

ប៉ុន្តែ ក្រុងប៉េកាំងមិនទុកចិត្តលើពួកជប៉ុននិងពួកអាមេរិកាំង ដើម្បីឲ្យជួយបញ្ជូនដំណឹងនេះឡើយ ។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៩ យុវអ្នកការទូតបារាំងម្នាក់ដែលមានមុខតំណែងនៅក្រុងម៉ានីលប្រទេសហ្វីលីពីនមានការងឿងឆ្ងល់ដែលបានទទួលការហៅតាមទូរស័ព្ទមួយពី ស៊ាវហ្វៃ (Xiao Fei) ជាសមភាគីចិនម្នាក់ដែលគាត់ធ្លាប់ជួបនៅក្នុងពិធីបដិសណ្ឋារកិច្ចផ្សេងៗ ហើយដែលមានបំណងជួបគាត់ជាបន្ទាន់ ។ គាត់បានប្រកាសយ៉ាងឱឡារិកថាប្រទេសចិនបានទ្រាំអត់ធ្មត់ដល់ទីបំផុត ហើយបានត្រៀមខ្លួនដាក់ទណ្ឌកម្មប្រទេសវៀតណាមជាស្រេច ។ គាត់បានអះអាងថា ៖ "ដូចការវាយប្រហារក្នុងបំណងដាក់ទណ្ឌកម្មប្រឆាំងនឹងឥណ្ឌាកាលពីឆ្នាំ១៩៦២ដែរ នេះជាប្រតិបត្តិការមានកំណត់មួយ" ។ អ្នកការទូតបារាំងបានសួរថា ៖ តើក្រុងមូស្គូនឹងធ្វើយ៉ាងម៉េច? ។ ស៊ាវ បានឆ្លើយតបដោយគ្មានរួញរាថា "ពួកសូវៀតបានផ្តល់នូវការធានាអះអាងថា សូវៀតនឹងមិនចូលធ្វើអន្តរាគមន៍ឡើយ" ។ ដូច្នេះសង្គ្រាមមួយច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។ អ្នកការទូតបារាំងដែលត្រូវធ្វើឲ្យទ័លគំនិតដោយសារការលាតត្រដាងខុសពីធម្មតានេះ បានប្រញាប់ប្រញាល់ផ្ញើសារទូរលេខមួយទៅក្រសួងការបរទេសភ្លាម ។ អាស្រ័យដោយដំណើររអាក់រអួលផ្នែកការិយាធិបតេយ្យ លិខិតទូរលេខរបស់គាត់ចុះថ្ងៃទី១២ ខែកុម្ភៈ ដែលប្រាប់ដំណឹងពីការលុកលុយរបស់ចិនពុំត្រូវបានគេវាយចេញទៅទេ ប៉ុន្តែបានទៅដល់តាមហិបអ្នកការទូតទៅវិញ ។ ទូរលេខនេះបានទៅដល់ទីក្រុងប៉ារីស បន្ទាប់ពីមានការចាប់ផ្តើមផ្តល់"មេរៀន"ពីរថ្ងៃទៅហើយ[៧១] ។

ដូច្នេះ ក្រុងប៉ារីសពុំមានពេលគ្រប់គ្រាន់ផ្តល់ព័ត៌មានឲ្យក្រុងហាណូយដឹង ទាំងពុំមានពេលស្ទាបស្ទង់យោបល់ក្រុងមូស្គូស្តីអំពីភាពត្រឹមត្រូវតាមការពិតនៃទឡ្ហីករណ៍ផ្សេងៗរបស់ពួកចិនដែរ ។ ប៉ុន្តែ គេអាចបញ្ជាក់ដោយមិនខ្លាចភ័ន្តច្រឡំថា ក្រុងមូស្គូបានទទួលនូវការធានាអះអាងអំពីលក្ខណៈមានកំណត់នៃការធ្វើប្រតិបត្តិនេះរួចហើយ មុនពេលដែលកាំភ្លើងធំរបស់ចិនរាប់រយដើមចាប់បាញ់ផ្គត់ស្រោចដូចភ្លៀងនៅព្រឹកថ្ងៃទី១៧

ខែកុម្ភៈ ដែលធ្វើឲ្យមានមហន្តរាយយ៉ាងសម្បើមនៅតាមបណ្តោយព្រំដែនរបស់វៀតណាម ។

នៅវេលាព្រឹកថ្ងៃទី១៦ ខែកុម្ភៈ (ម៉ោងនៅទីក្រុងវ៉ាស៊ីនតោន) ប្រាំមួយម៉ោងគត់មុនបើកយុទ្ធនាការវាយប្រហារ ចាយ ហ្សេមិន (Chai Zemin) ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំសហរដ្ឋអាមេរិកបាននាំសារលិខិតមួយទៅកាន់សេតវិមាន ដែលប្រកាសឲ្យដឹងពីការចាប់ផ្តើម“វិធានការការពារខ្លួន”ប្រឆាំងនឹងប្រទេសវៀតណាម ។ ក្រុងប៉េកាំងបានជ្រើសរើសម៉ោងពេលរបស់ខ្លួនល្អណាស់ ។ រដ្ឋមន្ត្រីការបរទេសរបស់ឥណ្ឌា អាតាល់ ប៊ីហារី វ៉ាស់ប៉ាយី បានស្ថិតនៅប្រទេសចិន ទុកណាជាទំនាក់ទំនងផ្សេងៗរវាងចិន-ឥណ្ឌាត្រូវធ្វើឲ្យកកស្ទះក្នុងរយៈពេលដប់ប្រាំពីរឆ្នាំ បន្ទាប់ពីសង្គ្រាមនៅឆ្នាំ១៩៦២ក៏ដោយ ។ គ្មាននរណាម្នាក់ ហើយប្រាកដជាមិនមែនវៀតណាមទេ អាចគិតទៅលើអ្វីដែលក្រុងប៉េកាំងប្រថុយប្រថានធ្វើឲ្យអន្តរាយដល់ភាពធូរស្រាលដែលទើបនឹងកើតមានថ្មីៗនេះ ដោយផ្តើមធ្វើការវាយប្រហារប្រឆាំងនឹងប្រទេសជាមិត្តមួយរបស់ឥណ្ឌា ចំពេលវេលាដ៏ជាក់លាក់នេះណាស់ ។ តាមពិតក្រុងហាណូយមានសង្ឃឹមយ៉ាងខ្លាំងថា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៩ នោះនាយករដ្ឋមន្ត្រីផាំវ៉ាន់ដុង ដែលអមដំណើរដោយនាយសេនាធិការ វ៉ាន់ ទៀន យុង និងមេដឹកនាំជាន់ខ្ពស់ជាច្រើនរូបទៀតត្រូវចេញដំណើរមកកាន់ក្រុងភ្នំពេញផង ។ ពួកគេត្រូវស្ថិតនៅកម្ពុជា បួនថ្ងៃ ដើម្បីពង្រឹងចំណងទាក់ទងផ្សេងៗជាមួយរបបថ្មី[៧២] ។

ថ្ងៃសៅរ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៩ មុនពេលព្រះអាទិត្យរះបន្តិចអ័ព្ទដ៏ក្រាស់មួយបានគ្របដណ្តប់ជួរភ្នំតូចៗសម្បូរទៅដោយព្រៃឈើនៅតាមព្រំដែនចិន-វៀតណាមនៅឡើយ ។ នេះគឺជាពេលវេលាដែលកងទ័ពរបស់ចិនបានជ្រើសរើសដើម្បីបញ្ចេញកំហឹងក្រេវក្រោធរបស់ខ្លួន ។ វាមានភាពដូចគ្នាមួយនឹងការវាយលុកចុងក្រោយ នៅពេលដែល ជាន ឡុងជា ព្រះចៅអធិរាជ ម៉ាន់ជូ បញ្ជូនកងទ័ពសេះនិងកងទ័ពថ្មើរជើងមួយ នៅឆ្នាំ១៧៨៨ ដើម្បីដាក់ស្តេចមួយអង្គឲ្យសោយរាជ្យនៅក្រុងហាណូយតាមការជ្រើសរើសរបស់ខ្លួនដែរ ។ កម្លាំងផ្ទុះអាវុធដ៏សម្បើមរបស់ពួកចិន-កាំភ្លើងធំបាញ់បានរយៈឆ្ងាយទំហំ១៣០មិល្លីម៉ែត្រ និង១២០មិល្លីម៉ែត្រ និងកាំភ្លើងបាញ់គ្រាប់រ៉ុក្កែតទំហំ១៤០មិល្លីម៉ែត្ររាប់រយដើម-បានធ្លាក់ស្រោចមកលើប្រទេសវៀតណាមតាមសន្ទុះប្រហែលមួយគ្រាប់ក្នុងមួយវិនាទី ។ អ្នកយកព័ត៌មានអាមេរិកាំងម្នាក់ដែលស្ថិតនៅផ្ទាល់នឹងទីកន្លែងបានសរសេរថា “សំឡេងគ្រាប់កាំភ្លើងដែលបាញ់ចេញមានសភាពឡើងណែន បើគេស្តាប់ពីចម្ងាយលាន់ឮស្នូរហាក់ដូចជាការវាយប្រហារមួយពីសំណាក់យន្តហោះបេ-៥២អ៊ីចឹង” ។ គាត់បានបន្ថែមថា យ៉ាងហោចក្នុងមួយលើកៗការបាញ់ផ្លោងមានថិរវេលាម្ភៃនាទីជាប់គ្នារហូតតាងឲ្យការបាញ់ច្រើនបំផុតក្នុងមួយនាទីទៅតាមវិធាននៃការទម្លាក់គ្រាប់បែករបស់អាមេរិកាំង[៧៣] ។

តមកទៀត ទាហានចិនប្រហែល៨៥.០០០នាក់ ដែលគាំទ្រដោយរថក្រោះជាច្រើនគ្រឿងបានសម្រុកចូលស្រដូចទឹកបាក់ទំនប់មកលើប្រទេសវៀតណាមតាមចំណុចព្រំដែនម្ភៃប្រាំមួយកន្លែងខុសៗគ្នា ។ ចំណុច

សំខាន់បំផុតនៃការវាយលុកបានប្រមូលផ្តុំយ៉ាងឆាប់រហ័សមកលើផ្លូវចំនួនប្រាំ ដែលនាំឆ្ពោះទៅរកធានីរបស់ខេត្តផ្សេងៗដោយបោសសម្អាតអ្វីៗទាំងអស់នៅតាមតំបន់ទាំងនោះ ដើម្បីបំផ្លាញប៉ុស្តិ៍ជួរមុខរបស់វៀតណាម ។ តាមយុទ្ធវិធីដ៏ល្បីល្បាញមួយគឺ «ការឲ្យកងទ័ពសម្រុកចូលទាំងហ្វូង» ដែលកងទ័ពប្រជាជនជាតិចិន ធ្លាប់បានប្រើមកហើយក្នុងសង្គ្រាមនៅកូរ៉េ កងទ័ពរាប់ពាន់នាក់បានប្រើងប្រែងកម្ចាត់កងឈ្លប និងឆ្មាំព្រំដែនរបស់វៀតណាមឲ្យខ្ចាតចេញពីជម្រកនានាយ៉ាងខ្លាំងក្លាបំផុត ។ យុទ្ធវិធីនេះ គឺជាបរាជ័យកែលែងកើតមួយដែលក្រុងប៉េកាំងបានទទួលស្គាល់ពីរឿងនេះនៅពេលក្រោយមកទៀត ។ ពួកចិនធ្លាប់គិតថាគ្មានអន្ទាក់ដែលរៀបចំដាក់ដោយវៀតណាម និងគ្មានផ្លូវខ្វាត់ខ្វែងធ្វើឲ្យវង្វេងក្នុងរូងដីកលុងក្រោមដីនិងលេណដ្ឋានធំៗ ដែលពួកគេបានជីកនៅតាមតំបន់ព្រំដែនឡើយ ។ បីថ្ងៃដំបូងក្នុងការវាយប្រយុទ្ធបានធ្វើឲ្យកងទ័ពចិនស្លាប់យ៉ាងវេត្តាល ៈ នៅពេលធ្វើការវាយសម្រុកទីតាំងនានា ទាហានរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយសារការ បាញ់រះពីកាំភ្លើងយន្ត ជាន់គ្រាប់មីន ឬត្រូវបាត់បង់អវៈយវៈដោយសារអន្ទាក់គ្រាប់កាំភ្លើងធំរបស់ពួកវៀតណាម ។

ដោយតែងតាំងឧត្តមសេនីយ៍ យ៉ាង ដេហ្ស៊ី ឲ្យធ្វើជាអ្នកដឹកនាំកងទ័ពលុកលុយជំនួសឧត្តមសេនីយ៍ ស៊ូស៊ីយូ ក្រុងប៉េកាំងបាននិយាយសារភាពពីបរាជ័យរបស់ខ្លួនដោយរបៀបមិនច្បាស់លាស់ ។ យ៉ាង ដេហ្ស៊ី ដែលមានវ័យនៅក្មេងនៅឡើយត្រូវបានឲ្យឈ្មោះក្រៅថា ៈ «ឧត្តមសេនីយ៍ ច្បាំងមិនចេះចាញ់»តាំងពីគាត់មានតួនាទីក្នុងសង្គ្រាមនៅកូរ៉េម្ល៉េះ ។ គាត់បានផ្តើមធ្វើការផ្លាស់ប្តូររបៀបប្រយុទ្ធមួយជាបន្ទាន់ និងដាក់ចេញបទបញ្ជាឲ្យធ្វើការវាយប្រហារតាមរបៀបជ្រើសរើសមួយ ដោយមានការគាំទ្រពីកងភ្លើងធំ និងហ្វូងរថក្រោះផង ។ ក្នុងរវាងដប់ថ្ងៃ កងទ័ពរំដោះប្រជាជនបានរុលទៅមុខយឺតៗដែលនាំមុខដោយកងរថក្រោះរបស់ខ្លួនរហូតដល់ជម្រៅសាមសិបទៅសែសិបគីឡូម៉ែត្រពីព្រំដែន ។ បន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ កងទ័ពរបស់ចិន បានសម្រេចជោគជ័យវាយកាន់កាប់ធានីរបស់ខេត្តចំនួនបួនគឺ ឡាយចូវ, ឡាវកៃ, ហាយ៉ាង និងកាវបាង ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៩ បន្ទាប់ពីការចាត់ចែងបាញ់កាំភ្លើងធំយ៉ាងសម្បើម ការវាយប្រហារទម្លុះចូលដោយហ្វូងរថក្រោះបានជ្រៀតចូលដល់ ឡាងសុង ជាធានីខេត្តចុងក្រោយនៅតំបន់ព្រំដែនដែលធ្លាក់ក្នុងកណ្តាប់ដៃពួកចិន ។ ប្រតិបត្តិការទាំងនេះបានបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនជាងគេក្នុងបណ្តាការច្បាំងគ្នាទាំងអស់ ។ ទីក្រុងដែលកសាងដោយពួកបារាំងនេះមានទំនងជាត្រូវធ្វើឲ្យធូរស្រាក ។ ប៉ុន្តែ បន្ទាប់ពីបានកាន់កាប់ទួលភ្នំទាំងឡាយ កងទ័ពចិនត្រូវប្រយុទ្ធគ្នាពីផ្ទះមួយទៅផ្ទះមួយតាមលេណដ្ឋានធំៗថែមទៀត ដើម្បីកម្ចាត់អ្នកនៅការពារ ។ ទីបំផុត នៅវេលាម៉ោង៧ៈ៤០នាទី ថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៩ ពួកចិនបានដណ្តើមកាន់កាប់ ឡាងសុង ដូចជាបើកមាត់ច្រកឆ្ពោះទៅកាន់ដែនដីសណ្តទន្លេក្រហមដែរ ។ ទីក្រុងរបស់ខេត្តឡាងសុង គ្រាន់តែជាជនបទមួយដែលរងការហិនហោចប៉ុណ្ណោះនិងមានដេរដាសទៅដោយសាកសពសមមិត្តថ្មីៗ ហើយពេលនេះជាសត្រូវនឹងគ្នាវិញ ។ ពីរ-បីម៉ោងក្រោយមក ក្រុងប៉េកាំងបានប្រកាសជាសាធារណៈថា កងទ័ពរបស់ខ្លួនបានទៅដល់គោលដៅរបស់គេ

ហើយ ។ នៅថ្ងៃដដែលនោះ កងទ័ពរបស់ចិនបានចាប់ផ្ដើមដកថយទៅកាន់ទឹកដីចិនវិញ ។

"សង្គ្រាមតាមច្បាប់ក្បួន"រយៈពេលដប់ប្រាំមួយថ្ងៃនេះ បានបំផ្លាញព្រំដែនចិន-វៀតណាមឲ្យខូចខាតយ៉ាងដំណំ ។ ពួកចិនបានសម្រេចជោគជ័យក្នុងការបង្ហិនបង្ហោចតំបន់មួយដែលរួចផុតពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ ដោយខ្លាចធ្វើឲ្យប៉ះពាល់ដល់ទឹកដីរបស់ចិន ពួកអាមេរិកាំងពុំបានទម្លាក់គ្រាប់បែកលើទីក្រុងនានាតាមតំបន់ព្រំដែនដែលនៅគង់វង្សជាមួយនឹងទីក្រុងហាណូយ ដែលអគារផ្សេងៗធ្វើពីឥដ្ឋនៅមិនទាន់ខូចខាតនៅឡើយ ។ ប៉ុន្តែ កងទ័ពរបស់ចិនបានកម្ទេចរាបដល់ដីគ្មានសល់នៅតាមផ្លូវធ្វើដំណើររបស់គេ ។ ទីក្រុងឡាងសុងទទួលរងការវិនាសអន្តរាយក្នុងពេលមានការប្រយុទ្ធគ្នា ប៉ុន្តែភាគច្រើននៃទីក្រុងផ្សេងៗទៀតដែលកាន់កាប់ដោយពួកចិន ក៏ជាកម្មវត្ថុនៃការបំផ្លិចបំផ្លាញមួយដោយចេតនាយ៉ាងជាក់ច្បាស់ ។ ប៉ុន្មានខែបន្ទាប់ពីការឈ្លានពាន ខ្ញុំ(អ្នកនិពន្ធ)បានធ្វើដំណើរទៅ កាវបាង ហើយស្រឡាំងកាំងដោយសង្កេតឃើញថា ក្រុមទាហានវិស្វកម្មរបស់ចិនបានដាក់ថ្នាស៊ីកបំផ្លាញអ្វីៗដែលមិនទាន់ខូចខាតនៅឡើយ : គ្រឹះស្ថាននានារបស់ទីក្រុងការិយាល័យប្រៃសណីយ៍ សាលារៀន និងមន្ទីរពេទ្យ ។ ភ្នំតូចៗដែលកាលពីដើម ហូជីមិញ ធ្លាប់រៀបចំការបដិវត្តន៍ជាមួយបណ្ដាសមមិត្តចិនរបស់គាត់ សុទ្ធតែជាសាក្សីនៅស្ងៀមស្ងាត់ចំពោះការបំផ្លិចបំផ្លាញនេះ ។ បង្កង់, ដែរណែងដែកថែបនៃផ្សារកណ្ដាលបានលេចឡើងយ៉ាងច្បាស់ដូចជា គ្រោងឆ្អឹងមួយងើបទៅរកមេឃដ៏ល្ហល្ហេវនៅពេលដែលដំបូលប្រក់ក្បឿងរបស់វាត្រូវបើងបាត់អស់ដោយការផ្ទុះ ។ ប្រដាប់រម្ងាប់មេរោគពៀចប៉ិច, បំណែកនៃដបអុកស៊ីសែនជាច្រើនដុំ និងដុំមូលតូចៗនៃដើងគ្រែ ដែលលេចចេញពីកម្ទេចបាក់បែកអាចឲ្យដឹងថា ទីនេះជាមន្ទីរពេទ្យមួយ ។ មិនឆ្ងាយប៉ុន្មានពីទីក្រុង ស្ពានដែកថែបមួយបានបាក់ធ្លាក់ទៅក្នុងទឹកមើលទៅហាក់ដូចជាលុតជង្គង់ ។ គ្មានសញ្ញាណាមួយបញ្ជាក់ថា មានការប្រយុទ្ធគ្នាប្រព្រឹត្តទៅនៅក្នុងទីក្រុងឡើយ ។ វរសេនីយ៍ឯកវៀតណាមម្នាក់ បានធ្វើការចាប់អារម្មណ៍បញ្ជាក់ប្រាប់ខ្ញុំថា ការកម្ទេចបំផ្លាញទីក្រុងកាវបាង បានកើតមានឡើងនៅថ្ងៃទី១០ ខែមីនា គឺប្រាំថ្ងៃក្រោយការប្រកាសដកកងទ័ពរបស់ចិនជាសាធារណៈ ។ ហេតុដែលពួកចិនពុំបានធ្វើការបំផ្លិចបំផ្លាញតាំងពីដំណាក់កាលដំបូងនៃការឈ្លានពាន គឺពីព្រោះចិនចង់ប្រើប្រាស់ទឹកដីដែលកាន់កាប់ដើម្បីចរចាគ្នាពីការដកកងទ័ពវៀតណាមចេញពី កម្ពុជា ។

## ការមិចភ្នែករបស់ក្រុងវ៉ាស៊ីនតោន

តើក្រុងប៉េកាំងត្រូវការអ្វីប្រាកដក្នុងការដែលខ្លួនចូលលុកលុយប្រទេសវៀតណាម? វាទំនងថា គោលដៅផ្សេងៗបានប្រែប្រួលតាំងពីខែកក្កដា ឆ្នាំ១៩៧៨ ជាកាលបរិច្ឆេទដែលការិយាល័យនយោបាយបានគ្រោងគិតជាលើកដំបូងដើម្បី"ផ្ដល់មេរៀនមួយឲ្យវៀតណាម" ។ ជាសំខាន់ ប្រទេសចិននៅតែមានបំណងដាក់ទណ្ឌកម្ម "សម្ព័ន្ធមិត្តមួយដែលរមិលគុណ"និង"កូនសិស្សម្នាក់ដែលរឹងរូស"ជានិច្ច ។ ដោយវាយប្រហារយ៉ាងចាស់ដៃ

ប្រទេសចិនមានបំណងបង្ខិតបង្ខំប្រទេសវៀតណាមឲ្យពិនិត្យជម្រើសនយោបាយរបស់ខ្លួនឡើងវិញ ប៉ុន្តែការវិវត្តនៃស្ថានការណ៍អន្តរជាតិបានផ្តល់ឲ្យវៀតណាមមានហេតុផលផ្សេងៗ ក្នុងការធ្វើអន្តរាគមន៍បន្ថែមទៀត ។ សន្ធិសញ្ញាមិត្តភាពវៀតណាម-សូវៀត និងការចូលលុកលុយប្រទេសកម្ពុជាគឺជាការបង្កហេតុចំពោះភាពខ្លង់ខ្លស់ជាងគេបំផុតប្រចាំតំបន់របស់ប្រទេសចិន ។ ការដួលរលំនៃរបប ប៉ុល ពត បានធ្វើឲ្យចិនបាក់មុខបាក់មាត់ហើយក្រុងមូស្គូគំរាមឡោមព័ទ្ធប្រទេសខ្លួនថែមទៀត ។ ប៉ុន្តែ ប្រទេសចិនបានតបតទៅវិញដោយកម្លាំងទ័ព ។ ការព្រលែងកងទ័ពចំនួនម្ភៃប្រាំម៉ឺននាក់ឲ្យធ្វើការវាយលុកប្រទេសវៀតណាមដើម្បី“កម្ទេចភាពមិនចេះចាញ់របស់វៀតណាម”ដូច តេង អះអាង គឺមិនមែនសំដៅត្រឹមតែបំបាក់មុខវៀតណាមនិងប្រគល់ភាពគួរឲ្យជឿជាក់មកប្រទេសចិនវិញប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅបង្ខំឲ្យក្រុងហាណូយឲ្យដកកងឯកភាពទ័ពរបស់ខ្លួនខ្លះៗចេញពីកម្ពុជាផងដែរ ។ ចិនត្រូវការបង្ហាញឲ្យឃើញដូចគ្នាថា ៖ ប្រតិបត្តិការនេះជាមេរៀនមួយសម្រាប់ប្រទេសលោកខាងលិចទាំងអស់ដែលត្រូវញាំងឲ្យលែងធ្វើអ្វីកើតនៅចំពោះមុខនិន្នាការផ្សងព្រេងនិយមរបស់សូវៀត ។ តេង បានប្រកាសប្រាប់អ្នកកាសែតនៅពេលដែលកងទ័ពរបស់គាត់កំពុងវាយប្រយុទ្ធនៅប្រទេសវៀតណាមថា ៖ “យើងមិនអាចបណ្តោយឲ្យពួកគុយបា ធ្វើអំពើអាក្រក់នៅអាហ្វ្រិក មជ្ឈិមបូព៌ា និងនៅទីដទៃទៀតដោយគ្មានប្រទះនឹងការប្រឆាំងតទល់ឡើយ ។ ម្យ៉ាងទៀត យើងក៏មិនអាចបណ្តោយឲ្យពួកគុយបាទិសខាងកើត(វៀតណាម) ធ្វើអំពីអាក្រក់នៅប្រទេសឡាវ កម្ពុជា ថែមទាំងនៅតាមព្រំដែនរបស់ចិនទៀតផង” ។ “ប្រទេសខ្លះក្នុងពិភពលោកភ័យខ្លាចក្រែងធ្វើឲ្យពួកវៀតណាមអន់ចិត្តទោះបីជាប្រទេសទាំងនោះអាចធ្វើបានក៏ដោយ ។ ពួកគេនឹងមិនហ៊ានល្បងប្រឆាំងនឹងពួកវៀតណាមសោះឡើយ”[៧៤] ។

ទិនានុប្បវត្តិកងទ័ពរំដោះបានសរសេររឹតតែចំៗជាងនេះទៅទៀត ៖ “ការវាយបកទៅវិញដើម្បីការពារខ្លួនគឺជាឱសថដែលជួយទ្រទ្រង់កិត្តិយសមួយរបស់អ្នកទាំងឡាយដែលឈឺចាប់នឹង“ជំងឺស្អប់សូវៀត” ។ ជ័យជម្នះជាការលើកទឹកចិត្តដ៏ថ្លៃថ្លាមួយសម្រាប់ប្រជាជននៅអាស៊ីអាគ្នេយ៍ និងសម្រាប់ពិភពលោកទាំងមូលក្នុងការប្រយុទ្ធរបស់ខ្លួនប្រឆាំងនឹងអនុត្តរភាពនិយម”[៧៥] ។

បើសិននយោបាយធ្វើឲ្យមានការធូរស្រាលដែលអួតអាងហួសហេតុដោយលោកខាងលិចធ្វើឲ្យ តេង មានកំហឹងក្រេវក្រោធមួយបែបនោះ គឺថានយោបាយនោះបង្កជាការមិនទទួលស្គាល់មួយចំពោះមាគ៌ានយោបាយរឹងត្អឹងរបស់ចិន ។ ដោយសារលោក ប្រឺហ្សីនស្គី សហរដ្ឋអាមេរិកបានលើកម្រាមដៃពីរយល់ព្រមជាចំហចំពោះសង្គ្រាមនេះ ហើយគ្មានប្រទេសលោកខាងលិចណាមួយផ្សេងទៀតធ្វើតាមទេ ។ ដោយចាត់ទុកការលុកលុយប្រទេសកម្ពុជាជា“ការគំរាមប្រឆាំងនឹងសន្តិភាព និងស្ថិរភាពតំបន់ដែលអាចជាមូលហេតុនៃជម្លោះមួយរឹតតែធំជាងមុន” ក្រុងវ៉ាស៊ីនតោនបាននិយាយដោះសាពីសកម្មភាពរបស់ចិនដោយពាក្យសម្តីមិនច្បាស់លាស់សោះ ។ ប្រធានាធិបតី ខាធ័រ បានប្រកាសថា ៖ “ក្នុងបណ្តាសប្តាហ៍ថ្មីៗនេះ យើងបានដឹងពីការលុកលុយប្រទេសកម្ពុជា

ដោយប្រទេសវៀតណាម និងការជ្រៀតចូលរបស់ចិននៅតាមព្រំដែនរបស់ប្រទេសវៀតណាម» ។ ដោយហេតុនេះ អ្នកនាំពាក្យរបស់សហរដ្ឋអាមេរិកបានស្នើឲ្យមានការដកនូវកងទ័ពរបស់វៀតណាមពីប្រទេសកម្ពុជា និងកងទ័ពរបស់ចិននៅប្រទេសវៀតណាមជាបន្ទាន់ ។ នៅជំនាន់នោះ ប្រទេសខ្លះបានសន្និដ្ឋានពីរឿងនេះថា ក្រុងវ៉ាស៊ីនតោននឹងមិនជំទាស់ពីការរក្សាកងទ័ពរបស់ចិននៅប្រទេសវៀតណាមទេ ល្អិកណាវៀតណាមនៅតែរក្សាទ័ពពីប្រទេសកម្ពុជានោះ[៧៦] ។

រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក វ៉ាន់ស៍ ប្រាថ្នាលុបចោលទស្សនកិច្ចរបស់រដ្ឋមន្ត្រីរតនាគារ ម៉ៃឃើល ប៊្លូម៉េនថល ដែលជាសញ្ញានៃការតវ៉ាប្រឆាំងនឹងការវាយប្រហាររបស់ចិន ។ ប្រ៊ីហ្សីនស្គី បានជំទាស់នឹងរឿងនេះយ៉ាងដាច់ខាត ។ ប្រ៊ីហ្សីនស្គី បានអះអាងថា «ដោយសារភាពម៉ឺងម៉ាត់របស់ ខាធ័រ និងដោយមិននិយាយឲ្យចំគឺសម្ដីរបស់គាត់ផ្ទាល់ ទំនាក់ទំនងថ្មីរវាងចិន-អាមេរិកាំង បានទទួលជោគជ័យតាំងតែពីចាប់ផ្ដើមដំបូង»[៧៧] ។

សង្គ្រាមចិន-វៀតណាម ហាក់ដូចជាបានឆ្លៀតទាញយកគុណប្រយោជន៍ពីសហប្រតិបត្តិការរវាងក្រុងប៉េកាំង និងក្រុងវ៉ាស៊ីនតោនខាងវិស័យសន្តិសុខដែលកើតឡើងពីដំណើររបស់ ប្រ៊ីហ្សីនស្គី នៅខែឧសភា ឆ្នាំ ១៩៧៨ ។ ជាច្រើនឆ្នាំក្រោយមក អ្នកទទួលខុសត្រូវអាមេរិកាំងជាច្រើននាក់ បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ) ជាឯកជននូវភាគល្អិតល្អន់ខ្លះៗ ស្ដីអំពីសហប្រតិបត្តិការនេះ ។ ក្នុងសប្ដាហ៍ដំបូងនៃការប្រយុទ្ធគ្នា ដោយសារមានដុំពពកយ៉ាងក្រាស់គ្របដណ្ដប់ពីលើតំបន់ព្រំប្រទល់ចិន-វៀតណាមនោះ បានរារាំងមិនឲ្យផ្កាយរណបចារកម្មរបស់អាមេរិកាំងឃ្លាំមើលការដាក់ពង្រាយកងទ័ពរបស់វៀតណាមបានឡើយ ប៉ុន្តែ ក្រុងវ៉ាស៊ីនតោនបានជួយប្រទេសចិន ដោយផ្ដល់ជាសម្ងាត់នូវព័ត៌មានស្ដីពីការដាក់ពង្រាយកងទ័ពរបស់សូវៀត នៅតាមបណ្ដោយព្រំដែនចិនដែលទទួលបានពីផ្កាយរណបដែរ ហើយបានប្រាប់ឲ្យដឹងពីការប្រកាសដាក់កងទ័ពសូវៀតនៅតំបន់ស៊ីបេរីឲ្យស្ថិតក្នុងភាពអាសន្នផង ក្រោយពីការចូលលុកលុយប្រទេសវៀតណាម[៧៨] ។

## មេរៀនមួយសម្រាប់ពិភពលោកទាំងមូល

លក្ខណៈទូលំទូលាយនៃការវាយលុករបស់ចិន ការខូចខាតនិងការបំផ្លិចបំផ្លាញដែលចិនដាក់ទោសទៅលើប្រទេសវៀតណាមនិងការមិនឃើញមានការតបតរបស់សូវៀតបានបន្ថែមភាពគួរឲ្យទុកចិត្តរបស់ប្រទេសចិនយ៉ាងប្រាកដ ។ លើសពីការប្រើមធ្យោបាយគំរាមខ្លះៗនៅតាមបណ្ដោយព្រំដែនចិន ពួកសូវៀតគិតតែចង់បង្កើនល្បឿនក្នុងការប្រគល់សម្ភារសឹកឲ្យប្រទេសវៀតណាមប៉ុណ្ណោះ ៖ តាមការឃោសនារបស់ចិន ប្រការនេះមានន័យស្មើនឹងការវាយតម្លៃថាខ្លួនជា«ខ្លាឃ្មុំក្រដាសនៅអក្សោសានខាងជើង»ដូច្នោះ ។ ប្រទេសចិនពេញចិត្តនឹងជ័យជម្នះរបស់ខ្លួនណាស់ ប៉ុន្តែ ទោះបីយ៉ាងណាក៏មានបញ្ហាខ្លះនៅមិនទាន់ឲ្យពេញចិត្តទាំងស្រុងដែរ នៅពេលដែលពួកចិនប្រកាសនូវការចាកចេញរបស់ខ្លួន កងទ័ពរៀបរយរបស់វៀតណាមចំនួនបីកងពលធំកំពុងធ្វើដំណើរ

សំដៅមក ឡាំងសុង ហើយក្រុងមូស្គូទើបនឹងចេញការព្រមានយ៉ាងម៉ឺងម៉ាត់មួយដោយគាបសង្កត់ឲ្យក្រុងប៉េកាំង បញ្ចប់ការឈ្លានពានរបស់ខ្លួន"មុនវាមិនទាន់ហួសពេល" ។ បើគិតឲ្យសព្វទៅ ដូចអ្នកជំនាញការស៊ើទ្ធចិនម្នាក់បាន សង្ខេបសេចក្ដីយ៉ាងត្រឹមត្រូវថា ជោគជ័យដ៏ធំរបស់ក្រុងប៉េកាំង គឺបានត្រឹមតែបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ យោធា ផ្លូវគមនាគមន៍ និងសម្ភារបរិក្ខារសង្គមនៅវៀតណាមខាងជើងឲ្យខ្ទេចខ្ទីប៉ុណ្ណោះ[៧៩] ។

ឧបសគ្គផ្សេងៗខាងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសមានសភាពកាន់តែដុនដាបថែមទៀត ហើយវៀតណាម ត្រូវតែការពារព្រំដែនខាងជើងរបស់ខ្លួន ប្រឆាំងទល់នឹងការវាយប្រហាររបស់ពួកចិននៅថ្ងៃមុខទៀត ។ ការ ប្រឆាំងនឹងក្រុងប៉េកាំងមុខជាមានតម្លៃកាន់តែថ្លៃជាងកាលពីមុនទៅទៀត ។ នៅត្រង់នេះឯង គឺជាផលចំណេញ សរុបដែលពួកចិនទទួលបានពីប្រតិបត្តិការរបស់ខ្លួនមកវិញនោះ ។ វៀតណាមនៅត្រូវចំណាយទាំងជីវិតមនុស្ស និងយោធាជាច្រើននាក់ថែមទៀត តាមការវាយតម្លៃរបស់ចិនថា មានចំនួន២០.០០០នាក់[៨០] ។

ទោះជាប្រទេសចិនសន្និដ្ឋានថា ការស្លាប់របស់មនុស្សមួយចំនួនធំនិងការបំផ្លិចបំផ្លាញផ្សេងៗនឹងធ្វើឲ្យ វៀតណាម"អន់ចង់"ក៏ដោយ ក៏ប្រទេសចិនត្រូវធ្វើឲ្យតូចចិត្តយ៉ាងខ្លាំងដែរ ៖ នៅមុនការដកថយកងទ័ពរបស់ចិន ក្រុងហាណូយបានសម្រេចធ្វើកំណែនជាទូទៅមួយ ដោយបញ្ញត្តិរៀបចំប្រជាជាតិទាំងមូលឲ្យមានទម្រង់ត្រឹមត្រូវ មួយដើម្បីធ្វើការវាយប្រយុទ្ធ ។ ក្រុងហាណូយបានប្រកាសយ៉ាងក្រអឺតថា "នេះគឺជាការចាប់ផ្ដើមសង្គ្រាមតស៊ូ មួយប្រឆាំងនឹងពួកឈ្លានពានរបស់ប្រទេសចិនប្រតិកិរិយា" ។

ដោយជាក់ស្ដែង ប្រទេសវៀតណាមពុំបានទទួលយកមេរៀនរបស់ចិនទេ ហើយក៏ពុំមានអ្វីផ្លាស់ប្ដូរដែរ នៅប្រទេសកម្ពុជា ។ ផាំ វ៉ាន់ដុង បានបន្តទស្សនកិច្ចរបស់គាត់នៅក្រុងភ្នំពេញ ហាក់ដូចជាគ្មានរឿងអ្វីកើតឡើង ទាល់តែសោះ ។ គាត់បានចុះហត្ថលេខាជាមួយ ហេង សំរិន នូវសន្ធិសញ្ញាសន្តិភាពនិងសហប្រតិបត្តិការមួយ សម្រាប់ថិរវេលាម្ភៃប្រាំឆ្នាំ ដែលជាភស្តុតាងបង្ហាញឲ្យឃើញពីវត្តមានរបស់កងទ័ពវៀតណាមជាច្រើនកងពលធំ នៅប្រទេសកម្ពុជាពិតមែន ។ ជាជាងដកទ័ពចេញពីសមរភូមិកម្ពុជា ក្រុងហាណូយដែលមានការវៃឆ្លាតបាន បណ្ដោយឲ្យកងសេនាជននិងកងទ័ពតំបន់ទប់ទល់នឹងការវាយលុករបស់ចិន ហើយថែមទាំងមិនប្រើកងទ័ពរៀបរយ ជាច្រើនកងពលធំផ្សេងទៀតផង ។ វៀតណាមបានបាត់បង់ប្រជាជនស៊ីវិលនិងយោធាប្រហែល១០.០០០ នាក់[៨១] គឺពិតជាសន្ធឹកសន្ធាប់មែន ប៉ុន្តែដោយមិនព្រមឲ្យកងទ័ពរៀបរយចូលប្រយុទ្ធ ក៏ក្រុងហាណូយមិនទុកឲ្យ ក្រុងប៉េកាំងមានសំណាងណាមួយដណ្ដើមបានជ័យជម្នះជាស្ថាពរដែរ* ។

ប្រហែលជាពួកចិនផ្ទាល់ខ្លួនឯង ដែលដកស្រង់បទពិសោធន៍ពីការធ្វើប្រតិបត្តិការសឹករបស់ខ្លួន ។ តាម របាយការណ៍សម្ងាត់មួយដែលចេញពីក្រុងប៉េកាំងបានឲ្យដឹងថា ការខូចខាតរបស់ចិននិងវៀតណាមមានចំនួន "ស្មើគ្នាច្រើនគួរសម" ហើយកងទ័ពរំដោះប្រជាជនមិនចេះ"ដឹកនាំធ្វើសង្គ្រាមទំនើបមួយ"ឡើយ ។ ដោយឃើញ ការខូចខាតយ៉ាងធ្ងន់ធ្ងរដែលខ្លួនបានរងទទួលនិងបរាជ័យក្នុងការប្រើប្រាស់អាវុធ និងយុទ្ធវិធីដែលប្រើប្រាស់

ប្រទេសចិនបានសម្រេចថា ត្រូវតែធ្វើទំនើបនីយកម្មកងទ័ពរបស់ខ្លួនដោយឆាប់រហ័សបំផុត[៨៧] ។

ទោះជាយ៉ាងណាក៏ដោយ ក៏សង្គ្រាមពុំដែលមានអ្នកឈ្នះដែរ ។ នៅពេលដែលខ្ញុំធ្វើដំណើរទៅការវបាង នៅខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំឃើញប្រជាជនម្នាក់ដែលក្រីក្ររហេមរហាមកំពុងសាកល្បងធ្វើដុះលើគំនរបាក់បែកឡើងវិញទាំងទឹកមុខក្រៀមក្រំជាមួយបំណែកគេហដ្ឋានដែលរកបានពីក្នុងគំនរបាក់បែកជាច្រើន ។ នៅខែបន្ទាប់ ខ្ញុំបានធ្វើដំណើរឆ្លងកាត់តាមខេត្តពីររបស់ចិនគឺ ហ្គាងស៊ី និងយុនណាន ។ ខ្ញុំត្រូវធ្វើឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយចំនួនទាហានពិការរបស់កងទ័ពរំដោះប្រជាជនមានចំនួនមួយមិនគួរឲ្យជឿ ដែលកំពុងដើរខ្ញើចៗលីឈើច្រត់របស់ខ្លួន និងការព្រងើយកន្តើយទាំងស្រុងរបស់ប្រជាជន ទោះបីជាមានតាំងពិព័រណ៍នៅ គុនមីង ស្ដីពីជោគជ័យនៃ “ការវាយបកការពារខ្លួនត្រឹមត្រូវតាមច្បាប់”ក៏ដោយ ។ ខ្ញុំបានរួមដំណើរជាមួយអ្នកទទួលខុសត្រូវចិនម្នាក់ទៅទស្សនាទស្សនីយភាពចម្រៀងនិងរបាំមួយ ដែលសម្ដែងដោយជនជាតិភាគតិចផ្សេងៗរបស់ខេត្ត ហ្គាងស៊ី ។ នៅទីនោះខ្ញុំមានឱកាសវាស់ស្ទង់ពីប្រជាប្រិយភាពនៃសង្គ្រាមតាមច្បាប់ក្បួននេះបានប្រសើរបំផុត ។ សាធារណជនយ៉ាងច្រើនបានទះដៃលាន់ឮកងរំពងនៅពេលចប់ការប្រគំភ្លេងមួយបទឬរបាំមួយឈុត និងការលេងពន្លឺភ្លើងនិងភ្លើងពណ៌ ។ តមកទៀត គេចាប់ផ្ដើមលេងឆាកមួយក្រោមចំណងជើងថា វីរភាពរបស់កងទ័ពរំដោះប្រជាជនដាក់ទោសពួកខ្មាំងវៀតណាម ។ នៅលើឆាក គេឃើញមនុស្សពីរនាក់ បង្ហាញរូបរាងឡើងក្នុងសម្លៀកបំពាក់ពណ៌បៃតងនិងពាក់មួកបែបអាណានិគមវៀតណាម ។ ពួកគេស្ទួមសុំស្បៀងអាហារ, វាយប្រតប់គ្នាដណ្ដើមសំណល់ម្ហូបអាហារ, ញើសសំបោរ និងយកដៃមកដូតខោរបស់ខ្លួន ។ គេធ្លាប់និយាយពីទាហានអាមេរិកាំង ពីរនាក់ក្នុងល្ខោនបដិវត្តន៍មួយកាលសម័យបដិវត្តន៍វប្បធម៌ ។ តមក វីរបុរសកងទ័ពរំដោះប្រជាជនម្នាក់ស្លៀកពាក់សទាំងអស់បានហក់ចូលមកក្នុងឆាកភ្លាម ។ ដោយសម្ដែង របៀបលោតផ្លោះក្រឡាប់ផ្កាប់ផ្ងារលាយចម្រុះទៅដោយក្បាច់របាំនិងហ្ស៊ូយដូ (Judo) អ្នកស្លៀកពាក់សនេះ បានកម្ទេចពួកខ្មាំងវៀតណាមតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ។ នៅពេលដែលវាំងននធ្លាក់ចុះ មានភាពស្ងប់ស្ងាត់គួរឲ្យរំខានមួយនៅក្នុងចំណោមអ្នកមើលទាំងអស់ ។ អ្នកមកជាមួយខ្ញុំសម្លឹងមើលពិតានរោងល្ខោនគ្មានដាក់ភ្នែក ។ គ្មាននរណាម្នាក់ដឹងថា មានមឈូសប៉ុន្មានពាន់ដែលដឹកមកពីវៀតណាមជាងប្រជាជននៅណានីងទេ ។

# ជំពូកទី១១
# ឥណ្ឌូចិន : នៅពេលណាទើបមានសន្តិភាព?

*អ៊ីៗបានចាប់ផ្តើមនៅល្ងាចថ្ងៃសៅរ៍ទី១៣ ខែមករា ឆ្នាំ១៩៧៩ ដោយការចាប់រលាក់ដៃជាមិត្តភាពមួយរបៀបលាក់លៀមជាមួយភ្នាក់ងារម្នាក់នៃក្រុមស៊ើបការណ៍សម្ងាត់អាមេរិកាំង ។ បន្ទាប់ពីចប់ការប្រជុំចុងក្រោយរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ សម្តេច ព្រះនរោត្តម សីហនុ បានយាងត្រឡប់មកកាន់សណ្ឋាគារវ៉ាល់ដ័រអាស់ថូរីយ៉ា នៅក្រុងញូវយ៉កវិញរួមជាមួយនឹងខ្មែរក្រហមជាច្រើននាក់ក្នុងសម្លៀកបំពាក់ពណ៌ក្រមៅ និងភ្នាក់ងារសម្ងាត់មួយចំនួនតូច ។ កម្រមានអ្នកណាសម្គាល់ឃើញព្រះអាការៈតឹងតែងរបស់សម្តេច សីហនុ ណាស់ ដែលបំភាន់អ្នកដទៃដោយសារព្រះសិតាការដែលមិនប្រែប្រួល, ការគួរសមរបៀបដាក់ព្រះកាយ និងព្រះរាជកាយវិការលើកព្រះហស្តបន្តិចរបស់ព្រះអង្គ ។ ជណ្តើរយន្តរបស់សណ្ឋាគារដែលមានមនុស្សចូលពេញបានលាន់សំឡេងឮប្រឹបៗ សម្តេច សីហនុ បានឆ្លៀតឱកាសនេះចាប់កញ្ឆក់ដៃភ្នាក់ងារសម្ងាត់ម្នាក់យ៉ាងខ្លាំងក្នុងចំណោមភ្នាក់ងារសម្ងាត់ជាច្រើននាក់ ។ ដោយនឹកស្មានថា សម្តេចចង់បង្ខំគាត់ឲ្យទទួលយកប្រាក់ភ្នាក់ងារនេះបានចាប់ផ្តើមរអ៊ូរទាំរបៀបតវ៉ាមួយ ប៉ុន្តែនៅចំពោះមុខការសម្លឹងមើលរបៀបអង្វររបស់សម្តេច សីហនុ និងសញ្ញាងក់ព្រះកេសរបស់ព្រះអង្គ គាត់ក៏យក“កូនសំបុត្រ”មួយ ដាក់ចូលក្នុងហោប៉ៅទាំងញញើតញញើម... ។*

*តាំងពីដំណើរយាងទៅដល់ទីក្រុងញូវយ៉កនៅថ្ងៃទី៩ ខែមករា សម្តេច សីហនុ បានប្រើពេលវេលាទាំងអស់របស់ព្រះអង្គក្នុងការចូលរួមសន្និបាត សន្និសីទកាសែត ការជួបសម្ភាសន៍និងការថ្លែងសុន្ទរកថាផ្សេងៗ ហើយព្រះអង្គទ្រង់ផ្ទំបានតែបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយខ្វះខាតព័ត៌មានមកពីប្រភពដើមស្តីពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយនានាបានរំខានព្រះអង្គដោយការចោទសួរជាសំណួរផ្សេងៗស្តីពី“ការសម្លាប់រង្គាល”នៅកម្ពុជា និងការស្តីបន្ទោសពីរឿងដែលព្រះអង្គព្រមទទួលធ្វើជាតំណាងរបបមួយដែលប្រឡាក់ទៅដោយឈាម ។ ព្រះអង្គបានបណ្តោយព្រះកាយទៅតាមព្រះទ័យពិរោធរបស់ព្រះអង្គប្រឆាំងនឹងអ្នកលុកលុយវៀតណាម ប៉ុន្តែបានត្រៀមពាក្យពេចន៍ដែលធ្វើឲ្យឈឺចាប់បំផុតដោយឡែក សម្រាប់របបដែលព្រះអង្គសន្មតថាត្រូវការពារ ។ សម្តេចបានប្រកាសប្រាប់អ្នកកាសែតម្នាក់ថា “ប៉ុល ពត ប្រហែលជាអ្នកស្រឡាញ់ជាតិមាតុភូមិម្នាក់ ប៉ុន្តែក៏ជាមនុស្សកំណាចយង់ឃ្នងម្នាក់ដែរ ។ គាត់បានចាត់ទុកប្រជាជនកម្ពុជា ដូចសត្វពាហនៈដែលត្រូវបង្ខំឲ្យធ្វើជាទម្ងន់ដូចសត្វជ្រូកដែលគេយកទៅសម្លាប់នៅទីសត្តឃាតដែរ”[១] ។*

*ដោយមានព្រះរាជបន្ទូលក្នុងសម័យប្រជុំវិសាមញ្ញមួយរបស់ក្រុមប្រឹក្សាសន្តិសុខ សម្តេច សីហនុ បានទទូចសុំដោយព្រះសូរសៀងមួយពោរពេញដោយការរំជួលព្រះទ័យឲ្យសហគមន៍អន្តរជាតិជួយបណ្តេញវៀតណាម*

ចេញពីកម្ពុជា ។ សុន្ទរកថារបស់ព្រះអង្គបានធ្វើឲ្យគេចាប់អារម្មណ៍ខ្លាំង ហើយប្រជាប្រិយភាពរបស់ព្រះអង្គក្នុងបណ្ដាប្រទេសតតិយលោក ល្មមតែធ្វើឲ្យព្រះអង្គទទួលបានសមានចិត្ត និងការគាំទ្រជាទូទៅ ប៉ុន្តែឆ្នោតវេតូរបស់សូវៀតដែលមិនអាចចៀសរួច បានរារាំងការរិះគន់ជាឯកច្ឆ័ន្ទមួយចំពោះប្រទេសវៀតណាម ។ ការស្រឡាញ់ជាតិមាតុភូមិ សេចក្ដីទៀងត្រង់ និងសេចក្ដីក្លាហានរបស់សម្ដេច សីហនុ បានធ្វើ ឲ្យគេភ្លេចគិតពីរបបដែលព្រះអង្គធ្វើជាតំណាងបន្តិចបន្តួចដែរ ។ នៅអង្គការសហប្រជាជាតិ ព្រះអង្គបានជួបមិត្តភក្ដិចាស់ៗមួយចំនួន ហើយបានធ្វើឲ្យព្រះអង្គខ្វល់ខ្វាយព្រះទ័យជាថ្មី ។ ព្រះអង្គឲ្យតម្លៃយ៉ាងសម្បើមចំពោះឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំអង្គការសហប្រជាជាតិ អាន់ឌ្រូយ៉ង់ (Andrew Young) ដែលជាអ្នកការពារសិទ្ធិមនុស្សយ៉ាងខ្លាំងក្លាក្នុងពិភពលោកទាំងមូល ហើយសមានចិត្តនេះគឺមានទៅវិញទៅមក ។ យ៉ង់ សម្គាល់ឃើញថា សម្ដេចជា«គំរូបុគ្គលដ៏អស្ចារ្យមួយអង្គ» ។ តាមភាពខាងក្រៅ ព្រះអង្គសម្របព្រះកាយ ដើម្បីរួចរស់ជីវិតពីទុក្ខលំបាកវេទនាទាំងឡាយ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ព្រះកិត្តិនាមផ្ទាល់របស់ព្រះអង្គឡើយ[៧] ។

យ៉ង់ ពុំដឹងថា ការកោតសរសើររបស់គាត់ចំពោះសម្ដេចនឹងធ្វើឲ្យព្រះអង្គត្រូវស្ថិតនៅក្នុង«ការសោកពិសោធន៍»ពីសំណាក់ខ្មែរក្រហមយ៉ាងឆាប់រហ័សផងទេ ។ នៅថ្ងៃដែលឆ្នោតវេតូរបស់សូវៀតបញ្ចប់សម័យប្រជុំក្រុមប្រឹក្សាសន្តិសុខ សម្ដេច សីហនុ បានប្រកាន់យកការសម្រេចព្រទ័យដ៏ត្រឹមត្រូវមួយស្រេចទៅហើយ ទាក់ទងទៅនឹងអនាគតរបស់ព្រះអង្គជា«អ្នកតំណាងជាន់ខ្ពស់»របស់កម្ពុជាប្រជាធិបតេយ្យ ដោយមិនឲ្យមនុស្សទាំងអស់ដឹងក្រៅអំពីមហេសីរបស់ព្រះអង្គឡើយ ។ សម្រាប់សម្ដេចទ្រង់ជ្រាបច្បាស់ណាស់ ដែលបុត្រជាច្រើនអង្គរបស់ព្រះអង្គត្រូវបាត់ព្រះកាយ ព្រះអនុជថ្លៃ(ឬព្រះរៀមថ្លៃ) និងស្វាមីរបស់អ្នកទាំងនោះ ត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ ការសន្ទនាទាំងឡាយរបស់ព្រះអង្គជាមួយអ្នកការទូត អ្នកកាសែត និងបណ្ដាជនរួមជាតិខ្មែរ បានជួយឲ្យព្រះអង្គជ្រាបកាន់តែច្បាស់ថែមទៀតអំពីលក្ខណៈធំធេងនៃរឿងរ៉ាវដែលកើតមាននៅប្រទេសកម្ពុជា ។ ការគ្មានរំពឹងផ្ទាល់របស់ព្រះអង្គ និងការបរិហាររិះគន់ផ្សេងៗ ដែលក្នុងនោះព្រះអង្គត្រូវរងទទួលក្នុងឋានៈជាអ្នកតំណាងរបប ប៉ុល ពត នោះបានធ្វើឲ្យទុក្ខព្រួយដោយសារការព្រាត់ប្រាសបុគ្គលជាទីស្រឡាញ់ផ្ទាល់របស់ព្រះអង្គ ដែលខ្មែរក្រហមធ្វើទុក្ខទោសមកលើព្រះអង្គកាន់តែធ្ងន់ធ្ងរឡើង ។ គ្មានអ្វីទៀតដែលត្រូវរៀបចំទាំងអស់, ទាំងកិត្តិយស, ទាំងការយកចិត្តទុកដាក់ដែលក្រុមអ្នកតំណាងប្រទេសចិនប្រចាំអង្គការសហប្រជាជាតិ បំពេញព្រះរាជបំណងព្រះអង្គ–«ទូលបង្គំសូមឲ្យព្រះអង្គកុំគិតពីការចំណាយ», ឯកអគ្គរដ្ឋទូតប្រទេសចិនបានទូលប្រាប់ព្រះអង្គយ៉ាងច្បាស់ ដោយដាក់ព្រះអង្គឲ្យគង់នៅបន្ទប់សណ្ឋាគារដ៏ប្រណីតមួយ – ទាំងមិនឲ្យព្រះអង្គទាក់ទងជាមួយអ្នកការសែតផង ៖ សម្ដេច សីហនុ នៅតែជាអ្នកទោសជានិច្ច ។ កម្មាភិបាលខ្មែរក្រហមបីនាក់ដែលអមដំណើរព្រះអង្គតាំងពីក្រុងភ្នំពេញមិនសប្បាយចិត្តនឹងដើរតាមព្រះអង្គដូចស្រមោលអន្ទោលតាមប្រាណ គ្រប់តែការបង្ហាញព្រះភក្ត្រជាសាធារណៈ ដោយបែកគ្នាដើរជាមួយព្រះអង្គនិងមហេសីព្រមទាំងក្រុមអ្នកហែហមរបស់

ព្រះអង្គនៅសណ្ឋាគារ វ៉ាល់ដ័រអាស់ ថូរីយ៉ា ផង ។ ពីរបីសប្តាហ៍ក្រោយមកសម្តេចត្រូវគេប្រាប់ឲ្យដឹងថា នៅពេល អៀង សារី ធ្វើដំណើរមកដល់ព្រះអង្គនឹងត្រូវបញ្ចុះឋានៈជាអនុប្រធានគណៈប្រតិភូរបស់កម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិវិញ ។ សម្តេច សីហនុ បានមានព្រះរាជបន្ទូលនៅពេលក្រោយមកទៀតថា ទឹកពេញប្រៀបកែវហើយ ។ សម្តេចបានសម្រេចព្រះទ័យថា នេះជាពេលវេលាដ៏ប្រសើរមួយ ដើម្បីដណ្តើមយកសេរីភាពព្រះអង្គមកវិញ ។

នៅយប់ថ្ងៃសៅរ៍នោះ កូនសំបុត្រដែល សម្តេច សីហនុ ផ្ញើតាមពួកភ្នាក់ងារសម្ងាត់បានធ្វើឲ្យ អាន់ឌ្រូយ៉ង់ បាត់មាត់បាត់ក ។ សម្តេច សីហនុ បានសរសេរខ្សៀកដោយខ្មៅដៃលើបំណែកក្រដាសខ្មុកខ្មួរមួយនូវពាក្យដូចតទៅ ៖ «លោកអធិការ ខ្ញុំសូមទទូចសុំជំនួយពីក្រុមរបស់លោកដើម្បីឲ្យខ្ញុំរួចផុតពីពួកខ្មែរក្រហម ដែលពេលនេះកំពុងស្នាក់នៅសណ្ឋាគារ វ៉ាល់ដ័រ អាស់ថូរីយ៉ា ជាមួយខ្ញុំដែរ ។ យប់នេះ វេលាម៉ោងពីរគត់ ខ្ញុំនឹងចាកចេញដោយសម្ងាត់ពីក្រុមអ្នកហែហមខ្ញុំតែមួយអង្គឯងជាមួយវ៉ាលិសមួយ ។ សូមលោកមេត្តានាំយករូបខ្ញុំតាមរថយន្តឆ្ពោះត្រង់ទៅប៉ុយរ៉ូរបស់លោក អាន់ឌ្រូយ៉ង់ ឯកអគ្គរដ្ឋទូតអចិន្ត្រៃយ៍របស់សហរដ្ឋអាមេរិកប្រចាំអង្គការសហប្រជាជាតិតែម្តង ។ សូមថ្លែងអំណរគុណលោកជាអនេកប្បការ ។ ព្រះហស្តលេខា "សីហនុ" ។ យ៉ង់ បានប្រាប់ឲ្យ វ៉ាន់ស៍ និង រីឆាដ ហូលប្រ៊ូក ដឹងភ្លាមៗ ដែលបានកោះ អញ្ជើញអ្នកទទួលខុសត្រូវនៃក្រុមស៊ើបការណ៍សម្ងាត់ និងផ្នែកសន្តិសុខជាតិជាច្រើនរូបមកធ្វើការប្រជុំមួយជាបន្ទាន់ ។ ហូលប្រ៊ូក បាននិយាយនៅពេលក្រោយមកថា នៅពាក់កណ្តាលអធ្រាត្រយើងបានរៀបចំនូវគម្រោងសាច់រឿងមួយដូចខ្សែភាពយន្តអ៊ីចឹងដែលនិយាយពីវីរបុរសមានចិត្តទូលំទូលាយម្នាក់ ។ ក្រុមភ្នាក់ងារសម្ងាត់ជាច្រើននាក់នៅរង់ចាំសម្តេចតាមពេលម៉ោងកំណត់នៅមាត់ទ្វារកន្លែងស្នាក់នៅរបស់ក្រុមអ្នកហែហមព្រះអង្គ ។ ហូលប្រ៊ូក បានឡើងទៅកាន់បន្ទប់រៀបចំការធ្វើប្រតិបត្តិការនៅជាន់ទីប្រាំពីរនៃអគារក្រសួងការបរទេស ជាទីដែលគាត់អាចតាមដានការវិវត្តស្ថានការណ៍នេះនៅពេលដែល វ៉ាន់ស៍ ស្ថិតនៅក្បែរទូរស័ព្ទឯផ្ទះរបស់គាត់ ។ ក្រោយមក ហូលប្រ៊ូក បាននិយាយឲ្យដឹងថា "គឺជាការប្រថុយគ្រោះថ្នាក់មួយធំណាស់ ។ យើងភ័យខ្លាចតែព្រះអង្គត្រូវគេសម្លាប់ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយព្រះអង្គនៅតែជាអ្នកទោសម្នាក់របស់ខ្មែរក្រហមដដែល» ។

នៅក្នុងល្វែងបន្ទប់របស់ព្រះអង្គ សម្តេច សីហនុ នៅគង់រង់ចាំពេលម៉ោងដែលបានសន្មតទាំងប្រាស់ប្រាល់ក្នុងព្រះទ័យ ។ តាមធម្មតាពួកឆ្មាំខ្មែរក្រហមច្រើនតែដេកនៅពេលពាក់កណ្តាលអធ្រាត្រ ប៉ុន្តែនៅយប់នេះពួកនោះហាក់ដូចជាមិនងងុយដេកសោះ ។ នៅម៉ោងដប់ពីរនិងសាមសិបនាទីអធ្រាត្រ ព្រះអង្គទ្រង់នៅសណ្តាប់ឮសំឡេងប៉ិកប៉ក់ៗនៃម៉ាស៊ីនអង្គុលីលេខមួយនៅក្នុងបន្ទប់ក្បែរខាងទៀត ។ ក៏ប៉ុន្តែនៅវេលាម៉ោងពីរទៀបភ្លឺ អ្វីៗបានស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់ទាំងស្រុង ។ ព្រះអង្គមានបន្ទូលលាអ្នកម្នាង ម៉ូនិច ដែលមានព្រះភក្ត្រក្រៀមក្រំហើយចាកចេញទៅដោយលួចលាក់ ។ អាមេរិកាំងបួននាក់នៅអង្គុយរង់ចាំព្រះអង្គដោយគ្មាននិយាយស្តីមួយ

*ម៉ាត់ ។ មុននឹងយាងចាកចេញ ព្រះអង្គបានបង្គាប់ដាច់ខាតឲ្យអ្នកម្នាង ម៉ូនិច ប្រាប់ខ្មែរក្រហមនិងពួកចិនបានដឹងអំពីការសម្រេចព្រះទ័យគេចចេញរបស់ព្រះអង្គនេះផង ។ សម្ដេចក៏បានស្នើឲ្យអ្នកម្នាងសងប្រាក់ចំនួន២០.០០០ ដុល្លារទៅឲ្យខ្មែរក្រហមដែលបានផ្ដល់ឲ្យព្រះអង្គ នៅពេលព្រះអង្គយាងចេញពីក្រុងភ្នំពេញវិញផង ។ អមសងខាងដោយពួកភ្នាក់ងារអាមេរិកាំង សម្ដេចបានបោះជំហានយ៉ាងរហ័សសំដៅជណ្ដើរយន្តមួយ ។ នៅខាងចុងផ្លូវរបៀងខ្វាត់ខ្វែងមួយដែលនាំឲ្យវង្វេង ព្រះអង្គបានរកឃើញផ្លូវមកដល់ខាងក្រោជាទីដែលរថយន្តមួយគ្រឿងនៅរង់ចាំជាស្រេច ដើម្បីបើកជូនសម្ដេចរហូតដល់ការិយាល័យរបស់ យ៉ង់ ។ សម្ដេច សីហនុ មានព្រះរាជបន្ទូលក្រោយមកថា រូបព្រះអង្គដូចជាស្ថិត នៅក្នុងខ្សែភាពយន្តផ្នែកចារកម្មមួយអ៊ីចឹង!» ។*

*ព្រឹត្តិការណ៍ដែលមិនបានគិតទុកទាំងនេះ បានធ្វើឲ្យផែនការផ្សេងៗរបស់ យ៉ង់ ដែលត្រូវធ្វើដំណើរទៅទីក្រុងអាឡិនតា(Atlanta)នៅថ្ងៃទី១៨ ខែមករា ដើម្បីចូលរួមពិធីបុណ្យរំឭកខួបកំណើតលើកទី៥០របស់លោក ម៉ារតាំង លូធ័រ ឃីង ប្រែត្រឡប់អស់ ។ ប្រធានាធិបតីខាធ័រត្រូវទទួលភារកិច្ចនិយាយពន្យល់ប្រាប់អ្នកកាសែតពីអវត្តមានរបស់គាត់នេះ ។ គាត់និយាយថា យ៉ង់ ត្រូវហៅឲ្យមកកាន់ក្រសួងការបរទេសនៅម៉ោង៧ៈ៣០នាទីព្រឹក ព្រោះតែ«បេសកម្មពិសេសមួយ» ។ ទីបំផុត នៅពេលដែល យ៉ង់ មកដល់ដោយយឺតពេលនៅថ្ងៃនោះ គាត់បានប្រកាសប្រាប់សារព័ត៌មានថា គាត់ត្រៀមជួបពិភាក្សាជាមួយអ្នកតំណាងរបស់ចិន ដើម្បី«សាកល្បងលុបបំបាត់ការលំបាកខ្លះៗដែលទាក់ទងនឹងប្រទេសកម្ពុជា»[៣] ។*

*កាលនោះអ្វីដែលគាត់ពុំអាចនិយាយឲ្យដឹងគឺថា នៅមុនពេលព្រឹកព្រលឹមគាត់បានទៅជួបសម្ដេច សីហនុ ដែលកំពុងស្រយុតស្រយង់ព្រះទ័យ បន្ទាប់មកជួបជាមួយពួកចិន ដើម្បីពិភាក្សាពីព្រះរាជបំណងចង់ចាកចេញពីខ្មែរក្រហមរបស់សម្ដេច ។ ឯកអគ្គរដ្ឋទូតចិនប្រចាំអង្គការសហប្រជាជាតិបានត្រូវកោះ អញ្ជើញឲ្យទៅកាន់ប៉ុស្តិ៍របស់ យ៉ង់ ភ្លាមជាកន្លែងដែល សម្ដេច សីហនុ បានមានបន្ទូលប្រាប់ឯកអគ្គរដ្ឋទូតចិន ដោយផ្ទាល់ពីបំណងស្នើសុំសិទ្ធិជ្រកកោនខាងនយោបាយជាបណ្ដោះអាសន្ននៅសហរដ្ឋអាមេរិក ។ សម្ដេចបានមានព្រះរាជបន្ទូលប្រាប់គាត់ថា ៖ «ថ្ងៃណាមួយ ខ្ញុំនឹងត្រឡប់ទៅគង់ប្រថាប់នៅប្រទេសចិនវិញ ប៉ុន្តែខ្ញុំបានរងការប៉ះទង្គិចខាងផ្លូវព្រះទ័យយ៉ាងខ្លាំង ។ វាចាំបាច់ដែលខ្ញុំត្រូវតែទៅកាន់មន្ទីរពេទ្យមួយនៅក្រុងញូវយ៉កជាបន្ទាន់ ដើម្បីសម្រាកព្យាបាលឲ្យមានព្រះកាយពលឡើងវិញ» ។*

*សម្ដេច សីហនុ បានធ្វើឲ្យក្រសួងការបរទេសអាមេរិកទ័លគំនិតយ៉ាងខ្លាំង ។ បទពិសោធន៍ដែលព្រះអង្គធ្លាប់ឆ្លងកាត់នៅប្រទេសកម្ពុជា បានធ្វើឲ្យព្រះអង្គទាក់ទាញបានសមានចិត្តជាទូទៅ ។ ប៉ុន្តែ វ៉ាន់ស៍ និង ហូលប្រ៊ុក ភ័យខ្លាចថា ការបោះបង់ចោលបក្សពួករបស់ព្រះអង្គអាចធ្វើឲ្យឆាកនយោបាយរបស់កម្ពុជាបាត់បង់មេដឹកនាំដែលមានសមត្ថភាពមួយអង្គ និងជានិមិត្តរូបមួយនៃឯកភាពជាតិ ។ អ្វីដែលកាន់តែធ្វើឲ្យព្រួយបារម្ភថែមទៀតនោះ គឺគ្រោះថ្នាក់ធ្វើឲ្យទំនាក់ទំនងចិន-អាមេរិកាំងដែលទើបរៀបចំឲ្យមានថ្មីៗចុះអន់ខ្សោយ បើសិនជាគេយល់*

ព្រមផ្តល់សិទ្ធិជ្រកកោនឲ្យព្រះអង្គមែននោះ ។ ដោយសារគំនិតផ្តួចផ្តើមរបស់ប្រទេសចិន ជាសំខាន់និងការប្រឹងប្រែងទាំងស្រុងរបស់ខ្លួន ទើប សម្តេច សីហនុ អាចយាងចាកចេញពីក្រុងភ្នំពេញមុនការចូលមកដល់របស់វៀតណាម ហើយប្រទេសចិនផងដែរដែលបានបញ្ជូនព្រះអង្គទៅកាន់ក្រុងញូវយ៉កឲ្យធ្វើជាតំណាងរបស់ ប៉ុល ពត នោះ ។ ដោយជាក់ស្តែង ក្រុងប៉េកាំងមានគោលបំណងប្រើប្រាស់កិត្តិសព្ទជាអន្តរជាតិរបស់សម្តេច ដើម្បីប្រមូលសាធារណៈមតិប្រឆាំងនឹងប្រទេសវៀតណាម ។ ឧបនាយករដ្ឋមន្ត្រី តេង ស៊ាវពីង បានពន្យារពេលនៅសហរដ្ឋអាមេរិកពីរសប្តាហ៍ក្រោយមកទៀត ។ ឱកាសដែលត្រូវសម្រេចចិត្តយល់ព្រមផ្តល់សិទ្ធិជ្រកកោនផ្នែកនយោបាយឲ្យ សម្តេច សីហនុ មានសភាពមិនល្អឡើយ ។ រ៉ូហ្សេ ស៊ុលលីវ៉ាន់ ឧបការីរបស់លោក ហូលប្រ៊ុក ទទួលបន្ទុកកិច្ចការប្រទេសចិនត្រូវបានដាស់ឲ្យភ្ញាក់ពីដំណេកនៅពាក់កណ្តាលអធ្រាត្រនិងសុំឲ្យអញ្ជើញមកកាន់ក្រសួងការបរទេស ។ គឺរូបគាត់នេះហើយដែលទទួលបន្ទុកប្រាប់ដំណឹងនេះដល់ពួកចិន ។ នៅម៉ោង៤ព្រឹក គាត់បានហៅ ហាន់ ស៊ូ ប្រធានការិយាល័យទំនាក់ទំនងរបស់ ចិននៅក្រុងវ៉ាស៊ីនតោនតាមទូរស័ព្ទ ដើម្បីប្រាប់ឲ្យគាត់ដឹងថា សម្តេច សីហនុ ដែលអស់ព្រះកាយយ៉ាងខ្លាំង បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យហើយ ។ មុនដំបូងហានស៊ូ មានអាការៈងឿងឆ្ងល់ ប៉ុន្តែគាត់បានពង្រឹងស្មារតីឡើងវិញយ៉ាងឆាប់រហ័ស ។ ស៊ូ បានឆ្លើយតបយ៉ាងខ្លីថា ៖ «ល្អណាស់ បើព្រះអង្គសព្វព្រះទ័យមែនយើងយល់ព្រម»[៤] ។

ពន្លឺព្រះអាទិត្យស្រពាងៗបានរះឡើងចាំងមកលើទន្លេ East River នៅពេលដែល សម្តេច សីហនុ ត្រូវបានគេជូនដំណើរយាងទៅកាន់មន្ទីរពេទ្យ លីណូសហ៊ីល (Lenox Hill) នៅតាមដងវិថី Park Avenue ។ នៅវេលាព្រឹកថ្ងៃបន្ទាប់ ព្រះអង្គម្ចាស់ក្សត្រី ម៉ូនិច បានយាងមកគង់នៅជាមួយព្រះអង្គដែរក្នុងបន្ទប់នាជាន់ទី៩នៃមន្ទីរពេទ្យ ជាទីដែលព្រះអង្គទាំងពីរនឹងត្រូវបានបង្ខាំងដោយខុសច្បាប់ស្ទើរតែទាំងស្រុង ។ ក្រសួងការបរទេសយល់ឃើញថាគួរតែដាក់សម្តេចឲ្យនៅដាច់ពីគេឯងសិនដើម្បីផ្តល់ពេលវេលាឲ្យព្រះអង្គធ្វើការត្រិះរិះពិចារណាជាដាវផ្តល់សិទ្ធិជ្រកកោនឲ្យព្រះអង្គដោយប្រញាប់ប្រញាល់ពេក ។ សេចក្តីជូនដំណឹងមួយបានប្រកាសឲ្យដឹងពីការយាងចូលមន្ទីរពេទ្យរបស់សម្តេចបន្ទាប់ពីមាន «សភាពតានតឹងយ៉ាងធ្ងន់ធ្ងរមួយផ្នែកសរសៃប្រសាទនិងការអស់ព្រះកាយពលយ៉ាងខ្លាំងមួយ» ។ ហ្វ្រង់តាទូ មន្ត្រីនៅក្រសួងការបរទេសដែលចេះនិយាយភាសាបារាំង និងដែលធ្លាប់រស់នៅប្រទេសកម្ពុជាអស់ជាច្រើនឆ្នាំត្រូវបានចាត់ឲ្យទៅសាកសួរសុខទុក្ខ សម្តេច ដើម្បីបញ្ជាក់ថា ព្រះអង្គពុំមែនជាអ្នកទោសទេ ៖ វិធានការផ្សេងៗផ្នែកសន្តិសុខ គឺគ្រាន់តែការពារព្រះអង្គ និងទុកឲ្យព្រះអង្គមានពេលគ្រប់គ្រាន់ដើម្បីទ្រង់ព្រះតម្រិះប៉ុណ្ណោះ ។ លោក យ៉ង់ ក៏អញ្ជើញទៅជួបសម្តេចដែរ ។ ច្បាស់ណាស់ យោបល់របស់អាមេរិកាំងមានដូចតទៅ ៖ «ព្រះអង្គអាចគង់នៅជាមួយយើងបើសិនជាព្រះអង្គសព្វព្រះទ័យ ប៉ុន្តែហេតុអ្វីបានជាព្រះអង្គមិនពិចារណាថែមទៀតពីរឿងនេះ? នៅពេលដែលគេចូលខាងគូប្រឆាំងពួកគេមុខជាបាត់បង់អត្តសញ្ញាណរបស់ខ្លួន ហើយលែងមានប្រយោជន៍អ្វីទាំងអស់ ក្នុងឋានៈជាមេដឹកនាំនយោបាយ» ។ ហូលប្រ៊ុក

បានដំណាលថា ៖ «យើងបានទូលសួរព្រះអង្គថា អ្នកណាដែលព្រះអង្គនឹងត្រូវពឹងផ្អែក? អ្នកណាដែលបោះបង់ព្រះអង្គចោល? ខ្មែរក្រហម? ។ មនុស្សទាំងអស់ដឹងថា ព្រះអង្គបានផ្ដាច់ទំនាក់ទំនងជាមួយខ្មែរក្រហមហើយ ។ តើសម្ដេចចង់បោះបង់ប្រទេសមួយដែលទោះជាយ៉ាងណាក៏ដោយ ក៏ព្រះអង្គពុំអាចយាងត្រឡប់ទៅវិញនៅពេលនេះមែនឬ?» ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៩ វ៉ាន់ស៍ បានធ្វើដំណើរដោយផ្ទាល់ទៅកាន់មន្ទីរពេទ្យ ។ គាត់បានទូល សម្ដេច សីហនុ ថា ព្រះអង្គគឺជាភ្ញៀវរបស់រដ្ឋាភិបាលអាមេរិកាំង ហើយថាព្រះអង្គអាចគង់នៅសហរដ្ឋអាមេរិកក្នុងរយៈពេលយូរតាមតែព្រះអង្គសព្វព្រះទ័យ ។ វ៉ាន់ស៍ ពុំមាននិយាយពីសិទ្ធិជ្រកកោនផ្នែកនយោបាយមួយម៉ាត់ទាល់តែសោះ[៥] ។

សម្ដេចមានព្រះទ័យត្រេកអរជាពន្លឹកដែលព្រះអង្គបានដោះព្រះកាយចេញពីក្រញាំខ្មែរក្រហម និងក្លាយជាមនុស្សម្នាក់មានសេរីភាពឡើងវិញ ។ ប៉ុន្តែអ្វីៗពុំមែនសុទ្ធតែល្អនោះទេ ៖ ខុសប្លែកពីបណ្ដាមេដឹកនាំប្រទេសតតិយលោកភាគច្រើន អតីតព្រះមហាក្សត្រអង្គនេះពុំមានលេខគណនីណាមួយចុះក្នុងធនាគារនានានៅបរទេសឡើយ ។ អ្នកគ្រប់គ្រងមន្ទីរពេទ្យលីណូសហ៊ីសត្រូវធ្វើឲ្យស្រឡាំងកាំង នៅពេលដែលដឹងថា អ្នកជំងឺប្រកបដោយកិត្តិនាមរបស់ខ្លួនពុំមានការធានារ៉ាប់រងខាងផ្នែកសុខភាពមួយនោះ ។ មន្ទីរពេទ្យគ្មានគិតអ្វីក្រៅពីទាមទារឲ្យ «អាណាព្យាបាល»ទាំងពីររបស់ព្រះអង្គ គឺខ្មែរក្រហម និងពួកចិនឲ្យបង់ថ្លៃពេទ្យឡើយ ។ ប៉ុន្តែគឺរដ្ឋាភិបាលអាមេរិកាំងជាអ្នកចេញប្រាក់បង់ថ្លៃពេទ្យចំនួន ១៥.០០០ដុល្លារទៅវិញ ។ ប៉ុន្តែ បន្ទាប់ពីការទៅសួរសុខទុក្ខរបស់ វ៉ាន់ស៍ សម្ដេច សីហនុ ទ្រង់ជ្រាបថា សហរដ្ឋអាមេរិកនឹងពុំយល់ព្រមផ្ដល់សិទ្ធជ្រកកោនផ្នែកនយោបាយឲ្យព្រះអង្គឡើយ ។ ដោយត្រូវធ្វើឲ្យខូចព្រះទ័យសម្ដេចបានប្រញាប់ធ្វើការទាក់ទងជាមួយឯកអគ្គរដ្ឋទូតបារាំងប្រចាំអង្គការសហប្រជាជាតិភ្លាម ក្នុងគោលបំណងសុំឲ្យគាត់បញ្ជូនទៅកាន់ក្រុងប៉ារីសនូវពាក្យស្នើសុំលិខិតឆ្លងដែនបារាំងសម្រាប់ព្រះអង្គ និងអ្នកម្នាង ម៉ូនិក ។ ព្រះអង្គក៏បានស្នើសុំការអនុញ្ញាតគង់នៅក្នុងភូមិគ្រឹះតូចមួយដែលជាកម្មសិទ្ធិរបស់ព្រះមាតាព្រះអង្គនៅមូហ្សង់ ផងដែរ ។ សម្ដេចជឿជាក់នឹងទង្វើរបស់ព្រះអង្គណាស់ ទើបព្រះអង្គទ្រង់លិខិតទៅក្រសួងការបរទេសដើម្បីប្រាប់ឲ្យដឹងថាព្រះអង្គនឹងទៅរស់នៅប្រទេសបារាំងវិញ ។ ប៉ុន្តែ ពួកបារាំងសុខចិត្តយល់ព្រមផ្ដល់សិទ្ធិជ្រកកោនឲ្យព្រះអង្គក្នុងលក្ខខណ្ឌដាច់ណាត់ថា សម្ដេច សីហនុ ត្រូវតែចៀសវាងសកម្មភាពនយោបាយទាំងអស់និងការធ្វើសម្ភាសន៍ផ្សេងៗដែលមានលក្ខណៈនយោបាយផង ។ អ្នកម្នាង ម៉ូនិក ដែលមានកំណើតពីឪពុកជាជនជាតិបារាំងអាចទទួលបានលិខិតឆ្លងដែនបារាំងមួយ ចំណែកឯសម្ដេចគឺពុំអាចទេ ។ សម្រាប់សម្ដេច សីហនុ ការជ្រើសនៅពេលនេះមានលក្ខណៈលំបាកជាទីបំផុត ៖ ឬមួយត្រូវរស់នៅជាអ្នកនិរទេសខ្លួនដោយគ្មានទ្រព្យសម្បត្តិនិងគ្មានមាតុភូមិ ឬមួយយល់ព្រមធ្វើជាតំណាងថ្នាក់ថ្មីដោយរបបមួយ ដែលកាប់សម្លាប់មនុស្សអស់យ៉ាងច្រើនដោយចេតនា? ។ លទ្ធភាពទីបីបានលេចឡើងភ្លាមតែមិនសូវទាក់ចិត្តប៉ុន្មានឡើយ ។ តាមការជួយខ្នះខ្នែងរបស់ឯកអគ្គរដ្ឋទូតនៃប្រទេសមិនចូលបក្សសម្ព័ន្ធមួយ ក្រុង

*ហាណូយបានទូលឲ្យសម្ដេចដឹងថា បើសិនព្រះអង្គចង់យាងត្រឡប់មកក្រុងភ្នំពេញវិញដើម្បីធ្វើជាមេដឹកនាំរបបមួយ ដែលរៀបចំឡើងដោយវៀតណាមព្រះអង្គនឹងត្រូវបានទទួលស្វាគមន៍ ។*

*នៅទីបំផុតគឺ គេង ស៊ាវពីង ដែលត្រូវសម្រេចចិត្តពីរឿងព្រះអង្គ ។ គេង នឹកព្រួយបារម្ភយ៉ាងខ្លាំង ដោយការប្រកាសយ៉ាងខ្វរខ្វាររបស់ សម្ដេច សីហនុ ប្រឆាំងនឹងខ្មែរក្រហម និងព្រះរាជបំណងចង់គង់ប្រថាប់នៅបស្ចិមប្រទេសរបស់ព្រះអង្គ ។ កាលវិភាគរបស់គាត់ដែលមានរបៀបវារៈច្រើនហួសត្រូវបានកែប្រែ ដើម្បីអាចបើកឱកាសឲ្យគាត់បានជួបសម្ដេចនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៩ ដោយមានសហប្រតិបត្តិការពីពួកអាមេរិកាំងផង ។ អមការពារដោយភ្នាក់ងារសន្តិសុខរបស់ក្រសួងការបរទេសបួនរូប សម្ដេច សីហនុ និងមហេសីបានយាងតាមរថយន្តពីញូវយ៉កទៅប្លែរហាវ (Blair House) ជានិវេសនដ្ឋានរបស់ គេង ដើម្បីចូលរួមលៀងសាយភោជន៍ពេលល្ងាចជាលក្ខណៈឯកជនមួយ ។*

*នៅមុខម្ហូបអាហារចិនដ៏សម្បូរពោរពាស គេង បានប្រកាសថា ៖ “សម្ដេច សីហនុ! ព្រះអង្គជាអ្នកស្នេហាជាតិដ៏ឆ្នើមមួយអង្គ ព្រះអង្គមិនត្រូវបោះបង់មាតុភូមិរបស់ព្រះអង្គគឺកម្ពុជាប្រជាធិបតេយ្យឡើយ” ។ សម្ដេច សីហនុ បានមានបន្ទូលតបវិញយ៉ាងរហ័សថា ៖ “មាតុភូមិតែមួយគត់របស់ខ្ញុំ គឺកម្ពុជាពុំមែនកម្ពុជាប្រជាធិប-តេយ្យទេ ។ ខ្ញុំក៏ពុំមែនជាអ្នកប្រជាធិបតេយ្យខ្លាំងក្លាដែរ ខ្ញុំជាស្ដេចសក្ដិភូមិមួយអង្គ” ។ គេង បានប្រកែកតឹងសំឡេងថា សម្ដេចជាអ្នកប្រជាធិបតេយ្យពិតប្រាកដមួយអង្គ! ។ គាត់បានបន្ថែមថា ៖ “ខ្ញុំគួរតែសារភាពថាចំពោះយើងជាចិនពុំសូវចូលចិត្តលក្ខណៈនយោបាយខ្លះៗរបស់ ប៉ុល ពត ទេ ព្រោះគាត់ជាមនុស្សតឹងតែងពេក” ។ ប្រទេសចិនបានសាកល្បងបន្ទន់ព្រះទ័យសម្ដេច ។ សម្ដេចដែលមិនជឿបានសួរថា “ពិតមែនឬ? តើលោកជឿប្រាកដថា គេអាចធ្វើឲ្យសត្វខ្លាប្រែក្លាយទៅជាសត្វស្លូតបូតបានទេ?” ។ គេង បានទទួលស្គាល់ថាប្រទេសចិនពុំមានអំណាចនេះទេ ប៉ុន្តែ គាត់បានរំឭកទូលប្រាប់សម្ដេចពីការប្រឹងប្រែងផ្សេងៗដែលប្រទេសរបស់គាត់បានធ្វើដើម្បីរំដោះសម្ដេចពីខ្មែរក្រហមដែរ ។ ដោយធ្វើជាយកការដឹងគុណដ៏ជ្រាលជ្រៅរបស់សម្ដេចចំពោះប្រទេសចិនជាសំអាង គេង បានទូលសម្ដេចថា គឺព្រះអង្គជាអ្នកមានបន្ទូលព្រមគ្នាថា ប្រទេសចិនជាមិត្តចាស់មួយផងនិងជាមាតុភូមិទីពីរផង តាំងពីមានការផ្ដួលរំលំព្រះអង្គនៅឆ្នាំ១៩៧០ម៉្លេះ ។ វានឹងជាការចំអកចំពោះប្រទេសចិនដែល សម្ដេច សីហនុ បដិសេធមិនយាងត្រឡប់ទៅរស់នៅក្រុងប៉េកាំងវិញ ។ គេង បានផ្ដល់នូវការធានាអះអាងនឹងសម្ដេចថា ការតាំងព្រះទ័យមិនសហការជាមួយខ្មែរក្រហមនឹងត្រូវបានគោរពធ្វើតាម ហើយថាគ្មានការគាបសង្កត់ណាមួយនឹងត្រូវធ្វើទៅលើរូប ព្រះអង្គដើម្បីបង្ខំព្រះអង្គពីរឿងនេះឡើយ ។ ម្យ៉ាងទៀត គេនឹងមិនតម្រូវឲ្យព្រះអង្គយាងទៅកាន់ទីណាដែលផ្ទុយនឹងព្រះទ័យព្រះអង្គផងទេ ។ គេង បានសន្យាប្រើលទ្ធភាពទាំងអស់របស់គាត់ជាមួយខ្មែរក្រហម ដើម្បីឲ្យជួយស្វែងរកព្រះរាជបុត្រា-បុត្រី ព្រះរាជនត្តា(ចៅ) និងបណ្ដាញាតិវង្សដទៃទៀតរបស់សម្ដេច សីហនុ ដែលបាត់ខ្លួនថែមទៀត ។ ការអញ្ជើញដ៏ជាទីកក់ក្ដៅរបស់ គេង*

និងកិច្ចធានាឲ្យមានសេរីភាពទាំងស្រុងបានបញ្ចប់ការស្នាក់នៅស្វ៊ែរព្រះទ័យចំនួនពីរសប្ដាហ៍របស់សម្ដេច សីហនុត្រឹមនេះ ។ ព្រះអង្គនឹងយាងទៅគង់ប្រថាប់នៅទីក្រុងប៉េកាំងជាថ្មីដោយសេចក្ដីសង្ឃឹមថា ស្ថានភាពនយោបាយដ៏ប្រសើរមួយមុខជាអនុញ្ញាតឲ្យព្រះអង្គយាងត្រឡប់ទៅកាន់ប្រទេសកម្ពុជាដែលឯករាជ្យមួយវិញមិនខាន[៦] ។

សម្ដេច សីហនុ បានយល់ច្រឡំដែលសម្ដែងចេញនូវគំនិតសុទិដ្ឋិនិយមដូចនេះ ហើយនឹកស្មានថា គេនឹងបណ្ដោយឲ្យព្រះអង្គគង់នៅស្ងប់ស្ងាត់នៅប្រទេសចិននោះ ។ ពិតជាឆាប់រហ័សមែន! ការគាបសង្កត់ ការលួងលោម ការបញ្ឆោរ និងការទាក់ទាញចិត្តគ្រប់បែបយ៉ាងបានបង្ខំឲ្យព្រះអង្គចូលរួមធ្វើការតស៊ូជាថ្មី ដែលជំរុញដោយការកាន់កាប់របស់វៀតណាម ។ កិត្តិស័ព្ទជាអន្តរជាតិនិងប្រជាប្រិយភាពដ៏ធំធេងរបស់ព្រះអង្គនៅកម្ពុជាបានផ្ដល់ឲ្យព្រះអង្គនូវតួនាទីគន្លឹះមួយជាថ្មីក្នុងសោកនាដកម្មរបស់កម្ពុជា ។ នៅឆ្នាំ១៩៧០ សម្ដេច សីហនុ ព្រះប្រមុខរដ្ឋដែលគេទម្លាក់ពីតំណែង បានចងភ្ជាប់ជោគវាសនារបស់ព្រះអង្គជាមួយពួកខ្មែរក្រហមនិងសម្ពន្ធ័មិត្តវៀតណាមនិងចិនរបស់ពួកគេ ។ នៅឆ្នាំ១៩៧៩ ការចាប់ផ្ដើមប្រកួតប្រជែងគ្នានៅខាងក្រៅបានកើនឡើងយ៉ាងខ្លាំង ។ ការកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាម មិនគ្រាន់តែបង្ហាញឲ្យឃើញការបន្តហេតុមួយចំពោះប្រទេសចិនប៉ុណ្ណោះទេ តែក៏ធ្វើឲ្យសមាគមអាស៊ានព្រួយបារម្ភយ៉ាងខ្លាំងដែរ ។ ជាងនេះទៅទៀត ការកាន់កាប់នេះបានធ្វើឲ្យប្រទេសថៃបាត់បង់“ទ្រនាប់”មួយ ដែលខណ្ឌចែកប្រទេសពីគូប្រជែងវៀតណាមដែលមានរាប់សតវត្សរ៍មកហើយ ។ នៅដើមដំបូង នេះជាជម្លោះធម្មតាមួយរវាងប្រទេសវៀតណាមម្ខាង ហើយម្ខាងទៀតគឺប្រទេសចិននិងប្រទេសនៅក្នុងការឧបត្ថម្ភរបស់ខ្លួនគឺកម្ពុជា ដែលនៅពេលនេះបានត្រូវរ៉ូវគ្នាដោយសារជម្លោះជាប្រវត្តិសាស្ត្រមួយផ្សេងទៀត ដែលកំពុងធ្វើឲ្យប្រទេសវៀតណាម និងប្រទេសថៃប្រឈមមុខដាក់គ្នា ដើម្បីដណ្ដើមការត្រួតត្រាវាលទំនាបទន្លេមេគង្គ ។ សង្គ្រាមថ្មីនេះបានផ្ដល់ឲ្យពួកសូវៀតនូវឱកាសបើកផ្លូវមួយមកកាន់សមុទ្រប៉ាស៊ីហ្វិកដែលពុំធ្លាប់មានពីមុនមក ។ បណ្ដាសម្ព័ន្ធមិត្តក្នុងតំបន់របស់ប្រទេសថៃ និងបណ្ដាប្រទេសជាមិត្តនៅបស្ចិមប្រទេស បានត្រូវអូសទាញឲ្យចូលក្នុងជម្លោះម្ដងទៀត ។ ប្រទេសកម្ពុជាបានក្លាយទៅជាចំណុចក្ដៅថ្មីមួយក្នុងការប្រឈមមុខដាក់គ្នារវាងខាងកើតនិងខាងលិច ។ ការវិវាទជាប្រវត្តិសាស្ត្រត្រូវបានដុតបញ្ឆេះជាថ្មី មិត្តនិងសម្ព័ន្ធមិត្តទាំងឡាយដែលជាអ្នកនាំអាទិ៍បានប្រើល្បិចកលផ្សេងៗ ដើម្បីទទួលបានអត្ថប្រយោជន៍ជាយុទ្ធសាស្ត្រមួយក្នុងពេលដែលគ្មានប្រទេសណាមួយខ្វល់ខ្វាយពីជោគវាសនារបស់ប្រជាជាតិខ្មែរ ។

## ទីបញ្ចប់នៃសុបិនអាក្រក់

ការកាន់កាប់ទីក្រុងភ្នំពេញដោយវៀតណាម និងការដេញតាមខ្មែរក្រហមរហូតដល់ព្រំដែនថៃ បានបន្តឲ្យមានការភ្ញាក់ផ្អើលស្រឡាំងកាំងនៅក្រុងបាងកក ។ តើពួកនេះធ្វើដំណើរទៅដល់ណាទៀត? ។ ពេលនេះ“ជនជាតិព្រូស្សអាស៊ី” (Les Prussiens d'Asie) គឺវៀតណាមនឹងដេញតាមអ្នកដើរតាមរបប ប៉ុល ពត ចុងក្រោយរហូតដល់

ទឹកដីថៃមែនឬ? ពួកគេនឹងបញ្ជូនក្បួនរថក្រោះរបស់ខ្លួនរហូតដល់ក្រុងបាងកកទៀតទេដឹង? ។

ការមកដល់របស់វៀតណាម ត្រូវបានទទួលស្វាគមន៍ដោយទឹកចិត្តរីករាយ នៅតាមបណ្តាភូមិរាប់រយរបស់កម្ពុជា ។ ប្រជាជនមិននឹកស្មានថាមានរឿងអ្វីចឹងឡើយ ៖ ពួកកម្មាភិបាលខ្មែរក្រហមនិងកងឈ្លបទីបំផុតបានចាកចេញពីស្រុកភូមិអស់ ។ ប្រជាជនម្នាក់ៗមានសេរីភាពជាថ្មីក្នុងការរស់នៅជួបជុំគ្រួសារ ហើយអាចទៅដេកពួននៅទីណាក៏បាន ដោយគ្មានភ័យខ្លាចពីថ្ងៃស្អែកឡើយ ។ ក្រោមការបង្ខិតបង្ខំប្រជាជនជិត៣០.០០០នាក់នៃបណ្តាខេត្តភាគខាងលិចនិងក្រុងភ្នំពេញត្រូវកៀរទៅតាមខ្មែរក្រហមចូលទៅក្នុងព្រៃទៀត ។ ប៉ុន្តែ សម្រាប់តំបន់ដទៃទៀតនៃប្រទេស នេះគឺជាដំណើររួចផុតពីគ្រោះថ្នាក់មួយ ។ អ្នកភូមិបាននាំគ្នារើកកាយជង្រុកស្រូវរបស់អង្គការ និងសម្លាប់ជ្រូក មាន់ ទា ដើម្បីរៀបចំការបរិភោគជាលើកដំបូងរបស់គេយ៉ាងឆ្អែតស្កប់ស្កល់ ព្រោះពួកគេមិនដែលស្គាល់អ្វីដែលថា "ឆ្អែត" តាំងពីបួនឆ្នាំមកហើយ ។ ប្រជាជនកម្ពុជារាប់រយពាន់នាក់បានចាប់ផ្តើមចេញដំណើរ ដើម្បីវិលត្រឡប់ទៅស្រុកកំណើតរបស់គេវិញ ។ ប្រជាជនប្រុសស្រីដែលមានសម្លៀកបំពាក់ពណ៌ខ្មៅរហែករហ៊ៃ កំពុងដឹកជញ្ជូនអីវ៉ាន់ដ៏តិចតួចរបស់ពួកគេ តាមរទេះរុញដោយដៃដែលធ្វើឡើតែបានៗ និងដើរច្រវាត់ច្រវ៉ែងទៅមកពាសពេញប្រទេស មើលទៅហាក់ដូចជាហ្វូងស្រមោចដើរជាជួរដែរ ។ ប្រាំមួយខែបន្ទាប់ពីការឈ្លានពាន នៅពេលដែលខ្ញុំ(អ្នកនិពន្ធ) ធ្វើដំណើរទៅកម្ពុជាជាថ្មីមានប្រជាជនខ្លះនៅតែធ្វើដំណើរតាមផ្លូវនៅឡើយ ។ បន្ទាប់ពីការធ្វើដំណើរអស់រាប់រយ ម៉ោងទាំងអស់កម្លាំងនិងស្រេកឃ្លាន ពួកគេនៅតែបន្តដើរទាំងត្រដាបត្រដួសរហូតដល់គោលដៅចុងក្រោយរបស់គេ ។ "បើសិនជាវៀតណាមមិនមកទេ យើងទាំងអស់គ្នានឹងត្រូវស្លាប់" នេះជាពាក្យដែលអ្នករួចផុតពីគ្រោះថ្នាក់ទន្ទេញមិនឈប់ ។ ប៉ុន្តែ ប្រយោគសម្តែងការដឹងគុណនេះពុំមានគិតព្រួយបារម្ភពីការមកដល់នៃព្រឹត្តិការណ៍អាក្រក់ឡើយ ៖ ប្រទេសវៀតណាមដែលជាសត្រូវគ្មានទីបំផុតនឹងមិនក្លាប់ប្រទេសកម្ពុជាជារណបរបស់ខ្លួនមែនឬ? អតីតគ្រូបង្រៀនម្នាក់បានខ្សឹបដាក់ត្រចៀកខ្ញុំនៅតាមផ្លូវដែលនាំគាត់មកផ្ទះវិញថា ៖ "ខ្ញុំភ័យខ្លាច ថាពួកគេ(វៀតណាម)សម្រេចចិត្តស្ថិតនៅទីនេះ ដើម្បីស៊ីអង្ករបស់យើង" ។

វៀតណាមពុំបានធ្វើអ្វីដើម្បីឲ្យសក្តិសមទៅនឹងជំនឿទុកចិត្តរបស់ប្រជាជនកម្ពុជាឡើយ ។ ក្នុងរយៈបីខែបន្ទាប់ពីការមកដល់របស់ខ្លួន វៀតណាមបានរុករើបំផ្លាញទៅតាម"ទម្លាប់"នៅក្នុងរដ្ឋធានី ។ ក្បួនរថយន្តកាមីញ៉ុងជាច្រើនគ្រឿងដែលផ្ទុកពេញទៅដោយទូទឹកកក ម៉ាស៊ីនត្រជាក់ គ្រឿងសម្ភារអគ្គិសនី គ្រឿងសង្ហារិម ម៉ាស៊ីនគ្រប់ប្រភេទ និងរូបចម្លាក់ដ៏មានតម្លៃយ៉ាងច្រើនបានបើកតម្រង់ឆ្ពោះទៅទីក្រុងហូជីមិញ ។ វត្ថុដែលប្រមូលសន្សំទាំងអស់នេះត្រូវបានបោះបង់ចោលនៅឆ្នាំ១៩៧៥ ដោយប្រជាពលរដ្ឋទីក្រុងភ្នំពេញ នៅពេលដែលពួកគេត្រូវបណ្តេញចេញយ៉ាងឃោរឃៅ ហើយខ្មែរក្រហមដែលពោរពេញទៅដោយការមើលងាយចំពោះនិមិត្តរូបនៃការចុះអាប់ឱនរបស់វណ្ណៈគហបតី បានទុកចោលដោយគ្មានអ្នកណាប៉ះពាល់ឡើយ ។ ទោះជា"ជយភណ្ឌ"ទាំងនេះ

ដែលនាំយកពីក្រុងភ្នំពេញជួយបំពេញឃ្លាំងព្រទ្យសម្បត្តិរបស់ក្រុងហាណូយបានមួយចំនួនតូចក៏ដោយ ក៏ពួកគេបានបន្សល់ទុកនូវស្លាកស្នាមយ៉ាងជ្រៅក្នុងចិត្តគំនិតរបស់ប្រជាជនខ្មែរ ហើយធ្វើឲ្យបុរេនិច្ឆ័យ(គំនិតដែលគេប្រកាន់យកជាស្រេចដោយគ្មានត្រិះរិះពិចារណា) ដែលបង្ហាញនូវភាពជាសត្រូវរបស់ប្រជាជនខ្មែរចំពោះពួកយួនមានរឹតតែខ្លាំងឡើងថែមទៀត ។ ទន្ទឹមនឹងនោះ វៀតណាមបានក្លាយទៅជា“អ្នកដែលប្រជាជនលែងសូវមានជំនឿ”ក្នុងតួនាទីជា“អ្នករំដោះ”ប្រទេសកម្ពុជាដែរ ។

នៅពេលដែលខ្ញុំ(អ្នកនិពន្ធ)មកដល់ទីក្រុងភ្នំពេញនៅខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំបានឃើញទីក្រុងខ្មោចមួយដែលផ្លូវចូលទីក្រុងត្រូវបិទមិនឲ្យមនុស្សចេញចូលឡើយ លើកលែងតែអ្នកក្លាហានជាអតីតអ្នកធ្លាប់រស់នៅទីក្រុងដែលរង់ចាំក្នុងជំរំទាំងឡាយដែលបង្កើតឡើងដោយគ្មានព្រាងទុកជាមុន នៅតាមបរិវេណខាងក្រៅរដ្ឋធានីប៉ុណ្ណោះទើបហ៊ានធ្វើដំណើរចូល ។ អ្នកទាំងឡាយដែលលួចជ្រៀតចូលទៅដល់ក្នុងក្រុងភ្នំពេញ បានដើរក្រវែលចុះក្រវែលឡើង ដើម្បីស្វែងរកវត្ថុមួយចំនួនដែលគេអាចយកមកប្រើឡើងវិញបាន ។ ដោយធ្វើដំណើរចុះតាមមហាវិថីព្រះមុនីវង្ស ខ្ញុំអាចស្តាប់ឮសំឡេងខ្ទរខ្ទួរឲ្យខ្លាចនៃជំហានជើងផ្ទាល់របស់ខ្ញុំ ។ សង្កាត់ជំនួញរបស់ចិនដែលកាលពីដើមមានសភាពរស់រវើកនោះហាក់ដូចជាត្រូវរងគ្រោះពីមហាវិនាសកម្មមួយ ។ គេហដ្ឋាននិងហាងលក់ទំនិញនានាបានត្រូវរើបំផ្លាញខ្ទេចខ្ទីគ្មានសល់ ។ ក្រែ តុ ទូ កៅអី ដែលបាក់បែកនិងសំណល់គ្រឿងប្រើប្រាស់ក្នុងចង្ក្រានបាយនៅរាយដេរដាសតាមទ្រូងថ្នល់គ្របពេញទៅដោយសំឡឹកសើមៗ ដែលធ្លាយចេញមកពីពូកនិងខ្នើយដោយសារគេវះរកមាស និងគ្រឿងអលង្ការមានតម្លៃ ។ នេះជាសញ្ញាថា ពួកចោរលួចបានចូលរុករើគ្រប់ផ្ទះទាំងអស់ ។

វៀតណាមពុំទុកចិត្តលើការដួលរលំដ៏គំហុកមួយរបស់ចលនាតស៊ូខ្មែរក្រហមទេ ។ ពួកគេមិនប្រាថ្នាការពារជាមុននូវអ្វីដែលពួកគេរកឃើញនៅខាងក្នុងប្រទេសឡើយ ។ ការជំទាស់ប្រាកដប្រជារបស់អន្តរជាតិដែលពួកគេត្រូវប្រឈមមុខហាក់ដូចជាជួយកាន់ជើងពួកគេដោយមិនដឹងខ្លួន ។ កម្ពុជាប្រជាធិបតេយ្យពុំត្រឹមតែជាប្រទេសមួយដែលគ្មានប្រាក់កាស គ្មានទីផ្សារ គ្មានប្រព័ន្ធប្រៃសណីយ៍ គ្មានសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែគឺជាកន្លែងមួយដែលមានគំនរឆ្អឹងខ្មោចនិងរណ្តៅសាកសពយ៉ាងសម្បើម ។ ការអត់ឃ្លានបានគំរាមកំហែងអ្នកដែលរស់រានមានជីវិតយ៉ាងខ្លាំង ហើយក្រៅពីអបអរយ៉ាងក្លៀវក្លានៅពេលបានដេញកម្ចាត់របបមួយដែលពិភពលោកទាំងមូលថ្កោលទោសជាសកល ប្រទេសវៀតណាមក៏ត្រូវរងទទួលការទិតៀន និងការបន្ទោសពីសំណាក់អន្តរជាតិផងដែរ ។

បក្សប្រជាជនបដិវត្តន៍កម្ពុជាដែលរៀបចំឡើងទាំងប្រញាប់ប្រញាល់ក្នុងអំឡុងពេលនៃដំណើរឆ្ពោះមកក្រុងភ្នំពេញរបស់កងទ័ពវៀតណាម តាមទ្រឹស្តីត្រូវតែរ៉ាប់រងបង្កើតរដ្ឋាភិបាលរបស់ប្រទេសជាតិថែមទៀត ។ ប៉ុន្តែសមាជិក២០០នាក់របស់បក្សនិងពួកនិរទេសខ្លួនមួយក្តាប់តូចព្រមទាំងអ្នកបែកគំនិតប្រឆាំងខ្មែរក្រហម

ដែលគ្មានបទពិសោធន៍ ហើយដែលរួមបង្កើតជាក្រុមប្រឹក្សាបដិវត្តន៍នោះពុំមានសមត្ថភាពគ្រប់គ្រាន់នឹងបំពេញភារកិច្ចដែលរង់ចាំពួកគេទេ ៖ ធ្វើឲ្យប្រជាជាតិរស់ឡើងវិញ និងផ្តល់ឲ្យប្រជាជនដែលងើបពីសុបិនអាក្រក់នូវជីវភាពមួយប្រហាក់ប្រហែលពីមុន ។ ម្យ៉ាងទៀត ពួកគេពុំអាចសង្ឃឹមការពាររបបថ្មីតែម្នាក់ឯងប្រឆាំងទល់នឹងកងទ័ពរបស់ខ្មែរក្រហមបានឡើយ ។ ការបំបាត់បណ្តាសមាជិកអ្នកមានវិជ្ជាជីវៈសេរី និងការរាវែកមិនបម្រើរបបកុម្មុយនីស្តមួយទៀតរបស់អ្នកដែលរួចផុតពីគ្រោះថ្នាក់ បានធ្វើឲ្យការស្តារប្រទេសឡើងវិញជួបការលំបាករឹតតែខ្លាំងឡើង ។

មន្ត្រីរដ្ឋការនិងអ្នកបច្ចេកទេសវៀតណាមរាប់ពាន់នាក់ ត្រូវបានគេណ្ឌប្រមូលដើម្បីរៀបចំស្តារប្រព័ន្ធទឹកនិងអគ្គិសនី ជួសជុលផ្លូវរទេះភ្លើងឲ្យមានដំណើរការឡើងវិញ និងបើកឱសថាល័យជាច្រើនកន្លែង ដែលមានគ្រូពេទ្យនិងគិលានុបដ្ឋាកវៀតណាមជាច្រើននាក់នៅធ្វើការជាមួយគ្រូពេទ្យខ្មែរមួយក្តាប់តូច ។ គេបានបង្កើតទីស្តីការក្រសួងនានាដោយមានសុទ្ធតែទីប្រឹក្សាវៀតណាមជាអ្នកចាំញាក់ខ្សែពីខាងក្រោយឆាក ។ ជនជាតិខ្មែររាប់រយនាក់ត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម ដើម្បីបន្តការបណ្តុះបណ្តាលថែមទៀតខាងផ្នែកវេជ្ជសាស្ត្រសិក្សាធិការ ធនាគារ ពាណិជ្ជកម្មអន្តរជាតិនិងសន្តិសុខ ។

ប្រាក់កាសត្រូវបានដាក់ឲ្យប្រើជាថ្មីនៅកម្ពុជាក្នុងឆ្នាំ១៩៨០ បន្ទាប់ពីរយៈកាលមួយដែលជំនួញតូចតាចប្រព្រឹត្តទៅលើមូលដ្ឋាននៃការដោះដូរគ្នារវាងអង្ករនិងមាស ។ ដោយសារការរត់ពន្ធមួយដែលមានលក្ខណៈធំធេងនៅតាមព្រំដែនថៃ ទីផ្សារនានារបស់កម្ពុជាត្រូវបានបំពេញដោយគ្រឿងសម្ភារៈចាំបាច់ជាគ្រឿងឧបភោគ-បរិភោគជាថ្មី ។ ជំនួយអន្តរជាតិដ៏សន្ធឹកសន្ធាប់បានបញ្ចៀសគ្រោះទុរ្ភិក្ស ។ កុមារាកុមារីកម្ពុជាបានធ្វើដំណើរចូលសាលារៀនឡើងវិញ ។ គេក៏ឃើញមានថ្នាំពេទ្យជាច្រើនមុខនៅតាមមន្ទីរពេទ្យនានា ។ ដំណើររស់ឡើងវិញនៅកម្ពុជា ដូចដែលខ្ញុំ(អ្នកនិពន្ធ) បានសម្គាល់ឃើញក្នុងរយៈពេលប្រាំមួយឆ្នាំគឺទុកថាជាអព្ភូតហេតុមួយ ។ នេះប្រៀបដូចជាសត្វហ្វេនិច(*phénix*) –បក្សីម្យ៉ាងក្នុងរឿងព្រេងដែលគេដុតរំលាយហើយអាចរស់ឡើងវិញបាន- កម្ពុជាបានរស់ឡើងវិញពីផេះផង់របស់ខ្លួន ។ វៀតណាមបានផ្តល់ឲ្យកម្ពុជានូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយ ហើយបានទទួលគុណប្រយោជន៍ពីជំនួយអន្តរជាតិដ៏សប្បុរសមួយថែមទៀត ប៉ុន្តែ មុនអ្វីៗទាំងអស់គឺកម្លាំងផ្លូវចិត្តនិងភាពស៊ិតស្វាញក្នុងការងាររបស់ជនជាតិខ្មែរដែលត្រូវតែធ្វើឲ្យប្រទេសជាតិខ្លួនរស់ឡើងវិញ ។

វាងាយស្រួលណាស់ដើម្បីធ្វើឲ្យប្រទេសកម្ពុជារស់ឡើងវិញ ជាងនាំមកនូវដំណោះស្រាយមួយចំពោះបញ្ហាអនាគតនយោបាយរបស់ខ្លួន ។ ក្នុងពេលដែលប្រជាជនកម្ពុជាជាប់រវល់នឹងកិច្ចការរបស់ខ្លួន ដោយខំប្រឹងរៀបចំការរស់នៅឡើងវិញ ក្រុងហាណូយក៏ប្រមូលផ្តុំកិច្ចប្រឹងប្រែងទាំងអស់របស់គេក្នុងការពង្រឹងការត្រួតត្រារបស់ខ្លួនលើប្រទេសកម្ពុជាតាមរយៈរដ្ឋថ្មីរបស់ខ្មែរ រដ្ឋាភិបាល និងបណ្តាស្ថាប័នបក្សរបស់របបនេះដែរ ។

## “បើភ្នំពេញរលំ ព្រៃនគរក៏នឹងរលាយដែរ...”

រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានអនុម័តនៅនិទាឃរដូវឆ្នាំ១៩៨១ ។ បន្ទាប់មកគឺការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាជាតិចំនួន១១៧រូប ក្នុងចំណោមបេក្ខជន១៤៨រូប ។ បេក្ខជនឈរឈ្មោះទាំងនោះគឺ អតីតខ្មែរក្រហមឬខ្មែរឥស្សរៈ ប៉ុន្តែ ក៏មានបញ្ញវន្តរួចផុតពីគ្រោះថ្នាក់នៃរបបដែលត្រូវដេញចេញពីអំណាចដែរ បានបង្កើតការប្រមូលផ្តុំគ្នាយ៉ាងគួរឲ្យឆ្ងល់មួយ ហើយការរួបរួមគ្នានេះគឺដោយសារតែពួកគេមានគំនិតប្រឆាំងនឹងរបប ប៉ុល ពត ដូចគ្នាប៉ុណ្ណោះ ។ ដូចដែលលោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេសបានបកស្រាយថា ការបោះឆ្នោតនេះ គឺមានគោលដៅ“ជ្រើសរើសមនុស្សពុំមែនជ្រើសរើសមាគ៌ានយោបាយមួយទេ ។ មាគ៌ានយោបាយយើងបានជ្រើសរើសរួចហើយដោយបង្ហូរឈាមរបស់យើង”[៧] ។ ពិតហើយ អ្នកគាំទ្ររបបថ្មីបានទទួលសំឡេងឆ្នោតគាំទ្រទាំងអស់ជាង៩៩ភាគរយ ។

បន្ទាប់ពីការបោះឆ្នោត មហាសន្និបាតបក្សមួយបានប្រារព្ធធ្វើឡើងក្នុងខែមករា ឆ្នាំ១៩៧៩ នៅមេមត់ ដែលបង្ហាញឲ្យឃើញពីការរៀបចំអង្គការរបស់ខ្លួនជាថ្មី ។ បក្សថ្មីដែលប្រសិទ្ធនាមឡើងវិញថា បក្សប្រជាជនបដិវត្តន៍កម្ពុជានិងមានសមាជិក៨០០នាក់ តាមពិតគឺជាក្រុមថ្មីមួយនៃផ្នែកស្និទ្ធវៀតណាមរបស់បក្សកុម្មុយនិស្តកម្ពុជាដែលត្រូវកម្ចាត់ស្ទើរតែទាំងស្រុងដោយ ប៉ុល ពត[៨] ។ មេដឹកនាំបក្សនេះជាមនុស្សម៉ឺងម៉ាត់និងស្គមកំព្រឹងម្នាក់ឈ្មោះ ប៉ែន សុវណ្ណ ជាខ្មែរឥស្សរៈនិរទេសខ្លួនដែលទើបត្រឡប់ពីក្រុងហាណូយមកវិញ ។ បក្សថ្មីបាននាំមកវិញនូវឯកភាពប្រជាជនឥណ្ឌូចិនដែល ប៉ុល ពត មានបំណងបំបែកបំបាក់ ។ ដោយផ្ទុយពី ប៉ុល ពត ដែលមិនទទួលស្គាល់“ចំណងជាបងប្អូន”នឹងវៀតណាម ប៉ែន សុវណ្ណ បានទទួលស្គាល់ថា បក្សប្រជាជនបដិវត្តន៍កម្ពុជានឹងធ្វើឲ្យប្រពៃណីដ៏ថ្លៃថ្នូររបស់បក្សកុម្មុយនិស្តឥណ្ឌូចិនដែលបង្កើតឡើង ដោយ ហូជីមិញ ស្ថិតស្ថេរចីរកាលតទៅ ។ កិច្ចប្រឹងប្រែងសំខាន់បំផុតមួយក្នុងចំណោមកិច្ចប្រឹងប្រែងសំខាន់ៗរបស់វៀតណាមនៅកម្ពុជា ស្ថិតនៅត្រង់ការពារបក្សប្រជាជនបដិវត្តន៍កម្ពុជា - ហើយជាពិសេសការពារសមាជិកថ្មីៗរបស់បក្សនេះ - ប្រឆាំងនឹងគ្រោះថ្នាក់ផ្សេងៗដែលពួកគេហៅថា “ជាតិនិយមចង្អៀតចង្អល់” និងការប៉ុនប៉ងដោះខ្លួនពីសាមគ្គីភាពរបស់ឥណ្ឌូចិន ។ ដើម្បីរ៉ាប់រងពីភាពបរិសុទ្ធផ្នែកមនោគមវិជ្ជារបស់បក្សថ្មី ទីប្រឹក្សាវៀតណាមជាច្រើននាក់បានពិនិត្យពាក្យស្នើសុំចូលបក្សនៅថ្នាក់ភូមិភាគ ហើយអ្នកសុំកន្លែងធ្វើការសុទ្ធតែត្រូវបញ្ជូនជាបន្ទាប់ទៅប្រទេសវៀតណាម ដើម្បីបំពេញការសិក្សាខាងផ្នែកនយោបាយ[៩] ។

ការត្រួតត្រាប្រទេសកម្ពុជាខាងផ្នែកយោធា គឺជាបន្ទុកនៃអង្គភាពទ័ពលេខ៤របស់វៀតណាមដែលតាមធម្មតាទទួលបន្ទុកមើលខុសត្រូវនៅតាមបណ្តាខេត្តនៃដែនដីសណ្តទន្លេមេគង្គប្រទេសវៀតណាមឯណោះ ។ ទីស្តីការក្រសួងការពារប្រទេសមួយត្រូវបានបង្កើតឡើង ។ កងពលធំរបស់ខ្មែរចំនួនបីបានជ្រើសរើសមនុស្សឲ្យចូលធ្វើកងទ័ព[១០] ហើយបានដាក់ពង្រាយចាប់តាំងពីឆ្នាំ១៩៨៣ ក្នុងឋានៈជាទ័ពជំនួយ ។ ប៉ុន្តែគឺកងទ័ពរបស់

វៀតណាមនិងទាហានចំនួន១៤០.០០០នាក់របស់ឧត្តមសេនីយ៍ ឡេ ឌឹកអាញ់ ជាមេបញ្ជាការអង្គភាពទ័ពលេខ៤ ដែលជាអ្នករ៉ាប់រងការការពាររបបថ្មីទាំងស្រុង ។

ក្នុងសភាពលាក់ការណ៍ គឺអង្គភាពបីរបស់វៀតណាមជាអ្នកក្តាប់សភាពការណ៍របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា-នេះជាឈ្មោះរបស់រដ្ឋថ្មី ។ នៅថ្នាក់លើបំផុតគឺក្រុមអា-៤០ (A-40) រួមមានសមាសភាពសុទ្ធតែអ្នកជំនាញការនៃគណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្តវៀតណាម សម្រាប់រ៉ាប់រងទំនាក់ទំនងរវាងបក្សទាំងពីរនិងផ្តល់ការណែនាំលើបញ្ហាធំៗទាំងអស់ ។ បន្ទាប់មកគឺក្រុមបេ-៦៨ (B-68) ដឹកនាំដោយ ត្រាន់ ស៊ិនបាច់ ជាសមាជិកលេខាធិការដ្ឋានបក្សកុម្មុយនីស្តវៀតណាម និងរួមមានសមាសភាពសុទ្ធតែអ្នកជំនាញការវៀតណាមថ្នាក់អន្តរការី ត្រូវបានចាត់ឲ្យទៅចូលរួមធ្វើការងារអមក្រសួងនានារបស់កម្ពុជាដោយសហការគ្នាសម្រេចទៅលើបញ្ហាផ្សេងៗប្រចាំថ្ងៃ ។ ក្រុមទីបីដែលមានសុទ្ធតែទីប្រឹក្សាគឺក្រុមអា-៥០ (A-50) ជាអ្នកជួយខាងផ្នែករដ្ឋបាលនៅគ្រប់ខេត្ត[១១] ។

នៅថ្នាក់ខេត្តនិងតំបន់ជនបទទាំងឡាយ គឺត្រូវគ្រប់គ្រងមួយចំណែកដោយពួកទីប្រឹក្សាស៊ីវិលដែលមកពីបណ្តាខេត្តជា«បងប្អូន»នៅប្រទេសវៀតណាម ។ នៅថ្នាក់មូលដ្ឋានគឺក្រុមពិសេសដែលចេញមកពីកងទ័ពវៀតណាម និងដែលដឹកនាំបញ្ជាដោយពួកអនុសេនីយ៍ឯកជាអ្នករ៉ាប់រងមុខងារជាទីប្រឹក្សា[១២] ។

ចាប់តាំងពីមានការឈ្លានពាននិងការកាន់កាប់ប្រទេសកម្ពុជា វៀតណាមបានរិះរកមូលហេតុប្រសើរៗដោយខ្លួនឯងមិនឈប់ ដើម្បីបង្កើតសម្ពន្ធ័ភាពឥណ្ឌូចិនមួយ ។ វៀតណាមបានបង្កើតច្បាប់មួយប្រភេទដែលមិនបេះប្រែផ្លាស់ តម្រូវទៅតាមភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ ។ គេអាចយល់ផ្ទុះនូវអត្ថបទដ៏សំខាន់មួយរបស់ឧត្តមសេនីយ៍ ឡេ ឌឹកអាញ់ ដែលនិយាយថា «ក្នុងអំឡុងពេលជាច្រើនសតវត្សរ៍មកហើយ ប្រទេសទាំងបី ឡាវ កម្ពុជា វៀតណាម បានរួមសុខទុក្ខក្នុងស្ថានភាពមួយដូចគ្នា : ស្ថានភាពជាអ្នករងគ្រោះពីអំពើឈ្លានពានរបស់កងទ័ពសក្តិភូមិចិន ចក្រពត្តិនិយម និងកម្លាំងប្រតិកិរិយាអន្តរជាតិ» ។ បំបែកបំបាក់ប្រទេសទាំងបីនេះដោយប្រើប្រាស់ប្រទេសមួយជាឈ្នាន់ ដើម្បីភ្ជាប់ប្រទេសមួយទៀតជារណប ហើយនៅទីបំផុត ភ្ជាប់ប្រទេសទាំងបីជារណបតែម្តង «នេះហើយជាគោលការណ៍នៃសង្គ្រាមឈ្លានពានទាំងអស់ ដែលប្រព្រឹត្តឡើងដោយកម្លាំងខាងក្រៅប្រឆាំងនឹងឧបទ្វីបឥណ្ឌូចិន» ។ ដោយហេតុនេះ ការបង្កើត«សម្ព័ន្ធជាយុទ្ធសាស្ត្រមួយរវាងប្រទេសឥណ្ឌូចិនទាំងបីជារឿងចាំបាច់ខានមិនបានសម្រាប់ការគង់វង្ស និងការរីកលូតលាស់របស់ប្រទេសនីមួយៗ និងឥណ្ឌូចិនទាំងមូល»[១៣] ។

គេបានបង្ហាញពីទាហានវៀតណាមដែលកំពុងស្លាប់ដោយសារជំងឺគ្រុនចាញ់នៅប្រទេសកម្ពុជា របួសនិងដាច់ដៃដាច់ជើងក្នុងការពួនស្ទាក់វាយប្រហាររបស់ខ្មែរក្រហម និងរបៀបបកស្រាយលម្អិតមួយអំពី«ច្បាប់»នេះ ។ ពួកនាយទាហានរបស់គេបានបំភ្លឺពីមូលហេតុនៃវត្តមានរបស់ខ្លួននៅប្រទេសវៀតណាមដូច្នេះថា «បើ

*ភ្នំពេញរលំព្រៃនគរក៏នឹងរលាយដែរ ។ បើយើងត្រូវស្លាប់ក្នុងការប្រយុទ្ធ គឺស្លាប់នៅទីនេះ ប្រសើរជាងស្លាប់នៅប្រទេសវៀតណាម»[១៤] ។*

## ជ័យជម្នះផ្នែកយោធា បរាជ័យផ្នែកការទូត

*ដំណាក់កាលជាផ្លូវការដំបូងក្នុងការចាត់តាំងសម្ពន្ធ័ភាពឥណ្ឌូចិននេះ បានកើតមាននៅខែមករា ឆ្នាំ ១៩៨០ ។ បណ្ដារដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងបីដែលរួមប្រជុំនៅក្រុងភ្នំពេញបានប្រកាសជាសាធារណៈនូវភាពដូចគ្នាខាងទស្សនៈស្ដីពីបញ្ហារបស់កម្ពុជា និងបញ្ហាអន្តរជាតិផ្សេងៗទៀត ។ តាំងពីនោះមក បែបផែននៃសម័យប្រជុំនេះបានប្រព្រឹត្តធ្វើឡើងវិញពីរដងក្នុងមួយឆ្នាំ រាល់ការប្រជុំមួយលើកៗគឺជាឱកាសបង្ហាញឲ្យឃើញពីការប្រកាន់យកជំហរចុងក្រោយរបស់ក្រុងហាណូយដែលហាក់ដូចជាចេញមកពីក្រុមឥណ្ឌូចិនទាំងមូល ។ ដូច្នេះ ក្រុងហាណូយបានធ្វើឲ្យតួនាទីជាមេដឹកនាំរបស់ខ្លួននៅឥណ្ឌូចិនទៅជាផ្លូវការពង្រឹងភាពស្របច្បាប់ដល់របបរណបក្រុងភ្នំពេញឲ្យរឹតតែរឹងមាំឡើង និងធ្វើឲ្យមានការចាប់អារម្មណ៍ថា សម្ពន្ធថ្មីនេះមិនអាចប្រែក្រឡាស់បានឡើយ ។ នៅឆ្នាំ១៩៨០ ក្រុងហាណូយបានចាប់ផ្ដើមពង្រីកទស្សនៈប្លុកពីរនៅអាស៊ីអាគ្នេយ៍ គឺឥណ្ឌូចិននិងសមាគមអាស៊ានដោយបំបាត់គំនិតដែលថា វៀតណាមអាចមាននាទីមួយក្នុងការរៀបចំនេះក្នុងនាមនៃកម្ពុជាជារដ្ឋទ្រនាប់មួយ ។ ង្វៀន កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមបានថ្លែងប្រាប់លោក សិទ្ធិ សាវេត ស៊ីឡា ជាសមភាគីថៃរបស់គាត់ថា "ខ្ញុំពុំត្រូវការថា ប្រទេសមួយនៃសមាគមអាស៊ានក្លាយទៅជារដ្ឋទ្រនាប់មួយឡើយ" ។ ដូច្នេះ "មានតែលោកចង់ឲ្យប្រទេសមួយក្នុងចំណោមប្រទេសទាំងបីនៅឥណ្ឌូចិនទៅជាប្រទេសតែមួយ?"[១៥] ។*

*ក្រុងហាណូយមិនត្រឹមតែស្វែងរកសន្តិសុខសម្រាប់ប្លុកនយោបាយមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ស្វែងរកការធ្វើសមាហរណកម្មខាងផ្នែកសេដ្ឋកិច្ចផងដែរ ក្នុងគោលបំណង"បែងចែកហត្ថពលករដោយស្មើភាពគ្នា និងប្រើប្រាស់ប្រភពធនធានមនុស្ស និងធនធានធម្មជាតិរបស់ប្រទេសទាំងបីឲ្យអស់លទ្ធភាព"[១៦] ។ ចំពោះប្រទេសវៀតណាមដែលមានផ្ទៃដីដាំដុះប្រាំមួយលានហិកតាសម្រាប់ប្រជាជន៦០លាននាក់នៅឆ្នាំ១៩៨៥ ប្រទេសកម្ពុជាដែលមានប្រជាជនជិត(៧លាននាក់) ជាមួយផ្ទៃដីដាំដុះមួយលានហិកតាកន្លះ និងតំបន់នេសាទ ដែលសម្បូរទៅដោយត្រីច្រើនបំផុតនោះ បានចាប់ផ្ដើមប្រមើលមើលអនាគតដែលមិនអាចមិនយកចិត្តទុកដាក់បានឡើយ[១៧] ។*

*ក្នុងខ្សែបន្ទាត់នយោបាយដែលចាប់ផ្ដើមជាមួយការចុះហត្ថលេខាលើសន្ធិសញ្ញាឡាវ-វៀតណាម នៅឆ្នាំ ១៩៧៧ បណ្ដាខេត្តរបស់ប្រទេសឡាវនិងកម្ពុជាបានត្រូវគេកំណត់ឲ្យធ្វើសម្ពន្ធ័មេត្រីជាមួយ "បណ្ដាខេត្តជាបងប្អូន" នៅប្រទេសវៀតណាម ។ ដោយអនុលោមទៅតាមការធ្វើសម្ព័ន្ធមេត្រីភាពនេះ ពួកទីប្រឹក្សា ពួកជំនាញការបច្ចេកទេស និងពួកគ្រូពេទ្យរបស់វៀតណាមបានមកកាន់បណ្ដាខេត្តជាបងប្អូននៅកម្ពុជា និងនៅប្រទេសឡាវយ៉ាងច្រើន ដើម្បីសហការក្នុងគម្រោងការតូចៗដោយចូលរួមក្នុងការបង្កើតឲ្យមានទំនាក់ទំនងពិសេសរវាង*

ប្រទេសទាំងបីនៅឥណ្ឌូចិន ។

គណៈកម្មាធិការសេដ្ឋកិច្ចរួមមួយរវាងវៀតណាម ឡាវ កម្ពុជា បានត្រូវរៀបចំបង្កើតក្នុងសន្និសីទកំពូលមួយរវាងប្រទេសទាំងបីនៅឥណ្ឌូចិននាទីក្រុងវៀងចន្ទន៍ក្នុងខែកុម្ភៈ ឆ្នាំ១៩៨៣ ។ គណៈកម្មាធិការនេះ ដែលមានសុទ្ធតែរដ្ឋមន្ត្រីសេដ្ឋកិច្ច និងផែនការត្រូវរួមប្រជុំពីរដងក្នុងមួយឆ្នាំ «ដើម្បីបង្កើនល្បឿនសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងការសម្របសម្រួលផែនការអភិវឌ្ឍន៍ជាតិ»[១៨] ។ ក្នុងប្រទេសនីមួយៗគណៈកម្មាធិការជាតិសម្រាប់សហប្រតិបត្តិការផ្នែកវប្បធម៌និងសេដ្ឋកិច្ចត្រូវបង្កើតឡើង ដែលពីដំបូងត្រូវមានតួនាទីសម្រាប់ពិគ្រោះឬឲ្យយោបល់ប៉ុណ្ណោះ ។ ប៉ុន្តែក្រុងហាណូយបានបញ្ជាក់ឲ្យដឹងភ្លាមថា «គោលបំណងយូរអង្វែងរបស់ខ្លួន គឺបង្រួបបង្រួមប្រទេសទាំងបី និងធ្វើឲ្យសម្រេចពិតប្រាកដនូវសមាហរណកម្មខាងផ្នែកសេដ្ឋកិច្ចរបស់គេ»[១៩] ។

មុនរដ្ឋប្រហារឆ្នាំ១៩៧០ នៅប្រទេសកម្ពុជាមានអាណិកជនវៀតណាមរស់នៅចំនួន៥០ម៉ឺននាក់ ហើយត្រូវសម្លាប់យ៉ាងរង្គាលក្នុងចលនាបំបាត់ជាតិសាសន៍វៀតណាមដោយរបប លន់ នល់ និងក្រោយមករបប ប៉ុល ពត ឬត្រូវបណ្តេញចេញពីប្រទេសកម្ពុជាតែម្តង ។ វៀតណាមបានទាញយកទឡ្ហីករណ៍នេះ ដើម្បីបង្ហាញឲ្យឃើញថា ការវិលត្រឡប់របស់ខ្លួនពិតជាត្រឹមត្រូវ ។ ក្នុងឋានៈជានិគមជនថ្មី វៀតណាមអាចសម្តែងតួនាទីគន្លឹះមួយតាមកាលកំណត់ក្នុងការធ្វើសមាហរណកម្មផ្នែកសេដ្ឋកិច្ចដែលបានគ្រោងរួចមកហើយ ។ សារាចរមួយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីចុះកាលបរិច្ឆេទខែឧសភា ឆ្នាំ១៩៨២ បានចែងច្បាស់ថា ប្រជាជនវៀតណាមដែលមកដល់ប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៩ ហើយ«កំពុងប្រកបមុខរបរផ្សេងៗដែលរួមវិភាគទានជួយដល់ការធ្វើឲ្យមាននីតិសម្បទាឡើងវិញ និងដល់ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យកសិកម្ម នេសាទ ការផលិតអំបិល និងសិប្បកម្ម» នឹងត្រូវអនុញ្ញាតឲ្យស្ថិតនៅទីនេះដើម្បីបំពេញការងារ[២០] ។ បើទុកជាដឹងថា ការហូរជន់ដោរគ្មានអ្នកណាត្រួតត្រារបស់វៀតណាមមកក្នុងប្រទេសកម្ពុជាអាចបង្កឲ្យមានសម្ពប់ជាប្រពៃណីរបស់ប្រជាជនខ្មែរប្រឆាំងប្រទេសជិតខាងខ្លួន និងបង្កឲ្យមានភាពតានតឹងខ្លះៗក៏ដោយ ក៏វៀតណាមពុំភ្លេចថា មួយផ្នែកនៃប្រជាជនខ្លួនបានទៅជាអ្នកស៊ីឈ្នួលនៅប្រទេសកម្ពុជា និងកាន់កាប់តំណែងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសនេះ ដែលរួមបង្កជាអត្ថប្រយោជន៍មួយមិនអាចរំលងបាន ។ អ្នកបង្អាប់គុណូបការៈរបស់ក្រុងហាណូយបានចោទប្រកាន់ថាបានអនុវត្តនយោបាយ ដែលគិតទុកជាមុនមួយក្នុងការដាក់បញ្ចូលប្រជាជនវៀតណាមឲ្យមករស់នៅកម្ពុជា ។ វាអាចថានេះជាដំណើរមានឡើងវិញនូវរូបភាពជាប្រវត្តិសាស្ត្រមួយដែលគេដឹងជាយូរមកហើយ ៖ ការស្វែងតាំងទីនៅប្រទេសផ្សេងដោយខ្លួនឯងរបស់ប្រជាជនវៀតណាមឆ្ពោះទៅកាន់តំបន់ផ្សេងៗដែលមានប្រជាជនតិច ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលដែលបានមកគឺការពង្រឹងការកាន់កាប់របស់វៀតណាមលើប្រទេសកម្ពុជាឲ្យរឹតតែរឹងមាំឡើងទៀត ។ នៅឆ្នាំ១៩៨៥ តាមការវាយតម្លៃរបស់អ្នកប្រជាសាស្ត្រលោកខាងលិចដ៏ឆ្នើមម្នាក់បានឲ្យដឹងថា មានប្រជាជនស៊ីវិលវៀតណាមចំនួនជាង១៧៥.០០០នាក់បានមកតាំងលំនៅនៅ

ប្រទេសកម្ពុជា ៖ ក្នុងចំណោមនោះមានអតីតអ្នកធ្លាប់រស់នៅកាលពីដើមពួកនិគមជនថ្មីដែលគ្មានដីធ្លី(នៅវៀតណាម) ពួកអ្នកជំនួញ និងទាហានដែលរំសាយឲ្យមកកាន់ជីវភាពជាស៊ីវិលវិញ[៧១] ។ ការវាយតម្លៃផ្សេងៗទៀត ឈានរហូតដល់ទៅអះអាងថា មាន៦០០.០០០នាក់ឯណោះ[៧២] ។

ក្នុងពេលដែលកងទ័ព និងពួកទីប្រឹក្សាស៊ីវិលប្រើងប្រែងពង្រឹងរបបថ្មីរបស់កម្ពុជា ក្រុងហាណូយបានប្រើប្រាស់ឥទ្ធិពលផ្នែកការទូតទាំងអស់របស់ខ្លួន ដើម្បីធ្វើឲ្យមានការទទួលស្គាល់ជាអន្តរជាតិចំពោះសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ។ ការថ្កោលទោសជាឯកច្ឆ័ន្ទចំពោះការចូលឈ្លានពានរបស់វៀតណាមនិង ការដាក់ទណ្ឌកម្មដែលបន្តឡើងដោយការឈ្លានពាននេះ បានធ្វើឲ្យការទទួលស្គាល់ភាពស្របច្បាប់នៃរបបថ្មីក្លាយទៅជាអាទិភាពដាច់ខាតមួយនៃនយោបាយបរទេសរបស់វៀតណាម ។ ក្នុងគោលដៅនេះ ក្រុងហាណូយចូលចិត្តផ្តោតការចោទប្រកាន់ខាងផ្លូវសីលធម៌និងស្របច្បាប់ ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ជាជាងលើកឡើងពីគុណសម្បត្តិរបស់រដ្ឋាភិបាលដែលខ្លួនបានលើកបន្តុបឡើង ។

បណ្តាប្រទេសដំបូងៗដែលទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជាជាផ្លូវការ គឺស្ថិតក្នុងប្លុកសូវៀតចំនួនដប់មួយប្រទេស និងអង្គការស្និទ្ធសូវៀតជាច្រើនក្នុងចំណោម៨៨អង្គការដែលមានក្នុងចលនាមិនចូលបក្សសម្ព័ន្ធ ។ បណ្តាមិត្តភក្តិរបស់ក្រុងហាណូយពុំបានសម្រេចជោគជ័យក្នុងការបណ្តេញកម្ពុជាប្រជាធិបតេយ្យចេញពីចលនានេះបានទេ ប៉ុន្តែ នៅទីបំផុតប្រទេសវៀតណាមបានសម្រេចបំបិទមាត់ខ្មែរក្រហមមិនឲ្យនិយាយបាននៅក្នុងសន្និសីទមួយ ដោយការប្រើមធ្យោបាយការទូតយ៉ាងខ្លាំងក្លា ។ ការិយាល័យសម្របសម្រួលរបស់ចលនាមិនចូលបក្សសម្ព័ន្ធ ដែលរួមប្រជុំនៅទីក្រុងកូឡុំបូ(រដ្ឋធានីប្រទេសស្រីលង្កា) នាខែមិថុនា ឆ្នាំ១៩៧៩ បានបដិសេធមិនយល់ព្រមតាមពាក្យស្នើសុំរបស់វៀតណាមឡើយ ៖ ដូច្នេះពុំមែន ហ៊ុន សែន រដ្ឋមន្ត្រីការបរទេសវ័យក្មេងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាទេ ដែលនឹងត្រូវអង្គុយកៅអីនោះ ប៉ុន្តែគឺ អៀង សារី ជាសមភាគីរបស់គាត់នៃកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ហ៊ុន សែន ទទួលបានលក្ខខណ្ឌមួយ គឺគាត់អាចស្ថិតនៅក្នុងសាលប្រជុំបានតែពុំមានសិទ្ធិឡើងនិយាយនៅលើវេទិកាឡើយ ។ លោក ហ៊្វីដែល កាស្ត្រូ មេដឹកនាំថ្មីរបស់ចលនានេះគឺជាអ្នកបញ្ចប់រឿង«កៅអី»កម្ពុជានៅក្នុងសម័យប្រជុំកំពូលនៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងឡាហាវ៉ាន នាខែកញ្ញា ឆ្នាំ១៩៧៩ ។ ខៀវ សំផន ប្រធានរដ្ឋាភិបាល ដែលត្រូវដេញចេញពីអំណាច បានទទួលទិដ្ឋាការឲ្យចូលប្រទេសគុយបាជាធម្មតា ប៉ុន្តែ គណៈប្រតិភូរបស់គាត់ត្រូវបានគេដាក់ឲ្យសម្រាកនៅសណ្ឋាគារមួយមានចម្ងាយ៣០គីឡូម៉ែត្រពីវិមានសម្រាប់ធ្វើសន្និសីទដោយគ្មានមធ្យោបាយដឹកជញ្ជូនសម្រាប់ទុកឲ្យគណៈប្រតិភូគាត់ប្រើប្រាស់ឡើយ ។ ម្យ៉ាងទៀត គេពុំផ្តល់ប័ណ្ណសម្គាល់ សម្រាប់ពាក់ជាប់នឹងអាវដែលត្រូវតែមានជាចាំបាច់ខានមិនបាន ដើម្បីមានសិទ្ធិចូលទៅក្នុងសាលប្រជុំផងទេ ។ បើទោះជាមានការប្រឆាំងជំទាស់ពីបណ្តាគណៈប្រតិភូនៃសមាគមអាស៊ានក៏ដោយ ក៏កៅអីរបស់កម្ពុជាបានត្រូវប្រកាសដាក់ឲ្យនៅទំនេរសិន ។ ខៀវ សំផន នៅតែ

ស្ថិតនៅទីនោះជានិច្ច ។

នៅអង្គការសហប្រជាជាតិ គេមិនអាចប្រើប្រាស់កលខបាយដូចនោះបានទេ ហើយសិទ្ធិវ៉េតូមួយរបស់សូវៀត ក៏ពុំគ្រប់គ្រាន់រារាំងការទទួលស្គាល់រដ្ឋណាមួយដោយអង្គការអន្តរជាតិនេះដែរ ។ ក្នុងសម័យប្រជុំនៃមហាសន្និបាតអង្គការសហប្រជាជាតិនៅខែកញ្ញា ឆ្នាំ១៩៧៩ វៀតណាមបានខំប្រឹងធ្វើឲ្យមានការបណ្តេញកម្ពុជាប្រជាធិបតេយ្យចេញពីអង្គការនេះដែរ ប៉ុន្តែគ្មានបានជោគជ័យ ។ ដោយមាន ៦ សំឡេង-ដែលមានសំឡេងសហរដ្ឋអាមេរិកដែរ-ទល់នឹង៣ គណៈកម្មាធិការពិនិត្យសារតាំងរបស់អង្គការសហប្រជាជាតិបានសម្រេចរក្សាទុកកៅអីឲ្យកម្ពុជាប្រជាធិបតេយ្យដដែល ។ ដូច្នេះ សហរដ្ឋអាមេរិកបានបោះឆ្នោតជាគុណប្រយោជន៍ដល់របបមួយ ដែលកាលពីមុនត្រូវលោកប្រធានាធិបតី ខាធ័រ ឲ្យឈ្មោះថា "របបដែលរំលោភសិទ្ធិមនុស្សធំជាងគេបំផុត" នៅលើពិភពលោកទៅវិញ ។ នេះជាការសម្រេចចិត្តដែលធ្វើឲ្យឈឺចាប់មួយសម្រាប់វ៉ាន់ស៍ ។ បោះឆ្នោតដើម្បីផ្តល់អាសនៈឲ្យ ប៉ុល ពត នឹងមិនមែនសម្តែងឲ្យឃើញនូវការគាំទ្រមួយចំពោះរបបនេះទេឬ? ហើយបោះឆ្នោតប្រឆាំងកម្ពុជាប្រជាធិបតេយ្យមានន័យថា ប្រឆាំងជំទាស់ចំពោះប្រទេសចិននិងសមាគមអាស៊ាន ហើយធ្វើឲ្យការឈ្លានពានរបស់វៀតណាមទៅជាស្របច្បាប់ទៅវិញ ។ ក្រោយមក អ្នកទទួលខុសត្រូវជាន់ខ្ពស់អាមេរិកាំងម្នាក់បានទទួលស្គាល់ថា : "ការជ្រើសរើសសម្រាប់យើងគឺ សំអាងលើគោលការណ៍សីលធម៌ និងច្បាប់អន្តរជាតិ ។ ការសម្រេចចិត្តត្រូវលំអៀងទៅរកច្បាប់ ពីព្រោះនេះក៏ជាផលប្រយោជន៍សម្រាប់សន្តិសុខយើងដែរ" ។ ប៉ុន្តែតាមរយៈការបោះឆ្នោតដែលព្រហ្មលិខិតគម្រូវនេះ គឺសហរដ្ឋអាមេរិកបានគាំទ្រឃាតករមួយក្រុមដែលពួកមន្ត្រីរដ្ឋការអាមេរិកាំងពុំមានសិទ្ធិចាប់រលាក់ដៃពួកនេះផងទេ[២៣] ។

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៩ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានបោះឆ្នោតអនុម័តរបាយការណ៍របស់គណៈកម្មាធិការពិនិត្យសារតាំងដោយ ៧១សំឡេងយល់ព្រម ៣៥សំឡេងប្រឆាំង និង៣៤សំឡេងអនុបវាទ ។ នៅលើកម្រាលពណ៌បៃតងនិងពណ៌មាសនៃទីស្នាក់ការអង្គការសហប្រជាជាតិ ដែលការវាយលុកខាងយោធារបស់ប្រទេសវៀតណាមប្រឆាំងកម្ពុជាប្រជាធិបតេយ្យ ប្រហែលជាបរាជ័យនៅទីបំផុត ។ របប ប៉ុល ពត ប្រហែលនៅមានតែក្រុមកងទ័ពតូចៗដែលទ្រាំទ្រលំបាកនៅក្នុងព្រៃប៉ុណ្ណោះ : ហើយក៏ប្រហែលជាលែងត្រូវបានជ្រើសតាំងជាតំណាងស្របច្បាប់របស់ប្រជាជនកម្ពុជាទៀតដែរ ។ តាំងពីការបោះឆ្នោតនេះមក ការតស៊ូដើម្បីត្រួតត្រាប្រទេសកម្ពុជា បានចេញពីព្រៃស្បាតនៅតាមព្រំដែនខ្មែរ-ថៃមកសំដែងនៅក្រោមពិតានដ៏ល្អឆើតនៃមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក សង្កាត់ ម៉ាន់ហាតាន់ ក្នុងរយៈពេលពីរ-បីសប្តាហ៍ រៀងរាល់សរទរដូវ ។

ការជជែកតទល់គ្នានៅអង្គការសហប្រជាជាតិ ដើម្បីឲ្យមានការដកទ័ពរបស់វៀតណាមនិងដើម្បីផ្តល់សិទ្ធិស្វ័យសម្រេចឲ្យប្រជាជនខ្មែរ បានបង្កឲ្យមានការពួតដៃគ្នាដ៏ចម្លែកមួយ : ប្រជាជាតិជាងមួយរយប្រទេស

បានអះអាងនូវការគាំទ្ររបស់ខ្លួនចំពោះខ្មែរក្រហមជានិច្ច ដែលប្រទេសជាច្រើននៅក្នុងចំណោមនោះ នៅតែថ្កោលទោស និងបន្តថ្កោលទោសដដែល ។ ការណ៍ដែលថាអង្គការសហប្រជាជាតិចចេសទទួលស្គាល់កម្ពុជាប្រជាធិបតេយ្យ បណ្ដាលឲ្យផ្នែកការទូតរបស់វៀតណាមឯកោពីគេ ។ បរិយាកាសមានលក្ខណៈអនុគ្រោះដល់ការដាក់ទណ្ឌកម្មលើប្រទេសវៀតណាម និងការវាយសម្រុកតបតដោយយោធារបស់ចិន ។

## ការគន់គូររបស់ចិន

«មេរៀន»ផ្នែកយោធាដែលប្រទេសចិនផ្ដល់ឲ្យប្រទេសវៀតណាមនៅខែកុម្ភៈ ឆ្នាំ១៩៧៩ ពុំធ្វើឲ្យប៉ះពាល់ដល់ការប្ដេជ្ញាចិត្តក្នុងការស្ថិតនៅប្រទេសកម្ពុជារបស់ក្រុងហាណូយឡើយ ។ ទោះជាយ៉ាងណាក៏ដោយក៏ក្រុងប៉េកាំងជឿប្រាកដក្នុងចិត្តថា ដោយធ្វើការគាបសង្កត់ផ្នែកយោធាពេញទំហឹង(នៅតាមព្រំដែនចិន-វៀតណាមនិងនៅប្រទេសកម្ពុជា) ការធ្វើឲ្យផ្នែកការទូតឯកោនិងការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ចពីអន្តរជាតិ នៅទីបំផុតក្រុងហាណូយច្បាស់ជាត្រូវការសន្តិភាពមិនខាន ។ គោលដៅរបស់ប្រទេសចិនគឺលើកសម្ព័ន្ធមិត្ត ខ្មែរក្រហមរបស់ខ្លួនឲ្យកាន់អំណាចវិញ បើទុកជាពួកនេះលែងមានអ្វីដែលពួកគេត្រូវមានទាំងស្រុងក៏ដោយ ។ គោលដៅប្រហែលមានលក្ខណៈប្រាកដនិយមតិចតួចក្នុងរយៈពេលខ្លី ប៉ុន្តែគំនិតនៃការប្រយុទ្ធមួយតាមរយៈការប្រគល់សិទ្ធិប្រឆាំងនឹងប្រទេសវៀតណាម ពិតជាទាក់ទងគ្នាជាមួយនឹងគោលដៅផ្សេងៗរយៈពេលមធ្យមនៃនយោបាយការបរទេសរបស់ចិន ។ ការចូលឈ្លានពានប្រទេសអាហ្វហ្គានីស្ថាន (Afghanistan) ដោយពួកសូវៀតនៅខែធ្នូ ឆ្នាំ១៩៧៩ បានធ្វើឲ្យការប្រឆាំងសូវៀតរបស់ក្រុងប៉េកាំងកើនរឹតតែខ្លាំងឡើង ។ ចាប់ពីពេលនោះទៅ ប្រទេសចិនអាចប្រកាន់យកតួនាទី(ដែលខ្លួនមិនត្រូវមាន) ជាជើងឯកនៃឯករាជ្យភាពនិងអធិបតេយ្យភាពសម្រាប់ប្រទេសតូចទាំងពីរ និងជាអ្នករិះគន់ដល់អនុត្តរភាពរបស់សូវៀតនិងលទ្ធិវាតទីនិយមរបស់វៀតណាមផង ។ ដោយមានមូលហេតុត្រឹមត្រូវ ប្រទេសចិនសង្ឃឹមទៅលើការគាំទ្ររបស់លោកខាងលិចចំពោះកម្មវិធី ទំនើបភាវូបនីយកម្មរបស់ខ្លួនមិនខាន ។

ដោយមិនបញ្ឈរក់ពីរឿងនេះ ប្រទេសចិនភ័យខ្លាចយ៉ាងខ្លាំងអំពីរឿងដែលថា ដំណោះស្រាយឆាប់រហ័សនៃបញ្ហាកម្ពុជានឹងផ្ដល់ផលចំណេញលើសលប់ដល់ក្រុងហាណូយ ដូច្នេះហើយ ចិនពេញចិត្តទុកឲ្យរឿងនេះបន្ទាយពេលតទៅទៀត ។ ការធ្វើឲ្យរដ្ឋាភិបាលស្និទ្ធវៀតណាមមួយនៅក្រុងភ្នំពេញមានលក្ខណៈស្របច្បាប់ និងការពង្រឹងប្លុកឥណ្ឌូចិនក្រោមការដឹកនាំរបស់ក្រុងហាណូយ បានបណ្ដាលឲ្យក្រុងប៉េកាំងបាត់បង់ឥទ្ធិពលរបស់ខ្លួនក្នុងតំបន់ ។ ការដោះស្រាយជម្លោះ និងការបង្កើតទំនាក់ទំនងដ៏ល្អប្រសើររវាងក្រុងហាណូយនិងសមាគមអាស៊ាន ក៏នឹងធ្វើឲ្យទំនាក់ទំនងដ៏លំបាកដែលក្រុងប៉េកាំងបានចាប់ផ្ដើមធ្វើជាមួយសមាគមនេះត្រូវអន្តរាយផងដែរ ៖ ឥទ្ធិពលដែលវៀតណាមរៀបចំឲ្យមានឡើងយ៉ាងល្អនៅឥណ្ឌូចិន ប្រហែលនឹងបណ្ដាលឲ្យប្រទេសថៃ

*មិនសូវសម្តែងឲ្យឃើញលក្ខណៈសហប្រតិបត្តិការប៉ុន្មានឡើយ ។ បណ្តាប្រទេសផ្សេងទៀតនៃសមាគម អាស៊ាន ជាពិសេសប្រទេសឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីដែលកំពុងពិចារណាចំពោះអាណិកជនចិនក្នុងប្រទេសរបស់ខ្លួនជាមួយការមិនទុកចិត្តនិងកំពុងព្រឺខ្លាចលទ្ធិវាតទីនិយមរបស់ក្រុងប៉េកាំងនោះ នឹងធ្វើការជាមួយប្រទេសចិនដោយប្រុងប្រយ័ត្នបំផុត ។ ផ្ទុយទៅវិញ ការធ្វើឲ្យជម្លោះមួយនៅស្ថិតស្ថេរយូរអង្វែងដែលប្រទេសវៀតណាមនិងសហភាពសូវៀតត្រូវប្រឈមមុខនឹងប្រទេសផ្សេងៗនៃពិភពលោក បង្ហាញឲ្យឃើញអត្ថប្រយោជន៍មួយដែលមិនអាចកាត់ថ្លៃឲ្យត្រូវបាន ព្រោះវាធ្វើឲ្យប្រភពធនធានរបស់សហភាពសូវៀតខូចខាតអន្តរាយនិងធ្វើឲ្យប្រទេសវៀតណាមខ្សោះខ្សែ ។ ជាសាធារណៈ ប្រទេសចិនតម្រូវឲ្យប្រទេសវៀតណាមដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជា ប៉ុន្តែក្នុងការចរចាដ៏ស្មោះត្រង់ខុសប្លែកពីធម្មតាមួយ តេង ស៊ាវពីង បានស្តីបន្ទោសលោក ម៉ាសាយ៉ូឈី អូហ៊ីរ៉ា នាយករដ្ឋមន្ត្រីជប៉ុនពីការខ្វះអំណត់របស់ប្រទេសលោក ព្រមទាំងប្រទេសលោកខាងលិចដទៃទៀតដែលទាមទារឲ្យមានការដកកងទ័ពវៀតណាមឆាប់រហ័សពីកម្ពុជា ។ តេង បានប្រាប់រឿងអាថ៌កំបាំងឲ្យ អូហ៊ីរ៉ា ដឹងថា "ប្រទេសចិនមានផលប្រយោជន៍ទាំងស្រុងក្នុងការខំប្រឹងប្រែងធ្វើឲ្យវៀតណាមស្ថិតនៅប្រទេសកម្ពុជាតទៅទៀត ។ ការលំបាកផ្សេងៗរបស់ពួកគេនឹងកើនឡើង ហើយពួកគេនឹងលែងមានបំណងគំរាមកំហែងទៅលើប្រទេសថៃ ម៉ាឡេស៊ី និងសិង្ហបុរីទៀតផង"[៧៤] ។*

*ក្នុងឱកាសនៃការធ្វើសម្ភាសន៍មួយ ដែលគាត់បានអនុញ្ញាតឲ្យខ្ញុំ(អ្នកនិពន្ធ)ចូលជួបនាខែមេសា ឆ្នាំ ១៩៨០ ហាន នានឡុង អនុរដ្ឋមន្ត្រីការបរទេស និងជាអ្នកបង្កើតយុទ្ធសាស្ត្រឥណ្ឌូចិនដ៏ចម្បងរបស់ប្រទេសចិន បានពង្រីកការសំអាងហេតុផលដោយពាក្យពេចន៍ផ្សេងៗទៅវិញ ។ ការស្នើឲ្យវៀតណាមដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា គឺមិនសូវមានលក្ខណៈប្រាកដនិយមប៉ុន្មានទេ ។ "គេអាចគិតគូរពីដំណោះស្រាយនយោបាយមួយបានតែនៅពេលដែលពួកសូវៀតលែងអាចគាំទ្រវៀតណាមប៉ុណ្ណោះ" ។ សម្រាប់ពេលនេះ យើងមិនត្រូវធ្វើអ្វីដែលអាច"សម្រាលបន្ទុកដ៏ធ្ងន់របស់ពួកសូវៀតឡើយ" ។ "យើងត្រូវតែធ្វើឲ្យសូវៀតយល់ថា ពួកគេនឹងពុំអាចបន្តទ្រាំទ្របៀបនេះយូរទៅទៀតបានទេ ហើយយើងខំប្រមូលសាធារណមតិពិភពលោកឲ្យចូលរួមក្នុងន័យនេះដែរ ។ វាសំខាន់ណាស់ដែលត្រូវធ្វើឲ្យសូវៀតស្ថិតក្នុងស្ថានភាពនៅដាច់ពីគេឯងទាំងស្រុង"[៧៥] ។*

*ការវិវាទចិននិងវៀតណាមបានកម្រើកឡើងវិញជាថ្មីពេញរយៈពេលនៃរដូវក្តៅឆ្នាំ១៩៧៩ ។ នៅពេលនោះ ប្រទេសចិនបានចាប់ផ្តើមរៀបចំចលនាតស៊ូមួយប្រឆាំងវៀតណាម ដោយប្រមូលផ្តុំតែអ្នកខ្វែងមតិ និងអ្នកបែកបក្សពួកនៅឥណ្ឌូចិនប៉ុណ្ណោះ ។ មន្ត្រីថ្នាក់កណ្តាលរបស់បក្សកុម្មុយនីស្តវៀតណាម និងឡាវ ប្រមាណជាងដប់នាក់បានធ្វើដំណើរទៅកាន់ក្រុងប៉េកាំង ។ ដោយមានជំនួយពីប្រទេសថៃ អ្នកភៀសខ្លួន ដែលមានកំណើតពីបណ្តាកុលសម្ព័ន្ធនៅប្រទេសឡាវ ត្រូវបានផ្ទេរបញ្ជូនទៅប្រទេសចិនវិញតាមយន្តហោះ ។ ក្នុងពេលជាមួយគ្នានោះ ហ័ន វ៉ាន់ហាន បងប្អូនរួមអាវុធរបស់ហូជីមិញ និងជាអតីតសមាជិកការិយាល័យនយោបាយបានធ្វើ*

ដំណើរទៅប្រទេសចិនដែរ ដែលធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅខែកក្កដា គាត់ត្រូវធ្វើដំណើរទៅទីក្រុងប៊ែរឡាំងខាងកើតទៀត [កាលនោះជារដ្ឋធានីរបស់សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ។ បច្ចុប្បន្នជារដ្ឋធានីរបស់សហព័ន្ធអាល្លឺម៉ង់ ក្រោយពីបានបង្រួបបង្រួមជាប្រទេសតែមួយ] ដោយសារមូលហេតុសុខភាព និងបានឈប់សំចតមួយរយៈខ្លីនៅទីក្រុងការ៉ាជី ប្រទេសប៉ាគីស្ថាន ។ នៅទីនោះបុរសចំណាស់អាយុ៧៦ឆ្នាំរូបនេះត្អូញត្អែរថា ឈឺដើមទ្រូង ។ ពួកបុគ្គលិកបម្រើការផារប៉ាគីស្ថានបានយកគាត់ចេញពីបន្ទប់រង់ចាំជាបន្ទាន់ ដើម្បីយកទៅមន្ទីរពេទ្យពិនិត្យសុខភាព ។ មុនការហោះឡើងរបស់យន្តហោះ អង្គរក្សរបស់ ហ៊័ន ដែលជាអ្នកមាននិន្នាការនយោបាយដូចគ្នាដែរនោះ បានសម្គាល់ ឃើញថាបុគ្គលិកប្រចាំអាកាសយានដ្ឋានមិនដឹងថា ហ៊័នស្ថិតនៅកន្លែងណាឡើយ ។ មួយខែក្រោយមក គាត់បានលេចមុខជាថ្មីនៅទីក្រុងប៉េកាំង ហើយបានចោទប្រកាន់ "ឡេ យន់ និងបនរបស់គាត់"ថាលក់ប្រទេសវៀតណាមទៅឲ្យក្រុងមូស្គូ ។ ហ៊័ន ទាមទារឲ្យមាន"ការបដិវត្តន៍ទីពីរ" មួយក្នុងប្រទេសគាត់ថែមទៀត ។ ស្របពេលជាមួយគ្នានោះ ពួកចិនបានបង្កើតមជ្ឈមណ្ឌលហ្វឹកហាត់ជាច្រើនកន្លែងសម្រាប់អ្នក បែកបក្សពួកសញ្ជាតិវៀតណាមនិងឡាវ ព្រមទាំងជនជាតិភាគតិចនានាផង ។ ពួកគេចាប់ផ្ដើមគាំទ្របណ្ដាចលនាកងទ័ពព្រៃប្រឆាំងកុម្មុយនីស្តដែលវាយប្រយុទ្ធទល់នឹងបណ្ដារដ្ឋាភិបាលនៅឥណ្ឌូចិន ដែលកំពុងកាន់អំណាចផង[២៦] ។

អ្នកឯកទេសម្នាក់ខាងបញ្ហាចិននៅក្រសួងការបរទេសអាមេរិកាំងបានកត់សម្គាល់ថា "ពួកចិនមិនគ្រាន់តែផ្ដល់មេរៀនមួយឬពីរឲ្យវៀតណាមប៉ុណ្ណោះទេ គឺពួកគេផ្ដល់ការបង្រៀនទាំងមូលមួយតែម្ដង" ដោយប្រើការគាបសង្កត់ឥតឈប់ឈរទៅលើប្រទេសឡាវនិងកម្ពុជា និងរារាំងអ្នកដែលផ្ដល់មូលនិធិមិនឲ្យជួយវៀតណាម និងបង្ខំឲ្យវៀតណាមរៀបចំសេដ្ឋកិច្ចរបស់ខ្លួនជារបៀបយោធាថែមទៀត ។ តាមយោបល់អ្នកឯកទេសនោះថា "ការបង្រៀន"នឹងមានរយៈពេលពីបីទៅប្រាំឆ្នាំ ប៉ុន្តែ "គេមិនដឹងពីប្រភេទនៃពិធីប្រគល់រង្វាន់ដែលគ្រោងទុកជាមុនដោយពួកចិនទេ"[២៧] ។

បែបបទនៃព្រឹត្តិការណ៍ផ្សេងៗនៅប្រទេសកម្ពុជា បានធ្វើឲ្យសម្ព័ន្ធភាពផ្សេងៗក្នុងតំបន់ប្រែប្រួល ។ សម្រាប់ក្រុងបាងកកយល់ថា គ្រោះអាក្រក់នៃការចូលកាន់កាប់ប្រទេសកម្ពុជា គឺជារបៀបសម្ដែងសម័យថ្មីនៃលិទ្ធិវាតទីនិយមរបស់សន្តតិវង្ស ង្វៀន នៅដើមសតវត្សរ៍ទី១៩ ។ ការមកដល់ឥណ្ឌូចិនរបស់ពួកបារាំងបានបញ្ចប់ជាបណ្ដោះអាសន្ននូវការប្រកួតប្រជែងគ្នារវាងប្រទេសថៃនិងវៀតណាម ដើម្បីដណ្ដើមការត្រួតត្រាលើឧបទ្វីបនេះ ។ ការប្រកួតប្រជែងនេះបានស្ដែងឲ្យឃើញជាពិសេសចាប់ពីសតវត្សរ៍ទី១៧មក នៅពេលដែលប្រទេសទាំងពីរ(ថៃនិងវៀតណាម) សាកល្បងរក្សាការគ្រប់គ្រងលើព្រះរាជាណាចក្រទ្រនាប់ទាំងពីរ ឡាវនិងកម្ពុជា និងធ្វើឲ្យទន់ខ្សោយទៅវិញទៅមក ។ ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ប្រទេសថៃបានធ្វើអ្វីៗទាំងអស់ ដើម្បីបំផ្លាញប្រទេសវៀតណាមកុម្មុយនីស្ត ៖ ប្រទេសថៃបានចូលរួមក្នុង"សង្គ្រាមសម្ងាត់"ដែល

រៀបចំដោយក្រុមសេ.អ៊ី.អា.នៅប្រទេសឡាវ គាំទ្រចលនាខ្មែរសេរីប្រឆាំងកុម្មុយនីស្តនៅប្រទេសកម្ពុជា និងបញ្ជូនកងទ័ពទៅជួយច្បាំងនៅវៀតណាមខាងត្បូង ។ ជាថ្នូរមកវិញ ក្រុងហាណូយបានគាំទ្រពួកខុទ្ទាមកុម្មុយនីស្តរបស់ថៃដែរ ។ ការប្រឹងប្រែងទាំងអស់នេះគ្មានបានផលប្រយោជន៍អ្វីទាំងអស់ ។ ជ័យជម្នះរបស់ពួកកុម្មុយនីស្តនៅប្រទេសឡាវក្នុងឆ្នាំ១៩៧៥ កងទ័ពប្រហែល៥០.០០០នាក់របស់វៀតណាមបានបោះទ័ពជាប្រចាំនៅទីនោះ ហើយទីបំផុត ការចូលលុកលុយប្រទេសកម្ពុជាបានបំបាត់ចោល"ដែនដីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមប្រជាជន (Espace Vital)" របស់ខ្លួនដែលប្រទេសថៃខំប្រយុទ្ធតាំងពីសតវត្សរ៍ទី១៧ម៉្លេះ ។ ក្រុងបាងកកពុំត្រៀមទទួលខ្លួនបោះបង់ឡើយ ។ កាលពីមុន ប្រទេសថៃធ្លាប់បានធ្វើប្រតិកម្មដោយបញ្ជូនកងទ័ពរបស់ខ្លួនទៅវាយប្រយុទ្ធនឹងវៀតណាមនៅប្រទេសកម្ពុជា ។ ការដោះស្រាយរបៀបនេះលែងយកមកប្រើបានទៀតហើយ ។ នៅក្នុងអំឡុងពេលនៃការពិភាក្សាអំពីយុទ្ធសាស្ត្រដ៏ពុះកញ្ជ្រោលមួយនៅដើមឆ្នាំ១៩៧៩ នាយករដ្ឋមន្ត្រីថៃ គ្រៀងសាក់ បានប្រឆាំងជំទាស់នឹងការចូលធ្វើអន្តរាគមន៍ដោយផ្ទាល់ទាំងអស់ ។ គាត់សួរថា ៖ "ក្នុងនាមអ្នកណា? ក្នុងនាមខ្មែរក្រហមឬ?" ។ ប៉ុន្តែ ការរឹងទទឹងយ៉ាងចចេសរបស់ខ្មែរក្រហម និងការប្តេជ្ញាចិត្តរបស់ប្រទេសចិនប្រឆាំងនឹងប្រទេសវៀតណាមបានបង្ហាញឲ្យប្រទេសថៃឃើញថា ចិននៅតែជាកម្លាំងដ៏មានអំណាចដដែលដើម្បីធ្វើឲ្យឧត្តមភាពរបស់វៀតណាមត្រូវបរាជ័យ ។ អ្នកយុទ្ធសាស្ត្រចិនអះអាងថា ដោយមិនធ្វើអ្វីទាំងអស់វានឹងធ្វើឲ្យសមតា កម្លាំងក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដែនគោកផ្លាស់ប្តូរទាំងស្រុង ។ ប្រទេសវៀតណាមនឹងមកដល់មាត់ទ្វារប្រទេសថៃ ការបំផ្លិចបំផ្លាញអាចនឹងធ្វើបានតាមចិត្ត ហើយនៅទីបំផុតវៀតណាមអាចដាក់ប្រទេសនេះឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួនទៀត ។ តាមយោបល់របស់អ្នកយុទ្ធសាស្ត្រថៃម្នាក់ថា ប្រទេសកម្ពុជាលែងជារដ្ឋទ្រនាប់មួយហើយ ជាការប្រសើរអ្វីដែលត្រូវធ្វើគឺគាំទ្រការតស៊ូរបស់ខ្មែរមិនមែនកុម្មុយនីស្តដែលបន្តជាទ្រនាប់មួយដោយខ្លួនឯងផ្ទាល់[២៨] ។

## ក្រុងប៉ាស៊ីនគោនបោះបង់សមាគមអាស៊ាន

ដោយពិត សម្ព័ន្ធភាពរវាងរដ្ឋាភិបាលក្រុងប៉េកាំងនិងក្រុងបាងកក បាននាំទៅដល់ការបើកឲ្យមាន"ការចាប់ផ្តើមមួយសម្រាប់ គេង ស៊ាវពីង" នៅប្រទេសថៃ ដោយដាក់បញ្ចូលការចាប់ផ្តើមនេះជាចំណុចសំខាន់នៃការត្រៀមបម្រុងជាយុទ្ធសាស្ត្ររបស់ចិនផង ។ អាស្រ័យដោយការរៀបចំជាសម្ងាត់ផ្សេងៗ នាវារបស់ចិនជាច្រើនគ្រឿងបានរើដាក់នៅកំពង់ផែ សាត់តាហ៊ីប និងខ្លងយៃ នូវសព្វាវុធគ្រប់ប្រភេទ ព្រមទាំងគ្រាប់រំសេវជាច្រើនតោន ដែលកងទ័ពរបស់ថៃត្រូវដឹកជញ្ជូនរហូតដល់ជំរំនានារបស់ខ្មែរក្រហម ហើយក្រោយមក រហូតដល់ចលនាតស៊ូមិនមែនកុម្មុយនីស្តជាច្រើនក្រុមនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃផងដែរ ។ ស្ថានទូតចិនប្រចាំក្រុងបាងកកដែលជួយជ្រោមជ្រែងដោយអ្នកជំនួញចិនកាត់ថៃ និងដោយកងទ័ពភូមិន្ទថៃបានទទួលរ៉ាប់រងធ្វើជាអ្នកផ្គត់ផ្គង់

ស្បៀងអាហារ ថ្នាំពេទ្យ និងគ្រឿងប្រើប្រាស់ចាំបាច់ផ្នែកស៊ីវិលទៅឲ្យកងទ័ពខ្មែរក្រហមទៀត ។ ក្រុងប៉េកាំង បានបង់ពន្ធសម្រាប់សិទ្ធិឆ្លងកាត់មួយទៅឲ្យកងទ័ពរបស់ថៃ ហើយម្យ៉ាងទៀត ក៏បណ្តោយឲ្យកងទ័ពថៃដក សព្វាវុធទាំងនេះមួយផ្នែកដែរ ។ ដោយអនុលោមតាមកិច្ចព្រមព្រៀងមួយផ្សេងទៀត ប្រទេសចិនបានផ្តល់ បច្ចេកវិជ្ជាចាំបាច់មួយចំនួនសម្រាប់ការផលិតអាវុធប្រឆាំងរថក្រោះរួមគ្នាក្នុងរោងចក្រផលិតអាវុធមួយរបស់ ថៃក្នុងលក្ខខណ្ឌថា មួយផ្នែកនៃផលិតផលនេះត្រូវបម្រុងទុកសម្រាប់ខ្មែរក្រហមផង ។

ការរៀបចំជាសម្ងាត់ទាំងនេះ បង្ហាញឲ្យឃើញនូវភាពចៃដន្យដ៏ល្អសម្រាប់ក្រុមហ៊ុនដឹកជញ្ជូនរបស់ថៃ ដែលគ្រប់គ្រងដោយកងទ័ពរកចំណូលបានយ៉ាងច្រើនព្រោះថា ក្រុមហ៊ុននេះបានចុះដុនដាបតាំងពីមានការបិទ មូលដ្ឋាននានារបស់អាមេរិកាំងដែលមាននៅលើទឹកដីថៃម្ល៉េះ ។ នេះក៏ជាឱកាសរកកម្រៃខុសច្បាប់ដែរ សម្រាប់ នាយទាហានខ្លះរបស់ថៃដោយសារ «ច្បាប់» តម្រូវឲ្យសម្រាប់ការប្រគល់សព្វាវុធរបស់ចិន[២៩] ។

តាំងពីចុងឆ្នាំ១៩៧៩ កងទ័ពរបស់ ប៉ុល ពត ដែលត្រូវធ្វើឲ្យក្លាយទៅជាក្រុមមនុស្សគោកយ៉ាក ហើយ ដែលកំពុងឈឺចាប់ដោយជំងឺគ្រុនចាញ់និងការខ្វះស្បៀងអាហារបានរកឃើញថាមពលថ្មីមួយឡើងវិញ ដោយ សារជំនួយសប្បុរសរបស់ពួកចិន ។ បន្ទាប់ពីការលុកលុយរបស់វៀតណាម កងទ័ពខ្មែរក្រហមមាននៅសល់ ប្រមាណដប់ពីរកងពលធំប៉ុណ្ណោះដែលនៅរាត់រាយពាសពេញប្រទេស ដោយគ្មានការទាក់ទងរវាងគ្នានឹងគ្នា ហើយជាញឹកញយគ្មានការទាក់ទងជាមួយនឹងបញ្ជាការដ្ឋានផ្ទាល់របស់ខ្លួនផងទេ ។ ខ្មែរក្រហមបានរស់ឡើងវិញ ដោយសារជំនួយរបស់អន្តរជាតិ និងការបំពាក់យុទ្ធោបករណ៍ជាថ្មីដោយការផ្គត់ផ្គង់អាវុធរបស់ចិន ។ នៅចុងឆ្នាំ ១៩៨០ គេបានវាយតម្លៃថា ចំនួនទ័ពរបស់ខ្មែរក្រហមបានឡើងពី២ម៉ឺនរហូតដល់៤ម៉ឺននាក់[៣០] ។

សេនាធិការដ្ឋានរបស់ខ្មែរក្រហមមានទីតាំងស្ថិតនៅតែពីរប្ញីគីឡូម៉ែត្រប៉ុណ្ណោះពីព្រំដែនថៃ ប៉ុន្តែ កង កុម្ម៉ង់ដូជាច្រើនក្រុមមានគ្នាពីដប់ទៅដប់ពីរនាក់ត្រូវបានបញ្ជូនចូលមកផ្ទៃក្នុងប្រទេស ដើម្បីធ្វើការពួនស្ទាក់វាយ ប្រហារ ដាក់មីនតាមផ្លូវថ្នល់និងបំផ្លិចបំផ្លាញស្ពាន ។ នៅចុងឆ្នាំ១៩៨១ សង្គ្រាមទ័ពព្រៃនៅកម្ពុជាមានសភាព រឹតតែខ្លាំងឡើងៗ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់តំបន់មួយភាគយ៉ាងធំរបស់ប្រទេស ។

ប៉ុន្តែការរួបរួមកម្លាំងគ្នាប្រឆាំងក្រុងហាណូយដែលទើបនឹងចាប់កំណើត ហាក់ដូចជាមិនសូវមានសេចក្តី សង្ឃឹមប៉ុន្មានទេនៅលើឆាកអន្តរជាតិ ។ ប្រាកដណាស់ ដោយសារកិច្ចប្រឹងប្រែងរួមគ្នារបស់សហរដ្ឋអាមេរិក សមាគមអាស៊ាននិងប្រទេសចិន ខ្មែរក្រហមនៅរក្សាបានអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិដដែល ប៉ុន្តែការគាំទ្ររបស់អន្តរជាតិបានថយចុះគួរឲ្យបារម្ភ ។ នៅឆ្នាំ១៩៨០ វៀតណាមបានបើកទ្វារប្រទេសកម្ពុជា យ៉ាងធំសម្រាប់ប្រពន្ធ័ផ្សព្វផ្សាយព័ត៌មានលោកខាងលិចនានា ។ តាំងពីពេលនោះមក ក្រុមអ្នកយកព័ត៌មាន និង ក្រុមអ្នកថតទូរទស្សន៍ជាច្រើនអាចធ្វើដំណើរចុះឡើងដោយសេរីនៅក្នុងប្រទេស អាចនិយាយជាមួយអ្នកដែល នៅរស់រានមានជីវិតពីវាលពិឃាត អាចទៅទស្សនារណ្តៅឆ្អឹងខ្មោច និងគុកទួលស្លែងដ៏ល្បីល្បាញនៅក្រុងភ្នំពេញ

*ដែលនៅក្នុងគុកនេះចម្លើយសារភាពរាប់ពាន់ទំព័រដែលគាបចម្រាញ់យកពីអ្នកទោសក្រោមការធ្វើទារុណកម្មយ៉ាងឃោរឃៅបំផុត និងរូបថតជនរងគ្រោះជាច្រើន បានបង្ហាញឲ្យឃើញពី“ប្រសិទ្ធភាព”នៃម៉ាស៊ីនសម្លាប់មនុស្សនៅកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ។ បទយកព័ត៌មាននិងខ្សែភាពយន្តផ្សេងៗដែលនាំទៅបង្ហាញប្រាប់គេឯងដោយអ្នកកាសែត បានបង្កឲ្យមានការស្អប់ខ្ពើមទូទាំងពិភពលោក ហើយបានជំរុញឲ្យប្រទេសអង់គ្លេស និងអូស្ត្រាលី លែងទទួលស្គាល់របប ប៉ុល ពត[៣១]តទៅទៀត ។*

*នៅឆ្នាំ១៩៨០ រដ្ឋមន្ត្រីក្រសួងការបរទេសថ្មីរបស់អាមេរិកាំងគឺលោក អេដម៉ុន មឺស្គី ដែលដើរតាមអនុសាសន៍របស់អ្នកកាន់តំណែងមុនគាត់គឺលោក វ៉ាន់ស៍ អំពីចំណុចនេះបានពោលអះអាងថា ប្រទេសរបស់គាត់មិនប្រើសិទ្ធរបស់ខ្លួនក្នុងការបោះឆ្នោត ដើម្បីធ្វើឲ្យ ប៉ុល ពត មាននីតិសម្បទាឡើងវិញនៅអង្គការសហប្រជាជាតិឡើយ ។ គាត់ក៏រងទទួលនូវការគាបសង្កត់ខ្លះៗពីសំណាក់ប្រទេសចិន និងពីបណ្តាឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំប្រទេសនានានៃសមាគមអាស៊ានផងដែរ ហើយប្រាកដណាស់ពី ប្រ៊ីហ្សឹនស្គី ផ្ទាល់ ដែលនៅទីបំផុត បានសម្រេចចិត្តអនុញ្ញាតឲ្យគាត់បោះឆ្នោតជាគុណប្រយោជន៍ដល់កម្ពុជាប្រជាធិបតេយ្យម្តងទៀត ។ ពួកខ្មែរក្រហមនៅកាន់កាប់អាសនៈរបស់ខ្លួនដដែល ។ ការបញ្ចុះបញ្ចូលដែលធ្វើឡើងដោយសហរដ្ឋអាមេរិក ប្រទេសចិន និងសមាគមអាស៊ានបានទទួលការគាំទ្រ៩៧សំឡេង ចំពោះសេចក្តីសម្រេចចិត្តរបស់ខ្លួនដែលទាមទារឲ្យមានការដកកងទ័ពរបស់វៀតណាមចេញពីកម្ពុជា ។ បើទុកជាទទួលបានជោគជ័យនេះក៏ដោយ ក៏បណ្តាប្រទេសនៃសមាគមអាស៊ានដឹងច្បាស់ថា ដើម្បីការពារអាសនៈកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ គេមិនត្រឹមតែកែលម្អរូបភាពជា“ផ្លាកសញ្ញា”ខ្មែរក្រហមឲ្យបានប្រសើរជាងមុនប៉ុណ្ណោះទេ ប៉ុន្តែជាពិសេសត្រូវពង្រីកមូលដ្ឋានរបស់ចលនាតស៊ូប្រឆាំងវៀតណាមថែមទៀត ។ នៅសរទរដូវឆ្នាំ១៩៨០ លោក លី ក្វាន់យូ រដ្ឋមន្ត្រីទី១សិង្ហបុរីបានទទួលស្គាល់ជាសាធារណៈថា «ដើម្បីប្រមូលនិងរក្សាការគាំទ្រពីពិភពមិនមែនកុម្មុយនីស្ត គេគោងតែដាក់មេដឹកនាំកម្ពុជាម្នាក់ដែលមានកិត្យានុភាពជាអន្តរជាតិឲ្យគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ មុនពេលមហាសន្និបាតរបស់អង្គការសហប្រជាជាតិបើកប្រជុំនៅឆ្នាំ១៩៨១»[៣២] ។*

*គេគោងតែគ្រោងគិតពីការសម្រេចចិត្តផ្លាស់ប្តូរមួយថែមទៀត ដោយដេញខ្មែរក្រហមចេញដែលអាស៊ានមិនអាចគាំទ្រតទៅទៀត ។ អ្នកការទូតជាន់ខ្ពស់ម្នាក់របស់ថៃបាននិយាយពីរឿងនេះក្រោយមកថា : “ចាំបាច់អីទៅអន្ទោលអន្ទេកដើម្បីឲ្យទទួលបានដំណោះស្រាយនយោបាយមួយ បើសមាគមអាស៊ានពុំមានដំណោះស្រាយសម្រាប់ជំនួសផ្តល់ឲ្យផងនោះ?” ។ នេះហើយជាប្រភពនៃគំនិតក្នុងការបង្កើតឲ្យមានការរួមកម្លាំងគ្នាមួយរបស់ខ្មែរប្រឆាំងកុម្មុយនីស្តនោះ ។ មុនពេលដែលគំនិតនេះលេចចេញជារូបរាងបណ្តាអ្នកឧបត្ថមគាំទ្ររបស់ពួកគេគោងតែធ្វើដំណើរខ្វាត់ខ្វែងរាប់ពាន់គីឡូម៉ែត្រ និងរៀបចំឲ្យមានការជួបគ្នាដ៏កក្រើកញាប់ញ័ររាប់មិនអស់ជាមួយបណ្តាឥស្សរជនខ្មែរនិងចិនជាច្រើនរូប ។*

ក្រុងប៉េកាំងបានសម្តែងឲ្យឃើញនូវការសប្បាយរីករាយបន្តិចបន្តួចប៉ុណ្ណោះ ចំពោះការប្រឹងប្រែងទាំងឡាយរបស់សមាគមអាស៊ានដែលប៉ុនប៉ងរៀបចំសន្និសីទអន្តរជាតិមួយក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិក្នុងគោលដៅស្វែងរកដំណោះស្រាយនយោបាយមួយ ។ អ្វីដែលប្រទេសចិនចង់បានគឺការពារកម្ពុជាប្រជាធិបតេយ្យឲ្យនៅមានលក្ខណៈដដែល ដោយបង្កើតរណសិរ្សរួបរួមស្របគ្នាមួយឈរលើមូលដ្ឋានយ៉ាងទូលំទូលាយមួយ ដើម្បីបន្តការតស៊ូដោយអាវុធតទៅទៀត ។ ប្រទេសចិននឹកបារម្ភថា ការបង្កើតរដ្ឋាភិបាលចម្រុះមួយរបស់ខ្មែរជាមួយឥស្សរជនផ្សេងៗដូចជា សម្តេច ព្រះនរោត្តម សីហនុ និងអតីតនាយករដ្ឋមន្ត្រីរបស់ព្រះអង្គ សឺន សាន ដែលលើកឡើងដោយសមាគមអាស៊ាននោះអាចធ្វើឲ្យឥទ្ធិពលរបស់ខ្មែរក្រហមរួមតូចទៅៗ ។ តាំងពីការយាងត្រឡប់របស់ព្រះអង្គទៅក្រុងប៉េកាំងវិញនៅខែកុម្ភៈ ឆ្នាំ១៩៧៩ ទំនាក់ទំនងផ្សេងៗរបស់ សម្តេច សីហនុ ជាមួយពួកម្ចាស់ផ្ទះរបស់ព្រះអង្គមានសភាពសុខដុមរមនានឹងគ្នាណាស់ ។ ពួកចិនបានរៀបចំឲ្យព្រះអង្គគង់នៅក្នុងវិមានមួយយ៉ាងធំជាមួយអាងហែលទឹកខាតអូឡាំពិក និងបន្ទប់បញ្ចាំងខ្សែភាពយន្តក្នុងគ្រួសារមួយដែលមានទីតាំងស្ថិតនៅចំកណ្តាលបេះដូងក្រុងប៉េកាំង ។ ប៉ុន្តែ គេង ពុំប្រកាន់ពាក្យសន្យាដែលគាត់បាននិយាយនៅក្រុងវ៉ាស៊ីនតោនទេ ហើយមិនយូរប៉ុន្មាន សម្តេចបានត្រូវទទូចសុំឲ្យធ្វើជាមេដឹកនាំរណសិរ្សរួបរួមមួយក្រោមការឧបត្ថម្ភគាំពាររបស់ចិនម្តងទៀត ។ ដោយជំទាស់ប្រឆាំងនឹងការបដិសេធយ៉ាងចចេសមួយតាមពាក្យស្នើសុំរបស់ចិន សម្តេចបានទាមទារឲ្យមានការបណ្តេញកម្ពុជាប្រជាធិបតេយ្យចេញពីអង្គការសហប្រជាជាតិ ទម្រាំការបង្កើតបានរដ្ឋាភិបាលតំណាងមួយ ដើម្បីកាន់កាប់អាសនៈដែលទុកឲ្យទំនេរនៅអង្គការសហប្រជាជាតិឡើងវិញ[៣៣] ។ ថ្វីបើប្រទេសចិនបានបំពោកសម្ភារប្រណីតៗយ៉ាងច្រើន និងផ្តល់នូវកិត្តិយសយ៉ាងណាក៏ដោយ ក៏សម្តេច សីហនុ នៅតែប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ក្នុងការបរិហារខ្មែរក្រហមយ៉ាងខ្លាំងក្លា និងការទិតៀននយោបាយរបស់ពួកចិនដែលព្រះអង្គចោទថា "ចង់វាយប្រយុទ្ធទល់នឹងប្រទេសវៀតណាមរហូតដល់ខ្មែរចុងក្រោយបង្អស់" ។ តាមព្រះអង្គឈ្វេងយល់ច្រកចេញមានតែមួយគត់ គឺសន្និសីទហ្សឺណែវថ្មីមួយដែលធានាសន្តិសុខប្រទេសវៀតណាមផង និងប្រគល់ឯករាជ្យឲ្យប្រទេសកម្ពុជាវិញផង ។ ព្រះអង្គសម្គាល់ឃើញដោយហួសព្រះទ័យដែលពួកចិននឹកស្ម័គ្រថា ប្រទេសវៀតណាមច្បាស់ជាចុះញ៉មក្រោមការគាបសង្កត់មិនខាន ។ ពីការរិះគន់ផ្សេងៗបែបនោះ ដែលសម្តេចបន្ទឺឲ្យដឹងនៅក្រុងប៉េកាំងនិងការប្រកាសជាសាធារណៈនៅដើមឆ្នាំ១៩៨០ថា ព្រះអង្គប្រាថ្នាយាងត្រឡប់មកប្រទេសកម្ពុជាវិញនោះ មានន័យថា សម្តេច សីហនុ អាចប្រហែលត្រូវពួកចិនដែលត្រូវធ្វើក្តៅក្រហាយខ្លាំងទាត់ចោលមិនខាន ។ នៅខែកក្កដា ឆ្នាំ១៩៨០ ពួកចិនបានច្រានចោលនូវការសុំអនុញ្ញាតរបស់រដ្ឋមន្ត្រីការបរទេសថៃមិនឲ្យជួបគាល់សម្តេចឡើយ[៣៤] ។ ដោយខុសព្រះរាជបំណងនិងតូចព្រះទ័យខ្លួនឯង សម្តេចបានយាងត្រឡប់មកពីក្រុងព្យុងយ៉ាងវិញដោយចេតនាព្រោះតែការជួបគ្នានេះដោយប្រកាសប្រាប់អ្នកសារព័ត៌មានថា ព្រះអង្គនឹងដកព្រះកាយចេញពីជីវភាពនយោបាយ ។ រឿងដូចគ្នានេះ

ធ្លាប់កើតមានរួចម្តងមកហើយកាលពីខែសីហា ឆ្នាំ១៩៧៩ ៖ កាលណោះ ពួកចិនបានរារាំងមិនឲ្យមានការជួបគ្នាមួយដែលគ្រោងទុកជាមុន ជាមួយអនុប្រធានាធិបតីអាមេរិកាំងលោក វល់ធ័រ ម៉ុនដែល ផងដែរ ។ សម្រាប់សម្តេច សីហនុ វាជារឿងគួរឲ្យឆ្អែតព្រះទ័យណាស់[៣៥] ។

សមាគមអាស៊ានបានបន្តធ្វើការគាបសង្កត់ទៅលើប្រទេសចិនតទៅទៀត ។ ក្នុងឱកាសនៃការធ្វើដំណើរជាបន្តបន្ទាប់គ្នាមួយទៅកាន់ក្រុងប៉េកាំងនាសរទរដូវឆ្នាំ១៩៨០ រដ្ឋមន្ត្រីទី១សិង្ហបុរី លី ក្វាន់យូ និងសមភាគីថៃរបស់គាត់ ព្រេម ទិនស៊ូឡាណុន បានគាបសង្កត់ចិនឲ្យធ្វើការផ្លាស់ប្តូរមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺមេខ្មែរក្រហមដ៏ល្បីល្បាញបីនាក់ ប៉ុល ពត, អៀង សារី, ខៀវ សំផន ចេញដោយដាក់ សម្តេច សីហនុ និង សឺន សាន ជំនួសវិញ ។ តេង ស៊ាវពីង បានឆ្លើយតបដោយត្រង់ៗទៅវិញភ្លាមថា ការដកមេដឹកនាំទាំងបីនឹងធ្វើឲ្យពួកយុទ្ធជនខ្មែរក្រហមដែលយើងធ្លាប់ប្រើជាទ្រនាប់រវាងទាហានវៀតណាមនិងប្រទេសថៃធ្លាក់ទឹកចិត្ត ។ ក៏ប៉ុន្តែ តេង បានយល់ស្របនឹងគំនិតក្នុងការពួតកម្លាំងគ្នាមួយដោយប្រមូលផ្តុំខ្មែរក្រហម សម្តេច សីហនុ និង សឺន សាន បើសិនជា«អ្នកទាំងពីរមិនមានបំណងបំផ្លាញការតស៊ូប្រឆាំងនឹងពួកវៀតណាមទេនោះ»[៣៦] ។

ប្រទេសចិនមានហេតុផលត្រឹមត្រូវដែលមិនទុកចិត្ត សម្តេច សីហនុ និងអតីតនាយករដ្ឋមន្ត្រី សឺន សាន របស់ព្រះអង្គ ។ មនុស្សស្តើងខ្ពស់ សុខភាពមិនមាំទាំ និងសម្តីប៉ប៉ាច់ប៉ប៉ោច នេះ ចេះធ្វើឲ្យគេគោរពកោតខ្លាចពីសំណាក់មនុស្សប្រហែល៦.០០០នាក់នៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលដឹកនាំបញ្ជាដោយឧត្តមសេនីយ៍ ឌៀន ដែល (Dien Del) នៅតាមព្រំដែនខ្មែរ-ថៃ បានបដិសេធមិនសហការជាមួយខ្មែរក្រហមឡើយ ដរាបណាមេដឹកនាំដែលល្បីឈ្មោះយ៉ាងអាក្រក់នៅតែកាន់មុខដំណែងដដែលនោះ ។ គាត់ក៏បានទាមទារគ្រឿងសាស្ត្រាវុធសម្រាប់មនុស្សរបស់គាត់ផងដែរមុននឹងយល់ព្រមជួបគ្នា ។ គាត់តែងនិយាយច្រំដែលៗមិនចេះធុញទ្រាន់ថា «ដើម្បីចូលទៅក្នុងទ្រុងខ្លា ខ្ញុំត្រូវតែកាន់ព្រនង់ធំមួយ» ។

តេង បានផ្តល់ការសន្យាប្រាប់ លី ថា ប្រទេសចិននឹងមិនទទូចដើម្បីឲ្យខ្មែរក្រហមឡើងកាន់អំណាចវិញទេ ។ ក្នុងពេលបោះឆ្នោតដោយសេរីដែលរៀបចំឡើងក្រោយការដកថយរបស់វៀតណាម បើសិនជាខ្មែរក្រហមចាញ់ ប្រទេសចិននឹងគោរពតាម ។ ក្នុងការចរចាប្រកបដោយសេចក្តីសប្បាយរីករាយយ៉ាងខ្លាំងមួយដើម្បីលទ្ធិប្រជាធិបតេយ្យបែបគហបតី តេង បានសួរទៅ លី ថា «តើលោកយល់ព្រមទេ បើសិនជាការបោះឆ្នោតផ្តល់អំណាចទៅឲ្យខ្មែរក្រហមវិញនោះ?» ។ លី ឆ្លើយថា «ពិតជាយល់ព្រម»ទាំងបញ្ចុះបញ្ចូលថា នេះគឺជាសម្មតិកម្មដ៏ត្រឹមត្រូវមួយ[៣៧] ។ លី បានត្រឡប់ពីប្រទេសចិនមកវិញដោយមានការពេញចិត្តជាខ្លាំង នៅទីបំផុតក្រុងប៉េកាំងបានផ្តល់នូវការព្រមព្រៀងរបស់ខ្លួនចំពោះការបើកឲ្យមានសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា និងស្តីពីដំណោះស្រាយនយោបាយមួយតាមរយៈការបោះឆ្នោតដោយសេរី ។

អ្វីៗមានគ្រប់សព្វហើយ ។ សមាគមអាស៊ានអាចចាប់ផ្តើមការវាយលុកខាងការទូតរបស់ខ្លួនជាប្រយោជន៍

ដល់ការបង្កើតរដ្ឋាភិបាលចម្រុះមួយរបស់កម្ពុជាមុនការបើកប្រជុំរបស់សន្និសីទ ។ នៅខែកុម្ភៈ ឆ្នាំ១៩៨១ បេសកជនពិសេសរបស់សមាគមអាស៊ានគឺអ្នកការទូតម្នាក់របស់ឥណ្ឌូនេស៊ីឈ្មោះ អាន់វ៉ា សានី បានធ្វើដំណើរទៅទីក្រុងព្យុងយ៉ាងដើម្បីជួបគាល់ សម្ដេច សីហនុ និងអង្វរព្រះអង្គក្នុងនាមសមាគមអាស៊ានឲ្យធ្វើជាមេដឹកនាំរដ្ឋាភិបាលចម្រុះមួយ ។ តមកទៀត សម្ដេចបានទទួលជួបឯកអគ្គរដ្ឋទូតប្រទេសចិន និងកម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុងព្យុងយ៉ាងដែលអង្វរករព្រះអង្គឲ្យចូលរួមក្នុងការពួតកម្លាំងគ្នានេះដែរ ។

នៅសរទរដូវឆ្នាំ១៩៧៩ សម្ដេចបានប្រមូលផ្ដុំយុទ្ធិកៈរបស់ព្រះអង្គជាថ្មីក្នុងបក្សសម្ពន្ធខ្មែរអ្នកជាតិនិយមមួយនិងស្នើចរចាជាមួយវៀតណាម ដើម្បី«រៀបចំឯករាជ្យភាព និងអព្យាក្រឹតភាព»របស់កម្ពុជាឡើងវិញ ។ ចុតហ្មាយចំនួនបីដែលសម្ដេចទ្រង់លិខិតផ្ញើទៅអតីតមិត្តភក្តិព្រះអង្គគឺ ផាំ វ៉ាន់ដុង សុទ្ធតែគ្មានចម្លើយឆ្លើយតបមកវិញទាំងអស់ ។ ក្រុងភ្នំពេញក៏បានច្រានចោលការស្នើរបស់ព្រះអង្គក្នុងការយាងត្រឡប់មកកម្ពុជារបស់ហេង សំរិន វិញក្នុងឋានៈជាប្រជាពលរដ្ឋសាមញ្ញ[៣៨] ។ ទ្វាររបស់ប្រទេសវៀតណាម ហាក់ ដូចជាបិទសម្រាប់ព្រះអង្គដែរ ។ បស្ចិមប្រទេសបានបង្ហាញឲ្យឃើញអំណរសាទរបន្តិចបន្តួចប៉ុណ្ណោះ នៅពេលដែលព្រះអង្គសាកល្បងបង្កើតជម្រើសមួយរវាងលទ្ធភាពពីរ សម្រាប់កម្ពុជាប្រជាធិបតេយ្យដោយបង្កើតរដ្ឋាភិបាលនិរទេសផ្ទាល់របស់ព្រះអង្គ ។ ដូច្នេះ សម្ដេច សីហនុ ត្រូវស្ថិតក្នុងស្ថានភាពប្រឈមមុខនឹងការជ្រើសរើសដែលមិនជាទីពេញព្រះទ័យមួយ : ឬមួយដកព្រះកាយទាំងស្រុងនិងគ្មានលក្ខខណ្ឌចេញពីជីវភាពនយោបាយ ឬមួយរួបរួមជាមួយបណ្ដាអតីតដៃគូដែលព្រះអង្គស្អប់ខ្ពើម? ។ ព្រះអង្គបានត្រូវធ្វើឲ្យអាក់អន់ព្រះទ័យដោយការរិះគន់របស់ជនរួមជាតិខ្លះៗដែលរស់នៅក្រៅប្រទេស ដោយស្ដីបន្ទោសពីអត្តទត្តភាព និងការមិនយកព្រះទ័យទុកដាក់របស់ព្រះអង្គក្នុងការប្រយុទ្ធរបស់កម្ពុជាដើម្បីឯករាជ្យភាព ។ ម្យ៉ាងទៀត សម្ដេចលើកតម្កើងព្រះអង្គឯងខ្ពស់ខ្លាំងពេកក្នុងឋានៈជាព្រះបិតាប្រទេសកម្ពុជាសម័យទំនើប និងមានការយល់ដឹងពីប្រវត្តិសាស្ត្រហួសហេតុទោះជាបោះបង់ជីវភាពនយោបាយក៏ដោយ ។ សម្ដេចបានសម្រេចលុបបំបាត់ភាពរារែកព្រះទ័យរបស់ព្រះអង្គដោយប្រកាសត្រៀមព្រះកាយចូលរួមជាមួយខ្មែរក្រហមក្នុងមូលហេតុផ្សេងៗដែលធ្វើឲ្យសម្ព័ន្ធភាពមួយបែបនោះមិនអាចកើតឡើងបាន ។

ក្រោយពីប្រកាសប្រាប់ពិភពលោកពីព្រះរាជបំណងសហការជាមួយខ្មែរក្រហមដ៏គួរឲ្យភ្ញាក់ផ្អើលរបស់ព្រះអង្គបន្តិច សម្ដេច សីហនុ បានយល់ព្រមឲ្យខ្ញុំ(អ្នកនិពន្ធ)ជួបធ្វើការសន្ទនាមួយ ។ តាំងពីការនិរទេសខ្លួនលើកដំបូងរបស់ព្រះអង្គនៅទីក្រុងប៉េកាំងកាលពីឆ្នាំ១៩៧០ ព្រះអង្គតែងយាងទៅគង់នៅក្រុងព្យុងយ៉ាង ដោយទៀងទាត់ក្នុងមួយឆ្នាំៗអស់រយៈពេលជាច្រើនខែ ។ អតីតមិត្តភក្តិរបស់ព្រះអង្គ គីម អ៊ីលស៊ុង ប្រធានាធិបតីកូរ៉េ ខាងជើងបានស្ថាបនាវិមានដ៏ធំស្កឹមស្កៃមួយមាន៤០បន្ទប់ថ្វាយព្រះអង្គ ដែលស្ថិតនៅមាត់ច្រកចេញពីរដ្ឋធានី ។ ដោយទទួលបានទិដ្ឋាការមួយដែលសម្ដេចបានស្នើប្រធានាធិបតី គីម សម្រាប់ខ្ញុំ ខ្ញុំបានធ្វើដំណើរទៅកាន់រដ្ឋធានី

ដីសម្បើមនិងដីត្រជាក់ស្រេងរបស់កូរ៉េខាងជើងជាបន្ទាន់ ។ សម្ដេច សីហនុ បានទទួលស្វាគមន៍ ខ្ញុំក្នុងវិមានផ្ទាល់របស់ព្រះអង្គដែលបែរមុខទៅរកភ្នំទាបៗគ្របទៅដោយហិមៈនិងបឹងកករឹងមួយ ។ នៅពេលធ្វើការសន្ទនាបានពាក់កណ្ដាល ព្រះអង្គបានចង្អុលទៅតុមួយ ហើយមានបន្ទូលជាមួយស្នាមញញឹមបន្តិចថា «គឺត្រង់ហ្នឹងឯងហើយដែលខ្ញុំនឹងត្រូវចរចាជាមួយ ខៀវ សំផន ហើយយើងនឹងមិនព្រមព្រៀងអ្វីទាំងអស់» ។ ជាមួយសេចក្ដីស្មោះត្រង់ដែលមានតាំងពីយូរមកហើយរបស់ព្រះអង្គ សម្ដេចបានមានព្រះរាជបន្ទូលបន្ថែមថា «ខ្ញុំគ្មានបំណងធ្វើការព្រមព្រៀងជាមួយខ្មែរក្រហមឡើយ ទាំងបច្ចុប្បន្ន ទាំងថ្ងៃស្អែក ទាំងនៅខែវិច្ឆិកា (ជាកាលបរិច្ឆេទដែលព្រះអង្គបានកំណត់សម្រាប់ការពិភាក្សាជាលើកទីពីរជាមួយ ខៀវ សំផន) ៖ ខ្ញុំចង់លេងសើចបន្តិចជាមួយពួកចិន» ។

ដូចដែលបានគ្រោងទុកជាមុន ការជួបគ្នានៅខែមីនារវាង ខៀវ សំផន និង សម្ដេច សីហនុ បានទទួលលទ្ធផលបរាជ័យមួយដោយសារការទាមទារផ្សេងៗរបស់សម្ដេចជាដើមហេតុ ។ សម្ដេច សីហនុ បានដាក់លក្ខខណ្ឌជាអាទិភាពចំនួនប្រាំបួន ក្នុងការចូលរួមជាមួយខ្មែរក្រហមក្នុងផ្ទៃរណសិរ្សរួបរួមមួយ ។ ខសំខាន់ដែលលំបាកជាងគេសម្រាប់ការចរចាគឺមានទាក់ទងនឹងថ្ងៃអនាគត[៣៩] ។ ក្រោយពីមានដំណោះស្រាយនយោបាយមួយ និងការដាក់ជំនួសកងទ័ពវៀតណាមដោយកងទ័ពថែរក្សាសន្តិភាពអន្តរជាតិ សម្ដេច សីហនុ បានទាមទារឲ្យមានការដកអាវុធពីខ្មែរក្រហម និងសមាសភាពផ្សេងៗទៀតរបស់ចលនាតស៊ូ ។ ខៀវ សំផន បានច្រានចោលសំណើនេះ ។ ត្រង់កន្លែងនេះ សម្ដេចបានធ្វើឲ្យយកចិត្តទុកដាក់ដល់ចំណុចរសើបមួយ ៖ មួយផ្នែកគឺភាពមិនស្របគ្នាខាងផលប្រយោជន៍រវាងប្រទេសចិននិងសម្ព័ន្ធមិត្តខ្មែរក្រហមរបស់គេ ហើយមួយផ្នែកទៀតគឺផលប្រយោជន៍រវាងប្រទេសចិននិងតំបន់អាស៊ីអាគ្នេយ៍មិនមែនកុម្មុយនីស្ត ។

បណ្ដាប្រទេសនៃសមាគមអាស៊ាន សុទ្ធតែវាយតម្លៃមិនល្អពីភាពរឹងរូសរបស់ពួកមេដឹកនាំខ្មែរក្រហមដែលច្រានចោលដំណោះស្រាយទាំងអស់រួមមានការដកអាវុធពីយុទ្ធជន និងការដកថយផ្ទាល់របស់ពួកគេ ។ ប្រទេសទាំងនោះមានទឹកចិត្តរីករាយយ៉ាងខ្លាំង នៅពេលដែលប្រទេសចិនបានយល់ព្រមចូលរួមក្នុងសន្និសីទអន្តរជាតិមួយស្ដីពីប្រទេសកម្ពុជា ។ ក្រុងមូស្គូ និងក្រុងហាណូយបានឲ្យដឹងថា ពួកគេនឹងមិនចូលរួមក្នុងសន្និសីទនេះទេ ។ ប្រទេសចិនបានប្រកាសថា ខ្លួននឹងមិនស្វះស្វែងធ្វើឲ្យមានឥទ្ធិពលរបស់ខ្លួនលើប្រទេសកម្ពុជាតាមរយៈខ្មែរក្រហមឡើងវិញឡើយ ដោយហេតុនេះសមាគមអាស៊ានបានសម្រេចចិត្តប្រញាប់រៀបចំសន្និសីទនេះឡើង ។ វាទំនងថា ផែនការសន្តិភាពដ៏សមហេតុសមផលមួយដែលគិតទៅដល់ផលប្រយោជន៍ផ្សេងៗសម្រាប់សន្តិសុខប្រទេសវៀតណាម ហើយដែលគាំទ្រដោយមហាអំណាចធំៗ ជាពិសេសសហរដ្ឋអាមេរិក និងប្រទេសចិនប្រហែលជាទាក់ទាញចិត្តក្រុងហាណូយបាន បើទោះជាវៀតណាមបដិសេធមិនចូលរួម ដើម្បីរក្សាមុខមាត់ខ្លួនក៏ដោយ ។ សមាគមអាស៊ាន និងជាពិសេសប្រទេសសិង្ហបុរីបានត្រៀមខ្លួននឹងហេតុការណ៍ដែលមិនជាទីពេញចិត្តជាស្រេច ។

ការព្រាងសេចក្ដីថ្លែងការណ៍របស់សមាគមអាស៊ាន សម្រាប់សន្និសីទអន្តរជាតិស្ដីពីបញ្ហាកម្ពុជានៅខែកក្កដា ឆ្នាំ១៩៨១ ត្រូវបានគាក់តែងឡើងជាពិសេសតាមគំនិតផ្ដួចផ្ដើមរបស់ លី ក្វាន់យូ ដែលបង្ហាញឲ្យឃើញនូវភាពសម្រុះសម្រួលមួយចំពោះប្រទេសវៀតណាមយ៉ាងគួរឲ្យឆ្ងល់ ។ វាបានឆ្លុះបញ្ចាំងឲ្យឃើញនូវការព្រមព្រៀងគ្នាមួយក្នុងចំណោមប្រទេសអាស៊ានទាំងអស់ដែលមិនសម្គាល់ឃើញផលប្រយោជន៍របស់ខ្លួន ក្នុងយុទ្ធសាស្ត្ររបស់ចិនដែលមានគោលដៅធ្វើឲ្យវៀតណាមខ្សោះរីងរៃឡើយ ។ ការថមថយកម្លាំងរបស់វៀតណាមនិងការវិលត្រឡប់មកកាន់អំណាចវិញរបស់ខ្មែរក្រហមស្និទ្ធចិននឹងធ្វើឲ្យសមតាកម្លាំងក្នុងតំបន់ប្រែប្រួលក្រឡាប់ចាក់យ៉ាងធំធេង ។ ក៏ប៉ុន្តែ ការកម្ចាត់ខ្មែរក្រហមចេញតាមរយៈការបោះឆ្នោត ហើយដាក់ជំនួសដោយរដ្ឋាភិបាលមួយដែលឯករាជ្យនិងមិនចូលបក្សសម្ព័ន្ធ នឹងធ្វើឲ្យប្រទេសថៃនិងប្រទេសវៀតណាមលែងភ័យព្រួយ ហើយបំបាត់មិនឲ្យប្រទេសចិនមានលេសដើម្បីធ្វើអន្តរាគមន៍នៅតំបន់អាស៊ីអាគ្នេយ៍ដែនគោកថែមទៀត ។

គម្រោងនៃសេចក្ដីថ្លែងការណ៍របស់អាស៊ានបានទទួលស្គាល់នូវ "ការព្រួយបារម្ភដ៏ត្រឹមត្រូវរបស់បណ្ដាប្រទេសជិតខាងកម្ពុជា-និយាយដោយឡែកប្រទេសវៀតណាម-ថា ប្រទេសនេះពុំអាចក្លាយទៅជាការគំរាមកំហែងមួយចំពោះប្រទេសជិតខាងទាំងនោះ ហើយក៏មិនត្រូវបានប្រើប្រាស់ដោយរដ្ឋណាមួយសម្រាប់ប្រព្រឹត្តអំពើវិទ្ធង្សនា ឬការឈ្លានពានដោយកម្លាំងយោធាដែរ" ។ អត្ថបទនេះបានច្រានចោលដោយគ្មានថែងច្បាស់លាស់នូវការទទួលខុសត្រូវមួយផ្នែកនៃការធ្វើអន្តរាគមន៍របស់វៀតណាមចំពោះនយោបាយផ្សងព្រេងរបស់ខ្មែរក្រហមនិងវត្តមានយោធារបស់ចិននៅប្រទេសកម្ពុជាផងដែរ ។ អត្ថបទបានអួតសរសើរថា ប្រទេសវៀតណាមនឹងបានទទួលជំនួយអន្តរជាតិមួយក្នុងការស្ដារប្រទេសជាតិឡើងវិញ ដើម្បីជួសជុលការខូចខាតដែលទទួលរងការបំផ្លិចបំផ្លាញដោយសារសង្គ្រាម បន្ទាប់ពីការដោះស្រាយបញ្ចប់បញ្ហាកម្ពុជា ។ ទិសដៅរបស់អាស៊ាន ដំបូងគឺធ្វើឲ្យទទួលបាននូវការដកកងទ័ពវៀតណាមចេញពីកម្ពុជា បន្ទាប់មក ការដកហូតអាវុធពីខ្មែរក្រហមនិងការបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ ដើម្បីរៀបចំការបោះឆ្នោតដោយសេរី ។

សន្និសីទនេះបានចាប់ផ្ដើមធ្វើនៅអគ្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែកក្កដា ។ មិនទាន់បានអីផង ពួកចិននិងខ្មែរក្រហមបានសម្ដែងនូវការមិនយល់ព្រមនឹងគម្រោងរបស់អាស៊ានយ៉ាងម៉ឺងម៉ាត់ ។ គំនិតអញ្ជើញបក្សប្រជាជនបដិវត្តខ្មែរស្និទ្ធវៀតណាមឲ្យចូលរួមសន្និសីទបានត្រូវច្រានចោល ។ វាក្យខ័ណ្ឌនៃសេចក្ដីថ្លែងការណ៍ទាក់ទងនឹងការព្រួយបារម្ភដ៏ត្រឹមត្រូវរបស់បណ្ដាប្រទេសជិតខាងកម្ពុជា ក៏ត្រូវបានសម្រាលដែរ ។ សមាគមអាស៊ាននៅតែមិនរាថយចំពោះការដកហូតអាវុធពីក្រុមបះបោរប្រឆាំងជាច្រើនរបស់ខ្មែរ និងការបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ ។ ដោយត្រូវធ្វើឲ្យឆ្ងល់ស្រឡាំងកាំង អ្នកការទូតរបស់សិង្ហបូរីបានមើលឃើញថាការធានារ៉ាប់រងផ្សេងៗដែលអះអាងដោយ គេង ជាមួយ លី ក្វាន់យូ ទាក់ទងនឹងការគោរពសេចក្ដីសម្រេចតាមរយៈហិបឆ្នោត ប្រហែលជាមិនគួរឲ្យទុកចិត្តឡើយ ។ នៅថ្ងៃទី១៥ ខែកក្កដា ក្នុងឱកាសនៃការប្រជុំការងារ

មួយដែលមានអ្នកសង្កេតការណ៍៤០រូប ក្នុងចំណោមនោះមានអ្នកការទូតអាមេរិកាំងដែរ បាននៅទីនោះពេលមានទាស់សម្ដីគ្នាយ៉ាងខ្លាំងរវាង ថមមី កូស ឯកអគ្គរដ្ឋទូតសិង្ហបូរីប្រចាំអង្គការសហប្រជាជាតិ និងជាតំណាងសមាគមអាស៊ានជាមួយនឹង លីន ជីង ជាឯកអគ្គរដ្ឋទូតរបស់ប្រទេសចិន ។ ដោយធ្វើឲ្យស្រគៀវត្រចៀកនឹងស្ដាប់ លីន បានលើកយកច្បាប់អន្តរជាតិមកធ្វើជាសំអាង ដើម្បីជួយការពារខ្មែរក្រហម ។ ចំណែក កូស ដែលជាអតីតព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យសិង្ហបូរីបានស្រែកភ្ញាក់មាត់ថា ៖ «យ៉ាងហោចណាស់ ខ្ញុំចេះដឹងពីច្បាប់អន្តរជាតិជាងលោកឯកអគ្គរដ្ឋទូតទៅទៀត ប៉ុន្តែ ច្បាប់ពុំមែនធ្វើឡើងសម្រាប់ការពារក្រុមមនុស្សសាហាវយង់ឃ្នងនេះទេ» ។ តមកទៀត គាត់បានចាប់ធ្វើការរ៉ាយរ៉ាប់យ៉ាងល្អិតល្អន់នូវភាពគួរឲ្យរន្ធត់ញាប់ញ័រដែលប្រព្រឹត្តឡើងដោយ ប៉ុល ពត និងដៃជើងរបស់គាត់ក្នុងអំឡុងពេលនៃការកាន់អំណាចបួនឆ្នាំ ។ ជនជាតិខ្មែរខ្លះដែលមានវត្តមានក្នុងសាលប្រជុំដែរ នោះបាននាំគ្នាទ្រហោយំភ្លាម[៤០] ។

ក្នុងឱកាសនៃការជួបប្រជុំមួយផ្សេងទៀតជាមួយបណ្ដារដ្ឋមន្ត្រីការបរទេសអាស៊ាន ហាន នានឡុង អនុរដ្ឋមន្ត្រីការបរទេសចិនបានយកកណ្ដាប់ដៃគោះតុលាន់ផូង ជាសញ្ញាប្រាប់ឲ្យដឹងនូវការក្ដៅក្រហាយរបស់គាត់ចំពោះការទិតៀនគ្មានឈប់ឈរប្រឆាំងនឹងខ្មែរក្រហម ។ «បើគ្មានការតស៊ូយ៉ាងស្វិតស្វាញរបស់កម្ពុជាប្រជាធិបតេយ្យទេ ក៏ថ្ងៃនេះពួកយើងមិននៅទីនេះ ដើម្បីពិភាក្សាពីបញ្ហាប្រទេសកម្ពុជាដែរ ប៉ុន្តែ ច្បាស់ជាពិភាក្សាគ្នាពីបញ្ហាប្រទេសថៃមិនខាន»[៤១] ។ ហាន បានគ្រើនរំឭកថា ការដកហូតអាវុធពីពួកខ្មែរក្រហមមិនគ្រាន់តែធ្វើឲ្យយុទ្ធជនទាំងឡាយធ្លាក់ទឹកចិត្តប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ភាពត្រឹមត្រូវតាមច្បាប់របស់កម្ពុជាប្រជាធិបតេយ្យទៀតផង ។ ហាន បានសួរទាំងខឹងច្រឡោតទៅកាន់បណ្ដាគូសន្ទនារបស់គាត់ថា ៖ «ហេតុអ្វីបានជាស្នើសុំឲ្យសមាជិកស្របច្បាប់មួយរបស់អង្គការសហប្រជាជាតិដាក់អាវុធចុះ? ហេតុអ្វីបានជាបង្ខំឲ្យមានរដ្ឋាភិបាលបណ្ដោះអាសន្នចំពោះរដ្ឋជាសមាជិកមួយរបស់អង្គការសហប្រជាជាតិដែលរងគ្រោះពីការឈ្លានពានមួយទៅវិញ? ។ គាត់បានបន្តថា ៖ បន្ទាប់ពីការដកថយរបស់កងទ័ពវៀតណាម បន្ទុករៀបចំប្រទេសនឹងត្រូវធ្លាក់លើរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ ហើយមានតែរដ្ឋាភិបាលនេះមួយគត់ដែលត្រូវរៀបចំការបោះឆ្នោត» ។

ជំហររបស់ចិននៅក្នុងសន្និសីទបានធ្វើឲ្យសមាគមអាស៊ានខឹងចិត្តយ៉ាងខ្លាំង ប៉ុន្តែតួនាទីដែលសម្ដែង ដោយសហរដ្ឋអាមេរិកក្នុងសន្និសីទនោះ ទើបជាការធ្វើឲ្យទាស់ចិត្តខ្លាំងមួយយ៉ាងពិតប្រាកដ ។ នៅឆ្នាំ១៩៨០ ក្នុងឱកាសនៃការឃោសនាបោះឆ្នោតរបស់ខ្លួន ប្រធានាធិបតី រ៉ូណាល់ រីហ្គេន ធ្លាប់បង្កឲ្យមានរឿងហេតុជាមួយពួកចិនម្ដងហើយ ដោយគាត់បានសន្យារៀបចំឲ្យមានទំនាក់ទំនងផ្លូវការជាមួយប្រទេសតៃវ៉ាន់ឡើងវិញ ។ នៅពេលនេះ រដ្ឋមន្ត្រីការបរទេសរបស់គាត់លោក អាឡិចសង់ដ័រ ហេក បានប្រឹងប្រែងយ៉ាងអស់ពីចិត្តពីថ្លើមដើម្បីធ្វើឲ្យចិនពេញចិត្តគាត់វិញ ដោយលើកហេតុផលថា «ប្រទេសចិនប្រហែលជាប្រទេសដ៏មានសារសំខាន់ជាងគេ

នៃពិភពលោកសម្រាប់សហរដ្ឋអាមេរិក» បើសម្លឹងមើលផលប្រយោជន៍ជាយុទ្ធសាស្ត្រផ្សេងៗរបស់ប្រទេសទាំងពីរ[៤២] ។

នៅក្នុងសន្និសីទ ហេក បានបន្តផ្គាប់ចិត្តចិនរហូតដល់កាន់ជើងក្រុងប៉េកាំងប្រឆាំងនឹងបណ្តាសម្ព័ន្ធមិត្តនិងមិត្តភក្តិមិនមែនកុម្មុយនីស្តរបស់សហរដ្ឋអាមេរិកថែមទៀត ។ អ្នកការទូតអាស៊ានដ៏ឆ្នើមម្នាក់បានរំឭកពីរឿងនេះជាមួយការតូចចិត្តថា ៖ «ហេក និងឧបការីរបស់គាត់គឺលោក ហូលព្រ៊ីដហ្ស៍ បានដើរចេញពីមហាសន្និបាតអង្គការសហប្រជាជាតិនៅពេលដែល អៀង សារី ងើបឈរដើម្បីឡើងនិយាយ ។ អំពើដ៏អស្ចារ្យនេះបានត្រូវចុះក្នុងទំព័រទីមួយនៃកាសែតញូវយ៉កថែមស៍ ប៉ុន្តែក្នុងទីកំបាំងវិញ មនុស្សពីរនាក់នេះ ហេក និង ហូល ព្រ៊ីដហ្ស៍ បានធ្វើការគាបសង្កត់មកលើយើង ដើម្បីឲ្យពួកយើងសម្របខ្លួនទៅតាមជំហររបស់ចិន»[៤៣] ។

ហូលព្រ៊ីដហ្ស៍ និងអនុប្រធានរបស់គាត់ទទួលបន្ទុកកិច្ចការអាស៊ីអាគ្នេយ៍ឈ្មោះ ហ្សន ណេហ្គ្រូប៉ុង បានធ្វើដំណើរបំពេញបេសកកម្មឆ្លងម្នាក់នៅតាមបណ្តាប្រទេសអាស៊ាន ដោយគាបសង្កត់រដ្ឋមន្ត្រីការបរទេសជាច្រើនរូបកុំឲ្យផ្ទុញផ្ទាល់ការធ្វើសម្បទានផ្សេងៗរបស់ប្រទេសចិន ដើម្បីសម្របសម្រួលគ្នាចំពេលដែលអ្នកប្រតិបត្តិនិយម តេង ស៊ាវពីង រិះគន់ទៅលើក្រុមនិយមឆ្វេងរបស់គាត់ ។ លោក ម៉ុកតារ គូសូម៉ាអាតម៉ាជ្សា រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីបានខឹងច្រឡោតថា ៖ «បើសិនជា តេង ពុំមានសេរីភាពនឹងធ្វើអ្វីកើតនោះ គឺជារឿងរបស់គាត់ ។ ពួកយើងពុំមែនជាមេដោះរបស់គាត់ទេ»[៤៤] ។

នៅចំពោះមុខការមិនយល់ព្រមរបស់លោក ស៊ីបពីយ៉ាស់ ដាណាបាឡាន់ រដ្ឋមន្ត្រីការបរទេសសិង្ហបុរីឲ្យដកចេញខសំខាន់ៗ ដែលប្រទេសចិនមានការខ្វែងយោបល់ដែរនោះ លោក ហូលព្រ៊ីដហ្ស៍ បានគំរាមថានឹងយករឿងនេះទៅប្តឹងលោក លីក្វាន់យូ ។ ដាណាបាឡាន់ បានផ្ទុះសម្តីទាំងកំហឹងថា «សូមអញ្ជើញដោយសេរី! បើសិនជាលោកចង់» មុននឹងចាកចេញពីសម័យប្រជុំទាំងដំណើរខឹងតតូងតតាង ។ លី ទំនងជាមិនអត់ឱននូវការប្រឈមមុខនឹង ហេក និង ហូលព្រ៊ីដហ្ស៍ នេះឡើយ[៤៥] ។

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំក្រុងម៉ានីល (រដ្ឋធានីប្រទេសហ្វីលីពីន) និងប្រចាំក្រុងបាងកក បានទទួលបញ្ជាពីលោក ហេក ឲ្យចូលជួបប្រាស្រ័យអំពីបញ្ហានេះជាមួយប្រធានាធិបតី ម៉ារកូស និងនាយករដ្ឋមន្ត្រីព្រេមទិនស៊ូឡាណុន ដើម្បីបញ្ចុះបញ្ចូលឲ្យរឹតបន្តឹងរដ្ឋមន្ត្រីការបរទេសរបស់ផងខ្លួនដែលធ្វើការនៅទីក្រុងញូវយ៉កផង ។ សមាគមអាស៊ាននៅតែបន្តចោទសហរដ្ឋអាមេរិកថា បានចូលដៃជាមួយសត្រូវ ប៉ុន្តែ ដោយទប់ទល់មិនបាននឹងការគាបសង្កត់របស់ចិននិងអាមេរិកាំង អាស៊ានក៏យល់ព្រមនិយាយពីការសម្របសម្រួលគ្នាវិញ ដែលជាការបោះបង់ចោលនូវចំណុចគន្លឹះពីរក្នុងផែនការរបស់ខ្លួន ។

គេបានចេញរួចពីភាពទ័លច្រក នៅថ្ងៃដែលអាស៊ានបោះបង់លែងទាមទារឲ្យមានការដកអាវុធពីក្រុមខ្មែរច្បាំងគ្នាទាំងឡាយ ដោយគ្រាន់តែផ្តល់នូវការធានាមិនច្បាស់លាស់ថា «វិធានការសមស្របផ្សេងៗនឹងត្រូវ

ប្រកាន់យកដើម្បីបញ្ចៀសមិនឲ្យបក្សពន្ធប្រឆាំងរបស់កម្ពុជារារាំងឬអុកឡុក» ការបោះឆ្នោត ។ លែងមានការនិយាយណែនាំពីរដ្ឋបាលបណ្តោះអាសន្នមួយទៀតហើយ ប៉ុន្តែ «វិធានការផ្សេងៗត្រូវដាក់បន្ថែមឲ្យទទួលដើម្បីការពារភាពសុខសាន្តរបស់ពលរដ្ឋ» ។ នៅទីបំផុតរូបមន្តសម្រុះសម្រួលគ្នានេះបានជួយសង្គ្រោះសន្និសីទឲ្យប្រព្រឹត្តទៅបាន ។ ការប្រឈមមុខដ៏រំដើបរំជួលរបស់ប្រទេសចិន និងសមាគមអាស៊ាន បានធ្វើឲ្យឃើញយ៉ាងជាក់ច្បាស់នូវជ្រោះដ៏ជ្រៅមួយដែលខណ្ឌចែកភាគីទាំងពីរ បើទោះជាពួកគេធ្វើការជំទាស់រួមគ្នាប្រឆាំងនឹងការកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាមក៏ដោយ ហើយត្រូវវិនិច្ឆ័យដោយ ថមមីកូស ថា «វាជារឿងដែលធ្វើឲ្យពិបាកចិត្តបំផុត ដែលខ្ញុំមិនធ្លាប់បានជួបប្រទះក្នុងអំឡុងពេល១៣ឆ្នាំនៃការបំពេញមុខងារនៅអង្គការសហប្រជាជាតិ» ។ សម្រាប់ប្រទេសទាំងឡាយនៃសមាគមអាស៊ាន នេះជាឱកាសរកឃើញផងដែរនូវអ្វីដែលជាបន្ទុករបស់ប្រទេសតូចៗប្រឈមមុខទល់នឹងមហាអំណាចនានា[៩៦] ។

## សម្ព័ន្ធភាពមួយដែលខុសប្រក្រតី

សម្តេច សីហនុ បានបដិសេធមិនចូលរួមសន្និសីទនេះទេ ដែលតាមព្រះអង្គមានព្រះរាជតម្រិះថានោះជា«តុលាការ»សាមញ្ញមួយសម្រាប់វិនិច្ឆ័យប្រទេសវៀតណាមប៉ុណ្ណោះ នៅពេលដែលគេត្រូវស្វែងរកដំណោះស្រាយមួយជាបន្ទាន់ ។ ប៉ុន្តែនៅរដូវក្តៅ ឆ្នាំ១៩៨១ ព្រះអង្គហាក់ដូចជាមិនសូវជំទាស់នឹងគំនិតចង់ឲ្យមានការរួបរួមកម្លាំងគ្នាមួយប៉ុន្មានឡើយ ។ នៅខែសីហា ព្រះអង្គបានជួប សឺន សាន ជាលើកដំបូងបង្អស់តាំងពីការចាកចេញរបស់អតីតនាយករដ្ឋមន្ត្រីរបស់ព្រះអង្គទៅទីក្រុងប៉ារីស ។ ជាសេដ្ឋវិទូដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ មុនដំបូងគាត់ គឺគេជាអ្នកទទួលបន្ទុកបង្រៀនសម្តេចឧបយុវរាជ នរោត្តម សីហនុ តមកទៀត គាត់បានក្លាយទៅជាធនាគារិកទីមួយ ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងនាយករដ្ឋមន្ត្រីរបស់ព្រះអង្គ ។ ថ្វីបើមានកិច្ចសហការដ៏យូរលង់ និងជិតស្និទ្ធនឹងគ្នាក៏ដោយ ក៏នៅទីបំផុតទំនាក់ទំនងផ្សេងៗរបស់អ្នកទាំងពីរបានថមថយចុះយ៉ាងខ្លាំងនៅចុងរជ្ជកាលរបស់ សម្តេច សីហនុ ហើយពួកគេក៏លែងនិយាយពីគ្នាតាំងពីច្រើនឆ្នាំមកហើយ ។ សមាគមអាស៊ានគឺជាអ្នកអន្ទោលអន្ទេរកឲ្យមានការរួបរួមគ្នា ដោយមិនរវល់ដល់ការអាក់អន់ចិត្តរវាងគ្នានឹងគ្នារបស់អ្នកទាំងពីរឡើយ ។ រដ្ឋមន្ត្រីការបរទេសថៃ សិទ្ធិ សាវេតស៊ីឡា បានជួបធ្វើការសន្ទនាក្រៅផ្លូវការមួយជាមួយ សម្តេច សីហនុ នៅស្ថានទូតថៃប្រចាំទីក្រុងប៉ារីស ។ គាត់គឺជាអ្នកការទូតថៃដំបូងបង្អស់ដែលបានជួបសម្តេចតាំងពីជាង១៥ឆ្នាំមកហើយ ។ គឺគាត់នេះដែរដែលស្នើសម្តេចឲ្យបំភ្លេចអតីតកាលហើយដឹកនាំរដ្ឋាភិបាលចម្រុះមួយនោះ ។

សម្រាប់ប្រទេសថៃ ការចងសម្ព័ន្ធមេត្រីជាមួយ សម្តេច សីហនុ បើមើលតាមប្រវត្តិសាស្ត្ររបស់ខ្លួន គឺជាការប្រែប្រួលភ្លាមៗមួយ ដែលធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅឆ្នាំ១៩៦២ សម្តេចធ្លាប់បានប្តឹងទៅតុលាការអន្តរជាតិនៅក្រុងឡាអេ ឲ្យជំនុំជម្រះពីរឿងប្រាសាទព្រះវិហារ ដែលប្រទេសថៃបានដណ្តើមទៅធ្វើជា

*កម្មសិទ្ធិរបស់ខ្លួន ហើយព្រះអង្គបានឈ្នះក្នុងរឿងក្ដីនេះនិងទទួលបានប្រាសាទព្រះវិហារមកវិញ ។ ក្នុងរយៈពេល ១៥ឆ្នាំនៃរជ្ជកាលព្រះអង្គមិនដែលបោះបង់ឱកាសក្នុងការបរិហារពីលទ្ធិវាតទីនិយមរបស់ថៃ និងមហិច្ឆតារបស់បណ្ដាមេទ័ពប្រទេសនេះឡើយ ។ ប៉ុន្ដែដោយគិតដល់ផលប្រយោជន៍សន្ដិសុខប្រទេស និងបញ្ចប់សង្គ្រាមពាក្យសម្ដីដ៏គ្រោតគ្រាតស្ដីពីភាពតួរដល់កាលនៃការធ្វើសម្ព័ន្ធភាពមួយជាមួយសម្ដេច សីហនុ នោះ ព្រះរាជវាំងក្រុងបាងកកបានប្រាប់កងទ័ពភូមិន្ទថៃថា ចាប់ពីពេលនេះទៅការផ្សះផ្សាជាមួយសម្ដេច គឺជាកម្មវត្ថុនៃការជជែកពិភាក្សាគ្នាក្នុងរដ្ឋសភា[៤៧] ។*

*សមាគមអាស៊ាននិងសហរដ្ឋអាមេរិកបានឈានដល់គោលដៅរបស់ពួកគេ : នៅខែកញ្ញា ឆ្នាំ១៩៨១ សម្ដេច សីហនុ និង សឺន សាន បានយាងនិងធ្វើដំណើរទៅសិង្ហបុរីដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលនាំទៅដល់ការបង្កើតឲ្យមានរដ្ឋាភិបាលចម្រុះមួយ ។*

*វាមានការព្រមព្រៀងច្រើនគ្នា(Consensus)មួយក្នុងផ្ទៃសមាគមអាស៊ាន ស្ដីពីភាពចាំបាច់នៃការបង្កើតរដ្ឋាភិបាលចម្រុះមួយ ដើម្បីរក្សាការគាំទ្រពីអន្ដរជាតិចំពោះកម្ពុជាប្រជាធិបតេយ្យ ប៉ុន្ដែ ពុំមែនស្ដីពីតួនាទីរបស់រដ្ឋាភិបាលនេះទេ ។ ពួកម៉ាឡេស៊ី និងឥណ្ឌូនេស៊ី យល់ឃើញថា វានឹងទៅជាក្របខ័ណ្ឌដែលល្អឥតខ្ចោះសម្រាប់ពង្រីក"កម្លាំងទីបី"មួយ ដោយប្រមូលផ្ដុំភាគច្រើននៃប្រជាជនកម្ពុជាដែលពុំមែនជាយុទ្ធិកៈរបស់ខ្មែរក្រហម ទាំងក៏ពុំមែនជាយុទ្ធិកៈរបស់វៀតណាម ។ នេះជាស្នៀតដ៏ល្អមួយ ដើម្បីរៀបចំដាក់ពួកមេដឹកនាំមិនមែនកុម្មុយនីស្ដឲ្យកាន់អំណាច និងសម្រេចបានកិច្ចព្រមព្រៀងមួយជាមួយវៀតណាមក្រោយពីរលាស់ចោលខ្មែរក្រហម ។ រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី តាន់ស្រ៊ី ហ្កាហ្សាលី ស្វាហ្វី បានបំភ្លឺប្រាប់ខ្ញុំ(អ្នកនិពន្ធ) ថា "ពួកចិនពុំចង់ឲ្យមានការដកអាវុធពីខ្មែរក្រហមទេ យើងត្រូវតែរៀបចំកម្លាំងប្រឆាំងមិនមែនកុម្មុយនីស្ដមួយ" ។ ការរៀបចំរដ្ឋាភិបាលចម្រុះមួយនឹងបើកឱកាសបំពាក់អាវុធឲ្យកម្លាំងមិនមែនកុម្មុយនីស្ដបាន ។ កម្លាំងទ័ពទីបីនេះ "ពុំមែនបម្រុងទុកសម្រាប់វាយប្រយុទ្ធនឹងវៀតណាមទេ ប៉ុន្ដែសម្រាប់បង្កើតឲ្យមានភាពស្មើគ្នាមួយរវាងដៃគូទាំងឡាយរបស់រដ្ឋាភិបាលចម្រុះ និងធ្វើឲ្យកម្លាំងមិនមែនកុម្មុយនីស្ដទៅជាគូសន្ទនាដ៏គួរឲ្យទុកចិត្តមួយសម្រាប់ការចរចាផ្សេងៗជាមួយវៀតណាម"[៤៨] ។*

*ការរក្សាការគាបសង្កត់ផ្នែកយោធាទៅលើវៀតណាមតាមរយៈការជួបទាក់ទងនឹងខ្មែរក្រហម គឺជាអាទិភាពដែលប្រទេសថៃត្រូវធ្វើមុនគេ ។ រដ្ឋាភិបាលចម្រុះមិនបម្រើអ្វីក្រៅតែពីរ៉ាប់រងឲ្យមានការគាំទ្រពីសហគមន៍អន្ដរជាតិប៉ុណ្ណោះ ។ ប្រទេសសិង្ហបុរីបានយល់ព្រមនឹងទស្សនៈផ្សេងៗរបស់ក្រុងបាងកកតែគោលធំៗ ប៉ុន្ដែម្យ៉ាងទៀត ក៏មានបំណងឲ្យប្រុងប្រយ័ត្នមិនឲ្យខ្មែរក្រហមឆ្លៀតទាញយកផលប្រយោជន៍ណាមួយខាងផ្នែកនយោបាយពីរដ្ឋាភិបាលចម្រុះនេះដែរ ។ បន្ទាប់ពីបានសម្រេចកិច្ចព្រមព្រៀងជាគោលការណ៍មួយនៅខែកញ្ញារួចមក ភាគីទាំងបីបែរជាជាប់គាំងក្នុងការឈ្លោះប្រកែកគ្នាគ្មានទីបញ្ចប់ស្ដីពីការប្រគល់តំណែងរដ្ឋមន្ត្រីផ្សេងៗ និងស្ដីពី*

ការចាត់ចែងដឹកនាំដែលប្រមូលផ្តុំមកនៅក្រោមអំណាចតែមួយ ។ ដើម្បីបញ្ចប់បញ្ហានេះ ប្រទេសសិង្ហបុរី បានដាក់ស្នើគម្រោង«រដ្ឋាភិបាលចម្រុះឥតដឹកនាំ»មួយ ដោយប្រគល់ស្វ័យភាពរបស់គេឲ្យដៃគូផ្សេងៗ និងដោយបំបាត់គ្រប់លទ្ធភាពទាំងអស់មិនឲ្យខ្មែរក្រហមគ្រប់គ្រងរដ្ឋាភិបាលនេះបានឡើយ ។ បន្ទាប់ពីព្យាយាមធ្វើការចរចាដ៏លំបាកអស់ចិរវេលាប្រាំបីខែ នៅទីបំផុត រូបមន្តដែលអាចទទួលយកបានមួយត្រូវបានរៀបចំឲ្យមានឡើង ។ ដើម្បីបង្កើនល្បឿនកិច្ចការទាំងនោះ សមាគមអាស៊ានគោងតែប្រើការគំរាមកំហែងផ្សេងៗជាចាំបាច់ : មួយផ្នែកគឺកាត់ផ្តាច់ស្បៀងអាហារសម្រាប់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ហើយមួយផ្នែកទៀតឈប់ទទួលស្គាល់កម្ពុជាប្រជាធិបតេយ្យ ។

ឧបសគ្គចុងក្រោយទាក់ទងទៅនឹងការប្រគល់តំណែងសំខាន់ៗចំនួនពីរក្នុងរដ្ឋាភិបាលបានត្រូវដកចេញនៅខែឧសភា ឆ្នាំ១៩៨២ ។ នៅពេលនោះ ស៊ីធី បានធ្វើដំណើរទៅទីក្រុងប៉េកាំងដើម្បីជួបសម្តេច សីហនុ លើកនេះដោយមានការជ្រោមជ្រែងពីសំណាក់ពួកចិនផង ។ សម្តេច សីហនុ នឹងកាន់មុខតំណែងជាប្រធានរដ្ឋាភិបាលចម្រុះ សឺន សាន ជានាយករដ្ឋមន្ត្រី ហើយ ខៀវ សំផន នឹងកាន់មុខតំណែងជារដ្ឋមន្ត្រីការបរទេសនិងមានឋានៈជាអនុប្រធានរបស់សម្តេច ។ សម្តេច សីហនុ បានមានព្រះរាជបន្ទូលប្រាប់ខ្ញុំ(អ្នកនិពន្ធ)ជាសម្ងាត់ថា "បន្ទាប់ពីបានសាកល្បងធ្វើសកម្មភាពដោយគ្មានជំនួយពីអ្នកដទៃ យើងបានត្រូវបង្ខំឲ្យបោះបង់មតិ" ។ សមាគមអាស៊ាននិងសហរដ្ឋអាមេរិកបានធ្វើឲ្យព្រះអង្គ និង សឺន សាន ដឹងយ៉ាងច្បាស់ថា ពួកគេនឹងយល់ព្រមផ្តល់ជំនួយរបស់ខ្លួនទៅឲ្យតែរដ្ឋាភិបាលស្របច្បាប់មួយដូចរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ គឺពុំមែនជាចលនាតស៊ូតាមព្រៃមួយឡើយ ។ ទីបំផុត នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ មេដឹកនាំទាំងបីបានជួបជុំគ្នាជាថ្មីនៅទីក្រុងកូឡាលំពួរសម្រាប់ពិធីមួយដែលកំណត់នូវការចាប់កំណើតនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ។ បើគិតឲ្យសព្វទៅ ពាក្យថារដ្ឋាភិបាលចម្រុះហាក់ដូចជាអនុគ្រោះសម្រាប់ខ្មែរក្រហមច្រើនជាង ។ ដៃគូទាំងអស់របស់រដ្ឋាភិបាលនេះបានយល់ស្របនឹងលក្ខខណ្ឌបួនរបស់ពួកគេ : រចនាសម្ព័ន្ធត្រីភាគី ការមិនមានភាពលើសលប់ជាងគេរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងបី (បានន័យថាគ្មានអ្នកណាលើសអ្នកណាទេ) របៀបប្រកាន់យកការសម្រេចចិត្តជាឯកច្ឆ័ន្ទ និងការអនុម័តយកទង់ជាតិនិងបទភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ ។ បើសិនជាពួកគេ(ភាគីពីរ)ចាកចេញពីរដ្ឋាភិបាលចម្រុះ ខ្មែរក្រហមនឹងអាចរក្សាទុកការហៅកម្ពុជាប្រជាធិបតេយ្យដដែល ។ ពិតហើយវាមានសង្ឃឹមតិចតួចណាស់ដែលថា ខ្មែរក្រហមសម្រេចចិត្តចាកចេញពីរដ្ឋាភិបាលចម្រុះនោះ ប៉ុន្តែចំណុចចុងក្រោយនេះ បានបញ្ចប់សេចក្តីសង្ឃឹមផ្សេងៗដែលថា ថ្ងៃណាមួយពួកមិនមែនកុម្មុយនីស្តច្បាស់ជាឆក់ឱកាសយកភាពស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យទៅប្រើមិនខាន ។ ម្យ៉ាងទៀត ខ្មែរក្រហមបានសម្រេចជោគជ័យធ្វើឲ្យនយោបាយបរទេសទៅជានាទីផាច់មុខរបស់គេ ។ មន្ត្រីការទូតរបស់កម្ពុជាប្រជាធិបតេយ្យដែលប្រចាំការនៅបរទេសនឹងត្រូវគាំទ្រឲ្យកាន់មុខតំណែងរបស់ខ្លួនដដែល ។

ប្រទេសវៀតណាមហាក់ដូចជាមិនសូវចាប់អារម្មណ៍នឹងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យប៉ុន្មានឡើយ ថ្វីបើការបង្កើតរបស់ខ្លួនបានផ្ដល់ជាទម្ងន់ដល់សមាគមអាស៊ានសម្រាប់តទល់គ្នានៅលើឆាកអន្តរជាតិ និងធ្វើឲ្យមានការកែប្រែថ្មីក្នុងចលនាតស៊ូក៏ដោយ ។ ចាប់ពីឆ្នាំ១៩៨២ ប្រទេសវៀតណាមក៏លែងជំទាស់នឹងភាពជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិទៀតដែរ ។ ចំនួនប្រទេសដែលបោះឆ្នោតគាំទ្រការសម្រេចចិត្តរបស់អាស៊ានប្រឆាំងនឹងវៀតណាមបានឈានឡើងពី៩១សំឡេងនៅឆ្នាំ១៩៧៩ រហូតដល់ចំនួនជាឯតទគ្គៈ១១៨សំឡេងនៅឆ្នាំ១៩៨៥ ។ សមាគមអាស៊ាននិងសហរដ្ឋអាមេរិកបានរៀបចំឲ្យមានកម្មវិធីផ្ដល់ជំនួយសេដ្ឋកិច្ច និងយោធាមួយព្រមទាំងការបណ្ដុះបណ្ដាលសម្រាប់ពួកសមាសភាពមិនមែនកុម្មុយនីស្ដនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យថែមទៀត ។ ចំណែកប្រទេសចិនដែលធ្លាប់ជួយខ្មែរក្រហមយ៉ាងសន្ធឹកសន្ធាប់រួចមកហើយ ព្រមទាំងប្រទេសកូរ៉េខាងជើងផងបានស្នើផ្ដល់ជំនួយមកឲ្យរដ្ឋាភិបាលចម្រុះនេះដែរ ។ ដោយសារជំនួយស្បៀងអាហារនិងមនុស្សធម៌ដែលផ្ដល់ដោយបណ្ដាអង្គការអន្តរជាតិចំពោះប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅតាមជំរំនានានៅតាមបណ្ដោយព្រំដែនរបស់ថៃ និងដោយសារសម្ភារយោធាដែលផ្ដល់ដោយប្រទេសចិននិងសមាគមអាស៊ាននោះ ចំនួនអ្នកប្រយុទ្ធមិនមែនកុម្មុយនីស្ដបានឡើងដល់ចំនួនប្រហែល៣០.០០០នាក់ ។

សមាគមអាស៊ានបានបំពាក់អាវុធឲ្យពួកមិនមែនកុម្មុយនីស្ដដើម្បីធ្វើឲ្យអ្នកទាំងនោះទៅជាគូសន្ទនា ដែលអាចទទួលយកបានជាមួយនឹងប្រទេសវៀតណាម ដោយនៅរក្សាការគាបសង្កត់ផ្នែកការទូតទៅលើក្រុងហាណូយដដែល ដើម្បីធ្វើឲ្យសម្រេចដំណោះស្រាយមួយតាមការចរចា ។ ដោយពាក្យពេចន៍ស្រដៀងគ្នានឹងសេចក្ដីថ្លែងការណ៍របស់អាស៊ាននៅសន្និសីទអន្តរជាតិស្ដីពីបញ្ហាកម្ពុជា បណ្ដាប្រទេសមិនមែនកុម្មុយនីស្ដបានសាកល្បងជាងដប់ពីរលើក ដើម្បីខំប្រឹងធ្វើឲ្យប្រទេសវៀតណាមដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា និងអនុញ្ញាតឲ្យប្រជាជនខ្មែរមានសិទ្ធិស្វ័យសម្រេចក្រោមការត្រួតត្រារបស់អន្តរជាតិ ។ ប៉ុន្តែវាមានការឯកភាពមួយតែសំបកក្រៅប៉ុណ្ណោះនៅក្នុងផ្ទៃសមាគមអាស៊ាន ។ ប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ដែលព្រួយបារម្ភជាងគេពីការគំរាមកំហែងរយៈពេលយូរដែលប្រទេសចិនដើរតួជាថ្មីក្នុងតំបន់នេះ បានខំប្រឹងសម្ដែងឲ្យឃើញភាពឆាប់ស្រុះស្រួលតែខាងខ្លួនដែរ ។ លោកឧត្ដមសេនីយ៍ បេននី មឺដានី ដែលពេលនោះជាប្រមុខផ្នែកស៊ើបការណ៍សម្ងាត់របស់ឥណ្ឌូនេស៊ី បានធ្វើដំណើរជាផ្លូវការចំនួនពីរលើកទៅកាន់ក្រុងហាណូយនៅឆ្នាំ១៩៨០ម្ដង និងឆ្នាំ១៩៨២ម្ដង ដើម្បីសាកល្បងស្វែងរករូបមន្តសម្រុះសម្រួលមួយ ។ ក្រុងហ្សាកាតាពុំមានជំនឿទុកចិត្តណាមួយទៅលើប្រទេសចិនដែលត្រូវសង្ស័យថា បានសម្ដែងតួនាទីមួយក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់កុម្មុយនីស្ដ(មិនបានសម្រេច) នៅឆ្នាំ១៩៦៥ឡើយ ។ ឥណ្ឌូនេស៊ីបានបង្ហាញនូវសមានចិត្តចំពោះការប្រយុទ្ធរំដោះជាតិនៅប្រទេសវៀតណាម និងការបង្កហេតុរបស់ខ្លួនចំពោះក្រុងប៉េកាំង ។ បេននី បានថ្លែងប្រកាសជាពិសេសថា ប្រទេសរបស់គាត់ចាត់ទុកការធ្វើអន្តរាគមន៍នៅប្រទេសកម្ពុជាជាទង្វើការពារខ្លួនត្រឹមត្រូវតាមច្បាប់មួយ ។ ប៉ុន្តែនៅចំពោះមុខ

ការប្រឆាំងជំទាស់យ៉ាងខ្លាំងក្លាពីសំណាក់ប្រទេសថៃ និង សិង្ហបូរី បេននី ត្រូវតែលះបង់គំនិតស្វែងរកដំណោះស្រាយរបស់គាត់ដែលសំអាងលើស្ថានការណ៍ជាក់ស្តែង ដែលកំពុងមានប្រៀបជាងនៅកម្ពុជា ។ នៅដើមឆ្នាំ ១៩៨៣ ប្រទេសម៉ាឡេស៊ីបានប្រឹងប្រែងបង្កឲ្យមានការសន្ទនាគ្នាមួយរវាងអាស៊ាននិងប្រទេសពីរនៅឥណ្ឌូចិន គឺប្រទេសឡាវនិងវៀតណាម ។ ប្រទេសថៃនិងប្រទេសចិនបានធ្វើឲ្យការប៉ុនប៉ងនេះបរាជ័យដោយសំអាងលេសថា នេះជាការអនុម័តយល់ព្រមផ្តល់សញ្ញាណនៃប្លុកឥណ្ឌូចិន ។ ក្នុងសំណើមួយផ្សេងទៀតនៅឆ្នាំ១៩៨៥ ប្រទេសម៉ាឡេស៊ីបានផ្តល់យោបល់ឲ្យរៀបចំការចរចាដោយមិន ចំពោះរវាងរដ្ឋាភិបាល ហេង សំរិន និងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ សំណើនេះបានពើបប្រទះនឹងការប្រឆាំងជំទាស់ជាថ្មីពីសំណាក់ប្រទេសថៃ ប្រទេសចិន និងខ្មែរក្រហម : គេមិនត្រូវជួយការពាររបបអាយ៉ងមួយឡើយ ។ សំណើមួយទៀតដែលម្តងនេះចេញមកពីប្រទេសឥណ្ឌូនេស៊ីបានស្នើឲ្យមានការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតជាមួយសហរដ្ឋអាមេរិកសិនដើម្បីជំរុញវៀតណាមឲ្យចាកចេញពីប្រទេសកម្ពុជា ប៉ុន្តែ ត្រូវបានច្រានចោលដោយប្រទេសថៃ និងសិង្ហបូរីទៀត ។

សមាគមអាស៊ានចេះទាញយកផលចំណេញពីការកេរ្តិ៍ឈ្មោះរបស់សហគមន៍អន្តរជាតិ ចំពោះតួនាទីរបស់ខ្លួនក្នុងបញ្ហារបស់កម្ពុជា ។ ឥឡូវនេះអាស៊ានត្រូវតែការពារឯកភាពរបស់ខ្លួនឲ្យបានជាដាច់ខាត គោលដៅនៅពេលនេះមានសារសំខាន់សម្រាប់ខ្លួនដូចគ្នានឹងការដោះស្រាយបញ្ហាកម្ពុជាដែរ ។ ដោយគោរពចំពោះមុខការទាមទាររបស់ប្រទេសថៃ- ដែលស្ថិតនៅជួរមុខទល់នឹងវៀតណាម - នេះហើយ ដែលការឯកភាពនេះត្រូវបានការពារ ។ ការប្រឆាំងជំទាស់ដោយគ្មានលាក់លៀមរបស់ប្រទេសថៃ បានបង្កឲ្យមានការអាក់អន់ចិត្តខ្លះៗនៅប្រទេសឥណ្ឌូនេស៊ី ដែលហាក់ដូចជាមានអារម្មណ៍ថា បណ្តោយ«ឲ្យក្រុងបាងកកដឹកនាំ» ស្រេចនឹងក្បាលចិត្តដោយយល់ថា ប្រទេសរបស់ខ្លួនជាប្រទេសមួយដែលមានផ្ទៃដីធំល្វឹងល្វើយនិងមានប្រជាពលរដ្ឋច្រើនជាងគេនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ ក្រុងហ្សាការតាយល់ឃើញថា ជម្លោះមួយដែលចេះតែបន្តឲ្យវែងឆ្ងាយនៅប្រទេសកម្ពុជាច្បាស់ជាគំរាមកំហែងដល់ឯកភាពរបស់តំបន់ និងបើកផ្លូវឲ្យមានការចូលធ្វើអន្តរាគមន៍កាន់តែខ្លាំងឡើងពីមហាអំណាចធំៗជាក់ជាប្រាកដ ។ ដូច្នេះ គេត្រូវតែនាំប្រទេសវៀតណាមឲ្យធ្វើសហប្រតិបត្តិការក្នុងផ្ទៃសហគមន៍អាស៊ីអាគ្នេយ៍ ហើយរៀប«គ្រឿងការពារ»ជុំវិញសហគមន៍នេះ ដើម្បីបញ្ចៀសមហាអំណាចផ្សេងៗឲ្យចេញឆ្ងាយរួមទាំងប្រទេសចិនផង[៤៩] ។

ប៉ុន្តែមានទស្សនៈខ្លះៗ ដែលត្រូវប្រញាប់ប្រញាល់រក្សាឲ្យមានភាពរួបរួមគ្នាក្នុងរដ្ឋាភិបាលចម្រុះមួយដែលមិនទាន់ស៊ីខ្សែគ្នានៅឡើយ ក៏ដូចរក្សាឯកភាពរបស់អាស៊ានដែរ ។ មិនត្រឹមតែគ្មានការសម្រុះសម្រួលណាមួយរវាងដៃគូនានារបស់រដ្ឋាភិបាលចម្រុះប៉ុណ្ណោះទេ ប៉ុន្តែពួកគេពុំសំចៃនឹងវាយប្រហារគ្នាជាសាធារណៈឡើយ ។ ខ្មែរក្រហមនិងពួកមិនមែនកុម្មុយនីស្តបានប្រឈមមុខដាក់គ្នាដោយយោធាម្តងម្កាលដែរ ។ ការ

ប្រើងប្រែងទាំងឡាយដែលធ្វើដោយបណ្តាប្រទេសខ្លះរបស់សមាគមអាស៊ាន ដើម្បីបំបាត់មិនឲ្យមានការរួបរួមកម្លាំងពីខ្មែរក្រហមមួយចំនួនតូចដែលមានប្រវត្តិអាក្រក់ជាងគេ បានធ្វើឲ្យមានបរិយាកាសមន្ទិលសង្ស័យមួយរវាងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និងបណ្តាប្រទេសឧបត្ថម្ភគាំទ្ររបស់ខ្លួន ។ នៅខែកញ្ញា ឆ្នាំ១៩៨៣ ក្នុងឱកាសនៃពិធីលៀងសាយភោជន៍មួយដែលរៀបចំដោយសមាគមអាស៊ានជាកិត្តិយសដល់ សម្តេច សីហនុ នៅសណ្ឋាគារ វ៉ាល់ដ័រ អាស់ថូរីយ៉ា នៅទីក្រុងញូវយ៉ក រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី ហ្គាហ្សាលី បានផ្តើមពិភាក្សាពីបញ្ហាមួយដោយប្រយ័ត្នប្រយែងបំផុតនៅមុខ ខៀវ សំផន ថា "ខ្ញុំសូមទោស តើលោកអាចស្នើឲ្យ ប៉ុល ពត, អៀង សារី និង តាម៉ុក ដកខ្លួនថយដើម្បីជាគុណប្រយោជន៍ខ្ពង់ខ្ពស់ដល់ប្រទេសកម្ពុជាឬទេ?" ។ សម្តេច សីហនុ ដែលចូលរួមជាមួយគ្នាដែរនោះបានលើកឡើងនូវសំណើដ៏ថ្លៃថ្នូរមួយថា "បើសិនឯកឧត្តម ប៉ុល ពត" មានបំណងប្រគល់ភារកិច្ចដឹកនាំកងទ័ពទៅឲ្យ ខៀវ សំផន ។ សីហនុ នឹងសព្វព្រះទ័យដាក់វិមាននៅទីក្រុងព្យុងយ៉ាងនិងភូមិគ្រឹះតូចមួយ នៅទីក្រុងមូហ្សីនរបស់ព្រះអង្គនៅប្រទេសបារាំងសម្រាប់ឲ្យប្រើប្រាស់តាមត្រូវការ ។ ត្រូវធ្វើឲ្យក្មៀវក្លាដោយទស្សនៈវិស័យនេះ សម្តេចឈានរហូតដល់បញ្ជាក់ថា វិមាននៅទីក្រុងព្យុងយ៉ាងមានអាងហែលទឹកមួយ សាលបញ្ចាំងភាពយន្តមួយ តារាងវាយសីនិងតារាងបាល់ទះទៀតផង ។ "អស់លោកអាចបរិភោគម្ហូបអាហារតាមតែអស់លោកចូលចិត្តមានតាំងពីម្ហូបបារាំង, ខ្មែរ និងចិន ។ អស់លោកច្បាស់ជាទទួលបានការរស់នៅមួយដ៏ស្ងប់ស្ងាត់បំផុតក្នុងទីនោះ" ។ ខៀវ សំផន ធ្វើមុខក្រញូវ ហើយឆ្លើយតបដោយសម្តីម៉ឺងម៉ាត់មួយថា : "របស់ទាំងអស់នោះពុំមានសារសំខាន់ទេ ។ អ្វីដែលសំខាន់គឺឯកភាព ។ យើងត្រូវរួបរួមគ្នាជានិច្ច ហើយយើងនឹងនៅតែរួបរួមគ្នាដដែល ។ គ្មានអ្នកណាមួយអាចបំបែកយើងឲ្យឃ្លាតពីគ្នាបានឡើយ" ។ បន្ទាប់ពីស្ថិតក្នុងសភាពស្ងៀមស្ងាត់គួរឲ្យធុញថប់មួយរយៈ រដ្ឋមន្ត្រីទាំងអស់បានចាប់ផ្តើមបរិភោគអាហារ[៥០] ។

ក្នុងឱកាសនៃសម័យប្រជុំគណៈរដ្ឋមន្ត្រីមួយនាខែកក្កដា ឆ្នាំ១៩៨៤ តេង ស៊ាវពីង ដែលដឹងថាសមាគមអាស៊ានបានជជែកពិភាក្សាគ្នាជាថ្មីអំពីការដកថយរបស់មេខ្មែរក្រហមល្បីឈ្មោះអាក្រក់មួយចំនួននោះ បានចេញនូវការព្រមានមួយដោយត្រង់ៗចំពោះរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យតែម្តង ។ នៅខែតុលា គាត់បានទទួលជួបរួមគ្នាទាំងសម្តេច សីហនុ, សឺន សាន និង ខៀវ សំផន នៅទីក្រុងប៉េកាំងហើយបានគំរាមថានឹងកាត់ផ្តាច់ជំនួយរបស់ចិនទាំងស្រុង បើសិនជាដៃគូណាមួយក្នុងរដ្ឋាភិបាលចម្រុះត្រូវគេកម្ចាត់ចេញ ។ គេងមានអាការៈខឹងច្រឡោតយ៉ាងខ្លាំង ។ គាត់បាននិយាយដោយសម្តីធ្ងន់ៗថា : "ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជាមានអ្នកខ្លះចង់រលាស់ ប៉ុល ពត ចោល? ពិតមែនតែថា គាត់បានប្រព្រឹត្តខុសខ្លះមែនកាលពីអតីតកាលប៉ុន្តែសព្វថ្ងៃ គឺគាត់នេះហើយដែលដឹកនាំការប្រយុទ្ធប្រឆាំងនឹងពួកឈ្លានពានវៀតណាមនោះ"[៥១] ។

ភាពតានតឹងដែលនៅដក់ជាប់ក្នុងផ្ទៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យមានសភាពរឹតតែធ្ងន់ធ្ងរឡើងៗដោយសារការគំរាមសុំលាលែងពីតំណែងរបស់ សម្តេច សីហនុ ម្តងទៀត ។ សម្តេចបានមានព្រះរាជ

បន្ទូលជាសម្ងាត់ប្រាប់សហការីម្នាក់ទាំងតូចព្រះទ័យថា ៖ «មុនប្រទេសកម្ពុជាទទួលបានឯករាជ្យភាព ខ្ញុំមានចៅហ្វាយតែមួយគត់គឺប្រទេសបារាំង ។ បន្ទាប់ពីបាត់បង់ឯករាជ្យភាពខ្ញុំមានចៅហ្វាយដល់ទៅប្រាំបីឯណោះ» ។ ចៅហ្វាយទាំងប្រាំបី គឺប្រទេសប្រាំមួយនៃសមាគមអាស៊ាន ប្រទេសចិន និងសហរដ្ឋអាមេរិក ។

នៅខែវិច្ឆិកា ឆ្នាំ១៩៨៤ សម្តេចបានស្នើសុំលាលែងពីតំណែងយកតែមែនទែន ។ ព្រះអង្គបានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសបារាំង ហើយពាក្យចចាមអារ៉ាមផ្សេងៗបានលេចឮសុសសាយមិនព្រមបាត់ស្តីពីការជួបគ្នារបស់ព្រះអង្គជាមួយ ហ៊ុន សែន រដ្ឋមន្ត្រីការបរទេសរបស់រដ្ឋាភិបាល ហេង សំរិន ដែលពេលនោះ កំពុងធ្វើទស្សនកិច្ចជាឯកជននៅរដ្ឋធានីប្រទេសបារាំងដែរ ។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៨៤ អារុណ ផានុពង្ស ឯកអគ្គរាជទូតប្រទេសថៃប្រចាំប្រទេសបារាំងបានចូលរួមក្នុងសន្និសីទមួយរបស់អង្គការអ៊ុយណេស្កូ និងបានត្រៀមខ្លួនឡើងថ្លែងសុន្ទរកថាមួយជាស្រេចនៅពេលដែលគាត់បានទទួលទូរលេខមួយពីមេកោយរបស់គាត់គឺ សិទ្ធិ សាវេតស៊ីឡា ដែលស្នើឲ្យគាត់ស្វះស្វែងធ្វើយ៉ាងណាឲ្យមានការណាត់ជួបគ្នាមួយជាបន្ទាន់រវាង សម្តេច សីហនុ និងរូបគាត់(សិទ្ធិ) ។ ពេលនោះ សិទ្ធិ បានឡើងជិះយន្តហោះមួយគ្រឿងរបស់ក្រុមហ៊ុនថៃ អន្តរជាតិស្រេចទៅហើយក្នុងដំណើរឆ្ពោះទៅទីក្រុងប៉ារីស ដើម្បីសាកល្បងឃាត់ឃាំងសម្តេចកុំឲ្យលាលែងពីតំណែង ។ អារុណ បានចាកចេញយ៉ាងប្រញាប់ប្រញាល់ពីសន្និសីទ ដោយពុំបានថ្លែងសុន្ទរកថារបស់គាត់ផងទេ ។

នៅពេលដែល អារុណ ទៅជួបសម្តេច គាត់បានទូលសួរថា តើពិតមែនទេដែលថា ព្រះអង្គបានដាក់ពាក្យសុំលាលែងពីតំណែងជូនទៅ ខៀវ សំផន ជាថ្មីនោះ? ។ អារុណ បានរៀបរាប់នៅពេលក្រោយមកថា ៖ «ព្រះអង្គបានបញ្ចេញព្រះពិរោធក្លាមតែម្តង» ។ «ខ្ញុំធុញទ្រាន់នឹងរឿងនេះណាស់ ។ ខ្ញុំលែងចង់ធ្វើអ្វីទាំងអស់ជាមួយរដ្ឋាភិបាលចម្រុះនេះហើយ» ។ ភាពប្រឡោតតូចតាចរបស់សម្តេចបានបន្តដោយព្រះបន្ទូលចំអកផ្សេងៗដែលព្រះអង្គធ្លាប់រងទទួលពីសំណាក់ពួកបាតុករស្នេហ៍ សឺន សាន កាលពីដប់ពីរថ្ងៃមុននៅទីក្រុងមីននា ផូលីស ក្នុងរដ្ឋមីណេសូតា សហរដ្ឋអាមេរិក ។ កាលបើរសាយកំហឹងហើយ ព្រះអង្គបានសម្រេចព្រះទ័យ សូមអញ្ជើញ សិទ្ធិ ឲ្យមកចូលរួមបរិភោគអាហារនៅសណ្ឋាគាររបស់ព្រះអង្គគង់ប្រថាប់នៅតំបន់ជាយក្រុងប៉ារីសដែរ ។ អារុណ បានភ្ជាប់ការទាក់ទងនឹង សិទ្ធិ ដែលកំពុងស្ថិតនៅក្នុងយន្តហោះរបស់គាត់ ដោយមធ្យោបាយវិទ្យុរបស់ក្រុមហ៊ុនថៃអន្តរជាតិជាបន្ទាន់ ។ នៅពេលមកដល់ចំណតអាកាសយានដ្ឋានស្ទាលដឺហ្គោលមិនទាន់បានស្រួលបួលផង អារុណ បាននាំ សិទ្ធិ មកបរិភោគអាហារនៅសណ្ឋាគារ សម្តេច សីហនុ ដោយគ្មានអែអង់ឡើយ ។ ដោយឆ្លៀតឱកាសក្នុងពេលបរិភោគអាហារដែលមានម្ហូបចំនួនដប់ពីរមុខ សិទ្ធិ បានថ្លែងថ្កោលទោសការនាំបង្កហេតុនៃពួកយុទ្ធិកជនរបស់ សឺន សាន ហើយបានបញ្ចុះបញ្ចូលសម្តេចឲ្យស្ថិតនៅជាមេដឹកនាំរដ្ឋាភិបាលចម្រុះតទៅទៀត ។ នៅយប់ថ្ងៃដដែលនោះ សិទ្ធិ បានក្ដួតចង្អោរពេញក្នុងឡានដែលកំពុងដឹកគាត់ ដោយពេញល្បឿនឆ្ពោះមកទីក្រុងប៉ារីសវិញ ។ រថយន្តមែរសីដេសមួយគ្រឿងត្រូវធ្វើឲ្យប្រឡាក់អស់ ៖ តើនេះជាតម្លៃដែលត្រូវបង់យ៉ាងថ្លៃបំផុត

សម្រាប់ភាពគង់វង្សនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យឬ?[៥៧] ។

បួនខែក្រោយមក សម្តេច សីហនុ បានធ្វើការគំរាមសុំលាលែងពីតំណែងជាថ្មី ដោយលើកនេះ ព្រះអង្គសំអាងលើមូលហេតុសុខភាព ។ តាមពិតការសម្រេចចិត្តរបស់ព្រះអង្គមានប្រភពជាដើមហេតុគឺ ដោយសារការបដិសេធរបស់ក្រុងប៉េកាំងមិនសន្ទនាជាមួយក្រុងហាណូយ ។ បណ្តារដ្ឋមន្ត្រីការបរទេសនៃសមាគមអាស៊ានបានរួមប្រជុំគ្នាជាបន្ទាន់នៅទីក្រុងបាន់ឌុង(ប្រទេសឥណ្ឌូនេស៊ី) ហើយបានតាក់តែងសេចក្តីអំពាវនាវរួមគ្នាមួយចំពោះសម្តេច ក្នុងគោលបំណងសូមឲ្យព្រះអង្គសើរើការសម្រេចព្រះទ័យរបស់ព្រះអង្គឡើងវិញ ។ សម្តេចបានយល់ព្រម ប៉ុន្តែនៅខែកក្កដា ឆ្នាំ១៩៨៥ ព្រះអង្គបានចោទប្រកាន់ជាសាធារណៈថា ដៃគូរបស់ព្រះអង្គគឺខ្មែរក្រហមបានសម្លាប់យុទ្ធិកៈរបស់ទ្រង់អស់ចំនួន៣៨នាក់ ។ ជាងនេះទៅទៀត ព្រះអង្គបានប្រកាសថា "ការសម្រេចព្រះទ័យចាកចេញពីរដ្ឋាភិបាលចម្រុះនឹងពុំអាចប្រែក្រឡាស់បានឡើយ" ។ រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យមានជីវិតគង់នៅមិនជាល្អ មិនជាអាក្រក់(ធម្មតា) ទោះជាមានវិបត្តិផ្ទៃក្នុងរបស់ខ្លួនក៏ដោយ ។ ពេញថិរវេលានៃរដូវប្រាំងឆ្នាំ១៩៨៤-១៩៨៥ ដែលការវាយប្រយុទ្ធគ្នាដ៏តឹងតែងបំផុតបានប៉ះពាល់ដល់ភាពគួរឲ្យទុកចិត្តរបស់ព្រះអង្គ ។ ការវាយលុកយ៉ាងខ្លាំងក្លាមួយក្នុងរយៈពេលប្រាំខែ ដោយប្រើប្រាស់កាំភ្លើងធំនិងរថក្រោះ ដើម្បីវាយប្រហារបណ្តាជំរំស៊ីវិលនិងមូលដ្ឋានកងទ័ពនានានៅតាមព្រំដែនខ្មែរ-ថៃ វៀតណាមបានធ្វើឲ្យដែនដីដែលគ្មានភាពប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ វៀតណាមបានដណ្តើមយកពីខ្មែរក្រហមជាពិសេសមូលដ្ឋានផ្គត់ផ្គង់សំខាន់ៗជាច្រើន និងធានីដែលគេមិនអាចយកជាការឈ្មោះភូមិថ្មីដែលកសាងឡើងក្នុងព្រៃស្បាតក្បែរព្រំដែនរបស់ថៃ ហើយជាកន្លែងមួយដែលសម្តេច សីហនុ ទទួលលិខិតសារតាំងរបស់ឯកអគ្គរដ្ឋទូតនានារបស់បរទេសដោយការក្រេបស្រាសាំប៉ាញផង ។ បន្ទាប់ពីការវាយលុករបស់វៀតណាម ចលនាតស៊ូមាននៅសល់តែមូលដ្ឋានមួយប៉ុណ្ណោះនៅលើទឹកដីរបស់កម្ពុជា ។ ខ្មែរក្រហមបានបង្ខំចិត្តបំបែកកងទ័ពរបស់ខ្លួន ជាកងឯកភាពតូចៗនិងពង្រាយចូលមកផ្ទៃក្នុងប្រទេសវិញ ។ ប្រជាជនស៊ីវិលចំនួន៤៦.០០០នាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនបានស្វែងរកទីជម្រកនៅប្រទេសថៃ ។ ពួកយុទ្ធិកជនរបស់សម្តេច និង សឺន សាន ព្រមទាំងជនភៀសខ្លួនចំនួន២៥០.០០០នាក់ ដែលត្រូវទទួលឲ្យស្នាក់នៅតាមជំរំនានាដែលត្រួតត្រា ដោយចលនាតស៊ូនៅក្បែរព្រំដែនថៃនោះប្រហែលជាដកថយទៅព្រំដែនម្ខាងទៀត ។

បរាជ័យផ្នែកយោធានេះបង្ហាញឲ្យឃើញច្បាស់នូវភាពទន់ខ្សោយផ្នែកមនោគមវិជ្ជា និងការខ្វះការរៀបចំនិងការហ្វឹកហាត់របស់ក្រុមមិនមែនកុម្មុយនីស្តទាំងឡាយ ជាពិសេសរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ ជាក្រុមមិនសូវប្តូរផ្តាច់ក្នុងជំនឿហួសហេតុណាមួយដូចខ្មែរក្រហម ទាហាននៃក្រុមមិនមែនកុម្មុយនីស្តទាំងនោះមិនចង់បោះបង់គ្រួសាររបស់ខ្លួន ដើម្បីមកធ្វើសង្គ្រាមទ័ពព្រៃខាងក្នុងប្រទេសឡើយ ។ អ្នកប្រយុទ្ធសីហនុនិយមបានដឹកនាំកម្លាំងធ្វើការលុកលុយក្នុងដែនដីសត្រូវដាច់ៗពីគ្នា ក្នុងគោលបំណងធ្វើការឃោសនាប៉ុណ្ណោះ ប៉ុន្តែ

នៅគ្រាដែលបាត់បង់ជីវិតអស់ យុទ្ធជន១៤.០០០នាក់របស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរបានត្រូវធ្វើឲ្យធ្លាក់ក្នុងស្ថានភាពលែងរីកលូតលាស់ទាល់តែសោះ ។ នាយទាហានជាច្រើននាក់របស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ មិនសូវចូលចិត្តរបៀបដឹកនាំ“ផ្ដាច់ការ”របស់ សឺន សាន ប៉ុន្មានឡើយ ហើយក៏មិនចូលចិត្តការជ្រៀតជ្រែករបស់គាត់ក្នុងកិច្ចការយោធា និងការបដិសេធរបស់គាត់ មិនសហការជាមួយសម្ដេច សីហនុ ដែរ ។ នៅទីបំផុត កំហឹងដែលមិនបង្ហាញលក្ខណៈមកខាងក្រៅបានប្រែក្លាយទៅជាការបះបោរជាចំហនៅខែធ្នូ ឆ្នាំ១៩៨៥ ។ សមាគមអាស៊ានបានធ្វើអន្តរាគមន៍ដើម្បីរម្ងាប់អធិករណ៍នេះ ហើយការចាត់ចែងដឹកនាំទាហានរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរត្រូវធ្លាក់ទៅលើដៃទាហានថៃវិញ ។

## ខ្លាឃ្មុំ ដាក់ជើងមកទិសខាងត្បូង

ដើម្បីទ្រទ្រង់ចលនាតស៊ូនិងរដ្ឋាភិបាលចម្រុះដែលឃ្លេងឃ្លោងឲ្យនៅគង់វង្សដដែលនោះ សមាគមអាស៊ានបានផ្លាស់ប្ដូរគោលដៅរបស់ខ្លួនជាថ្មី ៖ បញ្ចៀសមហាអំណាចធំៗឲ្យផុតពីអាស៊ីអាគ្នេយ៍ ។ ក្នុងរយៈពេល៦ឆ្នាំដែលមានបន្ទាប់ពីការចូលលុកលុយប្រទេសកម្ពុជា គេឃើញមានការពង្រឹងកម្លាំងដ៏សម្បើមអស្ចារ្យមួយនៃវត្តមានយោធារបស់សូវៀតក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដែលយកតម្រាប់តាមដោយសហរដ្ឋអាមេរិកដែរ ។ ដោយឆ្លៀតទាញយកគុណប្រយោជន៍ពីភាពឯកោរបស់វៀតណាមនិងស្ថានភាពសេដ្ឋកិច្ចប្រកបដោយគ្រោះថ្នាក់និងការគំរាមកំហែងរបស់ចិន ក្រុងមូស្គូបានធ្វើខ្លួនទៅជាអ្នកការពារប្រទេសវៀតណាមដ៏សំខាន់បំផុត ។ ជាថ្នូរមកវិញ ពួកសូវៀតត្រូវបានអនុញ្ញាតឲ្យតាំងមូលដ្ឋានយោធាជាច្រើនកន្លែង ដែលក្រុងហាណូយធ្លាប់ចចេសបដិសេធតាំងពី៤ឆ្នាំមកហើយ ។ ក្នុងរយៈពេល២ឆ្នាំដែលមានជាបន្តបន្ទាប់ពីការឈ្លានពានរបស់ចិន ក្រុងមូស្គូបានផ្គត់ផ្គង់សព្វាវុធទៅក្រុងហាណូយមានតម្លៃរហូតដល់២កោដិដុល្លារ (២.០០០លានដុល្លារ) គឺច្រើនជាងឆ្នាំ១៩៧៨ចំនួនដប់ដង ។ តមកទៀត ការប្រគល់សម្ភារសឹកបានត្រូវថយចុះ ប៉ុន្តែទំហំជាមធ្យមនៃជំនួយយោធារបស់សូវៀតនៅតែមានចំនួនប្រហែល៧៥០លានដុល្លារក្នុងមួយឆ្នាំៗដែរ ។ ក្រុងហាណូយបានទទួលជាពិសេសនូវសម្ភារចាស់ៗដែលបណ្ដាប្រទេសនៃកតិកាសញ្ញា វ៉ាសូវី (បច្ចុប្បន្នរលាយបាត់ស្រមោល) និងសម្ព័ន្ធមិត្តដទៃៗទៀតរបស់សូវៀតទុកចោលលែងប្រើទៅហើយ ប៉ុន្តែវៀតណាមត្រូវតែបង្ហាញនូវការដឹងគុណខ្លះៗដូចគេដូចឯងដែរ ។ ចាប់ពីថ្ងៃនេះទៅទ្វារទាំងអស់របស់ប្រទេសបានបើកចំហយ៉ាងធំសម្រាប់បុគ្គលិកធ្វើការរបស់សូវៀត ។ នៅឆ្នាំ១៩៨៦ គេឃើញមានទីប្រឹក្សាសូវៀតប្រចាំការនៅវៀតណាមប្រហែល២.០០០នាក់ទល់នឹង២៥នាក់ប៉ុណ្ណោះកាលពីដើមឆ្នាំ១៩៧៧ ។ ម្យ៉ាងទៀត ខាងផ្នែកជំនួយបច្ចេកទេសមានជំនាញការសូវៀតប្រហែល៣.០០០នាក់បានធ្វើការនៅតាមការដ្ឋានផ្សេងៗច្រើនកន្លែង ជាពិសេសកន្លែងរុករកប្រេងកាតនៅលំហសមុទ្រក្បែរឆ្នេរវៀតណាម ។ តាមក្រុមស៊ើបការណ៍សម្ងាត់អាមេរិកាំងបានឲ្យដឹងថា

តាំងពីឆ្នាំ១៩៧៩ ទំហំនៃជំនួយផ្នែកសេដ្ឋកិច្ចរបស់សូវៀតបានឡើងដល់១.០០០លានដុល្លារក្នុងមួយឆ្នាំ[៥៣] ។ ក្នុងពេលជាមួយគ្នានោះ សហភាពសូវៀតបានបង្កើតជំនួយសេដ្ឋកិច្ចនិងយោធារបស់ខ្លួនទៅប្រទេសឡាវនិងកម្ពុជាផងដែរ និងពង្រីងវត្តមានរបស់ខ្លួននៅប្រទេសទាំងពីររឹតតែខ្លាំងឡើងថែមទៀត ។

វៀតណាមបានបង់បំណុលរបស់ពួកគេឲ្យពួកសូវៀតបន្តិចម្ដងៗជារៀងរាល់ខែ... ។ ដប់មួយថ្ងៃ បន្ទាប់ពីការចាប់ផ្ដើមចូលឈ្លានពានរបស់ចិន ផាំ វ៉ាន់ដុង បានធ្វើដំណើរដោយសម្ងាត់ទៅកាន់ទីក្រុងមូស្គូ ។ នៅខែមីនា ឆ្នាំ១៩៧៩ ក្រោយដំណើរវិលត្រឡប់របស់គាត់បន្តិច នាវាគាំទ្រជាច្រើនគ្រឿងនៃកងនាវាស៊ើបការណ៍សូវៀតនៅសមុទ្រចិនខាងត្បូង បានបោះយុថ្កាសំចតនៅកំពង់ផែ ដាណាង[៥៤] ។ ប្រាកដណាស់ ការអនុញ្ញាតនេះពិតជាផ្ដល់ភ្លើងបៃតងដោយ ដុង ក្នុងឱកាសនៃការសន្ទនាផ្សេងៗដែលគាត់បានធ្វើនៅទីក្រុងមូស្គូ ។ តាមអ្នកជំនាញការអាមេរិកាំងថា ការពង្រីងវត្តមានយោធារបស់សូវៀតរឹតតែច្រើនឡើងនៅប្រទេសវៀតណាម គឺជាលទ្ធផលនៃកិច្ចព្រមព្រៀងដោយឡែក ដែលបានសម្រេចក្នុងអំឡុងពេលមានការជួបគ្នាដោយទៀងទាត់រវាងអ្នកទទួលខុសត្រូវនៃប្រទេសទាំងពីរ ពុំមែនជាកិច្ចសន្យាមួយដែលមានរយៈពេលមិនកំណត់ ឬការជួលមានកំណត់នូវទីតាំងនានារបស់វៀតណាមទេ ។ មាត្រាទី៦នៃសន្ធិសញ្ញាសូវៀត-វៀតណាមបានចែងការពារជាមុនថាត្រូវជួបធ្វើការពិគ្រោះគ្នាក្នុងករណីដែលមានការគំរាមកំហែងដល់សន្តិសុខរបស់ភាគីហត្ថលេខី និងការប្រកាន់យកវិធានការសមស្របដើម្បីប្រឈមមុខទល់នឹងការគំរាមកំហែងនោះ ។

កាន់តែមានន័យជាក់លាក់ទៅទៀត នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៩ កងនាវាដើងទឹកតូចមួយរួមមាននាវាល្បាតបើកមុខក្បួនមួយគ្រឿង នាវាប្រដេញល្បឿនលឿនមួយគ្រឿង និងនាវាស្រង់មីនមួយគ្រឿងបានបោះយុថ្កាឈប់សំចតនៅឆកសមុទ្រកាំរ៉ាញ់ ជាទីកន្លែងដែលនាវាសូវៀតច្រើនគ្រឿងធ្លាប់មកបោះយុថ្កា ជាលើកដំបូងបំផុតតាំងពីថ្ងៃទី១២ ខែមេសា ឆ្នាំ១៩០៥ម៉្លេះ ។ នៅថ្ងៃនោះនាវាមួយកងធំមានចំនួន៤២គ្រឿងដែលដឹកនាំដោយឧត្ដមនាវីនិយមស្ដេចត្បារ ឈ្មោះ ស៊ីណូវី រ៉ូដេសវិនស្គី បានជ្រៀតចូលមកក្នុងឆកសមុទ្រនេះ ។ ភាពខុសគ្នាតែមួយគត់គឺកាលពី ឆ្នាំ១៩០៥ នៅទីនោះមានតែកន្លែងយកធ្យូងថ្មមួយប៉ុណ្ណោះ ដែលពិបាកស្នាក់អាស្រ័យនៅផងនិងដែលកាន់កាប់ដោយពួកបារាំងផង ។ ពួកនេះបានបញ្ជាឲ្យកងនាវារបស់សូវៀតចាកចេញពីទីនោះ ដើម្បីការពារអព្យាក្រឹតភាពរបស់ប្រទេសក្នុងសង្គ្រាមរវាងសូវៀត-ជប៉ុន ។ ៧៤ឆ្នាំក្រោយ ពួកអាមេរិកាំងបានបន្សល់ទុកពីក្រោយពួកគេនូវមូលដ្ឋានអាកាសចរ និងមូលដ្ឋាននាវាចរមួយដែលមានសារសំខាន់ខ្លាំងជាងគេបំផុត ។ នៅទីបំផុត មូលដ្ឋាននេះក៏ក្លាយទៅជាមូលដ្ឋាននាវាចរយ៉ាងធំរបស់ពួកសូវៀតវិញ និងជាកំពង់ផែឈប់សំចតដ៏សំខាន់របស់គេនៅក្រៅសហភាពសូវៀត ហើយក៏ជា“មូលដ្ឋាន”សម្រាប់ការវាតទីនៃកងនាវាចររបស់ខ្លួន នៅសមុទ្រចិនភាគខាងត្បូង និងមហាសមុទ្រឥណ្ឌាដែរ ។

អាស្រ័យដោយការសម្រេចតាំងពីដំបូងមួយ ពួកសូវៀតមិនកសាងមូលដ្ឋានទ័ពណាមួយនៅទឹកដី

ប្រទេសក្រៅដែលអាចត្រូវបោះបង់ចោលវិញឡើយ លើកលែងតែមូលដ្ឋានកាំរ៉ាញ់នៅវៀតណាមមួយប៉ុណ្ណោះ ។ នៅទីនោះមានស្ថានីយឈ្លបចាំស្តាប់មួយសម្រាប់កត់ត្រាទុកនូវចលនាកងនាវាចររបស់អាមេរិកាំង និងចិននៅក្នុងសមុទ្រចិនខាងត្បូង ។ ក៏ប៉ុន្តែ ពួកសូវៀតបានបង្កើនចំនួននាវាធំៗនិងយន្តហោះរបស់ខ្លួន ដែលតាំងមូលដ្ឋាននៅឆកសមុទ្រកាំរ៉ាញម្តងបន្តិចៗ ប៉ុន្តែដោយគ្មានភ័យនឹងអន្តរាយ ។ នាវាដែលបញ្ជូនមកនៅឆ្នាំ១៩៧៩មានពី៥ទៅ១០គ្រឿង និងពី២៥ទៅ៣៥គ្រឿងនៅឆ្នាំ១៩៨៥ ។ ចំណែកយន្តហោះគេបានបញ្ជូនមកជាមធ្យម មួយថ្ងៃពី១០ទៅ១៥គ្រឿងនៅឆ្នាំ១៩៧៩ និងពី៣៥ទៅ៤០គ្រឿងនៅរយៈពេល៦ឆ្នាំក្រោយមកទៀត ។ ជាមួយយន្តហោះទម្លាក់គ្រាប់បែកសម្រាប់វាយប្រហារតាមសមុទ្រចំនួន១៦គ្រឿង ម៉ាក Badger យន្តហោះMIG-២៣មួយកង ដែលអាចធ្វើអន្តរាគមន៍គ្រប់ពេលទោះជាស្ថានភាពខគុនិយមបែបណាក៏ដោយ បូកបន្ថែមនឹងយន្តហោះដឹកជញ្ជូន និងយន្តហោះស៊ើបការណ៍ជាច្រើនដែលសុទ្ធតែសំចតនៅវៀតណាមទាំងអស់ បានធ្វើឲ្យសមត្ថភាពធ្វើអន្តរាគមន៍របស់សហភាពសូវៀតនៅភូមិភាគអាស៊ីអាគ្នេយ៍លឿនហួសពីបំណងដ៏ខ្ជាប់ខ្ជួនមិនសមហេតុផលរបស់ខ្លួនមុនឆ្នាំ១៩៧៨ទៅទៀត ។ នៅដើមឆ្នាំ១៩៨៦ សហភាពសូវៀតបានក្លាយទៅជាមហាអំណាចជើងទឹកមួយក្នុងចំណោមមហាអំណាចជើងទឹកដំបូងៗនៅអាស៊ី[៥៥] : នាវាធំៗរបស់សូវៀតពី២០ទៅ២៥គ្រឿង រួមទាំងនាវាមុជទឹកមួយចំនួនផង បានបើកបរល្បាតច្រវាត់ច្រវែងនៅសមុទ្រចិនភាគខាងត្បូងដោយរៀបចំបម្រុងឆកសមុទ្រកាំរ៉ាញ់ឲ្យទៅជាកន្លែងសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារ ប្រេងឥន្ធនៈ គ្រាប់រំសេវនិងអ្វីសម្រាប់ជួសជុលកប៉ាល់ផង ។ ដោយហេតុនេះ ក្រុងមូស្គូអាចពង្រាយកម្លាំងរបស់ខ្លួនក្នុងមហាសមុទ្រឥណ្ឌាចំនួនពីរដងខ្លាំងជាងកាលពីអតីតកាល ។ បើក្រឡេកមើលទៅក្រោយវិញ ការជ្រើសរើសរបស់ប្រឹហ្សឺនស្គីក្នុងការគាំទ្រប្រទេសចិនដើម្បីវាយប្រហារលទ្ធិវាតទីនិយមរបស់សូវៀតអាចមានផ្លូវអ៊ុតហើយ ។

## ច្រកផ្លូវដែលនាំទៅរកការចាប់ផ្តើមបានត្រូវបិទ

នៅប្រទេសកម្ពុជា សង្គ្រាមទ័ពព្រៃបានកញ្ជ្រោលឡើងយ៉ាងខ្លាំងក្នុងបរិបទនៃការពង្រឹងកម្លាំងយោធារបស់សូវៀតនៅឥណ្ឌូចិន ។ ក៏ប៉ុន្តែ បន្ទាប់ពីរយៈពេលពីរឆ្នាំនៃដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់ តេង នៅក្រុងវ៉ាស៊ីនតោន ភាពចាំបាច់ជាយុទ្ធសាស្ត្រដែលធ្លាប់ធ្វើឲ្យពួកអាមេរិកាំងលេងសន្លឹកបៀចិនលែងដូចមុនទៀតហើយ ។ សម្ព័ន្ធភាពជាយុទ្ធសាស្ត្ររវាងចិន-អាមេរិកដែល ប្រឹហ្សឺនស្គី តស៊ូយ៉ាងស្វិតស្វាញធ្វើឲ្យបានសម្រេចនៅឆ្នាំ១៩៧៨បានចាប់ផ្តើមជួបការលំបាកជាមួយការជ្រើសតាំងលោក រ៉ូណាល់ រីហ្គេន[៥៦] ជាប្រធានាធិបតីដែលបានសន្យាក្នុងអំឡុងពេលធ្វើការឃោសនារកសំឡេងឆ្នោតថា គាត់នឹងកែលម្អទំនាក់ទំនងផ្សេងៗរវាងសហរដ្ឋអាមេរិកនិងតៃវ៉ាន់ឲ្យបានល្អប្រសើរជាងមុន ។ រហូតមកដល់ឆ្នាំ១៩៨០ ទើបសម្ព័ន្ធភាពនេះបានទទួលផ្លែផ្កា (បន្ទាប់ពីការលុកលុយប្រទេសអាហ្វហ្គានីស្ថានដោយពួកសូវៀត) ក្រោមទម្រង់ជាសហ-

ប្រតិបត្តិការមួយខាងសន្តិសុខទាក់ទងនឹងវិស័យជាច្រើន ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសចិន បានចាប់ផ្តើមពិនិត្យឡើងវិញក្នុងការសម្របផ្នែកយុទ្ធសាស្ត្ររបស់ខ្លួនតាមសហរដ្ឋអាមេរិក សម្រាប់មូលហេតុផ្សេងៗខាងនយោបាយក្នុងប្រទេស ។ កាលបើការទាស់ទែងគ្នារបស់ខ្លួន ជាមួយក្រុងវ៉ាស៊ីនតោន ស្តីពីបញ្ហាលក់អាវុធទៅឲ្យតៃវ៉ាន់ក្លាយជាច្បាស់លាស់ហើយនោះ-ជាបញ្ហាដែលទុកមិនទាន់សម្រេចក្នុងកិច្ចព្រមព្រៀងរួមមួយនៅខែធ្នូ ឆ្នាំ១៩៧៨ ដើម្បីប្រញាប់ចង់ឃើញការធ្វើឲ្យមានប្រក្រតីភាពចេញជាលទ្ធផលសិន-នយោបាយបរទេសរបស់ក្រុងប៉េកាំងក៏ផ្លាស់ប្តូរទិសដែរ ។ ពីសេចក្តីអំពាវនាវឲ្យមានការចាត់តាំងរណសិរ្សរួបរួមមួយប្រឆាំងនឹងក្រុងមូស្គូដែលអូតដោយ តេង ស៊ាវពីង ប្រទេសចិនបានបែរទៅចងសាមគ្គីភាពជាមួយបណ្តាប្រទេសតតិយលោកវិញ និងស្វែងរកការធ្វើសហប្រតិបត្តិការខាងសេដ្ឋកិច្ចជាជាងការប្រឈមមុខដាក់គ្នា ។ ការតម្រង់ទិសថ្មីនេះមានប្រយោជន៍សម្រាប់ប្រទេសទាំងអស់រួមទាំងសហភាពសូវៀត និងអឺរ៉ុបខាងកើតផង ប៉ុន្តែលើកលែងតែប្រទេសវៀតណាមមួយប៉ុណ្ណោះ ។ នៅចុងឆ្នាំ១៩៨១ លី ស៊ាននាន ឧបនាយករដ្ឋមន្ត្រីចិនបានប្រកាសថាប្រទេសរបស់គាត់ប្រាថ្នាបន្តដំណើរធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងមូស្គូឡើងវិញ ដែលបានផ្អាកតាំងពីមានការលុកលុយប្រទេសអាហ្វហ្កានីស្ថានមក ។

ដោយឆ្លៀតទាញយកប្រយោជន៍ពីភាពតានតឹងរវាងក្រុងវ៉ាស៊ីនតោននិងក្រុងប៉េកាំង សហភាពសូវៀតបានធ្វើប្រតិកម្មដោយអនុគ្រោះចំពោះការកម្រើកជាថ្មីនូវយកចិត្តទុកដាក់ពីសំណាក់ប្រទេសចិននេះ ។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៨២ ឡេអូនីដ ប្រេសណេវ អគ្គលេខាបក្សកុម្មុយនីស្តសូវៀតបានសម្តែងឲ្យដឹងជាសាធារណៈនូវបំណងកែលម្អទំនាក់ទំនងផ្សេងៗរវាងប្រទេសទាំងពីរឡើងវិញ ។ ដោយរំលឹកទាំងប្រុងប្រយ័ត្នថាក្រុងមូស្គូមិនដែលយល់ស្របនឹងនិក្ខេបបទប្រទេសចិនពីរឡើយ គាត់ចៀសវាងមិនចោទពួកចិនថា "ជនក្បត់នឹងលទ្ធិម៉ាក្ស-លេនីន"ដូចកាលពីដើមទេ : "យើងមិនដែលជំទាស់ ហើយឥឡូវនេះយើងមិនជំទាស់ពីអត្ថិភាពនៃប្រព័ន្ធសង្គមនិយមមួយនៅប្រទេសចិនទេ"[៥៧] ។ ក្រុងប៉េកាំងបានសងសម្តីទៅវិញភ្លាមៗ ដោយបន្ទុំឲ្យក្រុងមូស្គូដកចោលនូវឧបសគ្គចំនួនបីក្នុងការធ្វើឲ្យមានប្រត្រតីភាពរវាងប្រទេសទាំងពីរ ដែលប្រទេសចិន ចាត់ទុកថាជាការគំរាមកំហែងដល់សន្តិសុខរបស់ខ្លួន :

១) ការគាំទ្ររបស់សូវៀតចំពោះការកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាម ។

២) ការកាន់កាប់ប្រទេសអាហ្វហ្កានីស្ថាន ដោយពួកសូវៀត ។

៣) ការពង្រាយទ័ពយ៉ាងសម្បើមនៅតាមព្រំដែនចិន ។

ប្រាំពីរខែក្រោយមក ការជួបចរចាគ្នាស្តីពីការធ្វើឲ្យមានប្រក្រតីភាពបានចាប់ផ្តើមជាថ្មី ។

បើទុកជាមានការធានាដែលអះអាងជាសាធារណៈដោយ ប្រេសណេវ ថាការខិតចូលជិតគ្នាជាមួយប្រទេសចិននឹងមិនធ្វើឲ្យ"ខូចប្រយោជន៍ដល់ប្រទេសទីបី"ក៏ដោយ ក៏ក្រុងហាណូយត្រូវធ្វើឲ្យអាក់អន់ក្នុងចិត្ត

ដោយការបើកកិច្ចចរចានេះរួចជាស្រេច ។ នេះពុំមែនជាលើកទីមួយទេ ដែលមហាអំណាចជាមិត្តម្នាក់បានលះបង់ផលប្រយោជន៍របស់វៀតណាមសម្រាប់អត្ថប្រយោជន៍ជាយុទ្ធសាស្ត្រផ្ទាល់របស់ខ្លួននោះ ។ ប៉ុន្តែ ការជួបគ្នាជាបន្តបន្ទាប់ចំនួនប្រាំពីរលើក រវាងចិននិងសូវៀតដែលប្រព្រឹត្តទៅចាប់ពីសរទរដូវឆ្នាំ១៩៨២ ហាក់ដូចជាពុំនាំទៅដល់ភាពធូរស្រាលណាមួយស្តីពីការគាំទ្ររបស់សូវៀតឡើយ ។ ដោយជាក់ស្តែង ក្រុងមូស្គូ ក៏មិនធ្វើឲ្យមានគ្រោះថ្នាក់ដល់គោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួននៅប្រទេសវៀតណាម ដើម្បីបំពេញចិត្តចិនដែរ ។ ថ្វីបើមាន“ឧបសគ្គ”ជាច្រើនដែលត្រូវដោះស្រាយជាបន្ទាន់ក៏ដោយ ក៏ទំនាក់ទំនងផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្ម និងវប្បធម៌រវាងប្រទេសចិននិងសហភាពសូវៀតបានរីកលូតលាស់គួរឲ្យកត់សម្គាល់ ។ ឧទាហរណ៍នៅឆ្នាំ១៩៨៥ មានការផ្លាស់ប្តូរគណៈប្រតិភូទៅវិញទៅមករវាងប្រទេសទាំងពីរលើសពីប្រាំពីរលើក ។ បន្ទាប់ពីទស្សនកិច្ចជាលើកដំបូងនៅប្រទេសចិននាខែធ្នូ ឆ្នាំ១៩៨៤ របស់អ្នកទទួលខុសត្រូវជាន់ខ្ពស់សូវៀតម្នាក់ គឺឧបនាយករដ្ឋមន្ត្រី អ៊ីវ៉ាន់ អាឃីប៉ូវ និងទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិន យ៉ាវ យីលីន នៅសហភាពសូវៀតក្នុងខែកក្កដា ឆ្នាំ១៩៨៥ ក្រុងមូស្គូបានយល់ព្រមសន្យាផ្តល់ហិរញ្ញវត្ថុសម្រាប់ការធ្វើទំនើបកម្មខាងផ្នែកឧស្សាហកម្មចំនួនដប់ប្រាំពីរកន្លែង និងស្ថាបនារោងចក្រថ្មីចំនួនប្រាំពីរទៀត ។ កិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខានៅឆ្នាំ១៩៨៥បានចែងថា ពាណិជ្ជកម្ម ជាឧភតោភាគីនឹងត្រូវបង្កើនចំនួនមួយគុណនឹងដប់ពីរដង ក្នុងរយៈពេលប្រាំឆ្នាំ ។ ក្រុងប៉េកាំងបានបន្តទាមទារថា ទំនាក់ទំនងជាក់លាក់ខាងនយោបាយនឹងអាចកែលំអឲ្យបានប្រសើរលើសមុនតែងរាបណា“ឧបសគ្គ”ផ្សេងៗ ជាពិសេសឧបសគ្គស្តីពីប្រទេសកម្ពុជានឹងត្រូវបានដកចេញដោយក្រុងមូស្គូ ។ ប៉ុន្តែការទាក់ទងគ្នាជាច្រើនទៀតចេះតែមានជាហូរហែក្នុងកម្រិតសហជីពនិងអង្គការយុវជន ហើយរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរបានគ្រោងធ្វើដំណើរទស្សនកិច្ចទៅវិញទៅមកថែមទៀតនៅឆ្នាំ១៩៨៦ ។

ប៉ុន្តែក្រុងប៉េកាំងនៅតែមិនទុកចិត្តទាល់តែសោះចំពោះក្រុងមូស្គូដែលបង្ហាញឲ្យឃើញការគំរាមកំហែងយូរអង្វែងមួយចំពោះប្រទេសចិនដដែល ។ ប៉ុន្តែ ដោយមានទំនាក់ទំនងជិតស្និទ្ធនឹងសូវៀត គឺវាអាចផ្តល់គុណប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច ហើយនឹងផ្តល់ជាមធ្យោបាយមួយឲ្យក្រុងមូស្គូធ្វើការកៀបសង្កត់ខាងចិត្តសាស្ត្រទៅលើប្រទេសវៀតណាម ដែលអាចជំរុញឲ្យប្រទេសនេះស្វែងរកការសម្របសម្រួលមួយជាមួយប្រទេសចិន ។ ជាការជាក់ច្បាស់ណាស់ ដោយមានគោលដៅសាបព្រោះនូវភាពមន្ទិលសង្ស័យរវាងក្រុងមូស្គូ និងក្រុងហាណូយ តេង ស៊ាវពីង បានប្រកាសប្រាប់មេដឹកនាំអឺរ៉ុបម្នាក់នៅដើមឆ្នាំ១៩៨៥ថា ប្រទេសចិន នឹងមិនជំទាស់ការតាំងមូលដ្ឋានទ័ពមួយរបស់សូវៀតនៅឆកសមុទ្រកាំរ៉ាញ់ឡើយ បើសិនជាវៀតណាមចាកចេញពីប្រទេសកម្ពុជានោះ[៥៨] ។ នេះប្រហែលជាសម្តីប្រកបដោយល្បិចកលសុទ្ធសាធ ប៉ុន្តែវាគួរឲ្យរីករាយផងដែរ ដែលសម្គាល់ឃើញថា តេង បានធ្វើបញ្ច្រាសទៅនឹងគោលជំហររបស់ចិនកាលពីពាក់កណ្តាលទសវត្សរ៍៧០ ដែលនៅពេលនោះក្រុងប៉េកាំងបានព្រមានពិភពលោកទាំងមូលមិនឈប់ឈរឲ្យប្រឆាំងនឹងពួកអនុត្តរភាពសូវៀត និងគម្រោង

ការបង្កើតមូលដ្ឋានមួយរបស់គេនៅឆកសមុទ្រកាំរ៉ាញ់ ។ នៅដើមឆ្នាំ១៩៨៦ ដោយអស់សង្ឃឹមនឹងការបាត់មិនឃើញការស្នើធ្វើកិច្ចចរចាពីសំណាក់សហភាពសូវៀតស្តីពីបញ្ហាទាំងឡាយដែលលើកឡើងដោយប្រទេសចិន ក្រុងប៉េកាំងបានបង្កើនការឃោសនាវាយលុករបស់ខ្លួន ប្រឆាំងនឹងក្រុងមូស្គូជាថ្មី ។ ជំហររបស់ខ្លួនទាក់ទងនឹងប្រទេសកម្ពុជាពុំមានប្រែប្រួលឡើយ ហើយដើម្បីធ្វើឲ្យសហរដ្ឋអាមេរិកនិងប្រទេសថៃជឿជាក់ និងបង្ហាញពីការសម្រេចចិត្ត (បន្ទាប់ពីការរារែកដ៏យូរ) របស់ខ្លួនឲ្យក្រុងមូស្គូឃើញ ប្រទេសចិនបានបង្កើននូវការទម្លាក់គ្រាប់បែកដំណាលគ្នានឹងការឆ្មក់វាយប្រហារដោយទាហានថ្មើរជើងទៅលើប្រទេសវៀតណាមរឹតតែខ្លាំងឡើងដែរ ។

ជាមួយការឡើងកាន់អំណាចរបស់ មីខាអ៊ីលហ្គ័របាឆូវ ក្រុងមូស្គូបានបន្តផ្តល់ជំនួយសេដ្ឋកិច្ចនិងយោធាមួយទៅឲ្យប្រទេសវៀតណាមទៀត ប៉ុន្តែបានតម្រូវឲ្យបង្កើនការនាំចេញកសិផលរបស់វៀតណាម និងការគ្រប់គ្រងដ៏ម៉ឺងម៉ាត់មួយទៅលើជំនួយដែលបានផ្តល់ឲ្យ ។ ចំណែកការគាំទ្ររបស់សូវៀតក្នុងរឿងរ៉ាវរបស់កម្ពុជាក៏ត្រូវបានអះអាងជាផ្លូវការដែរ ។ ក្នុងឱកាសនៃការធ្វើអន្តរាគមន៍ជាលើកដំបូងរបស់គាត់ស្តីពីបញ្ហាភូមិភាគអាស៊ីអាគ្នេយ៍ អនុរដ្ឋមន្ត្រីការបរទេសសូវៀត មីខាអ៊ីលកាពីតសា បានវាយតម្លៃថា ស្ថានការណ៍នៅប្រទេសកម្ពុជា“មិនអាចប្រែក្រឡាស់បានឡើយ” និងបាននិយាយទុកជាមុនថា “ឧបសគ្គទាំងបី” ដែលរៀបរាប់ដោយប្រទេសចិន នៅទីបំផុតនឹងរលាយបាត់ជាមួយពេលវេលាមិនខាន ។ ជាឯកជន ពួកមេដឹកនាំសូវៀតបានសម្តែងឲ្យឃើញលក្ខណៈមិនសូវមានសុទិដ្ឋិនិយមប៉ុន្មានទេ ។ ពួកគេបានសង្កត់បញ្ជាក់ថា ការបន្តជម្លោះតទៅទៀតនឹងផ្តល់“អត្ថប្រយោជន៍ទាំងស្រុងសម្រាប់ពួកអាមេរិកាំងនៅអាស៊ីអាគ្នេយ៍” ធ្វើឲ្យស្មុគស្មាញដល់ទំនាក់ទំនងផ្សេងៗរវាងអាស៊ាននិងសហភាពសូវៀត និងកម្រិតព្រំដែនវត្តមានរបស់សូវៀតក្នុងតំបន់ដ៏មានថាមពលមួយ ក្នុងចំណោមតំបន់ដ៏មានថាមពលទាំងឡាយនៃពិភពលោក ។ ឈមមុខនឹងការផុសឡើងនូវចលនាអ្នកជាតិនិយមខ្មែរ វាប្រហែលជាប្រសើរណាស់សម្រាប់ប្រទេសវៀតណាមដើម្បីដកខ្លួនថយពីប្រទេសកម្ពុជា ។ នៅខែធ្នូ ឆ្នាំ១៩៨៥ អ្នកឯកទេសសូវៀតខាងបញ្ហាអាស៊ីដ៏ឆ្នើមម្នាក់បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ) ដោយត្រង់ៗថា ៖ “ប្រទេសវៀតណាមគួរតែស្វែងរកការសម្របសម្រួលមួយជាមួយប្រទេសចិនហើយ ។ វៀតណាមពុំអាចអនុញ្ញាតឲ្យមានប្រទេសចិនមួយដែលជាសត្រូវនៅជាប់នឹងព្រំដែនរបស់ខ្លួនជានិច្ចនិរន្តរ៍នោះឡើយ”[៥៩] ។

នៅឆ្នាំ១៩៨៥ ច្រកដែលនាំចេញទៅរកការចាប់ផ្តើមត្រូវបានបិទ ។ ដប់ឆ្នាំក្រោយពេលដែលឧទ្ធម្ភាគចក្រចុងក្រោយរបស់អាមេរិកាំងចាកចេញពីក្រុងព្រៃនគរ បណ្តារដ្ឋមន្ត្រីការបរទេសរបស់តណ្ហចិនបានធ្វើការអំពាវនាវមួយចំពោះសហរដ្ឋអាមេរិក ដោយស្នើឲ្យសម្តែងជាថ្មីនូវតួនាទីស្ថាបនាមួយក្នុងតំបន់នេះ ។ ការចាប់ផ្តើមធ្វើឲ្យមានភាពធូរស្រាលរវាងចិន-សូវៀត ត្រូវរាប់បញ្ចូលក្នុងការផ្លាស់ប្តូរគំនិតភ្លាមៗនេះដែរ ហើយជម្លោះដែលធ្វើឲ្យរដ្ឋបាលរីហ្គេនប្រឈមមុខនឹងក្រុងប៉េកាំងពីបញ្ហាតៃវ៉ាន់នោះបានជួយជំរុញឲ្យក្រុងហាណូយបែរត្រឡប់ទៅរកសត្រូវកាលពីពេលថ្មីៗរបស់ខ្លួនវិញ ។

នៅឆ្នាំ១៩៨២ នៅពេលដែលលោក ហ្សុក ស៊ូល ឡើងកាន់តំណែងជំនួស អាឡិច ហ្សេង់ឌ័រ ហេក នៅក្នុងឋានៈជាមេដឹកនាំនយោបាយការបរទេសរបស់អាមេរិកាំង សហរដ្ឋអាមេរិកបានចាប់ផ្តើមសង្ស័យពីផលប្រយោជន៍ជាយុទ្ធសាស្ត្រ ដែលប្រទេសចិនអាចសម្តែងជំនួសខ្លួន ។ ប្រាកដណាស់ ក្រុងប៉េកាំងនៅតែជាតួឯកដ៏សំខាន់មួយក្នុងតំបន់ដែលជាទីផ្សារដ៏មានសក្តានុពលយ៉ាងសម្បើមមួយសម្រាប់ពាណិជ្ជកម្មនិងពួកវិនិយោគិនអាមេរិកាំង ហើយបង្កជាកម្លាំងទប់ដ៏លើសលុបមួយទល់នឹងឥទ្ធិពលរបស់សូវៀតនៅអាស៊ី ។ ក៏ប៉ុន្តែ ប្រទេសចិនលែងជាចំណុចសំខាន់សម្រាប់យុទ្ធសាស្ត្ររបស់អាមេរិកាំងទៀតហើយ ។ ក្រុងវ៉ាស៊ីនតោន មើលពុំឃើញផលវិបាកចំពោះអ្វីដែលក្រុងប៉េកាំងធ្វើការគាបសង្កត់ទៅលើប្រទេសវៀតណាមទេ ប៉ុន្តែគោលដៅទាំងឡាយរបស់អាមេរិកាំងចំពោះប្រទេសកម្ពុជាមានលក្ខណៈខុសគ្នាដោយជាក់ស្តែង ។ ដោយធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសចិន រដ្ឋការរីហ្គេនបានប្រកាសនូវការជំទាស់របស់ខ្លួនជារឿយៗចំពោះការវិលត្រឡប់របស់ខ្មែរក្រហមមកកាន់អំណាចវិញ ។ សហរដ្ឋអាមេរិកមិនសូវថ្កោលទោសឲ្យបានខ្លាំងក្លាដូចប្រទេសចិនឡើយចំពោះការកាន់កាប់របស់វៀតណាមលើប្រទេសកម្ពុជា ប៉ុន្តែការធ្វើដូច្នេះគឺដោយសារអាមេរិកបារម្ភពីស្ថិរភាពនិងការរួបរួមគ្នារបស់អាស៊ាន និងដើម្បីការពារសន្តិសុខប្រទេសថៃនិងពុំមែនធ្វើតម្រូវចិត្តពួកចិនទេ ។ ក្រុងវ៉ាស៊ីនតោន បានចៀសវាងគំនិតផ្តួចផ្តើមជាឯកត្តជនទាំងអស់ស្តីពីបញ្ហាកម្ពុជា ប៉ុន្តែនៅពីក្រោយឆាកវិញ សហរដ្ឋអាមេរិកបានជួយជ្រោមជ្រែងអាស៊ានឲ្យបង្កើតរដ្ឋាភិបាលចម្រុះមួយសម្រាប់ប្រទេសកម្ពុជា និងធានាស្វែងរកជ័យជម្នះឲ្យរដ្ឋាភិបាលនេះនៅអង្គការសហប្រជាជាតិថែមទៀត ។ នៅឆ្នាំ១៩៨២ សហរដ្ឋអាមេរិកបានផ្តើមកម្មវិធីផ្តល់ជំនួយដោយមិនចំពោះមុខ ដែលមានចំនួនទឹកប្រាក់១៥លានដុល្លារក្នុងមួយឆ្នាំ សម្រាប់ផ្តល់ឲ្យដៃគូទាំងឡាយមិនមែនកុម្មុយនីស្តក្នុងរដ្ឋាភិបាលចម្រុះតាមរយៈប្រទេសផ្សេងៗនៃសមាគមអាស៊ាន ។ ដោយអនុលោមទៅតាមនិន្នាការនយោបាយថ្មីរបស់អាមេរិកាំងក្នុងការគាំទ្រ“អ្នកប្រយុទ្ធដើម្បីសេរីភាព” ប្រឆាំងកុម្មុយនីស្តក្នុងទូទាំងពិភពលោក សភាជាន់ទាបរបស់អាមេរិកាំងបានសម្រេចនៅឆ្នាំ១៩៨៥អនុញ្ញាតឲ្យផ្តល់ជំនួយសេដ្ឋកិច្ច ឬយោធាដល់ចលនាតស៊ូរបស់កម្ពុជាជាផ្លូវការក្នុងទឹកប្រាក់រហូតដល់ទៅ៥លានដុល្លារ ។

នៅក្រុងហាណូយ មានសញ្ញាថាពេលវេលាផ្លាស់ប្តូរ គេមិនព្រួយបារម្ភដោយហួសហេតុពេកទេពីការសម្រេចចិត្តនេះ ដែលរួមជាការជាប់ពាក់ព័ន្ធដោយផ្ទាល់លើកដំបូងរបស់សហរដ្ឋអាមេរិកនៅឥណ្ឌូចិន តាំងពីឆ្នាំ១៩៧៥មក ។ គេពិតជាដឹងពីលក្ខណៈជានិមិត្តរូបនៃរឿងនេះហើយ ជាពិសេសគេដឹងណាស់ពីការពង្រីកស្ថានការណ៍ជាយុទ្ធសាស្ត្រដែលកើតមានភ្លាមៗនៅអាស៊ីខាងកើត ។ ការគន់គូររបស់វៀតណាមធ្វើឲ្យគេនឹកឃើញដល់ការគន់គូរកាលពីឆ្នាំ១៩៧៨ដែរ ។ មុនការចុះហត្ថលេខាលើសន្ធិសញ្ញាជាមួយក្រុងមូស្គូ និងការធ្វើអន្តរាគមន៍នៅប្រទេសកម្ពុជា ប្រទេសវៀតណាមបានខំប្រឹងប្រែងទាំងអស់សង្ឃឹម ដើម្បីឲ្យធ្វើទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយក្រុងវ៉ាស៊ីនតោនមានប្រក្រតីភាព ។ បន្ទាប់ពីរយៈពេលប្រាំពីរឆ្នាំក្នុងការពង្រឹងឥទ្ធិពលរបស់ខ្លួននៅ

កម្ពុជាកន្លងផុតទៅប្រទេសវៀតណាមបានប្រឹងប្រែងភ្ជាប់ចំណងទាក់ទងជាថ្មីជាមួយសហរដ្ឋអាមេរិក និងបង្កើនសកម្មភាពទៅរកគោលដៅអ្វីមួយរបស់ខ្លួនចំពោះមុខក្រុងមូស្គូថែមទៀត ។ បើទុកជាគ្រឿងសាស្ត្រាវុធរបស់សូវៀតបានជួយឲ្យមានការផ្តួលរលំ ប៉ុល ពត ក៏ដោយ ក៏ប្រទេសវៀតណាមកាន់តែសប្បាយចិត្តឡើងៗថា ទីបំផុតផលប្រយោជន៍ផ្នែកសន្តិសុខរបស់ខ្លួននៅឥណ្ឌូចិនអាចនឹងត្រូវធានាបានតែតាមរយៈដំណោះស្រាយជាអន្តរជាតិមួយប៉ុណ្ណោះ ដែលក្នុងនោះ សហរដ្ឋអាមេរិកគោងតែសម្ដែងតួនាទីគន្លឹះមួយ ។ នៅក្រុងវ៉ាស៊ីនតោនឥឡូវនេះគេឆ្លងផុតសម័យក្រោយ ប្រឺហ្សីនស្គី ហើយ ៈ សម្ព័ន្ធភាពជាមួយប្រទេសចិនបានទៅជារឿងបន្ទាប់បន្សំ ផ្ទុយទៅវិញគេយល់ថា ថ្វីបើសម្ព័ន្ធភាពរបស់ខ្លួនជាមួយក្រុងមូស្គូមានសភាពជិតស្និទ្ធយ៉ាងណាក៏ដោយ ក៏ប្រទេសវៀតណាមគ្រាន់តែជាអាយ៉ងធម្មតាមួយប៉ុណ្ណោះ ។ អនុរដ្ឋមន្ត្រីការពារប្រទេសអាមេរិកាំង រីឆាដ អារមីថេច បាននិយាយប្រាប់ខ្ញុំ(អ្នកនិពន្ធ)ជាសម្ងាត់ថា “សហភាពសូវៀត និងវៀតណាម ពុំបានរៀបការនៅមុខអាចារ្យទេ” ។ គាត់ជឿជាក់ថា សម្ព័ន្ធភាពនេះនឹងដោះដៃចេញពីគ្នា នៅពេលដែលភាគីទាំងពីរលែងរកបានផលប្រយោជន៍របស់ខ្លួនតទៅទៀត ។ ទោះបីជាសហរដ្ឋអាមេរិកពុំទាន់បានត្រៀមខ្លួនត្រឡប់មកសម្ដែងតួនាទីដ៏សកម្មមួយក្នុងតំបន់ដូចដែលប្រជាជនឥណ្ឌូចិនត្រូវការក៏ដោយ ក៏រដ្ឋការ រីហ្កេន បានបង្ហាញឲ្យវៀតណាមដឹងពីមធ្យោបាយកៀបសង្កត់មួយ ដើម្បីបង្ខំឲ្យសហរដ្ឋអាមេរិកផ្ដើមធ្វើការសន្ទនាឡើងវិញ ដោយនិយាយពីការដោះស្រាយបញ្ហាទាហានអាមេរិកាំងបាត់ខ្លួននៅឥណ្ឌូចិន ចំនួន២.៥០០នាក់គឺជា“អាទិភាពជាតិដ៏សំខាន់មួយ” ។ ដោយជឿលើសញ្ញាលើកទឹកចិត្តផ្សេងៗក្នុងចំណោមជនជាតិវៀតណាម នៅខែកុម្ភៈ ឆ្នាំ១៩៨២ រីឆាត អារមីថេច បានធ្វើដំណើរទៅក្រុងហាណូយ ដើម្បីពិភាក្សាពីបញ្ហាទាហានបាត់ខ្លួនក្នុងសង្គ្រាម ។ ប៉ុន្តែ ដំណើរជាលើកដំបូងទៅក្រុងហាណូយរបស់អ្នកទទួលខុសត្រូវជាន់ខ្ពស់អាមេរិកាំងម្នាក់ចាប់តាំងពីឆ្នាំ១៩៧៧ ថ្វីដ្បិតតែបានទទួលលទ្ធផលជាក់លាក់ស្ដួចស្ដើងក៏ដោយ ប៉ុន្តែវាបានធ្វើឲ្យវៀតណាមចេញផុតពីភាពឯកោ ហើយធ្វើឲ្យក្រុងប៉េកាំង និងរដ្ឋធានីខ្លះៗរបស់អាស៊ានព្រួយបារម្ភដូចគ្នា ។ ដោយអនុលោមទៅតាមទិសនយោបាយថ្មីដែលប្រកាន់យកនៅដើមរដូវក្ដៅ ឆ្នាំ១៩៨២ ក្រុងវ៉ាស៊ីនតោនមិនទាន់សម្រេចចិត្តទទូចពីរឿងនេះទៅកាន់ក្រុងហាណូយនៅឡើយទេ ទោះបីជាស្ថានការណ៍របស់កម្ពុជាមិនផ្លាស់ប្ដូរបន្តិចបន្តួចក៏ដោយ ។ បន្ទាប់ពីការជួបគ្នាកម្រិតខ្ពស់ជាច្រើនលើក និងការធ្វើដំណើរដ៏ជាក់លាក់មួយចំនួន អដ្ឋិធាតុទាហានអាមេរិកាំងប្រហែលមួយរយនាក់បានត្រូវដឹកយកទៅស្រុកវិញ ។ នៅឆ្នាំ១៩៨៥ ក្រុងហាណូយ ឈានរហូតដល់អនុញ្ញាតឲ្យកងទ័ពអាមេរិកាំងមួយក្រុមធ្វើការរុករកអដ្ឋិធាតុនៅតាមកន្លែងធ្លាក់យន្តហោះថែមទៀត ។ វៀតណាមក៏បានសន្យាធ្វើគ្រប់លទ្ធភាពទាំងអស់របស់ខ្លួន ដើម្បីដោះស្រាយពីបញ្ហាទាហានបាត់ខ្លួនក្នុងសង្គ្រាមក្នុងរយៈពេលពីរឆ្នាំ ។ នៅដើមឆ្នាំ១៩៨៦ អារមីថេច ដែលអមដំណើរដោយលោក ប៉ូល វ៉ូលហ្វូវីត អនុរដ្ឋមន្ត្រីការបរទេសសម្រាប់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក បានធ្វើដំណើរទៅកាន់ប្រទេសវៀតណាម ក្នុងឋានៈជាមេដឹកនាំគណៈប្រតិភូ

អាមេរិកាំងមួយក្រុម ដែលជាគណៈប្រតិភូថ្នាក់ខ្ពស់លើកដំបូង តាំងពីបេសកកម្មរបស់លោក ឡេអូណារដ៍ វូដខុក មក ។ អារមីថេច បានវិលត្រឡប់មកប្រទេសវិញជាមួយការធានាធ្វើសហប្រតិបត្តិមួយយ៉ាងពេញលេញ ពីសំណាក់ប្រទេសវៀតណាម ដែលគ្មានដាក់លក្ខខណ្ឌអ្វីជាបឋមឡើយ ។

ដោយបន្តនូវការវាយលុកប្រលោមស្នេហ៍របស់ខ្លួន ក្រុងហាណូយបានបង្ហាញឲ្យឃើញនូវលទ្ធភាពកម្រិតកំណត់ក្នុងការចេញចូលរបស់ពួកសូវៀតទៅឆកសមុទ្រកាំរ៉ាញ់របស់ខ្លួន ។ នៅឆ្នាំ១៩៨៥ក្រុងហាណូយ បានចាប់ផ្តើមបន្ទុយពាក្យឲ្យដឹងនៅក្រុងវ៉ាស៊ីនតោនថា ឆកសមុទ្រកាំរ៉ាញ់នៅតែស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាមជានិច្ច ហើយក្នុងករណីដែលមានដំណោះស្រាយពីជម្លោះរបស់កម្ពុជា វត្តមានយោធារបស់សូវៀតនៅទីនោះអាចនឹងត្រូវកាត់បន្ថយ ។ រឿងទាំងអស់នេះពិតជាគួរឲ្យទាក់ទាញចិត្តមែន ប៉ុន្តែពួកអាមេរិកាំងស្គាល់ច្បាស់ណាស់ពី«ល្បិច»របស់វៀតណាម ព្រោះតែមិនទុកចិត្ត ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកអាមេរិកាំងមិនចង់បណ្តោយខ្លួនឲ្យអូសទាញចូលទៅក្នុងកិច្ចរចាផ្សេងៗដែលអាចនឹងធ្វើឲ្យខូចប្រយោជន៍ដល់ការរួបរួមគ្នារបស់អាស៊ាន និងធ្វើឲ្យមានគ្រោះថ្នាក់ដល់យុទ្ធសាស្ត្ររបស់ក្រុងបាងកកស្តីពីបញ្ហាកម្ពុជាឡើយ ។

ក្រុងវ៉ាស៊ីនតោនបានទទួលយកដោយអនុគ្រោះនូវសំណើធ្វើសហប្រតិបត្តិការផ្នែក«មនុស្សធម៌»របស់ប្រទេសវៀតណាម ដែលតាមរយៈសហប្រតិបត្តិការអាចរៀបចំឲ្យមានប្រក្រតីភាពផ្នែកការទូតជាយថាហេតុមួយ ប៉ុន្តែបានបន្តទាមទារឲ្យមានការដកថយកងទ័ពរបស់វៀតណាមចេញពីប្រទេសកម្ពុជា ទុកជាលក្ខខណ្ឌដំបូងសម្រាប់ការផ្សះផ្សាទាំងអស់ ។ ចំណែកវៀតណាមបានអះអាងថាសហប្រតិបត្តិការរបស់គេស្តីពីបញ្ហាទាហានបាត់ខ្លួនក្នុងសង្គ្រាម បាននាំមកផ្តល់ឲ្យគេនូវគុណប្រយោជន៍មួយចំនួនមិនខាន ។ ពួកវៀតណាមសង្ឃឹមថា បរិយាកាស មានលក្ខណៈមិនសូវប្រឆាំងប៉ុន្មានទេ ក្រុងវ៉ាស៊ីនតោននឹងបន្ទន់ជំហររបស់ខ្លួនស្តីពីបញ្ហាកម្ពុជា និងញ៉ាំងឲ្យប្រទេសចិនបង្ហាញលក្ខណៈសម្របសម្រួលច្រើនជាងមុន ហើយនឹងញ៉ាំងឲ្យប្រទេសថៃលុះក្នុងអំណាចខ្លួនដូចគ្នា ។ យ៉ាងហោចណាស់ ក៏ពួកគេមានគំនិតការពារគ្រោះថ្នាក់ទុកជាស្រេចអំពីយុទ្ធនាការប្រឆាំងវៀតណាម ដែលកំពុងដុះដាលនៅសហរដ្ឋអាមេរិកស្តីពីរឿងអ្នកទោសដែលតាមគេអះអាងថា ត្រូវឃុំឃាំងដោយក្រុងហាណូយ ។ ពួកមេដឹកនាំវៀតណាមក៏សង្ឃឹមផងដែរថា ការគាំទ្ររបស់អាមេរិកាំងចំពោះចលនាតស៊ូកម្ពុជាដែលបង្ហាញដើមហេតុ ដោយការដឹកនាំផ្នែកមនោគមវិជ្ជារបស់រដ្ឋការីហ្គេននឹងថមថយចុះមិនខាន ។

## តម្លៃដែលត្រូវបង់

តាំងពីការចូលលុកលុយប្រទេសកម្ពុជា វៀតណាមនិងគូសត្រូវទាំងឡាយរបស់ខ្លួនគិតថា ពេលវេលា និងសិទ្ធិស្ថិតនៅជាមួយពួកគេ ។ ក្រុងហាណូយសង្ឃឹមថា រៀងរាល់ឆ្នាំដែលកន្លងផុតទៅនឹងធ្វើឲ្យជំហររបស់របបហេង សំរិន រឹតតែរឹងមាំឡើងក្នុងកម្ពុជាមួយដែលរស់ឡើងវិញ ហើយថា នៅទីបំផុត ពិភពលោកក៏ទទួលស្គាល់

អំពើដែលបានជាធ្វើជ្រុលស្រេចទៅហើយ ព្រោះគេធុញទ្រាន់នឹងគាំទ្រសង្គ្រាមតស៊ូមួយ ដែលគ្មានសង្ឃឹមនឹងឈ្នះ ។ ទន្ទឹមនឹងនោះក្រុងប៉េកាំងគិតថា វៀតណាមដែលលង់ទ្រនេសក្នុងសង្គ្រាមទ័ពព្រៃមួយដែលគ្មានច្រកចេញ និងដោយមើលឃើញសេដ្ឋកិច្ចនិងសន្តិសុខរបស់ខ្លួនត្រូវគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ បន្ទាប់មកការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនិងការគាបសង្កត់ខាងយោធា នៅទីបំផុតច្បាស់ជាដកកងទ័ពថយពីកម្ពុជាមិនខាន ។ ប៉ុន្តែសង្គ្រាមនៅប្រទេសកម្ពុជាបានឈានចូលដល់ឆ្នាំទីប្រាំពីរហើយ ហើយគ្មានការប្រមាណទុកជាមុនណាមួយ ទំនងជាធ្វើឲ្យសម្រេចលេចជារូបរាងឡើយ ។

សង្គ្រាមពង្រេចពង្រិលដែលប្រទេសចិនបង្កើតឡើង បានធ្វើឲ្យប្រទេសវៀតណាមចុះខ្សោយយ៉ាងខ្លាំង ។ ការបដិសេធរបស់បស្ចិមប្រទេសមិនផ្តល់ជំនួយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយមកឲ្យវៀតណាមបានធ្វើឲ្យសេដ្ឋកិច្ចរបស់ខ្លួនកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ។ តាំងពីសង្គ្រាមបានបញ្ចប់ ប្រជាជនវៀតណាមជាងមួយលាននាក់បានរត់ចេញពីមាតុប្រទេស ដែលមានមួយចំនួនធំបានរត់ចេញនៅក្រោយឆ្នាំ១៩៧៩ ។ ប្រទេសវៀតណាមដែលកាលពីដើមជា ដាវីឌ [*David* ជាព្រះមហាក្សត្រទីពីររបស់ជនជាតិអេប្រឺ (*Hébreu*) ប្រហែលឆ្នាំ១០១០-៩៧០មុនគ្រិស្តសករាជ] និងជាអ្នកវាយឈ្នះហ្គូលីយ៉ាត អាមេរិកាំង [*Goliath* អ្នកចម្បាំង ជនជាតិហ្វីលីស្តាំង (*Philistin*) បានវាយចាញ់ ដាវីដ ក្នុងការប្រយុទ្ធមួយ] បានក្លាយទៅជាប្រទេសដែលសហគមន៍អន្តរជាតិមិនរាប់រក និងធ្វើឲ្យអង្គការសហប្រជាជាតិមើលងាយដែលជាអ្នកបោះឆ្នោតសម្រេចផ្តល់នូវជំនួយដ៏សំខាន់មួយក្នុងការស្តារប្រទេសឡើងវិញកាលពីប៉ុន្មានឆ្នាំមុន ។ នៅដើមឆ្នាំ១៩៨៦ បំណុលខាងក្រៅរបស់វៀតណាមបានឡើងដល់៦,៧កោដិដុល្លារ ។ ដោយសារមូលហេតុមិនសងបំណុល អង្គការទាំងអស់ដែលឲ្យប្រាក់ខ្ចីនៅលោកខាងលិចបានបដិសេធលែងឲ្យខ្ចីតទៅទៀត ។ ការកែទម្រង់សេដ្ឋកិច្ចបែបទីផ្សារសេរី ដែលផ្តើមឡើងតាំងពីឆ្នាំ១៩៨០ បានធ្វើឲ្យផលិតផលផ្នែកស្បៀងអាហាររបស់ខ្លួនកើនចំនួនឡើងយ៉ាងជាក់ច្បាស់ ហើយបានជួយឲ្យប្រទេសជាតិចាកផុតពីវិបត្តិសេដ្ឋកិច្ចដ៏អាក្រក់នៃប្រវត្តិសាស្ត្ររបស់ខ្លួនថែមទៀត ។ ក៏ប៉ុន្តែ អនាគតប្រទេសវៀតណាមដែលបំបាត់មិនឲ្យមានមូលធន នៅតែស្ថិតក្នុងសភាពគួរឲ្យព្រួយបារម្ភយ៉ាងខ្លាំង ។ ការគ្រប់គ្រងប្រកបដោយមហន្តរាយមួយ គឺពុំមែនបង្កើតឡើងដើម្បីរៀបចំបញ្ហាផ្សេងៗឲ្យមានសភាពដូចដើមឡើងវិញទេ ៖ អ្នកមនោគមវិជ្ជាដែលកែមិនឡើងខ្លះក្នុងផ្ទៃបក្ស បានប្រឆាំងជំទាស់នឹងការកែទម្រង់ទាំងអស់ ។ ការសាកល្បងដែលពួកនោះចង់ឲ្យកាត់បន្ថយការប្រើប្រាស់ដោយអនុវត្តការផ្លាស់ប្តូរក្រដាសប្រាក់ នៅខែកញ្ញា ឆ្នាំ១៩៨៥ ឃើញថានាំឲ្យវិនាសអន្តរាយទៅវិញ ។ ក្រោមទម្ងន់នៃអតិផរណាចំនួន៥០០ភាគរយ ដែលមានជាបន្តបន្ទាប់មកទៀត ប្រជាជននៅភាគខាងជើងថ្វីត្បិតតែមានភក្តីភាពមួយជានិច្ចក៏ដោយ បានចាប់ផ្តើមទាមទារឲ្យមានការផ្លាស់ប្តូរមួយក្នុងក្បាលម៉ាស៊ីនដឹកនាំប្រទេស ។ ពេញថិរវេលានៃរដូវក្តៅឆ្នាំ១៩៨៦ ក្នុងកិច្ចប្រឹងប្រែងមួយដើម្បីស្តារជំនឿទុកចិត្តរបស់ប្រជាជនឡើងវិញ អគ្គលេខាបក្សកុម្មុយនីស្តវៀតណាម ឡេយន់ ដែលពេលនោះកំពុង

មានជំងឺបានលះបង់អំណាចស្ទើរតែទាំងអស់ ។ ការរើរុះគណៈរដ្ឋមន្ត្រីយ៉ាងធំមួយបានកើតមានឡើង ដោយមានការបញ្ចូលអ្នកកែទម្រង់សំខាន់ៗមួយចំនួនមកក្នុងរដ្ឋាភិបាលផង ។ តាមគេសន្និដ្ឋាន មហាសន្និបាតបក្សកុម្មុយនីស្តវៀតណាមលើកទី៦ដែលគ្រោងធ្វើនៅចុងឆ្នាំ១៩៨៦នឹងផ្លាស់ប្តូរអ្នកដឹកនាំមានវ័យចាស់មួយភាគចេញដោយដាក់ពួកមេដឹកនាំវ័យក្មេងដែលមានគំនិតជឿនលឿនជំនួសវិញ ។ ប៉ុន្តែ គ្មានអ្វីមួយបង្ហាញឲ្យឃើញថាមេដឹកនាំដែលមានវ័យក្មេងទាំងនោះនឹងមានជំហរមួយខុសគ្នាពីជំហរមេដឹកនាំរៀមច្បងរបស់ពួកគេស្តីពីបញ្ហាកម្ពុជា ឬក៏យ៉ាងណាឡើយ ។

ការខូចទឹកចិត្តបានរាលដាលយ៉ាងរហ័សក្នុងចំណោមដៃគូទាំងឡាយរបស់សមាគមអាស៊ាន ទោះបីជាប្រទេសថៃនិងប្រទេសចិនដែលជាតួឯកពីរដ៏សំខាន់ហាក់ដូចជាពុំត្រៀមចុះញ៉មក៏ដោយ ។ ប្រទេសវៀតណាមបានក័ន្តប្រឡុំយ៉ាងធ្ងន់ដោយនឹកស្មានថា ខ្មែរក្រហមនឹងត្រូវវាយឲ្យចុះចាញ់ដោយឆាប់រហ័ស ហើយថា ពិភពលោកនឹងភ្លេចពីកម្ពុជាក្នុងពេលដ៏ខ្លី ។ ពីមួយឆ្នាំទៅមួយឆ្នាំ ការកាន់កាប់ខុសច្បាប់របស់វៀតណាមមកលើប្រទេសកម្ពុជាបានត្រូវពង្រឹងរឹតតែរឹងមាំឡើង ប៉ុន្តែ នៅអង្គការសហប្រជាជាតិក៏មានការប្រឆាំងជំទាស់ចំពោះការកាន់កាប់នេះដែរ ។ ខ្មែរក្រហមដែលត្រូវប្រជាជនស្អប់ខ្ពើមនិងភ័យខ្លាចជានិច្ចនោះបានសម្រេចជោគជ័យវិលត្រឡប់មក“ខាងមុខឆាក”វិញ ដោយមានការគាំទ្ររបស់ប្រទេសចិននិងប្រទេសថៃផង ។ ថ្វីបើទទួលរងបរាជ័យក្នុងអំឡុងរដូវប្រាំងឆ្នាំ១៩៨៥ក៏ដោយ ក៏សង្គ្រាមទ័ពព្រៃនៅផ្ទៃក្នុងប្រទេសនៅតែមានសកម្មភាពខ្លាំងក្លាជានិច្ច ។ បន្ទាប់ពីការកាន់កាប់កម្ពុជាអស់រយៈពេលជាងប្រាំមួយឆ្នាំ សម្អប់ដ៏យូរលង់របស់ប្រជាជនខ្មែរប្រឆាំងនឹងវៀតណាមបានលេចឡើងជាថ្មី ។ គេចាប់ផ្តើមដឹងនូវសញ្ញានៃការរវាតចិត្តជាច្រើនក្នុងជួរកងទ័ពរបស់ ហេង សំរិន ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជាលែងស្ថិតនៅក្រោមអំណាចក្រុងហាណូយទៀតហើយ ។

នៅដើមឆ្នាំ១៩៨៦វៀតណាមដឹងខ្លួនថា ពេលវេលាប្រហែលជាពុំផ្តល់ការអនុគ្រោះឲ្យខ្លួនឡើយ បើពួកគេនៅត្រួតត្រាប្រទេសកម្ពុជាទៀតនោះ ។ បើសិនជាឈ្នះការប្រយុទ្ធនៅប្រទេសកម្ពុជា ក៏ប្រទេសវៀតណាមមុខជានឹងចាញ់ការប្រយុទ្ធដើម្បីសន្តិភាពនិងវិបុលភាពដែរ ។ នៅប្រទេសចិន ការធ្វើទំនើបភាវូបនីយកម្មបានរីកលូតលាស់យ៉ាងលឿន រីឯភាគច្រើននៃបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីភាគអាគ្នេយ៍សុទ្ធតែរីកដុះដាលដូចផ្កាត្រូវទឹកសន្សើម : មានតែឥណ្ឌូចិនមួយប៉ុណ្ណោះដែលហាក់ដូចជាជំរុញទៅរកភាពចុះដុនដាប ។ ទោះជាដូច្នេះក៏ដោយ ក៏ក្រុងហាណូយពុំមានកែប្រែជំហររបស់ខ្លួនស្តីពីបញ្ហាកម្ពុជាបន្តិចណាសោះដោយ នៅតែចាត់ទុកថាកម្ពុជាជាមូលដ្ឋានផ្តល់សន្តិសុខដល់ប្រទេសខ្លួន ហើយមានះប្រឹងកម្ចាត់ចោលចលនាតស៊ូថែមទៀត ប៉ុន្តែបានចាប់ផ្តើមគ្រោងគិតពីដំណោះស្រាយខាងការទូតមួយជាជាងគ្រោងគិតពីរដ្ឋាភិបាលចម្រុះមួយដែលដឹកនាំដោយសម្តេច សីហនុ និងដែលទ្រទ្រង់ដោយការធានារ៉ាប់រងផ្សេងៗរបស់អន្តរជាតិ ។ ដំណោះស្រាយនេះប្រហែលពើបប្រទះនឹងការប្រឆាំងជំទាស់ពីគូសត្រូវទាំងឡាយរបស់ខ្លួន ដែលសង្ឃឹមថាប៉ុន្មានឆ្នាំទៅមុខទៀត ប្រទេស

វៀតណាមនឹងយល់ច្បាស់មិនខាន ។ ប៉ុន្តែ ជាមួយនឹងក្រុមមេដឹកនាំថ្មីមួយ ក្រុងហាណូយពុំបានត្រៀមដាក់អាវុធចុះឡើយ បើទុកខ្លួនត្រូវបង់ខាតក្នុងរឿងនេះយ៉ាងណាក៏ដោយ ។

# អវសានកថា

សង្គ្រាមឥណ្ឌូចិនលើកទីបីពិតជាមិនអាចចៀសរួចមែនឬ? ។ ដោយក្រឡេកមើលទៅអតីតកាល គេអាចឆ្លើយព្រមគ្នាថា ៖ អាចចៀសរួចនិងមិនអាចចៀសរួច ។ ប្រាកដហើយ ភាពតានតឹងដ៏ជាក់លាក់មួយនៅតែមាន ។ ប្រវត្តិសាស្ត្របានបន្សល់នូវស្លាកស្នាមយ៉ាងជ្រៅក្នុងផ្នត់គំនិតគូទំនាស់ផ្សេងៗ មួយផ្នែកគឺ វៀតណាមនិងខ្មែរ ហើយមួយផ្នែកទៀតគឺវៀតណាមនិងចិន ដែលតែងមិនទុកចិត្តគ្នាទៅវិញទៅមកយ៉ាងខ្លាំង ។ ដំណើរផុសឡើងវិញនូវចលនាអ្នកជាតិនិយម ដើម្បីទាមទារទឹកដីនិងការតស៊ូដើម្បីការត្រួតត្រាប្រភពធនធានផ្សេងៗ ដែលធ្វើឲ្យខ្សោះអស់តាំងពីយូរមកហើយដោយការកាន់កាប់របស់អាណានិគមនិងការធ្វើអន្តរាគមន៍របស់បរទេស គឺសុទ្ធតែជារឿងដែលមានជាធម្មតាក្នុងវិធានការដ៏ជាក់លាក់មួយ ។ ប៉ុន្តែ ក្នុងពេលនោះគ្មានអ្នកណាម្នាក់បោះបង់សង្គ្រាមមួយដោយពិតប្រាកដនោះទេ ។

សម្រាប់វៀតណាមយល់ថា ឥណ្ឌូចិនគឺជាកន្លែងតែមួយគត់ដែលធានាសន្តិសុខដល់ប្រទេសរបស់ខ្លួន និងជា“កន្លែងរស់” ដែលចាំបាច់សម្រាប់សេដ្ឋកិច្ចរបស់ខ្លួនដែរ ហើយប្រការទាំងនេះអាចជាប្រភពនៃការប៉ះទង្គិចគ្នាជាមួយខ្មែរក្រហមជាតិនិយមជ្រុលមិនខាន ។ ក៏ប៉ុន្តែនៅពេលដែលសង្គ្រាមចប់ ការពង្រឹងអំណាចរបស់បក្សកុម្មុយនីស្តលើប្រទេសទាំងមូល និងការស្តារសេដ្ឋកិច្ចឡើងវិញគឺជាអាទិភាពពីររបស់ប្រទេសវៀតណាមដែលត្រូវធ្វើមុនគេ ។ នេះពុំមែនការបង្កើតចក្រភពឥណ្ឌូចិនមួយទេ ។ វៀតណាម ពិតជាព្រួយបារម្ភពីការបែកបក្សពួករបស់ខ្មែរក្រហម ប៉ុន្តែវៀតណាមពុំបង្ខំធ្វើឲ្យអ្នកទាំងនោះ ផ្លាស់ប្តូរមាគ៌ានយោបាយឡើយ ។ ប៉ុល ពត និងបក្សពួកក្តិរបស់គាត់សុទ្ធតែយកប្រៀបលើពេលវេលា ។ ពួកគេគោងតែធ្វើអ្វីមួយឲ្យឆាប់បំផុត ដើម្បីបង្កើតរដ្ឋអំណាចបដិវត្តមួយរបស់កម្ពុជានិង“បន្សុទ្ធ” ប្រជាជាតិចេញពីពួកមនុស្សអគតិ និងអាក្រក់ទាំងអស់ដែលស៊ីឈ្នួលបម្រើឲ្យប្រទេសវៀតណាមនៅមុនការប្រយុទ្ធស្លាប់រស់ដែលចៀសមិនផុតជាមួយ“ពួកវាតទីវៀតណាម” ។ ត្រូវធ្វើឲ្យមានចិត្តមោះមុត ដោយសារស្ថានភាពដុនដាបខាងផ្នែកសេដ្ឋកិច្ចនិងការលំបាកផ្ទៃក្នុងរបស់ប្រទេសវៀតណាម ខ្មែរក្រហមជឿថា អាចឈ្នះលើអ្វីដែលពួកគេចាត់ទុកជាការវាយប្រហារមួយដែលមិនអាចចៀសរួចដោយដឹកនាំការវាយប្រយុទ្ធនៅលើទឹកដីផ្ទាល់របស់វៀតណាមតែម្តង ។ ការបង្កហេតុផ្សេងៗរបស់ខ្មែរក្រហមបានបង្ខំឲ្យក្រុងហាណូយកែប្រែកម្មវិធី និងប្រមូលផ្តុំការយកចិត្តទុកដាក់ទាំងស្រុងទៅលើសន្តិសុខរបស់ខ្លួននៅឥណ្ឌូចិនមិនខាន ។ តាំងពីយូរយារមកហើយ ប្រទេសចិនតែងមន្ទិលសង្ស័យពីមហិច្ឆតារបស់ប្រទេសវៀតណាមជានិច្ច ។ ចិនធ្លាប់បានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួននិងមធ្យោបាយផ្សេងៗផ្នែកការទូត ដើម្បីរារាំងអនុត្តរភាពរបស់ក្រុងហាណូយនៅឥណ្ឌូចិន បើទុកជាកម្មវិធីរបស់ខ្លួនជាឧបសគ្គដល់គំនិតផ្តួចផ្តើមរបស់ពួកខ្មែរក្រហមក៏ដោយ ។ បន្ទាប់ពីការរាវែកចិត្តមួយរយៈប្រទេសចិនត្រូវតែគាំទ្រប្រទេសកម្ពុជាយ៉ាងពេញបន្ទុកក្នុងសង្គ្រាម

មួយដែលខ្មែរក្រហមខ្លួនឯងជាអ្នកបង្កឡើង ។

ភាពគាប់ជួនមួយនៃស្ថានការណ៍ដ៏ចង្រៃនៅលើឆាកអន្តរជាតិបាននាំឲ្យស្ថានការណ៍នៅឥណ្ឌូចិនមានភាពរឹតតែធ្ងន់ធ្ងរឡើងដែរ ។ ក្នុងរយៈពេលប្រហែលបីឆ្នាំ ប្រទេសចិនបានត្រូវធ្វើឲ្យជាប់រវល់យ៉ាងខ្លាំងក្នុងការតស៊ូផ្ទៃក្នុងរបស់ខ្លួនរហូតមកទល់ចុងឆ្នាំ១៩៧៨ ព្រោះតែរៀបចំការពិភាក្សាជាថ្មីមួយស្តីពីបញ្ហានៅឥណ្ឌូចិន ។ នាមនៃនយោបាយ ប្រទេសចិនគិតតែអំពីការប្រឆាំងជាអកម្មមួយដែលធ្វើឲ្យនឹកឃើញដល់ទម្លាប់ជាប្រពៃណី និងការអនុវត្តដូចម៉ាស៊ីននូវគោលការណ៍សំខាន់ៗនៃលទ្ធិម៉ៅនិយម ។ វៀតណាមរក្សាក្តីសង្ឃឹមនឹងធ្វើឲ្យពួកអាមេរិកាំងត្រឡប់មកក្នុងតំបន់វិញ ដើម្បីធ្វើជាអ្នកធានាថ្មីដល់សមតាកម្លាំងនៅទីនេះ ។ សេចក្តីសង្ឃឹមនេះត្រូវបានធ្វើឲ្យខកចិត្តដោយការព្រងើយកន្តើយរបស់សហរដ្ឋអាមេរិកចំពោះអាស៊ី ក្រោយសម័យសង្គ្រាមវៀតណាម និងដោយការប្រឆាំងជិតាស់យ៉ាងម៉ឺងម៉ាត់ពីសហសភាអាមេរិកាំង ។ ថ្វីបើ ស៊ីរុស វ៉ាន់ស៍ និង រីឆាដ ហូលប្រ៊ូក យល់ច្បាស់ពីឱកាសដែលជម្លោះនៅឥណ្ឌូចិនបង្ហាញខ្លួនជាថ្មីចំពោះក្រុងវ៉ាស៊ីនតោនក៏ដោយ ក៏អ្នកទាំងពីរបានចាញ់ការប្រយុទ្ធខាងការិយាធិបតេយ្យជាគុណប្រយោជន៍ដល់អ្នកប្រឆាំងសូវៀតដ៏ខ្លាំងក្លាម្នាក់គឺ ប៊ីកញូវ ប្រ៊ីហ្សីនស្គី ដែរ ។

តើមានបម្រុងទុកនៅពេលខាងមុខ? បើវិនិច្ឆ័យរឿងនេះតាមប្រវត្តិសាស្ត្រថ្មីៗ បណ្តាឆ្នាំដែលមកដល់នៅពេលបន្ទាប់ មុខជានឹងជួបប្រទះការឈឺចាប់និងប្រហែលជាបង្ហូរឈាមច្រើនជាងមុនផង ។ ប្រទេសចិនបានសម្រេចចិត្តបំបាក់ប្រទេសវៀតណាម ហើយអះអាងពីឧត្តមភាពផ្ទាល់របស់ខ្លួននៅអាស៊ីអាគ្នេយ៍ថែមទៀត ។ ប្រទេសចិនគ្រាន់តែគាំទ្រដោយអន្ទើៗក្នុងការដាក់ឲ្យអនុវត្តនូវគម្រោងការនេះដោយសមាគមអាស៊ាននិងបស្ចិមប្រទេសប៉ុណ្ណោះ ។ ប្រទេសវៀតណាមបានសម្រេចចិត្តរក្សាអត្ថប្រយោជន៍ដែលដណ្តើមបានដោយកម្លាំងអាវុធ និងដោយសេចក្តីត្រូវការដែលដាក់បង្ខំមកលើប្រជាជនផ្ទាល់របស់ខ្លួន ។ បើក្រុងប៉េកាំង និងក្រុងហាណូយមិនទប់មហិច្ឆតាផ្សេងៗរបស់ខ្លួនទេ ឥណ្ឌូចិនពិតជាមិនបានស្គាល់សន្តិភាពឡើយ ។

ថ្វីបើប្រទេសចិនមានវិសាលភាពធំល្វឹងល្វើយ និងមានប្រភពធនធានមនុស្សមិនចេះរីងស្ងួតក៏ដោយ ក៏ប្រទេសចិនពុំអាចធ្វើឲ្យប្រទេសវៀតណាមលុះក្នុងអំណាចរបស់ខ្លួនដែរ ។ ប្រទេសវៀតណាម ដោយមានការគាំទ្រពីក្រុងម៉ូស្គូផង នៅតែជាមហាអំណាចយោធាដ៏គួរឲ្យព្រឺខ្លាចមួយដដែល ។ ប៉ុន្តែដើម្បីពង្រឹងឧត្តមភាពរបស់ខ្លួននៅឥណ្ឌូចិន វៀតណាមត្រូវតែពុះពារយកឈ្នះចលនាជាតិនិយមខ្មែរនិងភាពជាសត្រូវដែលមិនអាចសម្រុះសម្រួលបាននៃគូប្រជែងអស់រយៈពេលច្រើនសតវត្សរ៍មកហើយ គឺប្រទេសថៃថែមទៀតក្រៅពីការលំបាកផ្សេងៗផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចផ្ទាល់របស់ខ្លួន ។

ក៏ប៉ុន្តែ បើប្រវត្តិសាស្ត្របង្រៀនឲ្យអ្នកនាំអាទិ៍ទាំងអស់ចេះតែសង្ស័យគ្នាទៅវិញទៅមកដូច្នេះ ក៏វាបង្រៀនឲ្យអ្នកទាំងនោះដឹងថា សន្តិភាពជារឿងដែលអាចធ្វើបាន ។ ជម្លោះដ៏ស៊ិតស្មុគស្មាញដែលក្នុងនោះ ប្រទេសចិន និង

ប្រទេសវៀតណាមបានចូលរួម ពុំអាចឃាត់ឃាំងប្រទេសទាំងពីរដែលធ្លាប់ស្គាល់គ្នាយូរមក ហើយមិនឲ្យឈ្លោះគ្នានោះទេ ។ កាលពីអតីតកាលនៅក្នុងចន្លោះសម័យកាលសង្គ្រាម វាមានសម័យកាលសន្តិភាពយូរអង្វែងដែរ នៅពេលដែលប្រទេសចិនទទួលស្គាល់ថា ពិបាកនឹងដាក់ប្រទេសវៀតណាមឲ្យស្ថិតនៅក្រោមអំណាចខ្លួនណាស់ ថ្វីបើប្រទេសវៀតណាមទទួលស្គាល់ឧត្តមភាពរបស់«អាណាចក្រកណ្តាល»ក៏ដោយ ។ ដើម្បីនឹងឲ្យសន្តិភាពអាចត្រូវគេយកចិត្តទុកដាក់ ប្រទេសចិនទទួលស្របថា ការព្រួយបារម្ភដែលប្រទេសវៀតណាមមានចំពោះសន្តិសុខរបស់ខ្លួនបាននាំទៅដល់ការយកចិត្តទុកដាក់ចំពោះស្ថានការណ៍នៅប្រទេសកម្ពុជា របៀបដូចគ្នានឹងរឿងដែលប្រទេសចិនស្នើឲ្យក្រុងហាណូយប្រុងប្រយ័ត្ននឹងសន្តិសុខរបស់ខ្លួនដែរ ។ ដោយក្រអឺតក្រអោងហួសហេតុ«ពួកមេដឹកនាំ»ប្រទេសវៀតណាមសព្វថ្ងៃ ប្រហែលជាពុំត្រៀមខ្លួនធ្វើតាមគំរូរបស់ ង្វៀន ហ៊ុយ វីរបុរសនៃចលនាតស៊ូប្រឆាំងចិន ដែលបន្ទាប់ពីជ័យជម្នះខាងយោធារបស់គាត់ ប្រឆាំងនឹងអាណាចក្រកណ្តាលហើយបែរជានាំយកសួយសារអាករទៅថ្វាយព្រះចៅអធិរាជនៅក្រុងប៉េកាំងទេមើលទៅ ។ ផ្ទុយទៅវិញ ពួកមេដឹកនាំវៀតណាមពុំអាចធ្វើមិនដឹងថា ប្រទេសចិនជាមហាអំណាចដ៏សំខាន់មួយប្រចាំតំបន់ ។ បរាជ័យក្នុងការប៉ុនប៉ងច្បាំងដណ្តើមយកប្រទេសកម្ពុជានៅសតវត្សរ៍ទី១៩ និងបទពិសោធន៍កាលពីពេលថ្មីៗប្រហែលជាធ្វើឲ្យក្រុងហាណូយត្រិះរិះពិចារណាជាថ្មី ។

ក្នុងប្រវត្តិទំនាក់ទំនងទាំងអស់រវាងប្រទេសថៃនិងប្រទេសវៀតណាម គេប្រទះឃើញតែសម័យកាលមួយប៉ុណ្ណោះ–ដើមសតវត្សរ៍ទី១៩– ដែលប្រទេសកម្ពុជាលែងជាដើមហេតុនៃការទាស់ទែងគ្នារវាងក្រុងបាងកក និងក្រុងវ៉េទៀតហើយ ។ នៅពេលនោះ វៀតណាមបានប្រើអំណាចពិតប្រាកដមួយមកលើប្រទេសកម្ពុជា ប៉ុន្តែព្រះរាជវាំងនៅក្រុងវ៉េបានស្រុះស្រួលគ្នាថា ប្រទេសថៃក៏មានផលប្រយោជន៍ដូចគ្នានៅក្នុងប្រទេសនេះដែរ ។ ឃ្លារបស់ទេសាភិបាលវៀតណាមឈ្មោះ ឡេ វ៉ាន់យៀត នៅតែល្បីល្បាញដដែល ដែលមានខ្លឹមសារថា : «ប្រទេសកម្ពុជាគឺជាកូនក្មេងម្នាក់ដែលមានប្រទេសថៃជាឪពុកនិងប្រទេសវៀតណាមជាម្តាយ» ។ ប្រជាជនខ្មែរមិនសូវចូលចិត្តឲ្យគេប្រៀបធៀបប្រទេសរបស់ខ្លួនទៅនឹងកូនក្មេងម្នាក់ដែលគ្មានអ្វីការពារនោះទេ ។ ប៉ុន្តែបន្ទាប់ពីសង្គ្រាមនិងការបាត់បង់មនុស្សយ៉ាងច្រើនក្នុងរយៈពេលដប់ឆ្នាំដែលគ្រប់គ្រងដោយ ប៉ុល ពត ប្រទេសកម្ពុជាពិតជាចុះខ្សោយខ្លាំងណាស់ព្រោះតែជាប្រទេសមួយដែលគ្រាន់តែជាទ្រនាប់ប៉ុណ្ណោះ ។ កម្ពុជាត្រូវតែរៀនសូត្រឡើងវិញ ដើម្បីធ្វើខ្លួនឲ្យទៅជាប្រជាជាតិពេញលេញមួយក្រោមការការពារពីអន្តរជាតិ គឺពុំមែនក្រោមសហវិជិតរដ្ឋ(Condominium)–[ដែនដីដែលដណ្តើមបានដោយការច្បាំងរួមគ្នា]របស់វៀតណាមនិងថៃឡើយ ។ កម្ពុជានឹងត្រូវធ្វើឲ្យមានការគាំពារពីអន្តរជាតិប្រឆាំងនឹងការវិលត្រឡប់មកវិញរបស់ខ្មែរក្រហម និងលទ្ធិជ្រុលហួសហេតុប្រឡាក់ទៅដោយឈាមរបស់ពួកនេះ ហើយប្រឆាំងនឹងអន្តរាគមន៍ទាំងអស់របស់បរទេស ។ មានតែការធានាពីសំណាក់មហាអំណាចធំៗប៉ុណ្ណោះ ដែលអាចធ្វើឲ្យប្រជាពលរដ្ឋខ្មែរកក់ក្តៅក្នុងចិត្តលុបបំបាត់ការមិន

ទុកចិត្តគ្នាទៅវិញទៅមករវាងប្រទេសវៀតណាមនិងប្រទេសថៃ ហើយអាចបម្រើយ៉ាងពេញសមត្ថភាពសម្រាប់សន្តិសុខផ្ទាល់ខ្លួនរបស់ប្រទេសនីមួយៗផង ។

ប៉ុន្តែការធានាពីអន្តរជាតិនេះនឹងអាចកើតមាន បើសិនជាក្រុងមូស្គូទទួលស្គាល់ថាវានឹងឲ្យគុណប្រយោជន៍ដល់ខ្លួនច្រើនជាងគេ ដោយបោះបង់ការប្រើជម្លោះផ្នែកយោធាគ្មានអៀនខ្មាស ហើយទទួលស្របថា វានឹងផ្ដល់គុណប្រយោជន៍ជាង ទាំងខាងទស្សនៈយល់ឃើញពីឥទ្ធិពលនយោបាយរបស់ខ្លួន ក៏ដូចទស្សនៈមួយមានលក្ខណៈពាណិជ្ជកម្មយ៉ាងត្រឹមត្រូវដែរ ដែលមិនត្រូវចចេសស្វែងរកឲ្យខាងតែបាននូវឧត្ដមភាពនៅអាស៊ីអាគ្នេយ៍ឡើយ ។

ចំណែកខាងពួកអាមេរិកាំង ការទទួលខុសត្រូវយ៉ាងធ្ងន់ធ្ងរមួយបានធ្លាក់មកលើខ្លួនដែលស្ថិតនៅក្នុងស្ថានភាពអស់សង្ឃឹមមួយដែរ ។ បន្ទាប់ពីកង់ប្រវត្តិសាស្ត្រវិលគ្រប់មួយជុំពួកអាមេរិកាំងត្រូវបានលើកឲ្យកាន់មុខងារជាអាជ្ញាកណ្ដាលម្ដងទៀត ។ គឺពួកអាមេរិកាំងនេះហើយដែលមានលក្ខណៈប្រសើរជាងគេ ដើម្បីធានាឲ្យមានសមតាកម្លាំងជាថ្មីមួយនៅអាស៊ីអាគ្នេយ៍, រ៉ាប់រងសន្តិសុខប្រទេសថៃទល់នឹងប្រទេសវៀតណាម និងរំដោះក្រុងហាណូយពីការភ័យខ្លាចរបស់ខ្លួនពីអនុត្តរភាពចិន ដោយរំសាប់ការមិនទុកចិត្តដែលក្រុងមូស្គូមានទៅលើក្រុងប៉េកាំង ។ ប៉ុន្តែដើម្បីរៀបចំរឿងនេះ ក្រុងវ៉ាស៊ីនតោនគោងតែផ្អាកអំពីការធ្វើជំរឿនចំនួនទាហានបាត់ខ្លួនក្នុងសង្គ្រាម ហើយទីបំផុតត្រូវតែទទួលយល់ព្រមសម្ដែងតួនាទីដ៏សកម្មជាងមុនមួយនៅឥណ្ឌូចិន ។ សហរដ្ឋអាមេរិកអាចទទួលមកវិញនូវកិត្យានុភាពនិងអំណាចដែលបានបាត់បង់កាលពីមុនក្នុងការផ្សងព្រេងខាងយោធាដែលខុសកាលៈទេសៈរបស់ខ្លួន ។ លុះត្រាតែប្រើប្រាស់ដោយត្រឹមត្រូវនូវអំណាចខាងសេដ្ឋកិច្ច និងការទូតរបស់ខ្លួន ជាពិសេសដោយមានខដាក់លក្ខណ្ឌជួយប្រទេសកម្ពុជាឲ្យរស់រានមានជីវិតឡើងវិញផង ។

# កាលប្បវត្តិសំខាន់ៗ

**ឆ្នាំ១៩៧៥**

- ១៧មេសា ការដណ្តើមបានទីក្រុងភ្នំពេញដោយខ្មែរក្រហម ។
- ៣០មេសា ការដណ្តើមបានទីក្រុងព្រៃនគរដោយពួកកុម្មុយនីស្តវៀតណាម ។
- ០៤ឧសភា ការវាយប្រហាររបស់ខ្មែរក្រហមនៅលើកោះនានារបស់វៀតណាម ។
- ១២ឧសភា ការស្ទាក់ចាប់បាននាវាដឹកទំនិញអាមេរិកាំងមួយគ្រឿងឈ្មោះ ម៉ៃយ៉ាហ្គេ ដោយពួកខ្មែរក្រហម ។
- ១២មិថុនា ការកាន់កាប់កោះមួយរបស់កម្ពុជាដោយប្រទេសវៀតណាម ។ ទស្សនកិច្ចជាសម្ងាត់របស់ ប៉ុល ពត នៅក្រុងហាណូយ ។
- ២១មិថុនា ការជួបគ្នាជាសម្ងាត់រវាង ម៉ៅ សេទុង និង ប៉ុល ពត នៅក្រុងប៉េកាំង ។
- ១៨ សីហា ការសន្យារបស់ចិនក្នុងការផ្តល់ជំនួយសេដ្ឋកិច្ចយ៉ាងសន្ធឹកសន្ធាប់មកឲ្យប្រទេសកម្ពុជា ។
- ២៥កញ្ញា ការបញ្ចប់ទស្សនកិច្ចរបស់ ឡេ យន់ នៅក្រុងប៉េកាំង គ្មានការព្រមព្រៀងគ្នាណាមួយត្រូវបានសម្រេចឡើយ ។
- ៣០តុលា ការសន្យារបស់សូវៀតចំពោះប្រទេសវៀតណាមក្នុងការផ្តល់ជំនួយសេដ្ឋកិច្ចរយៈពេលយូរក្នុងអំឡុងពេលនៃការស្នាក់អាស្រ័យរបស់ ឡេ យន់ នៅទីក្រុងមូស្គូ ។
- ២១វិច្ឆិកា ការប្រកាសផ្សាយជាសាធារណៈនូវការបង្រួបបង្រួមភាគខាងជើង និងភាគខាងត្បូងវៀតណាមដែលច្បាស់ជាកើតមានក្នុងពេលឆាប់ៗ ។

**ឆ្នាំ១៩៧៦**

- ០៦កុម្ភៈ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយយោធាជាសម្ងាត់រវាងប្រទេសចិន និងកម្ពុជា ។
- ០២មេសា ការលាលែងរបស់ សម្តេច ព្រះនរោត្តម សីហនុ ពីមុខតំណែងជាប្រមុខរដ្ឋរបស់កម្ពុជា ។
- ១៤មេសា ការប្រកាសពីរដ្ឋាភិបាលថ្មីរបស់កម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត ។
- ២០កក្កដា ការទទួលជួបគណៈប្រតិភូអ្នកកាសែតវៀតណាមមួយក្រុមដោយ ប៉ុល ពត ។
- ០៩កញ្ញា មរណភាពរបស់ប្រធាន ម៉ៅ ។

- ០៦តុលា ការចាប់ខ្លួនបណ្ដាសមាជិករបស់ "បន៤នាក់" ។
- ១៨ធ្នូ ការបើកមហាសន្និបាតរបស់បក្សកុម្មុយនីស្តវៀតណាម ។

## ឆ្នាំ១៩៧៧

- ២៨កុម្ភៈ ការប្រកាសជាសាធារណៈនូវការមិនបន្តផ្ដល់ជំនួយរបស់ចិនទៅឲ្យប្រទេសវៀតណាម ។
- ១៦មីនា ការផ្ដើមស្នាក់អាស្រ័យនៅក្រុងហាណូយរបស់គណៈប្រតិភូតំណាងប្រធានាធិបតីអាមេរិកាំងមួយក្រុមដែលដឹកនាំដោយលោក ឡេអូណារដ៍ វូដខូក ។
- ២៥មេសា ការផ្ដើមទស្សនកិច្ចរបស់ ផាំ វ៉ាន់ដុង នៅអឺរ៉ុបខាងលិច ។
- ៣០មេសា ការវាយប្រហាររបស់ខ្មែរក្រហមទៅលើភូមិនានារបស់វៀតណាមនៅតាមព្រំដែន ។
- ០៣ឧសភា ការបើកកិច្ចសន្ទនាក្នុងការធ្វើឲ្យមានប្រក្រតីភាពរវាងអាមេរិកាំងនិងវៀតណាមនៅទីក្រុងប៉ារីស ។
- ០៧មិថុនា ការជួបគ្នារវាង ផាំ វ៉ាន់ដុង និង ឡេអូនីដប្រេសណេវ នៅទីក្រុងមូស្គូ ។
- ១០មិថុនា ការជួបគ្នារវាង ផាំ វ៉ាន់ដុង និង លី ស៊ាននាន នៅក្រុងប៉េកាំង ។
- ១៧កក្កដា ការចុះហត្ថលេខាសន្ធិសញ្ញាមិត្តភាពមួយដែលមានរយៈពេល២៥ឆ្នាំរវាងប្រទេសវៀតណាម និងប្រទេសឡាវ ។
- ២៤កញ្ញា ការវាយប្រហារទៅលើភូមិរបស់វៀតណាមមួយដោយខ្មែរក្រហម បណ្ដាលឲ្យជនស៊ីវិលស្លាប់អស់ប្រមាណ១០០នាក់ ។
- ២៨កញ្ញា ការចាប់ផ្ដើមធ្វើទស្សនកិច្ចប្រកបដោយជោគជ័យរបស់ ប៉ុល ពត នៅប្រទេសចិន ។
- ១០តុលា ការមកដល់ប្រទេសវៀតណាមនូវគណៈប្រតិភូយោធាសូវៀតជាន់ខ្ពស់មួយក្រុម ។
- ២១វិច្ឆិកា ទស្សនកិច្ចរបស់ ឡេ យន់ នៅក្រុងប៉េកាំង ។ ក្នុងពេលនោះមានការប៉ុនប៉ងបំបែកពួកចិនឲ្យឃ្លាតចេញពីខ្មែរក្រហម ។
- ០៣ធ្នូ ទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិន ចេន យ៉ុងហ្គុី នៅប្រទេសកម្ពុជា ។
- ២៥ធ្នូ ការវាយប្រហាររបស់វៀតណាមប្រឆាំងនឹងប្រទេសកម្ពុជា ។
- ៣១ធ្នូ ការផ្ដាច់ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងវៀតណាម ។

## ឆ្នាំ១៩៧៨

- ១៨មករា ការស្នាក់អាស្រ័យនៅប្រទេសកម្ពុជារបស់លោកជំទាវ តេង យីងជាវ ភរិយាសព

លោក ដូ អេនឡាយ ដែលមកធ្វើទស្សនកិច្ចដើម្បីបញ្ចុះបញ្ចូលខ្មែរក្រហមឲ្យប្រកាន់យកនយោបាយនិយមផ្លូវកណ្តាល ។

- ០៥កុម្ភៈ សំណើរបស់វៀតណាមអំពីបទឈប់បាញ់គ្នា និងការបើកកិច្ចចរចាជាមួយប្រទេសកម្ពុជា ។
- ២២កុម្ភៈ ដំណើរជាសម្ងាត់ទៅក្រុងប៉េកាំងរបស់អ្នកចរចាវៀតណាមម្នាក់ ។
- ២៨មីនា ការចាប់ផ្តើមធ្វើការបង្ក្រាបទៅលើអាណិកជនចិននៅប្រទេសវៀតណាម ។
- ២២មេសា ការបង្កើតកងពលតូចទី១របស់ខ្មែរនៅប្រទេសវៀតណាមដើម្បីប្រឆាំងរបប ប៉ុល ពត ។
- ១២ឧសភា ការលុបចោលផ្នែកខ្លះនៃជំនួយរបស់ចិនទៅឲ្យប្រទេសវៀតណាម ។
- ២០ឧសភា ការមកដល់ក្រុងប៉េកាំងរបស់លោក ប៊ីកញ្ញូ ប្រ៊ីហ្សីនស្គី ។
- ២៨ឧសភា នៅប្រទេសកម្ពុជាភាគខាងកើត ប៉ុល ពត បានផ្តើមការវាយប្រហាររបស់ខ្លួនទល់នឹងអ្នកប្រឆាំងក្នុងផ្ទៃបក្ស ។ ការប្តឹងបរិហារដោយក្រុងប៉េកាំងអំពីជោគវាសនាដែលបម្រុងទុកសម្រាប់អាណិកជនចិននៅប្រទេសវៀតណាម ។
- ២៨មិថុនា ការចូលជាសមាជិកអង្គការសគ្គហសេដ្ឋកិច្ច(COMECON)របស់ប្រទេសវៀតណាម ។
- ០៥កក្កដា នៅក្រុងប៉េកាំង ការផ្តើមកិច្ចចរចាជាសម្ងាត់រវាងអាមេរិកាំង-ចិន ស្តីពីការធ្វើឲ្យមានប្រក្រតីភាពឡើងវិញ ។
- ១១កក្កដា ការលះបង់លក្ខខណ្ឌជាអាទិភាពជាផ្លូវការដោយប្រទេសវៀតណាមក្នុងការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងវ៉ាស៊ីនតោន ។
- ១០កញ្ញា ការចាប់ផ្តើមធ្វើទស្សនកិច្ចរបស់ ដាំ វ៉ាន់ដុង ក្នុងបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ។
- ២៧កញ្ញា ការជួបសន្ទនាគ្នាជាសម្ងាត់រវាងអាមេរិកាំង-វៀតណាម ដែលមានវឌ្ឍនភាពយ៉ាងឆាប់រហ័សអំពីអភិក្រមនៃការធ្វើឲ្យមានប្រក្រតីភាពឡើងវិញរវាងប្រទេសទាំងពីរ ។
- ១១តុលា ការផ្អាកដំណើរនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាមដោយលោកប្រធានាធិបតីអាមេរិក ខាធ័រ រហូតដល់ការបង្កើតឲ្យមានទំនាក់ទំនងជាមួយក្រុងប៉េកាំងសិន ។
- ០៣វិច្ឆិកា ការចុះហត្ថលេខាសន្ធិសញ្ញាមិត្តភាពមួយរវាងសូវៀត-វៀតណាម ដែលមានថិរវេលា ២៥ឆ្នាំ ។

- ០៥វិច្ឆិកា តេង ស៊ាវពីង ចាប់ផ្តើមធ្វើទស្សនកិច្ចមួយនៅបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ។ គណៈប្រតិភូរបស់ចិនមួយទៀតបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ។
- ១១វិច្ឆិកា ការបើកសម័យប្រជុំវិសាមញ្ញមួយរបស់ក្រុមមេដឹកនាំបក្សកុម្មុយនីស្តចិន ៖ តេង ស៊ាវពីង ចាប់ផ្តើមពង្រឹងឧត្តមភាពរបស់គាត់ ។
- ០២ធ្នូ ការប្រកាសជាសាធារណៈដោយក្រុងហាណូយស្តីពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលប្រឆាំងនឹង ប៉ុល ពត ។
- ១៥ធ្នូ ការប្រកាសជាសាធារណៈស្តីពីការធ្វើឲ្យមានប្រក្រតីភាពផ្នែកការទូតរវាងក្រុងប៉េកាំងនិងក្រុងវ៉ាស៊ីនតោន ។
- ២៥ធ្នូ ការចាប់ផ្តើមការចូលលុកលុយប្រទេសកម្ពុជាដោយប្រទេសវៀតណាម ។

**ឆ្នាំ១៩៧៩**

- ០៧មករា ការវាយដណ្តើមបានក្រុងភ្នំពេញដោយវៀតណាម ។
- ១៨មករា ការជួបគ្នាជាសម្ងាត់រវាងចិននិងថៃ ៖ ការគាំទ្រសង្គ្រាមទ័ពព្រៃប្រឆាំងវៀតណាមនៅប្រទេសកម្ពុជា ។
- ២៨មករា ដំណើរទៅដល់ក្រុងវ៉ាស៊ីនតោនរបស់ តេង ស៊ាវពីង ។ នៅទីនោះគាត់បានថ្លែងឲ្យដឹងពីគម្រោងការរបស់គាត់ក្នុងការផ្តល់"មេរៀន"មួយឲ្យប្រទេសវៀតណាម ។
- ១៧កុម្ភៈ ប្រទេសចិនបានចូលលុកលុយប្រទេសវៀតណាម ។
- ២៧មីនា នាវាចម្បាំងសូវៀតមួយកងបានបោះយុថ្កាសំចតនៅឆកសមុទ្រកាំរ៉ាញ់របស់វៀតណាម ។

# អក្សរកាត់ដែលប្រើប្រាស់ក្នុងប្រភពឯកសារសំអាង

| | |
|---|---|
| *A.C.N.* | *Agence Chine Nouvelle (ទីភ្នាក់ងារព័ត៌មានចិនថ្មី)* |
| *A.F.P.* | *Agence France-Presse (ទីភ្នាក់ងារព័ត៌មានបារាំង)* |
| *A.V.I* | *Agence Vietnamienne d' Information (ទីភ្នាក់ងារព័ត៌មានវៀតណាម)* |
| *B.P* | *Bangkok Post (កាសែតបាងកកប៉ុស្តិ៍)* |
| *C.V.* | *Le Courrier du Vietnam* |
| *F.E.E.R.* | *Far Eastern Economic Review (ទស្សនាវដ្ដីសេដ្ឋកិច្ចចុងបូព៌ា)* |
| *F.B.I.S.-P.R.C.* | *Foreign Broadcast Information Service-People's Republic of China.* |
| ***F.B.I.S.-A.P.A.*** | ***Foreign Broadcast Information Service-Asia Pacific*** |
| *N.D.* | *Nhan Dan* |
| *N.Y.T.* | *The New York Times (កាសែតញូវយ៉កថែមស៍)* |
| *P.I.* | *Pékin Information* |
| *Q.D.N.D.* | *Quan Doi Nhan Dan* |
| *R.R.* | *Renmin Ribao* |
| *S.W.B.* | *Summary of World Broadcast (BBC)* |
| *W.P.* | *Washington Post (កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍)* |

# ប្រភពឯកសារសំអាង

## ជំពូកទី១


១ Roy Rowan, The Four Days of Mayaguez, New York, Norton, 1975; pp. 38-48 ។

២ The Vietnamese Air Force, 1951-1975: An Analysis of its Role in Combat and Fourteen Hours at Koh Tang, Southeast Asia Monograph Series, Vol.3, Washington, D.C., VSAF, 1981, p. 106 ។

៣ Roy Rowan, ibidem, p. 123 ។

៤ ការប្រាស្រ័យទាក់ទងគ្នាផ្ទាល់ខ្លួនរបស់មន្ត្រីម្នាក់នៃក្រសួងការបរទេសអូស្ត្រាលី ក្រោយការសន្ទនារបស់គាត់ជាមួយតូត (Tot) នៅប្រទេសម៉ាឡេស៊ី, ថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៩ ។

៥ Michael Chinoy, “A Close Look at the Mayaguez”, F.E.E.R, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៥, p. 18 ។

៦- R.M.Smith, Cambodia Foreign Policy, Ithaca, N.Y., Cornell University Press, 1965, p. 159 ។

៧ Ben Kiernan, “មាន់ព្រៃ, មាន់ស្រុក និងក្អែកទឹក ៖ ភូមិភាគបូព៌ាក្រោមរបប ប៉ុល ពត” ក្នុងការនិពន្ធល្បែងទី៨ “បដិវត្តន៍និងផលវិបាកក្នុងប្រទេសកម្ពុជា” David Chandler and Ben Kiernan éd., Monograph Series N°25, New Haven, Conn. Yale University Southeast Asia Studies, 1983, p. 178. ការបកប្រែទៅជាភាសាបារាំងក្នុង Camille Scalabrino និង Marie-Claire Orieux: Cambodge: ប្រវត្តិសាស្ត្រ និងក្រយាគំណាំង, 1945-1985, Asie-Débat 2, l’Harmattan, 1985, pp. 159-160 ។

៨ Dossier Kampuchéa, Vol. 1, C.V., Hanoi, 1978, p. 128 ។

៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយ ផាំ វ៉ាន់បា អតីតឯកអគ្គរដ្ឋទូតរបស់វៀតណាមប្រចាំកម្ពុជាប្រជាធិបតេយ្យ, ទីក្រុងហូជីមិញ, ថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១ ។

១០ S.W.B., 5 août 1975 ។

១១ Dossier Kampuchéa, p. 127 ។

១២ Kenneth M. Quinn, The Origin and Development of Radical Cambodia Communism, និក្ខេបបទថ្នាក់បណ្ឌិត, University of Maryland, 1982, p. 187 ។

១៣ Ibid ។

១៤ កំណត់ហេតុអូសរ៉ូណេអូ ស្តីពីការសន្ទនាវ៉ាង វ៉ាង ស្វាងរ៉ុង-សុន សេន នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលបង្ហាញឲ្យដឹងក្នុងពេលគាត់ក្តី ប៉ុល ពត-អៀង សារី ដោយកំបាំងមុខៗ សំណៅដើមត្រូវបាត់បង់ ប៉ុន្តែការរៀបរាប់យ៉ាងល្អិតល្អន់ជាច្រើនបាននាំឲ្យនឹកឃើញពីលក្ខណៈពិតនៃការបកប្រែជាភាសាបារាំង

នេះ ។ ជាពិសេស ទាក់ទងទៅនឹងភាពស្លូតស្លើងនៃជំនួយរបស់ចិន ដែលផ្ទុយនឹងការបញ្ជាក់អះអាងរបស់អ្នកកាន់អំណាចវៀតណាម ។

១៥ *F.B.I.S.-P.R.C.*, ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៦, A-7 ។

១៦ *The Straits Times*, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៤ ។

១៧ ហង់រី គីស្ស៊ីងហ្គ័រ, *The White House Years*, Boston, Little, Brown, 1979, p. 1114. សៀវភៅបកប្រែជាភាសាបារាំង : *អំពីសេតវិមាន : 1968-1973*, Paris, Fayard, 1979 ។

១៨ *Kiessing's Contemporary Archives*, janvier 1974, p. 26488 ។

១៩ សេចក្ដីរាយការណ៍សង្ខេបស្ដីពីការសន្ទនារបស់ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ជាមួយ ផាំ វ៉ាន់ដុង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧, *A.C.N.*, ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៩ ។

២០ *S.W.B.*, ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៥ ។

២១ *S.W.B.*, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៥ ។

២២ *S.W.B.*, ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៥ ។

២៣ "Fighting a New Kind of War", *F.E.E.R*, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៥, p. 10 ។

២៤ *F.B.I.S.-P.R.C.*, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៥, A-16 ។

២៥ *Ibid.*, A-18-19 ។

២៦ តាមយោបល់មន្ត្រីចិនម្នាក់ថា ការទាមទារដោយទទូចរបស់ ឡេ ថាញ់នី ដើម្បីសុំជំនួយរបស់ចិន ក្នុងអំឡុងនៃការធ្វើដំណើរគ្មានឈប់ឈររបស់គាត់បានធ្វើឲ្យគាត់មានឈ្មោះហៅក្រៅថា "ស្មូមយាចក" ។

២៧ *P.I.*, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៨, pp. 12-16 ។ អត្ថបទពុំមានបញ្ជាក់ទាំងកាលបរិច្ឆេទនៃការសន្ទនានេះ ទាំងឈ្មោះមេដឹកនាំរបស់វៀតណាមទេ ប៉ុន្តែ ការនិយាយបញ្ចិតបញ្ចៀងពី "ជំងឺដ៏ធ្ងន់ធ្ងរ"របស់ ជូ និងការនិយាយយោងពី"សម័យសង្គ្រាម"ធ្វើឲ្យគេគិតថា គាត់នោះជា ឡេ ថាញ់នី : នៅខែសីហា ឆ្នាំ១៩៧៥ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ចិន បានលើកយកមកនិយាយពីការជួបគ្នាមួយរបស់ នី ជាមួយ ជូ ដែលនៅពេលនោះចូលព្យាបាលរោគក្នុងមន្ទីរពេទ្យ ។

២៨ លើកយកមកនិយាយជាសំអាងដោយ *A.C.N.*, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៨១ ។

២៩ *អំពីអធិបតេយ្យភាពរបស់វៀតណាមលើប្រជុំកោះ ហ័ងសា និង ត្រឿងសា*, ក្រុងហាណូយ, ក្រសួងការបរទេស, ១៩៧៩, p. 60 ។ ការបកស្រាយរបស់វៀតណាមបានត្រូវអះអាងបញ្ជាក់ដោយ *A.C.N.*, ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៩ ។

៣០ ការសន្ទនារបស់អ្នកនិពន្ធជាមួយនាយករងមជ្ឈមណ្ឌលប្រវត្តិសាស្ត្រសម័យបច្ចុប្បន្នរបស់ចិន, ក្រុង

*ប៉េកាំង, ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៨២ ។*

៣១ *S.W.B., ថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៨ ។*

៣២ *S.W.B., ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៥ ។*

៣៣ *Carlyle A. Thayer និង David G. Marr, Vietnam Since 1975, Center for the Study of Australian-Asian Relations, Research Paper N°20, Brisbane, Griffith University, 1980, p. 7 ។*

៣៤ *Ta Kung Pao, ហុងកុង, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។*

៣៥ *Gareth Porter, "នយោបាយវៀតណាមនិងវិបត្តិនៅឥណ្ឌូចិន" ក្នុងសង្គ្រាមឥណ្ឌូចិនលើកទី៣, David W.P. Elliott éd., Boulder, Colo., Westview Press, 1981, p. 80 ។*

៣៦ *S.W.B., ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៦ ។*

៣៧ *ការសន្ទនារបស់ អៀង សារី ជាមួយលោក Patrice de Beer, អ្នកឆ្លើយឆ្លងព័ត៌មាននៃកាសែត ឡឺម៉ុង សម្រាប់ភូមិភាគអាស៊ីអាគ្នេយ៍, បាងកក, ខែតុលា ឆ្នាំ១៩៧៥ ។ ខ្ញុំសូមអគុណលោក Beer ដែលបានបញ្ជូនកំណត់ត្រាខ្លីៗរបស់លោកមកឲ្យខ្ញុំ ។*

៣៨ *សារិន ឆាក, "ព្រំដែនប្រទេសកម្ពុជា", Paris, Dalloz, 1966, pp. 207-208; សូមអានផងដែរនូវ សៀវភៅ កម្ពុជា-វៀតណាម, International Boundary Study N°155, ក្រសួងការបរទេសអាមេរិកាំង, ការិយាល័យស៊ើបការណ៍ និងស្រាវជ្រាវ, Washington, D.C., 1976, pp. 11-12 ។*

៣៩ *សេចក្តីចម្លងនៃការសន្ទនារបស់ ភាំង ទុង ជាមួយលោក James Burnet, ហាណូយ, ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៨៦ ។ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក James Burnet ។*

៤០ *S.W.B., ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៦ ។*

៤១ *S.W.B., ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ។*

៤២ *"សេចក្តីរាយការណ៍សង្ខេបស្តីពីការសន្ទនារបស់ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ជាមួយនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧", A.C.N., ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៩ ។*

៤៣ *Jurgen Domes, ប្រទេសចិនក្រោយសម័យបដិវត្តន៍វប្បធម៌, London, Hurst, 1976, pp. 247-251 ។*

៤៤ *Michel Oksenberg, "មួយទសវត្សរ៍នៃទំនាក់ទំនងចិន-អាមេរិក", ការបរទេស, សរទរដូវ 1982, pp. 180-181 ។*

## ឧត្តម : "នរោត្តម សីហនុ : ម៉ោងនៃជ័យជម្នះ"

១ *Henry Kissinger, បណ្តាឆ្នាំដែលចលាចលខ្លាំង Little, Brown, 1982, p. 59. ការបកប្រែជាភាសាបារាំង :*

“បណ្តាឆ្នាំដ៏រំដើបរំជួល”, *Paris, fayard, 1982* ។

២ អ៊ី ផាន់ដារ៉ា, “ការត្រឡប់មកភ្នំពេញវិញ”, *Paris, A.M. Métailié, 1982, p. 37* ។

## ជំពូកទី២

១ *Paul Mus,* វៀតណាម ៖ សង្គមសាស្ត្រនៃសង្គ្រាមមួយ, *Paris, Editions du Seuil, 1952, p. 17* ។

២ *Michael G. Cotter, “Towards a Social History of Vietnamese Southward Movement”, Journal of Southeast Asia History, Vol. IX, N°1, mars 1968, p. 14* ។

៣ *Georges Maspero,* “ព្រះរាជាណាចក្រចម្ប៉ា”, *Paris, Van Houst, 1928, p. 26* ។ ចំពោះតួលេខដែលថ្មីបំផុត សូមអានស្ថិតិជំរឿនប្រជាជននៅឆ្នាំ១៩៧៦ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម ។

៤ *Alexander Barton Woodside,* វៀតណាម និងគំរូរបស់ចិន, *Cambridge, Harvard University Press, 1971, p. 247* ។

៥ *David Chandler,* កម្ពុជាមុនសម័យបារាំង ៖ *Politics in a Tributary Kingdom. 1794-1848, Ann Arbor, Mich., University Microfilms, 1973, p. 108* ។

៦ *David Chandler, “An Anti-Vietnamese Rebellion in Early Nineteenth Century Cambodia: Pre-Colonial Imperialism and a Pre-Nationalist Response”, Journal of Southeast Asian Studies, Vol. VI, N°1, mars 1975, pp. 16-24* ។

៧ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក *David Chandler,* ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៨២; *aussi, David Chandler, op. cit., p. 154; David Chandler, “Kampuchea-Vietnam-The Roots of Strife”, in The Vietnam-Kampuchea-China Conflict, Malcolm Salmon éd., Working paper N°1 Canberra, Department of Political and Social Change, Research School of Pacific Studies, Australian National University, 1979, pp. 4-5* ។

៨ រឿងខ្លីៗក្នុងប្រវត្តិសាស្ត្រនេះ បានផ្តល់ជាប្រយោគដែលគេទន្ទេញមិនឈប់មួយក្នុងការឃោសនារបស់ខ្មែរក្រហម ។ ចំពោះការបកស្រាយរបស់អ្នករួចផុតពីគ្រោះថ្នាក់ម្នាក់ជាជនជាតិកម្ពុជា សូមអានសៀវភៅ “ការវិលត្រឡប់មកភ្នំពេញវិញ” របស់លោក អ៊ី ផាន់ដារ៉ា, *Paris, Métailié, 1982, p. 129* ព្រមទាំង សៀវភៅរបស់លោក *A. Pannetier,* កំណត់ហេតុខ្លីៗអំពីកម្ពុជា ៖ នៅកណ្តាលប្រទេសខ្មែរ, *Paris, Payot, 1921; Paris, Cedoreck, 1983, pp. 15-16* ផង ។

៩ *Chandler, op. cit., p.153* ។

១០ សេចក្តីប្រកាសព័ត៌មាន, កម្ពុជាប្រជាធិបតេយ្យ, គណៈបេសកកម្មអចិន្ត្រៃយ៍នៅអង្គការសហប្រជាជាតិ,

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៨ ។ តាមការពិត រឿងនេះមានពិតប្រាកដតាំងពីឆ្នាំ១៩៧៧មក ។

១១ សារិន ឆាក, "ព្រំដែនប្រទេសកម្ពុជា", Paris, Dalloz, 1966, tome 1, p. 179 ។

១២ Michael Leifer, Cambodia: The Search for Security, London, Pall Mall, 1967, p. 95; Roger M. Smith, Cambodia's foreign Policy, Ithaca, N.Y., Cornell University Press, 1965, pp. 158-159 ។ ការទទួចដើម្បីឲ្យមានការប្រើអាកប្បកិរិយាប្រយ័ត្ន (ខាងផ្លូវកាយ ឬវាចា) ដោយឡែកមួយចំពោះជនជាតិភាគតិចខ្មែរក្រោមនៅភាគខាងត្បូងវៀតណាម គឺជាមូលហេតុនៃបរាជ័យក្នុងការចរចានៅខែតុលា ឆ្នាំ១៩៦៤ រវាងរណសិរ្សរំដោះជាតិវៀតណាម(វៀតកុង) និងកម្ពុជា ។ កំណត់ហេតុនៃការប្រជុំរបស់គណៈប្រតិភូនៃរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងនៅវិមានទទួលភ្ញៀវនាទីក្រុងប៉េកាំង, ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៦៤ វេលាម៉ោង៤ល្ងាច, ឯកសារផ្ទាល់ខ្លួនរបស់លោក ស្ហាល មៃយ័រ ។

១៣ Alain Forest, "កម្ពុជានិងការតាំងអាណានិគមរបស់បារាំង", Paris, l' Harmattan, 1980, p. 452 ។

១៤ លើកមកនិយាយជាសំអាងដោយលោក Gareth Porter, "វៀតណាមនិងកម្ពុជា", ជម្លោះឥណ្ឌូចិនលើកទី៣, David Elliott éd., Boulder, Colo, Westview, 1981, p.124, note 101 ។

១៥ ក្រសួងការបរទេស, ទូរលេខN°749-S.D.C.S ខែតុលា ឆ្នាំ១៩៥២, មានប្រភពមកពីទីក្រុងព្រៃនគរ ។ តាមមតិណែនាំដែលថា បក្សកុម្មុយនីស្តឥណ្ឌូចិនបានប្រគល់អំណាចឲ្យបក្សកុម្មុយនីស្តវៀតណាមដើម្បី "រៀបចំនិងដាក់ឲ្យមានក្របខ័ណ្ឌនូវសមាជិករបស់ខ្លួន ដែលមានដើមកំណើតជាចិន ហើយដែលកំពុងស្នាក់អាស្រ័យនៅប្រទេសវៀតណាម, កម្ពុជានិងប្រទេសឡាវ" ។

១៦ អ្នកឯកទេសខាងបញ្ហាប្រទេសកម្ពុជា មិនបានព្រមព្រៀងគ្នាអំពីអត្ថន័យនៃមហាសន្និបាតឆ្នាំ១៩៦០ ដែលជាកាលបរិច្ឆេទនៃការបង្កើតបក្ស ដូចដែល ប៉ុល ពត បានអះអាងឬមហាសន្និបាតលើកទីពីរនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលកើតមកពីបក្សកុម្មុយនីស្តឥណ្ឌូចិនទេ ។ ការបញ្ជាក់អះអាងទាំងពីរប្រហែលជាមានការពិត(នៅក្នុងនោះ) តាមចំណែកនីមួយៗ ។

១៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Charles Meyer, ក្រុងប៉ារីសថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ។

១៨ នរោត្តម សីហនុ, សៀវភៅ "អ្នកទោសខ្មែរក្រហម", Hachette, 1986, p. 416 ។

១៩ Harald Munthe-Kaas, "សម្ភាសន៍ជាមួយសម្តេចព្រះ នរោត្តម សីហនុ", F.E.E.R. ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៦៥ ។

២០ Stephen Header, "Kampuchea's Armed Struggle: The Origin of an Independent Revolution", Bulletin of Concerned Asian Scholars, Vol. 11, N°1, 1979, p.7 ។

២១ Timothy Carney, "Cambodia: The Unexpected Victory", អត្ថបទមិនបានបោះពុម្ពផ្សាយ, ខែកុម្ភៈ

ឆ្នាំ១៩៧៩, p.10 ។

២២ Heder, "Kampuchea's Armed Struggle", p.14 ។

២៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ស្គាល មៃយ័រ, ប៉ារីស ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ។

២៤ Kissinger, The White House Years, p. 250; William Shawcross, ហេតុការណ៍បន្ទាប់បន្សំ, គីស្ស៊ីងហ្គ័រ, និចសុន និងការបំផ្លាញប្រទេសកម្ពុជា, New York, Simon and Schuster, 1979, p. 70 ។

២៥ លើកមកនិយាយសំអាងដោយលោក ស្គាវក្រូស op.cit.p. 123 ។ ក្នុងន័យដដែលលោក ស្គាវក្រូស ក៏លើកសម្ដីរបស់លោក William Colby អតីតនាយក C.I.A. មកសំអាងផងដែរ ។

២៦ Sihanouk, op.cit ។

២៧ Heder, "Kampuchea's Armed Struggle", p. 14 ។ នៅឆ្នាំ១៩៦៨ សម្ដេច សីហនុ បានអួតអាងថា បានឲ្យគេសម្លាប់អ្នកប្រឆាំងជាជនកុម្មុយនីស្ត១៥០០នាក់តាំងពីឆ្នាំ១៩៥៦មក ។

២៨ Ibid ។

២៩ Shawcross, op. cit., p. 250 ។

៣០ សៀវភៅខ្មៅ, ហេតុការណ៍និងភ័ស្តុតាងនៃអំពើឈ្លានពាននិងការក្លាប់ទឹកដីរបស់ប្រទេសវៀតណាមប្រឆាំងនឹងកម្ពុជា, ភ្នំពេញ : ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ, ឆ្នាំ១៩៧៨, p. 86 ។

៣១ Kissinger, Years of Upheaval, Boston, Little, Brown, 1981, p. 353 ។

៣២ Ibid., p. 341 ។

៣៣ Ibid., p. 36 ។

៣៤ Shawcross, op. cit., pp. 335-343 ។

៣៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយសម្ដេចព្រះ នរោត្តម សីហនុ នៅទីក្រុងប៉េកាំង ថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨០ ។

៣៦ Donald Kirk, "Revolution and Political Violence in Cambodia, 1970-74", dans Communism in Indochina, Joseph Zasloff and Paul Brown éd., Toronto, Lexington, 1975, p. 218 ។

៣៧ ទូរលេខដែលរៀបរាប់បញ្ចូលដោយលោក Ben Kiernan "មាន់ព្រៃ, មាន់ស្រុក និងក្អែកទឹក : ភូមិភាគបូព៌ារបស់កម្ពុជាក្រោមរបប ប៉ុល ពត",ក្នុងការនិពន្ធល្បងទី៨ស្ដីពីបដិវត្តន៍និងផលវិបាកនៅកម្ពុជា, David Chandler and Ben Kiernan éd., Monograph Series N°25, New Haven, Conn., Yale University Southeast Asia Studies, 1983, p. 176 ។

៣៨ Ibid., p. 159 ។

៣៩ *សំណុំរឿងកម្ពុជា, pp. 9-10 ។*

## ជំពូកទី៣

១ *ប្រតិកម្មរបស់ អៀង សារី ចំពោះការចាប់ខ្លួនពួកវ៉ាឌីកាល់ ត្រូវបានរៀបរាប់ប្រាប់ខ្ញុំ ដោយសហការីជិតស្និទ្ធម្នាក់របស់លោក ហ្កាសប៉ារី នៅទីក្រុងបាងកក ។ ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨២ ហ្កាសប៉ារី ជាឯកអគ្គរដ្ឋទូតប្រទេសយូហ្កោស្លាវីប្រចាំប្រទេសថៃ ។*

២ *J.B. Armstrong, Revolutionary Diplomacy: Chinese Foreign Policy and the United Front Doctrine, Berkeley, University of California Press, 1977, pp. 180-181 ។*

៣ *ចំពោះការបរិយាយមួយអំពីព្រឹត្តិការណ៍ខែតុលា ឆ្នាំ១៩៧៦ នៅប្រទេសចិន សូមអានសៀវភៅរបស់លោក Roger Garside, Coming Alive: China after Mao, New York, Mentor, 1981, pp. 101-154; Andres D. Onate, "ហ្វាគួហ្វេង និងការចាប់ខ្លួនបន៤នាក់", China Quarterly, ខែកញ្ញា ឆ្នាំ១៩៧៨, pp. 540-565 ។*

៤ *តាមវិទ្យុក្រុងភ្នំពេញថា នៅថ្ងៃទី១៣ ខែតុលា ឯកអគ្គរដ្ឋទូតនៃប្រទេសម៉ាលីនិងតង់ហ្សានីដែលអញ្ជើញមកជូនលិខិតសារតាំងត្រូវបានទទួលដោយ សុន សេន រដ្ឋមន្ត្រីការពារប្រទេស ដែលបំពេញភារកិច្ចក្នុងឋានៈជារដ្ឋមន្ត្រីការបរទេស, S.W.B., ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។*

៥ *សុន្ទរកថារបស់លោក លី ជាង (Li Qiang) រដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេសរបស់ចិនថ្លែងក្នុងឱកាសពិធីជប់លៀងមួយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦, F.B.I.S.-A.P.A., ថ្ងៃទី២៩ ខែតុលា ១៩៧៦ ។*

៦ *សង្កាត់(អត្ថបទ)នេះ សំអាងលើការសន្ទនារបស់ខ្ញុំជាមួយអ្នកការទូតដែលបំពេញមុខងារនៅទីក្រុងហាណូយនិងប៉េកាំង នាពាក់កណ្តាលឆ្នាំ១៩៧៧ ។ នៅចុងឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានទិញទំនិញពីក្រុងហុងកុងត្រឹមតែ១លានដុល្លារប៉ុណ្ណោះ ។ សូមអានអត្ថបទរបស់លោក ណាយ៉ាន់ ចាន់ដា : "Phnom Penh Undercover Men"ក្នុងទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា (F.E.E.R) ចេញថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៦ ។*

៧ *Ben Kiernan and Chanthou Boua, កសិករ និងនយោបាយនៅកម្ពុជា, London, Zed, 1982, p. 291 ។*

៨ *David P. Chandler, "A Revolution and Full Spate: Communist Party Policy in Democratic Kampuchea, ខែធ្នូ ឆ្នាំ១៩៧៦", អត្ថបទមិនបានបោះពុម្ពផ្សាយ, p. 7 ។*

៩ *Kenneth M. Quinn, The Origin and Development of Radical Cambodian Communism, និក្ខេបបទថ្នាក់បណ្ឌិត, University of Maryland, 1982, pp. 136-137 ។*

១០ *David P. Chandler, "Revising the Past in Democratic Kampuchea: When Was the Birthday of the*

Party?", Pacific Affairs, été 1983, pp. 297-299; Ben Kiernan and Chanthou Boua, កសិករ និង នយោបាយនៅកម្ពុជា, London, Zed, 1982, p. 291 ។

១១ Chandler, ibid., p. 297 ។

១២ Chanthou Boua and Ben Kiernan, "ការិយាធិបតេយ្យនៃសេចក្ដីស្លាប់", New Statesman, ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៨០; David Hawk, "មជ្ឈមណ្ឌលប្រល័យពូជសាសន៍ទួលស្លែង", Index on Censorship, ខែមករា ឆ្នាំ១៩៨៦, pp. 25-31 ។

១៣ Chandler, op. cit., p. 298 ។

១៤ ការបកប្រែអត្ថបទពីទស្សនាវដ្ដីទង់បដិវត្តដោយលោក Timothy Carney និង Kem Sos ដែលមានក្នុងសៀវភៅមួយជិតចេញផ្សាយ បោះពុម្ពផ្សាយដោយ Karl Jackson ។

១៥ ព័ត៌មានផ្ដល់ដោយ Timothy Carney, ជាអ្នកឯកទេសខាងបញ្ហាកម្ពុជានៅស្ថានទូតអាមេរិកាំងប្រចាំក្រុងបាងកក ។ សូមអានសៀវភៅ "Cambodia's Communist regime begins to purge its own ranks while continuing a crack-down", Wall Street Journal, ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ ។

១៦ S.W.B., ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។

១៧ A.V.I., ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ ។

១៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយសាស្ត្រាចារ្យ ប្រាមោជ្ជ ណាខនថាប (Pramoj Nakhonthap) អតីតគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យធម្មសាតក្រុងបាងកក នាទីក្រុងវៀងច័ន្ទ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៨២ ។

១៩ ព័ត៌មានផ្ដល់ឲ្យនៅខែឧសភា ឆ្នាំ១៩៧៧ ដោយអ្នកការទូតអាស៊ីម្នាក់ដែលបំពេញមុខងារនៅក្រុងហាណូយ ។

២០ ការសន្ទនារបស់អ្នកនិពន្ធជាមួយ ខាំគុណ មន្ត្រីនៃគណៈកម្មាធិការប្រជាជនខេត្តស្វាយរៀង, ស្វាយរៀង ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨១ ។

២១ បក្សកុម្មុយនីស្តនៅវៀតណាម ៖ មហាសន្និបាតជាតិលើកទីIV ។ ឯកសារក្រុងហាណូយ, ការបោះពុម្ពផ្សាយជាភាសាបរទេស, 1977, pp. 161-162 ។

២២ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រស់ សារឿន នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨១ នាទីក្រុងភ្នំពេញ ។

២៣ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក Michel Strulovici អ្នកឆ្លើយឆ្លងព័ត៌មានរបស់កាសែតអ៊ុយម៉ានីតេ (l'Humanité) ប្រចាំទីក្រុងហាណូយ, ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។

២៤ ការសន្ទនាជាមួយអ្នកការទូតឥណ្ឌាម្នាក់ដែលបំពេញមុខងារនៅទីក្រុងប៉េកាំង នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៧, ហុងកុង ។

២៥ «សេចក្តីរាយការណ៍សង្ខេបស្តីពីការសន្ទនារបស់ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ជាមួយ ផាំ វ៉ាន់ដុង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧», A.C.N., ២២ ខែមីនា ឆ្នាំ១៩៧៩ ។

២៦ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ស៊ីនណាថមប៊ី រ៉ាហ្សារ៉ាតណាម រដ្ឋមន្ត្រីការបរទេសសិង្ហបុរី, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៨២, សិង្ហបុរី ។

២៧ A.C.N., ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៧ ។

២៨ S.W.B., ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧ ។

២៩ S.W.B., ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៨ ។

៣០ សំណុំរឿងកម្ពុជា, p. 133 ។

៣១ S.W.B., ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧ ។

៣២ តាមកាសែត Sankei Shimbun, លើកយកមកនិយាយជាសំអាងក្នុង Issues and Studies, ខែមីនា ឆ្នាំ១៩៧៨ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ តាមប្រភពព័ត៌មានមួយរបស់វៀតណាមថា ទីប្រឹក្សាចិនយ៉ាងច្រើនត្រូវចាប់ជាឈ្លើយសឹកក្នុងឱកាសនៃការវាយបកមួយនៅក្នុងដែនដីរបស់កម្ពុជា ។

៣៣ «សេចក្តីរាយការណ៍សង្ខេបស្តីពីការសន្ទនារបស់ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ជាមួយ ផាំ វ៉ាន់ដុង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧», A.C.N., ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៩ ។

៣៤ S.W.B., ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៧ ។

៣៥ S.W.B., ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧ ។ បន្ថែមពីលើឯកសារនេះ មានការចុះហត្ថលេខាលើ ៖ សន្ធិសញ្ញាកំណត់ព្រំដែនមួយរវាងវៀតណាម-ឡាវ, កិច្ចព្រមព្រៀងផ្តល់ជំនួយសេដ្ឋកិច្ចមួយសម្រាប់រយៈពេលពាឆ្នាំដោយមិនបាច់សងវិញ និងផ្តល់នូវប្រាក់កម្ចីមួយដោយគ្មានយកការប្រាក់ និងកិច្ចព្រមព្រៀងមួយ ដើម្បីផ្តល់ទិដ្ឋាការសម្រាប់អ្នកការទូតនិងមន្ត្រីបុគ្គលិករដ្ឋការប្រទេសទាំងពីរ ។ តាមឯកអគ្គរដ្ឋទូតរបស់វៀតណាមប្រចាំប្រទេសឡាវ ង្វៀន ស៊ិន (Nguyen Xuan) ថា អ្វីដែលសំខាន់គឺជំនួយសេដ្ឋកិច្ចត្រូវតែប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់កងទ័ពវៀតណាមដែលសំចតនៅប្រទេសឡាវ ។

៣៦ បទសម្ភាសន៍របស់សមមិត្ត ប៉ុល ពត ជាមួយគណៈប្រតិភូអ្នកកាសែតយូហ្គោស្លាវី ដែលមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ, ភ្នំពេញ, កម្ពុជាប្រជាធិបតេយ្យ ខែមីនា ឆ្នាំ១៩៧៨ ។

៣៧ សុន្ទរកថារបស់ ប៉ុល ពត នៅមុខគណៈកម្មាធិការអចិន្ត្រៃយ៍បក្សនាថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៨ ដែលយកមកបង្ហាញនៅចំពោះមុខតុលាការបដិវត្តន៍ក្រុងភ្នំពេញនៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៩ ក្រោមលេខ

យោង ២.៥.១១ ។ តុលាការនេះបានកាត់ទោស ប៉ុល ពត និង អៀង សារី កំបាំងមុខ ដោយប្រហារជីវិតបង់ ។

៣៨ លើកយកមកនិយាយជាសំអាងដោយលោក ណាយ៉ាន់ ចាន់ដា ៖ "ឡាវ, វៀតណាម ៖ មិត្តជិតស្និទ្ធជាងគេ", ទស្សនាវដ្តី F.E.E.R., ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៧ ។

៣៩ លើកយកមកនិយាយជាសំអាងដោយលោក ហ្គារ៉េត ព័រទ័រ ៖ , "នយោបាយរបស់វៀតណាម និងវិបត្តិនៅឥណ្ឌូចិន", p. 97 ។

៤០ Kiernan and Boua, Peasants, p. 170 ។

៤១ ឯកសារNº2.5.11, ក្នុងកំណត់ជាសំអាងនៅត្រង់លេខរៀង៣៧ ។

៤២ S.W.B., ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៧ ។

៤៣ S.W.B., ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៧ ។

៤៤ P.I, ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧, pp. 20-30 ។

៤៥ កំណត់ហេតុស្តីពីការជួបរបស់ ប៉ុល ពត ជាមួយពួកមេដឹកនាំចិន, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ត្រូវរឹបអូសបាននៅទីក្រុងភ្នំពេញ ឯកសារនេះត្រូវបានបង្ហាញនៅចំពោះមុខតុលាការបដិវត្តន៍ នាខែសីហា ឆ្នាំ១៩៧៩ ក្រោមលេខយោង ២.៥.២៨ ។

៤៦ សេចក្តីរាយការណ៍បានធ្លាក់ក្នុងដៃក្រុមភ្នាក់ងារសម្ងាត់នៅតៃវ៉ាន់ ហើយបានបោះពុម្ពផ្សាយក្នុង Issues and Studies, ខែធ្នូ ឆ្នាំ១៩៧៧, pp. 77-79 ។ សេចក្តីរាយការណ៍នេះ បានបោះពុម្ពផ្សាយមួយខែមុនការផ្តើមសង្គ្រាមរវាងកម្ពុជានិងវៀតណាម ដែលវាបង្ហាញឲ្យឃើញច្បាស់ជាក់ ។

៤៧ P.I., ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧, pp. 20-30 ។

## ខគ្គ"នរោត្តម សីហនុ ៖ ក្សត្រដែលចាកចេញពីឆាកនយោបាយ"

១ ការសន្ទនារបស់អ្នកនិពន្ធជាមួយ ដាំ វ៉ាន់បា, អតីតឯកអគ្គរដ្ឋទូតរបស់វៀតណាមប្រចាំកម្ពុជាប្រជាធិបតេយ្យ ក្រុងហូជីមិញ ថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១ ។

## ជំពូកទី៤

១ Wang Gungwa, សហគមន៍និងប្រជាជាតិ ៖ ការនិពន្ធល្បងអំពីអាស៊ីអាគ្នេយ៍ និងប្រទេសចិន, Singapore, Heinemann, 1981, p. 53 ។

២ Georges Maspero, "ព្រះរាជាណាចក្រចម្ប៉ា", Paris, Van Houst, 1928, p. 224 ។

៣ កាសែត *Réalités Cambodgiennes*, លេខចេញថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៥ ។

៤ *Huynh Sanh Thong, éd. et trad., The Heritage of Vietnamese Poetry, New Haven, Conn., Yale University Press, 1979, p. 3* ។

៥ *Henri Maspero*, ដកស្រង់ជាសំអាងដោយលោក *M. Coughlin*, «វៀតណាមក្នុងស្រមោលរបស់ចិន», *Journal of Southeast Asian History*, កញ្ញា ឆ្នាំ១៩៦៧, *p. 242* ។

៦ ដកស្រង់មកនិយាយជាសំអាងដោយលោក *Keith W. Taylor, "The rise of Dai Viet and the establishment of Thang Long" dans Kenneth R. Hall and John K. Whitmore éd., Explorations in Early Southeast Asian History: The Origins of Southeast Asian Statecraft, Michigan Papers on South and Southeast Asia, Nº11, Ann Arbor, 1976, pp 165-166*, បកប្រែពីភាសាវៀតណាមដោយលោកតៃល័រ ។ សំណៅដើមជាភាសាចិនត្រូវបាត់បង់ ។ ប្រវត្តិវិទូ *Wang Gungwu* គិតថា លិខិតនេះទំនងជាបានបញ្ជូន ដោយពិតប្រាកដ ព្រោះបារម្ភធ្វើឲ្យរំជួលដល់មនោសញ្ចេតនាជាតិនិយម ប៉ុន្តែមានការកែបន្ថែមឲ្យកាន់តែល្អលើសមុនខ្លះពីសំណាក់អ្នកសរសេរកាលប្បវត្តិរបស់វៀតណាម ។

៧ *Gungwu, op. cit., p. 64* ។

៨ *Thomas Hodgkin, Vietnam: the Revolutionary Path, New York, St. Martin's Press, p. 56* ។

៩ *Hodgkin, ibid., p. 89* ។

១០ សាស្ត្រាចារ្យ *George Mct. Kahin*, ព័ត៌មានផ្ទាល់ខ្លួន, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៨៤ ។

១១ *Trung Buu Lam, "Intervention versus Tribute in Sino-Vietnamese Relations, 1788 -1790"*, ក្នុង *The Chinese World Order, John K. Fairbank éd., Cambridge, Harvard University Press, 1968, p. 178* ។

១២ *Le Thanh Khoi, Histoire du Vietnam des origines à 1858, Paris, Sudestasie, 1981, p. 214* ។

១៣ *Lloyd Eastman, Throne and Mandarins: China's Search for a Policy during the Sino-French Controversy 1880-1885, Cambridge, Harvard University Press, 1967, p. 43* ។

១៤ *Trung Buu Lam, ibidem, 174-175* ។

១៥ *John K. Whitmore, The Development of Le Government in Fifteenth Century Vietnam*, និក្ខេបបទថ្នាក់បណ្ឌិត, *Cornell University, 1968, p. 208* និងសៀវភៅ «ព្រះរាជាណាចក្រចម្ប៉ា» *p. 231* របស់លោក *Maspero* ផងដែរ ។

១៦ *Chandler, Cambodia Before the French, p. 63* ។

១៧ និក្ខេបបទរបស់ វូដសៃ ដែលត្រូវបានការពារយ៉ាងត្រចះត្រចង់ក្នុងសៀវភៅរបស់គាត់ មានចំណងជើង

ថា វៀតណាម និងគំរូចិន, *Cambridge, Harvard University Press, 1971, pp. 253-254* ។

១៨ *Dao Vang Vy, Nguyen Tri Phuong, Saigon, Nha Van Hoa, Ba Van Hoa, Giao Duc Va Than Nien, 1974, p. 53.* ខ្ញុំសូមអគុណលោក *Michael Eiland* ដែលបានទាក់ទាញការយកចិត្តទុកដាក់របស់ខ្ញុំទៅលើសង្កាត់អត្ថបទត្រង់នេះ ហើយដែលបានបកប្រែឲ្យខ្ញុំថែមទៀត ។

១៩ *John T. McAlister, Jr.,* "ភាពអាចនឹងកើតមានសម្រាប់ការផ្សារទូតនៅអាស៊ីអាគ្នេយ៍", *World Politics, Vol. XIX, N°2,* ខែមករា ឆ្នាំ១៩៧៦, *p. 273* ។

២០ ដកស្រង់យកមកនិយាយជាសំអាងដោយលោក *Huynh Kim Khanh,* លទ្ធិកុម្មុយនីស្តវៀតណាម, *Ithaca, N.Y., Cornell University Press, 1982, p. 129* ។

២១ *Dossier Kampuchéa, p. 95* ។

២២ *Ibid* ។

២៣ *William Turley, "Vietnam's View of Regional Order",* ការទាក់ទងគ្នានៅសន្និបាតប្រចាំឆ្នាំលើកទី២៦នៃសមាគមសិក្សាពីបញ្ហាអន្តរជាតិ, *Washington D.C., 8 mai 1985, p.6* ។

២៤ *Ibid* ។

២៥ អត្ថបទរបស់ *Che Viet Tan "Redistribute the work force in order to build and defend the fatherland", Tap Chi Cong San,* ខែសីហា ឆ្នាំ១៩៧៩ ត្រូវបានបកប្រែចុះផ្សាយក្នុងសេចក្តីរាយការណ៍របស់ប្រទេសវៀតណាម, *N°2148, Washington, D.C., National Technical Information Service, 1979, Washington D.C., 1979, p. 21* ។

២៦ *F.B.I.S.-A.P.A.,* ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៨៥, *K.G* ។

២៧ លើកមកនិយាយជាសំអាងដោយ *Suebsaeng Promboon, Sino-Siamese Tributary Relations, 1282-1853,* និក្ខេបបទថ្នាក់បណ្ឌិត, *University of Wisconsin, 1971, p. 173* ។

២៨ លើកយកមកនិយាយជាសំអាងដោយ *Gungwu, op. cit., pp. 46-47* ។

២៩ លើកយកមកនិយាយជាសំអាងដោយ *Eastman, op. cit., p. 39* ។

៣០ *Ben Kiernan,* សៀវភៅ "តើ ប៉ុល ពត ចូលកាន់អំណាចបែបណា?", *London, Verso, 1985, p. 140* ។

៣១ សេចក្តីរាយការណ៍ដែលតាមសង្កេតមើលតួនាទីរបស់ប្រទេសចិននៅសន្និសីទក្រុងហ្សឺណែវ គឺសំអាងជាសំខាន់លើសៀវភៅរបស់លោក *François Joyaux,* "ប្រទេសចិន និង ការដោះស្រាយជម្លោះឥណ្ឌូចិនទីមួយ", ហ្សឺណែវ ឆ្នាំ១៩៥៤, ប៉ារីស, ការបោះពុម្ពផ្សាយរបស់ *Sorbonne, 1979, pp. 231-323* ។

៣២ ចំពោះការវិភាគល្អិតល្អន់មួយអំពីឥរិយាបថរបស់ប្រទេសចិន ចំពោះការបង្រួបបង្រួមប្រទេសវៀតណាម

តែមួយ សូមអានសៀវភៅ *ជម្លោះចិន-វៀតណាម* របស់លោក *Eugène K. Lawson, New York, Praeger, 1984, pp. 52-69* ។

៣៣ *Roxane Witke, សមមិត្តនារី ចាង ឈិញ, Little, Brown, 1977, p. 271* ។

៣៤ *Mohamed Heikal, Nasser: ឯកសារក្រុងកែរ, London, New English Library, 1973, p. 269* ។

៣៥ សេចក្តីសារភាពរបស់លោកជំទាវ *Wang Guangmei* ចំពោះលោក *David G. Marr*, ប៉េកាំង, ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៨០ ។ អគុណចំពោះលោក *David G. Marr* ដែលបញ្ជូនមកឲ្យខ្ញុំនូវកំណត់ខ្លីៗរបស់លោក ។

៣៦ *Kissinger, Years of Upheaval, pp. 58-59* ។

៣៧ ត្រូវសាកសួរដោយអ្នកនិពន្ធនៅទីក្រុងវៀងច័ន្ទ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៨ នាយទាហានវៀតណាមម្នាក់បានប្រកាសប្រាប់ខ្ញុំថា ៖ «ជនជាតិឡាវកាត់ចិនម្នាក់គឺ ឧត្តមសេនីយ៍ ភូម៉ា ត្រូវបានសម្លាប់ក្នុងការប្រយុទ្ធនៅឆ្នាំ១៩៧១ ប៉ុន្តែគេបានបំផ្លើសថា គាត់ត្រូវកំចាត់ដោយវៀតណាម» ដោយធ្វើឲ្យគេជឿថា ពាក្យចចាមអារ៉ាមប្រហែលជាមូលហេតុមួយហើយមើលទៅ ។

៣៨ *Pierre Mendès France, ទល់មុខគ្នាជាមួយនឹងអាស៊ី, New York, Liveright, 174, pp. 107-108.* ការបោះពុម្ពផ្សាយតាមសំណៅដើម, *Pierre Mendès France, ការសន្ទនាជាមួយនឹងអាស៊ីថ្ងៃនេះ, សៀវភៅកំណត់ហេតុនៃការធ្វើដំណើរ, Paris, Gallimard, 1972* ។

៣៩ *Pierre Mendès France, op. cit., p.189* ។

៤០ *Etienne M. Mana'ch, ប្រទេសមួយដែលឆ្លងកាត់ដោយបណ្តាអានុភាពមិនអាចទប់ទល់បាន ៖ ចិន-ឥណ្ឌូចិន ឆ្នាំ១៩៧២-១៩៧៣ Paris Fayard, 1982, p. 575* ។

៤១ *Porter, «វៀតណាមនិងវិបត្តិឥណ្ឌូចិន», pp. 74-75* ។

៤២ ទស្សនាវដ្តី *F.E.E.R.*, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៩, *p. 39* ។

៤៣ *Lawson, op. cit., pp. 193-194* ។

៤៤ ការកត់សម្គាល់របស់ តាង (*Tang*) ត្រូវបានអះអាងបញ្ជាក់ដោយមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្រុងហាណូយ និងដកស្រង់យកមកនិយាយជាសំអាងដោយលោក *Stanley Karnow* ក្នុងសៀវភៅ *វៀតណាម, អំពីប្រវត្តសាស្ត្រមួយ, N.Y., Viking, 1983, p. 638.* ។ បួនខែមុនការធ្វើដំណើររបស់ប្រធានាធិបតី និចសុន ទៅកាន់ប្រទេសចិន (ខែកុម្ភៈ ឆ្នាំ១៩៧២) ប្រទេសចិនបានទូន្មានឲ្យប្រទេសវៀតណាមទុកបញ្ហាប្រធានាធិបតី ធីវ មួយដុំសិន ហើយសម្រេចឲ្យខាងតែបាននូវកិច្ចព្រមព្រៀងមួយសំដៅឲ្យមានការដកកងទ័ពអាមេរិកចុងក្រោយចេញពីប្រទេសវៀតណាម ។

៤៥ *François Missoffe, ការប្រយុទ្ធតតូរវាងក្រុមនយោបាយខាងឆ្វេង, Paris, Ramsay, 1977, p. 128* ។

៤៦ Thanh Nam, "ប៉េកាំងសង្គ្រោះក្រុងព្រៃនគរ" (បេកាំងជួយក្រុងព្រៃនគរ), ទិនានុប្បវត្តិវៀតណាម, ខែមិថុនា ឆ្នាំ១៩៧៩; Philippe Richer, ល្បែងលេងបួននាក់នៅអាស៊ីអាគ្នេយ៍, Paris, Presses Universitaires de France, 1982, p. 49 ។

៤៧ Joyaux, la Chine, p. 355 ។

៤៨ Lawson, op. cit., p. 242 ។

៤៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតវៀតណាមម្នាក់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៨៣ នាទីក្រុងបាងកក ។

## ជំពូកទី៥

១ Seymour Hersh, The Price of Power: Kissinger in the Nixon White House, New York, Summit Books, 1983, pp. 623-625 ។

២ តាមកិច្ចព្រមព្រៀងក្រុងប៉ារីស ប្រទេសវៀតណាមបានសន្យា "ជួយសម្រួលដល់ការបញ្ជូនទៅមាតុប្រទេសវិញនូវសាកសពទាហានទាំងឡាយដែលបាត់ក្នុងខ្លួនការប្រយុទ្ធ" ហើយសហរដ្ឋអាមេរិកសន្យា "ជួយផ្សះមុខរបួសសង្គ្រាម" ។

៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ឡេអូណាដ៍ វូដខុក នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៨៤នាទីក្រុងវ៉ាស៊ីនតោន ។

៤ ការិយាល័យអនុព័ន្ធព័ត៌មានរបស់សេតវិមាន, Presidential Commission on Americans Missing and Unaccounted for in Southeast Asia: A Report on Trip to Vietnam and Laos March 16-20, 1977, Washington, D.C., ថ្ងៃទី២៣ ខែមីនា ១៩៧៧, p. 11 ។

៥ W.P., ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។

៦ ថ្វីបើមតិភាគច្រើនលើសលុបមួយនៃរដ្ឋាភិបាលសហរដ្ឋអាមេរិក បង្ហាញភាពអមិត្តចំពោះប្រទេសវៀតណាមនៅឆ្នាំ១៩៧៥ក៏ដោយ ក៏មានអ្នកខ្លះលំអៀងទៅរកការផ្សះផ្សាគ្នាដែរ ។ លោកវរសេនីយ៍ត្រីយ៍ ម៉ែខឹល អ៊ីឡិន ដែលប្រឡូកយូរមកហើយក្នុងការប្រឹងប្រែងធ្វើសង្គ្រាមរបស់អាមេរិកាំងនៅឥណ្ឌូចិន បានសរសេរអនុស្សរណៈមួយទៅអនុរដ្ឋមន្ត្រីការពារប្រទេសនៅថ្ងៃទី៥ ខែមិថុនា ដោយណែនាំពីការធ្វើឲ្យមានប្រក្រតីភាពជាមួយក្រុងហាណូយ ទោះបីជាទម្រង់ដ៏ជាក់លាក់មួយនៃជំនួយផ្នែកសេដ្ឋកិច្ចត្រូវបង់ជាតម្លៃក៏ដោយ ។ សម្រាប់គាត់យល់ថា ការរាំងខ្ទប់ផ្នែកសេដ្ឋកិច្ច "គឺជាទង្វើរំលោភបំពានមួយថែមទាំងជាទង្វើប្រឡោតគោគគូងមួយផង ដែលមិនសមរម្យទាំងស្រុងក្នុងនយោបាយអន្តរជាតិរបស់ប្រជាជាតិ

ជឿនលឿនមួយ» ។ ដោយផ្ទុយទៅវិញ អ៊ីឡិន បានផ្តល់ជាអនុសាសន៍ឲ្យប្រកាន់យកវិធានការល្អិតល្អន់និងមោះមុតផ្សេងៗទល់នឹងតថភាពនៃប្រទេសវៀតណាមថ្មី ។

៧ N.Y.T., ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។

៨ ដកស្រង់មកនិយាយជាសំអាងដោយលោក Murray Hiebert, “Playing Politics with the MIAs”, Southeast Asia Chronicle, N°85, ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨២ ។

៩ N.Y.T., ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៦ ។

១០ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ ហូលប្រ៊ុក នៅថ្ងៃទី៥ ខែមិថុនា នាទីក្រុងប៉េកាំង ។

១១ តាមការឲ្យដឹងរបស់ក្រសួងការពារប្រទេសថា ក្នុងចំនួនសរុបមនុស្សបាត់ខ្លួននៅឥណ្ឌូចិន២.៥៤៦នាក់ មាន៧៥៣នាក់បានត្រូវចាត់ទុកថាបាត់ខ្លួនក្នុងការប្រយុទ្ធ, ៣៣នាក់ត្រូវចាប់ជាឈ្លើយសង្គ្រាម, ៦៤៧នាក់ ទំនងជាស្លាប់ ហើយ១.១១៣បានត្រូវសម្លាប់ក្នុងពេលប្រយុទ្ធ ដោយគេមិនអាចនាំសាកសពមកបាន ។ សូមអាចសៀវភៅរបស់លោក Bill Herod, “The Unfinished Business of America’s MIAs”, Indochina Issues, N°17, មិថុនា ឆ្នាំ១៩៨១, រួមទាំង “America’s Missing: A Look behind the Numbers”, Indochina Issues, N°៥៤, ខែកុម្ភៈ ឆ្នាំ១៩៨៥ផង ។

១២ W.P., ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៦ ។

១៣ Cyrus Vance, Hard Choices: Critical Years in American Foreign Policy, New York, Simon and Schuster, 1983, 450 ។

១៤ សន្និសីទកាសែតរបស់ប្រធានាធិបតី ខាធ័រ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧, ក្រុងវ៉ាស៊ីនតោន ។

១៥ S.W.B., ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ ។

១៦ ក្នុងការសន្ទនាមួយនៅទីក្រុងហុងកុង នាថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៨៣លោក មីស្លែល អូកសេនបឺក អ្នកឯកទេសខាងបញ្ហាអាស៊ីនៅក្រុមប្រឹក្សាសន្តិសុខជាតិ បាននិយាយប្រាប់ខ្ញុំជាឧទាហរណ៍ថា ៖ «បេសកកម្មរបស់ វូដខូក ប្រព្រឹត្តទៅមិនបានល្អឡើយ ។ តាមការពិត អ្នកខ្លះបានខំប្រឹងធ្វើដំណើរមួយសម្រាប់តែរឿងទាហានអាមេរិកបាត់ខ្លួនសុទ្ធសាធ, ឱកាសនៃការបោះតម្រុយដំបូងៗសម្រាប់ការធ្វើឲ្យមានប្រក្រតីភាពមួយជាមួយប្រទេសវៀតណាមកំពុងនាំឲ្យវៀតណាមយល់ច្រឡំ ។ នៅចំពោះមុខ វូដខូក វៀតណាមបានបង្ហាញលក្ខណៈទន់ភ្លន់អំពីបញ្ហាជួសជុលការខូចខាតដោយសារសង្គ្រាម ។ រហូតទាល់តែក្រោយមកទើបវៀតណាមលែងបន្ទន់ជំហរ ហើយខាំក្រាញចំពោះសំណើសុំជំនួយសេដ្ឋកិច្ចរបស់គេ» ។

១៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយ ង្វៀន ឡាំ ប្រធានគណៈកម្មាធិការផែនការរបស់វៀតណាមនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨១នាទីក្រុងហាណូយ ។ ទស្សនាវដ្តី F.E.E.R, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៨១ ។

១៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយ រីឆាដ ហូលប្រ៊ុក នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៨៣ នាទីក្រុងប៉េកាំង ។

១៩ *C.Vance, op. cit., p. 122.* ។ ខាធ័រ បានសម្តែងឲ្យដឹងពីទឹកចិត្តរបស់គាត់ថា "ត្រៀមប្រកួតប្រជែងនឹងពួកសូវៀតក្នុងតំបន់ជាយុទ្ធសាស្ត្រទាំងឡាយ ជាពិសេសនៅប្រទេសវៀតណាម" ។ *N.Y.T.*, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៧ ។

២០ *Zbigniew Brzezinski*, អំណាចនិងគោលការណ៍ ៖ កំណត់ប្រវត្តិអំពីក្រុមប្រឹក្សាសន្តិសុខជាតិ *(1977-1981), New York, Farrar, Straus, Giroux, 1983,p. 197* ។

២១ សាធារណរដ្ឋសង្គមនិយមវៀតណាមរបាយការណ៍សេដ្ឋកិច្ចមួយ, ធនាគារពិភពលោក, *Washington, D.C., August 1977, p. 66* ។

២២ ទូរលេខរបស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំក្រុងបាងកក *Charles Whitehouse, N°09191-2717442*, ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ ។

២៣ *Asian Wall Street Journal*, ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៧ ។

២៤ ការរៀបរាប់លំអិតល្អន់នេះគឺបានមកពីការសន្ទនារបស់អ្នកនិពន្ធជាមួយអនុរដ្ឋមន្ត្រីការបរទេស ផាន់ ហៀន នៅទីក្រុងប៉ារីស នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ និងជាមួយអតីតអនុរដ្ឋមន្ត្រី រីឆាដ ហូលប្រ៊ុក, ក្រុងវ៉ាស៊ីនតោន.ឌី.ស៊ី., ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨១ ។

២៥ *F.B.I.S-A.P.A.*, ថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៧៧, *K-5* ។

២៦ *Arkady N. Shevchenko*, បែកបាក់ជាមួយនឹងក្រុងមូស្គូ, *New York; Knopf, 1985, p. 265.* ការបោះពុម្ពផ្សាយ ជាភាសាបារាំង ៖ "ការផ្តាច់មិត្តភាពជាមួយក្រុងមូស្គូ" *(Rupture avec Moscou), Paris, Payot, 1985* ។

២៧ *Marc Menguy*, ហាណូយប្រឆាំងនឹងប៉េកាំង, មជ្ឈមណ្ឌលសម្រាប់កិច្ចការអន្តរជាតិ, *Harvard University, 1979, p. 36* ។

២៨ *Ibid., 40* ។

២៩ *Ibid., 41* ។

៣០ *Information-Documents, N°3*, ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៨២, បោះពុម្ពផ្សាយដោយ *C.V.*, ក្រុងហាណូយ, *p. 11* ។

## ជំពូកទី៦

១ ការរៀបរាប់អំពីឧបទ្ទវហេតុនៅសណ្ឋាគារថាំងឡនេះ គឺសំអាងលើការសន្ទនាជាមួយអ្នកការទូតជាច្រើន

ដែលមានមុខនៅក្នុងពិធីបដិសណ្ឋារកិច្ច ។ ឧបទ្ទវហេតុបានត្រូវលើកយកមកនិយាយដោយលោក Marc Menguy អ្នកការទូតបារាំង ដែលពេលនោះបំពេញមុខងារនៅទីក្រុងហាណូយ ៖ *ហាណូយប្រឆាំងនឹងប៉េកាំង*, មជ្ឈមណ្ឌលសម្រាប់កិច្ចការអន្តរជាតិ, 1979, p. 33 ។

២ ហូ ជីមិញ ៖ «ហេតុអ្វីខ្ញុំជ្រើសរើសលទ្ធិឡេនីននិយម», *សកម្មភាពនិងការបដិវត្តន៍ (Action et Révolution 1920-1967,)* អត្ថបទជម្រើស និងរៀបចំដោយលោក Colette Capitan -Peter-Paris, សហភាពទូទៅនៃការបោះពុម្ពផ្សាយ, coll. 10/18, 1968, p.18 ។

៣ អំពីដំណើរជីវិតរបស់ ហូ ជីមិញ សូមអានសៀវភៅរបស់លោក Jean Lacouture: *Ho Chi Minh*, Paris, éditions du Seuil, 1977 ។ អំពីចលនាកុម្មុយនីស្តវៀតណាម សូមអានសៀវភៅមួយក្នុងចំណោមសៀវភៅនានាដែលល្អជាងគេគឺ *លទ្ធិកុម្មុយនីស្តវៀតណាម ១៩២៥-៤៥* របស់លោក Huynh Kim Khanh, Ithaca, New York, Cornell University Press, 1982 ។

៤ Gareth Porter, "Vietnam and the Socialist Camp: Center or Periphery", *Vietnamese Communism in Comparative Perspective*, William Turley éd., Boulder, Colo., Westview Press, 1980, pp. 228-231 ។

៥ Bernard Fall, សៀវភៅ ៖ *វៀតមិញ ៖ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម 1945-60*, Paris, Presses de la Fondation nationale des sciences politiques, 1960, p. 116-119 ។

៦ Jean Lacouture និង Philippe Devillers, *End of a War: Indochina 1954*, New York, Praeger, 1969, pp. 291-293 ។ ការបោះពុម្ពច្បាប់ដើម ៖ *ទីបញ្ចប់នៃសង្គ្រាមមួយ, ឥណ្ឌូចិន ឆ្នាំ១៩៥៤*, Paris, éditions du Seuil, 1960 ។

៧ Porter, op. cit., p. 247 ។

៨ លើកយកមកនិយាយជាសំអាងដោយលោក Douglas Pike: "ឥទ្ធិពលនៃជម្លោះចិន-សូវៀតចំពោះអាស៊ីអាគ្នេយ៍", *ជម្លោះរវាងចិន-សូវៀត*, Herbert Ellison éd., Scattle, University of Washington Press, 1982, p. 196 ។

៩ Donald S. Zagoria, *Vietnam Triangle: Moscow, Peking, Hanoi*, New York, Pegasus, 1967, p. 127 ។

១០ សម្រាប់ការវិភាគស៊ីជម្រៅមួយអំពីនយោបាយរបស់វៀតណាមចំពោះសហភាពសូវៀត និងប្រទេសចិន សូមអានសៀវភៅរបស់លោក W.R. Smyser, *ភាពមិនពឹងផ្អែករបស់វៀតណាម ៖ លទ្ធិកុម្មុយនីស្តវៀតណាមនៅចន្លោះ រុស្ស៊ី និងចិន, 1956-69*, Papers on International Studies, Southeast Asia Series, N°55, Athens, Ohio, Ohio University Center for International Studies, 1980 ។

១១ David Butler, *ការដួលរលំរបស់ក្រុងព្រៃនគរ*, New York, Simon and Schuster, 1985, p. 299 ។

១២ *Daniel S Papp., វៀតណាម : មតិមកពីក្រុងមូស្គូ, ប៉េកាំង, វ៉ាស៊ីនតោន, Jefferson, N.C., Mc Farland, 1981, p. 195 ។*

១៣ *Shevchenko, បែកបាក់ជាមួយនឹងក្រុងមូស្គូ, pp. 262-263 ។*

១៤ *ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីម្នាក់នៃក្រសួងការបរទេសរបស់វៀតណាមនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៨១ នាទីក្រុងហាណូយ ។*

១៥ *Joseph Alsop, "Showdown Over Southeast Asia", ទស្សនាវដ្តី Reader's Digest, លេខចេញខែធ្នូ ឆ្នាំ ១៩៧៥, ទំព័រ១២៨ ។*

១៦ *ការសន្ទនារបស់អ្នកនិពន្ធជាមួយ វ៉ាង ទុង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៥ នាទីក្រុងហាណូយ ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេសវៀតណាម នៅទីក្រុងហាណូយ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៧៥ ។*

១៧ *Q.D.N.D., ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៤, ដកស្រង់មកនិយាយជាសំអាងក្នុង Asian Analyst, ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៥, p. 4 ។*

១៨ *ព័ត៌មានផ្ទាល់ខ្លួនរបស់លោក Peter Limqueco, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។*

១៩ *វិចារណកថារបស់កាសែត Giaiphong ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដកស្រង់មកនិយាយជាសំអាងដោយ Le Thi Tuyet, វៀតណាម : សង្គមនិយមក្នុងការស្វែងរកមូលធន, Washington, D.C., Center of Strategic and International Studies, 1976, p. 9 ។*

២០ *Nayan Chanda, "Hanoi Opts For a Broad Approach", ទស្សនាវដ្តី F.E.E.R, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៧៧ ។*

២១ *ការឆ្លើយឲ្យការណ៍របស់លោក Evelyn Colbert អតីតអនុរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការអាស៊ីខាងកើត និងប៉ាស៊ីហ្វិក នៅចំពោះមុខអនុគណៈកម្មការសភាទទួលបន្ទុកកិច្ចការអាស៊ីនិងប៉ាស៊ីហ្វិក, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៣, មុខងាររបស់សូវៀតនៅអាស៊ី, Washington, D.C., U.S. Government Printing Office, 1983, p. 193 ។*

២២ *Sevchenko, op. cit., p. 263 ។*

២៣ *ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតអឺរ៉ុបម្នាក់នៅថ្ងៃទី២៥ ខែវិច្ឆិកា នាទីក្រុងហាណូយ ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់នៃអគ្គទូតរបស់សូវៀត នៅទីក្រុងប៉េកាំងនាថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៨៣ ។*

២៤ *អ្នកឆ្លើយឆ្លងព័ត៌មានអនាមិក, "Le Duan backs the loners", ទស្សនាវដ្តី F.E.E.R., ថ្ងៃទី១៩ ខែមីនា*

ឆ្នាំ១៩៧៦ ។

២៥ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក Massimo Loche, អ្នកឆ្លើយឆ្លងព័ត៌មានកាសែត l'Unità នៅទីក្រុងហាណូយ, ខែធ្នូ ឆ្នាំ១៩៧៦ ។

២៦ "I.M.F., I.B.R.D., Tools of Imperialist Exploitation", ទីភ្នាក់ងារព័ត៌មាន Tass, ថ្ងៃទី៦ ខែមេសា ឆ្នាំ ១៩៨៣, F.B.I.S., U.S.S.R., ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៨៣, C.C.2 ។

២៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតឥណ្ឌាម្នាក់ដែលបំពេញមុខងារនៅក្រុងហាណូយ នាថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៧ នៅទីក្រុងហុងកុង ។

២៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតវៀតណាមម្នាក់នៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី៩ ខែមីនា ឆ្នាំ ១៩៧៧ ។

២៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកកាទូតអាស៊ីម្នាក់ដែលបំពេញមុខងារនៅទីក្រុងហាណូយ នាថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅទីក្រុងហុងកុង ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីម្នាក់នៃក្រសួងពាណិជ្ជកម្មអូស្ត្រាលីនៅទីក្រុងហុងកុងនាថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ ។ សូមអានអត្ថបទរបស់លោក Nayan Chanda, "Hanoi Opts For Broad Approach" ចុះផ្សាយក្នុងទស្សនាវដ្តី F.E.E.R. លេខចេញផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ផង ។

៣០ Robert Ross, Chana's Vietnam Policy, ១៩៧៥-១៩៧៩; The Politic of Alliance Termination, និក្ខេបបទថ្នាក់បណ្ឌិត, Colombia University, 1984, p. 140 ។

៣១ Nayan Chanda, "Vietnam's Economy: New Priorities", F.E.E.R., ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។

៣២ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតអាស៊ីម្នាក់ដែលបំពេញមុខងារនៅទីក្រុងហាណូយ នាថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៧នៅទីក្រុងហុងកុង ។

៣៣ S.W.B., ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៦ ។

៣៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតឥណ្ឌាម្នាក់ដែលបំពេញមុខងារនៅទីក្រុងហាណូយ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៧ នៅទីក្រុងហុងកុង ។

៣៥ ការសន្ទនាជាមួយលោក Philippe Richer អតីតឯកអគ្គរដ្ឋទូតបារាំងប្រចាំទីក្រុងហាណូយ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៨២ នៅទីក្រុងប៉ារីស ។

៣៦ សេចក្តីរាយការណ៍អំពីការចរចាសូវៀត-វៀតណាមនេះ គឺសំអាងលើការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតជាច្រើនរូប ទាំងខាងបស្ចិមប្រទេសក៏ដូចខាងបូកកុម្មុយនីស្ត រួមទាំងជាមួយអ្នកកាសែតអឺរ៉ុបខាងកើតនៅទីក្រុងហាណូយ នាខែវិច្ឆិកា ឆ្នាំ១៩៧៧ផង ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នក

ទទួលខុសត្រូវជាន់ខ្ពស់ផ្នែកការទូតរបស់សូវៀតនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៨៣ នាទីក្រុងប៉េកាំង ។

៣៧ *Ross, op., cit., 211* ។

៣៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតសូវៀត និង អឺរ៉ុបខាងកើត នៅទីក្រុងហាណូយ នាខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតឥណ្ឌាម្នាក់ ធ្វើការអមពួកសូវៀតនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨៦ នាទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។

## ជំពូកទី៧

១ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក *Sandor Gyori*, ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៨៥ ។

២ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក *Stephen Heder* នៅទីក្រុងបាងកក នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៨៣ ។

៣ ការពិពណ៌នានេះសំអាងលើការសន្ទនាជាឯកជនមួយជាមួយអ្នកទទួលខុសត្រូវវៀតណាមបីរូបក្នុងនោះមានម្នាក់ជាវរសេនីយ៍ឯក រួមទាំងជាមួយអ្នកការទូតនៃបណ្ដាប្រទេសមិនមែនកុម្មុយនីស្ត នៅទីក្រុងហាណូយ នាខែមីនា ឆ្នាំ១៩៧៨ផង ។

៤ សៀវភៅខ្មៅ : ហេតុការណ៍និងភស្តុតាងផ្សេងៗនៃអំពើឈ្លានពាននិងការក្លាប់ទឹកដីរបស់វៀតណាមប្រឆាំងនឹងកម្ពុជា, ភ្នំពេញ, ក្រសួងការបរទេស, ឆ្នាំ១៩៧៨, ទំព័រ៩៩ ។

៥ សំណុំរឿងកម្ពុជា, *Vol. 2. C.V., Hanoi, 1979, pp. 63-65* ។

៦ ការសន្ទនារបស់លោក *Stephen Heder* ជាមួយលោក ហ៊ុន សែន, ភ្នំពេញ, ខែកក្កដា ឆ្នាំ១៩៨១ ។

៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក *Stephen Heder* នៅទីក្រុងបាងកក នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៨៣ ។

៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតឥណ្ឌាម្នាក់ដែលបំពេញមុខងារនៅទីក្រុងហាណូយ នាខែសីហា ឆ្នាំ១៩៧៨ នៅទីក្រុងហុងកុង ។

៩ ការបកស្រាយស្របគ្នា ត្រូវបានផ្ដល់ដល់លោក *Stephen Heder* ដោយលោក ហ៊ុន សែន និង ហេង សំរិន ក្នុងឱកាសនៃការសន្ទនាដាច់ដោយឡែកពីគ្នានៅខែកក្កដា ឆ្នាំ១៩៨១ ។

១០ តាមលោក ហេង សំរិន ដែលកាន់មុខតំណែងសំខាន់ៗនៅក្នុងផ្ទៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅឆ្នាំ១៩៧៩ និងដែលក្លាយទៅជាប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ខេត្តកណ្ដាលបានឲ្យដឹងថា ក្រុមអ្នកបង្កើតរណសិរ្សនេះដំបូងគឺមានប្រាំបីនាក់ : គាត់, លោក ហ៊ុន សែន, នុត ថន, ញឹក ហួន, មាស ក្រូច, មាស ហួន, អ៊ុង ផន និង ប៉េង ប៉ាត់ (ការសន្ទនាជាមួយលោក *Heder*, ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨១

នៅក្រុងភ្នំពេញ) ។

១១ ការសន្ទនាជាមួយអ្នកការទូតវៀតណាមនិងអាស៊ីនៅក្រុងហាណូយ នាខែមីនា ឆ្នាំ១៩៧៨ ។

១២ ជម្លោះព្រំដែនរវាងចិន-វៀតណាម មានលក្ខណៈជានិមិត្តហេតុមួយច្រើនជាងជាបុព្វហេតុមួយនៃជម្លោះដែលមាននៅពេលខាងមុខ ។ ជម្លោះនេះបានចាប់ផ្ដើមនៅដើមទសវត្សរ៍១៩៧០ នៅពេលដែលផលប្រយោជន៍ ជាតិនិងជាយុទ្ធសាស្ត្ររបស់ប្រទេសទាំងពីរចាប់ផ្ដើមខ្វែងគ្នា ។ ចំពោះការបកស្រាយរបស់វៀតណាម សូមអានអនុស្សរណៈរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាមទាក់ទងទៅនឹងការបង្កហេតុ និងការរំលោភព្រំដែនរាប់មិនអស់ ដែលពួកអាជ្ញាធរចិននៅតាមបណ្ដោយព្រំដែនចិន-វៀតណាម ជាអ្នកទទួលខុសត្រូវ, ហាណូយ, ក្រសួងការបរទេស, ឆ្នាំ១៩៧៩, pp. 17-22 ។ សម្រាប់ភាព ច្បាស់លាស់ផ្សេងៗទាក់ទងនឹងព្រំដែនដែនគោកនេះ សូមអានអត្ថបទ *China-Vietnam Boundary, International Boundary Studies, N°38, Bureau of Intelligence and Research, U.S. Department of State, Washington, D.C.,* ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៦៤ ។ តាមអត្ថបទនេះថា “គ្មានការវិវាទដែនដីណាមួយឮមកដល់យើងទេ” ។

១៣ *A.V.I.,* ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៧ ។

១៤ ហ័ង វ៉ាន់ហាន បានចុះចូលនឹងពួកចិននៅខែកក្កដា ឆ្នាំ១៩៧៩ ប៉ុន្តែ ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់គាត់ជាមួយពួកចិន ត្រូវគេដឹងឮជាសាធារណៈតាំងពីមុនកាលបរិច្ឆេទនេះម៉្លេះ ។ វាអាចថា ក្រុងហាណូយខំប្រឹងប្រើប្រាស់ទំនាក់ទំនងផ្សេងៗរបស់គាត់ជាមួយពួកមេដឹកនាំចិន ដើម្បីទទួលបានការគាំទ្រពីក្រុងប៉េកាំងចំពោះគោលបំណងរបស់ខ្លួនដែរ ។ ពួកចិនប្រហែលជាបានទទួលពីគាត់នូវព័ត៌មានដ៏មានតម្លៃជាច្រើនស្ដីពីដំហររបស់ វៀតណាមទៅលើបញ្ហាសំខាន់ៗ ។ ទោះបីជាគាត់ផ្ទាល់ត្រូវទុកឲ្យមានមុខតំណែងជាផ្លូវការ (មានតែសំបកក្រៅ) ក៏ដោយ ក៏កូនរបស់គាត់បានកាន់កាប់ទីតាំងដ៏សំខាន់មួយក្នុងបក្សកុម្មុយនីស្តវៀតណាមដែរ ហើយអាចស៊ើប យកការណ៍តាមរយៈមិត្តភក្តិនិងអ្នកមានសមានចិត្តជាច្រើនរបស់គាត់ថែមទៀត ។

១៥ សំណៅនៃកិច្ចព្រមព្រៀង បានត្រូវប្រមូលបានដោយកងទ័ពរបស់វៀតណាមនៅក្រុងភ្នំពេញ នៅខែមករា ឆ្នាំ១៩៧៩ ។

១៦ *S.W.B.,* ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។

១៧ សេចក្ដីសម្រេចចិត្តដែលសន្មតថាជារបស់លោក ឡេ យន់ ត្រូវបាននាំមកនិយាយដោយទីភ្នាក់ងារព័ត៌មានចិនថ្មី(*A.C.N.*)នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៩បន្ទាប់ពីការចាប់ផ្ដើមអរិភាពរវាងចិន-វៀតណាម នៅឆ្នាំ១៩៧៨ ក្នុងគោលបំណងបរិហារពីការប្ដូរគំនិតភ្លាមៗរបស់វៀតណាម ។ ក៏ប៉ុន្តែ

*វាទំនងជាសំដៅប្រឆាំងនឹងសេចក្តីស្មោះត្រង់របស់វៀតណាមចំពោះប្រទេសចិនទៅភាពមិនស្មោះត្រង់របស់ក្រុងប៉េកាំងចំពោះប្រទេសវៀតណាមផងដែរ ។*

១៨ *S.W.B., ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។*

១៩ *S.W.B., ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។*

២០ *F.B.I.S.-P.R.C., ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៥, A-18-19 ។*

២១ *“Keng Piao’s របាយការណ៍អំពីស្ថានការណ៍នៅឧបទ្វីបឥណ្ឌូចិន” Issue and Studies, តៃប៉ិ, ខែមករា ឆ្នាំ១៩៨១, p. 85 ។ មន្ត្រីចិនថ្នាក់ខ្ពស់ម្នាក់បានបញ្ជាក់ប្រាប់ខ្ញុំពីលក្ខណៈពិតនៃឯកសារនេះ ។*

២២ *អ្នកទទួលខុសត្រូវចិនជាច្រើនរូប ដែលត្រូវសាកសួរនៅទីក្រុងប៉េកាំង និងទីក្រុងហុងកុង កាលពីឆ្នាំ ១៩៧៩ បាននិយាយអំពីភាពខ្វែងគំនិតគ្នាដែលនៅមានបន្តក្នុងផ្ទៃថ្នាក់ដឹកនាំចិន រហូតមកដល់ចុងឆ្នាំ ១៩៧៨ ស្តីពីបញ្ហាប្រទេសកម្ពុជា ។ នៅកាលបរិច្ឆេទនេះ ជម្លោះរវាងកម្ពុជា-វៀតណាមបានឡើងដល់កម្រិតមិនអាចត្រឡប់ក្រោយមួយ ដោយគំរាមកំហែងដល់ទីតាំងជាយុទ្ធសាស្ត្រទាំងឡាយរបស់ប្រទេសចិន នៅអាស៊ីអាគ្នេយ៍ ហើយ តេង ស៊ាវពីង ត្រូវបានជំរុញឲ្យបង្កើនការគាំទ្ររបស់ចិនដល់ប្រទេសកម្ពុជាទាំងទើសទាល់ ។*

២៣ *N.Y.T., ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៧, p.5 ។*

២៤ *ដោយលើកយកសម្តីសន្ទនាទាំងនេះមកនិយាយសំអាង ប្រព័ន្ធផ្សព្វផ្សាយរបស់វៀតណាមបានកត់សម្គាល់ថា “វាងាយយល់ណាស់ថា អ្នកណាដែលប្រើសម្តីបញ្ចិតបញ្ចៀងដែលមានគោលបំណងទាំងនេះ”, ជម្លោះវៀតណាម-កម្ពុជា ៖ ឯកសារមួយ, ហាណូយ, អគារបោះពុម្ពផ្សាយជាភាសាបរទេស, 1979, p. 23 ។*

២៥ *F.B.I.S.-A.P.A, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៧, H-3 ។*

២៦ *ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ចាន់ផេង ស៊ីផាកុំ ជាមន្ត្រីជាន់ខ្ពស់នៅក្រសួងការបរទេសឡាវ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៣ នៅទីក្រុងវៀងច័ន្ទ ។*

២៧ *ការសន្ទនារបស់អ្នកនិពន្ធជាមួយ វ៉ាង ទុង នៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៨ នាទីក្រុងហាណូយ ។*

២៨ *បរិយាកាសដែលកំពុងគ្របដណ្តប់ក្រុងភ្នំពេញនាពេលនោះ គឺត្រូវបានពិពណ៌នាដោយជនបរទេសជាអ្នកតាំងលំនៅក្រៅស្រុកម្នាក់ ក្នុងចំណោមជនបរទេសដ៏កម្រមានបំផុត គឺអ្នកស្រី ឡូរ៉ង់ពិច ជាភរិយារបស់កម្មាភិបាលថ្នាក់ដឹកនាំខ្មែរក្រហមម្នាក់ ដែលអ្នកស្រីបានរស់នៅប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ មុននឹងចាកចេញពីស្វាមីនិងប្រទេសដែលទទួលស្គាល់គាត់ទុកដូចជាកូន ។ សូមអានសៀវភៅ ៖ “ឆ្ងាយហួស ដើងមេឃ ៖ ប្រាំឆ្នាំជាមួយខ្មែរក្រហម”, Paris, Barrault, 1984, p. 116 ។*

២៩ *Ibid., p. 115* ។

៣០ *F.B.I.S.-A.P.A., ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨* ។

៣១ *ការសន្ទនារបស់អ្នកនិពន្ធជាមួយ Kieu Ming នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៨១ នាទីក្រុងភ្នំពេញ* ។

៣២ *ក្នុងឱកាសនៃសន្និសីទមួយ (នៅទីក្រុងប៉េកាំង ថ្ងៃទី៣១ ខែធ្នូ) ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យ ប៊ុច ជាង បានប្រកាសថា ៖ "ការជ្រើសរើសតែមួយគត់រវាងលទ្ធភាពពីររបស់យើងគឺវាយប្រយុទ្ធ ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីបណ្តាមិត្តរបស់យើងទាំងជិតទាំងឆ្ងាយលើទីបទាំងប្រាំ ដើម្បីជំរុញការគាំទ្រពីសាធារណៈមតិអន្តរជាតិ" ។ លើកយកមកនិយាយជាសំអាងដោយលោក Douglas Pick ក្នុងអត្ថបទជម្លោះវៀតណាម-កម្ពុជា, របាយការណ៍ដែលធ្វើសម្រាប់អនុគណៈកម្មការអំពីអាស៊ី និងកិច្ចការប៉ាស៊ីហ្វិក, Committee on International Relations, Washington, D.C., U.S. Congress, ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨, p. 11* ។

៣៣ *ទីភ្នាក់ងារព័ត៌មាន A.F.P., ថ្ងៃ២១ ខែតុលា ឆ្នាំ១៩៧៧* ។

៣៤ *នៅសម័យប្រជុំពេញអង្គរបស់បក្សកុម្មុយនីស្តចិននាខែកក្កដា ឆ្នាំ១៩៧៧ តេង ស៊ាវពីង បានថ្លែងសុន្ទរកថាមួយដែលរិះគន់ដោយត្រង់ៗបំផុតចំពោះនយោបាយក្រៅប្រទេសរបស់ចិនដោយចោទប្រកាន់ថា ផ្អែកទៅលើការគស្ទីវណ្ណៈខ្វាំងពេក (Issues and Studies, Taipei, mai 1979, p. 55)* ។ *មួយខែក្រោយមកចំនួនសមាជិកពាក់កណ្តាលនៃគណៈកម្មាធិការមជ្ឈិម សុទ្ធតែជាមនុស្សជិតដិតនឹង តេង ដែលពីមុនធ្លាប់ត្រូវធ្វើវិសុទ្ធកម្មចំពោះ"ភាពលំអៀងទៅរកស្តាំនិយម"របស់ខ្លួន ហើយត្រូវធ្វើឲ្យមាននីតិសម្បទាវិញសម្រាប់កាលៈទេសៈនេះ* ។ *នៅចុងឆ្នាំ១៩៧៧ ការបោសសម្អាតទូទៅមួយបានចាប់ផ្តើមសំដៅប្រឆាំងនឹងស្តាំនិយមឆ្វេងរបស់បក្ស* ។ *សូមអានសៀវភៅ នាគ និង ខ្លាឃ្មុំ, London, Pall Mall, 1982, pp. 226-229 របស់លោក Philip Short* ។ *គេអាចសន្និដ្ឋានដោយសមហេតុផលថា ស្ថានទូតរបស់កម្ពុជានៅទីក្រុងប៉េកាំងបានតាមសង្កេតមើលដោយយកចិត្តទុកដាក់នូវការឡើងយកកិត្តិសព្ទនៃក្រុមឆ្វេងនិយមនៅប្រទេសចិននេះ* ។

៣៥ *F.B.I.S., "Trend in Communist Media", ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៨, pp. 10-11, លើកយកមកនិយាយជាសំអាងដោយលោក Ross, "China's Vietnam Policy", p. 286* ។

៣៦ *ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតម្នាក់នៃប្រទេសតតិយលោកមួយនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៨ នាទីក្រុងហាណូយ* ។

៣៧ *Laurence Picq, Au-delà du ciel, p. 52* ។

៣៨ *S.W.B., ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៨* ។

៣៩ S.W.B., ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៨ ។

៤០ F.B.I.S-A.P.A., ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៨, H-2 ។

៤១ S.W.B., ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

៤២ តាមក្រុមស៊ើបការណ៍សម្ងាត់លោកខាងលិចថា ការផ្គត់ផ្គង់កាំភ្លើងធំនិងអាវុធប្រឆាំងរថក្រោះរបស់ចិនបានចាប់ផ្តើមមកដល់ដែកម្ពុជានៅចុងខែមករា-ដើមខែកុម្ភៈ ។ សូមអានសៀវភៅរបស់លោក Evelyn Colbert, "Issues of Power, Balance and Security in Indochina", យោបល់នៅសន្និសីទស្តីពីសន្តិសុខនៅអាស៊ីនិងក្នុងមហាសាគរប៉ាស៊ីហ្វិក ដែលប្រព្រឹត្តទៅនៅ Palm Springs ៨-១០ ខែមករា ឆ្នាំ១៩៨២, p. 14 និងសៀវភៅ "ឥទ្ធិពលនៃជម្លោះចិន-សូវៀត", p. 11 របស់លោក Douglas Pick ។

៤៣ សុន្ទរកថារបស់លោក វ៉ា គូហ្វេង នៅក្នុងមហាសន្និបាតជាតិលើកទីV ដែលដកស្រង់មកនិយាយជាសំអាងដោយលោក Ross ក្នុងសៀវភៅ China's Vietnam Policy, ១៩៧៥-១៩៧៩, p. 290 ។

៤៤ Ben Kiernan, "Khmer Bodies with Vietnam Mind's: Kampuchea Eastern Zone, 1975-1978", p. 31 ។

៤៥ S.W.B., ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨ ។

៤៦ ការរៀបរាប់ពីព្រឹត្តិការណ៍ផ្សេងៗនៅភូមិភាគបូព៌ាគឺសំអាងលើការសន្ទនាជាមួយមនុស្សជាច្រើន នៅក្នុងខេត្តកំពង់ចាមនិងព្រៃវែង នាខែមីនា ឆ្នាំ១៩៨០ និងខែមករា ឆ្នាំ១៩៨១ ។

៤៧ ការសន្ទនារបស់អ្នកនិពន្ធ (ខែមករា ឆ្នាំ១៩៨១) ជាមួយមន្ត្រីវៀតណាមថ្នាក់ខ្ពស់ម្នាក់ ដែលដោយសារគាត់នេះហើយ ដែលខ្ញុំបានដឹងភាគច្រើននៃភាគល្អិតល្អន់ទាក់ទងទៅនឹងការរៀបចំប្រុងប្រៀបធ្វើអន្តរាគមន៍របស់វៀតណាមនៅប្រទេសកម្ពុជា ។ សម្រាប់ហេតុផលដែលឲ្យមន្ទិលសង្ស័យ មន្ត្រីរូបនេះត្រូវការរក្សាអនាមិកភាពរបស់ខ្លួនមិនឲ្យគេដឹងឡើយ ។

៤៨ ព័ត៌មានទាំងនេះដែលទាក់ទងនឹងជំរំហ្វឹកហ្វឺននានារបស់ចលនាតស៊ូកម្ពុជា គឺបានមកពីការធ្វើសម្ភាសន៍មន្ត្រីប្រមាណជាដប់ប្រាំនាក់នៃរបបលោក ហេង សំរិន នៅភ្នំពេញ កំពង់ចាម ស្វាយរៀង និង កំពង់ធំនៅខែមីនា ឆ្នាំ១៩៨០ ។

៤៩ ថ្ងៃខែឆ្នាំនៃការបង្កើតកងពលតូចដំបូងនេះ ត្រូវបាននិយាយឲ្យដឹងក្នុងឱកាសនៃការប្រារព្ធខួបកំណើតលើកទីបីរបស់កងពលតូចនេះនៅខែមេសា ឆ្នាំ១៩៨១, F.B.I.S-A.P.A., ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៨១, H-4 ។

៥០ Kissinger, The White House Years, p. 1414 ។

៥១ Richard Dudman, "កម្ពុជាទល់នឹងសត្វក្រពើ", Asian Wall Street Journal, ថ្ងៃ២៧ ខែធ្នូ ឆ្នាំ១៩៧៨ ។

៥២ F.B.I.S.-A.P.A., ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨, H-2 ។

## ជំពូកទី៨

១ S.W.B., ថ្ងៃ៣ ខែឧសភា ឆ្នាំ១៩៧៨ ។

២ Roland-Pierre Paringaux, កាសែតឡឺម៉ុង ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨ ។

៣ Tsai Maw-kuey, សៀវភៅ "ជនជាតិចិននៅវៀតណាមខាងត្បូង" (Les Chinois au Sud-Vietnam), Paris, បណ្ណាល័យជាតិ, 1968 pp. 23-29 ។ សូមអាននិក្ខេបបទរបស់លោក Michael Eiland ដែលជិតចេញផ្សាយផងដែរ(Cornell University) ស្តីពីទំនាក់ទំនងផ្សេងៗរវាងវៀតណាម-ថៃនៅសតវត្សរ៍ទី១៨ ។

៤ លើកយកមកនិយាយជាសំអាងដោយលោក Alexander Woodside, វៀតណាម និងគំរូរបស់ចិន Cambridge, Harvard University Press, 1971, p. 244 ។

៥ Fujiwara Riichiro, "Vietnamese Dynastie's Policies Toward Chinese Immigrants", Acta Asiatica, N°18, mars 1970, pp. 68-69 ។

៦ Hoa in Vietnam Dossier, Hanoi: Foreign Language Publishing House, 1978, p. 24 ។ មន្ត្រីម្នាក់នៃគណៈកម្មការសម្រាប់កិច្ចការជនជាតិចិននៅឯនាយសមុទ្រ បាននិយាយប្រាប់ខ្ញុំថា ការបកប្រែជាវៀតណាមនូវការព្រមព្រៀងដោយមាត់ទទេនេះ បានភ្លេចនិយាយពាក្យសំខាន់មួយ ៖ "ដោយស្ម័គ្រចិត្ត" ។ ដោយខ្ញុំសាកសួរពីរឿងនេះ Nguyen Trong Vinh, ឯកអគ្គរដ្ឋទូតរបស់វៀតណាមនៅក្រុងប៉េកាំងបានអះអាងនឹងខ្ញុំថា គឺប្រទេសចិនដែលជាអ្នកធ្វើឲ្យកិច្ចព្រមព្រៀងប្រែចាកពីសភាពដើម ។ សូមអានសៀវភៅរបស់លោក Nayan Chanda, "Southeast Asia Comes into Focus", ទស្សនាវដ្តី F.E.E.R. ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៨ ។

៧ Pao-min Chang, Beijing, Hanoi and the Overseas Chinese, Berkeley Institute of East Asian Studies, University of California, 1982, p. 11 ។

៨ ដកស្រង់មកនិយាយជាសំអាងដោយលោក Charles Benoit, ក្នុងសៀវភៅ"អ្នកកៀសខ្លួនតាមទូករបស់វៀតណាម", ក្នុងជម្លោះឥណ្ឌូចិនលើកទី៣, David W.P. Elliott éd. Boulder, Colo, Westview Press, 1981, p. 144 ។

៩ Gareth Porter, "Vietnam Policy and the Indochina Crisis" ក្នុងជម្លោះឥណ្ឌូចិនលើកទី៣, David W.P. Elliott, éd. Boulder, Colo, Westview Press, 1981, p. 74 ។

១០ សុន្ទរកថារបស់ To Huu នៅសាលាក្របខ័ណ្ឌកម្មាភិបាល Nguyen Ai Quoc, Giao Duc Ly Luan (traduit), J.P.R.S. Southeast Asia, ១ ខែមីនា ឆ្នាំ១៩៨៥ ។

១១ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Nguyen Trong Vinh, ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំក្រុងប៉េកាំង,

*ប៉េកាំង ខែមិថុនា ឆ្នាំ១៩៧៨ ។*

១២ *«សេចក្ដីរាយការណ៍សង្ខេបស្ដីពីការសន្ទនារបស់ឧបនាយករដ្ឋមន្ត្រី លី ស៊ាននាន ជាមួយ ផាំ វ៉ាន់ដុង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧», A.C.N., ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៩ ។*

១៣ *P.I., ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៨, p. 28 ។ Ibid. ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៨, p. 15 ។*

១៤ *ចំពោះសេចក្ដីរាយការណ៍មួយអំពីការពិបាកផ្នែកសេដ្ឋកិច្ចនៅប្រទេសវៀតណាមនាដើមឆ្នាំ១៩៧៨ សូមអានអត្ថបទរបស់លោក ណាយ៉ាន់ ចាន់ដា "Hanoi Takes the Campaign behind the Lines" ក្នុងទស្សនាវដ្ដី F.E.E.R. ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ និងអត្ថបទ "Hanoi Takes a Grip on the South", ក្នុងទស្សនាវដ្ដី F.E.E.R. ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៨ ។*

១៥ *F.B.I.S., ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨, E-11-21 ។*

១៦ *ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីវៀតណាមម្នាក់នៅទីក្រុងហូជីមិញ នាខែកក្កដា ឆ្នាំ១៩៧៩ ។*

១៧ *ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតវៀតណាមម្នាក់នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨ នាទីក្រុងវៀងច័ន្ទ ។*

១៨ *S.W.B., ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ ។*

១៩ *Nayan Chanda, "Peking Says It Out Loud to Hanoi", F.E.E.R., 12 mai 1978 ។*

២០ *អំពីប្រទេសវៀតណាមធ្វើការបណ្ដេញអាណិកជនចិនចេញ, ប៉េកាំង, អគារបោះពុម្ពផ្សាយសៀវភៅជាភាសាបរទេស, 1978, pp. 2-6 ។*

២១ *Benoit, ក្នុងជម្លោះឥណ្ឌូចិនលើកទី៣, p. 151 ។*

២២ *សម្រាប់ភាពជាក់ស្ដែងស្ដីពីការដកជំនួយរបស់ចិន សូមអានសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេសវៀតណាមចុះថ្ងៃទី១៧ ខែមិថុនា, S.W.B., ថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៧៨ ។*

២៣ *ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតវៀតណាមនៅទីក្រុងវៀងច័ន្ទនាថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨ ។*

២៤ *F.B.I.S.-A.P.N., ថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៨, K1-7 ។*

២៥ *S.W.B., ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៨ ។ ការស្រាវជ្រាវមួយរបស់សេ.អ៊ី.អា. បានវាយតម្លៃក្រោយមកថា ជនជាតិចិនប្រហែល២០០.០០០នាក់ បានត្រូវសម្លាប់នៅប្រទេសកម្ពុជាក្រោមរបប ប៉ុល ពត ។ A Demographic Catastrophe, Washington, D.C., C.I.A., 1980, p. 14 ។*

២៦ *S.W.B., ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៨ ។*

២៧ *Michael Godley, "A Summer Cruise to Nowhere: China and the Vietnamese Chinese in Perspective", The Australian Journal of Chinese affairs, N°4, July 1980, p. 41 ។*

២៨ Pao-Min Chang, Beijing, Hanoi and the Overseas Chinese, p. 40 ។

២៩ Benoit, op. cit., p. 153 ។

៣០ សេចក្ដីរាយការណ៍ល្អជាងគេអំពីប្រតិបត្តិការខាងហិរញ្ញវត្ថុគឺសេចក្ដីរាយការណ៍របស់លោក Barry Wain, The Refused: The Agony of Indochina Refugees, Hong-Kong, Dow Jones, 1981, pp. 85-106 ។

៣១ The Boat People: An «Age» Investigation, introduction de Bruce Grants, Victoria, Australia, Penguin, 1979, pp. 80-81 ។

៣២ Stephen Heder, ពី ប៉ុល ពត ទៅ ប៉ែន សុវណ្ណ, Bangkok, Chulalongkorn University, 1980, p. 16 ។

៣៣ តាមសាក្សីម្នាក់ដែលដកស្រង់សម្ដីមកនិយាយជាសំអាងដោយលោក Michael Vickery: សោ ភឹម ធ្លាប់បានប្រកាសថា គោលដៅនៃការធ្វើបដិវត្តន៍ គឺលើកកម្ពស់ជីវភាពរស់នៅ ពុំមែនធ្វើឲ្យថយឬបង្ខំឲ្យមនុស្សម្នាទៅរកភាពវេទនាតោកយ៉ាកក្នុងគោលបំណងតែមួយគត់ ដើម្បីធ្វើឲ្យអ្នកទាំងនោះស្គាល់ថា អ្វីទៅជាភាពក្រីក្រឡើយ (ដែលនេះជានយោបាយរបស់ ប៉ុល ពត) ។ Michael Vickery, Cambodia, 1975-1982, Boston, South End Press, 1984, p. 137 ។

៣៤ សម្រាប់ការវិភាគគួរឲ្យចាប់អារម្មណ៍មួយអំពីភាពទីទៃពីគ្នានៃភូមិភាគនៅប្រទេសកម្ពុជា សូមអានសៀវភៅ Cambodia របស់លោក Vickery ទំព័រ៦៥-១៨៨ ជាពិសេស ទំព័រ១៣១-១៣៨ ។ ចំពោះសក្ខីភាពមួយស្ដីពីដំណើររស់នៅក្នុងភូមិភាគបូព៌ា សូមអានសៀវភៅ «មាន់ព្រៃ...» pp. 136-196 របស់លោក Ben Kiernan ផង ។

៣៥ តាមប្រហែល ការប៉ុនប៉ងលួចសម្លាប់មួយក្នុងចំណោមការប៉ុនប៉ងលួចសម្លាប់ដំបូងៗទៅលើបុគ្គល ប៉ុល ពត គឺការប៉ុនប៉ងលួចសម្លាប់របស់ ចាន់ ចក្រី ជាអ្នកទទួលខុសត្រូវដ៏មានប្រជាប្រិយម្នាក់នៅភូមិភាគបូព៌ា ។ បន្ទាប់ពីបរាជ័យ គាត់ត្រូវបានចាប់ខ្លួននិងសម្លាប់នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ។ បញ្ជីឈ្មោះ ពួកមេដឹកនាំដែលត្រូវសម្លាប់គឺមាននៅក្នុង «ផែនការរួមចុងក្រោយ», សេចក្ដីរាយការណ៍ប្រតិចារកម្មរបស់ កម្ពុជាដែលរកឃើញជាថ្មីនៅមណ្ឌលសួរចម្លើយទួលស្លែង ។ ខ្ញុំសូមអរគុណលោក Murray Hiebert ដែល បានផ្ដល់អត្ថបទបកប្រែជាភាសាអង់គ្លេសមួយមកឲ្យខ្ញុំ ។

៣៦ Kiernan, « មាន់ព្រៃ...», p. 187 ។

៣៧ S.W.B., ថ្ងៃ១៥ ខែឧសភា ឆ្នាំ១៩៧៨ ។

៣៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយ Stephen Heder នៅទីក្រុងញូវយ៉កថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៨០ ។ Heder បានសំអាងលើការឆ្លើយសារភាពរបស់បណ្ដាសហការីខ្លះរបស់ សោ ភឹម មាន ភួង ជាដើម និងការ សន្ទនាជាមួយមេដឹកនាំខ្មែរក្រហមជាច្រើនរូបដែលស្គាល់គាត់ច្បាស់ ។

៣៩ សៀវភៅខ្មៅ, ទំព័រ១០១-១០៤ ។ ឯកសារខ្លះដែលរកឃើញក្រោយមកនៅក្នុងគុកទួលស្លែងបង្ហាញថារបប ប៉ុល ពត ជឿពីអត្ថិភាពនៃការរួមគំនិតក្បត់មិនពិតជាច្រើន ដែលពាក់ព័ន្ធមិនត្រឹមតែក្រុមស៊ើបការណ៍សម្ងាត់វៀតណាមប៉ុណ្ណោះទេ ប៉ុន្តែសហភាពសូវៀត អាល្លឺម៉ង់ខាងកើត សហរដ្ឋអាមេរិកនិងតៃវ៉ាន់ផងដែរ ។

៤០ ការរៀបរាប់អំពីការស្លាប់របស់ សោ ភឹម គឺសំអាងលើសៀវភៅរបស់ Kiernan, *op. cit.* ទំព័រ១៦៨-១៧២, លើការស្រាវជ្រាវរបស់ Heder និងលើការសន្ទនាផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយកម្មាភិបាល ជាច្រើនរូបរបស់ភូមិភាគបូព៌ា នៅកំពង់ចាម និងស្វាយរៀង នៅខែមីនា ឆ្នាំ១៩៨០ និងខែមករា ឆ្នាំ១៩៨១ ។ ចម្លើយជាសាក្សីទាំងអស់បាននិយាយត្រូវគ្នាអំពីការណ៍ថា សោ ភឹម បានធ្វើដំណើរទៅកាន់ ក្រុងភ្នំពេញ ប៉ុន្តែ ភាពខ្វែងគំនិតគ្នាខ្លះនៅតែមានអំពីទីកន្លែងដ៏ជាក់លាក់និងកាលៈទេសៈនៃការស្លាប់របស់គាត់ ។ អ្នកខ្លះអះអាងថា គាត់បានត្រូវសម្លាប់ដោយកងទ័ពរបស់ ប៉ុល ពត ប៉ុន្តែ គេទទួលស្របជាទូទៅថា គាត់ស្លាប់ដោយការធ្វើអត្តឃាដ ។

៤១ ការនិទានរបស់ Run Dun មេបញ្ជាការកងវរសេនាតូច, A.V.I., ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៨ ។

៤២ រូបមន្តនេះមានមកតាំងពីឆ្នាំ១៩៧១ នៅពេលដែលចាប់ផ្តើមការធ្វើវិសុទ្ធកម្មពួកកម្មាភិបាល ដែលត្រឡប់មកពីក្រុងហាណូយវិញជាសម្ងាត់ ។ ការសន្ទនារបស់ Heder ជាមួយលោក ហេង សំរិន នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨១ ។

៤៣ នៅខែមករា ឆ្នាំ១៩៧៩ នៅពេលដែលគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយត្រូវបង្កើតឡើង គឺក្នុងចំណោមសមាជិក២០រូប មាន១៦រូបជាអ្នកមានដើមកំណើតពីបណ្តាខេត្តរបស់កម្ពុជា ដែលមានព្រំដែនជាប់ជាមួយវៀតណាម ហើយក្នុងចំណោមខេត្តទាំងនេះភាគច្រើនគឺនៅភូមិភាគបូព៌ា ។

៤៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ហេង សំកៃ នៅស្វាយរៀងនាថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៨១ ។ ភាគល្អិតល្អន់នៃសម័យប្រជុំដែលនាំទៅលទ្ធផលចុងក្រោយនេះ ត្រូវបានផ្តល់មកឲ្យខ្ញុំដោយមន្ត្រីរបស់វៀតណាមថ្នាក់ខ្ពស់ម្នាក់ ។

៤៥ លើកយកមកនិយាយជាសំអាងដោយ *Branning Garrett, "The China Card" and Its origins: U.S. Bureaucratic Policies and the Strategic Triangle"*, និក្ខេបបទថ្នាក់បណ្ឌិត *Brandeis University, 1983, p. 132* ។

៤៦ ព័ត៌មានផ្សេងៗស្តីពីបណ្តាការជួបគ្នាជាសម្ងាត់រវាងវៀតណាមនិងសូវៀត ត្រូវបានផ្តល់មកឲ្យខ្ញុំដោយមន្ត្រីវៀតណាមថ្នាក់ខ្ពស់ម្នាក់នៅខែមករា ឆ្នាំ១៩៨១, "ដោយការគោរពចំពោះប្រវត្តិសាស្ត្រ" ហើយថ្វីដ្បិតតែការលាតត្រដាងទាំងនេះ ពុំឲ្យចំណេញដល់បុព្វហេតុរបស់ប្រទេសវៀតណាមថែមទាំងចំពោះ

អាជីពផ្ទាល់របស់គាត់ក៏ដោយ ។

៤៧ "Who is the Instigator?", R.R., បោះពុម្ពផ្សាយជាថ្មីក្នុង On Vietnam's Expulsion of Chinese Residents, Pékin, 1978, p. 131 ។

៤៨ S.W.B., ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៨ ។

៤៩ Michael Pillsbury, "Strategic Acupuncture", Foreign Policy, N°41, hiver 1980-81, p. 56. នៅឆ្នាំ១៩៧៥ Pillsbury ជាអ្នកឯកទេសទីមួយរបស់អាមេរិកាំងខាងវិស័យការពារប្រទេសដែលនិយាយណែនាំជាសាធារណៈពីការប្រគល់គ្រឿងសព្វាវុធឲ្យប្រទេសចិន ។ សូមអានសៀវភៅ : "U.S.-Chinese Military Ties?" របស់អ្នកនិពន្ធដដែល, Foreign Policy, automne 1975 ។

៥០ Michel Oksenberg, "មួយទសវត្សរ៍នៃទំនាក់ទំនងចិន-អាមេរិកាំង", foreign Affairs, automne 1982, p. 185 ។

៥១ Jiji Press, ទាញហេតុសំអាងពីប្រភពមួយនៅហុងកុង, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៧៨ ។ ដកស្រង់មកនិយាយជាសំអាងម្តងទៀតដោយលោក Masa hi Nishihara, "The Sino-Vietnamese War of 1979: Only the First Round?", អត្ថបទបានបោះពុម្ពផ្សាយ ។

៥២ ការសន្ទនារបស់អ្នកនិពន្ធជាមួយឥស្សរជនដ្ឋការរបស់ចិនម្នាក់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៨០ នាទីក្រុងហុងកុង ។ ចំពោះការវិភាគដ៏ល្អិតល្អន់មួយអំពីជំហររបស់ចិនចំពោះប្រទេសវៀតណាមនៅជំនាន់នោះ សូមអានសៀវភៅរបស់លោក Robert G. Sutter, "China's Strategy Towards Vietnam and Its Implications for the United States", David W.P. Elliott éd. The Third Indochina Conflict, Boulder, Colo, Westview Press, 1981, pp. 175-190 ។

៥៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកទទួលខុសត្រូវចិនម្នាក់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៩ នាទីក្រុងហុងកុង ។ ក្នុងសុន្ទរកថាមួយដែលមានលក្ខណៈនៅតែសម្ងាត់ ថ្លែងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៩ កេង ប៉ាវ សមាជិកការិយាល័យនយោបាយរបស់ចិន បាននិយាយអំពីការប្រឹងប្រែងរបស់ចិនដើម្បី "លើកសម្តេច សីហនុ ឲ្យសោយរាជ្យឡើងវិញ" ។ សូមអានសៀវភៅ "Keng Piao's របាយការណ៍អំពីស្ថានការណ៍ខបទ្វីបឥណ្ឌូចិន", Issues and Studies, Taipei, ខែមករា ឆ្នាំ១៩៨១, p. 83 ។

## ជំពូកទី៩

១ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រ៉ូបឺត អូកលី បច្ចុប្បន្នជារដ្ឋលេខាធិការទទួលបន្ទុកប្រឆាំងភេរវកម្ម, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៨៤, វ៉ាស៊ីនតោនឌី.ស៊ី. ។

២ ការសន្ទនារបស់អ្នកនិពន្ធជាមួយឥស្សរជនផ្លូវការឥណ្ឌាម្នាក់នៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៨ នាទីក្រុងហាណូយ ។

៣ សេចក្ដីចម្លងនៃសន្និសីទកាសែតដែលផ្ដល់ដោយ ផាន់ ហៀន នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៨ ។ ទូរលេខរបស់ក្រសួងការបរទេស មានប្រភពមកពីក្រុងតូក្យូ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៨ ។

៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក អាន់ទ្រូ ភីខូក នៅទីក្រុងកង់បែរ៉ា នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៨២ ។

៥ សេចក្ដីចម្លងមួយនៃការសន្ទនារវាងលោក ហ្សី.ភី.មីរថា និង ផាន់ ហៀន នេះត្រូវបានផ្ដល់ឲ្យខ្ញុំ ដោយអ្នកចូលរួមអាមេរិកាំងម្នាក់នៃបណ្ដាអ្នកចូលរួមរបស់អាមេរិកាំងក្នុងការជួបគ្នា ។

៦ *Congressional Record Times*, ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨ ។

៧ កាសែត *Los Angeles Times*, ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៨ ។

៨ *Daniel Southerland, "US Wary Over Vietnam's Overtures", Christian Science Monitor*, ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៧៨ ។

៩ *Zbignew Brzezinski, Power and Principle, p. 224* ។

១០ *Ibid., p. 562* ។

១១ *"Teng Hsiao-ping's speech on Foreign Policy at the Third Plenum, July 20 1977", Issue and Studies, Taipei, mai 1979, p. 55* ។

១២ *Jimmy Carter, Keeping Faith, Memoirs of a President, London, Collins, 1982, p. 189* ។

១៣ *Cyrus Vance, Hard Choice: Cristal Years in American Foreign Policy, New York, Simon and Schuster, 1983, p.81* ។

១៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ស៊ីរុស វ៉ាន់ស៍ នៅទីក្រុងញូវយ៉ក នាថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៨០ ។

១៥ *William Gleysteen* ដែលគេសង្ស័យបន្តិចបន្តួចពីការផ្គាប់ចិត្តលោក ប្រ៊ីហ្សីនស្គី យល់ឃើញថា ការលេចរឿងសម្ងាត់គឺជាផលនៃ "ការសប្បាយរីករាយខ្លាំងមួយដែលខុសកាលៈទេសៈជាដាច់គិតថា ជាការឃុបឃិតគ្នាដោយសម្ងាត់មួយសំដៅធ្វើឲ្យបរាជ័យ"ការប្រជុំចរចាដែលដឹកនាំធ្វើដោយ វ៉ាន់ស៍ ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក *William Gleysteen* នៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៨៥ ។

១៦ *Brzezinski, op. cit. p. 197* ។

១៧ *Ibid. p. 560* ។

១៨ Oksenberg, “មួយទសវត្សរ៍នៃទំនាក់ទំនងចិន-អាមេរិកាំង”, p. 183 ។

១៩ *Vance, op. cit., p. 116* ។

២០ *Jonathan D. Pollack, The Lessons of Coalition Politics: Sino-American Security Relations, Santa Monica, Rand, 1984, p. 29* ។

២១ *Brzezinski, op. cit., annexe 1, pp. 1-3* ។

២២ *Garrett, “The “China Card” and Its Origins”, p. 46* ។

២៣ ក្នុងឱកាសនៃការសន្ទនាមួយជាមួយអ្នកនិពន្ធ សមាជិកម្នាក់របស់គណៈប្រតិភូលោក ប្រ៊ីហ្សីនស្គី បាននិយាយប្រាប់ខ្ញុំដោយបដិសេធមិនផ្តល់ព័ត៌មានផ្សេងៗស្តីពីការសន្ទនាគ្នានោះថា ៖ “សេចក្តីសន្និដ្ឋានទាំងឡាយរបស់លោក មិនផ្ទុយនឹងអ្វីដែលខ្ញុំបានដឹងទេ” ។ តាម *Electronic Warfare/Defense Electronics*, ខែសីហា ឆ្នាំ១៩៧៨, p. 23-24 ថា ប្រ៊ីហ្សីនស្គី បានផ្តល់ទៅឲ្យពួកចិននូវ “ភ្នែកនិងត្រចៀករបស់លោកខាងលិច” ។ អត្ថបទបោះពុម្ពដដែលនេះ (ខែមករា ឆ្នាំ១៩៧៩) មានព័ត៌មានមួយដែលប្រហែលជាធ្វើឲ្យភ្ញាក់ផ្អើល យ៉ាងពិតប្រាកដ ៖ សហរដ្ឋអាមេរិកបានរៀបចំនិងដាក់ឲ្យដំណើរការនូវស្ថានីយសង្កេតពិនិត្យ (S.I.G.I.N.T.) ជាច្រើននៅតាមបណ្តោយព្រំដែនសូវៀត-ចិន ។ រឿងនេះត្រូវបានអះអាងបន្ថែមនៅឆ្នាំ១៩៨១ ។

២៤ ប្រ៊ីហ្សីនស្គី, *Power and Principle, p. 212* ។

២៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ស៊ីរុស វ៉ាន់ស៍ នៅទីក្រុងញូវយ៉ក នាថ្ងៃទី១៥ ខែសីហា ឆ្នាំ ១៩៨០ ។

២៦ *Vance, op. cit. p. 117* ។

២៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយអតីតសមាជិកម្នាក់នៃក្រុមប្រឹក្សាសន្តិសុខជាតិ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៨១ នាទីក្រុងហុងកុង ។

២៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Michel Oksenberg នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៨៣ នៅក្រុងហុងកុង ។

២៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Michel Oksenberg នៅទីក្រុងហុងកុង នាថ្ងៃទី៣ ខែមីនា ឆ្នាំ ១៩៨៣ ។

៣០ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Raphael Iungerich នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៨៤ នាទីក្រុង វ៉ាស៊ីនតោន ឌី.ស៊ី. ។

៣១ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Raphael Iungerich នៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. នាថ្ងៃទី២២ ខែធ្នូ

ឆ្នាំ១៩៨៤ ។

៣២ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក Andrew Peacock នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៨២ នាទីក្រុងកង់បែរ៉ា ។

៣៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ ហូលប្រ៊ុក, នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨៥ នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៣៤ Brzezinski, op. cit., p. 228 ។

៣៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ប៊ីកញូ ប្រ៊ីហ្សីនស្គី នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៨១ ។

៣៦ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ឡេអូណាដ់ វូដខូក នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៨៤ នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៣៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ ហូលប្រ៊ុក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨៥នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។ យោបល់ដែលថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិនគឺមិនត្រូវធ្វើស្រប គ្នាជាមួយការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម បានពើបប្រទះនឹងការប្រឆាំងយ៉ាងខ្លាំង ក្លាមួយពីសំណាក់បណ្តាមន្ត្រីខ្លះនៃក្រសួងការបរទេសអាមេរិកនៅទីក្រុងប៉េកាំង និងវ៉ាស៊ីនតោន ។ ការគិតមមៃអំពីប្រតិកម្មរបស់ប្រទេសចិន គឺច្រើនតែជាអំពើរបស់អ្នកទាំងឡាយ ដូចជាលោក អូសេនបឹក និង លោក រ៉ូហ្សេ ស៊ូលីវ៉ាន់ ជាដើម ដែលបំបាត់និងពន្លាត់សម្តីសន្ទនាតិចតួចរបស់ចិនរហូតដល់ធ្វើឲ្យ គាត់អះអាងថា ការខិតចូលជិតគ្នាជាមួយប្រទេសវៀតណាមធ្វើឲ្យរំខានដល់ការខិតចូលជិតគ្នាជាមួយ ប្រទេសចិន ។

៣៨ J. Carter, op. cit., p. 195 ។ ប្រាំពីរឆ្នាំក្រោយមក បន្ទាប់ពីទស្សនកិច្ចមួយនៅជំរំជនភៀសខ្លួនខ្មែរ តាមព្រំដែនកម្ពុជា-ថៃ ខាធ័រ បានប្រកាសប្រាប់អ្នកកាសែតថា ៖ “សហរដ្ឋអាមេរិកត្រូវតែថែរក្សាទំនាក់ទំនងផ្សេងៗជាមួយប្រទេសវៀតណាម ។ នេះជាបញ្ហាគ្រឹះមួយ ។ ទោះជាការខ្វែងគំនិតគ្នា ស្ថិតនៅមានក៏ដោយ ក៏វាមានប្រយោជន៍ជាង ដែលយើងនៅរក្សាការទាក់ទងគ្នា”, Philadelphia Inquirer, ៥ មិថុនា ឆ្នាំ១៩៨៥ ។

៣៩ ព័ត៌មានផ្តល់ដោយមន្ត្រីម្នាក់នៃក្រសួងការបរទេសអាមេរិកាំង ។ ការលាក់រឿងតូចតាចទាំងនេះរបស់សេតវិមាននៅតែជាបញ្ហារសើបមួយ ។ ប្រាំមួយឆ្នាំក្រោយមក មន្ត្រីរូបនេះបានទទូចថា កុំឲ្យរៀបរាប់ឈ្មោះរបស់គាត់បញ្ចូលទៅក្នុងអ្វីដែលទាក់ទងទៅនឹងសេចក្តីបង្គាប់បញ្ជាទាំងនោះរបស់សេតវិមាន ។

៤០ ការសន្ទនារបស់អ្នកនិពន្ធជាមួយ ផាំ ប៊ិញ (Pham Binh) ប្រធាននាយកដ្ឋានស្រាវជ្រាវអន្តរជាតិ នៃក្រសួងការបរទេសវៀតណាម នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៨១ នាទីក្រុងហាណូយ ។

៤១ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតឥណ្ឌាម្នាក់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៩ ។ តាំងពីដើមឆ្នាំ១៩៧៨ វៀតណាមបានប្រើកាន់តែច្រើនឡើងនូវខ្សែហោះហើរមួយរបស់ឥណ្ឌា ដើម្បីធ្វើដំណើរទៅកាន់ក្រុងមូស្គូ ។ សំណើសុំការអនុញ្ញាតធ្វើការហោះហើរ បានផ្ដល់ដល់ពួកឥណ្ឌានូវភ័ស្តុតាងដ៏មានតម្លៃមួយក្នុងការវិវត្តន៍នៃទំនាក់ទំនងជម្រុងៗរវាងសូវៀត-វៀតណាម ។

៤២ ក្រៅពីហេតុការណ៍ដែលថា គេរកយល់មិនឃើញថា ហេតុដូចម្ដេចបានជាសន្ធិសញ្ញាទ្វេភាគីមួយជាមួយប្រទេសតតិយលោកមួយ គួរតែមានឥទ្ធិពលទៅលើការសម្រេចចិត្តទទួលស្គាល់ប្រទេសវៀតណាមរបស់អាមេរិកាំងនោះ គេគ្រាន់តែកត់សម្គាល់ថា សន្ធិសញ្ញាសូវៀត-វៀតណាមត្រូវបានចុះហត្ថលេខានៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ការលុកលុយប្រទេសកម្ពុជាដោយវៀតណាមចាប់ផ្ដើមនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ គឺវាគ្រប់គ្រាន់ហើយ ។

៤៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ ហូលប្រ៊ូក នៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨៥ ។

៤៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រ៉ូបឺត អូកលី នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៨៤ នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៤៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ ហូលប្រ៊ូក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨៥នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៤៦ Rowland Evans and Robert Novak, "A Case of Soviet "Disinformation"", W.P., ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

## ខគ្គ"នរោត្តម សីហនុ : រួចផុតពីគ្រោះថ្នាក់"

១ S.W.B., ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ ។

## ជំពូកទី១០

១ ការសន្ទនារបស់អ្នកនិពន្ធជាមួយ :

- ឯកឧត្ដមឯកអគ្គរដ្ឋទូត ខាំផាន វីឡាជិត (Khamphan Vilachit) នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៨៣ នាទីក្រុងវៀងច័ន្ទ ។
- អ្នកការទូតឡាវបំពេញមុខងារនៅក្រុងភ្នំពេញម្នាក់ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៨៣ នាទីក្រុងវៀងច័ន្ទ ។

- ឥស្សរជនផ្លូវការរបស់យូហ្គោស្លាវីម្នាក់នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៩ ។
- វរសេនីយ៍ឯក ប៊ួយ ទិន (Bui Tin) នៅទីក្រុងហាណូយនាថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៨១ ។
- ពួកកម្មកររបស់ក្រុមហ៊ុនសុរាគារនៅភ្នំពេញថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៨១ ។
- សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨០ នាទីក្រុងប៉េកាំង ។ សូមអានសៀវភៅ "ការវិលត្រឡប់មកភ្នំពេញវិញ" របស់លោក អ៊ី ផាន់ដារ៉ា, *Métailié,* ១៩៨២, *pp. 183-186* ។

២ *N.D.,* ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧១ ។

៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតម៉ាឡេស៊ីម្នាក់នៅទីក្រុងហុងកុង នាថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៨ ។

៤ "*Vietnam-Economic Situation*", *Washington, D.C., World Bank, 1979, p. 3* ។

៥ ទស្សនកិច្ចនៅសហភាពសូវៀតរបស់គណៈប្រតិភូបក្សនិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម, មូស្គូ, ទីភ្នាក់ងារព័ត៌មានណូវូស្ទី *(Novosti), 1978, p. 17* ។

៦ *Ibid* ។

៧ *Gareth Porter, "Vietnam's Soviet Alliance: A Challenge to US Policy" Indochina Issues, N°6,* ខែឧសភា ១៩៨០, *p. 4* ។

៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកឯកទេសអាមេរិកាំងម្នាក់ នៅក្នុងរដ្ឋធានីអាស៊ីមួយ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨៣ ។ *Don Oberdorfer, "Reds vs. Reds In Indochina: A New, Confusing Kind of War", W.P.,* ថ្ងៃទី១ មេសា ឆ្នាំ១៩៧៩ ។

៩ សេចក្តីសង្ខេបនៃការសួរចម្លើយមួយ មានកាលបរិច្ឆេទថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨២ ត្រូវបានផ្តល់មកឲ្យខ្ញុំដោយអ្នកឯកទេសលោកខាងលិចម្នាក់ ដែលសំណូមពររក្សាអនាមិកភាព ។ ការយកចិត្តទុកដាក់របស់ខ្ញុំទៅលើតួនាទីរបស់ *Wei* នៅប្រទេសវៀតណាមត្រូវបានទាក់ទាញចិត្តដោយនាយទាហានចិនម្នាក់ក្នុងការសន្ទនាមួយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧៩ ។

១០ ទស្សនាវដ្តី *F.E.E.R.,* ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

១១ ការសន្ទនារបស់ *Michael Chinoy* ជាមួយឥស្សរជនផ្លូវការថ្នាក់លើម្នាក់នៅទីក្រុងបាងកក នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ខ្ញុំសូមអគុណលោក *Chinoy* ដែលបញ្ជូនមកឲ្យខ្ញុំនូវកំណត់ខ្លីៗរបស់លោក ។ គេងបានរំពឹកជាសាធារណៈផងដែរ ពីយថាភាពមួយនៃការដួលរលំរបស់ក្រុងភ្នំពេញ ទោះបីជាគាត់ប្រហែលមិនចង់ថាដូច្នេះក៏ដោយ ។ មុនទស្សនកិច្ចរបស់គាត់ទៅកាន់ប្រទេសថៃ គាត់បានប្រកាសប្រាប់អ្នកកាសែត ថៃមួយក្រុមថា : "បើសិនជាការប៉ាន់ស្មានទុកជាមុនរបស់ខ្ញុំត្រឹមត្រូវ ប្រទេសកម្ពុជានឹងត្រូវ

បំផ្លាញឲ្យសាបសូន្យទាំងស្រុង ។ ប្រការនេះនឹងបង្ហាញឲ្យពិភពលោកឃើញពីសារជាតិពិតប្រាកដនៃរបបរបស់វៀតណាម ។ នៅពេលនោះ វានឹងជាឱកាសសម្រាប់អាស៊ានដែលត្រូវសម្តែងតួនាទីដ៏សំខាន់មួយក្នុងការដោះស្រាយបញ្ហាហើយ» ។ *Nayan Chanda, “Cambodia: Waiting for the Inevitable”,* ទស្សនាវដ្តី *F.E.E.R.,* ថ្ងៃ២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

១២ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីម្នាក់នៃក្រសួងការបរទេសថៃ ដែលបានចូលរួមយ៉ាងជិតស្និទ្ធក្នុងការសន្ទនាវាងក្រៀងសាក់-គេង ។ ការសន្ទនារបស់ខ្ញុំគឺមានឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៨១ នាទីក្រុងហុងកុង ។

១៣ *Chanda, “Cambodia: Waiting for the Inevitable”* ។

១៤ តាមឯកសារសម្ងាត់មួយរបស់ចិនថា រដ្ឋាភិបាលកម្ពុជាបានបញ្ចេញឲ្យដឹងសំណើនេះ ។ សូមអាន *“Keng Piao’ s Report on the situation of the Indochinese Peninsula”, Issues and Studies, Tapei, January 1981, p. 85* ។ ការអះអាងបន្ថែមពីរឿងនេះត្រូវបានបង្ហាញក្នុងសៀវភៅ “ឆ្លាយហួសដើងមេឃ...” ទំព័រ១៤១ របស់អ្នកស្រី ឡូរ៉ង់ ពិច ។

១៥ *Jurgen Domes, The Government and Politics of the P.R.C.: A time of Transition, Boulder, Colo. Westview Press, p. 163* ។

១៦ *Parris Chang, Elite Conflict in the Post Mao China, Baltimore, University of Maryland, Occasional Papers/Reprint Series in Contemporary Asian Studies, N°2, 1983, pp. 10-11* ។

១៧ *King C. Chen, Politics and Process of Peiping’s Decision to Attack Vietnam, Taipei, Institute of Internation Relations, 1983, p. 81.* សូមអានសៀវភៅ *“Keng-Piao’s Report on the Situation of the Indochinese Peninsula”, pp. 85-86* ។

១៨ *“Keng Piao’s Report”, op. cit., pp. 88-89* ។

១៩ *Chen, Politics and Process, pp. 86-87* ។

២០ *Oksenberg, “A Decade of Sino-American Relation”, p. 187.*

២១ *Ibid* ។

២២ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោកឯកអគ្គរដ្ឋទូត ឡេអូណាដ៍ វូដខូក នៅទីក្រុងហុងកុង នាថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨០ ។

២៣ *Carter, Keeping faith, pp. 198-199* ។

២៤ *Ibid., p. 197* ។

២៥ Vance, Hard Choices, p. 118-119 ។

២៦ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោកឯកអគ្គរដ្ឋទូត ឡេអូណាដ៍ វូដខូក នៅទីក្រុងហុងកុង ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨០ និងនៅទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៨៤ ។

២៧ ការមិនទុកចិត្តគេឯង ឬការភាន់ច្រឡំនៃក្រុមភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់វៀតណាមហាក់ ដូចជាបាន ប្រមាណហួសពីវត្តមានរបស់ជនជាតិចិននៅប្រទេសកម្ពុជា ។ ភាគច្រើននៃអ្នកឯកទេសដែលទទួលបាន ព័ត៌មានត្រឹមត្រូវគិតថា ចំនួនពិតប្រាកដមានមិនលើសពី៥.០០០នាក់ឡើយ ។ ក្រោយមក វរសេនីយ៍ ឯកម្នាក់នៃកងទ័ពរបស់វៀតណាម បានអះអាងប្រាប់ខ្ញុំថា ឈរលើមូលដ្ឋាននៃអ្វីដែលគាត់សង្កេតឃើញ នៅភ្នំពេញ ទីប្រឹក្សាចិនគឺមានចំនួន៨.០០០នាក់ ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយវរសេនីយ៍ឯក ប៊ួយ ទិន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៨១នាទីក្រុងហាណូយ ។

២៨ Daniel Burstein, "On Cambodia: But, Yet", N.Y.T., ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

២៩ B.P., ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ ។

៣០ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ឆាតឆៃ ឈុនហាវ៉ាន (Chatchai Choonhavan), ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៨៤ នាទីក្រុងបាងកក ។

៣១ S.W.B., ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៨ ។

៣២ ការសន្ទនារបស់អ្នកនិពន្ធជាមួយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៨២ នៅទីក្រុងកង់បែរ៉ា ។

៣៣ ចម្លើយជាសាក្សីរបស់ ឌិញ កាន ស្តីពីសម័យប្រជុំដែលបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានទទួលដោយមន្ត្រីអូស្ត្រាលីម្នាក់ នាខែវិច្ឆិកា ឆ្នាំ១៩៧៩ ក្រោយពេលដែល កាន ភៀសខ្លួនទៅ ប្រទេសម៉ាឡេស៊ី ។ ខ្ញុំសូមអគុណមន្ត្រីរូបនេះ ដែលបានបញ្ជូនមកឲ្យខ្ញុំនូវកំណត់ខ្លីៗរបស់គាត់ ។ ភាគច្រើន នៃការនិយាយប្រាប់រឿងអាថ៌កំបាំងរបស់ កាន បានត្រូវអះអាងបន្ថែមប្រាប់ខ្ញុំដោយកម្មាភិបាលខ្មែរ ជាច្រើនរូបដែលបានចូលរួមក្នុងការប្រជុំនេះ ។

៣៤ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា, ក្រុមព័ត៌មាននៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា, ឆ្នាំ១៩៧៩, 31ff., ទីកន្លែងបោះពុម្ពផ្សាយពុំមានបញ្ជាក់ ។

៣៥ រណសិរ្សឯកភាពឥស្សរៈត្រូវបានបង្កើតឡើងបន្ទាប់ពីមហាសន្និបាតជាតិទី១របស់ចលនាតស៊ូខ្មែរថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៥០ ។ នៅឆ្នាំ១៩៥២ ឯកសារខ្មែរមួយបានសន្មតជោគជ័យរបស់ចលនាតស៊ូថា មកពីឥទ្ធិពលនិងការគាំទ្ររបស់ប្រជាជនវៀតណាម ។

៣៦ Timothy Carney, "Heng Samrin's Armed forces and a Military Balance in Cambodia" ។ ការបញ្ជូន

ព័ត៌មានផ្ទាល់ឲ្យសន្និសីទនៅ Princeton ស្ដីពីកម្ពុជា, ថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ១៩៨២, p. 4 ។

៣៧ សមាជិកដប់បួនរូបនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាគឺ ហេង សំរិន (អតីតខ្មែរក្រហម ឬខ្មែរក្រហម), ជា ស៊ីម (ខ្មែរក្រហម), រស់ សម័យ (ខ្មែរឥស្សរៈ), ម៉ាត់ លី (ខ្មែរក្រហម), ប៊ុន មី (ខ្មែរក្រហម), ហ៊ុន សែន (ខ្មែរក្រហម), លោកស្រី មាន សំអាន (ខ្មែរក្រហម), មាស សំណាង (ខ្មែរក្រហម), នៅ សាម៉ុន (ខ្មែរឥស្សរៈ), ម៉ុង ឡុងស៊ីម, ហែម សាមិន (ខ្មែរឥស្សរៈ), លោកស្រី ជ័យ កញ្ញា, ចាន់ វ៉ែន និង ប្រាជ្ញ ស៊ុន ។

៣៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយឥស្សរជនផ្នែកការវៀតណាមម្នាក់, ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៨១ នៅទីក្រុងហាណូយ ។

៣៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយវរសេនីយ៍ឯក ប៊ួយ ទិន, ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៨១ នៅទីក្រុងហាណូយ ។

៤០ ការសន្ទនារបស់អ្នកនិពន្ធជាមួយសម្ដេច ព្រះនរោត្តម សីហនុ នៅទីក្រុងប៉េកាំង នាថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨០ ។

៤១ សៀវភៅ "ការត្រឡប់មកភ្នំពេញវិញ" របស់លោក អ៊ី ផាន់ដារា, ទំព័រ១៨០ ។

៤២ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក Ben Kiernan, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨២, ក្រុងម៉ែលប៊ន ។

៤៣ *Van Tien Dung, Our Great Spring Victory, New York, Monthly Review Press, 1977,* ការបោះផ្សាយជាភាសាបារាំងដោយលោក *Camille Scalabrino* និង *Nguyen Ngoc Giao, Et nous primes Saigon* ។ *Le Sycomore, 1979. Tran Van Tra, Vietnam: history of the Bulwark B-2 Theatre, Vol.5. Concluding the 30 Years War, Washington, D.C., Joint Publication Research Service, 1983* ។ អត្ថបទស្រង់ជាភាសាបារាំងមួយដែលបកប្រែដោយលោក *Georges Boudarel* គឺមាននៅក្នុងសៀវភៅ "ការិយាធិបតេយ្យនៅប្រទេសវៀតណាម" (ការិយាល័យនៅវៀតណាម), *Asie-Débat 1, L' Harmattan, 1983* ។

៤៤ *Dung, op. cit., p. 25* ។

៤៥ ការសន្ទនារបស់លោក *Stephen Heder* ជាមួយលោក ជា សុទ្ធ នៅក្រុងភ្នំពេញ នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៨១ (សេចក្ដីចម្លង) ។

៤៦ ការសន្ទនារបស់លោក *Stephen Heder* ជាមួយលោក ហែម សាមិន, ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨១ នៅទីក្រុងភ្នំពេញ(សេចក្ដីចម្លង) ។

៤៧ *Stephen Heder,* អត្ថបទមិនទាន់បោះពុម្ពផ្សាយ ។ តាម *Heder* ថា មហាសន្និបាតបានជ្រើសតាំងគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានសមាជិកប្រាំពីររូបដឹកនាំដោយ ប៉ែន សុវណ្ណ ។ សមាជិកដទៃទៀតគឺ ហ៊ុន

សែន, ប៊ូ ថង, ចាន់ គីរី, វ៉ាន់ សុន, ហេង សំរិន, និង ជា សុទ្ធ ។ ក្នុងចំណោមនោះ មានសមាជិកតែពីររូបប៉ុណ្ណោះ ហ៊ុន សែន និង ហេង សំរិន-ដែលជាអតីតខ្មែរក្រហម ចំណែកសមាជិកដទៃទៀតសុទ្ធតែខ្មែរឥស្សរៈ ។

៤៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកឯកទេសម្នាក់ខាងបញ្ហាឧបទ្វីបឥណ្ឌូចិន នៅស្ថានទូតអាមេរិកាំងប្រចាំក្រុងបាងកក នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៨៣ ។

៤៩ សេចក្តីដកស្រង់នៃកំណត់ហេតុនេះ មាននៅក្នុង "Record of a conversation between Deng Xiaoping and Ieng Sary, le 13 Janvier", C.V., octobre 1979 ។ សន្លាត់អត្ថបទម្តុំៗដែលខ្វះត្រូវបានបោះពុម្ពផ្សាយនៅពេលក្រោយក្នុង The Chinese Ruler's Crimes Against Kampuchea, 1984 ។ ភ័ស្តុតាងសម្បូរពោរពាសមាននៅក្នុងអត្ថបទដើមនៃការសន្ទនាគ្នាទាំងស្រុង ។ ម្យ៉ាងទៀត លក្ខណៈពិតនៃកំណត់ហេតុនេះ មិនដែលត្រូវជំទាស់ដោយក្រុងប៉េកាំងសោះឡើយ ។

៥០ The Chinese Ruler's Crimes Against Kampuchea, p. 111 ។

៥១ អត្ថបទដកស្រង់នៃសម័យប្រជុំនេះគឺមាននៅក្នុងសៀវភៅ The Chinese Ruler's Crimes Against Kampuchea, p. 112 ។

៥២ Ibid ។

៥៣ Don Oberdorfer, "Reds vs. Reds", W.P., ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៩ ។

៥៤ Newsweek, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៩ ។

៥៥ Brzezinski, Power and Principle, p. 409 ។

៥៦ U.S. State Department Bulletin, កុម្ភៈ ឆ្នាំ១៩៧៩, pp. 7-11 ។

៥៧ Brzezinski, op. cit., p. 409 ។

៥៨ Zbigniew Brzezinski, "East Asia and Global Security: Implications for Japan" The Journal of International Affairs, Vol. 37, N°1, été 1983, p. 8 ។

៥៩ លោក ខាធ័រ និយាយថា ទស្សនកិច្ចរបស់ តេង បានរួមបង្កជា "ឱកាសដែលនាំឲ្យរីករាយបំផុតមួយក្នុងចំណោមឱកាសដែលនាំឲ្យរីករាយបំផុតនៃអាណត្តិជាប្រធានាធិបតីរបស់ខ្ញុំ ។ ខ្ញុំរីករាយខ្លាំងណាស់ ហើយមេដឹកនាំចិនក៏ដូច្នេះដែរ" Keeping faith, p. 202 ។

៦០ Brzezinski, Power and Principle, p. 408 ។

៦១ Vance, Hard Choices, p. 122 ។

៦២ Brzezinski, Power and Principle, p. 408.នៅថ្ងៃទី២ ខែកុម្ភៈ វ៉ាន់ស៍ បានដាក់ឲ្យ ខាធ័រ ពិនិត្យសេចក្តីថ្លែង

ការណ៍មួយដែលត្រូវផ្សាយនៅក្នុងរយៈពេលនៃទស្សនកិច្ចរបស់ តេង ។ តាមសេចក្ដីថ្លែងការណ៍នោះថា ទំនាក់ទំនងរវាងចិន-អាមេរិកាំងគឺជាលក្ខខណ្ឌដ៏សំខាន់នៃសន្តិភាពយូរអង្វែងមួយ ដូចការធ្វើឲ្យកាន់តែប្រសើរជាងមុននូវទំនាក់ទំនងផ្សេងៗជាមួយសហភាពសូវៀតដែរ ។ មុននឹងអានសេចក្ដីថ្លែងការណ៍ខាងរ បានសួរទាំងថា "មានការសុំទោសថែមទៀតដែរឬ?" ។ ប្រ៊ីហ្សីនស្គី បានបញ្ចុះបញ្ចូលគាត់ថា ប្រភេទនៃសេចក្ដីថ្លែងការណ៍នេះ បានផ្ដល់ឲ្យសហរដ្ឋអាមេរិកនូវរូបភាពមិនដាច់ស្រេច និងមិនប្រាកដមួយ ។ សម្រេចសម្រួចទៅ គឺពុំមានសេចក្ដីថ្លែងការណ៍ណាមួយឡើយ ។

៦៣ *Carter, op. cit., p. 209* ។

៦៤ *Brzezinski, Power and Principle, p. 412.* មុនពេលមានការវាយលុករបស់ចិន ឯកអគ្គរដ្ឋទូតអាមេរិកាំងនៅក្រុងមូស្គូ *Malcolm Toon* បានឲ្យលោក ហ្គ្រូមីកូ ដឹងពីសេចក្ដីសង្ឃឹមរបស់គាត់អំពីការមិនប្រព្រឹត្តអ្វីឲ្យហួសហេតុរបស់សូវៀត នៅពេលដែលការវាយលុកនេះកើតមាន ។ *Christian Science Monitor,* ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៩ ។

៦៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ឡេអូណាដ់ វូដខូក, ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨០ នៅក្រុងហុងកុង ។

៦៦ *P.I.,* ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៩, *pp. 13-14* ។

៦៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេសជប៉ុន, ថ្ងៃទី៣១ ខែឧសភា នៅទីក្រុងតូក្យូ ។

៦៨ ក្នុងឱកាសនៃការប្រជុំដោយឡែកមួយជាមួយលោក ហួង ហួ លោក ស៊ូណាអូ សូណូដា រដ្ឋមន្ត្រីការបរទេសជប៉ុន បានប្រកាសប្រាប់គាត់ថា ៖ "ប្រទេសចិនមិនត្រូវពឹងលើការប្រើកម្លាំងក្នុងជម្លោះព្រំដែនរបស់ខ្លួនជាមួយប្រទេសវៀតណាមឡើយ...។ ក្នុងនាមនៃប្រទេសយើង ប្រទេសចិនត្រូវតែធ្វើអ្វីមួយ ដោយប្រយ័ត្នប្រយែង" ។ កាសែត *Mainichi Daily News,* ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ ។

៦៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកទទួលខុសត្រូវចិនម្នាក់នៅទីក្រុងហុងកុង នាថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៩ ។

៧០ *Brzezinski, Power and Principle, p. 140.* ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេសជប៉ុននៅទីក្រុងតូក្យូ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៨៣ ។

៧១ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតបារាំងម្នាក់នៅទីក្រុងប៉ារីស, ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៨៥ ។

៧២ នៅពេលដឹងពីការវាយប្រហាររបស់ចិន វ៉ាជ៉ាយី (នាយករដ្ឋមន្ត្រីឥណ្ឌា) បានបំព្រួញដំណើរទស្សនកិច្ចរបស់គាត់ហើយត្រឡប់មកប្រទេសឥណ្ឌាវិញ ។ ផាំ វ៉ាន់ដុង បានបន្តដំណើរទស្សនកិច្ចរបស់គាត់ ។

៧៣ *N.Y.T.,* ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៩ ។

៧៤ *Time,* ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៩ ។

៧៥ Daniel Tretiak, "China's Vietnam War and Its Consequences", ការបញ្ជូនព័ត៌មានទៅកាន់សិក្ខាសាលាមួយស្តីពីប្រទេសចិន, សាកលវិទ្យាល័យរបស់ចិននៅហុងកុង, ថ្ងៃទី៥-៧ ខែធ្នូ ឆ្នាំ១៩៧៩, p.7 ។

៧៦ Garrett, "The "China Card" and "Its Origins"", p. 156 ។

៧៧ Brzezinski, Power and Principle, p. 414 ។

៧៨ ក្នុងព័ត៌មានមួយមានចំណងជើងថា "Major Power Interest in the Asia Pacific Region" នៅក្នុងការប្រជុំសន្ទនារវាងអ្នកនយោបាយឥណ្ឌូចិន-អូស្ត្រាលី ដែលប្រព្រឹត្តទៅនៅកោះបាលី នាថ្ងៃទី៥-៨ ខែធ្នូ ឆ្នាំ១៩៨២-ការផ្សាយជាសាធារណៈតែមួយគត់ដែលនិយាយពីជំនួយសម្ងាត់នេះ-T.B. Miller បានលើកយកមកនិយាយពី"ជំនួយបច្ចេកទេសដែលប្រហែលជាផ្តល់ឲ្យដោយសហរដ្ឋអាមេរិកក្រោមទម្រង់ជារូបថតផ្សេងៗដែលថតបានដោយផ្កាយរណប" ។ សាស្ត្រាចារ្យ Miller នាយកមជ្ឈមណ្ឌលនៃការស្រាវជ្រាវផ្នែកយុទ្ធសាស្ត្រនិងការពាររបស់អូស្ត្រាលី បានសម្រេចយកបានព័ត៌មានសម្ងាត់ជាច្រើន ។ គាត់បានថ្លែងប្រាប់ខ្ញុំ (នៅទីក្រុងកង់បែរ៉ា នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៨២) ថា តាម"ប្រភពព័ត៌មានផ្សេងៗ ដែលមិនអាចបដិសេធបាន"ថា សហរដ្ឋអាមេរិកបានផ្តល់ទៅឲ្យពួកចិននូវព័ត៌មានជាច្រើនទាក់ទងទៅនឹងការធ្វើចលនារបស់កងទ័ពសូវៀត ។

៧៩ Li Man Kin, Sino Vietnamese War, Hong Kong, Kingsway International Publications, 1981, p. 61 ។

៨០ Ibid, 60 ។

៨១ ការវាយតម្លៃរបស់ចិន ។ គ្មានតួលេខណាមួយត្រូវបានផ្តល់ឲ្យដោយវៀតណាមឡើយ ។ F.B.I.S.-A.P.A., ថ្ងៃទី២២ មីនា ឆ្នាំ១៩៧៩, L1 ។

៨២ ចំពោះការវិភាគអំពីតម្លៃដែលប្រទេសចិនត្រូវបង់ទៅលើផែនការក្នុងប្រទេសសូមអានសៀវភៅរបស់លោក Daniel Tretiak, op. cit. ។ អ្នករត់ចូលខាងសត្រូវម្នាក់ដែលមានឋានៈខ្ពស់នៃកងទ័ពប្រជាជនរំដោះបានប្រកាសក្រោយមកចំពោះអ្នកទទួលខុសត្រូវម្នាក់នៃក្រុមស៊ើបការណ៍សម្ងាត់បស្ចិមប្រទេសថា : "ការធ្វើប្រតិបត្តិការប្រឆាំងវៀតណាមបានបណ្តាលឲ្យមានមហន្តរាយយ៉ាងធំ" ។ ក្នុងចំណោមកងទ័ព ៣០០នាក់នៃកងវរសេនាតូចរបស់គាត់មាន៤៥នាក់ត្រូវស្លាប់និងរបួស៩៥នាក់ គឺការបាត់បង់មានប្រហែលជិត៥០ភាគរយ ។

## ជំពូកទី១១

១ កាសែត Le Matin, ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៩ ។

២ Elizabeth Becker, "Sihanouk Center Stage", W.P., ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៩ ។

៣ កាសែត N.Y.T., ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៩ ។

៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយ រ៉ូហ្សេ ស៊ូលីវ៉ាន់ , ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៥ នៅក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៥ ក្នុងសៀវភៅ "អ្នកទោសខ្មែរក្រហម", ទំព័រ៣៦៥ សម្តេច សីហនុ បានអះអាងថា : "នៅចំពោះមុខភាពស្ងៀមស្ងាត់ [របស់ វ៉ាន់ស៍] នេះ មហេសីខ្ញុំ បានផ្តល់យោបល់ឲ្យខ្ញុំធ្វើការទាក់ទងជាមួយប្រទេសបារាំងកុំបង្អង់ ដើម្បីសុំឲ្យប្រទេសបារាំងយល់ព្រមផ្តល់នូវសិទ្ធិជ្រកកោនខាងនយោបាយដល់យើង ព្រោះថា សហរដ្ឋអាមេរិកហាក់ដូចជាបដិសេធសំណើរបស់យើងទៅហើយ" ។

៦ ការបរិយាយពីការជួបគ្នាតាមការណាត់របស់សម្តេច សីហនុ ជាមួយ គេង ស៊ាវពីង គឺសំអាងលើការជួបសន្ទនាពីរលើកជាមួយសម្តេចនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៩ នាទីក្រុងប៉េកាំង និងខែសីហា ឆ្នាំ១៩៧៩ (ការសន្ទនាតាមទូរស័ព្ទពីទីក្រុងព្យុងយ៉ាង) ។

៧ Nayan Chanda, "The Ballot-box Response", F.E.E.R., ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៨១ ។

៨ ៨០ភាគរយនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជាសុទ្ធតែជាអតីតយុទ្ធជន ក្នុងការប្រយុទ្ធប្រឆាំង-បារាំង (ខ្មែរឥស្សរៈ) និងធ្លាប់ធ្វើសម្ពន្ធមិត្រជាមួយវៀតណាម ហើយ២០ភាគរយជាអតីតខ្មែរក្រហម ។ Stephen Heder, ព័ត៌មានដែលមានចំណងជើងថា "The Elite of the People Republic of Kampuchea" នៅ Cornell University, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៨១ ។ Heder បានសង្កត់បញ្ជាក់ថា ៨០ភាគរយនៃសមាជិកគណៈកម្មាធិការមជ្ឈិមមានដើមកំណើតពីខេត្តនានាដែលមានព្រំដែនជាប់នឹងវៀតណាម ហើយថា ៦០ភាគរយធ្លាប់រស់នៅ២០ឆ្នាំឬលើសពីនេះ នៅប្រទេសវៀតណាម ។

៩ Timothy Cerney, "Kampuchea in 1982: Political and Military Escalation", Asian Survey, មករា ឆ្នាំ១៩៨៣, p. 82 ។

១០ Ibid., p. 79 ។

១១ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតម្នាក់នៃប្រទេសសង្គមនិយមមួយ, ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៨០ នៅទីក្រុងភ្នំពេញ ។ សូមអានអត្ថបទរបស់លោក John McBeth, "Bureaucrats from B68"ចុះផ្សាយក្នុងទស្សនាវដ្តី F.E.E.R. ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៨២ផង ។

១២ Ibid., p. 82 ។

១៣ F.B.I.S.-A.P.A., ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៨៥ , K-6 ។

១៤ Paul Quinn-Judge, "View From the Front", ទស្សនាវដ្តី F.E.E.R, ថ្ងៃ៩ ខែមេសា ឆ្នាំ១៩៨២ ។

១៥ Nayan Chanda, "Making of a Bloc", ទស្សនាវដ្តី F.E.E.R., ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨០ ។

១៦ វ៉ី វ៉ាន់គៀត, នៅសន្និសីទលើកទីមួយនៃការរៀបចំធ្វើផែនការសម្រាប់ឥណ្ឌូចិន នៅខែកុម្ភៈ ឆ្នាំ១៩៨៤ ដែលរៀបរាប់បញ្ចូលអត្ថបទមួយគ្មានចុះហត្ថលេខា : "The Vietnamisation of Kampuchea: A New Model of Colonialism", Indochina Report, ខែតុលា ឆ្នាំ១៩៨៤, ប្រទេសសិង្ហបុរី ។

១៧ ផ្ទៃដីកសិកម្មដែលប្រើប្រាស់នៅប្រទេសវៀតណាមអាចឡើងពី ០,០៩ហិកតា នៅឆ្នាំ១៩៨៥ ដល់ ០,១៣ហិកតាសម្រាប់ប្រជាជនម្នាក់ៗនៅឆ្នាំ២០០០ លុះណាតែត្រូវបង្កើនផ្ទៃដីកសិកម្មដែលប្រើប្រាស់នេះ៨៥ភាគរយ និងដំឡើងវាឲ្យដល់១០លានហិកតា ។ នៅពេលនេះ ប្រជាជនវៀតណាមប្រហែលជាឡើងដល់៧៥លាននាក់យ៉ាងទាបបំផុត ។ Stewart E. Fraser, "Vietnam Struggles with Exploding Population", Indochina Issues, N°57, ខែឧសភា ឆ្នាំ១៩៨៥, p. 5 ។

១៨ F.B.I.S-A.P.A., ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៨៣, p. I.6 ។

១៩ កាថ្លែងរបស់អ្នកទទួលខុសត្រូវជាន់ខ្ពស់វៀតណាមម្នាក់ចំពោះលោក W.S.Turley ក្នុងឱកាសនៃការសន្ទនាមួយនៅទីក្រុងហាណូយ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៨៣ ។ ព័ត៌មានផ្ទាល់ខ្លួនរបស់លោក Turley ។

២០ Policy of the People's Republic of the Kampuchea with Regard to Vietnamese Residents, ភ្នំពេញ ខែកញ្ញា ឆ្នាំ១៩៨៣, p. 12 ។ នៅខែមិថុនា ឆ្នាំ១៩៨៣ ង្វៀន កូថាច់ រដ្ឋមន្ត្រីការបរទេសវៀតណាម បានប្រកាសប្រាប់សមភាគីអូស្ត្រាលី ប៊ីល ហៃដេន ថា និគមជនវៀតណាមនៅប្រទេសកម្ពុជាមានមិនលើសពី៥០០.០០០នាក់ទេ ដោយបញ្ជាក់ថា បន្ទាប់ពីការស្លាប់របស់វៀតណាមដែលមានដើមកំណើតនៅទីនោះ សព្វថ្ងៃនេះមានមិត្តភក្តិប្អូនប្អូនសាច់ញាតិខ្លះរបស់ពួកគេបានចូលទៅតាំងនៅជំនួស ។ ការសន្ទនារបស់អ្នក និពន្ធជាមួយលោក ប៊ីល ហៃដេន (Bill Hayden) នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៣ នាទីក្រុងហុងកុង ។

២១ Fraser, op. cit., 6 ។

២២ Marie-Alexandrine Martin, "នីតិក្រមវៀតណាមូបនីយកម្មនៅកម្ពុជា", នយោបាយអន្តរជាតិ, និទាឃរដូវ ឆ្នាំ១៩៨៤, p. 184 ។

២៣ នៅឆ្នាំ១៩៨១ សារាចរមួយរបស់ក្រសួងការបរទេស បានហាមមិនឲ្យអ្នកទទួលខុសត្រូវ អាមេរិកាំងចាប់ដៃនឹងខ្មែរក្រហមឡើយ ។ ក្នុងឱកាសនៃពិធីបដិសណ្ឋារកិច្ចមួយនៅអង្គការសហប្រជាជាតិ នាខែមិថុនា ឆ្នាំ១៩៨១ រដ្ឋមន្ត្រីការបរទេសអាមេរិកាំង អាឡិចហ្សង់ដឺរ ហេក (Alexander Haig) បានចាប់ដៃអ្នកការទូតដែលរវៀសរវៃម្នាក់យ៉ាងណែន ដោយមិនដឹងថា អ្នកនោះជា អៀង សារី ឡើយ ។

២៤ អ្នកទទួលខុសត្រូវម្នាក់នៃក្រសួងការបរទេសរបស់ជប៉ុននៅទីក្រុងតូក្យូ បានបញ្ជូនមកឲ្យខ្ញុំនូវសេចក្តីចម្លងការសន្ទនារវាង អូហ៊ីរ៉ា-តេង នេះ (តូក្យូ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៩) ។ សូមអានអត្ថបទរបស់

លោក Nayan Chanda, "Japan's Kampuchea Diplomacy" ក្នុងទស្សនាវដ្តី F.E.E.R. លេខចេញផ្សាយថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៨០ ។

២៥ "វាសនាចុងក្រោយសម្រាប់ខ្មែរក្រហម", ទស្សនាវដ្តី F.E.E.R., ចេញថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៨០ ។

២៦ អ្នករត់ចោលជួរឡាវម្នាក់ បានបញ្ជាក់ប្រាប់ខ្ញុំពីអត្ថិភាពនៃជំរំហ្វឹកហាត់មួយរបស់ចលនាតស៊ូប្រឆាំងវៀតណាមនៅប្រទេសឡាវថា គឺស្ថិតនៅប្រទេសចិនភាគខាងត្បូង ។ ការសន្ទនារបស់អ្នកនិពន្ធជាមួយសាស្ត្រាចារ្យ ខាំសេងកែវ សេងសាធីត(Khamsengkeo Sengsathit)នៅទីក្រុងប៉េកាំងនាខែកុម្ភៈ ឆ្នាំ១៩៨២ ។ សាស្ត្រាចារ្យសាកលវិទ្យាល័យអាមេរិកាំងមួយក្រុមបានជួបជនជាតិថៃជាច្រើននាក់ ដែលកំពុងបង្ហាត់បង្រៀនអ្នកតស៊ូឡាវ នៅក្នុងតំបន់មួយនៃខេត្តយុនណាន (Yunnan) ។ ដើម្បីឲ្យរឹតតែជាក់ច្បាស់ស្តីពីការគាំទ្ររបស់ក្រុងប៉េកាំងចំពោះសង្គ្រាមឆ្នក់ប្រឆាំងកុម្មុយនីស្តសូមអានអត្ថបទ "Fancy meeting you here" របស់លោក ណាយ៉ាន់ ចាន់ដា ក្នុងទស្សនាវដ្តី F.E.E.R. លេខចេញផ្សាយថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨១, ទំព័រ១៤-១៥ ។

២៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយមន្ត្រីម្នាក់នៃក្រសួងការបរទេសអាមេរិកាំង នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៨០ នាទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។

២៨ ឧត្តមសេនីយ៍ Saiyud Kerdphol មេបញ្ជាការជាន់ខ្ពស់នៃកងទ័ពភូមិន្ទថៃ, ដកស្រង់មកនិយាយជាសំអាងក្នុង The Nation Review, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៨២ ។

២៩ ខ្ញុំធ្លាប់ឮនិយាយពី"សិទ្ធិ"នេះពីមាត់របស់អ្នកជូនដំណើរជាខ្មែរក្រហម ក៏ដូចពីមាត់ពួកមេៗនៃចលនាតស៊ូខ្មែរមិនមែនកុម្មុយនីស្តដែរ ។

៣០ Stephen Heder, "Democratic Kampuchea: The Regime's postmortem", Indochina Issues, N°13, Janvier 1981, p. 5 ។

៣១ ប្រទេសអូស្ត្រាលីបានឈប់ទទួលស្គាល់កម្ពុជាប្រជាធិបតេយ្យជាផ្លូវការនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៨០ ។ សូមអានអត្ថបទរបស់លោក Frank Frost, "The Conflict over Cambodia: Implications of the Khmer Coalition Agreement", Canberra, Department of the Parliamentary Library, 1982, Basic Paper N°14 ។

៣២ លី ខាន់ យូ, ស្រង់មកនិយាយជាសំអាងក្នុងទស្សនាវដ្តី F.E.E.R., ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨០ ។

៣៣ ឆ្លើយតបនឹងលិខិតមួយរបស់ ខៀវ សំផន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៩ ដែលស្នើឲ្យព្រះអង្គទទួលតំណែងជាប្រធានរណសិរ្ស សម្តេច សីហនុ បានបញ្ចេញព្រះរាជយោបល់ថា ៖ "រណសិរ្សថ្មីក៏ដូចកម្មវិធីនយោបាយថ្មី ដែលបង្ហាញដោយខ្មែរក្រហម ជាក់ស្តែង គឺជាការលាក់ពុតថ្មីមួយដែលនឹងទាក់ទាញចិត្តបានតែពួកមនុស្សភ្លីភ្លើនិងឆោតល្ងង់ប៉ុណ្ណោះ" ។

៣៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតជាន់ខ្ពស់របស់ថៃម្នាក់ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៦ នាទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។

៣៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតជាន់ខ្ពស់ម្នាក់របស់សហរដ្ឋអាមេរិក ដែលអមដំណើរលោក Mondale ទៅទីក្រុងប៉េកាំង, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៨៥ នៅទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។

៣៦ ការរៀបរាប់ពីដំណើររបស់លោក ព្រេម ទៅប្រទេសចិន គឺសំអាងលើបណ្តាការសន្ទនារបស់ខ្ញុំជាមួយអ្នកទទួលខុសត្រូវចិនម្នាក់ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៨០ និងជាមួយអ្នកទទួលខុសត្រូវម្នាក់នៃក្រសួងការបរទេសថៃ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨០ នាទីក្រុងបាងកក ។

៣៧ ការរៀបរាប់ពីដំណើររបស់លោក លី ខ្វាន់យូ នៅទីក្រុងប៉េកាំង គឺផ្អែកលើការសន្ទនាមួយជាមួយអ្នកទទួលខុសត្រូវចិនម្នាក់ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៨០ នាទីក្រុងហុងកុង និង ជាមួយមន្ត្រីម្នាក់នៃក្រសួងការបរទេសសិង្ហបុរីនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៨០ ។ ក្នុងឱកាសនៃការសន្ទនាមួយនៅខែកុម្ភៈ ឆ្នាំ១៩៨៣ នាទីក្រុងបាងកក លោករដ្ឋមន្ត្រីការបរទេសសិង្ហបុរី ស៊ូពីយ៉ាស់ ដាណាបាឡាន់ បានអះអាងប្រាប់ខ្ញុំថា បានទទួលការធានាពីពួកចិនថា ពួកគេនឹងប្រតិបត្តិតាមការវិនិច្ឆ័យមួយរបស់ប្រជារាស្ត្រ ដោយបោះបង់ពួកខ្មែរក្រហមចោល ។

៣៨ ក្នុងឱកាសនៃការសន្ទនាមួយ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨០ នាទីក្រុងប៉េកាំង សម្តេច សីហនុ បានមានព្រះរាជបន្ទូលប្រាប់ខ្ញុំថា ៖ «ខ្ញុំជាជនជាតិខ្មែរនិងជាអ្នកស្នេហាជាតិម្នាក់ ។ ខ្ញុំមិនចង់ធ្វើខ្លួនជា សីហនុ ដែលស្លាប់នៅលើទឹកដីបរទេសមួយឡើយ ។ ខ្ញុំចង់ចូលទិវង្គតនៅក្នុងប្រទេសរបស់ដូនតានិងប្រជាជនខ្ញុំ ។ ខ្ញុំស្រឡាញ់ប្រទេសចិននិងកូរ៉េខាងជើង ប៉ុន្តែប្រទេសទាំងនោះពុំមែនជាមាតុភូមិ(ស្រុកកំណើត)របស់ខ្ញុំទេ ។ មាតុភូមិរបស់ខ្ញុំ គឺប្រទេសកម្ពុជា ហើយមានតែមួយគត់... ។ បើនិយាយឲ្យស្មោះត្រង់ទៅមុននឹងចូលទិវង្គត ខ្ញុំប្រាថ្នាចង់មានចំណែកក្នុងប្រវត្តិសាស្ត្រក្នុងឋានៈជាអ្នកកសាងប្រទេសកម្ពុជា ជាពិសេសក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ។ ប្រជារាស្ត្រតូចតាចជាអ្នកក្រីក្រ, ប្រជាជនសាមញ្ញតែងតែជាមនុស្សសម្រាប់ខ្ញុំជានិច្ច ។ មុននឹងចូលទិវង្គត ខ្ញុំត្រូវតែធ្វើអ្វីដែលមានផលប្រយោជន៍ដល់អ្នកទាំងនោះ ។ វៀតណាម និងលោក ហេង សំរិន ប្រហែលដឹងថា ពួកគេនឹងឆ្លៀតទាញគុណប្រយោជន៍យ៉ាងច្រើនពីការយាងត្រឡប់ទៅវិញរបស់ខ្ញុំ ។ អ្វីៗនឹងត្រូវចប់ ៖ សង្គ្រាមប្រឆាំងខ្មែរក្រហមនឹងត្រូវឈ្នះ» ។

៣៩ លក្ខខណ្ឌទាំងប្រាំបួនគឺមានដូចខាងក្រោម ៖

ក. ការសម្រេចចូលរួបរួមនឹងខ្មែរក្រហមក្នុងរណសិរ្សរួបរួមមួយនិងក្នុងរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយ គឺត្រូវមានលក្ខខណ្ឌ ។ បើសិនជាលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះត្រូវប្រានចោលដោយខ្មែរក្រហមឬប្រទេសចិន សម្តេច សីហនុ នឹងមិនអាចសហការបានឡើយ ។

**ខ.** កម្ពុជាប្រជាធិបតេយ្យត្រូវតែប្រែក្លាយជាប្រទេសកម្ពុជាដូចពីមុន ។ ទង់ជាតិនិងបទភ្លេងជាតិមុនឆ្នាំ ១៩៧០ នឹងត្រូវរៀបចំឲ្យដូចដើមវិញ ។

**គ.** កងទ័ពសីហនុនិយមនឹងត្រូវបំពាក់អាវុធដោយប្រទេសចិនឲ្យស្មើគ្នានឹងកងទ័ពខ្មែរក្រហមដែរ ហើយនឹងនៅតែស្ថិតនៅក្រោមអំណាចបញ្ជាការឯករាជ្យដដែល ។

**ឃ.** ដោយទទួលបន្ទុកមុខតំណែងជាប្រធានរណសិរ្ស សម្តេច សីហនុ នឹងមិនទទួលខុសត្រូវលើរដ្ឋាភិបាលរបស់ព្រះអង្គឡើយ ។

**ង.** ព្រះអង្គនឹងត្រូវអនុញ្ញាតឲ្យធ្វើការផ្សាយនិងយាងធ្វើដំណើរជាមួយនឹងអ្នកតំណាងសំខាន់ៗរបស់រដ្ឋា-ភិបាល ។

**ច.** ព្រះអង្គនឹងមានសិទ្ធិបញ្ចេញមតិដូចអ្នកកាសែតនិងអ្នកនិពន្ធដែរ ។

**ឆ.** ការបញ្ជាក់ឲ្យដឹងនឹងត្រូវផ្តល់ឲ្យស្តីពីជោគវាសនារបស់ព្រះញាតិវង្សនិងសហការីរបស់ព្រះអង្គដែលបាត់ខ្លួនក្រោមរបបខ្មែរក្រហម ។

**ជ.** បន្ទាប់ពីការដកថយរបស់វៀតណាម ប្រទេសកម្ពុជាត្រូវតែប្រកាសខ្លួនជាប្រទេសអព្យាក្រឹត ហើយកងទ័ពទាំងអស់របស់ខ្លួនត្រូវដកហូតអាវុធ ។ មុនការដកថយនេះ កងទ័ពអន្តរជាតិរក្សាសន្តិភាពមួយនឹងត្រូវដាក់ពង្រាយ ។

**ឈ.** ការបោះឆ្នោតសកលនឹងត្រូវរៀបចំឡើង ។ កងទ័ពរក្សាសន្តិភាពនឹងត្រូវជំនួសដោយគណៈកម្មការត្រួតពិនិត្យអន្តរជាតិមួយ ។

៤០ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតម្នាក់នៃប្រទេសមួយជាសមាជិកសមាគមអាស៊ាន ដែលមានមុខនៅសម័យប្រជុំនាទីក្រុងញូវយ៉ក, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨១ ។

៤១ ហាន នានឡុង បានរំឭកប្រាប់ខ្ញុំពីការកត់សម្គាល់នេះដោយផ្ទាល់ក្នុងអំឡុងនៃការសន្ទនាមួយដែលគាត់បានយល់ព្រមឲ្យខ្ញុំជួបពីរបីខែក្រោយមក : *"Han Fire a Warning Volley"*, ទស្សនាវដ្តី F.E.E.R. លេខចេញផ្សាយថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨២ ។

៤២ *Alexander M. Haig, Caveat: Realism, Reagan, and foreign Policy, New York, Mcmillan, 1984, p. 194* ។

៤៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់នៃសមាគមអាស៊ាន នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៥ នាទីក្រុងវ៉ាស៊ីនតោន ។

៤៤ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក ម៉ុកតា គូស៊ូម៉ាអាតម៉ាជ្យា នៅទីក្រុងញូវយ៉ក នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨១ ។

៤៥ *Ibid* ។

៤៦ ដោយរៀបរាប់ពីហេតុការណ៍បន្ទាប់បន្សំនេះ អ្នកការទូតម្នាក់នៃប្រទេសមួយជាសមាជិកសមាគមអាស៊ាន បាននិយាយប្រាប់ខ្ញុំថា ៖ «យ៉ាងហោច សន្និសីទនេះបានធ្វើឲ្យយើងដឹងរឿងរ៉ាវមួយចំនួនតូចដែរ ។ នៅពេលប្រកាន់យកសេចក្ដីសម្រេចចិត្ត ប្រទេសតូចៗលែងមានមិត្តទៀតហើយ» ។ ភាគច្រើននៃបណ្ដាប្រទេសលោកខាងលិចបានបដិសេធមិនចូលរួមជាមួយសមាគមអាស៊ានក្នុងការប្រឈមមុខជាមួយនឹងប្រទេសចិនឡើយ ។

៤៧ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកការទូតជាន់ខ្ពស់ម្នាក់របស់ថៃ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នាទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។

៤៨ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក តាន់ស្រ៊ីហ្គាហ្សាលី នៅទីក្រុងហុងកុង នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៨១ ។

៤៩ *Sabam Siagian, "Potentials of Conflict and Potentials of Peace in Southeast Asia"*, ព័ត៌មានទាក់ទងនឹងការប្រជុំលើទី៣រវាងឥណ្ឌូនេស៊ី-សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់, *Hambourg, 15-17 Avril 1985* ។

៥០ ការសន្ទនារបស់អ្នកនិពន្ធជាមួយសម្ដេចព្រះ នរោត្ដម សីហនុ នៅទីក្រុងញូវយ៉កនាថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៨៤ ។

៥១ *Nayan Chanda, "Sihanouk Stonewalled"*, ទស្សនាវដ្ដី *F.E.E.R.*, លេខចេញផ្សាយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៨៤ ។

៥២ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក អារុន ដានុពង្ស នៅទីក្រុងប៉ារីសនាថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៥ ។

៥៣ ការសន្ទនារបស់អ្នកនិពន្ធជាមួយអ្នកឯកទេសខាងព័ត៌មានរបស់អាមេរិកាំង នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨៦ នាទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។ *The U.S.S.R. in Indochina, Report N°334, Bureau of Intelligence and Research, Department of State, Washington, D.C., mars 1982* ។

៥៤ *W.P., 10 mars 1979* ។

៥៥ ការសន្ទនារបស់អ្នកនិពន្ធជាមួយលោក រីឆាដ អារមីថេច អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ទទួលបន្ទុកផ្នែកសន្តិសុខអន្តរជាតិនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៨៥ នាទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី. ។

៥៦ ចំពោះការពិនិត្យមើលដ៏ប្រសើរមួយអំពីសហប្រតិបត្តិការរវាងចិន-អាមេរិកាំងខាងវិស័យសន្តិសុខនៅឆ្នាំ១៩៧៩-៨០ សូមអានសៀវភៅរបស់លោក *Jonathan D. Pollack, The Lesson of Coalition Politics: Sino-American Security Relations, Santa Monica, Rand Corporation, 1984, pp. 39-72* ។

៥៧ *Banning N. Garrett and Bonnie S. Glaser, War and Peace: The view from Moscow and Beijing, Policy*

*Papers in International Affairs N°20, Institute of International Studies, Berkeley, University of California Press, 1984, pp. 48-49* ។

៥៨ *Richard Nations, “Great Leap Sideways”, F.E.E.R., 30 mai 1985* ។

៥៩ ការសន្ទនារបស់អ្នកនិពន្ធជាមួយសាស្ត្រាចារ្យសាកលវិទ្យាល័យដ៏ឆ្នើមម្នាក់របស់សូវៀតជាអ្នកឯកទេសខាងបញ្ហាអាស៊ីភាគអាគ្នេយ៍នៅ Bellagio នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៨៥ ។

# សេចក្តីថ្លែងអំណរគុណពីអ្នកប្រែសម្រួល

*ជាបឋម ខ្ញុំសូមថ្លែងអំណរគុណជាពន្លឹកចំពោះលោក ណាយ៉ាន់ ចាន់ដា ដែលបានផ្តល់សិទ្ធិឲ្យខ្ញុំប្រែសម្រួលសៀវភៅរបស់លោកក្រោមចំណងជើងថា «សត្រូវបងប្អូនឯង» តាមរយៈលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅនេះ ខ្ញុំធ្លាប់បានប្រែសម្រួលចុះផ្សាយក្នុងការសែតរស្មីកម្ពុជាម្តងរួច មកហើយកាលពីចុងឆ្នាំ១៩៩៧ ។ ប៉ុន្តែ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានសិទ្ធិប្រែសម្រួលពីអ្នកនិពន្ធ និងសម្រេចឲ្យបោះពុម្ពស្នាដៃនេះ ខ្ញុំក៏ចាប់ផ្តើមពិនិត្យ និងកែសម្រួលឃ្លោងឃ្លាឡើងវិញដោយល្អិតល្អន់ ដើម្បីធ្វើឲ្យខ្លឹមសារសៀវភៅនេះមានលក្ខណៈកាន់តែសុក្រឹតឡើង ។ ទោះជាយ៉ាងណាក៏ដោយ ការប្រែសម្រួលពីភាសាបរទេសមកជាភាសាខ្មែរពិតជាមានការលំបាកនិងការខ្វះខាតខ្លះៗមិនខាន ។ អាស្រ័យហេតុនេះ ខ្ញុំបាទសូមអធ្យាស្រ័យចំពោះការខ្វះចន្លោះមួយចំនួនដែលពិតជាមាននៅក្នុងសៀវភៅនេះ ។*

*ខ្ញុំបាទសូមថ្លែងអំណរគុណជាអនេកប្បការចំពោះលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំខ្នះខ្នែងគ្រប់បែបយ៉ាងរហូតដល់សៀវភៅនេះសម្រេចចេញជារូបរាងឡើង ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក ស៊ុម មាន អតីតទីប្រឹក្សានាយករដ្ឋមន្ត្រីហ៊ុនសែន លោក ដុង ឆុំ នាយកគ្រប់គ្រងនិងលោក ប៉ែន សមិទ្ធិ និពន្ធនាយកកាសែតរស្មីកម្ពុជាដែលបានជួយជ្រោមជ្រែង និងគាំពារខ្ញុំរហូតដល់ខ្ញុំមានថ្ងៃនេះ ។ លើសពីនេះ ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះមិត្តរួមការងារទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលខិតខំបំពេញការងារជាធ្លុងមួយធ្វើឲ្យសម្រេចបានជោគជ័យធំៗជាបន្តបន្ទាប់ ។*

*ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះមិត្តអ្នកអានដែលធ្លាប់បានផ្តល់កម្លាំងចិត្ត និងលើកសរសើរខ្ញុំដោយផ្ទាល់ក្តីឬមិនផ្ទាល់ក្តី ព្រមទាំងអ្នកនិយមការអានសៀវភៅគ្រប់រូប សូមទទួលបានសេចក្តីសុខ និងជោគជ័យគ្រប់ប្រការក្នុងការបំពេញភារកិច្ចដើម្បីសុភមង្គលរបស់ខ្លួនរៀងទៅ ។*

*ជីហែ, ថ្ងៃទី៩ ខែមករា ឆ្នាំ២០០៦*

*ទេព ម៉េងឃាន ហៅ ទីឃាយុ*

# ប្រវត្តិអ្នកបកប្រែ

*ទេព ម៉េងឃាន កើតនៅខែកុម្ភៈ ឆ្នាំ១៩៤៧ នៅភូមិដីហែ ឃុំពាមប្រធ្មោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ លោកបានជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ១៩៦៧ នៅទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៦៨ លោកបានទទួលសញ្ញាប័ត្រគរុកោសល្យពីមហាវិទ្យាល័យគរុកោសល្យក្រុងភ្នំពេញ ។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០២ លោកធ្វើការជាបុគ្គលិកបកប្រែភាសាបារាំងនៅកាសែតរស្មីកម្ពុជា បច្ចុប្បន្នលោកគឺជាអ្នកបកប្រែភាសាបារាំងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។*

# សេចក្តីឧទ្ទិស

*ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះលោកឪពុក ទេព ខុង និងអ្នកម្តាយ ជាម ទី និងប្អូនប្រុស-ស្រីរបស់ខ្ញុំបួននាក់ ព្រមទាំងប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណ២លាននាក់ដែលបានស្លាប់បាត់បង់ជីវិតទាំងមិនអស់ចិត្តក្រោមការកាប់សម្លាប់យ៉ាងសាហាវព្រៃផ្សៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។*